**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៤/១/០៧-០៩-២០០៩-អវតក-កសចស
**ដាក់ទៅ** : សហចៅក្រមស៊ើបអង្កេត
**ថ្ងៃដាក់** : ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2018, 11:46
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់** អមដោយ**ឧបសម្ព័ន្ធសម្ងាត់** [សាធារណៈ កោសលប់]

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:** សាធារណៈ/Public

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម**

---

| | | |
|---|---|---|
| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **សហមេធាវីការពារក្តី អ៊ឹម ចែម** |
| **សហព្រះរាជអាជ្ញាអន្តរជាតិ** | **សហចៅក្រមស៊ើបអង្កេត** | ប៊ិត ស៊ាងលីម |
| លោក Nicholas KOUMJIAN | ចៅក្រម យូ ប៊ុនឡេង | Wayne JORDASH |
| | ចៅក្រម Michael BOHLANDER | |
| **ចម្លងជូន:** | | |
| លោកស្រី ជា លាង | **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤ ទាំងអស់** | |

# មាតិកាសង្ខេប


**I. សេចក្តីផ្តើម ........ 11**

ក. និដ្ឋភាពទូទៅនៃសំណុំរឿង ........ 11

ខ. ប្រវត្តិនីតិវិធី ........ 13

គ. បទដ្ឋាននៃភស្តុតាងដែលចាំបាច់ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ........ 20

**II. អង្គហេតុសម្ភារៈ ........ 22**

ក. ជម្លោះប្រដាប់អាវុធ ........ 22

ខ. រចនាសម្ព័ន្ធសិទ្ធិអំណាច ........ 24

គ. ប្រព័ន្ធទំនាក់ទំនងរបស់ បកក ........ 32

ឃ. ផែនការឧក្រិដ្ឋកម្មរួម ........ 36

ង. តួនាទីរបស់ អ៊ឹម ចែម ........ 42

ច. ឧក្រិដ្ឋកម្ម ........ 62

**III. ច្បាប់ ........ 100**

ក. ឧក្រិដ្ឋកម្ម ........ 100

ខ. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ........ 127

គ. យុត្តាធិការបុគ្គល ........ 144

**IV. ការកំណត់បទចោទ ........ 147**

ក. ឧក្រិដ្ឋកម្ម ........ 147

ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល ........ 169

គ. យុត្តាធិការបុគ្គល ........ 182

**V. បទចោទ ........ 187**

**VI. ប្រភពភស្តុតាង ........ 189**

**VII. ឧបសម្ព័ន្ធ ........ 797**

**ឧបសម្ព័ន្ធ ១** : តារាងរចនាសម្ព័ន្ធសិទ្ធិអំណាចក្នុងតំបន់ ១៣ ភូមិភាគនិរតី

**ឧបសម្ព័ន្ធ ២** : តារាងរចនាសម្ព័ន្ធសិទ្ធិអំណាចក្នុងតំបន់ ៥ ភូមិភាគពាយ័ព្យ

**ឧបសម្ព័ន្ធ ៣** : ផែនទីកម្ពុជាប្រជាធិបតេយ្យ

**ឧបសម្ព័ន្ធ ៤** : ផែនទីទីតាំងឧក្រិដ្ឋកម្មក្នុងភូមិភាគនិរតី

**ឧបសម្ព័ន្ធ ៥** : ផែនទីទីតាំងឧក្រិដ្ឋកម្មក្នុងភូមិភាគពាយ័ព្យ

**ឧបសម្ព័ន្ធ ៦** : បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ មកពីតំបន់ ៥ ភូមិភាគពាយ័ព្យ

**ឧបសម្ព័ន្ធ ៧** : អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/០១

**ឧបសម្ព័ន្ធ ៨**: ការប្រៀបធៀបជនជាប់ចោទក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

**ឧបសម្ព័ន្ធ ៩** : សន្ទានុក្រម

# មាតិកាលម្អិត

**I. សេចក្តីផ្តើម ........ 11**

ក. និដ្ឋភាពទូទៅនៃសំណុំរឿង ........ 11

ខ. ប្រវត្តិនីតិវិធី ........ 13

*ការបើកកិច្ចស៊ើបសួរ ........ 13*

*ការថ្លែងយោបល់ខ្វែងគ្នារបស់សហព្រះរាជអាជ្ញា ........ 14*

*ការផ្លាស់ប្តូរចៅក្រមស៊ើបអង្កេតក្នុងកំឡុងពេលនៃកិច្ចស៊ើបសួរ ........ 15*

*ដីកាកោះ និងដីកាបង្គាប់ឱ្យនាំខ្លួន ........ 15*

*ការដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយតុលាការ និងការដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ........ 16*

*សេចក្តីសន្និដ្ឋានស្តីពី 'មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត' ........ 17*

*ការបិទកិច្ចស៊ើបសួរ និងការបំបែកសំណុំរឿង០០៤/០១ ........ 17*

*ការប្តឹងទៅអង្គបុរេជំនុំជម្រះមិនទាន់ដោះស្រាយចប់ ........ 18*

*ភស្តុតាងលើសំណុំរឿង០០៤/០១ ........ 19*

គ. បទដ្ឋាននៃភស្តុតាងដែលចាំបាច់ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ........ 20

**II. អង្គហេតុសម្ភារៈ ........ 22**

ក. ជម្លោះប្រដាប់អាវុធ ........ 22

***ទិដ្ឋភាពទូទៅ ........ 22***

***ឆ្នាំ១៩៧៥ ........ 22***

***ឆ្នាំ១៩៧៦ ........ 23***

***ឆ្នាំ១៩៧៧ ........ 23***

***ឆ្នាំ១៩៧៨ - ឆ្នាំ១៩៧៩ ........ 24***

ខ. រចនាសម្ព័ន្ធសិទ្ធិអំណាច ........ 24

*រចនាសម្ព័ន្ធសិទ្ធិអំណាច បកក ........ 25*

***រចនាសម្ព័ន្ធសិទ្ធិអំណាចនៃភូមិភាគនិរតី ឆ្នាំ១៩៧៦-ឆ្នាំ១៩៧៧ ........ 28***

ភូមិភាគនិរតី ........ 28

តំបន់១៣ ........ 29

ស្រុកកោះអណ្តែត ........ 29

*របទាសម្ព័ន្ធសិទ្ធិអំណាចនៃភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧-ឆ្នាំ១៩៧៩* ........ *30*

ភូមិភាគពាយ័ព្យ ........ 30

តំបន់ ៥ ........ 30

ស្រុកព្រះនេត្រព្រះ ........ 31

**គ. ប្រព័ន្ធទំនាក់ទំនងរបស់ បកក** ........ 32

*ការទំនាក់ទំនងនៅក្នុងភូមិភាគនិរតី (១៩៧៦-១៩៧៧)* ........ *33*

ការប្រជុំ និងវគ្គឃោសនាក្នុងតំបន់១៣ និងភូមិភាគនិរតី ........ 33

ការរាយការណ៍តាមថ្នាក់នានារបស់តំបន់ ១៣ ទៅកាន់មជ្ឈិមបក្ស ........ 33

*ការទំនាក់ទំនងនៅក្នុងភូមិភាគពាយ័ព្យ (១៩៧៧-១៩៧៩)* ........ *34*

ការប្រជុំ និងវគ្គឃោសនានៅក្នុងតំបន់៥ និងភូមិភាគពាយ័ព្យ ........ 34

ការរាយការណ៍តាមថ្នាក់នានានៃតំបន់៥ ទៅកាន់មជ្ឈិមបក្ស ........ 36

**ឃ. ផែនការឧក្រិដ្ឋកម្មរួម** ........ 36

*ការលុបបំបាត់ខ្មាំង និងអ្នកប្រឆាំងនឹងការដឹកនាំរបស់ បកក* ........ *37*

*គោលនយោបាយកសិកម្ម សេដ្ឋកិច្ច និងសង្គមកិច្ច* ........ *39*

សហករណ៍ និងការដ្ឋាន ........ 39

អាពាហ៍ពិពាហ៍ដោយបង្ខំ ........ 41

**ង. តួនាទីរបស់ អ៊ឹម ចែម** ........ 42

*ទិដ្ឋភាពទូទៅ* ........ *42*

*ភូមិភាគនិរតីឆ្នាំ ១៩៧០ ដល់១៩៧៧* ........ *44*

តួនាទី និងសិទ្ធិអំណាច ........ 44

មុនឆ្នាំ ១៩៧៦ ........ 44

ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧ ........ 46

ការចូលរួមក្នុងឧក្រិដ្ឋកម្ម ........ 47

*ការផ្ទេរទៅភូមិភាគពាយ័ព្យ (ពាក់កណ្តាលឆ្នាំ ១៩៧៧)* ........ *47*

*ភូមិភាគពាយ័ព្យ ឆ្នាំ ១៩៧៧ ដល់ ១៩៧៩* ........ *48*

តួនាទី និងសិទ្ធិអំណាច ........ 48

ការចូលរួមក្នុងឧក្រិដ្ឋកម្ម ........ 50

*ការចូលរួម និងសិទ្ធិអំណាចលើការរស់នៅរបស់ប្រជាជន* ........ *50*

ការចូលរួម និងសិទ្ធិអំណាចលើការប្រជុំដែលពិភាក្សាពីឧក្រិដ្ឋកម្ម ........ 51

ការចូលរួម និងសិទ្ធិអំណាចលើការដ្ឋាន ..... 52

ការចូលរួម និងសិទ្ធិអំណាចលើអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ..... 54

ការចូលរួម និងសិទ្ធិអំណាចលើ "ការរៀនសូត្រ" របស់ខ្មាំង ..... 55

ការចូលរួម និងសិទ្ធិអំណាចលើការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ ..... 56

ការចាប់ខ្លួន ..... 56

ការឃុំខ្លួន ..... 57

ការសម្លាប់ ..... 58

**ច. ឧក្រិដ្ឋកម្ម** ..... 62

***ភូមិភាគនិរតី*** ..... *62*

ការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម (១៩៧៦-១៩៧៧) ..... 62

គោលនយោបាយរបស់ បកក ពាក់ព័ន្ធនឹងខ្មែរក្រោម ..... 62

ការប្រាស្រ័យទាក់ទងនៃគោលនយោបាយរបស់ បកក ពាក់ព័ន្ធនឹងខ្មែរក្រោម ..... 62

ការអនុវត្តគោលនយោបាយនៅក្នុងតំបន់១៣ ..... 63

(២) មន្ទីរសន្តិសុខវត្តអង្គសិរីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន (ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ១៩៧៧) ..... 64

ទីតាំង និងដំណើរការ ..... 64

រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង ..... 64

ការចាប់ខ្លួន និងឃុំខ្លួនខុសច្បាប់ ..... 65

លក្ខខណ្ឌអមនុស្សធម៌ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្លូវភេទ ..... 65

ការសម្លាប់ដោយខុសច្បាប់ ..... 66

***ភូមិភាគពាយ័ព្យ*** ..... *67*

(១) ការបោសសម្អាតនៅតំបន់ ៥ នៃភូមិភាគពាយ័ព្យ (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩) ..... 67

(២) ការធ្វើទុក្ខបុកម្នេញចំពោះវៀតណាម (១៩៧៧-១៩៧៩) ..... 69

គោលនយោបាយ បកក ទាក់ទងនឹងវៀតណាម ..... 69

ការប្រាស្រ័យទំនាក់ទំនងនៃគោលនយោបាយ បកក ទាក់ទងនឹងវៀតណាម ..... 70

ការអនុវត្តគោលនយោបាយ នៅក្នុងតំបន់៥ ..... 71

(៣) មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩) ..... 73

ទីតាំង និងដំណើរការ ..... 73

រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង ..... 73

ការចាប់ខ្លួន និងឃុំខ្លួនដោយខុសច្បាប់ ..... 74

លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌ ..... 75

ការងារដោយបង្ខំ ... 76

ការធ្វើទារុណកម្ម និងការរំលោភបំពានផ្លូវភេទ ... 77

ការសម្លាប់ដោយខុសច្បាប់ ... 77

(៤) មន្ទីរសន្តិសុខចក្រី និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ រួមទាំងព្រៃតារុត (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨) ... 79

ទីតាំង និងដំណើរការ ... 79

រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង ... 80

ការចាប់ខ្លួន និងឃុំខ្លួនដោយខុសច្បាប់ ... 80

លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌ ... 81

ការសម្លាប់ដោយខុសច្បាប់ ... 81

(៥) មន្ទីរសន្តិសុខវត្តចំការខ្នុរ និងទីតាំងពាក់ព័ន្ធ (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨) ... 82

ទីតាំង និងដំណើរការ ... 82

រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង ... 83

ការចាប់ខ្លួន និងឃុំខ្លួនដោយខុសច្បាប់ ... 83

ការងារដោយបង្ខំ ... 84

លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌ ... 84

ការធ្វើទារុណកម្ម ... 84

ការសម្លាប់ដោយខុសច្បាប់ ... 84

(៦) វត្តព្រះនេត្រព្រះ និងទីកតាំង ឃុំខ្លួន និងសម្លាប់មនុស្សពាក់ព័ន្ធ (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ឆ្នាំ១៩៧៨) ... 86

ទីតាំង និងតំណើរការ ... 86

រចនាសម្ព័ន្ធសិទ្ធិអំណាច ... 87

លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌ ... 88

ការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ដោយខុសច្បាប់ ... 88

(៧) ស្ពានស្រែង និងការដ្ឋានទំនប់ព្រៃនោម (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨) ... 89

ទីតាំង និងប្រតិបត្តិការ ... 89

រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង ... 91

ពលកម្មដោយបង្ខំ ... 91

ស្ថានភាពរស់នៅដោយអមនុស្សធម៌ ... 92

អាពាហ៍ពិពាហ៍ដោយបង្ខំ ... 93

ការចាប់ខ្លួន ឃុំឃាំង និងសម្លាប់ដោយខុសច្បាប់ ... 93

(៨) ការដ្ឋានទំនប់ត្រពាំងថ្ម (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨) ... 94

ទីតាំង និងតំណើរការ ........ 94

រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង ........ 95

ពលកម្មដោយបង្ខំ ........ 96

ស្ថានភាពរស់នៅដោយអមនុស្សធម៌ ........ 96

អាពាហ៍ពិពាហ៍ដោយបង្ខំ ........ 98

ការចាប់ខ្លួន ការបាត់ខ្លួន និងការកាប់សម្លាប់ដោយខុសច្បាប់ ........ 98

**III. ច្បាប់ ........ 100**

**ក. ឧក្រិដ្ឋកម្ម** ........ 100

***ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*** ........ *100*

លក្ខខណ្ឌទូទៅ ........ 100

ការវាយប្រហារ ........ 100

លក្ខណៈរីករាលដាល ឬជាប្រព័ន្ធ ........ 101

សំដៅប្រឆាំងនឹងប្រជាជនស៊ីវិល ........ 102

មូលដ្ឋាននៃការរើសអើង ........ 103

ចំណងទាក់ទងរវាងអំពើរបស់ចារី និងការវាយប្រហារ ........ 104

បទល្មើសជាក់លាក់ ........ 105

ការធ្វើមនុស្សឃាត ........ 105

ការសម្លាប់រង្គាល ........ 105

ការធ្វើឱ្យទៅជាទាសករ ........ 107

ការដាក់ក្នុងមន្ទីរឃុំឃាំង ........ 109

ការធ្វើទារុណកម្ម ........ 110

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាតិសាសន៍ ឬជំនឿសាសនា ........ 112

អំពើអមនុស្សធម៌ដទៃទៀត ........ 116

**ការបាត់ខ្លួនដោយបង្ខំ** ........ 117

**ការរំលោភសេពសន្ថវៈ** ........ 118

**អាពាហ៍ពិពាហ៍ដោយបង្ខំ** ........ 119

**ការឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌** ........ 121

***អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ*** ........ *121*

លក្ខខណ្ឌទូទៅ ........ 122

ជម្លោះប្រដាប់អាវុធអន្តរជាតិ ... 122
បុគ្គលដែលទទួលបានការការពារ ... 123
ការដឹងអំពីកាលៈទេសៈអង្គហេតុ ... 124
បទល្មើសជាក់លាក់ ... 124
ការធ្វើមនុស្សឃាតដោយចេតនា ... 124
ការធ្វើបាបដោយអមនុស្សធម៌ ... 125
ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ... 125
ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ... 126
ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ... 126
**ខ. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល** ... 127
***ទម្រង់នៃការទទួលខុសត្រូវ*** ... *127*
ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ... 128
ការរៀបចំផែនការ ... 132
ការញុះញង់ ... 134
ការបញ្ជា ... 135
ការជួយ និងជំរុញ ... 137
ការទទួលខុសត្រូវរបស់ថ្នាក់លើ ... 139
**គ. យុត្តាធិការបុគ្គល** ... 144
"មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ... 144
ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ... 145
មេដឹកនាំជាន់ខ្ពស់ ... 146
**IV. ការកំណត់បទចោទ** ... **147**
**ក. ឧក្រិដ្ឋកម្ម** ... 147
***ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*** ... *147*
ធាតុផ្សំយុត្តាធិការនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ... 147
ការវាយប្រហារប្រឆាំងជនស៊ីវិល ... 147
លក្ខណៈរីករាលដាល និងជាប្រព័ន្ធ ... 148
មូលហេតុនៃការរើសអើង ... 148
*ការដឹងឮរបស់ អ៊ឹម ចែម អំពីការវាយប្រហារ* ... 149

ឧក្រិដ្ឋកម្មជាក់លាក់ ..... 149
អំពើមនុស្សឃាត ..... 150
**អំពើកម្ម និងអកម្ម** ..... 150
**ចេតនា** ..... 151
ការសម្លាប់រង្គាល ..... 152
**អំពើកម្ម និងអកម្ម** ..... 152
**ចេតនា** ..... 153
ការធ្វើឱ្យទៅជាទាសករ ..... 154
**អំពើកម្ម និងអកម្ម** ..... 154
**ចេតនា** ..... 155
ការដាក់ក្នុងមន្ទីរឃុំឃាំង ..... 155
**អំពើកម្ម និងអកម្ម** ..... 155
**ចេតនា** ..... 156
ការធ្វើទារុណកម្ម ..... 157
**អំពើកម្ម និងអកម្ម** ..... 157
**គោលបំណង** ..... 157
**ចេតនា** ..... 157
ការធ្វើទុក្ខបុកម្នេញ ..... 158
**អំពើកម្ម និងអកម្ម** ..... 158
**ចេតនា** ..... 159
អំពើអមនុស្សធម៌ផ្សេងៗទៀត ..... 159
**អាពាហ៍ពិពាហ៍ដោយបង្ខំ** ..... 159
**ការរំលោភសេពសន្ថវៈ** ..... 160
**ការបាត់ខ្លួនដោយបង្ខំ** ..... 162
**ការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌** ..... 162
***ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ*** ..... *164*
ធាតុផ្សំយុត្តាធិការនៃការបំពារបំពានធ្ងន់ធ្ងរ ..... 164
ជម្លោះប្រដាប់អាវុធអន្តរជាតិ ..... 164
បុគ្គលដែលត្រូវទទួលបានការការពារ ..... 164
ការដឹងឮអំពីជម្លោះប្រដាប់អាវុធ ..... 165

ឧក្រិដ្ឋកម្មជាក់លាក់ ..... 165

ការធ្វើមនុស្សឃាតដោយចេតនា ..... 166

**អំពើកម្ម និងអកម្ម** ..... 166

**ចេតនា** ..... 166

ការប្រព្រឹត្តដោយអមនុស្សធម៌ ..... 166

**អំពើកម្ម និង អកម្ម** ..... 166

**ចេតនា** ..... 167

ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព ..... 167

ការដកហូតដោយចេតនានូវការជំនុំជម្រះដោយ យុត្តិធម៌ និងទៀងទាត់ ..... 167

**អំពើកម្ម និង អកម្ម** ..... 168

**ចេតនា** ..... 168

ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ..... 168

**អំពើកម្ម និង អកម្ម** ..... 168

**ចេតនា** ..... 169

**ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល** ..... 169

***ទិដ្ឋភាពទូទៅ*** ..... *169*

***ទម្រង់នៃការទទួលខុសត្រូវ*** ..... *170*

ការប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម ..... 170

JCE នៅភូមិភាគនិរតី ..... 170

JCE នៅភូមិភាគពាយ័ព្យ ..... 174

ការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងការជំរុញ ..... 180

ការទទួលខុសត្រូវរបស់ថ្នាក់លើ ..... 182

**គ. យុត្តាធិការបុគ្គល** ..... 182

**V. ចំណោទ ..... 187**

**VI. ប្រភពតំណាង ..... 189**

# I. សេចក្តីផ្តើម

## ក. និដ្ឋភាពទូទៅនៃសំណុំរឿង

1. **អ៊ឹម ចែម** ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានច្បាប់មនុស្សធម៌អន្តរជាតិ ដែលមានចែងនៅទីនេះ។ ឧក្រិដ្ឋកម្មទាំងនេះបានកើតឡើងនៅក្នុងអំឡុងពេលនៃការរីករាលដាល និងជាប្រព័ន្ធ នូវការវាយប្រហារប្រឆាំងនឹងប្រជាជនកម្ពុជា ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ របស់បក្សកុម្មុយនីសកម្ពុជា។ **អ៊ឹម ចែម** បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងយុទ្ធនាការឧក្រិដ្ឋ ដែលមានចេតនាផ្លាស់ប្តូរដាច់ខាតនូវសង្គមកម្ពុជា ហើយដែលបណ្តាលឲ្យមានជា បកក ឬ "អង្គការ" ដែលបានអនុវត្តនូវការត្រួតត្រាដាច់ខាតទៅលើជីវិតរស់នៅរបស់ប្រជាជនស៊ីវិលទាំងអស់៖ ការធ្វើប្រជាជនឲ្យទៅជាទាសករ ការដកហូតពីពួកគាត់នូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានបំផុត ការដាក់ក្នុងមន្ទីរឃុំឃាំងជាច្រើននាក់ និងជាចុងក្រោយ សម្លាប់ពួកគាត់ចោលអស់ចំនួនជាច្រើន។

2. **អ៊ឹម ចែម** បានកាន់មុខតំណែងមានអំណាចដ៏សំខាន់ ទាំងនៅក្នុងភូមិភាគនិរតី និងទាំងភូមិភាគពាយ័ព្យអស់រយៈពេលភាគច្រើននៃរបបកម្ពុជាប្រជាធិបតេយ្យ ("DK")។ ភាពស្មោះត្រង់ និងប្រសិទ្ធិភាពរបស់គាត់នៅក្នុងការអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់ បកក បានបណ្តាលឲ្យគាត់ឡើងឋានន្តរស័ក្តិយ៉ាងឆាប់រហ័ស កាន់កាប់មុខតំណែងដែលមានសិទ្ធិអំណាចជាងមុន។ **អ៊ឹម ចែម** ជាលេខាស្រុកកោះអណ្តែត និងជាសមាជិកគណៈតំបន់១៣ នៅភូមិភាគនិរតី ពីឆ្នាំ១៩៧៦ រហូតដល់ ពាក់កណ្តាលឆ្នាំ១៩៧៧។ នៅទីនោះ ការទទួលខុសត្រូវរបស់គាត់ រួមមាន មន្ទីរសន្តិសុខវត្តអង្គសិរីមាលី និងការធ្វើទុក្ខបុកម្នេញក្នុងវិសាលភាពដ៏ធំទៅលើពួកខ្មែរក្រោម និងពួកដែលបានរួមចំណែកជាមួយនឹងខ្មែរក្រោម នៅតំបន់១៣។ បន្ទាប់មក **អ៊ឹម ចែម** ត្រូវបានទុកចិត្តដោយកម្មាភិបាលជាន់ខ្ពស់របស់ បកក រួមមាន ប៉ុល ពត និងតាម៉ុក ដើម្បីដឹកនាំការបោសសម្អាតភូមិភាគពាយ័ព្យ ជាទីកន្លែងដែលគាត់បានបញ្ជា និងសម្របសម្រួលឲ្យមានការដកហូតកម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់ចេញពីមុខតំណែងរបស់ពួកគាត់ និងដាក់ទណ្ឌកម្ម ឬសម្លាប់ពួកគាត់ចោល ដោយមកពីការខកខានមិនបានអនុវត្តគោលនយោបាយរបស់ បកក។ កម្មាភិបាលទាំងនេះ ភាគច្រើនត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ដ៏ល្បីល្បាញនៅទីក្រុងភ្នំពេញ ដែលជាកន្លែង

ដែលពួកគាត់ត្រូវបានធ្វើទារុណកម្ម និងសម្លាប់ចោល។ **អ៊ឹម ចែម** បានក្លាយទៅជាព្រះនេត្រព្រះ ក៏ដូចជាសមាជិកគណៈតំបន់៥ និង ក្រោយមក ជាអនុលេខាតំបន់៥ នៅភូមិភាគពាយ័ព្យ ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៧ រហូតដល់ ខែមករា ឆ្នាំ១៩៧៩។ ក្នុងកំឡុងពេលនោះ ការទទួលខុសត្រូវរបស់គាត់ រួមមាន មន្ទីរសន្តិសុខផ្សេងៗ និងទីកន្លែងសម្លាប់មនុស្ស ដូចជា ភ្នំត្រយោង ចក្រី វត្តចំការខ្នុរ និង វត្តព្រះនេត្រព្រះ, ការដ្ឋានពលកម្មដោយបង្ខំ រួមមាន ត្រពាំងថ្ម និង ស្ពានស្រែង, និង ការធ្វើទុក្ខបុកម្នេញក្នុងវិសាលភាពយ៉ាងធំ ទៅលើប្រជាជននៃជាតិពន្ធុវៀតណាម ឬ បុគ្គលដែលបានមើលឃើញថាបានជាប់ទាក់ទងនឹងវៀតណាម។

3. **អ៊ឹម ចែម** បានកាន់អំណាចយ៉ាងធំដោយមកពីតួនាទីនានារបស់គាត់។ ស្រុកគឺជាផ្នែកគន្លឹះនៃរចនាសម្ព័ន្ធរបស់ បកក ដោយសារស្រុកបានរក្សាទុកនូវ “មន្ទីរសន្តិសុខ” ដែលបានធ្វើឲ្យខុសគ្នារវាង “ខ្មាំង” ដែលត្រូវបានកំចាត់ចោលនៅមូលដ្ឋាន និងពួកដែលត្រូវបានបញ្ជូនទៅកាន់អាជ្ញាធរជាន់ខ្ពស់[1]។ លេខាស្រុកត្រូវបានគិតថាជា “ថ្នាក់ដឹកនាំដ៏សំខាន់ មានសារៈសំខាន់ទីពីរតែចំពោះគណៈមជ្ឈិមបក្ស បកក ខ្លួនឯងប៉ុណ្ណោះ ពីព្រោះពួកគាត់បានភ្ជាប់សហករណ៍ទៅនឹងថ្នាក់លើ”[2]។ បន្ថែមលើនេះ គណៈតំបន់មាន “ការទទួលខុសត្រូវទូទៅ” លើគ្រប់បញ្ហានៅក្នុងយុត្តាធិការរបស់ពួកគាត់ - ទាំងកងទ័ព និងទាំងប្រជាជនស៊ីវិល[3]។ ដូច្នេះ **អ៊ឹម ចែម** មានអំណាច និងការទទួលខុសត្រូវ *ដានីតិន័យ* និង/ឬ *តាមព្រឹត្តន័យ* ចំពោះគ្រប់រឿងទាំងអស់ដែលបានកើតឡើងនៅក្នុងស្រុក និងក្នុងតំបន់ ដែលគាត់បានកាន់កាប់អំណាច។

4. **អ៊ឹម ចែម** បានប្រើប្រាស់មុខតំណែងទាំងនេះដើម្បីអនុវត្តគោលនយោបាយរបស់ បកក តាមរយៈ៖ ការចាត់តាំងជនរងគ្រោះឲ្យទៅការដ្ឋានពលកម្មដោយបង្ខំ ដោយបានដឹងថា លក្ខខណ្ឌនានានាំឲ្យមានការធ្វើឲ្យទៅជាទាសករ, ការធ្វើផែនការ និងការរៀបចំសហករណ៍ដែលនៅទីនោះប្រជាជនត្រូវបានបង្ខំឲ្យរស់នៅ និងធ្វើការ, ការចូលរួមចំណែកនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ, ការញុះញង់/ការជួយ និងការជំរុញអ្នកប្រព្រឹត្តបទល្មើសដទៃទៀត តាមរយៈការជួយជ្រោមជ្រែងឃោសនាអំពីការស្វែងរក និងសម្លាប់ “ខ្មាំង” - បណ្ដាលឲ្យមានជាបរិយាកាសភ័យ និងខ្លាច, ការបោសសម្អាតដោយគ្មានមេត្តាប្រណីដល់ពួកកម្មាភិបាល ដែលត្រូវបានគិតថាមិនបានបំពេញគោលនយោបាយរបស់ បកក - និង ការដាក់ជំនួសពួកគាត់ដោយអ្នកនៅក្រោមបង្គាប់ដ៏ស្មោះស្ម័គ្រ, និង ការបញ្ជាឲ្យគេចាប់បុគ្គលទាំងនោះ, បានឃុំឃាំង និងបានសម្លាប់។ **អ៊ឹម ចែម** បានអនុវត្តសិទ្ធិអំណាចរបស់ថ្នាក់លើទៅលើអ្នកប្រព្រឹត្តបទល្មើសនៅ

ក្នុងកន្លែងនោះ នៅក្រោមសិទ្ធិអំណាចរបស់គាត់ ខណៈដែលបានដឹងថាត្រូវបានប្រព្រឹត្ត និងខកខានមិនបានចាត់វិធានការចាំបាច់ ឬសមហេតុផល ដើម្បីរារាំង ឬដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តបទល្មើស។

5. ការអនុវត្តគោលនយោបាយរបស់ បកក **អ៊ឹម ចែម** នៅភូមិភាគនិរតី និងពាយ័ព្យ បណ្តាលឲ្យមានមនុស្សរាប់ពាន់នាក់ រួមទាំងកូនក្មេងដែលរាប់មិនអស់ផង ត្រូវបានបង្ខំឲ្យធ្វើការនៅក្រោមលក្ខខណ្ឌដែលនាំឲ្យមានការធ្វើឲ្យទៅជាទាសករ, ការរីករាលដាលនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមសង្វាសដោយបង្ខំនៃអាពាហ៍ពិពាហ៍, រាប់ពាន់នាក់ទទួលរងនូវការធ្វើទារុណកម្មខាងផ្លូវកាយ និងផ្លូវចិត្តៈ ការរស់នៅក្រោមការភ័យខ្លាចជាប្រចាំ ពីការដាក់ទណ្ឌកម្ម ឬពីការស្លាប់, ត្រូវបានបែកពីក្រុមគ្រួសារ, ឆ្លងកាត់ការបាត់ខ្លួនជាច្រើននាក់, បានឃើញ ឬបានដឹងឮពីការសម្លាប់ និងការរំលោភសេពសន្ថវៈ, រាប់ពាន់នាក់ត្រូវបានចាប់ខ្លួន, ការឃុំឃាំង និងការសម្លាប់បុគ្គលដែលបានគិតថាប្រឆាំងនឹងបដិវត្តរបស់ "អង្គការ", និងរាប់ពាន់នាក់ត្រូវបានស្លាប់ដោយសារការអត់បាយ ធ្វើការលើសកម្លាំង និង ដោយសារជម្ងឺ។

6. **អ៊ឹម ចែម** បានអនុវត្តនៅក្រោមទិសដៅ និងសេចក្តីណែនាំរបស់អ្នកដឹកនាំជាន់ខ្ពស់របស់ បកក, ត្រូវបានចាត់តាំងឲ្យទទួលមុខតំណែងនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី និងតំបន់៥ នៃភូមិភាគពាយ័ព្យ តាមរយៈ ប៉ុល ពត និង តាម៉ុក។ តាមពាក្យសម្តីរបស់គាត់ផ្ទាល់ គាត់បានធ្វើការដោយសប្បាយរីករាយ និងដោយយកចិត្តទុកដាក់ ដើម្បីអនុវត្តនូវការវាយប្រហារយ៉ាងមហន្តរាយរបស់ បកក ទៅលើសង្គមកម្ពុជា។

## ខ. ប្រវត្តិនីតិវិធី

## ការបើកកិច្ចស៊ើបសួរ

7. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ អនុលោមតាមវិធាន៥០ នៃវិធានផ្ទៃក្នុង សម្រាប់ អ.វ.ត.ក សហព្រះរាជអាជ្ញាបានចាប់ផ្តើមការស៊ើបអង្កេតបឋម ដើម្បីកំណត់មើលថាតើមានភស្តុតាងបញ្ជាក់ថា ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្ត និងដើម្បីកំណត់អត្តសញ្ញាណលើជនសង្ស័យ និងសាក្សីសក្តានុពលដែរ ឬមួយយ៉ាងណា។

8. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ដោយបានរកឃើញថាមានហេតុផលគួរឲ្យជឿជាក់ថាឧក្រិដ្ឋកម្ម នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តដោយជនសង្ស័យថ្មីចំនួនបីនាក់ សហព្រះរាជអាជ្ញា

អន្តរជាតិបានស្នើសុំបើកការស៊ើបសួរទាក់ទងនឹងការទទួលខុសត្រូវរបស់ **អ៊ឹម ចែម**, អោ អាន និង យឹម ទិត្យ ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") បានស្នើសុំដល់សហចៅក្រមស៊ើបអង្កេត ឱ្យស៊ើបអង្កេតលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មួយចំនួន ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ[4]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានសេចក្តីសង្ខេបពីអង្គហេតុ បទល្មើសដែលចោទប្រកាន់ បទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ដែលបានផ្តល់និយមន័យ និងផ្តន្ទាទោសលើឧក្រិដ្ឋកម្មនោះ និងឈ្មោះរបស់បុគ្គលទាំងឡាយដែលត្រូវបានស៊ើបអង្កេត។ ដីកាសន្និដ្ឋាននោះត្រូវបានដាក់អមនៅក្នុងសំណុំរឿង ដែលរួមមានភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។ សំណុំរឿងដែលគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ មានជាង ១០០០ ឯកសារ។

9. សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនបួន ដើម្បីពង្រីក និង/ឬ ធ្វើឱ្យមានគុណវុឌ្ឍិដល់វិសាលភាពនៃកិច្ចស៊ើបសួរ ទាក់ទងទៅនឹងទីកន្លែង និងព្រឹត្តិការណ៍ដូចតទៅ៖ (i) តំបន់១ នៃភូមិភាគពាយ័ព្យ និងការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍លើខ្មែរក្រោមនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ[5], (ii) អាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាលើផ្លូវភេទ ឬ យ៉ិនឌ័រ[6], (iii) វត្តតាមាក់[7] និង (iv) អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់១ និង៥[8]។

10. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងដល់ **អ៊ឹម ចែម** ថាគាត់ជាជនសង្ស័យមួយរូបនៅក្នុងកិច្ចស៊ើបសួរលើសំណុំរឿង០០៤ដែលកំពុងបន្ត និងបានជម្រាបគាត់អំពីសិទ្ធិរបស់គាត់ ក្នុងចំណោមនោះ មានអ្នកតំណាងស្របច្បាប់ដែលគាត់ជ្រើសរើស និងការបានចូលមើលសំណុំរឿង[9]។

## ការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា

11. នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នាជាមួយនឹងសហព្រះរាជអាជ្ញាជាតិអំពីការចោទប្រកាន់ជនសង្ស័យថ្មី អនុលោមតាមវិធាន៧១.២ នៃវិធានផ្ទៃក្នុង[10]។ បន្ទាប់មក សហព្រះរាជអាជ្ញាជាតិបានធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដាក់ទៅអង្គបុរេជំនុំជម្រះអំពីការខ្វែងយោបល់គ្នានេះ[11]។ ក្រោយពីបានទទួលសេចក្តីសង្កេតបន្ថែមនានាលើ

បញ្ហានេះ[12] អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងគាំទ្រគ្រប់គ្រាន់សម្រាប់ធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាបានទេ[13]។ អនុលោមតាមវិធាន ៧៤.១ និង ៥៣.១ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បន្ទាប់មក បានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ ទៅសហចៅក្រមស៊ើបអង្កេតដើម្បីបើកកិច្ចស៊ើបសួរ[14]។

## ការផ្លាស់ប្តូរចៅក្រមស៊ើបអង្កេតក្នុងកំឡុងពេលនៃកិច្ចស៊ើបសួរ

12. ការស៊ើបអង្កេតប្រឆាំងនឹង **អ៊ឹម ចែម** បានចាប់ផ្តើមនៅក្រោមសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde និងសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង[15]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Lemonde បានលាឈប់នៅខែវិច្ឆិកា ឆ្នាំ២០១០[16] និងត្រូវបានបន្តដោយ Siegfried Blunk។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk បានលាឈប់[17]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet បានស្បថចូលកាន់តំណែងនៅចំពោះមុខកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមិនធ្លាប់បានតែតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[18]។ ចៅក្រម Kasper-Ansermet បានសុំលាឈប់នៅខែមីនា ឆ្នាំ២០១២[19]។ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចៅក្រម Mark Harmon ត្រូវបានស្បថចូលកាន់តំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[20]។ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ចៅក្រម Harmon បានប្រកាសនូវការលាឈប់របស់គាត់ និងត្រូវបានជំនួសដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael Bohlander[21] សព្វថ្ងៃនេះ។

## ដីកាកោះ និងដីកាបង្គាប់ឱ្យនាំខ្លួន

13. នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកោះហៅ **អ៊ឹម ចែម** ឱ្យមកបង្ហាញខ្លួនជាលើកដំបូងនៅ អ.វ.ត.ក នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤[22]។ ដីកាកោះត្រូវបានដាក់ឈ្មោះ **អ៊ឹម ចែម** នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤[23]។ នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១៤ **អ៊ឹម ចែម** បានជូនដំណឹងដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា គាត់មិនពិចារណាលើដីកាកោះនោះថាមានសុពលភាពទេ ដោយសារវាត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង[24]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានឆ្លើយតបនៅថ្ងៃដដែលនោះថា គាត់អាចចេញដីកាកោះយ៉ាងមានសុពលភាព ដោយអនុលោមតាមវិធាន៧២ នៃវិធានផ្ទៃក្នុង - ដោយយោងទៅដល់ដីកាសម្រេច

របស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង០០២ ថាចំណាត់ការបែបនេះ គឺមានសុពលភាពស្របតាមច្បាប់[25]។

14. នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៤ **អ៊ឹម ចែម** បានដាក់សំណើមួយជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីសុំមោឃភាពលើដីកាកោះនោះ[26] និងសំណើមួយទៅកាន់អង្គបុរេជំនុំជម្រះឲ្យផ្អាកដីកាកោះនោះ មុននឹងមានការសម្រេចលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងសុពលភាពនៃដីកាកោះ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្នាក់ឯង[27]។ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ អង្គបុរេជំនុំជម្រះបានបដិសេធសំណើរបស់ **អ៊ឹម ចែម**[28] ដោយកត់សម្គាល់ថា "អង្គបុរេជំនុំជម្រះបានបញ្ជាក់នាពេលមុនរួចហើយថា សហព្រះរាជអាជ្ញាម្នាក់ ឬសហចៅក្រមស៊ើបអង្កេតម្នាក់ អាចបំពេញកិច្ចតែម្នាក់ឯងបាន នៅពេលការខ្វែងយោបល់គ្នាបានចុះបញ្ជីរួចរាល់នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬការិយាល័យសហចៅក្រមស៊ើបអង្កេត តាមករណីសមស្រប និងរយៈពេលនាំយកការខ្វែងយោបល់គ្នា មកចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុត"[29]។

15. បន្ទាប់ពី **អ៊ឹម ចែម** ខកខានមិនបានអនុវត្តតាមដីកាកោះទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបង្គាប់ឲ្យនាំខ្លួននៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ដើម្បីធានាថាគាត់មានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងនៅ អ.វ.ត.ក[30]។ នគរបាលយុត្តិធម៌ខកខានការអនុវត្តដីកានោះ។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសរសេរនៅក្នុងលិខិតមួយផ្ញើជូនប្រធានគណៈកម្មការសន្តិសុខរបស់ អ.វ.ត.ក ថា ប្រសិនបើ **អ៊ឹម ចែម** ខកខានមិនបានមកបង្ហាញខ្លួន ឬប្រសិនបើរូបគាត់មិនត្រូវបាននាំខ្លួនត្រឹមថ្ងៃទី១៨ ខែកុម្ភៈ ទេនោះ គាត់នឹងត្រូវដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[31]។

## ការដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ

16. នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់ **អ៊ឹម ចែម** ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[32] ចំពោះឧក្រិដ្ឋកម្មនានា និងទម្រង់ទាំងឡាយនៃការទទួលខុសត្រូវដែលមានបញ្ជាក់នៅក្នុងការជូនដំណឹងអំពីបទចោទប្រកាន់[33]។ **អ៊ឹម ចែម** ត្រូវបានចោទអំពី៖ ការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (តាមរយៈសហចារី) ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងការជម្រុញ[34] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការប្រព្រឹត្តដោយការចូលរួមក្នុងសហ

ឧក្រិដ្ឋកម្មរួម ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងជួយ និងការជម្រុញ[35] ការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ[36]។

**សេចក្តីសន្និដ្ឋានស្តីពី "មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត"**

17. នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតបានស្នើឱ្យភាគីនានាដាក់សេចក្តីសន្និដ្ឋានលើបញ្ហាថាតើ **អ៊ឹម ចែម** គួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ" ឬស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជាដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ៦ មករា ១៩៧៩"[37]។

18. មេធាវីការពារក្តី សហព្រះរាជអាជ្ញាអន្តរជាតិ និងសហព្រះរាជអាជ្ញាជាតិ បានធ្វើសេចក្តីសន្និដ្ឋាន[38]។ ទាំងសហព្រះរាជអាជ្ញាជាតិ និងទាំងមេធាវីការពារក្តី បានសន្និដ្ឋានថា **អ៊ឹម ចែម** មិនមែនជាមេដឹកនាំជាន់ខ្ពស់ និងមិនស្ថិតនៅក្នុងចំណោមជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ហើយហេតុដូច្នេះស្ថិតនៅក្រៅយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[39]។ សហព្រះរាជអាជ្ញាអន្តរជាតិបានសន្និដ្ឋានថា **អ៊ឹម ចែម** មិនមែនជាមេដឹកនាំជាន់ខ្ពស់នោះទេ[40] ប៉ុន្តែស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយហេតុដូច្នេះស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[41]។

**ការបិទកិច្ចស៊ើបសួរ និងការបំបែកសំណុំរឿង០០៤/០១**

19. នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតបានដាក់ "សេចក្តីជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង **អ៊ឹម ចែម**"[42]។ នៅថ្ងៃដដែល សហចៅក្រមស៊ើបអង្កេតបានដាក់ "សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់"[43] ដោយថ្លែងថាពួកគេ "មាននិន្នាការចង់លើកលែងការចោទប្រកាន់ [...] ដោយសារកង្វះយុត្តាធិការបុគ្គល" និង "បំបែកកិច្ចដំណើរការនីតិវិធី" ប្រឆាំងនឹង **អ៊ឹម ចែម** ចេញពីជនសង្ស័យដែលត្រូវបានចោទប្រកាន់ផ្សេងទៀតក្នុងសំណុំរឿង០០៤[44]។

20. នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៦ មេធាវីការពារក្ដីបានធ្វើសេចក្ដីសន្និដ្ឋានគាំទ្រការបំបែក **អ៊ឹម ចែម** ចេញពីសំណុំរឿង០០៤[45]។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានជូនដំណឹងសហចៅក្រមស៊ើបអង្កេតថា ពួកគេមិនជំទាស់ទៅនឹងការបំបែកសំណុំរឿងនេះទេ[46]។ ជាលទ្ធផល នៅថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានបំបែករឿងក្ដីប្រឆាំង **អ៊ឹម ចែម** ពីសំណុំរឿង ០០៤[47] ដើម្បីនាំយកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ឈានដល់ការបញ្ចប់មួយ ខណៈដែលកំពុងបន្តកិច្ចស៊ើបសួរនានាសម្រាប់ជនសង្ស័យដែលត្រូវបានចោទប្រកាន់ដែលនៅសល់។ នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតលុបចោលដីកាបង្គាប់ឲ្យនាំខ្លួន **អ៊ឹម ចែម** ដោយថ្លែងថា "វាមិនចាំបាច់សម្រាប់ [គាត់] ក្នុងការចូលរួមក្នុងនីតិវិធីជូនដំណឹងអំពីបទចោទប្រកាន់ទេ"[48]។

21. នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង[49]។ ដោយកត់សម្គាល់ថា **អ៊ឹម ចែម** មានសិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់បញ្ចប់ក្នុងពេលវេលាសមស្រប សហចៅក្រមស៊ើបអង្កេតបានស្នើឲ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនក្នុងរយៈពេលបីខែ ដូចមានចែងក្នុងវិធាន ៦៦(៥) នៃវិធានផ្ទៃក្នុង[50]។

## ការប្ដឹងទៅអង្គបុរេជំនុំជម្រះមិនទាន់ដោះស្រាយចប់

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦ **អ៊ឹម ចែម** បានដាក់ពាក្យប្ដឹងមួយទៅអង្គបុរេជំនុំជម្រះ សុំឲ្យពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារឹក និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីមួយចំនួន[51]។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៦ **អ៊ឹម ចែម** បានដាក់*សេចក្ដីបន្ថែម*ទៅលើកសំណើនោះ ដោយរួមទាំងឯកសារបន្ថែមផង[52]។ សំណើនោះបានលើកឡើងថាកំណត់ហេតុនៃការស្ដាប់ចម្លើយដែលបានបញ្ជាក់នោះ មានកំហុសនីតិវិធី[53]។ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានទទួលយកសំណើនោះដោយផ្នែក ទាក់ទងនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយមានកម្រិតមួយចំនួន និងបានណែនាំក្រឡាបញ្ជីឲ្យបញ្ជូនសំណុំរឿង០០៤/០១ ទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧៦(៣) នៃវិធានផ្ទៃក្នុង ដើម្បីឲ្យអង្គបុរេធ្វើការសម្រេច[54]។

22. កិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះកំពុងផ្អាកនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតបានថ្លែងថា ដីកាដំណោះស្រាយមួយនឹងមិនត្រូវបានចេញនោះទេ នៅមុនពេលមានដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងសំណើនោះ[55]។

## ភ័ស្តុតាងលើសំណុំរឿង០០៤/០១

23. នៅពេលបិទការស៊ើបអង្កេត មានឯកសារប្រមាណ ៨៩០០ នៅក្នុងសំណុំរឿង០០៤/០១[56]។ ទាំងនេះរួមមានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ១៤៥០ ដែលបានធ្វើឡើងដោយ កសចស ក៏ដូចជាឯកសារជាច្រើនទៀតដូចជា៖ កំណត់ត្រាសហកាលរបស់ បកក និងកម្ពុជាប្រជាធិបតេយ្យ, បញ្ជីឈ្មោះអ្នកទោស ស-២១, បទសម្ភាសន៍ដោយ DC-Cam និងការកត់ត្រាជាច្រើនទៀត, ប្រតិចារឹកសវនាការពីសំណុំរឿង០០១, ០០២/០១ និង០០២/០២, រូបថត, ផែនទី, សៀវភៅ និងអត្ថបទសិក្សា។ សំណុំរឿងនេះក៏មានបទសម្ភាសន៍មួយចំនួនដែលបានធ្វើឡើងជាមួយនឹង **អ៊ឹម ចែម**។ បទសម្ភាសន៍ទាំងនោះរួមមានការទទួលស្គាល់យ៉ាងទូលំទូលាយ *ជាអាទិ៍* អំពីតួនាទី និងសិទ្ធិអំណាចរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[57] ទំនាក់ទំនងជាមួយនឹង តាម៉ុក និងថ្នាក់លើ[58] ការគ្រប់គ្រងការដ្ឋានការងារដោយបង្ខំ[59] និងលក្ខខណ្ឌនានានៅក្នុងតំបន់ក្រោមការទទួលខុសត្រូវរបស់គាត់[60]។ ការទទួលស្គាល់ជាច្រើនរបស់ **អ៊ឹម ចែម** ស្របគ្នាទៅនឹងភ័ស្តុតាងផ្សេងទៀតនៅលើសំណុំរឿង ខណៈដែលការបដិសេធ និងការប៉ុនប៉ងរបស់គាត់ដើម្បីកាត់បន្ថយតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានជំទាស់ទាំងស្រុងដោយភ័ស្តុតាដែលមានបង្ហាញខាងក្រោមនេះ។ បន្ថែមលើនេះទៀត មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨៧ នៅក្នុងសំណុំរឿងទាក់ទងនឹងការទទួលខុសត្រូវរបស់ **អ៊ឹម ចែម** និងទីកន្លែងឧក្រិដ្ឋកម្មនានាដែលគាត់មានសិទ្ធិអំណាច[61]។ ពាក្យសុំទាំងនេះតំណាងឱ្យប្រភពសំខាន់មួយនៃភ័ស្តុតាងដែលទាក់ទង និងជាភវនីយភាព។ ជាឧទាហរណ៍ មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន បានកំណត់អត្តសញ្ញាណដោយឡែកលើ **អ៊ឹម ចែម** ថាបានត្រួតពិនិត្យមើលការដ្ឋានពលកម្មដោយបង្ខំ និងបញ្ជាឱ្យឃុំខ្លួន និងសម្លាប់មនុស្សតាមទំនើងចិត្ត[62]។

24. ភ័ស្តុតាងនៅក្នុងសំណុំរឿង ០០៤/០១ បង្ហាញពីរបៀបដែលរចនាសម្ព័ន្ធសិទ្ធិអំណាចឋានានុក្រមដ៏តឹងរឹង និងបណ្តាញទំនាក់ទំនងរបស់ បកក ក៏ដូចជាអំណាចដែលដែលបានធ្វើប្រតិភូកម្មទៅឱ្យ **អ៊ឹម ចែម** បានធានាឱ្យមានការអនុវត្តគោលនយោបាយរបស់ បកក យ៉ាងមានប្រសិទ្ធភាព។ ទាំងនៅក្នុងភូមិភាគ

និរតី និងទាំងនៅក្នុងភូមិភាគពាយ័ព្យ ភ័ស្តុតាងបង្ហាញយ៉ាងច្បាស់អំពីវិសាលភាពដែល **អ៊ឹម ចែម** ជាប់ពាក់ព័ន្ធ និងទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកានខាងក្នុងនេះ។

## គ. បទដ្ឋាននៃភ័ស្តុតាងដែលចាំបាច់ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ

25. វិធាន៦៧(៣)(គ) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងចោទប្រកាន់ *ក្នុងចំណោមរឿងផ្សេងទៀត* កាលណា “ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ”[63]។ស្រដៀងគ្នានេះ មាត្រា២៤៧(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ចៅក្រមស៊ើបសួរ ត្រូវចេញដីកាលើកលែងចោទប្រកាន់ កាលណា “គ្មានភ័ស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ”[64]។ មិនមានឯកសារណាមួយផ្តល់និយមន័យថា “ភ័ស្តុតាងគ្រប់គ្រាន់” មានន័យថាយ៉ាងដូចម្តេចនៅក្នុងការអនុវត្ត នោះឡើយ[65]។

26. សហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវបទដ្ឋាននៃ “ភ័ស្តុតាងគ្រប់គ្រាន់” នៅក្នុងសំណុំរឿង០០១[66] និង ០០២[67] ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា បទដ្ឋាននៃភ័ស្តុតាងជាធរមាន ដែលរួមបញ្ចូលក្នុងវាក្យស័ព្ទ “ភ័ស្តុតាងគ្រប់គ្រាន់” គឺ ភវនីយភាពនៃពិរុទ្ធ ជាជាងគ្រាន់តែជាលទ្ធភាពនៃពិរុទ្ធ[68]។ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា “ភ័ស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីចង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានតម្លៃជាភ័ស្តុតាងបន្ទាល់”[69]។ ការសម្រេចចុងក្រោយអំពីពិរុទ្ធភាពឲ្យហួសពីវិមតិសង្ស័យ នៅតែត្រូវវាយតម្លៃដោយអង្គជំនុំជម្រះសាលាដំបូងដដែល[70]។

27. នៅក្នុងការគាំទ្រលើនិយមន័យនៃ “ភ័ស្តុតាងគ្រប់គ្រាន់” នេះ សហចៅក្រមស៊ើបអង្កេតបានយោង *ក្នុងចំណោមរឿងផ្សេងទៀត* ទៅលើច្បាប់របស់ប្រទេសបារាំង និងយុត្តិសាស្ត្រច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[71] ។ ទាក់ទងទៅនឹងច្បាប់របស់ប្រទេសបារាំង មាត្រា១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង មានបទដ្ឋាននៃភ័ស្តុតាងដូចគ្នានៃ “charges suffisantes” (“ភស្តុតាងគ្រប់គ្រាន់”)[72] ប៉ុន្តែមិនបានផ្តល់នូវនិយមន័យនោះទេ។ នៅក្នុងប្រព័ន្ធរបស់ប្រទេសបារាំង ចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិស្វ័យប្រវត្តិក្នុងការធ្វើការសម្រេចក្នុងការអនុវត្តជាក់ស្តែង[73]។

28. យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិផ្តល់នូវការណែនាំច្រើនទៀត សម្រាប់ធ្វើការវាយតម្លៃអំពីបទដ្ឋានស្តីពីភ័ស្តុតាងចាំបាច់សម្រាប់ការបញ្ជូនទៅជំនុំជម្រះ។ នៅតុលាការ ICC មាត្រា៦១(៥) ដែលជាមាត្រាចែងអំពីការគ្រប់គ្រងបទចោទ ចែងថា "រដ្ឋអាជ្ញាត្រូវគាំទ្រចំពោះបទចោទនីមួយៗតាមរយៈភ័ស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់អំពីទឡ្ហីករណ៍ជាសារវ័ន្តដែលនាំឱ្យជឿបានថា បុគ្គលរូបនោះពិតជាបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់នោះមែន"[74]។ នៅក្នុងសេចក្តីសម្រេចថ្មីៗរបស់ខ្លួនក្នុងរឿងក្តី *Al Mahdi*, អង្គបុរេជំនុំជម្រះ I បានថ្លែងថា គោលបំណងនៃការបញ្ជាក់អំពីបទចោទគឺដើម្បីធានាឱ្យប្រាកដថា "មានតែបុគ្គលដែលរងការចោទប្រកាន់ដ៏គួរឱ្យជឿជាក់លើសពីទ្រឹស្តី ឬ ការសង្ស័យតែប៉ុណ្ណោះ ត្រូវបានបញ្ជូនទៅជំនុំជម្រះ"[75]។ អង្គបុរេជំនុំជម្រះក៏បានបន្ថែមទៀតថា បទដ្ឋានភ័ស្តុតាងជាធរមានត្រូវបានបង្កើតឡើង ប្រសិនបើរដ្ឋអាជ្ញាផ្តល់នូវ "តឹកតាងរឹងមាំ និងច្បាស់លាស់ដែលបង្ហាញពីខ្សែបន្ទាត់យ៉ាងច្បាស់ក្រឡែតនៃសំអាងហេតុដែលគាំទ្រដល់ [...] ការចោទប្រកាន់ជាក់លាក់[76]។

29. វិធានស្តីពីនីតិវិធី និង ភ័ស្តុតាងនៃយន្តការចុងក្រោយ សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងអតីតៈយូហ្គោស្លាវី ចែងថា រដ្ឋអាជ្ញាត្រូវដំណើរការចោទប្រកាន់ប្រសិនបើ "មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តល់នូវទឡ្ហីករណ៍សមហេតុផលនាំឱ្យជឿបានថា [...] ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង"[77]។ តុលាការ ICTR ធ្លាប់សម្រេចពីមុនថា "ទឡ្ហីករណ៍សមហេតុផលអាចត្រូវបានគេបកស្រាយថាជាអង្គហេតុ ឬកាលៈទេសៈនានា ដែលអាចធ្វើយុត្តិកម្មបុគ្គលធម្មតា ឬបុគ្គលដែលមានហេតុផល ជឿថាជនសង្ស័យម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្ម។ ត្រូវមានអង្គហេតុដែលអាចបញ្ជាក់បានយ៉ាងច្បាស់លាស់ចំពោះការសង្ស័យថា ជនសង្ស័យរូបនោះ គឺពិតជាមានពិរុទ្ធភាពដោយសារការប្រព្រឹត្តបទល្មើសនោះមែន ដើម្បីបង្ហាញថាអត្ថិភាពនៃទឡ្ហីករណ៍សមហេតុផលពិតជាបានកើតឡើង"[78]។

30. ជាការបន្ថែម ច្បាប់លក្ខន្តិកៈទាំងរបស់តុលាការ ICTY និង ICTR សុទ្ធតែតម្រូវឱ្យចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង "បំពេញឱ្យបានថា ករណីបឋម ត្រូវបានបង្កើតឡើង" ដើម្បីបញ្ជាក់ទៅលើបទចោទ[79]។ តុលាការ ICTY បានកំណត់និយមន័យចំពោះ "ករណីបឋម" ថាជា "ករណីគួរឱ្យជឿទុកចិត្តបាន ដែលនឹង (ប្រសិនបើមេធាវីការពារក្តីមិនជំទាស់) ជាមូលដ្ឋានគ្រប់គ្រាន់មួយដើម្បីកាត់ទោសជនជាប់ចោទចំពោះបទចោទ"[80]។

# II. អង្គហេតុសម្ភារៈ

## ក. ជម្លោះប្រដាប់អាវុធ

### ទិដ្ឋភាពទូទៅ

31. ស្ថានភាពនៃជម្លោះប្រដាប់អាវុធមួយបានកើតឡើងរវាងកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅចន្លោះខែឧសភា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩[81]។ ក្នុងរយៈពេលនេះ ជម្លោះប្រដាប់អាវុធរវាងប្រទេសទាំងពីរ បានធ្វើឲ្យមានការវាយប្រហារគ្នា និងការវាយបកតបតវិញជាច្រើន ដោយការប្រើធនធានយោធាយ៉ាងទូលំទូលាយ និងការចាប់យកទឹកដីគ្នាទៅវិញទៅមក។ ដោយមានការប៉ះទង្គិចគ្នា និងការលុកលុយផ្នែកយោធាមួយចំនួនក្នុងឆ្នាំ១៩៧៥ បានធ្វើឲ្យជម្លោះនេះកាន់តែឡើងកម្តៅចាប់ពីឆ្នាំ១៩៧៦មក ដែលជាចុងក្រោយ នាំឲ្យមានការឈ្លានពានទ្រង់ទ្រាយធំរបស់កងទ័ពវៀតណាមមកលើកម្ពុជា ក្នុងខែធ្នូ ឆ្នាំ១៩៧៨[82]។

32. បុព្វហេតុដែលនាំឲ្យមានជម្លោះប្រដាប់អាវុធនេះ គឺមានលក្ខណៈជាប្រវត្តិសាស្ត្រផង និងមានលក្ខណៈស្មុគស្មាញផង ប៉ុន្តែវាបានចាក់ឫសយ៉ាងជ្រៅមួយផ្នែកធំនៅក្នុងការទាមទារទឹកដីនៃប្រទេសទាំងពីរ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យជាញឹកញាប់មានការភ័យខ្លាចយ៉ាងខ្លាំងចំពោះការត្រួតត្រារបស់វៀតណាម[83]។

33. ទោះបីជាមានរបាយការណ៍ជាសាធារណៈរាយការណ៍អំពីជម្លោះនេះក៏ដោយ ក៏របបនៃប្រទេសទាំងពីររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ទើបបានអនុញ្ញាតឲ្យមានរបាយការណ៍តិចតួចប៉ុណ្ណោះទាក់ទងនឹងជម្លោះប្រដាប់អាវុធនេះ គឺនៅពេលដែលកម្ពុជាប្រជាធិបតេយ្យបានផ្តាច់ចំណងទាក់ទងជាផ្លូវការរបស់ខ្លួនជាមួយវៀតណាម ដោយការលើកឡើងអំពីការកាន់កាប់របស់វៀតណាមមកលើផ្នែកមួយចំនួននៃទឹកដីរបស់កម្ពុជា[84]។ អត្ថិភាពនៃជម្លោះប្រដាប់អាវុធដែលចេះតែរីកធំឡើងៗនៅពេលនេះ ត្រូវបានទទួលស្គាល់កាន់តែធំទូលាយនៅក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងអ្នកជំនាញ[85]។

### ឆ្នាំ១៩៧៥

34. ជម្លោះប្រដាប់អាវុធបានផ្ទុះឡើងនៅដើមខែឧសភា ឆ្នាំ១៩៧៥ នៅពេលកងទ័ពខ្មែរក្រហម បានធ្វើការ

វាយប្រហារទៅលើកោះភូកុក (កោះត្រល់) និងកោះថូជូ (ពូឡូប៉ាំនចាង ឬកោះក្រចកសេះ) ដែល បកក បានទាមទារថា ជាផ្នែកនៃទឹកដីរបស់កម្ពុជា[86]។ ការវាយប្រហារត្រូវបានវាយរុញច្រានមកវិញដោយវៀតណាមនៅក្នុងការវាយប្រយុទ្ធគ្នាក្នុងទ្រង់ទ្រាយធំមួយ ពីរសប្តាហ៍ក្រោយមក ដោយទាហានកម្ពុជាប្រមាណ៣០០នាក់ ត្រូវបានចាប់ខ្លួនជាឈ្លើយសឹក[87]។ នៅក្នុងរយៈពេលដំបូងរបស់កម្ពុជាប្រជាធិបតេយ្យ កងកម្លាំងខ្មែរក្រហមក៏បានវាយលុកទៅក្នុងវៀតណាមនៅតាមបណ្តោយព្រំដែនគោកផងដែរ[88]។ ដើម្បីជាការតបតវិញចំពោះការវាយប្រហាររបស់ខ្មែរក្រហមនេះ វៀតណាមក៏បានចាប់យកជាបណ្តោះអាសន្ននូវកោះប៉ូឡូវៃរបស់ កម្ពុជា ប្រហែលជានៅមុំ ឬនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៧៥[89]។ ឧប្បត្តិហេតុយោធាជាច្រើនត្រូវបានគេរាយការណ៍ដល់មេដឹកនាំជាន់ខ្ពស់របស់ បកក ("មជ្ឈិមបក្ស") នៅអំឡុងឆ្នាំ១៩៧៥ ដែលនាំឲ្យមានការរៀបចំផែនការការពារមួយដោយ បកក[90]។

## ឆ្នាំ១៩៧៦

35. ការទាស់ទែងគ្នាខាងយោធាបន្ថែមទៀតបានកើតឡើងនៅដើមឆ្នាំ១៩៧៦[91]។ ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍ បកក បានធ្វើការឆ្លើយតបតាមរយៈការចេញសេចក្តីណែនាំនានាស្តីពីបញ្ហាយោធា មានដូចជា ការផលិតរំសេវ និងការហ្វឹកហ្វឺនជាដើម ហើយការបង្កើតវាលយន្តហោះ មន្ទីរពេទ្យយោធា និងរោងចក្រយុទ្ធភណ្ឌ[92]។ នៅក្នុងឆ្នាំ១៩៧៦ទាំងមូល ការប៉ះទង្គិចគ្នាជាច្រើនបានកើតឡើងរវាងកងកម្លាំងនៃកម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំងសាធារណរដ្ឋសង្គមនិយមវៀតណាម[93]។ ក្នុងខែធ្នូ ឆ្នាំ១៩៧៦ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ អៀង សារី បានផ្តល់នូវការទទួលស្គាល់ជាសាធារណៈមុនគេមួយអំពីជម្លោះប្រដាប់អាវុធនេះ ដោយបាននិយាយដៀមដាមថា អំពើឈ្លានពានរបស់វៀតណាមមកលើកម្ពុជា អាចត្រូវប្រឆាំងតបតវិញ[94]។

## ឆ្នាំ១៩៧៧

36. ចាប់ពីដើមឆ្នាំ១៩៧៧ ជម្លោះប្រដាប់អាវុធរឹតតែខ្លាំងឡើងបន្ថែមទៀត ហើយទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែយ៉ាប់យ៉ឺនខ្លាំងឡើងៗ[95]។ នៅខែមេសា និងខែកញ្ញា ឆ្នាំ១៩៧៧ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានបង្កើនការវាយលុកទ្រង់ទ្រាយធំនៅតាមទីកន្លែងនានាក្នុងប្រទេសវៀតណាម ដោយបានប្រព្រឹត្តឧក្រិដ្ឋកម្មជាទ្រង់ទ្រាយធំប្រឆាំងនឹងប្រជាជនមូលដ្ឋាន រួមមាន ការសម្លាប់ប្រជាជនស៊ីវិលរាប់ពាន់នាក់ និងការបំផ្លាញទ្រព្យសម្បត្តិដែលមិនមែនជារបស់យោធា[96]។ ពីខែមិថុនា ឆ្នាំ១៩៧៧ តទៅ

មានការប៉ះទង្គិចគ្នាធំបានកើតឡើងនៅភូមិភាគបូព៌ា[97] ដែលចុងក្រោយបណ្ដាលឲ្យមានការជ្រៀតចូលធំមួយទៅក្នុងទឹកដីកម្ពុជា ពីសំណាក់កងកម្លាំងសាធារណរដ្ឋសង្គមនិយមវៀតណាម[98]។ ការវាយប្រយុទ្ធគ្នា ជាពិសេស គឺខ្លាំងក្លានៅភូមិភាគបូព៌ា នៅចន្លោះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៧ និងថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៧[99]។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ បណ្ដាញសារព័ត៌មានអន្តរជាតិក៏បានរាយការណ៍ផងដែរថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានបើក "ការវាយប្រហារធំ" មួយផ្សេងទៀត ចូលទៅក្នុងខេត្តតាយនិញរបស់ប្រទេសវៀតណាម[100]។ នៅខែធ្នូ ឆ្នាំ១៩៧៧ បណ្ដាញសារព័ត៌មានអន្តរជាតិបានរាយការណ៍ពី "ការប្រយុទ្ធពេញទំហឹង" រវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយយោងថាបានប្រើប្រាស់យន្តហោះ និងកាំភ្លើងត្បាល់ ក៏ដូចជាចំនួនមនុស្សរបួស និងស្លាប់យ៉ាងធ្ងន់ធ្ងរទាំងសងខាង[101]។ ជាលទ្ធផល នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ("MFA") បានប្រកាសផ្សាយជាសាធារណៈនូវការបាក់បែកខាងទំនាក់ទំនងការទូតជាមួយនឹងប្រទេសវៀតណាម បណ្ដាលមកពីអ្វីដែលខ្លួនបានរៀបរាប់ថាជា អំពើនៃការឈ្លានពាន និងការលុកលុយរបស់វៀតណាម[102]។

**ឆ្នាំ១៩៧៨ - ឆ្នាំ១៩៧៩**

37. នៅដើមឆ្នាំ១៩៧៨ កងពលទាំងឡាយរបស់កម្ពុជាប្រជាធិបតេយ្យ បានប្ដូរទីតាំងពីភូមិភាគនិរតី ទៅកាន់ភូមិភាគបូព៌ា ដើម្បីចូលរួមនៅក្នុងការប្រយុទ្ធប្រឆាំងនឹងវៀតណាម[103]។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨ សេវាផ្សាយព័ត៌មានក្នុងស្រុកនៅភ្នំពេញបានបញ្ជាក់ថា ក្នុងកំឡុងនៃថិរវេលាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ "ការវាយប្រយុទ្ធគ្នាបានកើតឡើងជាបន្តបន្ទាប់ជាទ្រង់ទ្រាយតូច មធ្យម និងធំ"[104]។ ចំណែកនៅខែកញ្ញា ឆ្នាំ១៩៧៨ MFA បានចេញនូវការបោះពុម្ពផ្សាយ "សៀវភៅខ្មៅ៖ ការពិត និងភស្តុតាងនៃអំពើឈ្លានពាន និងភ្ជាប់យកទឹកដីកម្ពុជាពីសំណាក់វៀតណាម"[105]។ ការប្រយុទ្ធគ្នានៅបន្តពេញក្នុងឆ្នាំ១៩៧៨ ហើយបានចប់ដោយមានការលុកលុយចូលក្នុងកម្ពុជាប្រជាធិបតេយ្យយ៉ាងពេញទំហឹង ដោយកងកម្លាំងរបស់វៀតណាម នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ ដែលជាលទ្ធផលនាំឲ្យមានការគ្រប់គ្រងទីក្រុងភ្នំពេញ និងការដួលរលំនៃរបបនោះនៅថ្ងៃទី ៦ មករា ឆ្នាំ ១៩៧៩[106]។

**ខ. រចនាសម្ព័ន្ធសិទ្ធិអំណាច**

## រចនាសម្ព័ន្ធសិទ្ធិអំណាច បកក

38. បកក គ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ[107] តាមរយៈរចនាសម្ព័ន្ធឋានានុក្រមតឹងរ៉ឹង ដែលនៅក្រោមរចនាសម្ព័ន្ធនេះ បទបញ្ជាទាំងឡាយត្រូវបានប្រគល់ពីថ្នាក់លើទៅថ្នាក់ក្រោម និងត្រូវបានអនុវត្តដោយយ៉ាងម៉ឺងម៉ាត់។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា បានកំណត់អត្តសញ្ញាណគណៈមជ្ឈិមថាជា "អង្គភាពប្រតិបត្តិការខ្ពស់បំផុតនៅទូទៅប្រទេស"[108]។ គណៈមជ្ឈិម - ជួនកាលគេហៅថា "គណៈ៨៧០"[109] – មានសមាជិកសរុបយ៉ាងតិច៣០នាក់[110]។ គណៈមជ្ឈិមមានសមាសភាពមកពីគណៈអចិន្ត្រៃយ៍ - ដែលជាអនុ គណៈកម្មាធិការមួយរបស់គណៈមជ្ឈិម - និងរួមមាន លេខាភូមិភាគ និងតំបន់[111]។ គណៈមជ្ឈិមជួបគ្នារៀងរាល់ប្រាំមួយខែម្តង[112]។

39. តាមការអនុវត្ត គណៈអចិន្ត្រៃយ៍[113] គឺជាអង្គភាពខ្ពស់បំផុត និងមានអំណាចបំផុតនៅក្នុង បកក និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ[114]។ ខៀវ សំផន ធ្លាប់និយាយថា "មាគ៌ានយោបាយ និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត គឺ[...] ត្រូវបានបង្កើតឡើងនៅឯគណៈអចិន្ត្រៃយ៍[115] ហើយ ឌុច ធ្លាប់បានប្រកាសថា វាជា "ស្ថាប័នដ៏សំខាន់បំផុតនៅក្នុងបក្ស"[116]។ ទីស្នាក់ការរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ស្ថិតនៅក្នុងទីក្រុងភ្នំពេញ ដែលស្គាល់ថា "មន្ទីរ ៨៧០"។ នៅក្នុងអំឡុងនៃសម័យកាលកម្ពុជាប្រជាធិបតេយ្យ គណៈអចិន្ត្រៃយ៍ មានសមាជិកប្រាំពីរនាក់ ដែលក្នុងចំនួននេះ មានប្រាំនាក់ជាសមាជិក "ពេញសិទ្ធិ" និងពីរនាក់ជាសមាជិក "តៀម" ឬ "បម្រុង"[117]។ គិតត្រឹមខែមេសា ឆ្នាំ១៩៧៥ សមាជិក "ពេញសិទ្ធិ" រួមមាន ប៉ុល ពត, នួន ជា, អៀង សារី, លេខាភូមិភាគបូព៌ា រស់ ញឹម និងលេខាភូមិភាគនិរតី តា ម៉ុក[118]។

40. គណៈអចិន្ត្រៃយ៍ បានបង្កើត បញ្ជា និងតាមដានការអនុវត្តគោលនយោបាយទាំងអស់របស់ បកក និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ និយាយឲ្យចំ គណៈអចិន្ត្រៃយ៍បានត្រួតត្រានៅលើគោលនយោបាយនានាទាក់ទងនឹងសន្តិសុខខាងក្នុង និងខាងក្រៅ[119] កិច្ចការបរទេស[120] កិច្ចការក្នុងប្រទេស ដែលរួមមានទាំងកិច្ចការហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សុខភាព និងសង្គម[121] ឃោសនាការ និងការអប់រំឡើងវិញ[122] និងកិច្ចការបុគ្គលិក និងរដ្ឋបាលរបស់ បកក និងរដ្ឋ[123]។ គណៈអចិន្ត្រៃយ៍បានពិភាក្សា និងបញ្ជាឲ្យមានការបន្លាស់ទីដោយបង្ខំក្នុងទ្រង់ទ្រាយធំ[124] ការប្រើពលកម្មដោយបង្ខំ[125] និងការចាប់ខ្លួន និងការសួរចម្លើយ "ខ្មាំង"[126] បានតាមដានទៅលើលក្ខខណ្ឌរស់នៅ នៅទូទាំងប្រទេស[127]

និងមានសិទ្ធិអំណាចដើម្បីបញ្ជាឲ្យសម្លាប់មនុស្សភ្លាមៗ[128]។

41. សារាចរណែនាំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ត្រូវបានបញ្ជូនទៅកាន់មន្ទីរភូមិភាគ កងពលធំ និងក្រសួង និងដែលត្រូវបានបញ្ជូនបន្តចេញពីទីនេះទៅតាមតំបន់ ស្រុក និងថ្នាក់ក្រោមផ្សេងៗទៀត[129] ។ របៀបនៃការធ្វើការប្រាស្រ័យទំនាក់ទំនងគ្នា និងអនុវត្តសារាចរទាំងនេះ ត្រូវបានគេផ្តល់តាមរយៈសេចក្តីណែនាំច្បាស់លាស់[130]។ សមាជិកគណៈអចិន្ត្រៃយ៍ ក៏បានចុះធ្វើអធិការកិច្ចតាមភូមិភាគផងដែរ[131]។

42. គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍បានអនុវត្តម៉ឺងម៉ាត់នូវគោលនយោបាយនានារបស់ បកក ដែលជារួមត្រូវបានគេស្គាល់ថា "មាគ៌ា" បក្ស[132]។ ដូចបានរៀបរាប់ដោយកម្មាភិបាល បកក ម្នាក់ថា "អ្វីៗទាំងអស់" មានដើមកំណើតចេញពីមជ្ឈិមបក្ស[133]។ ការព្យាយាមដើម្បីរិះគន់ ឬកែប្រែមាគ៌ាបក្ស ត្រូវបានចាត់ទុកថា ជាអំពើក្បត់នៃ "សេរីនិយម"[134]។ លក្ខន្តិកៈ បកក ហាមឃាត់ចំពោះ "ឯករាជ្យនិយម, សេរីនិយម [និង] និកាយនិយម" និងដាក់វិន័យចំពោះសមាជិកបក្សណាដែល "ជំទាស់នឹងមាគ៌ាបក្ស" និង "គោលជំហរមនោគមវិជ្ជារបស់បក្ស"[135]។

43. នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បកក បានបែងចែកប្រទេសទៅជាភូមិភាគស្នូលចំនួនប្រាំ ដោយមានលេខកូដៈ ភូមិភាគឦសាន (១០៨), ភូមិភាគឧត្តរ (៣០៤), ភូមិភាគពាយ័ព្យ (៥៦០), ភូមិភាគនិរតី (៤០៥) និងភូមិភាគបូព៌ា (២០៣) និង "ភូមិភាគពិសេស" ដែលរួមបញ្ចូលទាំងតំបន់នៅជុំវិញទីក្រុងភ្នំពេញ[136]។ ភ្លាមៗបន្ទាប់សង្គ្រាម ភូមិភាគបស្ចិម (៤០១) ត្រូវបានបង្កើតឡើង ចេញពីកងពលមួយរបស់ភូមិភាគនិរតី[137]។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ភូមិភាគទីប្រាំពីរក៏បានបង្កើតឡើង ពេលដែលពីមុនធ្លាប់ជាតំបន់ស្វ័យត្ត១០៣ និង១០៦ ក៏បានក្លាយជាភូមិភាគឧត្តរ (៨០១) ហើយភូមិភាគឧត្តរចាស់ ក៏ត្រូវបានប្តូរឈ្មោះថ្មីទៅជា ភូមិភាគកណ្តាល[138]។

44. ភូមិភាគទាំងឡាយត្រូវបែងចែកទៅជាអង្គភាពផ្សេងៗដែលគេស្គាល់ថា តំបន់ ដែលត្រូវបានបែងចែកជាបន្តទៀតទៅជា ស្រុក[139]។ ស្រុក មានសមាសភាពឃុំ ឬ អនុស្រុកជាច្រើននៅក្នុងនោះ ហើយដែលនៅក្នុងឃុំ/អនុស្រុក មានភូមិជាច្រើន។ ការធ្វើស្រែចម្ការ និងការអនុវត្តពលកម្មតាមបែបប្រពៃណីផ្សេងទៀតត្រូវបានគេលុបបំបាត់បន្តិចម្តងៗ និងត្រូវបានរៀបចំឡើងវិញជា"សហករណ៍"[140]។ សាខាគឺជាអង្គការថ្នាក់ទាបបង្អស់នៃឋានានុក្រមរបស់ បកក ហើយត្រូវបានបង្កើតឡើងនៅគ្រប់សហករណ៍

រោងចក្រ អង្គភាពយោធាថ្នាក់កងអនុសេនាធំ ការដ្ឋាន និងមន្ទីរក្រសួងនិមួយៗ[141]។

45. ភូមិភាគ តំបន់ ស្រុក និងសាខាទាំងឡាយ ជាឧបករណ៍នៅក្នុងការអនុវត្តសេចក្តីណែនាំរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់ បកក នៅទូទាំងប្រទេស។ គណៈកម្មាធិការដែលមានគ្នាបីនាក់ ជាលេខា អនុលេខា និងសមាជិក គ្រប់គ្រងតាមថ្នាក់នីមួយៗនៅក្នុងឋានានុក្រមនៃអង្គការរបស់ បកក។ ឧទាហរណ៍ គណៈភូមិភាគទទួលខុសត្រូវក្នុងការពិនិត្យមើលលើការអនុវត្តផែនការរបស់បក្សនៅក្នុងតំបន់ ស្រុក និងសាខាទាំងឡាយនៅក្នុងភូមិភាគនោះ និង "រាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ភូមិភាគ ជូនគណៈកម្មាធិការមជ្ឈិម"[142]។ គណៈដែលនៅតាមកម្រិតតំបន់ ស្រុក និងសាខា បានបំពេញមុខងារស្រដៀងគ្នាមួយនៃការអនុវត្តកិច្ចការដែលចាត់តាំងដោយថ្នាក់លើនៃ បកក និងរាយការណ៍ជូនទៅថ្នាក់លើវិញនូវស្ថានភាព និងអំពីកិច្ចការរៀងៗខ្លួន[143]។ សមាជិកនៃគណៈនីមួយៗ ជាទូទៅ ត្រូវបានចាត់តាំងឲ្យកាន់តួនាទីជាក់លាក់៖ លេខា ត្រូវទទួលខុសត្រូវក្នុងការចាត់តាំង និងដកសមាជិកនានាចេញពី គណៈកម្មាធិការ, អនុលេខា ត្រូវទទួលខុសត្រូវលើសន្តិសុខ និងសមាជិក ត្រូវទទួលខុសត្រូវលើសេដ្ឋកិច្ច[144]។ យ៉ាងណាក៏ដោយ ការប្រជុំរបស់គណៈកម្មាធិការ ត្រូវបានធ្វើឡើងជាទៀងទាត់ នៅតាមកម្រិតនីមួយៗនៃអង្គការ ដើម្បីពិនិត្យ តាមដាន និងពិភាក្សាសម្រេចលើការងារ[145] ហើយសមាជិកទាំងអស់មានមតិយោបល់សំខាន់នៅក្នុងកិច្ចការរបស់គណៈកម្មាធិការ[146]។

46. គណៈភូមិភាគតម្រូវឲ្យ "ប្រជុំជាសាមញ្ញ ៣ខែម្តង ដើម្បីពិនិត្យតាមដាន វិនិច្ឆ័យ ការងារចាស់ និងលើកការងារថ្មី"[147]។ ជាទូទៅ សមាជិកគណៈភូមិភាគកាន់កាប់មុខតំណែង នៅក្នុង គណៈអចិន្ត្រៃយ៍ និង/ឬ គណៈមជ្ឈិមនៃ បកក[148]។ នៅក្នុងភូមិភាគជាច្រើន លេខាតំបន់នីមួយៗ បានចូលរួមនៅក្នុងការប្រជុំរបស់គណៈភូមិភាគ និងបានកាន់កាប់នូវមុខតំណែងមួយជាអនុលេខាភូមិភាគ ឬមួយជាសមាជិក ឬសមាជិកបម្រុងនៃគណៈភូមិភាគ[149]។

47. គណៈតំបន់តម្រូវឲ្យធ្វើការប្រជុំប្រចាំខែ[150]។ គណៈតំបន់តម្រូវឲ្យធ្វើការសម្របសម្រួលគ្រប់ការងារទាំងអស់ដែលបានធ្វើនៅក្នុងតំបន់ តាម "មាគ៌ាគោលនយោបាយរបស់បក្ស"[151]។ គណៈតំបន់ ទទួលខុសត្រូវធានាថាប្រជាជននៅក្នុងតំបន់ ត្រៀមរៀបចំមនោគមន៍វិជ្ជា និងនយោបាយទៅតាមមាគ៌ារបស់បក្ស[152]។ គណៈតំបន់ក៏ត្រូវទទួលខុសត្រូវផងដែរ នូវការគ្រប់គ្រងខាង "វិន័យ"[153] និង "ការការពារ" របបកម្ពុជាប្រជាធិបតេយ្យ។[154] គណៈតំបន់តម្រូវឲ្យរាយការណ៍ជូនទៅថ្នាក់លើអំពីស្ថានភាពនៅក្នុង

តំបន់[155]។

48. គណៈស្រុកតម្រូវឱ្យធ្វើការប្រជុំប្រចាំខែ[156]។ ពួកគេត្រូវដឹកនាំ និងមើលការខុសត្រូវលើកិច្ចការរបស់កម្មាភិបាល សាខា សហករណ៍ និងឃោធាទាំងអស់ នៅក្នុងតំបន់ទៅតាមមាគ៌ារបស់បក្ស[157]។ គណៈស្រុកក៏ត្រូវបានដាក់ទិសដោយបក្សផងដែរ ដើម្បីធានាថាការបង្រៀនមនោគមន៍វិជ្ជា និងនយោបាយដល់បុគ្គលទាំងអស់ដែលនៅក្នុងស្រុក និង "ការពារ" របបកម្ពុជាប្រជាធិបតេយ្យ[158]។ ការណ៍នេះ ជារួម មានការគ្រប់គ្រង "វិន័យ"[159]។ គណៈស្រុកតម្រូវឱ្យរក្សានូវ "របបរាយការណ៍ អំពីស្ថានការណ៍ និងការងារ របស់ស្រុក ជូនថ្នាក់លើ"[160]។

49. រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យបានផ្តល់ដល់កងទ័ពបដិវត្តកម្ពុជា ("RAK") ដែលត្រូវបានបង្កើតជាផ្លូវការក្នុងឆ្នាំ១៩៧៥ នូវកិច្ចការ "ការពាររដ្ឋអំណាច" និង "រួមចំណែកកសាងប្រទេស"[161]។ សាខាទាំងបីនៃ RAK - កងទ័ពស្រួច កងទ័ពតំបន់ និង កងឈ្លប ឬ*ឈ្លប* - បានផ្តល់នូវសន្តិសុខផ្ទៃក្នុង និងខាងក្រៅ នៅក្រោមការដឹកនាំដាច់ខាតនៃ បកក[162]។ នៅកម្រិតភូមិភាគ មានកងពលធំមួយចំនួនត្រូវបានរក្សាទុកនៅនឹងកន្លែង ទទួលបន្ទុកខាងសន្តិសុខភូមិភាគប្រចាំថ្ងៃ[163]។ ខាងស្រុកក៏បានរក្សាទុកកងវរសេនាតូចសម្រាប់ការការពារក្នុងស្រុកផងដែរ[164] ដែលជាការបន្ថែមទៅនឹងការត្រួតពិនិត្យរបស់ឈ្លបមូលដ្ឋាន[165]។

## **រចនាសម្ព័ន្ធសិទ្ធិអំណាចនៃភូមិភាគនិរតី ឆ្នាំ១៩៧៦-ឆ្នាំ១៩៧៧**

### **ភូមិភាគនិរតី**

50. មានតំបន់ចំនួនបួននៅក្នុងភូមិភាគនិរតី[166]។ ចាប់ពីឆ្នាំ១៩៧៥ តាម៉ុកជាលេខាភូមិភាគនិរតី[167]។ អ្នកនៅក្រោមបង្គាប់របស់គាត់នៅក្នុងគណៈកម្មការ រួមមាន តាស៊ី[168] តាប៊ិត[169] និងតាចាប[170]។ តាម៉ុកបានបញ្ជាឱ្យកម្មាភិបាល ជាក់ស្តែង ដូចជា **អ៊ឹម ចែម**[171] និង យឹម ទិត្យ[172] ត្រូវបានបញ្ជូនពីភូមិភាគនិរតី ទៅកាន់ភូមិភាគពាយ័ព្យពីឆ្នាំ១៩៧៦ ឡើងទៅ។

51. គណៈភូមិភាគនិរតីបានទទួលបញ្ជាពីគណៈមជ្ឈិម[173]។ នៅពេលនោះ គណៈភូមិភាគនិរតីផ្សព្វផ្សាយសេចក្តីណែនាំទាំងនោះទៅកាន់ថ្នាក់ក្រោម តាមរយៈការប្រជុំ និងវគ្គរៀនសូត្រនានា រួមមាន ការ

ព្រមានអំពី "ខ្មាំង" និងប្រឆាំងនឹងការធ្វើឲ្យមានកំហុស[174]។ គណៈភូមិភាគក៏បានសម្របសម្រួលផង ដែរ អំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលបានធ្វើឡើងនៅថ្នាក់ក្រោម[175]។

<u>តំបន់១៣</u>

52. មានស្រុកប្រាំនៅក្នុងតំបន់១៣៖ ស្រុកត្រាំកក់ ស្រុកអង្គរជ័យ ស្រុកទ្រាំង ស្រុកកោះអណ្ដែត និងស្រុក គីរីវង់[176]។ តាសោម ជាគណៈលេខាតំបន់១៣ រហូតដល់ឆ្នាំ១៩៧៦[177] និងត្រូវបានជំនួសដោយ តា ប្រាក់[178]។ មាស មុត ជាអនុលេខានៃគណៈតំបន់១៣[179]។ **អ៊ឹម ចែម** បានក្លាយជាសមាជិកនៃគណៈ តំបន់១៣ នៅឆ្នាំ១៩៧៦[180]។

53. គណៈតំបន់បានធ្វើតាមសេចក្ដីណែនាំរបស់គណៈភូមិភាគយ៉ាងហ្មត់ចត់[181] និងមើលខុសត្រូវក្នុង ចំណោម រឿងទាំងនោះ គឺវគ្គរៀនសូត្រ ការឃោសនា ការអប់រំ ការងារ និងសន្តិសុខ[182]។ ជាញឹក ញាប់ ការប្រជុំតំបន់ត្រូវបានធ្វើឡើងជាមួយលេខាស្រុក និង/ឬ លេខាឃុំទាំងអស់នៅក្នុងតំបន់ កាល ណាមានសេចក្ដីណែនាំពីថ្នាក់លើ ត្រូវបញ្ជូនចុះមកក្រោម[183]។ កិច្ចប្រជុំទាំងនេះពិភាក្សា ក្នុងចំណោម រឿងទាំងនោះ គឺ គោលនយោបាយរបស់ បកក ផែនការការងារ លក្ខខណ្ឌនៃការរស់នៅ ការប្រុង ប្រយ័ត្នចំពោះខ្មាំង និង ព័ត៌មានស្ដីពីអ្វីដែលបានកើតឡើងនៅថ្នាក់ក្រោម[184]។

<u>ស្រុកកោះអណ្ដែត</u>

54. មានឃុំប្រាំមួយនៅក្នុងស្រុកកោះអណ្ដែត។ សៀង ជាលេខាគណៈស្រុកកោះអណ្ដែត រហូតដល់មាន ការផ្លាស់ប្ដូររបស់គាត់ទៅស្រុកគីរីវង់ ក្នុងឆ្នាំ១៩៧៦[185]។ **អ៊ឹម ចែម** នៅពេលនោះ ត្រូវបានចាត់តាំងជា លេខាស្រុកនេះ[186]។ អ៊ូច នាង *ហៅ* សាន ជាអនុលេខាស្រុកកោះអណ្ដែត ក្រោម សៀង[187] និង **អ៊ឹម ចែម**[188]។

55. គណៈស្រុករៀបចំសហករណ៍ និងឃុំ ចាត់តាំងមនុស្សឲ្យធ្វើការ និងបើកវគ្គអប់រំ និងប្រជុំជាទៀង ទាត់សម្រាប់សមាជិកនានានៅថ្នាក់ក្រោម[189]។ គណៈស្រុកត្រួតត្រាសន្តិសុខនៅក្នុងស្រុក[190] រួមមាន បញ្ជាឲ្យ កម្មាភិបាលថ្នាក់ក្រោមផ្ដោតលើក្រុមគោលដៅដែលបានចាត់ទុកថាជា"ខ្មាំង" - ដូចជាពួកយួន ពួកទាហាន លន់ នល់ និងពួក "១៧ មេសា"[191]។

# របនាសម្ព័ន្ធសិទ្ធិអំណាចនៃភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧-ឆ្នាំ១៩៧៩

## ភូមិភាគពាយ័ព្យ

56. មានតំបន់ចំនួនប្រាំពីរនៅក្នុងភូមិភាគពាយ័ព្យ[192]។ ចាប់ផ្តើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ រស់ ញឹម ជាលេខាភូមិភាគពាយ័ព្យ[193]។ តាគី គឺជាអនុលេខា[194] ហើយ តាប៉ែត *ហៅ* ហេង ទាវ ជាសមាជិកគណៈកម្មាធិការ[195]។ រស់ ញឹម ត្រូវបានដកនៅឆ្នាំ១៩៧៨[196] និងត្រូវបានជំនួសដោយ តាម៉ុក[197]។ តាប៉ែត ក៏ត្រូវបានដក នៅឆ្នាំ១៩៧៨ ផងដែរ[198]។ តាម៉ុក ជាលេខា ទាំងភូមិភាគពាយ័ព្យ និង ទាំងភូមិភាគនិរតី[199]។

57. សមាជិកគណៈភូមិភាគពាយ័ព្យបើកការប្រជុំ[200] ដែលអ្នកចូលរួមមកពីតំបន់ និងស្រុក ត្រូវបានប្រាប់ឲ្យរស់នៅ និងធ្វើការទៅតាម 'មាគ៌ាបក្ស'[201]។ សេចក្តីណែនាំពីមជ្ឈិម រួមមាន ប្រឹងធ្វើការដើម្បីបង្កើនផលិតផលដំណាំ[202] និងស្វែងរក "ខ្មាំង" ផ្ទៃក្នុង រួមទាំងភ្នាក់ងារ KGB និងពួក "យួន"[203]។ សមាជិកគណៈកម្មាធិការបានចុះមើលការដ្ឋាន[204] ធ្វើជាអធិបតីអាពាហ៍ពិពាហ៍ដោយបង្ខំ[205] និងណែនាំថ្នាក់ក្រោមពាក់ព័ន្ធនឹងបញ្ហាសន្តិសុខ ដូចជា បញ្ហាថាត្រូវបញ្ជូនមនុស្សមួយចំនួនទៅ "អប់រំ" - មានន័យថាពួកនោះត្រូវបានសម្លាប់[206]។

### <u>តំបន់ ៥</u>

58. មានស្រុកចំនួនបួននៅក្នុងតំបន់៥៖ ស្រុកភ្នំស្រុក ស្រុកស៊ីសុផុន ស្រុកថ្មពួក និងស្រុកព្រះនេត្រព្រះ[207]។ នៅចុងឆ្នាំ១៩៧៨ តំបន់នានានៃភូមិភាគពាយ័ព្យត្រូវបានរៀបចំឡើងវិញ ហើយភាគខាងជើងនៃតំបន់ ៣ ត្រូវបានបញ្ចូលទៅក្នុងតំបន់៥[208]។ ម៉ែន ជុន *ហៅ* ហ៊ឹង្ស គឺជាលេខាតំបន់៥[209]។ តារុធ ជាអនុលេខា[210] គង់ ឡែម ហៅ ឡៃ គឺជាសមាជិកគណៈកម្មាធិការ[211] ហើយ តាជៀល គឺជាជំនួយការ[212]។ កម្មាភិបាលនិរតីឈ្មោះ ហេង រិន បានមកជំនួស ហ៊ឹង្ស ក្នុងឋានៈជាលេខាតំបន់៥ ក្នុងខែមិថុនា ឆ្នាំ១៩៧៧[213]។ រិន បន្ទាប់មក ត្រូវបានបោសសម្អាតក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨[214]។ ក្រោយពី តារុធ បានបាត់ខ្លួន ក្នុងខែកញ្ញា ឆ្នាំ១៩៧៧[215] តាជៀល បានដើរតួពេញសិទ្ធិជាអនុលេខា[216]។ នៅពេលដែល តាជៀល ត្រូវបានបញ្ជូនទៅស-២១ ក្នុងខែមិថុនា ឆ្នាំ១៩៧៨[217] **អ៊ឹម ចែម** បានក្លាយជាអនុលេខាតំបន់

៥[218]។ **អ៊ឹម ចែម** បានជំនួស តាឡៃ រួចទៅហើយក្លាយជាសមាជិកគណៈកម្មាធិការតំបន់៥ ភ្លាមៗ បន្ទាប់ពីគាត់បានមកដល់ភូមិភាគពាយ័ព្យនៅពាក់កណ្តាលឆ្នាំ១៩៧៧[219]។

59. សមាជិកគណៈកម្មាធិការតំបន់ធ្វើដំណើរជាញឹកញាប់នៅទូទាំងតំបន់ទាំងមូល ដោយរួមទាំងការទស្សនាការដ្ឋាន[220] និងមន្ទីរសន្តិសុខ[221]។ សមាជិកតំបន់បានធ្វើការប្រជុំជាប្រចាំដើម្បីផ្សព្វផ្សាយគោលនយោបាយ ប.ក.ក ទៅកាន់កម្មាភិបាលថ្នាក់ក្រោម និងកម្មករទូទៅមកពីគ្រប់ស្រុកទាំងអស់នៅក្នុងតំបន់[222]។ គណៈកម្មាធិការតំបន់ត្រួតពិនិត្យការផ្លាស់ទីប្រជាជន[223] គ្រប់គ្រងរបបអាហារ[224] អាពាហ៍ពិពាហ៍ដោយបង្ខំ[225] និងបញ្ហាសន្តិសុខ ដូចជា ការផ្តោតលើក្រុមជាក់លាក់ណាមួយដែលគេជឿជាក់ថាជា "ខ្មាំង" រួមមាន អតីតមន្ត្រីរបប លន់ នល់ និងប្រជាជន "១៧ មេសា"[226]។

## <u>ស្រុកព្រះនេត្រព្រះ</u>

60. មានឃុំចំនួនប្រាំមួយនៅក្នុងស្រុកព្រះនេត្រព្រះ៖ ឃុំរហាល ឃុំព្រះនេត្រព្រះ ឃុំប្រាសាទ ឃុំទឹកជោរ ឃុំភ្នំលាប និងឃុំទាមកាម[227]។ អាន ម៉ោង[228] គឺជាលេខាស្រុកព្រះនេត្រព្រះ ហើយ សំ អាត[229] គឺជាអនុលេខាចាប់ពីឆ្នាំ១៩៧៥ រហូតដល់ពេលកម្មាភិបាលនិរតីបោសសម្អាតស្រុកនោះ។ ខុ គឺជាសមាជិកគណៈកម្មាធិការស្រុក[230] ចាប់តាំងពីដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបន្តនៅជាផ្នែកមួយនៃគណៈកម្មាធិការនោះ ក្រោយពេលកម្មាភិបាលនិរតីបានមកដល់[231]។ **អ៊ឹម ចែម** គឺជាលេខាស្រុកព្រះនេត្រព្រះចាប់ពីពេលដែលគាត់បានមកដល់ក្នុងពាក់កណ្តាលឆ្នាំ១៩៧៧[232] រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ[233]។ **អ៊ឹម ចែម** អះអាងថារូបគាត់តែម្នាក់គាត់ដែលត្រូវបានបញ្ជូនមកក្នុងឋានៈជាមេដឹកនាំ[234]។ កម្មាភិបាលពាយ័ព្យ រួមមាន មេឃុំក៏ត្រូវបានដកចេញ និងសម្លាប់ចោលផងដែរក្នុងអំឡុងពេលបោសសម្អាត[235]។ ក្រោយមក ស្រុកព្រះនេត្រព្រះត្រូវបានរៀបចំឡើងវិញ ហើយកម្មាភិបាលនិរតីត្រូវបានតែងតាំងឲ្យកាន់តំណែងនានា[236]។ ដោយបាននាំពួកយោធាពីភូមិភាគនិរតីមកជាមួយផងនោះ[237] **អ៊ឹម ចែម** បានដកអាវុធពួកយោធាដែលមាននៅក្នុងស្រុកនោះ[238]។

61. ក្នុងឋានៈជាលេខាស្រុក **អ៊ឹម ចែម** ជាញឹកញាប់បានធ្វើដំណើរទូទាំងស្រុកនោះ[239] រួមមានការទៅទស្សនាការដ្ឋាននានា[240] និងមន្ទីរសន្តិសុខ[241]។ គម្រោងការងារនៅក្នុងស្រុកនោះ ត្រូវបានអនុម័តដោយថ្នាក់លើ[242]។ **អ៊ឹម ចែម** បានធ្វើការប្រជុំជាប្រចាំ[243] រួមមាន នៅក្នុងឃុំ[244] តាមការដ្ឋាន[245] និងតាមមន្ទីរ

សន្តិសុខ[246]។ ការប្រជុំត្រូវបានប្រើប្រាស់ដើម្បីអនុវត្តការគ្រប់គ្រង និងផ្សព្វផ្សាយអំពីគោលនយោបាយនានារបស់ ប.ក.ក ដូចជា ត្រូវធ្វើការងារឲ្យខ្លាំង[247] និងការកំណត់អត្តសញ្ញាណ "ខ្មាំង"[248]។ គណៈកម្មាធិការស្រុកបានរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ[249] និងទទួលខុសត្រូវផ្នែកសន្តិសុខនៅក្នុងស្រុកនោះ ដែលរួមទាំង ការផ្ដោតលើក្រុមជាក់លាក់ណាមួយដែលគេជឿជាក់ថាជា "គិញ" និងជា "ខ្មាំងផ្ទៃក្នុង" ដោយរួមទាំង ជនជាតិវៀតណាម ខ្មែរក្រោម អតីតមន្ត្រីរបប លន់ នល់ និងប្រជាជន "១៧ មេសា"[250]។

## គ. ប្រព័ន្ធទំនាក់ទំនងរបស់ បកក

62. បកក បានបង្កើតប្រព័ន្ធមួយដែលក្នុងនោះថ្នាក់ក្រោមរាយការណ៍ជាប្រចាំទៅថ្នាក់លើអំពី "ស្ថានភាព" និង "ការងារ" របស់ពួកគេ[251]។ ប្រព័ន្ធទំនាក់ទំនងអនុញ្ញាតឲ្យគណៈអចិន្ត្រៃយ៍ចេញសេចក្ដីណែនាំទៅកាន់ថ្នាក់ក្រោម បានផ្ដល់លទ្ធភាពឲ្យគណៈអចិន្ត្រៃយ៍រក្សាការត្រួតពិនិត្យដ៏តឹងរ៉ឹងលើការអនុវត្តគោលនយោបាយរបស់បក្ស។ បកក បានប្រើប្រាស់មធ្យោបាយជាច្រើនដើម្បីរក្សាការទំនាក់ទំនង ដោយរួមមានប្រព័ន្ធវិទ្យុទាក់ទងទូទាំងប្រទេស ទូរស័ព្ទ ទូរលេខ និងនីរសា[252]។

63. មជ្ឈិមបក្សបានផ្លាស់ប្ដូរព័ត៌មានទៅវិញទៅមកជាមួយនឹងភូមិភាគនានាតាមពេលវេលា ដែលបានគ្រោងទុកដ៏ទាងទាត់ ដោយប្រើការបញ្ជូនសារតាមវិទ្យុទាក់ទង[253]។ មជ្ឈិមបានទំនាក់ទំនងទៅកាន់ បណ្ដាស្រុកតាមរយៈភូមិភាគ និងតំបន់[254]។ ការប្រជុំនានាត្រូវបានធ្វើឡើងនៅថ្នាក់តំបន់ និងថ្នាក់ស្រុក ដើម្បីផ្សព្វផ្សាយសេចក្ដីណែនាំរបស់មជ្ឈិមបក្ស ដែលបន្ទាប់មកត្រូវបានបញ្ជូនទៅកាន់ប្រធានឃុំ និងប្រធានសហករណ៍[255]។ ការទំនាក់ទំនងនៅថ្នាក់ឃុំ និងភូមិ ត្រូវបានបញ្ជូនដោយនីរសា ដែលនាំសំបុត្រ[256] ឬបញ្ជូនសារផ្ទាល់មាត់[257]។ ការទំនាក់ទំនងពីស្រុកទៅស្រុក ពីតំបន់ទៅតំបន់ ឬពីភូមិភាគទៅភូមិភាគត្រូវបានហាមឃាត់ ដោយរាល់ការទំនាក់ទំនងទាំងអស់តម្រូវឲ្យឆ្លងកាត់មជ្ឈិម[258]។

64. មេដឹកនាំ បកក ក៏បានប្រើប្រាស់ឯកសារជាលាយលក្ខណ៍អក្សរជាប្រចាំផងដែរ ដូចជាសំបុត្រ អនុស្សរណៈ របាយការណ៍ សេចក្ដីណែនាំគោលនយោបាយ និងការបោះពុម្ពផ្សាយផ្លូវការដើម្បីផ្សព្វផ្សាយសេចក្ដីណែនាំ និងគោលនយោបាយ[259]។ ទស្សនាវដ្ដី 'ទង់បដិវត្តន៍' និង 'យុវជនយុវនារីបដិវត្តន៍' គឺជាប្រភពផ្លូវការសម្រាប់ការផ្សព្វផ្សាយផ្ទៃក្នុងអំពីគោលនយោបាយរបស់ បកក[260]។ សៀវភៅទាំងអស់នេះត្រូវបានចែកចាយទៅកាន់សមាជិកបក្សនៅថ្នាក់ភូមិភាគ តំបន់ ស្រុក និងឃុំ[261] និងត្រូវ

បានអាននៅអំឡុងពេលប្រជុំ និងវគ្គសិក្សានានា[262]។

## ការទំនាក់ទំនងនៅក្នុងភូមិភាគនិរតី (១៩៧៦-១៩៧៧)

## ការប្រជុំ និងវគ្គឃោសនាក្នុងតំបន់១៣ និងភូមិភាគនិរតី

65. មេដឹកនាំតំបន់ ១៣ បានជួបជាមួយកម្មាភិបាលថ្នាក់ស្រុកពីរទៅបីដងក្នុងមួយខែ[263]។ មេដឹកនាំតំបន់ រួមទាំង **អ៊ឹម ចែម** បាននិយាយនៅក្នុងការប្រជុំទាំងនេះអំពីបញ្ហានានា ដូចជា ការកំណត់អត្តសញ្ញាណ 'ខ្មាំង' ផ្ទៃក្នុង[264]។ តំបន់ក៏បានធ្វើការប្រជុំប្រចាំឆ្នាំ ដែលមេដឹកនាំថ្នាក់ស្រុកទាំងអស់បានចូលរួម[265]។ ការប្រជុំទាំងអស់នេះត្រូវបានប្រើប្រាស់ដើម្បីណែនាំមេដឹកនាំងនោះអំពីបញ្ហាដ៏ទូលំទូលាយ រួមមាន នយោបាយ និងកិច្ចការយោធា[266]។ លេខាភូមិភាគនិរតី តាម៉ុក ដែលជាសមាជិក គណៈអចិន្ត្រៃយ៍ របស់ បកក ក៏បានជួបជាមួយមេដឹកនាំនានា ដោយរួមទាំង **អ៊ឹម ចែម** ដើម្បីផ្តល់ការណែនាំស្តីពីការ រៀបចំថ្នាក់ក្រោម[267]។

66. ការប្រជុំថ្នាក់ស្រុកត្រូវបានធ្វើឡើងចំនួនពីរ ឬ បីដងក្នុងមួយខែ ដើម្បីណែនាំមេដឹកនាំថ្នាក់ឃុំអំពីគោល នយោបាយ បកក[268]។ មេដឹកនាំឃុំ និងសហករណ៍[269] ត្រូវបានណែនាំអំពីប្រធានបទនានា ដូចជា ផែនការការងារ[270] ការផលិតស្បៀង[271] និងការបោសសម្អាត "ខ្មាំង" ផ្ទៃក្នុង[272]។ បញ្ហានានាពីថ្នាក់ ក្រោមទាំងនេះក៏ត្រូវបានបញ្ជូនទៅថ្នាក់ស្រុកផងដែរ[273]។

67. វគ្គសិក្សានានាត្រូវបានធ្វើឡើងជាប្រចាំនៅតាមឃុំ ភូមិ និងការដ្ឋាន ដោយមេដឹកនាំដូចជា **អ៊ឹម ចែម**[274] ដើម្បីណែនាំ និង បញ្ចូលមនោគមវិជ្ជាដល់កម្មករ[275]។ អ្នកចូលរួមត្រូវបានរំលឹកឲ្យខិតខំធ្វើការ ដើម្បី សម្រេចឲ្យបាននូវគោលដៅរបស់ បកក និងថា "ជនក្បត់" ដែលបានក្បត់ "អង្គការ" នឹងត្រូវសម្លាប់[276] ។

## ការរាយការណ៍តាមថ្នាក់នានារបស់តំបន់ ១៣ ទៅកាន់មជ្ឈិមបក្ស

68. ភូមិភាគនិរតីបានធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងប្រចាំខែទៅកាន់មន្ទីរ ៨៧០ ផ្អែកលើព័ត៌មានបញ្ជូន មកពីថ្នាក់ក្រោមបំផុតទៅលើ[277]។ ថ្នាក់ក្រោមរាយការណ៍អំពីសន្តិសុខនៅក្នុងស្រុក ដូចជាការចាប់ "ខ្មាំង"[278] និងផ្តល់ព័ត៌មានលម្អិតអំពីការផលិតស្រូវ រួមមានចំនួនហិកតាដែលត្រូវដាំដុះនៅក្នុងស្រុក

នីមួយៗ[279]។ ភូមិភាគនិរតីបានបញ្ជូនសារ និងសេចក្តីណែនាំទៅកាន់តំបន់នានាតាមរយៈទូរលេខ[280]។ ទូរលេខត្រូវបានដាក់លេខកូដ និងបញ្ជូនទៅតាមរយៈអ្នកប្រតិបត្តិទូរលេខពិសេស[281]។ ទូរលេខទាំងនោះបន្ទាប់មកត្រូវបានបញ្ជូនជាសំបុត្រដោយនីរសាតាមរយៈកង់ ឬ សេះ[282]។ លិខិតទាំងនេះជាទូទៅមានព័ត៌មានដែលមេដឹកនាំមិនចង់រាយការណ៍តាមរយៈវិទ្យុទាក់ទង[283]។

69. តំបន់ ១៣ បានទទួលរបាយការណ៍ជាប្រចាំពីគណៈស្រុក ដែលត្រូវបានបញ្ជូនទៅកាន់ភូមិភាគនិរតី[284]។ មេដឹកនាំតំបន់ក៏បានបញ្ជូនរបាយការណ៍ទាំងនោះទៅកាន់លេខាភូមិភាគនិរតី តាម៉ុក អំពីមន្ទីរសន្តិសុខនានានៅក្នុងតំបន់ ១៣[285]។ គណៈស្រុកផ្តល់របាយការណ៍ទៅតំបន់ ១៣[286] ក្នុងទម្រង់ជាទូរលេខដែលបញ្ជូនដោយនីរសា ឬ តារមយៈវិទ្យុទាក់ទង[287]។ មានតែនីរសាដែលទទួលបានការអនុញ្ញាតប៉ុណ្ណោះ បញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរពីស្រុកទៅកាន់តំបន់[288]។ របាយការណ៍ទាំងនេះមានព័ត៌មានពីថ្នាក់ក្រោមអំពី "ខ្មាំង" ផ្ទៃក្នុង និងខាងក្រៅ ផលិតកម្មស្បៀង ផែនការការងារ និងលក្ខខណ្ឌរស់នៅរបស់កម្មករ[289]។

70. មេដឹកនាំឃុំត្រូវផ្តល់របាយការណ៍លម្អិតជាប្រចាំទៅកាន់ថ្នាក់ស្រុកតាមលំដាប់[290]។ របាយការណ៍ទាំងនេះត្រូវបានបញ្ជូនទៅមេដឹកនាំថ្នាក់ស្រុកតាមរយៈនីរសានៅទូទាំងតំបន់ ១៣[291]។ មេដឹកនាំឃុំក៏រៀបចំបញ្ជីមាន ឈ្មោះ អាយុ និងព័ត៌មានលម្អិតអំពីគ្រួសាររបស់អ្នកដែលរស់នៅក្នុងឃុំរាងរាល់ពីរ ឬ បីខែម្តង[292]។ បញ្ជីទាំងនោះត្រូវបានប្រើនៅពេលអនុវត្តការផ្លាស់ទីប្រជាជនដោយបង្ខំទៅកាន់ឃុំផ្សេងៗ[293]។ ប្រធានភូមិក៏បានធ្វើប្រវត្តិរូបជាលាយលក្ខណ៍អក្ខរ ដែលមានព័ត៌មានអំពីប្រវត្តិរូបរបស់ប្រជាជន និងជាតិពន្ធុ[294] ដែលត្រូវបានបញ្ជូនទៅថ្នាក់ឃុំ និងថ្នាក់ស្រុក[295]។ ផ្អែកលើព័ត៌មាននេះ គេរៀបចំបញ្ជីបន្ថែមទៀត[296] អំពីអ្នកដែលត្រូវ "បោសសម្អាតទាំងស្រុង" ដោយកំណត់ឈ្មោះអ្នកទាំងឡាយដែលស្ថិតនៅក្នុងក្រុមគោលដៅ ដូចជា ជនជាតិវៀតណាម ខ្មែរក្រោម និងអ្នកដទៃផ្សេងទៀត ដែលគេជឿជាក់ថាជា "ខ្មាំង"[297]។ អាពាហ៍ពិពាហ៍ដោយបង្ខំក៏ត្រូវបានរាយការណ៍ពីឃុំទៅកាន់តំបន់ ១៣ ហើយមេដឹកនាំនៅថ្នាក់ក្រោមបានបញ្ជូនជាប្រចាំនូវបញ្ជីឈ្មោះគូស្រករដែលត្រូវរៀបអាពាហ៍ពិពាហ៍[298]។

## ការទំនាក់ទំនងនៅក្នុងភូមិភាគពាយ័ព្យ (១៩៧៧-១៩៧៩)

## ការប្រជុំ និងវគ្គឃោសនានៅក្នុងតំបន់៥ និងភូមិភាគពាយ័ព្យ

71. មេដឹកនាំភូមិភាគពាយ័ព្យបានចូលរួមក្នុងកិច្ចប្រជុំធំៗជាមួយនឹងកម្មាភិបាលថ្នាក់ក្រោម ដើម្បីណែនាំពួកគេអំពីគោលនយោបាយ និងមនោគមវិជ្ជារបស់ បកក[299]។ មេដឹកនាំភូមិភាគក៏បានណែនាំថ្នាក់ក្រោមអំពីផែនការការងារផងដែរ[300]។ ក្នុងអំឡុងពេលបោសសម្អាត ការប្រជុំបែបទាំងនោះត្រូវបានប្រើដើម្បីចោទប្រកាន់ជាសាធារណៈចំពោះកម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបានបោសសម្អាតថាជា "ជនក្បត់"[301]។

72. មេដឹកនាំតំបន់៥ បានផ្តល់ការណែនាំអំពីគោលនយោបាយ បកក ទៅកាន់កម្មាភិបាលថ្នាក់ស្រុកនៅពេលប្រជុំ[302] ដោយសង្កត់ធ្ងន់លើបញ្ហានានា ដូចជា គម្រោងការងារ និងការបង្កើនផលិតកម្មស្បៀង[303]។ ការប្រជុំទាំងនោះត្រូវបានប្រើផងដែរដោយមេដឹកនាំតំបន់ ដើម្បីដកកម្មាភិបាលថ្នាក់ក្រោមពីតួនាទីរបស់ពួកគេក្នុងអំឡុងពេលនៃការបោសសម្អាត[304]។ ស្ត្រីជារើយៗត្រូវបានហៅឱ្យចូលរួមក្នុងការប្រជុំទាំងនោះជាមួយនឹងមេដឹកនាំតំបន់ ដូចជា **អ៊ឹម ចែម** ដើម្បីបង្ខំឱ្យពួកគេឱ្យរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[305]។

73. គណៈស្រុកបានធ្វើការប្រជុំជាមួយនឹងមេដឹកនាំសហករណ៍ប្រមាណជាបីដងក្នុងមួយខែ[306]។ នៅក្នុងកិច្ចប្រជុំទាំងនេះ ប្រធានសហករណ៍ និងប្រធានឃុំបានទទួលការណែនាំពី **អ៊ឹម ចែម** ឱ្យធ្វើការចាប់ខ្លួន[307]។ គាត់ក៏បានចេញការណែនាំអំពីការផលិតកសិផល និងការដឹកប្រឡាយផងដែរ[308]។ **អ៊ឹម ចែម** ក៏បានដឹកនាំកម្មាភិបាលក្នុងវគ្គសិក្សានៅទូទាំងតំបន់៥ អំពីការរៀបចំកម្មាភិបាលថ្នាក់ក្រោមផងដែរ[309]។

74. មេដឹកនាំឃុំបានធ្វើការប្រជុំមួយដងជារៀងរាល់ខែ[310] ហើយការប្រជុំធំៗដែលបានចូលរួមដោយប្រជាជនទាំងអស់នៅក្នុងឃុំ ត្រូវបានធ្វើឡើងយូរៗម្តង[311]។ **អ៊ឹម ចែម** បានថ្លែងជាប្រចាំនៅក្នុងកិច្ចប្រជុំទាំងនោះ[312] និងនៅការដ្ឋានជុំវិញស្រុកព្រះនេត្រព្រះ[313]។ កម្មករត្រូវបានណែនាំឱ្យលុបបំបាត់ "ខ្មាំង" ផ្ទៃក្នុង[314] ត្រូវបានព្រមានឱ្យគោរពតាមគោលនយោបាយរបស់ បកក[315] និងត្រូវបានប្រាប់ឱ្យខិតខំធ្វើការ[316]។ ទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យជាច្រើនច្បាប់ ដែលមានរៀបរាប់អំពីការឃោសនារបស់បក្ស ត្រូវបានផ្សព្វផ្សាយរៀងរាល់ប្រាំមួយខែម្តង[317]។ ទស្សនាវដ្តី បកក ត្រូវបានចែកចាយទៅកាន់ថ្នាក់ស្រុកជាមុន បន្ទាប់មកទៅកាន់ភូមិនៅពេលប្រជុំ[318]។

## ការរាយការណ៍តាមថ្នាក់នានានៃតំបន់៥ ទៅកាន់មជ្ឈិមបក្ស

75. ផ្អែកតាមរបាយការណ៍នានាពីថ្នាក់ក្រោម ភូមិភាគពាយ័ព្យបានធ្វើរបាយការណ៍ប្រចាំខែទៅកាន់ បកក[319]។ មេដឹកនាំភូមិភាគពាយ័ព្យក៏បានស្នើសុំដំបូន្មានពីមជ្ឈិមបក្សផងដែរ។ ឧទាហរណ៍ លេខាភូមិភាគពាយ័ព្យ រស់ ញឹម បានស្នើសុំការណែនាំអំពីវិធីដោះស្រាយ "ខ្មាំង" ដែលចាប់បាន[320] និងបានធ្វើរបាយការណ៍មួយទៀតដោយស្នើសុំថា "ស្នើអង្គការមានមតិ សូមណែនាំថែម"[321]។

76. តំបន់៥ បានបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំសប្តាហ៍ទៅភូមិភាគពាយ័ព្យ កត់ត្រាអំពីបញ្ហានានាដូចជាចំនួន "ខ្មាំង" ខាងក្នុង ដែលត្រូវបានបោសសម្អាត "អស់ទាំងស្រុង" ពីឃុំ និង ភូមិ[322]។ របាយការណ៍ទាំងនោះក៏រៀបរាប់លម្អិតផងដែរ អំពីវិធីដែលថ្នាក់ឃុំ និងថ្នាក់ស្រុកគោរពតាមគោលនយោបាយ បកក[323] ដូចជាព័ត៌មានអំពី "ការបញ្ចូលមនោគមវិជ្ជា" កម្មករនៅពេលប្រជុំ[324] និងធ្វើបច្ចុប្បន្នភាពអំពីការផលិតស្បៀង[325]។

77. មេដឹកនាំស្រុកបានរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរជាប្រចាំ ដើម្បីផ្ញើរទៅតំបន់៥[326]។ របាយការណ៍ទាំងនោះរួមបញ្ចូលព័ត៌មានដែលបានទទួលមកពីប្រធានសហករណ៍ និង ប្រធានឃុំ[327]។ បន្ថែមលើរបាយការណ៍ពីថ្នាក់ក្រោម **អ៊ឹម ចែម** បានទទួលបញ្ជីចំនួនប្រជាជននៅពេលដែលគាត់បានមកដល់ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ[328]។ គាត់ក៏ត្រូវបានផ្តល់ជូននូវប្រវត្តិរូប[329] ដែលមានព័ត៌មានអំពីក្រុមគោលដៅ ដូចជាអ្នកដែលមានសញ្ជាតិវៀតណាម[330]។

78. ក្រោមពេលដែល **អ៊ឹម ចែម** និង កម្មាភិបាលភូមិភាគនិរតីបានមកដល់ មេដឹកនាំឃុំត្រូវបានណែនាំឲ្យពិនិត្យប្រវត្តិរូបប្រជាជន និងរាយការណ៍អំពីអ្នកដែលត្រូវបានសង្ស័យថាជា "ខ្មាំង"[331]។ កម្មករ និងអ្នកភូមិត្រូវបានណែនាំឲ្យរាយការណ៍អំពី សេ អ៊ី អា កា ហ្សេ បេ និង ខ្សែបណ្តាញវៀតណាម ,[332]។ ប្រធានក្រុមបានរៀបចំរបាយការណ៍អំពីអ្នកដែលត្រូវបានសង្ស័យថាជា "ខ្មាំង"[333] និងបញ្ជូនរបាយការណ៍ទាំងនោះទៅថ្នាក់ស្រុក[334]។

## ឃ. ផែនការឧក្រិដ្ឋកម្មរួម

79. **អ៊ឹម ចែម** ត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយ ដូចបានចោទប្រកាន់នៅក្នុងសេចក្តីសន្និដ្ឋាននេះ តាមរយៈសហឧក្រិដ្ឋកម្មរួមចំនួនពីរ មួយនៅក្នុងភូមិភាគនិរតី និងមួយនៅក្នុងភូមិភាគពា

យ័ព្យ។ ផែនការរួមនៃ JCE ទាំងពីរ គឺត្រូវលុបបំបាត់អ្នកដែលគេគិតថាជាខ្មាំង និងអ្នកប្រឆាំងនឹងថ្នាក់ដឹកនាំ បកក និង អនុវត្តគោលនយោបាយនិយមកសិកម្ម សង្គមកិច្ច និងសេដ្ឋកិច្ចដាច់ខាតរបស់បក្សតាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មនានា។

80. ដូចមានរៀបរាប់យ៉ាងលម្អិតខាងក្រោម ការកំណត់គោលដៅរបស់ បកក ចំពោះអ្នកដែលគិតថាប្រឆាំងនឹងខ្លួន ស្ថិតក្នុងទម្រង់ផ្សេងៗដូចជា ការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ "ខ្មាំង" ដែលគេសន្មតក្នុងប្រភេទខុសៗគ្នាជាច្រើន ដែលត្រូវបានគេសម្លាប់ភ្លាមៗក្រៅប្រព័ន្ធច្បាប់ ឬ ត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខនានា។ ការអនុវត្តគោលនយោបាយនិយមកសិកម្ម សង្គមកិច្ច និងសេដ្ឋកិច្ចដាច់ខាតរបស់ បកក មានការពាក់ព័ន្ធទៅនឹងការធ្វើការផ្លាស់ទីលំនៅជនស៊ីវិលដោយបង្ខំ ទៅកាន់ការដ្ឋាន និងសហករណ៍នានានៅតាមជនបទ នៅក្រោមលក្ខខណ្ឌដែលស្មើទៅនឹងការដាក់ឲ្យទៅជាទាសករ ក៏ដូចជាការបង្ខំគូរស្រកឲ្យរៀបការ ដើម្បីបង្កើនចំនួនប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ។

## ការលុបបំបាត់ខ្មាំង និងអ្នកប្រឆាំងនឹងការដឹកនាំរបស់ បកក

81. ដោយចាប់ផ្តើមមានតាំងពីសមាជបក្សលើកទី១ ក្នុងឆ្នាំ១៩៦០ មក ខ្មែរក្រហមបានតាំងចិត្តប្រើប្រាស់ហិង្សាដោយអាវុធ ដើម្បីកម្ទេចខ្មាំង "ខ្មាំង" ហើយរយៈពេលក្រោយមកបានអនុវត្តគោលនយោបាយនេះ មិនត្រឹមតែទៅលើគូរសត្រូវយោធាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តទៅលើជនស៊ីវិលដែលគេមើលឃើញថាជាការគំរាមកំហែងខាងនយោបាយដ៏មានសក្តានុពលផងដែរ[335]។ លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា បានដាស់តឿនសមាជិករបស់ខ្លួន ឲ្យមានការប្រុងប្រយ័ត្នជាប់ជានិច្ចប្រឆាំងនឹង "ខ្មាំង" និងការការពារកម្លាំងបដិវត្តន៍ ទាំងខាងក្នុង និងខាងក្រៅបក្ស[336]។ មាត្រា១០ នៃរដ្ឋធម្មនុញ្ញ កម្ពុជាប្រជាធិបតេយ្យ ចែងថា "សកម្មភាពគ្រោះថ្នាក់" ត្រូវតែ "ផ្តន្ទាទោសកំរិតខ្ពស់បំផុត" និងថា "ចំពោះប្រភេទបទល្មើសផ្សេងទៀត" ត្រូវអប់រំកសាង[337]។

82. បកក មិនបានកំណត់និយមន័យថា តើនរណាជា "ខ្មាំង" ទេ ប៉ុន្តែបានកំណត់គោលដៅទៅលើបុគ្គល ឬក្រុមដែលគេចាត់ទុកថា ប្រឆាំង ឬ ជាការគំរាមកំហែង ដល់របបកម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះរួមមាន៖ អតីតមន្ត្រីរបប លន់ នល់[338] ពុទ្ធសាសនិកជន[339] ជនជាតិវៀតណាម[340] ខ្មែរក្រោម[341]

ចាម[342] អ្នកដែលគេចាត់ទុកថាជា “គិញ” របស់ សេ.អ៊ី.អា និង កា.ហ្សេ៊.បេ ហើយនិងជនដែលស្ថិតក្នុងវណ្ណៈ “គហបតី” “សក្តិភូមិ” ឬ “នាយទុន”[343]។ បកក បានបង្កឲ្យមាន “ការស្អប់ខ្ពើមប្រឆាំងខ្លាំង”[344] និងបានសង្កត់ធ្ងន់ជាប្រចាំអំពីតម្រូវការចាំបាច់ដើម្បីថែរក្សាឲ្យមាន “ការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់”[345]។

83. បកក បានលុបបំបាត់រចនាសម្ព័ន្ធតុលាការ ឬ ច្បាប់ទាំងអស់[346] និងបានអនុវត្តគោលនយោបាយ នៃការកំណត់គោលដៅជនដែលគេគិតថាជាអ្នកប្រឆាំងនឹងខ្លួន តាមរយៈការសម្លាប់ និងការចាប់ខ្លួនភ្លាមៗក្រៅដំណើរការច្បាប់ និងការបង្កើតបណ្តាញមន្ទីរសន្តិសុខយ៉ាងធំធេង[347]។ សេចក្តីសម្រេចមួយក្នុងឆ្នាំ១៩៧៦ របស់គណៈមជ្ឈិម បាន ផ្តល់ឲ្យគណៈភូមិភាគជាក់លាក់ នូវ “សិទ្ធិកម្ទេចទាំងនៅក្នុងជួរ និងក្រៅជួរ”[348]។ ពាក្យថា “កម្ទេច” សំដៅទៅលើការសម្លាប់ក្រៅតុលាការ[349]។ នៅតាមតំបន់ខ្លះ សេចក្តីសម្រេចដើម្បី “កម្ទេច” ត្រូវបានធ្វើប្រតិភូកម្មអំណាចបន្តទៅឲ្យតំបន់[350] និងស្រុក[351]។ តាមបណ្តាមន្ទីរសន្តិសុខនៅទូទាំងប្រទេស មានមនុស្សជាច្រើនត្រូវបានគេឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ចោល[352]។ ការធ្វើទារុណកម្ម និងការសួរចម្លើយចំពោះអ្នកដែលគេសន្មតថាជា “ខ្មាំង” ជាញឹកញាប់មានការពាក់ព័ន្ធនឹងចម្លើយសារភាពដោយការបង្ខិតបង្ខំដែលឆ្លើយដាក់អ្នកដទៃទៀត - ដែលនេះបង្កើតឲ្យមានវដ្តនៃការចាប់ខ្លួន និងការសម្លាប់[353]។

84. គោលនយោបាយនៃ “ការកម្ទេចខ្មាំង” និង ការចាប់ខ្លួន “សមាសភាពមិនល្អ” ត្រូវបានគេផ្សព្វផ្សាយតាមរយៈការបោះពុម្ពផ្សាយថ្នាក់ជាតិរបស់ បកក[354] ការផ្សាយតាមវិទ្យុ បកក[355] និងការប្រជុំរបស់ បកក នៅគ្រប់កម្រិតថ្នាក់ទាំងអស់[356]។ ពាក្យថា “ការកម្ទេចខ្មាំង” ត្រូវបានគេកត់ត្រាទុកយ៉ាងស៊ីចង្វាក់គ្នានៅក្នុង ទស្សនាវដ្តី “ទង់បដិវត្ត” និង ទស្សនាវដ្តី “យុវជន យុវនារី បដិវត្ត” នៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៨[357]។ ទូរលេខនានា រវាងថ្នាក់ខុសៗគ្នានៃឋានានុក្រម បកក ក៏បានធ្វើរបាយការណ៍អំពី “សកម្មភាពខ្មាំង” និងសេចក្តីលម្អិតអំពីមនុស្សដែលត្រូវបានសម្លាប់ចោលផងដែរ[358]។

85. ក្នុងឆ្នាំ១៩៧៧ ការលុបបំបាត់ “ជនក្បត់” និង “ខ្មាំង” របស់ បកក ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ[359] កាន់តែមានសភាពខ្លាំងឡើងៗ[360]។ មជ្ឈិមបានជួយសម្របសម្រួលក្នុងការបោសសម្អាតកម្មាភិបាល បកក[361]ជាទ្រង់ទ្រាយធំ រួមទាំង ការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ ដោយកម្មាភិបាលភូមិភាគនិរតីផងដែរ[362]។ ខណៈដែលសង្គ្រាមជាមួយវៀតណាមកាន់តែមានសភាពខ្លាំងឡើងៗ បក

ក      ក៏កាន់តែបើកការវាយប្រហារខ្លាំងឡើងថែមទៀតដែរទៅលើប្រជាជនវៀតណាមដែលនៅសេសសល់នៅកម្ពុជា[363] និងអ្នកណាដែលជាប់ពាក់ព័ន្ធនឹងវៀតណាម[364] រួមទាំងខ្មែរក្រោមផង[365]។ ទស្សនាវដ្តី "ទង់បដិវត្ត" ឆ្នាំ១៩៧៨ បានបញ្ជាឱ្យបក្សគ្រប់ថ្នាក់ "ត្រូវប្រកាន់នាទីដឹកនាំ កងទ័ព និងប្រជាជនវាយខ្មាំង [...] ទាំងនេះ បោសសម្អាតខ្មាំងទាំងនេះ បោសហើយ បោសទៀត បោសហើយ បោសទៀត គ្មានឈប់ឈរ ដើម្បីឱ្យកម្លាំងបក្សរបស់យើងស្អាត កម្លាំងដឹកនាំរបស់យើងគ្រប់ថ្នាក់ គ្រប់ផ្នែក និងគ្រប់ពេលវេលាស្អាត"[366]។

## គោលនយោបាយកសិកម្ម សេដ្ឋកិច្ច និងសង្គមកិច្ច

## សហករណ៍ និងការដ្ឋាន

86. បកក បានស្វែងរកដើម្បីបង្កើតឱ្យបានយ៉ាងឆាប់រហ័សនូវរដ្ឋសង្គមនិយមមួយ ដែលនៅក្នុងរដ្ឋបែបនេះ ប្រជាជនទាំងអស់ធ្វើការជាសមូហភាពនៅក្នុងវិស័យកសិកម្ម និងឧស្សាហ៍កម្ម ដើម្បីធានាកម្លាំងសេដ្ឋកិច្ចរបស់ បកក និងភាពឧបត្ថម្ភខ្លួនបាន[367]។ ការអនុវត្តគោលនយោបាយនេះ បាននាំឱ្យមានការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋាននានា ដែលនៅតាមសហករណ៍ និងការដ្ឋានទាំងនេះ ប្រជាជនត្រូវបានគេបង្ខំឱ្យរស់នៅ និង ធ្វើការងារក្រោមលក្ខខណ្ឌផ្សេងៗដែលមានតម្លៃស្មើនឹងការធ្វើឱ្យទៅជាទាសករ[368]។

87. ចាប់ពីឆ្នាំ១៩៧២មក បកក បានបង្កើតសហករណ៍ និងការដ្ឋានជាច្រើននៅតាមតំបន់នានាដែលពួកគេបានត្រួតត្រា[369]។ លុយកាក់ និងផ្សារឯកជន ត្រូវបានលុបបំបាត់[370]។ ក្នុងឆ្នាំ១៩៧៣ បកក បានប្រកាន់យកគោលនយោបាយផ្លាស់ទីប្រជាជនចេញពីទីប្រជុំដោយបង្ខិតបង្ខំ ដើម្បីឱ្យទៅធ្វើការនៅតាមសហករណ៍ និងការដ្ឋាននៅជនបទ[371]។ គោលនយោបាយនេះមានគោលបំណងផ្នែកសេដ្ឋកិច្ច នយោបាយ និងមនោគមវិជ្ជា៖ (i) ដើម្បីវាយប្រហារលើអំណាចសេដ្ឋកិច្ចរបស់ "ពួកសក្តិភូមិ និងម្ចាស់ដី"[372] (ii) ដើម្បីបំបែក តាមដាន ត្រួតត្រា និងសម្លាប់អ្នកដែលប្រឆាំងនឹង បកក និងបដិវត្តន៍[373] និង (iii) ដើម្បីបង្កើនផលិតផលកសិកម្មឱ្យបានឆាប់រហ័ស[374]។

88. បកក បានបង្កើតសហករណ៍ និងការដ្ឋាននៅទូទាំងប្រទេសនៅពេលឡើងកាន់អំណាច[375]។ ការណ៍ទាំងនេះ រួមមាន សហករណ៍ស្រែចំការ ការដ្ឋានសាងសង់ប្រព័ន្ធស្រោចស្រព[376] ទំនប់[377] វាលយន្ត

ហោះ[378] ស្រែអំបិល និងកន្លែងវាយថ្ម[379]។ កងចល័តត្រូវបានបង្កើតឡើងដើម្បីធ្វើការនៅតាមការដ្ឋានជាច្រើន និងសហករណ៍កសិកម្ម[380]។ គោលនយោបាយរបស់ បកក ពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋាន[381] គឺត្រូវបានផ្សព្វផ្សាយតាមសារាចរណែនាំរបស់ បកក[382] ការប្រជុំតាមគ្រប់លំដាប់ថ្នាក់[383] ការបោះពុម្ពផ្សាយ[384] និងការផ្សាយសំឡេងតាមវិទ្យុ បកក[385]។ សហករណ៍ និងការដ្ឋានត្រូវបានតម្រូវឱ្យទទួលយករចនាសម្ព័ន្ធ និង វិធីសាស្ត្រនៃការប្រតិបត្តិមួយដែលស្រដៀងគ្នានៅទូទាំងប្រទេស[386]។ បកក បានទទួលស្គាល់ថាមានគោលនយោបាយបង្ខិតបង្ខំ[387] ដោយបានថ្លែងថា ទិន្នផលត្រូវតែសម្រេចឱ្យបានដោយមធ្យោបាយចាំបាច់ណាក៏ដោយ[388] និងពង្រាយកងទ័ពដើម្បីឱ្យអនុវត្តវា[389]។ បកក បានកំណត់កូតាទិន្នផលដែលហួសពីការពិត ដូចជា ការតម្រូវឱ្យផលិតស្រូវឱ្យបាន៣តោន ក្នុងមួយហិកតា ជាដើម[390]។

89. ការជម្លៀសប្រជាជនដោយបង្ខំបានធ្វើឱ្យចំនួនប្រជាជននៅតាមសហករណ៍ និង ការដ្ឋានកើនឡើងយ៉ាងយ៉ាងរហ័ស[391]។ ប្រជាជនត្រូវបានបង្ខំឱ្យរស់នៅ និង ធ្វើការនៅក្នុងលក្ខខណ្ឌអមនុស្សធម៌។ ការណ៍នេះរួមមាន៖ កូតាការងារ និង ពេលម៉ោងអមនុស្សធម៌ ម្ហូបអាហារមិនគ្រប់គ្រាន់ សមាជិកគ្រួសារបែកបាក់គ្នា កង្វះអនាម័យ និងថ្នាំពេទ្យ ហើយនិង វិន័យតឹងតែង។ ពលកម្មត្រូវបានធ្វើឡើងទាំងស្រុងដោយមិនមានជំនួយពីម៉ាស៊ីន[392]។ កម្មាភិបាល បកក បានចាត់ថ្នាក់កម្មករអត់ឃ្លានដែលបានស្វែងរកអាហារ ទៅលេងគ្រួសារដោយគ្មានការអនុញ្ញាត ឬ ព្យាយាមរត់គេច ថាបានក្បត់បដិវត្ត[393]។ លក្ខខណ្ឌអមនុស្សធម៌ត្រូវបានដឹង និង បានរាយការណ៍យ៉ាងទូលំទូលាយ[394]។ កម្មាភិបាល បកក នៅតាមកម្រិតថ្នាក់ផ្សេងៗ បានចុះទៅមើលការដ្ឋាន[395] ហើយកង្វះខាតម្ហូបអាហារ និង ជំងឺនានាត្រូវបានទទួលស្គាល់នៅតាមកិច្ចប្រជុំនានា[396] តាមការបោះពុម្ពផ្សាយរបស់ បកក[397] និងត្រូវបានរាយការណ៍តាមរយៈទូរលេខ[398]។

90. ទោះជាមិនមានម្ហូបអាហារគ្រប់គ្រាន់នៅតាមការដ្ឋាន និង សហករណ៍ក៏ដោយ[399] ក៏របបកម្ពុជាប្រជាធិបតេយ្យបានអះអាងថាមានស្រូវលើសសម្រាប់នាំចេញ[400] និងមិនទទួលយកជំនួយអន្តរជាតិនោះឡើយ[401]។ ក្នុងឆ្នាំ១៩៧៧ ចំពេលដែលរបាយការណ៍ស្តីពីការអត់ឃ្លាននៅភូមិភាគពាយ័ព្យ[402] មជ្ឈិមបក្សបានបញ្ជូនកម្មាភិបាល និងកម្មកររាប់រយនាក់ពីភូមិភាគនិរតី ទៅកាន់ភូមិភាគពាយ័ព្យ[403] ដើម្បីបោសសម្អាតអ្នកដឹកនាំភូមិភាគពាយ័ព្យ[404]។ លក្ខខណ្ឌកាន់តែដុនដាបខ្លាំងជាងមុន ដោយសារមានការកាត់បន្ថយរបបអាហារដែលមានបរិមាណតិចរួចទៅហើយនោះ[405] និងការកើនឡើងនូវការចាប់ខ្លួន

និងការកាប់សម្លាប់[406]។ ដោយទីបំផុត នយោបាយរបស់ បកក ជាការឆ្លើយតបទៅនឹងការធ្វើបាបជាប្រព័ន្ធរបស់ខ្លួនទៅលើប្រជាជននោះ គឺដើម្បីស្វែងរក និងបោសសម្អាតខ្មាំងដោយភាពស្វាហាប់យ៉ាងខ្លាំង[407]

## អាពាហ៍ពិពាហ៍ដោយបង្ខំ

91. ក្រោយពេលឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ បកក បានផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួនស្តីពី "គ្រួសារជិវត្ត" ដែលត្រូវជំនួសឲ្យគ្រួសារតាមបែបប្រពៃណីរបស់ខ្មែរ[408]។ បកក បានដាស់តឿនប្រឆាំងនឹងកង្វល់ និងសតិអារម្មណ៍បុគ្គល[409] ធ្វើចំណាត់ថ្នាក់នៃទំនាក់ទំនងមិនមានត្រូវបានឯកភាពរវាងភេទផ្ទុយគ្នាថាជាការធ្វេសប្រហែសពី "បដិវត្ត"[410]។ ផ្ទុយទៅវិញ ចំណងគ្រួសារត្រូវផ្តោតទៅលើការបង្កើតកូន[411]។

92. បកក បានស្វែងរកនូវការបង្កើនចំនួនប្រជាជនកម្ពុជាឲ្យបានឆាប់រហ័ស - ដើម្បីធ្វើជាយោធាការពារប្រទេសពី "ខ្មាំង" និងកម្មករឲ្យបានច្រើនទៀត ដើម្បីកសាងសេដ្ឋកិច្ច[412]។ នៅខែមករា ឆ្នាំ១៩៧៧ បកក បានប្រកាសថា កម្ពុជាប្រជាធិបតេយ្យត្រូវការមនុស្សពី ១៥ ទៅ ២០ លាននាក់ ដើម្បីឲ្យត្រូវទៅនឹងតម្រូវការដី ក្នុងរយៈពេលពីប្រាំ ទៅ ដប់ឆ្នាំ[413]។ ប៉ុល ពត ខ្លួនគាត់ផ្ទាល់ បានពន្យល់ថាគោលដៅនេះត្រូវតែសម្រេចឲ្យបានតាមរយៈការរៀបចំអាពាហ៍ពិពាហ៍[414]។

93. បកក គ្រប់គ្រងការកសាងគ្រួសារដោយការបង្ខំគូស្រករឲ្យរៀបអាពាហ៍ពិពាហ៍[415] និងដាក់កម្រិតលើផ្នែកសីលធម៌យ៉ាងតឹងតែង នៅគ្រប់ទំនាក់ទំនងដទៃទៀតទាំងអស់[416]។ គូស្វាមីភរិយាត្រូវបានជ្រើស-វត្តិស្អាតល្អ និងគូស្រករនានាត្រូវតែមានវណ្ណៈនយោបាយដូចគ្នារើស ដោយមានប្រ[417]។ ជាញឹកញាប់បុគ្គលនានាមិនបានដឹងថាអ្នកណាដែលពួកគេត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនោះទេ[418]។ សេចក្តីសម្រេចរបស់កម្មាភិបាល បកក ស្តីពីអាពាហ៍ពិពាហ៍គឺត្រូវតែ "គោរពតាមយ៉ាងដាច់ខាត"[419]។ ពួកអ្នកដែលប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍ ត្រូវប្រថុយនឹងការរៀនសូត្រ ជាប់គុក ឬ សម្លាប់ចោល[420]។

94. ពីធីរៀបអាពាហ៍ពិពាហ៍ ដែលមានរហូតដល់ទៅ ១០០ គូ[421] ត្រូវបានធ្វើជារួម និងជំនួសអាពាហ៍ពិពាហ៍តាមរបៀបប្រពៃណីខ្មែរ[422]។ គូស្រករត្រូវបានបង្ខំឲ្យរួមសង្វាសអាពាហ៍ពិពាហ៍[423]

ដោយអ្នកដែលបានប្រកែកត្រូវបានគំរាមកំហែង[424] និងពេលខ្លះត្រូវសម្លាប់ចោល[425]។ ជាញឹកញាប់ កម្មាភិបាល បកក ដែលបានធ្វើជាអធិបតីក្នុងពិធីនោះ បានប្រាប់គូស្រករដែលទើបនឹងរៀបការថ្មីឲ្យ "បង្កើតកូនឲ្យអង្គការ"[426]។ នៅពេលដែលអាពាហ៍ពិពាហ៍ត្រូវបានរួមសង្វាសរួចហើយ គូស្រករ ជាទូទៅ ត្រូវបានបំបែកឲ្យទៅបន្តការងាររបស់ពួកគេវិញ ហើយជួបគ្នាឡើងវិញម្តងម្កាល[427]។

## ខ. តួនាទីរបស់ អ៊ឹម ចែម

### ទិដ្ឋភាពទូទៅ

95. **អ៊ឹម ចែម** កើតនិងរស់នៅក្នុងភូមិក្បាលអូរ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ[428]។ ត្រាំកក់ក៏ជាទីកន្លែងកំណើតរបស់តាម៉ុកផងដែរ ហើយក៏ជាមូលដ្ឋានស្នូលរបស់ខ្មែរក្រហម[429]។ **អ៊ឹម ចែម** ចូលរួមជាមួយខ្មែរក្រហមនៅក្នុងឆ្នាំ ១៩៧០ ដោយបានបញ្ជាក់ថា គាត់ចូលរួមដោយសារតែភ័យខ្លាច "បាត់ទឹកដី បាត់ពូជសាសន៍របស់ខ្លួន"[430]។ ទោះបីជាគាត់រៀបរាប់ខ្លួនគាត់ថាជា "កម្មាភិបាលធម្មតានៅថ្នាក់ក្រោម ធ្វើតាមមេដឹកនាំ"[431] ក៏ដោយ ក៏អង្គហេតុបានបង្ហាញថា **អ៊ឹម ចែម** បានឡើងឋានៈជាបន្តបន្ទាប់នៅក្នុងរបបខ្មែរក្រហមរហូតដល់កាន់តួនាទីនៅថ្នាក់ស្រុក និងថ្នាក់តំបន់។

96. តួនាទីរបស់ **អ៊ឹម ចែម** ត្រូវបានកត់សម្គាល់ដោយសារទំនាក់ទំនងរបស់គាត់ជាមួយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ គឺតាម៉ុក។ រាល់តួនាទីដែល **អ៊ឹម ចែម** ទទួលបាន នៅក្នុងភូមិភាគនិរតី និងពាយ័ព្យ សុទ្ធតែត្រូវបានតែងតាំងដោយតាម៉ុក។ **អ៊ឹម ចែម** គឺជាកម្មាភិបាលម្នាក់ដែលជិតស្និទ្ធបំផុតរបស់គាត់[432] ដែលត្រូវបានរៀបរាប់ផ្សេងៗគ្នាថាជា "មនុស្សទីពីរបន្ទាប់ពីតាម៉ុក"[433] "ដៃស្តាំរបស់តាម៉ុក"[434] និង "ជាមនុស្សពិសេសរបស់តាម៉ុក"[435]។ **អ៊ឹម ចែម** បញ្ជាក់ថា គាត់ស្គាល់តាម៉ុក "ច្បាស់" ហើយគាត់ប៉ាននជំទាស់ និងតវ៉ាជាមួយគាត់[436]។

97. ប៉ុល ពត ទុកចិត្តផ្ទាល់លើ **អ៊ឹម ចែម** ដោយឲ្យដឹកនាំការបោសសម្អាត នៅក្នុងតំបន់ទីមួយនៃភូមិភាគពាយ័ព្យ ដែលត្រូវ "បោសសម្អាត"[437]។ **អ៊ឹម ចែម** ខ្លួនឯងផ្ទាល់ក៏បានទទួលស្គាល់ថា គណៈកម្មាធិការមជ្ឈិម តាមដានការងាររបស់គាត់យ៉ាងជិតដល់ ហើយការពារគាត់[438] បើទោះបីជាមានគេឆ្លើយដាក់យ៉ាងហោចណាស់នៅក្នុង "ចម្លើយសារភាព" នៅស២១ ចំនួនពីរ[439]។ ដោយសារតែគាត់មានទំនាក់

ទំនងយ៉ាងជិតស្និទ្ធជាមួយថ្នាក់ខ្ពស់បំផុតនៃបក្សនោះហើយ ទើបគាត់ទុកចិត្តថារស់ ញឹម ដែលជាមេដឹកនាំភូមិភាគពាយ័ព្យ "មិនប៉ានចាប់ខ្លួនខ្ញុំ"[440]។ នៅក្នុងពេលបោសសម្អាតផ្ទៃក្នុងជាច្រើននោះ **អ៊ឹម ចែម** ត្រូវបានកោះហៅឲ្យមកកាន់តំណែងអាជ្ញាធរជាបន្តបន្ទាប់។ បើតាមសម្តីរបស់គាត់ "ទៅដល់កន្លែងណា គេឲ្យខ្ញុំធ្វើប្រធានហ្នឹងរហូត"[441]។

98. ការអនុវត្តដោយស្មោះត្រង់របស់ **អ៊ឹម ចែម** នូវគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានផ្តល់ជារង្វាន់ តាមរយៈការតម្លើងឋានៈយ៉ាងឆាប់រហ័សពីប្រធានពលកម្មសហករណ៍ខ្មែរក្រហម រហូតទៅដល់តួនាទីជាអនុលេខាតំបន់ដ៏សំខាន់មួយ នៅក្នុងភូមិភាគពាយ័ព្យ។ ការឡើងតំណែងរបស់គាត់រហូតដល់កាន់អំណាចបែបនេះ ត្រូវបានពន្យល់យ៉ាងច្បាស់ដោយការទទួលស្គាល់របស់គាត់ដែលថា នៅក្នុងរបបខ្មែរក្រហមគាត់ "ធ្វើការស្មោះត្រង់ មហាស្មោះត្រង់ ថាខំតស៊ូ"[442]។ តាមពិតទៅ គាត់មិនត្រូវបានរារាំងដោយសារការដួលរលំនៃរបបឡើយ ដោយគាត់នៅធ្វើការក្រោមតាម៉ុក នៅអន្លង់វែង រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៩០[443] ហើយបន្តទទួលបានការកោតសរសើរពីបុគ្គលសំខាន់មួយចំនួន ដូចជា ប៉ុល ពត, តាម៉ុក, នួន ជា និង ខៀវ សំផន[444]។ ទោះបីជាមានការលើកឡើងថា គាត់គ្រាន់តែគោរពតាមបញ្ជា[445] ក៏ដោយ ក៏ **អ៊ឹម ចែម** បញ្ជាក់ដោយនិយាយថា គាត់ "រីករាយនឹងធ្វើការងារខ្ញុំ"[446]។ ប៉ុន្តែនៅពេលដែលសួរជាក់លាក់អំពីចំនួនមនុស្សយ៉ាងច្រើនដែលត្រូវបានសម្លាប់ដោយខ្មែរក្រហមនោះ **អ៊ឹម ចែម** បាននិយាយយករួចខ្លួនចេញពីផែនការណាដែលបណ្តាលឲ្យមានការសម្លាប់មនុស្សបែបនេះ ដោយគាត់រៀបរាប់ថា គាត់បាន "តស៊ូដើម្បីជាតិ និងពូជសាសន៍របស់ខ្ញុំ"[447] ហើយមិនបានបង្ហាញពីអារម្មណ៍សោកស្តាយចំពោះអ្វីដែលបានកើតឡើងឡើយ[448]។

99. ការអះអាងរបស់ **អ៊ឹម ចែម** ថាធ្វើការងារដើម្បីលើកកម្ពស់ស្ថានភាពរបស់ប្រជាជនដែលស្ថិតក្រោមសិទ្ធិអំណាចគ្រប់គ្រងរបស់គាត់គឺផ្ទុយពីភស្តុតាង[449]។ ទោះបីរបបនេះមានភាពសម្ងាត់ក៏ដោយ[450] ក៏ **អ៊ឹម ចែម** ទទួលបានភាពល្បីល្បាញថាកាចសាហាវ[451] ដែលបង្ហាញដោយឧទាហរណ៍ ដែលគាត់បានប្រាប់អ្នកដែលត្រូវបានបង្ខំឲ្យចូលរួមកិច្ចប្រជុំរបស់គាត់ថា ស៊ូទុកពូជស្រូវ មិនទុកពូជមនុស្សទេ[452]។ **អ៊ឹម ចែម** បានរៀបរាប់ដោយលម្អិតអំពីស្ថានភាពរបស់ប្រជាជននៅព្រះនេត្រព្រះ នៅពេលគាត់ទៅដល់ទីនោះក្នុងនាមជាលេខាស្រុក[453] ដោយនិយាយជាច្រើនក្នុងនោះអំពី "ស្ថានភាពដ៏អាក្រក់" ដែលមនុស្ស១ម៉ឺននាក់បានបាត់ខ្លួន[454]។ កម្មាភិបាលភូមិភាគនិរតីបានប្រាប់ប្រជាជនថា កម្មាភិបាលពាយ័ព្យធ្វើខុសទើបបណ្តាលឲ្យខ្វះអាហារ[455]។ ទោះជាយ៉ាងនេះក្តីភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ស្ថានភាព

នៅក្រោម **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីគឺអាក្រក់ជាងស្ថានភាពនៅក្រោមកម្មាភិបាលភូមិភាគពាយ័ព្យទៅទៀត[456]។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការបន្ថែម[457] ហើយមានការកើនឡើងច្រើនបន្ថែមទៀតនូវការចាប់ខ្លួន ការបាត់ខ្លួន[458] និងការសម្លាប់[459]។ មិនមានអាហារគ្រប់គ្រាន់[460] ហើយអ្នកដែលត្រូវចាប់បានដោយមានអាហារ នឹងត្រូវរងទណ្ឌកម្ម[461]។ មនុស្សស្លាប់យ៉ាងច្រើនដោយសារភាពអត់ឃ្លាន និងជំងឺ[462]។

100. ការអះអាងរបស់ **អ៊ឹម ចែម** ថាបានការពារប្រជាជន ដូចជា ប៊ិន សុខ[463] និង ខូ[464] ត្រូវបានបដិសេធដោយប៊ិន សុខ[465] និងខូ[466] ផ្ទាល់។ ប៉ុន្តែអ្វីដែលបង្ហាញដោយការប្រឌិតបែបនេះ ព្រមទាំងដោយការអះអាងរបស់គាត់ដែលថា បដិសេធបញ្ជាឲ្យចាប់ខ្លួនមនុស្សនោះ[467] គឺថា **អ៊ឹម ចែម** មានសិទ្ធិអំណាចការពារមនុស្ស ប៉ុន្តែគាត់បែរជាមិនការពារទៅវិញ។ **អ៊ឹម ចែម** មានសិទ្ធិអំណាចសម្រេចស្លាប់រស់ចំពោះប្រជាជនដែលស្ថិតក្រោមការត្រួតត្រារបស់គាត់ ក្នុងតួនាទីផ្សេងៗគ្នាជាច្រើនរបស់គាត់ នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ **អ៊ឹម ចែម** បានអួតអំពីសិទ្ធិអំណាចសម្រេចស្លាប់រស់របស់គាត់ ដោយនិយាយថា បើទោះបីជាប្រជាជន ត្រូវបានចោទប្រកាន់ខុសថាជាខ្មាំង "បើខ្ញុំជាប្រធានហើយខ្ញុំយល់ព្រមតាម ជីវិតពួកគេចប់ហើយ។ ប្រជាជនស្លូតត្រង់ទាំងនោះនឹងត្រូវគេយកទៅសម្លាប់"[468]។

## ***ភូមិភាគនិរតីឆ្នាំ ១៩៧០ ដល់១៩៧៧***

### **តួនាទី និងសិទ្ធិអំណាច**

<u>មុនឆ្នាំ ១៩៧៦</u>

101. **អ៊ឹម ចែម** មានតួនាទី និងការទទួលខុសត្រូវជាច្រើន នៅក្នុងភូមិភាគនិរតីក្នុងអំឡុងសង្គ្រាមឆ្នាំ ១៩៧០ ដល់ ១៩៧៥ និងក្នុងអំឡុងរបបបក្សកុម្មុយនីស្តកម្ពុជា មុនពេលបោសសម្អាតភូមិភាគពាយ័ព្យ[469]។ នៅក្នុងឆ្នាំ ១៩៧១ តាម៉ុកបានតែងតាំង **អ៊ឹម ចែម** ឲ្យដឹកនាំសហករណ៍ពលកម្ម នៅក្នុងឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ[470] ដែលនៅសហករណ៍នោះគាត់ទទួលត្រួតពិនិត្យលើការបំពេញភារកិច្ចពលកម្មប្រចាំថ្ងៃ។ បន្ទាប់មក គាត់បានក្លាយជាប្រធានឃុំជាងទង ហើយបានរៀបចំភូមិនៅក្នុងឃុំនោះ[471]។ ក្នុងនាមជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា **អ៊ឹម ចែម** បានចាត់ចែងឲ្យសហករណ៍គោរពតាមគោលជំហរនយោបាយ និងមនោគមវិជ្ជារបស់បក្ស[472]។ **អ៊ឹម ចែម** ឃោសនាអប់រំមហាជនអំពី

នយោបាយ សតិអារម្មណ៍ ការចាត់តាំងរបស់បក្ស[473] បន្តការពាររបបកម្ពុជាប្រជាធិបតេយ្យ និងសម្រេចនូវគោលដៅដែលបានកំណត់របស់បក្សក្នុងការកែទម្រង់ឆាប់រហ័ស[474] គោរពអង្គការវិន័យរបស់បក្សដោយគ្មានលក្ខខណ្ឌ[475] និងខិតខំថែរក្សា ពង្រឹង ពង្រីកសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្សដោយមានគោលជំហរប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ច[476]។

102. នៅក្នុងឆ្នាំ ១៩៧២ **អ៊ឹម ចែម** ត្រូវបានតែងតាំងឲ្យគ្រប់គ្រងកងយោធានារីដែលមានកងទ័ពនារី ចំនួន ៤00 ទៅ ៥00នាក់ នៅភ្នំដំរីរមៀស ស្រុកត្រាំកក់ ខេត្តតាកែវ[477]។ ការទទួលខុសត្រូវរបស់គាត់ គឺអប់រំ និងបណ្តុះបណ្តាលនារីៗអំពីនយោបាយ និងការផលិត[478]។ នារីៗត្រូវតែគោរពក្រមសីលធម៌ ហើយ **អ៊ឹម ចែម** ចូលរួមក្នុងការរៀបចំពិធីអាពាហ៍ពិពាហ៍[479]។ **អ៊ឹម ចែម** ទទួលបានការទុកចិត្តឲ្យគ្រប់គ្រងនារីទាំងអស់នៅក្នុងតំបន់ ១៣ ក្នុងឆ្នាំ ១៩៧៣[480]។ គាត់គ្រប់គ្រងនារីរាប់ពាន់នាក់នៅក្នុងស្រុកទាំងប្រាំនៃតំបន់ ១៣[481], គីរីវង់, កោះអណ្តែត, ទ្រាំង, អង្គរជ័យ និងត្រាំកក់[482]។ គាត់មានសិទ្ធិអំណាចតែងតាំងនារី ឲ្យកាន់តំណែងក្នុងសហករណ៍ភូមិ ឃុំ និងស្រុក និងកងនារី[483] ក៏ដូចជាបានជ្រើសរើសពួកគេឲ្យចូលខ្មែរក្រហម[484]។

103. នៅពេលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៥ **អ៊ឹម ចែម** ទទួលខុសត្រូវលើប្រជាជន ដែលត្រូវបានជម្លៀសទៅខេត្តតាកែវ[485] ហើយគាត់ទទួលស្គាល់ថា ខ្មែរក្រហមមានផែនការជម្លៀសប្រជាជន នៅពេលដែលពួកគេកាន់កាប់តំបន់ណាមួយ[486]។ ក្នុងនាមជាអ្នកគ្រប់គ្រងនារីនៅក្នុងតំបន់ **អ៊ឹម ចែម** បើកវគ្គសិក្សា និងរៀនសូត្រ នៅក្នុងភូមិ និងឃុំ[487]។ អ្នកដែលត្រូវបានចាត់ទុកថាមានប្រវត្តិមិនល្អចាំបាច់ត្រូវរៀនសូត្របន្ថែម[488]។ គាត់បន្តតួនាទីនេះ ហើយគាត់ក៏មានតួនាទីដឹកនាំផ្ទៃទៀត នៅក្នុងភូមិភាគនិរតី រហូតដល់ពេលដែលគាត់ផ្ទេរទៅភូមិភាគពាយ័ព្យ ក្នុងឆ្នាំ ១៩៧៧។

104. ក្នុងឆ្នាំ ១៩៧៤ តាម៉ុក និង ប៉ុល ពត បានតែងតាំង **អ៊ឹម ចែម** ឲ្យគ្រប់គ្រងប្រជាជននៅក្នុងស្រុកអង្គរជ័យ[489]។ គាត់ចាត់ចែងពលកម្មនៅក្នុងស្រុកនេះ[490] រួមទាំងការកំណត់ពេលវេលានៃថ្ងៃធ្វើការ[491]។ ក្នុងពេលគាត់គ្រប់គ្រងស្រុកអង្គរជ័យ គាត់ទទួលស្គាល់ថា គាត់គ្រប់គ្រងលើការផលិតស្រូវបីតោនក្នុងមួយហិចតា តាមគោលនយោបាយដែលដាក់ចេញដោយ ប៉ុល ពត[492]។ ជាផ្នែកមួយនៃតួនាទីរបស់គាត់ក្នុងស្រុកអង្គរជ័យ **អ៊ឹម ចែម** គ្រប់គ្រងការដ្ឋាន[493]។ នៅពេលក្រោយមក ប្តីរបស់គាត់ឈ្មោះ ណុប ញៀន បានក្លាយជាលេខាស្រុកអង្គរជ័យ[494]។

ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧

105. ក្នុងឆ្នាំ ១៩៧៦ **អ៊ឹម ចែម** ត្រូវបានផ្ទេរពីស្រុកអង្គរជ័យ ទៅកោះអណ្តែត[495] ហើយត្រូវបានតែងតាំងជាលេខាស្រុក[496]។ **អ៊ឹម ចែម** បានបង្ហាញពីគោលជំហរមនោគមវិជ្ជាដែលចាំបាច់[497] និងអនុវត្តតាម "ជំហរប្រយុទ្ធមោះមុតក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសបដិវត្តសង្គមនិយម"[498]។ **អ៊ឹម ចែម** បាននិយាយថា គាត់ត្រូវបានតែងតាំងឲ្យជំនួសលេខាស្រុកកោះអណ្តែតចាស់ ដោយសារតែគាត់ "អាចសម្រេចផែនការ"[499]។ អនុលេខារបស់គាត់នៅកោះអណ្តែតគឺនាង អ៊ួច ហៅ តាសាន ដែលជាប្អូនថ្លៃរបស់ តាម៉ុក ដែលនៅពេលបន្ទាប់មកបានក្លាយជាលេខាស្រុកត្រាំកក់[500]។ នៅខែ មីនា ឆ្នាំ ១៩៧៦ **អ៊ឹម ចែម** ក៏ត្រូវបានតែងតាំងជាតំណាងភូមិភាគនិរតី នៅក្នុងសភាតំណាងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ[501]។

106. នៅកោះអណ្តែត **អ៊ឹម ចែម** រៀបចំភូមិ ហើយចាត់តាំងប្រជាជនឲ្យធ្វើការ[502]។ ក្រុមយុវជនមានភារកិច្ចធ្វើស្រែ និងសាងសង់គម្រោងធារាសាស្ត្រ ដូចជាទំនប់ ប្រលាយជាដើម[503]។ **អ៊ឹម ចែម** ជួបតាម៉ុកញឹកញាប់ដើម្បីទទួលការណែនាំ ទាក់ទងការរៀបចំស្រុករបស់គាត់[504]។ គាត់ក៏បានចូលរួមក្នុងកិច្ចប្រជុំ[505] រួមមានការប្រជុំបីថ្ងៃនៅក្នុងឆ្នាំ ១៩៧៦ ដែលក្នុងកិច្ចប្រជុំនេះ អ្នកចូលរួមចំនួន១៥០០នាក់ ត្រូវបានប្រាប់អំពីការឈ្លានពានរបស់វៀតណាម ការចល័តកម្លាំងពលកម្មទាំងអស់នៅសហករណ៍[506] និងការតែងតាំងឡើងវិញនូវកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ[507]។ ក្នុងនាមជាលេខាស្រុក **អ៊ឹម ចែម** មានសិទ្ធិអំណាចលើមន្ទីរសន្តិសុខវត្តអង្គស្រី និងទីតាំងសម្លាប់មនុស្សព្រៃសុខននៅក្បែរនោះ[508]។

107. ក្នុងឆ្នាំ ១៩៧៦ អ៊ឹម ចែម ត្រូវបានតែងតាំងជាសមាជិកគណៈតំបន់ ១៣[509] ជាមួយនឹង *ជាអាទិ៍* មាស មុត[510]។ ក្នុងឋានៈជាលេខាស្រុកកោះអណ្តែត[511] និងជាសមាជិកតំបន់ ១៣[512] អ៊ឹម ចែម ជាប់ពាក់ព័ន្ធនឹងរាល់ការធ្វើសេចក្តីសម្រេចទាំងអស់ដែលទាក់ទងនឹងស្រុក និងតំបន់នោះ[513]។ សេចក្តីណែនាំត្រូវបានបញ្ជូនទៅថ្នាក់ក្រោម[514] ហើយថ្នាក់ក្រោមដូកំណត់ទុកបានរាយការណ៍ត្រឡប់មកវិញអំពីការអនុវត្តកិច្ចការរបស់ពួកគេ[515]។ បន្ទាប់គាត់ត្រូវបាន តាម៉ុក ផ្ទេរឲ្យទៅទីរួមខេត្តតាកែវ គឺទីតាំងមន្ទីរភូមិភាគនិរតី និងតំបន់ ១៣[516]។ នៅទីនោះគាត់ធ្វើការនៅកម្រិតតំបន់ និងស្រុកៈ ដោយបន្តធ្វើជាលេខាស្រុកកោះអណ្តែងផង ជាអ្នកគ្រប់គ្រងស្ត្រីនៅក្នុងតំបន់ ១៣ និងជាសមាជិកគណៈតំបន់ ១៣[517]។

## ការចូលរួមក្នុងឧក្រិដ្ឋកម្ម

108. ក្នុងនាមជាលេខាស្រុក និងជាសមាជិកតំបន់ **អ៊ឹម ចែម** អនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា រួមទាំង "ការប្រុងប្រយ័ត្ន" ចំពោះខ្មាំងខាងក្នុង និងខាងក្រៅ[518] ហើយត្រូវតាមដានស្វែងរកការគម្រាមកំហែងទាំងនោះ[519]។ **អ៊ឹម ចែម** ចូលរួមក្នុងការប្រជុំក្នុងនាមជាកម្មាភិបាលថ្នាក់តំបន់ក្នុងតំបន់ ១៣[520] ដែលក្នុងការប្រជុំនេះអ្នកចូលរួមត្រូវបានប្រាប់ថា អ្នកដែលប្រព្រឹត្តខុសសីលធម៌ត្រូវ "កម្ទេច"[521]។ ការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានពិភាក្សានៅក្នុងការប្រជុំ[522] ហើយ "បញ្ហាសន្តិសុខ" ដូចជាការប្រយុទ្ធជាមួយ "យួន" ឈ្លានពាន និងប្រុងប្រយ័ត្នចំពោះអ្នកដែលឈឺ ឬធ្វើឱ្យខូចខាតសម្ភារៈធ្វើការ ដែលអាចជាគិញ្ញសម្ងាត់របស់ខ្មាំង[523] ក៏ត្រូវបានពិភាក្សាផងដែរ។ នៅក្នុងការប្រជុំថ្នាក់តំបន់ដែល **អ៊ឹម ចែម** បានចូលរួម ក៏បានពិភាក្សាអំពីប្រជាជនដែលស្លាប់ ដោយសារការអត់ឃ្លាន[524]។ មានការណែនាំទៅថ្នាក់ក្រោម ឱ្យស៊ើបរកអ្នកដែលត្រូវបានកំណត់ថាជា "ខ្មាំងផ្ទៃក្នុង"[525]។ លើសពីនេះ ការចាប់ខ្លួនក៏ត្រូវបានធ្វើផងដែរ នៅក្នុងការប្រជុំថ្នាក់តំបន់[526]។ **អ៊ឹម ចែម** ក្នុងនាមជាសមាជិកតំបន់បានបញ្ជាឱ្យប្រធានសន្តិសុខស្រុកគឺតាសឿនឱ្យធ្វើការចាប់ខ្លួន[527]។

109. **អ៊ឹម ចែម** ក៏បានចូលរួមផងដែរ ក្នុងវគ្គរៀនសូត្រនៅតាកែវនៅពេលនោះ[528]។ នៅក្នុងការជួបជុំរៀនសូត្រមួយ **អ៊ឹម ចែម** បានដឹកនាំវគ្គរៀនសូត្របីថ្ងៃ ដែលមានអ្នកចូលរួម ១៥០០ នាក់ ដែលក្នុងវគ្គនេះគាត់បានប្រាប់អ្នកចូលរួមថា៖ វៀតណាមទម្លាក់គ្រាប់បែកលើមូលដ្ឋានបក្សកុម្មុយនីស្តកម្ពុជា ហើយបានដុតផ្ទះសំបែង ហើយថា កម្មាភិបាលនិរតីនឹងត្រូវបញ្ជូនទៅភូមិភាគពាយ័ព្យ និងបានបញ្ជាឱ្យប្រឹងប្រែងធ្វើការឱ្យសម្រេចបានឆាប់រហ័សនូវគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា[529]។

110. **អ៊ឹម ចែម** បញ្ជាក់ថា គាត់នៅតាកែវប្រហែលមួយឆ្នាំ មុនពេលត្រូវបានផ្ទេរទៅភូមិភាគពាយ័ព្យ[530]។

## ការផ្ទេរទៅភូមិភាគពាយ័ព្យ (ពាក់កណ្ដាលឆ្នាំ ១៩៧៧)

111. នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ **អ៊ឹម ចែម** បានដឹកនាំមនុស្សមួយក្រុមជាង ១០០០ នាក់ ពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ[531]។ តាម៉ុក[532] និង ប៉ុល ពត បានបញ្ជូន **អ៊ឹម ចែម** ឱ្យទៅដឹកនាំការបោសសម្អាតភូមិភាគពាយ័ព្យ[533]។ អ្នកដែលបញ្ជូនទៅជាមួយ **អ៊ឹម ចែម** រួមមានប្រជាជនទូទៅ មេភូមិ និងមេឃុំ[534]

។ **អ៊ឹម ចែម** ជ្រើសរើសមនុស្សទាំងអស់នេះ ដោយសារតែគាត់ត្រូវការពួកគេដើម្បីធ្វើការនៅក្នុងភូមិភាគពាយ័ព្យ[535] និងដើម្បីធ្វើជា “គំរូ” សម្រាប់ “ប្រជាជនមូលដ្ឋាន” នៅក្នុងភូមិភាគពាយ័ព្យ[536]។ ក្រុមនេះក៏មានកងទ័ពប្រហែល ៥០០នាក់ផងដែរ ដែលត្រូវបញ្ជូនទៅការដ្ឋាន[537]។ **អ៊ឹម ចែម** បញ្ជាក់ថា មិនមានសមាជិកគណៈណាផ្សេង ត្រូវបានបញ្ជូនទៅជាមួយគាត់ឡើយ ហើយគាត់គឺជាអ្នកដឹកនាំក្រុម[538]។ ការអនុវត្តការបោសសម្អាតដោយ **អ៊ឹម ចែម** តាមគោលដៅដែលបានលើកឡើងរបស់បក្សកុម្មុយនីស្តកម្ពុជា មានគោលបំណងធានា “វិន័យ” ក្នុងបក្ស[539]។

112. ក្រុមនេះបានចាកចេញពីតាកែវ តាមរថភ្លើងដែលរៀបចំដោយ តាម៉ុក[540]។ នៅតាមផ្លូវទៅកាន់ភូមិភាគពាយ័ព្យ ពួកគេឈប់នៅទីក្រុងភ្នំពេញ ដើម្បីចូលរួមក្នុងការប្រជុំមួយជាមួយ ប៉ុល ពត[541]។ **អ៊ឹម ចែម** អង្គុយនៅជួរមុខក្នុងការប្រជុំជាមួយសមាជិកធម្មតារបស់បក្សកុម្មុយនីស្តកម្ពុជា[542]។ ប៉ុល ពត និយាយថា ពួកគេត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែ និងផ្លាស់ប្តូរបទពិសោធន៍ជាមួយពួកនៅពាយ័ព្យ[543]។ **អ៊ឹម ចែម** បានប្រាប់ថា គាត់បានជួប ប៉ុល ពត ផ្ទាល់ ហើយ ប៉ុល ពតបានពន្យល់គាត់ពីមូលហេតុដែលគាត់ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ[544]។ ក្នុងពេលស្នាក់នៅក្នុងទីក្រុងភ្នំពេញ **អ៊ឹម ចែម** ក៏បានជួបជាមួយកម្មាភិបាលថ្នាក់លើផងដែរ[545] ហើយបានដឹកនាំការប្រជុំបែងចែកកម្លាំងមុនពេលចាកចេញទៅភូមិភាគពាយ័ព្យ[546]។

113. បន្ទាប់ពីពួកគេទៅដល់ស្រុកស្វាយស៊ីសុផុន ខេត្តបន្ទាយមានជ័យ[547] គេបានប្រមូលផ្តុំប្រជាជន ហើយបែងចែកឲ្យទៅធ្វើការ នៅតាមឃុំផ្សេងៗគ្នាក្នុងស្រុកព្រះនេត្រព្រះ[548]។ នៅពេលដែលពួកគេទៅដល់ឃុំ ពួកគេត្រូវបានបញ្ជូនទៅកាន់សហករណ៍ផ្សេងៗគ្នា[549]។ **អ៊ឹម ចែម** ជាអ្នកបញ្ជាឲ្យបែងចែកកម្លាំងទាំងអស់នេះ[550]។

## *ភូមិភាគពាយ័ព្យ ឆ្នាំ ១៩៧៧ ដល់ ១៩៧៩*

### តួនាទី និងសិទ្ធិអំណាច

114. **អ៊ឹម ចែម** បានរៀបរាប់ថា ការចាត់ចែងស្រុកព្រះនេត្យព្រះដំបូង គឺគោរពតាមភារកិច្ចដែលបានចាត់តាំងដោយថ្នាក់លើ[551]។ ក្នុងនាមជាលេខាស្រុក[552] **អ៊ឹម ចែម** គ្រប់គ្រងលើរាល់សហករណ៍ ឃុំ[553] ភូមិ

និងកងចល័តទាំងអស់ នៅក្នុងស្រុកព្រះនេត្រព្រះ[554] ដែលមានមនុស្ស ១០០ ០០០ នាក់ ក្នុងនោះ "ប្រជាជនចាស់" ១០ ០០០ នាក់ និង "ប្រជាជនថ្មី" ៩០ ០០០ នាក់ ដែលត្រូវបានជម្លៀសពីភ្នំពេញ និងកន្លែងផ្សេងៗទៀត[555]។

115. បន្ថែមពីលើការងារជាលេខាស្រុកព្រះនេត្រព្រះ **អ៊ឹម ចែម** ក៏កាន់តួនាទីថ្នាក់តំបន់ បន្ទាប់ពីអ្នកនៅក្នុងគណៈតំបន់ត្រូវបានបោសសម្អាត។ ដំបូង **អ៊ឹម ចែម** បានក្លាយជាសមាជិកគណៈតំបន់ ៥ ភ្លាមៗក្រោយពេលមកដល់ភូមិភាគពាយ័ព្យ[556]។ បន្ទាប់មកនៅពាក់កណ្ដាលឆ្នាំ ១៩៧៨ ដល់ចុងឆ្នាំ១៩៧៨ **អ៊ឹម ចែម** ក្លាយជាអនុលេខាតំបន់ ៥[557]។ ឯកសារដែលនៅសល់ពីសម័យនោះបង្ហាញពីកាលបរិច្ឆេទដែលអតីតសមាជិកគណៈតំបន់៥ ត្រូវបានចាប់ខ្លួន ហើយ **អ៊ឹម ចែម** បានកាន់តួនាទីជាសមាជិកហើយបន្ទាប់មកជាអនុលេខា។ **អ៊ឹម ចែម** បញ្ជាក់ថា អតីតលេខាតំបន់ ៥ ឈ្មោះហឿង ត្រូវបានយកទៅសម្លាប់ មុនពេលដែលគាត់មកដល់ភូមិភាគពាយ័ព្យ[558] គឺនៅសល់ "តាឡៃ និង ជាល [កូនរបស់ រស់ ញឹម លេខាភូមិភាគ]" នៅថ្នាក់តំបន់[559]។ ឡៃ *ហៅ* គង់ ឡែម ដែលជាសមាជិកគណៈតំបន់ ៥ បានចូល ស ២១ នៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៧៧[560] ចំណែក ជាល ត្រូវបានចាប់ខ្លួន ប្រហែលក្នុងពេលជាមួយឪពុករបស់គាត់ គឺនៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៨[561]។ វុធ ដែលជាសមាជិកមួយរូបទៀតរបស់អតីតគណៈតំបន់ ក៏ត្រូវបានបោសសម្អាតផងដែរក្នុងឆ្នាំ១៩៧៧[562]។ កម្មាភិបាលនិរតីឈ្មោះ ហេង រិន ហៅ មី បានឡើងជាលេខាតំបន់ ៥ ជំនួស ហឿង[563]។ ជាលទ្ធផល **អ៊ឹម ចែម** ពិតជាបានឡើងជាសមាជិកគណៈតំបន់ ៥ មុន ឬ ក្នុងខែ កញ្ញា ឆ្នាំ ១៩៧៧ (គឺនៅពេលដែលចាប់ខ្លួនឡៃ) ហើយបានក្លាយជាអនុតំបន់ មុន ឬ ក្នុងខែ មិថុនា ឆ្នាំ១៩៧៨ (គឺនៅពេលចាប់ខ្លួនជាល)។

116. នៅចុងឆ្នាំ ១៩៧៨ តំបន់នានានៅក្នុងភូមិភាគពាយ័ព្យ ត្រូវបានរៀបចំឡើងវិញ ហើយតំបន់ថ្មីមួយត្រូវបានបង្កើតឡើង ដោយបញ្ចូលផ្នែកខាងជើងនៃតំបន់ ៣ចាស់ (មង្គលបូរី) ទៅក្នុងតំបន់៥[564]។ រិន ដែលជាលេខាតំបន់ ៥ ចាស់ ត្រូវបានចាប់ខ្លួននៅក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៨[565] ហើយត្រូវបានជំនួសដោយ តាចាយ អតីតប្រធានស្រុកត្រាំកក់[566]។ កម្មាភិបាលភូមិភាគនិរតីម្នាក់ដែលត្រូវបានតាចាយចាត់តាំងឲ្យមកភូមិភាគពាយ័ព្យ ហើយដែលមានវត្តមាននៅក្នុងការប្រជុំ គណៈតំបន់ថ្មីនោះបានផ្ដល់សក្ខីកម្មថា **អ៊ឹម ចែម** បានក្លាយជាអនុលេខាតំបន់ថ្មីនោះ[567]។ គាត់ក៏បានបញ្ជាក់ផងដែរថា ញៀន ដែលជាប្ដីរបស់ ចែម បានក្លាយជាសមាជិកគណៈតំបន់[568]។ នៅកម្រិតតំបន់ ៥ **អ៊ឹម ចែម** មានសិទ្ធិអំណាច

និងការទទួលខុសត្រូវលើការងារ ក្នុងស្រុកភ្នំស្រុក ព្រះនេត្រព្រះ អូរជ្រៅ សេរីសោភ័ណ ថ្មពួក និងស្វាយចេក។

117. **អ៊ឹម ចែម** បំពេញការងារជាលេខាស្រុកព្រះនេត្រព្រះផង[569] និងជាសមាជិកតំបន់ ៥ ផង ហើយបន្ទាប់មកជាអនុលេខាទៀត[570]។ គាត់ចូលរួមក្នុងរាល់ការសម្រេចទាំងអស់ដែលទាក់ទងស្រុកនិងតំបន់[571]។ ការណែនាំត្រូវបានបញ្ជូនទៅថ្នាក់ក្រោម គឺពីថ្នាក់តំបន់ និងស្រុក ទៅថ្នាក់ឃុំ និងភូមិ[572] ហើយថ្នាក់ក្រោមអនុវត្តបញ្ហាទាំងនោះ និងរាយការណ៍ត្រឡប់ទៅវិញ[573]។

118. **អ៊ឹម ចែម** បានបង្កើតមន្ទីរ និងកន្លែងស្នាក់នៅក្នុងឃុំភ្នំលៀប[574] ហើយមានកងការពារប្រដាប់ដោយអាវុធ[575]។ **អ៊ឹម ចែម** បញ្ជាក់ថា នៅពេលដែលគាត់មកដល់អគារនេះភ្លាម អ្នកទោសដែលឃុំនៅទីនោះត្រូវបានរើចេញ[576]។

## ការចូលរួមក្នុងឧក្រិដ្ឋកម្ម

### ការចូលរួម និងសិទ្ធិអំណាចលើការរស់នៅរបស់ប្រជាជន

119. នៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បានប្រើប្រាស់សិទ្ធិអំណាចជាម្ចាស់លើការរស់នៅរបស់ប្រជាជនទូទៅ។ បុគ្គលម្នាក់ត្រូវបានបង្ខំឲ្យធ្វើការងារដោយមិនទទួលបានកម្រៃ ហើយរស់នៅក្រោមការគម្រាមកំហែងនៃការចាប់ខ្លួន ឃុំខ្លួន និងសម្លាប់រាល់ពេល។ ការរស់នៅជាក្រុមគ្រួសារត្រូវបានគ្រប់គ្រង និងរិតបន្តឹង ហើយការបញ្ចេញមតិត្រូវគោរពតាមគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលអនុវត្តដោយ **អ៊ឹម ចែម**។ សិទ្ធិអំណាចរបស់គាត់ គឺមាននៅគ្រប់ទិសទីនៅក្នុងអង្គការស្រុកព្រះនេត្រព្រះ គាត់ជាអ្នកតែងតាំងកម្មាភិបាលនៅក្នុងស្រុក[577] ផ្លាស់ទីលំនៅប្រជាជននៅក្នុងស្រុក[578] ត្រួតត្រាលើអាហារដែលមាន[579] និងត្រួតត្រា សូម្បីការដើរហើរជាមូលដ្ឋាន គឺតម្រូវឲ្យមានលិខិតដើរផ្លូវ ដែលចេញដោយ **អ៊ឹម ចែម** នៅពេលធ្វើដំណើរនៅក្នុងតំបន់[580]។

120. **អ៊ឹម ចែម** ដឹកនាំការប្រជុំជាញឹកញាប់ ដែលក្នុងការប្រជុំនេះកម្មាភិបាល និងប្រជាជនធម្មតា ត្រូវបានបណ្តុះបណ្តាលមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជា។ **អ៊ឹម ចែម** បានបញ្ជូននីរសាឲ្យនាំយក បញ្ហារបស់

គាត់ទៅប្រាប់កម្មាភិបាលថ្នាក់ក្រោម ហើយតម្រូវឱ្យរាយការណ៍ផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរឱ្យបានទៀងទាត់ត្រឡប់មកវិញ[581]។ ថ្នាក់ក្រោមអនុវត្តការណែនាំរបស់ **អ៊ឹម ចែម**[582]។ គាត់ក៏បានកោះហៅមនុស្សឱ្យមកមន្ទីររបស់គាត់ តាមរយៈនីរសាររបស់គាត់[583] ឬតាម រយៈថ្នាក់ក្រោមផងដែរ[584]។ នីរសាក៏បានយកសំបុត្រពីថ្នាក់តំបន់ទៅឱ្យ **អ៊ឹម ចែម** នៅភ្នំល្មៀបផងដែរ[585]។

<u>ការចូលរួម និងសិទ្ធិអំណាចលើការប្រជុំដែលពិភាក្សាពីឧក្រិដ្ឋកម្ម</u>

121. ការប្រជុំគឺជាវិធីសាស្ត្រចម្បង ក្នុងការគ្រប់គ្រងមនុស្ស។ **អ៊ឹម ចែម** បានបញ្ជាឱ្យមានវត្តមាននៅក្នុងការប្រជុំជាប្រចាំ[586]។ ពេលក្លាយជាលេខាស្រុក **អ៊ឹម ចែម** បានប្រាប់អ្នកចូលរួមថា កម្មាភិបាលពាយ័ព្យចាស់បានក្បត់បដិវត្ត[587] បន្ទាប់ពីកម្មាភិបាលពាយ័ព្យត្រូវបានសម្លាប់[588]។ **អ៊ឹម ចែម** បានប្រើការប្រជុំដើម្បីផ្សព្វផ្សាយពីគោលនយោបាយរបស់ បកក[589] ពីតម្រូវការក្នុងការស្វែងរកអ្នកមានតំណែងខ្ពស់ ដែលជាប់ទាក់ទងនឹងរបបចាស់ ដើម្បីយកមកសម្លាប់[590] ការប្រុងប្រយ័ត្ន និងការលុបបំបាត់ "ខ្មាំង" ខាងក្នុង[591] ការព្រមានចំពោះអ្នកដែលប្រឆាំងអង្គការ[592] ការព្រមានមិនឱ្យ "ខ្ជិលច្រអូស"[593] និងគំរាមថានឹងយកមនុស្សទៅរៀនសូត្រ ឬដាក់ទណ្ឌកម្ម ប្រសិនបើពួកគេមានកំហុស[594]។ ការប្រជុំក៏បានចេញនូវការណែនាំផងដែរ៖ អំពីការកសាងទំនប់ និងប្រឡាយ[595] ការធ្វើការឱ្យខ្លាំងក្លា និងឆាប់រហ័សជាងមុន[596] និងធ្វើតាមអង្គការ[597]។ លើសពីនេះ **អ៊ឹម ចែម** ក៏បានប្រើប្រាស់ការប្រជុំ ដើម្បីបញ្ជូនមនុស្សទៅរៀនសូត្រ ឬទៅសមរភូមិក្រោយ[598] ចាត់តាំងការងារ[599] តែងតាំងកម្មាភិបាល[600] និងប្រើការប្រជុំជាលេសដើម្បីចាប់ខ្លួន និងសម្លាប់កម្មាភិបាល[601]។

122. **អ៊ឹម ចែម** ជួបជាមួយអ្នកភូមិ[602] មេភូមិ មេឃុំ[603] កងចល័ត[604] និងមេកងធំៗ[605]។ ការប្រជុំជាមួយអ្នកភូមិជាញឹកញាប់គឺជាការប្រជុំធំ ដែលមានអ្នកចូលរួមរាប់ពាន់នាក់[606] ដែលពួកគេភាគច្រើនត្រូវបានតម្រូវឱ្យធ្វើដំណើរមកពីចម្ងាយ[607]។ ការប្រជុំធ្វើឡើងនៅមន្ទីររបស់ **អ៊ឹម ចែម** នៅភ្នំល្មៀប[608] នៅវត្ត[609] ឬការដ្ឋាន ដូចជាទំនប់ត្រពាំងថ្ម ការដ្ឋានវាយថ្មភ្នំទ្រយោង និងទំនប់ស្ពានស្រែង[610] ដែលនៅតាមកន្លែងទាំងនោះ ផែនការការងារប្រចាំថ្ងៃត្រូវបានកំណត់សម្រាប់ពលករ[611] ហើយអ្នកជាប់ឃុំឃាំងត្រូវបានព្រមានថា ប្រសិនបើមិនអាចកែប្រែខ្លួនបានទេ ពួកគេនឹងត្រូវសម្លាប់ចោល[612]។ ការប្រជុំបែបនេះត្រូវបានដឹកនាំដោយ **អ៊ឹម ចែម** ឬអ្នកនៅក្រោមបង្គាប់របស់គាត់[613]។

123. **អ៊ឹម ចែម** រៀបចំ និងចូលរួមក្នុងការប្រជុំថ្នាក់ស្រុក[614]។ នៅក្នុងឆ្នាំ ១៩៧៨ គាត់បានដឹកនាំការប្រជុំយ៉ាងទៀតទាត់ ដែលពេលខ្លះប្រជុំរាល់ពីរសប្តាហ៍ម្តងជាមួយមេកងចល័តថ្នាក់តំបន់[615]។ ដូចគ្នានឹងកិច្ចប្រជុំថ្នាក់ស្រុកដែរ ការប្រជុំថ្នាក់តំបន់បានពិភាក្សាពីការស្វែងរកខ្មាំងផ្ទៃក្នុង[616]។ នៅក្នុងឆ្នាំ ១៩៧៨ **អ៊ឹម ចែម** និង តាម៉ុក បានដឹកនាំការប្រជុំធំមួយ ដែលក្នុងការប្រជុំនេះអ្នកណាដែលនិយាយប្រឆាំងអង្គការត្រូវបានយកទៅសម្លាប់ និងកប់នៅបាតទំនប់ត្រពាំងថ្ម[617]។

124. **អ៊ឹម ចែម** តែងតែមាននីរសាប្រដាប់ដោយអាវុធ តាមអមដំណើរនៅពេលចុះពិនិត្យភូមិ ឬចូលរួមក្នុងការប្រជុំ[618]។

<u>ការចូលរួម និងសិទ្ធិអំណាចលើការដ្ឋាន</u>

125. **អ៊ឹម ចែម** ទទួលស្គាល់ថា គាត់គ្រប់គ្រងលើពលករ និងការងារនៅព្រះនេត្រព្រះ[619]។ គាត់បានទទួលស្គាល់ថា គាត់អនុវត្តផែនការពីថ្នាក់លើ ទាក់ទងគម្រោងការងារ ទំនាក់ទំនងជាមួយថ្នាក់លើ[620] និងបញ្ជូនរបាយការណ៍ទៅគណៈមជ្ឈិម[621]។ ចាប់តាំងពីពេលដែលគាត់មកដល់ភូមិភាគពាយ័ព្យ **អ៊ឹម ចែម** បានចេញបញ្ជាអំពីការបែងចែកកម្លាំងពលកម្ម[622] ផ្តួចផ្តើមគម្រោងការងារ[623] ហើយទទួលខុសត្រូវលើការដ្ឋានទំនប់ និងប្រឡាយទាំងអស់ និងវាលស្រែទាំងអស់នៅក្នុងស្រុក[624]។ មានពលកររាប់ពាន់នាក់នៅក្នុងកងនានារបស់ស្រុកដែលស្ថិតក្រោមការត្រួតត្រារបស់ **អ៊ឹម ចែម**[625]។ កងទាំងនោះមានទាំងកងកុមារផងដែរ[626]។

126. **អ៊ឹម ចែម** បានចុះទៅមើលវាលស្រែ ការដ្ឋានសាងសង់ទំនប់ និងការដ្ឋានផ្សេងៗទៀតជាច្រើន នៅក្នុងសហករណ៍ក្នុងស្រុកព្រះនេត្រព្រះ[627]។ គាត់បានចុះពិនិត្យការដ្ឋាន និងកងចល័ត ហើយសាក្សីខ្លះបានចាំថា គាត់បានបង្ខំ ពលករឲ្យប្រឹងធ្វើការខ្លាំងជាងមុន[628]។

127. **អ៊ឹម ចែម** បានតែងតាំងមេកងពលកម្ម[629] ហើយបានណែនាំដល់មេកងអំពីការងារដែលពលករត្រូវធ្វើ[630]។ គាត់បានកោះហៅមេកងចល័តឲ្យមករាយការណ៍ប្រាប់គាត់អំពីការងាររបស់ពួកគេ[631] និងទទួលរបាយការណ៍លាយលក្ខណ៍អក្សរពីកងពលកម្ម[632]។ មេកងត្រូវរាយការណ៍ទៅ**អ៊ឹម ចែម** អំពីបញ្ហានានាដូចជាចំនួនពលករ និងសំណើសុំអាហារ[633]។ **អ៊ឹម ចែម** ចេញបញ្ជាទៅកងចល័ត និងកម្លាំង

ឲ្យផ្ទេរទៅតំបន់ផ្សេង[634] និងបង្គាប់ដល់កងនានាដែលទទួលពលករឲ្យតាមដានលើកម្មករ[635]។ បញ្ជារបស់ **អ៊ឹម ចែម** លើការងារត្រូវបានថ្នាក់ក្រោមគោរពតាម[636]។

128. **អ៊ឹម ចែម** បានបញ្ជាឲ្យស្វែងរក និងចាប់ពលករណាដែលរត់ចេញពីការដ្ឋាន[637]។ ជាឧទាហរណ៍កោ ឡិន ដែលជាប្រធានកងចល័ត បានរាយការណ៍ទៅ តាពល់ថា មនុស្សនៅក្នុងកងការងាររបស់គាត់បានរត់គេច។ តាពល់ បានរាយការណ៍ពីបញ្ហានេះទៅ **អ៊ឹម ចែម** ហើយ **អ៊ឹម ចែម** ក៏បានបញ្ជាឈ្លបឲ្យចុះទៅតាមសហករណ៍ និងប្រាប់ប្រធានសហករណ៍ និងមេឃុំឲ្យស្វែងរកមនុស្សទាំងនោះត្រឡប់មកវិញ[638]។ នីរសាររបស់ **អ៊ឹម ចែម** បានប្រាប់ កោ ឡិនថា គេចាប់ពលករទាំងនោះបានវិញហើយ ត្រូវទៅទទួលយកពួកគេពីមន្ទីរសន្តិសុខ[639]។

129. តាមការទទួលស្គាល់ផ្ទាល់របស់គាត់ **អ៊ឹម ចែម** បានបញ្ជូនពលករ និងគ្រប់គ្រងការងារនៅទំនប់ត្រពាំងថ្ម និងតាមវាលស្រែនៅជុំវិញនោះ[640]។ **អ៊ឹម ចែម** ចុះត្រួតពិនិត្យលើការងារ[641] អមដោយកងការពារប្រដាប់ដោយអាវុធ[642] ឬបញ្ជូនអ្នកក្រោមបង្គាប់ឲ្យចុះពិនិត្យការងារ[643]។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការតាមបញ្ជារបស់ **អ៊ឹម ចែម** ដោយមិនមានអាហារគ្រប់គ្រាន់[644]។ គាត់បានកំណត់ការងារដែលប្រជាជនត្រូវធ្វើ[645] ហើយចូលរួមក្នុងការដាក់ទណ្ឌកម្មចំពោះអ្នកណាដែលធ្វើខុសវិន័យច្បាប់[646]។ **អ៊ឹម ចែម** កោះហៅមេក្រុម និងមេកង ឲ្យចូលរួមក្នុងការប្រជុំ នៅពេលដែលគាត់ចុះពិនិត្យទំនប់[647]។ នៅក្នុងការប្រជុំដែលដឹកនាំដោយ **អ៊ឹម ចែម** ហើយដែលមានអ្នកចូលរួមរាប់ពាន់នាក់នោះ អ្នកចូលរួមត្រូវបានបង្គាប់ឲ្យស្រែកតាមអំពីការខិតខំធ្វើការ និងលប់បំបាត់ឲ្យអស់វណ្ណៈមូលធននិយម[648]។ **អ៊ឹម ចែម** ក៏បានស្វាគមន៍ប្រតិភូពីប្រទេសចិនមកទស្សនកិច្ចទំនប់ត្រពាំងថ្ម រួមជាមួយ ប៉ុល ពត និង ខៀវ សំផន[649]។ ពលករដែលរត់គេចពីទំនប់ ត្រូវបានបង្ខំឲ្យត្រឡប់មកវិញ តាមបញ្ជារបស់ **អ៊ឹម ចែម**[650] ឬត្រូវបានកងទ័ពដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** សម្លាប់[651]។

130. **អ៊ឹម ចែម** ក៏បានទទួលស្គាល់ផងដែរពីការរៀបចំផែនការ កសាងទំនប់ស្ពានស្រែង និងអាងស្តុកទឹកព្រៃរនាម ដែលត្រូវជីកដោយដៃ ហើយចំណាយពេលមួយឆ្នាំទើបកសាងហើយ[652]។ **អ៊ឹម ចែម** បានបញ្ជូនពលករ[653] បានកំណត់ផែនការការងារ[654] និងត្រួតពិនិត្យលើការដ្ឋាន[655] រួមទាំងការកោះហៅប្រជុំពេលនៅការដ្ឋាន[656]។ **អ៊ឹម ចែម** បានបញ្ជាក់ថា ប៉ុល ពត ជួយដល់ការកសាង តាមរយៈការផ្តល់គ្រឿងផ្គត់

ផ្លូង ដូចជាសម្លៀកបំពាក់ និងអាហារ[657]។ គម្រោងសាងសង់បន្ថែមត្រូវបានគ្រោង ប៉ុន្តែមិនបានចាប់ផ្តើមដំណើរការឡើយ ដោយសារតែកងទ័ពវៀតណាម ចូលមកដល់ក្នុងឆ្នាំ ១៩៧៩[658]។

131. ការដ្ឋានវាយថ្មភ្នំទ្រយោង ដែលនៅក្បែរមន្ទីរសន្តិសុខភ្នំទ្រយោង គឺជាការដ្ឋានការងារ[659] ដែលដំណើរការក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**[660]។ **អ៊ឹម ចែម** ក៏គ្រប់គ្រងការដ្ឋានបន្ទាប់បន្សំផងដែរនៅភ្នំទ្រយោង[661] ក្នុងនោះរួមទាំងវាលស្រែជាដើម[662]។

<u>ការចូលរួម និងសិទ្ធិអំណាចលើអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ</u>

132. **អ៊ឹម ចែម** ធ្វើជាអធិបតីលើពិធីអាពាហ៍ពិពាហ៍ដោយបង្ខំ[663]។ ជាឧទាហរណ៍ ថង ធឿយ មានអាយុ ១៥ឆ្នាំ[664] នៅពេលដែលគាត់ត្រូវរៀបការដោយបង្ខំ ក្នុងពិធីមួយដែលដឹកនាំដោយ **អ៊ឹម ចែម**។ ពីដំបូង ថង ធឿយ បានបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍ឡើយ ប៉ុន្តែគេប្រាប់ថា បើគាត់បដិសេធ គេនឹងសម្លាប់គាត់ចោល[665]។ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ហើយ គេតាមដានមើលប្តីប្រពន្ធគាត់ទៀតតាមបញ្ជារបស់ **អ៊ឹម ចែម** ដើម្បីធានាថា ប្តីប្រពន្ធគាត់បានរួមដំណេកជាមួយគ្នា[666]។ ស្ត្រីមួយចំនួនដែលបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងក្រុមតែមួយជាមួយ ថង ធឿយ ត្រូវបានសម្លាប់ ដោយសារតែពួកគេមិនព្រមរួមដំណេកជាមួយប្តីរបស់ខ្លួន[667]។

133. នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ គេហៅឈ្មោះបុរស និងនារី ហើយពួកគេត្រូវសន្យាថាត្រូវរស់នៅជាមួយគ្នាជាប្តីប្រពន្ធរហូត។ ពិធីបែបនេះតែងតែមានការចូលរួមពីប្រធាននានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**[668]។ ប្រសិនបើនរណាម្នាក់បដិសេធ ពួកគេនឹងត្រូវបានចាត់ទុកថាជាខ្មាំង[669]។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក៏ធ្វើឡើងផងដែរ នៅតាមការដ្ឋានដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ **អ៊ឹម ចែម** ហើយបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច គូស្រករត្រូវបានគេតាមដាន ដើម្បីធានាថា ពួកគេរួមដំណេកជាមួយគ្នា[670]។ លើសពីនេះទៀតបញ្ជីឈ្មោះអ្នកដែលត្រូវរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នឹងត្រូវផ្ញើទៅថ្នាក់តំបន់[671]។

134. ទោះបីជាបុរសពេលខ្លះអាចស្នើសុំរៀបអាពាហ៍ពិពាហ៍ជាមួយនារីណាម្នាក់បានក៏ដោយ ក៏ពួកគេមិនត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយនារី "១៧មេសា" ឡើយ[672]។ នៅក្នុងការប្រជុំ **អ៊ឹម**

**ថែម** ណែនាំនារីៗឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយកម្មាភិបាលពិការ[673]។ អ្នកដែលមិនបានអនុវត្តតាមនឹងត្រូវបានចាប់ខ្លួន[674]។

135. បន្ថែមលើនេះ កម្មាភិបាលក្រោមសិទ្ធិអំណាចរបស់ អ៊ឹម ថែម និងដែលធ្វើតាមផែនការរួម បានរំលោភសេពសន្ថវៈស្ត្រី មុនពេលសម្លាប់ពួកគេនៅស្រុកព្រះនេត្រព្រះ[675]។

<u>ការចូលរួម និងសិទ្ធិអំណាចលើ "ការរៀនសូត្រ" របស់ខ្មាំង</u>

136. **អ៊ឹម ថែម** បញ្ជាឲ្យលត់ដំ កែប្រែ និងអបរំ និងរៀនសូត្រ ចំពោះអ្នកទាំងឡាយណាដែលរបបនោះមើលឃើញថាជាជនសង្ស័យ។ ប្រជាជនពាយ័ព្យត្រូវបានបញ្ជូនទៅលត់ដំ បន្ទាប់ពីកម្មាភិបាលនិរតីមកដល់[676]។ **អ៊ឹម ថែម** បានដឹកនាំវគ្គរៀនសូត្រយ៉ាងទៀតទាត់[677] ហើយសម្រេចថានរណាត្រូវបញ្ជូនទៅរៀនសូត្រ[678]។ ជាឧទាហរណ៍ ភួន ស៊ុនទី បានទទួលលិខិតពី **អ៊ឹម ថែម** ដែលបញ្ជាឲ្យគាត់ទៅឃុំភ្នំលៀប ដើម្បីរៀនសូត្រ[679]។ បន្ទាប់ពីមកដល់ភ្នំលៀប **អ៊ឹម ថែម** បានបញ្ជាឲ្យគាត់ទៅរៀនសូត្រនៅមន្ទីរសន្តិសុខភ្នំទ្រយោង[680] ដែលនៅទីនោះគាត់ត្រូវបានបង្ខំឲ្យធ្វើការ ហើយឃុំឃាំងដោយដាក់ខ្នោះ[681]។

137. **អ៊ឹម ថែម** បានបញ្ជាថ្នាក់ក្រោមឲ្យបញ្ជូនមនុស្សដែលត្រូវរៀនសូត្រ និងកែប្រែ[682]។ ជុំ កន ដែលត្រូវបាន **អ៊ឹម ថែម** តែងតាំងជាគណៈឃុំភ្នំលៀប បានបញ្ជាក់ថា គាត់បានទទួលបញ្ជាបែបនេះយ៉ាងច្រើន ហើយបើមិនអនុវត្តតាមបញ្ជាបែបនេះទេគឺអាចស្លាប់[683]។

138. **អ៊ឹម ថែម** បង្កើត "ផ្នែកអប់រំ" នៅមន្ទីរសន្តិសុខភ្នំទ្រយោង[684] ដោយដាក់ចេញនូវបទបញ្ជា និងគោលនយោបាយដែលត្រូវអនុវត្ត ចំពោះពលករដែលត្រូវបានចាត់ទុកថា "រឹងរូស" និងអ្នកទោសស្រាល[685]។ **អ៊ឹម ថែម** បានតែងតាំង ទុំ សឿន ឲ្យទទួលខុសត្រូវលើការងារនេះ[686]។ ប្រសិនបើនរណាម្នាក់ត្រូវបានចាត់ទុកថាមាន "កំហុស" នៅសហករណ៍ អ្នកនោះត្រូវបានរាយការណ៍ទៅ**អ៊ឹម ថែម** ហើយគាត់នឹងសួរថាតើម្នាក់នោះអាចអប់រំនៅសហករណ៍បានដែរឬទេ។ បើមិនអាចទេ បុគ្គលនោះនឹងត្រូវបញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោង[687]។ នៅក្នុងឆ្នាំ ១៩៧៨ យ៉េង ឆាន ដែលស្ថិតក្នុងចំណោមក្រុមពលករនារីដែលធ្វើការដោយបង្ខំ នៅទំនប់ត្រពាំងថ្ម ត្រូវបានឈ្លបចាប់ខ្លួន ដោយសារតែដើររកទឹកផឹកនៅក្នុងការដ្ឋាន[688]។ ស្ត្រីដទៃទៀតនៅក្នុងក្រុមត្រូវបានចាប់ចង ហើយវាយដំយ៉ាងធ្ងន់ធ្ងរ ហើយពួកគេទាំង

អស់ត្រូវបានយកទៅអប់រំ នៅភូមិរហាល ក្នុងស្រុកព្រះនេត្រព្រះ[689]។ ពលករដែលមិនអាចបំពេញការងារដែលបានកំណត់នោះ នឹងត្រូវបានបញ្ជូនទៅរៀនសូត្រផងដែរ[690]។

139. ភាគច្រើននៃអ្នកដែលត្រូវបានហៅទៅ "រៀនសូត្រ" មិនដែលឃើញត្រឡប់មកវិញទេ ហើយច្បាស់ណាស់ថា ពួកគេត្រូវបានយកទៅសម្លាប់[691]។

## ការចូលរួម និងសិទ្ធិអំណាចលើការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់

140. **អ៊ឹម ចែម** បាននាំឈ្លបប្រដាប់ដោយអាវុធចំនួន ៥០០ នាក់ មកភូមិភាគពាយ័ព្យ[692]។ គាត់ទទួលស្គាល់ថា បន្ទាប់ពីគាត់មកដល់ គាត់បានបញ្ជាឲ្យឈ្លបដែលពេលនោះមានវត្តមាននៅក្នុងស្រុកឲ្យប្រគល់អាវុធ[693] ហើយឲ្យអតីតកងទ័ពទាំងអស់នោះ ទៅធ្វើការនៅការដ្ឋានការងារ[694]។ ដូចគ្នានឹង តាម៉ោង[695] ដែលកាន់តំណែងនេះមុនគាត់ដែរ **អ៊ឹម ចែម** គ្រប់គ្រងទៅលើកម្លាំងប្រដាប់អាវុធនៅព្រះនេត្រព្រះ[696]។

### ការចាប់ខ្លួន

141. **អ៊ឹម ចែម** មានអំណាច និងតួនាទីបញ្ជាឲ្យចាប់ខ្លួនមនុស្ស នៅក្នុងស្រុកព្រះនេត្រព្រះ និងតំបន់៥[697]។ ការចាប់ខ្លួន រួមទាំងការចាប់ខ្លួនកម្មាភិបាលពាយ័ព្យ បន្ទាប់ពីនិរតីបានឡើងកាន់កាប់នោះ ត្រូវបានធ្វើឡើងដោយអ្នកនៅក្រោមបង្គាប់របស់ **អ៊ឹម ចែម** ទាំងកម្មាភិបាល និងទាំងកងទ័ព តាមសិទ្ធិអំណាចរបស់គាត់[698]។ ប៊ិន ហឺយ ត្រូវបានចាប់ខ្លួនជាមួយឪពុករបស់គាត់[699] ដែលជាអតីត "អាចារ្យ" (មុខងារខាងផ្នែកពុទ្ធសាសន) តាមបញ្ជារបស់ **អ៊ឹម ចែម** ដោយសារតែឪពុករបស់ ប៊ិន ហឺយ មានជាប់ទាក់ទងជាមួយអតីតកម្មាភិបាលពាយ័ព្យ[700]។ ដំបូង គិម យ៉េត ត្រូវបាន **អ៊ឹម ចែម** ផ្ទេរទៅក្រុមគ្រូពេទ្យដែលមានគ្នាបីនាក់នៅភ្នំលៀប ក្នុងឆ្នាំ១៩៧៧[701]។ បន្ទាប់មក គាត់ និងសមាជិកក្រុមរបស់គាត់ ត្រូវបានចាប់ខ្លួនតាមបញ្ជារបស់ **អ៊ឹម ចែម** ហើយត្រូវបានបញ្ជូនទៅ មន្ទីរសន្តិសុខភ្នំទ្រយោង[702]។ ប៊ិន សុខ ដែលជាអតីតនីរសាររបស់ **អ៊ឹម ចែម** ក៏បានរៀបរាប់ផងដែរ ពីការដែលប្រធានសហករណ៍បានទៅជួប **អ៊ឹម ចែម** ដើម្បីពិភាក្សាអំពីការចាប់ខ្លួនមនុស្សយ៉ាងច្រើន[703]។ ទុំ សឿន ដែលជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង បានផ្តល់សក្ខីកម្មថា ប្រធានសហករណ៍បានពិភាក្សាផ្ទាល់ជាមួយ **អ៊ឹម ចែម** អំពីការចាប់ខ្លួន[704]។

142. ជាញឹកញាប់ ប្រជាជនត្រូវបានយកមកផ្ទះរបស់ **អ៊ឹម ចែម** នៅភ្នំលៀប មុនពេលបញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោង ដើម្បីឃុំឃាំង និងសម្លាប់[705]។ ប៊ិន សុខ ដែលជាអតីតនីរសាររបស់ **អ៊ឹម ចែម** បានរៀបរាប់លម្អិតអំពីការដែលគេបញ្ជាគាត់ឲ្យទៅប្រមូលមនុស្ស ៧ នាក់ ដែលត្រូវបានចាប់ខ្លួនដោយកម្មាភិបាលនៅភូមិជប់ ហើយនាំយកពួកគេមកមន្ទីររបស់ **អ៊ឹម ចែម** នៅភ្នំលៀប[706]។

143. ការចាប់ខ្លួនកើតឡើងនៅតាមទីកន្លែងផ្សេងៗគ្នា ដូចជានៅវត្ត[707] នៅការដ្ឋាន[708] និងនៅក្នុងការប្រជុំ[709] ដែលត្រូវបាន **អ៊ឹម ចែម** ប្រើប្រាស់ផងដែរ ដើម្បីបញ្ជាឲ្យចាប់ខ្លួនអ្នកដែលមិនបានចូលរួម[710]។ អ្នកដែលរត់គេចពីការដ្ឋាន ត្រូវបានរាយការណ៍ទៅ **អ៊ឹម ចែម** ហើយគាត់បញ្ជាឲ្យចាប់ខ្លួនអ្នកទាំងនោះ ហើយនាំយកមកការដ្ឋានវិញ[711]។ ប្រហែលគ្នានេះ អ្នកដែលធ្វើដំណើរ ដោយមិនមានការអនុញ្ញាតនៅព្រះនេត្រព្រះ ត្រូវបានចាប់ខ្លួន និងឃុំខ្លួន[712]។

144. សិទ្ធិអំណាចរបស់ **អ៊ឹម ចែម** ក្នុងការបញ្ជាឲ្យចាប់ខ្លួន គឺមិនត្រឹមតែនៅក្នុងស្រុកព្រះនេត្រព្រះប៉ុណ្ណោះទេ ប៉ុន្តែទៅដល់ស្រុកដទៃនៅក្នុងតំបន់ ៥។ ជាឧទាហរណ៍សាក្សី គោ ពិនថង ដែលធ្វើការនៅក្នុងកងចល័តក្នុងស្រុកសេរីសោភ័ណ្ឌ[713] ត្រូវបានចាប់ខ្លួន ហើយនាំយកទៅភ្នំលៀប។ បន្ទាប់ពីការពិភាក្សារវាងអ្នកចាប់ខ្លួនគាត់ និង **អ៊ឹម ចែម** សាក្សីនេះត្រូវបានយកទៅមន្ទីរសន្តិសុខភ្នំទ្រយោង និងត្រូវបានឃុំខ្លួននៅទីនោះ[714]។

## ការឃុំខ្លួន

145. **អ៊ឹម ចែម** មានសិទ្ធិអំណាចបញ្ជាថានរណាត្រូវឃុំខ្លួន ហើយគាត់ទទួលខុសត្រូវលើមន្ទីរសន្តិសុខ និងអ្នកទោសទាំងអស់នៅព្រះនេត្រព្រះ[715]។ ក្រៅពីមនុស្សដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន នៅមន្ទីររបស់គាត់នៅភ្នំលៀប[716] គឺមានមន្ទីរសន្តិសុខមួយដែលនៅទល់មុខផ្ទះរបស់ **អ៊ឹម ចែម** នៅភ្នំលៀប ដែលនៅទីនោះអ្នកទោសជាច្រើនត្រូវបានឃុំឃាំង មុនពេលបញ្ជូនត្រឡប់ទៅការដ្ឋាន ទៅមន្ទីរសន្តិសុខភ្នំទ្រយោង ឬយកទៅសម្លាប់[717]។

146. មន្ទីរសន្តិសុខភ្នំទ្រយោងត្រូវបានបង្កើតឡើង បន្ទាប់ពី **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីមកដល់[718] ហើយស្ថិតក្រោមការត្រួតត្រារបស់ **អ៊ឹម ចែម**[719]។ មន្ទីរនេះមានអ្នកទោសមកពីស្រុក និងតំបន់[720]។ **អ៊ឹម ចែម** តែងតាំង ទុំ សឿន ឲ្យទទួលខុសត្រូវលើដំណើរការប្រចាំថ្ងៃរបស់មន្ទីរសន្តិសុខ

នេះ[721]។ សឿនរាយការណ៍តែទៅ **អ៊ឹម ចែម** ប៉ុណ្ណោះ[722] ហើយគាត់ចេញបញ្ជាទាក់ទងអ្នកជាប់ឃុំ[723]។ **អ៊ឹម ចែម** បង្គាប់ដល់សឿនឲ្យតាមដានយ៉ាងម៉ត់ចត់លើអ្នកទោសទាំងអស់ មុនពេលសម្រេចថាត្រូវធ្វើបែបណា ចំពោះអ្នកទោសនីមួយៗ[724] ឧទាហរណ៍ថាតើអ្នកទោសល្មើសធ្ងន់ធ្ងរ អាចត្រូវដោះខ្នោះដែរ ឬទេ[725]។ គាត់ក៏បានបញ្ជូនអ្នកក្រោមបង្គាប់ឲ្យទៅពិនិត្យមើលតាមមន្ទីរសន្តិសុខ[726]។ **អ៊ឹម ចែម** មានអំណាច និងតួនាទីក្នុងការដោះលែងអ្នកទោស "ស្រាល"[727]។ សឿនរាយការណ៍រាល់ការរត់គេចពីមន្ទីរសន្តិសុខទៅ **អ៊ឹម ចែម** ហើយ **អ៊ឹម ចែម** ជាអ្នកចាត់វិធានការបន្ត[728]។ **អ៊ឹម ចែម** ទាក់ទងជាមួយសឿន តាមរយៈនីរសាររបស់ខ្លួន និងដោយជួបផ្ទាល់ក្នុងពេលប្រជុំនៅមន្ទីរសន្តិសុខ[729] ហើយចុះពិនិត្យមើលផ្ទាល់ ឬបញ្ជូនអ្នកក្រោមបង្គាប់ឲ្យទៅពិនិត្យមន្ទីរសន្តិសុខរៀងរាល់ពីរទៅបីថ្ងៃម្តង[730]។

147. អ្នកដែលត្រូវបានចាប់ខ្លួននៅសហករណ៍ ហើយត្រូវបានចោទប្រកាន់ថាខ្ជិលច្រអូស ថាមានកំហុស ឬព្យាយាមរត់គេចនោះ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោង[731]។ អ្នកជាប់ឃុំរួមមានអតីតអ្នករដ្ឋការ និងទាហានពីរបប លន់ នល់, "ប្រជាជនថ្មី" ដែលត្រូវបានជម្លៀសចេញពីភ្នំពេញ[732] និងប្រជាជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តខុសសីលធម៌[733]។ ធិប សំផាត់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅភ្នំទ្រយោង តាមបញ្ជាជាលាយលក្ខណ៍អក្សររបស់ **អ៊ឹម ចែម** ដោយសារតែរឹះគន់អាហារដែលគាត់បានទទួលនៅក្នុងឃុំ[734]។ ភួន ស៊ុនទី ត្រូវបាន **អ៊ឹម ចែម** បញ្ជូនទៅភ្នំទ្រយោងដើម្បីចូលរួម "ប្រជុំ" ប៉ុន្តែតាមពិតទៅត្រូវបានដាក់ខ្នោះ ហើយយកទៅអប់រំកែប្រែ[735]។ អ្នកទោសដែលត្រូវបានបញ្ជូនទៅភ្នំទ្រយោង កម្រមានអ្វីដែលបញ្ជាក់ពីការចោទប្រកាន់ពីកំហុសរបស់ពួកគេណាស់[736]។

148. សិទ្ធិអំណាចរបស់ **អ៊ឹម ចែម** លើការចាប់ខ្លួន និងឃុំខ្លួន ត្រូវបានបង្ហាញតាមរយៈចម្លើយរបស់គាត់ដែលថា គាត់មានម្តងនោះបានបញ្ជាកងការពារឲ្យដោះលែងបុរសម្នាក់ ដែលត្រូវបានឃុំខ្លួននៅផ្ទះរបស់គាត់នៅភ្នំលៀប ដោយសារតែបុរសនោះចាស់ជរា[737]។ ទោះបីពីដំបូងគាត់អះអាងថាមិនដឹងថាមន្ទីរសន្តិសុខភ្នំទ្រយោងមានទីតាំងនៅទីណាក៏ដោយ ក៏នៅពេលក្រោយមក **អ៊ឹម ចែម** បានទទួលស្គាល់ថា មន្ទីរនេះស្ថិតនៅប្រហែល ២០០ ទៅ៣០០ ម៉ែត្រពីផ្ទះរបស់គាត់នៅភ្នំលៀប[738]។

## ការសម្លាប់

149. **អ៊ឹម ចែម** មានអំណាច និងតួនាទីបញ្ជាឲ្យសម្លាប់មនុស្ស[739]។ ទោះបីថាសិទ្ធិអំណាចនេះបានមកដោយសារតែតួនាទីរបស់គាត់ជាកម្មាភិបាលថ្នាក់តំបន់ ឬអត់ក៏ដោយ[740] វាច្បាស់ណាស់ថា ក្នុងការ

អនុវត្តជាក់ស្តែង **អ៊ឹម ចែម** បានបញ្ជាដោយផ្ទាល់ឲ្យសម្លាប់មនុស្ស។ ទុំ សឿន បានផ្តល់សក្ខីកម្មថា **អ៊ឹម ចែម** បញ្ជាគាត់ឲ្យសម្លាប់អ្នកទោសធ្ងន់បួននាក់ដែលមិនអាចដើរបាន បន្ទាប់ពីគេធ្វើទារុណកម្មរួចហើយ[741]។ ប៊ូ ម៉ៅ ដែលធ្វើការនៅក្នុងកងចល័តក្នុងតំបន់ ៥ បានឃើញ មឿន ដែលជាប្រធានក្រុមពេទ្យចល័ត ត្រូវបានឃុំខ្លួននៅផ្ទះរបស់ **អ៊ឹម ចែម** ហើយគាត់ឮ **អ៊ឹម ចែម** និយាយថា "បើវាពិបាក វាប្រឆាំងក្បត់ហើយ វៃចោលទៅ"[742]។

150. បញ្ជាពី **អ៊ឹម ចែម** ទៅក្រោមគឺធ្វើឡើងតាមថ្នាក់ ដើម្បីចាប់ខ្លួន និងសម្លាប់[743] ហើយ **អ៊ឹម ចែម** មានសិទ្ធិអំណាចលើអ្នកដែលទទួលខុសត្រូវផ្ទាល់លើការសម្លាប់[744]។ សំ ប៊ុន ដែលជាមេឃុំ ត្រូវបានឃុំខ្លួននៅមន្ទីររបស់ **អ៊ឹម ចែម** នៅភ្នំលៀប មុនពេលដែលគាត់ត្រូវបានយកទៅភ្នំទ្រយោង ហើយសម្លាប់ចោលដោយសារខុសសីលធម៌ គឺដោយសារមាននារីៗទៅលេងផ្ទះរបស់គាត់[745]។ ភួន ស៊ុនទី ដែលត្រូវបាន **អ៊ឹម ចែម** បញ្ជូនទៅមន្ទីរសន្តិសុខភ្នំទ្រយោង ដើម្បីរៀនសូត្រនោះ បានឃើញការសម្លាប់មនុស្សនាពេលយប់នៅមន្ទីរសន្តិសុខនេះ ហើយគាត់ត្រូវបានបង្ខំឲ្យកប់សាកសពជាច្រើន[746]។ **អ៊ឹម ចែម** មានវត្តមានដោយផ្ទាល់នៅកន្លែងនោះ នៅពេលមានការសម្លាប់មនុស្ស[747] ហើយគាត់មានសិទ្ធិអំណាចដោះលែងអ្នកដែលនឹងត្រូវសម្លាប់[748]។ ការសម្លាប់នៅតាមកន្លែងនានាដូចជា ភូមិចក្រី និងវត្តព្រះនេត្រព្រះ ត្រូវបានធ្វើឡើងតាមអំណាចរបស់ **អ៊ឹម ចែម**[749]។

151. ការកំណត់គោលដៅ និងការសម្លាប់អតីតទាហាន អ្នករដ្ឋការ និងអ្នកដែលជាប់ទាក់ទងនឹងរបប លន់ នល់ ដែលផ្តួចផ្តើមឡើងដោយកម្មាភិបាលភូមិភាគពាយ័ព្យ ត្រូវបានបន្តទៀត ក្រោយពេលដែល **អ៊ឹម ចែម** និងកម្មាភិបាលនិរតីមកដល់[750]។ ការសម្លាប់អ្នកដែលជាប់ទាក់ទង និងកម្មាភិបាលពាយ័ព្យក៏នៅតែបន្តមាន ក្រោយពេលការបោសសម្អាតបឋម ដោយស្របតាមគោលនយោបាយជីកស្មៅត្រូវជីកទាំងឫស[751]។ ឪពុករបស់ ប៊ិន ហឺយ ដែលជាអាចារ្យពុទ្ធសាសនា ត្រូវបានចាប់ខ្លួន ហើយសម្លាប់នៅព្រះនេត្រព្រះ ដោយសារតែគាត់ជាប់ទាក់ទងនឹងកម្មាភិបាលពាយ័ព្យ ដែលគ្រប់គ្រងលើតំបន់[752]។ ប៊ិន ហឺយ ដែលត្រូវបានចាប់ខ្លួន ហើយជាប់ខ្នោះនៅក្បែរឪពុករបស់គាត់ នៅឃុំព្រះនេត្រព្រះបានរៀបរាប់ថា បានឮឪពុករបស់គាត់ស្រែកសុំឲ្យជួយ មុនពេលគាត់ត្រូវសម្លាប់[753]។ **អ៊ឹម ចែម** ជាអ្នកបញ្ជាឲ្យសម្លាប់[754]។

152. ជនជាតិភាគតិច ដូចជាជនជាតិវៀតណាម[755] ជនជាតិចិន[756] និងខ្មែរក្រោម[757] ក៏ក្លាយជាគោលដៅផងដែរ។ ជាឧទាហរណ៍ ស្ត្រីវៀតណាមពីរនាក់ ត្រូវបានកម្មាភិបាលភូមិភាគនិរតីដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** សម្លាប់ចោលនៅស្រុកព្រះនេត្រព្រះ[758]។ ជាតិសាសន៍វៀតណាមដែលជាគោលដៅនៃការសម្លាប់នៅពេលក្រោយ ត្រូវបានរកឃើញតាមរយៈការស្រាវជ្រាវប្រវត្តិរូបរបស់ប្រជាជននៅក្នុងស្រុក និងការបង្កើតប្រវត្តិរូបដែលត្រូវប្រគល់ជូនទៅ **អ៊ឹម ចែម**[759]។ នៅថ្នាក់តំបន់ គ្រួសារខ្មែរក្រោមត្រូវបានយកទៅវាយរហូតដល់ស្លាប់ បន្ទាប់ពីកម្មាភិបាលនិរតីមកដល់។ ពួកគេរួមទាំងគ្រួសារបុរសខ្មែរក្រោមដែលរៀបការជាមួយនារីខ្មែរ[760]។

153. ក្រុមដែលជាគោលដៅក៏ត្រូវបានកំណត់អត្តសញ្ញាណផងដែរ ពីបញ្ជីប្រជាជនស្រុកព្រះនេត្រព្រះ ដែលកម្មាភិបាលភូមិភាគពាយ័ព្យបានរៀបចំ មុនពេលមានការបោសសម្អាត[761]។ បញ្ជីនេះត្រូវបានបញ្ជូនទៅមេភូមិ និងមេឃុំ ដើម្បីស្វែងរកអ្នកដែលមានឈ្មោះនៅក្នុងបញ្ជី ហើយនៅពេលរកឃើញ គេនឹងបញ្ជូនកម្លាំងទៅចាប់យកពួកគេទៅបាត់[762]។ **អ៊ឹម ចែម** និយាយថា ប៉ុល ពត និងគណៈមជ្ឈិមបានបញ្ជាឲ្យគេប្រគល់បញ្ជីនេះទៅគាត់[763] ហើយគាត់ទទួលស្គាល់ថា គាត់បានទទួលពីអតីតកម្មាភិបាលស្រុក មុនពេលពួកគេស្លាប់[764]។

154. អ្នកផ្សេងៗទៀតដែលជាគោលដៅនៃការសម្លាប់ ក្រោមរបបរបស់ **អ៊ឹម ចែម** រួមមានៈ អ្នកដែលខុសសីលធម៌[765] អ្នកដែលលែងមានប្រយោជន៍ក្នុងការងារ[766] និងអ្នកដែលត្រូវបានចោទថាជា "ជនក្បត់"[767] ឬជា "គីញ"[768]។ **អ៊ឹម ចែម** សារភាពថាបានទទួលបញ្ជាពីថ្នាក់លើ ដើម្បីស្វែងរក និងចាប់ខ្លួន "សមាសភាពមិនល្អ" រួមបញ្ចូលទាំងអ្នកដែលជាប់ទាក់ទងនឹងរបប លន់ នល់ ឬអ្នកដែលត្រូវបានចោទថាជា "គីញ"[769]។

155. បន្ថែមលើនេះ ការសម្លាប់ក៏កើតឡើងផងដែរ បន្ទាប់ពី **អ៊ឹម ចែម** បានចុះពិនិត្យការដ្ឋាន។ ជាឧទាហរណ៍ មានការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ នៅមន្ទីរសន្តិសុខភ្នំទ្រយោង បន្ទាប់ពី **អ៊ឹម ចែម** បានចុះទៅត្រួតពិនិត្យ[770]។ ស្ត្រីមានផ្ទៃពោះត្រូវបានសម្លាប់ ហើយកប់នៅបាតគ្រឹះស្ពាន នៅការដ្ឋានត្រពាំងថ្ម ដោយសារតែជំនឿថា ការធ្វើបែបនេះនឹងជួយដល់គម្រោងសាងសង់[771]។

156. **អ៊ឹម ចែម** បានបដិសេធថាមិនមានសិទ្ធិអំណាចក្នុងការសម្លាប់ឡើយ ដោយគាត់អះអាងថាមានតែកងទ័ពប៉ុណ្ណោះ ដែលមានសិទ្ធិអំណាចបែបនេះ[772]។ ចំណុចនេះគឺផ្ទុយនឹងភស្តុតាងយ៉ាងច្រើនលើសលប់ ដែលបង្ហាញផងដែរពីការគ្រប់គ្រងរបស់គាត់ទៅលើកងកម្លាំងប្រដាប់អាវុធនៅព្រះនេត្រព្រះ[773]។

# ច. ខ្មែរក្រោម

## *ភូមិភាគនិរតី*

### ការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម (១៩៧៦-១៩៧៧)

<u>គោលនយោបាយរបស់ បកក ពាក់ព័ន្ធនឹងខ្មែរក្រោម</u>

157. គោលនយោបាយរបស់ បកក ស្តីពីការផ្តោតគោលដៅទៅលើខ្មែរក្រោម[774] វិវត្តពីជម្លោះរវាងវៀតណាម និង ការមិនទុកចិត្តរបស់ បកក ទៅលើជនដែលបានមើលឃើញថាមានការទាក់ទងជាមួយនឹងវៀតណាម[775]។ ខ្មែរក្រោមជាបុគ្គលនៃជាតិពន្ធុកម្ពុជា ពីតំបន់ប្រវត្តិសាស្ត្រកម្ពុជា ប៉ុន្តែឥឡូវនេះនៅក្នុងព្រំដែនវៀតណាម។ កម្មាភិបាលខ្មែរក្រហម ជាញឹកញាប់ បានចោទប្រកាន់ខ្មែរក្រោមថាជាគេញ "យួន"[776]។ កាលពីដំបូងនៃ រយៈកាលកម្ពុជាប្រជាធិបតេយ្យ បកក បានទទួលខ្មែរក្រោមពីវៀតណាម ខណៈដែលបានជម្លៀសដោយបង្ខំនូវបុគ្គលនៃជាតិពន្ធុវៀតណាម ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាឲ្យទៅវៀតណាមវិញក្នុងការដោះដូរគ្នាដែលត្រូវបានរៀបចំទុកជាច្រើន[777]។ យ៉ាងណាក៏ដោយ ដោយជម្លោះជាមួយនឹងវៀតណាមបានកើនឡើងយ៉ាងខ្លាំង គោលនយោបាយរបស់ បកក បាននាំឲ្យមានការសម្លាប់យ៉ាងរង្គាលនូវពួកខ្មែរក្រោម ពីព្រោះតែការយល់ឃើញរបស់ពួកនោះថាមានការទាក់ទងជាមួយនឹងវៀតណាម[778]។

<u>ការប្រាស្រ័យទាក់ទងនៃគោលនយោបាយរបស់ បកក ពាក់ព័ន្ធនឹងខ្មែរក្រោម</u>

158. បកក បានផ្សព្វផ្សាយនូវគោលនយោបាយរបស់ខ្លួន ដោយផ្តោតគោលដៅទៅលើបុគ្គលទាំងឡាយណាដែលមានទំនាក់ទំនងជាមួយនឹងវៀតណាម ពីក្នុងមជ្ឈិមបក្ស រហូតដល់ថ្នាក់ក្រោម[779]។ នៅពេលប្រជុំនៅពាសពេញតំបន់១៣ ខ្មែរក្រោមត្រូវបានរៀបរាប់ផ្សេងៗគ្នាថាជា "ខ្មាំង"[780], "ជនក្បត់"[781], "គេញយួន"[782], "ភ្នាក់ងារកាហ្សេបេ"[783], និងមាន "ក្បាលយួនខ្លួនខ្មែរ"[784]។ កម្មាភិបាលនិរតីបានប្រាប់ដល់ថ្នាក់ក្រោមថា ខ្មែរក្រោមត្រូវតែ "សម្លាប់" ឬ "កំទេច"[785] និងថាវាជា "កិច្ចការរបស់អង្គការ"[786] ដែលថាខ្មែរក្រោមត្រូវតែ "បោសសម្អាត"[787]។

## <u>ការអនុវត្តគោលនយោបាយនៅក្នុងតំបន់១៣</u>

159. កម្មាភិបាលនិរតីនៅតំបន់១៣ បានកំណត់អត្តសញ្ញាណខ្មែរក្រោមសម្រាប់ផ្តោតជាគោលដៅតាមវិធីមួយចំនួន។ ក្នុងកំឡុងឆ្នាំ១៩៧៦ ខ្មែរក្រោមត្រូវបានប្រាប់ឲ្យទៅចុះបញ្ជីនៅតាមការប្រជុំសហករណ៍ ហើយថា "អង្គការ" នឹងបញ្ជូនពួកគាត់ឲ្យវិលត្រឡប់ទៅកម្ពុជាក្រោមវិញ[788]។ ផ្ទុយទៅវិញ កម្មាភិបាលទាំងនោះបានប្រមូលផ្តុំខ្មែរក្រោមជាក្រុម ធ្វើបញ្ជីឈ្មោះអ្នកទាំងនោះ[789] និងយកពួកគេទៅសម្លាប់ចោល[790]។

160. កម្មាភិបាល បកក ក៏បានកំណត់អត្តសញ្ញាណខ្មែរក្រោម តាមរយៈប្រវត្តិរូបដែលបក្សបានតម្រូវឲ្យបុគ្គលទាំងនោះឲ្យរៀបចំ[791]។ បន្ថែមលើនេះ ខ្មែរក្រោមត្រូវបានកំណត់អត្តសញ្ញាណសម្រាប់ជាគោលដៅដោយសម្លៀកបំពាក់[792], សំនៀង[793], និងពណ៌សម្បុរស្បែករបស់ពួកគេ[794]។

161. ក្នុងឋានៈជាលេខាស្រុកកោះអណ្តែត[795] និងសមាជិកគណៈតំបន់១៣[796] **អ៊ឹម ចែម** បានបញ្ជាឲ្យមានការចាប់ខ្លួន[797] និងមានសិទ្ធិអំណាចលើពួកឈ្លបដែលបានដឹកនាំការសម្លាប់[798]។ គ្រួសារខ្មែរក្រោមទាំងមូលត្រូវបានយកចេញទៅរាល់ថ្ងៃ ហើយ "បាត់ខ្លួន" ពីស្រុក មានន័យថា ពួកគេត្រូវបានសម្លាប់[799]។

162. ខ្មែរក្រោមជាក្រុមដំបូងដែលត្រូវបានឃុំខ្លួន និងត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តអង្គសេរីមាលី និងនៅជាប់ក្បែរទីកន្លែងសម្លាប់មនុស្សនៅព្រៃសុខុន នៅកោះអណ្តែតនៅអំឡុងពេលដែល **អ៊ឹម ចែម** កាន់អំណាច[800]។ ពួកគេ តាមធម្មតា ត្រូវបានឃុំខ្លួននៅវត្តអង្គសេរីមាលី ជាបណ្តោះអាសន្នមុននឹងត្រូវបានសម្លាប់[801]។ នៅចន្លោះឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ការសម្លាប់រង្គាលខ្មែរក្រោមបានកើតឡើងនៅព្រៃសុខុន[802]។ ខ្មែរក្រោមបុរស និងស្ត្រី ត្រូវបានគេចងដៃ និងបណ្តើរជាជួរ ដើម្បីសម្លាប់ចោល[803]។ បុគ្គលត្រូវបានគេវាយនឹងដំបងឈើរហូតដល់ស្លាប់[804] ហើយបន្ទាប់មក បោះចូលទៅក្នុងរណ្តៅ[805]។ សាក្សី មុំ ផល្លា ដែលបានធ្វើការនៅក្បែរព្រៃសុខុន បានរៀបរាប់ថាបានឮសម្លេងស្រែកចេញពីទីកន្លែងសម្លាប់មនុស្ស[806]។ ការសម្លាប់គឺញឹកញាប់ណាស់រហូតដល់សាក្សីនិយាយថាបានកើតឡើង "មានថ្ងៃ មានយប់"[807]។ ទោះបីជាមិនមានចំនួនដាច់ស្រេចនៃមនុស្សដែលត្រូវបានសម្លាប់នៅវត្តអង្គសេរីមាលី និងនៅព្រៃសុខុនក៏ដោយ សាក្សីថាមានការសម្លាប់រហូតដល់ទៅរាប់ពាន់នាក់[808]។

## (២) មន្ទីរសន្តិសុខវត្តអង្គសិរីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន (ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ១៩៧៧)

### ទីតាំង និងដំណើរការ

163. មន្ទីរសន្តិសុខវត្តអង្គសិរីមាលី[809] ស្ថិតនៅខាងជើងភូមិសំភ្លី ឃុំព្រៃខ្លា ស្រុកកោះអណ្តែត ខេត្តតាកែវ[810] នៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី[811]។ ទីតាំងសម្លាប់មនុស្សព្រៃសុខុនស្ថិតនៅខាងជើងនៃមន្ទីរសន្តិសុខនេះ តាមផ្លូវលំមួយឆ្ពោះទៅទិសខាងជើងចេញពីភូមិសំភ្លី ទៅភូមិស៊ីស្លា[812]។ ទីតាំងទាំងពីរនេះបានដំណើរការពីខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់យ៉ាងហោចណាស់ខែ វិច្ឆិកា ឆ្នាំ១៩៧៨[813]។

164. មន្ទីរសន្តិសុខនេះ រួមបញ្ចូលទាំងវត្ត ជាទីកន្លែងដែលត្រូវបានប្រើជាមូលដ្ឋានយោធាស្រុក[814] និងយ៉ាងហោចណាស់អគារចំនួនពីរ ត្រូវបានប្រើដើម្បីឃុំខ្លួនមនុស្ស[815]។ ក្នុងឆ្នាំ ១៩៧៥ អគារឈើមួយខ្នងត្រូវបានប្រែក្លាយពីសាលារៀនមួយទៅជាកន្លែងឃុំឃាំង[816] ហើយក្នុងឆ្នាំ ១៩៧៦ ទាហានបានសាងសង់រោងធំមួយនៅជិតវត្តនេះ ដើម្បីធ្វើជាមន្ទីរឃុំឃាំង[817]។

165. ទីតាំងសម្លាប់មនុស្សព្រៃសុខុន[818] ស្ថិតនៅក្នុងព្រៃក្រាស់[819] ដែលមានទំហំប្រហែល ១០ ហិចតា[820]។ ការចូលទៅទីតាំងសម្លាប់មនុស្សនេះត្រូវបានខ្មែរក្រហមហាមឃាត់[821] ប៉ុន្តែប្រជាជនអាចដើរតាមផ្លូវលំដែលនៅជាប់នឹងព្រៃនេះ ដែលតភ្ជាប់ពីភូមិស៊ីស្លាទៅភូមិសំភ្លី[822]។

### រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

166. ក្នុងនាមជាលេខាស្រុកពីឆ្នាំ ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧ **អ៊ឹម ចែម** មានសិទ្ធិអំណាចលើមន្ទីរសន្តិសុខវត្តអង្គសិរីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន[823]។ **អ៊ឹម ចែម** ប្រើអំណាចដើម្បីបញ្ជាឲ្យប្រធានសន្តិសុខស្រុកឈ្មោះ តា សឿន ធ្វើការចាប់ខ្លួន[824]។ កងឈ្លបស្រុកប្រដាប់ដោយកាំភ្លើងកាប៉ាប៊ីន និងកាំភ្លើងអាកា[825] បានជួយក្នុងការចាប់ខ្លួន និងកាប់សម្លាប់នៅមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស[826]។ **អ៊ឹម ចែម** បានទទួលការណែនាំដោយផ្ទាល់ពី តាម៉ុក លើការងារចាត់ចែងក្នុងស្រុក កោះអណ្តែត[827]។

167. **អ៊ឹម ចែម** បានចូលរួមនៅក្នុងកិច្ចប្រជុំមួយចំនួនដើម្បីពិភាក្សាការងារនៅក្នុងតំបន់នេះ[828] ដូចជា ៖"ការកម្ទេច" ជនទាំងឡាយដែលបានប្រព្រឹត្តខុសសីលធម៌[829] ការប្រយុទ្ធប្រឆាំងនឹង "យួន" ឈ្លានពាន[830] ការរក្សាការប្រុងប្រយ័ត្នខ្ពស់បំផុតប្រឆាំងនឹងពលករ ដែលអាចជាអ្នកស៊ើបការណ៍[831] និងការណែនាំក្នុងការស្វែងរក "ខ្មាំងផ្ទៃក្នុង"[832]។

<u>ការចាប់ខ្លួន និងឃុំខ្លួនខុសច្បាប់</u>

168. ប្រជាជនត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅវត្តអង្គសិរីមាលីជារៀងរាល់ថ្ងៃ ក្នុងអំឡុងពេលដែល **អ៊ឹម ចែម** គ្រប់គ្រងស្រុកនេះ[833]។ ក្រុមដ៏ចម្បងដែលត្រូវបានកំណត់គោលដៅ គឺជាខ្មែរក្រោមដែលបានមកពីប្រទេសវៀតណាម ឬពីតំបន់ព្រំដែន[834]ដែលបានបន្តគោលនយោបាយដែលមានស្រាប់មុនការតែងតាំងរបស់ **អ៊ឹម ចែម**[835]។ ក្រុមផ្សេងៗទៀត ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួន រួមមាន ខ្មែរលើ[836] ជនជាតិចាម[837] និងអ្នកដែលត្រូវបានចាត់ទុកថាជា "ខ្មាំង"[838]។ លើសពីនេះទៀត ប្រជាជនពីបណ្តាភូមិនៅជុំវិញភូមិសំភី្ត និងភូមិផ្សេងៗទៀតនៅក្នុងស្រុកកោះអណ្តែត ដែលត្រូវបានចាត់ទុកថា "ជាអ្នកប្រព្រឹត្តខុស" ត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខនេះ ឬនាំយកចេញទៅសម្លាប់ និងបានបាត់ខ្លួន[839]។ ជាទូទៅ ខ្មែរក្រោមត្រូវបានកំណត់ធ្វើជាគោលដៅក្នុងការសម្លាប់តាមរយៈការបញ្ចេញសំឡេងរបស់ពួកគេ[840] ខណៈពេលដែលប្រវត្តិរូបរបស់អ្នកភូមិ ត្រូវបានរៀបចំដោយអាជ្ញាធរថ្នាក់ក្រោម[841]។

<u>លក្ខខណ្ឌអមនុស្សធម៌ ការធ្វើទារុណកម្ម និងការរំលោភបំពានផ្លូវភេទ</u>

169. ជនជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំងដែលបានកសាងឡើងនៅក្នុងឆ្នាំ ១៩៧៦ ត្រូវបានដាក់ខ្នោះជើងទាំងថ្ងៃ និងយប់[842]។ អ្នកដែលត្រូវបានឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្ន ស្ថិតនៅក្នុងសាលារៀនចាស់ មិនត្រូវបានដាក់ខ្នោះនោះទេ ប៉ុន្តែមិនអាចដើរហើរដោយសេរីឡើយនៅក្នុងមន្ទីរសន្តិសុខនេះ[843]។ អ្នកជាប់ឃុំខ្លះ ត្រូវបានសួរចម្លើយ និងទទួលរងការធ្វើទារុណកម្មមុនពេលបញ្ជូនទៅសម្លាប់នៅព្រៃសុខុន[844] ។ យ៉ាងហោចណាស់មានករណីមួយដែលស្ត្រីម្នាក់ត្រូវបានរំលោភនៅវត្តអង្គសិរីមាលី មុនពេលត្រូវបានសម្លាប់[845]។

## <u>ការសម្លាប់ដោយខុសច្បាប់</u>

170. ការសម្លាប់បានកើតឡើងជាញឹកញាប់នៅទីតាំងសម្លាប់មនុស្សព្រៃសុខុន ពេញមួយអំឡុងពេលនៃការគ្រប់គ្រងរបស់ **អ៊ឹម ចែម**[846]។ ក្រុមមនុស្សផ្សេងៗគ្នា និងពេលខ្លះ ក្រុមគ្រួសារទាំងមូលត្រូវបានសម្លាប់នៅទីតាំងនេះ។ ជនរងគ្រោះគឺជាខ្មែរក្រោម[847] "ប្រជាជន១៧មេសា" និងអ្នកដទៃទៀតដែលត្រូវបានចាត់ទុកថាជា "អ្នកស៊ើបការណ៍" ឬ "ខ្មាំង"[848]។ អ្នកដែលត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខវត្តអង្គសិរីមាលីត្រូវបានសម្លាប់នៅព្រៃសុខុន[849]។

171. មុនពេលសម្លាប់ ប្រជាជនត្រូវបានគេប្រាប់ថា ពួកគេនឹងបានត្រឡប់ទៅផ្ទះរបស់ពួកគេវិញ[850] ឬត្រូវបញ្ជូនឲ្យទៅរស់នៅកន្លែងផ្សេងទៀត[851]។ ផ្ទុយទៅវិញ ពួកគេត្រូវបានបណ្តើរចេញទៅ[852]ដោយកងឈ្លបប្រដាប់អាវុធ[853] ដោយចងស្លាបសេក[854] យកទៅសម្លាប់នៅព្រៃសុខុន[855]។ ដំបង ឬព្រនង់ត្រូវបានប្រើដោយកងឈ្លប និងទាហាន[856] ដើម្បីសម្លាប់មនុស្ស[857]។ គេបានឮសម្រែករបស់ជនរងគ្រោះមុនពេលស្លាប់[858] ហើយសាកសពរបស់ពួកត្រូវបានទុកចោលនៅកន្លែងសម្លាប់នោះ ឬកប់នៅក្នុងរណ្តៅកប់សាកសពរួម[859]។ ជនរងគ្រោះមួយចំនួនត្រូវបានកប់ទាំងរស់[860]។

172. ខ្មែរក្រហមបានព្យាយាមលាក់ការណ៍សម្ងាត់នៃការឃុំឃាំង និងការសម្លាប់នេះតាមរយៈការផ្លាស់ទីលំនៅអ្នកស្រុកដែលរស់នៅក្បែរមន្ទីរសន្តិសុខ[861] និងការរារាំងមិនឲ្យអ្នកភូមិចូលទៅកាន់ទីតាំងសម្លាប់មនុស្សព្រៃសុខុន[862]។ ទីតាំងសម្លាប់មនុស្សនេះ មានរណ្តៅសាកសពរួមធំៗពីបីទៅបួនរណ្តៅ [863] ដោយមានទំហំផ្ចិតរណ្តៅចាប់ពីប្រហែល ២០ ម៉ែត្រ និងជម្រៅពីរម៉ែត្រទៅ ១០ ម៉ែត្រគុណនឹងប្រាំម៉ែត្រ និងជម្រៅពីរម៉ែត្រ[864]។ រណ្តៅទាំងនេះធំក្លិនអាក្រក់[865] ហើយសាកសពមួយចំនួនត្រូវបានដាក់ចោលនៅលើគោក ឬកប់ពាក់កណ្តាល[866]។ បើទោះបីជាមានការប៉ាន់ស្មានខុសៗគ្នា សាក្សីបញ្ជាក់ថាមានបុគ្គលរាប់ពាន់នាក់ត្រូវបានសម្លាប់នៅព្រៃសុខុន[867]។

# ភូមិភាគពាយ័ព្យ

## (១) ការបោសសម្អាតនៅតំបន់ ៥ នៃភូមិភាគពាយ័ព្យ (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩)

173. ការបោសសម្អាតនៅភូមិភាគពាយ័ព្យ ត្រូវបានរៀបចំឡើងដោយកម្មាភិបាលជាន់ខ្ពស់បំផុតនៃបក្សកុម្មុយនីសកម្ពុជា ដោយសារតែការយល់ឃើញថាមានអំពើក្បត់របស់ពួកភូមិភាគពា-យ័ព្យ[868]។ ភូមិភាគនិរតីត្រូវបានចាត់ទុកថាជាតំបន់ដែលបដិវត្តន៍បានចាប់ផ្តើម និងមានកម្មាភិ-បាលស្មោះត្រង់ជាច្រើន[869]។

174. ការចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យបានចាប់ផ្តើម បន្ទាប់ពី **អ៊ឹម ចែម** និងក្រុមភូមិភាគនិរតីបានមកដល់នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៧[870]។ ការអះអាងរបស់ **អ៊ឹម ចែម** ថាគាត់បានមកដល់ស្រុកព្រះនេត្រព្រះនៅចុងឆ្នាំ ១៩៧៨ ឬដើមឆ្នាំ ១៩៧៩[871] គឺផ្ទុយនឹងសេចក្តីថ្លែងការណ៍របស់គាត់ផ្ទាល់។ **អ៊ឹម ចែម** បានជំនួសអតីតលេខាស្រុកឈ្មោះ អាន ម៉ោង ជាគណៈស្រុកព្រះនេត្រព្រះ[872] និងទទួលស្គាល់ថា អាន ម៉ោង បន្តរស់នៅក្នុងស្រុកព្រះនេត្រព្រះ បន្ទាប់ពីគាត់បានមកដល់[873]។ **អ៊ឹម ចែម** សារភាពថាបានជួបជាមួយ អាន ម៉ោង ដើម្បីទទួលបញ្ជីឈ្មោះប្រជាជននៅក្នុងស្រុកព្រះនេត្រព្រះ និងបញ្ជាក់ថា ក្រោយមក ម៉ោង ត្រូវបាន "ហៅទៅគោលដៅមិនស្គាល់មួយ" និងបានបាត់ខ្លួន[874]។ កំណត់ត្រានៅមន្ទីរ ស-២១ បញ្ជាក់ថា លេខាស្រុកព្រះនេត្រព្រះឈ្មោះ អាន ម៉ោង បានចូលទៅមន្ទីរ ស-២១ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ហើយត្រូវបានចាប់ខ្លួនយ៉ាងហោចណាស់ ១០ ថ្ងៃមុន[875]។ ដូច្នេះ **អ៊ឹម ចែម** ប្រាកដជាបានមកដល់ស្រុកព្រះនេត្រព្រះយ៉ាងហោចណាស់ក្នុងពាក់កណ្តាលខែ មិថុនា ឆ្នាំ ១៩៧៧។ ទីបំផុត អាន ម៉ោង ត្រូវបានសម្លាប់នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧ ជាមួយនឹងកម្មាភិបាល ៦៩ នាក់ផ្សេងទៀតមកពីភូមិភាគពាយ័ព្យ[876]។

175. **អ៊ឹម ចែម** បញ្ជាក់ថា បន្ទាប់ពី អាន ម៉ោង ត្រូវបាន "យកចេញទៅ"[877] អនុលេខាស្រុកឈ្មោះ សំអាត "ក៏បានបាត់ខ្លួនផងដែរ"[878]។ ទោះជាយ៉ាងណា កម្មាភិបាលមូលដ្ឋានម្នាក់បានរៀបរាប់ពីរបៀបដែល សំអាត ត្រូវបានចាប់ខ្លួន និងយកចេញទៅ បន្ទាប់ពីការប្រជុំ ដែលនៅពេលនោះ **អ៊ឹម ចែម** បានចោទប្រកាន់គាត់ថាជាជនក្បត់[879] ហើយកម្មាភិបាលភូមិភាគពាយ័ព្យផ្សេងទៀតនៅក្នុងកិច្ចប្រជុំនោះ ក៏ត្រូវបានចាប់ខ្លួនផងដែរ[880]។ កំណត់ត្រាបង្ហាញថា សំអាត ក៏ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ដែរ[881]។

របាយការណ៍សួរចម្លើយមួយរបស់មន្ទីរ ស-២១ ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ១៩៧៧ ពិពណ៌នាថា៖ "ការធ្វើទារុណកម្មកន្លងមក ឃោរឃៅខ្លាំងណាស់ដែរ ឯសុខភាពវាក៏ខ្សោយណាស់ដែរ ប៉ុន្តែវានៅតែធ្វើជាមិនស្គាល់អីងអីផុតលេខ"[882]។

176. ក្រៅពីអតីតលេខាស្រុកឈ្មោះ អាន ម៉ោង និងអតីតអនុលេខាឈ្មោះ សំអាត[883] កោ ឡិន បានរៀបរាប់ពីការរង់ចាំនៅក្បែរនោះ នៅពេលដែលលេខាឃុំព្រះនេត្រព្រះឈ្មោះ តា ក្រក និងកម្មាភិបាលដទៃទៀត បានទៅចូលរួមកិច្ចប្រជុំនៅឯផ្ទះរបស់ **អ៊ឹម ចែម** នៅភ្នំលៀប ជាទីកន្លែងដែលកម្មាភិបាលទាំងនោះ ត្រូវបានចាប់ខ្លួន[884]។ បន្ទាប់មកគាត់បានឮសំឡេងស្រែកចេញមកពីកន្លែងប្រជុំនេះ ដែលទំនងជាសំឡេងរបស់ តា ក្រក និងកម្មាភិបាលផ្សេងទៀតដែលកំពុងត្រូវបានសម្លាប់[885]។ អតីតលេខាឃុំភ្នំលៀបឈ្មោះ តា ធាង ត្រូវបានចាប់ខ្លួន និងសម្លាប់នៅភ្នំលៀប[886]។ នៅកម្រិតតំបន់ ៥ ប្រធានកងចល័តតំបន់ឈ្មោះ តា វ៉ាល់ លេខាតំបន់ឈ្មោះ តា ហ៊ឹង និងអនុលេខាឈ្មោះ តា ជាល បានបាត់ខ្លួន[887]។

177. ក្រៅពីឧទាហរណ៍ទាំងនេះ ការបោសសម្អាតកើតមាននៅគ្រប់កម្រិតទាំងអស់[888] ៖ ចាប់ពីសហករណ៍[889] ឃុំ[890] កងចល័ត[891] រហូតដល់ស្រុក[892] និងតំបន់[893]។ កម្មាភិបាលភូមិភាគពាយ័ព្យជាច្រើនត្រូវបានចាប់យកចេញទៅ និង "បានបាត់ខ្លួន"[894] មានន័យថាពួកគេត្រូវបានសម្លាប់[895]។ ជាសរុប កម្មាភិបាលភូមិភាគពាយ័ព្យជាង ១.២០០ នាក់ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ និងសម្លាប់ ហើយចំនួនច្រើនបំផុត គឺចាប់ពីខែ មិថុនា ឆ្នាំ ១៩៧៧ រហូតដល់ខែ ឧសភា ឆ្នាំ ១៩៧៨[896]។ បញ្ជីឈ្មោះបុគ្គលនានាពីតំបន់ ៥ ដែលត្រូវបានកត់ត្រាថាត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ក្នុងអំឡុងពេលនេះ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ៦ ទៅនឹងដីកាសន្និដ្ឋាននេះ។ លើសពីនេះទៀត ក្រុមគ្រួសាររបស់កម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរសន្តិសុខភ្នំទ្រយោងក្នុងស្រុកព្រះនេត្រព្រះ[897]។ តាម៉ុក និងកម្មាភិបាលភូមិភាគនិរតីផ្សេងទៀត រួមទាំង **អ៊ឹម ចែម** បានបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យទាំងនេះ[898]។ បន្ទាប់ពីបានដកកម្មាភិបាលភូមិភាគពាយ័ព្យចេញ **អ៊ឹម ចែម** និងកម្មាភិបាលមកពីភូមិភាគនិរតី ចាប់ផ្តើមតែងតាំងកម្មាភិបាលរបស់ខ្លួននៅតាមមុខតំណែងទំនេរជាច្រើន[899]។ ក្នុងអំឡុងពេលនោះ ប្តីរបស់ **អ៊ឹម ចែម** ឈ្មោះ ញ៉ែន ត្រូវបានតែងតាំងជាលេខាស្រុកសិរីសោភ័ណ្ឌ[900]។ ទាំងពីនាក់រួមគ្នាបានគ្រប់គ្រងស្រុកចំនួនពីរក្នុងចំណោមស្រុកទាំងបួនក្នុងតំបន់ ៥។

178. ការបោសសម្អាតត្រូវបានជួយដោយសេចក្តីសម្រេចរបស់ **អ៊ឹម ចែម** ដោយទទួលបានការអនុម័តពីថ្នាក់លើឱ្យដកហូតអាវុធ[901] និងចាប់ខ្លួន[902] យោធាដែលកំពុងបំពេញការងារនៅក្នុងតំបន់នេះ និងទប់ស្កាត់មិនឱ្យមានការតស៊ូណាមួយឡើយ។ **អ៊ឹម ចែម** ត្រូវបានអមដំណើរដោយក្រុមយោធាផ្ទាល់ខ្លួនរបស់គាត់ទៅកាន់ភូមិភាគពាយ័ព្យ[903]។

## (២) ការធ្វើទុក្ខបុកម្នេញចំពោះវៀតណាម (១៩៧៧-១៩៧៩)

### <u>គោលនយោបាយ បកក ទាក់ទងនឹងវៀតណាម</u>

179. បកក បានបញ្ជា និងរឹតបន្តឹងការអនុវត្តគោលនយោបាយមួយនៃការនិរទេសដោយបង្ខំនូវ ជាតិពន្ធុ វៀតណាមនៅកម្ពុជា ភ្លាមៗបន្ទាប់ពីពួកគេបានឡើងកាន់អំណាច[904]។ គិតត្រឹមខែកញ្ញា ឆ្នាំ១៩៧៥ ជាតិពន្ធុវៀតណាមប្រមាណ ១៥០.០០០នាក់ ត្រូវបាននិរទេសទៅកាន់ប្រទេសវៀតណាម[905]។ ចាប់ពីឆ្នាំ១៩៧៧ គោលនយោបាយរបស់ បកក បានវិវឌ្ឍន៍ទៅជាការសម្លាប់រង្គាលចំពោះជនជាតិវៀតណាមដែលនៅសល់នៅក្នុងប្រទេស[906](ភាគច្រើនជាប្តីប្រពន្ធ ឬជាកូននៃគ្រួសារកូនកាត់នៃជាតិពន្ធុវៀតណាម)។ ជាការបន្ថែម អ្នកដែលគេយល់ថា ពាក់ព័ន្ធ ឬមានសម្ព័ន្ធភាពជាមួយវៀតណាម ត្រូវបានចាត់ទុកថា "ខ្មាំង" និង ត្រូវបានកំណត់គោលដៅសម្រាប់មូលហេតុនោះ[907]។

180. បកក បានផ្តល់យុត្តិកម្មនៃការសម្លាប់ទាំងនេះដោយផ្អែកលើសកម្មភាពវាតទីនិយមជាប្រវត្តិសាស្ត្ររបស់វៀតណាម មកលើកម្ពុជា និងជម្លោះប្រដាប់អាវុធដែលមានស្រាប់[908]។ ការឃោសនារបស់ បកក សង្កត់ធ្ងន់ថាវត្តមានតែមួយគត់របស់វៀតណាមនៅក្នុងប្រទេសកម្ពុជា គឺជាការគំរាមកំហែងមួយចំពោះការរស់រានមានជីវិតរបស់ប្រទេស និងពូជសាសន៍ខ្មែរ[909]។ ត្រឹមឆ្នាំ១៩៧៩ ជនជាតិវៀតណាម បើមិនទាំងអស់ ក៏មួយចំនួនធំដែលនៅសេសសល់នៅក្នុងប្រទេសកម្ពុជា ត្រូវបានសម្លាប់[910] ព្រមទាំងជាច្រើនរាប់មិនអស់ផ្សេងទៀតដែលគេបានចាត់ទុកថា "ខ្មាំង" ដោយសារជាប់ពាក់ព័ន្ធជាមួយវៀតណាម[911]។

## <u>ការប្រាស្រ័យទំនាក់ទំនងនៃគោលនយោបាយ បកក ទាក់ទងនឹងវៀតណាម</u>

181. ថ្នាក់ដឹកនាំ បកក បានផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួនប្រឆាំងនឹងជាតិពន្ធុវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយវៀតណាម ដល់ថ្នាក់ក្រោមតាមរយៈសុន្ទរកថា[912] ការប្រជុំ[913] វគ្គអប់រំគោលនយោបាយ[914] និងឯកសារឃោសនាផ្សេងៗទៀត[915]។

182. បន្ទាប់ពីការមកដល់របស់ពួកគេនៅភូមិភាគពាយ័ព្យនៅពាក់កណ្តាលឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតី បានចាប់ផ្តើមធ្វើការកំណត់អត្តសញ្ញាណជាតិពន្ធុវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយវៀតណាម ជាផ្នែកនៃ "ខ្សែបណ្តាញយួន" នៅក្នុងការប្រជុំនានា[916]។ **អ៊ឹម ចែម** បាននិយាយគ្នាអំពី "ការសម្រិតសម្រាំងជនជាតិ" ក្នុងស្រុកព្រះនេត្រព្រះ[917]។ សាក្សីនានាក៏បានរំលឹកឡើងវិញអំពីពួកកម្មាភិបាលនិរតី បានធ្វើការវាយប្រហារទៅលើជនជាតិវៀតណាម ថាជា "ខ្មាំង" នៅក្នុងសុន្ទរកថានានានៅក្នុងស្រុកនេះដែរ[918]។ អ្នកភូមិ និងសមាជិកសហករណ៍ ត្រូវបានគេតម្រូវឲ្យ "រាយការណ៍ជូនអង្គការ" អំពីវត្តមាន "វៀតណាមដែលកំពុងលាក់ខ្លួននៅក្នុងចំណោមប្រជាជន"[919]។

183. ពាក្យរើសអើង "យួន" ដែលកម្ពុជាប្រជាធិបតេយ្យបានបញ្ជាក់មានន័យថា "សាហាវ"[920] ដែលតែងតែត្រូវបានប្រើប្រាស់ដោយ **អ៊ឹម ចែម**[921] និងអ្នកដឹកនាំ បកក ដទៃទៀត[922] ដើម្បីរីកសាយនូវភាពភ័យខ្លាច និងកំហឹងចំពោះជនជាតិវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយវៀតណាម នៅក្នុងអង្គប្រជុំ[923] និងតាមរយៈឯកសារឃោសនានានា[924]។ **អ៊ឹម ចែម** បានបន្តប្រើប្រាស់ពាក្យនេះ រហូតដល់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[925]។ ជនណាក៏ដោយដែលគេបានចាត់ទុកថា "យួន" ត្រូវបានគេចាត់ទុកថាជាខ្មាំងរបស់ បកក ដែលត្រូវកម្ទេចចោល[926]។ ការបញ្ជាឲ្យសម្លាប់អ្នកដែលជាប់ពាក់ព័ន្ធនឹងវៀតណាម ហើយអ្នកដែលគេជឿខ្លាំងជាងនេះ គឺជាតិពន្ធុ ឬជនជាតិវៀតណាមតែម្តង ត្រូវបានគេធ្វើការប្រាស្រ័យទំនាក់ទំនងគ្នានៅគ្រប់ថ្នាក់ទាំងអស់[927]។

## ការអនុវត្តគោលនយោបាយ នៅក្នុងតំបន់៥

184. ការកំណត់គោលដៅ និងការសម្លាប់វៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយវៀតណាម បានកើនឡើងនៅក្នុងតំបន់៥ នៅក្រោយការមកដល់របស់ **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតី[928]។ **អ៊ឹម ចែម** បានសារភាពអំពីការទទួលបញ្ជាពីថ្នាក់លើឲ្យស្រាវជ្រាវរក និងចាប់ខ្លួន "ភ្នាក់ងារវៀតណាម"[929]។

185. វិធីសាស្ត្រខុសៗគ្នាត្រូវបានគេប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណជាតិពន្ធុវៀតណាម។ ជាឧទាហរណ៍ បុគ្គលម្នាក់ៗជាញឹកញាប់ត្រូវបានគេចាត់ទុកជាវៀតណាម ដោយផ្អែកលើពណ៌សម្បុរ[930]។ សាក្សីម្នាក់ដែលរស់នៅព្រះនេត្រព្រះ បានរៀបរាប់អំពីការចាប់ខ្លួនឪពុករបស់គាត់ដោយកងឈ្លប និងត្រូវបានយកទៅសម្លាប់ចោលដោយសារគេចោទថាជា"យួន" ដោយសារគាត់ស[931]។ វៀតណាមជាញឹកញាប់ក៏ត្រូវបានគេកំណត់អត្តសញ្ញាណ តាមរយៈសំនៀងនៃការនិយាយរបស់ពួកគេផងដែរ[932]។ អ្នកផ្សេងទៀតណាក៏ដោយដែលមិនចេះនិយាយខ្មែរ ក៏អាចត្រូវបានចាត់ទុកថាវៀតណាម និងត្រូវបានសម្លាប់ចោលផងដែរ[933]។

186. ក្នុងចំណោមជាតិពន្ធុវៀតណាមទាំងនោះ ក៏ត្រូវបានគេរកឃើញតាមរយៈការស្រាវជ្រាវតាមប្រវត្តិសាវតារ និងការបង្កើតជីវប្រវត្តិផងដែរ[934]។ សាក្សី ប្រាក់ គឿន បានរៀបរាប់អំពីកម្មាភិបាលនៅព្រះនេត្រព្រះ និយាយគ្នាពីការចង់សម្លាប់គាត់នៅក្រោយពេលគាត់បានលាតត្រដាងថា ឪពុករបស់ខ្លួនជាវៀតណាម[935]។ ជីវប្រវត្តិ ត្រូវបានគេបញ្ជូនទៅថ្នាក់លើ រួមទាំង **អ៊ឹម ចែម** ផងដែរដែលបន្ទាប់មកក៏បានចេញបញ្ជាទាក់ទងនឹងជនដែលត្រូវបានគេកំណត់អត្តសញ្ញាណថាជា វៀតណាម[936]។ **អ៊ឹម ចែម** ក៏បានទទួលបញ្ជីមួយដែលកំណត់អត្តសញ្ញាណមនុស្សទាំងអស់នៅក្នុងព្រះនេត្រព្រះ ផងដែរ បន្ទាប់ពីគាត់បានក្លាយជាលេខាស្រុកនេះ[937]។

187. អ្នកណាដែលត្រូវបានគេចោទថា "ភ្នាក់ងារ" ឬ "ចារកម្ម" វៀតណាម[938] ឬ "មានការជាប់ពាក់ព័ន្ធ" នឹងវៀតណាម[939] ក៏ត្រូវបានចាប់ខ្លួនផងដែរ[940]។ **អ៊ឹម ចែម** ធ្លាប់បាននិយាយក្រោយទទួលបានសំណើពីថ្នាក់លើឲ្យស្រាវជ្រាវរកមនុស្សទាំងនោះថាពួកគេ "ត្រូវបានចាប់ខ្លួនអស់ហើយ"[941]។

188. បន្ថែមទៅលើបុគ្គលម្នាក់ៗដែលត្រូវបានគេកំណត់អត្តសញ្ញាណជាវៀតណាម ឬមានជាប់ពាក់ព័ន្ធជាមួយវៀតណាម ដៃគូរបស់ពួកគេ និងក្រុមគ្រួសារទាំងមូល ក៏ត្រូវបានសម្លាប់ចោលរួមទាំងកុមារ[942]។

ឧទាហរណ៍ សាក្សី **ប៊ូ ម៉ៅ** ដែលជាប្រធានអង្គភាពទំនប់អាងត្រពាំងថ្ម បានរៀបរាប់ពីរបៀបដែលក្រុមគ្រួសារនានា និងកូនៗរបស់ពួកអ្នកដែលគេរកឃើញថាជាប់សាច់ឈាម ឬជាប់ពាក់ព័ន្ធជាមួយនឹងវៀតណាម ត្រូវបានគេស្រាវជ្រាវ និងសម្លាប់ចោលនៅការដ្ឋាននេះ[943]។

189. ការអនុវត្តគោលនយោបាយនៃការកំណត់គោលដៅវៀតណាម និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយ វៀតណាម បានកើតឡើងក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** នៅទូទាំងព្រះនេត្រព្រះ និងតំបន់៥ទាំងមូល។ នៅមន្ទីរចំការខ្នុរ[944] ជនរងគ្រោះភាគច្រើនដែលបានចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ចោល គឺជាវៀតណាម[945]។ សាក្សី **ស៊ិន ឃិន** បានរៀបរាប់ពីការដឹកមនុស្សទាំងឡាន១ យកទៅសម្លាប់នៅទីតាំងសម្លាប់មនុស្សព្រៃតារុត ដែលនៅជាប់នោះ[946]។ សាក្សី **ម៉ក់ វន្នី** អតីតកម្មករកងចល័តដែលរស់នៅក្បែរព្រៃតារុត និយាយថា អ្នកដែលគេយកទៅសម្លាប់គឺជាអ្នកដែលគេចោទថាវៀតណាម[947]។

190. អ្នកដែលគេចោទថា វៀតណាម ក៏ត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខភ្នំត្រយោងផងដែរ[948]។ សាក្សី **អៀ លឿ** ត្រូវបានឃុំខ្លួនដោយសារតែគាត់មានស្បែកស ហើយដូច្នេះត្រូវបានសន្មត់ថាជាវៀតណាម[949]។ មនុស្សមួយក្រុមមានគ្នាប្រហែល១៥-២០នាក់ រួមទាំងអ្នកដែលត្រូវបានចោទថាមានការជាប់ពាក់ព័ន្ធជាមួយនឹងវៀតណាម ត្រូវបានគេសម្លាប់ចោលនៅភ្នំត្រយោងនេះក្នុងមួយយប់ៗ[950]។

191. នៅការដ្ឋានទំនប់អាងត្រពាំងថ្ម កម្មករជាវៀតណាម ឬកម្មករត្រូវបានចោទថាមានការជាប់ពាក់ព័ន្ធជាមួយវៀតណាម ត្រូវបានគេតាមរុករក និងសម្លាប់ចោល[951]។ សាក្សី **ប៊ុត ស៊្វីយ** អតីតប្រធានកងចល័តនៅទំនប់អាងត្រពាំងថ្ម បានរៀបរាប់អំពីគ្រួសារវៀតណាមចំនួន ១០០០គ្រួសារ ត្រូវបានគេបញ្ជូនពីសហករណ៍ផ្សេងៗគ្នា មកកាន់ទំនប់អាងត្រពាំងថ្ម ក្នុងឆ្នាំ១៩៧៨ ហើយក្រោយមក ពួកគេទាំងអស់បានបាត់ខ្លួន[952]។

192. នៅការដ្ឋានស្ពានស្រែង **អ៊ឹម ចែម** បានបញ្ជាឲ្យសម្លាប់ស្ត្រីវៀតណាមពីរនាក់ ដែលត្រូវបានគេរំលោភសេពសន្ថវៈយ៉ាងព្រៃផ្សៃ មុននឹងសម្លាប់ចោល[953]។ សាក្សីក៏ផ្តល់អត្តសញ្ញាណកម្ម និងការសម្លាប់គ្រួសារវៀតណាមទាំងគ្រួសារៗ នៅក្បែរឃុំស្ពានស្រែងក្នុងឆ្នាំ១៩៧៨[954] ផងដែរ។

01342087



## (៣) មន្ទីរសន្តិសុខ និងការដ្ឋានភ្នំទ្រយោង (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩)

<u>ទីតាំង និងដំណើរការ</u>

193. មន្ទីរសន្តិសុខភ្នំទ្រយោង ការដ្ឋានវាយថ្ម និងការដ្ឋានពាក់ព័ន្ធផ្សេងៗទៀត ស្ថិតនៅភ្នំទ្រយោង ក្នុងឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ តំបន់ ៥ នៃភូមិភាគពាយ័ព្យ[955]។ មន្ទីរសន្តិសុខ និងការដ្ឋានទាំងនេះត្រូវបានបង្កើតឡើង និងគ្រប់គ្រងដោយកម្មាភិបាលភូមិភាគនីរតី[956] នៅឆ្នាំ ១៩៧៧[957] និងបន្តប្រតិបត្តិការរហូតដល់អំឡុងខែ មករា ឆ្នាំ ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់[958]។

194. មន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានពាក់ព័ន្ធ ស្ថិតក្នុងទីតាំងដ៏ធំលើផ្ទៃដីជាង ២ ហិចតា[959]។ ទីតាំងនេះមានកន្លែងឃុំឃាំង និងផ្ទះខ្ទមជាច្រើន រោងបាយមួយ ការដ្ឋានវាយថ្ម និងវាលស្រែ[960] ហើយដោយសារមានអ្នកទោសច្រើន មន្ទីរសន្តិសុខនេះត្រូវបានបន្ថែមទៀត[961]។ យើងអាចធ្វើដំណើរទៅដល់ភ្នំត្រឡោក តាមផ្លូវរទេះគោដោយឆ្លងកាត់មន្ទីរសន្តិសុខពីជើងទៅត្បូងចេញពីផ្លូវជាតិលេខ ៦[962]។ ស្ថិតនៅភាគខាងជើងនៃភ្នំនេះមានមន្ទីរឃុំឃាំង "អ្នកទោសធ្ងន់"[963] រោងអ្នកយាម និងផ្ទះរបស់មេគុក[964] និងរណ្ដៅសាកសពរួមដ៏ធំសម្រាប់កប់អ្នកដែលត្រូវបានសម្លាប់ ឬស្លាប់ដោយសារភាពអត់ឃ្លាន ជំងឺ ឬការងារធ្ងន់[965]។ "អ្នកទោសស្រាល"[966] ត្រូវបានឃុំឃាំងនៅខាងកើត និងខាងត្បូងភ្នំនេះ ហើយមានរោងបាយ និងទីធ្លាមួយ ស្ថិតនៅចន្លោះផ្ទះមេគុក និងបន្ទប់ឃុំឃាំង "អ្នកទោសស្រាល"[967]។

195. ការដ្ឋានវាយថ្មស្ថិតនៅភាគនីរតីនៃភ្នំ[968] ដោយមានអ្នកយាមចាំការពារ[969]។ វាលស្រែស្ថិតនៅព័ទ្ធជុំវិញភ្នំនេះ[970]។ មន្ទីរសន្តិសុខភ្នំទ្រយោងគ្មានរបងព័ទ្ធនោះទេ ហើយគេហៅវាថាជា "គុកឥតជញ្ជាំង"[971]។ នៅពេលដែលវៀតណាមចូលមកដល់ ខ្មែរក្រហមបានត្រៀមពង្រីកមន្ទីរសន្តិសុខមួយផ្សេងទៀត[972]។ បច្ចុប្បន្ននេះ គេមិនឃើញមានស្លាកស្នាមមន្ទីរសន្តិសុខនេះទៀតឡើយ[973]។

<u>រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង</u>

196. មន្ទីរសន្តិសុខភ្នំទ្រយោងឃុំឃាំងអ្នកទោសដែលបញ្ជូនមកពីស្រុកផ្សេងៗក្នុងតំបន់នេះ[974] ដោយមាន **អ៊ឹម ចែម** ជាអ្នកគ្រប់គ្រងរួម[975] និងមានសិទ្ធិអំណាចយ៉ាងទូលំទូលាយ ដូចជា បង្កើតបទបញ្ជា និង

គោលនយោបាយរបស់មន្ទីរសន្តិសុខ[976] ចេញបញ្ជាឱ្យចាប់ខ្លួន និងឃុំខ្លួនអ្នកទោសនៅមន្ទីរសន្តិសុខ[977] ចេញបញ្ជាឱ្យដាក់ខ្នោះ ឬដោះលែងអ្នកទោស[978] និងបញ្ជាឱ្យសម្លាប់[979]។ ប្រធានសហករណ៍ និងគណៈឃុំរាយការពីការចាប់ខ្លួននានាទៅ **អ៊ឹម ចែម**[980] ដែលចេញបញ្ជាឱ្យចាប់ខ្លួន និងបញ្ជូនអ្នកដែលត្រូវបានចាប់ខ្លួនទៅភ្នំទ្រយោង[981]។

197. ទុំ សឿន គឺជាប្រធានមន្ទីរសន្តិសុខនេះ[982] និងត្រូវបានចាត់តាំងដោយ **អ៊ឹម ចែម**[983]។ គណៈឃុំបានបញ្ជូនឆ្មាំនៅមន្ទីរសន្តិសុខភ្នំត្រយោងឱ្យមកធ្វើការក្នុងគុកនេះ[984]។ មានឆ្មាំប្រហែល ១៥-៣០ នាក់[985] ប្រដាប់ដោយកាំភ្លើង និងដាវ[986]។

198. ទុំ សឿន ត្រូវរាយការផ្ទាល់មាត់ទៅ **អ៊ឹម ចែម** ប្រហែលជាម្តងទៅពីរដងក្នុងមួយខែ[987]។ **អ៊ឹម ចែម** ដាក់បញ្ជាឱ្យគាត់អនុវត្ត[988] ដូចជា ថាតើត្រូវដាក់ខ្នោះ ឬដោះលែងអ្នកទោស[989]។ **អ៊ឹម ចែម** ហៅអ្នកយាមគុកទៅប្រជុំនៅផ្ទះរបស់គាត់[990] និងការប្រជុំធំៗនៅគុក[991]។ នៅពេលនោះ **អ៊ឹម ចែម** *ក្នុងចំណោមចំណុចផ្សេងទៀត* បានប្រាប់អ្នកទោសឱ្យខំបង្កបង្កើនផល និងព្រមានថា អ្នកដែលមិនអាចកសាងខ្លួនបាននឹងត្រូវស្លាប់[992]។

199. នីរសាររបស់ **អ៊ឹម ចែម** តែងតែចុះមកមើលគុក និងនាំយកបទបញ្ជា និងសំបុត្រពាក់ព័ន្ធនឹងអ្នកទោស[993] ។ សាក្សីឈ្មោះ ធិប សំផាត់ ដែលជាគ្រូពេទ្យមូលដ្ឋានម្នាក់ បានរៀបរាប់ថា គាត់បានឃើញសំបុត្រមួយច្បាប់ពី **អ៊ឹម ចែម** ដែលបញ្ជាឱ្យចាប់ខ្លួនគាត់ បូករួមនឹងអ្នកទោសពីរនាក់ទៀតដោយចោទថាជា "អ្នកក្បត់បដិវត្តន៍"[994]។ សាក្សីឈ្មោះ ភួន ស៊ុនទី បានរៀបរាប់លម្អិតថា គាត់បានទទួលសំបុត្រមួយពី **អ៊ឹម ចែម** ដែលជាសំបុត្រសរសេរដោយដៃ ដោយមានចុះហត្ថលេខារបស់ **អ៊ឹម ចែម**។ សំបុត្រនោះប្រាប់ឱ្យគាត់ និងសមមិត្ត សាមុន ឡើងមករៀនសូត្រនៅភ្នំលៀប[995]។ បន្ទាប់ពីបានមកដល់ផ្ទះរបស់ **អ៊ឹម ចែម**, **អ៊ឹម ចែម** បានបញ្ជូនគាត់ទៅភ្នំទ្រយោង ជាទីដែលគាត់បានជួបឃោធាប្រដាប់អាវុធ និងត្រូវបានគេដាក់ខ្នោះ[996]។

<u>ការចាប់ខ្លួន និងឃុំខ្លួនដោយខុសច្បាប់</u>

200. មន្ទីរសន្តិសុខភ្នំទ្រយោងត្រូវបានពង្រីកជាបន្តបន្ទាប់ ដើម្បីដាក់អ្នកទោសរាប់ពាន់នាក់ក្នុងអំឡុងពេលធ្វើប្រតិបត្តិការ[997]។ **អ៊ឹម ចែម** ជាអ្នកចេញបញ្ជាឱ្យចាប់ខ្លួន[998]។ បទបញ្ជាទាំងនោះត្រូវបានអនុវត្តដោយ

កងឈ្លប[999] ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់គាត់[1000]។ អ្នកដែលត្រូវបានចាប់ខ្លួនត្រូវបញ្ជូនមកគុកនេះជារៀងរាល់ពីរបីថ្ងៃម្តង[1001] ដោយថ្មើរជើង[1002] ដឹកតាមរទេះគោ[1003] ត្រាក់ទ័រ[1004] ឡាន[1005] ឬម៉ូតូ[1006] ហើយជាទូទៅ ពួកគេត្រូវបានដាក់ខ្នោះ ឬចងស្លាបសេក[1007]។ មេគុក ឬអ្នកយាមទទួលយកអ្នកទោសទាំងនោះ[1008] និងបែងចែកជា "អ្នកទោសស្រាល" និង "អ្នកទោសធ្ងន់"[1009]។ ក្រៅពីនេះ អ្នកទោសក៏ត្រូវបានបញ្ជូនពីមន្ទីរសន្តិសុខផ្សេងៗទៀតមកកាន់ភ្នំទ្រយោងផងដែរ[1010]។

201. អ្នកទោស រួមមានអ្នកដែលគេជឿថាជាជនជាតិវៀតណាម ឬ ពាក់ព័ន្ធនឹងវៀតណាម[1011] ត្រូវបានចោទថាជាជនក្បត់ ដោយសារតែពួកគេបានទិតៀនរឿងហូបចុកមិនគ្រប់គ្រាន់[1012] អត់ឃ្លាន និងលួចអាហារ[1013] ត្រូវបានចោទពីបទចោរកម្ម[1014] ព្យាយាមរត់គេចខ្លួន[1015] បានប្រព្រឹត្ត "ខុសសីលធម៌"[1016] ត្រូវបានចាត់ទុកថា "ខ្ជិល ឬខ្សោយ"[1017] ឬត្រូវបានឆ្លើយដាក់ដោយអ្នកដទៃ[1018]។ អ្នកទោសជាច្រើនមិនបានដឹងពីមូលហេតុដែលពួកគេត្រូវបានចាប់ខ្លួនឡើយ[1019]។ មនុស្សទាំងគ្រួសារត្រូវបានចាប់ខ្លួនរួមគ្នា[1020] រួមទាំង កូនក្មេង[1021]។ សាច់ញាតិរបស់មន្ត្រីដែលធ្លាប់បម្រើការក្នុងរបប លន់ នល់[1022] និងសាច់ញាតិរបស់អ្នកដែលត្រូវបានឃុំខ្លួន ក៏ជាចំណុចផ្តោតនៃការចាប់ខ្លួនផងដែរ[1023]។

202. អ្នកដែលត្រូវបានចាប់ខ្លួនជាច្រើនត្រូវបានបញ្ជូនទៅផ្ទះរបស់ **អ៊ឹម ចែម** នៅភ្នំលៀប ដែលមានចម្ងាយតិចជាង ១ គីឡូម៉ែត្រពីមន្ទីរឃុំឃាំង[1024] មុនពេលត្រូវបានបញ្ជូនបន្តទៅមន្ទីរសន្តិសុខ[1025]។

203. ប្រជាជនបានអង្វរឲ្យ **អ៊ឹម ចែម** ដោះលែងអ្នកដែលត្រូវបានចាប់ខ្លួន ឬទុកជីវិតរបស់ពួកគេ[1026]។ ប៊ុត ស្វយ ដែលត្រូវបានឃុំឃាំងក្នុងសាលាឃុំភ្នំលៀបដោយសារមិនមានលិខិតធ្វើដំណើរ ត្រូវបានដោះលែងបន្ទាប់ពីមេបញ្ជាការកងវរសេនាតូច (ប្រធានវីរៈ) របស់គាត់ទាក់ទងទៅ **អ៊ឹម ចែម**[1027]។ គិម យ៉េត ដែលត្រូវបានជាប់ឃុំនៅគុកភ្នំទ្រយោង ជឿជាក់ថា គាត់នឹងត្រូវបានយកទៅសម្លាប់ រហូតទាល់តែប្រធានមន្ទីរសន្តិសុខឈ្មោះ ទុំ សឿន ធ្វើអន្តរាគមន៍ បន្ទាប់ពីម្តាយរបស់គាត់បានស្នើ **អ៊ឹម ចែម** ឲ្យដោះលែងកូនរបស់គាត់[1028]។

## លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌

204. "អ្នកទោសធ្ងន់" ត្រូវបានគេដាក់ខ្នោះនៅពេលយប់ក្នុងរោងប្រក់ស័ង្កសី និងជញ្ជាំងបិទស័ង្កសីយ៉ាងវែង និងត្រូវបានដោះលែងឲ្យធ្វើការនៅពេលថ្ងៃ[1029] ចំណែក "អ្នកទោសស្រាល" ត្រូវបានឃុំឃាំងក្នុងរោង និង

ខ្ទមដោយមិនដាក់ខ្នោះ[1030]។ អ្នកទោសដែលត្រូវបានកំណត់ថាជា "អ្នកទោសធ្ងន់" រួមមាន អ្នកដែលត្រូវបានចាប់ខ្លួនពីបទព្យាយាមរត់គេចខ្លួន[1031] អ្នកដែលចាត់ទុកថា "ខ្ជិលធ្វើការ"[1032] និងអ្នកដែលត្រូវបានចោទប្រកាន់ពីបទលួចប្លន់ស្រូវ[1033]។ ក្នុងកាលៈទេសៈមួយចំនួន **អ៊ឹម ចែម** អនុញ្ញាតឲ្យប្រធានមន្ទីរសន្តិសុខឈ្មោះ ទុំ សឿន ធ្វើការកំណត់ឡើងវិញពី "អ្នកទោសធ្ងន់" ទៅជា "អ្នកទោសស្រាល[1034] ជាថ្មីម្តងទៀត នេះបង្ហាញអំពីអំណាចរបស់គាត់។

205. អង្ករត្រូវបានដឹកពីឃ្លាំងមួយនៅក្បែរផ្ទះរបស់ **អ៊ឹម ចែម**[1035]។ ជាទូទៅ របបអាហារមិនគ្រប់គ្រាន់នោះទេ គឺទទួលបានត្រឹមតែបបររាវប៉ុណ្ណោះ[1036] ដែលធ្វើឲ្យអ្នកទោសមានភាពអត់ឃ្លាន[1037]។ ពលករត្រូវបានបង្ខំឲ្យរស់នៅក្នុងស្ថានភាពកខ្វក់ និងត្រូវសុំច្បាប់គ្រប់ពេលនៅពេលត្រូវការបត់ជើងបត់ដៃ[1038]។ គេដាក់ខ្នោះអ្នកទោស និងបញ្ជូនឲ្យទៅមុជទឹក ដោយមានភ្ជង់កាំភ្លើងពីក្រោយផងដែរ[1039]។ ទោះបីជាអ្នកទោសមួយចំនួនទទួលបានការព្យាបាលក្តី[1040] ក៏អ្នកទោសផ្សេងទៀតបានស្លាប់ដោយសារគ្មានថ្នាំសង្កូវ[1041] ឬទទួលបានត្រឹមតែបបរស្លរប៉ុណ្ណោះ[1042]។ អ្នកទោសរាប់ពាន់នាក់បានស្លាប់ដោយសារភាពអត់ឃ្លាន ជំងឺ និងការងារធ្ងន់[1043]។ ប៊ូ តួក រៀបរាប់ថា គាត់ត្រូវដេកជាមួយខ្មោច ពីព្រោះគេមិនទាន់យកចេញ[1044]។

<u>ការងារដោយបង្ខំ</u>

206. អ្នកទោសនៅគុកភ្នំទ្រយោងត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ។ អ្នកទោសធ្ងន់ត្រូវបានបង្ខំឲ្យធ្វើការនៅការដ្ឋានវាយថ្មនៅក្បែរនោះ[1045]។ អ្នកទោសត្រូវឡើងទៅលើភ្នំគាស់ថ្ម[1046] ហើយទម្លាក់មកឲ្យអ្នកខាងក្រោមរើបំបែកដោយប្រើញញួរធំ[1047]។ លក្ខខណ្ឌនេះគឺគ្មានសុវត្ថិភាពឡើយ ហើយអ្នកទោសមួយចំនួនត្រូវថ្មរមៀលសង្កត់ពីលើស្លាប់ និងត្រូវបានយកទៅសម្លាប់[1048]។

207. ក្រៅពីនេះ អ្នកទោសត្រូវបានបង្ខំឲ្យធ្វើការងារកសិកម្ម ដូចជា ធ្វើជី[1049] គាស់ឫស្សី[1050] និងធ្វើស្រែ[1051] និងដាំដំណាំផ្សេងទៀត[1052]។ អ្នកទោសផ្សេងទៀតត្រូវធ្វើការក្នុងមន្ទីរសន្តិសុខ[1053] ដូចជា សង់ផ្ទះ និងធ្វើខ្នោះ[1054] និងចម្អិនអាហារ[1055]។ ក្រៅពីនេះ អតីតអ្នកទោសបានប្រាប់ថា ពួកគេត្រូវបានបង្ខំឲ្យសែងសាកសពអ្នកទោស ដែលត្រូវបានសម្លាប់ និងស្លាប់ដោយអត់បាយទៅកប់[1056]។ នូ ខាំ រៀបរាប់ថា គាត់មានក្លិនស្អុយជាប់ខ្លួន និងពេលខ្លះដើរធ្លាក់រណ្តៅសពនៅពេលយប់[1057]។

## ការធ្វើទារុណកម្មនិងការរំលោភបំពានផ្លូវភេទ

208. នៅក្នុងអង្គប្រជុំនៅភ្នំទ្រយោង **អ៊ឹម ចែម** បានព្រមានថា អ្នកដែលមិនអាចកសាងខ្លួនបាននឹងត្រូវស្លាប់[1058]។ អ្នកទោសត្រូវបាននាំទៅសួរចម្លើយពីសាវតារ និងកំហុសរបស់ខ្លួន ហើយពេលខ្លះធ្វើឡើងដោយហិង្សា[1059]។

209. អ្នកយាមធ្វើទារុណកម្មអ្នកទោស ហើយពេលខ្លះរហូតដល់ស្លាប់[1060]។ អ្នកទោសផ្សេងទៀតត្រូវបានវាយនឹងរំពាត់ឫស្សី និងដំបងឈើយ៉ាងព្រៃផ្សៃ ដោយសារការប្រព្រឹត្តិខុសឆ្គងតិចតួច ដូចជា គ្មានកម្លាំងធ្វើការ[1061]។ អតីតអ្នកទោសឈ្មោះ ឡេង វ៉ុង រៀបរាប់ថា គាត់បានឃើញគេឲ្យអ្នកទោសដេកផ្ងារមុខឡើង ហើយក្រោយមក អ្នកយាមរត់ជាន់ពីលើពួកគេចុះឡើង។ ក្រោយមក គេឲ្យអ្នកទោសទាំងនោះដេកផ្កាប់មុខ ហើយអ្នកយាមបានយកដំបងវាយដំទៅលើពួកគេ[1062]។

210. អ្នកទោសត្រូវរស់នៅដោយភ័យខ្លាចជាប្រចាំថា ខ្លួននឹងត្រូវបានយកទៅសម្លាប់[1063] បន្ទាប់ពីបានឃើញការបាត់ខ្លួនរបស់អ្នកទោសផ្សេងទៀត[1064] បានស្តាប់ឮសំឡេងមនុស្សត្រូវបានសម្លាប់ និងចាប់រំលោភ[1065] ត្រូវបានវាយដំរហូតដល់ស្លាប់[1066] និងបង្ខំឲ្យជីករណ្ដៅកប់សាកសព[1067]។

211. អតីតអ្នកទោសឈ្មោះ ជុំ ជិម រៀបរាប់ពីរបៀបដែលអ្នកយាមអនុញ្ញាតឲ្យក្មេងស្រីទៅរស់នៅជាមួយឪពុកម្ដាយរបស់ពួកគេវិញនៅពេលថ្ងៃ ប៉ុន្តែបានចាប់រំលោភក្មេងស្រីទាំងនោះក្នុងរោងអ្នកយាមនៅពេលយប់[1068]។ ធិប សំផាត់ ដែលបានជីកកប់សាកសពរបស់អ្នកទោសដែលត្រូវបានសម្លាប់ ឃើញថាមានតែសាកសពអ្នកទោសស្រីប៉ុណ្ណោះដែលគ្មានសម្លៀកបំពាក់[1069]។

## ការសម្លាប់ដោយខុសច្បាប់

212. អ្នកទោសរាប់ពាន់នាក់មកពីស្រុក និងតំបន់ត្រូវបានគេយកមកសម្លាប់នៅភ្នំទ្រយោង[1070]។ អ្នកយាមបានសម្លាប់អ្នកទោសទៅតាមអំណាចរបស់ ទុំ សឿន[1071] ដែលទទួលបញ្ជាពី **អ៊ឹម ចែម**[1072]។ ឧទាហរណ៍ **អ៊ឹម ចែម** បញ្ជាឲ្យ ទុំ សឿន សម្លាប់អ្នកទោស ៤ នាក់ដែលបានទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរ[1073]។

213. ការសម្លាប់អ្នកទោសធ្វើឡើងជារៀងរាល់ថ្ងៃ[1074]នៅតាមទីតាំងជាច្រើននៅខាងជើងភ្នំ[1075]។ អ្នកទោសត្រូវបានបង្ខំឱ្យជីករណ្តៅសាកសពរួមសម្រាប់កប់សាកសព[1076] ហើយទីតាំងមួយស្ថិតនៅចម្ងាយប្រហែលជា ១០០ ទៅ ២០០ ម៉ែត្រពីខ្ទមរបស់ សឿន[1077]។ អ្នកយាមសម្លាប់អ្នកទោសដោយធាងត្នោត[1078] និងកាំបិតមុតស្រួច[1079] ឬវាយជនរងគ្រោះនឹងដំបង ឬចបកាប់រហូតដល់ស្លាប់[1080]។ អ្នកយាមខ្លះដែលសម្លាប់អ្នកទោសគឺជាក្មេងជំទង់[1081]។

214. ជនរងគ្រោះនៅភ្នំទ្រយោងរួមមានទាំង "អ្នកទោសធ្ងន់" និង "អ្នកទោសស្រាល"[1082] ស្ត្រី[1083] អ្នកដែលចាត់ទុកថាជាអ្នកចេះដឹង[1084] អ្នកដែលប្រឆាំងនឹងកម្មាភិបាល[1085] អ្នកដែលខ្សោយពេកមិនអាចធ្វើការទៅរួច[1086] និងអ្នកដែលព្យាយាមរត់គេចខ្លួន[1087]។ ក្រៅពីនេះ ជនរងគ្រោះ រួមមាន អ្នកទោសដែលត្រូវបានឃុំឃាំងនៅភ្នំលៀប និងអ្នកដែលត្រូវបានចាប់ខ្លួន និងបញ្ជូនមកដោយ **អ៊ឹម ចែម**[1088]។ អ្នករស់នៅភ្នំលៀបតែងតែបានឃើញទាហានយកអ្នកទោសមកពីតំបន់ជុំវិញទៅសម្លាប់នៅព្រៃខាងជើងភ្នំទ្រយោង[1089] និងបានឃើញការបាត់ខ្លួនរបស់សាច់ញាតិខ្លួន[1090]។ ឧទាហរណ៍ ពេជ្រ រស់ បានមើលឃើញការចាប់ខ្លួន សំ ប៊ុន ដែលជាគណៈឃុំ ដែលត្រូវបានបញ្ជូនខ្លួនដោយកងឈ្លបទៅផ្ទះ **អ៊ឹម ចែម**[1091]។ ដោយឡែក ក្នុងពេលចាប់ខ្លួនពេទ្យកងចល័តស្រីម្នាក់ គេឮ **អ៊ឹម ចែម** និយាយថា "បើវាពិបាកវាប្រឆាំងក្បត់ហើយ វៃចោលទៅ"[1092]។ បុគ្គលទាំងពីរនាក់នេះសុទ្ធតែត្រូវបានយកទៅសម្លាប់នៅភ្នំទ្រយោង[1093]។

215. ក្នុងរយៈពេលប៉ុន្មានថ្ងៃមុនពេលវៀតណាមចូលមកដល់ និងក្រោយពីការជួបគ្នាដ៏ធំដែលធ្វើឡើងដោយ **អ៊ឹម ចែម** នៅគុក[1094] ទុំ សឿន បានបញ្ជាឱ្យមានការសម្លាប់ទ្រង់ទ្រាយធំ[1095]។ ធិប សំផាត់ និងអ្នកទោសបួននាក់ផ្សេងទៀតបញ្ជាឱ្យជីករណ្តៅបួនម៉ែត្របួនជ្រុង និងមានជម្រៅមួយម៉ែត្រ[1096]។ គេវៃសម្លាប់អ្នកទោស ១០ នាក់ក្នុងមួយលើក[1097]។ នៅពេលអ្នកសម្លាប់នោះអស់កម្លាំង គេសម្រាក ហើយមានអ្នកសម្លាប់ម្នាក់ទៀត បន្តការសម្លាប់ជំនួស[1098]។

216. បន្ទាប់ពីការដួលរលំរបបខ្មែរក្រហម អ្នកភូមិបានចូលទៅក្នុងមន្ទីរសន្តិសុខ និងបានឃើញសាកសពជាច្រើន ហើយសាកសពខ្លះនៅជាប់ខ្នោះ និងនៅសល់តែគ្រោងឆ្អឹង[1099]។ ឆ្អឹងជាច្រើនត្រូវបានប្រមូលដុតចោល ឬប្រមូលទៅតម្កល់នៅក្នុងស្តូបមួយក្នុងវត្តភ្នំលៀប[1100]។

## (៤) មន្ទីរសន្តិសុខចក្រី និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធ រួមទាំងព្រៃតារុត (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩)

### <u>ទីតាំង និងដំណើរការ</u>

217. មន្ទីរសន្តិសុខភូមិចក្រី និងទីតាំងសម្លាប់មនុស្សពាក់ព័ន្ធនឹងមន្ទីរនេះ រួមទាំងទីតាំងសម្លាប់មនុស្ស ព្រៃតារុត មានទីតាំងនៅឃុំជប់ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ តំបន់ ៥ ភូមិភាគពាយ័ព្យ[1101]។ ភូមិចក្រីត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំង និងភូមិព្រៃតារុតត្រូវបានប្រើប្រាស់ជា ទីតាំងសម្លាប់មនុស្ស[1102] បន្ទាប់ពី **អ៊ឹម ចែម** ឡើងធ្វើជាគណៈស្រុកព្រះនេត្រព្រះនៅពាក់កណ្តាលឆ្នាំ ១៩៧៧[1103] និងបន្តប្រតិបត្តិការរហូតដល់ការដួលរលំរបបខ្មែរក្រហមនៅអំឡុងខែ មករា ឆ្នាំ ១៩៧៩[1104]។

218. មន្ទីរសន្តិសុខភូមិចក្រីដែលបច្ចុប្បន្នហៅថា មន្ទីរឃុំឃាំងជប់ភាវី[1105] និងទីតាំងសម្លាប់មនុស្សក្បែរៗនោះ ស្ថិតក្នុងភូមិចក្រី[1106] ដែលស្ថិតនៅភាគខាងកើតក្រុងសុីសុផុនឆ្ពោះទៅខេត្តសៀមរាបនៅខាងស្តាំដៃផ្លូវជាតិលេខ ៦[1107]។ ព្រៃតារុត ដែលត្រូវបានហៅផងដែរថា ព្រៃបុស្សចេក[1108] ស្ថិតក្នុងភូមិក្រសាំងថ្មី ដែលមានចម្ងាយប្រហែល ៣ គីឡូម៉ែត្រ ភាគពាយ័ព្យនៃភូមិចក្រី[1109] ចម្ងាយពីរគីឡូម៉ែត្រពីផ្លូវកែងបត់ចូលទៅត្រពាំងថ្មតាមផ្លូវជាតិលេខ ៦[1110]។

219. មន្ទីរសន្តិសុខភូមិចក្រីគឺជាផ្ទះឈើមួយខ្នង[1111] ដែលមានបណ្តោយប្រហែល ៦ ម៉ែត្រ និងទទឹង ៥ ម៉ែត្រ ហើយមានជញ្ជាំងក្តារ និងដំបូងស័ង្កសី[1112] ដែលដាក់អ្នកទោស ២០ ទៅ ៣០ នាក់[1113]។ នៅជិតមន្ទីរសន្តិសុខភូមិចក្រី មានទីតាំងសំខាន់ៗពីរដែលគេយកមនុស្សទៅសម្លាប់៖ ស្រះជប់[1114] និងនៅម្តុំដើមដូងបីដើម[1115]។ អ្នកដែលត្រូវបានសម្លាប់ ត្រូវបានកប់ក្នុងរណ្តៅនៅសងខាងផ្លូវឆ្ពោះទៅកាន់ផ្លូវជាតិលេខ ៦ ឬក៏សាកសពរបស់ពួកគេត្រូវបានបោះចោលក្នុងស្រះជប់[1116]។ ស្រះនោះមានចម្ងាយប្រហែល ១០០ ម៉ែត្រខាងត្បូងផ្លូវជាតិលេខ ៦[1117]។ ទីតាំងដើមដូងបីដើមស្ថិតនៅចន្លោះរណ្តៅកប់សាកសព និងមន្ទីរឃុំឃាំង[1118]។

220. ព្រៃតារុត គឺជាវាលចម្ការដ៏ធំមួយដែលអ្នកទោសត្រូវបានសម្លាប់ និងកប់ក្នុងរណ្តៅសាកសពរួម។ គេបានរកឃើញរណ្តៅសាកសពធំៗប្រាំ ដែលពោរពេញដោយអដ្ឋិធាតុគ្រោងឆ្អឹង[1119]។ រណ្តៅទាំងនោះ

មានទំហំខុសគ្នា ចាប់ពី បី ម៉ែត្របួនជ្រុង និងជម្រៅ ពីរ ម៉ែត្រ រហូតដល់ បួន ម៉ែត្របួនជ្រុង និងជម្រៅ ពីរ ម៉ែត្រ[1120]។

<u>រចនាសម្ព័ន្ធសិទ្ធិអំណាចនិងការប្រាស្រ័យទាក់ទង</u>

221. មេគុកឃុំជប់ ដែលជាទីតាំងរបស់មន្ទីរសន្តិសុខភូមិចក្រី និងព្រៃតារុត ឈ្មោះ រាម[1121]។ គាត់ជាមនុស្សក្រោមបង្គាប់របស់ **អ៊ឹម ចែម**។ ប៊ិន សុខ ដែលជានីរសាររបស់ **អ៊ឹម ចែម** រៀបរាប់ថា គាត់ទទួលបញ្ជាពី **អ៊ឹម ចែម** ឱ្យប្រមូលអ្នកទោស ៧ នាក់ពីឈ្មោះ រាម ក្នុងភូមិចក្រី រួចបញ្ជូនពួកគេទៅផ្ទះ **អ៊ឹម ចែម** នៅភ្នំលៀប[1122]។ រាម គឺជាកម្មាភិបាលម្នាក់មកពីភូមិភាគនីរតី និងត្រូវបានចាត់បញ្ជូនទៅស្រុកព្រះនេត្រព្រះ ក្រោយ **អ៊ឹម ចែម**[1123]។ ដោយសារតែ **អ៊ឹម ចែម** ផ្ទាល់បានចាត់តាំងកម្មាភិបាលភូមិភាគនិរតី ក្រោយការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ រាម ទំនងជាត្រូវបាន **អ៊ឹម ចែម** ចាត់តាំងជាមេគុក[1124]។

222. **អ៊ឹម ចែម** ជាអ្នកគ្រប់គ្រងកងឈ្លប[1125] ដែលធ្វើការចាប់ខ្លួន និងសម្លាប់អ្នកទោសនៅព្រៃតារុត[1126] និងបានបញ្ជាឱ្យមានការបញ្ជូនអ្នកទោសពីមន្ទីរសន្តិសុខភូមិចក្រីទៅមន្ទីរសន្តិសុខផ្សេងទៀតក្នុងបណ្តាញតំបន់[1127]។

<u>ការចាប់ខ្លួននិងឃុំខ្លួនដោយខុសច្បាប់</u>

223. ការចាប់ខ្លួនតែងត្រូវបានធ្វើឡើងក្រោមរូបភាពជាការបោកប្រាស់[1128]។ គេប្រាប់ប្រជាជនថា ពួកគេត្រូវបានចាត់តាំងឱ្យបំពេញកិច្ចការថ្មីនៅទីកន្លែងផ្សេង[1129] ឬត្រូវបានហៅឱ្យចូលរៀន[1130] ប៉ុន្តែតាមពិតត្រូវបានកងឈ្លបបញ្ជូនខ្លួនទៅមន្ទីរសន្តិសុខភូមិចក្រី និងទីតាំងសម្លាប់មនុស្សព្រៃតារុត[1131]។ អ្នកដែលត្រូវបានចាប់ខ្លួន រួមមាន អ្នកដែលរងការចោទថាជាជនជាតិវៀតណាម[1132] អតីតទាហាន លន់ នល់[1133] និង "ប្រជាជនថ្មី" ដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ[1134]។

## លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌

224. អតីតអ្នកជាប់ឃុំក្នុងមន្ទីរសន្តិសុខភូមិចក្រីដែលបានរត់គេចខ្លួនដោយជោគជ័យ បានរៀបរាប់លម្អិតពីរបៀបដែលគាត់ត្រូវបានចងស្លាបសេក និងរុញគាត់ចូលទៅក្នុងគុកដែលនៅទីនោះ គាត់បានឃើញអ្នកទោសប្រហែលជា ២០ ទៅ ៣០ នាក់ទៀត"[1135] ត្រូវបានចងស្លាបសេក ដូចគាត់ដែរ ហើយដែលចំណងចងដៃទាំងនោះស្ទើរតែកប់ចូលទៅក្នុងដៃ ពីព្រោះដៃរបស់ពួកគេបានហើមធំ[1136]។ អ្នកជាប់ឃុំត្រូវបានដាក់ឃុំនៅពេលថ្ងៃ និង "បានបាត់ខ្លួន" នៅពេលយប់[1137]។

## ការសម្លាប់ដោយខុសច្បាប់

225. វដ្តនៃការឃុំខ្លួន និងការសម្លាប់កើតឡើងជាញឹកញាប់[1138]។ អ្នកទោសត្រូវបានឃុំខ្លួននៅពេលថ្ងៃក្នុងមន្ទីរសន្តិសុខភូមិចក្រី និងយកទៅសម្លាប់នៅពេលយប់[1139]។ ការសម្លាប់អ្នកជាប់ឃុំ រួមមាន ការសម្លាប់មនុស្សទាំងគ្រួសារមកពីភូមិចក្រី[1140] ក្រុមគោលដៅ ដូចជា អ្នកដែលត្រូវបានចោទថាជាជនជាតិវៀតណាម[1141] ខ្មែរក្រោម[1142] អតីតទាហាន លន់ នល់[1143] និង "ប្រជាជនថ្មី"[1144] ធ្វើឡើងនៅស្រះជប់ នៅម្តុំដើមដូងបីដើម និងទីតាំងសម្លាប់មនុស្សព្រៃតារុត។

226. ជនរងគ្រោះត្រូវបានយកទៅសម្លាប់ និងទម្លាក់សាកសពទៅក្នុងស្រះជប់[1145] ចំណែកទីតាំងដើមដូងបីដើម ដែលស្ថិតនៅចន្លោះរណ្តៅសាកសព និងមន្ទីរសន្តិសុខនេះ ត្រូវបានប្រើប្រាស់សម្រាប់បោកសម្លាប់កូនក្មេង[1146]។ សាក្សីម្នាក់បានរំលឹកឡើងវិញនូវកិច្ចសន្ទនាស្តីពីកុមារដែលត្រូវបាន "ចាប់បោកផ្ទប់នឹងគល់ឈើ"[1147]។ សាក្សីនានាបានរៀបរាប់ថាបានស្តាប់ឮសម្រែកចេញពីទីតាំងនេះនៅពេលយប់[1148]។

227. ជនរងគ្រោះផ្សេងទៀតនៃការសម្លាប់ រួមមាន បុរសម្នាក់ដែលព្យាយាមជំទាស់នឹងការចាប់ខ្លួន ក្នុងពេលបញ្ជូនខ្លួនទៅមន្ទីរសន្តិសុខភូមិចក្រី[1149]។ គាត់ត្រូវបានពួកយោធាបាញ់ និងវាយសម្លាប់នឹងដុំឥដ្ឋ[1150]។ ការចុះកំណត់ទីតាំងវាលពិឃាតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ាន់ស្មានថា ជនរងគ្រោះសរុបប្រមាណ ៣.៥៨០ នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខភូមិចក្រី និងទីតាំងសម្លាប់មនុស្សនៅក្បែរៗនោះ[1151]។

228. ចាប់ពីយ៉ាងហោចណាស់ពាក់កណ្តាលឆ្នាំ ១៩៧៨[1152] ជនរងគ្រោះត្រូវបានដឹកមកតាមឡានទៅកាន់ទីតាំងសម្លាប់មនុស្សព្រៃតារុត[1153] ដើម្បីសម្លាប់ រួច "ទម្លាក់សាកសពទៅក្នុងរណ្តៅ"[1154]។ នៅពេលល្ងាច ប្រជាជនដែលរស់នៅក្បែរភូមិព្រៃតារុតបានឮសំឡេងមនុស្ស "ស្រែក" នៅពេលដែលពួកគេត្រូវបានសម្លាប់[1155]។ DC-Cam បានប៉ាន់ស្មានថា មនុស្សប្រហែល ៣.៨៩០ នាក់ត្រូវបានសម្លាប់នៅទីតាំងនេះ[1156] ហើយគេបានរកឃើញរណ្តៅសាកសពធំៗ ៥ ដែលមានសុទ្ធតែឆ្អឹងមនុស្ស[1157]។

## (៥) មន្ទីរសន្តិសុខវត្តចំការខ្នុរ និងទីតាំងពាក់ព័ន្ធ (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩)

### ទីតាំង និងដំណើរការ

229. មន្ទីរសន្តិសុខចំការខ្នុរ និងទីតាំង ស្ថិតក្នុងទីតាំងមួយដែលគេហៅថា ចំការខ្នុរ[1158] ក្នុងឃុំអូរអំបិល ស្រុកស៊ីសុផុន[1159] ខេត្តបន្ទាយមានជ័យ ដែលពីមុនស្ថិតក្នុងខេត្តបាត់ដំបង[1160] ក្នុងតំបន់ ៥ នៃភូមិភាគពាយ័ព្យ[1161]។ ក្រៅពីវត្តនោះ[1162] (ដែលជាមន្ទីរសន្តិសុខរបស់តំបន់ ៥[1163]) ចំការខ្នុរគឺជាទីតាំងសម្លាប់មនុស្ស[1164] និងការដ្ឋានការងារដោយបង្ខំ[1165]។ វត្តចំការខ្នុរ និងទីតាំងពាក់ព័ន្ធ ដំណើរការពីឆ្នាំ ១៩៧៥ រហូតដល់ការមកដល់របស់កងទ័ពវៀតណាមនៅឆ្នាំ ១៩៧៩[1166]។

230. មន្ទីរសន្តិសុខចំការខ្នុរស្ថិតក្នុងបរិវេនវត្តមួយដែលមានអគារជាច្រើន[1167]។ រោងសម្រាប់ឃុំខ្លួនអ្នកទោសមានទទឹង ៣០ ម៉ែត្រ និងបណ្តោយ ៥០ ម៉ែត្រ[1168]។ ក្រៅពីនេះ មានផ្ទះស្បូវពីរសម្រាប់ដាក់អ្នកទោសស្រាល[1169] ហើយបរិវេណមន្ទីរឃុំឃាំងនេះមានរបងលួសបន្លាព័ទ្ធជុំវិញ[1170]។

231. ទីតាំងសម្លាប់មនុស្សចំការខ្នុរស្ថិតនៅខាងត្បូងមន្ទីរសន្តិសុខចំការខ្នុរ[1171] និងស្ថិតលើផ្ទៃដីដ៏ធំ[1172] ដែលមានព្រៃក្រាស់[1173]។ ទីតាំងនេះមានភ្នំបីព័ទ្ធជុំវិញ៖ ភ្នំស្វាយនៅខាងកើត[1174] ភ្នំដូងព្រះនៅខាងលិច[1175] និងភ្នំកង្វានៅខាងជើង[1176]។ ផ្លូវជាតិលេខ៥ ស្ថិតតាមបណ្តោយភាគខាងត្បូងនៃទីតាំងនេះ[1177]។ រណ្តៅសាកសពមាននៅពាសពេញទីតាំងនេះ ចាប់ពីមន្ទីរសន្តិសុខវត្តចំការខ្នុរ រហូតដល់ផ្លូវជាតិលេខ ៥[1178]។

## <u>រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង</u>

232. មន្ទីរសន្តិសុខចំការខ្នុរ និងទីតាំងពាក់ព័ន្ធ ស្ថិតក្រោមយុត្តាធិការអំណាចរបស់តំបន់ ៥[1179]។ មុនពេលមានការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យដោយកម្មាភិបាលភូមិភាគនិរតីនៅអំឡុងឆ្នាំ ១៩៧៧[1180] តា ញ៉ាន គឺជាប្រធានគុកចំការខ្នុរ[1181]។ វ័ន្ត[1182] គឺជាប្រធានមន្ទីរសន្តិសុខតំបន់ ៥ ហើយ តា ហ៊ឹង គឺជាលេខាតំបន់ ៥[1183]។ តាជៀល (កូនប្រុសរបស់ រស់ ញឹម) គឺជាអនុលេខា[1184]។ ក្នុងអំឡុងពេលបោសសម្អាត បុរសទាំងនេះបានបាត់ខ្លួន និងត្រូវបានដាក់ជំនួស[1185]។

233. បន្ទាប់ពីបានមកដល់ភូមិភាគពាយ័ព្យនៅពាក់កណ្ដាលឆ្នាំ ១៩៧៧ ភ្លាម **អ៊ឹម ចែម** បានក្លាយជាសមាជិកគណៈតំបន់ ៥[1186] ហើយប្ដីរបស់គាត់ឈ្មោះ តា ញ៉ែន បានក្លាយជាលេខាគណៈស្រុកស៊ីសុផុន[1187]។ ដូច្នេះ **អ៊ឹម ចែម** ពាក់ព័ន្ធ និងទទួលខុសត្រូវលើមន្ទីរសន្តិសុខចំការខ្នុរ និងទីតាំងពាក់ព័ន្ធ[1188]។

234. មានទាហានយ៉ាងតិច ២០ នាក់យាមការពារចំការខ្នុរ[1189] ហើយមួយចំនួនជាយោធាក្មេងៗ[1190] ដែលរស់នៅក្នុងផ្ទះជិតវត្តចំការខ្នុរ[1191]។

## <u>ការចាប់ខ្លួន និងឃុំខ្លួនដោយខុសច្បាប់</u>

235. អ្នកទោសត្រូវបានដឹក*ទាំងហ្វូង*តាមឡានមកកាន់មន្ទីរសន្តិសុខចំការខ្នុរ[1192]។ អ្នកទោសមួយចំនួនត្រូវបានដាក់ខ្នោះ ឬចងស្លាបសេកក្នុងពេលដឹកបញ្ជូនមក[1193] និងតែងតែត្រូវបានដឹកបញ្ជូនមកមន្ទីរសន្តិសុខនេះពីស្រុកផ្សេងៗក្នុងតំបន់ ៥[1194]។ អ្នកទោសទាំងនោះ រួមមាន កម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបោសសម្អាត[1195] និងក្រុមគ្រួសាររបស់ពួកគេ[1196] អ្នកដែលបដិសេធអាពាហ៍ពិពាហ៍ដោយបង្ខំ[1197] និងអ្នកដែលត្រូវបានចាត់ទុកថាជា "ខ្មាំង"[1198]។ អ្នកទោសស្រី និងអ្នកទោសប្រុសត្រូវបានឃុំខ្លួនក្នុងទីតាំងដាច់ដោយឡែកពីគ្នា[1199]។ បន្ទាប់ពីការឃុំខ្លួននៅមន្ទីរសន្តិសុខចំការខ្នុរ អ្នកទោសខ្លះត្រូវបានដាក់ខ្នោះជើង និងបញ្ជូនទៅមន្ទីរសន្តិសុខ និងការដ្ឋានផ្សេងទៀត ដូចជា ភ្នំទ្រយោង[1200] ដែលមាន **អ៊ឹម ចែម** ជាអ្នកគ្រប់គ្រង។

## ការងារដោយបង្ខំ

236. ប្រជាជនជាច្រើនត្រូវបានបង្ខំឲ្យធ្វើការងារធ្ងន់នៅការដ្ឋានចំការខ្នុរ[1201]។ អ្នកទោសបង្កបង្កើនផលស្រូវ[1202] ជីករណ្ដៅកប់សាកសព[1203] ជីកប្រឡាយ[1204] និងធ្វើការនៅចំការកប្បាសនៅជិតជើងភ្នំជុំវិញចំការខ្នុរ[1205]។ អឿ លឿ ត្រូវបានបង្ខំឲ្យដាំដំណាំនៅជិតមន្ទីរសន្តិសុខចំការខ្នុរ ក្រោយពេលសម្រាលកូនរួច[1206]។

## លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌

237. អ្នកទោសបានស្លាប់ដោយសាររបបអាហារមិនគ្រប់គ្រាន់[1207]។ អ្នកទោសមួយចំនួនមិនមានសម្លៀកបំពាក់ជាប់ខ្លួនឡើយ[1208]។ អតីតអ្នកទោសម្នាក់រៀបរាប់ថា គាត់ត្រូវបានដាក់ច្រវាក់ជើង[1209]។ នៅការដ្ឋានទាំងនេះ ជុំវិញមន្ទីរសន្តិសុខចំការខ្នុរ ពលករបរិភោគបបររាវលាយស្លឹកឈើ[1210]។ កិញ អាយ រាយការណ៍ថា ក្នុងពេលធ្វើការក្នុងចំការកប្បាសនៅចំការខ្នុរ គាត់មានរូបរាងស្គមស្គាំង ហើយ "ក្បាលជង្គង់របស់គាត់គឺធំជាងក្បាល"[1211]។

## ការធ្វើទារុណកម្ម

238. អ្នកទោសបានទទួលរងការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខចំការខ្នុរ[1212] ដូចជា តាមរយៈការវាយដំ[1213] ដើម្បីបង្ខំឲ្យឆ្លើយសារភាព មុនពេលយកទៅសម្លាប់[1214]។ អ្នកទោសមួយចំនួនត្រូវបានសម្លាប់ដោយឆក់ខ្សែភ្លើង ដោយឆក់ដៃ ប្រអប់ជើង និងក[1215]។ អ្នកទោសផ្សេងទៀតត្រូវបានគេចាប់ដកក្រចកម្ដងមួយៗ[1216]។ ស្នាមមុតកាំបិត និងស្នាមជាំត្រូវបានប្រទះឃើញនៅលើខ្លួនសាកសព កាលពីអំឡុងឆ្នាំ ១៩៧៥[1217]។

## ការសម្លាប់ដោយខុសច្បាប់

239. អ្នកទោសរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សចំការខ្នុរ ក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**[1218]។ ការសម្លាប់បានកើនឡើងនៅចុងឆ្នាំ ១៩៧៨ ហើយសាក្សីបានរៀបរាប់ថា បានឃើញអ្នក

ជាប់ឃុំ ត្រូវបានដឹកតាមឡានជាច្រើនមកកាន់ទីតាំងសម្លាប់មនុស្សនេះ[1219]។ អ្នកទោសត្រូវបានចងស្លាបសេក ចងមុខ[1220] រួចយកទៅសម្លាប់ទាំងជួរៗ មុនពេលរុញទម្លាក់ទៅក្នុងរណ្តៅ[1221]។ ភាគច្រើន ការសម្លាប់ធ្វើនៅពេលយប់[1222]។ ពលករនៅជិតការដ្ឋានស្តាប់ឮសំឡេងមនុស្សយំស្រែករកជំនួយ និងសម្រែកចេញពីទីតាំងសម្លាប់មនុស្សនេះ[1223]។ អ្នកទោសត្រូវបានបាញ់[1224] ឬវាយសម្លាប់[1225]។

240. មនុស្សទាំងស្រី ប្រុស ក្មេង ចាស់[1226] និងមកពីក្រុមគោលដៅផ្សេងៗ[1227] ត្រូវបានសម្លាប់ ដូចជាទាហាន លន់ នល់[1228] ជនស៊ីវិលដែលធ្លាប់បម្រើការក្នុងរដ្ឋការ លន់ នល់[1229] កម្មាភិបាលភូមិភាគពាយ័ព្យ[1230] និស្សិត[1231] សាស្ត្រាចារ្យ[1232] ជនជាតិវៀតណាម[1233] ជនជាតិចិន ជនជាតិចាម ជនជាតិឡាវ[1234] អ្នកដែលត្រូវបានចោទថាជា "ជនក្បត់"[1235] និងអ្នកដែលប៉ុនប៉ង[1236] ឬត្រូវបានចោទថាបានលួចអាហារ[1237]។ អ្នកខ្លះត្រូវបានសម្លាប់ បន្ទាប់ពីពួកគេបានបញ្ចប់គម្រោងការងារ[1238]។ មនុស្សទាំងគ្រួសារត្រូវបានសម្លាប់នៅទីតាំងនេះ[1239]។ ជាទូទៅ ក្រោយពេលសម្លាប់ សាកសពត្រូវបានយកទៅកប់ ប៉ុន្តែសាកសពខ្លះត្រូវបានបោះចូលក្នុងរណ្តៅសាកសពរួមកណ្តាលវាល[1240] ទាំងដៃជាប់ចំណង ឬជាប់ខ្នោះ[1241]។ សុត ផល បានរៀបរាប់លម្អិតថា គាត់បានឃើញមនុស្សត្រូវបានគេកប់ទាំងរស់[1242]។ នៅឆ្នាំ ១៩៧៩ សាក្សីបានរកឃើញសាកសព ដំបងឫស្សី ចបកាប់ ខ្នោះ[1243] និងស្នាមឈាម[1244] នៅមន្ទីរសន្តិសុខចំការខ្នុរ។

241. ចំការប្រាំ ត្រូវបានរកឃើញថាមានរណ្តៅសាកសពរួមធំៗ ចំនួន ៤[1245] និងរណ្តៅសាកសពតូចៗជាច្រើនដែលមានទំហំចាប់ពី ៣ ម៉ែត្របួនជ្រុង រហូតដល់ទទឹង ៥ ម៉ែត្រ និងបណ្តោយ ១០ ម៉ែត្រ[1246]។ រណ្តៅទាំងនោះមានរាងមូល ចតុកោណ ឬស្ថិតក្នុងលេណដ្ឋាន ឬស្នាមភ្លោះដែលត្រូវបានគេជីក ឬកើតឡើងដោយធម្មជាតិ[1247]។ រណ្តៅសាកសពរួមជាច្រើនដែលស្ថិតនៅជុំវិញទីតាំងសម្លាប់មនុស្សនេះអាចមានរហូតដល់ ១០០ រណ្តៅ[1248]។ រណ្តៅតូចៗមានសាកសពរហូតដល់ ៦០ នាក់ ចំណែករណ្តៅធំៗមានសាកសពរហូតដល់ ១.០០០ នាក់[1249]។ គេឃើញមានសាកសពស្អុយរលួយ ឆ្អឹង និងខោអាវ[1250] ដូចជា ក្នុងអណ្តូងទឹកមួយនៅទីតាំងនេះ[1251]។ អដ្ឋិធាតុជាច្រើនដែលបានជីកកកាយចេញពីមន្ទីរសន្តិសុខចំការខ្នុរ និងទីតាំងពាក់ព័ន្ធ ត្រូវបានប្រមូលមកតម្កល់ទុកនៅស្តូបក្នុងវត្តសុភមង្គល[1252]។ ក្រៅពីរណ្តៅសាកសពដែលត្រូវបានជីកគាស់[1253] រណ្តៅជាច្រើនផ្សេងទៀតដែលស្ថិតក្នុងទីតាំងដែលមានរុក្ខជាតិដុះក្រាស់[1254] មិនទាន់ត្រូវបានជីកគាស់ឡើយ[1255]។ ទោះបីជាចំនួន និងទីតាំងរណ្តៅសាកសពបាន

បង្កការលំបាកក្នុងការប៉ាន់ស្មានចំនួនសាកសពជាក់លាក់ ក៏ដោយ ក៏ទំហំ និងចំនួនរណ្តៅសាកសព បង្ហាញថា ចំនួនជនរងគ្រោះអាចមានពី ២០.០០០ នាក់ ដល់ ២៥.០០០ នាក់[1256]។

## (៦) វត្តព្រះនេត្រព្រះ និងទីកតាំង ឃុំខ្លួន និងសម្លាប់មនុស្សពាក់ព័ន្ធ (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ឆ្នាំ១៩៧៩)

### ទីតាំង និងតំណើរការ

242. វត្តព្រះនេត្រព្រះ និងកន្លែងសម្លាប់មនុស្សព្រមទាំងមន្ទីរឃុំឃាំងពាក់ព័ន្ធនឹងវត្តនេះស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ តំបន់ ៥ នៃភូមិភាពពាយ័ព្យ[1257]។ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ វត្តព្រះនេត្រព្រះព័ទ្ធជុំវិញដោយភូមិតូចៗចំនួន ១១ ភូមិ ដែលរួមគ្នាបង្កើតបានជាឃុំព្រះនេត្រព្រះ[1258]។

243. ទីតាំងវត្តព្រះនេត្រព្រះស្ថិតនៅខាងត្បូងផ្លូវជាតិលេខ ៦ ហើយរួមមានវត្តមួយ និងអាគារកំពស់ពីរជាន់ដែលត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរពេទ្យតាំងពីឆ្នាំ ១៩៧៦ រហូតមក[1259]។ ច្រកចេញចូលវត្តបែរមុខទៅទិសខាងលិច និងខាងកើត ហើយច្រកចេញចូលមន្ទីរពេទ្យបែរមុខចំវត្តតែម្តង[1260]។ អាគារវត្ត និងអាគារមន្ទីរពេទ្យនៅសល់មកទល់សព្វថ្ងៃ[1261]។

244. ផ្ទះ តាក្រក ដែលស្ថិតនៅប្រហែលជាចម្ងាយ ៨០០ ម៉ែត្រខាងជើងវត្ត ដែលក្រោយ **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីដក តាក្រក ចេញពីមុខតំណែងជាប្រធានឃុំព្រះនេត្រព្រះ[1262] ត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំងបណ្តោះអាសន្នដែលទុកសម្រាប់ឃុំឃាំងមនុស្ស មុនពេលយកចេញទៅសម្លាប់ចោល[1263]។ ព័ទ្ធជុំវិញដោយព្រៃក្រាស់ៗ ផ្ទះនេះជាសំណង់សង់ពីឈើមានកម្ពស់មួយជាន់ដោយច្រកចេញចូលខាងមុខបែរចំផ្លូវដី[1264]។ នៅខាងក្រោយផ្ទះមានអណ្តូងទឹកមួយ[1265] និងរណ្តៅធំមួយ[1266]។ ផ្ទះនេះនៅឃើញនៅឡើយនៅខាងឆ្វេងផ្លូវដីតូចមួយឆ្ពោះទៅទិសខាងជើងផ្លូវជាតិលេខ ៥ ពីវត្តព្រះនេត្រព្រះ[1267]។

245. កន្លែងសម្លាប់មនុស្សចម្ការតាឡឹងស្ថិតនៅចម្ងាយប្រហែល ៥០ ម៉ែត្រភាគអាគ្នេយ៍វត្តព្រះនេត្រព្រះ1268។ទីតាំងរណ្តៅធំៗចំនួន ៦ រណ្តៅត្រូវបានគាស់កកាយនៅចម្ការតាឡឹង ដោយរណ្តៅនីមួយៗ

មានទំហំ ៤ ម៉ែត្រការ៉េ និងជម្រៅ ២ ម៉ែត្រ[1269]។ សព្វថ្ងៃ កន្លែងសម្លាប់មនុស្សនេះភាគច្រើនគឺជាដីទំនេរ ហើយឃើញមានតែចេតិយ និងស្រះមួយតែប៉ុណ្ណោះ[1270]។

246. កន្លែងសម្លាប់មនុស្សចម្ការដូង និងចម្ការយាយណឹងមានចម្ងាយ ១០០០ ទៅ ១៥០០ ម៉ែត្រភាគពាយ័ព្យផ្ទះតាក្រកក្នុងភូមិប៉ោយក្អៀង ឃុំព្រះនេត្រព្រះ[1271]។ កន្លែងសម្លាប់មនុស្សនេះអាចចេញចូលតាមផ្លូវដើរមួយខាងឆ្វេងផ្ទះតាក្រក។ កន្លែងនេះសឹងតែស្ថិតនៅទល់មុខគ្នា ប៉ុន្តែគ្រាន់តែខណ្ឌដោយផ្លូវដើរមួយតែប៉ុណ្ណោះ[1272]។

## <u>រចនាសម្ព័ន្ធសិទ្ធិអំណាច</u>

247. វត្តព្រះនេត្យព្រះ និងកន្លែងសម្លាប់មនុស្សជុំវិញវត្តនេះស្ថិតក្រោមអំណាចគ្រប់គ្រងរបស់ឃុំ និងស្រុក។ នៅមុនពេលបោសសម្អាត តាក្រក គឺជាលេខាគណៈឃុំព្រះនេត្រព្រះ[1273] ហើយ តាផន គឺជាអនុរបស់គាត់[1274]។ តាក្រក ត្រូវបាន **អ៊ឹម ចែម** ដកចេញ[1275] និងជំនួសដោយ នារីថា ដែលជាកម្មាភិបាលភូមិភាគនិរតី[1276]។

248. ក្នុងនាមជាលេខាស្រុក វត្តព្រះនេត្រព្រះ និងកន្លែងសម្លាប់មនុស្សជុំវិញវត្តនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** ពីពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ[1277]។

249. ប្រជាជននៅក្នុងឃុំព្រះនេត្យព្រះរាយការណ៍ជូនប្រធានក្រុមរបស់ខ្លួនពួកគេ ហើយប្រធានក្រុមរាយការណ៍បន្តទៅប្រធានភូមិ[1278]។ ប្រធានភូមិ និងសមាជិកគណៈណសហករណ៍ចំនួនបីនៅក្នុងឃុំនេះត្រូវរាយការណ៍ជូនសមាជិកគណៈឃុំព្រះនេត្រព្រះ ពោលគឺ តាឡុញ និង នារីថា ដែលត្រូវរាយការណ៍បន្តផ្ទាល់ទៅឱ្យ **អ៊ឹម ចែម**[1279]។

250. **អ៊ឹម ចែម** ធ្វើជាអធិបតីនៅក្នុងការប្រជុំធំៗជាច្រើននៅខាងមុខវត្តព្រះនេត្រព្រះ[1280]។ មនុស្សរាប់ពាន់នាក់បានចូលរួមការប្រជុំទាំងនេះ[1281] ដែលមានការពិភាក្សាអំពីការកំទេច "ខ្មាំង" ផ្ទៃក្នុង ការខិតខំប្រឹងប្រែងបង្កបង្កើនផល និងការរស់នៅសាមគ្គីគ្នា[1282]។

## លក្ខខណ្ឌរស់នៅដោយអមនុស្សធម៌

251. មនុស្សជាច្រើននាក់បានស្លាប់នៅក្នុងមន្ទីរពេទ្យវត្តព្រះនេត្រព្រះ[1283] ដោយសារជំងឺ ការអត់អាហារ និងកង្វះថ្នាំសង្កូវ[1284]។ អ្នកជំងឺនៅក្នុងមន្ទីរពេទ្យនេះត្រូវបានគេយកភេសជ្ជៈ ឬទឹកដូងមកចាក់ជំនួសសេរ៉ូម ហើយទទួលបានតែថ្នាំអាចម៍ទន្សាយ[1285]។ សាកសពមនុស្សស្លាប់នៅមន្ទីរពេទ្យនោះត្រូវបានដុតចោល ឬ កប់នៅជុំវិញបរិវេណវត្តព្រះនេត្រព្រះ ឬ នៅចម្ការដូង និងចម្ការឃាយណឹង[1286]។

## ការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ដោយខុសច្បាប់

252. ការស្រាវជ្រាវពិនិត្យប្រវត្តិរូបត្រូវបានធ្វើឡើងនៅតាមភូមិ និងសហករណ៍ ហើយប្រវត្តិរូបទាំងនេះត្រូវបានបញ្ជូនទៅ **អ៊ឹម ចែម**[1287]។ បុគ្គលដែលត្រូវបានចោទប្រកាន់ថាមានកំហុស ឬ ជាខ្មាំងអង្គការត្រូវបានស៊ើបអង្កេតនៅថ្នាក់នីមួយៗ មុនពេលរបាយការណ៍ត្រូវបានបង្កើតឡើងទៅតាមខ្សែសង្វាក់នៃការបញ្ជា[1288]។ **អ៊ឹម ចែម** បានបញ្ជាឲ្យមានការចាប់ខ្លួនដោយផ្អែកលើរបាយការណ៍ទាំងនេះដែលគាត់បានទទួលមកពីគណៈឃុំ[1289]។

253. ប្រជាជនមកពីតាមភូមិនានាត្រូវបានចាប់ខ្លួន[1290] ហើយបន្ទាប់មកត្រូវបានឃុំឃាំងបណ្ដោះអាសន្ននៅផ្ទះ តាក្រក[1291] មុនពេលពួកគេត្រូវបានបញ្ជូនចេញទៅសម្លាប់ចោល[1292] នៅពេលយប់ខាងក្រោយផ្ទះតាក្រក[1293] នៅតាមកន្លែងសម្លាប់មនុស្សចម្ការតាឡឹង[1294] ចម្ការដូង ឬ ចម្ការឃាយណឹង[1295]។ កម្មាភិបាលយោធា និងកងទ័ពមូលដ្ឋានបណ្ដើរអ្នកដែលត្រូវបានចាប់ខ្លួនទាំងនេះជាជួរដើម្បីនាំយកទៅឃុំឃាំង និងសម្លាប់ចោល[1296]។

254. អ្នកដែលត្រូវបានចាប់ខ្លួន និងសម្លាប់ចោល រួមមាន ប្រជាជន "១៧ មេសា"[1297] អតីតទាហាន និងអ្នករដ្ឋការ លន់ នល់[1298] អ្នកដែលត្រូវបានសង្ស័យថាជាប់ពាក់ព័ន្ធនឹងវៀតណាម[1299] កម្មាភិបាលភូមិភាគពាយ័ព្យ[1300] អតីតគ្រូបង្រៀន[1301] គ្រួសារអ្នកដែលបានរត់គេចទៅប្រទេសថៃ[1302] អ្នកដែលបានលួចម្ហូបអាហារ[1303] និងអ្នកដែលត្រូវបានចោទថាជាជនក្បត់[1304]។ "អ្នកខុសសីលធម៌" ក៏ត្រូវបានសម្លាប់ចោលដូចគ្នា[1305]។ ឈឹម ផាន អតីតអនុលេខាឃុំព្រះនេត្រព្រះទទួលស្គាល់ថាបានវាយដំបុរសម្នាក់ និង

ស្ត្រីម្នាក់រហូតដល់ស្លាប់ ដោយសារបានចោទថាមានកំហុសសីលធម៌នៅមុខមនុស្សជាច្រើននាក់ នៅវត្តព្រះនេត្រព្រះ ក្រោយ **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីបានឡើងគ្រប់គ្រង[1306]។

255. ការកាប់សម្លាប់បានកើនឡើង ក្រោយពេល **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតី[1307] បានមកដល់ ហើយបានកើតឡើងជាដរាប នៅក្នុងអំឡុងពេលមុនវៀតណាមចូលមកដល់ស្រុកព្រះនេត្រព្រះ[1308]។ ក្រោយពីដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ សាកសពត្រូវបានគាស់កកាយនៅចម្ការតាឡឹងដើម្បីយកមកបូជា[1309]។ ផ្អែកតាមការរៀបរាប់របស់សាក្សីអំពីការគាស់កកាយរណ្តៅសាកសពធំៗចំនួន ៦ ដែលរណ្តៅនីមួយៗមានសាកសពចំនួន ១១០ ទៅ ១២០ សាកសពនោះ មានមនុស្សចំនួនប្រហែលជា ៧០០ នាក់ដែលត្រូវបានកប់នៅចម្ការតាឡឹង[1310] ហើយរបាយការណ៍ឆ្នាំ ១៩៨៤ បានបញ្ជាក់ថាមានសាកសពចំនួន ២៥៣ បន្ថែមទៀតដែលត្រូវបានរកឃើញនៅកន្លែងនោះ[1311]។

256. គ្មានតួលេខជនរងគ្រោះដែលត្រូវបានសម្លាប់ និងកប់នៅរណ្តៅធំមួយនៅខាងក្រោយមន្ទីរឃុំឃាំងបណ្តោះអាសន្នត្រង់ផ្ទះ តាក្រក នោះទេ[1312] ហើយក៏មិនមានតួលេខសាកសពដែលត្រូវបានទម្លាក់ចូលក្នុងអណ្តូងខាងក្រោយផ្ទះ តាក្រក ផងដែរ[1313]។ តាមការប៉ាន់ស្មាន មនុស្សចំនួន ២០០ នាក់ត្រូវបានសម្លាប់ចោលនៅចម្ការតាដួង និងចម្ការយាយណឹង[1314]។ គេបានឮសម្រែកជនរងគ្រោះដែលកំពុងត្រូវបានសម្លាប់ចោលស្ទើរតែរាល់យប់ នៅក្នុងរយៈពេលមួយខែចុងក្រោយនៃរបបនោះ[1315]។ ចំនួនមនុស្សសរុបដែលត្រូវបានសម្លាប់ចោលពុំមាននរណាដឹងនោះទេដោយសារសាកសពទាំងនោះត្រូវបានគាស់កកាយ និងបូជានៅក្រោយការដួលរលំនៃរបបនោះនៅក្នុងឆ្នាំ១៩៧៩[1316]។

### (៧) ស្ពានស្រែង និងការដ្ឋានទំនប់ព្រៃរនាម (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩)

<u>ទីតាំង និងប្រតិបត្តិការ</u>

257. ការដ្ឋានស្ពានស្រែងលាតសន្ធឹងកាត់ស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះក្នុងខេត្តបាត់ដំបងពីមុន ដែលបច្ចុប្បន្នជាខេត្តបន្ទាយមានជ័យ ក្នុងតំបន់ ៥ នៃភូមិភាគពាយ័ព្យ[1317]។ ប្រឡាយស្ពានស្រែងដែលស្ថិតនៅទិសខាងត្បូងទំនប់ត្រពាំងថ្ម[1318] ត្រូវបានបែងចែកជាពីរផ្នែក មួយផ្នែកក្នុងស្រុកភ្នំស្រុក និងមួយផ្នែកទៀតនៅក្នុងស្រុកព្រះនេត្រព្រះ[1319]។ ប្រលាយផ្នែកខាងភ្នំស្រុកត្រូវបានសាងសង់ដោយកម្មា

ភិបាលភូមិភាគពាយ័ព្យ ហើយប្រលាយផ្នែកខាងព្រះនេត្រព្រះត្រូវបានសាងសង់ដោយ **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតី ("ប្រលាយស្ពានស្រែង")[1320]។ ព្រំប្រទល់រវាងប្រឡាយទាំងពីរផ្នែកនេះស្ថិតនៅជាប់ស្ពានមួយហៅថា "ស្ពានមេម៉ាយ"[1321]។

258. ប្រឡាយស្ពានស្រែងមានទទឹងប្រហែល ៣០ ម៉ែត្រ និងជម្រៅ ១៥ ម៉ែត្រ ហើយត្រូវបានសាងសង់ឡើងក្នុងគោលបំណងពីរគឺដើម្បីសម្រួលការធ្វើស្រូវប្រាំងក្នុងតំបន់នោះ និងដើម្បីការពារជំនន់ទឹកនៅឃុំទឹកឈូរ និងឃុំភ្នំលៀប[1322]។ អូរ និងប្រលាយភ្ជាប់តូចៗត្រូវបានជីកភ្ជាប់ប្រឡាយមេនៅក្នុងអំឡុងសម័យដែលកម្មាភិបាលភូមិភាគនិរតីកាន់កាប់[1323]។

259. ប្រឡាយខាងផ្នែកស្ពានស្រែងហូរកាត់ពីជើងទៅត្បូងប្រវែងប្រហែល ៨ ទៅ ១០ គីឡូម៉ែត្រ ហើយហូរកាត់ឆ្លងផ្លូវជាតិលេខ ៦ ត្រង់ខាងកើតភ្នំលៀប និងខាងលិចតាប៉ុន[1324]។ ប្រលាយខាងជើងផ្លូវជាតិលេខ ៦ ហូរកាត់ឃុំភ្នំលៀប (ចម្ងាយប្រវែងតិចជាងបីគីឡូម៉ែត្រពីមន្ទីររបស់ **អ៊ឹម ចែម**[1325]) ហើយត្រូវបានពលករខ្លះស្គាល់ឈ្មោះថាជាប្រលាយអូរលៀប[1326]។ ប្រឡាយស្ពានស្រែងខណ្ឌត្រឹមខាងត្បូងផ្លូវជាតិលេខ ៦ ត្រង់អាងស្តុកទឹកព្រៃរនាម[1327] ដែលត្រូវបានកសាងឡើងដើម្បីសម្រួលដល់ការធ្វើស្រូវប្រាំង[1328]។

260. ការសាងសង់ប្រឡាយស្ពានស្រែងក្នុងដំណាក់កាលដំបូងបានចំណាយរយៈពេលតិចបំផុត ៣ ខែ[1329] ហើយការងារជីកប្រឡាយ ការសាងសង់អាងស្តុកទឹកព្រៃរនាម និងការជីកប្រឡាយតភ្ជាប់បានបន្តធ្វើឡើងយ៉ាងហោចណាស់រយៈពេល ១ មួយឆ្នាំបន្ថែមទៀតរហូតដល់ពេលវៀតណាមចូលមកដល់ក្នុងឆ្នាំ ១៩៧៩[1330]។ លើសពីនេះ ការខូចខាតប្រលាយដែលបានបណ្តាលមកពីទឹកជំនន់នៅក្នុងឆ្នាំ ១៩៧៨ រួមទាំងការខូចខាតដល់ផ្នែកខាងភ្នំស្រុក ដែលត្រូវបានកសាងឡើងដោយកម្មាភិបាលភូមិភាគពាយ័ព្យនៅមុនពេល **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីបានមកដល់ តម្រូវឲ្យមានការជួសជុលច្រើនដែរ នៅក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**[1331]។ គម្រោងទំនប់ប្រលាយផ្សេងទៀតត្រូវបានគ្រោងធ្វើឡើងសម្រាប់កន្លែងនៅជុំវិញប្រលាយស្ពានស្រែង ប៉ុន្តែការចូលមកដល់របស់វៀតណាមបានរាំងការសាងសង់ទំនប់ប្រលាយទាំងនេះបន្ថែមទៀត[1332]។

<u>រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង</u>

261. តាវ៉ាល់ដែលជាមេកងចល័តតំបន់ ៥ និងជាអ្នកមើលការខុសត្រូវលើការសាងសង់ប្រលាយផ្នែកភ្នំស្រុក[1333] ត្រូវបានបញ្ជូនទៅ ស-២១ រួមជាមួយនឹងកម្មាភិបាលភូមិភាគពាយ័ព្យផ្សេងទៀត[1334] បន្ទាប់ពី **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីបានមកដល់ភ្លាម[1335]។

262. ក្រោយពេលបានក្លាយជាលេខាស្រុក **អ៊ឹម ចែម** ទទួលបានសិទ្ធិអំណាចគ្រប់គ្រងលើការដ្ឋានទាំងអស់នេះដែលពីមុនក្ដោបក្ដាប់ដោយតាវ៉ាល់[1336]។ **អ៊ឹម ចែម** បានដឹកនាំសកម្មភាពកសាងទំនប់ប្រលាយនៅស្ពានស្រែង និងព្រៃរនាម[1337]។ គាត់បានបញ្ជាឱ្យឃុំនីមួយៗក្នុងស្រុកព្រះនេត្រព្រះបញ្ជូនពលករចំនួន ២០០ ទៅ ៣០០ នាក់ឱ្យមកធ្វើការងារកសាងទំនប់ប្រលាយទាំងនេះ[1338]។ នៅក្រោម **អ៊ឹម ចែម** កម្មាភិបាលភូមិភាគនិរតីម្នាក់គឺ តាពាល់ ត្រូវបានដាក់ឱ្យទទួលខុសត្រូវលើសកម្មភាពប្រចាំថ្ងៃនៅការដ្ឋានទាំងនោះ[1339]។

263. **អ៊ឹម ចែម** បានចុះមកមើលការរដ្ឋានទាំងនេះដើម្បីពិនិត្យមើលដំណើរការសាងសង់ និងដើម្បីជម្រុញឱ្យពលករខិតខំធ្វើការងារឱ្យបានលឿនជាងមុន តាមរយៈការបង្កការភ័យខ្លាច និងការបំភិតបំភ័យជារឿយៗ[1340]។ គាត់ក៏បានធ្វើជាអធិបតីក្នុងពេលប្រជុំអំពីការដ្ឋានទាំងនោះផងដែរ[1341] ហើយតែងតែសម្របសម្រួលជាមួយនឹងប្រធានភូមិពាក់ព័ន្ធនឹងតម្រូវការជាក់លាក់ក្នុងការសាងសង់[1342]។

<u>ពលកម្មដោយបង្ខំ</u>

264. ប្រជាជនរាប់ពាន់នាក់ត្រូវបានបង្ខំឱ្យធ្វើការងារនៅស្ពានស្រែង និងព្រៃរនាម[1343] នៅតាមកងចល័តដែលមានទំហំខុសៗគ្នា រួមទាំងកងកុមារផងដែរ[1344]។ ពលកម្មទាំងអស់ត្រូវធ្វើឡើងដោយប្រើដៃដោយពុំមានគ្រឿងម៉ាស៊ីនជួយនោះទេ[1345]។ ពលករត្រូវបានបង្ខំឱ្យជីកប្រលាយ លើកទំនប់ និងសាងសង់អាងស្តុកទឹក ហើយពេលខ្លះត្រូវបានបញ្ជូនឱ្យទៅធ្វើការងារនៅគម្រោងកសាងទំនប់ប្រលាយផ្សេងទៀត ដូចជាទំនប់ត្រពាំងថ្មជាដើម[1346]។

## ស្ថានភាពរស់នៅដោយអមនុស្សធម៌

265. ក្រោយកម្មាភិបាលភូមិភាគនិរតីបានមកដល់ ស្ថានភាពសម្រាប់ពលករនៅតាមការដ្ឋានទាំងអស់ក្នុងស្រុក រួមទាំងការដ្ឋាននៅស្ពានស្រែង និងព្រៃរនាមមានភាពដុនដាបដោយមានម្ហូបអាហារតិចតួចសម្រាប់ហូប ហើយមានមនុស្សស្លាប់ច្រើន[1347]។

266. ពលកររស់នៅតាមខ្ទម និងរោង[1348] ហើយត្រូវបានឲ្យសម្រាកតិចតួចប៉ុណ្ណោះ[1349]។ របបអាហារមិនគ្រប់គ្រាន់[1350] ដោយឲ្យអង្ករតែពីរកំប៉ុងទុកដាំបបរសម្រាប់មនុស្ស ២០០ នាក់[1351]។ ពលករបានទទួលអាហារពីរពេលក្នុងមួយថ្ងៃ ជាធម្មតា ជាបបររាវៗ[1352]។ ដោយសារកង្វះម្ហូបអាហារ ពលករម្នាក់ៗបានស្វះស្វែងដើរបេះរុក្ខជាតិផ្សេងៗទៀត ដូចជា ផ្កាកំប្លោក និងផ្កាខ្ទុរទុកសម្រាប់ហូប[1353]។ ម្ហូបអាហារកាន់តែខ្សត់ឡើងៗនៅក្នុងអំឡុងរដូវវស្សា[1354]។

267. ការស្លាប់ដោយសារដាច់អាហារ និងដោយសារជំងឺឃើញកើតឡើងសាមញ្ញទៅហើយ[1355]។ ពល ករមានជំងឺ ទទួលបានថ្នាំ "អាចម៍ទន្សាយ" ហើយត្រូវបានបញ្ជូនទៅមន្ទីរពេទ្យឃុំដែលពលករទាំងនេះជាច្រើននាក់បានស្លាប់នៅទីនោះ[1356]។ ក្នុងករណីខ្លះ ពលករមានជំងឺត្រូវបានបញ្ជូនត្រឡប់មកតាមឃុំវិញ[1357]។

268. ពលករនៅប្រលាយស្ពានស្រែង និងអាងស្តុកទឹកព្រៃរនាមត្រូវបានគេរំពឹងថាធ្វើការពីព្រឹកព្រហាមរហូតដល់ពេលចុងល្ងាច ហើយត្រូវបានបង្ខំឲ្យធ្វើការពេលយប់ផងដែរនៅពេលពួកគេពុំបានបំពេញតាមផែនការការងារ[1358] ដែលត្រូវបានកំណត់នៅក្នុងពេលប្រជុំ[1359] ដោយពលករម្នាក់ៗតម្រូវឲ្យជីកដីពី ១ ទៅ ៣,៥ ម៉ែត្រគីបក្នុងមួយថ្ងៃ[1360]។ ការមិនបានបំពេញតាមផែនការការងារនឹងទទួលរងទណ្ឌកម្ម រួមមានការបន្ថយរបបអាហារ ការងារបន្ថែម ឬការចាប់ខ្លួន[1361]។ មេឃុំទទួលខុសត្រូវលើការស្វែងរកកម្លាំងមកជំនួស ប្រសិនបើមានពលករធ្លាក់ខ្លួនឈឺ ហើយអាចអាចទទួលរងទណ្ឌកម្មប្រសិនបើបង្ហាញថាមានការអត់ឱនចំពោះពលករ[1362]។

## អាពាហ៍ពិពាហ៍ដោយបង្ខំ

269. មេកងក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** រៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំឲ្យពលករនៅការដ្ឋានស្ពានស្រែង[1363]។ ប្រជាជនមិនអាចបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍នោះទេបើមិនដូច្នោះទេពួកគេនឹងត្រូវបានចាត់ទុកថាជា "ខ្មាំង"[1364]។

## ការចាប់ខ្លួន ឃុំឃាំង និងសម្លាប់ដោយខុសច្បាប់

270. **អ៊ឹម ចែម** មានសិទ្ធិអំណាចបញ្ជាឲ្យចាប់ខ្លួននៅប្រលាយស្ពានស្រែង និងអាងស្តុកទឹកព្រៃរនាម ហើយដាក់ទណ្ឌកម្ម រួមមាន ការឃុំឃាំង និងការសម្លាប់[1365]។ កម្មករដែលត្រូវបានចោទថាមានកំហុសស្រាលត្រូវបានចាប់ខ្លួន និង "កសាង"[1366]។ អ្នកដែលប្រព្រឹត្តខុសទៀត ឬ ដែលត្រូវបានចាត់ទុកថា "មាននិន្នាការប្រឆាំងនឹងអង្គការ" ត្រូវបានសម្លាប់ចោល ឬ បាត់ខ្លួន[1367]។ ការបាត់ខ្លួនពីការដ្ឋានឃើញកើតមានជាធម្មតា ហើយការបញ្ជូនទៅអប់រំ ឬ លុតដំ ត្រូវបានយល់ឃើញថាត្រូវបានសម្លាប់ចោល[1368]។ ការចាប់ខ្លួនធ្វើឡើងនៅពេលយប់ដោយយោធាប្រដាប់ដោយអាវុធរួមជាមួយនឹងមេសហករណ៍ដែលជាអ្នកផ្តល់ឈ្មោះប្រជាជនដែលត្រូវចាប់ខ្លួន[1369]។ ពលករ និងក្រុមគ្រួសាររបស់ពួកគេត្រូវបានចាប់ខ្លួន ឬ ទទួលទណ្ឌកម្មនៅប្រលាយស្ពានស្រែង និងអាងស្តុកទឹកព្រៃរនាម[1370] ដោយសារហេតុផលដូចជាព្យាយាមរត់គេច "ខ្ជិល" និង ធ្វើ "ខុស"[1371]។ សាក្សីពីររូបដែលធ្វើការងារនៅប្រឡាយស្ពានស្រែងដែលមានសាក្សីម្នាក់គឺជាមេកងពលករ ២០០ នាក់ បានពិពណ៌នាអំពី "ពលករស្គមស្គាំង" ដែលព្យាយាមរត់ចេញពីការដ្ឋាន ប៉ុន្តែត្រូវបានកងកម្លាំងរបស់ **អ៊ឹម ចែម** ចាប់ខ្លួនបញ្ជូនត្រឡប់មកវិញ[1372]។

271. អ្នកដែលត្រូវបានគេចាប់ខ្លួនត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខផងដែរ ដូចជា មន្ទីរសន្តិសុខភ្នំទ្រយោង[1373] ដែលមានការសម្លាប់មនុស្សជារឿយៗនៅទីនោះ[1374]។ អ្នកដែលត្រូវបានចាប់ខ្លួនយកទៅបាត់ ត្រូវបានដាក់ជំនួសដោយពលករថ្មីៗមកវិញ[1375]។

## (៨) ការដ្ឋានទំនប់ត្រពាំងថ្ម (ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩)

### ទីតាំង និងតំណើរការ

272. ទំនប់ត្រពាំងថ្មស្ថិតនៅជិតភូមិត្រពាំងថ្មក្នុងឃុំប៉ោយចារ ស្រុកភ្នំស្រុក ដែលបច្ចុប្បន្នជាខេត្តបន្ទាយមានជ័យ[1376] និងជាអតីតខេត្តបាត់ដំបង[1377] ក្នុងតំបន់ ៥ ភូមិភាគពាយ័ព្យ[1378]។ ទំនប់នេះបានចាប់ផ្តើមសាងសង់នៅក្នុងឆ្នាំ ១៩៧៦[1379] ឬ ដើមឆ្នាំ ១៩៧៧[1380] ហើយបានបន្តរហូតដល់ឆ្នាំ ១៩៧៨[1381]។ ទំនប់នេះត្រូវបានស្តារឡើងវិញនៅក្នុងឆ្នាំ ២០០៤ ហើយបន្តប្រើប្រាស់រហូតដល់សព្វថ្ងៃដោយទំហំនៅដដែល ក៏ប៉ុន្តែមានការប្រែប្រួលរូបរាងខ្លះចាប់តាំងពីពេលកសាងក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ មកទល់បច្ចុប្បន្ន[1382]។

273. ទំនប់នេះមានខ្នងទំនប់ចំនួនពីរ ដោយខ្នងទំនប់ពីខាងកើតទៅខាងលិចមានប្រវែងប្រហែល ៩ គីឡូម៉ែត្រ ហើយខ្នងទំនប់ពីខាងជើងទៅខាងត្បូងមានប្រវែងប្រហែល ១៣ គីឡូម៉ែត្រ[1383]។ ផែនការសាងសង់បានបង្ហាញថា ទំនប់នេះនឹងត្រូវសាងសង់កំពស់ ៨ ម៉ែត្រ[1384] ទទឹងទំហំប្រហែល ២០ ម៉ែត្រ[1385] ទៅ ៥០ ម៉ែត្រ[1386] ត្រង់ផ្នែកខាងលើទំនប់ ហើយបាតទំនប់ទំហំ ៦០ ម៉ែត្រ[1387] ទៅ ១២០ ម៉ែត្រ[1388]។ អាងស្តុកទឹកធំមានសមត្ថភាពអាចរក្សាទុកទឹកបានជិត ២០០ លានម៉ែត្រគីប[1389]។ ទំនប់នេះមានស្ពានចំនួនបីនៅតាមខ្នងទំនប់ពីខាងកើតទៅខាងលិច[1390]។ ស្ពានទីមួយស្ថិតនៅខាងកើតបំផុត ហើយស្ថិតនៅខាងលិចចំណុចប្រសព្វនៃខ្នងទំនប់ទាំងពីរ[1391]។ ស្ពានកណ្តាល ឬ ស្ពានទីពីរនៅខាងលិចស្ពានទីមួយចម្ងាយ ៣,២ គីឡូម៉ែត្រ[1392]។ ស្ពានទីបីគឺស្ពានខាងលិចបំផុតនៅចុងខ្នងទំនប់ពីខាងកើតទៅខាងលិច ហើយនៅខាងលិចស្ពានទីពីរចម្ងាយ ៣,៥ គីឡូម៉ែត្រ[1393]។ ផ្លូវតូចៗរត់តាមបណ្តោយខ្នងទំនប់ទាំងពីរ[1394]។

274. បន្ទាប់ពីការសាងសង់ដំណាក់កាលដំបូង ការងារសាងសង់បន្ថែមដែលរួមមានការពង្រីករចនាសម្ព័ន្ធទំនប់ធំ[1395] ការកសាងទ្វារទឹក[1396] ប្រលាយ[1397] និងភ្លឺស្រែ[1398]បានធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៨។ វាលស្រែនៅជាប់នឹងអាងស្តុកទឹក ត្រូវបានដាំដុះច្រូតកាត់ចាប់ពីចុងឆ្នាំ ១៩៧៨ រហូតមក[1399]។ ទំនប់នេះក៏មានការជួសជុលច្រើនលើកដែរ ក្រោយពីបានបំភ្លិចបំផ្លាញធ្ងន់ធ្ងរដោយជំនន់ទឹកនៅក្នុងអំឡុងរដូវវស្សាក្នុងឆ្នាំ ១៩៧៨[1400]។

<u>រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង</u>

275. **អ៊ឹម ចែម** មានតួនាទីពីរនៅត្រពាំងថ្ម ពោលគឺជាលេខាស្រុកព្រះនេត្រព្រះផង និងជាគណៈតំបន់ ៥ ផង។ **អ៊ឹម ចែម** បានបញ្ជូនពលករទៅធ្វើការងារនៅត្រពាំងថ្ម ក្រោយក្លាយជាលេខាស្រុកព្រះនេត្រព្រះនៅក្នុងខែមិថុនា ឆ្នាំ ១៩៧៧[1401]។ ក្នុងនាមជាគណៈតំបន់ ៥ ពោលគឺជាសមាជិកនៅក្នុងឆ្នាំ ១៩៧៧[1402] និងជាអនុលេខានៅក្នុងឆ្នាំ ១៩៧៨[1403] **អ៊ឹម ចែម** ក៏ទទួលខុសត្រូវលើការដ្ឋាននេះ និងពលករនៅទីនោះផងដែរ[1404]។

276. តាវ៉ាល់ មានអំណាចគ្រប់គ្រងលើកម្មករនៅទំនប់[1405] ក្នុងនាមជាមេកងចល័តតំបន់ ៥[1406] នៅមុនពេល **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីទៅដល់។ តាវ៉ាល់ ត្រូវបានបោសសម្អាតនៅពាក់កណ្តាលឆ្នាំ ១៩៧៧[1407] ហើយជំនួសដោយ តាយន់ ដែលជាកម្មាភិបាលភូមិភាគនិរតី[1408]។

277. **អ៊ឹម ចែម** បានចូលរួមយ៉ាងសកម្មនៅក្នុងការកសាងទំនប់នេះ[1409]។ គាត់បានចុះទៅមើលការដ្ឋាននេះជារៀងរាល់សប្តាហ៍[1410] ហើយបានបញ្ជូនថ្នាក់ក្រោមរបស់គាត់ទៅពិនិត្យមើលការដ្ឋាន និងពិនិត្យចាត់ចែងពលករដោយផ្ទាល់[1411]។ គាត់ក៏បានទទួលស្វាគមន៍ ខៀវ សំផន ជាទៀងទាត់ ហើយពេលខ្លះ ប៉ុល ពត ដែលមកពិនិត្យមើលទំនប់នោះ ព្រមទាំងបានអមដំណើរគណៈប្រតិភូចិនដែលបានចុះមកពិនិត្យទំនប់នោះយ៉ាងហោចណាស់ក៏ម្តងផងដែរ[1412]។

278. **អ៊ឹម ចែម** បានជួបប្រជុំនៅទំនប់[1413] ដែលបានរៀបចំឡើងដោយថ្នាក់ក្រោមរបស់គាត់[1414]។ នៅក្នុងកិច្ចប្រជុំទាំងនេះដែលជារឿយៗមានការចូលរួមពីពលកររាប់ពាន់នាក់[1415] **អ៊ឹម ចែម** បានណែនាំពួកគេឱ្យប្រឹងប្រែងធ្វើការ ពង្រឹងជំហរ និងយកចិត្តទុកដាក់លើការងារ[1416]។ **អ៊ឹម ចែម** ក៏បានប្រាប់ពលករនៅក្នុងកិច្ចប្រជុំថា ពួកគេត្រូវ "ខិតខំធ្វើការ និងលុបបំបាត់ឱ្យអស់នូវវណ្ណៈមូលធននិយម" ដែលឃ្លានេះត្រូវបានឱ្យពលករស្រែកតាមផងដែរ[1417]។

279. **អ៊ឹម ចែម** បានគ្រប់គ្រង និងចេញបញ្ជា[1418] ឱ្យទៅកងឈ្លប កងទ័ព និងមេកងក្នុងស្រុកដែលត្រូវតពិនិត្យចាត់ចែង និងតាមដានលើពលករ[1419]។ នៅពេលពលកររត់គេចចេញពីទំនប់ **អ៊ឹម ចែម** បានឱ្យគេចាប់ពួកគេមកវិញ ហើយយកទៅមន្ទីរសន្តិសុខភ្នំត្រលៀប[1420] នៅមុនពេលចេញបញ្ជាឱ្យមេកងបញ្ជូនពលករទាំងនោះត្រឡប់ទៅទំនប់វិញ ក្រោមការដឹកបណ្តើរដោយកងឈ្លប[1421]។

## ពលកម្មដោយបង្ខំ

280. ពលកររាប់ពាន់[1422] ទៅរាប់ម៉ឺននាក់[1423]ត្រូវបានបង្ខំឱ្យសាងសង់ទំនប់ត្រពាំងថ្ម។ ពលករមានចំនួនយ៉ាងច្រើនរហូតដល់សាក្សីខ្លះមិនអាចប៉ាន់ស្មានថាមានចំនួនមនុស្សប៉ុន្មាននាក់បានធ្វើការងារនៅការដ្ឋាននោះទេ[1424]។

281. បុរស ស្ត្រី[1425] យុវជនយុវនារី[1426] និងកុមារ[1427] ត្រូវបានដកយកមកពីស្រុកទាំងអស់ចំនួន ៤ ស្រុកក្នុងតំបន់ ៥ ដើម្បីឱ្យមកធ្វើការងារនៅការដ្ឋាននោះ[1428]។ ពលករភាគច្រើនជា "ប្រជាជនថ្មី" ដែលត្រូវបានជម្លៀសពីក្រុងភ្នំពេញដោយមានពលករមួយចំនួនតូចតែប៉ុណ្ណោះគឺជា "ប្រជាជនមូលដ្ឋាន"[1429]។ កម្លាំងពលកម្មត្រូវបានបែងចែកចេញជាកងៗដោយមានសមាជិក១០នាក់[1430] ដោយបីកងនេះបង្កើតបានមួយកងតូច[1431] ហើយប្រហែល ៣ កងតូច ទៅ ៦ កងតូច បង្កើតបានជាមួយកងធំ[1432]។

282. ពលករមានចំនួនថេរ ទោះបីក្រោយការសាងសង់ដំណាក់កាលដំបូងបានបញ្ចប់ហើយក៏ដោយដោយសារមានការសាងសង់ពង្រីកទំនប់បន្ថែម[1433] ព្រមទាំងការជួសជុលការដ្ឋាននេះក្រោយពេលមានការបំផ្លិចបំផ្លាញពីជំនន់ទឹកធំនៅក្នុងឆ្នាំ១៩៧៨[1434] ដោយសារលារដ្ឋាននេះត្រូវការពល ករពីកងចល័តរាប់ពាន់នាក់ឱ្យមានធ្វើការងារនេះ[1435]។

## ស្ថានភាពរស់នៅដោយអមនុស្សធម៌

283. ក្រោយពេល **អ៊ឹម ចែម** និងកម្មាភិបាលភូមិភាគនិរតីបានមកដល់ លក្ខខណ្ឌរស់នៅ និងការងារនៅនៅទំនប់កាន់តែមានសភាពអមនុស្សធម៌ទៅ[1436]។ ទោះបីជាបានអះអាងថា គាត់បានធ្វើឱ្យលក្ខខណ្ឌចំពោះអ្នកនៅក្រោមអំណាចគ្រប់គ្រងរបស់គាត់ប្រសើរឡើងក៏ដោយ[1437] ក៏របបអាហារសម្រាប់ពលករនៅការដ្ឋានត្រូវបានកាត់បន្ថយ[1438]។ ម្ហូបអាហារមានតិចតួច[1439] ជាធម្មតា មានតែបបរ[1440] បបររាវៗ[1441] ឬ បាយតែប៉ុណ្ណោះ[1442]។ ពលករខ្លះមានខ្លួនប្រាណស្គមស្គាំងសល់តែស្បែកដណ្តប់ឆ្អឹង[1443]។ អ្នកដែលបានលួចម្ហូបអាហារដើម្បីបំបាត់ភាពស្រេកឃ្លានត្រូវបានចាប់ខ្លួនយកទៅសម្លាប់ចោល[1444] ក្នុងនោះរួមមានសាក្សីម្នាក់ដែលមានផ្ទៃពោះបួនខែផងដែរ[1445]។

284. ទោះបីជាបានដឹងថាមានការខ្វះខាតអាហារក៏ដោយ ក៏ **អ៊ឹម ចែម** បានបង្កើនផែនការការងារ[1446] សម្រាប់មនុស្សម្នាក់យ៉ាងតិចបីម៉ែត្រគីបក្នុងមួយថ្ងៃ[1447]។ ម៉ោងធ្វើការងារជាទូទៅត្រូវបានបែងចែកជាបីពេល ពោលគឺ ពេលព្រឹក ពេលរសៀល និងពេលល្ងាច[1448]។ ពលកម្មធ្ងន់ធ្ងរ និងម្ហូបមិនគ្រប់គ្រាន់[1449] ធ្វើឱ្យពលករជាច្រើននាក់ឈឺ ហើយនាំឱ្យកើតជម្ងឺខ្វះជីវជាតិ និងដាច់អាហារពាសពេញទីកន្លែង[1450]។ ប្រសិនបើពលករមិនបានបំពេញតាមផែនការការងារ ពួកគេនឹងត្រូវបានគេបង្ខំឱ្យធ្វើការនៅពេលយប់[1451] ដកម្ហូបអាហារ[1452] ឬ សម្លាប់ចោល[1453]។ អ្នកដែលមានរាងកាយខ្សោយពេកមិនអាចធ្វើការងារបានត្រូវបានចោទថាធ្វើពុតជាឈឺ[1454] វាយដំ[1455] ឃុំឃាំង ឬ បញ្ជូនទៅ "រៀនសូត្រ" ជាធម្មតា វាមានន័យថា ពួកគេត្រូវបានយកទៅសម្លាប់ចោល[1456]។

285. ពលករសាងសង់ជម្រកសម្រាប់ខ្លួនឯងនៅជាប់ការដ្ឋាន[1457] ជារោងៗមានប្រហែល ១០ ម៉ែត្រ ធ្វើអំពីឈើប្រក់ស្បូវ[1458] ឬ ស្លឹកដូង[1459]។ ពលករដេកផ្ទាល់នៅលើដី[1460] ឬនៅក្នុងអង្រឹងធ្វើអំពីបាវអង្ករ[1461] ដោយគ្មានខ្នើយកើយ[1462] ភួយដណ្តប់[1463] ឬ មុងចងនោះទេ[1464]។

286. នៅទំនប់នេះពុំមានអនាម័យ[1465] គ្មានបង្គន់ ហើយពលករបត់ជើងនៅតាមវាល[1466]។ រុយ[1467] និងមូសឃើញមាននៅពាសពេញការដ្ឋាន ។ ពស់ និងសត្វអសិរពិសផ្សេងទៀតមករំខានពលករជាដរាបខណៈពេលពួកគេគេងហាលវាល[1468]។ គ្មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់[1469] ដូច្នេះពលករមានតែហូបទឹកកង្វក់[1470]។

287. ជំងឺឃើញកើតមានពីកន្លែងមួយទៅកន្លែងមួយទៀត ក្នុងនោះជំងឺទូទៅរួមមានក្តៅខ្លួន[1471] ឈឺពោះ[1472] រាគមួល[1473] គ្រុនចាញ់[1474] និងអាសន្នរោគ[1475]។ អ្នកដែលចាត់ឱ្យធ្វើជា "ពេទ្យ" ទទួលការបណ្តុះបណ្តាលមិនគ្រប់គ្រាន់ ឬ គ្មានការបណ្តុះបណ្តាលតែម្តង[1476] ហើយបានរអ៊ូរទាំរឿងការខ្វះថ្នាំផ្គត់ផ្គង់ដើម្បីជួយពលករដែលឈឺនៅការដ្ឋាន[1477]។ ពេទ្យទាំងនេះទម្លាប់ចែកតែថ្នាំ "អាចម៍ទន្សាយ" ឬ ថ្នាំបុរាណសម្រាប់ជំងឺគ្រប់យ៉ាង[1478]។ ពលករជាច្រើននាក់រួមទាំងកុមារស្លាប់ដោយសារជំងឺ[1479] ហើយត្រូវបានកប់ចោលនៅទំនប់នោះតែម្តង[1480]។ ពលករឈឺធ្ងន់ជាច្រើននាក់ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យតំបន់ ៥ ដែលនៅជិត ប៉ុន្តែនៅតែស្លាប់ដដែល[1481]។ អតីតពេទ្យម្នាក់ពិពណ៌នាថាបានទទួលការបណ្តុះបណ្តាលផ្នែកពេទ្យតែពីរ ឬបីថ្ងៃតែប៉ុណ្ណោះ ហើយបានលើកឡើងថា "កាលនោះអ្នកណាងាប់ក៏ងាប់ទៅ អ្នកណារស់ក៏រស់ទៅ"[1482]។

## អាពាហ៍ពិពាហ៍ដោយបង្ខំ

288. ពលករនៅទំនប់ត្រពាំងថ្មត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍[1483]។ អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានរៀបចំឡើងជាក្រុមរហូតដល់ ១០០ គូ[1484] ដែលត្រូវបានហៅឱ្យទៅអង្គុយជាប់គ្នា ហើយប្តេជ្ញាថា ពួកគេនឹងបម្រើ "អង្គការ"[1485]។ គូភាគច្រើនពុំដែលធ្លាប់បានជួបគ្នានៅមុនថ្ងៃរៀបការនោះទេ[1486]។ សាក្សីម្នាក់លើកឡើងថា នៅក្នុងយប់ថ្ងៃគាត់រៀបការ កងឈ្លបបានមកតាមដានគាត់ដើម្បីចង់ដឹងថាគាត់ "ចុះសម្រុង" ជាមួយនឹងប្តីរបស់គាត់ដែរឬទេ[1487] ពោលគឺ ដើម្បីមកតាមដានថា គាត់បានរួមដំណេកដែរ ឬទេ។ អាពាហ៍ពិពាហ៍ដោយបង្ខំបានបន្តរៀបចំឡើងនៅការដ្ឋានរហូតមកទល់មុនពេលវៀតណាមចូលដល់តែបន្តិចប៉ុណ្ណោះ[1488]។

## ការចាប់ខ្លួន ការបាត់ខ្លួន និងការកាប់សម្លាប់ដោយខុសច្បាប់

289. ការចាប់ខ្លួន រួមទាំង ស្ត្រី និងកុមារ[1489] ឃើញកើតឡើងសាមញ្ញទៅហើយនៅតាមកាដ្ឋាន[1490] ហើយជាពិសេសនៅពេលយប់[1491]។ ទោះបីជា "ប្រជាជនថ្មី" គឺជាគោលដៅចំបងនៃការចាប់ខ្លួនក៏ដោយ[1492] ក៏អ្នកដែលជាប់ពាក់ព័ន្ធនឹងវៀតណាម ឬអ្នកដែលត្រូវបានគេយល់ឃើញថាមានការជាប់ពាក់ព័ន្ធនឹងវៀតណាមក៏ក្លាយជាគោលដៅរបស់គេផងដែរ[1493]។ អ្នកដែលត្រូវបានកងទ័ពចាប់ខ្លួន នាំមកពីការដ្ឋានត្រូវបានសម្លាប់ចោល[1494]។ សាក្សីបានឃើញ អ្នកទោសត្រូវបានបណ្តើរជាជួរដោយចងស្លាបសេក[1495]។ អ្នកទោសខ្លះត្រូវបានបញ្ជូនទៅសម្លាប់ចោលនៅមន្ទីរសន្តិសុខភ្នំទ្រយោង[1496]។

290. ក្រោមសិទ្ធិអំណាចគ្រប់គ្រងរបស់ **អ៊ឹម ចែម** ពលករត្រូវបានបញ្ជូនឱ្យទៅរៀនសូត្រ និងសម្លាប់ចោលកាន់តែច្រើនជាងមុន[1497]។ សាក្សីម្នាក់ពិពណ៌នាថាបានដឹង **អ៊ឹម ចែម** ប្រកាសថា អ្នកដែលធ្លាប់ជាសិស្ស និស្សិត ទាហាន ឬអ្នករដ្ឋការ នឹងត្រូវយកទៅលត់ដំ ហើយអ្នកទាំងនោះក៏ត្រូវបានយកទៅមន្ទីរសន្តិសុខភ្នំទ្រយោងសម្លាប់ចោលផងដែរ[1498]។

291. ពលករដែលរត់គេចពីការដ្ឋាន និងត្រឡប់មកវិញ ឬ ត្រូវបានចាប់បានមកវិញ ត្រូវបានចាប់ខ្លួនបញ្ជូនទៅរៀនសូត្រ និងបានបាត់ខ្លួន[1499]។ អ្នកដែលបាត់ខ្លួនពីការដ្ឋាន[1500] មិនដែលឃើញវិលត្រឡប់មកវិញទេ[1501] ឬត្រូវបានសម្លាប់ចោល[1502]។ ការបាត់ខ្លួនបែបនេះឃើញកើតឡើងជាញឹកញាប់ដោយមាន

មនុស្សពីរ ឬបីនាក់បានបាត់ខ្លួនពីកងនីមួយៗរៀងរាល់ពីបីយប់ម្តង[1503]។ ពលករបុរស និងស្ត្រីដែលត្រូវបានចោទថាមានកំហុសសីលធម៌ ក៏ត្រូវបានយកទៅសម្លាប់ចោលផងដែរ[1504]។

292. ការកាប់សម្លាប់ឃើញកើតមានពីកន្លែងមួយទៅកន្លែងមួយនៅការដ្ឋាននោះ[1505]។ អ្នកដែលជាប់ពាក់ព័ន្ធនឹងវៀតណាម[1506] អតីតទាហាន សាធារណៈរដ្ឋខ្មែរ[1507] បញ្ញាជន[1508] និង "ប្រជាជនថ្មី" គឺជាគោលដៅចំបងនៃការកាប់សម្លាប់[1509]។ **អ៊ឹម ចែម** បានទទួលរបាយការណ៍អំពីពលករនៅតាមកន្លែងប្រជុំ ហើយបានអនុញ្ញាតឲ្យកាប់សម្លាប់អ្នកដែលត្រូវបានចាត់ទុកថាមានការលំបាក ឬជាជនក្បត់[1510]។ ពលករខ្វាក់មាន់ក៏ក្លាយជាគោលដៅរបស់គេផងដែរ[1511] ដោយគេឲ្យដើរសំដៅទៅរករណ្តៅលាមកនៅពេលយប់[1512]។ អ្នកដែលធ្លាក់ចូលរណ្តៅលាមកត្រូវបានទុកជីវិតឲ្យ ចំណែកអ្នកដែលមិនធ្លាក់ទេនោះត្រូវបានចោទថាធ្វើពុត ហើយត្រូវបានចាប់ខ្លួន និងបាត់ខ្លួន[1513] ឬត្រូវបាន យកទៅសម្លាប់ចោល[1514]។

293. សាកសពអ្នកដែលត្រូវបានសម្លាប់ជារឿយៗ ត្រូវបានកប់នៅក្រោមគ្រឹះទំនប់[1515] ឬដាក់ចូលក្នុងរណ្តៅជិតទំនប់[1516]។ សាក្សីម្នាក់ពិពណ៌នាសាកសពអ្នកទោសម្នាក់ដែលមិនអាចបំពេញតាមផែនការការងារ ហើយត្រូវបានទម្លាក់ចូលក្នុងទឹកនៅអាងស្តុកទឹកត្រពាំងថ្ម[1517]។ នៅក្នុងកិច្ចប្រជុំមួយដែលមាន **អ៊ឹម ចែម** ជាសហប្រធាន មនុស្សចន្លោះពី ៨០ ទៅ ៩០ នាក់ដែលបាននិយាយប្រឆាំង "អង្គការ" ត្រូវបានចាប់ខ្លួន សម្លាប់ចោល និងកប់នៅក្រោមគ្រឹះត្រពាំងថ្ម[1518]។ សាក្សីនានាក៏ពិពណ៌នាការកាប់សម្លាប់ និងការកប់ស្ត្រីមានផ្ទៃពោះនៅតាមស្ពានទំនប់តាមបញ្ជារបស់ **អ៊ឹម ចែម** ផងដែរ[1519] ដោយគេគិតថា សាកសពស្ត្រីទាំងនេះនឹងទប់ឲ្យស្ពានរឹងមាំ[1520]។

# III. ច្បាប់

## ក. ឧក្រិដ្ឋកម្ម

### ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

294. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក អនុញ្ញាតឲ្យ អ.វ.ត.ក មានយុត្តាធិការជំនុំជម្រះបុគ្គល ដែលជាប់សង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[1521]។ បទល្មើសជាក់លាក់រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណ្ណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា និងអំពើអមនុស្សធម៌ដទៃទៀត។ ធាតុផ្សំនីមួយៗនៃបទល្មើសទាំងនេះត្រូវបានពិភាក្សាខាងក្រោម។ ការប្រព្រឹត្តបទឧក្រិដ្ឋនេះ អាចនឹងកើតឡើងតាមរយៈអំពើកម្ម ឬ អកម្ម[1522] និង មិនកម្រិតត្រឹមតែអ្នកប្រព្រឹត្តបទល្មើសដោយកាយផ្ទាល់[1523]។ អ្នកប្រព្រឹត្តបទល្មើសត្រូវតែមានចេតនាលើអំពើកម្ម ឬ អកម្ម, ឬ បានដឹងពីភវនីយភាពយ៉ាងសំខាន់ ដែលឧក្រិដ្ឋកម្មមួយនឹងត្រូវកើតឡើងជាវិបាកនៃអាកប្បកិរិយារបស់គាត់[1524]។

### លក្ខខណ្ឌទូទៅ

295. អនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានលក្ខណៈខុសគ្នាត្រង់លក្ខខណ្ឌទូទៅដែលកំណត់ថា ឧក្រិដ្ឋកម្មទាំងនោះត្រូវតែ "បានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុជាតិសាសន៍ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា"[1525]។ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឆ្នាំ ១៩៧៥ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនតម្រូវឲ្យមានភាពទាក់ទងគ្នាទៅនឹងជម្លោះប្រដាប់អាវុធនោះទេ[1526]។

296. ធាតុផ្សំនីមួយៗនៃលក្ខខណ្ឌ *ទូទៅ* នឹងលើកយកមកពិភាក្សានៅខាងក្រោម។

#### <u>ការវាយប្រហារ</u>

297. ការវាយប្រហារគឺជាអំពើពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើហិង្សាច្រើន ឬការធ្វើបាបប្រជាជនស៊ីវិលរួមទាំង

អំពើដែលផ្ទុះបញ្ចាំងបទល្មើសជាក់លាក់នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[1527]។ នៅក្នុងការវាយប្រហារតែមួយ វាអាចកើតមានអំពើហិង្សាច្រើន ឧទាហរណ៍អំពើមនុស្សឃាត រំលោភសេពសន្ថវៈ និងទារុណ្ណកម្ម[1528]។ អំពើទាំងឡាយដែលបង្កើតបានជាការវាយប្រហារ មិនចាំបាច់ត្រូវយកអំពើនោះមកផ្ដន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងមិនកម្រិតត្រឹមតែការប្រើកម្លាំងប្រដាប់អាវុធឡើយ[1529]។ លើសពីនេះទៀត ទោះបីជាសញ្ញាណនៃការវាយប្រហារមានលក្ខណៈខុសគ្នាពីសញ្ញាណនៃជម្លោះប្រដាប់អាវុធក៏ដោយ ក៏"ការវាយប្រហារ" សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល គឺជាសញ្ញាណមួយដាច់ដោយឡែកពីជម្លោះប្រដាប់អវុធ។ ប្រសិនបើមានជម្លោះប្រដាប់អាវុធ ការវាយប្រហារនោះអាចអូសបន្លាយពេលយូរ ឬបន្តមានរហូតក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធនោះ ដោយមិនចាំបាច់ជាផ្នែកនៃជម្លោះនោះទេ[1530]។

<u>លក្ខណៈរីករាលដាល ឬជាប្រព័ន្ធ</u>

298. ការវាយប្រហារត្រូវតែមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ។ លក្ខខណ្ឌទាំងនេះមិនអាចបំបែកចេញពីគ្នាបានទេ[1531]។ ពាក្យ "លក្ខណៈជាទូទៅ" គឺសំដៅទៅលើ "ការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានជនរងគ្រោះច្រើន"[1532] និងអាចរកឃើញតាមរយៈ "អានុភាពត្រួតគ្នានៃអំពើអមនុស្សធម៌ជាច្រើន ឬអានុភាពនៃអំពើអមនុស្សធម៌តែមួយដែលមានទ្រង់ទ្រាយធំ"[1533]។ ពាក្យ "ជាប្រព័ន្ធ" មិនតម្រូវឲ្យការវាយប្រហារមានលក្ខណៈធំទូលាយ ប៉ុន្តែសំដៅលើ "អំពើហិង្សាដែលមានការរៀបចំ ហើយដែលអំពើនោះមិនអាចកើតមានឡើងដោយចៃដន្យនោះទេ"[1534]។ ភាពមានលក្ខណៈជាប្រព័ន្ធនេះ អាចត្រូវបានរកឃើញតាមរយៈភ័ស្តុតាងនៃ "អំពើឧក្រិដ្ឋស្រដៀងគ្នាដែលមិនកើតឡើងដោយចៃដន្យ"[1535]។

299. មានតែការវាយប្រហារប៉ុណ្ណោះ ដែលចាំបាច់តម្រូវឲ្យមានលក្ខណៈជាទូទៅ ឬជាប្រព័ន្ធ ចំណែកបទល្មើសជាក់លាក់ មិនតម្រូវឲ្យមានលក្ខខណ្ឌទាំងនេះទេ[1536]។ អំពើរបស់ចារី តម្រូវឲ្យគ្រាន់តែជាផ្នែកមួយនៃការវាយប្រហារនេះប៉ុណ្ណោះ និងកាលណាលក្ខខណ្ឌដទៃទៀតត្រូវបានបំពេញ អំពើដាច់ដោយឡែកមួយ ឬអំពើមានចំនួនកំណត់ណាមួយដែលជាចំណែករបស់គាត់ អាចបំពេញលក្ខខណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបាន លើកលែងតែអំពើទាំងនោះ ត្រូវបានចាត់ទុកថាជាអំពើដាច់ដោយឡែក ឬដោយចៃដន្យ[1537]។

300. សញ្ញាណដែលទំនងជាអាចបញ្ជាក់អំពីការកើតមានឡើងនៃការវាយប្រហារលក្ខណៈជាទូទៅ ឬលក្ខណៈជាប្រព័ន្ធ រួមមាន "ផលវិបាកដែលកើតចេញពីការវាយប្រហារ ទៅលើប្រជាជនដែលបានកំណត់ថាជាគោលដៅ មានចំនួនជនរងគ្រោះច្រើន លក្ខណៈនៃអំពើទាំងនោះ លទ្ធភាពនៃការចូលរួមរបស់មន្ត្រី ឬអាជ្ញាធរ ឬគំរូនៃឧក្រិដ្ឋកម្មផ្សេងទៀតដែលអាចកត់សម្គាល់បាន"[1538]។ ទោះបីជាអត្ថិភាពនៃគោលនយោបាយ ឬផែនការអាចជាភ័ស្តុតាងមួយទាក់ទងនឹងការបង្ហាញពីការវាយប្រហារដែលមានលក្ខណៈទូទៅ ឬជាប្រព័ន្ធក៏ដោយ ក៏អត្ថិភាពនៃគោលនយោបាយ និង ផែនការទាំងនោះ មិនមែនជាធាតុផ្សំច្បាប់ចាំបាច់នៃឧក្រិដ្ឋកម្មនោះទេ[1539]។ ដូចគ្នានេះដែរ ការប្រើប្រាស់ធនធានច្រើនទៅលើការវាយប្រហារនោះ មិនមែនជាលក្ខខណ្ឌតម្រូវនោះទេ ប៉ុន្តែអាចមានតម្លៃភ័ស្តុតាងបាន[1540]។

<u>សំដៅប្រឆាំងនឹងប្រជាជនស៊ីវិល</u>

301. ការវាយប្រហារត្រូវតែ "សំដៅប្រឆាំងនឹងប្រជាជនស៊ីវិល"។ ចំណុចនេះតម្រូវឱ្យប្រជាជនស៊ីវិលនោះត្រូវតែជាគោលដៅចម្បងនៃការវាយប្រហារ ជាជាងជាជនរងគ្រោះដោយចៃដន្យនៃការវាយប្រហារនោះ[1541]។ កត្តាដែលកំណត់បានថាតើការវាយប្រហារមួយ ធ្វើឡើងសំដៅប្រឆាំងនឹងប្រជាជនស៊ីវិល រួមមាន៖ មធ្យោបាយ និងវិធីសាស្ត្រដែលប្រើប្រាស់ក្នុងការវាយប្រហារ ឋានៈនៃជនរងគ្រោះ ចំនួននៃជនរងគ្រោះ លក្ខណៈរើសអើងនៃការវាយប្រហារ លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលវាយប្រហារ និងទំហំនៃកម្លាំងវាយប្រហារ ដែលអាចនិយាយបានថាបានគោរពតាម ឬ មានចេតនាគោរពតាមលក្ខខណ្ឌប្រុងប្រយ័ត្នទាំងឡាយនៃច្បាប់សង្គ្រាម[1542]។

302. ពាក្យ "ប្រជាជនស៊ីវិល" សម្រាប់គោលបំណងនៃធាតុផ្សំនេះ គឺសំដៅលើជនទាំងឡាយដែលមិនមែនជាសមាជិកនៃកម្លាំងប្រដាប់អាវុធខាងបច្ចាមិត្ត ដែលចូលរួមសកម្មណាមួយនៅក្នុងជម្លោះ និងដូច្នេះរួមបញ្ចូលមនុស្ស ដូចជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ និងអ្នកត្រូវបានចាត់ទុកថា *បាត់បង់សមត្ថភាពប្រយុទ្ធ* ដោយសារជំងឺ របួស ជាប់ឃុំ ឬមូលហេតុដទៃណាមួយទៀត[1543]។

303. ពាក្យ "ណាមួយ" គឺចង់បញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនមែនកម្រិតការអនុវត្តបានត្រឹមតែក្រុមប្រជាជនស៊ីវិលជាក់លាក់ណាមួយ ដែលអាចញែកអត្តសញ្ញាណដោយសញ្ជាតិ ជាតិពន្ធុ ឬកត្តាដទៃទៀតណាមួយនោះទេ[1544]។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចរួមបញ្ចូលទាំងការវាយប្រហារ

របស់រដ្ឋមួយទៅលើប្រជាជនរបស់ខ្លួនឯង[1545] ក្នុងនោះរួមទាំងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ឬរបស់អង្គការខ្លួនឯង[1546]។ វាមិនចាំបាច់បង្ហាញថា ទាល់តែប្រជាជនទាំងអស់នៅក្នុងទីតាំងភូមិសាស្ត្រណាមួយ ត្រូវរងការវាយប្រហារនោះទេ[1547]។ វាមានលក្ខណៈគ្រប់គ្រាន់ដោយគ្រាន់តែបង្ហាញថា ប្រជាជននៅក្នុងក្រុមនោះមួយចំនួនល្មម ត្រូវបានកំណត់ថា ជាគោលដៅនៃការវាយប្រហារ ឬពួកគេត្រូវបានកំណត់ថាជា "ប្រជាជន" ស៊ីវិល ដែលជាគោលដៅនៃការវាយប្រហារ ជាជាងការវាយប្រហារសំដៅប្រឆាំងទៅលើតែបុគ្គលមួយចំនួនតូច ដែលបានកំណត់ ឬត្រូវបានជ្រើសរើសខ្លះៗនោះ[1548]។ "ប្រជាជនស៊ីវិល" អាចរាប់បញ្ចូលទាំងអ្នកដែលមិនមែនជាប្រជាជនស៊ីវិលផងដែរ ដោយមិនប៉ះពាល់ដល់ភាពជាប្រជាជនស៊ីវិលរបស់ខ្លួន ឲ្យតែចំនួនប្រជាជនទាំងនោះមានជនស៊ីវិលច្រើនលើសលុប[1549]។

304. កាលណាលក្ខខណ្ឌចាំបាច់ផ្សេងទៀតត្រូវបានបំពេញ ជនរងគ្រោះជាលក្ខណៈបុគ្គលនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនចាំបាច់ទាល់តែជា "ជនស៊ីវិល" នោះទេ[1550]។

<u>មូលដ្ឋាននៃការរើសអើង</u>

305. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ចែងថា ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល ក្នុងករណីនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវតែធ្វើឡើងដោយមូលហេតុជាតិសាសន៍ នយោបាយ ជាតិពន្ធុ ឬសាសនា[1551]។ លក្ខខណ្ឌតម្រូវនៃការរើសអើងនេះ ជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ដែលកម្រិតវិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលប្រៀបធៀបគ្នាជាមួយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអនុវត្តនៅចន្លោះឆ្នាំ ១៩៧៥ និង ឆ្នាំ ១៩៧៩[1552]។ វាមានភាពគ្រប់គ្រាន់ទៅតាមលក្ខណៈនៃការវាយប្រហារទូលំទូលាយ ជាជាងបទល្មើសជាក់លាក់ លើកលែងតែក្នុងករណីនៃការធ្វើទុក្ខបុកម្នេញ ដែលចេតនានៃការរើសអើង ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនតម្រូវឲ្យក្លាយជាធាតុផ្សំផ្លូវច្បាប់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[1553]។

306. យុត្តិសាស្ត្រពាក់ព័ន្ធនឹងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ កំណត់និយមន័យថា អំពើមួយមានភាពរើសអើង កាលណាចារីកំណត់ថា ជនរងគ្រោះណាមួយជាគោលដៅនៃការវាយប្រហារ ដោយសារតែបុគ្គលនោះជាសមាជិក ឬត្រូវសន្មតថាជាសមាជិក នៅក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ[1554]។ ក្រុមគោលដៅនោះអាចត្រូវបានចារីកំណត់និយមន័យជាទូទៅ ក្នុងន័យអវិជ្ជមាន និងរួមទាំងអ្នកដែល

មានជាប់ទាក់ទងគ្នាជិតស្និទ្ធ និងមានសមានចិត្តចំពោះក្រុមជនរងគ្រោះ ព្រមទាំងជនសង្ស័យផងដែរ[1555] ។ វិធីសាស្ត្រនេះ អាចអនុវត្តបានដូចគ្នាសម្រាប់កំណត់និយមន័យក្រុមណាមួយ ដែលលេចធ្លោជាងគេ និងជាគោលដៅនៃការវាយប្រហារ។

## ចំណងទាក់ទងរវាងអំពើរបស់ចារី និងការវាយប្រហារ

307. អំពើរបស់ចារីត្រូវតែបង្កើតបានជាផ្នែកមួយនៃការវាយប្រហារ។ លក្ខខណ្ឌនៃទំនាក់ទំនងរវាងអំពើរបស់ចារី និងការវាយប្រហារ មានធាតុផ្សំពីរ៖ ការប្រព្រឹត្តអំពើអ្វីមួយដែលលក្ខណៈ ឬផលវិបាកនៃអំពើនោះជាផ្នែកមួយនៃការវាយប្រហារដោយសត្យានុម័ត[1556] ដោយរួមផ្សំនឹងការដឹង ដែលជាចំណែកមួយរបស់ចារីដែលដឹងថា មានការវាយប្រហារលើប្រជាជនស៊ីវិល និងអំពើរបស់គាត់ជាផ្នែកនៃការវាយប្រហារនោះ[1557]។

308. ពាក់ព័ន្ធនឹងធាតុផ្សំទីមួយនោះ អំពើមិនចាំបាច់ទាល់តែប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការវាយប្រហារ ដើម្បីឲ្យមានទំនាក់ទំនងគ្រប់គ្រាន់របស់វាទេ។ អំពើណាមួយដែលត្រូវបានប្រព្រឹត្តនៅមុន ឬនៅក្រោយការវាយប្រហារធំ ឬនៅឆ្ងាយពីនោះ ក៏នៅតែមានភាពពាក់ព័ន្ធគ្រប់គ្រាន់ និង ត្រូវចាត់ទុកថាជាផ្នែកមួយនៃការវាយប្រហារនោះដែរ។ ប៉ុន្តែ បទឧក្រិដ្ឋនោះមិនត្រូវមានលក្ខណៈជាបទឧក្រិដ្ឋដាច់តែឯងនោះឡើយ។ បទឧក្រិដ្ឋណាមួយអាចត្រូវចាត់ទុកថាជាបទឧក្រិដ្ឋដាច់តែឯង កាលណាវានៅឆ្ងាយគ្នាពេកពីការវាយប្រហារនោះ ដ្បិតបើពិចារណាទៅលើបរិបទ និងកាលៈទេសៈដែលអំពើនោះត្រូវបានប្រព្រឹត្ត គេមិនអាចរកហេតុផលសមស្រប ដើម្បីនិយាយថា វាជាផ្នែកមួយនៃការវាយប្រហារនោះទេ[1558]។

309. ចំពោះធាតុផ្សំទីពីរ មិនចាំបាច់ត្រូវដឹងលម្អិតអំពីការវាយប្រហារនោះទេ[1559]។ វាជាការគ្រប់គ្រាន់ឲ្យតែចារីដឹងអំពីបរិបទទាំងមូលនៃការកើតឡើងនៃអំពើរបស់គាត់[1560]។ ការដឹងនេះនឹងត្រូវវាយតម្លៃតាមករណីជាក់ស្តែងនីមួយៗ[1561]។ ចេតនារបស់ចារីមានភាពមិនពាក់ព័ន្ធ[1562] ហើយចេតនានេះមិនចាំបាច់ទាល់តែចារីដឹងអំពីគោលបំណង ឬគោលដៅនៃការវាយប្រហារនោះទេ[1563]។ វាមិនមានភាពពាក់ព័ន្ធនោះទេ ដែលថាជនជាប់ចោទ មានចេតនាចង់ឲ្យអំពើរបស់ខ្លួន សំដៅប្រឆាំងទៅនឹងប្រជាជនស៊ីវិលដែលបានកំណត់ជាគោលដៅ ឬមួយគ្រាន់តែប្រឆាំងទៅលើជនរងគ្រោះ[1564]។ វាមិនមានលក្ខខណ្ឌតម្រូវថា ចារីត្រូវតែដឹងអំពីលក្ខណៈរើសអើងនៃការវាយប្រហារនោះទេ[1565]។

## បទល្មើសជាក់លាក់

### ការធ្វើមនុស្សឃាត

310. ការធ្វើមនុស្សឃាតត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឆ្នាំ ១៩៧៥[1566]។ ជាងនេះទៀត គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេលនោះថាគេអាចនឹងត្រូវចោទប្រកាន់ពីបទធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[1567]។

311. *ធាតុផ្សំសត្យានុម័ត*នៃការធ្វើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តម្រូវឱ្យរកភ័ស្តុតាងនៃធាតុផ្សំពីរ៖ (១) ការស្លាប់របស់ជនរងគ្រោះ និង (២) ការស្លាប់នោះបណ្តាលមកពីអំពើសកម្ម ឬអកម្មរបស់ចារី[1568]។ សាកសពរបស់ជនរងគ្រោះ មិនចាំបាច់រកឱ្យឃើញដើម្បីបញ្ជាក់អំពីការស្លាប់របស់ជនរងគ្រោះនោះទេ[1569]។ ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌតម្រូវនៃការបង្កឱ្យមានការស្លាប់ ភាពជាក់លាក់ដែលថា ការស្លាប់របស់ជនរងគ្រោះ "បណ្តាលមកពី" អំពើសកម្ម ឬ អំពើអកម្មរបស់ចារី មិនមែនបានន័យថា វាត្រូវតែជាមូលហេតុតែមួយគត់ ដែលបណ្តាលឱ្យមានមនុស្សស្លាប់នោះទេ។ គ្រាន់តែអំពើរបស់ចារី ដែលចូលរួមមួយចំណែកយ៉ាងធំទៅនឹងកត្តាដែល បណ្តាលឱ្យជននោះស្លាប់ គឺវាគ្រប់គ្រាន់ហើយ[1570]។ ទាំងអង្គហេតុអំពីការស្លាប់របស់ជនរងគ្រោះ និងធាតុផ្សំនៃកត្តាដែលបណ្តាលឱ្យស្លាប់ អាចទាញសេចក្តីសន្និដ្ឋានពីកាលៈទេសៈនៃករណីនោះ ឱ្យតែគេអាចរកឃើញថា សេចក្តីសន្និដ្ឋានសមហេតុសមផលតែមួយដែលមានគឺថា ជនរងគ្រោះបានស្លាប់ ដោយសារអំពើសកម្ម ឬអកម្មរបស់ចារី[1571]។

312. ចំពោះ*ធាតុផ្សំអត្តនោម័ត*នៃការធ្វើមនុស្សឃាត អំពើត្រូវតែបានប្រព្រឹត្តរួចហើយ ឬអំពើអកម្មបានធ្វើរួចហើយ ដោយមានចេតនាសម្លាប់ ឬធ្វើឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរូបរាងកាយ ដោយមានការដឹងសមហេតុសមផលមួយថា អំពើនោះនឹងទំនងជាបណ្តាលឱ្យមានមនុស្សស្លាប់[1572]។ គ្មានលក្ខខណ្ឌតម្រូវដែលថា ការសម្លាប់នោះត្រូវតែជាឃាតកម្មគិតទុកជាមុននោះទេ[1573]។

### ការសម្លាប់រង្គាល

313. ការសម្លាប់រង្គាលត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រឹមឆ្នាំ ១៩៧៥[1574]។ មិនតែប៉ុណ្ណោះ គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេលនោះថា គេអាចត្រូវបានចោទប្រកាន់ពីបទសម្លាប់រង្គាលដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1575]។

314. ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល គឺជាអំពើនៃការសម្លាប់ទ្រង់ទ្រាយធំមួយ[1576]។ *ធាតុផ្សំសត្យានុម័ត*នៃការសម្លាប់រង្គាលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានអំពើសកម្ម ឬអកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ ដែលនាំឱ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំ[1577]។ តួនាទីរបស់ចារីអាចពីចម្ងាយ ឬដោយប្រយោល[1578] និងអាចអាចរួមបញ្ចូលទាំងការបង្កើតនូវលក្ខខណ្ឌនៃការរស់នៅ ដែលមានគោលបំណងកម្ទេចប្រជាជន ដូចជាការមិនផ្គត់ផ្គង់ម្ហូបអាហារ ឬថ្នាំពេទ្យជាដើម[1579]។ ពុំមានលក្ខខណ្ឌតម្រូវដែលថា ជនរងគ្រោះ "ប្រាកដជាត្រូវប្រឈមនឹងលក្ខខណ្ឌ *ដែលចៀសមិនរួចពី សេចក្តីស្លាប់នោះឡើយ*"[1580]។

315. ការរកឃើញពិរុទ្ធភាពសម្រាប់ការសម្លាប់រង្គាល គ្រាន់តែតម្រូវឱ្យបំពេញលក្ខខណ្ឌលើសពីវិមតិសង្ស័យនៃការកើតឡើងនៃការសម្លាប់ខុសច្បាប់ ដោយផ្អែកលើភ័ស្តុតាងទាំងមូល។ ការបង្ហាញឱ្យឃើញថាមានការសម្លាប់ទ្រង់ទ្រាយធំកើតឡើង គឺជាការគ្រប់គ្រាន់ហើយ[1581]។ ការកំណត់អត្តសញ្ញាណជាក់លាក់ ការពិពណ៌នា ឬការកំណត់ឈ្មោះជនរងគ្រោះ មិនមែនជាធាតុផ្សំឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលនោះទេ[1582]។ ការកំណត់ចំនួនអ្នកស្លាប់ជាក់លាក់ ក៏មិនចាំបាច់នោះដែរ[1583]។

316. ការកំណត់ទៅលើការសម្លាប់ "ទ្រង់ទ្រាយធំ" មិនចាំបាច់ត្រូវបង្ហាញនូវចំនួននៃជនរងគ្រោះ ក្នុងកម្រិតអប្បបរមាណាមួយនោះទេ[1584]។ ទោះបីការសម្លាប់រង្គាលក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានរកឃើញពាក់ព័ន្ធនឹងការសម្លាប់មនុស្សរាប់ពាន់នាក់ក៏ដោយ[1585] ក៏គេអាចរកឃើញថាមានការសម្លាប់រង្គាលផងដែរ ពាក់ព័ន្ធនឹងការសម្លាប់មនុស្សតិចជាងនេះ[1586]។ ចំនួនច្រើនជាក់លាក់ណាមួយនៃជនរងគ្រោះ អាចជាស្ថានទម្ងន់ ពាក់ព័ន្ធនឹងការកំណត់ទោស ប្រសិនបើទំហំនៃការសម្លាប់ទាំងនោះហួសពីលក្ខខណ្ឌកំណត់សម្រាប់ការសម្លាប់រង្គាល[1587]។

317. លក្ខខណ្ឌតម្រូវនៃទ្រង់ទ្រាយធំ ត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ ដោយផ្អែកលើកត្តានៃ កាលៈទេសៈនៃការកើតមានឡើងនូវការសម្លាប់ទាំងនោះ[1588]។ កត្តាពាក់ព័ន្ធរួមមាន ពេលវេលា និងទីកន្លែងនៃការសម្លាប់[1589] ការសម្រិតសម្រាំងជនរងគ្រោះ និងវិធីកំណត់គោលដៅជនរងគ្រោះ និង អំពីការសម្លាប់

ដែលមានចេតនាសំដៅលើក្រុមរួមណាមួយ[1590] ជាជាងសំដៅតែទៅលើជនរងគ្រោះម្នាក់ៗ[1591]។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានលក្ខខណ្ឌដែលតម្រូវថា ចារីមានចេតនាបំផ្លាញក្រុម ឬផ្នែកនៃក្រុមណាមួយ ដែលជនរងគ្រោះជាសមាជិកនៃក្រុមនោះឡើយ[1592]។ ការត្រៀម និង រៀបចំនៃឧក្រិដ្ឋកម្ម អាចត្រូវយកមកពិចារណាផងដែរ នៅពេលសម្រេចអំពី*ធាតុផ្សំសត្យានុម័ត*នៃការសម្លាប់រង្គាល[1593]។

318. *ធាតុផ្សំអត្តនោម័ត* រួមមានចេតនា (i) សម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬ (ii) បង្ករបួសលើរូបរាងកាយធ្ងន់ធ្ងរ ឬបង្កើតលក្ខខណ្ឌនៃការរស់នៅ ដែលនាំឱ្យមានការស្លាប់ដោយមានហេតុផល ដឹងថាអំពើសកម្ម ឬអកម្មនោះមុខជាបង្កឱ្យមានការបាត់បង់ជីវិតមនុស្សជាច្រើន[1594]។ ទាំងចេតនាសម្លាប់ជនរងគ្រោះក្នុងចំនួនកំណត់ជាអប្បបរមាជាក់លាក់ណាមួយ[1595] ទាំងការដឹងអំពី "ផែនការនៃការសម្លាប់រួម"[1596] សុទ្ធតែមិនមែនជាធាតុផ្សំនៃការសម្លាប់រង្គាល។

## <u>ការធ្វើឱ្យទៅជាទាសករ</u>

319. ការធ្វើឱ្យទៅជាទាសការត្រូវបានទទួលស្គាល់ដោយគ្មានការតវ៉ា នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រឹមឆ្នាំ ១៩៧៥[1597]។ មិនតែប៉ុណ្ណោះ គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេលនោះថា គេអាចត្រូវបានចោទប្រកាន់ពីបទនៃការធ្វើឱ្យទៅជាទាសករ ដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1598]។

320. ការធ្វើឱ្យទៅជាទាសករ ត្រូវបានកំណត់និយមន័យថាជាការការប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់កម្មសិទ្ធិលើមនុស្ស[1599]។ សញ្ញាណនៃការធ្វើឱ្យទៅជាទាសករ រួមមាន "ការគ្រប់គ្រងលើការដើរហើររបស់មនុស្សណាម្នាក់ ការគ្រប់គ្រងជារូបវន្តលើកន្លែងរស់នៅ ការគ្រប់គ្រងលើផ្លូវចិត្ត ការចាត់វិធានការនានាដើម្បីទប់ស្កាត់ ឬរារាំងមិនឱ្យគេចខ្លួន ការប្រើកម្លាំង ការគម្រាមកំហែង និងប្រើកម្លាំង ឬការបង្ខិតបង្ខំ រយៈពេលនៃការធ្វើទាសករ ការអះអាងជាម្ចាស់កម្មសិទ្ធិផ្តាច់មុខ ការដាក់ឱ្យស្ថិតនៅក្រោមការប្រព្រឹត្តិ និងការរំលោភបំពានព្រៃផ្សៃ ការគ្រប់គ្រងលើផ្លូវភេទ និងការធ្វើពលកម្មដោយបង្ខំ"[1600]។ ធាតុផ្សំនៃបទល្មើសនៃការធ្វើឱ្យទៅជាទាសករ អាចនឹងត្រូវបានបំពេញ ដោយមិនចាំបាច់មានភស្តុតាងនៃការធ្វើបាបបន្ថែមនោះទេ[1601]។

321. ក្នុងការពិនិត្យសញ្ញាណទាំងនេះ សំខាន់បំផុតគេត្រូវកំណត់សញ្ញាណនៃ"*ភាពជាម្ចាស់*"[1602] ដែលជាអង្គ

ហេតុបង្ហាញថា ជនរងគ្រោះត្រូវបានបន្ទាបឋានៈមកជាទំនិញ មានន័យថាបុគ្គលនោះជាកម្មវត្ថុនៃ *"ការចាត់ចែង"* ដែលជនរងគ្រោះជាបុរស ឬស្ត្រី ត្រូវគេប្រើប្រាស់ (ឧទាហរណ៍ ក្នុងបំណងផ្លូវភេទ ឬបំណងផ្សេងៗទៀត) ត្រូវរងការជិះជាន់ជាប្រយោជន៍សេដ្ឋកិច្ច ត្រូវបានប្រើប្រាស់ក្នុងគោលបំណងសម្រាប់ដោះដូរសរីរាង្គ ហើយទីបញ្ចប់ ត្រូវបានបោះចោល[1603]។ ភាពប្រាកដក្នុងអំណាចកម្មសិទ្ធិ គឺជាការខិតខំប្រឹងប្រែង ដើម្បីបង្កើនផលចំណេញខ្លះ តាមរយៈការប្រើអំណាចក្នុងនាមជាម្ចាស់ ទោះបីចំណុចនេះមិនមែនជាធាតុផ្សំបន្ថែមនៃឧក្រិដ្ឋកម្មក៏ដោយ[1604]។ រយៈពេលនៃការធ្វើឱ្យទៅជាទាសករ មិនមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្ម។ ប៉ុន្តែ រយៈពេលអាចមានភាពពាក់ព័ន្ធ ក្នុងពេលសម្រេចអំពីទំនាក់ទំនង[1605]។

322. ការធ្វើពលកម្មដោយបង្ខំ ឬដោយគ្មានការស្ម័គ្រចិត្ត អាចជាការធ្វើឱ្យទៅជាទាសករផងដែរ[1606]។ អ្វីដែលត្រូវបង្ហាញគឺថា បុគ្គលពាក់ព័ន្ធមិនមានជម្រើសច្បាស់លាស់ ថាតើពួកគាត់ត្រូវការងារ ឬ មិនត្រូវធ្វើការងារនោះ ដែលជាការកំណត់លើអង្គហេតុដែលត្រូវតែធ្វើ ក្រោយពីសញ្ញាណនៃការធ្វើឱ្យទៅជាទាសករត្រូវបានគូសបញ្ជាក់[1607]។ ការមិនមានការផ្តល់កម្រៃ មិនមែនជាធាតុផ្សំនៃការធ្វើឱ្យទៅជាទាសករនោះទេ ប៉ុន្តែអាចបង្កើតបានជាកត្តាភ័ស្តុតាងដែលពាក់ព័ន្ធមួយ សម្រាប់ការសម្រេចថាតើពលកម្មនោះធ្វើឡើងដោយបង្ខំឬយ៉ាងណា[1608]។

323. ការមិនបានយល់ព្រមរបស់ជនរងគ្រោះ ក៏មិនមែនជាធាតុផ្សំឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករដែរ ពីព្រោះការធ្វើឱ្យទៅជាទាសករ ត្រូវបានកំណត់ដោយការអនុវត្តអំណាចរបស់ចារី ប៉ុន្តែ វាអាចមានភាពពាក់ព័ន្ធជាភ័ស្តុតាង ដើម្បីបញ្ជាក់អំពីការអនុវត្តអំណាចនៃកម្មសិទ្ធិ[1609]។ ក្នុងស្ថានភាពដែលមិនអាចបង្ហាញការយល់ព្រមបាន គេសន្មតថាពុំមានការយល់ព្រម[1610] ដូចជាក្នុងករណីដែលជនរងគ្រោះរស់នៅ "ក្នុងបរិយាកាសភ័យខ្លាច"[1611]។ ក្នុងកាលៈទេសៈទាំងនេះ ការខ្វះការតវ៉ា ឬ ការខ្វះការយល់ព្រមច្បាស់លាស់ និងទៀងទាត់ នឹងមិនអាចបកស្រាយថាជាសញ្ញាណនៃការយល់ព្រមបានឡើយ[1612]។ គេរកឃើញថា ស្ថានភាពកន្លែងចង្អៀតខ្លាំង បញ្ហាខ្វះអនាម័យខ្លាំង កង្វះការទទួលទានដំណេក ចំណីអាហារមិនគ្រប់គ្រាន់ ការចាក់សោទ្វារ ការវាយដំជាប្រចាំ ហិង្សាផ្លូវចិត្ត និងស្ថានភាពរស់នៅបែបតិរច្ឆាន ធ្វើឱ្យអ្នកជាប់ឃុំសម្តែងការយល់ព្រម ដើម្បីធ្វើការ ដូច្នេះពលកម្មរបស់ពួកគេ គឺត្រូវបានធ្វើឡើងដោយបង្ខំ[1613]
។

324. *ចំពោះធាតុផ្សំអត្តនោម័តិ* គេត្រូវតែបង្ហាញថា ចារីមានចេតនាអនុវត្តអំណាចណាមួយ ឬទាំងអស់ ក្នុង

នាមជាម្ចាស់កម្មសិទ្ធិលើបុគ្គលម្នាក់ទៀត[1614]។

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង</u>

325. ការដាក់ក្នុងមន្ទីរឃុំឃាំងត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ ១៩៧៥[1615]។ បន្ថែមលើនេះ គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេលនោះថា គេអាចត្រូវបានចោទប្រកាន់ពីបទការដាក់ក្នុងមន្ទីរឃុំឃាំង ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1616]។

326. *ធាតុផ្សំសត្យានុម័ត*នៃការដាក់ក្នុងមន្ទីរឃុំឃាំង[1617] តម្រូវថា បុគ្គលម្នាក់ត្រូវបានដកហូតនូវសិទ្ធិសេរីភាពរបស់គាត់តាមអំពើចិត្ត ពោលគឺ ដោយមិនមានមូលដ្ឋានគតិយុត្ត ដែលអាចផ្តល់យុត្តិកម្មបាន និងដោយមិនមានដំណើរការគតិយុត្តិត្រឹមត្រូវ[1618]។ ប្រសិនបើច្បាប់ជាតិត្រូវបានពឹងផ្អែក បទប្បញ្ញត្តិដែលពាក់ព័ន្ធចាំបាច់ត្រូវតែមិនរំលោភបំពានទៅលើច្បាប់អន្តរជាតិ[1619]។ ក្នុងការសម្រេចថាតើមូលដ្ឋាន និងនីតិវិធីសម្រាប់ការដកហូតបឋមនូវសិទ្ធិសេរីភាព ធ្វើឡើងដោយស្របច្បាប់ដែរឬយ៉ាងណា តុលាការអាចធ្វើការពិចារណាទៅលើកត្តាមួយចំនួនដែលរួមមានថាតើ (១) ការចាប់ខ្លួនផ្អែកទៅលើដីកាដែលមានសុពលភាពដែរឬទេ[1620] (២) អ្នកជាប់ឃុំត្រូវបានជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួនដែរឬទេ នៅពេលចាប់ខ្លួន[1621] (៣) អ្នកជាប់ឃុំត្រូវបានជូនដំណឹងភ្លាមៗ និងលម្អិតដែរឬទេ អំពីបទចោទណាមួយប្រឆាំងរូបគាត់ និង/ឬត្រូវបានចោទប្រកាន់ជាផ្លូវការដែរ ឬទេ[1622] (៤) អ្នកជាប់ឃុំត្រូវបានជូនដំណឹងដែរឬទេ អំពីសិទ្ធិតាមនីតិវិធីរបស់គាត់[1623] រួមមានសិទ្ធិទទួលបានមេធាវីប្រឹក្សាច្បាប់[1624] និង(៥) អ្នកជាប់ឃុំត្រូវបាននាំយកទៅជួបភ្លាមៗ បុគ្គលដែលមានសិទ្ធិតាមផ្លូវច្បាប់ ក្នុងការប្រើប្រាស់អំណាចតាមផ្លូវតុលាការ (ហើយបុគ្គលនោះជាបុគ្គលឯករាជ្យ មិនលម្អៀង និងប្រកបដោយលក្ខណៈសត្យានុម័ត) ដែរឬទេ[1625]។ អ្នកជាប់ឃុំមានសិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធី ដែលភាពស្របច្បាប់នៃការឃុំឃាំងខ្លួនគាត់ ត្រូវបានពិភាក្សាសម្រេចដោយឆាប់រហ័សដោយតុលាការ ហើយនឹងត្រូវបានដោះលែងវិញ ប្រសិនបើរកឃើញថា ការឃុំឃាំងគាត់ធ្វើឡើងដោយមិនស្របច្បាប់[1626]។

327. ប្រសិនបើមានមូលដ្ឋានគតិយុត្តិសម្រាប់ការដកហូតបឋម មូលដ្ឋានគតិយុត្តិនោះចាំបាច់ត្រូវតែបន្តមានរហូត ក្នុងរយៈពេលនៃការឃុំឃាំងនោះ ហើយនៅពេលដែលមូលដ្ឋានស្របច្បាប់សម្រាប់ការឃុំឃាំង

លែងអាចអនុវត្តបាន ការឃុំឃាំងខ្លួនបន្តនឹងត្រូវបានចាត់ទុកថា ធ្វើឡើងតាមអំពើចិត្ត[1627]។ អ្នកជាប់ឃុំមានសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងដោយយុត្តិធម៌ នៅក្នុងពេលវេលាសមស្របមួយ ឬត្រូវបានដោះលែង[1628] ហើយត្រូវទទួលបានសច្ចធារនៃនិរទោស រហូតទាល់តែសម្រេចថាមានពិរុទ្ធភាព[1629]។

328. ចំពោះ*ធាតុផ្សំអត្តនោម័តិ*វិញ ជាការចាំបាច់ត្រូវបង្ហាញថា ចារីមានចេតនាដកហូតតាមអំពើចិត្ត ពីបុគ្គលម្នាក់នូវសិទ្ធិសេរីភាព ឬថា គាត់អនុវត្តដោយមានការដឹងឮសមហេតុផលថា អំពើរបស់គាត់អាចបណ្ដាលឲ្យមានការដកហូតតាមអំពើចិត្តនូវសេរីភាពខាងរូបរាងកាយ[1630]។

<u>ការធ្វើទារុណកម្ម</u>

329. ឧក្រិដ្ឋកម្មការធ្វើទារុណកម្ម ត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅត្រឹមឆ្នាំ ១៩៧៥[1631]។ បន្ថែមលើនេះ គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេលនោះថា គេអាចត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1632]។

330. ទាំងអង្គបុរេជំនុំជម្រះ ក៏ដូចជាអង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា និយមន័យ និងធាតុផ្សំការធ្វើទារុណកម្ម ដែលមានចែងនៅក្នុងសេចក្ដីប្រកាសឆ្នាំ ១៩៧៥ ស្ដីពីការធ្វើទារុណកម្ម បានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥[1633]។

331. *ធាតុផ្សំសត្យានុម័ត*នៃការធ្វើទារុណកម្ម តម្រូវឲ្យមានអំពើសកម្ម ឬអកម្ម ដែលបណ្ដាលឲ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរ ចំពោះរូបរាងកាយ ឬផ្លូវចិត្ត[1634]។ ក្នុងការសម្រេចថាតើអំពើសកម្ម ឬអកម្មបង្កើតបានបានជាការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរ។ ជាការចាំបាច់ដែលត្រូវពិចារណាទៅលើកត្តាសត្យានុម័ត និងកត្តាអត្តនោម័តិទាំងអស់[1635]។ កត្តាសត្យានុម័តរួមមានភាពធ្ងន់ធ្ងរនៃព្យសនកម្មដែលបានបង្កឡើង។ លក្ខណៈវិនិច្ឆ័យអត្តនោម័តិអាចរួមមាន អាយុ ភេទ ស្ថានភាពសុខភាពរបស់ជនរងគ្រោះ ឬផលប៉ះពាល់ផ្នែកផ្លូវកាយ ឬស្មារតីពីការប្រព្រឹត្តិលើជនរងគ្រោះជាក់លាក់មួយ[1636]។ លើសពីនេះ ប្រភេទ និងបរិបទនៃការបង្កការឈឺចាប់ ការគិតទុកមុន និងការបង្កើតការធ្វើបាប ស្ថានភាពផ្លូវកាយរបស់ជនរងគ្រោះ របៀប និងវិធីសាស្ត្រដែលបានប្រើប្រាស់ និងភាពទន់ខ្សោយរបស់ជនរងគ្រោះ គឺសុទ្ធតែជាកត្តាពាក់ព័ន្ធទាំងអស់[1637]។ ក្នុងកម្រិតមួយដែលបុគ្គលម្នាក់ ត្រូវបានប្រព្រឹត្តដោយមិនត្រឹមត្រូវ ក្នុងរយៈពេល

យ៉ាងយូរ ឬថា គាត់ត្រូវទទួលរងការធ្វើបាបជាច្រើនប្រភេទ ឬច្រើនដង ភាពធ្ងន់ធ្ងរនៃអំពើទាំងនោះ គួរត្រូវបានវាយតម្លៃជារួម[1638]។

332. មិនមានការចាត់ចំណាត់ថ្នាក់ច្បាស់លាស់ ចំពោះអំពើដែលអាចចាត់ទុកថាជាការធ្វើទារុណកម្មទេ[1639]។ ផលវិបាកនៃអំពើសកម្ម ឬអកម្ម មិនចាំបាច់មើលឃើញ នៅលើជនរងគ្រោះនោះឡើយ[1640] ហើយមិនមានកម្រិតអប្បរមានៃការឈឺចាប់ ដែលចាំបាច់ត្រូវតែបង្កឡើងនោះឡើយ[1641] ហើយក៏មិនមានលក្ខខណ្ឌតម្រូវដែលថា ការរងរបួសត្រូវតែអចិន្ត្រៃយ៍នោះដែរ[1642]។

333. អំពើដែលចាត់ទុកថាមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ជាការធ្វើទារុណកម្ម អាចកើតចេញពីស្ថានភាពដែលកើតឡើងក្នុងពេលឃុំឃាំង ហើយអាចរួមបញ្ចូលការវាយដំ ការដុត ការដកក្រចក ឬធ្មេញ ការឆក់ខ្សែរភ្លើង ការធ្វើឲ្យថប់ដង្ហើម អំពើរំលោភបំពានលើផ្លូវភេទ និងការបដិសេធមិនឲ្យដេក មិនឲ្យចំណីអាហារ គ្មានអនាម័យ និងជំនួយផ្នែកពេទ្យក្នុងរយៈពេលយូរ ការរក្សាទុកក្នុងភាពមិនច្បាស់លាស់ ការបំពានក្នុងពេលសួរចម្លើយ ការធ្វើត្រាប់ការសម្លាប់ និងការគម្រាមកំហែងធ្វើទារុណកម្ម រំលោភសេពសន្ថវៈ ឬការគម្រាបកំហែងសម្លាប់សាច់ញាតិ[1643]។ ការរស់នៅក្នុងស្ថានភាពអន្ទះសារ និងមិនប្រាកដប្រជាជាបន្តបន្ទាប់ ដែលជាលទ្ធផលនៃការបំពានរូបរាងកាយ និងការឃុំឃាំង បង្កើតបានជាការឈឺចាប់ផ្លូវចិត្ត ដែលអាចចាត់ទុកថាជាការធ្វើទារុណកម្ម[1644]។ ប្រហែលគ្នានេះដែរ ការគម្រាមកំហែងដែលអាចជឿបាន អំពីការធ្វើទារុណកម្មផ្លូវកាយ បង្កើតបានជាការធ្វើទារុណកម្មផ្នែកស្មារតី[1645]។ បន្ថែមលើនេះបុគ្គលម្នាក់អាចទទួលរងព្យសនកម្មផ្នែកផ្លូវចិត្តធ្ងន់ធ្ងរ តាមរយៈការបានមើលឃើញអំពើធ្វើឡើងចំពោះអ្នកដទៃ[1646]។ ដោយសារលក្ខណៈរបស់វា អំពើមួយចំនួនត្រូវបានចាត់ទុកថាជាអំពើដែលនឹងនាំឲ្យមានការឈឺចាប់ និងរងទុក្ខធ្ងន់ធ្ងរ។ អំពើទាំងនោះរួមមានការរំលោភផ្លូវភេទ[1647] អំពើហិង្សាលើផ្លូវភេទ[1648] និងការធ្វើឲ្យមានកាយវិកលកម្ម[1649]។

334. តាមយុត្តិសាស្ត្ររបស់តុលាការ ICTY/ICTR ទោះបីជាចារីមិនចាំបាច់ធ្វើសកម្មភាពក្នុងតួនាទីផ្លូវការក៏ដោយ[1650] តែអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា និយមន័យនៃការធ្វើទារុណកម្ម ដែលមានបញ្ជាក់នៅក្នុងសេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីការធ្វើទារុណកម្ម រួមទាំងតម្រូងការផ្លូវការជាសាធារណៈ គឺជាការប្រកាសអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥[1651]។ អនុលោមតាមនិយមន័យនោះ អំពើសកម្ម ឬអកម្មចាំបាច់ត្រូវតែអនុវត្តឡើង "ដោយខ្លួនឯង ឬដោយមានការញុះញង់ពីមន្ត្រីសាធារ

ណៈ”។ កសព សូមជូនសេចក្តីសន្និដ្ឋានថា ខណៈដែលធាតុផ្សំនេះនៃនិយមន័យនៃការធ្វើទារុណកម្ម បានផ្ទុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឲ្យតែកាតព្វកិច្ចរបស់រដ្ឋត្រូវបានចាប់អារម្មណ៍ តុលាការ , ICTY និង ICTR បានច្រានចោលយ៉ាងត្រឹមត្រូវនូវលក្ខខណ្ឌតម្រូវផ្លូវការជាសាធារណៈ នៅក្នុងច្បាប់ *ព្រហ្មទណ្ឌ* តាមទំនៀមទម្លាប់អន្តរជាតិ។ សេចក្តីប្រកាសពីអំពើទារុណកម្ម ឆ្នាំ១៩៧៥ និងក្រោយមកអនុសញ្ញាស្តីពីអំពើទារុណកម្ម ឆ្នាំ១៩៨៤ ត្រូវបានលើកឡើងទៅកាន់រដ្ឋទាំងឡាយ និងបានស្វែងរកធ្វើឲ្យរៀបរយនូវអាកប្បកិរិយារបស់គាត់។ នៅក្នុងបរិបទនោះ គេអាចយល់បានថា ពួកគាត់ទាក់ទងជាមួយនឹងអំពើរបស់បុគ្គលដែលបានធ្វើសកម្មភាពនៅក្នុងសមត្ថកិច្ចជាផ្លូវការយ៉ាងណាក៏ដោយ ក្នុងនាមជា , មិនមានន័យអ្វីនោះទេក្នុងការញែកបុគ្គលនានាដែលសុទ្ធតែជាមន្ត្រីសាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាធារណៈ ឲ្យខុសពីអ្នកដទៃទៀតដែលមិនមែនជាមន្ត្រីសាធារណៈ ប៉ុន្តែ ជាអ្នកដែលប្រព្រឹត្តនូវអំពើកម្មដូចគ្នា ដោយមានចេតនាដូចគ្នា និង ដោយមានផលវិបាកដូចគ្នាចំពោះជនរងគ្រោះ ដែលការរងឈឺចាប់របស់គាត់ពិបាកនឹងធ្វើឲ្យបានធូរស្បើយដោយការដឹងឮថា បុគ្គលរូបនោះមិនមែនជាមន្ត្រីសាធារណៈនោះទេ។

335. ការឈឺចាប់ និងការរងទុក្ខដែលចាត់ទុកថាជាការធ្វើទារុណកម្ម ចាំបាច់ត្រូវតែធ្វើឡើងដោយចេតនា[1652]។ អំពើសកម្ម ឬអកម្ម ចាំបាច់ត្រូវតែធ្វើឡើង ឬអនុវត្តឡើងដើម្បីទទួលបានលទ្ធផល ឬគោលបំណងជាក់លាក់មួយ។ គោលបំណងបែបនោះរួមមាន ការទទួលបានព័ត៌មាន ឬចម្លើយសារភាព ការដាក់ទណ្ឌកម្ម ការបង្ខិតបង្ខំ ឬការបំភិតបំភ័យ ឬការរើសអើង ដោយផ្អែកលើមូលដ្ឋានណាមួយ ប្រឆាំងនឹងជនរងគ្រោះ ឬតតិយជន[1653]។ គោលបំណងទាំងអស់នេះមិនបង្កើតបានជាបញ្ជីលម្អិត តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ហើយជាជំនួសវិញគឺគ្រាន់ជាការតំណាងប៉ុណ្ណោះ[1654]។ គ្មានលក្ខខណ្ឌតម្រូវដែលថាអំពើមួយត្រូវបានប្រព្រឹត្តឡើង សម្រាប់តែគោលបំណងជាក់លាក់មួយៈ ដែលគោលបំណងជាក់លាក់នោះចាំបាច់ត្រូវតែជា “ផ្នែកនៃការលើកទឹកចិត្តដល់ការប្រព្រឹត្តិរបស់ខ្លួន ហើយវាមិនចាំបាច់ជាគោលបំណងច្បាស់លាស់ ឬតែមួយនោះទេ"[1655]។

<u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាតិសាសន៍ ឬជំនឿសាសនា</u>

336. ការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានអត្ថិភាព តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ ១៩៧៥[1656]។ បន្ថែមលើនេះ គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេល

នោះថា គេអាចត្រូវបានចោទប្រកាន់ ពីការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1657]។

337. *ធាតុផ្សំសត្យានុម័ត*នៃការធ្វើទុក្ខបុកម្នេញ គឺជាអំពើសកម្ម ឬអកម្ម ដែលរើសអើងលើផ្នែកអង្គហេតុ និងដែលបដិសេធ ឬរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានដែលកំណត់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញា[1658]។

*អំពើកម្ម ឬអកម្ម ដែលបដិសេធ ឬរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋាន*

338. "អំពើធ្វើទុក្ខបុកម្នេញ" រួមបញ្ចូលបទល្មើសជាមូលដ្ឋានដទៃទៀត សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងអំពើសកម្ម ឬអកម្មដទៃទៀត ដែលមានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ដូចគ្នា បើទោះបីជាដាច់ដោយឡែក ឬរួមជាមួយអំពើដទៃទៀតក៏ដោយ[1659]។ អំពើសកម្ម ឬអកម្មដទៃទៀតទាំងអស់នេះ អាចជាឧក្រិដ្ឋកម្មអន្តរជាតិដោយខ្លួនឯង[1660] ប៉ុន្តែមិនចាំបាច់ថាជាឧក្រិដ្ឋកម្មអន្តរជាតិឡើយ[1661]។ បើទោះបីជាអំពើទាំងនោះបង្កើតបានជាការធ្វើទុក្ខបុកម្នេញដែរ ឬអត់នោះ គឺគ្រាន់តែជាការចោទសួរទៅលើអង្គហេតុជាក់លាក់ប៉ុណ្ណោះ[1662]។

339. បរិបទដែលអំពើសកម្ម ឬអកម្មមួយបានកើតឡើង គឺមានភាពសំខាន់សម្រាប់គោលបំណងនៃការវាយតម្លៃលើភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់របស់វា[1663]។ កត្តាដទៃទៀតដែលគួរធ្វើការពិចារណាក្នុងការវាយតម្លៃនោះរួមមាន (១) ថាតើអំពើនោះត្រូវបានប្រព្រឹត្តឡើងនៅក្នុងបរិបទ ឬជាផ្នែកនៃបណ្តាហេតុការណ៍ នៅក្នុងយុទ្ធនាការធ្វើទុក្ខបុកម្នេញទ្រង់ទ្រាយធំដែលគោលដៅចុងក្រោយ និងលទ្ធផលចុងក្រោយគឺមានភាពធ្ងន់ធ្ងរខ្លាំង ដែលបណ្តាលឲ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិជាមូលដ្ឋាន[1664] និង (២) ផលប៉ះពាល់នៃការរើសអើងដែលត្រូវបានព្យាយាមជំរុញ នៅក្នុងចំណោមប្រជាជនទូទៅ ប្រឆាំងក្រុមគោលដៅមួយ[1665]។

340. បន្ទាប់ពីបានធ្វើការត្រួតពិនិត្យយ៉ាងល្អិតល្អន់លើយុត្តិសាស្ត្ររបស់តុលាការយោធាអន្តរជាតិ និងតុលាការនានាដែលអនុវត្តតាមច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "អំពើផ្សេងៗទៀតដែលមិនមានចែងនៅក្នុងលិខិតុបករណ៍នានា បង្កើតបានជាការរំលោភបំពានយ៉ាងច្រើនទៅលើសិទ្ធិបុគ្គលដែលរួមមាន សិទ្ធិលើកម្មសិទ្ធិ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិក្នុងការទទួលបានការការពារ ដោយស្មើៗគ្នានៅចំពោះមុខច្បាប់ សិទ្ធិជាពលរដ្ឋ សិទ្ធិ

ក្នុងការជ្រើសរើសមុខរបរ សិទ្ធិក្នុងការទទួលបានការអប់រំ សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ សិទ្ធិឯកជន និងសេរីភាពក្នុងការដើរហើរ"[1666]។ នៅក្នុងអត្ថន័យតែមួយនេះ អំពើខាងក្រោមដែលមិនត្រូវបានបញ្ជាក់ច្បាស់លាស់ នៅក្នុងមាត្រា៥នៃច្បាប់ អ.វ.ត.ក ត្រូវបានចាត់ទុកថាជាអំពើធ្វើទុក្ខបុកម្នេញ នៅតុលាការ ICTY និងតុលាការ ICTR គឺ[1667]៖ ការបំផ្លាញអគារសាសនា[1668] អំពើប្រទូស្តកេរ្តិ៍ភេទ ការធ្វើឱ្យអាម៉ាស ការបន្ទាបបន្ថោក និងការរើសអើងផ្នែកស្មារតី រួមបញ្ចូលទាំងការបង្ខំឱ្យជនរងគ្រោះមើល ឬស្តាប់ការធ្វើទារុណកម្ម ការសួរចម្លើយ និងអំពើហិង្សាដោយចៃដន្យនៅក្នុងមន្ទីរឃុំឃាំង[1669] ការបំផ្លិចបំផ្លាញដោយឥតក្រែងទៅលើទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន រួមទាំងបូជនីយដ្ឋានវប្បធម៌ និងទីសក្ការៈបូជា[1670] ការបំផ្លាញក៏ដូចជាការដុតកម្ទេចផ្ទះសម្បែង និងមធ្យោបាយសម្រាប់ការរស់នៅដទៃទៀត[1671] ពលកម្មដោយបង្ខំ[1672] ស្ថានភាពរស់នៅអមនុស្សធម៌[1673] ការបាត់ខ្លួនដោយបង្ខំ[1674] ការបដិសេធសិទ្ធិក្នុងការជ្រើសរើសការងារ សេរីភាពក្នុងការដើរហើរ សិទ្ធិទទួលបានដំណើរការយុត្តិធម៌ដោយត្រឹមត្រូវ និងសិទ្ធិទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រសមស្រប[1675] និងពាក្យពេចន៍ ក៏ដូចជាការអំពាវនាវឱ្យស្អប់ខ្ពើម និងបង្កឱ្យមានអំពើហិង្សា[1676]។

*ការរើសអើងជាក់ស្តែង*

341. អំពើកម្ម ឬអកម្មចាំបាច់ត្រូវតែមានផលវិបាកជាក់ស្តែងនៃការរើសអើង[1677]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ការរើសអើងជាក់ស្តែង" កើតមានឡើង នៅពេលដែលជនរងគ្រោះត្រូវបានគេកំណត់ជាគោលដៅ ដោយសារតែជនរងគ្រោះជាសមាជិកពិត ឬត្រូវបានសន្មត នៅក្នុងក្រុមណាមួយដែលចារីបានកំណត់ ដោយមូលហេតុជាក់លាក់មួយចំនួនពោលគឺមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា[1678] ហើយជនរងគ្រោះតាមពិត ត្រូវតែស្តែងឱ្យឃើញច្បាស់លាស់គ្រប់គ្រាន់ថា ស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនាណាមួយ[1679]។ ក្រុមនេះអាចត្រូវបានចារីកំណត់យ៉ាងទូលំទូលាយ។ ក្រុមនេះអាចត្រូវកំណត់ក្នុងន័យអវិជ្ជមាន និងរួមបញ្ចូលអ្នកជាប់ពាក់ព័ន្ធជិតស្និទ្ធ ឬអ្នកគាំទ្រ ព្រមទាំងជនសង្ស័យផងដែរ[1680]។

342. ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋាននយោបាយ មិនមានលក្ខខណ្ឌតម្រូវដែលថាក្រុមដែលត្រូវបានកំណត់គោលដៅត្រូវមានទស្សនៈនយោបាយជាក់លាក់ណាមួយឡើយ។ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អាចកើតឡើងនៅក្នុងករណី ដែលការរើសអើងត្រូវបានប៉ះពាល់

ដោយយោងតាមការជំរុញ ឬរបៀបវារៈនយោបាយ*ប្រឆាំង*ក្រុមមួយ ដោយផ្អែកលើការវាយតម្លៃអត្តនោម័តិ ថាជាក្រុមគំរាមកំហែងនយោបាយ ឬជាគ្រោះថ្នាក់ ចំពោះចារី[1681]។ ក្រុមមួយ ឬច្រើនដែលត្រូវបានធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើមូលដ្ឋាននយោបាយនោះ អាចរួមបញ្ចូលនូវក្រុមផ្សេងៗគ្នាដូចជា ៖ អ្នករដ្ឋការ និងសកម្មជននយោបាយ ក្រុមជនដែលមានទស្សនៈ និន្នាការ និងជំនឿណាមួយ ក្រុមជនដែលជាជនជាតិភាគតិចណាមួយ ឬក្រុមជននៃសញ្ជាតិណាមួយ ឬក្រុមជនដែលតំណាងឲ្យវណ្ណៈណាមួយនៅក្នុងសង្គម (ដូចជា "បញ្ញវន្ត" បុព្វជិត ឬវណ្ណៈគហបតី)[1682]។

## *ធាតុផ្សំអត្តនោម័តិ*

343. ចំពោះ*ធាតុផ្សំអត្តនោម័តិ* ការធ្វើទុក្ខបុកម្នេញតម្រូវឲ្យមានការប្រព្រឹត្តិដោយចេតនានូវអំពើសកម្ម ឬអកម្ម ដែលមានចេតនាជាក់លាក់ដើម្បីរើសអើង ដោយផ្អែកលើមូលដ្ឋាននយោបាយ ពូជសាសន៍ ឬសាសនា[1683]។ ចេតនារើសអើងតម្រូវថា ចារីធ្វើសកម្មភាពដោយមានចេតនាជាក់លាក់ ដែលធ្វើឲ្យជនរងគ្រោះរងរបួស ដោយសារតែគាត់ស្ថិតក្នុងក្រុម ឬសហគមន៍ជាក់លាក់មួយ[1684]។ មិនមានលក្ខខណ្ឌតម្រូវដែលថា ចារីត្រូវមានចេតនានៃការធ្វើទុក្ខបុកម្នេញ គឺចេតនាក្នុងការដកហូតបុគ្គលណាម្នាក់ចេញពីសង្គម ឬមនុស្សជាតិ លើសពីចេតនានៃការរើសអើងនោះឡើយ[1685]។ ប្រហែលគ្នានេះ ចេតនារើសអើងមិនតម្រូវថា ចារីត្រូវតែមានការជាប់ពាក់ព័ន្ធនឹងមូលហេតុផ្ដាច់ការជាមូលដ្ឋានជាក់លាក់នៃរបបគ្រប់គ្រងដែលអនុវត្តយុទ្ធនាការ ឬនយោបាយធ្វើទុក្ខបុកម្នេញនោះទេ[1686]។ មូលហេតុដែលចារីបានចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ មិនពាក់ព័ន្ធឡើយចំពោះការយល់ឃើញដែលថា ជនជាប់ចោទមានចេតនាជាក់លាក់នោះទេ[1687]។

344. ទោះបីជាចេតនាជាក់លាក់ មិនអាចទាញយកបានត្រឹមតែតាមរយៈការយោងទៅរកលក្ខណៈនៃការរើសអើងជាទូទៅនៃការវាយប្រហារក៏ដោយ តែចេតនានេះអាចទាញចេញពីបរិបទបែបនេះ ប្រសិនបើពិចារណាទៅលើអង្គហេតុនៃរឿងក្ដី កាលៈទេសៈជុំវិញការប្រព្រឹត្តិបទល្មើសដែលបានចោទប្រកាន់នោះបញ្ជាក់អំពីអត្ថិភាពនៃចេតនាដូច្នេះ[1688]។ កាលៈទេសៈដែលអាចយកមកពិចារណារួមមាន លក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តទៅលើក្រុមមួយ និងចរិតលក្ខណៈទូទៅនៃចារី ដែលត្រូវបានចោទប្រកាន់ ដែលស្ដែងឡើងតាមរយៈការប្រព្រឹត្តិរបស់ចារីនោះ[1689]។ ចេតនាត្រូវបានទាញចេញ "តាមរយៈការចូលរួមដោយដឹងច្បាស់របស់ចារី ទៅក្នុងប្រព័ន្ធ ឬសហកម្ម ដែលរើសអើង ដោយសារតែមូលដ្ឋាន

នយោបាយ ពូជសាសន៍ ឬសាសនា”[1690]។ ប៉ុន្តែ អត្ថិភាពនៃគោលនយោបាយរើសអើង គឺមិនមែនជាលក្ខខណ្ឌតម្រូវសម្រាប់បង្ហាញពីការធ្វើទុក្ខបុកម្នេញទេ[1691]។ ភស្តុតាងនៃការជាប់ទាក់ទងក្នុងក្រុមគោលដៅនោះ មិនអាចធ្វើឲ្យអ្នកវិនិច្ឆ័យអង្គហេតុ អាចគេចចេញពីការសម្រេចប្រកបដោយសំអាងហេតុអំពីចេតនាតម្រូវក្នុងការប្រព្រឹត្តិអំពើធ្វើទុក្ខបុកម្នេញឡើយ[1692]។

## <u>អំពើអមនុស្សធម៌ដទៃទៀត</u>

345. “អំពើអមនុស្សធម៌ដទៃទៀត” ត្រូវបានកំណត់ថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនឆ្នាំ ១៩៧៥[1693]។ បន្ថែមលើនេះ គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេលនោះថា គេអាចត្រូវបានចោទប្រកាន់ពីបទអំពើអមនុស្សធម៌ដទៃទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1694]។ “អំពើអមនុស្សធម៌ដទៃទៀត” គឺជាឧក្រិដ្ឋកម្មដោយខ្លួនឯងផ្ទាល់ តាមច្បាប់អន្តរជាតិ។ គ្មានលក្ខខណ្ឌតម្រូវដែលថា អនុប្រភេទនីមួយៗអាចត្រូវកំណត់ថាជាបទល្មើស ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងឡើយ ក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ បើតម្រូវបែបនេះ នោះនឹងធ្វើឲ្យប្រភេទ “អំពើអមនុស្សធម៌ដទៃទៀត” ទៅជាគ្មានន័យ[1695]។

346. “អំពើអមនុស្សធម៌ដទៃទៀត” គឺជាប្រភេទបទល្មើសនៅសេសសល់របស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះអំពើដែលបំពេញលក្ខណៈវិនិច្ឆ័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនស្ថិតក្នុងប្រភេទមួយនៃឧក្រិដ្ឋកម្មជាមូលដ្ឋានជាក់លាក់ដទៃទៀត[1696]។ អំពើសកម្ម ឬអកម្ម ចាំបាច់ត្រូវតែមានលក្ខណៈស្រដៀងគ្នាគ្រប់គ្រាន់ ទាំងក្នុងលក្ខណៈ ក៏ដូចជាស្ថានទម្ងន់ ធៀបនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងដទៃទៀត[1697]។

347. ធាតុផ្សំនៃឧក្រិដ្ឋកម្ម “អំពើអមនុស្សធម៌ដទៃទៀត” គឺជាអំពើសកម្ម ឬអកម្មរបស់ចារី៖ (១) បង្កឲ្យមានការឈឺចាប់រាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ឬការវាយប្រហារដ៏ធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ គឺ (២) ប្រព្រឹត្តឡើងដោយមានចេតនា បង្កឲ្យមានការឈឺចាប់រាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ឬប្រព្រឹត្តការវាយប្រហារដ៏ធ្ងន់ធ្ងរមួយទៅលើសេចក្តីថ្លៃថ្នូរជាមនុស្សជាតិរបស់ជនរងគ្រោះ នៅពេលប្រព្រឹត្តអំពើសកម្ម ឬអកម្មនោះ ឬក្នុងការដឹងឮថាអំពើកម្ម ឬអកម្មទំនងជាបណ្តាលឲ្យមានទុក្ខវេទនាផ្នែកផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូរមនុស្សជាតិរបស់ជនរងគ្រោះ[1698]។

348. ភាពធ្ងន់ធ្ងរនៃអំពើ ត្រូវយកមកវាយតម្លៃ តាមករណីជាក់ស្តែង ដោយពិចារណាទៅលើកាលៈទេសៈនីមួយៗនៃរឿងក្តី[1699]។ ហេតុដូច្នេះ នេះគឺជាបញ្ហារួមគ្នារវាងអង្គហេតុ និងអង្គច្បាប់[1700]។ កាលៈទេសៈនីមួយៗអាចរួមបញ្ចូលនូវលក្ខណៈនៃអំពើសកម្ម ឬអកម្ម បរិបទដែលអំពើនោះបានធ្វើឡើង កាលៈទេសៈបុគ្គលរបស់ជនរងគ្រោះ ដែលរួមមានអាយុ ភេទ និងសុខភាព ព្រមទាំងផលប៉ះពាល់ផ្លូវកាយ ផ្លូវចិត្ត និងសីលធម៌ចំពោះជនរងគ្រោះ ដោយសារអំពើនោះ[1701]។ គ្មាន លក្ខខណ្ឌតម្រូវដែលថាជនរងគ្រោះទទួលរងផលប៉ះពាល់រយៈពេលយូរឡើយ ទោះបីជាផលប៉ះពាល់នោះ អាចពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃអំពើនោះក៏ដោយ[1702]។

349. បន្ថែមពីលើអំពើដែលនឹងត្រូវពិនិត្យមើល ដោយលម្អិតនៅផ្នែកខាងក្រោម "អំពើអមនុស្សធម៌ដទៃទៀត" ត្រូវបានសម្រេចថារួមមាន៖ "ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ និងការជម្លៀសដោយបង្ខំ"[1703] ការប្រព្រឹត្តិដោយហិង្សា ប្រមាថមើលងាយ អមនុស្សធម៌ និងបន្ទាបបន្ថោក[1704] ការប្រព្រឹត្តិពេស្យាកម្មដោយបង្ខំ[1705] ការបង្កព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ[1706] ការធ្វើវិកលកម្ម ការវាយដំ និងប្រភេទផ្សេងទៀតនៃការបង្ករបួសស្នាមផ្លូវកាយធ្ងន់ធ្ងរ[1707] អំពើហិង្សាផ្លូវភេទ[1708] និង ការមើលឃើញអំពើព្រហ្មទណ្ឌប្រឆាំងក្រុមគ្រួសារ ឬមិត្តភ័ក្តិ[1709]។

## ការបាត់ខ្លួនដោយបង្ខំ

350. សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក តុលាការ ICTY និងតុលាការ SCSL សុទ្ធតែបានទទួលស្គាល់ថា ការបាត់ខ្លួនដោយបង្ខំ អាចមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ជា "អំពើអមនុស្សធម៌ដទៃទៀត" បើលក្ខខណ្ឌដទៃទៀតទាំងអស់ត្រូវបានបំពេញ[1710]។ តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ទទួលស្គាល់ផងដែរថា ការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1711]។

351. ការបាត់ខ្លួនដោយបង្ខំកើតឡើងនៅពេលដែល (១) បុគ្គលណាម្នាក់ត្រូវបានដកហូតសេរីភាពរបស់ខ្លួន ដូចជាតាមរយៈការចាប់ខ្លួន ការឃុំខ្លួន ឬការចាប់ពង្រត់ (២) ការដកហូតសេរីភាពនេះត្រូវបានធ្វើឡើងតាមរយៈការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងនឹងជោគវាសនា ឬទីកន្លែងដែលបុគ្គលពាក់ព័ន្ធនោះស្ថិតនៅ ឬមិនទទួលស្គាល់ការដកហូតសេរីភាពនេះ ដោយបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់ និងការធានាផ្នែកនីតិវិធីចំពោះបុគ្គលនោះ និង (៣) ធាតុផ្សំទីមួយ និងទីពីរ ត្រូវបានអនុវត្តដោយភ្នាក់ងាររដ្ឋ ឬ

ដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ ឬអង្គការនយោបាយណាមួយ[1712]។

## *ការរំលោភសេពសន្ថវៈ*

352. ទោះបីជាការរំលោភសេពសន្ថវៈ ត្រូវបានចែងកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក អនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ក៏ដោយ ក៏អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា ការរំលោភសេពសន្ថវៈពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែកនោះទេនៅក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[1713]។ អង្គបុរេជំនុំជម្រះ បានបញ្ជាក់ថា អង្គហេតុនានាដែលចាត់ទុកការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំពើអមនុស្សធម៌ផ្សេងទៀត[1714]។ ម្យ៉ាងវិញទៀត តុលាការ ICTY តុលាការ ICTR តុលាការ SCSL និងតុលាការ ICC បានកំណត់ទាំងអស់គ្នាថា ការរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដោយឡែក[1715]។ ការរំលោភសេពសន្ថវៈអាចចាត់ទុកផងដែរថាជាទារុណកម្មក្នុងករណីដែលធាតុផ្សំនៃទារុណកម្មត្រូវបានរកឃើញ[1716]។ ហេតុដូច្នេះ ស្ថានទម្ងន់ដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការចាត់ថ្នាក់ការរំលោភសេពសន្ថវៈថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានបំពេញយ៉ាងច្បាស់លាស់។

353. មានភាពប្លែកគ្នាខ្លះនៅក្នុងនិយមន័យនៃការរំលោភសេពសន្ថវៈក្នុងចំណោមសាលាក្តីអន្តរជាតិនានា។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានយកតាមនិយមន័យទូលាយមួយនៃការរំលោភសេពសន្ថវៈ ពោលគឺ "ការឈ្លានពានលើផ្លូវភេទ ដែលបានប្រព្រឹត្តលើបុគ្គលណាម្នាក់ក្រោមកាលៈទេសៈនៃការចាប់បង្ខំ"[1717]។ កសចស បានអនុម័តពីមនុមកនូវនិយមន័យស្រដៀងគ្នា ដោយបន្ថែមទៅក្នុងជម្រើលដែលថា ការយល់ព្រមរបស់ជនរងគ្រោះម្យ៉ាងវិញនោះគួរតែអវត្តមាន[1718]។ នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានអនុវត្តតាមតុលាការ ICTY ដោយបានកំណត់និយមន័យនៃធាតុផ្សំផ្នែករូបរាងកាយឲ្យមានលក្ខណៈចង្អៀតជាងមុន ថាជាការបញ្ចូលទៅក្នុង (ក) រន្ធយោនី ឬ រន្ធគូទរបស់ជនរងគ្រោះ ដោយចារីបានប្រើលិង្គ ឬ វត្ថុណាមួយផ្សេង ឬ (ខ) មាត់របស់ជនរងគ្រោះដោយចារីបានប្រើលិង្គក្នុងករណីដែលការបញ្ចូលបែបនេះបានកើតឡើងដោយពុំមានការយល់ព្រមពីជនរងគ្រោះ[1719]។ និយមន័យនៃតុលាការ ICC ស្ថិតនៅចន្លោះនិយមន័យទាំងពីរដោយទាមទារនូវលក្ខខណ្ឌថា "ចារីបានឈ្លានពានរូបកាយរបស់បុគ្គលណាម្នាក់ដោយអំពើរបស់ខ្លួន ហើយបណ្តាលឲ្យមានការបញ្ចូល

ក្នុងផ្នែកណាមួយនៃរាងកាយរបស់ជនរងគ្រោះ ឬរបស់ចារីដោយប្រើប្រាស់នូវសរិរាង្គផ្លូវភេទ ឬ នៅក្នុងរន្ធគូទ ឬរន្ធផ្លូវភេទរបស់ជនរងគ្រោះដោយប្រើប្រាស់វត្ថុ ឬផ្នែកណាមួយនៃរាងកាយ"[1720]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា និយមន័យដ៏ត្រឹមត្រូវតម្រូវឱ្យមាន ការដាក់បញ្ចូល ទោះបីជាតិចតួច នូវផ្នែកណាមួយនៃរាងកាយរបស់បុគ្គលម្នាក់ដោយបុគ្គលម្នាក់ផ្សេងទៀត ដោយមិនមានការយល់ព្រមពីភាគីម្ខាង ឬទាំងសងខាង ក្នុងសកម្មភាពផ្លូវភេទ។ កាលៈទេសៈប្រយោលអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញឱ្យឃើញនូវការរំលោភសេពសន្ថវៈ[1721]។

354. ការយល់ព្រមក្នុងគោលបំណងនេះត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ទៅតាមឆន្ទៈរបស់ជនរងគ្រោះដោយត្រូវយកមកវាយតម្លៃទៅតាមបរិបទនៃកាលៈទេសៈជុំវិញនោះ[1722]។ ការបង្ខំ ឬការគម្រាមប្រើប្រាស់កម្លាំងអាចផ្តល់ជាភ័ស្តុតាងនៃការមិនយល់ព្រម ក៏ប៉ុន្តែកម្លាំងពុំមែនជាធាតុផ្សំនៃការរំលោភសេពសន្ថវៈនោះទេ ហើយវាមានកត្តានានាក្រៅពីការបង្ខំដែលអាចធ្វើឱ្យអំពើនៃការបញ្ចូលផ្លូវភេទក្លាយជាការមិនយល់ព្រម ឬការមិនស្ម័គ្រចិត្តពីជនរងគ្រោះ[1723]។ បុគ្គលម្នាក់អាចពុំមានសមត្ថភាពបង្ហាញការស្ម័គ្រចិត្តពិតប្រាកដ ប្រសិនបើទទួលរងនូវអសមត្ថភាពពីធម្មជាតិ ដោយការល្បួងលោម ឬដោយសារវ័យ[1724]។ ភ័ស្តុតាងនៃការទប់ទល់ (ឬការបន្តទប់ទល់) ដោយជនរងគ្រោះក៏ពុំមែនជាលក្ខខណ្ឌតម្រូវនោះទេ[1725]។ កាលៈទេសៈនានាដែលឃើញមាននៅស្ទើរគ្រប់រឿងក្តីទាំងអស់ដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ជារួមមកគឺសុទ្ធសឹងតែជាការចាប់បង្ខំទាំងអស់" ដែលវាពុំនាំឱ្យមានការយល់ព្រមដោយពិតប្រាកដ[1726]។ ស្រដៀងគ្នានេះដែរ ស្ថានភាពនៃការឃាត់ទុក ឬឃុំឃាំង ត្រូវបានទទួលស្គាល់ថានាំឱ្យការយល់ព្រមដោយពិតប្រាកដក្លាយជាមោឃៈ[1727]។

355. *ធាតុផ្សំអត្តនោម័តិ*គឺចេតនាឈានទៅរកការបញ្ចូលប្រដាប់ភេទ និងការដឹងថា ការបញ្ចូលនេះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ[1728]។ ការដឹងថាគ្មានការយល់ព្រមអាចបង្ហាញឱ្យឃើញ ប្រសិនបើចារីបានដឹង ឬមានហេតុផលដឹងអំពីកាលៈទេសៈចាប់បង្ខំដែលធ្វើឱ្យបាត់បង់លទ្ធភាពនៃការយល់ព្រមពិតប្រាកដ[1729]។

## *អាពាហ៍ពិពាហ៍ដោយបង្ខំ*

356. កសចស និង តុលាការ SCSL បានទទួលស្គាល់ថា អាពាហ៍ពិពាហ៍ដោយបង្ខំស្ថិតនៅក្នុងទិដ្ឋភាពនៃ "អំពើអមនុស្សធម៌ផ្សេងទៀត"[1730]។

357. *ធាតុផ្សំសត្យានុម័ត*នៃអាពាហ៍ពិពាហ៍ដោយបង្ខំតម្រូវឱ្យចារីបង្ខំបុគ្គលណាម្នាក់ដោយប្រើប្រាស់កម្លាំង ការគម្រាមថានឹងប្រើប្រាស់កម្លាំង ឬការបង្ខិតបង្ខំដើម្បីបម្រើជាដៃគូរួមភេទរបស់ខ្លួន[1731]។ "អាពាហ៍ពិពាហ៍" មានន័យបង្កប់ថាជាទំនាក់ទំនងដោយឡែកតែរវាង "ប្ដី" និង "ប្រពន្ធ"[1732]។ អាស្រ័យទៅតាមកាលៈទេសៈ "អាពាហ៍ពិពាហ៍" អាចពាក់ព័ន្ធនឹងភារកិច្ចច្រើនបែបច្រើនយ៉ាង ដូចជា ការរួមសង្វាស កិច្ចការក្នុងផ្ទះ ភាពមានគភ៌ក្នុងរយៈពេលយូរ និងការមើលថែកូនៗក្នុងចំណោង "អាពាហ៍ពិពាហ៍"[1733] ហើយអាចរួមមានការប្រព្រឹត្តិឧក្រិដ្ឋកម្មអន្តរជាតិមួយ ឬច្រើនផងដែរក្នុងចំណោមឧក្រិដ្ឋកម្មអន្តរជាតិនានា ដូចជា ការធ្វើឱ្យទៅជាទាសករ ការរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ ឬទាសភាពផ្លូវភេទ[1734]។ ទោះបីជាយ៉ាងនេះក្ដី ជាគោលការណ៍ អាពាហ៍ពិពាហ៍ដោយបង្ខំពុំមែនជាឧក្រិដ្ឋកម្មផ្លូវភេទនោះទេ និងត្រូវបានប្រព្រឹត្តឡើងមិនចំពោះថាតើ "ប្ដី" និង "ប្រពន្ធ" មានទំនាក់ទំនងផ្លូវភេទឬអត់នោះ[1735]។

358. កម្លាំងដែលបានប្រើប្រាស់ដើម្បីបង្ខំឱ្យបុគ្គលម្នាក់រៀបការ ពុំមែនកម្រិតត្រឹមកម្លាំងផ្លូវកាយប៉ុណ្ណោះទេ។ វារួមទាំងការគម្រាមថានឹងប្រើប្រាស់កម្លាំង ឬការចាប់បង្ខំផងដែរ ដូចជា អាពាហ៍ពិពាហ៍ដែលកើតមានឡើងដោយការភ័យខ្លាចអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំឃាំង ការគាបសង្កត់ផ្លូវចិត្ត ឬការបំពានអំណាច ឬការទាញប្រយោជន៍ពីបរិយាកាសនៃការចាប់បង្ខំ[1736]។ ក្នុងករណីដែលវាបង្ហាញថាបរិយាកាសមានលក្ខណៈបង្ខំខ្លាំង ដែលការអនុវត្តការជ្រើសរើសដោយសេរីមិនអាចធ្វើទៅបាននោះ វាមិនតម្រូវឱ្យមានការបញ្ជាក់អំពីអវត្តមានការយល់ព្រមចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ កាលៈទេសៈនានា ដែលឃើញមាននៅស្ទើរគ្រប់រឿងក្ដីទាំងអស់ ដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ជារួមមកគឺសុទ្ធសឹងតែជាការចាប់បង្ខំទាំងអស់" ដែលពុំនាំឱ្យមានការយល់ព្រមដោយពិតប្រាកដ[1737]។ ស្រដៀងគ្នានេះដែរ បរិយាកាសនៃការភ័យខ្លាច[1738] ឬស្ថានភាពនៃការឃាត់ទុក ឬ ការឃុំឃាំង[1739] ត្រូវបានទទួលស្គាល់ថានាំឱ្យការយល់ព្រមដោយពិតប្រាកដក្លាយជាមោឃៈ។ នៅក្នុងបរិយាកាសនៃការចាប់បង្ខំ ផលប្រយោជន៍ពាក់ព័ន្ធនានាដែលជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំទទួលបានពីចារី ពុំមែនបញ្ជាក់អំពីការយល់ព្រមចំពោះទំនាក់ទំនងផ្លូវភេទដោយបង្ខំ ហើយក៏ពុំមោឃៈនូវលក្ខណៈឧក្រិដ្ឋនៃអំពើរបស់ចារីនោះដែរ[1740]។

359. ចំពោះ*ធាតុផ្សំអត្តនោម័ត* ចារីត្រូវមានចេតនាបង្ខំឱ្យមានទំនាក់ទំនងសហព័ទ្ធលើជនរងគ្រោះ [1741]។

## *ការឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌*

360. យោងតាមយុត្តិសាស្ត្រអន្តរជាតិ ការឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌ រួមទាំង ការដកហូតអាហារ ទឹក ជំនួយវេជ្ជសាស្ត្រ និងជម្រកសមស្រប ការដាក់ឲ្យនៅដោយឡែក លក្ខខណ្ឌគ្មានអនាម័យត្រូវបានរកឃើញថាស្ថិតនៅក្នុងក្របខ័ណ្ឌនៃ "អំពើអមនុស្សធម៌ផ្សេងទៀត"[1742]។ ការប្រព្រឹត្តិ ក្នុងលក្ខខណ្ឌអមនុស្សធម៌នេះក៏ត្រូវបានរកឃើញថាឈានរហូតដល់កម្រិតធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មផ្សេងទៀត ដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ហើយគឺជាការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1743] ក៏ដូចជាបង្កើតបានជាបទល្មើសនៃការប្រព្រឹត្តិដ៏ឃោរឃៅដែលជាការរំលោភលើច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមក្រោមលក្ខន្តិកៈនៃតុលាការ ICTY[1744]។ ក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ ការដកហូតដូចគ្នាទាំងនេះត្រូវបានចាត់ទុកថាជាភ័ស្តុតាងបង្ហាញឲ្យឃើញនូវលក្ខខណ្ឌជីវិត ដែលនឹងបង្កឲ្យមានការបំផ្លិចបំផ្លាញលើរាងកាយរបស់ក្រុមមួយ[1745]។ ដូច្នេះ ការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌អាចមានស្ថានទម្ងន់ស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចមានចែងស្រាប់ ហើយអាចស្ថិតនៅក្នុងវង្វង់នៃ "អំពើអមនុស្សធម៌ផ្សេងទៀត"។

## អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅលើអនុសញ្ញាទីក្រុងហ្សឺណែវ

361. មាត្រា ៦ នៃច្បាប់ អ.វ.ត.ក អនុញ្ញាតឲ្យ អ.វ.ត.ក ជំនុំជម្រះបុគ្គលទាំងឡាយណាដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ("អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ")។ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរគឺជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិនៅក្នុងអំឡុងយុត្តាធិការពេលវេលានៃ អ.វ.ត.ក ដែល បុគ្គលម្នាក់ៗអាចប្រមើលមើលឃើញ និងអាចដឹងថាមានច្បាប់ចែង[1746]។ បទល្មើសជាក់លាក់នានាដូចមានចែងនៅក្នុងមាត្រា ៦ រួមមាន ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ ធាតុផ្សំនៃបទល្មើសទាំងនេះត្រូវបានយកមកពិភាក្សាខាងក្រោម។

362. ដើម្បីឲ្យការប្រព្រឹត្តិបទល្មើសទាំងនេះក្លាយជាអំពើបំពានយ៉ាងធ្ងន់ធ្ងរ លក្ខខណ្ឌទូទៅមួយចំនួនត្រូវ

បំពេញ៖ (i) បទល្មើសជាក់លាក់ត្រូវប្រព្រឹត្តឡើងនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (ii) ចារីត្រូវដឹងអំពីកាលៈទេសៈអង្គហេតុដែលបានបង្ហាញអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ (iii) អំពើត្រូវប្រព្រឹត្តឡើងប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលត្រូវបានការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ មួយ ឬច្រើន ("អនុសញ្ញាទីក្រុងហ្សឺណែវ ឬ អនុសញ្ញាទីក្រុងហ្សឺណែវនានា") និង (iv) ចារីត្រូវដឹងអំពីកាលៈទេសៈអង្គហេតុដែលបានបង្ហាញនូវឋានៈដែលទទួលបានការការពារនេះ[1747]។

## លក្ខខណ្ឌទូទៅ

### ជម្លោះប្រដាប់អាវុធអន្តរជាតិ

363. លក្ខខណ្ឌនៃជម្លោះប្រដាប់អាវុធអន្តរជាតិរួមមានធាតុផ្សំចំនួនពីរ៖ i) វាត្រូវមានជម្លោះប្រដាប់អាវុធអន្តរជាតិ និង ii) វាត្រូវមានចំណងទាក់ទងរវាងជម្លោះ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។

364. ជម្លោះប្រដាប់អាវុធអន្តរជាតិត្រូវមានអត្ថិភាពជាក់ស្តែង[1748]។ ជម្លោះប្រដាប់អាវុធកើតមានឡើង "នៅពេលណាដែលមានការដោះស្រាយដោយប្រើកម្លាំងប្រដាប់អាវុធរវាងរដ្ឋនានា ឬមានអំពើហិង្សាប្រដាប់អាវុធអូសបន្លាយរវាងអាជ្ញាធររដ្ឋាភិបាល និងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធ ឬរវាងអង្គការចាត់តាំងក្រុមជនប្រដាប់អាវុធទាំងនោះនៅក្នុងរដ្ឋមួយ"[1749]។ ជម្លោះប្រដាប់អាវុធមានលក្ខណៈអន្តរជាតិ នៅពេលវាពាក់ព័ន្ធនឹងរដ្ឋពីរ ឬ ច្រើន[1750]។ ការអនុវត្តអនុសញ្ញាទីក្រុងហ្សឺណែវលើភូមិសាស្ត្រ និងពេលវេលាគ្របដណ្តប់លើសពីបរិវេណនៃការប្រទូស្តរ៉ាយជាក់ស្តែង និងការបញ្ចប់ការប្រយុទ្ធគ្នា[1751] ពោលគឺនៅពេលមានភស្តុតាងបង្ហាញថា ជម្លោះប្រដាប់អាវុធអន្តរជាតិបានកើតឡើងនៅកន្លែង និងនៅក្នុងរង្វង់ពេលវេលាពាក់ព័ន្ធនឹងបទចោទ ច្បាប់មនុស្សធម៌អន្តរជាតិនឹងអនុវត្តលើទឹកដីទាំងស្រុងនៃរដ្ឋពាក់ព័ន្ធមិនថា ការប្រយុទ្ធជាក់ស្តែងកើតឡើងនៅទីនោះឬក៏អត់នោះទេ ហើយវានឹងបន្តអនុវត្តហួសពីការបញ្ចប់ការប្រទូស្តរ៉ាយរហូតដល់ពេលទទួលបានសន្តិភាពជារួម[1752]។

365. លើសពីនេះ ជម្លោះប្រដាប់អាវុធដែលកើតឡើងនៅក្នុងទឹកដីនៃរដ្ឋតែមួយអាចក្លាយជា "អន្តរជាតិ (ឬ អាស្រ័យលើកាលៈទេសៈ មានលក្ខណៈអន្តរជាតិក្នុងពេលជាមួយនឹងជម្លោះប្រដាប់អាវុធផ្ទៃក្នុង) ប្រសិនបើ (១) រដ្ឋមួយទៀតចូលអន្តរាគមន៍នៅក្នុងជម្លោះនោះតាមរយៈកងទ័ពរបស់រដ្ឋខ្លួន ឬ បើមិន

ដូច្នោះទេ ប្រសិនបើ (២) អ្នកចូលរួមមួយចំនួននៅក្នុងអំពើនៃជម្លោះប្រដាប់អាវុធផ្ទៃក្នុងធ្វើសកម្មភាពក្នុងនាមរដ្ឋមួយទៀតនោះ”[1753]។ ការទទួលស្គាល់ជាផ្លូវការនៃស្ថានភាពសង្គ្រាមពុំទាមទារឲ្យយកបទប្បញ្ញត្តិនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវនានា មកអនុវត្តនោះទេ។ ប៉ុន្តែ ការប្រទូស្តរ៉ាយ*តាមព្រឹត្តហេតុ*រវាងរដ្ឋអាចគ្រប់គ្រាន់ក្នុងការបំពេញលក្ខខណ្ឌអន្តរជាតិ ក្នុងករណីដែលការប្រទូស្តរ៉ាយទាំងនេះត្រូវបានប្រព្រឹត្តឡើងតាមរយៈកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋនីមួយៗ[1754]។

366. វាត្រូវមានចំណងទាក់ទងរវាងជម្លោះប្រដាប់អាវុធអន្តរជាតិ ជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[1755]។ លក្ខខណ្ឌចំណងទាក់ទងនេះត្រូវបានបំពេញ នៅពេលមានភស្តុតាងបង្ហាញថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនេះមាន “ភាពពាក់ព័ន្ធគ្នាជិតស្និទ្ធ” ជាមួយនឹងជម្លោះប្រដាប់អាវុធទាំងមូល[1756]។ ដូច្នេះ “ជម្លោះប្រដាប់អាវុធពុំចាំបាច់មានចំណងទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ ក៏ប៉ុន្តែ យ៉ាងហោចណាស់ អត្ថិភាពនៃជម្លោះប្រដាប់អាវុធត្រូវតែបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងលទ្ធភាពរបស់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ នៅក្នុងសេចក្តីសម្រេចរបស់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅក្នុងរបៀបដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ឬ គោលបំណងដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង”[1757]។ គេពុំចាំបាច់បង្ហាញថា វាមានសកម្មភាពប្រយុទ្ធគ្នាជាក់ស្តែងនៅតាមកន្លែងដែលអំពើបានចោទប្រកាន់ថាបានកើតឡើង ឬអំពើទាំងនោះជាផ្នែកនៃគោលនយោបាយ ឬ ការអនុវត្តដែលត្រូវបានអត់ឱនដោយភាគីណាមួយនៃជម្លោះប្រដាប់អាវុធនោះទេ។ ទោះបីជាយ៉ាងនេះក្តី ក្នុងករណីអំពើទាំងឡាយបានកើតឡើងនៅក្នុងជំរំអ្នកទោសក្រោមការទទួលខុសត្រូវ ឬដោយមានការអនុញ្ញាតពីអាជ្ញាដែលដំណើរការជំរំទាំងនេះ ហើយបានកើតឡើងជាផ្នែកមួយនៃគោលនយោបាយទទួលយកចំពោះអ្នកទោស អំពើទាំងនេះនឹង ច្បាស់ណាស់ថា “ពាក់ព័ន្ធយ៉ាងជិតស្និទ្ធ” ជាមួយនឹងជម្លោះប្រដាប់អាវុធ[1758]។

## <u>បុគ្គលដែលទទួលបានការការពារ</u>

367. មាត្រា ៦ នៃច្បាប់ អ.វ.ត.ក បានផ្តល់យុត្តាធិការដល់ អ.វ.ត.ក ទៅលើ “អំពើប្រឆាំងនឹងមនុស្ស [...] ដែលត្រូវទទួលបានការការពារស្របតាមបទប្បញ្ញត្តិ” នៃអនុសញ្ញាទីក្រុងហ្សឺណែវនានា[1759]។ ការចង្អុលយោងនេះកំណត់និយមន័យ “បុគ្គលដែលទទួលបានការការពារ” ស្របតាមមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV (ស្តីពីជនស៊ីវិល)។

368. អនុសញ្ញាទីក្រុងហ្សឺណែវ IV ពង្រីកឋានៈ "បុគ្គលដែលទទួលបានការការពារ" រហូតដល់ជនស៊ីវិល ដែលស្ថិត "នៅក្នុងកណ្តាប់ដៃរបស់ភាគីដែលមានជម្លោះ ឬដែលកាន់កាប់អំណាច ដែលពួកគេមិនមែន ជាប្រជាជាតិដូចគ្នា"[1760]។ ក្នុងនោះ អនុសញ្ញានេះការពារជនស៊ីវិលដែលយល់ឃើញថា ពួកគេស្ថិតនៅ លើទឹកដីដែលកាន់កាប់ដោយរដ្ឋសត្រូវ[1761]។ ទោះបីជាយ៉ាងនេះក្តី ជនម្នាក់អាចទទួលបានឋានៈទទួល បានការពារ បើទោះជាជននេះជាប្រជាជាតិដូចគ្នានឹងភាគីដែលមានជម្លោះក៏ដោយ[1762]។ ឋានៈទទួល បានការការពាររបស់ជនម្នាក់ពុំមែនអាស្រ័យលើចំណងផ្លូវការ និងទំនាក់ទំនងផ្លូវច្បាប់សុទ្ធសាធនោះទេ ប៉ុន្តែវាអាស្រ័យលើសារធាតុនៃទំនាក់ទំនងដែលកើតមានរវាងបុគ្គលម្នាក់ជាមួយនឹងរដ្ឋ[1763]។ ការ ពិចារណាសំខាន់នៅពេលវិភាគទំនាក់ទំនងសារធាតុទាំងនេះគឺភក្តីភាព ឬ នត្ថិភាពនៃភក្តីភាព ដែល បុគ្គលម្នាក់មានចំពោះភាគីដែលមានជម្លោះ[1764]។ ដូច្នេះ ជនស៊ីវិលអាចចាត់ទុកថាជាបុគ្គលដែលទទួល បានការការពារ យោងតាមគោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV នៅពេលដែលពួកគេត្រូវបាន យល់ឃើញពីសំណាក់រដ្ឋដែលពួកគេស្ថិតនៅក្នុងកណ្តាប់ដៃ "ថាជាកម្មសិទ្ធិរបស់ភាគីប្រឆាំងនៅក្នុង ជម្លោះប្រដាប់អាវុធ និងដែលបានដាក់ការគំរាមកំហែងដល់រដ្ឋនោះ"[1765]។

## <u>ការដឹងអំពីកាលៈទេសៈអង្គហេតុ</u>

369. ក្រៅពីឃើញមានលក្ខខណ្ឌ*អត្តនោម័ត*ចំពោះឧក្រិដ្ឋកម្មជាក់លាក់ ចារីក៏ត្រូវដឹងអំពីកាលៈទេសៈអង្គហេតុ ដែលបានបង្ហាញ៖ (i) អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និង (ii) ឋានៈទទួលបានការការពារ របស់ជនរងគ្រោះ[1766]។ ការដឹងថា រដ្ឋបរទេសបានចូលរួមពាក់ព័ន្ធនៅក្នុងជម្លោះប្រដាប់អាវុធនឹងបំពេញ ធាតុផ្សំទីមួយ[1767]។ ការដឹងថា ជនរងគ្រោះជាសមាជិកនៃភាគីបដិបក្ខដែលមានជម្លោះនឹងបំពេញធាតុផ្សំ ទីពីរ[1768] (ទោះបីជាដូចបានកត់សម្គាល់ខាងលើ ករណីនេះមិនមែនជាស៊ីណារីយ៉ូតែមួយគត់ដែលមាន ចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

# **បទល្មើសជាក់លាក់**

## <u>ការធ្វើមនុស្សឃាតដោយចេតនា</u>

370. ធាតុផ្សំនៃបទល្មើសការធ្វើមនុស្សឃាតដោយចេតនា[1769] អនុលោមតាមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក គឺ

ដូចគ្នានឹងបទល្មើសនៃការធ្វើមនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[1770]។

## ការធ្វើបាបដោយអមនុស្សធម៌

371. ការធ្វើបាបដោយអមនុស្សធម៌[1771] ត្រូវបានកំណត់និយមន័យថាជាអំពើសកម្ម ឬ អកម្មមានចេតនាប្រឆាំងនឹងបុគ្គលដែលទទួលបានការការពារ អនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវនានាដែលបង្កព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ ការឈឺចាប់ ឬ ព្យសនកម្មរាងកាយ ឬ ជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ[1772]។

372. ប្រភេទអំពើនេះគឺជាខប្បញ្ញត្តិរួមដែលការរំលោភលើភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដែលពុំមានចែងនៅក្នុងមាត្រា ៦ អាចចាត់ទុកថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ[1773]។ ករណីថាតើអំពើជាក់លាក់មួយគឺជាការធ្វើបាបដោយអមនុស្សធម៌ឬក៏អត់នោះ គឺជាបញ្ហាចោទផ្នែកអង្គហេតុដែលត្រូវយកមកវិនិច្ឆ័យដោយពិចារណាលើកាលៈទេសៈទាំងអស់[1774]។

373. អំពើនានាដែលជាទារុណកម្ម ឬការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព នឹងបង្កើតបានជាការធ្វើបាបដោយអមនុស្សធម៌ក្នុងពេលដំណាលគ្នា។ បទល្មើសនេះក៏ពង្រីកវិសាលភាពគ្របដណ្ដប់រួមទាំងអំពើផ្សេងៗទៀតដែលរំលោភលើគោលការណ៍នៃការប្រព្រឹត្តិដោយមនុស្សធម៌ ជាពិសេស ការគោរពលើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ[1775]។ អំពើនានាដែលមិនបំពេញលក្ខខណ្ឌអប្បបរមានៃទារុណកម្មដោយសារការខកខានមិនបានបង្ហាញថា អំពើទាំងនោះត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងហាមឃាត់ណាមួយក៏អាចចាត់ទុកជាការធ្វើបាបដោយអមនុស្សធម៌ដូចគ្នាផងដែរ[1776]។ ការធ្វើបាបដោយអមនុស្សធម៌លើជនជាប់ឃុំត្រូវបានចាត់ទុកថាស្ថិតនៅក្នុងវិសាលភាពនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរប្រភេទនេះ[1777]។ អំពើដូចជាការកាត់អវៈយវៈ និងប្រភេទផ្សេងៗទៀតនៃការធ្វើឲ្យខូចខាតរាងកាយធ្ងន់ធ្ងរ ការវាយដំ និងអំពើហិង្សាផ្សេងៗទៀត[1778] និងការធ្វើឲ្យមានរបួសរាងកាយ និងស្មារតីធ្ងន់ធ្ងរ[1779]ត្រូវបានចាត់ទុកថាជាការធ្វើបាបដោយអមនុស្សធម៌។

## ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬ ឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព

374. ឧក្រិដ្ឋកម្មនេះត្រូវបានកំណត់និយមន័យថាជាអំពើសកម្ម ឬអកម្មដោយចេតនាដែលបង្កឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព រួមទាំង សុខភាពផ្លូវចិត្តផងដែរ[1780]។ បទល្មើសនេះរួមទាំងអំពើដែលពុំបានបំពេញលក្ខខណ្ឌនៃទារុណកម្មផងដែរ ឧទាហរណ៍ លក្ខខណ្ឌតម្រូវនូវគោលបំណងជាក់លាក់មួយ ទោះបីជាអំពើទារុណកម្មទាំងអស់អាចស្ថិតនៅក្នុងវិសាលភាពនៃបទល្មើសនេះក៏ដោយ[1781]។ ទោះបីជាជនរងគ្រោះត្រូវបានបង្កឲ្យមានការខូចខាត "ធ្ងន់ធ្ងរ" ក៏ដោយ ក៏វាពុំមានភាពចាំបាច់ក្នុងការបង្ហាញថា របួសរាងកាយ ឬផ្លូវចិត្តមានលក្ខណៈអចិន្ត្រៃយ៍ ឬ មិនអាចជួសបាននោះទេ[1782]។ ប៉ុន្តែ ការខូចខាតនេះត្រូវកើតឡើងហួសព្រំដែននៃភាពគ្មានសុភមង្គលរយៈពេលខ្លី ភាពអាម៉ាស ឬការប្រមាថមើលងាយ[1783] ហើយនឹងត្រូវកើតឡើងហួសពីការខូចខាត ពាក់ព័ន្ធតែចំពោះសេចក្ដីថ្លៃថ្នូរមនុស្សជាតិរបស់ជនរងគ្រោះសុទ្ធសាធ[1784]។

<u>ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់</u>

375. ការដកហូតដោយចេតនាពីជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ តាមរយៈការបដិសេធការធានាតាមផ្លូវតុលាការដូចបានកំណត់និយមន័យនៅក្នុងអនុសញ្ញាទីក្រុង ហ្សឺណែវ IV គឺជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានោះ[1785]។ ការធានាតាមផ្លូវតុលាការទាំងនេះរួមមាន៖ (i) សិទ្ធិទទួលបានការជូនដំណឹងភ្លាមៗអំពីបទល្មើសដែលចោទប្រកាន់លើជនជាប់ចោទ[1786] (ii) ការការពារប្រឆាំងនឹងការដាក់ទោសរួម[1787] (iii) សិទ្ធិទទួលបានការការពារ អនុលោមតាមគោលការណ៍នីត្យានុកូលភាព[1788] (iv) សិទ្ធិមិនត្រូវដាក់ទោសលើសពីម្ដងចំពោះអំពើតែមួយ ឬលើបទចោទតែមួយ (*គោលការណ៍គ្មានការកាត់ទោសពីរដង*)[1789] (v) សិទ្ធិទទួលបានការជូនដំណឹងអំពីសិទ្ធិប្ដឹងឧទ្ធរណ៍[1790] និង (vi) សិទ្ធិមិនត្រូវកាត់ទោស ឬប្រហារជីវិតដោយគ្មានអំណាចសាលក្រមមុនកើតចេញពីការប្រកាសដោយតុលាការដែលត្រូវបានបង្កើតឡើងត្រឹមត្រូវ[1791]។

<u>ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់</u>

376. ធាតុផ្សំនៃការឃុំខ្លួនដោយខុសច្បាប់[1792] ដែលជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនានា គឺដូចគ្នានឹងធាតុផ្សំនៃការដាក់ពន្ធនាគារដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1793]។

377. ការឃុំខ្លួនជនស៊ីវិល "អាចនឹងស្របច្បាប់តែក្នុងលក្ខខណ្ឌនានាដូចមានចែងនៅក្នុងមាត្រា ៤២ [នៃអនុ

សញ្ញាទីក្រុងហ្សឺណែវ IV]" និង "ក្នុងករណីដែលបទប្បញ្ញត្តិនៃមាត្រា ៤៣ [នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV] ត្រូវបានគោរពតាម"[1794]។ ដូច្នេះ ការឃុំខ្លួនជនស៊ីវិលគឺស្របច្បាប់តែក្នុងករណីដែលមានហេតុផលសមហេតុផលអាចឲ្យជឿជាក់បានថា សន្តិសុខនៃអំណាចលើការឃុំខ្លួនប្រឈមនឹងគ្រោះថ្នាក់[1795]។ម្យ៉ាងវិញទៀត ការឃុំខ្លួនដោយស្របច្បាប់ដំបូងអាចក្លាយជាការឃុំខ្លួនខុសច្បាប់ ប្រសិនបើភាគីដែលមានសិទ្ធិឃុំខ្លួនមិនបានគោរពសិទ្ធិជាមូលដ្ឋានតាមនីតិវិធីរបស់អ្នកជាប់ឃុំ ឬបង្កើតតុលាការ ឬក្រុមប្រឹក្សាគ្រប់គ្រងសមស្របដូចមានចែងក្នុងមាត្រា ៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV[1796]។

378. នៅក្នុងការកំណត់នីត្យានុកូលភាពនៃការឃុំខ្លួនបឋម ការវិភាគអនុលោតាមតាមមាត្រា ៤២ អាចពិនិត្យមើលបានតាមរយៈបទប្បញ្ញត្តិផ្សេងៗទៀតនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ដែលអនុញ្ញាតឲ្យព្យួរសិទ្ធិមួយចំនួនរបស់ជនស៊ីវិលនៅក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ ជាពិសេស មាត្រា ៥ និងមាត្រា ២៧ (៤)[1797]។ ទោះបីជាយ៉ាងនេះក៏ដោយ អនុសញ្ញាទីក្រុងហ្សឺណែវនានាពុំបានផ្តល់ "អំណាចដាច់ណាត់ឲ្យឃុំជនស៊ីវិលទាំងអស់របស់ភាគីដែលមានជម្លោះនោះទេ"។ "វាតម្រូវឲ្យមានការវាយតម្លៃថា ជនស៊ីវិលម្នាក់ៗដែលត្រូវបានឃុំខ្លួនមានបង្ក *ហានិភ័យជាក់ស្តែង*ដល់សន្តិសុខរបស់រដ្ឋ"[1798]។

## ខ. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

### ទម្រង់នៃការទទួលខុសត្រូវ

379. មាត្រា ២៩ *ថ្មី*នៃច្បាប់ អ.វ.ត.ក ចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ចំពោះជនជាប់ចោទណាដែល៖ (i) មានផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ ឬប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក និង (ii) ថ្នាក់លើដែលមិនបានបង្ការ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក ដោយអ្នកនៅក្រោមបង្គាប់ខ្លួន។ ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌទាំងអស់នេះ នឹងបកស្រាយរៀបរាប់លម្អិតនៅផ្នែកខាងក្រោម។

380. សម្រាប់ទម្រង់ទាំងអស់នៃការទទួលខុសត្រូវ ហេតុផលជំរុញចិត្ត ចាំបាច់ត្រូវតែខុសពីចេតនា[1799]។ ស្រដៀងគ្នានេះដែរ តួនាទីរបស់ជនជាប់ចោទក្នុងនាមជាអ្នកក្រោមបង្គាប់ គឺមិនមានភាពពាក់ព័ន្ធផ្លូវច្បាប់ក្នុងការសម្រេចលើការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ[1800]។

## ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម

381. សហឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការទទួលខុសត្រូវ ដែលដាក់ការទទួលខុសត្រូវព្រហ្មទណ្ឌ ទៅលើបុគ្គលសម្រាប់អំពើដែលប្រព្រឹត្តឡើងដោយក្រុមមនុស្ស ដើម្បីជំរុញដល់ការរៀបចំឧក្រិដ្ឋកម្មរួមគ្នា។ ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម គឺជាការប្រព្រឹត្តិនៅក្នុងវិសាលភាពនៃមាត្រា ២៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក[1801]។ មានទម្រង់នៃសហឧក្រិដ្ឋកម្មរួមចំនួនបីដែលខុសប្លែកគ្នា តែមានទំនាក់ទំនងគ្នាទៅវិញទៅមក ៖

(១) ***ទម្រង់មូលដ្ឋាន*** ("សហឧក្រិដ្ឋកម្មរួមទម្រង់ទី១")៖ អ្នកចូលរួមទាំងអស់បានប្រព្រឹត្តដោយផ្អែកលើគោលបំណងឧក្រិដ្ឋរួមមួយ ហើយមានចេតនាដូចគ្នាក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1802]

(២) ***ទម្រង់ជាប្រព័ន្ធ*** ("សហឧក្រិដ្ឋកម្មរួមទម្រង់ទី២")៖ គឺជាទម្រង់បែកចេញពីទម្រង់មូលដ្ឋាន ដែលកំណត់លក្ខណៈដោយអត្ថិភាពរបស់ប្រព័ន្ធនៃការធ្វើបាបដែលរៀបចំ ដូចជាការឃុំឃាំង ឬជំរំប្រមូលផ្តុំ ដែលអ្នកចូលរួមបានពាក់ព័ន្ធនឹងប្រព័ន្ធនោះ[1803]

***(៣) ទម្រង់ពង្រីក*** ("សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣")៖ អ្នកចូលរួមទាំងអស់ប្រព្រឹត្តដោយអនុលោមតាមគោលបំណងឧក្រិដ្ឋកម្មរួម ដោយមានចេតនាឧក្រិដ្ឋរួមគ្នា នៅពេលអនុវត្តគោលបំណងនោះ ហើយអ្នកចូលរួមម្នាក់ ឬច្រើននាក់ បានអនុវត្តនូវអំពើមួយដែល ទោះបីជាកើតឡើងហួសពីគោលបំណងឧក្រិដ្ឋដើមក៏ដោយ ប៉ុន្តែមានផលវិបាកដែលអាចមើលឃើញ និងកើតឡើង[ដោយ]ឯកឯងនៃគោលបំណងរួមនោះ[1804]។

382. អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង បានសម្រេចដូចគ្នាថា ក្នុងឆ្នាំ ១៩៧៥ ទាំងសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងសហឧក្រិដ្ឋកម្មរួមទម្រង់ទី២ ត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការទទួលខុសត្រូវតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[1805] ហើយថា ការទទួលខុសត្រូវព្រហ្មទណ្ឌអនុលោមតាមទម្រង់ទាំងអស់នេះ គឺអាចប្រមើលមើលដឹងថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែង[1806]។

383. អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះបានសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនមានអត្ថិភាពទេនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥[1807]។ ចំណុចនេះគឺនៅតែជាបញ្ហា នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០២/០១ ហើយសហព្រះរាជអាជ្ញា សូមរក្សា

ដោយសេចក្តីគោរពនូវជំហរដែលបង្ហាញ នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ក្នុងសំណុំរឿងនេះ[1808] ដែលថា អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ក្នុងការសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ មុនឆ្នាំ ១៩៧៥។

384. *ធាតុផ្សំសត្យានុម័ត*នៃប្រភេទទាំងអស់របស់សហឧក្រិដ្ឋកម្មរួម គឺរួមមាននូវធាតុផ្សំចំនួនបី។ ទីមួយ តម្រូវឲ្យមាន "មនុស្សច្រើន"[1809]។ មនុស្សទាំងនោះមិនចាំបាច់ត្រូវបានចាត់តាំង ជារចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាលឡើយ[1810]។ ទោះបីជាការចាំបាច់ក្នុងការចង្អុលបង្ហាញថា មានមនុស្សជាច្រើនបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ប៉ុន្តែអ្នកចូលរួមអាចត្រូវបានកំណត់ជាប្រភេទ ហើយមិនចាំបាច់ក្នុងការកំណត់ឈ្មោះរបស់បុគ្គលម្នាក់ៗឡើយ[1811]។

385. ទីពីរ ចាំបាច់ត្រូវតែមានគោលបំណងរួម[1812] ដែលបង្កើតបានជាការប្រព្រឹត្តិ ឬចូលរួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក[1813]។ ហេតុដូច្នេះ មិនចាំបាច់ដែលថា គោលដៅរួមនៃផែនការរួម ត្រូវតែជាឧក្រិដ្ឋកម្មនោះឡើយ ដរាបណាអ្នកចូលរួមមានចេតនា សម្រេចគោលដៅនោះ តាមរយៈមធ្យោបាយឧក្រិដ្ឋ[1814]។ មិនមានការកម្រិតកំណត់ចំពោះវិសាលភាពរបស់សហឧក្រិដ្ឋកម្មរួម ទាំងលើកត្តាភូមិសាស្ត្រ ឬកត្តាផ្សេងឡើយ។ ការទទួលខុសត្រូវរបស់ជនជាប់ចោទ "អាចចង្អៀត ឬទូលាយតាមផែនការដែលខ្លួនបានចូលរួមដោយចេតនា"[1815]។ គោលបំណងនេះមិនចាំបាច់ត្រូវបានរៀបចំ ឬបង្កើតឡើងពីមុនៗឡើយ។ គោលបំណងនេះអាចកើតឡើងដោយឥតព្រៀងទុកមុន និងអាចត្រូវបានទាញសេចក្តីសន្និដ្ឋានពីអង្គហេតុ[1816]។

386. ទីបី ជនជាប់ចោទចាំបាច់ត្រូវចូលរួមនៅក្នុងគោលបំណងរួម[1817]។ ជនជាប់ចោទមិនចាំបាច់ត្រូវចូលរួមនៅក្នុងការបង្កើតផែនការរួម[1818] ឬប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ[1819]។ តួនាទីនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ[1820] ឬវត្តមានរបស់ជនជាប់ ក៏មិនបាច់ដែរ នៅពេលប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[1821]។ លើសពីនេះទៀត ការពិតដែលថា ការចូលរួមរបស់ជនជាប់ចោទត្រឹមតែ "តួនាទីជាប្រចាំ" របស់ជនជាប់ចោទនោះ នឹងមិនអាចដោះបន្ទុកគាត់បានដែរ[1822]។ ការតម្រូវ គឺត្រឹមតែថា គាត់បានចូលរួមតាមមធ្យោបាយមួយចំនួនក្នុងការជំរុញដល់គោលបំណងរួមប៉ុណ្ណោះ[1823]។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន បានពន្យល់ "លក្ខណៈដែលសមាជិករបស់សហឧក្រិដ្ឋកម្មរួម ធ្វើទំនាក់ទំនងគ្នា និងសហការគ្នា គឺអាចធ្វើឡើងតាមទម្រង់ជាច្រើន តាមការគិតឃើញរបស់អ្នកចូលរួម

ដើម្បីធ្វើឲ្យសម្រេចគោលបំណងឧក្រិដ្ឋរួមរបស់ពួកគេ”[1824]។

387. ការរួមចំណែករបស់ជនជាប់ចោទ ចាំបាច់ត្រូវតែមានលក្ខណៈដុំកំភួន[1825] ប៉ុន្តែមិនតម្រូវថាមានលក្ខណៈចាំបាច់ ឬជាសារវន្តឡើយ[1826]។ ដូច្នេះ វាមិនមែនជា*លក្ខខណ្ឌចាំបាច់* សម្រាប់ការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយឡើយ[1827]។ ភាពចាំបាច់នៃការរួមចំណែក ក្នុងសហឧក្រិដ្ឋកម្មរួម នឹងត្រូវសម្រេចទៅតាមមូលដ្ឋានជាក់ស្តែងនីមួយៗ ដោយពិចារណាទៅលើកត្តាជាច្រើនដូចជា៖ ទំហំ ភាពធ្ងន់ធ្ងរ និងវិសាលភាពនៃផែនការឧក្រិដ្ឋ ព្រមទាំងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត តួនាទី*ជាក់ស្តែង* ឬតួនាទី*តាមផ្លូវច្បាប់*របស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួមរបស់គាត់ ការថ្លែងជាសាធារណៈរបស់ជនជាប់ចោទដែលមានលក្ខណៈពាក់ព័ន្ធ និងការខិតខំប្រឹងប្រែងណាមួយក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មនេះ[1828]។

388. អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម អាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិកសហឧក្រិដ្ឋកម្មរួម ប្រសិនបើមានការកំណត់ថា ឧក្រិដ្ឋកម្មអាចត្រូវបានដាក់បន្ទុក ទៅលើអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមយ៉ាងហោចណាស់ម្នាក់ ហើយថា អ្នកចូលរួមម្នាក់នោះនៅពេលប្រើប្រាស់ចារីផ្ទាល់ម្នាក់នោះ គឺធ្វើឡើងដើម្បីជំរុញដល់គោលបំណងរួម[1829]។ ការបង្ហាញពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលកំពុងចោទជាបញ្ហា និងសមាជិកសហឧក្រិដ្ឋកម្មរួម គឺត្រូវវាយតម្លៃផ្អែកលើមូលដ្ឋានជាក់ស្តែង[1830]។ ទំនាក់ទំនងនេះអាចត្រូវបានកំណត់ តាមរយៈការបង្ហាញថា សមាជិកសហឧក្រិដ្ឋកម្មរួម (១) សហការគ្នាយ៉ាងជិតស្និទ្ធជាមួយចារីផ្ទាល់ ឬចារីអន្តរការី ដើម្បីជំរុញដល់គោលបំណងរួម[1831] (២) ស្នើដោយផ្ទាល់ ឬដោយប្រយោលទៅបុគ្គលដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[1832] ឬ (៣) ញុះញង់ បញ្ជា ជំរុញ ឬជួយដល់បុគ្គល ដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[1833]។ អាចមានភាពពាក់ព័ន្ធផងដែរចំពោះបញ្ហាថាតើ ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ដោយកងកម្លាំងដែលស្ថិតក្រោមការគ្រប់គ្រងរបស់សមាជិកសហឧក្រិដ្ឋកម្មរួមដែរឬយ៉ាងណា[1834] ឬធ្វើសកម្មភាពឡើងដើម្បីសម្របសម្រួលជាមួយកងកម្លាំងដែលស្ថិតក្រោមការគ្រប់គ្រងរបស់សមាជិកសហឧក្រិដ្ឋកម្មរួម[1835]។

389. ប៉ុន្តែមិនមានការតម្រូវថា សមាជិកសហឧក្រិដ្ឋកម្មរួម ប្រើប្រាស់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព[1836] ឬតាមពិតទៅ “ការគ្រប់គ្រង និងឥទ្ធិពល"[1837] ទៅលើចារីឡើយ។ ចារីនៃឧក្រិដ្ឋកម្មក៏ដូចជាជនជាប់ចោទ មិនចាំបាច់ត្រូវដឹងឮដោយផ្ទាល់ ឬមានការឯកភាពដោយផ្ទាល់ ក្នុងចំណោមពួកគេឡើយ

ពាក់ព័ន្ធការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1838]។ លើសពីនេះទៀត អ្នកដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម មិនចាំបាច់មាន*ធាតុផ្សំអត្តនោម័ត*រួមគ្នា ជាមួយសមាជិករបស់សហឧក្រិដ្ឋកម្មរួមឡើយ ឬគាត់ក៏មិនចាំបាច់ត្រូវដឹងឮអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមដែរ[1839]។

### *ធាតុផ្សំផ្លូវចិត្ត*

390. ធាតុផ្សំផ្លូវចិត្តដែលតម្រូវសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ ផ្អែកលើមូលដ្ឋាននៃការចូលរួម ក្នុងសហឧក្រិដ្ឋកម្មរួម មានការប្រែប្រួលយោងតាមទម្រង់នៃសហឧក្រិដ្ឋកម្មរួម។

391. ដើម្បីដាក់បន្ទុកលើការទទួលខុសត្រូវ អនុលោមតាមសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ជនជាប់ចោទចាំបាច់ត្រូវតែមានរួមគ្នា ជាមួយសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ទាំងចេតនា[1840] ប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងគោលបំណងរួម និងចេតនាចូលរួមក្នុងផែនការរួម ដែលមានគោលដៅប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[1841]។ ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជាការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជនជាប់ចោទចាំបាច់ត្រូវមានចេតនាជាក់លាក់ពាក់ព័ន្ធរួមគ្នា[1842]។ ចេតនាឧក្រិដ្ឋកម្មរួមគ្នាមិនត្រូវឲ្យមានការពេញចិត្ត ឬការត្រេកអរផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ឬការផ្តួចផ្តើមផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ក្នុងការរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមឡើយ[1843]។ បន្ថែមលើនេះ ជនជាប់ចោទមិនតម្រូវឲ្យដឹងឮអំពីហេតុការណ៍ឧក្រិដ្ឋកម្មជាក់លាក់ ដែលកំពុងរងការចោទនោះឡើយ[1844]។ ចេតនាអាចទាញចេញពីការដឹងឮរបស់បុគ្គលម្នាក់ រួមជាមួយការចូលរួមជាបន្តនៅក្នុងឧក្រិដ្ឋកម្មនោះ[1845]។ ភាពចាំបាច់ និងវិសាលភាពនៃការចូលរួមផ្ទាល់របស់បុគ្គលម្នាក់នៅក្នុងសហឧក្រិដ្ឋកម្មរួម អាចពាក់ព័ន្ធផងដែរដល់ការសម្រេចថាតើបុគ្គលនោះមាន*ធាតុផ្សំអត្តនោម័ត* ចាំបាច់ឬទេ[1846]។

392. សម្រាប់សហឧក្រិដ្ឋកម្មរួមទម្រង់ទី២ ជនជាប់ចោទត្រូវតែដឹងឮអំពីប្រព័ន្ធនៃការធ្វើបាប ព្រមទាំងចេតនាក្នុងការជំរុញប្រព័ន្ធនៃការធ្វើបាបដែលបានរៀបចំឡើងរួមគ្នានោះ[1847]។

393. ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលរួមមានឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់[1848] តាមសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ តម្រូវថា ជនជាប់ចោទមានចេតនារួមគ្នា ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងគោលបំណងរួម និងមានចេតនាក្នុងការចូលរួមក្នុងមធ្យោបាយពាក់ព័ន្ធដើម្បីជំរុញដល់គោលបំណងនោះ។ គាត់នឹងត្រូវទទួលខុសត្រូវលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលស្ថិតក្រៅគោលបំណងរួម ប្រសិនបើក្នុងកាលៈ

ទេសៈនៃរឿងក្តីនោះ (១) អាចប្រមើលមើលដឹងថា ឧក្រិដ្ឋកម្មនោះអាចត្រូវបានប្រព្រឹត្តឡើងដោយសមាជិកម្នាក់ ឬច្រើននាក់នៅក្នុងក្រុម និង (២) ជនជាប់ចោទមានចេតនាទទួលយកហានិភ័យនោះ[1849]។ ចាំបាច់ត្រូវបង្ហាញថា ក្នុងឧក្រិដ្ឋកម្មនោះ ជនជាប់ចោទអាចប្រមើលមើលឃើញដោយជាក់លាក់[1850]។ កម្រិតនៃការប្រមើលដឹងថាជាបទល្មើសដែលតម្រូវឱ្យមាន គឺការដឹងឮអំពីលទ្ធភាពដែលថា ឧក្រិដ្ឋកម្មអាចកើតឡើងក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្មរួម[1851]។ ប៉ុន្តែលទ្ធភាពដែលថា ឧក្រិដ្ឋកម្មអាចត្រូវបានប្រព្រឹត្តនោះ ចាំបាច់ត្រូវតែខ្ពស់គ្រប់គ្រាន់ ដើម្បីឱ្យជនជាប់ចោទអាចប្រមើលមើលដឹងថាជាបទល្មើស[1852]។

394. ប្រហែលគ្នានេះ នៅពេលដែលជនជាប់ចោទ ឬសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ដើម្បីជំរុញគោលបំណងឧក្រិដ្ឋកម្មរួម បានប្រើប្រាស់មនុស្សដែល បន្ថែមពីលើ (ឬជំនួសឱ្យ) ការអនុវត្ត*ធាតុផ្សំសត្យានុម័ត*នៃឧក្រិដ្ឋកម្ម ដែលបង្កើតបានជាផ្នែកនៃគោលបំណងរួមនោះ បានប្រព្រឹត្តឧក្រិដ្ឋកម្មដែលលើសពីគោលបំណងរួម ពេលនោះជនជាប់ចោទអាចត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មបែបនោះ ប្រសិនបើគាត់បានចូលរួមនៅក្នុងគោលបំណងរួម ដោយមានចេតនាដែលបានតម្រូវ ហើយនៅក្នុងកាលៈទេសៈនៃរឿងក្តី (១) អាចប្រមើលមើលដឹងថា ឧក្រិដ្ឋកម្មបែបនេះអាចប្រព្រឹត្តឡើង ដោយមនុស្សម្នាក់ ឬច្រើននាក់ ដែលគាត់បានប្រើប្រាស់ (ឬសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមបានប្រើប្រាស់) ដើម្បីអនុវត្ត*ធាតុផ្សំសត្យានុម័ត*នៃឧក្រិដ្ឋកម្ម ដែលបង្កើតជាផ្នែកនៃគោលបំណងរួម និង (២) ជនជាប់ចោទមានចេតនាទទួលយកហានិភ័យគឺថា ជនជាប់ចោទដោយបានដឹងឮថា ឧក្រិដ្ឋកម្មបែបនេះអាចជាផលវិបាកនៃការអនុវត្តសហកម្ម បានសម្រេចចូលរួមនៅក្នុងសហកម្មនោះ[1853]។

## <u>ការរៀបចំផែនការ</u>

395. ត្រឹមឆ្នាំ ១៩៧៥ ការរៀបចំផែនការគឺជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ដែលទទួលស្គាល់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ[1854]។ លើសពីនេះទៀត គេអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ចែងនៅពេលនោះថា គេអាចត្រូវបានចោទប្រកាន់តាមទម្រង់នៃការទទួលខុសត្រូវនេះ[1855]។

396. *ធាតុផ្សំសត្យានុម័ត* នៃ "ការរៀបចំផែនការ" តម្រូវថា មនុស្សម្នាក់ ឬច្រើននាក់បានចូលរួមក្នុងការរៀបចំអំពើសកម្ម ឬអកម្ម ដូច្នេះហើយគឺមានឥទ្ធិពលខ្លាំងក្លាទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលតាមអង្គហេតុគឺត្រូវបានប្រព្រឹត្តឡើង[1856]។ ហេតុដូច្នេះ ជនជាប់ចោទមិនចាំបាច់រៀបចំការប្រព្រឹត្តតែម្នាក់ឯងនោះ

ទេ[1857]។ ជនជាប់ចោទក៏មិនចាំបាច់ជាអ្នកបង្កើតការរៀបចំ ឬផែនការដែរ[1858] ត្រឹមតែការអនុម័តយល់ព្រមទៅលើផែនការ ដែលបានស្នើឡើងដោយអ្នកដទៃក៏គ្រប់គ្រាន់ដែរ[1859]។ ភស្តុតាងតាមកាលៈទេសៈអាចបង្ហាញភស្តុតាងអំពីអត្ថិភាពនៃផែនការ[1860]។ ការផ្តន្ទាទោសចំពោះការរៀបចំផែនការ មិនតម្រូវឱ្យមានការសម្រេចលើតួនាទីរបស់អាជ្ញាធរឡើយ[1861] ឬថាក៏មិនតម្រូវថាជនជាប់ចោទមានវត្តមាននៅទីតាំងឧក្រិដ្ឋកម្មដែរ[1862]។

397. ផែនការចាំបាច់ត្រូវតែបន្តអនុវត្ត ហើយបានចូលរួមចំណែកយ៉ាងសំខាន់ ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1863]។ ទោះបីជាអំពើជាក់លាក់មួយអាចត្រូវបានចាត់ទុក ឬមិនត្រូវបានចាត់ទុកថាជាការរួមចំណែកយ៉ាងសំខាន់នោះ គឺតម្រូវឱ្យធ្វើការវាយតម្លៃ តាមមូលដ្ឋានជាក់ស្តែង អនុលោមតាមភស្តុតាងជារួម[1864]។ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលឧក្រិដ្ឋកម្មផ្ទាល់ចាំបាច់ត្រូវតែប្រព្រឹត្តឡើង ជាផ្នែកនៃការវាយប្រហារទ្រង់ទ្រាយធំ និងជាប្រព័ន្ធនោះ អំពើរៀបចំធ្វើផែនការ អាចសម្រេចឡើង នៅមុនពេលប្រព្រឹត្តឧក្រិដ្ឋកម្ម និងនៅពេលកើតឡើងការវាយប្រហារទ្រង់ទ្រាយធំ ឬជាប្រព័ន្ធ[1865]។

398. ចំពោះខ្លឹមសារនៃផែនការ វាមិនចាំបាច់ត្រូវតែបង្កើតឡើងនូវការប្រព្រឹត្តិឧក្រិដ្ឋកម្មជាក់លាក់មួយឡើយ។ ផែនការអាចជាគោលដៅដែលត្រូវសម្រេច តាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ហេតុដូច្នេះ លក្ខណៈស្របច្បាប់នៃប្រតិបត្តិការមួយ មិនធ្វើឱ្យជនជាប់ចោទរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌសម្រាប់ការរៀបចំផែនការឧក្រិដ្ឋកម្ម ដែលត្រូវប្រព្រឹត្តក្នុងសកម្មភាពនោះឡើយ ប្រសិនបើគោលដៅត្រូវបានសម្រេចតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1866]។ ក្នុងករណីដែលជនជាប់ចោទរៀបចំផែនការសម្រាប់ការប្រព្រឹត្តិដែលមានគោលបំណងចម្បង ក្នុងការវាយប្រហារដោយឥតរើសអើងទៅលើប្រជាជនស៊ីវិលនោះ គឺគាត់រៀបចំផែនការការប្រព្រឹត្តិ ដែលបង្កើតបានជាឧក្រិដ្ឋកម្ម[1867]។

399. ចំពោះ*ធាតុផ្សំអត្តនោម័ត*វិញ ជនជាប់ចោទចាំបាច់ត្រូវមានចេតនា ឬបានដឹងឮអំពីលទ្ធភាពចម្បងនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅពេលអនុវត្តផែនការ[1868]។ *ធាតុផ្សំអត្តនោម័ត*របស់ជនជាប់ចោទអាចទាញចេញពីកាលៈទេសៈនានា[1869]។ មិនមានលក្ខខណ្ឌតម្រូវដែលថា ហានិភ័យរបស់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង អាច "សមហេតុផល" ឬ "អាចធ្វើយុត្តិកម្ម" បានឡើយ[1870]។ ក្នុងករណីដែលមានការសម្រេចថាចារីផ្ទាល់បានដឹងឮថាកាលៈទេសៈអង្គហេតុ បង្កើតឱ្យមានឋានៈជាជនរងគ្រោះ (ឧទាហរណ៍ប្រជាជន

ស៊ីវិល *យុទ្ធជនបាត់បង់សមត្ថភាពប្រយុទ្ធ* ជាដើម) ការសម្រេចបែបនេះគឺមិនចាំបាច់សម្រាប់ការផ្តន្ទាទោសចំពោះ ការរៀបចំផែនការឡើយ[1871]។

## ការញុះញង់

400. ការញុះញង់[1872] ត្រូវបានទទួលស្គាល់ថាជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ ១៩៧៥[1873]។ លើសពីនេះទៀត នៅពេលនោះគេអាចប្រមើលមើលដឹងថាជាបទល្មើស និងដឹងថាមានច្បាប់ចែងថា គេអាចត្រូវបានចោទប្រកាន់អនុលោមតាមទម្រង់នៃការទទួលខុសត្រូវមួយនេះ[1874]។

401. ដើម្បីដាក់ឲ្យទទួលខុសត្រូវលើការញុះញង់ ជនជាប់ចោទ តាមរយៈអំពើសកម្ម ឬអកម្ម ជំរុញឲ្យបុគ្គលម្នាក់ទៀតធ្វើសកម្មភាពណាមួយជាក់លាក់ ដែលមានឥទ្ធិពលធំធេងលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1875]។ ទម្រង់នៃការទទួលខុសត្រូវមួយនេះក៏ត្រូវបានពិពណ៌នាថាជា "ការជំរុញ ឬការលើកទឹកចិត្ត" ផងដែរ[1876]។ វាពុំមានលក្ខខណ្ឌតម្រូវទាមទារឲ្យការញុះញង់ធ្វើឡើង "ដោយផ្ទាល់ និងជាសាធារណៈ" នោះទេ[1877]។ ទាំងអំពើសកម្ម និងទាំងអំពើអកម្មអាចបង្កើតបានជាការញុះញង់[1878] ដែលអាចជាលទ្ធភាពកើតឡើងដោយអំពើស្ងៀមស្ងាត់ ជាលាយលក្ខណ៍អក្សរ ឬដោយទម្រង់អ្វីក៏ដោយរបស់ជនជាប់ចោទដោយមិនចាំបាច់តែការនិយាយនោះទេ[1879]។ វាពុំចាំបាច់ត្រូវបង្ហាញឲ្យឃើញនូវពាក្យពេចន៍ញុះញង់ចំៗដែលបានប្រើប្រាស់ដោយជនជាប់ចោទឡើយ[1880]។

402. ឋានៈនៃអំណាច[1881] ឬសិទ្ធិគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព[1882] លើចារីផ្ទាល់ពុំមែនជាលក្ខខណ្ឌធាតុផ្សំ ក្រោមទម្រង់នៃការទទួលខុសត្រូវមួយនេះនោះទេ។ ស្រដៀងគ្នានេះដែរ វត្តមានដោយផ្ទាល់របស់ជនជាប់ចោទនៅទីតាំងនៃឧក្រិដ្ឋកម្មពុំមែនជាលក្ខខណ្ឌតម្រូវដូចគ្នា[1883]។ ការខកខានរបស់ថ្នាក់លើម្តងហើយម្តងទៀតក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើចារីចំពោះឧក្រិដ្ឋកម្មអាចមានន័យស្មើនឹងការញុះញង់ឲ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមផ្សេងទៀត[1884]។

403. ដើម្បីឲ្យជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌលើការញុះញង់ គេត្រូវបង្ហាញថា បទឧក្រិដ្ឋមួយពិតជាត្រូវបានប្រព្រឹត្តឡើងមែន[1885] ទោះបីជាវាពុំតម្រូវឲ្យបង្ហាញជាក់លាក់អំពីអត្តសញ្ញាណរបស់ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋនោះក៏ដោយ[1886]។ ម្យ៉ាងវិញទៀត អំពើញុះញង់ត្រូវកើតឡើងមុន ហើយចូលរួម

ចំណែកយ៉ាងសំខាន់លើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1887]។ ទោះបីជាយ៉ាងនេះក្តី វាពុំចាំបាច់ត្រូវបង្ហាញថា ឧក្រិដ្ឋកម្មនឹងពុំអាចកើតឡើងនោះទេប្រសិនបើគ្មានការចូលរួមពីជនជាប់ចោទ[1888]។ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទោះបីជាបទឧក្រិដ្ឋមួយត្រូវប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារទ្រង់ទ្រាយធំ ឬជាប្រព័ន្ធក៏ដោយ ក៏ការញុះញង់អាចធ្វើឡើង នៅមុនពេលប្រព្រឹត្ត ឧក្រិដ្ឋកម្ម និងនៅមុនពេលកើតឡើងនៃការវាយប្រហារទ្រង់ទ្រាយធំ ឬប្រព័ន្ធនោះ[1889]។

404. ដោយសារជនជាប់ចោទ ចាំបាច់ត្រូវតែជំរុញឲ្យជនម្នាក់ទៀតធ្វើសកម្មភាពក្នុងវិធីណាពិសេសមួយ និងពុំចាំបាច់តែប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបទល្មើសជាក់លាក់ណាមួយទេនោះ ដូច្នេះលក្ខណៈ ស្រប ច្បាប់នៃប្រតិបត្តិការមួយ ពុំអាចច្រានចោលការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទចំពោះការញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តក្នុងដំណើរការប្រតិបត្តិការនោះទេ ប្រសិនបើគោលបំណងបានសម្រេចរួចហើយតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1890]។ ក្នុងករណីជនជាប់ចោទញុះញង់ឲ្យមានអំពើណាមួយដែលមានគោលបំណងចំបងគឺធ្វើការវាយប្រហារជនស៊ីវិលដោយមិនរើសមុខនោះ ជនជាប់ចោទបានញុះញង់អំពើដែលជាឧក្រិដ្ឋកម្ម[1891]។

405. *ធាតុផ្សំអត្តនោម័ត*ចំពោះការទទួលខុសត្រូវលើការញុះញង់គឺចេតនាញុះញង់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ឬការដឹងឮអំពីលទ្ធភាពចំបងដែលថា ឧក្រិដ្ឋកម្មនោះនឹងត្រូវបានប្រព្រឹត្តឡើងដោយសារតែការញុះញង់[1892]។ វាពុំទាមទារលក្ខខណ្ឌដែលថា ហានិភ័យនៃឧក្រិដ្ឋកម្មដែលនឹងបានប្រព្រឹត្តឡើងនោះ “មានភាពសមហេតុផល” ឬ “មានយុត្តិកម្ម” នោះទេ[1893]។ នៅក្នុងករណីដែលបានរកឃើញថា ចារីផ្ទាល់បានដឹងឮអំពីឋានៈរបស់ជនរងគ្រោះ (ឧ. ជនស៊ីវិល *អ្នកបោះបង់ចោលការប្រយុទ្ធ* ។ល។) ការរកឃើញបែបនេះពុំមានលក្ខណៈចាំបាច់សម្រាប់ការសម្រេចលើពិរុទ្ធភាពចំពោះការញុះញង់នោះឡើយ[1894]។

## ការបញ្ជា

406. គិតមកត្រឹមឆ្នាំ ១៩៧៥ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ការបញ្ជាថាជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល[1895]។ ជាងនេះទៀត គេអាចប្រមើលមើលដឹងថាជាបទល្មើស និងដឹងថាមានច្បាប់ចែងថា គេអាចត្រូវបានចោទប្រកាន់ តាមទម្រង់នៃការទទួលខុសត្រូវមួយនេះ[1896]។

407. អំពើនៃការបញ្ជាកើតឡើង នៅពេលបុគ្គលម្នាក់ក្នុងឋានៈជាអ្នកមានអំណាចបង្គាប់ឲ្យបុគ្គលម្នាក់ទៀតធ្វើ

សកម្មភាព ឬចូលរួមក្នុងអំពើអកម្មណាមួយដែលមានឥទ្ធិពលធំធេងលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1897]។ វាពុំទាមទារលក្ខខណ្ឌដែលថា បុគ្គលដែលបានចេញបញ្ជា និងចារីផ្ទាល់មានទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ជាផ្លូវការនោះទេ[1898] ឬជនជាប់ចោទមានសិទ្ធិអំណាចគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើខ្លួននោះទេ[1899] ប៉ុន្តែគេត្រូវបង្ហាញភស្តុតាងថា ជនជាប់ចោទមានអំណាចតាមផ្លូវច្បាប់ ឬតាមអង្គហេតុដែលបង្ខំឱ្យបុគ្គលម្នាក់ទៀតប្រព្រឹត្តឧក្រិដ្ឋកម្ម[1900]។ ទោះបីជាយ៉ាងនេះក្តី ជនជាប់ចោទពុំចាំបាច់ប្រើប្រាស់តួនាទីមានអំណាចរបស់ ខ្លួន "អូសទាញ" ចារីឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទល្មើសជាក់លាក់ណាមួយនោះទេ[1901]។ អំណាចនេះអាចមានលក្ខណៈក្រៅផ្លូវការ ឬមានលក្ខណៈបណ្តោះអាសន្នសុទ្ធសាធ[1902]។

408. បញ្ជានេះពុំចាំបាច់ចេញជាលាយលក្ខណ៍អក្សរ ឬជាទម្រង់ពិសេសណាមួយនោះទេ[1903] ប៉ុន្តែដោយសារតែការបញ្ជាទាមទារនូវ "អំពើវិជ្ជមានជាមុន" នោះ ការបញ្ជាពុំអាចចេញ តាមរយៈអំពើអកម្មបាននោះទេ[1904]។ បញ្ជាអាចចេញដោយជាក់លាក់ ឬដោយប្រយោល ហើយអាចបង្ហាញតាមស្ថានភាពបាន[1905]។ អត្ថិភាពនៃបញ្ជាអាចសន្និដ្ឋានតាមរយៈកត្តានានា រួមទាំងចំនួននៃអំពើខុសច្បាប់ ចំនួន និងប្រភេទបុគ្គលិកពាក់ព័ន្ធ សិទ្ធិអំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងអំណាចដឹកនាំលើបុគ្គលិក សម្ភារៈពាក់ព័ន្ធ និងការកើតឡើងក្នុងលក្ខណៈទូទៅនៃអំពើខុសច្បាប់ស្រដៀងគ្នា ចង្វាក់តាក់ទិកនៃប្រតិបត្តិការ *វិធីប្រព្រឹត្ត*អំពើសដៀងគ្នា ទីតាំងដែលថ្នាក់លើស្ថិតនៅនាពេលនោះ និងការដឹងឮរបស់ថ្នាក់លើអំពីអំពើព្រហ្មទណ្ឌដែលបានប្រព្រឹត្តឡើងនៅក្រោមការដឹកនាំរបស់ថ្នាក់លើនោះ[1906]។ ពុំទាមទារលក្ខខណ្ឌឱ្យជនជាប់ចោទមានវត្តមានដោយផ្ទាល់នៅកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មនោះឡើយ[1907]។

409. ជនជាប់ចោទពុំចាំបាច់ចេញបញ្ជាដោយផ្ទាល់ដល់ចារីផ្ទាល់នោះទេ។ ការទទួលខុសត្រូវលើការបញ្ជាអាចជាលទ្ធផលកើតឡើង ក្នុងករណីដែលជនជាប់ចោទបានចេញ បានផ្តល់អំណាច ឬបើមិនដូច្នោះទេផ្ទេរបញ្ជានោះ រួមទាំងតាមរយៈអន្តរការីផងដែរ[1908]។

410. បញ្ជាចាំបាច់ត្រូវចេញមុន និងចូលរួមចំណែកយ៉ាងសំខាន់លើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនាពេលក្រោយមក[1909]។ ប៉ុន្តែ វាពុំចាំបាច់ត្រូវបង្ហាញថា ឧក្រិដ្ឋកម្ម ឬបទល្មើសជាក់លាក់នោះ នឹងពុំត្រូវបានប្រព្រឹត្តឡើង ប្រសិនបើពុំមានបញ្ជាពីជនជាប់ចោទ[1910]។

411. ចំពោះខ្លឹមសារនៃបញ្ជា បញ្ជានោះចាំបាច់ធ្វើឡើងដើម្បីឱ្យប្រព្រឹត្តអំពើសកម្ម ឬអកម្ម។ ពុំចាំបាច់បង្ហាញ

ថា បញ្ជានោះខុសច្បាប់[1911] ឬធ្វើឡើងដោយផ្ទាល់អាចនឹងបង្កជាផលវិបាកនោះទេ[1912]។ លក្ខណៈស្រប ច្បាប់នៃប្រតិបត្តិការនោះពុំមែនច្រានចោលការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទចំពោះការ ចេញបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តក្នុងដំណើរការប្រតិបត្តិការនោះទេ ប្រសិនបើគោល បំណងបានសម្រេចរួចហើយតាមរយៈការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ[1913]។ ក្នុងករណីជនជាប់ចោទ បញ្ជាអំពើដែលមានគោលបំណងចំបងវាយប្រហារលើជនស៊ីវិលដោយមិនរើសមុខ ជនជាប់ចោទនោះ បានបញ្ជាអំពើដែលចាត់ទុកជាឧក្រិដ្ឋកម្ម[1914]។

412. ចំពោះ*ធាតុផ្សំអត្តនោម័ត* ជនជាប់ចោទត្រូវមានចេតនា ឬដឹងឮអំពីលទ្ធភាពចំបងដែលថា ការអនុវត្ត បញ្ជានោះនឹងនាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1915]។ ពុំទាមទារលក្ខខណ្ឌដែលថា ហានិភ័យនៃឧក្រិដ្ឋកម្ម ដែលនឹងប្រព្រឹត្តឡើងនោះ "មានភាពសមហេតុផល" ឬ "មានយុត្តិកម្ម" នោះទេ[1916]។ នៅក្នុងករណី ដែលបានរកឃើញថា ចារីផ្ទាល់បានដឹងអំពីឋានៈរបស់ជនរងគ្រោះ (ឧ. ជនស៊ីវិល *អ្នកបោះបង់ចោល ការប្រយុទ្ធ* ។ល។) ការរកឃើញបែបនេះពុំមានលក្ខណៈចាំបាច់សម្រាប់ការ សម្រេចពិរុទ្ធភាព ចំពោះការបញ្ជានោះឡើយ[1917]។

## <u>ការជួយ និងជំរុញ</u>

413. គិតមកត្រឹមឆ្នាំ ១៩៧៥ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទទួលស្គាល់ថា ការជួយ និងជំរុញ[1918] គឺជា ទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល[1919]។ម្យ៉ាងវិញទៀត ការទទួលខុសត្រូវលើការជួយ និងជំរុញអាចប្រមើលមើលដឹងថាជាបទល្មើស និងដឹងថាមានច្បាប់ចែង ដោយបុគ្គលនៅពេលនោះ[1920]។

414. ការជួយ និងជំរុញ[1921] រួមមានការជួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រខាងស្មារតីដែលមានឥទ្ធិ ពលយ៉ាងខ្លាំងចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1922]។ "គោលដៅជាក់លាក់" ពុំមែនជាធាតុផ្សំនៃការទទួល ខុសត្រូវលើការជួយ និងជំរុញនោះទេ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[1923]។

415. ការជួយ និងជំរុញគឺជាទម្រង់មួយនៃការទទួលខុសត្រូវលើការសមគំនិត ដូច្នេះ ជនជាប់ចោទមិនអាច ត្រូវបានសម្រេចពិរុទ្ធភាពលើឧក្រិដ្ឋកម្មនៃការជួយ និងជំរុញដែលពុំដែលបានប្រព្រឹត្តឡើងនោះទេ[1924]។ ក៏ប៉ុន្តែ ចារីនៃឧក្រិដ្ឋកម្មពុំចាំបាច់ត្រូវបានជំនុំជម្រះ ឬកំណត់អត្តសញ្ញាណនោះឡើយ[1925]។ ពុំទាមទារឱ្យ មានផែនការ ឬការព្រមព្រៀងគ្នារវាងអ្នកជួយ និងជំរុញ ជាមួយនឹងចារីផ្ទាល់ដើម្បីអាចឱ្យទទួលខុស

ត្រូវលើការជួយ និងជំរុញនោះឡើយ[1926]។ តាមពិតទៅ ចារីផ្ទាល់ពុំចាំបាច់សូម្បីតែដឹងឮអំពីការចូលរួមចំណែករបស់អ្នកជួយ និងជំរុញនោះទេ[1927]។

416. ទោះបីជាការជួយ និងជំរុញចាំបាច់ត្រូវមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តិឧក្រិដ្ឋកម្មក៏ដោយ[1928] ក៏វាពុំទាមទារលក្ខខណ្ឌចំណងទាក់ទងនៃហេតុ និងបច្ច័យរវាងអំពើរបស់អ្នកជួយ និងជំរុញ និងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬក៏ទាមទារលក្ខខណ្ឌដែលថា អំពើបែបនោះគឺជាលក្ខខណ្ឌនាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះឡើយ[1929]។ ករណីថាតើការចូលរួមចំណែកជាក់លាក់មួយត្រូវបានចាត់ទុកថា "សំខាន់ខ្លាំង" ដែរ ឬអត់នោះគឺទាក់ទងនឹងការសាកសួរលើអង្គហេតុ[1930]។ ក្នុងករណី ឧក្រិដ្ឋកម្មនោះគឺជាអំពើធ្វើទុក្ខបុកម្នេញ ការចូលរួមចំណែករបស់ជនជាប់ចោទលើបទឧក្រិដ្ឋនោះពុំចាំបាច់បង្ហាញអំពីលក្ខណៈរើសអើងនៃឧក្រិដ្ឋកម្មនោះឡើយ[1931]។

417. អំពើដែលចាត់ទុកជាការជួយ និងជំរុញអាចកើតឡើងនៅមុន នៅក្នុងអំឡុងពេល ឬនៅក្រោយពេល[1932] ប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយនៅកន្លែងផ្សេងពីកន្លែងបទឧក្រិដ្ឋកើតឡើង[1933]។ ស្រដៀងគ្នានេះដែរ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទោះបីជាបទឧក្រិដ្ឋត្រូវប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារទូលំទូលាយ ឬប្រព័ន្ធក៏ដោយ ក៏ការជួយ និងជំរុញអាចសម្រេចឡើងនៅមុន ឬ នៅក្រោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម ហើយនឹងនៅមុន ឬនៅក្រោយការកើតឡើងនៃការវាយប្រហារទូលំទូលាយ ឬជាប្រព័ន្ធនោះ[1934]។

418. ជនម្នាក់អាចរកឃើញថាត្រូវទទួលខុសត្រូវលើការជួយ និងជំរុញលើឧក្រិដ្ឋកម្មមួយ នៅពេលមានភស្តុតាងបង្ហាញថា អំពើរបស់ជននេះគឺជាការឯកភាពដោយតណ្ហីភាព និងជាការលើកទឹកចិត្តដល់ឧក្រិដ្ឋកម្មនោះ ហើយអំពើបែបនោះរួមចំណែកយ៉ាងសំខាន់លើឧក្រិដ្ឋកម្ម[1935]។ គេត្រូវបង្ហាញថា វត្តមានរបស់ជនជាប់ចោទនេះហើយដែលជាការផ្តល់ធម្មានុរូបលើ ឬបានផ្តល់ការលើកទឹកចិត្តដល់ចារីផ្ទាល់ដែលជាកត្តារួមចំណែកយ៉ាងសំខាន់លើឧក្រិដ្ឋកម្មនោះ[1936]។ ទោះបីជានៅក្នុងករណីបែបនេះ សិទ្ធិអំណាចរបស់ជនជាប់ចោទគឺជាកត្តាមួយចំណែកក៏ដោយ[1937] ក៏គេពុំចាំបាច់បង្ហាញថា ជនជាប់ចោទមានសិទ្ធិអំណាចលើចារីផ្ទាល់នោះឡើយ[1938]។

419. ជនជាប់ចោទអាចជួយ និងជំរុញតាមរយៈអំពើអកម្ម។ នៅក្នុងករណីនេះ លក្ខខណ្ឌនៃ*ធាតុផ្សំសត្យានុម័ត* និង*អត្តនោម័ត* គឺដូចគ្នាលក្ខខណ្ឌធាតុផ្សំនៃអំពើវិជ្ជមានដែរ[1939]។ ជនជាប់ចោទអាចនឹងទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងករណីដែលជនជាប់ចោទខកខានក្នុងការបំពេញភារកិច្ចផ្លូវច្បាប់របស់ខ្លួន ហើយ

ដោយសារការខកខាននេះហើយគឺជាការជួយ ការលើកទឹកចិត្ត និងការផ្តល់ការគាំទ្រខាងស្មារតីដែលមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ[1940]។ គេត្រូវបង្ហាញថា ជនជាប់ចោទមាន "លទ្ធភាពចាត់វិធានការ ឬក៏ជនជាប់ចោទមានមធ្យោបាយក្នុងការបំពេញភារកិច្ចរបស់ខ្លួន"[1941]។ ករណីថាតើអំពើអកម្មមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តិ ឧក្រិដ្ឋកម្ម ឬក៏អត់នោះ គឺជាពិនិត្យវិភាគលើអង្គហេតុ[1942]។ ទិដ្ឋភាពនៃការជួយ និងជំរុញតាមរយៈអំពើអកម្ម ត្រូវបានបកស្រាយក្នុងន័យថា ប្រសិនបើជនជាប់ចោទបានចាត់វិធានការនោះ ការប្រព្រឹត្តិឧក្រិដ្ឋនោះទំនងជាមិនអាចកើតឡើងបានឡើយ[1943]។

420. ចំពោះ*ធាតុផ្សំអត្តនោម័ត* ជនជាប់ចោទចាំបាច់ត្រូវដឹងឮថា នៅពេលខ្លួនផ្តល់ការជួយជ្រោមជ្រែង[1944] ឧក្រិដ្ឋកម្មប្រហែលជានឹងប្រព្រឹត្តឡើង ហើយអំពើរបស់ខ្លួនគឺជាការជួយ ឬសម្រួលដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ[1945]។ តាមការពិត អ្នកជួយ និងជំរុញពុំចាំបាច់ត្រូវដឹងឮឲ្យបានជាក់លាក់អំពីឧក្រិដ្ឋកម្មដែលចារីនឹងប្រព្រឹត្តនោះឡើយ។ វាគ្រប់គ្រាន់ ប្រសិនបើជនជាប់ចោទបានដឹងថា ឧក្រិដ្ឋកម្មមួយក្នុងចំណោមបទឧក្រិដ្ឋទាំងឡាយនោះនឹងប្រហែលជាត្រូវបានប្រព្រឹត្តឡើង ហើយឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋទាំងនោះពិតជាបានប្រព្រឹត្តឡើងមែន[1946]។ ជនជាប់ចោទក៏ត្រូវដឹងអំពីធាតុផ្សំសំខាន់នៃឧក្រិដ្ឋកម្មនោះផងដែរ រួមទាំង ស្ថានភាពស្មារតីរបស់ចារី ក៏ប៉ុន្តែជនជាប់ចោទពុំចាំបាច់មានចេតនាដូចចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ[1947]។ ឧក្រិដ្ឋកម្មដែលមានធាតុផ្សំចេតនាពិសេសទាមទារលក្ខខណ្ឌឲ្យអ្នកជួយ និងជំរុញដឹង ក៏ប៉ុន្តែពុំចាំបាច់មានចេតនាពិសេសដូចចារីផ្ទាល់នោះទេ[1948]។ ការដឹងឮនេះអាចទាញការសន្និដ្ឋានពីស្ថានភាពនានា[1949]។ ទោះបីជាយ៉ាងនេះក្តី អត្ថិភាពចេតនាពិសេសពុំមែន*រារាំង*ការសម្រេចពិរុទ្ធភាពលើការជួយ និងជំរុញនោះទេ ពោលគឺ វាពុំចាប់បង្ខំឲ្យសន្និដ្ឋានថា ជនជាប់ចោទគឺជាចារីផ្ទាល់នោះឡើយ[1950]។

## ការទទួលខុសត្រូវរបស់ថ្នាក់លើ

421. ការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលអាចយកមកអនុវត្តបានទាំងថ្នាក់លើនៅក្នុងជួរយោធា និង នៅក្នុងជួរស៊ីវិល ត្រូវបានទទួលស្គាល់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ ១៩៧៥[1951]។ ជាងនេះទៀតគេអាចប្រមើលមើលឃើញថាជាបទល្មើស និងដឹងថាមានច្បាប់ចែង ដែលថាគេអាចនឹងទទួលការចោទប្រកាន់ទោស ទៅតាមទម្រង់នៃការទទួលខុសត្រូវនេះ[1952]។ នៅក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ទម្រង់នៃការទទួលខុសត្រូវនេះត្រូវយកមកអនុវត្ត ដោយមិនគិតថា ជម្លោះនោះជាជម្លោះ

ផ្ទៃក្នុង ឬជាជម្លោះកម្រិតអន្តរជាតិទេ[1953] និងអនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[1954] ដែរ។

422. អនុលោមតាមវិធាន ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការទទួលខុសត្រូវរបស់ថ្នាក់លើ ផ្អែកទៅលើអត្ថិភាពនៃធាតុផ្សំចំនួនបីដូចខាងក្រោម៖

(i) ទំនាក់ទំនងថ្នាក់លើ-អ្នកនៅក្រោមបង្គាប់ រវាងជនជាប់ចោទ និងអ្នកដែលបានប្រព្រឹត្ត ឧក្រិដ្ឋកម្ម។ ថ្នាក់លើចាំបាច់ត្រូវមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់[1955]។

(ii) ថ្នាក់លើបានដឹង ឬមានមូលហេតុដឹងថា អ្នកនៅក្រោមបង្គាប់បានប្រព្រឹត្ត ឬនឹងប្រព្រឹត្តឧក្រិដ្ឋកម្ម និង

(iii) ថ្នាក់លើពុំបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីបង្ការការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬ ដាក់ទណ្ឌកម្មដល់ចារី[1956]។

423. ថ្នាក់លើអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន តែក្នុងករណីតែអ្នកក្រោមបង្គាប់នោះត្រូវបានរកឃើញថា ពិតជាបានចូលរួមនៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[1957]។ ការទទួលខុសត្រូវមិនត្រឹមតែផ្ដោតទៅលើការចោទប្រកាន់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់គាត់ប៉ុណ្ណោះទេ តែផ្ដោតទៅលើការផ្ដន្ទាទោសដល់រូបគាត់ពីការខកខានមិនបានអនុវត្តតួនាទីរបស់ខ្លួន ក្នុងនាមជាថ្នាក់លើក្នុងការអនុវត្តបញ្ជា[1958]។

*ទំនាក់ទំនងថ្នាក់លើ-អ្នកនៅក្រោមបង្គាប់*

424. ដោយមិនគិតដល់ករណីដែលថាតើជនជាប់ចោទជាថ្នាក់លើនៅក្នុងជួរស៊ីវិល ឬនៅក្នុងជួរយោធា ឬយ៉ាងណាទេ[1959] ទំនាក់ទំនងថ្នាក់លើ-អ្នកនៅក្រោមបង្គាប់ រវាងជនជាប់ចោទ និងចារីនៃឧក្រិដ្ឋ កម្មអាចមានជាលក្ខណៈផ្លូវការផង និងមិនផ្លូវការផង ពោលគឺ *តាមផ្លូវច្បាប់ ឬតាមការជាក់ស្ដែង*[1960]។ គេត្រូវបង្ហាញថា ថ្នាក់លើមាន "ការគ្រប់គ្រងដ៏មានប្រសិទ្ធភាព" ទៅលើអ្នកនៅក្រោមបង្គាប់របស់គាត់[1961] ឬនិយាយម្យ៉ាងទៀត "លទ្ធភាពសំខាន់" ដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់[1962]។ ទំនាក់ទំនងថ្នាក់លើ-អ្នកនៅក្រោមបង្គាប់អាចដោយផ្ទាល់ ឬដោយប្រយោលនិងពុំចាំបាច់មានលក្ខណៈផ្ដាច់មុខទេ។ រាល់បុគ្គលដែលស្ថិតនៅក្នុងតួនាទីជាអ្នកបញ្ជាដែលមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់ អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានារបស់អ្នកនៅ

ក្រោមបង្គាប់ទាំងនោះ[1963]។

425. លក្ខណៈវិនិច្ឆ័យនៃការគ្រប់គ្រងដ៏មានប្រសិទ្ធភាព មានលក្ខណៈដូចគ្នាចំពោះថ្នាក់លើនៅក្នុងជួរយោធា និងនៅក្នុងជួរស៊ីវិល[1964]។ នៅពេលការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវបានយកមកអនុវត្តចំពោះជនស៊ីវិលណាម្នាក់ ពុំតម្រូវថា ការគ្រប់គ្រងដែលថ្នាក់លើយកមកប្រើ មានលក្ខណៈដូចគ្នានឹងការគ្រប់គ្រងដែលមេបញ្ជាការយោធាយកមកប្រើទេ គឺត្រឹមតែតម្រូវឱ្យមានកម្រិតដូចគ្នាប៉ុណ្ណោះ[1965]។ ទោះជាយ៉ាងណាក្ដី ភ័ស្ដុតាងដែលថា ថ្នាក់លើ*តាមការជាក់ស្ដែង*នៅក្នុងជួរស៊ីវិលបានប្រើប្រាស់ការគ្រប់គ្រងតាមបែបយោធា ឬមានទម្រង់ស្រដៀងគ្នាទៅនឹងការគ្រប់គ្រងដែលអាជ្ញាធរ*តាមផ្លូវច្បាប់*បានប្រើប្រាស់ អាចធ្វើការសន្និដ្ឋានថា គាត់បានប្រើប្រាស់ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពនៅក្នុងកម្រិតចាំបាច់មួយ កាន់តែមានភាពរឹងមាំ[1966]។

426. សូចនាករអំពីការគ្រប់គ្រងដ៏មានប្រសិទ្ធភាពគឺជាបញ្ហាអង្គហេតុ ពុំមែនជាបញ្ហាអង្គច្បាប់ទេ ហើយគួរយកមកវាយតម្លៃទៅតាមករណីជាក់ស្ដែងនីមួយៗ[1967]។ កត្តានានាដែលនឹងបង្ហាញថា ជនជាប់ចោទបានប្រើប្រាស់ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់ រួមមាន៖ ប្រភេទនៃតួនាទីរបស់ជនជាប់ចោទ រួមមានតួនាទីរបស់បុគ្គលនោះនៅក្នុងរចនាសម្ព័ន្ធយោធា ឬនយោបាយ[1968] នីតិវិធីសម្រាប់តែងតាំង និងកិច្ចការជាក់ស្ដែងដែលបានអនុវត្ត[1969] សមត្ថភាពរបស់ជនជាប់ចោទក្នុងការចេញបញ្ជា និងទោះបីជាបញ្ជានោះពិតជាត្រូវបានអនុវត្ត ឬមិនបានអនុវត្តក្ដី[1970] ស្ថានភាពដែលអ្នកនៅក្រោមបង្គាប់បង្ហាញអំពីការគោរពវិន័យម៉ឺងម៉ាត់នៅពេលមានវត្តមានរបស់ជនជាប់ចោទ[1971] អំណាចក្នុងការប្រើប្រាស់វិធានការវិន័យ[1972] និងអំណាចដោះលែង ឬផ្ទេរអ្នកទោស[1973]។ ទស្សនៈនៃលទ្ធភាពសំខាន់ក៏ត្រូវពិចារណាដល់កត្តាទាំងអស់ដែលអាចបង្កជាឧបសគ្គដល់សមត្ថភាពរបស់ថ្នាក់ដឹកនាំក្នុងការទប់ស្កាត់ និងដាក់ទណ្ឌកម្មផងដែរ[1974]។

*បានដឹង និងមានហេតុផលដឹង*

427. ពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការដឹង ពាក្យថា “បានដឹង” សំដៅដល់ការដឹងជាក់ស្ដែងថា ឧក្រិដ្ឋកម្មពាក់ព័ន្ធត្រូវបានប្រព្រឹត្ត ឬបម្រុងនឹងប្រព្រឹត្ត ដែលអាចបង្ហាញបានតាមរយៈភ័ស្ដុតាងផ្ទាល់ ឬភ័ស្ដុតាងប្រយោល[1975]។ ថ្នាក់លើត្រូវតែដឹងថា អ្នកនៅក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ

ហើយមិនមែនគ្រាន់តែដឹងអំពីការកើតឡើងនូវឧក្រិដ្ឋកម្មប៉ុណ្ណោះទេ[1976]។ ថ្នាក់លើពុំចាំបាច់ដឹងពីអត្តសញ្ញាណច្បាស់លាស់របស់អ្នកនៅក្រោមបង្គាប់ដែលប្រព្រឹត្តឧក្រិដ្ឋកម្មទេ[1977] ទោះបីត្រូវបង្ហាញពីអត្ថិភាពរបស់អ្នកនៅក្រោមបង្គាប់ទាំងនោះក៏ដោយ[1978]។

428. លក្ខណៈវិនិច្ឆ័យចំពោះ "ហេតុផលដឹង" តម្រូវថា ថ្នាក់លើបានទទួលព័ត៌មានទូទៅដែលគាត់រកបានតាមរយៈការជូនដំណឹងមកគាត់អំពីលទ្ធភាពនៃអំពើមិនស្របច្បាប់របស់អ្នកនៅក្រោមបង្គាប់ខ្លួន[1979]។ បទដ្ឋាននេះត្រូវបានបំពេញ ប្រសិនបើមានព័ត៌មានដែលតម្រូវឱ្យធ្វើការស៊ើបអង្កេតបន្ថែមទៀត[1980]។ ពុំតម្រូវថា ត្រូវតែមាន "លទ្ធភាពចម្បង" ឬ "ហានិភ័យច្បាស់លាស់ និងជាក់ស្ដែង" ដោយសារឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនោះទេ[1981]។ បទដ្ឋាន "ហេតុផលដឹង" នេះ មិនកំណត់កាតព្វកិច្ចក្នុងការទទួលព័ត៌មានទេ វាពុំដូចពាក្យថា "គួរបានដឹង" ពោលគឺ បទដ្ឋាននៃការធ្វេសប្រហែលទេ។ ថ្នាក់លើមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការខកខានមិនបានស្វែងរកព័ត៌មានពាក់ព័ន្ធទេ[1982]។ ទោះជាយ៉ាងណាក្ដី ការទទួលខុសត្រូវព្រហ្មទណ្ឌនឹងត្រូវធ្លាក់ទៅលើជនជាប់ចោទដែល*ព្យាយាម*មិនព្រមទទួលព័ត៌មានពាក់ព័ន្ធ[1983]។

429. ព័ត៌មានដែលទទួលបាន អាចជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ ពុំមានតម្រូវឱ្យបំពេញតាមទម្រង់បែបបទរបាយការណ៍ជាក់លាក់ ដែលដាក់ទៅតាមប្រព័ន្ធតាមដានណាមួយទេ[1984] ហើយក៏ពុំតម្រូវឱ្យផ្ដល់ព័ត៌មានជាក់លាក់អំពីអំពើខុសច្បាប់ដែលបានប្រព្រឹត្ត ឬបម្រុងនឹងប្រព្រឹត្តដែរ[1985]។ ក្នុងគោលបំណងដើម្បីបង្ហាញថា ព័ត៌មានស្ថិតក្នុងដៃថ្នាក់លើ ពុំចាំបាច់ត្រូវបង្ហាញថា គាត់ពិតជាបានដឹងច្បាស់នូវព័ត៌មាននោះទេ ត្រឹមតែតម្រូវថា គាត់បានទទួលព័ត៌មាននោះ ឬគាត់អាចរកបាន ជាការគ្រប់គ្រាន់ហើយ[1986]។ តួនាទីរបស់ជនជាប់ចោទជាអ្នកបញ្ជាអាចជាកត្តាមួយបង្ហាញថា គាត់បានដឹងឧក្រិដ្ឋកម្មដែលអ្នកនៅក្រោមបង្គាប់គាត់បានប្រព្រឹត្ត[1987]។

430. ថ្នាក់លើពុំចាំបាច់បង្ហាញពីចេតនាឧក្រិដ្ឋ ដូចអ្នកនៅក្រោមបង្គាប់គាត់ទេ[1988]។

### *មិនបានបង្ការ ឬដាក់ទណ្ឌកម្ម*

431. តួនាទីរបស់ថ្នាក់លើត្រូវបានយកមកប្រើ នៅពេលគាត់បានចាត់វិធានការ "ចាំបាច់ និងសមស្រប" ដើម្បីបង្ការឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មអ្នកនៅក្រោមបង្គាប់ណាម្នាក់ចំពោះការប្រព្រឹត្ត ឧក្រិដ្ឋកម្ម នៅក្នុងបរិបទនៃស្ថានភាពជាក់លាក់ណាមួយ។ ហេតុនេះ ការទទួលខុសត្រូវកើតឡើងនៅពេលគាត់ពុំបានធ្វើ

ដូច្នេះ[1989]។ ពុំតម្រូវឲ្យមានអត្ថិភាពនៃកាតព្វកិច្ចផ្លូវច្បាប់ដោយឡែកដើម្បីចាត់វិធានការទៅតាមច្បាប់ជាតិទេ[1990]។ កាតព្វកិច្ចក្នុងការបង្ការ និងដាក់ទណ្ឌកម្មមានភាពខុសៗគ្នា និងតម្រូវឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នា។ កាតព្វកិច្ចក្នុងការបង្ការឧក្រិដ្ឋកម្មកើតមានមុនការប្រព្រឹត្ត នៅពេលថ្នាក់លើបានដឹង ឬមានហេតុផលដឹងថាបម្រុងប្រព្រឹត្តឧក្រិដ្ឋកម្ម ចំណែកការទទួលខុសត្រូវលើការដាក់ទណ្ឌកម្មចំពោះចារីកើតឡើងក្រោយពេលប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយវានឹងមានលក្ខណៈពេញលេញបានតែក្នុងករណីដែលថ្នាក់លើមិនបានដឹងពីឧក្រិដ្ឋកម្ម រហូតមានការប្រព្រឹត្តិរួចហើយប៉ុណ្ណោះ[1991]។ ថ្នាក់លើអាចទទួលខុសត្រូវចំពោះការខកខានរបស់គាត់ដែលមិនបានដាក់ទណ្ឌកម្មដល់អ្នកនៅក្រោមបង្គាប់ណាម្នាក់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម មុនពេលថ្នាក់លើមានការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់នោះ[1992]។ ការពុំបានបង្ការ ឬដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មអាចសន្និដ្ឋានពីកត្តានានាដូចជាភាពជាបន្ត ឬលក្ខណៈទូលំទូលាយនៃការរំលោភបំពានដែលអ្នកនៅក្រោមបង្គាប់បានប្រព្រឹត្ត[1993]។ ពុំចាំបាច់បង្ហាញពីទំនាក់ទំនងហេតុ និងបច្ច័យរវាងការខកខានរបស់ថ្នាក់លើក្នុងការបង្ការឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ខ្លួន និងការកើតឡើងនូវឧក្រិដ្ឋកម្មទាំងនោះទេ[1994]។

432. វិធានការ "ចាំបាច់" គឺជាវិធានការទាំងឡាយដែលសមស្របសម្រាប់ថ្នាក់លើអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយបង្ហាញថា គាត់ពិតជាបានព្យាយាមបង្ការ ឬដាក់ទណ្ឌកម្ម ហើយវិធានការ "សមស្រប" គឺជាវិធានការទាំងឡាយណាដែលស្ថិតនៅក្នុងអំណាចជាក់ស្តែងរបស់ថ្នាក់លើ ពោលគឺ វិធានការដែលគាត់អាចធ្វើបាន។ ការកំណត់ថាជាវិធានការចាំបាច់ និងសមស្រប ត្រូវតែធ្វើឡើងដោយផ្អែកតាមករណីជាក់ស្តែងនីមួយៗ[1995]។ ការកំណត់ថាវិធានការអ្វីមួយដែលអាចធ្វើបានជាក់ស្តែង ក្នុងន័យនៃការបំពេញទៅតាមតួនាទី ត្រូវបានវាយតម្លៃនូវកម្រិតនៃការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់ថ្នាក់លើមកវាយតម្លៃ[1996]។ អត្ថិភាពនៃស្ថានភាពវិបត្តិមួយមិនអាចឲ្យថ្នាក់លើរួចផុតពីតួនាទីរបស់ខ្លួនទេ[1997]។

433. តួនាទីរបស់ថ្នាក់លើក្នុងការដាក់ទណ្ឌកម្មចារីនៃឧក្រិដ្ឋកម្ម រួមមាន យ៉ាងហោចណាស់កាតព្វកិច្ចក្នុងការស៊ើបអង្កេតលើឧក្រិដ្ឋដែលអាចមាន ដើម្បីបង្ហាញអង្គហេតុ និងការដាក់ទណ្ឌកម្មដល់ចារីដោយផ្ទាល់ផង ឬរាយការណ៍ពីចារីនោះទៅអាជ្ញាធរមានសមត្ថកិច្ចផង ក្នុងករណីសមស្រប[1998]។ ទោះជាយ៉ាងណាក្តី ការណ៍ដែលគ្រាន់តែរាយការណ៍ពីឧក្រិដ្ឋកម្មក៏នឹងមានលក្ខណៈគ្រប់គ្រាន់ដែរ ប្រសិនបើការរាយការណ៍នេះ ហាក់ដូចជាជំរុញឲ្យមានការស៊ើបអង្កេត ឬផ្តួចផ្តើមឲ្យមានដំណើរការផ្នែកវិន័យ ឬដំណើរការនីតិវិធីព្រហ្មទណ្ឌ[1999]។ ប្រសិនបើថ្នាក់លើដឹងថា អាជ្ញាធរមានសមត្ថកិច្ចមិនដំណើរការ ឬថាការរាយ

ការណ៍ហាក់ដូចជាជំរុញឲ្យមានការស៊ើបអង្កេតក្លែងក្លាយ ការរាយការណ៍នេះនឹងមិនគ្រប់គ្រាន់ដើម្បីកំណត់ថា ខ្លួនបានបំពេញកាតព្វកិច្ចក្នុងការដាក់ទណ្ឌកម្មដល់អ្នកនៅក្រោមបង្គាប់ដែលបានប្រព្រឹត្តខុសនោះទេ[2000]។ តួនាទីក្នុងការដាក់ទណ្ឌកម្មមិនត្រូវបានបំពេញទេ នៅពេលដែលមេបញ្ជាការសំអាងទៅលើការធានាដែលគាត់បានដឹងថា នឹងមិនយកមកអនុវត្ត ឬមិនត្រូវបានយកមកអនុវត្ត[2001]។

# គ. យុត្តាធិការបុគ្គល

## "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"

434. ទាំងកិច្ចព្រមព្រៀង អ.វ.ត.ក[2002] និងច្បាប់ អ.វ.ត.ក[2003] ចែងថា គោលបំណងនៃការបង្កើតតុលាការនេះគឺ "ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការនៃ អ.វ.ត.ក ដែលបានប្រព្រឹត្តឡើងចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

435. ពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ពុំមានកំណត់និយមន័យបន្ថែមនៅក្នុងច្បាប់ ឬ កិច្ចព្រមព្រៀងនៃ អ.វ.ត.ក នោះឡើយ។ យោងតាមការវិភាគលម្អិតលើការងាររៀបចំ និងប្រវត្តិចរចាកិច្ចព្រមព្រៀងនៃ អ.វ.ត.ក[2004] អ.ជ.ត.ក នៅក្នុងរឿងក្តី *ឌុច* បានសម្រេចថា អ.វ.ត.ក មានយុត្តាធិការបុគ្គលចំពោះតែកម្មាភិបាលខ្មែរក្រហម[2005] ហើយពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" បានចែងកំណត់កម្មាភិបាលខ្មែរក្រហមជាពីរប្រភេទដោយឡែកពីគ្នា៖

> ប្រភេទទីមួយ គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនជាជនសង្ស័យដោយផ្អែកតែទៅលើតួនាទីជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ។ ប្រភេទមួយផ្សេងទៀត គឺអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែ ជាអ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ[2006]។
>
> អាស្រ័យហេតុនេះ ប្រសិនបើជនត្រូវចោទគឺជាកម្មាភិបាលខ្មែរក្រហម ជនត្រូវចោទពុំចាំបាច់ជាមេដឹកនាំជាន់ខ្ពស់ដើម្បីស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ។

436. ស.ច.ស.អ បានសម្រេចថា សំអាងហេតុថាតើជនត្រូវចោទគឺជា "មេដឹកនាំជាន់ខ្ពស់" និង/ឬ កម្មាភិបាលខ្មែរក្រហម "ដែលទទួលខុសត្រូវខ្ពស់បំផុត" ម្នាក់នោះ "គឺត្រូវធ្វើឡើងនៅពេលបិទកិច្ចស៊ើបសួរដោយផ្អែកលើភស្តុតាងសរុបនៅក្នុងសំណុំរឿង"[2007]។

<u>ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត</u>

437. ដើម្បីកំណត់ថាតើបុគ្គលម្នាក់ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មអន្តរជាតិ, អ.វ.ត.ក និងតុលាការ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនានាបានអនុវត្តតាមលក្ខណៈវិនិច្ឆ័យចំនួនពីរបែប៖ (i) ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើបុគ្គល និង (ii) កម្រិតនៃការទទួលខុសត្រូវរបស់បុគ្គល ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។

438. យោងតាមយុទ្ធសាស្ត្របញ្ចប់ការងារមួយផ្នែករបស់តុលាការនេះ តុលាការ ICTY ត្រូវបានផ្តល់យុត្តាធិការឲ្យផ្តោតលើ "មេដឹកនាំជាន់ខ្ពស់បំផុតដែលត្រូវបានសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[2008] នៅពេលពេលបញ្ជូនចារីដែលនៅសេសសល់ទៅធ្វើការជំនុំជម្រះនៅថ្នាក់ជាតិ[2009]។ នៅពេលវាយតម្លៃលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ក្រុមប្រឹក្សាជំនុំជម្រះទទួលបន្ទុកបង្វិលរឿងក្តីនៃតុលាការ ICTY បានពិចារណាលើ "ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់" ហើយនឹង "កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ"[2010]។ គោលការណ៍ពីរនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសម្រេចរបស់តុលាការ SCSL[2011] និងសេចក្តីថ្លែងការណ៍របស់ស្ថាប័នអយ្យការនៃតុលាការ ICC ("ស្ថាប័នអយ្យការនៃតុលាការ ICC") [2012] ហើយត្រូវបានអង្គជំនុំជម្រះសាលាដំបូង[2013] អ.ជ.ត.ក[2014] និង ស.ច.ស[2015] នៃ អ.វ.ត.ក យកមកអនុវត្តតាម។ ការអនុវត្តគោលការណ៍ទាំងពីរនេះពុំទាមទារឲ្យធ្វើការប្រៀបធៀប និងកំណត់ឋានៈនៃការទទួលខុសត្រូវរបស់ជនទាំងអស់ដែលអាចជាចារីនោះទេ[2016]។ ក៏ប៉ុន្តែ តុលាការគួរពិនិត្យពិចារណាលើរឿងក្តីទាំងឡាយដែលត្រូវបានវិនិច្ឆ័យដោយតុលាការនេះ និងកាលៈទេសៈ ព្រមទាំងបរិបទជាក់លាក់ដែលឧក្រិដ្ឋកម្មទាំងឡាយត្រូវបានប្រព្រឹត្តឡើង[2017]។

439. កត្តាពាក់ព័ន្ធនានាចំពោះការកំណត់ស្ថានទម្ងន់នៃបទល្មើសដែលត្រូវបានប្រព្រឹត្តឡើងរួមមាន៖ វិសាលភាពភូមិសាស្ត្រ និងវិសាលភាពពេលវេលានៃឧក្រិដ្ឋកម្ម[2018] វិធីដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង[2019] និងចំនួនហេតុការណ៍[2020] និងចំនួនជនរងគ្រោះ[2021]។ ការវាយតម្លៃលើកត្តាទាំងនេះពុំគួរចាត់ទុកជាការ

គណនាដ៏តឹងរ៉ឹងតាមរូបភាពគណិតវិទ្យានោះទេ។ ក៏ប៉ុន្តែ វាតម្រូវឲ្យមានការវិភាគលើភាពញឹកញាប់ខុសៗគ្នា[2022]។

440. កត្តាពាក់ព័ន្ធនានាចំពោះការកំណត់កម្រិតនៃការទទួលខុសត្រូវលើបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មរួមមាន៖ កម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[2023] ឋានៈ ឬ តួនាទីទៅតាមឋានានុក្រមរបស់ជនជាប់ចោទ[2024] រួមទាំងចំនួនបុគ្គលិកក្រោមបង្គាប់ និងថ្នាក់លើ[2025] សិទ្ធិអំណាចប្រកបដោយប្រសិទ្ធភាពរបស់ពួកគេ[2026] និងលទ្ធភាពក្នុងការចេញបញ្ជា[2027] វិសាលភាពពេលវេលានៃការគ្រប់គ្រងរបស់ពួកគេ[2028] សិទ្ធិអំណាចរបស់ពួកគេក្នុងការចរចា ចុះហត្ថលេខា ឬ អនុវត្តកិច្ចព្រមព្រៀង[2029] ការដឹងឮជាក់ស្តែងអំពីឧក្រិដ្ឋកម្ម និងករណីថាតើបុគ្គលទាំងឡាយដែលស្ថិតនៅក្នុងឋានៈខ្ពស់ៗជាងនោះត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពរួចហើយឬនៅ[2030]។

<u>មេដឹកនាំជាន់ខ្ពស់</u>

441. ចំពោះពាក្យ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ប្រវត្តិបង្កើតច្បាប់ អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិបង្ហាញថា ពាក្យនេះពុំកម្រិតត្រឹមសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក[2031] ឬ "ស្ថាបនិកនៃគោលនយោបាយរួម" នោះទេ[2032]។ ទោះបីជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាយល់ឃើញថា អត្ថន័យត្រង់នៃពាក្យនេះបង្ហាញថា ពាក្យនេះគ្របដណ្តប់រួមលើគ្រប់បុគ្គលមួយចំនួនតូចនៅថ្នាក់ខ្ពស់បំផុតនៃឋានានុក្រមនយោបាយ ឬ យោធានៃ ប.ក.ក និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

# IV. ការកំណត់បទចោទ

## ក. ឧក្រិដ្ឋកម្ម

### *ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*

442. ភ័ស្តុតាងនៅលើសំណុំរឿង និងដែលបានយោងទៅលើនៅក្នុងផ្នែកអង្គហេតុសម្អារៈ បង្ហាញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលអាចផ្តន្ទាទោសបានតាមមាត្រា៥ នៃច្បាប់ អវតក ត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការរៀបរាប់សង្ខេបអំពីអង្គហេតុនានាដែលបង្កើតធាតុផ្សំយុត្តាធិការចាំបាច់ និងឧក្រិដ្ឋកម្មជាក់លាក់ មានបង្ហាញខាងក្រោម។

### ធាតុផ្សំយុត្តាធិការនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

<u>ការវាយប្រហារប្រឆាំងជនស៊ីវិល</u>

443. បទល្មើសដែលរៀបរាប់លម្អិតនៅខាងក្នុងនេះគឺជាផ្នែកមួយនៃការវាយប្រហារពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើននៅក្នុងប្រព័ន្ធមួយនៃការគាបសង្កត់ដែលត្រូវបានរៀបចំឡើង។ អំពើទាំងនេះបានកើតឡើងក្រោយពេលដែល បកក បានដណ្តើមអំណាចដ៏ហិង្សា និងបានដាក់ឲ្យអនុវត្តនូវរបបផ្តាច់ការមួយដែលរួមមាន (i) ការជម្លៀសមនុស្សដោយបង្ខំចេញពីទីប្រជុំជនក្រុង (ii) ការធ្វើឲ្យទៅជាទាសករមនុស្សនៅក្នុងសហករណ៍ និង ការដ្ឋាននានាដែលត្រូវបានបង្កើតឡើងដោយ បកក (iii) ការធ្វើការដោយបង្ខំជាទ្រង់ទ្រាយធំ (iv) ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (v) ការបំបិទសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងការរឹបអូសយកកម្មសិទ្ធ និង (vi) ការអនុវត្តទម្រង់ទាំងឡាយនៃការគាបសង្កត់ទាំងអស់នេះតាមរយៈការចាប់ខ្លួនដោយខុសច្បាប់ ការដាក់ក្នុងបមន្ទីរឃុំឃាំង និងអំពើមនុស្សឃាត។ ការវាយប្រហារទាំងអស់នេះបានផ្តោតជាចំបងទៅលើជនស៊ីវិលទាំងមូលនៅប្រទេសកម្ពុជា ដោយរួមទាំងក្រុមជាតិពន្ធុ និងសាសនាផងដែរ។

## លក្ខណៈរីករាលដាល និងជាប្រព័ន្ធ

444. ការវាយប្រហាមានលក្ខណៈរីករាលដាល និងជាប្រព័ន្ធ។ វាមានលក្ខណៈរីករាលដាលដោយយោងទៅលើលក្ខណៈទ្រង់ទ្រាយធំរបស់វា រយៈពេលដ៏យូរ តំបន់ភូមិសាស្ត្រដែលវាបានកើតឡើង និងចំនួនជនរងគ្រោះដ៏ច្រើនដែលវាបានផ្តោតការវាយប្រហារលើ។ ការវាយប្រហារបានផ្តោតភាគច្រើនទៅលើជនស៊ីវិលរបស់ប្រទេសនេះនៅទូទាំងទឹកដីនៃប្រទេសកម្ពុជាទាំងមូល និងមានរយៈពេលជាងបីឆ្នាំ និងប្រាំបីខែ[2033]។ ជនស៊ីវិលជាងពីរលាននាក់ត្រូវបានផ្លាស់ទីលំនៅដោយបង្ខំចេញពីទីប្រជុំជនក្រុង ហើយប្រជាជនរាប់មិនអស់ត្រូវបានធ្វើឲ្យទៅជាទាសករនៅតាមសហករណ៍ និងការដ្ឋាននានា[2034]។ បកក បានបង្កើតមន្ទីរសន្តិសុខប្រមាណជាង ២៦០ ដោយបង្កើតបានជាផ្នែកដ៏សំខាន់មួយនៃការវាយប្រហារលើប្រជាជនស៊ីវិលកម្ពុជា[2035]។ មនុស្សរាប់រយពាន់នាក់ត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់នៅក្នុងមន្ទីរសន្តិសុខទាំងនេះ និងទីតាំងផ្សេងៗទៀត។ ចំនួនមនុស្សស្លាប់សរុបដែលបណ្តាលមកពីការវាយប្រហារនេះត្រូវបានគេប៉ាន់ប្រមាណថាមានចំនួនចន្លោះពី ១,៧ ទៅ ២,២ លាននាក់[2036]។

445. ការវាយប្រហារលើប្រជាជនស៊ីវិលក៏មានលក្ខណៈជាប្រពន្ធ័ផងដែរ។ គណៈអចិន្ត្រៃយ៍ បកក បានបង្កើតគោលនយោបាយបែបមជ្ឈការ ដោយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ការចេញសេចក្តីណែនាំសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ និងបានទទួលរបាយការណ៍ជាប្រចាំពីគ្រប់ថ្នាក់ដឹកនាំទាំងអស់របស់ បកក អំពីការអនុវត្តគោលនយោបាយនានានៅនឹងកន្លែង។

## មូលហេតុនៃការរើសអើង

446. ការវាយប្រហារទាំងនោះបានផ្អែកលើមូលហេតុរើសអើង មានដូចជា មូលហេតុនយោបាយ សាសនា និង/ឬជាតិពន្ធុ។ បកក បានដាក់ចេញនូវ *ជាអាទិ៍* បដិវត្តនយោបាយ និងបានទប់ស្កាត់ការប្រឆាំងណាមួយ។ ជនស៊ីវិលទាំងអស់ត្រូវបានចាត់ទុកថាជាខ្មាំងពិតប្រាកដ ឬខ្មាំងសក្តានុពល និងដោយឡែកៗពីគ្នានោះ ត្រូវស្ថិតក្រោមការអប់រំនយោបាយ ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើមនុស្សឃាត។ ការណ៍នេះរួមមានសមាជិកអតីតរបប លន់ នល់ កម្មាភិបាលនៅក្នុងជួរ បបក ដែលស្ថិតនៅក្នុងការសង្ស័យ អ្នកដែលត្រូវបានចាត់ថ្នាក់ថាជា "គិញ" របស់រដ្ឋាភិបាលបរទេស និង "ប្រជាជនថ្មី" ឬ "ប្រជាជន១៧ មេសា" ដែល បកក ចាត់ទុកថាបានប្រឆាំងនឹងបដិវត្តន៍។ បកក បានប្រើផែនការនានា

ដូចជា មនោគមន៍វិជ្ជានយោបាយ វគ្គសិក្សា ការលត់ដំ និងការប្រុងប្រយ័ត្នជាប្រចាំដើម្បីកំណត់អត្តសញ្ញាណអ្នកទាំងឡាយណាដែលត្រូវបានសង្ស័យថាមិនបានគោរពតាម ឬ ខ្វះភាពស្មោះត្រង់។

447. ការវាយប្រហារនោះក៏ផ្អែកផងដែរទៅលើមូលហេតុសាសនា ដោយវាបានពាក់ព័ន្ធ *ជាអាទិ៍* ទៅនឹងការលុបបំបាត់ និងការគាបសង្កត់សាសនា ការផ្លាស់ប្តូរដោយបង្ខំ និងការបំផ្លិចបំផ្លាយទ្រព្យសម្បត្តិសាសនា។ លើសនេះទៀត ការវាយប្រហារនោះផ្អែកលើមូលហេតុជាតិពន្ធុ ដោយពាក់ព័ន្ធ*ជាអាទិ៍*ទៅនឹងការធ្វើទុក្ខបុកម្នេញ និងការបំផ្លិចបំផ្លាយជនជាតិភាគតិច ដូចជា ចាម ខ្មែរក្រោម និងវៀតណាម។

*<u>ការដឹងឮរបស់ អ៊ឹម ចែម អំពីការវាយប្រហារ</u>*

448. **អ៊ឹម ចែម** និង ចារីផ្សេងទៀត បានដឹងឮអំពីការវាយប្រហារប្រឆាំងនឹងជនស៊ីវិល និងបានដឹងថាអំពើរបស់ពួកគេបានបង្កើតបានជាផ្នែកមួយនៃការវាយប្រហារនោះ។ **អ៊ឹម ចែម** បានចូលរួមក្នុងការផ្សព្វផ្សាយគោលនយោបាយនានា ដែលការវាយប្រហារនោះត្រូវអនុវត្តតាម។ គាត់បានត្រួតពិនិត្យការអនុវត្តគោលនយោបាយទាំងនេះ ទាំងនៅថ្នាក់ស្រុក និងថ្នាក់តំបន់ និងបានចូលរួមចំណែកក្នុងគោលនយោបាយទាំងនោះតាមវិធីជាច្រើន ដូចជា ការចេញបញ្ជា និងការណែនាំឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មស្របតាមគោលនយោបាយរបស់ បកក បានញុះញង់ និងជំរុញទឹកចិត្តឲ្យមានឧក្រិដ្ឋកម្មនៅក្នុងការវាយប្រហារនោះ បានកាន់អំណាច និងបានត្រួតពិនិត្យលើចារីផ្ទាល់ និងបានទទួលរបាយការណ៍អំពីឧក្រិដ្ឋកម្មទាំងនោះ[2037]។

## ឧក្រិដ្ឋកម្មជាក់លាក់

449. ភស្តុតាងនៅលើសំណុំរឿងបង្ហាញថា អំពើនានាបានបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា ៥ នៃច្បាប់ អវតក នោះ ត្រូវបានប្រព្រឹត្តឡើងដោយកម្មាភិបាល/យោធា/ឈ្លប របស់ បកក ចាប់ពីឆ្នាំ១៩៧៦-១៩៧៩ នៅតាមទីតាំងជាច្រើននៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និង តំបន់ ៥ នៃភូមិភាគពាយ័ព្យ។

450. កម្មាភិបាល/យោធា/ឈ្លប បកក ទាំងអស់នេះបានប្រព្រឹត្តក្រោមអំណាច និងការគ្រប់គ្រងរបស់ **អ៊ឹម ចែម** ដោយផ្ទាល់ និង/ឬ ដោយប្រយោល ឬដោយឈរលើមូដ្ឋានៃឥទ្ធិពល ការលើកទឹកចិត្ត ឬ ជំនួយរបស់

គាត់។

451. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងនោះមាន៖ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ ការបាត់ខ្លួនដោយបង្ខំ និងការឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌។

<u>អំពើមនុស្សឃាត</u>

**អំពើកម្ម និងអកម្ម**

452. **អ៊ឹម ចែម** តាមរយៈអំពើកម្ម និង អកម្មរបស់គាត់ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្លាប់ជនស៊ីវិលរាប់មិនអស់នៅតាមការដ្ឋាន តាមមន្ទីរសន្តិសុខ ក្នុងអំឡុងពេលបោសសម្អាត និងតាមរយៈការផ្តោតគោលដៅលើក្រុមជាតិពន្ធុ។

453. មនុស្សរាប់ពាន់នាក់ដែលបានធ្វើឱ្យទៅជាទាសករនៅតាមសហករណ៍នានានៅក្នុងតំបន់ ១៣ ក្នុងភូមិភាគនិរតី និងតំបន់ ៥ ក្នុងភូមិភាគពាយ័ព្យ និងទីតាំងធ្វើការដោយបង្ខំទាំងឡាយនៅក្នុងតំបន់ទាំងពីរ បានស្លាប់ដោយការសម្លាប់ និងលក្ខខណ្ឌអមនុស្សធម៌។ កម្មករនៅការដ្ឋានត្រពាំងថ្ម[2038] ស្ពានស្រែង[2039] និងភ្នំត្រយោង[2040] ត្រូវបានសម្លាប់នៅតាមទីតាំងទាំងនោះ ឬ ត្រូវបានយកទៅសម្លាប់នៅទីតាំងផ្សេងៗទៀត[2041]។ អ្នកដែលស្ថិតនៅកន្លែងធ្វើការដោយបង្ខំត្រូវបានចុចយក និង សម្លាប់ចោល ដោយសារមូលហេតុផ្សេងៗ រួមមាន៖ ស្ថិតនៅក្នុង ឬត្រូវបានសន្មតថាស្ថិតនៅក្នុងក្រុមដែលត្រូវបានកំណត់គោលដៅដូចជា "ប្រជាជនថ្មី"[2042] មន្ត្រីរបប លន់ នល់[2043] ឬ ជនជាតិវៀតណាម[2044] ដែលមានបំណងរត់គេច[2045] ដែលបានប្រព្រឹត្ត "កំហុស" ឬ បានធ្វើឱ្យខូចឧបករណ៍ប្រើប្រាស់[2046] ដែលត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងជាមួយនឹង សេ អ៊ី អា ឬ ប្រទេសវៀតណាម[2047] ដែលត្រូវគេជឿថាមានបញ្ហាសីលធម៌[2048] និងដែលត្រូវបានគេចោទថាខ្ជិលធ្វើការ[2049] ឈឺ[2050] ឬ លួចម្ហូបអាហារ[2051]។ មនុស្សរាប់មិនអស់ផ្សេងទៀតបានស្លាប់ ដោយសារតែការងារហួសកម្លាំង[2052] ការបង្អត់អាហារ[2053] និងជំងឺ[2054]។ ការស្លាប់ទាំងអស់នេះគឺជាលទ្ធផលផ្ទាល់មកពីលក្ខខណ្ឌនានាដែលបានដាក់ចេញដោយ **អ៊ឹម ចែម** និងកម្មាភិបាល បកក ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។

454. មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខរបស់ បកក នៅវត្តអង្គសិរីមាលី[2055] ភ្នំត្រយោង[2056] ភូមិចក្រី[2057] និងវត្តព្រះនេត្រព្រះ[2058]។ មន្ទីរសន្តិសុខទាំងនេះមានតំបន់មួយចំនួននៅជាប់ ឬនៅក្បែរ ទីកន្លែងដែលអ្នកទោសត្រូវបានយកទៅសម្លាប់ ដូចជា ព្រៃសុខុន[2059] ចំការតាឡឹង[2060] និងព្រៃតារុធ[2061]។ អ្នកជាប់ឃុំជាធម្មតាត្រូវបានសម្លាប់ដោយឧបករណ៍ទាល និងដាក់ចូលទៅក្នុងរណ្តៅ[2062]។ កូនក្មេងក៏ត្រូវបានសម្លាប់ផងដែរ រួមមានអ្នកខ្លះត្រូវគេបោកទៅនឹងដើមឈើនៅភូមិចក្រី[2063]។ មានភស្តុតាងនៃការសម្លាប់ដ៏ឃោរឃៅផ្សេងទៀតនៅក្នុងសំណុំរឿង ដូចជា ការរំលោភសេពសន្ថវៈ និងការធ្វើឲ្យមានរបួសលើរាងកាយស្ត្រីនៅក្នុងស្រុកព្រះនេត្រព្រះ[2064]។

455. ការបោសសម្អាតនៅតំបន់ ៥ ដែលដឹកនាំដោយ **អ៊ឹម ចែម** បាននាំឲ្យមានការស្លាប់កម្មាភិបាលជាច្រើន។ អ្នកដែលត្រូវបានសម្លាប់រួមមាន យោធានៅគ្រប់ជាន់ថ្នាក់របស់ បកក[2065]។ បន្ថែមពីលើអ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ និងត្រូវបានសម្លាប់នៅតាមមូលដ្ឋាន មានមនុស្សជាច្រើនទៀតត្រូវបានបញ្ជូនទៅសម្លាប់នៅមន្ទីរ ស-២១[2066]។

456. ក្រុមជាតិពន្ធុមួយចំនួនធំត្រូវបានសម្លាប់នៅតាមទីតាំងក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**។ ខ្មែរក្រោមត្រូវបានសម្លាប់នៅតាមទីតាំងជាច្រើននៅក្នុងស្រុកកោះអណ្តែត[2067] ជាពិសេសនៅមន្ទីរសន្តិសុខវត្តអង្គសិរីមាលី ក្នុងភូមិភាគនិរតី[2068]។ ជនជាតិវៀតណាមត្រូវបានសម្លាប់នៅទូទាំងស្រុកព្រះនេត្រព្រះនិងតំបន់ ៥ ក្នុងភូមិភាគពាយ័ព្យ ជាពិសេសនៅមន្ទីរសន្តិសុខភ្នំត្រយោង[2069] និងចំការខ្នុរ[2070] និងការដ្ឋានត្រពាំងថ្ម[2071] និងស្ពានស្រែង[2072]។

**ចេតនា**

457. រាល់ការសម្លាប់ទាំងអស់ដែលបានរៀបរាប់ខាងលើ ត្រូវបានអនុវត្តឡើងដោយមានចេតនាសម្លាប់។ ចារីផ្ទាល់បានអនុវត្តតាមគោលនយោបាយ បកក ស្តីពីការឃុំឃាំងមនុស្សឲ្យស្ថិតនៅក្នុងទីតាំងការងារដោយបង្ខំ សហករណ៍ មន្ទីរសន្តិសុខ និងការស្វែងរក និងការសម្លាប់បុគ្គល និងក្រុម ដែលត្រូវបានកំណត់អត្តសញ្ញាណ។ គោលនយោបាយទាំងនេះត្រូវបានអនុវត្តយ៉ាងស៊ីចង្វាក់នៅទូទាំងទីតាំងនានាក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម**។ តួនាទីរបស់ **អ៊ឹម ចែម** ក្នុងការបញ្ជាឲ្យសម្លាប់ និងការណែនាំ កម្មាភិបាលអំពីគោលនយោបាយរបស់ បកក ដូចជាការផ្តោតគោលដៅលើ "ខ្មាំង"[2073] និង ការរាយការណ៍អំពីការសម្លាប់ទៅកាន់ថ្នាក់លើ ដោយរួមមាន **អ៊ឹម ចែម**[2074] ទាំងនេះបញ្ជាក់ឲ្យឃើញអំពីចេតនារបស់គាត់។

ការសម្លាប់ជនជាតិវៀតណាម ខ្មែរក្រោម និងកម្មាភិបាល បកក ក្នុងអំឡុងពេលបោសសម្អាត ក៏ត្រូវបានអនុវត្តឡើងជាប្រព័ន្ធ និងអនុលោមតាមគោលនយោបាយរបស់បក្សផងដែរ ដូចដែល **អ៊ឹម ចែម** បានផ្សព្វផ្សាយ និងអនុវត្ត[2075]។

458. ក្នុងករណីទាំងឡាយដែលមនុស្សបានស្លាប់ដោយមូលហេតុវាយដំ ឬដោយការធ្វើទារុណកម្ម និងក្នុងករណីដែលការស្លាប់របស់ពួកគេមិនបង្ហាញពីចេតនាជាក់លាក់នោះ ចារីមានចេតនាធ្វើឱ្យមានព្យសនកម្មផ្នែករាងកាយធ្ងន់ធ្ងរ ឬរបួសដែលពួកគេបានដឹងឮ ឬយ៉ាងសមហេតុសមផលគួរបានដឹងឮនោះ អាចនាំឱ្យមានការស្លាប់។ នៅក្នុងស្ថានភាពដែលការស្លាប់បណ្តាលមកពីការធ្វើការដោយបង្ខំ លក្ខខណ្ឌអមនុស្សធម៌ និងការប៉ុនប៉ងរត់គេចខ្លួន ចារីទាំងនោះ (i) បានដាក់ចេញនូវលក្ខខណ្ឌនានាដែលបណ្តាលឱ្យមានការស្លាប់ ដោយចេតនាបង្កើតឱ្យមានព្យសនកម្មផ្នែករាងកាយធ្ងន់ធ្ងរដល់ជនរងគ្រោះ ដែលពួកគេបានដឹងឮ ឬយ៉ាងសមហេតុសមផលគួរបានដឹងនោះ អាចនាំឱ្យមានការស្លាប់ ឬ (ii) បានខកខានចាត់វិធានការដើម្បីដោះស្រាយលក្ខខណ្ឌអមនុស្សធម៌ទាំងនោះ ដោយដឹងថាការស្លាប់នោះគឺជាវិបាកដែលអាចកើតចេញពីការខាកខានរបស់ខ្លួន។ ចេតនាឧក្រិដ្ឋរបស់ **អ៊ឹម ចែម** ត្រូវបានបង្កើតឡើងដោយអង្គហេតុដែលថា រូបគាត់បានរក្សាជាប្រព័ន្ធនូវលក្ខខណ្ឌនានាដែលបាននាំឱ្យមានការស្លាប់នៅទូទាំងរយៈពេលនៃការកាន់តំណែងជាច្រើនរបស់គាត់[2076]។ តាមពិតនោះ **អ៊ឹម ចែម** បានទទួលស្គាល់ថាគាត់បានដឹងឮយ៉ាងពេញលេញអំពីលក្ខខណ្ឌនានានៅក្នុងតំបន់ ៥ នៅពេលគាត់បានមកដល់ ហើយភ័ស្តុតាងថែមទាំងបង្ហាញយ៉ាងច្បាស់ថាលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌធ្វើការបានធ្លាក់ចុះដុនដាបយ៉ាងខ្លាំងនៅក្រោមការគ្រប់គ្រងរបស់គាត់[2077]។

<u>ការសម្លាប់រង្គាល</u>

***អំពើកម្ម និងអកម្ម***

459. ការស្លាប់រាប់ពាន់អ្នក នៅតាមមន្ទីរសន្តិសុខ ការដ្ឋានការងារដោយបង្ខំ ក្នុងអំឡុងពេលបោសសម្អាត និងទីកន្លែងផ្សេងទៀតនៅក្នុងតំបន់ ១៣ និងតំបន់ ៥ បង្កើតបានជាការសម្លាប់ជនស៊ីវិលក្នុងទ្រង់ទ្រាយធំ។ ការស្លាប់ទាំងអស់នេះគឺជាផ្នែកមួយនៃការវាយប្រហាលើជនស៊ីវិលក្នុងប្រទេសកម្ពុជា ដែលនៅក្នុងនោះមនុស្សម្នាក់ក្នុងចំណោមបួននាក់បានស្លាប់។ វាជាលទ្ធផលផ្ទាល់នៃគោលនយោបាយ របស់ បកក

បង្កើតឡើងជាលក្ខណៈមជ្ឈការ ដែល **អ៊ឹម ចែម** និង កម្មាភិបាល បកក បានអនុវត្ត។ ការសម្លាប់ទ្រង់ទ្រាយធំនោះ នៅតាមតំបន់ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** រួមមានការសម្លាប់រាប់ពាន់នាក់នៅមន្ទីរសន្តិសុខ វត្តអង្គសិរីមាលី[2078] ភូមិចក្រី[2079] វត្តចំការខ្នុរ[2080] វត្តព្រះនេត្រព្រះ[2081] និង ភ្នំត្រយោង[2082] និងការស្លាប់រាប់ពាន់នាក់ទៀតដោយសារការអង្គត់អាហារ ការងារហួសកម្លាំង ជំងឺ និងលក្ខខណ្ឌអមនុស្សធម៌ជាច្រើនផ្សេងទៀតនៅការដ្ឋានត្រពាំងថ្ម[2083] និងស្ពានស្រែង[2084]។ ភ័ស្តុតាងនៃការសម្លាប់ទ្រង់ទ្រាយធំទាំងនេះរួមមាន៖ (i) ការប្រើប្រាស់បញ្ជីឈ្មោះ និងប្រវត្តិរូបដើម្បីជាជំនួយដល់ការសម្លាប់[2085] (ii) លក្ខណៈជាប្រព័ន្ធនៃការសម្លាប់ដែលឲ្យអ្នកជាប់ឃុំផ្លាស់ទីទៅកាន់ទីតាំងសម្លាប់ដូចជាព្រៃសុខុន[2086] ព្រៃតារុធ[2087] និងចំការតាឡឹង[2088] ដែលជាកន្លែងរណ្តៅធំៗត្រូវបានគេជីកដើម្បីប្រើជាផ្នូរកប់សពរួម (iii) ការសម្លាប់ជាច្រើនក្នុងពេលបោសសម្អាត[2089] (iv) ការសម្លាប់ខ្មែរក្រោមជាច្រើននៅក្នុងតំបន់ ១៣ ដូចជានៅវត្តអង្គសិរីមាលី[2090] និង (v) ការសម្លាប់ដ៏ទូលំទូលាយនូវជនជាតិវៀតណាមក្នុងតំបន់ ៥ ក្នុងទីតាំងនានាដូចជា មន្ទីរសន្តិសុខភ្នំត្រយោង និងចំការខ្នុរ និងការដ្ឋានត្រពាំងថ្ម និងស្ពានស្រែង[2091]។

## ចេតនា

460. ភ័ស្តុតាងនៃកាលៈទេសៈនានាជុំវិញអំពើមនុស្សឃាតដែលមានរៀបរាប់ពិស្តារខាងលើ បង្ហាញថា ក្នុងការប្រព្រឹត្តអំពើទាំងនោះ និងក្នុងការធ្វើអំពើអកម្មដែលបានបណ្តាលឲ្យមានការស្លាប់ក្នុងចំនួនដ៏ច្រើននោះ **អ៊ឹម ចែម** និងចារីផ្សេងទៀត (i) មានចេតនាធ្វើការសម្លាប់ក្នុងទ្រង់ទ្រាយធំ និង/ឬ (ii) មានចេតនាបង្កើតលក្ខខណ្ឌនៃការរស់នៅដែលនាំឲ្យមានការស្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ – ឬមានចេតនាបង្កើតលក្ខខណ្ឌបែបនោះដោយដឹងថាពួកវាទំនងជាបណ្តាលឲ្យមានការស្លាប់មនុស្សក្នុងទ្រង់ទ្រាយធំយ៉ាងពិតប្រាកដ។

461. ភ័ស្តុតាងបង្ហាញពីចេតនាធ្វើការសម្លាប់ក្នុងទ្រង់ទ្រាយធំ រួមមានចម្លើយរបស់ **អ៊ឹម ចែម** និង ការផ្សព្វផ្សាយរបស់ **អ៊ឹម ចែម** អំពីគោលនយោបាយ បកក ដើម្បីស្វែងរក និងសម្លាប់សមាជិកក្រុមដែលត្រូវបានកំណត់គោលដៅ ដូចជា "ខ្មាំង" និងជនជាតិភាគតិច[2092] ការចុះទៅពិនិត្យ និងការធ្វើការប្រជុំដែលគាត់បានធ្វើនៅតាមតំបន់នានាដែលការសម្លាប់បានកើតមានឡើង[2093] ភាពស៊ីចង្វាក់គ្នា និងលក្ខណៈជាប្រព័ន្ធនៃការសម្លាប់[2094] ការរាយការណ៍អំពីការសម្លាប់ និងចំនួនមនុស្សដែលត្រូវបានសម្លាប់[2095]។

ជាងនេះទៀត ដូចបានកត់សម្គាល់ **អ៊ឹម ចែម** បានដឹងឮអំពីការស្លាប់ក្នុងចំនួនដ៏ច្រើនដែលបណ្តាលមកពីលក្ខខណ្ឌនានានៅក្នុងតំបន់ស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គាត់មុនពេលគាត់មកដល់ ប៉ុន្តែបានធ្វើឱ្យលក្ខខណ្ឌទាំងនោះប្រព្រឹត្តទៅក្នុងលក្ខណៈឃោរឃៅជាងមុនទៅទៀតនៅពេលគាត់កាន់អំណាច[2096]។ ដោយសារតួនាទីរបស់គាត់នៅថ្នាក់ស្រុក និងតំបន់នោះ **អ៊ឹម ចែម** បានដឹងអំពីផែនការឧក្រិដ្ឋកម្មដ៏ធំដែលរូបគាត់បានចូលរួម និងបានដឹងអំពីអង្គហេតុដែលថាជនស៊ីវិលរាប់ពាន់នាក់ត្រូវបានសម្លាប់ដោយសារតែគោលនយោបាយទាំងនោះ។

## <u>ការធ្វើឱ្យទៅជាទាសករ</u>

### អំពើកម្ម និងអកម្ម

462. ដូចបានកត់សម្គាល់ខាងលើ ឧក្រិដ្ឋកម្មជាច្រើនដែលបានប្រព្រឹត្តឡើង ក្នុងអំឡុងពេលវាយប្រហារលើជនស៊ីវិលនោះ បានបណ្តាលមកពីការធ្វើឱ្យប្រជាជនរាប់ពាន់នាក់ឱ្យទៅជាទាសករ។ តាមរយៈការអនុវត្តរបស់ **អ៊ឹម ចែម** នូវគោលនយោបាយរបស់បក្សនោះ បកក បានអនុវត្តសិទ្ធិលើកម្មសិទ្ធស្ទើតែទាំងអស់របស់ជនស៊ីវិលនៅក្នុងសហករណ៍ និង ការដ្ឋាននានា ដោយបានដាក់ពួកគេក្រោមការគ្រប់គ្រងរបស់ខ្លួនទាំងស្រុង និងស្ទើតែមិនបានអនុញ្ញាតឱ្យផ្នែកណាមួយនៃជីវិតរបស់ពួកគេមានសិទ្ធិសម្រេចដោយខ្លួនឯងឡើយ។ កម្មាភិបាល បកក បានគ្រប់គ្រងការផ្តល់ផ្ទះ[2097] អាហារ[2098] ការផ្តល់ថ្នាំពេទ្យ[2099] ពេលវេលា និងទីកន្លែងធ្វើការ[2100] ការដេក និងការសម្រាក[2101]។ ពួកគេបានហាមឃាត់ការប្រតិបត្តិទំនៀមទំលាប់[2102] ការផ្លាស់ទីដោយសេរី[2103] ការនិយាយស្តី[2104] និងការចងក្រងជាហាគមន៍[2105] និងបានដាក់កម្រិតយ៉ាងតឹងរឹងនូវទម្រង់ដែលត្រូវទទួលយកខាងអាកប្បកិរិយា 'សីលធម៌' [2106] និងបានបដិសេធសេរីភាពជាមូលដ្ឋានទាំងអស់របស់បុគ្គល[2107]។ នៅក្នុងប្រព័ន្ធនេះ ជនស៊ីវិលត្រូវស្ថិតនៅក្រោមមនោគមវិជ្ជានយោបាយ[2108] ហើយអ្នកណាដែលខកខានមិនអនុវត្តតាមវិធានគ្រប់គ្រងការធ្វើការ ឬការរៀបចំការរស់នៅរបស់ខ្លួននោះ ត្រូវបានដាក់ទណ្ឌកម្ម និង/ឬ លត់ដំ ឬត្រូវបានបញ្ជូនទៅរៀនសូត្រ[2109] ហើយក្នុងករណីជាច្រើនពួកគេត្រូវបានចាប់ខ្លួន និងសម្លាប់ចោល[2110]។ ការបង្ហាញឱ្យឃើញមួយនៃការអនុវត្តកម្មសិទ្ធិនោះគឺ គោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ បកក ដែលគូរស្រករៀបអាពាហ៍ពិពាហ៍ត្រូវបានជ្រើសរើសដោយកម្មាភិបាល បកក[2111]។

## ចេតនា

463. **អ៊ឹម ចែម** មានចេតនាអនុវត្តគោលនយោបាយមួយដែល បកក បានអនុវត្តសិទ្ធិទាំងអស់លើកម្មសិទ្ធិរបស់អ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ចេតនារបស់ពួកគេត្រូវបានបង្ហាញតាមរយៈការប្រជុំជាច្រើនដែលរូបគាត់បានធ្វើនៅក្នុងសហករណ៍ ឃុំ និង ទីតាំងការងារដោយបង្ខំដែលផ្សព្វផ្សាយបន្តនូវគោលនយោបាយនេះ[2112] ក៏ដូចជាការណែនាំរបស់គាត់ទៅកាន់ប្រជាជនឲ្យខិតខំធ្វើការ និងមិនត្រូវប្រឆាំងនឹងគោលនយោបាយរបស់អង្គការ[2113]។ **អ៊ឹម ចែម** ក៏បានដាក់ចេញនូវ ឬត្រួតពិនិត្យលើការដាក់ទណ្ឌកម្មអ្នកដែលខកខានមិនបានអនុវត្តតាមសេចក្ដីណែនាំរបស់បក្សផងដែរ[2114]។

## ការដាក់ក្នុងមន្ទីរឃុំឃាំង

## អំពើកម្ម និងអកម្ម

464. ជនរងគ្រោះរាប់ពាន់នាក់ត្រូវបានឃុំខ្លួននៅតាមមន្ទីរសន្តិសុខ សហករណ៍ ការដ្ឋានការងារដោយបង្ខំ និងទីតាំងផ្សេងៗទៀតរបស់ បកក នៅទូទាំងតំបន់ក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**។ មិនមានប្រព័ន្ធច្បាប់ដំណើរការនោះឡើយនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ហើយមនុស្សត្រូវបានដកហូតសេរីភាពរបស់ខ្លួនស្របតាមគោលនយោបាយរបស់ បកក។ ការឃុំខ្លួនត្រូវបានធ្វើឡើងតាមទំនើងចិត្ត ដោយសារវាបានកើតឡើងដោយមិនមានមូលដ្ឋានច្បាប់ណាមួយ ឬតំណើរការច្បាប់ត្រឹមត្រូវនោះឡើយ។ អ្នកដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួននោះ មិនមានលទ្ធភាពតទល់ប្រឆាំងនឹងការចាប់ខ្លួន និង/ឬ ការឃុំខ្លួននៅចំពោះមុខអំណាចតុលាការណាមួយឡើយ។

465. មនុស្សរាប់ពាន់នាក់ត្រូវបានឃុំខ្លួននៅមន្ទីរសន្និតសុខវត្តអង្គសិរីមាលី[2115] ភ្នំត្រយោង[2116] ភូមិចក្រី[2117] វត្តចំការខ្នុរ[2118] និងវត្តព្រះនេត្រព្រះ[2119] ក៏ដូចជានៅក្នុងអគារនានានៅទល់មុខកន្លែងស្នាក់នៅរបស់ **អ៊ឹម ចែម** នៅភ្នំលាប[2120]។ ហេតុផលនានាសម្រាប់ការចាប់ខ្លួន និងការឃុំខ្លួនរួមមានៈ ជាសមាជិករបប លន់ នល់[2121] ជាជនជាតិវៀតណាម[2122] ធ្លាប់មានទំនាក់ទំនងជាមួយនឹងវៀតណាម[2123] ខ្មែរក្រោម[2124] ធ្លាប់មានទំនាក់ទំនងជាមួយនឹងខ្មែរក្រោម[2125] ត្រូវបានចាត់ទុកថាជា “គិញ” ឬ “ជនក្បត់” ឬមានទំនាក់ទំនងជាមួយនឹង “សេ អ៊ី អា” “កា ហ្សេ បេ”[2126] ក៏ដូចជា ការខកខានមិនបានអនុវត្តតាមវិន័យរបស់

បក្ស[2127] ធ្វើដំណើរគ្មានការអនុញ្ញាត[2128] តវ៉ាអំពីកង្វះខាតអាហារ[2129] ឬ លួចម្ហូបអាហារ[2130]។ ការចោទប្រកាន់ទាំងនេះគ្រប់គ្រាន់សម្រាប់ឲ្យបុគ្គលម្នាក់ធ្លាក់ទៅក្នុងការសង្ស័យ និងត្រូវបានចាប់ខ្លួន និងឃុំខ្លួន[2131]។ អ្នកទោសជាធម្មតាត្រូវបានឃុំនៅក្នុងមន្ទីរឃុំឃាំង ឬបន្ទប់ឃុំខ្លួនបណ្ដោះអាសន្ន[2132]។ អ្នកទោសជាញឹកញាប់ត្រូវបានតាមដាន និងគ្រប់គ្រងដោយឆ្មាំប្រដាប់អាវុធ និងមិនត្រូវបានអនុញ្ញាតឲ្យផ្លាស់ទីដោយសេរីនោះឡើយ[2133]។ ខ្នោះជើង និង/ឬខ្នោះដៃត្រូវបានប្រើដើម្បីរក្សាទុកអ្នកទោសនៅមន្ទីរសន្តិសុខ ភ្នំត្រយោង[2134] និង ចំការខ្នុរ[2135]។ អ្នកទោសជាញឹកញាប់ត្រូវបានរំលោភបំពានផ្នែករាងកាយ និងស្មារតី ដោយរួមមានការធ្វើទារុណកម្ម[2136] ត្រូវបានដាក់នៅក្នុងលក្ខខណ្ឌគ្មានអនាម័យ[2137] បានទទួលអាហារមិនគ្រប់គ្រាន់[2138] និងត្រូវបានបង្ខំឲ្យធ្វើការដោយកម្លាំង[2139]។ ភាពភ័យខ្លាចអំពីការដាក់ទណ្ឌកម្ម និងការធ្វើទារុណកម្មបានកើតឡើងជាប្រចាំ។

466. មនុស្សរាប់ពាន់នាក់ត្រូវបានឃុំខ្លួននៅតាមការដ្ឋានការងារដោយបង្ខំត្រពាំងថ្ម[2140] ស្ពានស្រែង[2141] ការដ្ឋានវាយថ្មភ្នំត្រយោង[2142] និងទីតាំងផ្សេងៗទៀត[2143]។ មនុស្សមិនអាចផ្លាស់ទីដោយសេរីបានទេ ហើយជាធម្មតាត្រូវបានឃ្លាំមើលដោយពួកឆ្មាំប្រដាប់អាវុធ[2144]។ រាល់ទិដ្ឋភាពនៃការរស់នៅត្រូវបានគ្រប់គ្រងដោយកម្មាភិបាល បកក ដូចជា ទីកន្លែង និងរយៈពេល ដែលពួកគេធ្វើការ[2145] សម្រាក និងដេក[2146] ពេលវេលា និង បរិមាណដែលពួកគេអាចបរិភោគ[2147] ក៏ដូចជានៅពេលណាដែលពួកគេត្រូវបានអនុញ្ញាតឲ្យទៅបន្ទោបង់[2148]។

## ចេតនា

467. **អ៊ឹម ចែម** និងចារីផ្ទាល់បានមានចេតនាដកហូតដោយចិត្តឯងនូវសេរីភាពផ្នែករូបវ័ន្តរបស់បុគ្គលទាំងនោះដោយការឃុំឃាំងពួគេ។ **អ៊ឹម ចែម** បានទៅមើល បានតាមដាន និង បានត្រួតពិនិត្យ មន្ទីរសន្តិសុខ សហករណ៍ និងការដ្ឋាន ដែលមនុស្សត្រូវបានឃុំឃាំង ក៏ដូចជាបានទទួលរបាយការណ៍អំពីស្ថានភាពនៅទីនោះផងដែរ។ **អ៊ឹម ចែម** បានបង្កើតវិធាន និងបានចេញបញ្ជាសម្រាប់ដំណើរការមន្ទីរសន្តិសុខ សហករណ៍ និងការដ្ឋានទាំងនោះ[2149] ដោយរួមមានការប្រព្រឹត្តលើអ្នកជាប់ឃុំនៅទីនោះ[2150]។ គាត់ក៏បានធ្វើការប្រជុំនៅតាមន្ទីរសន្តិសុខ សហករណ៍ និងការដ្ឋាន[2151] និងបានផ្តល់ការណែនាំទៅកាន់អ្នកដែលជាប់ឃុំទាំងនោះផងដែរ[2152]។

## ការធ្វើទារុណកម្ម

### អំពើកម្ម និងអកម្ម

468. អ្នកទោសជាច្រើនត្រូវបានធ្វើទារុណកម្មនៅក្នុងមន្ទីរសន្តិសុខរបស់ បកក ក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** ដោយរួមមានមន្ទីរសន្តិសុខវត្តចំការខ្នុរ[2153] ភ្នំត្រយោង[2154] និងវត្តអង្គសិរីមាលី[2155]។ អ្នកទោសត្រូវបានវាយដំដោយរំពាត់ និងដំបង[2156] ឆក់ខ្សែភ្លើង[2157] ដកក្រចក[2158] និងចាក់ដោយកាំបិត[2159]។ អ្នកទោសខ្លះត្រូវបានធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដែលពួកគេមិនអាចដើរបាន[2160] ឬ បានស្លាប់ដោយសាររបួសទាំងនោះ[2161]។ កម្មាភិបាលដែលបានបោសសម្អាតដោយ **អ៊ឹម ចែម** មកពីស្រុកព្រះនេត្រព្រះ និងតំបន់ ៥ ក៏ត្រូវបានធ្វើទារុណកម្មនៅ ស-២១ ផងដែរ[2162]។

469. អ្នកទោសក៏ត្រូវទទួលរងទារុណកម្មផ្លូវចិត្តផងដែរ។ ពួកគេបានរស់នៅក្នុងភាពភ័យខ្លាចការសម្លាប់ជាប្រចាំ ដោយ៖ បានឃើញអ្នកទោសផ្សេងទៀតបាត់ខ្លួន[2163] បានឃើញគ្រួសាររបស់ពួកគេត្រូវបានចាប់ខ្លួន[2164] បានឮគេនិយាយថាមនុស្សត្រូវបានគេសម្លាប់ និងរំលោភសេពសន្ថវៈ[2165] ត្រូវបានគេគំរាមសម្លាប់ជាញឹកញាប់[2166] និងត្រូវបានបង្ខំ ក្នុងករណីខ្លះ ឱ្យជីករណ្តៅកប់ខ្លួនឯង[2167]។

### គោលបំណង

470. គោលបំណងចំបងរបស់មន្ទីរសន្តិសុខ បកក រួមទាំងមន្ទីរសន្តិសុខនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** គឺត្រូវកំណត់អត្តសញ្ញាណ និង "កម្ទេច" អ្នកដែលគេយល់ថាជា "ខ្មាំង" និងក្រុមដែលគេមិនពេញចិត្តផ្សេងទៀត។ ទារុណកម្មត្រូវបានប្រើដើម្បីគំរាមកំហែង ដាក់ទណ្ឌកម្ម ហើយជាចុងក្រោយទាញយកចម្លើយសារភាព និងបង្ខំឱ្យសរសេរព័ត៌មានអំពី "ជនក្បត់" និង "ខ្មាំង" ផ្សេងៗទៀត។

### ចេតនា

471. **អ៊ឹម ចែម** និងចារីផ្ទាល់មានចេតនាឱ្យប្រើការធ្វើទារុណកម្មប្រឆាំងនឹងអ្នកទោស។ **អ៊ឹម ចែម** ជាញឹកញាប់បានទៅមើល ពិនិត្យតាមដានមន្ទីរសន្តិសុខដែលមានការធ្វើទារុណកម្មលើអ្នកទោស[2168]។ តាមពិតនោះ **អ៊ឹម ចែម** បានបញ្ជាឱ្យសម្លាប់អ្នកទោស ដែលត្រូវបានធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរដែលមិនអាចដើរ

បាន[2169]។ ការគ្រប់គ្រង និងបញ្ជារបស់គាត់លើដំណើរការមន្ទីរសន្តិសុខ[2170] បង្កឲ្យមានទុក្ខវេទនាផ្លូវចិត្តយ៉ាងខ្លាំងលើអ្នកទោស ដែលបានរស់នៅក្នុងភាពភ័យខ្លាចត្រូវគេសម្លាប់ជាប្រចាំ។

<u>ការធ្វើទុក្ខបុកម្នេញ</u>

**អំពើកម្ម និងអកម្ម**

472. អំពើជាច្រើនបង្កើតបានជាឧក្រិដ្ឋកម្មផ្សេងៗប្រឆាំងមនុស្សជាតិដែលត្រូវបានរៀបរាប់ពិស្តារនៅក្នុងផ្នែកនេះ ក៏បង្កើតបានជាអំពើរនានានៃការធ្វើទុក្ខបុកម្នេញផងដែរ ដោយសារតែអំពើទាំងនោះបានផ្តល់ឱកាសឲ្យមានការបដិសេធសិទ្ធិមនុស្សជាមូលដ្ឋានរបស់បុគ្គលទាំងឡាយ ដោយសំអាងលើមូលដ្ឋាននៃគំនិតនយោបាយពិតប្រាកដ ឬ ដែលគេជឿជាក់ ជាតិសាសន៍ និង/ឬ ជាតិពន្ធុ។ ទាំងអស់នេះរួមមាន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

473. ទោះបីជា បកក បានចាត់ទុកជនស៊ីវិលភាគច្រើនជាខ្មាំងនយោបាយសក្តានុពលក៏ដោយ ក៏អតីតមន្ត្រី របប លន់ នល់ “ប្រជាជនថ្មី” និង “ខ្មាំង” និង “ជនក្បត់” នយោបាយផ្សេងៗទៀតទទួលបានការរើសអើងប្រឆាំងខ្លាំងជាងគេ ដោយសារតែទស្សនៈប្រឆាំងទៅនឹងនយោបាយរបស់ បកក។ ដូចដែលបានរៀបរាប់ខាងលើ មន្ត្រីរបប នល់ នល់ និង “ប្រជាជនថ្មី” ត្រូវបានដៅយក ចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ចោល នៅមន្ទីរសន្តិសុខ ភ្នំត្រយោង[2171] ចក្រី[2172] ចំការខ្នុរ[2173] និងវត្តព្រះនេត្រព្រះ[2174] និងការដ្ឋានទំនប់ត្រពាំងថ្ម[2175]។ អ្នកដែលត្រូវបានគេជឿជាក់ថាជាខ្មាំងនយោបាយពិតប្រាកដ ដែលគេសន្មតនិងដែលជាសក្តានុពលរបស់ បកក នោះ ត្រូវបានសម្លាប់នៅទូទាំងតំបន់នានា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**។ ការបោសសម្អាតកម្មាភិបាលនៅភូមិភាគពាយ័ព្យនៅក្នុងតំបន់ ៥ ក៏ត្រូវបានធ្វើឡើងដើម្បីកំណត់អត្តសញ្ញាណ និងសម្លាប់អ្នកដែលគេជឿជាក់ថាជាខ្មាំងនយោបាយផងដែរ[2176]។

474. ជាតិពន្ធុវៀតណាម ខ្មែរក្រោម និងក្រុមជាតិពន្ធុដទៃផ្សេងទៀត ដូចជា ចាម និង ចិន ត្រូវបានដៅយក និងរើសអើង។ ដូចដែលបានរៀបរាប់រួចហើយ ជនជាតិវៀតណាម និងអ្នកដែលមានទំនាក់ទំនងជាមួយនឹងពួកគេ ឬត្រូវបានគេជឿថាមាននោះ ត្រូវបានកំណត់គោលដៅសម្រាប់ការចាប់ខ្លួន ឃុំខ្លួន និងសម្លាប់

ចោលនៅមន្ទីរសន្តិសុខ ចក្រី[2177] ចំការខ្នុរ[2178] ភ្នំត្រយោង[2179] និងវត្តព្រះនេត្រព្រះ[2180]។ ពួកគេក៏ត្រូវបានស្វែងរក និងសម្លាប់ចោលនៅតាមការដ្ឋានដូចជា ត្រពាំងថ្ម[2181] និងស្ពានស្រែង[2182]។ អំពើធ្វើទុក្ខបុកម្នេញប្រឆាំងខ្មែរក្រោមក៏បានកើតមានឡើងនៅក្នុងតំបន់នានា ក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម**។ ខ្មែរក្រោម ឬអ្នកដែលគេជឿថាជាខ្មែរក្រោម ឬជាប់ពាក់ព័ន្ធ ឬមានទំនាក់ទំនងជាមួយខ្មែរក្រោមនោះ ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងសម្លាប់នៅវត្តអង្គសិរីមាលី ក៏ដូចជានៅស្រុកកោះអណ្តែត និងក្នុងតំបន់ ១៣[2183]។ ក្រុមជាតិពន្ធុផ្សេងៗទៀត ដូចជា ចាម ខ្មែរលើ លាវ និងចិន ក៏ត្រូវបានស្វែងរក កំណត់អត្តសញ្ញាណ និងរើសអើង ប្រឆាំងស្រដៀងគ្នានេះដែរ នៅវត្តអង្គសិរីមាលី[2184] និងចំការខ្នុរ[2185] ដោយសំអាងលើមូលហេតុជាតិពន្ធុពិតប្រាកដ ឬដែលគេសន្មត។

## ចេតនា

475. **អ៊ឹម ចែម** មានចេតនារើសអើងប្រឆាំងនឹងបុគ្គល និងក្រុមនានាដោយមូលហេតុ នយោបាយ ជាតិសាសន៍ និង/ឬ ជាតិពន្ធុ។ អំពើធ្វើទុក្ខបុកម្នេញប្រឆាំងនឹងអ្នកដែលត្រូវបានជឿជាក់ថាជាអ្នកជំទាស់ទៅនឹងនយោបាយ និងសមាជិកក្រុមជាតិពន្ធុពិតប្រាកដ ឬដែលត្រូវបានសន្មតនោះ ត្រូវបានធ្វើឡើងនៅក្នុងកល្ខណៈឃោរឃៅ និងជាប្រព័ន្ធ។ **អ៊ឹម ចែម** បានផ្សព្វផ្សាយយ៉ាងសកម្មនូវគោលនយោបាយរបស់ បកក ដែលផ្តោតគោលដៅរើសអើងលើក្រុមផ្សេងៗទាំងអស់នេះ[2186] និងបានទទួលរបាយការណ៍នានាអំពីការអនុវត្តគោលនយោបាយទាំងនេះ[2187]។ នៅក្នុងការអនុវត្តអំពើធ្វើទុក្ខបុកម្នេញទាំងនេះ ចារីនានាបានដឹងថាពួកគេកំពុងអនុវត្តគោលនយោបាយរើសអើងរបស់ បកក។

## <u>អំពើអមនុស្សធម៌ផ្សេងៗទៀត</u>

## អាពាហ៍ពិពាហ៍ដោយបង្ខំ

*អំពើកម្ម និងអកម្ម*

476. **អ៊ឹម ចែម** បានអនុវត្តគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ បកក នៅក្នុងតំបន់នានាស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ គោលនយោបាយនោះបានបណ្តាលឲ្យមានព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ និងក្នុងករណីជាច្រើននាំឲ្យមានព្យសនកម្មផ្នែករាងកាយធ្ងន់ធ្ងរដល់ជនរងគ្រោះ។ អ្នកដែលរងការប៉ះពាល់

ជាញឹកញាប់មិនបានស្គាល់បុគ្គលដែលខ្លួនត្រូវបានបង្ខំឱ្យរៀបការជាមួយ និងត្រូវមានទំនាក់ទំនងផ្លូវភេទជាមួយនោះទេ។ **អ៊ឹម ចែម** បានធ្វើជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងតំបន់ ៥[2188]។ គាត់ក៏បានបង្ខំស្ត្រីក្មេងៗនៅក្នុងតំបន់ ១៣ ឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយនឹងយុទ្ធជនពិការផងដែរ[2189]។ អាពាហ៍ពិពាហ៍ដោយបង្ខំបានកើតឡើងនៅក្នុងកន្លែងជាច្រើនដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** រួមទាំង ការដ្ឋានត្រពាំងថ្ម[2190] និងស្ពានស្រែង[2191]។ បុគ្គលជាច្រើន មិនបានជំទាស់នោះទេដោយសារតែភ័យខ្លាចត្រូវគេសម្លាប់។ អ្នកដែលបានជំទាស់ ឬមិនបានរួមសង្វាសជាមួយនឹងគូស្រករបស់ខ្លួនអាចត្រូវបានដាក់ទណ្ឌកម្ម ឬ សម្លាប់ចោល[2192]។

*ចេតនា*

477. **អ៊ឹម ចែម** មានចេតនាបង្កឱ្យមានព្យសនកម្មរាងកាយ និង/ឬផ្លូវចិត្តធ្ងន់ធ្ងរ ដោយការបង្ខំមនុស្សឱ្យរៀបអាពាហ៍ពិពាហ៍។ គាត់បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ បកក និងបានដឹងថាព្យសនកម្មរាងកាយ និង/ឬផ្លូវចិត្តធ្ងន់ធ្ងរនឹងកើតមានឡើង។ ចេតនារបស់គាត់បានបង្ហាញ*ជាអាទិ៍* តាមរយៈ៖ ការគំរាមបង្ខំគេឱ្យរៀបអាពាហ៍ពិពាហ៍[2193] និងការបញ្ជាពួកឈ្លបឱ្យតាមដានថាតើគូស្រករទាំងនោះរួមសង្វាសឬអត់[2194]។

**ការរំលោភសេពសន្ថវៈ**

*អំពើកម្ម និងអកម្ម*

478. នៅទូទាំងតំបន់ក្រោមការគ្រប់គ្រងរបស់គាត់ ជនស៊ីវិលជាច្រើនបានរងគ្រោះដោយការរំលោភសេពសន្ថវៈ និងអំពើហិង្សារលើផ្លូវភេទ ដែល **អ៊ឹម ចែម** បានឯកភាព ឬបណ្តោយឱ្យកើតមាន។ **អ៊ឹម ចែម** បានរៀបចំ និងត្រួតពិនិត្យមើលអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលនៅក្នុងនោះការរំលោភសេពសន្ថវៈបានកើតមាន[2195] ស្របតាមគោលនយោបាយរបស់ បកក។ អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានដាក់ឱ្យអនុវត្តនៅតាមភូមិ និង ឃុំ[2196]។ ការរំលោភសេពសន្ថវៈនៅពេលរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖(i) រវាងភាគីដែលមិនមានការព្រមព្រៀងគ្នា និង (ii) ក្នុងករណីដែលស្ត្រីត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយបុរសដែលបានជ្រើសរើសគាត់។ បុគ្គលនានាបានចូលរួមក្នុងការរួមសង្វាសដោយភ័យខ្លាចទណ្ឌកម្មធ្ងន់ធ្ងរ។ អ្នកដែលខកខានមិនបានអនុវត្តតាម ក្នុងករណីខ្លះត្រូវបានសម្លាប់ចោល[2197]។ ឈ្លបតាមមូលដ្ឋាន

បានតាមដានអ្នកដែលត្រូវបានរៀបការដោយបង្ខំ ដើម្បីធានាថាពួកគេបានរួមសង្វាស[2198]។

479. ការរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តឡើងដោយឆ្មាំយាមមន្ទីរសន្តិសុខ រួមទាំង វត្តអង្គសិរីមាលី[2199] និងភ្នំត្រយោង[2200]។ សាកសពស្ត្រីជាញឹកញាប់ត្រូវបានគេរកឃើញអាក្រាតនៅភ្នំត្រយោង ខណៈដែលសាកសពបុរសនៅមានសម្លៀកបំពាក់[2201]។ ស្ត្រីក៏ត្រូវបានគេរំលោភសេពសន្ថវៈនៅស្រុកព្រះនេត្រព្រះ មុនពេលត្រូវបានសម្លាប់ និងនៅការដ្ឋានទំនប់ត្រពាំងថ្ម និងត្រូវបានកប់ក្រោមគ្រឹះទំនប់នោះ[2202]។

*ចេតនា*

480. **អ៊ឹម ចែម** មានចេតនា និង/ឬ អនុញ្ញាត និងបណ្តោយឱ្យមានការរួមសង្វាសដោយគ្មានការយល់ព្រមពីបុគ្គលនោះ។ គាត់ក៏មានចេតនាធ្វើឱ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់រាងកាយ និង/ឬផ្លូវចិត្ត ដល់បុគ្គលទាំងនោះផងដែរ។ **អ៊ឹម ចែម** បានធ្វើជាអធិបតី[2203] បានរៀបចំ[2204] និងបានទទួលរបាយការណ៍អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ[2205]។ **អ៊ឹម ចែម** បានអនុវត្តគោលនយោបាយរបស់ បកក នៃការបង្ខំមនុស្សឱ្យរៀបអាពាហ៍ពិពាហ៍ ដែលមានចេតនាធ្វើឱ្យសម្រេចបាននូវការរួមសង្វាស ដូចដែលបានបង្ហាញតាមរយៈការលបស្តាប់ និងការតាមដានអ្នកដែលត្រូវបានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដើម្បីឱ្យមានសកម្មភាពផ្លូវភេទ[2206]។ ការរួមសង្វាសគឺជារឿងចាំបាច់ដើម្បីបំពេញគោលនយោបាយរបស់ បកក ក្នុងការបង្កើនចំនួនប្រជាជនតាមរយៈកំណើតកូនក្មេង។ **អ៊ឹម ចែម** បានដឹងថា អំពើផ្លូវភេទកំពុងត្រូវបានប្រព្រឹត្ត ក្នុងករណីភាគច្រើន មិនមានការយលព្រមពីបុគ្គលនោះ។ អវត្តមានការយល់ព្រមគឺមានសភាពច្បាស់លាស់ណាស់ *ជាអាទិ៍* កង្វះសេរីភាពរូបវន្តនៅតាមសហករណ៍ មន្ទីរសន្តិសុខ និងការដ្ឋាន ការប្រើប្រាស់ការដាក់ទណ្ឌកម្មប្រឆាំងនឹងអ្នកដែលខកខានមិនបានរួមសង្វាសពេលរៀបការ[2207] និងការប្រើការតាមដានដោយឈ្លបដើម្បីធានាថាគូស្រករបានរួមសង្វាស[2208]។

481. ឆ្មាំគុក និងកម្មាភិបាលដែលបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈមានចេតនារួមភេទជាមួយជនរងគ្រោះ និងបានដឹងថាជនរងគ្រោះទាំងនោះមិនបានយល់ព្រមនោះទេ។ អវត្តមានការយល់ព្រមនេះបង្ហាញ *ជាអាទិ៍* អំពីភាពជាចំណាប់ខ្មាំងរបស់ជនរងគ្រោះ ការប្រើប្រាស់ការបង្ខំ ឬការគំរាមកំហែងប្រើការបង្ខំដើម្បីធ្វើឱ្យការរួមសង្វាសសម្រេចទៅបាន និងវត្តមាននៃកាលៈទេសៈចាប់បង្ខំនានាដែលក្នុងនោះការយល់ព្រមដ៏មានអត្ថន័យមួយមិនអាចកើតមានបាន[2209]។ **អ៊ឹម ចែម** បានដឹង ឬ បានដឹងឮអំពីភាពអាចកើតមានឡើងជាសំខាន់ថា អំពើផ្លូវភេទកំពុងត្រូវបានប្រព្រឹត្តឡើងនៅតាមមន្ទីរសន្តិសុខ និងការដ្ឋានក្រោមការ

01342176



គ្រប់គ្រងរបស់គាត់។ គាត់មិនបានធ្វើអ្វីមួយដើម្បីទប់ស្កាត់ការកើតឡើងទាំងនោះទេ ឬក៏ដាក់ទណ្ឌកម្មចារីផ្ទាល់នោះក៏ទេដែរ។

## ការបាត់ខ្លួនដោយបង្ខំ

*អំពើកម្ម និងអកម្ម*

482. **អ៊ឹម ចែម** និង បកក បានដកហូតសេរីភាពរបស់បុគ្គលរាប់ពាន់នាក់ នៅទូទាំងតំបន់១៣ និង តំបន់៥។ នៅមន្ទីរសន្តិសុខ រួមមាន វត្តអង្គសិរីមាលី[2210] ភ្នំត្រយោង[2211] ចក្រី[2212] វត្តចំការខ្នុរ[2213] វត្តព្រះនេត្រព្រះ[2214] និងនៅអាគារមួយជិតលំនៅដ្ឋានរបស់ **អ៊ឹម ចែម** នៅភ្នំលៀប[2215] ប្រជាជនស៊ីវិលត្រូវបានជាប់ឃុំឃាំង ដោយគ្មានមធ្យោបាយរកដំណោះស្រាយផ្លូវច្បាប់ និងការធានាតាមកិច្ចដំណើរការនីតិវិធីនោះទេ។ សាក្សីក៏បានរៀបរាប់ផងដែរអំពី ករណីជាច្រើននៅតាមមន្ទីរសន្តិសុខនានា និងនៅការដ្ឋានត្រពាំងថ្ម និងស្ពានស្រែង ថាមានមនុស្សត្រូវបានយកចេញដោយចំហរ ឬ ដោយលួចលាក់ ហើយមិនដែលបានឃើញ ឬ បានឮ ពីពួកគាត់ជាថ្មីម្តងទៀតនោះទេ[2216]។

*ចេតនា*

483. **អ៊ឹម ចែម** មានចេតនាដកហូតសេរីភាពរបស់បុគ្គល និងដកហូតពួកគាត់ចេញពីការការពារតាមផ្លូវច្បាប់។ គាត់ក៏មានចេតនាធ្វើឲ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់រាងកាយ និង/ឬ ផ្លូវចិត្ត របស់បុគ្គលទាំងនោះផងដែរ។ **អ៊ឹម ចែម** បានត្រួតពិនិត្យមន្ទីរសន្តិសុខនានា ដែលនៅទីនោះ មនុស្សត្រូវបានជាប់ឃុំឃាំង ហើយការដ្ឋានទាំងឡាយដែលមានមនុស្សចេញពីទីនោះទៅបាត់ ហើយមិនឃើញត្រឡប់វិញ[2217]។ គាត់បានចុះទៅមើល និងធ្វើការប្រជុំនៅតាមមន្ទីរសន្តិសុខ និងនៅតាមការដ្ឋាននានា ក៏ដូចជា បានទទួលរបាយការណ៍ជាទៀងទាត់ស្តីពីប្រតិបត្តិការ និងស្ថានភាពអ្នកធ្វើការ និង អ្នកជាប់ឃុំនានា[2218]។

## ការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌

*អំពើកម្ម និងអកម្ម*

484. អ្នកទោសរាប់ពាន់អ្នកទទួលរងព្យសនកម្មធ្ងន់ធ្ងរខាងផ្លូវចិត្ត និង ផ្លូវកាយ នៅតាមមន្ទីរសន្តិសុខនានា ដូច

ជា ភ្នំត្រយោង[2219] ចំការខ្នុរ[2220] វត្តអង្គសិរីមាលី[2221] វត្តព្រះនេត្រព្រះ[2222] និងចក្រី[2223]។ មនុស្សត្រូវបានចាប់ខ្លួន និង ឃុំខ្លួនដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយគណៈអចិន្ត្រៃយ៍ និងបានផ្សព្វផ្សាយដោយ **អ៊ឹម ចែម**។ មនុស្សទាំងនេះត្រូវបានឃុំឃាំងដោយមិនមានការជំនុំជម្រះត្រឹមត្រូវ និងត្រូវទទួលរងលក្ខខណ្ឌ និង ការប្រព្រឹត្តអមនុស្សធម៌ និងបន្ថោកបន្ទាប។ ស្ថានភាពនេះរួមមាន៖ ការធ្វើបាប និងការធ្វើទារុណកម្មផ្លូវកាយ និងផ្លូវចិត្ត ការឃុំខ្លួនដែលជាញឹកញាប់នៅក្នុងទីចង្អៀត និងគ្មានអនាម័យ[2224] ការបង្អត់អាហារ[2225] ការធ្វើការដោយបង្ខំ[2226] កង្វះការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ[2227] ការរំលោភសេពសន្ថវៈ[2228] និងការដកហូតសេរីភាពដោយគ្មានសង្ឃឹមថាត្រូវបានដោះលែង។ ស្រដៀងគ្នានេះ លក្ខខណ្ឌដ៏អាក្រក់ត្រូវបានជួបប្រទះដោយអ្នកដែលត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់នៅតាមទីតាំងនានា រួមទាំងការដ្ឋានត្រពាំងថ្ម[2229] និងស្ពានស្រែង[2230]។ មនុស្សត្រូវបានបង្ខំឲ្យធ្វើការដោយគ្មានប្រាក់ឈ្នួល ផ្ទុយទៅវិញត្រូវទទួលរងការប្រព្រឹត្តអមនុស្សធម៌ និងបន្ថោកបន្ទាប។ ស្ថានភាពនេះរួមមាន៖ ការបង្អត់អាហារ[2231] ការអស់កម្លាំង[2232] ការដាក់ទណ្ឌកម្មតាមអំពើចិត្ត[2233] ការរំលោភសេពសន្ថវៈ[2234] លក្ខខណ្ឌគ្មានអនាម័យ[2235] និងកង្វះខាតការថែទាំវេជ្ជសាស្ត្រ[2236]។ នៅក្នុងមន្ទីរសន្តិសុខ និងការដ្ឋាននានា មនុស្សបានរស់នៅក្នុងការភ័យខ្លាចជាប្រចាំ ខ្លាចការដាក់ទណ្ឌកម្ម ខ្លាចស្លាប់ និងជានិច្ចជាកាលប្រឈមនឹងការគំរាមកំហែង[2237] និងការរំលោភសេពសន្ថវៈដ៏អាក្រក់[2238] និងការសម្លាប់[2239]។ អ្នកខ្លះត្រូវបានបង្ខំឲ្យជីករណ្ដៅ កប់អ្នកដែលត្រូវបានសម្លាប់[2240]។

*ចេតនា*

485. **អ៊ឹម ចែម** មានចេតនាបង្ករឲ្យមានព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរលើអ្នកទាំងឡាយនៅក្នុងមន្ទីរសន្តិសុខ សហករណ៍ និងការដ្ឋាននីមួយៗ ដែលគាត់បានគ្រប់គ្រង។ វិសាលភាពដ៏ធំធេងនៃការឈឺចាប់ដែលកើតមានឡើងនៅក្នុងទីកន្លែងនីមួយៗបង្ហាញថា ចារីផ្សេងទៀតមានចេតនាដូចគ្នាដែរ។ **អ៊ឹម ចែម** ជានិច្ចជាកាលបានទៅមើលមន្ទីរសន្តិសុខ និងការដ្ឋានទាំងនេះ[2241] និងក្នុងតំបន់ ៥ បានទទួលខុសត្រូវចំពោះការធ្វើឲ្យលក្ខខណ្ឌនានាដែលគួរឲ្យស្អប់ខ្ពើមរួចទៅហើយនោះកាន់តែអាក្រក់ឡើងថែមទៀត[2242]។ គាត់បានអនុវត្តយ៉ាងស៊ីចង្វាក់នូវគោលនយោបាយ បកក នៃការធ្វើបាបអមនុស្សធម៌ និងឃោរឃៅលើជនស៊ីវិលដែលត្រូវបានឃុំខ្លួន និង/ឬធ្វើឲ្យទៅជាទាសករ។

## ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

486. ភស្តុតាងនៅលើសំណុំរឿង និងដែលបានយោងនៅក្នុងផ្នែកអង្គហេតុសម្ភារៈ បង្ហាញថាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដែលអាចផ្តន្ទាទោសបានតាមមាត្រា ៦ នៃច្បាប់ អវតក ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការគូសបញ្ជាក់នៃអង្គហេតុនានាដែលបង្កើតបានជាធាតុផ្សំយុត្តាធិការចាំបាច់ និងឧក្រិដ្ឋកម្មជាក់លាក់ត្រូវបានលើកឡើងខាងក្រោមនេះ។

### ធាតុផ្សំយុត្តាធិការនៃការបំពារបំពានធ្ងន់ធ្ងរ

<u>ជម្លោះប្រដាប់អាវុធអន្តរជាតិ</u>

487. ដូចបានលម្អិតជូននៅក្នុងផ្នែកជម្លោះប្រដាប់អាវុធ[2243] ភស្តុតាងនៅលើសំណុំរឿងបង្ហាញថា ពិតជាមានជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជាប្រជាធិបតេយ្យ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ចាប់ពីខែឧសភា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។

<u>បុគ្គលដែលត្រូវទទួលបានការការពារ</u>

488. ជាតិពន្ធុវៀតណាម និងអ្នកដែលត្រូវបានសន្មតដោយ បកក ថាជាវៀតណាម ក៏ដូចជាខ្មែរក្រោម និងអ្នកដែលត្រូវបានសន្មតដោយ បកក ថាជាខ្មែរក្រោម ដែលទទួលរងឧក្រិដ្ឋកម្មនានារៀបរាប់ខាងក្រោម គឺជាបុគ្គលដែលត្រូវទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវ IV។ ជនស៊ីវិលទាំងនេះ (១) បានស្ថិតនៅក្នុងដៃរបស់កម្ពុជាប្រជាធិបតេយ្យ ដែលជាភាគីទំនាស់ ដែលពួកគេមិនមែនជាជនជាតិនៃភាគីនោះ ឬ (២) ត្រូវបាន បកក សន្មតថាជារបស់វៀតណាម ដែលជាភាគីបដិបក្ខនៅក្នុងទំនាស់ និងបានដាក់ការគំរាមកំហែងមកលើកម្ពុជាប្រជាធិបតេយ្យ[2244] ហើយដូច្នេះមានឋានៈជាបុគ្គលដែលត្រូវទទួលបានការការពារ។

## ការដឹងឮអំពីជម្លោះប្រដាប់អាវុធ

489. **អ៊ឹម ចែម** និងចារីផ្ទាល់នៃការបំពារបំពានធ្ងន់ធ្ងរប្រឆាំងនឹងជនជាតិវៀតណាម បានដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។ ឧទាហរណ៍ **អ៊ឹម ចែម** ជានិច្ចជាកាល បានប្រើការប្រជុំជាមួយនឹងថ្នាក់ក្រោម ដើម្បីសង្កត់ធ្ងន់លើតម្រូវការប្រយុទ្ធប្រឆាំងនឹង "យួន" ឈ្លានពាន[2245]។

## ឧក្រិដ្ឋកម្មជាក់លាក់

490. ភស្តុតាងបង្ហាញថាការបំពារបំពានធ្ងន់ធ្ងរខាងក្រោមលើអនុសញ្ញាទីក្រុងហ្សឺណែវ តាមមាត្រា ៦ នៃច្បាប់ អវតក ត្រូវបានប្រព្រឹត្តឡើងដោយ កម្មាភិបាល/យោធា/ឈ្លប របស់ បកក ចាប់ពីឆ្នាំ ១៩៧៦-១៩៧៩ នៅតាមទីតាំងជាច្រើននៅក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និងតំបន់ ៥ នៃភូមិភាគពាយ័ព្យ៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

491. កម្មាភិបាល/យោធា/ឈ្លប របស់ បកក ទាំងអស់នេះបានប្រព្រឹត្តក្រោមការគ្រប់គ្រង និងការពិនិត្យដោយផ្ទាល់ និង/ឬ ដោយប្រយោលរបស់ **អ៊ឹម ចែម** ឬ ដោយផ្អែកលើឥទ្ធិពល ការលើកទឹកចិត្ត ឬជំនួយរបស់គាត់។

492. "ជនដែលត្រូវទទួលបានការការពារ" ដែលជាជនរងគ្រោះនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរផ្សេងៗ ដែលមានចែងនៅខាងក្រោមនេះ គឺ (i) ប្រជាជនស៊ីវិលនៃជាតិពន្ធុវៀតណាម ឬ ប្រជាជនស៊ីវិលដែលត្រូវបានយល់ឃើញដោយ បកក ថាបានទាក់ទង ឬ ចូលរួមចំណែកជាមួយនឹងប្រជាជនស៊ីវិលនៃជាតិពន្ធុវៀតណាម ឬ ប្រជាជនវៀតណាម ("ប្រជាជនស៊ីវិលវៀតណាម") និង (ii) ប្រជាជនស៊ីវិលខ្មែរក្រោម ឬប្រជាជនស៊ីវិលដែលត្រូវបានយល់ឃើញដោយ បកក ថាបានទាក់ទង ឬ ចូលរួមចំណែកជាមួយនឹងខ្មែរក្រោម ("ប្រជាជនស៊ីវិលខ្មែរក្រោម")។

<u>ការធ្វើមនុស្សឃាតដោយចេតនា</u>

***អំពើកម្ម និងអកម្ម***

493. ជនជាតិវៀតណាម និងខ្មែរក្រោមត្រូវបានកំណត់អត្តសញ្ញាណយ៉ាងជាក់លាក់ ត្រូវបានចាប់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខ វត្តអង្គសិរីមាលី[2246] ចក្រី[2247] ចំការខ្នុរ[2248] ភ្នំត្រយោង[2249] និងវត្តព្រះនេត្រព្រះ[2250] ស្ថិតក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម**។ ជនជាតិវៀតណាមត្រូវបានស្វែងរកក្នុងចំណោមអ្នកដែលត្រូវគេបង្ខំឲ្យធ្វើការនៅការដ្ឋានត្រពាំងថ្ម[2251] និងត្រូវបានសម្លាប់ចោល។ **អ៊ឹម ចែម** ក៏បានបញ្ជាឲ្យសម្លាប់ជនជាតិវៀតណាមនៅការដ្ឋានស្ពានស្រែងផងដែរ[2252]។

***ចេតនា***

494. អ្នកដែលបានសម្លាប់ជនជាតិវៀតណាម និងជនស៊ីវិលខ្មែរក្រោម បានប្រព្រឹត្តដោយមានចេតនាធ្វើដូច្នោះ និងបានធ្វើតាមគោលនយោបាយរបស់ បកក។ **អ៊ឹម ចែម** មានចេតនាឲ្យមានការសម្លាប់ទាំងអស់នេះ ជាផ្នែកមួយនៃការអនុវត្តគោលនយោបាយរបស់ បកក ដោយផ្តោតគោលដៅលើជនជាតិវៀតណាម និងជនស៊ីវិលខ្មែរក្រោមនៅក្នុងតំបន់នានាស្ថិតក្រោមការគ្រប់គ្រងរបស់គាត់[2253]។

<u>ការប្រព្រឹត្តដោយអមនុស្សធម៌</u>

***អំពើកម្ម និង អកម្ម***

495. ជនស៊ីវិលវៀតណាម ខ្មែរក្រោមដែលត្រូវបានឃុំឃាំងនៅតាមទីតាំងស្ថិតក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** ដូចជា នៅមន្ទីរសន្តិសុខ វត្តអង្គសិរីមាលី[2254] ភ្នំត្រយោង[2255] និងមន្ទីរសន្តិសុខចំការខ្នុរ[2256] ត្រូវបានគេដាក់នៅក្រោមការប្រព្រឹត្ត និងលក្ខខណ្ឌអមនុស្សធម៌យ៉ាងកំរោល។ ដូចបានរៀបរាប់ខាងលើ ទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម ពួកគេត្រូវបានគេបង្អត់អាហារ[2257] ទឹក[2258] ផាសុបករណ៍អនាម័យ[2259] និងការថែទាំវេជ្ជសាស្ត្រ[2260]។ លក្ខខណ្ឌដ៏រន្ធត់ស្រដៀងគ្នានេះ ដែលត្រូវទទួលរងដោយជនស៊ីវិលវៀតណាម ក៏ត្រូវបានបង្ខំទៅលើពលករនៅឯការដ្ឋានទំនប់អាងត្រពាំងថ្ម[2261] និងស្ពានស្រែងស្ថិតក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម**[2262]។ អ្នកទោស និងពលករ

ដោយបង្ខំនៅតាមទីតាំងទាំងនោះ រស់នៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំអំពីការដាក់ទណ្ឌកម្មលើរូបរាងកាយ និងការសម្លាប់។ លក្ខខណ្ឌទាំងនេះបានបង្កឲ្យអ្នកដែលត្រូវទទួលបានការការពារ ទទួលរងនូវការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ និង/ឬ ផ្លូវចិត្ត និងបង្កើតបានជាការវាយប្រហារដ៏ធ្ងន់ធ្ងរមួយទៅលើសេចក្តីថ្លៃថ្នូរមនុស្សជាតិរបស់ពួកគេ។

***ចេតនា***

496. ការដាក់ឲ្យអនុវត្តយ៉ាងស៊ីចង្វាក់នៃ ការប្រព្រឹត្ត និង លក្ខខណ្ឌនៃការឃុំខ្លួនជនស៊ីវិលវៀតណាម និងខ្មែរក្រោមដ៏អមនុស្សធម៌ បង្ហាញឲ្យឃើញអំពីចេតនារបស់ អ៊ឹម ចែម និងចារីផ្ទាល់ ដើម្បីប្រព្រឹត្តអំពើទាំងឡាយដែលបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ និង/ឬ ផ្លូវចិត្ត ទៅលើជនដែលត្រូវទទួលបានការការពារទាំងអស់នេះ។

<u>ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព</u>

497. អំពីកម្ម និង/ឬ អំពើអកម្ម និងចេតនារបស់ **អ៊ឹម ចែម** ដូចបានរៀបរាប់ខាងលើ ទាក់ទងនឹងការប្រព្រឹត្តដោយអមនុស្សធម៌ គឺអាចអនុវត្តបានស្មើៗគ្នាដូចនឹងឧក្រិដ្ឋកម្មនេះដែរ។

<u>ការដកហូតដោយចេតនានូវការជំនុំជម្រះដោយ យុត្តិធម៌ និងទៀងទាត់</u>

498. ភ័ស្តុតាងបញ្ជាក់ថា បទល្មើសនៃការដកហូតដោយចេតនាពីជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងទៀងទាត់ ជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ក្រោមមាត្រា៦ នៃច្បាប់ អវតក នោះ ត្រូវបានប្រព្រឹត្តដោយកម្មាភិបាល/យោធា/ឈ្លប របស់ បកក ចាប់ពីឆ្នាំ១៩៧៦-១៩៧៩ នៅតាមបណ្តាទីតាំងផ្សេងៗនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី និងតំបន់៥ នៃភូមិភាគពាយ័ព្យ។ កម្មាភិបាល/យោធា/ឈ្លប របស់ បកក ទាំងនេះ បានប្រព្រឹត្តក្រោមការគ្រប់គ្រង និងការត្រួតត្រាដោយផ្ទាល់ និង/ឬ ដោយប្រយោលរបស់ **អ៊ឹម ចែម** ឬ ដោយសំអាងលើឥទ្ធិពល ការលើកទឹកចិត្ត ឬជំនួយរបស់គាត់។

## *អំពើកម្ម និង អកម្ម*

499. អ្នកទោសនៅមន្ទីរសន្តិសុខ វត្តអង្គសិរីមាលី[2263] ភ្នំត្រយោង[2264] និងចំការខ្នុរ[2265] ត្រូវបានបំបិទសិទ្ធិរបស់ខ្លួនមិនឱ្យទទួលបាន ការធានាតាមផ្លូវតុលាការដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ IV។ ការប្រព្រឹត្ត ដែលជនស៊ីវិលវៀតណាម និងខ្មែរក្រោមត្រូវទទួលរងនៅក្នុងកន្លែងទាំងនេះ[2266] មិនស្របគ្នាទាំងស្រុងទៅនឹងការប្រតិបត្តិតាមការធានាបែបនោះទេ។

## *ចេតនា*

500. **អ៊ឹម ចែម** និង កម្មាភិបាល បកក ដែលបានអនុវត្តការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ទៅលើប្រជាជនស៊ីវិលវៀតណាម និងខ្មែរក្រោម មានចេតនាដកហូតពីជនទាំងនោះនូវសិទ្ធិរបស់ពួកគាត់ក្នុងការទទួលបាននូវការជំនុំជម្រះមួយដ៏ត្រឹមត្រូវ និងទៀងទាត់។ ដូចដែលបានរៀបរាប់យ៉ាងពិស្តារនៅខាងលើ ការដកហូតនេះត្រូវបានធ្វើឡើងដោយ **អ៊ឹម ចែម** និង កម្មាភិបាល ដោយអនុលោមតាមគោលនយោបាយរើសអើងរបស់ បកក[2267]។

<u>ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់</u>

501. ភស្តុតាងបានបង្ហាញថា បទល្មើសនៃការឃុំខ្លួនដោយខុសច្បាប់ ថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ក្រោមមាត្រា៦ នៃច្បាប់ អ.វ.ត.ក នោះ ត្រូវបានប្រព្រឹត្តដោយកម្មាភិបាល/យោធា/ឈ្លប របស់ បកក ពីឆ្នាំ១៩៧៦-ឆ្នាំ១៩៧៧ នៅតាមទីកន្លែងផ្សេងៗ នៅតំបន់១៣ នៃភូមិភាគនិរតី និងតំបន់៥ នៃភូមិភាគពាយ័ព្យ។ កម្មាភិបាល/យោធា/ឈ្លប របស់ បកក ទាំងនេះ បានធ្វើនូវអំពើនេះ នៅក្រោមសិទ្ធិអំណាច និងការគ្រប់គ្រងដោយផ្ទាល់ និង/ឬដោយប្រយោលរបស់ **អ៊ឹម ចែម** ឬនៅផ្អែកលើមូលដ្ឋាននៃឥទ្ធិពល ការលើកទឹកចិត្ត ឬ ជំនួយ របស់គាត់។

## *អំពើកម្ម និង អកម្ម*

502. ជនស៊ីវិលវៀតណាម និងខ្មែរក្រោម ត្រូវបានចាប់ខ្លួន ដាក់ក្នុងមន្ទីរឃុំឃាំង និង សម្លាប់ចោល ដោយគ្មានទទ្បីករណ៍សមហេតុសមផលដើម្បីឱ្យជឿជាក់បានថា សន្តិសុខនៃកម្ពុជាប្រជាធិបតេយ្យបានធ្វើការ

ដាក់ក្នុងមន្ទីរឃុំឃាំងជនទាំងនោះដោយសារភាពចាំបាច់[2268] ឬក៏ គ្មានការវាយតម្លៃណាមួយត្រូវបានធ្វើឡើងស្តីពីហានិភ័យដែលពួកគាត់អាចបង្កឡើងចំពោះសន្តិសុខនៃកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ផ្ទុយទៅវិញ ប្រជាជនស៊ីវិលវៀតណាម និងខ្មែរក្រោមត្រូវបានចាប់ខ្លួន និងដាក់ក្នុងមន្ទីរឃុំឃាំង ដើម្បីផ្តល់លទ្ធភាពឱ្យមានការសម្លាប់ពួកអ្នកទាំងនោះ[2269]។ មិនមានការធានាតាមកិច្ចដំណើរការនីតិវិធីណាមួយដែលប្រជាជនស៊ីវិលទាំងនេះត្រូវទទួលបាន តាមអនុសញ្ញាទីក្រុងហ្សឺណែវ IV ត្រូវបានអនុវត្តតាមនោះទេ។

### *ចេតនា*

503. **អ៊ឹម ចែម** និង កម្មាភិបាល បកក មានចេតនាដាក់ប្រជាជនស៊ីវិលវៀតណាម និងខ្មែរក្រោមក្នុងមន្ទីរឃុំឃាំង។ ដូចគ្នាទៅនឹងឧក្រិដ្ឋកម្មដទៃទៀតដែរ ការណ៍នេះត្រូវបានធ្វើឡើងជាប្រព័ន្ធនៅតាមកន្លែង នៅក្រោមសិទ្ធិអំណាចរបស់ **អ៊ឹម ចែម** ក្នុងការពន្លឿនគោលនយោបាយរើសអើងរបស់ បកក[2270]។

## ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល

### ទិដ្ឋភាពទូទៅ

504. ភស្តុតាងនៅក្នុងសំណុំរឿង និងដែលបានយោងនៅក្នុងវាក្យខណ្ឌស្តីពី អង្គហេតុជាសម្ភារៈ បានកំណត់ថា **អ៊ឹម ចែម** មានការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ អនុលោមតាមមាត្រា៥ និងមាត្រា៦ នៃច្បាប់ អវតក។

505. **អ៊ឹម ចែម** មានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយដូចមានចែងនៅក្រោមមាត្រា២៩ នៃច្បាប់ អ.វ.ត.ក និយាយឱ្យចំ គឺចំពោះ (i) ការប្រព្រឹត្ត ការធ្វើផែនការ ការញុះញង់ និងការបញ្ជា និង/ឬ ការជួយ និងទំនុកបម្រុងដល់ឧក្រិដ្ឋកម្មទាំងនេះ និង (ii) ការខកខានក្នុងនាមជាថ្នាក់លើដែលបានដឹង ឬមានហេតុផលត្រូវដឹងថា ថ្នាក់ក្រោមរបស់ខ្លួនប្រហែលជានឹងប្រព្រឹត្ត ឬបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ ដើម្បីរារាំងកុំឱ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ ឬដើម្បីផ្តន្ទាទោសជនប្រព្រឹត្ត។ **អ៊ឹម ចែម** "បានប្រព្រឹត្ត" ឧក្រិដ្ឋកម្មទាំងនេះ មិនមែនក្នុងនាមជាអ្នកប្រព្រឹត្តរូបវន្តទេ ប៉ុន្តែជាអ្នកចូលរួមប្រព្រឹត្តម្នាក់ក្នុងសហឧក្រិដ្ឋ

កម្មរួម។

## ទម្រង់នៃការទទួលខុសត្រូវ

## ការប្រព្រឹត្ត តាមរយៈសហឧក្រិដ្ឋកម្មរួម

506. **អ៊ឹម ចែម** បានប្រព្រឹត្តឧក្រិដ្ឋកម្មនិមួយៗ តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម(JCE) ចំនួនពីរ។ ផែនការរួមនៃ JCE ទាំងពីរ គឺដើម្បីអនុវត្តគោលនយោបាយកសិកម្ម សង្គម និងសេដ្ឋកិច្ចដាច់ខាតរបស់បក្ស និងដើម្បីលុបបំបាត់ខ្មាំងសត្រូវ និងការប្រឆាំងចំពោះមេដឹកនាំ បកក តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ JCE និមួយៗ មានការពាក់ព័ន្ធទៅនឹងទម្រង់ជាមូលដ្ឋាន ជាប្រពន្ធ និងបែបពង្រីក នៃការទទួលខុសត្រូវចំពោះផែនការរួម។

<u>JCE នៅភូមិភាគនិរតី</u>

507. JCE ទីមួយ បានកើតមានឡើងនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី យ៉ាងហោចណាស់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ រហូតដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧។

508. **អ៊ឹម ចែម** បានធ្វើសកម្មភាពរួមជាមួយសមាជិក JCE ដទៃទៀត ដែលរួមមានទាំងភូមិភាគនិរតី សមាជិកគណៈតំបន់១៣ និងសមាជិកគណៈស្រុកកោះអណ្តែត។ និយាយឲ្យចំ សមាជិក JCE រួមមាន លេខាភូមិភាគនិរតី តាម៉ុក, លេខាតំបន់១៣ តាប្រាក់, អនុលេខាតំបន់១៣ មាស មុត និង អនុលេខាស្រុកកោះអណ្តែត នាង អ៊ួច ។ សមាជិកយោធា បកក ភូមិភាគ តំបន់ ស្រុក និងឈ្លបឃុំ ដែលជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ គឺអាចជាផ្នែកនៃ JCE ឬត្រូវបានប្រើប្រាស់ដោយសមាជិកនៃផែនការរួម ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។

509. សមាជិក JCE ម្នាក់ៗ មានចេតនាចង់ឲ្យឧក្រិដ្ឋកម្មដូចតទៅ ត្រូវបានប្រព្រឹត្តជាផ្នែកនៃ JCE៖ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៃអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ ការបាត់ខ្លួនដោយបង្ខំ និងការឃុំឃាំងក្នុងលក្ខខណ្ឌបែបអមនុស្សធម៌ផ្សេងៗ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ការធ្វើ

មនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ (អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩)។

510. ជាការបន្ថែម **អ៊ឹម ចែម** ក៏ត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ តាមរយៈ JCE មួយ ដោយសារការប្រព្រឹត្តអនុលោមតាមប្រព័ន្ធនៃការធ្វើបាបដែលបានរៀបចំទុកជាមុន។ ប្រព័ន្ធនៃការធ្វើបាបនេះ ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងសហករណ៍ និងមន្ទីរសន្តិសុខ ដូចបានរៀបរាប់នៅក្នុងវគ្គខណ្ឌស្តីពី អង្គហេតុសម្ភារៈ។ **អ៊ឹម ចែម** បានដឹងអំពីប្រព័ន្ធនេះ បានចូលរួមក្នុងការពង្រឹងដល់ការអនុវត្តប្រព័ន្ធនេះ និងមានចេតនាចង់ឱ្យប្រព័ន្ធនៃការធ្វើបាបនេះ កាន់តែរីកធំធាត់ថែមទៀត។

511. ដូចគ្នានឹងចេតនានៃឧក្រិដ្ឋកម្មទាំងនេះដែរ គឺគេអាចព្យាករបានថា ជាវិបាកមួយនៃឧក្រិដ្ឋកម្មទាំងនេះនៅក្នុង JEC ការរំលោភសេពសន្ថវៈចេញពីអាពាហ៍ពិពាហ៍ អាចត្រូវបានប្រព្រឹត្តឡើងដោយសមាជិកម្នាក់ ឬច្រើននាក់នៃ JCE និង/ឬ ដោយបុគ្គលដែលបានប្រើដោយសមាជិកណាម្នាក់នោះ ដើម្បីឱ្យអនុវត្តគោលបំណងទាំងនោះ។ ខណៈបានដឹងថា ការរំលោភសេពសន្ថវៈចេញពីអាពាហ៍ពិពាហ៍ អាចជាផលវិបាកមួយបណ្តាលមកពីការអនុវត្តគោលបំណង JCE ក៏ដោយ ក៏ **អ៊ឹម ចែម** នៅតែហ៊ានប្រថុយធ្វើដោយចេតនា។

512. សមាជិកភាពនៃ JCE របស់ **អ៊ឹម ចែម** នៅភូមិភាគនិរតី ត្រូវបានបង្ហាញតាមរយៈការរួមចំណែក និងចេតនាចូលរួមប្រព្រឹត្តរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្ម មុខតំណែងនៃអំណាច និងឥទ្ធិពលរបស់គាត់នៅក្នុង បកក និងទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធរបស់គាត់ជាមួយសមាជិក JCE ដទៃទៀត ជាពិសេសតាម៉ុក[2271]។ មុខតំណែងជាក់លាក់ និងតួនាទីដែល **អ៊ឹម ចែង** បានកាន់នៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ បង្ហាញឱ្យឃើញបន្ថែមទៀតនូវភាពលេចធ្លោ និងសមាជិកភាពរបស់គាត់នៅក្នុង JCE នៅភូមិភាគនិរតី។ **អ៊ឹម ចែង** បានចូលរួម JCE តាំងពីដំបូងនៅមុនសម័យកម្ពុជាប្រជាធិបតេយ្យទៅទៀត ដូចបានបង្ហាញឱ្យឃើញតាមរយៈការចាត់តាំងរបស់គាត់ដោយ ប៉ុល ពត ក្នុងតួនាទីជាមេដឹកនាំនៅក្នុងស្រុកអង្គរជ័យ តំបន់ ១៣ ជាដើម[2272]។ នៅពេល បកក ឡើងកាន់អំណាច **អ៊ឹម ចែង** ដោយធ្វើសកម្មភាពរួមគ្នាជាមួយអ្នកផ្សេងទៀត ដើម្បីពង្រីកការអនុវត្តសហកម្មនេះ បានកាន់តួនាទីដូចតទៅ៖ ធ្វើតំណាងឱ្យ

ភូមិភាគនិរតីនៅក្នុងសភាប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ[2273] ជាប្រធាននារីក្នុងតំបន់១៣[2274] ជាលេខាស្រុកកោះអណ្ដែត[2275] និងជាសមាជិកគណៈតំបន់១៣[2276]។

513. **អ៊ឹម ចែម** បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុង JCE នៅភូមិភាគនិរតី តាមរយៈ ៖

(i) ការរៀបចំសហករណ៍ និងចាត់តាំងប្រជាជន ទៅក្នុងគម្រោងពលកម្មដោយបង្ខំ ដឹងថាជនស៊ីវិលទាំងនេះត្រូវបានដាក់ស្ថិតនៅក្នុងលក្ខខណ្ឌដែលស្មើទៅនឹងការធ្វើឲ្យទៅជាទាសករ[2277]។

(ii) ការបញ្ជាឲ្យចាប់ខ្លួន និងចម្រាញ់ពួកអ្នកដែលបានតម្រូវឲ្យទៅ "កសាងខ្លួនបន្ថែម"[2278]។

(iii) ការទទួល និងចាត់ការតាមរបាយការណ៍ពីថ្នាក់ក្រោម នៅតំបន់១៣ ទាក់ទងនឹងការអនុវត្តគោលនយោបាយរបស់ បកក[2279]។

(iv) ការធ្វើផែនការ និងការបញ្ជាលើគំរោងការងារ ដែលត្រូវបានធ្វើនៅស្រុកកោះអណ្ដែត និងផ្ដល់សេចក្ដីណែនាំទាក់ទងនឹងការកសាងទំនប់ និងប្រឡាយ, ដោយបានដឹងថាកិច្ចការនេះទាក់ទងនឹងពលករដោយបង្ខំឲ្យធ្វើការនៅក្នុងលក្ខខណ្ឌនានាដែលនាំឲ្យមានការធ្វើឲ្យទៅជាទាសករ[2280]។

(v) ការចាត់តាំងនារីដែលគាត់បានមើលការខុសត្រូវនៅតំបន់១៣ ឲ្យទៅសហករណ៍នានាតាមស្រុកដោយអនុលោមតាមគោលនយោបាយរបស់ បកក ហើយនិង ជ្រើសរើសនារីឲ្យចូលរួមនៅក្នុងបកក[2281]។

(vi) ក្នុងឋានៈជាលេខាស្រុក និងអ្នកដឹកនាំតំបន់ បានចូលរួមនៅក្នុងការប្រជុំនានា ដែលនៅក្នុងនោះកម្មាភិបាលថ្នាក់ក្រោមត្រូវបានណែនាំអំពីការអនុវត្តគោលនយោបាយនានារបស់ បកក ដូចជា៖ ការប្រមូលកម្មករ, ការបញ្ជូនកម្មាភិបាលភូមិភាគនិរតី ទៅភូមិភាគពាយ័ព្យ, "ការកម្ទេច" ជនណាដែលបានប្រព្រឹត្តបទល្មើសសីលធម៌ (ខុសសីលធម៌), ការស្រាវជ្រាវរកបុគ្គលណាដែលអាចជា "គិញ" - ដូចជា អ្នកមានជំងឺ ឬអ្នកដែលបានធ្វើឲ្យខូចឧបករណ៍ធ្វើការងារ, ហើយនិងការកំណត់ និងការស្វែងរក "ខ្មាំងស៊ីរូងផ្ទៃក្នុង"[2282]។

(vii) ក្នុងឋានៈជាអ្នកដឹកនាំតំបន់ បានចូលរួមប្រជុំនានាដើម្បីទទួលរបាយការណ៍មាន *ជាអាទិ៍* គោលនយោបាយរបស់ បកក ស្តីពីការរៀបការដោយបង្ខំ ក៏ដូចជា ការស្លាប់ជនស៊ីវិលដោយសារការអត់បាយ នៅក្នុងតំបន់១៣[2283]។

(viii) ការដឹកនាំ និងការចូលរួមវគ្គអប់រំរៀនសូត្រនានានៅក្នុងតំបន់១៣ ដែលនៅក្នុងវគ្គអប់រំរៀនសូត្រទាំងនេះ អ្នកចូលរួមត្រូវបានប្រាប់ឲ្យខំធ្វើការក្នុងការជួយជ្រោមជ្រែងដល់គោលនយោបាយរបស់ បកក ដោយបានដឹងថាកិច្ចការនេះទាក់ទងនឹងពលករដោយបង្ខំឲ្យធ្វើការនៅក្នុងលក្ខខណ្ឌនានាដែលនាំឲ្យមានការធ្វើឲ្យទៅជាទាសករ[2284]។

(ix) ការអនុវត្តតាមសេចក្តីណែនាំរបស់អ្នកដឹកនាំជាន់ខ្ពស់របស់ បកក តា ម៉ុក ស្តីពីការរៀបចំស្រុកកោះអណ្តែត[2285]។

(x) មានសិទ្ធិអំណាចទៅលើមន្ទីរសន្តិសុខវត្តអង្គស្រីមាលី និងទីតាំងសម្លាប់មនុស្សព្រៃសុខុនដែលនៅក្បែរនោះ ជាទីកន្លែងដែលមានការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់មនុស្សច្រើនសន្ធឹកសន្ធាប់ ជាពិសេស ខ្មែរក្រោម ព្រមទាំងការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ និងលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗទៀត[2286]។

(xi) ក្នុងឋានៈជាអ្នកដឹកនាំស្រុក និងតំបន់៖ ការបញ្ជា ការលើកទឹកចិត្ត ការញុះញង់ និង/ឬ ការអត់ទ្រាំដល់ការចាប់ខ្លួន ការដាក់ក្នុងគុក និង ការសម្លាប់ប្រជាជនស៊ីវិល និងក្រុមគោលដៅជាក់លាក់ ដូចជា ខ្មែរក្រោម ឬបុគ្គលដែលបានមើលឃើញថាបានចូលរួមជាមួយនឹងខ្មែរក្រោម ហើយនិង ពួកអ្នកដែលបានចោទថាជា "ខ្មាំង"[2287]។

(xii) ការមិនបាន ប្រើប្រាស់នូវអំណាច និងសិទ្ធិ ជាស្រុក ឬតំបន់ ដើម្បីដោះលែងបុគ្គលដែលនៅជាប់ឃុំ[2288] ហើយនិង,

(xiii) ការខកខានមិនបានប្រើសិទ្ធិអំណាចដែលគាត់មាន ដើម្បីបញ្ឈប់ការអនុវត្ត JCE ទោះបីជាបានដឹងថាឧក្រិដ្ឋកម្មនានាត្រូវបាន និងកំពុងត្រូវបានប្រព្រឹត្តនោះ និងទោះបីជាគាត់មានអំណាចដើម្បីរារាំង ឬបញ្ឈប់ឧក្រិដ្ឋកម្មទាំងនោះ ឬដើម្បីផ្តន្ទាទោសចំពោះអ្នកប្រព្រឹត្តក៏ដោយ[2289]។

514. ចេតនារបស់ **អ៊ឹម ចែម** អាចឲ្យគេកំណត់បាន និង/ឬ ទាញការសន្និដ្ឋានបាន *ជាអាទិ៍* ដូចខាងក្រោម៖

(i) ការទទួលយកដោយស្ម័គ្រចិត្ត និងការចូលរួមប្រព្រឹត្តដោយចេតនា នៅក្នុងមុខតំណែង និង តួនាទីជាច្រើន ដែលអាចឲ្យគាត់ចូលរួមប្រព្រឹត្ត JCE។

(ii) សកម្មភាពរបស់គាត់ជាលេខាគណៈស្រុកកោះអណ្ដែត និងជាសមាជិកគណៈតំបន់១៣ ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម និងបង្កើនការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ ដូចបានរៀបរាប់យ៉ាងលម្អិតនៅក្នុងវក្យខណ្ឌនិយាយអំពីការចូលរួមចំណែកខាងលើ។

(iii) ការសម្របសម្រួល និងអន្តរសកម្មភាពជិតស្និទ្ធរបស់គាត់ ជាមួយមេដឹកនាំជាន់ខ្ពស់ដូចជាតា ម៉ុក និង ប៉ុល ពត។

(iv) "ភាពស្មោះត្រង់លើសលប់" ដែលគាត់បានសារភាព ដើម្បីអនុវត្តគោលនយោបាយ បកក ដែលបានបង្ហាញតាមរយៈការតម្លើងយ៉ាងឆាប់រហ័សនូវមុខតំណែងនៅក្នុង បកក ពីប្រធានសហករណ៍ពលកម្មក្នុងស្រុកត្រាំកក់ ទៅជាសមាជិកគណៈតំបន់១៣[2290] និង

(v) សេចក្ដីថ្លែងការណ៍របស់គាត់ រួមមាន៖ ថាគាត់ "មានការសប្បាយចិត្តក្នុងការបំពេញការងាររបស់ខ្ញុំ", ថាគាត់ "តស៊ូដើម្បីប្រទេសជាតិ និងពូជសាសន៍ខ្ញុំ", ថាគាត់សូមកោតសរសើរចំពោះមេដឹកនាំជាន់ខ្ពស់ រួមមាន ប៉ុល ពត ជាដើម និងថាគាត់គ្មានវិប្បដិសារីចំពោះអ្វីដែលបានកើតឡើងឡើយ[2291]។

## JCE នៅភូមិភាគពាយ័ព្យ

515. JCE ទីពីរ បានកើតឡើងនៅក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ យ៉ាងហោចណាស់ ចាប់ពីថ្ងៃទី១ ខែ មិថុនា ឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

516. **អ៊ឹម ចែម** បានធ្វើសកម្មភាពរួមជាមួយសមាជិក JCE ដទៃទៀត ដែលរួមមាន ភូមិភាគពាយ័ព្យ តំបន់៥ និងសមាជិកគណៈស្រុកព្រះនេត្រព្រះ។ និយាយឲ្យចំ សមាជិក JCE រួមមាន លេខាភូមិភាគពាយ័ព្យ រស់ ញឹម និងអ្នកមកជំនួសគាត់គឺ តា ម៉ុក, កម្មាភិបាលជាន់ខ្ពស់ភូមិភាគពាយ័ព្យ យឹម ទិត្យ, លេខាតំបន់៥

ហេង រិន, អនុលេខាតំបន់៥ តា ជាល និងសមាជិកគណ:ស្រុកព្រះនេត្រព្រះ ពុំ ខូ។ សមាជិកយោធា បកក ភូមិភាគ តំបន់ ស្រុក និងឈ្លបឃុំ ដែលជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ គឺអាចជាផ្នែកនៃ JCE ឬត្រូវបានប្រើប្រាស់ដោយសមាជិកនៃផែនការរួម ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មដូចបានចោទប្រកាន់ទាំងនេះ។

517. សមាជិក JCE ម្នាក់ៗ មានចេតនាចង់ឲ្យឧក្រិដ្ឋកម្មដូចតទៅ ត្រូវបានប្រព្រឹត្តឡើង ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ ការបាត់ខ្លួនដោយបង្ខំ និង ការឃុំឃាំងក្នុងលក្ខខណ្ឌបែបអមនុស្សធម៌ផ្សេងៗ(ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ (អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩)។

518. ជាការបន្ថែម **អ៊ឹម ចែម** ក៏ត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ តាមរយៈ JCE មួយ ដោយសារការប្រព្រឹត្តអនុលោមតាមប្រព័ន្ធនៃការធ្វើបាបដែលបានរៀបចំទុកជាមុន។ ប្រព័ន្ធនៃការធ្វើបាបនេះ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងសហករណ៍ ការដ្ឋានពលកម្មដោយបង្ខំ ការរៀនសូត្រ និងមន្ទីរសន្តិសុខ ដូចបានរៀបរាប់នៅក្នុងវក្យខណ្ឌស្តីពី អង្គហេតុជាសម្ភារៈ។ **អ៊ឹម ចែម** បានដឹងអំពីប្រព័ន្ធនេះ បានចូលរួមក្នុងការពង្រឹងដល់ការអនុវត្តប្រព័ន្ធនេះ និងមានចេតនាចង់ឲ្យប្រព័ន្ធនៃការធ្វើបាបនេះកាន់តែរីកធំធាត់ថែមទៀត។

519. ដូចគ្នានឹងចេតនានៃឧក្រិដ្ឋកម្មទាំងនេះដែរ គឺគេអាចព្យាករបានថា ជាវិបាកមួយនៃឧក្រិដ្ឋកម្មទាំងនេះនៅក្នុង JEC ការរំលោភសេពសន្ថវៈចេញពីអាពាហ៍ពិពាហ៍ អាចត្រូវបានប្រព្រឹត្តឡើងដោយសមាជិកម្នាក់ ឬច្រើននាក់នៃ JCE និង/ឬ ដោយបុគ្គលដែលបានប្រើដោយសមាជិកណាម្នាក់នោះ ដើម្បីឲ្យអនុវត្តគោលបំណងទាំងនោះ។ ខណ:បានដឹងថា ការរំលោភសេពសន្ថវៈចេញពីអាពាហ៍ពិពាហ៍ អាចជាផលវិបាកមួយបណ្តាលមកពីការអនុវត្តគោលបំណង JCE ក៏ដោយ ក៏ **អ៊ឹម ចែម** នៅតែហ៊ានប្រថុយធ្វើដោយចេតនា។

520. សមាជិកភាពនៃ JCE របស់ **អ៊ឹម ចែម** នៅភូមិភាគពាយ័ព្យ ត្រូវបានបង្ហាញតាមរយៈការរួមចំណែក និង

ចេតនាចូលរួមប្រព្រឹត្តរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្ម មុខតំណែងនៃអំណាច និងឥទ្ធិពលរបស់គាត់នៅក្នុង បកក និងទំនាក់ទំនងការងារយ៉ាងជិតស្និទ្ធរបស់គាត់ជាមួយសមាជិក JCE ដទៃទៀត ជាពិសេស តាម៉ុក[2292]។ មុខតំណែងជាក់លាក់ និងតួនាទីដែល **អ៊ឹម ចែង** បានកាន់នៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ បង្ហាញឲ្យឃើញបន្ថែមទៀតនូវភាពលេចធ្លោ និងសមាជិកភាពរបស់គាត់នៅក្នុង JCE នៅភូមិភាគពាយ័ព្យ។ **អ៊ឹម ចែង** បានចូលរួមក្នុង JCE នៅភូមិភាគនិរតី ចាប់តាំងពីការចាប់ផ្តើមនៃសម័យកម្ពុជាប្រជាធិបតេយ្យ រហូតដល់គាត់ត្រូវបានបញ្ជូនទៅកាន់ភូមិភាគពាយ័ព្យប៉ុលដោយមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ រួមមាន ពត និង តា ម៉ុក[2293]។ បន្ទាប់មក **អ៊ឹម ចែង** ដោយធ្វើសកម្មភាពរួមគ្នាជាមួយអ្នកផ្សេងទៀតដើម្បីពង្រីកការអនុវត្តសហឧក្រិដ្ឋកម្មនៅភូមិភាគពាយ័ព្យនេះ បានកាន់តួនាទីដូចតទៅ៖ លេខាស្រុកព្រះនេត្រព្រះ សមាជិកគណៈតំបន់៥ និងអនុលេខាតំបន់៥។

521. **អ៊ឹម ចែម** បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុង JCE នៅភូមិភាគពាយ័ព្យ ដោយបាន៖

(i) ជ្រើសរើសមនុស្សពីភូមិភាគនិរតីជា "ជនគំរូ" ដើម្បីនាំយកទៅភូមិភាគពាយ័ព្យ[2294], ដឹកនាំក្រុមកម្មាភិបាល កងឈ្លប និងប្រជាជនពីភូមិភាគនិរតី នៅក្នុងការបោសសម្អាតដំបូងនៅភូមិភាគពាយ័ព្យ[2295], និងដឹកនាំ និងចូលរួមនៅក្នុងការប្រជុំនៅភ្នំពេញ និងនៅតំបន់៥ ដែលមានកងកម្លាំងនិរតីដែលគាត់បានដឹកនាំទៅកាន់ភូមិភាគពាយ័ព្យ ត្រូវបានបែងចែក និងបានរៀបចំ[2296]។

(ii) បញ្ជា លើកទឹកចិត្ត ជួយសម្រួល និង/ឬ អនុញ្ញាតឲ្យមានការដកចេញ និងការសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ ដែលត្រូវបានរៀបរាប់ថាជា "ជនក្បត់" និងគ្រួសារ[2297] និងបញ្ជា និង/ឬ ជួយសម្រួលដល់ការដកកម្មាភិបាលភូមិភាគពាយ័ព្យចេញទៅស-២១[2298]។

(iii) ចាត់តាំងកម្មាភិបាលភូមិភាគនិរតី ឲ្យជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ ដែលត្រូវបានបោសសម្អាត[2299]។

(iv) ធ្វើការប្រជុំនៅមន្ទីររបស់គាត់នៅភ្នំលៀប ដែលនៅក្នុងការប្រជុំនោះពួកកម្មាភិបាលត្រូវបានចាប់ខ្លួន និងណែនាំ និង/ឬ អនុញ្ញាតឲ្យប្រើប្រាស់មន្ទីរភ្នំលៀបជាកន្លែងឃុំខ្លួនបណ្ដោះអាសន្ននូវជនណាដែលក្រោយមកត្រូវបានជាប់ឃុំឃាំង និង/ឬ សម្លាប់ចោលនៅមន្ទីរសន្តិសុខភ្នំត្រយោង និងទីកន្លែងផ្សេងៗទៀត[2300]។

(v) ត្រួតពិនិត្យគ្រប់ឃុំ សហករណ៍ ភូមិ កងចល័ត និងកងកម្លាំង នៅព្រះនេត្រព្រះ រួមមាន[2301] និងបញ្ជូនប្រជាជននៅស្រុកព្រះនេត្រព្រះ សម្រាប់គម្រោងពលកម្មដោយបង្ខំនានា ដឹងថាការណ៍នេះពាក់ព័ន្ធនឹងពលករដែលត្រូវបង្ខំឲ្យធ្វើការក្នុងលក្ខខណ្ឌស្មើទៅនឹងការធ្វើឲ្យទៅជាទាសករ[2302]។

(vi) ប្រជុំវគ្គ រៀនសូត្រ/អប់រំមនោគមវិជ្ជា ជាប្រចាំ នៅតំបន់៥[2303]។

(vii) ចាត់តាំងកម្មាភិបាលឲ្យទទួលខុសត្រូវលើការដ្ឋាន និងមន្ទីរសន្តិសុខ[2304] និងបញ្ជូនអ្នកនៅក្រោមបង្គាប់ឲ្យទៅពិនិត្យមើលការដ្ឋាន និងមន្ទីរសន្តិសុខ[2305]។

(viii) ញុះញង់ អុចអាល ជម្រុញឲ្យ និងលើកទឹកចិត្តដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម រួមមាន ដោយការចុះពិនិត្យមើលមន្ទីរសន្តិសុខ និងការដ្ឋានពលកម្មដោយបង្ខំ និងគាំទ្រគោលនយោបាយ បកក នៃការផ្តោតគោលដៅលើ "ខ្មាំង"[2306]។

(ix) បញ្ជាឲ្យប្រជាជន ប្រធានភូមិ និងប្រធានឃុំ កងចល័ត និងប្រធានកងចល័ត ចូលរួមនៅក្នុងប្រជុំដែលគាត់បានដឹកនាំ ឬបានចូលរួម ហើយដែលនៅក្នុងនោះ បញ្ហានានាដែលបានពិភាក្សារួមមាន៖ ការចាំបាច់ចំរាញ់រកសមាជិកនៃរបបមុនដើម្បីសម្លាប់ចោល ការស្រាវជ្រាវ និងកំចាត់ចោលនូវខ្មាំងផ្ទៃក្នុង ដាស់តឿនអ្នកចូលរួមមិនឲ្យខ្ជិលច្រអូស ឬប្រឆាំងនឹងអង្គការ និងគំរាមអ្នកចូលរួមថាពួកគេនឹងត្រូវបានដាក់ទណ្ឌកម្មបើពួកគេបានធ្វើខុសអ្វីមួយ[2307]។

(x) ដឹកនាំ និងចូលរួមនៅក្នុងការប្រជុំថ្នាក់ស្រុក និងតំបន់៥ ដើម្បី៖ ចាត់តាំងគំរោងការ និងផ្តល់សេចក្តីណែនាំស្តីពីការអនុវត្ត ចាត់តាំងកម្មាភិបាល និងឲ្យគេចាប់ខ្លួនកម្មាភិបាល និងសម្លាប់ចោល[2308]។

(xi) ធ្វើជាអធិបតី រៀបចំ ជួយសម្រួល និង/ឬ សម្របសម្រួល និងដាក់ទិសឲ្យរៀបការដោយបង្ខំ និងទទួលរបាយការណ៍ស្តីពីប្រធានបទបែបដូចជាការរៀបការដោយបង្ខំនៅតំបន់៥[2309]។

(xii) ធ្វើសកម្មភាពតាមរបាយការណ៍ពីសហករណ៍នានានៅស្រុកព្រះនេត្រព្រះ ពាក់ព័ន្ធនឹងប្រជាជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនូវ "កំហុស" សម្រេចត្រូវបញ្ជូនអ្នកណាឲ្យទៅរៀនសូត្រ និងបញ្ជូនប្រជាជនឲ្យទៅកាន់កន្លែងដូចជា មន្ទីរសន្តិសុខភ្នំត្រយោងដើម្បីរៀនសូត្រ[2310]។

(xiii) បង្កើត ឬចូលរួមនៅក្នុងការបង្កើតមន្ទីរសន្តិសុខភ្នំត្រយោង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការរបស់វា រួមមាន ចាត់តាំងប្រធានមន្ទីរសន្តិសុខ ធ្វើសេចក្តីសម្រេចលើប្រភេទអ្នកជាប់ឃុំ និងដាក់វិធាន និងគោលនយោបាយដើម្បីអនុវត្ត[2311]។

(xiv) ចេញបញ្ជាឲ្យចាប់ខ្លួនពួកស្រុកព្រះនេត្រព្រះ និងសេរីសោភ័ណ្ឌ ដែលត្រូវបានដឹកនាំដោយយោធា និងអ្នកនៅក្រោមបង្គាប់របស់គាត់ និងបញ្ជូនប្រជាជនដែលគាត់បានបញ្ជាឲ្យចាប់ខ្លួន និង/ឬ លើកទោស ឲ្យទៅឃុំខ្លួននៅតាមទីកន្លែងផ្សេងៗ[2312]។

(xv) មិនប្រើនូវអំណាច និងសិទ្ធិរបស់គាត់នៅថ្នាក់ស្រុក និងតំបន់ ដើម្បីដោះលែងអ្នកជាប់ឃុំ ពីមន្ទីរសន្តិសុខទេ[2313]។

(xvi) បញ្ជា លើកទឹកចិត្ត ញុះញង់ និង/ឬ អត់ឱនដល់ការសម្លាប់ប្រជាជន និងដោយឡែក ក្រុមគោលដៅ ដូចជា អតីតសមាជិកនៃរបប លន់ នល់ អ្នកដែលមានជាតិពន្ធុវៀតណាម ឬ អ្នកដែលគេជឿថាមានទំនាក់ទំនងទៅនឹងវៀតណាម និងជនជាតិខ្មែរក្រោម ឬអ្នកដែលគេសន្មតថាមានទំនាក់ទំនងជាមួយនឹងខ្មែរក្រោម អ្នកដែលបានប្រព្រឹត្តិកំហុសសីលធម៌ អ្នកដែលលែងធ្វើការងារបាន និងអ្នកដែលត្រូវបានចោទប្រកាន់ថាជា "ខ្មាំង"[2314]។

(xvii) ផ្សព្វផ្សាយ លើកទឹកចិត្ត និង/ឬ ជួយសម្រួលដល់ការផ្សព្វផ្សាយការឃោសនារបស់ បកកដែលបានផ្តោតទៅលើការនាំឲ្យមានការភ័យខ្លាច និងការស្អប់ជនជាតិភាគតិច និងអ្នកដែលបានចាត់ទុកថាជា "ខ្មាំង"[2315]។

(xviii) បង្កើតគំរោងការងារពលកម្មដោយបង្ខំ ដូចជា ការដ្ឋានស្ពានស្រែង និងត្រួតពិនិត្យមើលការសាងសង់ដោយការប្រើមនុស្សដោយបង្ខំរាប់ពាន់នាក់ រួមទាំង កូនក្មេងផង បានដឹងថាការណ៍នេះពាក់ព័ន្ធនឹងពលករដែលត្រូវបង្ខំឲ្យធ្វើការក្នុងលក្ខខណ្ឌដែលស្មើទៅនឹងការធ្វើឲ្យទៅជាទាសករ[2316]។

(xix) ត្រួតត្រា និងត្រួតពិនិត្យមើលការដ្ឋាន ចាត់តាំងមេដឹកនាំកងការងារ និងផ្ដល់សេចក្ដីណែនាំ ស្ដីពីគំរោងការងារពលកម្មដោយបង្ខំ ចាត់ចែងលក្ខខណ្ឌការងារសម្រាប់កន្លែងពលកម្មដោយបង្ខំ រៀបចំ និងបញ្ជូនអ្នកធ្វើការឲ្យទៅកាន់ការដ្ឋានពលកម្មដោយបង្ខំ ដែលពួកគាត់ត្រូវបានបង្ខំឲ្យធ្វើការដោយគ្មានម្ហូបអាហារគ្រប់គ្រាន់ និងប្រកបដោយលក្ខខណ្ឌអមនុស្សធម៌ និងផ្លាស់ប្ដូរកងចល័តការងារឲ្យទៅកន្លែងគំរោងសាងសង់ផ្សេងៗ[2317]។

(xx) តំណាងឲ្យ បកក នៅពេលគណៈប្រតិភូបរទេសធ្វើទស្សនកិច្ចការដ្ឋានពលកម្មដោយបង្ខំ[2318]។

(xxi) ទទួលរបាយការណ៍ស្ដីពីអ្នកធ្វើការដោយបង្ខំ ដែលបានគេចចេញពីការដ្ឋាន និងបញ្ជាឲ្យឈ្លបស្រាវជ្រាវរក និងនាំជនរត់គេចខ្លួនទៅមន្ទីរសន្ដិសុខ[2319]។

(xxii) មានសិទ្ធិអំណាចលើមន្ទីរសន្តិសុខចំការខ្នុរ ភ្នំត្រយោង វត្តព្រះនេត្រព្រះ និងចក្រី និងកន្លែងសម្លាប់មនុស្សដែលនៅជាប់នោះ និងការដ្ឋានត្រពាំងថ្ម និងស្ពានស្រែង - ដែលមានមនុស្សរាប់ពាន់នាក់ត្រូវបានចាប់ខ្លួន បានឃុំឃាំង បានដាក់គុក ដោយស្ថិតនៅក្រោមពលកម្មដោយបង្ខំ អំពើទារុណកម្ម ការរំលោភផ្លូវភេទ និងលក្ខខណ្ឌអមនុស្សធម៌ និងត្រូវបានសម្លាប់[2320]។

(xxiii) ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងថ្នាក់លើ បញ្ជូនរបាយការណ៍ និងទទួលសេចក្ដីណែនាំពី កម្មាភិបាលថ្នាក់លើ ដូចជា តាម៉ុក[2321] និង,

(xxiv) ខកខានមិនបានប្រើសិទ្ធិអំណាចដែលគាត់មានដើម្បីបញ្ឈប់នូវការអនុវត្ត JCE នេះ ទោះបីជាបានដឹងថា ឧក្រិដ្ឋកម្មកំពុងត្រូវបានប្រព្រឹត្តទៅតាមនោះ ហើយទោះបីជាអំណាចរបស់គាត់ក្នុងការរារាំង ឬបញ្ឈប់ឧក្រិដ្ឋកម្ម ឬក្នុងការដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តបទល្មើសក៏ដោយ[2322]។

522. ចេតនារបស់ **អ៊ឹម ចែម** អាចត្រូវបានបង្កើត និង/ឬ ទាញសេចក្ដីសន្និដ្ឋានចេញពី *ក្នុងចំណោមរឿងទាំងនោះ* គឺមានដូចតទៅ៖

(i) ការទទួលយកដោយស្ម័គ្រចិត្តរបស់គាត់ និងការចង់ចូលរួមចំណែកនៅក្នុងមុខតំណែង និងតួនាទីផ្សេងៗ ដែលធ្វើឲ្យគាត់អាចចូលរួមចំណែកនៅក្នុង JCE។

(ii) អំពើរបស់គាត់ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ ជាសមាជិកគណៈតំបន់៥ និងជាអនុលេខាតំបន់៥ នៅក្នុងការនឹកគិតថាជាឧក្រិដ្ឋកម្ម ហើយបន្តមកទៀតការប្រព្រឹត្តរបស់ពួកគេ ដូចដែលបានលម្អិតនៅក្នុងការចូលរួមចំណែករបស់គាត់ដែលបានរៀបរាប់ខាងលើ។

(iii) ការសម្របសម្រួលយ៉ាងជិតស្និទ្ធរបស់គាត់ និងអន្តរកម្មជាមួយនឹងមេដឹកនាំជាន់ខ្ពស់ ដូចជា តាម៉ុក និង ប៉ុល ពត។

(iv) ការទទួលស្គាល់របស់គាត់ថា "ស្មោះត្រង់ខ្លាំង" ក្នុងការអនុវត្តនូវគោលនយោបាយរបស់ បកក បានបកស្រាយដោយការជឿជាក់របស់គាត់ក្នុងការដឹកនាំបោសសម្អាតភូមិភាគពាយ័ព្យ[2323]។

(v) សេចក្តីថ្លែងរបស់គាត់ រួមមាន៖ ថាគាត់ "សប្បាយនឹងធ្វើការងាររបស់ខ្ញុំ", ថាគាត់ "តស៊ូដើម្បីជាតិ និងពូជសាសន៍របស់ខ្ញុំ", ការកោតសរសើរពីសំណាក់មេដឹកនាំជាន់ខ្ពស់ រួមមាន ប៉ុល ពត, និងការមិនមានវិប្បដិសារីចំពោះអ្វីដែលបានកើតឡើង[2324] និង,

(vi) ការចូលរួមជាបន្តជាមួយនឹងខ្មែរក្រហម និងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹង តាម៉ុក នៅក្រោយឆ្នាំ១៩៧៩[2325]។

## ការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងការជំរុញ

523. **អ៊ឹម ចែម** បានធ្វើផែនការឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ ដោយសារតួនាទីរបស់គាត់នៅថ្នាក់ស្រុក និងថ្នាក់តំបន់ ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ **អ៊ឹម ចែម** មានអំណាចរៀបចំ និង/ឬ ចូលរួមចំណែកនៅក្នុងការរៀបចំ ថាតើគោលនយោបាយរបស់មជ្ឈិម បកក ត្រូវបានអនុវត្តនៅតាមទីកន្លែងទាំងនោះយ៉ាងដូចម្តេច។ ការចូលរួមចំណែករបស់ **អ៊ឹម ចែម** នៅក្នុងការរៀបចំ និងការធ្វើជារូបមន្តនៃការអនុវត្តក្នុងតំបន់ចំពោះគោលនយោបាយជាតិរបស់ បកក បានរួមចំណែកយ៉ាងសំខាន់ចំពោះការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ក្នុងតំបន់១៣ នៃភូមិភាគនិរតី និងតំបន់៥ នៃភូមិភាគពាយ័ព្យ។ **អ៊ឹម ចែម** មានបំណងធ្វើផែនការលើការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬដោយអាស្រ័យនូវតួនាទីនិងមុខងាររបស់គាត់ បានដឹងពីទំនាក់ទំនងគ្នាយ៉ាងសំខាន់ ដែលថាឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្តនៅក្នុងការអនុវត្តអំពើដែលគាត់បានចូលរួមចំណែកនៅក្នុងការធ្វើផែនការ។

524. **អ៊ឹម ចែម** បានញុះញង់ឲ្យមានឧក្រិដ្ឋកម្មដែលបានចែងនៅទីនេះ។ តាមរយៈមុខងាររបស់គាត់ គាត់បានជម្រុញ បង្ខំ លើកទឹកចិត្ត បង្ក និងញុះញង់ដល់អ្នកប្រព្រឹត្តបទល្មើស ដែលបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ។ អំពើញុះញង់របស់គាត់ឲ្យមានឧក្រិដ្ឋកម្ម ជាការរួមចំណែកយ៉ាងសំខាន់ចំពោះការប្រព្រឹត្តរបស់ពួកគេ។ សេចក្តីថ្លែងជាញឹកញាប់របស់ **អ៊ឹម ចែម** អំពីគោលនយោបាយរបស់ បកក ទៅកាន់កម្មាភិបាលថ្នាក់ក្រោម បង្ហាញថា គាត់មានចេតនាដើម្បីញុះញង់ដល់អ្នកប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឲ្យប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ ឬយ៉ាងហោចណាស់ ក៏បានដឹងពីភាពទំនាក់ទំនងគ្នាយ៉ាងសំខាន់ ដែលថាឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្តនៅក្នុងការអនុវត្តនូវអំពើដែលគាត់បានញុះញង់។

525. **អ៊ឹម ចែម** បានបញ្ជាឲ្យមានឧក្រិដ្ឋកម្មដែលបានលម្អិតនៅក្នុងដីកាសន្និដ្ឋាននេះ។ យោងទៅតាមមុខងារនៃសិទ្ធិអំណាចរបស់គាត់ **អ៊ឹម ចែម** បានបង្កើតជារូបមន្ត និងបានចេញបញ្ជា និងសេចក្តីណែនាំទៅកាន់កម្មាភិបាល បកក ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម។ **អ៊ឹម ចែម** មានបំណងធ្វើឲ្យអ្នកដែលនៅក្រោមសិទ្ធិអំណាច *តាមព្រឹត្តន័យ និង/ឬ តាមច្បាប់* ប្រព្រឹត្តឧក្រិដ្ឋកម្ម ឬយ៉ាងហោចណាស់ ក៏បានដឹងពីភាពទំនាក់ទំនងគ្នាយ៉ាងសំខាន់ ដែលថាឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្តនៅក្នុងការអនុវត្តនូវបញ្ជាទាំងនោះ។ ដោយសាររចនាសម្ព័ន្ធរបស់ បកក **អ៊ឹម ចែម** បានដឹងថា គាត់មានអំណាចដើម្បីនាំកម្មាភិបាលថ្នាក់ក្រោមធ្វើអំពើនោះ។

526. **អ៊ឹម ចែម** បានជួយ និងបានជម្រុញឲ្យមានឧក្រិដ្ឋកម្ម។ គាត់បានធ្វើដូច្នេះ ដោយបានផ្តល់នូវការលើកទឹកចិត្ត ផ្តល់នូវការគាំទ្រ និងផ្តល់នូវជំនួយអនុវត្តចំពោះកម្មាភិបាល បកក ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។ ការលើកទឹកចិត្តរបស់គាត់ គឺការគាំទ្រផ្លូវចិត្ត និងជំនួយអនុវត្តមានអានុភាពយ៉ាងសំខាន់ទៅលើការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនោះ។ ដោយសារមុខងារនៃសិទ្ធិអំណាចរបស់គាត់ និងរចនាសម្ព័ន្ធរបស់ បកក **អ៊ឹម ចែម** បានដឹងថាអំពើលើកទឹកចិត្តរបស់គាត់ និងការគាំទ្រខាងផ្លូវចិត្ត និងខាងការអនុវត្ត គឺបានជួយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម និងមានបំណងចង់ផ្តល់នូវជំនួយនោះ។ **អ៊ឹម ចែម** បានដឹងអំពីធាតុផ្សំយ៉ាងសំខាន់នៃឧក្រិដ្ឋកម្ម ដែលគាត់បានជួយ និងជម្រុញ ដូចដែលគាត់បានបន្តរក្សាទុកឲ្យបានដឹងអំពីអំពើនានានៃអ្នកប្រព្រឹត្តបទល្មើសដោយផ្ទាល់។

## ការទទួលខុសត្រូវរបស់ថ្នាក់លើ

527. ក្រោយមកទៀត និងតាមជម្រើសផ្សេង **អ៊ឹម ចែម** ទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ក្នុងឋានៈជាអ្នកជាន់ខ្ពស់ម្នាក់ ដោយអនុលោមតាមមាត្រា២៩ នៃច្បាប់ អ.វ.ត.ក ដោយអាស្រ័យនូវ៖ (i) មុខងាររបស់គាត់ក្នុងឋានៈជាថ្នាក់លើរបស់អ្នកប្រព្រឹត្តបទល្មើស ដែលបានលម្អិតនៅក្នុងដីកាសន្និដ្ឋាននេះ (ii) ការដឹងឮជាក់ស្តែងរបស់គាត់ ឬការមានព័ត៌មាននៅលើមូលដ្ឋានដែលគាត់មានហេតុផលនឹងត្រូវដឹងថាអ្នកនៅក្រោមបង្គាប់របស់គាត់បានប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តនូវឧក្រិដ្ឋកម្ម និង (iii) ការខកខានរបស់គាត់ នៅក្នុងការរារាំងដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬនៅក្នុងការដាក់ទណ្ឌកម្មដល់អ្នកប្រព្រឹត្តបទល្មើស។

528. ទំនាក់ទំនងរវាងថ្នាក់លើ-ថ្នាក់ក្រោម មានអត្ថិភាពរវាង **អ៊ឹម ចែម** និងរាល់កម្មាភិបាល បកក ទាំងអស់ដែលបានចូលរួមចំណែកដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ។ ខណៈដែលទំនាក់ទំនងខ្លះក្នុងចំណោមទំនាក់ទំនងទាំងនេះ មានលក្ខណៈដោយប្រយោល ឬ *តាមព្រឹត្តន័យ* **អ៊ឹម ចែម** ជាថ្នាក់លើរបស់បុគ្គលទាំងនេះ ដោយមកពីការត្រួតពិនិត្យមានប្រសិទ្ធភាពរបស់គាត់ទៅលើអ្នកទាំងនោះ ក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់ថ្នាក់ស្រុក និងថ្នាក់តំបន់[2326]។ **អ៊ឹម ចែម** មានសមត្ថភាពយ៉ាងសំខាន់ក្នុងការរារាំងដល់អ្នកនៅក្រោមបង្គាប់កុំឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មបាន គឺការដកចេញពីមុខងារ និង/ឬ ដាក់ទណ្ឌកម្ម ដូចដែលបានបង្ហាញ *ក្នុងចំណោមរឿងទាំងនោះ* ដោយការចូលរួមចំណែករបស់គាត់ នៅក្នុងការបោសសម្អាតពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងការតែងតាំងកម្មាភិបាល[2327]។ **អ៊ឹម ចែម** មានការដឹងឮជាក់ស្តែងអំពីឧក្រិដ្ឋកម្មដែលកំពុងត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់គាត់ ដែលបានបង្ហាញច្បាស់ដោយតួនាទីរបស់គាត់នៅក្នុងការបង្កើតនូវការអនុវត្តតាមតំបន់នៃគោលនយោបាយរបស់ បកក ដែលបណ្តាលឱ្យមានជាឧក្រិដ្ឋកម្ម និងរបាយការណ៍ជាញឹកញាប់ដែលគាត់បានទទួលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅក្នុងកន្លែងដែលនៅក្រោមសិទ្ធិអំណាចរបស់គាត់[2328]។ **អ៊ឹម ចែម** ខកខានមិនបានចាត់វិធានការណាមួយដើម្បីរារាំង ឬដាក់ទណ្ឌកម្មដល់ឧក្រិដ្ឋកម្មទាំងនេះ ទោះបីជាគាត់មានសមត្ថភាពក្នុងការធ្វើដូច្នេះក៏ដោយ។

## គ. យុត្តាធិការបុគ្គល

529. ដូចដែលបានបង្ហាញពីមុនមក សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា **អ៊ឹម ចែម** មិនមែនជា "មេ

ដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងអត្ថន័យនៃច្បាប់ និងកិច្ចព្រមព្រៀងនៃ អវតក នោះទេ[2329]។ ទោះបីជាតួនាទីយ៉ាងសំខាន់របស់គាត់នៅថ្នាក់ស្រុក និងថ្នាក់តំបន់ ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដោយយោងទៅលើការគ្រប់គ្រងរបស់គាត់លើកងយោធាជាច្រើន និងជីវិតរបស់ជនស៊ីវិលរាប់ម៉ឺននាក់ក៏ដោយ ក៏គាត់ស្ថិតនៅថ្នាក់ក្រោមគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម ភូមិភាគ និង លេខាតំបន់នៅក្នុងឋានានុក្រមរបស់ បកក ហើយមិនមែនជាមន្ត្រីថ្នាក់ខ្ពស់នៅក្នុងកងទ័ពរបស់ បកក នោះឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា **អ៊ឹម ចែម** មានមុខតំណែងសំខាន់ ប៉ុន្តែមិនមែនជា "កម្មាភិបាលជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ" នោះទេ។

530. ប៉ុន្តែ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា **អ៊ឹម ចែម** ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាមអត្ថន័យនៃច្បាប់ និង កិច្ចព្រមព្រៀងរបស់ អវតក។ ភស្តុតាងនៅលើសំណុំរឿង ០០៤/០១ បង្ហាញថា ក្នុងនាមជាមន្ត្រី បកក ក្នុងឋានានុក្រមដ៏សំខាន់នៅថ្នាក់ស្រុក និងថ្នាក់តំបន់ **អ៊ឹម ចែម** បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនានា ដែលបានប៉ះពាល់ដល់មនុស្សរាប់សិបពាន់នាក់ និងបានបណ្តាលឲ្យមានមនុស្សស្លាប់រាប់ពាន់អ្នក។

531. **អ៊ឹម ចែម** មានការទទួលខុសត្រូវខ្ពស់ នៅពេលដែលគាត់បានចូលរួមនៅក្នុងឧក្រិដ្ឋកម្មទាំងនេះ។ គាត់បានឡើងឋានៈពីប្រធានសហករណ៍មុនឆ្នាំ១៩៧៥ រហូតក្លាយជាអនុលេខាតំបន់ដ៏សំខាន់មួយនៅឆ្នាំ ១៩៧៨[2330]។ រាល់តួនាទីដែលគាត់មាននៅថ្នាក់ស្រុក និង ថ្នាក់តំបន់នៅក្នុងភូមិភាគពាយ័ព្យ និង និរតីត្រូវបានផ្តល់ឲ្យគាត់ដោយ តាម៉ុក[2331]។ ការឡើងឋានៈរបស់ **អ៊ឹម ចែម** នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ការចាត់តាំងឲ្យគាត់ដឹកនាំការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យ និង ការការពារ និងការទំនាក់ទំនងជាមួយសមាជិកជាន់ខ្ពស់បំផុតរបស់ បកក ដោយរួមមាន តាម៉ុក និង ប៉ុល ពត[2332] នោះបង្ហាញអំពីអំណាចរបស់គាត់ក្នុងការអនុវត្តគោលនយោបាយរបស់ បកក នៅគ្រប់ទីកន្លែងដែលគាត់បានប្រតិបត្តិ។

532. ការទទួលខុសត្រូវរបស់ **អ៊ឹម ចែម** មានវិសាលភាពចាប់ពីភូមិភាគនិរតី រហូតដល់ភូមិភាគពាយ័ព្យ និងភាគច្រើនបំផុតនៃរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ទទួលខុសត្រូវចំពោះព្រឹត្តិការណ៍នានានៅក្នុងស្រុកកោះអណ្តែត និង តំបន់ ១៣ ក្នុងឋានៈជាមន្ត្រីថ្នាក់ស្រុក និង ថ្នាក់តំបន់[2333]។ ការណ៍នេះរួម

មានមន្ទីរសន្តិសុខវត្តអង្គសិរីមាលី ដែលជាពិសេសខ្មែរក្រោម[2334] ត្រូវបានឃុំខ្លួន និងសម្លាប់ចាប់ពីឆ្នាំ ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧[2335]។ **អ៊ឹម ចែម** ត្រូវបានជ្រើសរើសដោយថ្នាក់លើរបស់ បកក ដើម្បីឲ្យដឹកនាំការបោសសម្អាតនៅក្នុងភូមិភាគពាយ័ព្យ នៅពាក់កណ្តាលឆ្នាំ១៩៧៧[2336] ដែលបណ្តាលឲ្យមានការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់កម្មាភិបាល បកក និងគ្រួសាររបស់ពួកគេជាបន្តបន្ទាប់[2337]។ គាត់ទទួលខុសត្រូវចំពោះព្រឹត្តិការណ៍នៅស្រុកព្រះនេត្រព្រះ និងតំបន់ ៥ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ ១៩៧៩ ដោយសំអាងលើមុខតំណែងរបស់គាត់នៅថ្នាក់ស្រុក និងតំបន់[2338]។ ការណ៍នេះរួមមានការបង្កើតមន្ទីរសន្តិសុខភ្នំត្រយោង ដែលជាមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខធំជាងគេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2339] ក៏ដូចជាការត្រួតត្រារបស់គាត់នៅមន្ទីរសន្តិសុខ ចក្រី[2340] វត្តព្រះនេត្រព្រះ[2341] និងវត្តចំការខ្នុរ[2342]។ **អ៊ឹម ចែម** ក៏បានផ្តួចផ្តើមការសាងសង់ទំនប់នៅការដ្ឋានស្ពានស្រែង[2343] និងមានការទទួលខុសត្រូវលើការដ្ឋានត្រពាំងថ្ម ដែលជាលទ្ធផលនៃមុខតំណែងរបស់គាត់[2344]។ ការចូលរួមរបស់ **អ៊ឹម ចែម** នៅក្នុងឧក្រិដ្ឋកម្មនានារួមមាន ការសម្លាប់ជាតិពន្ធុវៀតណាមក្នុងទ្រង់ទ្រាយធំ បុគ្គលដែលមានទំនាក់ទំនងជាមួយនឹងរបប លន់ នល់ និងអ្នកដែលត្រូវបានគេជឿដោយមូលហេតុផ្សេងៗថាជា "ខ្មាំង"[2345]។ ឧក្រិដ្ឋកម្មទាំងនេះមិនមែនជាការកើតមានឡើងដាច់ដោយឡែកពីគេនោះទេ ប៉ុន្តែបានកើតឡើងជាប្រព័ន្ធនៅទូទាំងរយៈពេលដែល **អ៊ឹម ចែម** បានកាន់អំណាចក្នុងតំណែងទាំងនេះ[2346]។ លេខាស្រុក បែបដូចជា **អ៊ឹម ចែម** ត្រូវបានចាត់ទុកថាជាថ្នាក់ដឹកនាំក្នុងកម្រិតដ៏សំខាន់មួយនៃ បកក ដោយមកពីមុខតំណែងរបស់ពួកគាត់ជាខ្សែសង្វាក់រវាងសហករណ៍ និងថ្នាក់លើ[2347]។ ខណៈដែលមេដឹកនាំតំបន់ ដូចជា **អ៊ឹម ចែម** មានសិទ្ធិអំណាចលើគ្រប់រឿងទាំងអស់ កងទ័ព និង ប្រជា - នៅក្នុងតំបន់របស់ពួកគេរៀងៗខ្លួន - ជនស៊ីវិល[2348]។

533. ទោះបីជា **អ៊ឹម ចែម** បានអះអាងថារូបគាត់ត្រូវបាន "ស្វាគមន៍" អរគុណ និងស្រលាញ់ដោយប្រជាជនដោយសារតែការខិតខំប្រឹងប្រែងរបស់គាត់ក្នុងការធ្វើឲ្យជីវភាពរបស់ពួកគេប្រសើរឡើងក៏ដោយ[2349] ក៏សាក្សីនានាដែល កសចស បានស្តាប់ចម្លើយប្រាប់រឿងខុសឆ្ងាយពីនេះ ដូចបានរៀបរាប់ខាងលើ។ ការពិតនៃកេរ្តិ៍តំណែលរបស់ **អ៊ឹម ចែម** ក៏ត្រូវបានបង្ហាញនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ទាំងឡាយ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ សហព្រះរាជអាជ្ញាអន្តរជាតិបានកំណត់អត្តសញ្ញាណអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាង ៤០០ នាក់ ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានចុះបញ្ជី និងសង្ខេបនៅក្នុង

01342199



ឧបសម្ព័ន្ធ ៧ - ដែលរៀបរាប់អំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរយៈកាលនៃការត្រួតត្រារបស់ **អ៊ឹម ចែម**។ ជនរងគ្រោះជាច្រើនក្នុងចំណោមជនរងគ្រោះទាំងនោះបញ្ជាក់អត្តសញ្ញាណ **អ៊ឹម ចែម** យ៉ាងជាក់លាក់តាមរយៈឈ្មោះក្នុងឋានៈជាបុគ្គលម្នាក់ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងប្រឆាំងនឹងពួកគេ និងសាច់ញាតិរបស់ពួកគេ[2350]។ ចំនួនអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដ៏ច្រើន ជាពិសេសធៀបទៅនឹងចំនួនដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២[2351] បង្ហាញឲ្យឃើញពីចំណាប់អារម្មណ៍ដ៏ខ្លាំងរបស់ជនរងគ្រោះក្នុងការចោទប្រកាន់ **អ៊ឹម ចែម**។

534. សហព្រះរាជអាជ្ញាអន្តរជាតិទទួលស្គាល់ថា ការទទួលខុសត្រូវរបស់ **អ៊ឹម ចែម** ចំពោះឧក្រិដ្ឋកម្មនានានៃរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈតិចជាងការទទួលខុសត្រូវរបស់ជនជាប់ចោទ ដែលបច្ចុប្បន្នកំពុងជំនុំជម្រះនៅក្នុងសំណុំរឿង០០២។ ប៉ុន្តែ កម្រិតនៃការទទួលខុសត្រូវប្រហាក់របស់គាត់ប្រហែលជាស្មើទៅនឹងការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជនជាប់ចោទក្នុងសំណុំរឿង០០១ បច្ចុប្បន្នជាទណ្ឌិក និងប្រហែលជាធំជាងការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងសំណុំរឿង០០២ អៀង ធីរិទ្ធ (បច្ចុប្បន្នស្លាប់)។ ទោះបីជា ឌុច ដើរតួផ្ទាល់ និងកៀកជាងក្នុងការសម្លាប់ និងការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ក៏ដោយ ក៏ **អ៊ឹម ចែម** មានអំណាចខ្ពស់ជាងនេះ ដែលគ្រប់គ្រងលើជីវិតរបស់ជនរងគ្រោះជាជនស៊ីវិលច្រើនជាងជាច្រើនដង។ មន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខនានា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ មានចំនួនជនរងគ្រោះស្មើ ឬ ច្រើនជាងចំនួនជនរងគ្រោះនៅ ស-២១ ក្នុងរយៈពេលដំណើរការដ៏ខ្លី។ ទោះបីជា អៀង ធីរិទ្ធ មានមុខងារជារដ្ឋមន្ត្រី និងបានដើរតួនាទីមួយនៅថ្នាក់ជាតិ ក៏គាត់មិនមានកងកម្លាំងយោធា មន្ទីរសន្តិសុខ ឬ ការដ្ឋានស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់គាត់ទេ។ អៀង ធីរិទ្ធ គ្រាន់តែមានអំណាចលើមនុស្សជាង ១២០០ ទៅ ១៣០០ នាក់ ប៉ុណ្ណោះ ហើយជាប់ទាក់ទងផ្ទាល់ទៅនឹងការចាប់ខ្លួនមនុស្សតិចជាង **អ៊ឹម ចែម** ខ្លាំងណាស់។ ការចូលរួមចំណែករបស់ អៀង ធីរិទ្ធ ក្នុងឧក្រិដ្ឋកម្មមិនមានលក្ខណៈផ្ទាល់ និង សំខាន់ ដូចការចូលរួមក្នុងឧក្រិដ្ឋកម្មរបស់ **អ៊ឹម ចែម** នោះទេ។

535. បន្ថែមលើនេះទៀត ទំហំ និងទម្ងន់នៃឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងក្រោមការគ្រប់គ្រងរបស់ **អ៊ឹម ចែម** ដាក់គាត់ក្នុងចំណោមបុគ្គលសំខាន់ៗបំផុតដែលត្រូវស៊ើបអង្កេតក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ការប្រៀបធៀបជាមួយអ្នកដែលត្រូវបានចោទប្រកាន់នៅតុលាការ ICTY, SCSL និង ICC - ដែលត្រូវ

បានសង្ខេបក្នុងឧបសម្ព័ន្ធ ៨- បង្ហាញថាកម្រិត លក្ខណៈ និងរយៈពេលនៃបទល្មើសព្រហ្មទណ្ឌដែល **អ៊ឹម ចែម** ទទួលខុសត្រូវមានទំហំច្រើនលើសបទល្មើសព្រហ្មទណ្ឌដែលគេឃើញមាននៅក្នុងរឿងក្តីផ្សេងៗទៀត។

536. សហព្រះរាជអាជ្ញាអន្តរជាតិពិចារណាថា **អ៊ឹម ចែម** បំពេញបានលក្ខខណ្ឌចាំបាច់ជាមេដឹកនាំមិនជាន់ខ្ពស់ នៃរបបខ្មែរក្រហម ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអត្ថន័យនៃច្បាប់ និង កិច្ចព្រមព្រៀងរបស់ អវតក។ ការចោទប្រកាន់ **អ៊ឹម ចែម** ដែលជាមន្ត្រី បកក ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ដែលបានបណ្តាលឲ្យមានទុក្ខវេទនាដល់ប្រជាជនកម្ពុជាជាង ១០០.០០០ នាក់ និងបាននាំឲ្យមានការស្លាប់មនុស្សរាប់សិបពាន់នាក់នោះ នឹងធ្វើឲ្យជឿនលឿនដល់ការស្វែងរកយុត្តិធម៌ និងគោលបំណងនានាដែល អវតក នេះត្រូវបានបង្កើតឡើង។

537. ប្រតិកម្មប្រកបដោយសន្តិភាព និងវិជ្ជមានរបស់ប្រជាជនកម្ពុជា ចំពោះការកាត់ទោស នួន ជា និង ខៀវ សំផន ដែលជាមេដឹកនាំជាន់ខ្ពស់បំផុតដែលនៅរស់ បានបង្ហាញឲ្យឃើញថា ការចោទប្រកាន់មន្ត្រី បកក ក្នុងចំនួនដ៏មានកម្រិតមួយនោះ មិនមែនជាការគំរាមកំហែងដល់សន្តិភាព និងសន្តិសុខរបស់ប្រទេសកម្ពុជានោះទេ។ ផ្ទុយទៅវិញ សំណុំរឿង០០២ បានបង្ហាញថាការចោទប្រកាន់ទាំងនោះបានជួយលើកកម្ពស់ការយល់ដឹងក្នុងចំណោមប្រជាជនកម្ពុជាថា ពេលនេះពួកគាត់រស់នៅក្នុងសង្គមមួយ ដែលគោលនយោបាយឧក្រិដ្ឋដ៏ឃោរឃៅដូចអ្វីដែលបង្កើតឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនោះ នឹងមិនត្រូវបានអត់ឱនទៀតនោះទេ។

538. ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិជឿជាក់ថា កិច្ចដំណើរការស៊ើបអង្កេត និង ចោទប្រកាន់ **អ៊ឹម ចែម** គឺជាការអនុវត្តដ៏ត្រឹមត្រូវនៃឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងថាប្រសិនបើការចោទប្រកាន់នេះដំណើរការទៅមុខ ការងាររបស់ អវតក អាចត្រូវបានបញ្ចប់ក្នុងរយៈពេលសមស្រប។

## V. បទចោទ

539. ដោយពិចារណាលើអង្គហេតុសម្ភារៈ និងការកំណត់បទចោទ ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនខ្លួន **អ៊ឹម ចែម** ទៅជំនុំជម្រះ អនុលោមតាមមាត្រា ២៩ ពីបទបានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយ និងជំរុញ និង/ឬ បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួមនូវឧក្រិដ្ឋកម្មដូចមានរៀបរាប់ខាងក្រោមនេះ៖

(1) **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ដែលអាចផ្តន្ទាទោសបានតាមមាត្រា ៥, ២៩ (ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ អវតក ជាពិសេស៖

(ក) អំពើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការធ្វើឱ្យទៅជាទាសករ

(ឃ) ការដាក់ក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ច) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាតិសាសន៍ និង/ឬ សាសនា

(ឆ) អំពើអមនុស្សធម៌ផ្សេងៗទៀត៖ អាពាហ៍ពិពាហ៍ដោយបង្ខំ

(ជ) អំពើអមនុស្សធម៌ផ្សេងៗទៀត៖ ការរំលោភសេពសន្ថវៈ

(ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត៖ ការបាត់ខ្លួនដោយបង្ខំ និង

(ញ) អំពើអមនុស្សធម៌ផ្សេងៗទៀត៖ ការឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌

(2) **ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១០៤៩** ដែលអាចផ្តន្ទាទោសបានតាមមាត្រា ៦, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ អវតក ជាពិសេស៖

(ក) ការធ្វើមនុស្សឃាតដោយចេតនា

(ខ) ការធ្វើបាបដោយអមនុស្សធម៌

(គ) ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រូបកាយ ឬសុខភាព

(ឃ) ការដកហូតដោយចេតនាពីជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង) ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

540. លើសពីនេះទៀត និងតាមរបៀបផ្សេងពីនេះ អនុលោមតាមមាត្រា ២៩ អាចអន្និដ្ឋានបានថា **អ៊ឹម ចែម** គួរត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងនេះ ក្នុងឋានៈជាថ្នាក់លើ ដោយសារគាត់បានដឹង ឬមានហេតុផលបានដឹងថា ថ្នាក់ក្រោមរបស់គាត់នឹងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ឬបានធ្វើដូច្នោះ ហើយគាត់ខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្របដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មបែបនោះ ឬដើម្បីដាក់ទណ្ឌកម្មចារីទាំងអស់នោះ។

541. ហេតុដូច្នេះ សហព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងលេខ ០០៤/០១/០៧-០៩-២០០៩-អវតក-កសចស ទៅសហចៅក្រមស៊ើបអង្កេត និងស្នើសុំឲ្យនាំខ្លួន និងឃុំខ្លួន អ៊ឹម ចែម និងនាំគាត់មកចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអនុលោមតាមវិធាន ៦៨ (១) ប្រសិនបើមូលហេតុសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងក្នុងវិធាន ៦៣(៣) ត្រូវបានបំពេញ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ២៧ តុលា ២០១៦ | Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

# VI. ប្រភពតំណាង

1 **D6.1.1533** កំណត់ហេតុវិភាគរបស់ Craig C. Etcheson, ១៨ កក្កដា ២០០៧, កថាខណ្ឌ៩, EN 00142827។

2 **D6.1.1533** កំណត់ហេតុវិភាគរបស់ Craig C. Etcheson, ១៨ កក្កដា ២០០៧, កថាខណ្ឌ៧៧, EN 00142825។

3 **D6.1.1533** កំណត់ហេតុវិភាគរបស់ Craig C. Etcheson, ១៨ កក្កដា ២០០៧, កថាខណ្ឌ៦៧, EN 00142825, កថាខណ្ឌ ៥៨, EN 00142840។

4 **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨។

5 **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, ១៨ កក្កដា ២០១១។

6 **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ អំពើហិង្សាយេនឌ័រ, ២៤ មេសា ២០១៤។

7 **D254/1** ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តតាមាក់, ៤ សីហា ២០១៥។

8 **D272/1** ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤, ២០ វិច្ឆិកា ២០១៥។

9 **D108** ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១.១ឃ], ២៤ កុម្ភៈ ២០១២។ សូមមើល ផងដែរ, **D122/11** ដីកាសម្រេចទទួលស្គាល់មេធាវីតំណាងជនសង្ស័យ អ៊ឹម ចែម, ២៤ កុម្ភៈ ២០១៤; **D122/13** ការចាត់តាំងសហមេធាវីដើម្បីការពារ អ៊ឹម ចែម ជាជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង០០៤, ២៩ មេសា ២០១៤។

10 **D251/6** សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តនន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251, ២១ កញ្ញា ២០១៥, កថាខណ្ឌ៣។

11 **D251/6** សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តនន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251, ២១ កញ្ញា ២០១៥, កថាខណ្ឌ៤។

12 **D251/6** សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តនន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251, ២១ កញ្ញា ២០១៥, កថាខណ្ឌ៧។

13 **D1/1.1** ឧបសម្ព័ន្ធ II: សេចក្តីដកស្រង់ ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១នៃវិធានផ្ទៃក្នុង, ១៨ សីហា ២០០៩។

14 **D1/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី៣, ៧ កញ្ញា ២០០៩។

15 **D1** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញា, ២០ វិច្ឆិកា ២០០៨។

16 **D114** កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនភាគីស្ដីអំពីភាពមិនអាចដំណើរការបានធូរធូរ ដែលរារាំងការបំពេញកិច្ចស៊ើបសួរឱ្យបានសមស្របក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤, ២១ មីនា ២០១២, កថាខណ្ឌ ១០, ១៧។

17 សេចក្ដីប្រកាសព័ត៌មានរបស់ អវតក, 'សេចក្ដីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ', ១០ តុលា ២០១១។

18 **D114** កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិផ្ញើជូនភាគីស្ដីអំពីភាពមិនអាចដំណើរការបានធូរធូរ ដែលរារាំងការបំពេញកិច្ចស៊ើបសួរឱ្យបានសមស្របក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤, ២១ មីនា ២០១២, កថាខណ្ឌ ១០។

19 សេចក្ដីប្រកាសព័ត៌មានរបស់ អវតក, 'សេចក្ដីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង', ១៩ មីនា ២០១២។

20 **D217.1.4** ញត្តិបន្ទាន់ស្នើសុំដីកាបង្គាប់ចូលមើលសំណុំរឿង, ១៤ ធ្នូ ២០១២, កថាខណ្ឌ៤, សេចក្ដីប្រកាសព័ត៌មាន អវតក, 'Mark Harmon បានស្បថចូលកាន់ដំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ', ២៦ តុលា ២០១២។

21 **D262** សេចក្ដីជូនដំណឹងពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅភាគីនានាស្ដីពីការចេញឡើងវិញនូវដីកាសម្រេចដែលចៅក្រម Harmon បានសម្រេចនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥, ៨ កញ្ញា ២០១៥, កថាខណ្ឌ១។

22 **A150** ដីកាកោះ អ៊ឹម ចែម ឱ្យបង្ហាញខ្លួនលើកដំបូង, ២៩ កក្កដា ២០១៤។

23 **A150/1** កំណត់ហេតុនៃការប្រគល់ដីកាកោះ, ៣១ កក្កដា ២០១៤។

24 **A151/2** ចម្លើយតបទៅនឹងដីកាកោះរបស់ កសចស, ១ សីហា ២០១៤។

25 **A122/6** ការឆ្លើយតបទាក់ទងនឹងទម្រង់នៃការប្រគល់ដីកាកោះជូន អ៊ឹម ចែម, ១ សីហា ២០១៤។

26 **D207** សំណើសុំបន្ទាន់របស់ អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ ចុះថ្ងៃទី៣១ ខែកក្កដា ២០១៤ ទៅអង្គបុរេជំនុំជម្រះ, ៦ សីហា ២០១៤។

27 **A122/6.1/1** សំណើបន្ទាន់របស់ អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង, ៧ សីហា ២០១៤។

28 **A122/6.1/3** សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅ អ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង, ១៥ សីហា ២០១៤; **A122/6.1/1**, សំណើបន្ទាន់របស់ អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង, ៧ សីហា ២០១៤។

29 **A122/6.1/3** សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង, ១៥ សីហា ២០១៤, កថាខណ្ឌ១៤។

30 **C1** ដីកាបង្គាប់ឱ្យនាំខ្លួន អ៊ឹម ចែម, ១៤ សីហា ២០១៤។

31 **D238** លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិជូនរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធានគណៈកម្មការសន្តិសុខប្រចាំ អវតក, ៣០ មករា ២០១៥។

32 **D239** ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ, ៣ មីនា ២០១៥។

33 **D239.1** ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ៣ មីនា ២០១៥។

34 **D239.1** ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ៣ មីនា ២០១៥, កថាខណ្ឌ ៤-៥, ១០, EN 01070895-01070896។

35 **D239.1** ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ៣ មីនា ២០១៥, កថាខណ្ឌ៦-៨, ១១-១២, EN 01070895-01070896។

36 **D239.1** ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង អ៊ឹម ចែម, ៣ មីនា ២០១៥, កថាខណ្ឌ១៣, EN 01070896។

37 **D251** សំណើសុំដាក់សារណាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" និង/ឬ ស្ថិតក្នុងចំណោម "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត", ២៤ កក្កដា ២០១៥។

38 **D251/4** សេចក្តីសង្កេតរបស់ អ៊ឹម ចែម ស្តីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ឬបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត", ២១ កញ្ញា ២០១៥; **D251/5**, សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ២១ កញ្ញា ២០១៥; **D251/6**, សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251, ២១ កញ្ញា ២០១៥។

39 **D251/4** សេចក្តីសង្កេតរបស់ អ៊ឹម ចែម ស្តីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ឬបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត", ២១ កញ្ញា ២០១៥, កថាខណ្ឌ៦០; **D251/6** សេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251, ២១ កញ្ញា ២០១៥, កថាខណ្ឌ១៣។

40 **D251/5** សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ២១ កញ្ញា ២០១៥, កថាខណ្ឌ ៤៤។

41 **D251/5** សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, ២១ កញ្ញា ២០១៥, កថាខណ្ឌ៤៥, ៥១។

42 **D285** សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម, ១៨ ធ្នូ ២០១៥។

43 **D286** សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់, ១៨ ធ្នូ ២០១៥។

44 **D285** សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ អ៊ឹម ចែម និងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់, ១៨ ធ្នូ ២០១៥, EN 01182560។

45 **D286/2** សារណារបស់ អ៊ឹម ចែម លើការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតចំពោះបំណងបោះបង់នូវបទចោទប្រកាន់ និងបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងអ្នកស្រី, ៨ មករា ២០១៦។

46 **D286/3** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអំពីការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំង អ៊ឹម ចែម, ១៥ មករា ២០១៦; **D286/3/2** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់មេធាវីការពារក្តីស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អ៊ឹម ចែម, ២២ មករា ២០១៦។

47 **D286/7** ដីកាសម្រេចបំបែកសំណុំរឿងទាក់ទងនឹង អ៊ឹម ចែម ចេញពីសំណុំរឿង០០៤, ៥ កុម្ភៈ ២០១៦។

48 **C1/1** ដីកាសម្រេចលុបចោលដីកាបង្គាប់ឲ្យនាំខ្លួន អ៊ឹម ចែម, ៥ កុម្ភៈ ២០១៦។

49 **D304** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤), ២៧ កក្កដា ២០១៦។

50 **D304** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤), ២៧ កក្កដា ២០១៦, EN 01308288, កថាខណ្ឌ៦-៧, ។

51 **D298**, សំណើរបស់ អ៊ឹម ចែម ស្នើឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះសុំឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំធ្វើមោឃភាពប្រតិចារឹក និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីមួយចំនួន, ១៦ កុម្ភៈ ២០១៦។

52 **D298/1**, សេចក្តីបន្ថែមលើការស្នើរបស់ អ៊ឹម ចែម ឲ្យដាក់ពាក្យបណ្តឹងទៅអង្គបុរេជំនុំជម្រះសុំធ្វើមោឃភាពលើប្រតិចារឹក និងកំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីមួយចំនួន, ៣ មីនា ២០១៦។

53 **D298/2**, ដីកាសម្រេចលើពាក្យសុំរបស់ អ៊ឹម ចែម ស្នើឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះ សុំឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពប្រតិចារឹក និងកំណត់ហេតុនៃការស្តាប់ចម្លើយ, ៦ ឧសភា ២០១៦, EN 01239004។

54 **D298/2**, ដីកាសម្រេចលើពាក្យសុំរបស់ អ៊ឹម ចែម ស្នើឲ្យប្តឹងទៅអង្គបុរេជំនុំជម្រះ សុំឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពប្រតិចារឹក និងកំណត់ហេតុនៃការស្តាប់ចម្លើយ, ៦ ឧសភា ២០១៦, EN 01239011-01239012។

55 **D304**, ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦(៤), ២៧ កក្កដា ២០១៦, កថាខណ្ឌ៨, EN 01308289។

56 ឯកសារដាក់នៅក្នុងសំណុំរឿង០០៤ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ នៅពេលសំណុំរឿងបញ្ជូនទៅសហព្រះរាជអាជ្ញា។

57 សូមមើល, កថាខណ្ឌ 60, 95-100, X103-105, 110-112, 118, 125, 129-130, .140, 148, 153-154, 174-175, 184, 187។

58 សូមមើល, កថាខណ្ឌ ៩០-៩៨, ១១២, ១៥៣-១៥៤, ១៨៤, ១៨៧។

59 សូមមើល, កថាខណ្ឌ ១០៣-១០៥, ១២៥, ១២៩-១៣០, ១៤០។

60 សូមមើល, កថាខណ្ឌ ៩៩, ១១៨, ១៤៨។

61 សូមមើល, ឧបសម្ព័ន្ធ ៥។

62 សូមមើល, ឧបសម្ព័ន្ធ ៥។

63 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩), ដូចដែលបានពិនិត្យសារឡើងវិញនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥, វិធាន៦៧(៣)(គ) (“វិធានផ្ទៃក្នុង”)។

64 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា២៤៧(៣)។

65 **D427**, ដីកាសំណោះស្រាយលើសំណុំរឿង០០២, ១៦ ធ្នូ ២០១០, EN 00604835, កថាខណ្ឌ ១៣២១។

66 **D99**, ដីកាសំណោះស្រាយលើសំណុំរឿង០០១, ១៨ សីហា ២០០៨, EN 00210815, កថាខណ្ឌ ១៣០។

67 **D427**, ដីកាសំណោះស្រាយលើសំណុំរឿង០០២, ១៦ ធ្នូ ២០១០, EN 00604835, កថាខណ្ឌ ១៣២១។

68 **D427**, ដីកាសំណោះស្រាយលើសំណុំរឿង០០២, ១៦ ធ្នូ ២០១០, EN 00604836, កថាខណ្ឌ ១៣២៣។

69 ដដែលដូចខាងលើ។

70 វិធានផ្ទៃក្នុង, វិធាន៨៧(១)។

71 **D427**, ដីកាសំណោះស្រាយលើសំណុំរឿង០០២, ១៦ ធ្នូ ២០១០, EN 00604835, កថាខណ្ឌ ១៣២១។

72 ក្រមនីតិវិធីព្រហ្មទណ្ឌនៃសាធារណរដ្ឋបារាំង ឆ្នាំ១៩៩៥, មាត្រា ១៧៧ ["Si le juge d'instruction estime que les faits ne constituent ni crime, ni délit, ni contravention, ou si l'auteur est resté inconnu, ou s'il n'existe pas de charges suffisantes contre la personne mise en examen, il déclare, par une ordonnance, qu'il n'y a lieu à suivre."]។

73 **D427**, ដីកាសំណោះស្រាយលើសំណុំរឿង០០២, ១៦ ធ្នូ ២០១០, EN 00604835, កថាខណ្ឌ ១៣២២។

74 ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, 2187 U.N.T.S. 38544, ដែលបានអនុម័តនៅថ្ងៃទី១៧ ខែកក្កដា ១៩៩៨, ចូលជាធរមាននៅថ្ងៃទី១ កក្កដា ២០០២, មាត្រា៦១(៥) ["នៅពេលសវនាការ រដ្ឋអាជ្ញាត្រូវគាំទ្រចំពោះបទចោទនីមួយៗតាមរយៈភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីកំណត់អំពីទឡ្ហីករណ៍ជាសារវន្តដែលនាំឱ្យជឿបានថា បុគ្គលរូបនោះពិតជាបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់នោះមែន។ រដ្ឋអាជ្ញាអាចពឹងផ្អែកលើភ័ស្តុតាងជាឯកសារ ឬភ័ស្តុតាងសង្ខេប និងមិនចាំបាច់កោះហៅសាក្សីដែលបានរំពឹងថានឹងមកផ្តល់សក្ខីកម្មនៅឯសវនាការទេ"]

75 *Al Mahdi*, សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ១៥, លើកឡើងពី *Lubanga* សេចក្តីសម្រេចលើការបញ្ជាក់,កថាខណ្ឌ៣៧។ *Abu Garda*, សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ៣៩។ *Banda & Jerbo*, សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ៣១។ *Mbarushimana*, សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ៤១។

76 Al Mahdi, សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ១៨, *យោង:* សេចក្តីសម្រេចលើការបញ្ជាក់ក្នុងរឿងក្តី Lubanga, កថាខណ្ឌ៣៩។*Katanga & Ngudjolo* សេចក្តីសម្រេចលើការបញ្ជាក់,,កថាខណ្ឌ៦៥។ *Bemba* សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ២៩។ សេចក្តីសម្រេចលើការបញ្ជាក់ក្នុងរឿងក្តី Abu Garda, កថាខណ្ឌ៣៧។ សេចក្តីសម្រេចលើការបញ្ជាក់ក្នុងរឿងក្តី Mbarushimana, កថាខណ្ឌ៤០។ *Muthaura នឹងគូកន.*,សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ៥២។ *Ntaganda*, , សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ៩។ *Gbagbo*, សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ១៩។ *Bemba* សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ២៥។ *Blé Goudé*,សេចក្តីសម្រេចលើការបញ្ជាក់, កថាខណ្ឌ១២។ *Ongwen*,សេចក្តីសម្រេចលើការបញ្ជាក់,, កថាខណ្ឌ១៧។

77 វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃយន្តការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ, MICT/1/វិសោធនកម្មលើកទី១, ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦, វិធាន៤៨ ["រដ្ឋអាជ្ញា ប្រសិនបើពេញចិត្តទៅនឹងដំណើរការនៃកិច្ចស៊ើបសួរថា មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តល់នូវទឡ្ហីករណ៍សមហេតុផលដែលនាំឱ្យជឿបានថា ឧក្រិដ្ឋកម្មដូចមានចែងក្នុងមាត្រា១ កថាខណ្ឌ៤ នៃច្បាប់លក្ខន្តិកៈត្រូវបានប្រព្រឹត្តមែននោះ ខ្លួនត្រូវរៀបចំ និងបញ្ជូនទៅក្រឡាបញ្ជីនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយអមទៅជាមួយនូវសម្ភារៈគាំទ្រ ដើម្បីសុំការបញ្ជាក់ពីចៅក្រម"]។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតៈយូហ្គោស្លាវី, IT/32/វិសោធនកម្មលើកទី៤៦, ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី២០ ខែតុលា ឆ្នាំ

២០១១, វិធាន៤៧(ខ) ["រដ្ឋអាជ្ញា ប្រសិនបើពេញចិត្តទៅនឹងដំណើរការនៃកិច្ចស៊ើបសួរថា មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តល់នូវទឡ្ហីករណ៍សមហេតុផលដែលនាំឱ្យជឿបានថា ជនសង្ស័យបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការតុលាការមែននោះ ខ្លួនត្រូវរៀបចំ និងបញ្ជូនទៅក្រឡាបញ្ជីនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីសុំការបញ្ជាក់ពីចៅក្រម ដោយអមទៅជាមួយនូវសម្ភារៈគាំទ្រ"]។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៥, វិធាន៤៧(ខ) ["រដ្ឋអាជ្ញា ប្រសិនបើពេញចិត្តទៅនឹងដំណើរការនៃកិច្ចស៊ើបសួរថា មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តល់នូវទឡ្ហីករណ៍សមហេតុផលដែលនាំឱ្យជឿបានថា ជនសង្ស័យបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការតុលាការមែននោះ ខ្លួនត្រូវរៀបចំ និងបញ្ជូនទៅក្រឡាបញ្ជីនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីសុំការបញ្ជាក់ពីចៅក្រម ដោយអមទៅជាមួយនូវសម្ភារៈគាំទ្រ"]។

78 *Ntakirutimana,* សេចក្តីសម្រេចលើសំណើបឋម, កថាខណ្ឌ៦។

79 ច្បាប់លក្ខន្តិកៈដែលបានធ្វើបច្ចុប្បន្នភាពរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតៈយូហ្គោស្លាវី, ដែលបានធ្វើបច្ចុប្បន្នភាពក្នុងខែកញ្ញា ឆ្នាំ២០០៩, មាត្រា១៩(១) ["ការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ - ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងដែលជាអ្នកទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ប្រសិនបើខ្លួនពេញចិត្តថាករណីបឋមត្រូវបានបង្កើតដោយរដ្ឋអាជ្ញាហើយ នោះខ្លួនត្រូវធ្វើការបញ្ជាក់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ បើសិនជាគាត់មិនពេញចិត្តនោះដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរបានបដិសេធចោល"]។ ច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា, មាត្រា១៨(១) ["ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងដែលជាអ្នកទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ប្រសិនបើខ្លួនពេញចិត្តថាករណីបឋម ត្រូវបានបង្កើតដោយរដ្ឋអាជ្ញាហើយ នោះខ្លួនត្រូវធ្វើការបញ្ជាក់លើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

80 *Kordic នឹងគូកន.,* សេចក្តីសម្រេចស្តីពីការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ទំព័រ៤។ *Milosevic នឹងគូកន.,*សេចក្តីសម្រេចស្តីពីការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ, កថាខណ្ឌ២។ *Rajic* ការពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ, ទំព័រ៦។

81 **D132.1.160** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ៤៥ ពី ឆុន ទៅកាន់ ប៉ុល ពត ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ EN 00182596។ **D6.1.741** *ទង់បដិវត្ត,* កុម្ភៈ ១៩៧៨, EN 00464061។

82 **D6.1.442** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែម ញ៉ា ១៤ ខែមករា ឆ្នាំ២០០៩, EN 00282321។ **D6.1.501** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន សុវណ្ណហាន ១១ ខែមីនា ឆ្នាំ២០០៩, EN 00295165។ **D6.1.858** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញាន ប៊ុក ២១ ខែសីហា ឆ្នាំ២០០៩ , EN 00373377។ **D6.1.840** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល ញ៉ុន ៣១ ខែសីហា ឆ្នាំ២០០៩ , EN 00377402។ **D6.1.640** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ្នកស្រី ស៊ិន អៀវ ១២ ខែមីនា ឆ្នាំ២០០៩ , EN 00301193។

83 សំណុំរឿង០០១ **D219/702.1.130** Nayan Chanda ប្រតិចារឹក ,២៦ ឧសភា ២០០៩, 9.49.47, EN 00334422។

84 **D6.1.83** David Chandler, *សម្លេងពី ស-២១ ,*១៩៩៩, EN 00192740។ សំណុំរឿង០០១ **D6.1.868** David Chandler ប្រតិចារឹក ៦ សីហា ២០០៩, 09.42.59 ដល់ 09.44.35, EN 00361355-56។

85 *សូមមើល ជាឧទាហរណ៍:* សំណុំរឿង០០១ **D219/702.1.130** Nayan Chanda ប្រតិចារឹក ២៦ ឧសភា ២០០៩, 11.34.50 ដល់ 11.38.17, EN 00334451។ **D6.1.83** David Chandler, *សម្លេងពី ស-២១ ,១៩៩៩*, EN 00192680។

86 **D6.1.85** Nayan Chanda, *សត្រូវបងប្អូនឯង ,១៩៨៦*, EN 00192197-98។

87 **D6.1.85** Nayan Chanda, *សត្រូវបងប្អូនឯង ,១៩៨៦*, EN 00192198។

88 **D1.3.10.4** សាធារណរដ្ឋសង្គមនិយមវៀតណាម, អង្គហេតុ និងឯកសារស្តីអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម មករា ១៩៧៨, EN 00196223។

89 **D117/36.1.23** Philip Short, *ប៉ុល ពត: ប្រវត្តិនៃសុបន្តិអាក្រក់មួយ* ២០០៥ , EN 00396505។

90 **D132.1.160** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ៤៥ ពី អុន ទៅកាន់ ប៉ុល ពត ១១ វិច្ឆិកា ១៩៧៥, EN 00182595-97។

91 **D132.1.83** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ពី អុន ជូនបង ៨៩ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧៦, EN 00183692។ **D132.1.83** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ពី អុន ជូនបង ៨៩ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ , EN 00183692។ **D132.1.108** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ តាមកូឡាំង ជូនអ៊ុំ ៨៩ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ , EN 00185223។

92 **D6.1.1165** កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ បកក ,២២ កុម្ភៈ ១៩៧៦ , EN 00182627។

93 **D132.1.124** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ពី អុន ជូនបង ៨៩ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៧៦, EN 00183693។ **D132.1.53** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ពី អុន ជូនបងជាទីគោរព ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៦, EN 00143175-76។ **D132.1.124** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ពី អុន ជូនបង ៨៩ ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៧៦, EN 00183693។ **D132.1.53** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ពី អុន ជូនបងជាទីគោរព ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៦ , EN 00143175-76។ **D132.1.8** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ២០ ពី យ៉ា ជូនបងជាទីគោរព ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៦, EN 00324803។ **D132.1.159** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ២១ ពី អុន ជូនបង ប៉ុល ថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៦ , EN 00185241។ **D132.1.128** កម្ពុជាប្រជាធិបតេយ្យ ទូរលេខ ជូនអង្គការ ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦, EN 00184005។ **D6.1.1138** កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ បកក , ២៦ មីនា ១៩៧៦, EN 00182657។ **D6.1.89** កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំយោធា ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦, EN 00195341។

94 **D6.1.808** ការផ្សាយសារព័ត៌មានបរទេស FBIS, ឯកសារស្តីពីសកម្មភាពដំណើរទស្សនកិច្ចរបស់គណៈប្រតិភូគុយបា សន្ទរកថា របស់ អៀង សារី ថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៧ ,EN 00168434។

95 **D219/702.1.149** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទា ទិត, ២៨ មករា ២០០៩, EN 00284712។

96 **D1.3.17.5** Ben Kiernan, *របប ប៉ុល ពត,* ឆ្នាំ១៩៩៦, EN 00104372។ សំណុំរឿង០០១ **D219/702.1.130** Nayan Chanda ប្រតិចារឹក. ២៦ ឧសភា ២០០៩, ម៉ោង 10.04.02 ដល់ 10.07.11, EN 00334428។

97 **D132.1.157** សេចក្តីរាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពីតំបន់២៣, ១៨ មិថុនា ១៩៧៧, EN 00185247-49។ **D132.1.167** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ពីសមមិត្ត លីន ផ្ញើជូន ម.៨៧០, ១៤ សីហា ១៩៧៧, EN 00183610។ **D132.1.74** សេចក្តីរាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពីតំបន់២០, ២៥ មិថុនា ១៩៧៧, EN 00184002។

**D132.1.158** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៣៩ ពី ឆុន ផ្ញើជូនបង ប៉ុល, ២៤ កញ្ញា ១៩៧៧, EN 00233793។ **D132.1.147** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៤១ ពី ឆុន ផ្ញើជូនបង ប៉ុល, ២៦ កញ្ញា ១៩៧៧, EN 00185252-53។ សំណុំរឿង០០១ **D219/702.1.130** Nayan Chanda ប្រតិចារឹក. ២៦ ឧសភា ២០០៩, ម៉ោង 10.04.02 ដល់ 10.07.11, EN 00334428។

98 **D132.1.68** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៥៦ ពី ឆុន ផ្ញើជូន ម.៨៧០, ២៦ តុលា ១៩៧៧, EN 00183616។ **D132.1.110** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៥៤ ពី ឆុន ផ្ញើជូន ម.៨៧០, ២៦ តុលា ១៩៧៧, EN 00182815-16។ **D1.3.30.5** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៦៩ ផ្ញើជូន ម.៨៧០, ៧ វិច្ឆិកា ១៩៧៧, EN 00183619។ **D132.1.122** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៧៦ ពី ឆុន ផ្ញើជូន ម.៨៧០, ១២ វិច្ឆិកា ១៩៧៧, EN 00183612។ **D132.1.36** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៥៧ ពី ឆុន ផ្ញើជូន ម.៨៧០, ២៧ តុលា ១៩៧៧, EN 00183618។ **D132.1.13** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៥៩ ពី ឆុន ផ្ញើជូន ម.៨៧០, ២៨ តុលា ១៩៧៧, EN 00185187-88។ **D132.1.129** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៨៥ ផ្ញើជូនបង ប៉ុល, ១៩ វិច្ឆិកា ១៩៧៧, EN 00335207-08។ **D132.1.34** New York Times, *កម្ពុជាផ្តាច់ទំនាក់ទំនងជាមួយនឹងវៀតណាម*, ៣១ ធ្នូ ១៩៧៧, EN 00166127។

99 **D132.1.130** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៥៥ ពី ឆុន ផ្ញើជូន ម.៨៧០, ២៦ តុលា ១៩៧៧, EN 00183615។ **D132.1.144** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៦១ ពី ឆុន ផ្ញើជូន ម.៨៧០, ២៩ តុលា ១៩៧៧, EN 00183617។ **D132.1.92** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៦៨ ពី ឆុន ផ្ញើជូនបង ប៉, ៦ វិច្ឆិកា ១៩៧៧, EN 00305256។ **D132.1.122** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៧៦ ពី ឆុន ផ្ញើជូន ម.៨៧០, ១២ វិច្ឆិកា ១៩៧៧, EN 00183611-12។ **IS21.53 (CF 2 #)** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៨៥ ពី ឆុន ផ្ញើជូន ម.៨៧០, ៧ ធ្នូ ១៩៧៧, EN 00183613។ **D132.1.162** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៩១ ពី ឆុន ផ្ញើជូន ម.៨៧០, ១០ ធ្នូ ១៩៧៧, EN 00183621។ **D132.1.55** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៩២ ពី ឆុន ផ្ញើជូន ម.៨៧០, ១២ ធ្នូ ១៩៧៧, EN 00183622។ **D132.1.60** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៩៦ ពី ឆុន ផ្ញើជូន ម.៨៧០, ១៣ ធ្នូ ១៩៧៧, EN 00183624។ **D1.3.30.6** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៥ ផ្ញើជូន ម.៨៧០, ២២ ធ្នូ ១៩៧៧, EN 00185193។ **D132.1.86** ទូរលេខកម្ពុជាប្រជាធិបតេយ្យ ពី ឆុន ជំរាបបង ជាទីគោរព, ២៣ ធ្នូ ១៩៧៧, EN 00183632។ **D132.1.156** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៧ ពី ភួង ផ្ញើជូន ម.៨៧០, ២៣ ធ្នូ ១៩៧៧, EN 00183637។ **D132.1.91**ទូរលេខកម្ពុជាប្រជាធិបតេយ្យ ពី ឆុន ផ្ញើជូនបង ប៉ុល, ២៤ ធ្នូ ១៩៧៧, EN 00183634។ **D132.1.48** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៨ ពី ភួង ផ្ញើជូន ម .៨៧០, ២៤ ធ្នូ ១៩៧៧, EN 00183636។ **D132.1.98** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១១ ពី ភួង ផ្ញើជូន ម.៨៧០, ២៧ ធ្នូ ១៩៧៧, EN 00183640។ **D6.1.1266** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៤ ពី ភួង ផ្ញើជូន ម.៨៧០, ៣១ ធ្នូ ១៩៧៧, EN 00183641។

100 **D132.1.34** New York Times, *កម្ពុជាផ្តាច់ទំនាក់ទំនងជាមួយនឹងវៀតណាម*, ៣១ ធ្នូ ១៩៧៧, EN 00166127។

101 **D1.3.17.5** Ben Kiernan, *របប ប៉ុល ពត*, ឆ្នាំ១៩៩៦, EN 00104372។

102 **D132.1.123** ការប្រកាសរបស់កម្ពុជាប្រជាធិបតេយ្យ, ការប្រកាសរបស់ក្រសួងការបរទេសរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ, ៣១ ធ្នូ ១៩៧៧, EN 00282392-00282393។ សូមអាន *ផងដែរ៖* **D6.1.742** *ទង់បដិវត្ត*, ច្បាប់លេខ៤, ខែមេសា ឆ្នាំ ១៩៧៨, EN 00519840។

103 **D6.1.840** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល ញ៉ាន, ៣១ សីហា ២០០៩, EN 00377400-01។

104 **D1.3.23.2** BBC/SWB, *របាយការណ៍អំពីយុត្តិសាស្ត្ររបស់កម្ពុជា ដើម្បីទប់ទល់ប្រឆាំងនឹងវៀតណាម,* ១០ ឧសភា ១៩៧៨, EN 00003959។

105 **D1.3.17.2** ក្រសួងការបរទេសនៃក្តុជាប្រជាធិបតេយ្យ, *សៀវភៅខ្មៅ*, ខែកញ្ញា ឆ្នាំ១៩៧៨, EN 00082510-60។ សូមអាន *ផងដែរ៖* **D6.1.826** FBIS, *អៀង សារី ទៅដល់ ហ្វីលីពីន នៅថ្ងៃទី១៧ ខែតុលា*, ២៣ តុលា ១៩៧៨, EN 00170293។

106 **D132.1.90** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៦៣ ពី រី គោរពជូនបងជាទីគោរព, ១ មករា ១៩៧៨, EN 00185194។ **D6.1.50, D6.1.516** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៤៧ ពី សារុន ផ្ញើជូន ម.៨៧០, ១ មករា ១៩៧៨, EN 00324809 ។ **D132.1.107** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៥ ពី ភួង ផ្ញើជូន ម.៨៧០, ១ មករា ១៩៧៨, EN 00183642។ **D132.1.140** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៧ ពី ភួង ផ្ញើជូន ម.៨៧០, ១៥ មករា ១៩៧៨, EN 00183644-45។ **D132.1.84** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១២ ពី ឆុន ផ្ញើជូនបង ប៉ុល, ១៥ មករា ១៩៧៨, EN 00301417។ **D132.1.125** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៦ ពី រ៉ុម, ២ មីនា ១៩៧៨, EN 00795287។ **D132.1.120** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៥ ពី រី ជូនបងជាទីគោរព, ២២ មីនា ១៩៧៨, EN 00305369។ **D6.1.508** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៩ ពី រី ជូនបងជាទីគោរព, ២៥ មេសា ១៩៧៨, EN 00185204។ **D132.1.79** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០២ ពី ម៉ុក ផ្ញើជូនបង ប៉ុល, ៨ មេសា ១៩៧៨, EN 00322059។ **D6.1.496** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ ១៨ ពី ៤៧ ផ្ញើជូនបង វ៉ាន់, ៨ មេសា ១៩៧៨, EN 00323164។ **D1.3.30.15** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៩ ពី ពក ផ្ញើជូនគណៈ ៨៧០, ២៩ មេសា ១៩៧៨, EN 00321722-23។ **D1.3.30.16** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១០ ពី ពក ផ្ញើជូនគណៈ ៨៧០, ៤ ឧសភា ១៩៧៨, EN 00185254។ **D1.3.23.2** BBC/SWB, *របាយការណ៍អំពីយុត្តិសាស្ត្ររបស់កម្ពុជា ដើម្បីទប់ទល់ប្រឆាំងនឹងវៀតណាម,* ១០ ឧសភា ១៩៧៨, EN 00003959។ **D1.3.17.2** ក្រសួងការបរទេសនៃក្តុជាប្រជាធិបតេយ្យ, *សៀវភៅខ្មៅ*, ខែកញ្ញា ឆ្នាំ១៩៧៨, EN 00082510-60។ **D6.1.826** FBIS, *អៀង សារី ទៅដល់ ហ្វីលីពីន នៅថ្ងៃទី១៧ ខែតុលា*, ២៣ តុលា ១៩៧៨, EN 00170293។ **D132.1.140** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៧ ពី ភួង ផ្ញើជូន ម.៨៧០, ១៥ មករា ១៩៧៨, EN 00183644-45។ **D132.1.84** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១២ ពី ឆុន ផ្ញើជូនបង ប៉ុល, ១៥ មករា ១៩៧៨, EN 00301417។ **D6.1.1268** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៥ ពី ឆុន ផ្ញើជូនបង ប៉ុល, ១៩ មករា ១៩៧៨, EN 00532795។ **D6.1.1269** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៦ ពី ឆុន ផ្ញើជូនបង ប៉, ២៣ មករា ១៩៧៨, EN 00182755។ **D132.1.54** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ៦២ ពី ឆុន ផ្ញើជូនបង ប៉, ២៩ មករា ១៩៧៨,EN 00183648។ **D6.1.83** David Chandler, *សំឡេងពីមន្ទីរ ស២១-*, ឆ្នាំ១៩៩៩, EN 00192750។ **D6.1.498** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់, ១៨ កុម្ភៈ ២០០៩, EN 00334060-61។ **D6.1.503** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់, ២៨ មីនា ២០០៩, EN 00483969។ **D132.1.115** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៦

ពី ៤៧ ផ្ញើជូនបង ០០៩, ២០ មីនា ១៩៧៨, EN 00185195។ **D132.1.111** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៦ ពី ៤៧ ផ្ញើជូនបង ០០៩, ២០ មីនា ១៩៧៨, EN00185183។ **D132.1.125** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៦ ពី រ៉ុម, ២ មីនា ១៩៧៨, EN 00795287។ **D132.1.120** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៥ ពី វី ផ្ញើជូនបងជាទីគោរព, ២២ មីនា ១៩៧៨, EN 00305369។ **D6.1.508** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៩ ពី វី ផ្ញើជូនបងជាទីគោរព, ២៥ មេសា ១៩៧៨, EN 00185204។ **D132.1.79** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០២ ពី ម៉ុក ផ្ញើជូនបង ប៉ុល, ៨ មេសា ១៩៧៨, EN 00322059។ **D6.1.496** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៨ ពី ៤៧ ផ្ញើជូន បងវ៉ាន់, ៨ មេសា ១៩៧៨, EN 00323164។ **D1.3.30.15, D6.1.464** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ០៩ ពី ពក ផ្ញើជូនគណៈ ៨៧០, ២៩ មេសា ១៩៧៨, EN 00321722-23។ **D1.3.30.16** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១០ ពី ពក ផ្ញើជូនគណៈ ៨៧០, ៤ ឧសភា ១៩៧៨, EN 00185254។ **D219/702.1.26** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១១ ពី ពក ផ្ញើជូនបងវ៉ាន់, ៦ ឧសភា ១៩៧៨, EN 00322057។ **D6.1.497** ទូរលេខកម្ពុជាប្រជាធិបតេយ្យ លេខ១៣ ពី ពក ផ្ញើជូនគណៈ ៨៧០, ៩ ឧសភា ១៩៧៨, EN 00321718។ **D6.1.734** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ឈឿន, ១៩ សីហា ២០០៩, EN 00374948-49។ សូមមើលផងដែរ **D1.3.19.3** សេចក្តីណែនាំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយមន្ទីរ ៨៧០ EN 00183666; **D132.1.16** សេចក្តីថ្លែងជាសាធារណៈរបស់ ប៉ុល ពត, ៥ មករា ១៩៧៩, EN S 00017564-65។

107 សូមអាន *ឧទា.*, ចម្លើយរបស់ ខៀវ សំផន នៅក្នុងកំណត់ហេតុរបស់ កសចស ស្តីពីការស្តាប់ចម្លើយជនត្រូវចោទ, ១៣ ធ្នូ ២០០៧, EN 00539264។ **D6.1.739** ទង់បដិវត្ត, ខែកញ្ញា ឆ្នាំ១៩៧៧, EN 00486215។ **D6.1.1533** របាយការណ៍វិភាគរបស់ Craig C. Etcheson, ១៨ កក្កដា ២០០៧, កថាខណ្ឌ ៦, EN 00142827។

108 **D1.3.20.1** លក្ខន្តិកៈកម្ពុជាប្រជាធិបតេយ្យ, (មាត្រា៧.១), EN 00184038។

109 **D6.1.503** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់, ២៨ មីនា ២០០៩, EN 00483967-68។ **D6.1.1068** កំណត់ហេតុនៃការសួរចម្លើយ ឌុច, ២២ វិច្ឆិកា ២០០៧, EN 00153570។ **D6.1.1051** កំណត់ហេតុនៃការសួរចម្លើយ ឌុច, ៤ ធ្នូ ២០០៧, EN 00154910]។ **D6.1.1059** កំណត់ហេតុនៃការសួរចម្លើយ ឌុច, ៨ មេសា ២០០៨, EN 00177636។ **D6.1.1036** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, ១៤ ធ្នូ ២០០៧, EN 00156754។ **D6.1.987, D6.1.987/Corr-1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ហុង *ហៅ* សាឡុត បាន, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី, ៧ មេសា ២០១០, EN 00503164។ **D6.1.662** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុង រ៉េន, ២៣ តុលា ២០០៩, EN 00408395 ។ **D6.1.786** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ឌុច, ១ វិច្ឆិកា ២០០៧, EN 00223511-12។ **D117/36.1.22** សេចក្តីណែនាំរបស់គណៈមជ្ឈិមនៃ បកក, ១១ កក្កដា ១៩៧៧, EN 00305412។

110 **D1.3.36.1** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, ១៣ ធ្នូ ២០០៧, EN 00539265។ **D1.3.27.5** Masato Matsushita និង Stephen Heder, បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅតាមបណ្តោយព្រំដែនថៃ-កម្ពុជា, កុម្ភៈ-មីនា ១៩៨០, EN 00170750។

111 **D1.3.36.1** កំណត់ហេតុសួរចម្លើយ ខៀវ សំផន, ១៣ ធ្នូ ២០០៧, EN 00539265។ **D6.1.93** កំណត់ហេតុនៃការសួរចម្លើយឌុច, ២៥ វិច្ឆិកា ២០០៨, EN 00242903-04។ **D6.1.95** កំណត់ហេតុនៃការសួចម្លើយឌុច, ២៨ វិច្ឆិកា ២០០៨, EN

"មកពីនិរតី តឹងបំផុតពេលពួកនិរតីមកដល់ភ្លាម តឹងមហាសែន អស្ចារ្យហើយ"។]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.36 KH 00978924 [សាក្សី បានធ្វើការនៅក្នុងកងចល័តមួយនៅព្រះនេត្រព្រះ និងស្ពានស្រែង៖ "ក្រោមការគ្រប់គ្រងរបស់ពួកនិរតី ស្ថានភាពរស់នៅ និងស្ថានភាពការងារ គឺមានការលំបាកដូចគ្នា។ ការកាប់សម្លាប់នៅក្នុងភូមិស្រែះកើត ត្រូវបានថយចុះ ប៉ុន្តែនៅកន្លែងគ្រប់គ្រងរបស់យាយ ចែម មានការចាប់ និងការសម្លាប់មានការកើនឡើង ពីព្រោះមានមនុស្សជាច្រើនត្រូវបានចាប់បណ្តើរមកទាំងខ្សែៗ យកមកដាក់នៅកន្លែងយាយ ចែម នៅភ្នំលៀប"។]។ ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.34 KH 01024729 [សាក្សីបានធ្វើការនៅក្នុងកងចល័តមួយនៅព្រះនេត្រព្រះ ស្រេះ កំបោរ ព្រៃមាន់ អូរលាប និងត្រពាំងថ្ម៖ "ក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី ការហូបចុកកាន់តែខ្សត់ខ្សោយ និងការធ្វើការងារកាន់តែលំបាកឡើងៗជាងកាលពីពួកពាយ័ព្យគ្រប់គ្រងទៅទៀត"]។ ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.38 KH 01148731-01148732 [សាក្សី គឺជាអ្នកធ្វើការ នៅក្នុងកងយុវជនមួយ នៅព្រះនេត្រព្រះ៖ "ស្ថានភាពរស់នៅរបស់ប្រជាជន មានស្ថានភាពអាក្រក់ជាងមុន ពីព្រោះគ្រួសាររបស់ខ្ញុំ រួមមានឪពុកម្តាយ និងបងប្អូន ត្រូវបានគេចាប់យកទៅសម្លាប់ ដោយមិនដឹងមូលហេតុ។ ស្ថានភាពរស់នៅ នៅពេលនោះ ពិតជាវេទនាខ្លាំងណាស់ ពីព្រោះយើងមិនមានអាហារហូបគ្រប់គ្រាន់ទេ។ គេដាំបបរ ដោយអង្ករ ២ កំប៉ុង ឲ្យមនុស្ស ២០០ នាក់ ហូប។ ដូច្នេះពួកយើងហូបមិនគ្រប់គ្រាន់ទេ ដោយនាំគ្នាបេះដើមកំប្លោក ដែលរសាត់តាមទឹក យកមកហូប។ នៅពេលអស់ដើមកំប្លោក ពួកយើងបានទៅបេះផ្កាខ្នុរ យកមកហូប។ នៅពេលអស់ផ្កាខ្នុរហូប ទើបគេបញ្ជូនពួកយើងទៅភូមិរហាល ដើម្បីដាំដំឡូង។"]។ ឯកសារ D119/76 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឆ.18 KH 00971143 [សាក្សីបានធ្វើការនៅក្នុងកងនារីចល័ត នៅព្រះនេត្រព្រះ៖ "ស្ថានភាពរស់នៅមានការលំបាកជាងមុន ពីព្រោះយើងមិនមានអាហារគ្រប់គ្រាន់ ដើម្បីហូបទេ"]។ ឯកសារ D219/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.27 KH 01066001 [សាក្សី បានធ្វើការនៅក្នុងកងចល័តមួយនៅក្នុងតំបន់ ៥ នៅត្រពាំងថ្ម៖ "មុនកម្មាភិបាលនិរតីមកដល់ ស្ថានភាពការងារ គឺគេឲ្យយើងជីកដីពីពីរ ឬបីម៉ែត្រគូប ក្នុងមួយថ្ងៃ។ ហើយនៅពេលដែលកម្មាភិបាលនិរតីមកដល់ គឺគេឲ្យយើងរែកដីបីម៉ែត្រគូប ក្នុងមួយថ្ងៃ។ ចំពោះរបបអាហារ គឺអ្នកធ្វើការនៅតាមកងចល័តមានលក្ខណៈមិនមានអ្វីហូបគ្រប់គ្រាន់ដូចតែគ្នា។ នៅមុន និងក្រោយពេលពួកកម្មាភិបាលនិរតីមកដល់ គឺគេឲ្យយើងធ្វើការរែកដីនៅពេលយប់។ ឆ.28 KH 01066001 ["តាមពិតទៅ មុនពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មិនសូវខ្លាំងប៉ុន្មានទេ ប៉ុន្តែក្រោយពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មនុស្សរឹតតែខ្លាំងៗឡើង។"]។ ឯកសារ D119/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច ឈានឡុង ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.37 KH 01024759 [សាក្សី គឺជាប្រធានកងភ្ជួរមួយ នៅព្រះនេត្រព្រះ៖ "ការរស់នៅ និងការធ្វើការ ក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី មានការលំបាកខ្លាំងណាស់ ពីព្រោះយើងត្រូវធ្វើការខ្លាំង ដូចជាទាសករអ៊ីចឹង។ ការហូបចុកនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ គេឲ្យអង្ករយើងម្នាក់ពីរកំប៉ុងក្នុង ១ ថ្ងៃ។ ចំណែកការហូបចុកនៅក្រោមគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី គឺគេឲ្យអង្ករយើង ៩ កំប៉ុង សម្រាប់ ៣០ គ្រួសារក្នុង ១ ថ្ងៃ។ ពេលម៉ោងធ្វើការ គឺដូចគ្នា ប៉ុន្តែយើងត្រូវបញ្ចប់តាមផែនការប្រចាំថ្ងៃ នៅពេលយើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ គេឲ្យយើងច្រូតស្រូវក្នុង ១ ហិចតា

២៥ នាក់ ប៉ុន្តែនៅស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី គេឱ្យយើងច្រូតស្រូវ ១ ហិចតាតែ ១៥ នាក់ប៉ុណ្ណោះ។"] ឆ.38 KH 01024759 ["ប្រសិនបើយើងមិនអាចបញ្ចប់តាមផែនការទេ គេឱ្យយើងនៅធ្វើឱ្យទាល់តែរួច។"]។ ឯកសារ D119/133 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.32 KH 00998139 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័តមួយ នៅព្រះនេត្រព្រះ៖ "ស្ថានភាពរស់នៅ នៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី គឺកាន់តែលំបាកឡើងៗ។"] ឆ.26 KH 00998138 ["ខ្ញុំសូមបញ្ជាក់ថា ស្ថិតនៅក្រោមការគ្រប់គ្រងទាំងពីរក្រុម គឺភូមិភាគពាយ័ព្យ និងនិរតី គឺសុទ្ធតែមានការលំបាកដូចគ្នា គឺគេមិនឱ្យយើងហូបចុកគ្រប់គ្រាន់ ហើយគេបញ្ជូនយើងឱ្យទៅធ្វើការនៅតាមការដ្ឋាននានា។ ក្រោយពីយើងបានធ្វើការពេលថ្ងៃរួច នៅរៀងរាល់យប់ គេតែងតែហៅយើងឱ្យចូលប្រជុំ ដើម្បីពង្រឹងគោលជំហររបស់ប្រជាជន។"]។ ឯកសារ D119/91 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.12 KH 00976148 [សាក្សី គឺជាប្រធានសហករណ៍មួយ នៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ៖ "នៅពេលដែលពួកនិរតីមកដល់ ការរស់នៅមានការលំបាកជាងមុនខ្លាំងណាស់ ហើយការធ្វើការងាររឹតតែមានការលំបាកខ្លាំង ជាពិសេស គឺមានការកាប់សម្លាប់យ៉ាងខ្លាំង ទោះបីជាមានកំហុសតិចតួចក៏ដោយ។"]។ ឯកសារ D106/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឹម សឹត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ឆ.31 KH 00800997 [សាក្សីបានធ្វើការនៅក្នុងកងចល័តសហករណ៍មួយ៖ "នៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ ស្ថានភាពរស់នៅមានភាពធម្មតា ប៉ុន្តែ នៅពេលពួកនិរតីមកគ្រប់គ្រង ស្ថានភាពតឹងតែងជាងមុន និងលំបាកខ្លាំង។ នៅពេលពួកពាយ័ព្យគ្រប់គ្រង យើងមានអាហារគ្រប់គ្រាន់ ហើយមានបាយហូប តែនៅពេលពួកនិរតីមកគ្រប់គ្រង យើងហូបតែបបរប៉ុណ្ណោះ គឺអង្ករ ១ កំប៉ុង សម្រាប់មនុស្ស ១០ នាក់។"]។ ឯកសារ D119/125 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.8 KH 00987278 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័តមួយ នៅព្រះនេត្រព្រះ៖ "ពេលពួកនិរតីមកដល់ដំបូង ពួកគេធ្វើល្អជាមួយប្រជាជន។ បន្ទាប់មក ពួកគេចាប់ផ្តើមចាប់កម្មាភិបាលពាយ័ព្យអស់ ហើយពេលនោះ ស្ថានភាពរស់នៅ និងធ្វើការ មានការលំបាកខ្លាំងជាងមុន។"]។ ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.38 KH 00996496 [សាក្សី គឺជាអ្នកធ្វើការ នៅត្រពាំងថ្ម៖ "ស្ថានភាពរស់នៅ និងស្ថានភាពការងារ នៅមុនពេលដែលយាយ ចែម មកគ្រប់គ្រងតំបន់ ដែលខ្ញុំរស់នៅ ស្ថានភាព គឺមានការលំបាកខ្លាំង ពីព្រោះគេឱ្យយើងហូបបបរវាវមួយស្លាបព្រាមួយនាក់តែប៉ុណ្ណោះ។ ចំណែកឯស្ថានភាពរស់នៅ និងធ្វើការងារ នៅក្រោយពេលដែលយាយ ចែម មកគ្រប់គ្រង គឺមានលក្ខណៈកាន់តែលំបាកខ្លាំងជាងមុនទៅទៀត។"] ឆ.42 KH 00996496 ["មិនមានថ្នាំព្យាបាលគ្រប់គ្រាន់ទេ"]។ ឯកសារ D119/21 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ងៀង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.16 KH 00894509 [សាក្សី គឺជាអ្នកធ្វើការ នៅក្នុងសហករណ៍មួយ នៅភ្នំលៀប៖ "ជីវភាពរស់នៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ គឺធម្មតា។ តែស្ថានភាពមានការលំបាក នៅពេលដែលពួកនិរតីមកដល់។ ការសម្លាប់ក៏កើនឡើងដែរ នៅពេលនោះ មិនថាចិន មិនថាខ្មែរទេ។"]។ ឯកសារ D119/145 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិប គឹមលន់ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឆ.51 KH 01022032 [សាក្សីបានធ្វើការនៅក្នុងកងចល័តមួយ នៅព្រះនេត្រព្រះ៖ "ស៖ ក្រោយពេលដែលក្រុមយាយ ចែម មកជំនួសកម្មាភិបាលចាស់ៗ តើស្ថានភាពរស់នៅរបស់ប្រជាជនមានលក្ខណៈដូចម្តេចដែរ? ឆ.51៖ ស្ថានភាពរស់នៅរបស់ប្រជាជននៅ

ពេលនោះ គឺមិនមានលក្ខណៈល្អប្រសើរទេ គឺមានការលំបាកខ្លាំង ពីព្រោះនៅពេលនោះ គេឱ្យយើងហូបតែបបរ លាយដើមចេក ដែលពេលនោះ គេកំណត់ឱ្យយើងហូបបបរ ១ ខ្ទះ សម្រាប់ ៣០ គ្រួសារ។"]។ ឯកសារ D119/93 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.11 KH 00976165 [សាក្សីបានធ្វើការនៅតាមការដ្ឋានផ្សេងៗ នៅព្រះនេត្រព្រះ៖ "ពេលពួកនិរតីចូលមកគ្រប់គ្រងនៅតំបន់នេះ ស្ថានភាពរស់នៅ និងស្ថានភាពការងារ រឹតតែមានការលំបាកធ្ងន់ធ្ងរឡើងៗ។ នៅពេលនោះ យើងមិនមានកម្លាំងធ្វើការទេ ព្រោះម្នាក់ៗកាន់តែស្គមស្គាំងទៅៗ។"] ឆ.12 KH 00976165 ["បាទ កាន់តែធ្ងន់ធ្ងរជាងមុនទៀត។ ត្រង់ចំណុចនេះ ខ្ញុំចង់និយាយថា ពីមុនយើងមានបាយហូប ប៉ុន្តែក្រោយមកយើងហូបតែបបរ ព្រមទាំងការងារកាន់តែច្រើនជាងមុន ហើយមនុស្សត្រូវគេចាប់យកទៅសម្លាប់ច្រើនជាងមុន"]។ ឯកសារ D219/474 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ចាន់រីន ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.24 KH 01134122 [សាក្សីបានធ្វើការនៅក្នុងកងចល័តមួយ នៅត្រពាំងថ្ម៖ "ការរស់នៅ និងធ្វើការ ក្នុងអំឡុងពេលនៃការការគ្រប់គ្រងរបស់ពួកនិរតី និងពាយ័ព្យ មានការលំបាកស្ទើរតែដូចគ្នា តែគ្រាន់ថាការរស់នៅនៅក្នុងពេលពួកពាយ័ព្យកាន់កាប់មានលក្ខណៈគ្រាន់បើជាងបន្តិច។ ស្ថានភាពដែលអាក្រក់បំផុត គឺក្នុងពេលដែលខ្ញុំធ្វើការ និងរស់នៅការដ្ឋានត្រពាំងថ្ម ព្រោះកាលនោះ គេឱ្យហូបចុកតិចតួចបំផុត ទាំងម្ហូបទាំងទឹក ហើយគេឱ្យធ្វើការងារយ៉ាងខ្លាំង។ គ្រប់ៗគ្នាសុទ្ធតែកើតថៃសៗនៅពេញខ្លួន ដោយសារពុំមានទឹកងូតគ្រប់គ្រាន់ និងកង្វះអានាម័យ។ ខ្ញុំនៅតែព្រឺក្បាល នៅពេលខ្ញុំនឹកឃើញដល់ពេលនោះ។ ឧទាហរណ៍ ក្នុងពេលដែលខ្ញុំស្នាក់នៅមន្ទីរពេទ្យប្រហែលមួយខែនោះ គឺមានអ្នកស្លាប់សរុបប្រហែល ១០០ នាក់។ ចំពោះចំនួនអ្នកស្លាប់នៅអាងត្រពាំងថ្ម ខ្ញុំមិនអាចប៉ាន់ស្មានបានទេ ដោយសារថាពេលនោះ មនុស្សច្រើនណាស់បានទៅធ្វើការនៅទីនោះ ហើយខ្ញុំមិនដឹងថាគេមកពីណាខ្លះទេ។"] ឆ.25 KH 01134122 [ខ្ញុំអាចនិយាយបានថា មានមនុស្សច្រើនណាស់ ដែលត្រូវបានគេយកទៅសម្លាប់ ក្នុងពេលពួកពាយ័ព្យគ្រប់គ្រង តែមានអ្នកដាច់ពោះស្លាប់តិចតួចទេ។ ចំណែកក្នុងអំឡុងពេលពួកនិរតីគ្រប់គ្រង មនុស្សគេយកទៅសម្លាប់ក៏ច្រើន មនុស្សដែលស្លាប់ដោយដាច់ពោះក៏ច្រើន។"]។ ឯកសារ D219/255 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ រឿប ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ឆ.16 KH 01085157 [សាក្សី គឺជាអនុប្រធានភូមិ នៅព្រះនេត្រព្រះ៖ "កម្មាភិបាលនិរតីមានលក្ខណៈលំបាកជាងកម្មាភិបាលពាយ័ព្យ ឧទាហរណ៍ ដូចជាកម្មាភិបាលនិរតីផ្តល់ការហូបចុកតិចជាងកម្មាភិបាលពាយ័ព្យ។"]។ ឯកសារ D219/473 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ហ៊ិន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ឆ.9 KH 01134108 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័តមួយ នៅព្រះនេត្រព្រះ៖ "ក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ និងកម្មាភិបាលនិរតី ស្ថានភាពរស់នៅ និងការងារ គឺស្ទើរតែដូចគ្នា។ តែក្រោមការគ្រប់គ្រងពួកនិរតី កាចសាហាវឃោរឃៅណាស់។ គេប្រើភាសាមើលប្រមាថយើងខ្លាំង ទាំងចាស់ទាំងក្មេង។"]។ ឯកសារ D219/256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី គាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.15 KH 01085164 [សាក្សី គឺជាអ្នកធ្វើការនៅភ្នំលៀប៖ "ការគ្រប់គ្រងរបស់កម្មាភិបាលនិរតី គឺកាន់តែយ៉ាប់ជាងមុន ដោយសារតែការហូបចុកតិចជាងមុន។ ការងារកាន់តែយ៉ាប់ជាងមុន និងមានមនុស្សកាន់តែច្រើនឈឺ និងស្លាប់។ ហើយការសម្លាប់ប្រជាជនក៏កាន់តែច្រើនថែមទៀត។"] សូមមើលផងដែរ ឯកសារ D219/574 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទ្រី ភឿត ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឆ.45 KH 01166346 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងរោងម៉ាស៊ីនកិនស្រូវមួយនៅភ្នំលៀប៖ [ក្រោមការគ្រប់គ្រងរបស់ តា ម៉ោង និងតា ធាង ការងារមិនមានពេលឈប់សម្រាកទេ ហើយការហូបចុកខ្វះ

ខាត ហើយវេទនាហូប។ ក្រោមការគ្រប់គ្រងរបស់យាយ ថែម គឺការងារ និងហូបចុក គឺយ៉ាប់ដូចតែគ្នា។”]។ ឯកសារ D119/137 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិត អៀក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.66 KH 01003864 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងសេដ្ឋកិច្ច នៅភ្នំលៀប៖ “ស៖ តាមបទពិសោធន៍របស់លោក នៅក្នុងសម័យខ្មែរក្រហម តើលោកអាចពន្យល់ប្រាប់យើងអំពីភាពខុសគ្នានៃការគ្រប់គ្រង រវាងកម្មាភិបាលភូមិភាគពាយ័ព្យ និងភូមិភាគនិរតីបានទេ? ឆ.66 ៖ តាមពិតទៅ វាមិនខុសគ្នាប៉ុន្មានទេ។ ការភ័យខ្លាចស្លាប់ គឺមានដូចគ្នា ហើយស្ថានភាពរស់នៅ និងស្ថានភាពការងារ មានការលំបាកដូចគ្នា។ សេរីភាព និងការហូបចុក គឺមានការខ្វះខាត និងលំបាកយ៉ាងខ្លាំង។ ទោះបីជាខ្ញុំបានធ្វើការនៅក្នុងកងលីសែងអង្ករក៏ដោយ ក៏ពួកខ្ញុំនៅតែហូបបបរមិនគ្រប់គ្រាន់ដដែល ពីព្រោះនៅពេលនោះ គេបានចាត់តាំងកម្លាំងមួយឱ្យនៅតាមដានក្រុមរបស់ខ្ញុំ។ ប្រសិនបើយើងលួចដាំបាយហូប បើគេឃើញ នោះយើងប្រាកដជាសូន្យតែម្ដង។ យើងធ្លាប់ទទួលបានការប្រមានថា បើហ៊ានលួចដាំបាយហូប ប្រសិនបើគេដឹង យើងនឹងត្រូវបានគេយកទៅសម្លាប់។ នៅពេលនោះ បើទោះបីជាយើងមិនអាចលួចដាំបាយហូបបាន ប៉ុន្តែយើងក៏មិនអាចលួចហូបអង្ករឆៅនោះបានដែរ។”]។ ឯកសារ D1.3.11.40 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ក្រុមវត្តព្រះនេត្រព្រះ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ KH 01084703-01084705 [សាក្សី ប៉ោ បណ្ដោត ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានក្រុម នៅព្រះនេត្រព្រះ ក្នុងឆ្នាំ ១៩៧៧៖ “យើងចង់ផ្ដោតទៅលើពេលដែលកម្មាភិបាលភូមិភាគនិរតីបានចូលមកដល់ ហើយតើជីវិតនៅពេលនោះ មានលក្ខណៈដូចម្ដេចដែរ បើប្រៀបធៀបទៅនឹងពេលដែលកម្មាភិបាលភូមិភាគពាយ័ព្យកំពុងគ្រប់គ្រង។ ជាដំបូង តើកម្មាភិបាលភូមិភាគនិរតីបានចូលមកដល់ នៅពេលណា? បណ្ដោត (សាក្សី គឺជាប្រធានក្រុម នៅព្រះនេត្រព្រះ)៖ នៅដើមឆ្នាំ ១៩៧៧ បណ្ដោត៖ កាលពីមុន នៅពេលស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ ពួកគេបានចាប់ខ្លួន និងសម្លាប់តែកងកម្លាំងប្រដាប់អាវុធ យោធានៃរបបមុន និងមន្ត្រីរាជការរបស់រដ្ឋាភិបាលមុនប៉ុណ្ណោះ។ ប្រជាជនធម្មតាមិនមានបញ្ហានោះទេ ហើយពួកគេមិនបានចាប់ខ្លួន ឬក៏ប៉ះពាល់ដល់ប្រជាជនធម្មតាឡើយ។ នៅពេលពួកភូមិភាគនិរតីបានចូលមកដល់ បញ្ហានេះបានរីករាលដាលរហូតដល់សាច់ញាតិរបស់មន្ត្រីនៃរដ្ឋាភិបាលមុន ហើយពួកភូមិភាគនិរតីបាននិយាយថា អ្នកទាំងនោះមាននិន្នាការ និងជាមនុស្សដែលមានការជាប់ពាក់ព័ន្ធជាមួយនឹងសាច់ញាតិរបស់មន្ត្រីរដ្ឋការដែលបានបម្រើការងារក្នុងរដ្ឋាភិបាលមុន។ អ្នកទាំងនោះ រួមទាំងប្រជាជនសាមញ្ញ ប្រជាជនចាស់ និងប្រជាជនថ្មីផងដែរ។ មានចំនួនខុសគ្នាច្រើនណាស់ ក្នុងរយៈពេលមុន និងបន្ទាប់ពីការមកដល់របស់ពួកភូមិភាគនិរតី នៅពេលពួកភូមិភាគនិរតីបានចូលមកដល់ ប្រជាជនរាប់រយនាក់បានបាត់ខ្លួនពីភូមិនេះ ហើយឃុំនេះ មាន ១២ ភូមិ ការបាត់ខ្លួនមានន័យថា ប្រជាជនទាំងនោះត្រូវបានចាប់ខ្លួន សម្លាប់ និងស្លាប់ដោយសារការបង្អត់អាហារ។ នៅក្នុងភូមិនេះ មានប្រជាជនចាស់ និងប្រជាជនថ្មី ប្រហែល ១.០០០ នាក់។ ប្រជាជនថ្មីមានចំនួនច្រើនជាងពាក់កណ្ដាលនៃចំនួនប្រជាជនសរុបនៅក្នុងភូមិនេះ ពោលគឺ ប្រជាជនប្រហែល ពី ២០% ទៅ ៣០% បានបាត់ខ្លួន។ ចំនួននេះប្រែប្រួលទៅតាមភូមិនីមួយៗ ហើយនេះគឺជាចំនួនមធ្យម។ នៅក្នុងភូមិមួយចំនួន ចំនួនអ្នកបាត់ខ្លួនអាចច្រើនជាងនេះ ហើយអ្នកភូមិស្ទើរតែទាំងអស់ ត្រូវបានគេបញ្ជូនចេញ ប៉ុន្តែនៅក្នុងភូមិផ្សេងៗទៀត ស្ថានភាពមិនធ្ងន់ធ្ងរដូច្នេះទេ”]។ ឯកសារ D123/1/1.6a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ពេជ្រ ហម ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧ KH 0057719 [សាក្សី គឺជាអ្នកធ្វើការក្នុងកងចល័តតំបន់ ដែលបានធ្វើការនៅត្រពាំងថ្ម នៅក្នុងរយៈពេលមានការបោសសម្អាតទាំងមូល “បើនិយាយពីរឿងមនុស្សដែលស្លាប់ ពេលពាយ័ព្យ មិនសូវស្លាប់ដូចកាលដែលពួកនិរតីមកទេ ពេលដែលពួកនិរតី

មក ស្លាប់ច្រើនជាងពាយ័ព្យនៅកាន់ក្តាប់។ ឧបមានថាស៊ើប ឧបមាថាពួកនេះទាហាន នោះវាសម្លាប់ហើយ អត់ទុកទេ។ បើសិនជាពួកនិរតីឮថា នាងនេះឃ្លួន នាងនេះចិន អត់បានទេ អត់បានសោះ។”]។

457 ឯកសារ **D219/384** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌឹក គុយ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ1.7 KH 01113233 [សាក្សីបានរស់នៅ និងធ្វើការនៅភូមិជ្រាប់ ស្រុកព្រះនេត្រព្រះ នៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី អាហារហូបកាន់តែតិច “ការធ្វើការរឹតតែច្រើនឡើងៗ។ នៅក្នុងសម័យគ្រប់គ្រងដោយពួកនិរតី មានមនុស្សជាច្រើនបានបាត់ខ្លួន តែខ្ញុំមិនដឹងពីមូលហេតុទេ។[”។ ឯកសារ **D119/152** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទារ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ3.4 KH 01024729 [សាក្សីបានធ្វើការនៅក្នុងកងចល័ត នៅត្រពាំងថ្ម៖ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី ការហូបចុក“ កាន់តែខ្សត់ខ្សោយ និងការធ្វើការកាន់តែលំបាកឡើងៗជាងកាលពីពួកពាយ័ព្យគ្រប់គ្រងទៅទៀត[”។ ឯកសារ **D219/175** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ2.7 KH 01066001 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅតំបន់ ៥៖ មុនកម្មាភិបាលនិរតីមកដល់ ស្ថានភាពការងារ គឺគេឲ្យយើងជីកដីពីពីរ ឬបីម៉ែត“្រគូបក្នុងមួយថ្ងៃ។ ហើយនៅពេលដែលកម្មាភិបាលនិរតីមកដល់ គឺគេឲ្យយើងរែកដីបីម៉ែត្រគូបក្នុងមួយថ្ងៃ។ ចំពោះរបបអាហារ គឺអ្នកធ្វើការនៅតាមកងចល័ត មានលក្ខណៈមិនមានអ្វីហូបគ្រប់គ្រាន់ដូចតែគ្នា។ នៅមុន និងក្រោយពេលពួកកម្មាភិបាលនិរតីមកដល់ គឺគេឲ្យយើងធ្វើការរែកដីនៅពេលយប់។[”។ ឯកសារ **D219/253** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ហួរ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥ ឆ2.4 KH 01085137 [សាក្សី គឺជាអ្នកធ្វើការ នៅព្រះនេត្រព្រះ៖ ការធ្វើការនៅទីនោះ ដូច“ម៉ែត្រក្នុងមួយថ្ងៃ ៤0ម៉ែត្រម្នាក់ឯង។ សម្រាប់ស្ទួង ១0ជាមិនសូវជាលំបាកទេ។ ជួនកាលគេឲ្យខ្ញុំលើកភ្លឺ ធ្វើការ ៤ នាក់។ ចំពោះការហូបចុក ហូបបបរ ហូបមិនគ្រប់ទេ បបររាវៗ។ អ្នកស្លាប់ភាគច្រើន គឺស្លាប់ដោយសារដាច់បាយ។ មិនសូវមានមនុស្សស្លាប់ដោយសារការវាយសម្លាប់ទេ។[”។ ឯកសារ **D119/155** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច ឈានឡុង ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ3.7 KH 01024759 [ការរស់នៅ និងការធ្វើការងារ ក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី មានការលំបាកខ្លាំងណាស់ ពីព្រោះយើងត្រូវធ្វើការខ្លាំង ដូចជាទាសករអ៊ីចឹង។ ការហូបចុកនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ គេឲ្យអង្ករយើងម្នាក់ ២ កំប៉ុងក្នុង ១ ថ្ងៃ។ ចំណែកការហូបចុកនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី គឺគេឲ្យអង្ករយើង ៩ កំប៉ុង សម្រាប់ ៣0 គ្រួសារក្នុង ១ ថ្ងៃ។ ពេលម៉ោងធ្វើការ គឺដូចគ្នា ប៉ុន្តែយើងត្រូវបញ្ចប់តាមផែនការប្រចាំថ្ងៃ នៅពេលយើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី។ ឧទាហរណ៍ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ គេឲ្យយើងច្រូតស្រូវ ក្នុង ១ ហិចតា ២៥ នាក់ ប៉ុន្តែនៅស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី គេឲ្យយើងច្រូតស្រូវ ១ ហិចតា តែ ១៥ នាក់ប៉ុណ្ណោះ។ ឆ.38 KH 01024759 “]ប្រសិនបើយើងមិនអាចបញ្ចប់ផែនការទេ គេឲ្យយើងទៅធ្វើឲ្យទាល់តែរួច។[”។ ឯកសារ **D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ិត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ2.6 KH 00998138 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ ខ្ញុំសូមបញ្ជាក់ថា ស្ថិតនៅក្រោមការគ្រប់គ្រងទាំងពីរក្រុម គឺភូមិភាគពាយ័ព្យ និងនិរតី គឺសុទ្ធតែ“មានការលំបាកដូចគ្នា គឺគេមិនឲ្យហូបចុកគ្រប់គ្រាន់ ហើយគេបញ្ជូនយើងឲ្យទៅធ្វើការនៅតាមការដ្ឋាននានា។ ក្រោយពីយើងបានធ្វើការពេលថ្ងៃរួច នៅរៀងរាល់យប់ គេតែងតែហៅយើងឲ្យចូលប្រជុំ ដើម្បីពង្រឹងគោលជំហររបស់ប្រជាជន។[”។ ឯកសារ **D119/91** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ1.2 KH 00976148

[សាក្សី គឺជាប្រធានសហករណ៍ ក្រោមពួកកម្មាភិបាលពាយ័ព្យ៖ នៅពេលដែលពួកនិរតីមកដល់ ការរស់នៅមានការលំបាក“ ជាងមុខខ្លាំងណាស់ ហើយការធ្វើការងាររឹតតែមានការលំបាកខ្លាំង ជាពិសេសគឺមានការកាប់សម្លាប់យ៉ាងខ្លាំង ទោះបីជាមាន [”កំហុសតិចតួចក៏ដោយ។។ ឯកសារ **D119/131** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ3.8 KH 00996496 [សាក្សី គឺជាអ្នកធ្វើការ នៅត្រពាំងថ្ម៖ ស្ថាន“ ភាពរស់នៅ និងស្ថានភាពការងារ នៅមុនពេលដែលយាយ ចែម មកគ្រប់គ្រងតំបន់ ដែលខ្ញុំរស់នៅ ស្ថានភាព គឺមានការលំបាកខ្លាំង ពីព្រោះគេឲ្យហូបបបររាវមួយស្លាបព្រាមួយនាក់តែប៉ុណ្ណោះ។ ចំណែកឯស្ថានភាពរស់នៅ និងធ្វើការងារ នៅក្រោយពេលដែលយាយ ចែម មកគ្រប់គ្រង គឺមានលក្ខណៈកាន់តែលំបាកខ្លាំងជាងមុនទៅទៀត។ [”ឆ.39 KH 00996496 នាក់ ១0នៅក្នុងក្រុមរបស់ខ្ញុំ មានគ្នា ] ហើយគេបានឲ្យពួកយើងស្ទូងស្រូវក្នុងមួយថ្ងៃឲ្យបានកន្លះហិកតា។ [”ឆ4.4 KH 00996497 “]ខ្ញុំធ្វើការចាប់ពីម៉ោងបីព្រឹក ដល់ម៉ោងដប់មួយថ្ងៃត្រង់ ហើយម៉ោងមួយ យើងចូលធ្វើការវិញ យើងធ្វើការរហូតដល់ម៉ោងប្រាំមួយល្ងាច។ ប្រសិនបើមានមនុស្សណាម្នាក់ធ្វើការងារមិនហើយ នោះគេឲ្យធ្វើការទាំងយប់ លុះត្រាតែយើងធ្វើការងារនោះចប់។ ឯកសារ **D219/474** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហួន ចាន់រីន ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ2.4 KH 01134122 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័តស្រុក៖ ការរស់នៅ និងធ្វើការក្នុងអំឡុងពេលនៃការគ្រប់គ្រង“ របស់ពួកនិរតី និងពាយ័ព្យ ម ានការលំបាកស្មើរតែដូចគ្នា តែគ្រាន់ថាការរស់នៅក្នុងពេលពួកពាយ័ព្យកាន់កាប់មានលក្ខណៈគ្រាន់បើជាងបន្តិច។ ស្ថានភាពដែលអាក្រក់បំផុត គឺក្នុងពេលដែលខ្ញុំធ្វើការ និងរស់នៅការដ្ឋានអាងត្រពាំងថ្ម ព្រោះកាលនោះគេឲ្យហូបចុកតិចតួចបំផុត ទាំងម្ហូបទាំងទឹក ហើយគេឲ្យធ្វើការងារយ៉ាងខ្លាំង។[”។ ឯកសារ **D219/256** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ1.5 KH 01085164 [សាក្សី គឺជាអ្នកធ្វើការនៅភ្នំលៀប៖ ដោយសារតែការហូបចុកតិចជាងមុន ការងារកាន់តែយ៉ាប់ជាង ការគ្រប់គ្រងរបស់កម្មាភិបាលនិរតី គឺកាន់តែយ៉ាប់ជាងមុន“ មុន និងមានមនុស្សកាន់តែច្រើនឈឺ និងស្លាប់ ហើយការសម្លាប់ប្រជាជនក៏កាន់តែច្រើនថែមទៀត[”។

458 ឯកសារ **D219/384** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌឹក គុយ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ1.7 KH 0113233 [សាក្សីបានរស់នៅ និងធ្វើការនៅក្នុងភូមិជ្រាប់ ស្រុកព្រះនេត្រព្រះ៖ នៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី មានមនុស្ស “ រធ្វើការងាររឹតតែច្រើនឡើងៗ។ នៅសម័យគ្រប់គ្រងដោយពួកនិរតី មានមនុស្សជាច្រើនបានបាត់អាហារហូបកាន់តែតិច កា [”ខ្លួន តែខ្ញុំមិនដឹងពីមូលហេតុទេ។។ ឯកសារ **D219/574** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទ្រី ភឿត ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ឆ4.6 KH 01166346 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងរោងម៉ាស៊ីនកិនស្រូវ នៅភ្នំលៀប៖ ក្រោមការ“ [”គ្រប់គ្រងរបស់និរតី បាត់ខ្លួនច្រើនជាង។ ក្រោមការគ្រប់គ្រងរបស់ពាយ័ព្យ មិនសូវអីទេ។។ ឯកសារ **D119/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ1.5 KH 00894493 [សាក្សីបានធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ ខ្ញុំពិបាកសន្និដ្ឋានណាស់ តែមនុស្សនៅក្នុងកងចល័តនៅតែបន្តបាត់ខ្លួន តែខ្ញុំមិនដឹងថា គេនាំ“ [”ទៅណាទេ។។ ឯកសារ **D119/145** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ធិប គឹមលន់ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឆ5.1 KH 01022032 [សាក្សីបានធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ស៖ “ ក្រោយពេលដែលក្រុមយាយ ចែម មកជំនួសកម្មាភិបាលចាស់ៗ តើស្ថានភាពរស់នៅរបស់ប្រជាជន មានលក្ខណៈដូចម្ដេ ?ចដែរឆ.51៖ ស្ថានភាពរស់នៅរបស់ប្រជាជននៅពេលនោះ គឺមិនមានលក្ខណៈល្អប្រសើរទេ គឺមានការលំបាកខ្លាំង ពីព្រោះ

នៅពេលនោះ គេឲ្យយើងហូបតែបបរ លាយដើមចេក ដែលពេលនោះ គេកំណត់ឲ្យយើងហូបបបរ ១ ខ្ទះ សម្រាប់ ៣០ គ្រួសារ។" ឆ.53 KH 01022032"] នៅចុងរបបនៃខ្មែរក្រហម ការបាត់ខ្លួន និងការចាប់ខ្លួន គឺកាន់តែច្រើន។["។ ឯកសារ **D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ4.3 KH 00976181 [សាក្សី គឺជាប្រធានកងចល័តមួយ ដែលមានអ្នកធ្វើការចំនួន ៣០ នាក់ ត្រូវបានចាត់តាំងឲ្យធ្វើការនៅត្រពាំងថ្ម និងស្ពានស្រែង៖ ស៖ "ក្រោមការគ្រប់គ្រងរបស់ តា ម៉ោង និង យាយ ចែម តើលោកដឹងថា តើការគ្រប់គ្រងមួយណា ដែលមានមនុស្សបាត់ខ្លួនច្រើនជាង ?ឆ4.3៖ មនុស្សបាត់ខ្លួនច្រើន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់យាយ ចែម។["។ ឯកសារ **D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ9.4 KH 01049236 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងយុវជនចល័ត នៅព្រះនេត្រព្រះ៖ ន និងចាប់ខ្លួនកាន់តែបាទ គឺមានការបាត់ខ្លួ" ["ច្រើន។ នៅពេលនោះ ប្រជាជនហូបមិនឆ្អែត លួចដកដំឡូងហូប បើគេចាប់បាន យើងលួចបេះ គេនឹងសម្លាប់ចោល។។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ3.8 KH 01115776 [សាក្សី បានធ្វើការនៅត្រពាំងថ្ម៖ស៖ ពេលពួកនិរតីមកដល់ តើលោកមានដែល" ?សង្កេតមើលឃើញពីការបាត់ខ្លួនច្រើន ឬនាំទៅច្រើន ដើម្បីយកទៅសម្លាប់ដែរទេឆ.38៖ យកទៅច្រើន ច្រើនជាងមុន គេចាប់ប៉ះទាំងខ្ញុំទៀត តែវៀតណាមចូលមកទាន់ ខ្ញុំក៏រួចខ្លួន។ ខ្ញុំនៅមានស្នាមគេចងដៃនៅឡើយ។["។ ឯកសារ **D43** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នៀម ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ 00722206 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត៖ តាមខ្ញុំស្មាន គឺមានការកើនឡើង"បើប្រៀបធៀបជាមួយការគ្រប់គ្រងពីមុន។["។ ឯកសារ **D219/12** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុយ វួចលាង ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ3.1 KH 01025682 [សាក្សី គឺជាអ្នកធ្វើការនៅព្រះនេត្រព្រះ៖ ["ពេលពួកនិរតីកាន់កាប់ គឺមានការបាត់ខ្លួនមនុស្សច្រើនជាង។"ឆ.96 KH 01025688 [ស៖ កាល" ពីព្រឹកមិញ លោកស្រីនិយាយថា នៅពេលដែលពួកនិរតីចូលមកដល់ មានមនុស្សបាត់ខ្លួនជាបន្តបន្ទាប់។ តើអ្នកនោះជា ?នរណា ឆ.96៖ ច្រើនតែប្រជាជនថ្មី គឺអ្នកមកពីភ្នំពេញ។["។

459 ឯកសារ D219/173 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្ដើង ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.49 KH 01065979 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "តាមខ្ញុំដឹង គឺវាមានលក្ខណៈលំបាកមិនខុសគ្នាទេ ប៉ុន្តែគ្រាន់តែក្រោយពេលដែលពួកកម្មាភិបាលនិរតីមកដល់ គឺការលំបាកមានការលំបាកកាន់តែធ្ងន់ឡើង ហើយមានការសម្លាប់មនុស្សច្រើនមុន។"]។ ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.43 KH 01114731 [សាក្សី គឺជានិរសារបស់ អ៊ឹម ចែម៖ "ដូចជាច្រើនដែរ រាប់រយនាក់ ក្នុងមួយស្រុកព្រះនេត្រព្រះ។"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.36 KH 00978924 [សាក្សីបានធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "ក្រោមការគ្រប់គ្រងរបស់ពួកនិរតី ស្ថានភាពរស់នៅ និងស្ថានភាពការងារ គឺមានការលំបាកដូចគ្នា។ ការកាប់សម្លាប់នៅក្នុងភូមិស្រែះកើត ត្រូវបានថយចុះជាងមុន ប៉ុន្តែនៅកន្លែងគ្រប់គ្រងរបស់យាយ ចែម នៅភ្នំលៀប ការចាប់ និងការសម្លាប់មានការកើនឡើង ពីព្រោះមានមនុស្សជាច្រើនត្រូវបានចាប់បណ្តើរមកទាំងខ្សែៗ យកមកដាក់នៅកន្លែងយាយ ចែម នៅភ្នំលៀប។"]។ ឯកសារ D219/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.28 KH 01066001 [សាក្សីបានធ្វើការនៅក្នុងកងចល័តមួយ

ក្នុងតំបន់ ៥ នៅត្រពាំងថ្ម៖ "តាមពិតទៅ មុនពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មិនសូវខ្លាំងប៉ុន្មានទេ ប៉ុន្តែក្រោយពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មនុស្សរឹតតែខ្លាំងៗឡើង។"]។ ឯកសារ D119/91 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម តាប់ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.12 KH 00976148 [សាក្សី គឺជាប្រធានសហករណ៍ នៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ៖ "នៅពេលពួកនិរតីមកដល់ ការរស់នៅមានការលំបាកជាងមុនខ្លាំងណាស់ ហើយការធ្វើការងាររឹតតែមានការលំបាកខ្លាំង ជាពិសេស គឺមានការកាប់សម្លាប់យ៉ាងខ្លាំងទោះបីជាមានកំហុសតិចតួចក៏ដោយ។"]។ ឯកសារ D119/21 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ដៀង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.16 KH 00894509 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងសហករណ៍មួយ នៅភ្នំលៀប៖ "ជីវភាពរស់នៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ គឺធម្មតា។ តែស្ថានភាពមានការលំបាកនៅពេលដែលពួកនិរតីមកដល់។ ការសម្លាប់ក៏កើនឡើងដែរ នៅពេលនោះ មិនថាចិន មិនថាខ្មែរទេ។"]។ ឯកសារ D119/93 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.11-12 KH 00976165 [សាក្សីបានធ្វើការនៅការដ្ឋានផ្សេងៗ នៅព្រះនេត្រព្រះ៖ "ឆ. 11៖ ពេលពួកនិរតីចូលមកគ្រប់គ្រងនៅតំបន់នេះ ស្ថានភាពរស់នៅ និងស្ថានភាពការងារ រឹតតែមានការលំបាកធ្ងន់ធ្ងរឡើងៗ។ នៅពេលនោះ យើងមិនមានកម្លាំងធ្វើការទេ ព្រោះម្នាក់ៗកាន់តែស្គមស្គាំងទៅៗ។ ស៖ លោកនិយាយថា ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៦ លោកត្រូវបានគេប្រើដូចសត្វធាតុ។ តើនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី ស្ថានភាពកាន់តែធ្ងន់ធ្ងរ ជាងសត្វធាតុទៀតឬ? ឆ.12៖ បាទ កាន់តែធ្ងន់ធ្ងរជាងមុនទៀត។ ត្រង់ចំណុចនេះ ខ្ញុំចង់និយាយថា ពីមុនយើងមានបាយហូប ប៉ុន្តែក្រោយមក យើងហូបតែបបរ ព្រមទាំងការងារកាន់តែច្រើនជាងមុន ហើយមនុស្សត្រូវគេចាប់យកទៅសម្លាប់ច្រើនជាងមុន។ ឆ.14 KH 00976166 ["មូលហេតុ ដែលគេចាប់យើងយកទៅសម្លាប់ ដោយសារតែកម្លាំងយើងខ្សោយជាងមុន ហើយមិនអាចធ្វើការងារឲ្យគ្រប់ផែនការបាន ទើបខ្មែរក្រហមចោទថាជាខ្មាំង ហើយចាប់យកទៅសម្លាប់។ នៅសម័យនោះ នៅពេលដែលនរណាម្នាក់ត្រូវបានគេចោទថាខ្មាំង អ្នកនោះនឹងត្រូវគេយកទៅសម្លាប់ហើយ។"]។ ឯកសារ D219/474 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ចាន់រីន ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.25 KH 01134122 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័តនៅក្នុស្រុកមួយ៖ "ខ្ញុំអាចនិយាយបានថា មានមនុស្សច្រើនណាស់ ដែលត្រូវបានគេយកទៅសម្លាប់ក្នុងពេលពួកពាយ័ព្យគ្រប់គ្រង តែមានអ្នកដាច់ពោះស្លាប់តិចតួចទេ។ ចំណែកក្នុងអំឡុងពេលពួកនិរតីគ្រប់គ្រង មនុស្សគេយកទៅសម្លាប់ក៏ច្រើន មនុស្សដែលស្លាប់ដោយដាច់ពោះក៏ច្រើន។"]។ ឯកសារ D219/256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.15-16 KH 01085164 [សាក្សី គឺជាអ្នកធ្វើការនៅភ្នំលៀប៖ "ឆ.15៖ ការគ្រប់គ្រងរបស់កម្មាភិបាលនិរតី គឺកាន់តែយ៉ាប់ជាងមុន ដោយសារតែការហូបចុកតិចជាងមុន ការងារកាន់តែយ៉ាប់ជាងមុន និងមានមនុស្សកាន់តែច្រើនឈឺ និងស្លាប់ ហើយការសម្លាប់ប្រជាជនក៏កាន់តែច្រើនថែមទៀត។ ស៖ តើលោកអាចប្រាប់បានទេ ចំពោះការសម្លាប់ប្រជាជន មូលហេតុអ្វីបានជាប្រជាជនត្រូវបានយកទៅសម្លាប់? តើនរណាជាអ្នកបញ្ជា? ឆ.16៖ មុនពេលចាប់ខ្លួនប្រជាជន ខ្មែរក្រហមបានចោទអ្នកទាំងនោះថាជាខ្មាំង ហើយបានយកទៅសម្លាប់។ ខ្ញុំមិនដឹងថាពាក្យខ្មាំងជាអ្វីទេ។ បើតាមខ្ញុំដឹង មេឃុំ ជាអ្នកបញ្ជាឲ្យចាប់ និងយកមនុស្សទៅសម្លាប់ ហើយកូនចៅរបស់មេឃុំជាអ្នកចាប់ និងយកទៅសម្លាប់។ នៅពេលដែលខ្ញុំដើរចល័ត ខ្ញុំឃើញគេចាប់បញ្ជូនមនុស្សពីការដ្ឋានព្រែកដីក មានទីតាំងនៅខាងកើតអូរលាប ទៅភ្នំលៀប។ គេ

ដាក់មនុស្សទាំងនោះ នៅសាលាឃុំ ព្រោះសាលាឃុំមានគុកមួយ សម្រាប់ដាក់អ្នកទោស។ ចំពោះការចាប់ខ្លួនមនុស្សទៅភ្នំលៀបនេះ គឺនៅក្រោយពេលដែលកម្មាភិបាលនិរតីចូលមកដល់។”]។

460 ឯកសារ D219/384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹក គុយ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.17 KH 01113233 [សាក្សីបានរស់នៅ និងធ្វើការនៅក្នុងភូមិជ្រាប់ ស្រុកព្រះនេត្រព្រះ៖ “នៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី អាហារហូបកាន់តែតិច ការធ្វើការងារកាន់តែច្រើនឡើងៗ។ នៅក្នុងសម័យគ្រប់គ្រងដោយពួកនិរតីមានមនុស្សជាច្រើនបានបាត់ខ្លួន តែខ្ញុំមិនដឹងពីមូលហេតុទេ។”]។ ឯកសារ D101/1.1 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 00743546 [សាក្សី ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានក្រុម នៅព្រះនេត្រព្រះ នៅក្នុងឆ្នាំ ១៩៧៧៖ “ប៉ុន្តែពេលគាត់មកកាន់នៅទីនេះ របបអាហារហូបចុកតឹងរ៉ឹងជាងមុន គឺគ្រប់ភូមិទាំងអស់ ហើយតាមខ្ញុំដឹង គឺគ្រប់ភូមិនៅក្នុងតំបន់ ៥ នេះ មានរបបហូបចុកតឹងរ៉ឹងដូចៗគ្នា។ ខ្ញុំដឹងអំពីបញ្ហានេះ ព្រោះពេលនោះខ្ញុំនៅជាប្រធានក្រុមដដែល។”]។ ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.38 KH 01148731-01148732 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងយុវជន នៅព្រះនេត្រព្រះ៖ “ស្ថានភាពរស់នៅរបស់ប្រជាជន មានស្ថានភាពអាក្រក់ជាងមុន ពីព្រោះគ្រួសាររបស់ខ្ញុំ រួមមានឪពុកម្តាយ និងបងប្អូន ត្រូវបានគេចាប់យកទៅសម្លាប់ ដោយមិនដឹងមូលហេតុ។ ស្ថានភាពរស់នៅ នៅពេលនោះ ពិតជាវេទនាខ្លាំងណាស់ ពីព្រោះយើងមិនមានអាហារហូបគ្រប់គ្រាន់ទេ។ គេដាំបបរដោយអង្ករ ២ កំប៉ុង ឲ្យមនុស្ស ២០០ នាក់ហូប ដូច្នេះយើងមិនមានអាហារហូបគ្រប់គ្រាន់ទេ ដោយនាំគ្នាបេះដើមកំប្លោកដែលរសាត់តាមទឹក យកមកហូប។ នៅពេលអស់ដើមកំប្លោក ពួកយើងបានទៅបេះផ្កាខ្នុរ យកមកហូប។ នៅពេលអស់ផ្កាខ្នុរហូប ទើបគេបញ្ជូនពួកយើងទៅភូមិរហាល ដើម្បីដាំដំឡូង។”]។ ឯកសារ D119/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច ឈានឡុង ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.37-38 KH 01024759 [សាក្សី គឺជាប្រធានកងភ្ជួរនៅព្រះនេត្រព្រះ៖ “ឆ.37៖ ការរស់នៅ និងការធ្វើការងារ ក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី មានការលំបាកខ្លាំងណាស់ ពីព្រោះយើងត្រូវធ្វើការខ្លាំង ដូចជាទាសករអ៊ីចឹង។ ការហូបចុកនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ គេឲ្យអង្ករយើងម្នាក់ ២ កំប៉ុងក្នុង ១ ថ្ងៃ។ ចំណែកការហូបចុកនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី គឺគេឲ្យអង្ករយើង ៩ កំប៉ុង សម្រាប់ ៣០ គ្រួសារក្នុង ១ ថ្ងៃ។ ពេលម៉ោងធ្វើការ គឺដូចគ្នា ប៉ុន្តែ យើងត្រូវបញ្ចប់តាមផែនការប្រចាំថ្ងៃ នៅពេលយើងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី។ ឧទាហរណ៍ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពាយ័ព្យ គេឲ្យយើងច្រូតស្រូវក្នុង ១ ហិចតា ២៥ នាក់ ប៉ុន្តែ នៅស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ គេឲ្យយើងច្រូតស្រូវក្នុង ១ ហិចតា ២៥ នាក់ ប៉ុន្តែ នៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតី គេឲ្យយើងច្រូតស្រូវ ១ ហិចតាតែ ១៥ នាក់ប៉ុណ្ណោះ។ ស៖ ប្រសិនបើយើងមិនអាចបញ្ចប់ផែនការប្រចាំថ្ងៃបាន តើនឹងមានរឿងអ្វីកើតឡើង ចំពោះយើង? ឆ.38៖ ប្រសិនបើយើងមិនអាចបញ្ចប់តាមផែនការទេ គេឲ្យយើងនៅធ្វើឲ្យទាល់តែរួច។”]។ ឯកសារ D119/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុន មុត ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.47 KH 01003884 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ “ស្ថានភាពរស់នៅ និងស្ថានភាពការងារ នៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី មានការលំបាកខ្លាំងណាស់ ការហូបចុកមិនគ្រប់គ្រាន់ ធ្វើការងារលំបាក ហើយនឹងមានការភ័យខ្លាចខ្លាំង ដោយសារតែយើងត្រូវបានគេតាមដានយ៉ាងខ្លាំង។ ពួកនិរតីបានផ្តល់អង្ករឲ្យយើងម្នាក់កន្លះកំប៉ុងក្នុងមួយថ្ងៃតែប៉ុណ្ណោះ។ ឯកសារ D119/133

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ិត ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.26 KH 00998138 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "ខ្ញុំសូមបញ្ជាក់ថា ស្ថិតនៅក្រោមការគ្រប់គ្រងទាំងពីរក្រុម គឺភូមិភាគពាយ័ព្យ និងនិរតី គឺសុទ្ធតែមានការលំបាកដូចគ្នា គឺគេមិនឱ្យយើងហូបចុកគ្រប់គ្រាន់ ហើយគេបញ្ជូនយើងឱ្យទៅធ្វើការនៅតាមការដ្ឋាននានា។ ក្រោយពីយើងបានធ្វើការពេលថ្ងៃរួច នៅរៀងរាល់យប់ គេតែងតែហៅយើងឱ្យចូលប្រជុំ ដើម្បីពង្រឹងគោលជំហររបស់ប្រជាជន។"]។ ឯកសារ D119/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.14 KH 00894493 [សាក្សីបានធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "ស៖ នៅពេលពួកនិរតីមកដល់ តើរបបហូបចុកមានភាពប្រសើរ ឬលំបាកជាងមុន? ឆ.14៖ ការហូបចុក មានភាពលំបាកជាងមុន។"]។ ឯកសារ D106/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឹត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ [សាក្សីបានធ្វើការនៅក្នុងកងចល័ត នៅសហករណ៍មួយ៖ "នៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ ស្ថានភាពរស់នៅមានភាពធម្មតា ប៉ុន្តែនៅពេលពួកនិរតីមកគ្រប់គ្រង ស្ថានភាពតឹងតែងជាងមុន និងលំបាកខ្លាំង។ នៅពេលពួកពាយ័ព្យគ្រប់គ្រង យើងមានអាហារគ្រប់គ្រាន់ ហើយមានបាយហូប តែនៅពេលពួកនិរតីមកគ្រប់គ្រង យើងហូបតែបបរប៉ុណ្ណោះ គឺអង្ករ ១ កំប៉ុងសម្រាប់មនុស្ស ១០ នាក់។"]។ ឯកសារ D219/477 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សាម៉ុត ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ ឆ.39 KH 01134151 [សាក្សី គឺជាជំនួយការឱ្យស្រុកព្រះនេត្រព្រះ ទទួលបន្ទុកឃុំរហាល (ពាក់កណ្តាលឆ្នាំ ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧)៖ "ខ្ញុំសូមប្រាប់ថា ជួនកាលយើងរស់នៅដោយភ័យខ្លាចដែរ ពេលពួកពាយ័ព្យគ្រប់គ្រង តែយើងបានហូបគ្រប់គ្រាន់។ ក្នុងពេលពួកនិរតីគ្រប់គ្រងវិញ យើងមានការភ័យខ្លាចជាប្រចាំ ហើយហូបក៏មិនឆ្អែតទៀត។"]។ ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.38 KH 00996496 [សាក្សីបានធ្វើការក្នុងកងកុមារមួយ នៅក្នុងកងចល័តនៅតំបន់ ៥៖ "ស្ថានភាពរស់នៅ និងស្ថានភាពការងារ នៅមុនពេលដែលយាយ ចែម មកគ្រប់គ្រងតំបន់ដែលខ្ញុំរស់នៅ ស្ថានភាព គឺមានការលំបាកខ្លាំង ពីព្រោះគេឱ្យយើងហូបបបរវារមួយស្លាបព្រាមួយនាក់តែប៉ុណ្ណោះ។ ចំណែកឯស្ថានភាពរស់នៅ និងធ្វើការងារ នៅក្រោយពេលដែលយាយ ចែម មកគ្រប់គ្រង គឺមានលក្ខណៈកាន់តែលំបាកខ្លាំងជាងមុនទៅទៀត។"] ឆ.40 KH 00996496 [ក្នុងករណីនេះ ដែលយើងមិនហើយតាមផែនការ គេនឹងមិនឱ្យបបរហូបទេ។"]។ ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.42 KH 01024749 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "ដោយខ្ញុំភាគច្រើនធ្វើការនៅក្នុងកងចល័ត ស្ថានភាពរស់នៅ និងស្ថានភាពការងារ គឺមានលក្ខណៈលំបាកដូចតែគ្នា។ ការងារនៅកងចល័ត គឺយើងត្រូវលើកដី ២ ម៉ែត្រគូបក្នុងម្នាក់។ តាមការពិត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ យើងបានបាយហូបខ្លះ ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី គឺយើងមិនមានអាហារគ្រប់គ្រាន់ទេ គឺគេឱ្យកន្ទួកយើងហូប ១ ថ្ងៃមួយស្លាបព្រា។"]។ ឯកសារ D219/39 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថួយ ធៀម ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.55 KH 01032127 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "មុនពេលគេមកដល់ ខ្ញុំមានបាយហូប ដល់ពេលពួកនិរតីមកដល់ ខ្ញុំហូបបបរ។ ខ្ញុំនៅធ្វើការកន្លែងដកសំណាបនៅឯស្រែ។"]។ ឯកសារ D119/93 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.11-12 KH 00976165 [សាក្សី គឺជាអ្នកធ្វើការនៅតាមការដ្ឋានផ្សេងៗ នៅព្រះនេត្រព្រះ៖ "ឆ. 11៖ ពេល

ពួកនិរតីចូលមកគ្រប់គ្រងនៅតំបន់នេះ ស្ថានភាពរស់នៅ និងស្ថានភាពការងារ រឹតតែមានការលំបាកធ្ងន់ធ្ងរឡើងៗ។ នៅពេលនោះ យើងមិនមានកម្លាំងធ្វើការទេ ព្រោះម្នាក់ៗកាន់តែស្គមស្គាំងទៅៗ។ សៈ លោកនិយាយថា ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦ លោកត្រូវបានគេប្រើដូចជាសត្វធាតុ។ តើនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី ស្ថានភាពកាន់តែធ្ងន់ធ្ងរជាងសត្វធាតុទៀតឬ? ឆ.12៖ បាទ កាន់តែធ្ងន់ធ្ងរជាងមុនទៀត។ ត្រង់ចំណុចនេះ ខ្ញុំចង់និយាយថា ពីមុនយើងមានបាយហូប ប៉ុន្តែ ក្រោយមក យើងហូបតែបបរ ព្រមទាំងការងារកាន់តែច្រើនជាងមុន ហើយមនុស្សត្រូវគេចាប់យកទៅសម្លាប់ច្រើនជាងមុន។”]។ ឯកសារ D219/474 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ចាន់រីន ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.24 KH 01134122 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័តស្រុក៖ “ការរស់នៅ និងធ្វើការក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ពួកនិរតី និងពាយ័ព្យ មានការលំបាកស្ទើរតែដូចគ្នា តែគ្រាន់ថាការរស់នៅក្នុងពេលពួកពាយ័ព្យកាន់កាប់មានលក្ខណៈគ្រាន់បើជាងបន្តិច។ ស្ថានភាពដែលអាក្រក់បំផុត គឺក្នុងពេលដែលខ្ញុំធ្វើការ និងរស់នៅការដ្ឋានអាងត្រពាំងថ្ម ព្រោះកាលនោះ គេឱ្យហូបចុកតិចតួចបំផុតទាំងម្ហូបទាំងទឹក ហើយគេឱ្យធ្វើការងារយ៉ាងខ្លាំង។ ឆ.25 KH 01134122 [“ខ្ញុំអាចនិយាយបានថា មានមនុស្សច្រើនណាស់ដែលត្រូវបានគេយកទៅសម្លាប់ ក្នុងពេលពួកពាយ័ព្យគ្រប់គ្រង តែមានអ្នកដាច់ពោះស្លាប់តិចតួចទេ។ ចំណែកក្នុងអំឡុងពេលពួកនិរតីគ្រប់គ្រង មនុស្សគេយកទៅសម្លាប់ក៏ច្រើន មនុស្សដែលស្លាប់ដោយដាច់ពោះក៏ច្រើន។”]។ ឯកសារ D219/255 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ រឿប ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ឆ.16 KH 01085157 [សាក្សី គឺជាអនុប្រធានភូមិម្នាក់ នៅព្រះនេត្រព្រះ៖ “កម្មាភិបាលនិរតីមានលក្ខណៈលំបាកជាងកម្មាភិបាលពាយ័ព្យ ឧទាហរណ៍ ដូចជាកម្មាភិបាលនិរតីផ្តល់ការហូបចុកតិចជាងកម្មាភិបាលពាយ័ព្យ។”]។ ឯកសារ D219/473 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ហ៊ិន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ឆ.10 KH 01134109 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ “បាទ យើងទទួលរងការលំបាក ទាំងក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលពាយ័ព្យ និកម្មាភិបាលនិរតី។ យើងមិនដែលមានអ្វីគ្រប់គ្រាន់ សម្រាប់ហូបទេ។ យើងតែងតែលួចបូតស្រូវនៅគេហូប។ ពេលដែលគេវាយជួងឱ្យយើងទៅទទួលរបបអាហារ យើងទៅឃើញតែបបរទឹករាវក្រក្លក មិនសូវមានគ្រាប់អង្ករទេ។ បើយើងមិនលួចគេទេ យើងមិនបានហូបឆ្អែតដែរ ដូច្នេះ ខ្ញុំលួចបូតស្រូវគេហូបរៀងរាល់ថ្ងៃ។ បើសិនជាគេឃើញយើងលួចបូតស្រូវនោះគេនឹងសម្លាប់យើងចោលហើយ ដោយពេលនោះ គេចោទយើងថាជាខ្មាំងលួចហូប និងក្បត់ និងមិនស្តាំបញ្ជាអង្គការ ពីព្រោះគេឱ្យយើងគ្រប់គ្រាន់ហើយ ហេតុអ្វីយើងលួចស្រូវគេហូបទៀត។”]។ ឯកសារ D219/455 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឆ.48 KH 01129810 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័តនៅព្រះនេត្រព្រះ៖ “ពេលនិរតីគ្រប់គ្រង យើងលែងឱ្យបាយហើយ គឺបបរ។ ដំបូង គេឱ្យហូបបបរមួយឆ្អែត ក្រោយមកវាល់ចែកគ្នា។ នៅចុងឆ្នាំ ១៩៧៧ និងដើមឆ្នាំ ១៩៧៨ ខ្ញុំបានទៅលេងម្តាយរបស់ខ្ញុំ ដែលគាត់ជាចុងភៅ នៅសហករណ៍ត្រពាំង។ អង្ករមួយកំប៉ុង លាយជាមួយដំឡូងមី ដាំបបរឱ្យមនុស្ស ១០០ នាក់ហូប។”]។ ឯកសារ D219/256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.15 KH 01085164 [សក្សី គឺជាអ្នកធ្វើការនៅភ្នំលៀប៖ “ការគ្រប់គ្រងរបស់កម្មាភិបាលនិរតី គឺកាន់តែយ៉ាប់ជាងមុន ដោយសារតែការហូបចុកតិចជាងមុន ការងារកាន់តែយ៉ាប់ជាងមុន និងមានមនុស្សកាន់តែច្រើនឈឺ និងស្លាប់។ ហើយការសម្លាប់ប្រជាជនក៏កាន់តែច្រើនថែមទៀត។”]។

461 ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.42 KH 01024749-01024750 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "ដោយខ្ញុំភាគច្រើនធ្វើការនៅក្នុងកងចល័ត ស្ថានភាពរស់នៅ និងស្ថានភាពការងារ គឺមានលក្ខណៈលំបាកដូចតែគ្នា។ ការងារនៅកងចល័ត គឺយើងត្រូវលើកដី ២ ម៉ែត្រគូបក្នុងម្នាក់។ តាមពិតទៅ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យយើងបានបាយហូបខ្លះ ប៉ុន្តែស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី គឺយើងមិនមានអាហារគ្រប់គ្រាន់ទេ គឺគេឲ្យកន្ទួកយើងហូប ១ ថ្ងៃមួយស្លាបព្រា។ ខ្ញុំធ្លាប់ឃើញព្រឹត្តិការណ៍មួយផ្ទាល់នឹងភ្នែកប្រហែលជានៅក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ ១៩៧៨ នៅពេលដែលខ្ញុំដាំដំឡូងនៅភ្នំជញ្ជាំង គឺមានយុវជន ៣ នាក់ ដោយសារពួកគេហូបមិនគ្រប់គ្រាន់ ពួកគេឃ្លានខ្លាំងពេក ពួកគេបានលួចកាត់ស្លឹកត្រចៀកគោម្ខាងយកទៅដុតហូប។ នៅពេលនោះ ពួកកម្មាភិបាលនិរតីបានចាប់ពួកគាត់យកមកកាត់ទោសនៅក្នុងអង្គប្រជុំមួយ ហើយបន្ទាប់មកពួកខ្មែរក្រហមទាំងនោះវាយសម្លាប់ពួកគាត់ចោលនៅទីនោះតែម្តង។"]។ ឯកសារ D219/13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.38 KH 01025645 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "ពេលពួកកម្មាភិបាលនិរតីបានចូលមក ពួកគេបានប្រមូលទ្រព្យសម្បត្តិមានតម្លៃទាំងអស់៖ សូម្បីតែសេនកោសខ្យល់ ក៏ពួកគេប្រមូលយកទៅដែរ ហើយបានប្រមូលចានឆ្នាំ ដើម្បីហូបបាយរួម ពីព្រោះគេការពារមិនឲ្យយើងរត់គេចខ្លួនទៅប្រទេសថៃ។ ចំណែកដំណាំដែលយើងដាំបាន គឺគេប្រមូលដាក់រួមទាំងអស់ គឺគេឲ្យយើងហូបរួម។ នៅពេលដែលពួកគេឃើញមានផ្សែងចេញពីផ្ទះណាមួយ ពួកឈ្លបនឹងមកដល់ ហើយចាប់យកទៅសម្លាប់ចោលហើយ។ នៅពេលនោះ យើងមានការវេទនាខ្លាំងណាស់ ហើយក៏មានមនុស្សស្លាប់ច្រើនណាស់ដែរ ដោយសារការអត់ឃ្លាន។"] ឆ.39 KH 01025645 [គេមិនបានប្រាប់យើងអំពីគោលការណ៍ ឬក៏ជាសេចក្តីសម្រេចអ្វីទេ គឺគេគ្រាន់តែមករឹបអូសយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់យើង ដើម្បីដាក់រួមតែប៉ុណ្ណោះ ហើយក្រោយមក គេបានប្រាប់យើងឲ្យទៅហូបបាយរួម។ ការងារនេះ ត្រូវបានអនុវត្តទាំងអស់នៅគ្រប់ភូមិទាំងអស់ ក្នុងស្រុកព្រះនេត្រព្រះ ដោយសារគេខ្លាចពួកយើងលួចរត់ទៅប្រទេសថៃ។"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.94 KH 01049236 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងយុវជនចល័ត នៅព្រះនេត្រព្រះ៖ "បាទ គឺមានការបាត់ខ្លួន និងចាប់ខ្លួនកាន់តែច្រើន។ នៅពេលនោះ ប្រជាជនហូបមិនឆ្អែត លួចដកដំឡូងហូប បើគេចាប់បានយើងលួចបេះ គេនឹងសម្លាប់ចោល។"]។

462 ឯកសារ D219/253 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ហូវ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥ ឆ.24 KH 01085137 [សាក្សី គឺជាអ្នកធ្វើការ នៅព្រះនេត្រព្រះ៖ "ការធ្វើការនៅទីនោះ ដូចជាមិនសូវជាលំបាកទេ។ ជួនកាល គេឲ្យខ្ញុំលើកភ្លឺ ១០ ម៉ែត្រម្នាក់ឯង។ សម្រាប់ស្ទូង ៤០ ម៉ែត្រក្នុងមួយថ្ងៃ ធ្វើការ ៤ នាក់។ ចំពោះការហូបចុក ហូបមិនគ្រប់ទេ។ ហូបបបររាវ។ អ្នកស្លាប់ភាគច្រើន គឺស្លាប់ដោយសារដាច់បាយ។ មិនសូវមានមនុស្សស្លាប់ដោយការវាយសម្លាប់ទេ។"]។ ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.38 KH 00996496 [សាក្សីបានធ្វើការនៅក្នុងកងកុមារចល័ត នៅតំបន់៖ "ស្ថានភាពរស់នៅ និងស្ថានភាពការងារ នៅមុនពេលដែលយាយ ថែម មកគ្រប់គ្រងតំបន់ ដែលខ្ញុំរស់នៅ ស្ថានភាព គឺមានការលំបាកខ្លាំង ពីព្រោះគេឲ្យហូបបបររាវមួយស្លាបព្រាមួយនាក់តែប៉ុណ្ណោះ។ ចំណែកឯស្ថានភាពរស់នៅ និងធ្វើការងារ នៅក្រោយពេលដែលយាយ ថែម

មកគ្រប់គ្រង គឺមានលក្ខណៈកាន់តែលំបាកខ្លាំងជាងមុនទៅទៀត។"] ឆ.42 KH 00996496 ["មិនមានថ្នាំព្យាបាលគ្រប់គ្រាន់ទេ។"] ឆ.43 KH 00996497 ["អ្នកខ្លះស្លាប់ដោយសារការអត់អាហារហូបគ្រប់គ្រាន់ និងខ្លះស្លាប់ដោយគ្មានថ្នាំសង្កូវព្យាបាល។"]។ ឯកសារ D119/145 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិប គឹមលន់ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឆ.51-52 KH 01022032 [សាក្សីបានធ្វើការនៅក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "សៈ ក្រោយពេលដែលក្រុមយាយ ចែម មកជំនួសកម្មាភិបាលចាស់ៗ តើស្ថានភាពរស់នៅរបស់ប្រជាជនមានលក្ខណៈដូម្តេចដែរ? ឆ.51៖ ស្ថានភាពរស់នៅរបស់ប្រជាជននៅពេលនោះ គឺមិនមានលក្ខណៈល្អប្រសើរទេ គឺមានការលំបាកខ្លាំង ពីព្រោះនៅពេលនោះ គេឲ្យយើងហូបតែបបរ លាយដើមចេក ដែលពេលនោះ គេកំណត់ឲ្យយើងហូបបបរ ១ ខ្ទះ សម្រាប់ ៣០ គ្រួសារ។ សៈ តើក្រោយពេលដែលពួកកម្មាភិបាលថ្មី មកជំនួសកម្មាភិបាលចាស់ មនុស្សដែលសម្លាប់ដោយសារការខ្វះអាហារ និងស្លាប់ដោយគ្មានថ្នាំសង្កូវ មានការថយចុះ ឬកើនឡើង? ឆ.52៖ មិនថយចុះទេ គឺចំនួនកាន់តែកើនឡើង។"]។ ឯកសារ D219/474 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ចាន់រីន ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.24 KH 01134122 [សាក្សី បានធ្វើការនៅក្នុងកងចល័តស្រុក នៅត្រពាំងថ្ម៖ "ការរស់នៅ និងធ្វើការក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ពួកនិរតី និងពាយ័ព្យ មានការលំបាកស្ទើរតែដូចគ្នា តែគ្រាន់តែថាការរស់នៅក្នុងពេលពួកពាយ័ព្យកាន់កាប់មានលក្ខណៈគ្រាន់បើជាងបន្តិច។ ស្ថានភាពដែលអាក្រក់បំផុត គឺក្នុងពេលដែលខ្ញុំធ្វើការ និងរស់នៅនៅការដ្ឋានអាងត្រពាំងថ្ម ព្រោះកាលនោះ គេឲ្យហូបចុកតិចតួចបំផុត ទាំងម្ហូបទាំងទឹក ហើយគេឲ្យធ្វើការងារយ៉ាងខ្លាំង។ គ្រប់ៗគ្នាសុទ្ធតែកើតចៃសៗនៅពេញខ្លួន ដោយសារពុំមានទឹកងូតគ្រប់គ្រាន់ និងកង្វះអនាម័យ។ ខ្ញុំនៅតែព្រឺក្បាលនៅពេលខ្ញុំនឹកឃើញដល់ពេលនោះ។ ឧទាហរណ៍ ក្នុងពេលដែលខ្ញុំស្នាក់នៅមន្ទីរពេទ្យប្រហែលមួយខែនោះ គឺមានអ្នកស្លាប់សរុបប្រហែល ១០០ នាក់។ ចំពោះចំនួនអ្នកស្លាប់នៅអាងត្រពាំងថ្ម ខ្ញុំមិនអាចប៉ាន់ស្មានបានទេ ដោយសារថាពេលនោះ មនុស្សច្រើនណាស់បានទៅធ្វើការនៅទីនោះ ហើយខ្ញុំមិនដឹងថាគេមកពីណាខ្លះទេ។"] ឆ.25 KH 01134122 ["ខ្ញុំមិនអាចនិយាយបានថា មានមនុស្សច្រើនណាស់ ដែលត្រូវបានគេយកទៅសម្លាប់ក្នុងពេលពួកពាយ័ព្យគ្រប់គ្រង តែមានអ្នកដាច់ពោះស្លាប់តិចតួចទេ។ ចំណែកក្នុងអំឡុងពេលពួកនិរតីគ្រប់គ្រង មនុស្សគេយកទៅសម្លាប់ក៏មានច្រើន មនុស្សដែលស្លាប់ដោយដាច់ពោះក៏ច្រើន។"]។ ឯកសារ D219/256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.15 KH 01085164 [សាក្សី គឺជាអ្នកធ្វើការនៅភ្នំល្មៀប៖ "ការគ្រប់គ្រងរបស់កម្មាភិបាលនិរតី គឺកាន់តែយ៉ាប់ជាងមុន ដោយសារតែការហូបចុកតិចជាងមុន ការងារកាន់តែយ៉ាប់ជាងមុន និងមានមនុស្សកាន់តែច្រើនឈឺ និងស្លាប់ ហើយការសម្លាប់ប្រជាជនក៏កាន់តែច្រើនថែមទៀត។"]។

463 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929759-00929760 ["សុខ ប្រុស។ ប្រពន្ធគាត់ឈ្មោះ ប៊ុ កាលហ្នឹង គាត់ធ្វើប្រធានភូមិ។ គាត់បានរស់រាល់ថ្ងៃហ្នឹង ខ្ញុំជួយ។ អាហ្នឹងខ្ញុំទៅទាន់អាជំនាន់ក្រោយទេណា ទៅបន្ទាប់ពីគេហ្នឹង។"]។ ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929786 ["ចែម៖ ចាស នៅស្រុកព្រះនេត្រព្រះហ្នឹង ក៏ស្គាល់ពូសុខមួយ ហើយប្រពន្ធឈ្មោះ ប៊ុះ កាលនេះ គេរកចាប់គាត់ ដល់នេះខ្ញុំជួយគាត់។ ដានី៖ អ៊ំជួយរៀបរាប់កន្លែងហ្នឹងតិច? ចែម៖ របៀបដូចថាសំបុត្រគេយកឲ្យចឹង ខ្ញុំអត់ឲ្យគេចាប់ ហើយខ្ញុំអត់ចាប់ដល់ ៣ ដង ខ្ញុំយកសំបុត្រឲ្យម្ចាស់ខ្លួនមើល ដល់ហើយគាត់រត់រកខ្លួនខ្ញុំរហូតហ្នឹង ហើយគាត់ខ្លាចគេចាប់ហ្នឹង។"] KH 00929792-

00929793 [“ដានី៖ ពីណាគេផ្ញើសំបុត្រមកឱ្យអ៊ំ? ចែម៖ ចាស ឈ្មោះសុខហ្នឹង។ ដានី៖ ផ្ញើមកអ៊ំប៉ុន្មានដង? ចែម៖ ៣ ដង ខ្ញុំយកទៅឱ្យគាត់ គាត់ភ័យ ដល់ខ្ញុំរត់ឡើងភ្នំ គាត់រត់ទៅតាម។ គាត់សុខចិត្តថា បើខ្ញុំទៅស្រុក ក៏គាត់ទៅតាម”]។

464 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929786 [“ហ្នឹងមួយ ហើយពីរដែរឈ្មោះ ឃូ? សមាជិកស្រុក។ គាត់នៅកងចល័ត គេចោទប្រកាន់ថាជាមេបេះបោរ ធ្វើបាតុកម្មហ្នឹង។ កងយុវជនហ្នឹងេបះដែរ។ យើងរំសាយហ្នឹងណា។ ប៉ុនការពិតអត់ ដល់ហើយខ្ញុំទុកគាត់។ គាត់គោរពខ្ញុំរហូត តែបែកគ្នាទៅខាងលិចម៉ាឡ័យ ខាងសំឡូតទៅ ហើយរត់ហ្នឹង ខ្ញុំនៅនេះមក ហ្នឹងនៅស្រុកកំណើតនេះដែរ ហ្នឹងខ្ញុំជួយជីវិតដែរ។”]។ ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929881-00929882 [“ដានី៖ ចុះ ឃូ នឹង គាត់រាប់អានជិតស្និតជាមួយអ៊ំដែរ? ចែម៖ ចាស អូ គាត់និយាយពីត្រង់មាហាត្រង់។ គ្រាន់តែសំបុត្រ គេឱ្យចាប់ ២-៣ ខ្ញុំលាក់។ ដានី៖ អូ! អ៊ំជួយគាត់ដែរ? ចែម៖ ចាស ខ្ញុំជួយគាត់ ចឹងបានគាត់រស់រហូតទល់ឥឡូវ។ ដានី៖ ចឹងបើខ្ញុំទៅសួរគាត់អី គាត់ប្រាកដជានិយាយពីអ៊ំ? ចែម៖ ខ្ញុំជួយគាត់ច្រើន។ ដានី៖ ត្រង់ចឹង អ៊ំជួយគាត់ទៅ? ចែម៖ ជួយគាត់ ដូចជា គាត់នេះខុស យុវជន ធ្វើបាតុកម្ម ខ្ញុំយកសំបុត្រនឹងមកលាក់ ហៅគាត់ណែនាំ។”]។

465 ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.21 KH 01114728-01114729 [សាក្សី គឺជាជំនួយការរបស់ អ៊ឹម ចែម៖ “ស៖ ការពិត គឺ តា រស់ញ៉ឹម ផ្ញើសំបុត្រមកឱ្យយាយ ចែម ឱ្យយាយ ចែម ចាប់លោក។ តើលោកមាននឹកឃើញរឿងហ្នឹងទេ? ឆ.21៖ អត់ទេ ខ្ញុំមិនដឹងពីសំបុត្រនោះទេ ទើបតែពេលដែលក្រុមលោកជួបសម្ភាសន៍ខ្ញុំពីលើកមុន ទើបខ្ញុំដឹងរឿងនេះ។ តាមពិត យាយ ចែម មិនបានប្រាប់ខ្ញុំអំពីរឿងនេះទេ។ បើពេលនោះ ខ្ញុំដឹងរឿងនេះ ខ្ញុំរត់បាត់ទៅហើយ។”]។ ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929793-00929794 [“ដានី៖ ចុះឈ្មោះ ឃូ? ចែម៖ ឈ្មោះហ្នឹងមិនដឹងស្លាប់ ឬរស់ទេ ព្រោះបែកគ្នាយូរហើយ។ ដានី៖ បាទ ប៉ុន្តែកាលហ្នឹងអ៊ំជួយគាត់ពីរឿងអីគេដែរ? ចែម៖ ជួយគាត់ពីរឿងគេចោទប្រកាន់គាត់ថាជាមេបេះបោរ។ គេឱ្យគ្រប់គ្រងខាងយុវជនហ្នឹងណា។ ដានី៖ បាទ។ ចែម៖ ខ្ញុំអាណិតគាត់។ ខ្ញុំអត់ប្រាប់ដល់គេចោទប្រកាន់ ផ្សព្វផ្សាយទូទាំងស្រុក ចឹងទៅខ្ញុំបំបែកយុវជនហ្នឹងអស់។ ខ្ញុំហៅគាត់មកធ្វើការជាមួយខ្ញុំ រហូត។ ដានី៖ គាត់ធ្វើជាសមាជិកស្រុក? ចែម៖ ចាស ធ្វើសមាជិកស្រុករហូត។ ដានី៖ បាទ សមាជិកស្រុក? កាលណុងពីណាគេដែរប្រុងចាប់គាត់ដែរ? ចែម៖ តាញ៉ឹមហ្នឹងដែរ។ ដានី៖ គេផ្ញើសំបុត្រចឹងដែរ? ចែម៖ ចាស។”] KH 00929794 [“ដានី៖ អ៊ំយកសំបុត្រហ្នឹងឱ្យគាត់មើលដែរអត់ទេ? ចែម៖ ដល់គេច្រើនលើកពេក ខ្ញុំយកឱ្យគាត់មើលពេលប្រជុំ។ ខ្ញុំយកអាននៅក្នុងអង្គប្រជុំ។ ដានី៖ អាននៅអង្គប្រជុំ? ចាស ថានែសំបុត្រនេះគេចាប់។ គាត់ភ័យ។ ចំណីម៉ាម៉ាត់ក៏យកមកឱ្យខ្ញុំដែរ។ គាត់បម្រុងហ្នឹងស្លាប់ហើយ។ ពីរនាក់ហ្នឹង គេចោទ ហើយបម្រុងចាប់មែនទែន។ តែខ្ញុំជួយគាត់បាន ហើយមួយទៀតតា១ដែរ នៅសង្គមកិច្ច គេយកទៅដាក់ផ្ទះខ្ញុំនៅហ្នឹងណា។”]។

466 ឯកសារ D219/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.70-71 KH 01029674-01029675 [សាក្សី គឺជាសមាជិកនៃគណៈស្រុកព្រះនេត្រព្រះ៖ “ស៖ យាយ ចែម ក៏បាននិយាយទៀតថា គាត់

បានការពារ ខូ នោះ រហូតមក។" តើលោកអាចបញ្ជាក់អំពីចំណុចនេះបានទេ? ឆ.70៖ យាយ ចែម និយាយនេះ មិនត្រឹមត្រូវទេ ពីព្រោះខ្ញុំមិនបានធ្វើការជាមួយគាត់ទេ។ ស៖ តើយាយ ចែម មិនដែលការពារលោកទេ មែនឬ? ឆ.71៖ អត់ទេ។"]។

467 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929787 ["ហើយមួយទៀត ប្រជាជនៗ ប្រធានភូមិ គេរកចាប់អីហ្នឹង ខ្ញុំអត់មានចាប់ ហើយខ្ញុំលាក់។ ចឹងបានជាគេចោទខ្ញុំថា ខ្ញុំនេះប្រើតែមនុស្សគេចោល។ គេមិនប្រើ តែឯងហ្នឹងយកប្រើ។ គេចោទថាខ្ញុំជាខ្មាំង។"]។

468 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929799 ["ខ្ញុំអាណិត ព្រោះបញ្ហាសុទ្ធតែអាយុជីវិត ហើយខ្ញុំឃើញចាស់ ម្យ៉ាងទៀត គេចោទប្រកាន់នឹង វាអត់ពិតដូចថាគាត់ធ្វើស្រែ ធ្វើចំការ គាត់ខំធ្វើដូចយើង អញ្ចឹងទៅចោទគាត់ថាធ្វើបំផុសបំផុលធ្វើបាតុកម្មអីអញ្ចឹងអានឹងវាអត់ពិត។ អញ្ចឹងខ្ញុំយកខ្លួនខ្ញុំធានា ព្រោះរឿងវាអត់ពិត អញ្ចឹងយើងអ្នកដឹកនាំ បើសិនណាចេះតែថាតាមគេ ត្រូវអ្នកនឹងអស់ជីវិត ហើយគេយកសម្លាប់អត់មានកំហុស ត្រង់នឹងហើយបានជាខ្ញុំសមាហរណ៍កម្ម ហើយខ្ញុំថាឈប់ធ្វើការអីហើយ ក៏ប្រជាជនមិនព្រមឲ្យឈប់។"]។

469 ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234193 ["គឺខ្ញុំយកមើល ខ្ញុំខំដឹកនាំគេទៀត ហើយ ... ភារកិច្ចរបស់ខ្លួន ដល់ខាងដឹកនាំហ្នឹងឃើញខ្ញុំខំប្រឹងប្រែងអញ្ចឹងគេចេះតែប្រគល់ទួនាទីឲ្យ ពីភូមិមោឃុំ ពីឃុំរហូតដល់ស្រុកទៀត ហ្នឹងកាលពីជំនាន់ខ្មែរក្រហម ឆ្នាំ៧៥ ខ្ញុំត្រូវទទួលស្រុកហ្នឹង ហើយខ្ញុំនៅស្រុកព្រះនេត្រព្រះចុងក្រោយបង្អស់"]។

470 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929863 ["ចែម៖ ដល់ឆ្នាំ៧២ តាម៉ុក គាត់សុំឲ្យទៅជួបនៅតាកែវ។ ដានី៖ សុំអីឲ្យទៅជួប? ចែម៖ ចា៎!។ ដានី៖ ចុះឆ្នាំ៧១នឹង យ៉ាងម៉េចដែរ? ចែម៖ ឆ្នាំ៧១នឹង ខ្ញុំគេឲ្យធ្វើសមាគមន៍ប្រវាស់ដៃអីដឹកនាំប្រជាជននៅក្នុងភូមិនឹង ឃើញខ្ញុំចេះតស៊ូទាមទារ ដូចថាដឹងខុសដឹងត្រូវ។ ចឹងខ្ញុំចេះមានជាក្រុមសមាគមន៍ជួយគ្នា ធ្វើស្រែប្រវាស់ដៃ ចេះលើកគ្នាប្រវាស់ដៃមួយថ្ងៃៗម្នាក់ចឹងទៅ។"]។ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234190-00234191 ["រួចមកដល់ឆ្នាំ៧០ហ្នឹងដែលចេញពីព្រៃ ពួកយើងទៅនៅព្រៃហ្នឹង ចេញមករៀបចំមានភូមិមានឃុំអី គាត់ឃើញខ្ញុំនៅក្នុងហ្នឹងដែរ គាត់ឲ្យខ្ញុំធ្វើមេឃុំ។ កាលជំនាន់ណោះ ឆ្នាំ៧០ហើយ ខ្ញុំយល់ពីការប្រវាស់ដៃគ្នា ធ្វើសមាគមន៍ ហ្នឹង! ខ្ញុំចេះតែណែនាំគេធ្វើស្រែអីប្រវាស់ដៃម្តងម្នាក់ខែច្រូតខែស្ទូងហ្នឹង ហើយសមាគមន៍ចេះជួយគ្នា អញ្ចឹងប្រជាជនមើលឃើញខ្ញុំខំខ្នះខ្នែងយមចិត្តទុកដាក់អប់រំគេ ពេលបុណ្យទានអីខ្ញុំចេះតែដើរហៅដើរនាំបបួលទៅធ្វើបុណ្យធ្វើខែរដូវអីអញ្ចឹងទៅ ហ្នឹងហើយ ទៅជាប់ ដល់អញ្ចឹងគាត់ឲ្យខ្ញុំធ្វើមេឃុំ មេឃុំទងហ្នឹង។. [...] ខ្ញុំបានធ្វើមេឃុំជាងទង ឃុំខ្ញុំហ្នឹងឈ្មោះឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ខ្ញុំធ្វើបាន២ឆ្នាំ ខ្ញុំដើរចោលកូនពីរនាក់ហ្នឹងទាំងយប់ទាំងថ្ងៃ ខំដើរទៅអប់រំរៀបចំប្រធានភូមិ ក្រុម តាមភូមិ គិតទៅពីរដណ្តប់(១២) ភូមិហ្នឹង ហើយរៀបចំហើយអីហើយ ក៏ធ្វើក្នុងឃុំរបស់ខ្លួនហ្នឹងបានពីរឆ្នាំ។"]។ ឯកសារ D6.1.75 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00978475 ["ដល់អីចឹងគាត់ឲ្យខ្ញុំធ្វើមេឃុំទងហ្នឹង។ អ៉! មេឃុំនែ៎ ... មេឃុំ ចេះភ្លេចឃុំខ្លួនឯង។ [...] ខ្ញុំបានធ្វើឃុំមេឃុំជាងទង ឃុំខ្ញុំហ្នឹងឈ្មោះឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ហ្នឹង។ ខ្ញុំធ្វើបានពីរឆ្នាំ។ ខ្ញុំដើរចោលកូនពីរនាក់ហ្នឹងទាំង

យប់ទាំងថ្ងៃ ខំដើរទៅអប់រំរៀបចំប្រធានភូមិ ក្រុម តាមភូមិ គិតទៅ១២ភូមិហ្នឹង។ ហើយរៀបចំហើយអីហើយ ក៏ធ្វើក្នុងឃុំរបស់ខ្លួនហ្នឹង បានពីរឆ្នាំ បានខ្ញុំចេញមកអង្គភាព ដែលគេប្រមូលផ្តុំ"]។

471 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929769 ["ហើយខ្ញុំគេឲ្យធ្វើប្រធាន ដូចថាខ្ញុំនេះជាអ្នកស្លូតបូត ចេះអធ្យាស្រ័យមិនដែលឈ្លោះ មិនដែលប្រកែកអីមួយណា ចឹងគេឲ្យធ្វើប្រធាន [...] ប្រធានក្រុមសមាគមន៍ហ្នឹងណាហ្នឹងប្រជាជនដូចថាយើងបោះឆ្នោតឥលូវចឹង [...] ធ្វើប្រធានហ្នឹងចេះតែដឹកនាំគេម៉ាថ្ងៃម៉ានាក់ ម៉ាថ្ងៃម៉ានាក់ទល់តែហើយទៅ [...] កាន់តែរីករហូតដល់យើងធ្វើ រហូតដល់ខ្ញុំទទួលគេឲ្យប្រជាជនគាត់ឲ្យក្តាប់នៅក្នុងឃុំជាងទង"] KH 00929770 ["ខ្ញុំក៏បានទទួលភារកិច្ចមិនមែននៅក្នុងឃុំ មិនមែននៅក្នុងភូមិ រៀបចំតាមភូមិ ដើររៀបចំហ្នឹង មានប្រធានភូមិអីចឹងទៅ ចាស់ទុំ អាចារ្យវត្តអីហ្នឹងព្រោះខ្ញុំចូលចិត្ត។"]។ ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929863-00929864 ["ចែម៖ ដល់ឆ្នាំ៧២ តាម៉ុក គាត់សុំឲ្យទៅជួបនៅតាកែវ។ ដានី៖ សុំអ៊ំឲ្យទៅជួប? ចែម៖ ចា៎!។ ដានី៖ ចុះឆ្នាំ៧១នឹង យ៉ាងម៉េចដែរ? ចែម៖ ឆ្នាំ៧១នឹង ខ្ញុំគេឲ្យធ្វើសមាគមន៍ប្រវាស់ដៃអីដឹកនាំប្រជាជននៅក្នុងភូមិនឹង ឃើញខ្ញុំចេះតស៊ូ ទាមទារ ដូចថាដឹងខុសដឹងត្រូវ។ ចឹងខ្ញុំចេះមានជាក្រុមសមាគមន៍ជួយគ្នា ធ្វើស្រែប្រវាស់ដៃ ចេះលើកគ្នាប្រវាស់ដៃមួយថ្ងៃៗម្នាក់ចឹងទៅ។ ហើយដល់ចឹងចេះប្រជុំ។ ដានី៖ ចេះប្រជុំ? ចែម៖ (សើច) ចេះប្រជុំ ក៏ចាស់ៗគាត់ចូលចិត្ត ហើយដល់ពេលធ្វើបុណ្យទានអីដើររៃអង្គាស់ឲ្យគេប្រមូលគ្នាជួយដូចថាមានអង្ករ មានបន្លែ អំបិលប្រហុកអីជួយគ្នា យើងចេះសាមគ្គីគ្នា។ ដានី៖ កាលនឹងចាប់ធ្វើសមាគមន៍ប្រវាស់ដៃនឹង នៅក្នុងភូមិក្បាលអូរនឹង ហើយក៏ក្នុងឃុំជាងទងម៉ង? ចែម៖ ក្នុងភូមិក្បាលអូរមួយមុនដំបូង។ ដានី៖ មុនដំបូងភូមិក្បាលអូរ? ចែម៖ ចា៎! ដល់គេរៀបចំ៧១នេះ ចូលឆ្នាំ៧១នឹង ខ្ញុំរៀបចំឃុំជាងទងហើយ។"]។ ឯកសារ D123/2/1.28a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សៅ ពត ហៅ សៅ វន ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១ KH 00957805 [សាក្សីជាសមាជិកគណ:ឃុំកំពង់ស្វាយ៖ "ហើយយាយចែមកំណើតគាត់នៅជាងទង។ ជាងទង ប៉ុនគាត់ទៅរៀនពីគណ:កៀរគរនារីឃុំទេ មុនដំបូង"]។

472 សូមមើលឯកសារ **D1.3.20.1** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00053013 [មាត្រា ១ ក)៖)(១) "ត្រូវមានសកម្មភាព ប្រយុទ្ធល្អ និងជាប់ជានិច្ច តាមការសាកល្បង ក្នុងការងារបដិវត្ត ជាបន្តបន្ទាប់ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្ត តាមមាគ៌ានយោបាយរបស់បក្ស តាមជំហរសតិអារម្មណ៍របស់បក្ស និងតាមមាគ៌ាចាត់តាំងរបស់បក្ស។"]។

473 សូមមើលឯកសារ **D1.3.20.1** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH00053017 [មាត្រា ២ ក)៖)(១) "ភារកិច្ចក្នុងមហាជន គឺ៖ ឃោសនាអប់រំមហាជន អំពីនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ហើយប្រឡូកជាប់ស្និទ្ធនឹងមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្ត ត្រូវទទួលខុសត្រូវខ្ពស់ ចំពោះមហាជន បំរើមហាជន អស់ពីចិត្តពីថ្លើម និងគ្មានលក្ខខណ្ឌ រាបសារនឹងមហាជន ហើយខិតខំរៀនសូត្រពីមហាជន។"]។

474 សូមមើលឯកសារ **D1.3.20.1** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00053017 [មាត្រា ២ ខ)៖)(១) "ភារកិច្ចក្នុងមហាជន គឺ៖ បំផុសបំផុលចលនាមហាជន ពិសេស មហាជនកម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្ត ឲ្យក្តៅគគុក និងជាប់ជានិច្ច ក្នុងភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជា ប្រជាធិបតេយ្យ តាមទិសនៃបដិវត្តសង្គមនិយម។"]។

475 សូមមើលឯកសារ **D1.3.20.1** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00053017 [មាត្រា ២ខ)៖)(២) "ភារកិច្ចផ្ទៃក្នុង គឺ៖ គោរពអង្គការវិន័យរបស់បក្ស ដោយគ្មានលក្ខខណ្ឌ និងដោយភ្ជាក់រលឹកខ្ពស់។"]។

476 សូមមើលឯកសារ D1.3.20.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00053017 [មាត្រា ២(២)(ឃ)៖ "ភារកិច្ចផ្ទៃក្នុង គឺ៖ ខិតខំថែរក្សា ពង្រឹង ពង្រីកសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្ស ឲ្យបានល្អជាប់ជានិច្ច ដាច់ខាត។"] មាត្រា ២ (២)(ង)៖ "ភារកិច្ចផ្ទៃក្នុង គឺ៖ ខិតខំរក្សាការសម្ងាត់របស់បក្សដាច់ខាត ដោយមានគោលជំហរប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ច។"]។

477 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929864-00929865 ["ចែម៖ ហើយក៏មានកើតជាអង្គការ ឲ្យខ្ញុំទៅនៅអង្គភាព ដឹកនាំនារី។ ដានី៖ ចឹងដល់ពេលឆ្នាំ៧០ប៉ុន្មានដែលអ៊ំទៅកន្លែងអង្គការដឹកនាំអង្គភាពនារី? ចែម៖ ៧២។ ដានី៖ នារីនឹងនៅណាទៅ? ចែម៖ នារី មុនដំបូងនារីកាត់ដេរ ដល់ក្រោយមកបានចូលអង្គភាពនារី ដែលមាននារីគេជម្លៀសពីមុនមកយកមកទុកក្រោយ ខ្ញុំទៅអប់រំៗ មានចេះនិយាយអី ចេះនិយាយតែរឿងសាមគ្គីគ្នា កុំបែកបាក់ កុំឈ្លោះគ្នា ដូចយើងអប់រំកូនចឹង។ ដានី៖ ប៉ុន្តែនៅកន្លែងណានៅអង្គភាពនឹង? ចែម៖ នៅភ្នំដំរីរមាល។ ដានី៖ នៅលើភ្នំនឹងម៉ង? ចែម៖ នៅជើងភ្នំ។ ដានី៖ នារីច្រើនកាលនឹង? ចែម៖ នារីម្តងមាន៤០០នាក់គ្រាន់អប់រំគេឲ្យល្អកុំឲ្យគេរត់គេអី។ ហើយខាងយុវជនអប់រំយុវជន នារីអប់រំនារី។ ហើយមែន អត់មានអ្នកខូចអ្នកខ្ជិលទាក់ទងអត់រលើង។ ដានី៖ នារី៣០០-៤០០នាក់នឹង មកពីដូចថាយើងប្រមូលគាត់មកពីភូមិតាមភូមិតាមស្រុក? ចែម៖ ទ័ពវ៉ៃចូលភូមិចឹងទៅ ម៉ែឪគាត់នៅតាមភូមិនឹង គាត់ចេះប្រគល់កូននឹងឲ្យមកៗឃើញទ័ពយើងស្រឡាញ់ ឃើញកូនទុកដូចកូនគាត់ចឹង។ ចឹងគាត់មានកូនស្រីកូនប្រុសអីគាត់ចេះប្រគល់ឲ្យមកតាមនឹងមក យកមកឲ្យអ្នកក្រោយ។ ដានី៖ បាទ! មកឲ្យយើងអ្នកណែនាំ? ចែម៖ ចា៎!"]។ ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929770-00929771 ["ចែម៖ ដល់ឆ្នាំ៧៣-៧៤មកខ្ញុំឈប់ធ្វើមេឃុំហើយ ខ្ញុំទៅនៅទទួលខាងយុវនារីដែលជម្លៀសមកពីឃុំគ្រប់ស្រុកមកណា មកប្រមូលផ្តុំ។ [...] នារីប្រមូលផ្តុំនារីនៅលីវៗ គេយកទៅដូចថាទ័ពទៅសមរភូមិចឹងទៅ បានមកយកហ្នឹង យកប្រគល់ឲ្យយើងដឹកនាំដោះស្រាយ ហូបចុកស៊ី។ ដានី៖ ហ្នឹងនារីម៉ាទូទាំង? ចែម៖ ម៉ាខេត្តតាកែវ។"]។ ឯកសារ D123/2/2.17a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ងឹម ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១១ KH 00733811 [សាក្សីជាកម្មាភិបាលខ្មែរក្រហមនៅព្រៃដំរីរមាល៖ "ស្គាល់គាត់យូរហើយ តាំងចំបក់ធ្វើសង្គ្រាមជាមួយគ្នានឹង តស៊ូ។ [...] គាត់ធ្វើប្រធានមន្ទីរ ប្រធានអីដែរនឹង [នៅព្រៃដំរីរមាល]"]។

478 ឯកសារ **D119/84** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មឹង វេត ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ29. KH 00975694-00975695 [សាក្សីធ្វើការនៅមន្ទីរ១៦០ ក្នុងតំបន់១៣៖ "យាយ ចែម ទទួលខុសត្រូវរៀបចំការអប់រំ នយោបាយ និងការបង្កបង្កើនផល"]។

479 ឯកសារ **D123/1/5.1b** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929771 ["ខ្ញុំអប់រំថា ឲ្យនារីហ្នឹងការពារសីលធម៌របស់ខ្លួនមិនភ្លើតភ្លើន ហើយដើររហេតរហូតអីអស់ទេ ព្រោះឪពុកម្តាយគេសង្ឃឹមយើងណា ថាយើងហ្នឹងការពារកូនចៅរបស់គាត់បាន ចឹងគាត់ចេះតែឲ្យមក ដល់ចឹងខ្ញុំអប់រំតាមហ្នឹង ហើយអ្នកណាដូចថាមានការស្រឡាញ់ទាក់ទងគ្នា ក៏រៀបចំទៅ"]។

480 ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.45 KH 00997028 [សាក្សីគឺជាអនុលេខា បន្ទាប់មកក្លាយជាលេខាស្រុកត្រាំកក់ (ស្រុក១០៥)៖ "មានការប្រកាសនៅក្នុងវគ្គសន្និបាតរៀនសូត្រក្នុងឆ្នាំ ១៩៧២ ឲ្យគាត់ [អ៊ឹម ចែម] ធ្វើជានារីតំបន់ ហើយគាត់ធ្វើជានារីតំបន់រហូតដល់ឆ្នាំ ១៩៧៥"] KH 00997028 ["អ្នកខ្លះគេនិយាយថា ចែម ជាគណៈតំបន់ទទួលខុសត្រូវខាងនារីផងដែរ ព្រោះគាត់តែងតែចុះទៅធ្វើការតាមស្រុកទាំងអស់ក្នុងតំបន់ ១៣។ [...] គណៈតំបន់ ឈ្មោះ សោម មុត និង ផែន។ យាយចែម គាត់ធ្វើការងារខាងនារីក្នុងតំបន់ ១៣"]។ ឯកសារ D118/79 កំណត់ហេតុស្តាប់ចម្លើយរបស់ ពេជ្រ ជឹម ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.6 KH 00934400 [សាក្សីគឺជាអនុលេខា បន្ទាប់មកក្លាយជាលេខាស្រុកត្រាំកក់ (ស្រុក ១០៥)៖ "នៅកាន់ខាងគណៈគៀងគរនារីរបស់តំបន់១៣ [...]"]។ ឯកសារ D119/15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ វ៉ន ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឆ.12 KH 00893277 [សាក្សីគឺជាប្រធានឃុំកំពង់ស្វាយ និងបានជួប អ៊ឹម ចែម នៅវគ្គសិក្សារៀនសូត្រមួយចន្លោះឆ្នាំ ១៩៧០ និងឆ្នាំ ១៩៧៥៖ "ខ្ញុំគ្រាន់តែដឹងថា ពីចន្លោះឆ្នាំ ១៩៧០ ដល់ ៧៥ [អ៊ឹម ចែម] ជាគណៈអប់រំនារី ប្រចាំតំបន់ ១៣។ ពីព្រោះនៅចុងឆ្នាំ ១៩៧៣ ឬ១៩៧៤ មានពិធីសន្និបាតមួយដែលគេធ្វើឡើងនៅតំបន់១៣"]។ ឯកសារ D118/274 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.28 KH 00999991 [សាក្សីជាសមាជិកឃុំសន្លុង ក្រោយមកក្លាយជាអនុប្រធានឃុំប្រាំបីមុំក្នុងតំបន់១៣៖ "យាយចែម គឺជាប្រធានសមាគមន៍នារីរបស់តំបន់ ១៣"]។ ឯកសារ D119/149 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤ ឆ.32 KH 01022478 [សាក្សីជាសមាជិកឃុំសន្លុង ក្រោយមកក្លាយជាអនុប្រធានឃុំប្រាំបីមុំក្នុងតំបន់១៣៖ "ខ្ញុំធ្លាប់បានឮគេនិយាយអំពីប្រវត្តិរបស់ យាយចែម ថាគាត់ជាប្រធានសមាគមនារីថ្នាក់តំបន់ ហើយខ្ញុំធ្លាប់ឃើញគាត់ ចូលរួមប្រជុំនៅស្រុកអង្គរជ័យផងដែរ"]។ ឯកសារ D118/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល ញ៉ន ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.29 KH 00920164 [សាក្សីគឺជាទាហានតំបន់១៣ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧៖ "ជាប្រធាននារីរបស់ស្រុកត្រាំកក់"]។ ឯកសារ D119/83 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.17 KH 00975684 [សាក្សីកើតនៅភូមិក្បាលអូរ ចម្ងាយ ៥០ ម ពីផ្ទះ អ៊ឹម ចែម និងបានធ្វើការនៅមន្ទីរ១៦០ ក្នុងតំបន់១៣៖ "ស៖ នៅក្នុងប្រតិចារឹកបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាភាសាអង់គ្លេស ទំព័រទី៨ លោកនិយាយថា "យាយចែម គឺទទួលខុសត្រូវខាងកងនារីតំបន់១៣ ហើយគាត់នៅស្រុកអង្គរជ័យ" តើត្រឹមត្រូវដែរឬទេ? ឆ.17៖ បាទ ត្រឹមត្រូវហើយ"] ឆ. 18-19 KH 00975684 ["យាយចែមគឺជាអនុម្នាក់នៅក្នុងគណៈតំបន់១៣ ទទួលខុសត្រូវនារីនៅក្នុងតំបន់។ យើងអាចនិយាយបានថា គាត់ជាសមាជិកម្នាក់របស់អចិន្ត្រៃយ៍តំបន់១៣ [...]។ ក្នុងឆ្នាំ ១៩៧៥ នៅពេលដែលគេរៀបចំមន្ទីររបស់តំបន់ ខ្ញុំត្រូវបានគេចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរ ១៦០ នៅពេលនោះដែលខ្ញុំដឹងថា យាយចែម គាត់ទទួលខុសត្រូវអង្គភាពនារីតំបន់ ១៣"]។ ឯកសារ D219/522 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន គឹមសេង ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.100 KH 01149854 [សាក្សីគឺជាអ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ក្នុងតំបន់១៣៖ "ចាស កាន់ខាងនារី ហើយប្តីកាន់ខាងបុរស"]។ ឯកសារ D118/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម បឿន ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឆ. 75-76 KH 00998732 [សាក្សីជាមេឃុំជាងទង ស្រុកត្រាំកក់៖ "យាយចែម គាត់ជាអ្នកគ្រប់គ្រងនារីតំបន់១៣។ យាយចែម ធ្លាប់ឡើងនិយាយនៅក្នុងការប្រជុំនៅមន្ទីរតំបន់១៣នេះ ហើយគាត់បានប្រកាសអំពីតួនាទីរបស់គាត់នៅពេលនោះ។ ស៖

ដោយសារ យាយចែម ធ្វើការនៅក្នុងថ្នាក់តំបន់១៣ ដូច្នេះគាត់អាចនិយាយនៅក្នុងកិច្ចប្រជុំនោះបាន។ តើត្រឹមត្រូវដែរឬទេ? ឆ.76៖ ចាស"] ឆ.77 KH 00998732 ["គាត់ធ្វើការនៅថ្នាក់តំបន់ពីឆ្នាំ១៩៧៣ ហើយប្រហែលជារហូតដល់ឆ្នាំ១៩៧៦ ឬក៏ ១៩៧៧"] ឆ.79 KH 00998733 ["ខ្ញុំដឹងថា អ៊ឹម ចែម ធ្លាប់ធ្វើជាអ្នកគ្រប់គ្រងនារីនៅក្នុងភូមិ រួចហើយគាត់ឡើងទៅតំបន់តែម្តង ដោយសារគាត់ធ្វើបានល្អ"] ឆ.105 KH 00998737 ["អ៊ឹម ចែម គាត់នៅថ្នាក់នារីតំបន់ គឺខ្ពស់ជាងគេហើយ"] ឆ. 108-110 KH 00998737 ["ខ្ញុំបានឃើញគាត់នៅមន្ទីរតំបន់ ហើយពេលដែលខ្ញុំទៅចម្ការរបស់ខ្ញុំ ខ្ញុំបានឃើញគាត់មន្ទីររបស់គាត់ដែលគ្រប់គ្រងខាងនារី ដោយគេហៅថា នារីតំបន់។ មន្ទីរនារីស្ថិតនៅជិតភ្នំជីរមៀល។ ចំណែកមន្ទីរតំបន់១៣ មុនពេលរំដោះក៏នៅជិតភ្នំនេះដែរ ក្រោយរំដោះឆ្នាំ១៩៧៥ ហើយទើបគេយកទៅដាក់នៅទីរួមខេត្តតាកែវ [...]។ ចាស [អ៊ឹម ចែម] គ្រប់គ្រងកម្មាភិបាលនារីទាំងអស់នៅក្នុងតំបន់ [...]។ ចាស ក្រោយខ្មែរក្រហមទទួលជ័យជម្នះ"]។ ឯកសារ D219/521 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តឹប ភី ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.63 KH 01149836 [សាក្សីគឺជាប្រធានកងនារីនៅស្រុកគិរីវង់ តំបន់១៣៖ "គាត់កាន់កងនារីថ្នាក់តំបន់ ក្នុងតំបន់១៣"]។ ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឆ.143 KH 01095257 [សាក្សីជាទាហាននៅតំបន់១៣ ដែលបានផ្លាស់ទៅភូមិភាគពាយ័ព្យនៅឆ្នាំ១៩៧៨ និងក្លាយជាប្រធានស្រុកបវេល៖ "យាយចែម មានតួនាទី ២។ គាត់ជាគណៈតំបន់១៣ ជាមួយ តាសោម ផង ហើយគាត់ជាគណៈនារីដឹកនាំតំបន់១៣ ផង"]។

481 ឯកសារ D119/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មឹង វេត ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.30 KH 00975695 [សាក្សីកើតនៅភូមិក្បាលអូរ ចម្ងាយ ៥០ ម ពីផ្ទះ អ៊ឹម ចែម និងបានធ្វើការនៅមន្ទីរ ១៦០ ក្នុងតំបន់១៣៖ "មានចំនួនរាប់ពាន់នាក់ ពីព្រោះពួកគេមកពីស្រុកទាំង៥ នៅក្នុងតំបន់១៣។ ពួកនារីទាំងអស់នេះត្រូវបានអប់រំនៅក្នុងដំណាក់កាលបី"]។

482 ឯកសារ D118/274 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.23 KH 0999990 [សាក្សីជាសមាជិកឃុំសន្លុង ក្រោយមកក្លាយជាអនុប្រធានឃុំប្រាំបីមុំក្នុងតំបន់១៣៖ "មាន៥ស្រុក គឺស្រុក១០៩ (ស្រុកគិរីវង់) ស្រុក១០៨ (ស្រុកកោះអណ្តែត) ស្រុក១០៧ (ស្រុកទ្រាំង) ស្រុក១០៦ (ស្រុកអង្គរជ័យ) និងស្រុក១០៥ (ស្រុកត្រាំកក់) នៅក្នុងតំបន់១៣"]។ សូមមើលផងដែរ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234191 ["ខ្ញុំបានធ្វើជាមេឃុំជាងទង [...] ស្រុកត្រាំកក់ ខេត្តតាកែវ"]។ ឯកសារ D123/2/1.28a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សៅ ពត ហៅ សៅ វន ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១១ KH 00957805 [សាក្សីគឺជាសមាជិកគណៈឃុំកំពង់ស្វាយ៖ "ឃុំជាងទងនឹង ដល់ហើយទៅបានខាងតំបន់នឹងហៅគាត់ទៅ ដល់ក្រោយមកចាត់តាំងគាត់ទៅខាងស្រុកណា ស្រុក១០៦"]។

483 ឯកសារ D119/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មឹង វេត ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.29 KH 00975694 [សាក្សីកើតនៅភូមិក្បាលអូរ ចម្ងាយ ៥០ ម. ពីផ្ទះ អ៊ឹម ចែម និងបានធ្វើការនៅមន្ទីរ១៦០ ក្នុងតំបន់១៣៖ "ពួកនារីតំបន់នៅក្រោមការក្តោបក្តាប់របស់ យាយចែម ត្រូវបានចាត់តាំងឱ្យកាន់មុខតំណែងទៅតាមមូលដ្ឋានថ្នាក់សហករណ៍ ភូមិ ឃុំ ស្រុក និងកងចល័តនារី"]។

484 ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឆ.144 KH 01095257 [សាក្សីជាទាហាននៅតំបន់១៣ ដែលបានផ្លាស់ទៅភូមិភាគពាយ័ព្យនៅឆ្នាំ១៩៧៨៖ "អំណាចហ្នឹងគឺមានខាងធ្វើចលនានារីឲ្យចូលធ្វើបដិវត្ត។ យាយចែម ជាអ្នកកៀងគរកម្លាំងនារីឲ្យប្រឆាំងនឹងទាហាន លន់ នល់ កាលជំនាន់សង្គ្រាម"]។

485 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929750 ["ដារ៉ា៖ ពេលខ្មែរក្រហមវាយបានភ្នំពេញ? ចែម៖ ចា៎! ដារី៖ ឆ្នាំ៧៥ណាអ៊ំ? ចែម៖ ចា៎! ដារ៉ា៖ ពេលហ្នឹងអ៊ំកំពុងធ្វើអី? ចែម៖ ខ្ញុំមានផែនការមួយ ព្រោះអីពេលដែលវាយបែកហ្នឹងមានជម្លៀសនារីមកចឹង ខ្ញុំទទួលខាងនារី"]។ ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01106996-01106997 ["អ៊ឹម ចែម៖ ឆ្នាំ៧៥ ដែលរំដោះទូទាំងប្រទេសហ្នឹង ខ្ញុំធ្វើនៅក្នុងមូលដ្ឋានឃុំ [...]។ ឲ្យធ្វើនៅក្តាប់ប្រជាជននៅខាងក្រោយ ចាស [...]។ ស.៖ ធ្វើពេលអ្នកកុងត្រូលលើអ្នកមូលដ្ឋាន អ្នកមាន អ្នក១៧មេសា អ្នកប្រជាជនថ្មីចូល? អ៊ឹម ចែម៖ ចម្រុះ។ ស.៖ អ៊ីចឹងប្រជាជនថ្មីមកពីណាទៅ? អ៊ឹម ចែម៖ ប្រជាជនគេជម្លៀសចេញពីតាមក្រុងខេត្ត យកទៅដាក់នៅតាកែវ"] KH 01107002 ["ធ្វើត្រឹមតែត្រួតមើលប្រជាជន"]។ សូមមើលផងដែរ D5/1026 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុក សារុធ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ KH 00991134 [សាក្សីត្រូវគេជម្លៀសទៅរស់នៅតំបន់១៣៖ "១៩៧៥ បែកភ្នំពេញ ពួកនោះបណ្តេញឲ្យមករស់នៅភូមិដើមដូង ឃុំម្រោម ស្រុក១០៦ តំបន់១៣ មានតាម៉ុកប្រធានភូមិភាគនិរតី យាម អ៊ឹម ចែម គណៈតំបន់"]។

486 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ EN 00929750-00929751 ["ដារ៉ា៖ ពេលដែលវាយបែកភ្នំពេញមានផែនការជម្លៀសនារី? ចែម៖ ចា៎! [...] ដារ៉ា៖ កាលហ្នឹងមានផែនការជម្លៀសចឹងហ្នងឬយ៉ាងម៉េច? ចែម៖ ជម្លៀសទ័ពគេវាយបានក៏បងប្អូនប្រជាជននៅកន្លែងហ្នឹងយក យកមកខ្ញុំគ្រាន់តែទទួលគាត់ឲ្យរស់នៅ ដូចថាឥឡូវមកដាក់ភូមិហ្នឹងចឹងគេយកមកប្រគល់ឲ្យខ្ញុំចឹង ខ្ញុំឲ្យគាត់មានកន្លែងរស់នៅស្រួលបួល ប៉ុណ្ណឹង"]។

487 ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.42 KH 00997028 [សាក្សីគឺជាអនុលេខា បន្ទាប់មកក្លាយជាលេខាស្រុកត្រាំកក់ (ស្រុក១០៥)៖ "យាយចែម គឺគ្រប់គ្រង អប់រំនារីក្នុងតំបន់។ ពេលដែលស្រុក ឃុំ ភូមិ មានប្រជុំ យាយចែម ចុះទៅបង្រៀន និងអប់រំនៅទីនោះ។ ចំពោះអ្នកល្អ (ប្រវត្តិល្អ)គឺយាយចែម ជាអ្នកជ្រើសរើសថាជា កម្លាំងទី១ ដោយឲ្យធ្វើការនៅក្នុងខ្សែបក្ស។ ចំពោះអ្នកដែលមានប្រវត្តិមិនសូវល្អ ឬខ្វះខាត គឺអប់រំបន្ថែម"]។

488 ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.42 KH 00997028 [សាក្សីគឺជាអនុលេខា បន្ទាប់មកក្លាយជាលេខាស្រុកត្រាំកក់ (ស្រុក១០៥)៖ "យាយចែម គឺគ្រប់គ្រង អប់រំនារីក្នុងតំបន់។ ពេលដែលស្រុក ឃុំ ភូមិ មានប្រជុំ យាយចែម ចុះទៅបង្រៀន និងអប់រំនៅទីនោះ។ ចំពោះអ្នកល្អ (ប្រវត្តិល្អ)គឺយាយចែម ជាអ្នកជ្រើសរើសថាជា កម្លាំងទី១ ដោយឲ្យធ្វើការនៅក្នុងខ្សែបក្ស។ ចំពោះអ្នកដែលមានប្រវត្តិមិនសូវល្អ ឬខ្វះខាត គឺអប់រំបន្ថែម"]។

489 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929868 ["ដានី៖ អ៊ំដូចថា ដូចជាមុននឹងយើងទៅនឹង ដូចអ៊ុំទៅមកអង្គរជ័យនឹង អ៊ំមកខ្លួនឯង ឬក៏ តា ម៉ុក គាត់អ្នក

រៀបចំចាត់ចែងឲ្យយើងមក? ចែម៖ គាត់ឲ្យខ្ញុំទៅទទួលជួយមើលប្រជាជននៅស្រុកនឹង។ ដានី៖ កាលនឹងយើងទៅក្រុមត្រៀម ប៉ុន្មាននាក់ទៅ យើងទៅមើលប្រជាជននឹង? ចែម៖ តែខ្ញុំទៅជួយរៀបចំអ្នកស្រុកនឹងម៉ង។ ដានី៖ តែអ៊ំម្នាក់ទេ? ចែម៖ ចា៎! [...] ដានី៖ (ភ្លៀងធ្លាក់ខ្លាំង) ចុះអ៊ំមិញមកកន្លែងកោះអណ្ដែត ដែលយើងចាប់ធ្វើស្រូវធ្វើស្រែ កាលនឹងអ៊ំមានប្រសាសន៍ថា បាន៣តានក្នុងមួយហិចតា ចឹងស្រូវល្អយើងធ្វើបាន៣តោន? ចែម៖ ហ្នឹងក្នុងស្រុកអង្គរជ័យ កែប្រែបានមែន ព្រោះអីយើងដាក់ជីច្រើនណាស់"]។

490 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929871 ["[ហើយចែកកម្លាំង (នៅអង្គរជ័យ) គ្នាធ្វើចំការ។ កម្លាំងម៉ាផ្នែកគាត់ចាស់ៗហើយ ឲ្យគាត់ដាំដំណាំខ្លះ វេញខ្សែពួរខ្លះអីទៅ តាមការងារ"]។

491 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929871 ["ដានី៖ កាលនៅអង្គរជ័យ ដូចថាប្រជាជនដូចថា យើងដាក់ផែនការឲ្យគាត់ធ្វើការចាប់ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ពីសម្រាកប៉ុន្មានម៉ោង ហើយម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន ហើយគាត់ធ្វើការក្រៅពីការធ្វើស្រែធ្វើចំការ គាត់ធ្វើការងារអីទៀត? ចែម៖ ដាក់ ព្រោះអីផែនការ គេកំណត់ថា ក្នុងមួយថ្ងៃធ្វើពីម៉ោង៧ចុះ ដល់ម៉ោង ១១ ឡើង ខ្ញុំដាក់ផែនការធ្វើតាមផ្ទះនឹង ពីម៉ោង ១២ ទៅម៉ោង១ ២ ម៉ោង"]។

492 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929867 ["ដានី៖ ចុះដល់ពេលមកអង្គរជ័យ មានជួបឧបស័គ្គ មានពិបាកអីយ៉ាងម៉េចដែរ កាលនឹងមកនៅអង្គរជ័យ? ចែម៖ មកអង្គរជ័យមានការលំបាក ហើយនឹងស្រួលនឹង បើយើងមានកម្លាំង ប្រជាជនគាំទ្រច្រើន ចឹងទៅម៉ាស្រួល។ ប៉ុន្តែពេលដែលថាលំបាក ក៏ប្រជាជនគាត់ខ្វះខាត ហើយយើងដោះស្រាយឲ្យគាត់ធ្វើចំការ ធ្វើស្រែធ្វើជី ចេះតែឲ្យធ្វើហើយ អត់មានជី ប្រើជីគីមីដូចយើងឥឡូវអី ប្រើជីលេខ១-២ ជីកំប៉ុស។ ធ្វើអូ! ខ្ញុំធ្វើបានថា ស្រូវម៉ាហិចតា៣តោននោះ គឺ៣តោនមែន"] KH 00929869 ["ដានី៖ ចឹងកាលនឹងគេមានផែនកាលថា យើងធ្វើស្រែធ្វើម៉េចឲ្យបានទិន្នផលមួយហិចតាឲ្យបាន៣តោន មានផែនការនៅកាលជំនាន់៧៥? ចែម៖ មែនហើយ។ ដានី៖ មានហើយ? ចែម៖ ចា៎! ៧៤ ៧៥ មានហើយ។ ដានី៖ មានចេញពីខាងណាដែរ ផែនការមួយហិចតាឲ្យបាន៣តោន? ចែម៖ ចេញពី តា ប៉ុល ពត។ [...] ពីលើ មកគ្រាន់ដាក់ផែនការឲ្យ ថា ឥឡូវឆ្នាំនេះ ធ្វើម៉េចឲ្យបានជី ឲ្យយើងឆ្លើយ បានជីក្នុងស្រុកមួយប៉ុន្មានតោន ប៉ុន្មានរយតោន ហើយធ្វើស្រែនឹង គេមើលតាមដីដែលយើងធ្វើជីឲ្យដូចថា មានដីប៉ុន្មានរយហិចតា ហើយក្នុងមួយហិចតា ដាក់ជីប៉ុន្មានតោន ជីលេខ ១-២ គិតតាមនឹង។ ហើយខ្ញុំៗ ធ្វើបាន"]។

493 ឯកសារ D119/13 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជៀម ជ្រៀវ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឆ.17-18 KH 00893265 [សាក្សីធ្វើការនៅក្នុងកងផលិតនៃស្រុកអង្គរជ័យ៖ "យាយ ចែម ខ្ញុំធ្លាប់បានឃើញគាត់ម្ដងម្កាលដែរ នៅពេលដែលគាត់ចុះមកមើលកងផលិតរបស់ខ្ញុំ [ស្រុកអង្គរជ័យ] កំពុងធ្វើស្រែ។ [...] ពួកគាត់ចុះមកមើលកងផលិតប្រហែលជាក្នុងឆ្នាំ ១៩៧៦។ ក្រោយមកទៀត ខ្ញុំមិនបានដឹងថា មានគណៈស្រុកថ្មីណាម្នាក់មកជំនួសតួនាទីរបស់ តា ញែន នោះទេ"]។

494 ឯកសារ D119/84 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.1 KH 00975688 [សាក្សីធ្វើការនៅមន្ទីរ ១៦០ ក្នុងតំបន់ ១៣៖ "សៈ កាលពីម្សិលមិញលោកបាននិយាយថា នៅក្នុងឆ្នាំ ១៩៧៥ គេបានរៀបចំ

មន្ទីរផ្សេងៗរបស់តំបន់ ១៣។ ពេលនោះ លោកត្រូវបានចាត់តាំងឱ្យទៅនៅមន្ទីរ១៦០ ហើយយាយ ចែម ទទួលខុសត្រូវអង្គភាពនារី តំបន់ ១៣ ហើយប្តីរបស់គាត់ឈ្មោះ ញ៉ែន។ តើពេលនោះ ញ៉ែន មានមុខងារជាអ្វី? ឆ.1៖ ពេលនោះ ញ៉ែន ជាលេខាស្រុកអង្គរជ័យ"]។ ឯកសារ D118/274 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ត្រង់ ឆ.45 KH 00999993 [សាក្សីគឺជាសមាជិកឃុំសន្លង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់ ១៣៖ "កាលនោះ តា ញ៉ែន គណៈស្រុក ១០៦ និងជាប្តីរបស់យាយ ចែម បានកោះហៅពួកខ្ញុំឱ្យទៅប្រជុំលាគ្នាជាមួយគាត់"] ឆ.90-92 KH 00999999 ["បាទ គាត់ [តា ញ៉ែន] ជាប្តីរបស់យាយ ចែម។ [...] តា ញ៉ែន ជំនួសគាត់ [លេខាស្រុក១០៦ចាស់] ជាលេខាស្រុក១០៦។"]។ ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.40 KH 00997028 [សាក្សីពគឺជាអនុលេខា ហើយបន្ទាប់មកជាលេខាស្រុកត្រាំកក់ (ស្រុក១០៥)៖ "លេខាស្រុក [អង្គរជ័យ] ឈ្មោះ ញ៉ែន"]។ ឯកសារ D119/13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដៀម ជ្រៀវ ឆ.4 KH 00893264 [សាក្សីធ្វើការនៅក្នុងកងផលិតនៃស្រុកអង្គរជ័យ៖ "តា ញេន ជាគណៈស្រុក១០៦។"]។ ឆ.5-8 KH 00893264 ["ខ្ញុំគ្រាន់តែដឹងថា គាត់ជាមនុស្សម្នាក់មកពីស្រុក ១០៥ (ស្រុកត្រាំកក់)។ ស៖ តើនៅពេលនោះ តា ញេន មានប្រពន្ធហើយឬនៅ? ឆ.6៖ គាត់មានប្រពន្ធហើយ។ ខ្ញុំដឹងទៀតថា ប្រពន្ធ តា ញេន ឈ្មោះ យាយ ចែម [...] ឆ.8៖ បាទ ខ្ញុំស្គាល់តែ តា ញេន ម្នាក់គត់។ ប៉ុន្តែនៅក្នុងគណៈស្រុកអង្គរជ័យមានមនុស្សបីនាក់។ ទី១ តា ញេន ជាគណៈស្រុក ទី២ ជាអនុគណៈស្រុក ទី៣ ជាសមាជិកគណៈស្រុក"]។ ឯកសារ D219/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.11 KH 01032102 [សាក្សីជាប្រធានភូមិនៅក្នុងភូមិភាគនិរតី ហើយត្រូវបានបញ្ជូនទៅស្រុកស៊ីសុផុនក្នុងអំឡុងពេលបោសសម្អាត៖ "តា និន គឺជាគណៈស្រុកអង្គរជ័យពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៣។ ក្រោយពេល តា និន ត្រូវបានគេចាប់ខ្លួននៅក្នុងឆ្នាំ ១៩៧៣ ពេលនោះ តា ញ៉ែន បានឡើងជំនួសតួនាទីរបស់គាត់"]។ ឆ.16 KH 01032102 [យាយ ចែម គឺជាប្រពន្ធរបស់ តា ញ៉ែន"]។ ឯកសារ D119/15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ វ៉ន ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឆ.12 KH 00893277 [សាក្សីគឺជាសមាជិកនៃគណៈឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ៖ "ប្តីរបស់គាត់ឈ្មោះ ញេន ជាគណៈស្រុក១០៦ ដែលបច្ចុប្បន្នជាស្រុកអង្គរជ័យ"]។ ឯកសារ D119/11 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផៃ អឿក ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឆ.5 KH 00893255 [សាក្សីធ្វើការនៅខាងសេដ្ឋកិច្ចស្រុកកៀនស្វាយ ក្នុងកងដឹកជញ្ជូន៖ "ខ្ញុំធ្លាប់ដឹកទៅស្រុកចំនួនពីរ គឺស្រុកអង្គរជ័យ និងស្រុកត្រាំកក់។ [...] នៅស្រុកអង្គរជ័យ ខ្ញុំបានប្រគល់លិខិតឱ្យទៅគណៈស្រុកឈ្មោះ ញេន ដែលមានប្រពន្ធឈ្មោះ ចែម"]។ ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929873 [បានបញ្ជាក់ថា ប្តីរបស់គាត់បានស្នាក់នៅអង្គរជ័យដើម្បីជួយរៀបចំស្រុកនេះ ហើយក្រោយមកត្រូវបានចាត់ឱ្យទៅទីរួមខេត្តតាកែវ]។

495 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929872 ["ដានី៖ ចុះអ៊ំ ខ្ញុំបន្តពីមុនបន្តិច ពីចប់អង្គរជ័យមកៗកោះអណ្តែត អ៊ំមកឆ្នាំណា? ចែម៖ ខ្ញុំមកឆ្នាំ ៧៦។ ដានី៖ ៧៦? ចែម៖ ចា៎! ដានី៖ ចុះកាលនឹងម៉េចបានគេ ដូចថាខាងលើគេចាត់ឱ្យអ៊ំ ឱ្យមកពីអង្គរជ័យមកកោះអណ្តែតវិញ? ចែម៖ ខ្ញុំធ្វើអីក៏សម្រេចតាមផែនការ។ ដានី៖ អូ! ធ្វើបានសម្រេច? ចែម៖ នឹង។ ដានី៖ ចឹងពីណាគេអ្នកចាត់អ៊ំឱ្យមកពីអង្គរជ័យមក? ចែម៖ តា ម៉ុក និងតា ប៉ុល ពត។ ដានី៖ តា ម៉ុក ហើយ តា ប៉ុល ពត? ចែម៖ ចា+! ដានី៖ ហើយកាលនឹងនៅកោះអណ្តែត

យ៉ាងម៉េច បានគេចាត់អ៊ំឲ្យមកកោះអណ្ដែតវិញ ហើយអ្នកគ្រប់គ្រងកោះអណ្ដែតពីមុនយ៉ាងម៉េច បានដក? ចែម៖ អ្នកគ្រប់គ្រងខាងកោះអណ្ដែតនឹងវាទំនាស់គ្នាផង ហើយធ្វើការងារអត់ឯកភាពគ្នា។ ដល់ខ្ញុំទៅនៅទៅ ដកប្រធាននឹងទៅគីរីវង់"]។

496 ឯកសារ D119/82 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នាង អ៊ូច ហៅ សាន ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ឆ.41 KH 00971372 [សាក្សីគឺជាជំនួយការរបស់ អ៊ឹម ចែម នៅគណៈស្រុកកោះអណ្ដែត ហើយក្រោយមក ជាលេខាស្រុកត្រាំកក់៖ "ឈ្មោះ សាន ជាឈ្មោះរបស់ខ្ញុំ ហើយខ្ញុំជាប្អូនថ្លៃរបស់ តា ម៉ុក។ យាយ ចែម គាត់មកពីសមាគមនារីតំបន់ ១៣ [ទៅធ្វើជាគណៈស្រុកកោះអណ្ដែត]"]។ ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929748 ["អ៊ំនៅតាកែវធ្វើអីមុនឆ្នាំ ៧៧ ខែ ធ្នូ ហ្នឹង? ចែម៖ នៅតាកែវហ្នឹង? ដារ៉ា៖ បាទ! ចែម៖ ខ្ញុំធ្វើការងារស្រុកនៅស្រុកកោះអណ្ដែត "] KH 00929750 ["ដារ៉ា៖ ឆ្នាំណាដែលអ៊ំទទួលស្រុកកោះអណ្ដែត? ចែម៖ ឆ្នាំ ៧៦"]។

497 សូមមើល ឯកសារ D6.1.960 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442264 [មាត្រា ៥(១)៖ គោលជំហរបដិវត្តរឹងប៉ឹង ខាងមាគ៌ានយោបាយរបស់បក្ស é ត្រូវមានជំហរនយោបាយត្រឹមត្រូវ និងរឹងប៉ឹងជាលំដាប់ មិនស្ពាំ "មិនឆ្វេង" ក្នុងការបំពេញភារកិច្ចនយោបាយជាក់ស្ដែងរបស់បក្សដែលខ្លួនអនុវត្តជាបន្តបន្ទាប់ ហើយជាពិសេសក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យក្នុងរយៈកាលបដិវត្តសង្គមនិយម និងការកសាងសង្គមនិយមបច្ចុប្បន្ននេះ"]។

498 សូមមើល ឯកសារ **D6.1.960** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442264 [មាត្រា ៥(២)៖ ជំហរបដិវត្តរឹងប៉ឹងខាងសតិអារម្មណ៍អធនរបស់បក្ស– [...] មានជំហរប្រយុទ្ធមោះមុត សកម្ម ទ្រាំទ្រលំបាកវេទនា គ្រប់កាលៈទេសៈ ក្នុងការតស៊ូវណ្ណៈដាច់ខាត ក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម"]។

499 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929872 ["ដានី៖ ចុះកាលនឹងម៉េចបានគេ ដូចថាខាងលើគេចាត់ឲ្យអ៊ំ ឲ្យមកពីអង្គរជ័យមកកោះអណ្ដែតវិញ? ចែម៖ ខ្ញុំធ្វើអីក៏សម្រេចតាមផែនការ។ ដានី៖ អូ! ធ្វើបានសម្រេច? ចែម៖ នឹង។ [...] ដានី៖ អ្នកគ្រប់គ្រងកោះអណ្ដែតពីមុនយ៉ាងម៉េច បានដក? ចែម៖ អ្នកគ្រប់គ្រងខាងកោះអណ្ដែតនឹងវាទំនាស់គ្នាផង ហើយធ្វើការងារអត់ឯកភាពគ្នា។ ដល់ខ្ញុំទៅនៅទៅ ដកប្រធាននឹងទៅគីរីវង់"]។

500 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929873 ["អនុខ្ញុំនឹងមានប្អូនថ្លៃ តា ម៉ុក [...] តាសាន"]។ ឯកសារ D118/242 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម ហឿន ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.28 KH 00998727 [សាក្សីគឺជាមេឃុំជាងទង ស្រុកត្រាំកក់៖ "ចុងក្រោយគេបំផុត គឺ តា សាន ជាគណៈស្រុកត្រាំកក់ [...] ចំណែកខ្ញុំ ត្រូវគេឲ្យធ្វើគណៈស្រុកត្រាំកក់ផងដែរ គឺនៅក្នុងខែ ១០ ឆ្នាំ ១៩៧៨ ជាមួយនឹង តា សាន ដោយពេលនោះគេឲ្យខ្ញុំគ្រប់គ្រងខាងនារី"]។ ឯកសារ D219/34 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុល ហឿន ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឆ.6-7 KH 01032068 [សាក្សីគឺជាកម្មាភិបាលភូមិភាគនិរតី៖ "នៅពេលនោះ តា អ៊ូច ហៅ សាន ជាគណៈស្រុកកោះអណ្ដែត ដែលជាប្អូនថ្លៃ តា ម៉ុក ហើយរស់នៅក្នុងភូមិជាមួយខ្ញុំ គឺគាត់

បានទៅធ្វើការនៅស្រុកកោះអណ្តែត។ [...] នៅឆ្នាំ ១៩៧៧ ក្រោយពី តា សាន ផ្លាស់ចេញពីស្រុកត្រាំកក់ ឈ្មោះ សឿន [...] បានមកជំនួសតួនាទីរបស់ តា សាន"]។ ឆ.13 KH 01032069 ["ក្រោយពេល យាយ ចែម ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ និងតា អ៊ូច ត្រូវបានគេតែងតាំងជាគណៈស្រុក១០៥នោះ"]។ ឯកសារ D118/208 កំណត់ហេតុស្តាប់ចម្លើយ អ៊ុល ហឿន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.113 KH 00980094 [សាក្សីគឺជាកម្មាភិបាលភូមិភាគនិរតី៖ " គ្រូ អ៊ូច ឡើងជាគណៈស្រុកជំនួស តា ជឹម និង តា ចាយ"]។ សូមមើលផងដែរ ឯកសារ D6.1.210 លិខិតពីគណៈស្រុកត្រាំកក់ឈ្មោះ សាន ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៧៨ KH 00270786 [ណែនាំឱ្យ "បោសសម្អាត" ទាំងកូនក្មេងតូចៗជាមួយម្តាយរបស់ពួកគេ]។

501 ឯកសារ D1.3.23.1 ការផ្សាយវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៧៦ KH 0032382 [លេខ. 4 – "ស្រី ចែម (ស)"]។ ឯកសារ D119/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មឹង វេត ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ. 33 KH 00975695 [សាក្សីធ្វើការនៅមន្ទីរ ១៦០ ក្នុងតំបន់ ១៣៖ "ស. [...] បញ្ជីឈ្មោះជាភាសាខ្មែរដែលមាន ERN 00323882 ចំណងជើងថា "តំណាងកសិករភូមិភាគនិរតី"។ បន្ទាប់ពីលោកបានអានបញ្ជីឈ្មោះរួច តើលោកអាចប្រាប់យើងបានដែរឬទេ អំពីឈ្មោះដែលលោកស្គាល់? ឆ.33៖ លេខ ៤ ឈ្មោះ ស្រី ចែម ហៅ យាយ ចែម ដែលយើងកំពុងនិយាយគ្នានេះហើយ គាត់ជាអ្នកទទួលខុសត្រូវកងនារីតំបន់ ១៣ កាលពីសម័យកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.55-58 KH 00953026 [សាក្សីគឺជាអនុប្រធានកងចល័តនៅក្នុងស្រុកទ្រាំង ខេត្តតាកែវ តំបន់ ១៣៖ "មុនពេលបញ្ជូនទៅភូមិភាគពាយ័ព្យ យាយ ចែម ជាសមាជិកសភារបស់មណ្ឌលតាកែវ។ [...] ក្រោយពេលចប់សង្គ្រាមឆ្នាំ ១៩៧៥ គាត់ត្រូវបានបោះឆ្នោតជ្រើសរើសឱ្យធ្វើជាតំណាងសភាប្រចាំខេត្តតាកែវ។ [...] គាត់ត្រូវបានបោះឆ្នោតជ្រើសរើសដោយតំណាងឃុំ និងស្រុកទាំងអស់នៅក្នុងខេត្តតាកែវក្នុងឆ្នាំ ១៩៧៦។ [...] ខ្ញុំដឹងព័ត៌មាននេះតាមរយៈសាច់ញាតិរបស់គាត់។ ប៉ុន្តែខ្ញុំមិនចាំឈ្មោះសាច់ញាតិគាត់នោះទេ"]។ យោងតាមរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ សភាមានការទទួលខុសត្រូវតែមួយគត់ក្នុងការតាក់តែងច្បាប់នៅក្នុងរបប។ សភាមានគោលដៅដើម្បីបិទបាំងការពារភាពស្របច្បាប់ប្រជាធិបតេយ្យចំពោះរបប ប៉ុន្តែភស្តុតាងទាំងអស់ បានចង្អុលបង្ហាញថា សភាបានជួបប្រជុំតែម្តងគត់ ហើយមិនបានអនុម័តច្បាប់អ្វីទាំងអស់ ហើយមិនមានតួនាទីអ្វីនៅក្នុងការបង្កើតគោលនយោបាយ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។

502 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929772 ["ចែម៖ រៀបចំចងក្រងខ្លះធ្វើជី ក្រុមខ្លះធ្វើស្រែចម្ការអីចឹងទៅ នៅតាមភូមិ។ ដានី៖ នៅអង្គរជ័យ ឬកោះអណ្តែត? ចែម៖ ចាស កោះអណ្តែតបានម៉ាឆ្នាំ បានខ្ញុំផ្លាស់មកស្រុកព្រះនេត្រព្រះ កាលឆ្នាំ ៧៨ ខ្ញុំផ្លាស់"]។

503 ឯកសារ **D219/264.1** ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107003-01107005 ["ឆ្នាំ ៧៦ [...] មាន មានលើកភ្លឺស្រែ ធ្វើប្រឡាយ។ កងកម្លាំងយើងមានចែកជាពីរ អាហ្នឹងនិយាយឱ្យខ្លីណា។ កម្លាំងក្មេងៗយុវជនជុវនារីអីហ្នឹងធ្វើស្រែ ធ្វើចម្ការ។ [...] កម្លាំងហ្នឹង ដែលគេហៅកម្លាំងយុវជនយុវនារីហ្នឹងជាកម្លាំងទី១ អ៊ីចឹងកម្លាំងហ្នឹងទៅធ្វើទំនប់។ ធ្វើទំនប់ ធ្វើប្រឡាយអីហ្នឹងសម្រាប់យកទឹក"]។

504 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929875 ["ដានី៖ កាលនឹងយើងធ្វើការចឹង មានការណែនាំអំពី តា [ម៉ុក] ពីអីដូចថាយើងត្រូវរៀបចំការងារអី? ចែម ៖ មានដែរ គាត់ហៅមកជួបអីទៅ"]។

505 ឯកសារ D119/82 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាង អ៊ូច ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤ ឆ.56 KH 00971374 [សាក្សីគឺជាជំនួយការរបស់ អ៊ឹម ចែម នៅគណៈស្រុកកោះអណ្តែត ហើយក្រោយមក ជាលេខាស្រុកត្រាំកក់៖ "ដោយសារនៅក្នុងកងចល័ត គឺមានទាំងនារី និងបុរស ដូច្នេះនៅពេលដែល យាយ ចែម មកប្រជុំគឺមានការផ្ញើសំបុត្រមកកងចល័តរបស់ខ្ញុំ ដើម្បីឲ្យនារីៗទៅចូលរួមប្រជុំ"]។

506 ឯកសារ D119/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឆ.47-48 KH 00979405 [សាក្សីជាកម្មករនៅស្រុកកោះអណ្តែត នៅក្នុងឆ្នាំ ១៩៧៦៖ "ខ្ញុំធ្លាប់បានឃើញគាត់មកធ្វើមេទ្ទិញ ជាមួយមិត្តខន និងសមមិត្តនារីធំផ្សេងៗទៀត។ [...] មេទ្ទិញ ធ្វើឡើងនៅកណ្តាលវាលស្រែ នៅថ្នល់ ស នៅក្បែរព្រំដែនវៀតណាម។ នៅក្នុងមេទ្ទិញនោះ មានមនុស្សប្រហែល ១៥០០នាក់ ទាំងប្រុស ទាំងស្រី ក្នុងរយៈពេល៣ថ្ងៃ។ មេទ្ទិញ និយាយឲ្យយើងខិតខំធ្វើការងារឲ្យខ្លាំងក្លា ការឈ្លានពានពីសំណាក់កងទ័ពវៀតណាម ពីព្រោះពេលនោះ ពួកវៀតណាម បានមកទម្លាក់គ្រាប់បែកលើជម្រកកងនារី ដោយឆេះអស់ផ្ទះ៣ខ្នង និងនិយាយអំពីការប្រមូលកម្លាំងទាំងអស់ទៅធ្វើការងារតាមសហករណ៍នានា ដើម្បីសម្រេចតាមផែនការឲ្យទាន់ពេលវេលា"]។ ឆ.49 KH 00979405 ["មេទ្ទិញ ធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៦ ក្រោយខែប្រមូលទិន្នផលស្រូវរួចក្នុងរដូវប្រាំង"]។

507 ឯកសារ D119/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឆ.47-48 KH 00979405 [សាក្សីជាកម្មករនៅស្រុកកោះអណ្តែត នៅក្នុងឆ្នាំ ១៩៧៦៖ "ខ្ញុំធ្លាប់បានឃើញគាត់មកធ្វើមេទ្ទិញ ជាមួយមិត្តខន និងសមមិត្តនារីធំផ្សេងៗទៀត។ [...] មេទ្ទិញ ធ្វើឡើងនៅកណ្តាលវាលស្រែ នៅថ្នល់ ស នៅក្បែរព្រំដែនវៀតណាម។ នៅក្នុងមេទ្ទិញនោះ មានមនុស្សប្រហែល ១៥០០នាក់ ទាំងប្រុស ទាំងស្រី ក្នុងរយៈពេល៣ថ្ងៃ។ មេទ្ទិញ និយាយឲ្យយើងខិតខំធ្វើការងារឲ្យខ្លាំងក្លា ការឈ្លានពានពីសំណាក់កងទ័ពវៀតណាម ពីព្រោះពេលនោះ ពួកវៀតណាម បានមកទម្លាក់គ្រាប់បែកលើជម្រកកងនារី ដោយឆេះអស់ផ្ទះ៣ខ្នង និងនិយាយអំពីការប្រមូលកម្លាំងទាំងអស់ទៅធ្វើការងារតាមសហករណ៍នានា ដើម្បីសម្រេចតាមផែនការឲ្យទាន់ពេលវេលា"]។ ឆ.49 KH 00979405 ["មេទ្ទិញ ធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៦ ក្រោយខែប្រមូលទិន្នផលស្រូវរួចក្នុងរដូវប្រាំង"]។ ឆ.50 KH 00979405 ["ចាស មាននិយាយពីរឿងនេះដែរ [ការបញ្ជូនកម្មាភិបាលពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ] ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថា គេប្រមូលកម្មាភិបាលថ្នាក់ណានោះទេ ហើយគេមិនបានប្រាប់ច្បាស់លាស់ពេលវេលា និងឆ្នាំដែលពួកគេត្រូវបញ្ជូនទៅទីនោះទេ"]។

508 ឯកសារ D119/9 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ KH 01100829 ["កន្លែងសម្លាប់មនុស្សព្រៃសុខុនចាប់ផ្តើមពីទិសខាងជើងបន្តិចនៃវត្តអង្គសិរីមាលី"]។ ឯកសារ D119/10 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ KH 00981802 ["នៅប្រហែល១គីឡូម៉ែត្រខាងជើងវត្ត តាមផ្លូវលំបុកទៅភូមិស៊ីស្លា [...] ចាប់ពី [...] ទីកន្លែងធ្លាប់សម្លាប់មនុស្ស"] KH 00981803 ["ទីតាំងនោះ នៅផុតខាងឆ្វេងដៃផ្លូវលំលាតសន្ទឹងពីជើងភូមិសំភ្លី ឃុំព្រៃខ្លា ដល់ភូមិស៊ីស្លា ឃុំធ្លាប្រជុំ។ ចម្ងាយ

ពីភូមិទាំងពីរប្រហែល២គីឡូម៉ែត្រកន្លះ។ [...] ព្រំប្រទល់ខាងត្បូងនៃកន្លែងសម្លាប់នោះ គឺភូមិសំភ្លី និងព្រំប្រទល់ខាងជើងគឺភូមិស៊ីស្លា"]។ ឯកសារ D119/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១២ ឆ.27-28 KH 00872469 [សាក្សីធ្វើការនៅក្នុងកងចល័តក្នុងស្រុកកោះអណ្តែត សៈ "តើអ្នកស្រីមានបាននឹកឃើញព្រឹត្តិការណ៍ណាខ្លះដែលកើតឡើងនៅព្រៃសុខុនដែរឬទេ? [...] តើអ្នកស្រីអាចប្រាប់ទីតាំងកន្លែងនោះបានដែរឬទេ?" កន្លែងនោះនៅខាងត្បូងភូមិស៊ីស្លា [...] សំដៅទៅភូមិសំភ្លី វត្តសំភ្លី "]។ ឯកសារ D119/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ ឆ.27 KH 00872486 [សាក្សីគឺជាកម្មករនៅស្រុកទ្រាំង៖ "ព្រៃសុខុនស្ថិតនៅចន្លោះវត្តសំភ្លី (ឬវត្តអង្គសិរីមាលី) ស្ថិតក្នុងភូមិសំភ្លី និងភូមិស៊ីស្លានេះ។ វានៅខាងជើងវត្តសំភ្លី"]។ ឯកសារ D219/591 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.34 KH 01178844 [សាក្សីគឺជាកម្មករនៅស្រុកទ្រាំង៖ "ព្រៃសុខុននៅខាងជើងវត្ត នៅខាងត្បូងភូមិស៊ីស្លា"]។ ឯកសារ D219/568 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.59 KH 01165967 [សាក្សីធ្វើការនៅក្នុងកងចល័តក្នុងស្រុកកោះអណ្តែត៖ "ព្រៃសុខុនគឺនៅចន្លោះរវាងស៊ីស្លា និងវត្តថ្មី បើគិតទៅប្រហែល២.៥គីឡូម៉ែត្រពីស៊ីស្លា និង២.៥គីឡូម៉ែត្រពីវត្តថ្មី"]។ ឯកសារ D1.3.10.14 របាយការណ៍វិភាគខេត្តតាកែវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ KH 00714207 ["ព្រៃសុខុន ជាទីតាំងសម្លាប់មនុស្ស (ព្រៃល្អាក់) ស្ថិតនៅភូមិស៊ីស្លា ឃុំផ្កាប្រជុំ"]។ ឯកសារ D119/10.1 ឧបសម្ព័ន្ធ ១ ផែនទីនៃបណ្តាញផ្លូវខេត្តតាកែវ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ EN 00887256។

509 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929876 ["ដានី៖ ប៉ុន្តែកាលនៅតាកែវនឹង អ៊ំនៅក្នុងកន្លែងតំបន់ ឬក៏នៅកន្លែងអីគេ? ចែម៖ ខ្ញុំនៅស្រុកដែរ ខាងស្រុកគេមកទាក់ទង ហៅមកប្រជុំអីចឹង ទល់ខ្ញុំចេញ"] KH 00929876 ["ដានី៖ ចឹងអ៊ំ កាលនឹងអ៊ំនៅតាកែវនឹង ប៉ុន្តែអ៊ំនៅធ្វើការងារស្រុកកោះអណ្តែតដដែល? ចែម៖ ចា! នៅអត់ទាន់ដាច់"]។ ["ចែម៖ [...] ខ្ញុំធ្វើជំនួសប្រធានខ្ញុំនឹង គ្រាន់ចូលសមាជិក។ ដានី៖ សមាជិកតំបន់? ចែម៖ ចា! ចែម៖ គាត់ស្លាប់បាត់ហើយ ឈ្មោះ ពូ សោមៗ។ ដានី៖ ពូ សោម? ចែម៖ ចា៎! [...] ហើយប្រធានខ្ញុំ ពូសោម គាត់ឈឺទៅ បានគេតំឡើងខ្ញុំប្រគល់ឲ្យខ្ញុំធ្វើ ... (ស្តាប់មិនបាន)។ ប៉ុន្តែខ្ញុំធ្វើនឹង តិចដែរ មួយឆ្នាំអីនឹង តា គាត់ដកឲ្យមកនៅបាត់ដំបង"]។ ឯកសារ D5/1528 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាយ គឹមលៀង ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ KH 01081273 [គ្រួសាររបស់សាក្សីបានស្លាប់នៅក្នុងស្រុកកោះអណ្តែត៖ "[...] នាងខ្ញុំឮតែឈ្មោះថា យាយ ចែម ជាប្រធានធំ"]។ ឯកសារ D5/1304 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធង ភួន ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ KH 01037783 [សាក្សីបានជួប អ៊ឹម ចែម នៅការដ្ឋាន៖ "នាងខ្ញុំបានជួបផ្ទាល់ជាមួយពួកគេនៅការដ្ឋានលើកទំនប់ ដឹកប្រឡាយ ឈ្មោះ យាយ អឹន ចែម គាត់ជាគណៈតំបន់ ១៣"]។ ឯកសារ D5/1133 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែម ជ្រេន ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ KH 01026735 [សាក្សីបានរស់នៅក្នុងស្រុក១០៦ តំបន់ ១៣៖ "អ្នកដែលទទួលខុសត្រូវនៅក្នុងតំបន់១៣ ឈ្មោះ យាយ អិន ចែម ចាប់ពីឆ្នាំ ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧"]។ ឯកសារ D5/1615 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភ្លី លី ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ KH 01092550 [សាក្សីបានធ្វើការនៅក្នុងស្រុកកោះអណ្តែត ជាទីកន្លែងដែលគ្រួសាររបស់គាត់ត្រូវបានចាប់ខ្លួននៅក្នុងកិច្ចប្រជុំ៖ "អ្នកដែលទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មនោះ ឈ្មោះ យាយ ចែម ជាលេខាបក្សតំបន់ ១៣ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ ហើយ

ប្តីរបស់គាត់ឈ្មោះ តា ញ៉ែន ជាលេខាបក្សស្រុក១០៥ (ត្រាំកក់) និងស្រុក ១០៦ (អង្គរជ័យ) ជាតំបន់ ១៣ ភូមិភាគនិរតី"] ។ ឯកសារ D5/1303 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ សាមី ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH 01037769 [សាក្សីបានរស់នៅក្នុងស្រុកកោះអណ្តែត៖ "ចុងឆ្នាំ ១៩៧៥-១៩៧៦ [...] នាងខ្ញុំឮតែឈ្មោះអ្នកដែលកាន់ (ស្រុក) ១៣ គឺឈ្មោះ ចែម ស្រី និងប្តីគាត់ជាគណ:ស្រុក ១០៥-១០៦"]។

510 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929877 ["ដានី៖ ពូ សោម? ចែម៖ ចា៎! [...] អនុគាត់ តា មុត នឹង។ ដានី៖ តា មាស មុត? [...] ដានី៖ ចឹង តា មុត គាត់ធ្វើជា [...] )? ចែម៖ តាកែវ គាត់ដាច់ពីការងារនៅខេត្តតាកែវនឹងទៅ"]។.

511 សូមមើល ឯកសារ **D6.1.960** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442269 [មាត្រា ៧(៤)៖ អង្គការមានសិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ស្រុកនីមួយៗ គឺសន្និបាតតំណាងស្រុក។ ក្នុងរយ:ពេលពីសន្និបាតស្រុកមួយទៅមួយទៀត មានអង្គការប្រតិបត្តិការសម្រាប់ស្រុកនីមួយៗនោះ គឺគណ:កម្មាធិការស្រុក"]។

512 សូមមើល ឯកសារ **D6.1.960** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442269 [មាត្រា ៧(៣)៖ អង្គការមានសិទ្ធិអំណាច ធំជាងគេបំផុតសម្រាប់តំបន់ ឬក្រុងនីមួយៗ គឺសន្និបាតតំណាងតំបន់ ឬក្រុងនីមួយៗនោះ។ ក្នុងរយ:ពេលពីសន្និបាតតំបន់ ឬក្រុងមួយ ទៅមួយទៀត មានអង្គការប្រតិបត្តិការខ្ពង់ជាងគេបំផុតសម្រាប់តំបន់ ឬក្រុងនីមួយៗនោះ គឺគណ:កម្មាធិការតំបន់ ឬក្រុង"]។

513 សូមមើល ឯកសារ **D6.1.960** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442268 [មាត្រា ៦ (១)-(២)៖ "គ្រប់អង្គការដឹកនាំរបស់បក្ស ត្រូវអនុវត្តរបបដឹកនាំសមូហភាព ហើយមានបុគ្គលទទួលខុសត្រូវដោយឡែក [...] គ្រប់ការសម្រេចផ្សេងៗរបស់បក្ស ត្រូវធ្វើឡើងដោយសមូហភាព"]។

514 សូមមើល ឯកសារ **D6.1.960** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442268 [មាត្រា ៦(៥)៖ "តាមកាលកំណត់នីមួយៗដែរ ថ្នាក់លើត្រូវរាយការណ៍ជូនថ្នាក់ក្រោម អំពីសភាពការណ៍រួម អំពីសេចក្តីណែនាំជាទិសការងារផ្សេងៗ"]។

515 សូមមើល ឯកសារ **D6.1.960** លក្ខន្តិក:បក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442268 [មាត្រា ៦(៥)៖ "តាមកាលកំណត់នីមួយៗ ថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើ អំពីសភាពការណ៍ និងអំពីកិច្ចការដែលខ្លួនបានធ្វើ"]។

516 ឯកសារ **D123/1/5.1c** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929876 ["ដានី៖ ចុះអ៊ំនៅកោះអណ្តែតនឹងបានរយ:ពេលប៉ុន្មានទៅ? ចែម៖ ខ្ញុំនៅបានមួយឆ្នាំ គ្រាន់តែច្រូតហើយ តា [ម៉ុក] ហៅខ្ញុំមកតាកែវ"]។

517 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929876 ["ដានី៖ ប៉ុន្តែកាលនៅតាកែវនឹង អ៊ំនៅក្នុងកន្លែងតំបន់ ឬក៏នៅកន្លែងអីគេ? ចែម៖ ខ្ញុំនៅស្រុកដែរ ខាងស្រុកគេមកទាក់ទង ហៅមកប្រជុំអីចឹង ទល់ខ្ញុំចេញ"] KH 00929876 ["ដានី៖ ចឹងអ៊ំ កាលនឹងអ៊ំនៅតាកែវនឹង ប៉ុន្តែអ៊ំនៅធ្វើការងារស្រុកកោះអណ្តែតដដែល? ចែម៖ ចា! នៅអត់ទាន់ដាច់"]។ ["ចែម៖ [...] ខ្ញុំធ្វើជំនួសប្រធានខ្ញុំនឹង គ្រាន់ចូលសមាជិក។ ដានី៖ សមាជិកតំបន់? ចែម៖ ចា! ចែម៖ គាត់ស្លាប់បាត់ហើយ ឈ្មោះ ពូ សោមៗ។ ដានី៖ ពូ សោម? ចែម៖ ចា៎! [...]

ហើយប្រធានខ្ញុំ ពូសោម គាត់ឈឺទៅ បានគេតំឡើងខ្ញុំប្រគល់ឲ្យខ្ញុំធ្វើ ... (ស្តាប់មិនបាន)។ ប៉ុន្តែខ្ញុំធ្វើនឹង តិចដែរ មួយឆ្នាំអីនឹង តា គាត់ដកឲ្យមកនៅបាត់ដំបង"]។ ឯកសារ D5/1528 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ាយ គឹមលៀង ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ KH 01081273 [គ្រួសាររបស់សាក្សីបានស្លាប់នៅក្នុងស្រុកកោះអណ្តែត៖ "[...] នាងខ្ញុំឮតែឈ្មោះថា យាយ ចែម ជាប្រធានធំ"]។ ឯកសារ D5/1304 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធង ភូន ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ KH 01037783 [សាក្សីបានជួប អ៊ឹម ចែម នៅការដ្ឋាន៖ "នាងខ្ញុំបានជួបផ្ទាល់ជាមួយពួកគេនៅការដ្ឋានលើកទំនប់ ជីកប្រឡាយ ឈ្មោះ យាយ អ៊ីន ចែម គាត់ជាគណៈតំបន់ ១៣"]។ ឯកសារ D5/1133 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែម ជ្រន ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ KH 01026735 [សាក្សីបានរស់នៅក្នុងស្រុក១០៦ តំបន់ ១៣៖ "អ្នកដែលទទួលខុសត្រូវនៅក្នុងតំបន់១៣ ឈ្មោះ យាយ អ៊ិន ចែម ចាប់ពីឆ្នាំ ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧"]។ ឯកសារ D5/1615 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភ្លី លី ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ KH 01092550 [សាក្សីបានធ្វើការនៅក្នុងស្រុកកោះអណ្តែត ជាទីកន្លែងដែលគ្រួសាររបស់គាត់ត្រូវបានចាប់ខ្លួននៅក្នុងកិច្ចប្រជុំ៖ "អ្នកដែលទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មនោះ ឈ្មោះ យាយ ចែម ជាលេខាបក្សតំបន់ ១៣ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ ហើយប្តីរបស់គាត់ឈ្មោះ តា ញ៉ែន ជាលេខាបក្សស្រុក១០៥ (ត្រាំកក់) និងស្រុក ១០៦ (អង្គរជ័យ) ជាតំបន់ ១៣ ភូមិភាគនិរតី"] ។ ឯកសារ D5/1303 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ សាមី ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH 01037769 [សាក្សីបានរស់នៅក្នុងស្រុកកោះអណ្តែត៖ "ចុងឆ្នាំ ១៩៧៥-១៩៧៦ [...] នាងខ្ញុំឮតែឈ្មោះអ្នកដែលកាន់ (ស្រុក) ១៣ គឺឈ្មោះ ចែម ស្រី និងប្តីគាត់ជាគណៈស្រុក ១០៥-១០៦"]។

518 សូមមើល ឯកសារ **D6.1.960** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442265 [មាត្រា ៥(៣)៖ "<u>ជំហរបដិវត្តរឹងប៉ឹង ខាងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្ស</u> ត្រូវមានជំហរ អត្តចរិត ស្មារតី និងសកម្មភាពថែរក្សា ការពារ កសាង ពង្រឹង និងពង្រីក សាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្សជាប់ជានិច្ច តាមជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងរបស់បក្ស។ ហើយមានលក្ខណៈសាមគ្គីបាន ជាមួយភាគច្រើនដាច់ខាត ពី៩៥ ដល់ ១០០ ភាគរយ ដោយមហាជនទទួលទំនុកចិត្ត កក់ក្តៅ ស្រឡាញ់ ពេញចិត្តក្នុងក្របខណ្ឌរបស់ខ្លួនក្តី ក្នុងក្របខណ្ឌទូទៅក្តី"]។ [មាត្រា ៥(៥)៖ "<u>ជំហរបដិវត្តរឹងប៉ឹង ខាងការប្រុងប្រយ័ត្នបដិវត្តរបស់បក្ស រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្ត</u> ត្រូវមានជំហរប្រុងប្រយ័ត្នបដិវត្ត រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្តត្រឹមត្រូវ និងរឹងប៉ឹង គ្រប់កាលៈទេសៈ និងគ្រប់អំពើប្រព្រឹត្ត ធ្វើការងារ និយាយស្តី អាកប្បកិរិយា ការរស់នៅគ្រប់បែបយ៉ាងចំពោះមុខ និងយូរអង្វែងក្នុងបក្ស និងក្រៅបក្ស"]។

519 សូមមើល ឯកសារ **D6.1.960** លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442266 [មាត្រា ៥(៧)៖ <u>ជំហរបដិវត្តរឹងប៉ឹង ខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូប និងជីវទស្សនៈបដិវត្ត</u> ត្រូវមានគោលជំហរបដិវត្តត្រឹមត្រូវ និងរឹងប៉ឹងដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការធ្វើការត្រួតពិនិត្យ និងកសាងប្រវត្តិរូបបដិវត្តជីវទស្សនៈបដិវត្តរបស់ខ្លួនជាបន្តបន្ទាប់"]។ [មាត្រា ៥(៩)៖ <u>ជំហរបដិវត្តរឹងប៉ឹង ខាងសីលធម៌រស់នៅ ស្អាតស្អំ និងស្អាតស្អំខាងនយោបាយ</u> ត្រូវមានសីលធម៌រស់នៅល្អ ស្អាតស្អំ ត្រឹមត្រូវ មិនពុករលួយ ពាលាអាវាសែហើយមិនជំពាក់ជំពិនជាមួយខ្មាំង។ ប្រយ័ត្នបំផុតចំពោះប្រភេទសេរីនិយមខាងការរស់នៅ"]។

520 ឯកសារ **D118/274** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឆ2.9 KH 00999991 [សាក្សីគឺជាសមាជិកឃុំសន្តង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់ ១៣៖ "រាល់ពេលប្រជុំតំបន់ គឺតែងតែមានវត្តមាន យាយ ចែម ដែរ"]។ ឆ.30 KH 00999991 [" ១ឆ្នាំម្តង គេហៅកម្មាភិបាលថ្នាក់ឃុំទាំងអស់ទៅចូលរួមប្រជុំបូកសរុបនៅថ្នាក់តំបន់"]។ ឯកសារ **D118/242** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឆ7.4 KH 00998732 [សាក្សីគឺជាប្រធានឃុំជាងទង ស្រុកត្រាំកក់៖ "តើ អ៊ឹម ចែម ហៅ យាយ ចែម ធ្លាប់ចូលរួមប្រជុំនៅក្នុងមន្ទីរតំបន់ ១៣ ដែរឬទេ? ឆ.74៖ ចាស គាត់ធ្លាប់ចូលរួមប្រជុំ"]។ ឆ.87 KH 00998734 ["ខ្ញុំចូលរួម [ប្រជុំនៅមន្ទីរតំបន់ ១៣] ប្រហែលជា ២ទៅ ៣ ខែ ប្រជុំម្តង"]។ ឆ.91 KH 00998734 ["ចាស [អ្នកចូលរួមក្នុងអង្គប្រជុំ] មាននិយាយអំពីបញ្ហាខ្មាំង។ ខ្ញុំមិនសូវចាំពាក្យគេនិយាយនោះទេ។ សេចក្តីរាយការណ៍ពីភូមិដែលសរសេរជាលាយលក្ខណ៍អក្សរ គឺខ្ញុំត្រូវផ្ញើលិខិតលាយលក្ខណ៍អក្សរនោះទៅខាងលើតែម្តង ដោយពុំមានការកែប្រែអ្វីនោះទេ។ ពេលដែលខ្ញុំឡើងនិយាយនៅក្នុងការប្រជុំនៅមន្ទីរតំបន់ គឺខ្ញុំធ្វើការចាប់អារម្មណ៍ទៅលើការលើកឡើងរបស់ប្រធានអង្គប្រជុំ ថាតើត្រឹមត្រូវដែរឬទេ ហើយមានអ្វីបន្ថែមទៀត។ ថ្នាក់លើណែនាំថា អ្នកណាខ្លះជាខ្មាំង ហើយខ្ញុំយកការណែនាំទាំងអស់នោះទៅប្រាប់ភូមិវិញ។ គេនិយាយថា ឲ្យស្វែងរកអ្នកណាដែលប្រឆាំង គេពុំនិយាយថាជាខ្មាំងនោះទេ។ ចំពោះការប្រជុំថ្នាក់តំបន់ ភាគច្រើនគឺថ្នាក់ស្រុកជាអ្នកឡើងធ្វើការចាប់អារម្មណ៍ និងមានមតិយោបល់។ ចំណែកខ្ញុំ គ្រាន់តែកត់ត្រានូវអ្វីដែលគេបានលើកឡើងនៅក្នុងការប្រជុំ ហើយយកមកអនុវត្តនៅក្នុងភូមិឃុំ"]។ ឆ.99 KH 00998735 ["ការចាប់អារម្មណ៍ វាអាស្រ័យទៅលើការលើកឡើងរបស់ប្រធានអង្គប្រជុំ ប្រសិនបើប្រធានអង្គប្រជុំលើកឡើងអំពីបញ្ហាទាំងអស់នេះ គឺមានន័យថា អ៊ឹម ចែម នឹងចាប់អារម្មណ៍ទៅលើបញ្ហាទាំងអស់នោះដែរ។ នៅក្នុងការប្រជុំនៅមន្ទីរតំបន់នេះ ក៏មានលើកឡើងអំពីបញ្ហាទាំងអស់នេះផងដែរ"]។

521 ឯកសារ **D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ KH 00368611-00368612 [សាក្សីគឺជាសមាជិកឃុំសន្តង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់ ១៣៖ "គេ [កម្មាភិបាលចូលរួមកិច្ចប្រជុំនៅតំបន់ ១៣ ក្នុងឆ្នាំ ១៩៧៧] និយាយពីប្តីមួយប្រពន្ធមួយ បើអ្នកណាប្រព្រឹត្តខុស ត្រូវតែកម្ទេច។ គេមាននិយាយពីរឿងរៀបការដែរ។ ការរៀបការ គេធ្វើឡើងដូចជាពិធីប្រជុំមួយ ដោយឲ្យសាមីខ្លួនឡើងប្តេជ្ញាចិត្ត (ឲ្យដើរតាមអង្គការ និងរស់នៅជាមួយគ្រួសារអស់មួយជីវិត) ហើយឃុំជាអ្នកសម្រេច។ ពេលរៀបការម្តងៗ មានពី៥គូទៅ១០គូ"]។

522 ឯកសារ **D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ KH 00384409 [សាក្សីគឺជាសមាជិកឃុំសន្តង់ ហើយក្រោយមកគឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់១៣៖ "គេ [កម្មាភិបាលចូលរួមកិច្ចប្រជុំនៅតំបន់១៣ ក្នុងឆ្នាំ ១៩៧៧] និយាយពីប្តីមួយប្រពន្ធមួយ បើអ្នកណាប្រព្រឹត្តខុស ត្រូវតែកម្ទេច។ គេមាននិយាយពីរឿងរៀបការដែរ។ ការរៀបការ គេធ្វើឡើងដូចជាពិធីប្រជុំមួយ ដោយឲ្យសាមីខ្លួនឡើងប្តេជ្ញាចិត្ត (ឲ្យដើរតាមអង្គការ និងរស់នៅជាមួយគ្រួសារអស់មួយជីវិត) ហើយឃុំជាអ្នកសម្រេច។ ពេលរៀបការម្តងៗ មានពី៥គូទៅ១០គូ"]។

523 ឯកសារ **D118/274** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឆ2.9 KH 0099991 [សាក្សីគឺជាសមាជិកឃុំសន្តង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់ ១៣៖ រាល់ពេលប្រជុំតំបន់ គឺតែងតែមានវត្តមាន យាយ ចែម ដែរ"]។ ឆ.30 KH 00999991 ["១ ឆ្នាំម្តង គេហៅកម្មាភិបាលថ្នាក់ឃុំទាំងអស់ទៅចូលរួមប្រជុំ

ប្លូកសរុបនៅថ្នាក់តំបន់"]។ ឆ.34 KH 00999992 ["ចំពោះបញ្ហាសន្តិសុខ គេ [កម្មាភិបាលដែលបានចូលរួមប្រជុំថ្នាក់តំបន់] ក៏មាននិយាយផងដែរ។ គេរំឭកឱ្យយើងប្រុងប្រយ័ត្នចំពោះអ្នកដែលឈឺច្រើន និងអ្នកដែលធ្វើឱ្យបែកបាក់សម្ភារៈបង្កបង្កើនផល ព្រោះអាចជាពួកខ្មាំង និងគិញស៊ី.អាយ.អេ។ល។ គេក៏បានព្រមានថ្នាក់ឃុំផងដែរ ថាប្រសិនបើនៅក្នុងឃុំមានប្រជាជនស្លាប់ច្រើនដោយសារអត់បាយ គណៈឃុំនោះក៏អាចត្រូវបានគេចោទថាជាខ្មាំងដែរ"]។ឯកសារ **D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ KH 00368610 [សាក្សីគឺជាសមាជិកឃុំសន្លង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់ ១៣៖ "គេបានប្រាប់ឱ្យតាមដានពួកបង្កប់ស៊ីស្វូងផ្ទៃក្នុង។ បើឃើញបញ្ហានេះកើតឡើង យើងត្រូវរាយការណ៍ទៅថ្នាក់លើ។ ខ្មាំងស៊ីរូងផ្ទៃក្នុងមានដូចជា ការធ្វើឱ្យបាក់នង្គ័ល បាក់ចប បាក់ដងរែក អ្នកដែលធ្វើពុតជាឈឺជាដើម។ ថ្នាក់លើបានបញ្ជាក់ទៀតថា អ្នកដែលបានធ្វើសកម្មភាពទាំងប៉ុន្មានខាងលើនេះ គឺជាខ្មាំងស៊ីរូងផ្ទៃក្នុង ដែលជាហេតុធ្វើឱ្យរាំងស្ទះដល់ចលនាបដិវត្តរបស់យើង។ ករណីនេះកើតមានឡើងតែនៅក្នុងសហករណ៍ទេ។ ដោយឡែកកម្មាភិបាលវិញ ថ្នាក់លើជាអ្នកតាមដាន ត្រួតពិនិត្យ ដូចជាការដឹកនាំធ្វើស្រែមិនអស់ផ្ទៃដី ធ្វើមិនគ្រប់ផែនការ ធ្វើឱ្យខ្មាំងរត់រួច (ឧទាហរណ៍ ដូចជាយកប្រជាជនមកអប់រំ នៅកន្លែងឈ្លប ហើយប្រជាជននោះរត់រួច)"] KH 00368611 ["សៈ តើផ្នែកយោធានិយាយពីអ្វីខ្លះ? ឆៈ ផ្នែកយោធា គេឱ្យរើសយុវជនដើម្បីទៅបម្រើកងទ័ព។ គេបានបំពាក់គោលជំហរថា កុំឱ្យយួនឈ្លានពាន និងវែងណ្តើមយកទឹកដីកម្ពុជាក្រោមយកមកវិញ។ នេះជាការណែនាំនៅពេលប្រជុំរបស់ថ្នាក់លើ ដូចជា តា ម៉ុក ជាដើម"]។

524 ឯកសារ **D118/274** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឆ2.9 KH 0099991 [សាក្សីគឺជាសមាជិកឃុំសន្លង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់ ១៣៖ រាល់ពេលប្រជុំតំបន់ គឺតែងតែមានវត្តមាន យាយ ចែម ដែរ"]។ ឆ.30 KH 00999991 ["១ ឆ្នាំម្តង គេហៅកម្មាភិបាលថ្នាក់ឃុំទាំងអស់ទៅចូលរួមប្រជុំប្លូកសរុបនៅថ្នាក់តំបន់"]។ ឆ.34 KH 00999992 ["ចំពោះបញ្ហាសន្តិសុខ គេ [កម្មាភិបាលដែលបានចូលរួមប្រជុំថ្នាក់តំបន់] ក៏មាននិយាយផងដែរ។ គេរំឭកឱ្យយើងប្រុងប្រយ័ត្នចំពោះអ្នកដែលឈឺច្រើន និងអ្នកដែលធ្វើឱ្យបែកបាក់សម្ភារៈបង្កបង្កើនផល ព្រោះអាចជាពួកខ្មាំង និងគិញស៊ី.អាយ.អេ។ល។ គេក៏បានព្រមានថ្នាក់ឃុំផងដែរ ថាប្រសិនបើនៅក្នុងឃុំមានប្រជាជនស្លាប់ច្រើនដោយសារអត់បាយ គណៈឃុំនោះក៏អាចត្រូវបានគេចោទថាជាខ្មាំងដែរ"]។

525 ឯកសារ **D118/242** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឆ7.4 KH 00998732 [សាក្សីគឺជាមេឃុំជាងទង ស្រុកត្រាំកក់៖ "តើ អ៊ឹម ចែម ហៅ យាយ ចែម ធ្លាប់ចូលរួមប្រជុំនៅក្នុងមន្ទីរតំបន់ ១៣ ដែរឬទេ? ឆ.74៖ ចាស គាត់ធ្លាប់ចូលរួមប្រជុំ"]។ ឆ.87 KH 00998734 ["ខ្ញុំចូលរួម [ប្រជុំនៅមន្ទីរតំបន់ ១៣] ប្រហែលជា ២ទៅ ៣ ខែ ប្រជុំម្តង"]។ ឆ.91 KH 00998734 ["ចាស [អ្នកចូលរួមក្នុងអង្គប្រជុំ] មាននិយាយអំពីបញ្ហាខ្មាំង។ ខ្ញុំមិនសូវចាំពាក្យគេនិយាយនោះទេ។ សេចក្តីរាយការណ៍ពីភូមិដែលសរសេរជាលាយលក្ខណ៍អក្សរ គឺខ្ញុំត្រូវផ្ញើលិខិតលាយលក្ខណ៍អក្សរនោះទៅខាងលើតែម្តង ដោយពុំមានការកែប្រែអ្វីនោះទេ។ ពេលដែលខ្ញុំឡើងនិយាយនៅក្នុងការប្រជុំនៅមន្ទីរតំបន់ គឺខ្ញុំធ្វើការចាប់អារម្មណ៍ទៅលើការលើកឡើងរបស់ប្រធានអង្គប្រជុំ ថាតើត្រឹមត្រូវដែរឬទេ ហើយមានអ្វីបន្ថែមទៀត។ ថ្នាក់លើណែនាំថា អ្នកណាខ្លះជាខ្មាំង ហើយខ្ញុំយកការណែនាំទាំងអស់នោះទៅប្រាប់ភូមិវិញ។ គេនិយាយថា ឱ្យស្វែងរកអ្នកណាដែលប្រឆាំង គេពុំនិយាយថាជាខ្មាំងនោះទេ។ ចំពោះការប្រជុំថ្នាក់តំបន់ ភាគច្រើនគឺថ្នាក់ស្រុកជាអ្នកឡើងធ្វើការចាប់

អារម្មណ៍ និងមានមតិយោបល់។ ចំណែកខ្ញុំ គ្រាន់តែកត់ត្រានូវអ្វីដែលគេបានលើកឡើងនៅក្នុងការប្រជុំ ហើយយកមកអនុវត្តនៅក្នុងភូមិឃុំ"]។ ឆ.99 KH 00998735 ["ការចាប់អារម្មណ៍ វាអាស្រ័យទៅលើការលើកឡើងរបស់ប្រធានអង្គប្រជុំ ប្រសិនបើប្រធានអង្គប្រជុំលើកឡើងអំពីបញ្ហាទាំងអស់នេះ គឺមានន័យថា អ៊ឹម ចែម នឹងចាប់អារម្មណ៍ទៅលើបញ្ហាទាំងអស់នោះដែរ។ នៅក្នុងការប្រជុំនៅមន្ទីរតំបន់នេះ ក៏មានលើកឡើងអំពីបញ្ហាទាំងអស់នេះផងដែរ"]។

526 ឯកសារ **D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ KH 00368608 [សាក្សី គឺជាសមាជិកឃុំសន្តង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់ ១៣៖ "ខ្ញុំធ្លាប់ចូលរួមប្រជុំថ្នាក់តំបន់ [តំបន់ ១៣] ដែរ គឺមួយឆ្នាំប្រជុំម្តង ក្នុងឆ្នាំ ១៩៧៧។ កន្លែងប្រជុំគឺនៅភ្នំខ្លែង។ ពេលប្រជុំនៅភ្នំខ្លែង លេខាឃុំត្រូវបានគេចាប់ខ្លួនទាំងអស់ ដោយហៅឈ្មោះ ប្រាប់ថាទៅធ្វើទស្សនកិច្ចនៅភូមិភាគផ្សេង [...] ខ្ញុំដឹង [អំពីការចាប់ខ្លួន] ព្រោះនៅប្រហែលម៉ោង៣រសៀលក្នុងថ្ងៃប្រជុំនោះ គេឲ្យឈប់សម្រាកបន្តិច ពេលនោះ យាយ ចែម បាននិយាយជាមួយគ្នាគាត់អំពីការចាប់អ្នកទាំងអស់នេះ ដោយនិយាយថា អ្នកទាំងអស់នោះពាក់ព័ន្ធជាមួយយួន"]។ ឯកសារ **D118/274** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធឿន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៤ ឆ3.7 KH 00999992 [សាក្សីគឺជាសមាជិកឃុំសន្តង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់១៣៖ "តាមខ្ញុំចាំ ការប្រជុំតំបន់ប្រចាំឆ្នាំ មានរយៈពេល៣ថ្ងៃ ហើយ តា ម៉ុក មានវត្តមាននៅក្នុងថ្ងៃទី៣នៃការប្រជុំ។ នៅពេលសម្រាកអាហារថ្ងៃត្រង់ ខ្ញុំបានឮដោយផ្ទាល់ យាយ ចែម បាននិយាយជាមួយគ្នាគាត់ថា ពួកដែលគេហៅទៅពីព្រឹក គឺពុំមែនហៅទៅធ្វើទស្សនកិច្ចនៅទីណាផ្សេងទេ គឺពួកគេត្រូវបានចាប់ខ្លួន"]។ ឆ 4.1 KH 00999992-00999993 ["គឺនៅថ្ងៃតែមួយដែលខ្ញុំបានឮ យាយ ចែម និយាយថាពួកគេនោះត្រូវបានចាប់ខ្លួន មិនមែនហៅទៅធ្វើទស្សនកិច្ចទេ។ គាត់និយាយនេះ គឺក្រោយពេលគេយកគណៈឃុំទាំងនោះទៅអស់ហើយ [...] ក្នុងពេលសម្រាកថ្ងៃត្រង់ ប្រហែលម៉ោង១១:៣០ នាទី ខ្ញុំបានឮ យាយ ចែម តា សោម និងលេខាស្រុកដែលឈ្មោះត្រង់នឹងគាត់ ប្រហែលជា៣ទៅ៤ នាក់ និយាយគ្នានៅក្នុងបន្ទប់រៀនមួយ ដែលមានបង្អួចបើក ហើយពេលនោះខ្ញុំបានដើរទៅបត់ជើងតូចនៅក្បែរនោះ។ ខ្ញុំបានឮ យាយ ចែម និយាយថា អ្នកដែលគេចាប់ខ្លួនព្រឹកមិញនេះ គឺពុំមែនយកទៅធ្វើទស្សនកិច្ចនៅទីណាទេ គឺពួកគេត្រូវបានចាប់ខ្លួន"]។ ឆ4.3 KH 00999993 ["ខ្ញុំពុំបានឮផ្ទាល់ពី យាយ ចែម អំពីមូលហេតុ [នៃការចាប់ខ្លួន] ទេ។ តែនៅម៉ោងប្រហែល ១:៣០ នាទី តា ផាត់ ដែលជាអនុគណៈឃុំសំឡាញ និយាយថា គាត់មានការភ័យខ្លាច បះសក់ ព្រោះថា កម្មាភិបាលឃុំ រួមមាន តា បូ ដែលគេចាប់ខ្លួនព្រឹកមិញ គឺមិនមែនបញ្ជូនទៅធ្វើទស្សនកិច្ចទីណាទេ គឺគេយកទៅសម្លាប់ចោលដោយសារ គេចោទពួកនេះថា ជាបក្សពួក តា ប៉ាល់ និង តា និន ដែលជាគណៈស្រុក ១០៧ ចាស់ និងបានធ្វើការតាំងពីដើមទស្សវត្សរ៍ឆ្នាំ ១៩៧០។ តាប៉ាល់ និង តា និន ត្រូវបានគេចាប់ខ្លួន ដោយគេចោទថាជាខ្មែរក្បត់យួន"]។

527 ឯកសារ **D193/8.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុល ហឿន ហៅ ឯក ហឿន ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឆ. 33 KH 01032072 [សាក្សីគឺជាកម្មាភិបាលភូមិភាគនិរតី៖ "តាមខ្ញុំយល់ គឺ តា ទិត្យ និង យាយ ចែម បានបញ្ជាឲ្យប្រធានសន្តិសុខស្រុកឈ្មោះ តា សឿន ឲ្យចាប់ខ្លួនមនុស្ស"]។

528 ឯកសារ **D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉ុ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឆ5.4 KH 00979406 [សាក្សីធ្វើការនៅស្រុកកោះអណ្តែត នៅក្នុងឆ្នាំ ១៩៧៨៖ "ពួកគេបញ្ជូនយើងមកក្រុងតាកែវ ហើយគេបានអប់រំយើងរយៈពេល២ថ្ងៃ។ ខ្ញុំមិនបានចាំអំពីខ្លឹមសារនៃការអប់រំនោះទេ ដោយសារតែមានមនុស្សចូលរួមច្រើន ហើយខ្ញុំស្តាប់មិនឮទេ អ្នក

បង្រៀននោះ គេឈរនៅលើវេទិកាឆ្ងាយពីខ្ញុំ"]។ ឆ.55 KH 00979406-00979407 ["អ្នកបង្រៀនមានប្រុសមានស្រី មានគ្នាប្រហែល៤ ឬ៥នាក់ ដោយប្តូរវេនគ្នាដើម្បីនិយាយក្នុងអង្គប្រជុំ។ នៅពេលនោះ ខ្ញុំមានឃើញ យាយ ឃែម ឡើងនិយាយនៅលើវេទិកា ប៉ុន្តែខ្ញុំមិនស្គាល់អ្នកផ្សេងទៀតទេ។ ក្រោយពីយើងទទួលការអប់រំរយៈពេល២ថ្ងៃមក គេបានបញ្ជូនយើងត្រឡប់ទៅស្រុក១០៨វិញ"]។ ឯកសារ **D6.1.688** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន ធៀន ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ KH 00368607 [សាក្សីគឺជាសមាជិកឃុំសន្លង់ ហើយក្រោយមក គឺជាអនុប្រធានឃុំប្រាំបីមុំ នៅក្នុងតំបន់១៣៖ "ខ្ញុំធ្លាប់បានចូលរួមប្រជុំរៀនសូត្រ [នៅឃុំសន្លង់] ដែរ [...] ការប្រជុំចែកចេញជាពីរផ្នែក គឺថ្នាក់ស្រុក និងថ្នាក់តំបន់។ ការប្រជុំថ្នាក់ស្រុក គឺធ្វើនៅអង្គរជ័យ។ តា និត ជាអ្នកដឹកនាំការប្រជុំ។ ការប្រជុំនោះ គេនិយាយតែពីសេដ្ឋកិច្ច មានន័យថា គេឱ្យខំប្រឹងបង្កបង្កើនផល។ ការប្រជុំថ្នាក់ស្រុកចែកជាពីរទៀត គឺលេខាឃុំប្រជុំផ្សេង និងសមាជិកឃុំប្រជុំផ្សេង។ នៅក្នុងស្រុកអង្គរជ័យ មាន១២ឃុំ ដូចជា ឃុំសន្លង់ ជីខ្មារ ប្រាំបីមុំ ព្រៃស្នឹក ខ្វារ អង្គកែវ សម្លាញ ប្រភ្នំ អង្គរជ័យ ភ្នំកុង ម្រោម និងឃុំត្នោតក្រចាង។ សមាជិកឃុំទាំងអស់ទៅប្រជុំពីរ ឬបីខែម្តង ហើយក្រុមនេះ ប្រជុំតែផ្នែកសេដ្ឋកិច្ចទេ ដោយឡែក ក្រុមផ្សេងខ្ញុំមិនបានដឹងទេ [...] ជាទូទៅ ការប្រជុំគេធ្វើរយៈពេលបីថ្ងៃ។ ថ្ងៃចុងក្រោយ គឺមាន យាយ ចែម ជាអ្នកចូលរួមដឹកនាំប្រជុំ។ យាយ ចែម មិន) (សហករណ៍ សមរភូមិក្រោយនារីនៅក្នុងនារីមានន័យថា កងមប្រធានសមាគមនារីតំបន់ (សមាគស្តាប់ ឬរស់) ជាដឹង "]។

529 ឯកសារ **D119/108** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឆ4.7-48 KH 00979405 [សាក្សីធ្វើការនៅស្រុកកោះអណ្តែត នៅក្នុងឆ្នាំ ១៩៧៦៖ "ស៖ កាលនៅកោះអណ្តែត តើលោកស្រីធ្លាប់ឃើញ យាយ ចែមដែរទេ ?ឆ4.7៖ ខ្ញុំធ្លាប់បានឃើញគាត់មកធ្វើមេទ្ទិញជាមួយមិត្ត ខន និងសមមិត្តនារីធំៗផ្សេងៗទៀត។ ស៖ តើមេទ្ទិញនោះបានធ្វើនៅកន្លែងណា ?ឆ4.8៖ មេទ្ទិញ ធ្វើឡើងនៅកណ្តាលវាលស្រែ នៅថ្ន ស នៅក្បែរព្រំដែនវៀតណាម។ នៅក្នុងមេទ្ទិញនោះមានមនុស្សប្រហែល ១៥០០នាក់ ទាំងប្រុស ទាំងស្រី ក្នុង រយៈពេល៣ថ្ងៃ [...] មេទ្ទិញ និយាយឱ្យយើងខិតខំធ្វើការងារឱ្យខ្លាំងក្លា ការណ្តានពានពីសំណាក់កងទ័ពវៀតណាម ពីព្រោះពេលនោះ ពួកវៀតណាម បានមកទម្លាក់គ្រាប់បែកលើជម្រកកងនារី ដោយឆេះអស់ផ្ទះ៣ខ្នង និងនិយាយអំពីការប្រមូលកម្លាំងទាំងអស់ទៅធ្វើការងារតាមសហករណ៍នានា ដើម្បីសម្រេចតាមផែនការឱ្យទាន់ពេលវេលា"]។

530 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929876 ["មកនៅតាកែវបានមិនដល់កន្លះឆ្នាំផង [តាម៉ុក] ឱ្យមកស្រុកព្រះនេត្រព្រះ។"] 00929877 ["ចែម៖ តាកែវ [...] ប្រធានខ្ញុំ ពូសោម គាត់ឈឺទៅ បានគេតំឡើងខ្ញុំប្រគល់ឱ្យខ្ញុំធ្វើ [...] ប៉ុន ខ្ញុំធ្វើនឹង តិចដែរ មួយឆ្នាំអីនឹង តា គាត់ដកមកនៅបាត់ដំបង។ ដានី៖ បានមកនៅព្រះនេត្រព្រះ? ចែម៖ ចា៎! នៅព្រះនេត្រព្រះ។"] 00929879 ["ដានី៖ ចឹងអ៊ំនៅតាកែវ បានតែមួយរយៈទេ? ចែម៖ ហ្នឹងខ្ញុំនៅបានប៉ុន្មានខែ។"]។ ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929748 ["ហ្វារីណា៖ អ៊ំនៅតាកែវធ្វើអីមុនឆ្នាំ៧៧ មុនខែ១២ ហ្នឹង? ចែម៖ [នៅតាកែវ] ខ្ញុំធ្វើការងារនៅស្រុកកោះអណ្តែត។ ខ្ញុំធ្វើតែជាមួយប្រជាជន ប៉ុនធ្វើបានតែស្នងហើយ នៅជាមួយប្រជាជនហ្នឹង ប៉ុននៅបានតែស្នងហើយ [...] វាមិនបានមួយឆ្នាំទេ"]។

531 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929775 ["ចែម៖ ខ្ញុំអ្នកនែដឹកនាំហ្នឹងមកតែខ្ញុំទេ។ ដានី៖ អ៎? ចែម៖ អ្នកពីរនាក់ប្តីប្រពន្ធហ្នឹង ពិតជាប្រជាពលរដ្ឋមក

៥០០។ ដានី៖ ប្រជាពលរដ្ឋហ្នឹងក៏មកជាមួយដែរ? ចែម៖ តាកែវ កំពត កំពង់ស្ពឺ។ ដានី៖ ម៉េចបានជាមកៗ ៥០០ គ្រួសារមកជាអ៊ំហ្នឹង? ចែម៖ មូលហេតុដែលមកតាមខ្ញុំច្រើន ហើយជ្រើសរើសទៀត ឲ្យខ្ញុំជ្រើសរើសខ្លួនឯងក៏យកមកដាក់តាមសហករណ៍។"]។ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234194 ["ខ្ញុំនាំកម្លាំងពីនិរតីទៅ ពីតាកែវទៅ ចល័តប្រាំរយ ដាក់តាមការដ្ឋានគេចាស់ហ្នឹង ទាហានប្រាំរយ ប្រជាជនបីខេត្តហ្នឹងក៏យកប្រាំរយគ្រួសារដែរ យករាយតាមភូមិនៅក្នុងស្រុកទាំងអស់ ហើយខ្ញុំដាក់នេះគឺដើម្បីស្រណុក(ស្រួល)ហៅធ្វើការ ព្រោះខ្ញុំអត់ស្គាល់សោះស្រុកព្រះនេត្រព្រះហ្នឹង។"]។ ឯកសារ D6.1.75 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00978479 ["[...] ដល់ខ្ញុំដើរមើលហើយ ខ្ញុំហៅប្រជុំ។ ខ្ញុំនាំកម្លាំងពីនិរតីទៅ ពីតាកែវទៅចល័ត ៥០០ ដាក់តាមការដ្ឋានគេចាស់ហ្នឹង។"]។ ឯកសារ D219/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.31-32 KH 01032104 [សាក្សីត្រូវបានបញ្ជូនពីភូមិភាគនិរតីទៅស្រុកស៊ីសុផុន ក្នុងអំឡុងពេលបោសសម្អាត៖ "ខ្ញុំមិនដឹងថា នរណាជាអ្នកចាត់យាយចែមទេ តែខ្ញុំបានឃើញគាត់នៅពេលដែលគាត់ដឹកនាំយើងទៅភូមិភាគពាយ័ព្យ។ នៅក្នុងឆ្នាំ ១៩៧៦ ខ្ញុំបានឃើញគាត់នៅលើរថភ្លើងជាមួយពួកយើង ដែលមានមនុស្សជិតមួយពាន់នាក់។ [...] មុនដំបូង ថ្នាក់ស្រុកស្នើឲ្យថ្នាក់ឃុំ និងភូមិជ្រើសរើសគ្រួសារដែលត្រូវបញ្ជូនទៅខេត្តបាត់ដំបង។ នៅពេលនោះ មានមនុស្សចំនួនប្រហែលមួយពាន់នាក់ ត្រូវបានប្រមូលផ្តុំនៅក្នុងស្ថានីយ៍រថភ្លើងខេត្តតាកែវ។ ពួកគស្នាក់នៅទីនោះ ១យប់ ហើយបន្ទាប់មក គេបានធ្វើដំណើរតាមរថភ្លើងទៅកាន់ស្វាយស៊ីសុផុន ដោយចំណាយពេលធ្វើដំណើរអស់១ថ្ងៃ១យប់។"]។ ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.11-13 KH 00801022-00801023 [សាក្សីត្រូវបានបញ្ជូនពីតំបន់ ១៣ ទៅភូមិភាគពាយ័ព្យ៖ "គឺមានមនុស្សច្រើន តែយាយចែមគឺជាអ្នកដឹកនាំយើងមកទីនោះ [...] នៅឆ្នាំ១៩៧៧ [...] មកដល់នៅដើមឆ្នាំ១៩៧៧ គឺប្រហែលជាមុនចូលឆ្នាំខ្មែរហើយមើលទៅពីព្រោះពេលមកដល់ គឺវាលស្រែនៅស្ងួតនៅឡើយ។ ដំបូង យើងធ្វើដំណើរតាមរថភ្លើងមកហួសខេត្តបាត់ដំបងបន្តិច រួចបន្តដំណើរតាមរថយន្ត អស់រយៈពេលប្រហែលជាបីម៉ោង ទើបមកដល់ខេត្តបន្ទាយមានជ័យ។ ពេលមកដល់ ត្រូវបានគេបែងចែងឲ្យទៅនៅតាមភូមិ តាមស្រុកនានា។""]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.30-31 KH 00953023 [សាក្សីត្រូវបានបញ្ជូនពីតំបន់ ១៣ ទៅភូមិភាគពាយ័ព្យ៖ "ខ្ញុំធ្វើការនៅស្រែប្រាំងរហូតដល់ដើមឆ្នាំ១៩៧៧។ នៅខែមីនា ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ។ [...] បាទ នេះជាចម្លើយត្រឹមត្រូវ ព្រោះខ្ញុំធ្វើស្រែប្រាំងនៅក្បាលពោធិ៍ ពីខែតុលា ឆ្នាំ១៩៧៦ រហូតដល់ខែមករា ឆ្នាំ១៩៧៧ បន្ទាប់មកក្នុងខែមីនា ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ។"]។ ឆ.39-40 KH 00953024 ["ការចេញទៅនោះ មិនមែនតែគ្រួសារខ្ញុំមួយទេ គឺប្រជាជនទូទាំងខេត្តតាកែវ។ គេបញ្ជូនយើងតាមឡាន ទៅជួបជុំទៅខេត្តតាកែវ។ សម្រាកនៅខេត្តតាកែវមួយយប់។ ពេលប្រមូលបានគ្នាច្រើន យើងចេញទៅពាយ័ព្យតាមរទេះភ្លើង។ [...] មនុស្សមកពីខេត្តកំពត ក៏បញ្ជូនមកជួបជុំគ្នានៅខេត្តតាកែវដែរ។ ឃុំខ្លះមានបីគ្រួសារ ឃុំខ្លះប្រាំគ្រួសារដែលមានមនុស្សសរុបប្រហែល ៥០០ ទៅ ៦០០ គ្រួសារ។ សមាជិកគ្រួសារនីមួយៗមានចំនួនមនុស្សតិចច្រើនមិនដូចគ្នាទេ។ ក្នុងនោះ មានកងនារីស្រែអំបិល បីបួនរយនាក់ និងកងទ័ពបីរយនាក់។ សរុបទាំងអស់គ្នា គឺមានមនុស្សរាប់ពាន់នាក់។"]។ ឆ.44 KH 00953025 ["ចំណែកអ្នកគ្រប់គ្រងប្រជាជន គឺយាយចែម។ ឯអ្នកគ្រប់គ្រងរួមក្នុងការបញ្ជូនមនុស្សទាំងអស់ទៅភូមិភាគពាយ័ព្យតែម្តងក៏យាយចែមហ្នឹងដែរ។"]។ ឯកសារ D219/102

ម្តាល ពេលគាត់មកពិនិត្យការងារនៅការដ្ឋាននេះ"]។ ឯកសារ D53 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃ ម៉ុត ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727206 [សាក្សីដែលធ្វើការ នៅ កង ចល័ត និងជាប្រធានកង៖ "ខ្ញុំមិនដែលបានឃើញគាត់ទេ គ្រាន់តែលឺគេនិយាយតែប៉ុណ្ណោះ។ ខ្ញុំ ឮថា គាត់បានមក [ត្រពាំងថ្ម] ប៉ុន្តែ ខ្ញុំមិនបានឃើញគាត់ទេ។ អ្នកធំៗ និយាយថាមានអ្នកធំមក ប៉ុន្តែខ្ញុំគិតតែពីរឿងលើកដីតែប៉ុណ្ណោះ"]។ ឯកសារ D5/1057 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ សាវី ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ KH 00993139 សាក្សីជាបុគ្គលិកពេទ្យ នៅការដ្ឋានកិច្ចការសង្គម មុននឹងត្រូវផ្លាស់ទៅសាងសងត្រពាំងថ្ម នៅឆ្នាំ ១៩៧៨៖ "នៅ ឆ្នាំ ១៩៧៨ នាងខ្ញុំត្រូវអង្គការ ប៉ុលពត បង្ខំឱ្យទៅលើកទំនប់នៅអាងត្រពាំងថ្ម មួយថ្ងៃ ២ម២។ ពេលនោះមិត្ត ចែមគ្រប់គ្រងតំបន់ គាត់ដើរត្រួតមានឈ្លបយោធាផង មេសហករណ៍ មេកងចល័តផង ដើរជាមួយគ្នា។ ពួកគេបង្ខំសូម្បីតែមនុស្សឈឺក៏អោយធ្វើការដែរ ធ្វើឱ្យបាក់កម្លាំង"]។

642 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.100 KH 00996504 [សាក្សីធ្វើការក្នុងកងពលកុមារនៅទំនប់ត្រពាំងថ្ម៖ "ស៖ នៅពេលដែលយាយ ចែម មកពិនិត្យមើលការដ្ឋាននៅទំនប់អាងត្រពាំងថ្ម តើគាត់មានកងការពារមកជាមួយគាត់ដែរទេ? ឆ.100៖ ចាសមានកងការពាររបស់គាត់ពីរនាក់មកជាមួយ។ កងការពារទាំងពីរនាក់នោះគឺមានកាន់កាំភ្លើងមកជាមួយផងដែរ"]។ ឯកសារ D119/112 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ឆ.17 KH 00982232 [សាក្សីជាពលករ ក្នុងកងពលកុមារនៅត្រពាំងថ្ម៖ "[អ៊ឹម ចែម] គ្រាន់តែឈរពិនិត្យការធ្វើដំណើររបស់យើង ហើយខ្ញុំបានឃើញអ្នកការពារពីរបីនាក់ នៅឈរអមគាត់"]។ សូមមើលផងដែរ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.87 KH 0098948 [សាក្សីធ្វើការនៅ ក្នុងកងពលកុមារនៅ ត្រពាំងថ្ម៖ "ខ្ញុំធ្លាប់ឮឈ្មោះយាយចែម នៅអាងត្រពាំងថ្ម។ ខ្ញុំធ្លាប់ឮគេនិយាយថា យាយចែមជាអ្នកនាំកងទ័ព និងប្រជាជនឱ្យទៅធ្វើការនៅអាងត្រពាំងថ្ម។ យាយចែមក៏គ្រប់គ្រងកងទ័ព"]។ ឯកសារ D119/90 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.13 KH 00976141 [សាក្សីដែលធ្វើការនៅកងចល័តថ្នាក់ស្រុក៖ "ពេលដែល យាយ ចែម មកពិនិត្យការដ្ឋាន [ត្រពាំងថ្ម] មានយោធាប្រហែល ៤ ឬ ៥ នាក់ ប្រដាប់ដោយអាវុធអមដំណើរគាត់"]។

643 ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.43 KH 01105586 [សាក្សីធ្វើការនៅកងចល័តនៅត្រពាំងថ្ម៖ "ខ្ញុំមិនដែលបានឃើញ ចែម និង ញ៉ូន ទេ ព្រោះគេបញ្ជូនតែកូនចៅឱ្យមើលយើងតែប៉ុណ្ណោះ"] ឆ.37 KH 01105586 ["ស៖ តើគាត់ធ្លាប់បានចុះមកណែនាំ ឱ្យលោកស្រីត្រូវធ្វើការយ៉ាងម៉េចដែរទេ? ឆ.47៖ ទេ គាត់ត្រូវគ្រាប់តែបញ្ជាឱ្យកូនចៅមកណែនាំប៉ុណ្ណោះ"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.109 KH 01049237 [សាក្សីជា កម្មករនៅកងចល័តយុវជន៖ "មនុស្សមកពីក្រុមរបស់យាយចែមមកត្រួតពិនិត្យការងារនៅកន្លែងការដ្ឋានសង់ទំនប់ដែរ [ត្រពាំងថ្ម]។ អ្នកធ្វើការមកពីព្រះនេត្រព្រះ សេរីសោភណ្ឌ ស្រុកភ្នំស្រុក និងថ្មពួក"]។

644 ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.97 KH 00989349-00989350 [សាក្សីធ្វើការក្នុងកងពលកុមារនៅ ត្រពាំងថ្ម៖ "សៈ នៅក្នុងពាក្យបណ្តឹងរបស់លោកស្រី ឯកសារលេខ D5/580 ជាភាសាខ្មែរត្រង់ KH 00907951 លោកស្រីនិយាយថា៖ "ក្នុងពេលនោះ នាងខ្ញុំត្រូវ បានបង្ខំឱ្យរែកដីយ៉ាងធ្ងន់តាមបញ្ជារបស់អង្គការ ប៉ុន្តែមិនឱ្យហូបឆ្អែត គឺគ្រាន់តែបាយមួយកូនចាន អត់មួយពេលនោះរត់ស្វះស្វែងរកក្តាមខ្យងធ្វើម្ហូប ហួសពេលវេលា អង្គការក្រោមបញ្ជារបស់យាយចែម បង្ខំឱ្យធ្វើពលកម្មទៅទៀត ដោយអត់អាហារ"។ លោកស្រីអាចបញ្ជាក់បន្ថែមបានទេ ហេតុអ្វីបានជាលោកស្រីដឹង វាគឺជាបញ្ជាដោយផ្ទាល់របស់យាយចែម? ឆ.97៖ ពីព្រោះយាយចែម ជាអ្នកបញ្ជាពីលើ"] ឆ.99 KH 00989350 ["សៈ តើអ្នកណាខ្លះស្ថិតក្រោមរបស់យាយចែម? ឆ.99៖ មានអ្នកធ្វើការងារនៅក្រោម យាយចែម តែខ្ញុំមិនដឹងថាមានអ្នកណាខ្លះនោះទេ"]។

645 ឯកសារ D219/39 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថូយ ថៀម ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.40 KH 01032125 [សាក្សីធ្វើការក្នុងកងចល័តនៅ ត្រពាំងថ្ម៖ "សៈ តើ ចែម មានបញ្ជាឱ្យអ្នកស្រីធ្វើអ្វីខ្លះ? ឆ.40៖ គាត់បញ្ជាឱ្យខ្ញុំរែកដី"]។

646 ឯកសារ D219/39 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថូយ ថៀម ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.42 KH 01032125 [សាក្សីធ្វើការក្នុងកងចល័តនៅ ត្រពាំងថ្ម៖ "សៈ ពេលខ្មែរក្រហមយកមនុស្សទៅដាក់ទោស តើចែមមានទៅចូលរួមដែរឬទេ? ឆ.42៖ ចាស ចែមទៅ"]។

647 ឯកសារ **D119/131** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ102. KH 00996504 [សាក្សីធ្វើការក្នុងកងពលកុមារនៅទំនប់ត្រពាំងថ្ម៖ "យាយ ចែម ធ្លាប់កោះហៅប្រធានក្រុម និងប្រធានកងឱ្យចូលរួមប្រជុំ [នៅពេលដែលយាយ ចែមមកត្រួតពិនិត្យការដ្ឋានអាងត្រពាំងថ្ម]។ ក្រុមដូចជាខ្ញុំ គេមិនកោះហៅឱ្យចូលរួមប្រជុំជាមួយទេ]។

648 ឯកសារ **D59** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច គា ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727218 [សាក្សីជាចុងភៅនៅ ត្រពាំងថ្ម៖ "សៈ លោកស្រីនិយាយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា អ៊ឹម ចែម បាននិយាយថា "អ្នកទាំងអស់គ្នាត្រូវខិតខំធ្វើការ និងលប់បំបាត់ឱ្យអស់នូវវណ្ណៈមូលធននិយម" ។ តើ លោក ស្រី អាច បញ្ជាក់ បានទេ ?ឆ៖ ចាស មែន គេឱ្យយើងស្រែកអញ្ចើង ខ្ញុំចេះតែស្រែកតាមគេទៅ។ អ៊ឹម ចែម គឺជាអ្នកគ្រប់គ្រងការងារទូទៅនៅទីនោះ [ត្រពាំងថ្ម]។ ខ្ញុំមិនចាំថាគាត់មកជំនួស តាវ៉ាល់ នៅពេលណាណោះទេ។ ពេលប្រជុំខ្ញុំមិនបានឃើញគាត់ទេ ពីព្រោះមានមនុស្សចូលរួមច្រើនណាស់ ប្រហែលរាប់ពាន់នាក់ ហើយខ្ញុំនៅឆ្ងាយណាស់ មិនអាចមើលឃើញគាត់ទេ។ ខ្ញុំដឹងថាគាត់ ជា អ៊ឹម ចែម ពីព្រោះពេលនិយាយពេលសន្និបាត គាត់និយាយថាគាត់ឈ្មោះ យាយ ចែម"]។

649 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929740 ["ដាវ៉ា៖ កាលពេលជំនាន់ដែលអ៊ំធ្វើការនៅត្រពាំងថ្មគ្រប់គ្រងនៅហ្នឹង ឧស្សាហ៍មានប្រតិភូ ឬថ្នាក់លើមជ្ឈិមអីចុះមកមើលដែរ? ចែម៖ ចុះមកមើលដែរ មកមើលខ្ញមជូនទៅ។ ដាវ៉ា៖ ចឹងអ៊ំធ្លាប់ជូនថ្នាក់លើពីណាខ្លះ? ចែម៖ ចិនហើយនឹងអ៊ំខៀវ សំផន ក៏ធ្លាប់មកមើលដែរ។ ដាវ៉ា៖ ចុះ នួន ជា ប៉ុលពតអី? ចែម៖ តា ប៉ុល ពត មិនសូវទេ បើខៀវ សំផនទៅ។ ដាវ៉ា៖ (ខៀវ សំផន) ទៅមើលដល់ទំនប់ហ្នឹងផ្ទាល់? ចែម៖ ចា ទៅមើលដល់ទំនប់ហ្នឹងផ្ទាល់! ដាវ៉ា៖ គាត់មានយោបល់

អីដែរពេលហ្នឹង? ចែមៈ គាត់ឃើញកម្លាំងនៅក្រោមទំនប់ចឹងហើយមានស្រូវមានអី គាត់ថាខំធ្វើទៅទៀត"]។ សូមមើលផង ដែរ ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107043 ["សៈ ពេលដែលធ្វើ ប្រឡាយទឹកអ្នកមីង មានអ្នកធំ មកមើលដែរពេលធ្វើហ្នឹង? អ៊ឹម ចែមៈ មានត្រឹមខេត្ត អី"]។

650 ឯកសារ **D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ31. KH 00976179 សាក្សីជាប្រធានកងចល័តនៃកម្មករប្រមាណ ៣០ នាក់ដែលត្រូវបញ្ជូនទៅធ្វើការនៅត្រពាំងថ្ម និងក្រោយមកស្ពានស្រែងៈ "ដោយសាកូនក្រុមរបស់ខ្ញុំ[នៅត្រពាំងថ្ម]ជាអ្នកមកពីស្រុកព្រះនេត្រព្រះ ហើយគេលួចរត់ទៅស្រុកព្រះនេត្រព្រះ។ ដូច្នេះ យាយ ចែម បានហៅឲ្យខ្ញុំមកយកមនុស្សត្រឡប់ទៅអាងត្រពាំងថ្ម"]។

651 ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.129-133 KH 01049239 [សាក្សីជាកម្មករនៅកងចល័តយុវជនៈ "សៈ តើអ្នកណាជាអ្នកគ្រប់គ្រង យោធាទាំងនោះ? ឆ.129ៈ គណៈស្រុកជាអ្នកគ្រប់គ្រង។ សៈ តើពួកគេស្ថិតនៅក្រោមគណៈស្រុកភ្នំស្រុកហ្នឹង ឬក៏ក្រោមអ្នក ណាទៀតដែរ? ឆ.130ៈ ពួកហ្នឹងគឺនៅក្រោមការត្រួតត្រារបស់គណៈស្រុក។ សៈ បើយាយចែមជាអ្នកគ្រប់គ្រងស្រុក អីចឹង គាត់ជាមេរបស់ពួកយោធាទាំងអស់ ឆ.131ៈ បាទ គាត់ជាមេ។ សៈ បើមានអ្នកធ្វើការចង់រត់ចេញពីកន្លែងហ្នឹង តើគេត្រូវធ្វើ យ៉ាងម៉េចដែរ? ឆ.132ៈ បើគាត់ចង់រត់ទាល់តែដឹងផ្លូវច្បាស់។ ឧទាហរណ៍ៈ បើចង់រត់ទៅថៃ គេត្រូវស្គាល់ផ្លូវទៅច្បាស់។ ស ៈ ហើយបើគេត្រូវបានគេចាប់ តើគេធ្វើយ៉ាងម៉េចដែរ? ឆ.133ៈ បើសិនជាគេចាប់បានអ្នករត់ គេនឹងសម្លាប់ចោលហើយ"]។

652 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929735 ["ចែមៈ ខ្ញុំធ្វើនៅស្រុករបស់ខ្ញុំ ប្រជាជនហ្នឹងខ្ញុំរៀបធ្វើទំនប់ពីរនិងប្រឡាយមួយកាលខ្ញុំនៅហ្នឹង បន្តពីទំនប់ខាង ក្រោមត្រពាំងថ្មមួយ។ ហ្សារីណាៈ ឈ្មោះទំនប់អីគេដែរអ៊ំ? ចែមៈ ឈ្មោះទំនប់ស្ពានស្រែង។ ដារ៉ាៈ ទំនប់ស្ពានស្រែង? ចែមៈ ចា នៅខាងក្រោមត្រពាំងថ្មហ្នឹង។ ដារ៉ាៈ ទំនប់មួយទៀត? ចែមៈ ខ្ញុំទប់ពីរនាមក្នុងឃុំប្រសាទ។ ដារ៉ាៈ រនាម? ចែមៈ ព្រៃ រនាមក្នុងឃុំ (ប្រាសាទ) KH 00929736 ដារ៉ាៈ ហើយយើងត្រូវធ្វើទំនប់? ចែមៈ ចា បានទប់ចឹងទៅ ខែវស្សាឡើងវាពេញ រាបចឹងមក ហើយធ្វើប្រឡាយបង្ហូរជាប់មកទំនប់យើងខាងលើនេះ។ [...] ខ្ញុំទប់អាក្បាល។ យើងជីកប្រឡាយក្បាល ៣០ ម៉ែត្រ និងប្រវែង ១០ គីឡូ ភ្ជាប់ពីអាងត្រពាំងថ្ម រហូតដល់ទៅទន្លេ។ មានត្រីច្រើនណាស៊ើ។ ឥឡូវប្រឡាយហ្នឹងរក្សាមកជាប់ រាល់ថ្ងៃ ត្រង់មើលទៅដល់ខាងកើតភ្នំលាភ ខ្ញុំធ្វើនៅទីនោះពេលនឹង។ ខ្ញុំបានពិភាក្សាផែនការរបស់ខ្ញុំជាមួយប្រជាជន [...] ដា រ៉ាៈ ចុះទំនប់ពី និង ប្រឡាយមួយអ៊ំរំលឹក សង់នៅឆ្នាំណាដែរ? ចែមៈ [...] ១៩៧៨ ពេញមួយឆ្នាំ។ ដារ៉ាៈ ពេញមួយឆ្នាំ? ចែម ៈ ចា"]។ ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107031 ["ប្រឡាយ [នៅ ស្ពានស្រែង] ធ្វើឡើងដោយកម្លាំងប្រជាពលរដ្ឋទាំងអស់"]។

653 ឯកសារ D106/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឹម សឹត ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២ ឆ.3 KH 00800993 [សាក្សីធ្វើការនៅកងចល័តសហការណ៍ៈ "យើងត្រូវបានក្រុមយាយចែមបញ្ជូនឲ្យទៅធ្វើការនៅទីនោះ នៅឆ្នាំ ១៩៧៦។ យាយចែមគឺជាគណៈស្រុក"]។

654 ឯកសារ D119/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ រិន ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.19 KH 01024736 [សាក្សីធ្វើការក្នុងកងពលកុមារនៅ ទំនប់ស្ពានស្រែងៈ "ខ្ញុំធ្លាប់ឮគេនិយាយអំពីយាយចែម ប៉ុន្តែខ្ញុំមិនដឹងថាគាត់មានតួនាទីអ្វី

ទេ។ ខ្ញុំធ្លាប់ឮគេនិយាយថា យាយចែម គឺជាអ្នកចុះមកត្រួតមើលមនុស្សធ្វើការនៅការដ្ឋានទំនប់ ហើយគាត់គឺជាអ្នកកំណត់ការលើកដីឲបាន៣ម៉ែត្រគូបក្នុងមួយថ្ងៃក្នុងម្នាក់។ បើសិនជាយើងលើកមិនរួច គេមិនឲ្យបាយយើងហូបទេ។ ខ្ញុំឮអំពីយាយចែម នៅពេលដែលខ្ញុំធ្វើការនៅស្ពានស្រែង នៅពេលដែលគាត់ចុះមកការដ្ឋាននេះ តែខ្ញុំមិនដែលឃើញគាត់ទេ”]។

655 ឯកសារ D119/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.32 KH 00978912 [សាក្សីជាជាប្រធានកងចល័តដែលធ្វើនៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងប្រឡាយអូរលៀប៖ “បាទ ខ្ញុំធ្លាប់បានឃើញគាត់ចុះមកការដ្ឋានដែរ ហើយជួនកាលគាត់ក៏ជួយរែកដីជាមួយអ្នកធ្វើការនៅទីនោះដែរ។ យាយ ចែម ចុះទៅពិនិត្យមើលការដ្ឋានអូរលៀប”]។ ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ. 27 KH 01024728 [សាក្សីធ្វើការក្នុងកងចល័ត ដែលសាងសងទំនប់ទឹក៖ “ខ្ញុំក៏ធ្លាប់ឮឈ្មោះតាវ៉ាល់ និងយាយចែម ជាអ្នកគ្រប់គ្រងនៅទំនប់អូរលាប តែខ្ញុំមិនដែលឃើញពួកគាត់ទេ”]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.14 KH 00915841 [សាក្សីធ្វើការនៅកងចល័តកុមារ នៅព្រះនេត្រព្រះ៖ “ខ្ញុំធ្លាប់បានឃើញយាយចែម ជាច្រើនដងនៅឯភ្នំលៀប ពីព្រោះនៅពេលនោះ គាត់បានដើរមើលមនុស្សធ្វើការនៅទំនប់អូលៀប ដែលមានទីតាំងខាងកើតភ្នំលៀប”] ឆ.15 KH 00915841 [“នៅសម័យនោះ ខ្ញុំមិនដឹងថា គាត់មានតួនាទីជាអ្វីទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា គាត់ជាអ្នកធំដែលដើរមើលមនុស្សធ្វើការតាមការដ្ឋាននានា។ នៅពេលនោះ គេគ្រប់ៗគ្នា គ្រាន់តែឮឈ្មោះគាត់ គេខ្លាចគ្រប់ៗគ្នា ពីព្រោះគាត់មានអំណាចខ្លាំងណាស់”]។ ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.46-47 KH 01148733 [សាក្សីធ្វើការនៅកងចល័ត៖ “ខ្ញុំធ្លាប់ឃើញគាត់ដើរត្រួតពិនិត្យកន្លែងធ្វើការ [ទំនប់ស្ពានស្រែង និង ប្រឡាយភ្នំលៀប] ប៉ុន្តែនៅពេលនោះខ្ញុំមិនបានឃើញមុខគាត់ច្បាស់ទេ [...] ខ្ញុំគ្រាន់តែឮគេថា យាយចែមៗ ប៉ុន្តែខ្ញុំមិនដឹងមួយណាជាយាយចែមទេ ព្រោះពេលនោះគឺមានមនុស្សមួយក្រុមប្រហែលជា ៦ ទៅ៧នាក់ដើរត្រួតពិនិត្យការងារ”]។ ឯកសារ D106/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឹម សឺត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ឆ.15 KH 00800995 [សាក្សីធ្វើការនៅកងចល័តសហការណ៍៖ “ស៖ តើពួកនិរតីដែលជាក្រុមរបស់យាយចែម ជាអ្នកគ្រប់គ្រងការងារនៅការដ្ឋាននោះឬ? ឆ.១៥៖ បាទ”] ឆ.27 KH 00800996 [“ស៖ តាមអ្វីដែលលោកចាំបាន តើលោកគិតថាយាយចែមជាអ្នកគ្រប់គ្រងរួមនៅការដ្ឋានព្រៃរនាមឬ? ឆ.27៖ បាទ”] ឆ.23-24 KH 00800996 [“ស៖ តើលោកមានបានឃើញយាយចែម ទៅ ការដ្ឋានព្រៃរនាមដែរឬទេ? ឆ.23៖ បាទ គាត់ធ្លាប់ទៅពិនិត្យមើលការងារនៅម្តុំបឹងខ្លាស្លាប់ ដែលមានទីតាំងនៅប៉ែកខាងកើតទំនប់ដែលខ្ញុំកំពុងធ្វើការ។ ស៖ តើយាយចែម ធ្វើអ្វីទៅ នៅពេលដែលគាត់ទៅពិនិត្យមើលការដ្ឋាននោះ? ឆ.24៖ គាត់នៅឆ្ងាយពីកន្លែងដែលខ្ញុំធ្វើការ ហើយខ្ញុំមិនអាចមើលគាត់ធ្វើអ្វីច្បាស់ទេ ព្រោះខ្ញុំខ្លាចមិនហ៊ានមើលគាត់ទេ តែខ្ញុំអាចស្គាល់ថាគាត់គឺជាយាយចែម”]។

656 ឯកសារ D119/93 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.19 KH 00976167 [សាក្សីធ្វើការនៅអូរលៀប៖ “បាទ ខ្ញុំធ្លាប់ឃើញ យាយ ចែម នៅទំនប់អូរលៀប។ នៅពេលនោះគាត់បានទៅកោះប្រជុំដោយហៅគ្រប់តំណាងស្រុកទាំងអស់ នៅក្នុងតំបន់ ៥ឲ្យចូលរួម”] ឆ.23 KH 00976167 [“ខ្ញុំចាំមិនច្បាស់ទេ នៅពេលនោះប៉ុន្តែតាមខ្ញុំចាំ គឺខ្ញុំបានឃើញយាយចែមតែពីរដងគត់នៅការដ្ឋានទំនប់អូរលៀប”]។

657 ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234199 ["មុននឹងចាប់ផ្តើមធ្វើទំនប់នឹង ខ្ញុំទៅសុំរហូតដល់ តា ប៉ុល ពត ឱ្យជួយដោះស្រាយ។ គាត់ដឹងក្រណាត់ ដឹកត្រី ដឹកស្អីៗមកមិនខ្វះទាំងឡានៗ យកមកចាក់ឱ្យខ្ញុំនៅស្រុកព្រះនេត្រព្រះព្រោះខ្ញុំទៅថ្មី"]។

658 ឯកសារ D219/264.1 ប្រតិចារិកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 1107040 ["មាត់ប្រឡាយ ៣០ ម៉ែត្រ [ស្ពាន ស្រែង]។ ល្មមតែយើងដោះស្រាយទឹកជំនន់បានរវាងពីរឃុំ ត្រូវដោះស្រាយឱ្យបាន។ នៅក្នុងស្រុកហ្នឹង បើមានប្រឡាយពីរ ខ្ញុំមានគម្រោងជាមួយបងប្អូនប្រជាជនដីកមួយទៀត ប៉ុន្តែវាធ្វើមិនទាន់ដល់ហើយប្រទេសជាតិក៏ច្របូកច្របល់"]។

659 ឯកសារ D119/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.15 KH 00894503 [សាក្សីជាកម្មករក្នុងកងចល័ត នៅព្រះនេត្រព្រះ៖ "តាមខ្ញុំចាំ [មន្ទីសន្តិសុខភ្នំត្រយោង]ត្រូវបានបង្កើត ឡើងប្រហែលក្នុងខែ មិថុនា ឬ កក្កដា ឆ្នាំ ១៩៧៧ នៅពេលដែលក្រុមយាយ ចែម មកដល់ស្រុកព្រះនេត្រព្រះ"]។

660 ឯកសារ D219/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.112 KH 01029680 [សាក្សីដែលជាសមាជិកនៃគណ:ស្រុកព្រះនេត្រព្រះ៖ "កន្លែងវាយថ្មនោះ ស្ថិតនៅភ្នំត្រយោង ហើយគ្រប់គ្រងដោយយាយចែម ដែលជាកម្មាភិបាលមកពីភូមិភាគនិរតី"] ឆ.114 KH 01029680 ["ខ្ញុំមិនស្គាល់អ្នកគ្រប់គ្រងកន្លែងវាយថ្មនៅភ្នំត្រយោងទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាគឺជាកម្លាំងរបស់យាយចែមទាំងអស់"]។ ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.7 KH 01043194 [សាក្សីជាប្រធានកងចល័ត ដែលក្រោយមកក្លាយទៅជាប្រធានមន្ទីសន្តិសុខនៅ ភ្នំត្រយោង និងកន្លែងវាយថ្ម៖ "ស៖ តើនរណាជាអ្នកបញ្ជាលោកឱ្យទៅធ្វើការនៅទីនោះ [នៅភ្នំត្រយោង]? ឆ.7៖ គឺយាយចែម។ យាយចែម ទទួលបញ្ជាពីថ្នាក់លើបន្តមកទៀត"]។ ឯកសារ D5/1246 [redacted] រង [redacted] KH 01036169 [សាក្សីធ្វើការនៅ ភ្នំត្រយោង៖ "នៅ ឆ្នាំ ១៩៧៨ មិត្តណុបជាមេកង បានបញ្ជូនឱ្យនាងខ្ញុំមកលើកភ្លឺស្រែនៅវាលគោកត្រាច ខាងត្បូងអាងត្រយោង នៅឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ។ ពេលនោះមិត្តចែម បញ្ជាឱ្យពួកខ្ញុំជីករណ្តោះរបៀបដូចលេនដ្ឋានកងទ័ព ជីករួច វាបញ្ជាឱ្យពួកខ្ញុំកាប់ឫស្សី បិទឫស្សី ធ្វើចំនួលស្រួចៗដាក់ក្នុងលេនដ្ឋាន"]។

661 ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 0091764 [សាក្សីជាប្រធានមន្ទីសន្តិសុខនៅ ភ្នំត្រយោង៖ "មន្ទីអប់រំនោះប្រហែល ២ ហិចតា នៅជើងភ្នំខាងជើង ជាប់ផ្លូវចេញពីភ្នំលៀបទៅ"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.151 KH 00953040 [សាក្សីជា ប្រធានមន្ទីសន្តិសុខនៅ ភ្នំត្រយោង៖ "ពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឱ្យកងចល័តរបស់ខ្ញុំប្រមូលឈើពីស្វាយ ពីខេត្តបាត់ដំបង យកទៅធ្វើផ្ទះ។ ខ្ញុំនៅទីនោះធ្វើផ្ទះជិតដប់ខ្នង ដោយលើកជាជួរអមតាមផ្លូវចន្លោះពីភ្នំត្រយោង និងភ្នំលៀប។ ផ្ទះនីមួយៗមានទំហំប្រាំគុណប្រាំមួយម៉ែត្រ"]។ ឯកសារ D106/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឆ.12 KH 00801001 [សាក្សីជាអ្នកយាយនៅមន្ទីសន្តិសុខភ្នំត្រយោង៖ "មន្ទីសន្តិសុខនោះធំ កន្លែងដាំដំឡូង និងពោត នៅជុំវិញបរិវេណនោះតែម្តង។ ហើយកន្លែងវាយថ្មស្ថិតនៅក្បែរនោះដែរ"]។

662 ឯកសារ D5/903 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នូ ខាំ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ KH 00974438 [សាក្សីជាអ្នកជាប់ឃុំខ្លួននៅភ្នំត្រយោង៖ "នៅឆ្នាំ ១៩៧៨ មិត្តភន់ បានជម្លៀសខ្ញុំឱ្យទៅនៅភ្នំត្រយ៉ូង ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ [...] ឱ្យតែពេលយាយថែមទៅត្រួតពិនិត្រម្តងៗ ពួកទាហានហាមកងចល័ត មិនឱ្យដើររហេតរហូតទៅណាមកណានោះទេ ហើយនៅតាមខ្ទមនីមួយៗ"]។ ឯកសារ D219/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.30 KH 01040788 [សាក្សីជាអ្នកជាប់ឃុំខ្លួន៖ "តាមខ្ញុំស្មាន មនុស្សដែលធ្វើការនៅតាមវាលនោះ គឺមានចំនួនប្រហែលពី ២០០-៣០០នាក់"]។

663 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.65 KH 00996500 [សាក្សីធ្វើការនៅកងកុមារ ក្នុងតំបន់ចល័តទី ៥៖ "គេបង្ខំឱ្យខ្ញុំរៀបការជាមួយប្តីរបស់ខ្ញុំ។ ខ្ញុំមិនដែលស្គាល់ប្តីខ្ញុំពីមុនទេ។ នៅក្នុងពិធីរៀបការនោះគឺមានមនុស្ស៨៥គូ គឺប្រហែលជាក្នុងឆ្នាំ ១៩៧៧] ឆ.66 KH 00996500 ["ចា យាយ ថែមបានមកដល់] ឆ.67 KH 00996500 ["ខ្ញុំរៀបការនៅក្នុងភូមិគោកកណ្តាល ឃុំស្ពានស្រែង ស្រុកភ្នំស្រុក] ឆ.68 KH 00996500 ["នៅពេលនោះ ប្តីខ្ញុំបានស្នើទៅប្រធានកង ឬប្រធានក្រុម ហើយប្រធានកងប្រធានក្រុមបានធ្វើសំណើទៅថ្នាក់លើប្តទៅទៀត។ ខ្ញុំបានចាប់ដៃជាមួយនឹងប្តីខ្ញុំនៅថ្ងៃទី ៣០ ប៉ុន្តែខ្ញុំមិនដឹងថានៅខែណាទេ] ឆ.69 KH 00996500 ["ខ្ញុំមិនដឹងច្បាប់អំពីតួនាទីប្រាកដរបស់ យាយ ថែម ទេ] ឆ.70 KH 00996500 ["យាយ ថែម ជាអ្នកគ្រប់គ្រងនៅក្នុងពិធីរៀបការនោះទាំងមូល ដោយពេលនោះ គាត់បានស្រែកឱ្យយើងចាប់ដៃគ្នា] ឆ.71 KH 00996500 ["ចាស គាត់នៅ [ទីនោះ] ឆ.72 KH 00996501 ["ពីព្រោះ យាយ ថែម ជាអ្នកប្រាប់យើងឱ្យចាប់ដៃគ្នាជាប្តីប្រពន្ធ នៅពេលនោះ]។

664 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.76 KH 00996501 [សាក្សីធ្វើការនៅកងកុមារ ក្នុងតំបន់ចល័តទី ៥ "នៅពេលនោះ ខ្ញុំមានអាយុ ១៥ ឆ្នាំហើយ]។ សូមមើលផងដែរ KH 00996490 ["ថ្ងៃខែឆ្នាំកំណើត៖ ១២ ខែ មីនា ១៩៥៨"]។

665 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.73 KH 00996501 [សាក្សីធ្វើការនៅកងកុមារ ក្នុងតំបន់ចល័តទី ៥៖ "ស៖ នៅក្នុងទំរង់បែបបទពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកកសារ D5/853) លោកស្រីបាននិយាយថា "ខ្ញុំបានបដិសេធមិនព្រមរៀបការជាមួយនឹងប្តីខ្ញុំទេ"។ តើត្រឹមត្រូវទេ? ឆ.73៖ ចាស ខ្ញុំបានបដិសេធ ប៉ុន្តែគេបានគំរាមខ្ញុំថា បើខ្ញុំមិនព្រមរៀបការទេ គេនឹងយកខ្ញុំទៅវៃចោល។] ឆ.74 KH 00996501 ["គឺអង្គការថ្នាក់លើ [ជាអ្នកគំរាម]។ ខ្ញុំមិនស្គាល់ឈ្មោះគេទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាមនុស្សនោះជាប្រុស"]។

666 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.77 KH 00996501 [សាក្សីធ្វើការនៅកងកុមារ ក្នុងតំបន់ចល័តទី ៥៖ "ស៖ ក្រោយពេលលោកស្រីបានរៀបការរួច តើមាននរណាមកតាមដានមើលោកស្រី ពេលរួមដំណេកជាមួយគ្នា នៅពេលយប់ដែរ ឬទេ? ឆ.77៖ ចាស មានតាមដាន គឺនៅពេលដែកប្តីប្រពន្ធណាមិនព្រមរួមដំណេកជាមួយគ្នា គេនឹងយកទៅសម្លាប់ចោលហើយ] ឆ.80 KH 00996502 ["ស៖ តើនរណាជាអ្នកបញ្ជាឱ្យយកស្ត្រីដែលមិនរួមដំណេកទាំងនោះយកទៅសម្លាប់? ឆ.80៖ តាមខ្ញុំយល់ គឺ

យាយ ថែម ជាអ្នកបញ្ជាឱ្យប្រធានកងប្រាប់ទៅពួកឈ្លបដើម្បីតាមដានអ្នកដែលរៀបការទាំងនោះ និងយកពួកទាំងនោះទៅសម្លាប់ នៅពេលដែលពួកគេមិនព្រមរួមដំណេក] ឆ.81 KH 00996502 [“សៈ ហេតុអ្វីបានជាលោកស្រីដឹងថា យាយ ថែម ជាអ្នកបញ្ជាឱ្យឈ្លបតាមដានពួកគេទាំងនោះ? ឆ.81៖ ប្រធានក្រុមរបស់ខ្ញុំជាអ្នកប្រាប់ខ្ញុំអំពីរឿងនេះ”] ឆ. 82 KH 00996502 [“គេយកទៅសម្លាប់នៅក្នុងព្រៃ នៅក្បែរភូមិគោកកណ្តាល”]។

667 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.77 KH 00996501 [សាក្សីធ្វើការនៅកងកុមារ ក្នុងតំបន់ចល័តទី ៥៖ “ក្រោយពេលលោកស្រីបានរៀបការរួច តើមាននរណាមកតាមដានមើលោកស្រី ពេលរួមដំណេកជាមួយគ្នា នៅពេលយប់ដែរ ឬ ទេ? ឆ.77៖ ចាស មានតាមដាន គឺនៅពេលដែកប្តីប្រពន្ធណាមិនព្រមរួមដំណេកជាមួយគ្នា គេនឹងយកទៅសម្លាប់ចោលហើយ] ឆ.78 KH 00996501 [“សៈ លោកស្រីនៅចាំទេថា តើមានប្តីប្រពន្ធណាដែលគេយកទៅសម្លាប់ចោល ដោយសារតែពួកគេមិនព្រមរួមដំណេកជាមួយគ្នាទេ។ ឆ.78៖ ចាស នៅក្នុងកងចល័តរបស់ខ្ញុំមានស្ត្រីពីរបីនាក់ត្រូវបានឈ្លបយកទៅសម្លាប់ ដោយសារែមិនព្រមរួមដំណែកជាមួយគ្នា] ឆ.79 KH 00996501 [“សៈ ស្ត្រីពីរបីនាក់ដែលមិនព្រមរួមដំណេកជាមួយគ្នានោះ គឺជាមនុស្សដែលស្ថិតនៅក្នុងរៀបការជាមួយនឹងលោកស្រ្រនៅពេលនោះ មែនទេ? ឆ.79៖ ចាស ត្រឹមត្រូវណាស់]។

668 ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.51 KH 01148734 [សាក្សីជាអ្នកធ្វើការនៅកងចល័ត “បាទ ខ្ញុំធ្លាប់ឃើញ[ការបង្ខំឱ្យរៀបការ]ព្រោះមានមនុស្សនៅក្នុងកងរបស់ខ្ញុំត្រូវគេបង្ខំឱ្យរៀបការ។ ហេតុការណ៍នេះកើតឡើងនៅក្រោមការគ្រប់គ្រងរបស់យាយថែម] ឆ.52 KH 01148734 [“ការរៀបការនោះ មិនមែនជាពិធីរៀបការធំដុំទេ គឺវាដូចជាការប្រជុំធម្មតាមួយ ហោយគេហៅមនុស្សប្រុស និងមនុស្សស្រី មកប្តេជ្ញាក្នុងការយកគ្នាជាប្តីប្រពន្ធ។ យាយថែម មិនបានចូលរួមដឹកនាំពិធីរៀបការនេះទេ គឺមានតែប្រធានកង តែប៉ុណ្ណោះដែលចូលរួម”]។ សូមមើលផងដែរ ឯកសារ D119/145 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិប គឹមលន់ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឆ.90 KH 01022036 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅស្រុកព្រះនេត្រព្រះ៖ “ក្រោយពិចប់ធ្វើការនៅកងតម្បាញ ខ្ញុំត្រូវបញ្ជូនត្រឡប់មកភូមិវិញ។ ក្រោយមកគេឲ្យ ទៅលើកទំនប់វន្ទះបាញ់ ហើយបន្ទាប់មកគេឲ្យមកធ្វើស្រែ នៅត្រពាំងអ្នកតា។ នៅពេលនោះ គឺមានខាងយុវជនគេបានស្នើអង្គការ ហើយខ្ញុំក៏យល់ព្រមរៀបការ។នៅពេលនោះ គឺមាន២៤ គូ បានរៀបការក្នុងពេលតែមួយជាមួយខ្ញុំ”] ឆ.92 KH 01022036 [“ត្រពាំងអ្នកតាស្ថិតនៅខាងត្បូងភ្នំស្រេះនៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ”] ឆ.93 KH 01022036 [“សៈ មុនថ្ងៃរៀបការរបស់លោកស្រី តើលោកស្រីស្គាល់បុរសដែលស្នើសុំរៀបការជាមួយលោកស្រីដែរឬទេ? ឆ.93៖ ខ្ញុំមិនដែលស្គាល់គាត់ពីមុនទេ។ ខ្ញុំគ្រាន់តែឮឈ្មោះគាត់តែប៉ុណ្ណោះ”] ឆ.96 KH 01022037 [“គេរៀបការឲ្យខ្ញុំនៅពាក់កណ្តាលឬចុងឆ្នាំ១៩៧៨”] ឆ. 99 KH 01022037 [“សៈ ក្នុងចំណោមយុវជន យុវនារីដែលគេរៀបការឲ្យនោះ តើមានអ្នកណាបដិសេធមុនព្រមរៀបការដែរឬទេ? ឆ.99៖ មិនមានទេ គឺគេព្រមទាំងអស់គ្នា”] ឆ.101 KH 01022037 [“សៈ តើលោកស្រីមានដឹងថា មានពួកឈ្លបតាមដានមើលគូស្រករទាំងនេះ ក្រោយពេលរៀបការហើយដែរឬទេ? ឆ.101៖ ចាស ប្រហែលជាមាន”]។ ឯកសារ D5/865 ទំរង់បែបបទព័ត៏មានអំពីជនរងគ្រោះ រឿង សារួន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១១ KH 00957090 [សាក្សីជាសមាជិកកងខចល័តក្នុង “កម្លាំងដំបូង” ឧទា. អ្នកធ្វើការខ្លាំងជាងគេ៖ “នៅចុងឆ្នាំ ១៩៧៧ ខ្ញុំត្រូវគេបង្ខំឱ្យរៀបការ ១០០គូ

នៅស្វាយស៊ីសុផន ដែលមានតាលស់ [...] តាមខ្ញុំដឹង អ្នកដឹកនាំសម័យនោះមានឈ្មោះតាវ៉ាល់ តាហាក់ តាផាំ តាញ៉ឹម តាជាល ឯយាយថែមជាអ្នកដឹកនាំតំបន់"]។

669 ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.51 KH 01148734 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "បាទ ខ្ញុំធ្លាប់ឃើញ[ការបង្ខំឱ្យរៀបការ]ព្រោះមានមនុស្សនៅក្នុងកងរបស់ខ្ញុំត្រូវគេបង្ខំឱ្យរៀបការ។ ហេតុការណ៍នេះកើតឡើងនៅក្រោមការគ្រប់គ្រងរបស់យាយថែម] ឆ.52 KH 01148734 ["ការរៀបការនោះ មិនមែនជាពិធីរៀបការធំដុំទេ គឺវាដូចជាការប្រជុំធម្មតាមួយ ហោយគេហៅមនុស្សប្រុស និងមនុស្សស្រី មកប្តេជ្ញាក្នុងការយកគ្នាជាប្តីប្រពន្ធ។ យាយថែម មិនបានចូលរួមដឹកនាំពិធីរៀបការនេះទេ គឺមានតែប្រធានកង តែប៉ុណ្ណោះដែលចូលរួម"] ឆ.53 KH 01148734 ["ប្រសិនបើមានអ្នកណាម្នាក់បដិសេធមិនរៀបការនៅពេលនោះ គឺប្រធានកងរយនឹងចោទប្រកាន់អ្នកនោះថាជាខ្មាំង"]។

670 ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.180 KH 01049244 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តយុវជន៖ "ស៖ តើមានអ្នកធ្វើការនៅត្រពាំងថ្មប៉ុន្មាននាក់ដែលត្រូវគេបង្ខំឱ្យរៀបការ? ឆ.180៖ មានច្រើនណាស់ ខ្ញុំចាំមិនអស់ទេ"] ។ ឆ.182 KH 01049244 ["ប្រហែលជាគេយកទៅវាយចោល [ប្រសិនបើពួកគេបដិសេធ]។ ខ្ញុំមិនច្បាស់ទេ។ តែភាគច្រើនគេមិនហ៊ានប្រកែកទេ។ បងស្រីខ្ញុំរៀបការពេលហ្នឹង រហូតមកដល់ឥឡូវ"]។ ឆ.191-193 KH 01049245-01049246 ["បាទ គេតម្រូវឱ្យរួមដំណេកជាមួយគ្នាមួយថ្ងៃ ឬក៏ពីរថ្ងៃ ហើយបន្ទាប់មក គេឱ្យអ្នកទាំងនោះត្រឡប់ទៅកន្លែងរៀងៗខ្លួន"]។ ឆ.192 KH 01049246 ["ពេលហ្នឹង គេឱ្យពួកឈ្លបតាមលបមើលថាតើគូហ្នឹងរួមដំណេកជាមួយគ្នា ឬក៏ អត់"]។ ឆ.193 KH 01049246 ["គេនឹងយកអ្នកទាំងនោះទៅកសាង [ប្រសិនបើពួកគេប្រកែកមិនរួមដំណេក"]។

671 ឯកសារ D118/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.111 KH 00998738 [សាក្សីគឺជាកម្មាភិបាល និងបានរៀបការជាមួយប្រធានឃុំពេល៖ "ថ្នាក់ឃុំជាអ្នកសរសេរឈ្មោះបុរសស្ត្រីដែលត្រូវរៀបការ ហើយបញ្ជូនទៅថ្នាក់តំបន់ ដើម្បីសម្រេចថាតើត្រូវរៀបការប៉ុន្មានគូម្តង។ ខ្ញុំថ្នាក់ក្រោមពុំហ៊ានសម្រេចចិត្តចំពោះបញ្ហានេះទេ។ អ្នកដែលស្រលាញ់គ្នាគេមកប្រាប់យើង ហើយយើងសរសេរឈ្មោះបញ្ជូនទៅតំបន់ ហើយអ្នកដែលមិនព្រមគឺប្រាប់ថាមិនព្រម យើងនឹងឆូតឈ្មោះចោល"]។ ឆ.111 KH 00998738 ["ស៖ យើងមានភស្តុតាង ហើយដឹងថាប្រជាជនពុំមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសប្តីប្រពន្ធនោះទេ បក្សគឺជាអ្នកបង្ខំប្រជាជនឱ្យរៀបការ តើនេះជាការពិតដែរឬទេ? ឆ.112៖ បក្សជាអ្នកសម្រេច ប៉ុន្តែគេរៀបចំឱ្យប្រជាជនថ្មីរៀបការជាមួយនឹងប្រជាជនថ្មី ចំណែកប្រជាជនចាស់ត្រូវរៀបការជាមួយនឹងអ្នកចាស់។ យើងអាចនិយាយថា បង្ខំឱ្យរៀបការបាន ព្រោះបក្សជាអ្នកសម្រេចនៅក្នុងការរៀបការនេះ។ បើសិនជាប្រជាជនថ្មីត្រូវរៀបការជាមួយនឹងប្រជាជនចាស់ ហើយបើមានអ្នកណាបដិសេធ គេនឹងឆូតឈ្មោះចេញ ព្រោះអ្នកខ្លះមានប្រវត្តិរូបមិនល្អ"]។ ឆ.113 KH 00998738 ["ស៖ តើការរៀបការដោយបង្ខំនេះ ឬការកំណត់ឱ្យរៀបការនេះ ថ្នាក់មជ្ឈិមកំណត់មកថ្នាក់ភូមិភាគ ហើយមកថ្នាក់តំបន់ រួចមកថ្នាក់ស្រុកឃុំតែម្តង ឬក៏ការរៀបការនេះ គឺថ្នាក់ឃុំស្រុកជាអ្នកសម្រេច? ឆ.113៖ ការរៀបការនេះគឺមិនមែនថ្នាក់មជ្ឈិមអ្វីនោះទេ គឺថ្នាក់ឃុំស្រុកជាអ្នករៀបចំ"]។

672 ឯកសារ D219/455 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូរ ចាន់សារ៉េត ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឆ.22 KH 01129805 [សាក្សីគឺជាកម្មករកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ ៖ "កម្មាភិបាលណាដែលស្នើសុំរៀបការជាមួយនារី ១៧ មេសា គឺចាត់ទុកជាជនក្បត់អង្គការ ហើយនឹងត្រូវសម្លាប់ចោល"]។

673 ឯកសារ D119/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឆ.108 KH 00979416 [អ្នកភូមិភាគនិរតីដែលបានមកដល់ភូមិភាគពាយ័ព្យក្នុងឆ្នាំ ១៩៧៧ ហើយធ្វើការនៅតាមវាលស្រែនៅស្វាយស៊ីសុផុន៖ "បងៗនារី [នៅក្នុងកងរបស់គាត់] បានចូលរួមប្រជុំជាមួយ យាយ ចែម នៅស្វាយ។ នៅក្នុងកិច្ចប្រជុំយាយ ចែម តែងតែនិយាយជំរុញឲ្យបងៗនារីរៀបការជាមួយយុវជន។ ប៉ុន្តែបងៗនារីទាំងនោះបានបដិសេធមិនព្រមការតាមសំណើរបស់ យាយ ចែម ទេ ជួនកាលមានបងៗនារីខ្លះបានរត់ពួននៅក្នុងចំការអំពៅ ពីព្រោះយុវជនដែលត្រូវរៀបការជាមួយពួកគាត់ ភាគច្រើនជាយុវជនពិការជើង និងមិនធ្លាប់ជួបមុខគ្នាពីមុន"]។

674 ឯកសារ D119/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រុំ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ឆ.108 KH 00979416 [អ្នកភូមិភាគនិរតីដែលបានមកដល់ភូមិភាគពាយ័ព្យក្នុងឆ្នាំ ១៩៧៧ ហើយធ្វើការនៅតាមវាលស្រែនៅស្វាយស៊ីសុផុន៖ "បងៗនារី [នៅក្នុងកងរបស់គាត់] បានចូលរួមប្រជុំជាមួយ យាយ ចែម នៅស្វាយ។ នៅក្នុងកិច្ចប្រជុំយាយ ចែម តែងតែនិយាយជំរុញឲ្យបងៗនារីរៀបការជាមួយយុវជន។ ប៉ុន្តែបងៗនារីទាំងនោះបានបដិសេធមិនព្រមការតាមសំណើរបស់ យាយ ចែម ទេ ជួនកាលមានបងៗនារីខ្លះបានរត់ពួននៅក្នុងចំការអំពៅ ពីព្រោះយុវជនដែលត្រូវរៀបការជាមួយពួកគាត់ ភាគច្រើនជាយុវជនពិការជើង និងមិនធ្លាប់ជួបមុខគ្នាពីមុន"]។ ឆ.110 KH 00979417 ["ចាស បើសិនមានអ្នកណាមិនគោរពតាមសំណើនោះ ពួកគេទាំងនោះនឹងត្រូវចាប់ខ្លួន។ នៅពេលនោះ ខ្ញុំបានឮពួកបងៗនារីនៅក្នុងកងជាមួយខ្ញុំ ដែលយាយ ចែម ស្នើឲ្យរៀបការនោះ បានប្រជុំនិយាយគ្នាអំពីការរត់គេចខ្លួន"]។

675 ឯកសារ D219/174 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.70 KH 01065993 [សាក្សីធ្វើការនៅក្នុងកងចល័តភូមិនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ខ្ញុំធ្លាប់ឮរឿងរំលោភនៅចំការគរ ដោយសារខ្ញុំបានឮអ្នកទោសស្រីម្នាក់យំ ហើយបានប្រាប់ខ្ញុំថា គេរំលោភលើនារី ហើយក្រោយមកនារីម្នាក់នោះត្រូវបានគេសម្លាប់"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.159 KH 01049242 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តយុវជន៖ "នៅពេលនោះ មានស្រីពីរនាក់ឈ្មោះ ឡា និងធុំ ជាអ្នកមកពីស្រុកព្រះនេត្រព្រះ។ គាត់ធ្វើពេទ្យទាំងពីរនាក់នៅក្នុងកងចល័តរបស់ខ្ញុំ។ ហើយពួកគាត់ត្រូវបានតា ពាល់ ដែលមកពីនិរតី និងគ្នាគាត់ម្នាក់ទៀតយកទៅសម្លាប់។ ខ្ញុំមិនបានឃើញការសម្លាប់នោះដោយផ្ទាល់ភ្នែកទេ តែអ្នកនៅកងជាមួយខ្ញុំបានប្រាប់ខ្ញុំថា សាកសពស្ត្រីទាំងពីរនាក់នោះស្លាប់ទាំងរាងកាយអាក្រាត។ កន្លែងសម្លាប់នោះនៅមិនដល់កន្លះគីឡូម៉ែត្រពីកន្លែងធ្វើការយើងទេ។ ដោយសាររាងកាយអាក្រាត យើងយល់ថា អ្នកទាំងពីរនោះត្រូវបានគេរំលោភមុនសម្លាប់"]។ ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្ណែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.41 KH 01066323 ["ស៖ តើលោកដែលធ្លាប់ដឹង ឬឮអំពីការរំលោភស្ត្រីដែរឬទេ នៅក្នុងស្រុកព្រះនេត្រព្រះ? ឆ.41៖ ខ្ញុំធ្លាប់ឮគេនិយាយថា មានស្ត្រីធ្វើការនៅតាមការដ្ឋានចម្ការកប្បាស ត្រូវបានគេរំលោភ ប៉ុន្តែខ្ញុំមិនដែលបានឃើញផ្ទាល់ភ្នែកទេ។ ចម្ការកប្បាសមានពីរកន្លែង ទី១ នៅជប់វារី និងទី២ នៅភ្នំកងវ៉ា នៅស្វាយស៊ីសុផុន ប៉ុន្តែខ្ញុំមិនដឹងថា ការរំលោភនោះ កើត

ឡើងនៅទីកន្លែងណាមួយទេ"]។ ឯកសារ D219/13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.50 KH 01025649 [សាក្សីគឺជាកម្មករកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ចាស ខ្ញុំដឹង។ នៅពេលដែលខ្ញុំធ្វើការនៅទំនប់ព្រៃមាន់ មានអ្នកចម្រៀងម្នាក់ឈ្មោះ ខ្លូត សាម៉េត ដែលជាអ្នកធ្វើការជាមួយខ្ញុំ ហើយបានដេកទល់ក្បាលជាមួយខ្ញុំ ត្រូវបានគេចាប់យកទៅសម្លាប់ចោលនៅពេលយប់ ដោយសារតែគាត់បាននិយាយថា សម្រុកតែធ្វើការ ហេតុអ្វីបានជាមិនឱ្យយើងសម្រុកហូបបាយផង។ លុះព្រឹកឡើង ខ្ញុំឮសួរគេនិយាយខ្សឹបខ្សៀវគ្នាថា មុនពេលសម្លាប់គាត់ត្រូវបានគេរំលោភជាច្រើននាក់"]។

676 ឯកសារ D118/230 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួន ប៊ុន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.126 KH 00985477 [សាក្សីធ្វើការនៅជិតវត្តចម្ការខ្នុរ៖ "ស៖ នៅក្នុងបទសម្ភាសន៍ដដែល សម្រាប់លោកផ្ទាល់ លោកត្រូវគេឱ្យមើលការខុសត្រូវម៉ាស៊ីន ពេលដែលពួកនិរតីមកដល់ លោកត្រូវគេបញ្ជូនទៅលត់ដំ១ខែ។ តើត្រឹមត្រូវដែរឬទេ? ឆ.126៖ បាទ"]។ ឆ.127 KH 00985477 ["ស៖ តើលោកត្រូវគេបញ្ជូនទៅលត់ដំនៅកន្លែងណា? ឆ.127៖ ដំបូងខ្ញុំនៅសហករណ៍កណ្តាល បន្ទាប់មកពួកនិរតីបញ្ជូនទៅលត់ដំនៅសហករណ៍ទឹកថ្លា"]។

677 ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ -068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045303 [OCIJ-068 (ទុំ សឿន - ប្រធានមន្ទីរសន្តិសុខភ្នំត្រយោង)៖ "លិខិតខ្លះបញ្ជាក់ប្រាប់ថា ថ្ងៃនេះមានគេបញ្ជូនមនុស្សពីសហករណ៍ ដែលត្រូវរៀបចំទទួល និងតាមដានពួកគេ។ ពេលខ្លះ គឺដើម្បីឱ្យខ្ញុំរាយការណ៍ពីចំនួនកម្លាំង និងស្នើសុំសម្ភារៈ និងម្ហូបអាហារ។ ខ្ញុំធ្លាប់បានប្រជុំនៅសាលា (រៀនសូត្រ) ជាមួយគាត់រៀងរាល់បីទៅប្រាំខែ ដែលនាពេលនោះ គាត់ណែនាំពីការដោះស្រាយជីវភាព គ្រប់គ្រងកម្លាំង ការណែនាំកុំឱ្យពួកខ្ញុំហូបចុកលើសពីប្រជាជន ក៏ដូចជាកុំឱ្យផ្តល់របបហូបលើសពីកន្លែងផ្សេង"]។ ឯកសារ D6.1.75 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00978502 ["អ្នកមិនធ្វើគឺត្រូវតែខ្លាចខ្ញុំ ខ្ញុំហៅមករៀន ហៅមកប្រជុំ ហៅមកណែនាំ"]។ ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.42 KH 01114731 [សាក្សីគឺជានីរសាររបស់ អ៊ឹម ចែម៖ "ការប្រជុំអប់រំទាំងអស់ ក៏ត្រូវធ្វើនៅផ្ទះយាយ ចែម នៅក្នុងភូមិភ្នំលៀបដែរ។ ខ្ញុំមិនដឹងថា គាត់បញ្ជូនមនុស្សទៅណាទេ"]។

678 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.222 KH 00953050 [សាក្សីគឺជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង ៖ "សហករណ៍ពិភាក្សាផ្ទាល់ជាមួយ យាយ ចែម ថាតើត្រូវចាប់ ឬមិនចាប់។ យាយ ចែម ជាអ្នកសម្រេចថា បើមិនអាចអប់រំនៅក្នុងសហករណ៍បាន ត្រូវបញ្ជូនទៅមន្ទីរអប់រំ"]។

679 ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឆ.12 KH 00895169 [សាក្សីគឺជាប្រធានកងយុវជននៅជប់៖ "តាមពិត គេមិនប្រាប់ខ្ញុំថា ខ្ញុំត្រូវចាប់ខ្លួននោះទេ។ គេប្រាប់ខ្ញុំថា ខ្ញុំត្រូវទៅរៀនសូត្រ។ គេមិនបានចាប់ចងខ្ញុំទេ។ ខ្ញុំបានទទួលសំបុត្រមួយពីរយាយ ចែម ដែលជាសំបុត្រសរសេរដោយដៃ ដោយមានចុះហត្ថលេខា និងឈ្មោះ ចែម តែមិនមានបោះត្រាទេ។ ក្នុងសំបុត្រនេះ គេសរសេរថា ស្នើសមមិត្ត ទី និងសមមិត្ត សាមុន ឡើងមករៀនសូត្រនៅមន្ទីរភ្នំលៀប...។ សំបុត្រនេះ ជាក្រដាសតូចមួយសន្លឹក ដែលសរសេរដោយដៃ ហើយសំបុត្រនេះត្រូវបានប្រគល់មកឱ្យខ្ញុំ តាមរយៈឈ្មោះ ភន ដែលបានជិះសេះយកសំបុត្រនោះមក"]។

680 ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឆ.15 KH 00895169 [សាក្សីគឺជាប្រធានកងយុវជននៅជប់៖ "ពេលទៅដល់ភ្លាម ខ្ញុំមិនឃើញយាយ ចែម ទេ។ បន្តិចក្រោយមក គាត់បានមកដល់។ គាត់បានយកសំបុត្រពីខ្ញុំវិញ ហើយប្រាប់ខ្ញុំថា ខ្ញុំត្រូវទៅប្រជុំនៅភ្នំត្រយោង"]។

681 ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឆ.18 KH 00895169 [សាក្សីគឺជាប្រធានយុវជននៅជប់៖ "ពេលទៅដល់ [ភ្នំត្រយោង] ខ្ញុំបានឃើញយោធាប្រដាប់អាវុធប្រហែល១០នាក់ស្លៀកពាក់ខ្មៅ។ ពួកគេខ្លះជាអ្នកពាយ័ព្យ ហើយខ្លះទៀតជាអ្នកនិរតី។ ខ្ញុំប្រាប់ពួកគេថា យាយ ចែម ជាអ្នកឲ្យខ្ញុំមកប្រជុំនៅទីនេះ។ ពេលនោះ យោធាបានឲ្យខ្ញុំទៅបែនស្រូវ ដោយគេនិយាយថា នេះជាកិច្ចការដែលខ្ញុំត្រូវធ្វើ។ គេបានឲ្យខ្ញុំបែនស្រូវ ហើយពេលល្ងាច គេបានឲ្យខ្ញុំហូបបបរមួយវែក។ នៅប្រហែលម៉ោង៦ល្ងាច គេបានដាក់ខ្នោះខ្ញុំ ហើយប្រាប់ខ្ញុំថា ឲ្យចូលកន្លែងកសាងខ្លួន"]។

682 ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.76 KH 00980393 [សាក្សីគឺជាកម្មាភិបាលភូមិភាគនិរតី ដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ និងត្រូវបានតែងតាំងជាប្រធានឃុំភ្នំលៀប៖ "ខ្ញុំសូមបញ្ជាក់ថា ព្រឹត្តិការណ៍នោះមានពិតមែន ពីព្រោះនៅពេលនោះខ្ញុំបានទទួលសំបុត្រពីគេជាច្រើន ដើម្បីបញ្ជូនមនុស្សទៅអប់រំកែប្រែ។ ខ្ញុំគ្មានសិទ្ធិអំណាចក្នុងការចាប់មនុស្ស ឬបញ្ជូនទៅទីណាទេ ប៉ុន្តែខ្ញុំបានទទួលបញ្ជាពី យាយ ចែម ប៉ុន្តែនៅក្នុងសំបុត្រនោះ មិនមានឈ្មោះ យាយ ចែម ទេ គឺមានមនុស្សនៅក្នុងតំបន់"]។ ឯកសារ D219/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.15 KH 01040786 [សាក្សីគឺជាប្រធានកងយុវជននៅជប់៖ "ស៖ ត្រង់ទំព័រ ៥ ភាសាអង់គ្លេស ត្រង់ចម្លើយ ១២ ដដែល [កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ D119/30] លោកនិយាយថា "ខ្ញុំបានទទួលសំបុត្រមួយពីយាយ ចែម ដែលជាសំបុត្រសរសេរដោយដៃ ដោយមានចុះហត្ថលេខា និងឈ្មោះ ចែម តែមិនមានបោះត្រាទេ។ ក្នុងសំបុត្រនេះ គេសរសេរថា ស្នើសមមិត្ត ទី និងសមមិត្ត សាមុន ឡើងមករៀនសូត្រនៅមន្ទីរភ្នំលៀប"]។ តើចម្លើយនេះត្រឹមត្រូវដែរឬទេ? ឆ.15៖ បាទ ត្រឹមត្រូវ"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.71 KH 01049234 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តយុវជន៖ "ស៖ តើលោកចាំច្បាស់ទេពីការចាប់ខ្លួនដែលបានបញ្ជាដោយយាយ ចែម? ឆ.71៖ ទេ ខ្ញុំចាំមិនច្បាស់ទេ ព្រោះពេលហ្នឹង គេគ្រាន់តែហៅអ្នកទាំងនោះទៅរៀនសូត្រទេ"]។

683 ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.77-80 KH 00980393-00980394 [សាក្សីគឺជាកម្មាភិបាលភូមិភាគនិរតី ដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ និងត្រូវបានតែងតាំងជាប្រធានឃុំភ្នំលៀប៖ "នៅពេលនោះ ខ្ញុំទទួលសំបុត្របែបនេះជាញឹកញាប់។ បើសិនជាខ្ញុំចង់ជួយលាក់មនុស្សគឺខ្ញុំអាចធ្វើទៅបាន ដោយខ្ញុំហែកសំបុត្រនោះចោល ប៉ុន្តែបើសិនជាថ្នាក់លើដឹងរឿងនោះ ខ្ញុំនឹងមានបញ្ហា។ ស៖ តើថ្នាក់លើរបស់លោក គឺយាយ ចែម ឬ? ឆ.78៖ បាទ [...] ប្រសិនបើ យាយ ចែម ដឹងថា ខ្ញុំជួយលាក់មនុស្សដែលគេត្រូវការនោះ ខ្ញុំនឹងត្រូវមានទោស ហើយនិងត្រូវចាប់ខ្លួនដោយចោទថា ខ្ញុំលាក់ខ្មាំង [...] បើតាមខ្ញុំយល់ ប្រសិនបើគេចាប់ខ្លួនយើងហើយនោះ គឺគេប្រាកដជាសម្លាប់យើងហើយ ពីព្រោះសម័យនោះ គេមិនបានរកខុសរកត្រូវទេ"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.28-29 KH 00976178 [សាក្សីគឺជាប្រធានកងចល័តដែលមានកម្មករ

៣០នាក់ ដែលត្រូវបានចាត់ឱ្យទៅត្រពាំងថ្ម ហើយក្រោយមកទៅស្ពានស្រែង៖ "ស៖ នៅទំព័រទី ១២ នៃកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (ERN 00730228) លោកបាននិយាយថា ពេលលោកធ្វើការនៅអាងត្រពាំងថ្ម ហើយលោកបានឃើញអ្នកធ្វើការជាច្រើនត្រូវបានគេហៅទៅរៀនសូត្រ ហើយបានបាត់ខ្លួនរហូត។ តើនេះជាមូលហេតុមួយដែលលោកភ័យខ្លាច ហើយរត់ទៅភូមិរបស់លោកឬ? ហើយនៅពេលណា? ឆ.28៖ បាទ ត្រឹមត្រូវហើយ។ ព្រឹត្តិការណ៍នេះបានកើតឡើងនៅពាក់កណ្តាលឆ្នាំ ១៩៧៨។ ស៖ នៅទំព័រ១២ ដដែល លោកបាននិយាយអំពីអ្នកនៅក្នុងកងរបស់លោក ដែលស្គមស្គាំង ហើយបានរត់ ហើយត្រូវបានកូនចៅ យាយ ចែម ចាប់ដាក់នៅមន្ទីរសន្តិសុខ។ តើលោកអាចពន្យល់បញ្ជាក់បន្ថែមបានដែរឬទេ? ឆ.29៖ ពេលនោះដោយសារកូនក្រុមរបស់ខ្ញុំស្គមស្គាំង ពួកគេក៏បានរត់ចេញពីការដ្ឋាន។ ពេលនោះ ពួកឈ្លបដែលជាកូនចៅរបស់ យាយ ចែម បានចាប់ពួកគេ។ ក្រោយពីពួកគេទាំងនោះ ត្រូវបានគេសួរថាតើលួចរត់មកពីកងណា ហើយពួកគេបានប្រាប់ថា ពួកគេបានលួចរត់មកពីកងរបស់ខ្ញុំ។ ដូច្នេះហើយបានជា យាយ ចែម បានប្រាប់ទៅ តា ពាល់ ហើយ តា ពាល់ បានប្រាប់មកខ្ញុំឱ្យទៅទទួលយកកូនក្រុមរបស់ខ្ញុំមកការដ្ឋានវិញ"]។

684 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.146 KH 00953039 [សាក្សីគឺជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "កន្លែងអប់រំនោះកើតឡើងប្រហែលមួយឆ្នាំ ក្រោយពីខាងនិរតីទៅដល់ [ភ្នំត្រយោង] "]។ ឆ.173 KH 00953043 ["ខ្ញុំទទួលបញ្ជាដោយផ្ទាល់មាត់។ តាមការសន្និដ្ឋានរបស់ខ្ញុំ បើយាយ ចែម តែម្នាក់ឯង ក៏មិនអាចបង្កើតកន្លែងនោះដែរ ព្រោះឈើដែលខ្ញុំយកទៅធ្វើផ្ទះនោះ គឺយកមកពីស្វាយ ពីបាត់ដំបង ដូច្នេះវាមកពីតំបន់៥។ ទាល់តែយាយ ចែម ទទួលបញ្ជាពីលើទើបអាចធ្វើបាន"]។ ឆ.158 KH 00953041 ["តាមការពិភាក្សាគ្នាដែល យាយ ចែម និយាយជាមួយខ្ញុំ គាត់ឱ្យខ្ញុំរៀបចំកន្លែងអប់រំនោះ។ ខ្ញុំមិនដឹងពីការបញ្ជាមកពីថ្នាក់លើទេ។ ខ្ញុំដឹងតែបញ្ជាមកពី យាយ ចែម។ អ្នកថ្នាក់ក្រោម ទាល់តែមានបញ្ជាមកពីលើទើបធ្វើ"]។

685 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.140 KH 00953038 [សាក្សីគឺជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "បើគេចាត់តាំងឱ្យធ្វើការហើយ ត្រូវតែបញ្ចប់ការងារសិន។ បើនៅតែរឹង នោះសហករណ៍នឹងមានវិធានការអប់រំនៅក្នុងសហករណ៍ម្តងពីរសិន។ គេមើលដែរ អ្នកដែលសុំទៅផ្ទះហ្នឹង បើសិនជាអ្នកផ្ទះមានឈើ នោះគេនឹងអនុញ្ញាតឱ្យទៅ"] ឆ.171 KH 00953042 ["បទបញ្ជា ឬគោលនយោបាយ [សម្រាប់មន្ទីរអប់រំ] គឺយាយ ចែម ជាអ្នកបង្កើតឡើង។ យាយ ចែម បញ្ជាថា អ្នកទោសស្រាលឱ្យខ្ញុំបង្កើតជាសហករណ៍"]។

686 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.175 KH 00953043 [សាក្សីគឺជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "យាយ ចែម ជាអ្នកចាត់តាំងខ្ញុំឱ្យទទួលខុសត្រូវកន្លែងនោះ។ ពេលកម្លាំងមកច្រើន គាត់ឱ្យខ្ញុំជួយរៀបចំកន្លែងនោះ"]។

687 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.189 KH 00953045 [សាក្សីគឺជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "បើមាននរណាម្នាក់មានកំហុសនៅតាមសហករណ៍ គេបានស្នើសុំទៅ យាយ ចែម ហើយ យាយ ចែម សួរថាតើអាចអប់រំគេបានទេ បើអប់រំមិនបានទេ ទើបបញ្ជូនទៅភ្នំត្រយោង"]។

688 ឯកសារ D119/132 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉េង ឆាន ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.57-59 KH 00997304 [សាក្សីគឺជាកម្មករនៅទំនប់ត្រពាំងថ្ម៖ "ស៖ នៅក្នុងពាក្យសុំ D230/11.1.471a របស់លោកស្រី១ និយាយថា

កាលធ្វើការនៅត្រពាំងថ្ម លោកស្រីបានដើររកបំពង់ឬស្សីមកដងទឹកហូប ហើយនៅពេលនោះត្រូវបានគចាប់ខ្លួន តើត្រឹមត្រូវដែរទេ? ឆ.57៖ ចាស ត្រឹមត្រូវ។ នៅពេលនោះ គេមិនបានធ្វើបាបយើងទេ គឺគ្រាន់តែកសាង បើសិនជាយើងចង់ទៅដងទឹក គ្រាន់តែប្រាប់ ឬសុំគេជាមុន។ [...] ខ្ញុំនៅចាំថា នៅពេលនោះគឺនៅចុងរបបខ្មែរក្រហម ហើយគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី។ [...] គឺពួកយោធា [ដែលបានចាប់ខ្លួនខ្ញុំ]"]។

689 ឯកសារ D119/132 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉េង ឆាន ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.64-65 KH 00997305 [សាក្សីគឺជាកម្មករនៅទំនប់ត្រពាំងថ្ម៖ "សៈ នៅក្នុងពាក្យសុំ D230/1.1.471a របស់លោកស្រីៗ និយាយថា យាយ ចែម គឺជាអ្នកដឹកនាំប្រជុំកសាងនោះ តើលោកស្រីនៅចាំទេ? ឆ.64៖ ខ្ញុំមិនចាំទេ។ ពីព្រោះពេលនោះ ខ្ញុំមិនបានឃើញ ហើយគេយកពួកយើងទុកមួយកន្លែងឆ្ងាយពីអង្គប្រជុំនោះ ហើយឈ្លបជាអ្នករាយការណ៍អំពីយើងទៅឱ្យអ្នកដឹកនាំអង្គប្រជុំកសាងនោះ។ សៈ តើអង្គប្រជុំនោះ គេធ្វើនៅកន្លែងណា? ឆ.65៖ ធ្វើនៅឃុំរហាល"]។ ឆ.67 KH 00997305 ["សៈ នៅក្នុងពាក្យសុំ D230/1.1.471a របស់លោកស្រីៗ និយាយថា យាយ ចែមគឺជាអ្នកជួយដោះស្រាយពួកខ្ញុំពីការចាប់ចងនេះ តើត្រឹមត្រូវដែរឬទេ? ឆ.67៖ ខ្ញុំសង្ស័យថា ប្រហែលជាយាយ ចែម ហើយដែលជាមនុស្សជួយពួកខ្ញុំឱ្យរួចពីការចាប់ចងនេះ"]។

690 ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.48-49 KH 01105587-01105587 [សាក្សីធ្វើការនៅក្នុងកងចល័តនៅត្រពាំងថ្ម ៖ "សម្រាប់ពួកខ្ញុំ ខ្ញុំជាប្រជាជនចាស់ ខ្ញុំអាចធ្វើបាន ព្រោះប្រជាជនចាស់ធ្លាប់ធ្វើស្រែ តែប្រជាជនជម្លៀស គាត់ធ្វើមិនហើយទេ។ ដូច្នេះហើយ ទើបពួកគេត្រូវបានយកទៅរៀនសូត្រ។ ខ្ញុំគ្រាន់តែដឹងថា [...] អ្នកដែលគេយកទៅមិនដែលយកមកវិញទេ"]។ ឆ.51 KH 01105587 ["ខ្ញុំគ្រាន់តែដឹងថា អ្នកដែលនៅក្នុងកងចល័តរបស់ខ្ញុំ មានអ្នកបាត់ខ្លួន ហើយកងចល័តដទៃទៀតខ្ញុំមិនដឹងទេ"]។

691 ឯកសារ D119/133 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.48 KH 01037368 [សាក្សីគឺជាកម្មករកងចល័តនៅព្រះនេត្រព្រះ ៖ "តាមបទពិសោធន៍របស់ខ្ញុំនៅក្នុងរបបនោះ បើមានអ្នកណាម្នាក់ជាខ្មាំងរបស់អង្គការហើយ ភាគច្រើនគឺត្រូវបានគេហៅឱ្យទៅរៀនសូត្រ ហើយអ្នកនោះមិនដែលឃើញត្រឡប់មកវិញទេ។ នៅក្នុងរបបនោះ គេមិនដែលនិយាយថាយកទៅសម្លាប់ទេ គេនិយាយថាយកទៅរៀនសូត្រ ហើយអ្នកដែលគេយកទៅរៀនសូត្រនោះ មិនដែលឃើញវិលត្រឡប់មកវិញឡើយ"] ឯកសារ D1.3.11.69 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ កសព ជាមួយ យូក នាម ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨ KH 00848166-00848167 [សាក្សីគឺជាកម្មករកងចល័ត៖ "ពួកគេនិយាយថា យកទៅរៀនសូត្រ [...] ពេលគេប្រាប់ថាទៅរៀនសូត្រ គឺមានន័យថា បាត់ខ្លួនហើយ [...] មានន័យថា ពួកគេសម្លាប់ប្រជាជនទាំងនោះ"]។

692 ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234194 ["ខ្ញុំនាំកម្លាំងពីនិរតីទៅ ពីតាកែវទៅ ចល័តប្រាំរយ ដាក់តាមការដ្ឋានគេចាស់ហ្នឹង ទាហានប្រាំរយ ប្រជាជនបីខេត្តហ្នឹងក៏យកប្រាំរយគ្រួសារដែរ យករាយតាមភូមិនៅក្នុងស្រុកទាំងអស់ ហើយខ្ញុំដាក់នេះ គឺស្រណុក (ស្រួល) ហៅធ្វើការ ព្រោះខ្ញុំអត់ដែលស្គាល់សោះស្រុកព្រះនេត្រព្រះហ្នឹង"]។

693 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929738 ["ខ្ញុំសុំខាងភូមិភាគខាងខេត្តអី សុំដកអាកាំភ្លើងកងសេនាជន កម្លាំងឈ្លបស្រុក សុំដកអាហ្នឹងយកមកទុក"] KH 00929748 ["ខ្ញុំសុំគេដកអាវុធទុក"]។ ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929779 ["នែ ខ្ញុំស្នើទៅខាងលើ ខ្ញុំសូមដកអាវុធពីឈ្លប ហើយពីសេនាជនអីទាំងអស់ដែរនៅក្នុងស្រុករបស់ខ្ញុំ"]។ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234196 ["អញ្ចឹងខ្ញុំនឹកឃើញ រួមផ្សំនឹងការដោះស្រាយដែលខាងលើប្រគល់ភារកិច្ចឲ្យខ្ញុំ ខ្ញុំចាប់ផ្តើម កម្លាំងជាពីរ កម្លាំងចល័តដែលគេរៀបចំមុន ហើយនិងកម្លាំងឈ្លប"]។ ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107037 ["ហើយមួយផ្នែកទៀត ខ្ញុំមានវិធានការដកអាវុធពីសេនាជន ពីឈ្លបទាំងអស់យកមកទុកនៅកន្លែង។ [...] ខ្ញុំៗដកអាវុធហ្នឹង ខ្ញុំស្នើដល់ភូមិភាគ ដល់ខេត្តដល់ភូមិភាគ។ មកអំពីបើទុកឲ្យអ្នកកាន់អាវុធនេះច្រើន វាប៉ះពាល់ដល់ ទី១ កម្លាំងការងារ ទី២ ក្រែងលោទំនាស់ជាមួយបងប្អូនណា អាងអាវុធទៅសម្លាប់ដោយងាយៗ។ អ៊ីចឹងហើយបានជាខ្ញុំមានវិធានការដកយកមកទុកមួយកន្លែង"]។

694 ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234196 ["កម្លាំងចលនាសេនាជន ខ្ញុំសុំគេដកអាវុធ ហើយរៀបចំពួកហ្នឹងទៅជាកងចល័តមួយនៅការដ្ឋាន ធ្វើទំនប់ ធ្វើប្រឡាយ ហើយលើកភ្លឺស្រែ"]។

695 ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.42 KH 00976181 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តស្រុក៖ "ពីមុនមក តា ម៉ោង គាត់គ្រប់គ្រងយោធា"]។ សូមមើលផងដែរ ឯកសារ D119/144 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឆ.51-52 KH 01009211 [សាក្សីបម្រើការងារជាទាហានស្រុក និងធ្វើការនៅក្នុងកងចល័ត៖ "ស៖ លោកនិយាយថា លោកធ្វើការនៅក្នុងកងទ័ពស្រុក តើនរណាជាអ្នកគ្រប់គ្រងទាហានរបស់ស្រុក? ឆ.51៖ តា ណាក និង តា ជឿ គឺជាអ្នកគ្រប់គ្រងយោធាស្រុកភ្នំស្រុក។ តា ហាត់ គឺជាគណៈស្រុកភ្នំស្រុក។ ស៖ តា ហាត់ ជាគណៈស្រុកភ្នំស្រុក តើមានន័យថា តា ហាត់ មានតួនាទីគ្រប់គ្រងលើ តា ណាក និង តា ជឿ ដែលជាអ្នកគ្រប់គ្រងយោធាស្រុកដែរឬទេ? ឆ.52៖ បាទ តា ហាត់ ជាអ្នកគ្រប់គ្រងរួមលើស្រុកទាំងមូល។ នៅពេលដែល តា ណាក និង តា ជឿ ត្រូវរាយការណ៍ គឺគាត់ត្រូវរាយការណ៍ផ្ទាល់ទៅឲ្យ តា ហាត់"]។

696 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929794 ["តែខ្ញុំជួយគាត់បាន ហើយមួយទៀត តាៗដែលនៅសង្គមកិច្ចដែរ គេយកទៅដាក់ ដែរផ្ទះខ្ញុំហ្នឹងណា។ ដានី ៖ ពេលនឹងគាត់ជាប់ទោសអី ដែលគេចាប់ឃុំគាត់ ហើយអ៊ំទៅដោះ? ចែម ៖ ខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំទៅឃើញគេឃុំគាត់។ ដានី៖ ដែលអ៊ំទៅដល់ប្រលែងគាត់បណ្តោយ? ចែម ៖ ខ្ញុំទៅដល់ឃើញគេបញ្ចេញពីផ្ទះនឹង ខ្ញុំសាកសួរគាត់ ដល់ឃើញគាត់ចាស់ ខ្ញុំឲ្យដោះលែងគាត់..."]។ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234194 ["ខ្ញុំនាំកម្លាំងពីនីរតីទៅ ពីតាកែវទៅ ចល័តប្រាំរយ ដាក់តាមការដ្ឋានគេចាស់ហ្នឹង ទាហានប្រាំរយ ប្រជាជនបីខេត្តហ្នឹងក៏យកប្រាំរយគ្រួសារដែរ យករាយតាមភូមិនៅក្នុងស្រុកទាំងអស់ ហើយខ្ញុំដាក់នេះ គឺស្រណុក (ស្រួល) ហៅធ្វើការ ព្រោះខ្ញុំអត់ដែលស្គាល់សោះស្រុកព្រះនេត្រព្រះហ្នឹង"]។ ឯកសារ D219/264.1 ប្រតិចារឹក

បទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01117960 [“សៈ យកឈ្លបទៅ [ធ្វើស្រែ] ដែរ? អ៊ឹម ចែមៈ ចាស។ ស្រេចតែយើងរៀបចំទេ។ សៈ ប៉ុន្តែយកទៅធ្វើអីឈ្លបហ្នឹង? អ៊ឹម ចែមៈ បានជាមានឈ្មោះថាឈ្លបភូមិ ការពារនៅភូមិ ក្រែងលោមានចោរ មានឈ្លបញអី ដូចរាល់ថ្ងៃអ៊ីចឹង។ បើថាគេត្រូវការកម្លាំងទៅស្រែប្រាំង ឬក៏ធ្វើអី”]។ ឯកសារ D119/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.37 KH 00976132 [“ខ្ញុំមិនដែលជួប យាយ ចែម ទេ។ នៅពេលនោះ ខ្ញុំបានសួរយោធានៅលើឡាន ហើយយោធានោះបានប្រាប់ខ្ញុំថា ពួកគេទៅដឹកយាយ ចែម”]។ ឯកសារ D219/357 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.124 KH 01104654 [“ឆ.124៖ ខ្ញុំធ្លាប់ឮគេហៅថា ឈ្មោះ យាយ ចែម ដែលជាប្រធានគ្រប់គ្រងយោធា”]។ ឆ.125 KH 01104655 [“ខ្ញុំគ្រាន់តែឮគេនិយាយថា គាត់គ្រប់គ្រងផ្នែកយោធាតែប៉ុណ្ណោះ”]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤, ឆ.66-68, EN 01059944-01059945 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តយុវជន៖ “ស: លោកនិយាយថាយាយចែមបញ្ជាទាំងឯយោធា តើយោធាយ៉ាងម៉េចដែរ? ឆ.66: យោធាមានកាំភ្លើង ដែលអាចចាប់ប្រជាជនបាន។ ស: អ៊ីចឹងពេលហ្នឹង យាយចែមអាចបញ្ជាឲ្យយោធាទាំងនោះចាប់ប្រជាជនបានឬ? ឆ.67: បាទ។ ឆ.68: ខ្ញុំដឹងពីក្រុមចល័តដែលអាចរត់រួចពីភ្នំត្រយោង”], ឆ.267, EN 01059970 [“ខ្ញុំឮថាគាត់[អ៊ឹម ចែម]កាចហើយបើគាត់បញ្ជាទាហានឲ្យធ្វើអ្វីមួយ គេត្រូវតែធ្វើតាម”] ។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.87 KH 00989348 [សាក្សីធ្វើការនៅក្នុងកងកុមារនៅត្រពាំងថ្ម៖ “ខ្ញុំធ្លាប់ឮឈ្មោះ យាយ ចែម នៅអាងត្រពាំងថ្ម។ ខ្ញុំធ្លាប់ឮគេនិយាយថា យាយ ចែម ជាអ្នកនាំកងទ័ព និងប្រជាជនឲ្យទៅធ្វើការនៅអាងត្រពាំងថ្ម។ យាយ ចែម ក៏គ្រប់គ្រងកងទ័ពដែរ”]។ ឯកសារ D219/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.57-59 KH 01029673 [សាក្សីគឺជាសមាជិកគណៈស្រុកព្រះនេត្រព្រះ ៖ “ខ្ញុំប្រគល់កាំភ្លើងអាកា ទៅឲ្យគេ នៅពេលដែលពួកនិរតីមកដល់។ [...] ខ្ញុំប្រគល់កាំភ្លើងទៅឲ្យយាយ ចែម នៅផ្ទះរបស់គាត់នៅភ្នំលៀប។ ខ្ញុំប្រគល់ឲ្យគេមុន [អ៊ឹម ចែម] នៅឆ្នាំ ១៩៧៧។ [...] ខ្ញុំបានប្រគល់កាំភ្លើងទៅឲ្យ យាយ ចែម”]។ ឯកសារ D119/144 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឆ.53 KH 01009211 [សាក្សីបម្រើការងារជាទាហានស្រុក និងធ្វើការនៅក្នុងកងចល័ត៖ “បាទ ជាទូទៅ នេះគឺជារចនាសម្ព័ន្ធគ្រប់គ្រងតាមស្រុករបស់ខ្មែរក្រហម គឺប្រធានយោធាស្រុកត្រូវរាយការណ៍ទៅគណៈស្រុក។ ខ្ញុំឮតាមប្រជាជនដែលរស់នៅស្រុកព្រះនេត្រព្រះថា យាយ ចែម មានអំណាចគ្រប់គ្រងមនុស្សទាំងអស់នេះ ហើយប្រធានយោធាស្រុក ក៏ត្រូវរាយការណ៍ជូនគាត់ដែរ”]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.66-68 KH 01049233 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តយុវជន៖ “សៈ លោកនិយាយថា យាយ ចែម បញ្ជាទាំងយោធា តើយោធាយ៉ាងម៉េចដែរ? ឆ.66៖ យោធាមានកាំភ្លើង ដែលអាចចាប់ប្រជាជនបាន។ សៈ អ៊ីចឹងពេលហ្នឹង យាយ ចែម អាចបញ្ជាឲ្យយោធាទាំងនោះចាប់ប្រជាជនបានឬ? ឆ.67៖ បាទ។ ឆ.68៖ ខ្ញុំដឹងពីក្រុមចល័តដែលអាចរត់រួចពីភ្នំត្រយោង”]។ ឆ.267 KH 01049252 [“ខ្ញុំឮថា គាត់[អ៊ឹម ចែម] កាច ហើយបើគាត់បញ្ជាទាហានឲ្យធ្វើអ្វីមួយ គេត្រូវតែធ្វើតាម”]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.82 KH

00953031 [សាក្សីគឺជាអនុប្រធានកងចល័តនៅក្នុងតំបន់ ១៣ ដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ៖ "ពេលយាយ ចែម ទៅដល់ គឺចូលរួមជាមួយកម្លាំងចាស់។ ពេលទៅដល់ព្រះនេត្រព្រះប្រហែល ១០ ថ្ងៃ យាយ ចែម និងគណៈស្រុកចាស់ ប្រជុំរួមគ្នា ដើម្បីរៀបចំកម្លាំង"]។ ឯកសារ D119/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.32 KH 00985871 [សាក្សីគឺជាប្រធានកងចល័តដែលធ្វើការនៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងប្រឡាយអូរលៀប៖ "ខ្ញុំត្រូវរាយការណ៍ទៅ តា ពាល់ ហើយ តា ពាល់ ត្រូវរាយការណ៍ទៅ យាយ ចែម ។ នៅពេលនោះ យាយ ចែម បានឱ្យឈ្លបចុះទៅតាមសហករណ៍ ដើម្បីឱ្យប្រធានសហករណ៍ ឬគណៈឃុំស្វែងរកមនុស្សទាំងនោះ ត្រឡប់មកការដ្ឋានវិញ"]។ ឯកសារ D119/88 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.30 KH 00976122 [សាក្សីបានដឹកជញ្ជូនថ្មពីភ្នំត្រយោងទៅត្រពាំងថ្ម ៖ "នៅពេលនោះ ខ្ញុំបានឃើញគាត់ជិះឡានសេអ៊ឹមសេ នៅផ្លូវជាតិលេខ៦ មកពីទិសខាងលិចឆ្ពោះទៅភ្នំលៀប ប្រហែលជាគាត់មកពីស្វាយស៊ីសុផុនហើយ។ ខ្ញុំបានឃើញគាត់នេះប្រហែលជាពីរបីថ្ងៃមុនវៀតណាមមកដល់។ នៅលើឡាននោះ មានយោធាប្រហែល១០នាក់ តែពួកគេមិនមានកាំភ្លើងទេ"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.54 KH 00976183 [សាក្សីគឺជាប្រធានកងចល័តដែលមានកម្មករ៣០នាក់ ដែលត្រូវបានចាត់ឱ្យទៅត្រពាំងថ្ម ហើយក្រោយមកទៅប្រឡាយស្ពានស្រែង និងអូរលៀប៖ "ស៖ លោកបាននិយាយថា យាយ ចែម ធ្លាប់បានបញ្ជូនឈ្លបឱ្យទៅចាប់មនុស្ស ដូចជាចាប់ ពេទ្យ មឿន ជាដើម តើលោកដឹងទេថា យាយ ចែម គាត់គ្រប់គ្រងលើយោធា និងឈ្លបដែរឬទេ? ឆ.54៖ ខ្ញុំបានឃើញយាយ ចែម គ្រប់គ្រងតែឈ្លបតែប៉ុណ្ណោះ។ ពួកឈ្លបទាំងនោះ ស្លៀកពាក់ជាសំលៀកបំពាក់ស៊ីវិលធម្មតា តែមានកាំភ្លើង"]។

697 ឯកសារ D119/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហឹយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.14 KH 00969016 [សាក្សីធ្វើការជាពេទ្យបុរាណនៅក្នុងតំបន់ ៥៖ "ពួកគាត់ [តា ម៉ុក និងយាយ ចែម] គឺជាបក្សពួកតែមួយ ដែលមានតួនាទី និងសិទ្ធិដើរចាប់មនុស្សក្នុងភូមិភាគពាយ័ព្យ"]។ ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.36 KH 01024748 [សាក្សីត្រូវបានចាប់ខ្លួននៅព្រះនេត្រព្រះ ៖ "ពីព្រោះនៅពេលនោះ ខ្ញុំឮគេនិយាយថា នៅពេលដែលអ្នកណាម្នាក់មានកំហុស ហើយអ្នកនោះត្រូវបានគេបញ្ជូនទៅជួប យាយ ចែម អ្នកទាំងនោះ ត្រូវយាយ ចែម បញ្ជូនទៅដាក់គុក ឬក៏ត្រូវយាយ ចែម សម្លាប់ចោលដែរ។ អ្នកដែលគេបញ្ជូនទៅដាក់គុកនៅភ្នំត្រយោងនោះ កម្រមានជីវិតណាស់ ព្រោះនៅទីនោះគេបង្ខំឱ្យធ្វើការធ្ងន់ និងបង្អត់អាហារ"]។ ឆ.37-38 01024749 ["ឈ្មោះ គិត ដែលជាប្រធានភូមិជញ្ជាំង ហើយជាកម្មាភិបាលនិរតី។ [...] នៅពេលនោះ គិត បានចាប់ពួកយើងប្រហែល៦ ឬ៧នាក់ ហើយដឹកតាមគោយន្តឱ្យទៅផ្ទះយាយ ចែម ដែលមានទីតាំងនៅភ្នំលៀប ក្នុងគោលបំណងបញ្ជូនយើងទៅភ្នំត្រយោង។ នៅពេលគោយន្តដឹកពួកយើង គឺពួកយើងមិនត្រូវបានគេចងទេ។ ពេលយើងទៅដល់ផ្ទះយាយ ចែម គាត់មិននៅទីនោះទេ ពីព្រោះគាត់បានគេចខ្លួនបាត់ទៅហើយ ដូច្នេះហើយទើប គិត ដឹកយើងមកភ្នំជញ្ជាំងវិញ ហើយឃុំយើងនៅក្រោមផ្ទះ គិត អស់រយៈពេល៣យប់"]។ ឯកសារ D119/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ. 22 KH 00895162 [សាក្សីគឺជាអនុប្រធានកងចល័តតំបន់៥ ៖ "ស៖ ក្នុងតួនាទីជាគណៈស្រុកព្រះនេត្រព្រះ តើគាត់មានសិទ្ធិអំណាចចាប់មនុស្សក្នុងស្រុករបស់គាត់ដែរឬទេ? ឆ. 22៖ ខ្ញុំមិនដឹងទេ។ តែតាមការស្មានរបស់ខ្ញុំ បើសិនជាមិនមានបញ្ជាពីគណៈស្រុក មេឃុំនានាមិនអាចចាប់មនុស្សបានទេ"]។ ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ

កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.85-86 KH 00980395 [សាក្សី ត្រូវបានតែងតាំងជាគណៈឃុំភ្នំលៀប ដោយ អ៊ឹម ចែម៖ "សៈ តើអ្នកដែលចុះមកចាប់មនុស្សនោះ មកពីថ្នាក់ស្រុក ឬតំបន់? ឆ.85៖ គេមកពីថ្នាក់តំបន់ ពីព្រោះគេមានឡានចុះមកចាប់មនុស្ស។ ថ្នាក់ស្រុកមិនមានឡានចុះមកចាប់មនុស្សទេ។ សៈ តើលោកធ្លាប់បានឃើញ យាយ ចែម ធ្វើដំណើរតាមឡាននៅក្នុងស្រុកព្រះនេត្រព្រះដែរឬទេ? ឆ.86៖ បាទ ខ្ញុំធ្លាប់ឃើញគាត់ជិះឡានជាមួយនឹងកម្មាភិបាលថ្នាក់តំបន់ និងភូមិភាគ"]។ ឯកសារ D119/75 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤ ឆ.13-14 KH 00971135 [សាក្សីគឺជានីរសាររបស់ អ៊ឹម ចែម៖ "សៈ នៅទំព័រ៣១ នៃបទសម្ភាសរបស់ អ៊ឹម ចែម ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (ERN 00907826) អ៊ឹម ចែម ដែលជាគណៈស្រុកព្រះនេត្រព្រះ បាននិយាយថា គាត់បានជួយការពារមិនឱ្យគេចាប់ តា សុខ នៅជប់ ចំនួនបីដង នៅពេលដែល តា ញ៉ឹម ដែលជាគណៈភូមិភាគពាយ័ព្យផ្ញើសំបុត្រចំនួនបីឱ្យចាប់ តា សុខ។ តើលោកជា តា សុខ នោះឬ? ឆ.13៖ បាទ ឈ្មោះ តា សុខ នោះ គឺជារូបខ្ញុំនេះតែម្តង។ សៈ មុននេះ លោកនិយាយថា លោកមិនមានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំនៅថ្នាក់ឃុំ ស្រុក ឬតំបន់ទេ។ ហេតុអ្វីបានជា អ៊ឹម ចែម ដែលជាគណៈស្រុក ការពាររូបលោកពីការចាប់ចងតាមលិខិតរបស់គណៈភូមិភាគពាយ័ព្យទៅវិញ ព្រោះលោកបាននិយាយថា លោកគ្រាន់តែជាប្រជាជនសាមញ្ញតែប៉ុណ្ណោះ? ឆ.14៖ ខ្ញុំមិនបានដឹងរឿងទាំងអស់នេះថាមានគេរកចាប់ខ្លួនខ្ញុំនៅពេលនោះ ទើបតែថ្ងៃនេះទេ ទើបខ្ញុំបានដឹងពីលោកវិញថា មានសំបុត្រចំនួនបីពីគណៈភូមិភាគរកចាប់ខ្លួនខ្ញុំ"]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឆ.9 KH 00895168 [សាក្សីត្រូវបានចាប់ខ្លួននៅព្រះនេត្រព្រះ៖ "តាមខ្ញុំយល់ ក្នុងតួនាទីគាត់ជាគណៈស្រុក គាត់មានអំណាចធ្វើដូច្នេះ [ចាប់ខ្លួនមនុស្ស] ..."]។ ឯកសារ D119/133 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.83 KH 00998147 [សាក្សីគឺជាកម្មករកងចល័តនៅព្រះនេត្រព្រះ៖ "តាមការសន្និដ្ឋានរបស់ខ្ញុំ [អ៊ឹម ចែម]មានសិទ្ធិដោះលែងនរណាម្នាក់ ដូច្នេះគាត់ក៏មានសិទ្ធិបញ្ជាឱ្យចាប់ខ្លួនអ្នកណាម្នាក់"]។ ឯកសារ D1.3.11.52 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ គក់ ប៊ុយ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧, KH 00057733 ["ប៊ុយ៖ គាត់ [អ៊ឹម ចែម] កាច។ សូម្បីតែ តា វ៉ាល់ ជាប្រធានភូមិភាគពាយ័ព្យនេះ ក៏កាចណាស់ដែរ"] KH 00057735 ["យាង៖ ពូនិយាយអម្បាញ់មិញថា យាយ ចែម ជាមនុស្សកាច កាលនោះ ពូដឹងដោយសារអីដែរ? ប៊ុយ៖ ទេ កាលហ្នឹងយើងឮគេនិយាយតគ្នាថា កាចណាស់ យាយ ចែម។ យាង៖ កាចយ៉ាងម៉េចខ្លះ? ប៊ុយ៖ កាចនេះគឺគំរាមកំហែងវាយមនុស្សចោល គ្រាន់តែធ្វើអ្វីខុសតែបន្តិចបន្តួច ដូចជា ស្តីកស្រពន់នឹងការងារ ដូចថាធ្វើឡេះឡោះ នឹងបាត់ខ្លួនហើយ"]។ KH 00057746 [សាក្សីគឺជាពលករកងចល័ត៖ "រឿងកាចនោះ ដែលបងប្អូនថាកាច គឺកាចដោយយកបងប្អូនទៅសម្លាប់ចោល។ [...] បើនិយាយទៅ គេឃោឃាសពូថ្ងៃ គេបែកគ្នាទៅណាទៅណែអស់ហើយ កាលហ្នឹងនៅជុំគ្នា ចេះតែនិយាយប្រាប់ថា ពួកយាយ ចែម កាចកំពូលមនុស្សស្រី កាចក្នុងការដូចថា មុឹងម៉ាត់នឹងការងារ អត់មានអនុគ្រោះពេលណាដែលខុសឆ្គងស្អី ដូចថាខុសបន្តិចបន្តួចយើងអាឲ្យស្រ័យគ្នា បើថាទៅខាងនេះទៅ បើមិនទៅដាក់ផ្នូង"]។ ឯកសារ D5/1721 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ណុប ណាត ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ KH 01157947 ["អ្នកដាក់ពាក្យបណ្តឹងបានរៀបរាប់បន្តថា គាត់ធ្លាប់ឮសូរគេនិយាយថា អ៊ឹម ចែម នោះជាអ្នកមកពីនិរតី។ [...] គាត់គឺជាជើងខ្លាំងនៅក្នុងសមរភូមិ និងជើងខ្លាំងខាងបញ្ជាឱ្យមានការធ្វើទារុណកម្ម និងកាប់សម្លាប់ប្រជាជនពេលដែលគាត់គ្រប់គ្រងនៅព្រះនេត្រព្រះ"]។

698 ឯកសារ D219/575 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទឹក សួង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.11 KH 01166354 [សាក្សីគឺជាឈ្លបឃុំនៅក្នុងភូមិប្រាសាទក្នុងស្រុកព្រះនេត្រព្រះ ៖ "ចំពោះការចាប់មនុស្សវិញ មានតែកូនចៅ នីរសារ យាយ ចែម ពីរនាក់ជាអ្នកចាប់"]។ ឆ.12 KH 01166355 ["ខ្ញុំភ្លេចឈ្មោះ។ ខ្ញុំគិតថាវានៅរស់ជាមួយ យាយ ចែម ដល់សព្វថ្ងៃ ព្រោះពួកវាជាសាច់ញាតិរបស់ យាយ ចែម។ ម្នាក់ឈ្មោះ មុំ និងម្នាក់ទៀតខ្ញុំភ្លេចឈ្មោះហើយ ព្រោះវាយូរណាស់មកហើយ។ សួរ អាឡុង វាស្គាល់ហើយ។ ការងារនេះលាក់ការណ៍ ដូច្នេះគេដកពាយ័ព្យចេញ ហើយដាក់បញ្ចូលគ្នាគេជំនួសវិញ"]។ ឯកសារ D119/98 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH 00978911 [សាក្សីគឺជាប្រធានកងចល័តដែលធ្វើការនៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងប្រឡាយអូរលៀប ៖ "ខ្ញុំគ្រាន់តែដឹងថា ទាហានស្រុកព្រះនេត្រព្រះ ដែលជាអ្នកពាយ័ព្យ ត្រូវបានគេហៅទៅរៀន ហើយមិនដែលឃើញត្រឡប់មកវិញទេ។ ចំណែកកម្មាភិបាលពាយ័ព្យ ក៏គេហៅទៅរៀនដែរ តែខ្ញុំមិនដឹងថា នរណាជាអ្នកហៅពួកគាត់ទៅរៀនទេ។ ចំណែកនៅតាមសហករណ៍វិញ គឺឈ្លបឃុំជាអ្នកចុះចាប់។ [...] ឈ្លបឃុំ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈឃុំ ហើយគណៈឃុំ ក៏ស្ថិតនៅក្រោមការគ្រប់គ្រងបន្តរបស់គណៈស្រុក"]។ ឯកសារ D219/94 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.18-19 KH 01043163 ["ស៖ តើ តា កាន មានបានឆ្លើយថា ហេតុអ្វីបានជាគេចាប់លោក [ហើយបញ្ជូនទៅភ្នំត្រយោង]ទេ? ឆ.18៖ គាត់ឆ្លើយថា ឲ្យខ្ញុំទៅទីនោះទៅ ទៅកន្លែងកសាងខ្លួន។ ស៖ តើ តា កាន បានប្រាប់ថា អ្នកណាជាអ្នកបញ្ជាឲ្យចាប់ខ្លួនទេ? ឆ.19៖ បាទ គាត់ប្រាប់ថា ឲ្យខ្ញុំទៅតាមអ៊ំ។ អ៊ំនោះ គឺយាយ ចែម"]។ ឯកសារ D119/49 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.32-33 KH 00933105-00933106 [សាក្សីត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខភ្នំត្រយោង៖ "ស៖ លោកនិយាយថា យាយ ចែម បានបញ្ជាឲ្យគេយកលោកទៅដាក់គុក តើត្រឹមត្រូវដែរឬទេ? ឆ.32៖ បាទ ត្រឹមត្រូវហើយ។ ស៖ តើលោកត្រូវបានគេបញ្ជូនទៅដាក់គុករយៈពេលប្រហែលប៉ុន្មាន? ឆ.33៖ ខ្ញុំត្រូវបានគេបញ្ជូនខ្ញុំទៅដាក់គុកប្រហែលជាដើមខែ៨ ឆ្នាំ ១៩៧៨ រហូតដល់វៀតណាមចូលមកដល់"]។ ឆ.42 KH 00933107 ["មេគុកបានឲ្យយោធាបីនាក់មកហៅខ្ញុំ គេមិនបានចងខ្ញុំទេ។ ពីកន្លែងមន្ទីរពេទ្យដែលខ្ញុំធ្វើការទៅគុកភ្នំត្រយោងមិនឆ្ងាយនោះទេ ប្រហែលជាង២គីឡូម៉ែត្រ។ យោធាទាំងបីនាក់នោះសុទ្ធតែមានអាវុធ។ ប្រធានគុកឈ្មោះតា សឿន"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.66-68 KH 01049233 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តយុវជន៖ "ស៖ លោកនិយាយថា យាយ ចែម បញ្ជាទាំងយោធា តើយោធាយ៉ាងម៉េចដែរ? ឆ.66៖ យោធាមានកាំភ្លើង ដែលអាចចាប់ប្រជាជនបាន។ ស៖ អ៊ីចឹងពេលហ្នឹង យាយ ចែម អាចបញ្ជាឲ្យយោធាទាំងនោះចាប់ប្រជាជនបានឬ? ឆ.67៖ បាទ។ ឆ.68៖ ខ្ញុំដឹងពីក្រុមចល័តដែលអាចរត់រួចពីភ្នំត្រយោង"]។ ឯកសារ D119/69 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឆ.130-132 KH 00969043 [សាក្សីគឺជាប្រធានសហករណ៍នៅភ្នំស្រុក៖ ["ឆ.130៖ តាមខ្ញុំដឹង គឺប្រធានសហករណ៍មើលការខុសត្រូវលើឈ្លប។ ស៖ ឧទាហរណ៍ ប្រធានសហករណ៍ចង់ចាប់ខ្លួនលោក តើប្រធានសហករណ៍មកខ្លួនឯង ឬក៏ឈ្លបមកចាប់? ឆ.131៖ ឲ្យពួកឈ្លបមកចាប់។ ស៖ ទាក់ទងនឹងការចាប់ខ្លួននោះ តើប្រធានសហករណ៍ចេញបញ្ជាឲ្យចាប់ខ្លួនដោយខ្លួនឯង ឬក៏ទទួលបញ្ជាពីថ្នាក់លើ? ឆ.132៖ តាមខ្ញុំយល់ ការចាប់ខ្លួននោះ គឺធ្វើតាមបញ្ជាពីថ្នាក់លើ ដូចជាថ្នាក់ឃុំ ស្រុកជាដើម"]។ ឯកសារ D119/19 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា

ឆ្នាំ ២០១៣ ឆ.17-18 KH 00894493 [សាក្សីធ្វើការនៅក្នុងកងចល័តនៅព្រះនេត្រព្រះ ហើយបន្ទាប់មក ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅភ្នំត្រយោង៖ "ឆ.17៖ ខ្ញុំដឹងថាមានគុកនៅភ្នំត្រយោង គឺនៅពេលដែលគេបញ្ជូនខ្ញុំទៅទីនោះ។ គុកនេះប្រហែលជាគុកថ្មី ព្រោះរោងសម្រាប់ដាក់អ្នកទោសនៅថ្មី ហើយខ្ញុំឮថា ពីមុនគុកនេះមានទីតាំងនៅស្វាយស៊ីសុផុន (បច្ចុប្បន្នក្រុងសេរីសោភ័ណ) តែខ្ញុំមិនដឹងទីតាំងទេ។ សៈ តើនរណាគេជាអ្នកមកចាប់លោក? តើពួកគេជាឈ្លប ឬជាយោធា? ឆ.18៖ ខ្ញុំមិនដឹងពួកគេជាឈ្លប ឬជាយោធាទេ។ ពួកគេស្លៀកពាក់ខ្មៅ ហើយមានកាន់កាំភ្លើង។ ពួកគេមានគ្នាប្រហែល៣ទៅ៥នាក់"]។

699 ឯកសារ D119/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហើយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.10 KH 00969015 [សាក្សីធ្វើការជាពេទ្យបុរាណនៅក្នុងតំបន់ ៥៖ "ព្រោះថ្ងៃដែលគេចាប់ខ្លួនឪពុកខ្ញុំ ខ្ញុំក៏ត្រូវបានគេចាប់ខ្លួនផងដែរ។ នៅពេលដែលគេចាប់ឪពុកខ្ញុំចងដៃ និងដាក់ខ្នោះជើងទាំងពីររបស់គាត់ ពេលនោះគេបានចងដៃខ្ញុំ ឱ្យអង្គុយទល់មុខជាមួយនឹងឪពុករបស់ខ្ញុំដែរ។ ឪពុករបស់ខ្ញុំត្រូវបានគេយកទៅសម្លាប់នៅក្នុងរណ្តៅជីមួយ ពេលនោះខ្ញុំបានឮស្នូរសំឡេងរបស់ឪពុកខ្ញុំស្រែកហៅឱ្យខ្ញុំជួយគាត់នៅពេលដែលគេវាយគាត់មួយដំបងដំបូង ហើយបន្ទាប់មកគេវាយគាត់មួយដំបងទៀត ខ្ញុំលែងបានឮសំឡេងគាត់តទៀត"]។ ឯកសារ D219/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ .11-12 KH 01040786 ["ឆ.11៖ ខ្ញុំបានជួបគាត់ [អ៊ឹម ចែម] តែម្តងគត់នៅពេលប្រជុំ នៅពេលដែលគេចាប់ខ្លួនខ្ញុំ។ ក្រោយមក ខ្ញុំមិនដែលបានជួបគាត់ទៀត។ សៈ លោក និយាយថា៖ "តាមខ្ញុំយល់ ក្នុងតួនាទីគាត់ជាគណៈស្រុក គាត់មានអំណាចធ្វើដូច្នោះ"។ តើលោកអាចបញ្ជាក់បន្ថែមអំពីចម្លើយនេះបានដែរឬទេ? ឆ.12៖ បាទ ត្រឹមត្រូវហើយ"]។ ឆ.14 KH 01040786 ["តាមពិតទៅ គេមិនចាប់ខ្លួនខ្ញុំទេ គេគ្រាន់តែយកលិខិតមកឱ្យខ្ញុំ ប្រាប់ឱ្យខ្ញុំទៅជួបយាយ ចែម ហើយក្រោយមក យាយ ចែម បានឱ្យខ្ញុំទៅកាន់ភ្នំត្រយោង"]។

700 ឯកសារ D119/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហើយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.9 KH 00969015 [សាក្សីធ្វើការជាពេទ្យបុរាណនៅក្នុងតំបន់ ៥៖ "ពួក [ដែលបញ្ជាឱ្យចាប់ និងសម្លាប់] គឺជាពួកនិរតី ដែលស្ថិតនៅក្រោមការដឹកនាំរបស់តា ម៉ុក និងយាយ ចែម។ ហើយក្រោយពីការបាត់ខ្លួនរបស់កម្មាភិបាលពាយ័ព្យ គឺយាយ ចែម ជាអ្នកឡើងជំនួសគណៈតំបន់ ៥ ដើមឆ្នាំ ១៩៧៨។ ពេលនោះ តា ម៉ុក និងយាយ ចែម ជាអ្នកចាប់ តា ហ៊ឹង (គណៈតំបន់ ៥) និង តា ញឹម (គណៈភូមិភាគពាយ័ព្យ) និងកម្មាភិបាលភូមិភាគពាយ័ព្យមួយចំនួនទៀត។ ក្រោយពីការចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យដទៃទៀត កម្មាភិបាលភូមិភាគនិរតី បានទទួលខុសត្រូវទាំងស្រុងនៅភូមិភាគពាយ័ព្យ]។ ឆ.8 KH 00969014-00969015 ["ពួកគេបានយកឪពុកខ្ញុំទៅសម្លាប់នៅភូមិដកពោធិ៍ ក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ នៅចន្លោះចុងឆ្នាំ ១៩៧៧ ដើមឆ្នាំ ១៩៧៨។ ពេលនោះ គេឱ្យឪពុកខ្ញុំចិញ្ចឹមមាន់ ហើយដោយសារតែមានពេលមួយនោះ អ្នកទទួលបន្ទុកចែកអង្ករម្នាក់បានឈឺ ដូច្នេះគេបានចាត់តាំងឪពុករបស់ខ្ញុំទៅទទួលជំនួសគាត់។ នៅពេលនោះ គឺចំពេលដែលពួកនិរតីចូលមកដល់ភូមិភាគពាយ័ព្យ ហើយពេលនោះ អ្នកដែលជាប់ពាក់ព័ន្ធនិន្នាការនឹងកម្មាភិបាលភូមិភាគពាយ័ព្យចាស់ ត្រូវបានគេចាប់យកទៅសម្លាប់ផងដែរ។ ក្នុងនោះក៏មានឪពុកខ្ញុំម្នាក់ដែរ ដោយសារគាត់ជាអតីតអាចារ្យវត្ត ហើយគាត់បានរក្សាទុកគម្ពីរស្លឹករឹត ដូច្នេះពួកនិរតីបានចាប់គាត់ ហើយយកគាត់ទៅសម្លាប់"]។

701 ឯកសារ D106/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.2 KH 00800979 ["ខ្ញុំត្រូវបានគេបញ្ជូនពីភូមិកំណើតរបស់ខ្ញុំ គឺភូមិអំពិល ឃុំប្រាសាទ ទៅកន្លែងមួយទៀត នៅភ្នំលៀប ហើយខ្ញុំត្រូវបានគេឱ្យ

ធ្វើពេទ្យនៅក្នុងកងចល័តសម្រាប់ព្យាបាលជំងឺគ្រុនចាញ់"]។ ឆ.3 KH 00800980 ["គឺ យាយ ចែម នៅក្នុងឆ្នាំ ១៩៧៧ [ដែលបានបញ្ជាឱ្យបញ្ជូន]"]។ ឆ.4 KH 00800980 ["យាយ ចែម ជាអ្នកចេញបញ្ជា តាមរយៈ តា កាន់ ដែលជាប្រធានសង្កាត់ព្រះនេត្រព្រះ។ តា កាន់ ជាអ្នកមកពីភូមិភាគនិរតី"]។ ឆ.5 KH 00800980 ["បាទ គឺក្រោយពេលចូលឆ្នាំខ្មែរ ក្នុងឆ្នាំ ១៩៧៧។ នោះគឺជាពេលដែលក្រុមនិរតីបានចូលមកគ្រប់គ្រង"]។

702 ឯកសារ D106/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.9 KH 00800980 ["គេឱ្យខ្ញុំដើរព្យាបាលមនុស្សពីភូមិមួយទៅភូមិមួយទៀត គឺព្យាបាលជំងឺគ្រុនចាញ់។ ពេលនោះ មានពេទ្យម្នាក់ទៀតឈ្មោះ ហ៊ុន ដែលត្រូវបានគេចាប់ខ្លួន និងសម្លាប់។ មានស្ត្រីម្នាក់ទៀត ដែលជាប្រធានស្រុក ដែលគាត់មានបញ្ហា ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់នៅភ្នំលៀប។ ខ្ញុំសូមធ្វើការកែតម្រូវថា តាមពិត ស្ត្រីនោះគឺជាប្រធានក្រុមពេទ្យនៅក្នុងស្រុកព្រះនេត្រព្រះ"]។ ឆ .10 KH 00800980 [" ពិតណាស់ គឺបញ្ជា [ឱ្យចាប់ខ្លួន] នោះចេញពីថ្នាក់ស្រុក"]។ ឆ.11 KH 00800980-00800981 ["យាយ ចែម គឺជាអ្នកចេញបញ្ជាឱ្យចាប់ក្រុមរបស់ខ្ញុំ ពីព្រោះខ្ញុំគឺជាអ្នកប្រកែកតវ៉ាមិនព្រមទៅមន្ទីរសន្តិសុខភ្នំត្រយោង"]។ ឆ.13 ["ខ្ញុំប្រកែកជាមួយចៅសង្កាត់ឈ្មោះ តា កាន់។ តា កាន់ គឺជាអ្នកដែលបានប្រាប់ខ្ញុំថា គេហៅខ្ញុំឱ្យទៅអប់រំកែប្រែនៅភ្នំត្រយោង ពីព្រោះ ហ៊ុន ដែលជាពេទ្យម្នាក់ដែរនោះ ត្រូវបានគេចាប់ ព្រោះគាត់មានពាក់ព័ន្ធជាមួយនារីម្នាក់ ហើយ នៅ និង ផាត់ ត្រូវបានគេចាប់បាត់ទៅហើយ ដូច្នេះ ចុងក្រោយ គឺជារូបខ្ញុំ"]។ ឯកសារ D219/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.12 KH 01043162 ["សៈ ខ្ញុំសូមអានសំណួរ-ចម្លើយលេខ១០ "សៈ តើអ្នកណាជាអ្នកបញ្ជាឱ្យចាប់រូបលោក? ឆៈ ពិតណាស់ គឺការបញ្ជានោះចេញមកពីថ្នាក់ស្រុក"។ "សៈ តើអ្នកណាជាថ្នាក់ស្រុក? ឆៈ ខ្ញុំចាំមិនបានទេថានរណាជាប្រធានថ្នាក់ស្រុក។ ខ្ញុំចាំបានតែយាយ ចែមទេ។ យាយ ចែម គឺជាអ្នកបានទៅជួប ហើយយាយ ចែម បានសុំឱ្យទុកជីវិតរបស់ខ្ញុំ។ តើត្រឹមត្រូវទេ? ឆ.12៖ បាទ ត្រឹមត្រូវ"]។

703 ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.42 KH 01114731 [សាក្សីគឺជានីរសាររបស់ អ៊ឹម ចែម៖ "ខ្ញុំអាចប្រាប់ថា ប្រធានសហករណ៍ទាំងអស់ មកពិភាក្សាជាមួយគាត់អំពីការចាប់ទាំងនោះ បានន័យថា រាល់ចង្កោមអ្នកទោសទាំងអស់ គឺត្រូវឆ្លងកាត់យាយ ចែម ជាមុន'']។

704 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.222 KH 00953050 [សាក្សីគឺជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង ៖ "សហករណ៍ពិភាក្សាផ្ទាល់ជាមួយ យាយ ចែម ថាតើត្រូវចាប់ ឬមិនចាប់។ យាយ ចែម ជាអ្នកសម្រេចថា បើមិនអាចអប់រំនៅក្នុងសហករណ៍បាន ត្រូវបញ្ជូនទៅមន្ទីរអប់រំ"]។

705 ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ាវ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.37-38 KH 01024749 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅព្រះនេត្រព្រះ៖ ["ឈ្មោះ គិត ដែលជាប្រធានភូមិជញ្ជាំង ហើយជាកម្មាភិបាលនិរតី។ [...] នៅពេលនោះ គិត បានចាប់ពួកយើងប្រហែល៦ ឬ៧នាក់ ហើយដឹកតាមគោយន្តឱ្យទៅផ្ទះយាយ ចែម ដែលមានទីតាំងនៅភ្នំលៀប ក្នុងគោលបំណងបញ្ជូនយើងទៅភ្នំត្រយោង។ នៅពេលគោយន្តដឹកពួកយើង គឺពួកយើងមិនត្រូវបានគេចងទេ។ ពេលយើងទៅដល់ផ្ទះយាយ ចែម គាត់មិននៅទីនោះទេ ពីព្រោះគាត់បានគេចខ្លួនបាត់ទៅហើយ ដូច្នេះហើយ ទើប គិត ដឹកយើងមកភ្នំជញ្ជាំងវិញ ហើយឃុំយើងនៅក្រោមផ្ទះ គិត អស់រយៈពេល៣យប់"] ឆ.36 KH 01024748 "ពីព្រោះនៅពេលនោះ ខ្ញុំឮគេនិយាយថា នៅពេលដែលអ្នកណាម្នាក់មានកំហុស ហើយអ្នកនោះត្រូវបានគេបញ្ជូនទៅជួប

យាយ ថែម អ្នកទាំងនោះ ត្រូវយាយ ថែម បញ្ជូនទៅដាក់គុក ឬក៏ត្រូវយាយ ថែម សម្លាប់ចោលដែរ។ អ្នកដែលគេបញ្ជូនទៅដាក់គុកនៅភ្នំត្រយោងនោះ កម្រមានជីវិតណាស់ ព្រោះនៅទីនោះគេបង្ខំឱ្យធ្វើការធ្ងន់ និងបង្អត់អាហារ"]។ ឯកសារ D5/1075 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01144959 [សាក្សីគឺជាកម្មករកងចល័ត៖ "ក្នុងឆ្នាំ ១៩៧៨ ពេលមកដល់ភ្នំត្រយោងភ្លាម ពេលនោះ មិត្ត ថែម ប្រធានយោធា បញ្ជូនឱ្យចុងភៅដាំបាយ ស្ងោរមាន់ឱ្យហូបទៀត រួចមកបញ្ជូនឱ្យឈ្លប ៣ ឬ៤ នាក់ នាំខ្ញុំយកទៅដាក់នៅមន្ទីរសន្តិសុខភ្នំត្រយោង"]

706 ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.20 KH 01114729 [សាក្សីគឺជានីរសាររបស់ អ៊ឹម ថែម៖ "យាយ ថែម បានសួរខ្ញុំថា ហ៊ានទៅជួបឈ្មោះ រាម ដែរឬទេ? ដែលឈ្មោះ រាម ឈរជើងនៅជប់ ហើយជាអ្នកទទួលខុសត្រូវមនុស្សដែលគេចាប់យកទៅ ខ្ញុំបានឆ្លើយប្រាប់គាត់ថា ខ្ញុំហ៊ានទៅ។ ដល់ខ្ញុំទៅ ឃើញនីរសារនៅទីនោះ នីរសារមិនទាន់ឱ្យខ្ញុំចូល ពេលនោះ រាម កំពុងតែដេក។ ពេលខ្ញុំឈប់បានកន្លះម៉ោង រាម ចេញមក ហើយគាត់បាននិយាយថា មិនមានអីទេ ហើយថា ពេលខ្ញុំត្រឡប់ទៅវិញ ត្រូវយកមនុស្សប្រាំពីរនាក់ទៅឱ្យយាយ ថែម ផង"]។

707 ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.9 KH 00915872 [សាក្សីធ្វើការនៅក្នុងកងចល័តកុមារនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ស៖ លោកដឹងទេថា តើនរណាជាប្រធាននារីមកពីនិរតី? ឆ.9៖ ខ្ញុំមិនច្បាស់ដែរ ប៉ុន្តែពួកគេហាក់បីដូចជាមានអំណាចក្នុងការចាប់មនុស្សទាំងអស់នោះ។ ខ្ញុំបានឃើញគេសម្លាប់មនុស្សប្រុសស្រីមួយគូនៅមុខកាច់ជ្រុងវត្តព្រះនេត្រព្រះ"]។ ឯកសារ D1.3.11.12 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ច្រាច់ គិត ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ EN 00210424 [សាក្សីគឺជាជាងឈើនៅព្រះនេត្រព្រះ៖ "ការប្រជុំគឺអំពីគណៈរងស្រុក តើគាត់ឈ្មោះអ្វី? ការប្រជុំនោះធ្វើឡើងនៅវត្តព្រះនេត្រព្រះ។ បន្ទាប់ពីការប្រជុំនោះ គណៈរងស្រុក ត្រូវបានចាប់ខ្លួន។ គាត់ឈ្មោះ សំ អាត។ យាយ ថែម ជាអ្នកចាប់ខ្លួនគាត់"]។

708 ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.20 KH 00915874 [សាក្សីធ្វើការនៅក្នុងកងចល័តកុមារនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ខ្ញុំបានឃើញគេចាប់មនុស្សជាច្រើននៅតាមការដ្ឋាន ប៉ុន្តែខ្ញុំមិនបានឃើញគេសម្លាប់ផ្ទាល់ភ្នែកទេ។ មនុស្សដែលគេចាប់នោះ គឺត្រូវបានគេយកចេញទៅក្រៅ។ ការចាប់ខ្លួនមនុស្សភាគច្រើនគឺនៅព្រះនេត្រព្រះ មានច្រើនជាងនៅទំនប់ស្ពានស្រែង។ ខ្ញុំនិយាយនេះ គឺនិយាយតែនៅក្នុងកងចល័តកុមារ ប៉ុន្តែខ្ញុំដឹងថា នៅក្នុងកងចល័តយុវជន និងវ័យកណ្តាល គឺមានការចាប់ខ្លួនច្រើនជាងនេះ"]។

709 ឯកសារ D1.3.11.12 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ច្រាច់ គិត ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ EN 00210424 [សាក្សីជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះ៖ "ប្រជុំអំពីអនុលេខា តើគាត់ឈ្មោះអ្វី? ការប្រជុំបានធ្វើនៅវត្តព្រះនេត្រព្រះ]។ ក្រោយពីប្រជុំ អនុលេខាស្រុកត្រូវបានចាប់ខ្លួន។ គាត់ឈ្មោះ សំអាត។ គឺយាយថែមជាអ្នកនាំគាត់ទៅ"]។ ឯកសារ D219/95 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.28 ឆ.30-31 KH 01043181 [សាក្សីបានធ្វើការក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "ខ្ញុំចង់កែតម្រូវសំណួរ-ចម្លើយ១៣ នៅឆ្នាំ ១៩៧៨ យាយថែម ហៅខ្ញុំ និងឈ្មោះទី ទៅប្រជុំជាមួយគាត់នៅមន្ទីរស្រុក។ ពេលដែលយើងទៅដល់មន្ទីរយាយថែម យើងបានជួបជាមួយយាយថែម ហើយគាត់បានប្រាប់ថា ឱ្យខ្ញុំនិងទីទៅភ្នំទ្រយោង"] ឆ.30 KH 01043181 ["ស៖តើលោកនៅចាំ

បានទេថា អ្នកណាមកប្រាប់ឱ្យលោកទៅប្រជុំជាមួយយាយថែម? ឆ.30៖ កាលនោះ មានលិខិតពីយាយថែម ផ្ញើមកឱ្យទី ហើយទីបានប្រាប់ខ្ញុំបន្ត"] ឆ.31 KH 01043181 ["សះ តើលោកបានអានលិខិតនោះទេ? ឆ.31៖ ពេលនោះ ទី ជាអ្នកកាន់លិខិតនោះ ដែលប្រាប់ថា ឱ្យមកប្រជុំជាមួយយាយថែម"] ឆ.35 KH 01043181 ["យាយថែម ប្រាប់ខ្ញុំផ្ទាល់មាត់ឱ្យទៅប្រជុំនៅភ្នំទ្រយោង"] ឆ.38 KH 01043181 ["ពេលខ្ញុំទៅដល់ភ្នំទ្រយោង មានឈ្លបម្នាក់ ឬពីរនាក់បានប្រាប់ខ្ញុំឱ្យទៅបែនស្រូវ ថានេះជាភារកិច្ចរបស់អ្នកឯង"]។ ឯកសារ D119/137 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិត អៀក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.37 KH 01003860 [សាក្សីជាអ្នកធ្វើការនៅផ្នែកសេដ្ឋកិច្ចនៅភ្នំល្មៀប៖ "សះតើលោកអាចបែងចែកពីការហៅទៅប្រជុំធំៗ ដូចជាមានគណៈស្រុក យាយថែម ជាប្រធាន ហើយមានសមាជិកច្រើនចូលរួម ហើយនិងការហៅមនុស្សមួយចំនួនតូច ក្នុងបំណងចាប់ខ្លួនបានដែរឬទេ? ឆ.37៖ មិនសូវប្រាកដទេ ពីព្រោះជួនកាលគេហៅមនុស្សពីរបីនាក់ឱ្យទៅទទួលផែនការ ហើយតាមពិតគេចាប់អ្នកនោះ ហើយជួនកាល គេហៅមនុស្សនោះ ទៅប្រជុំដើម្បីទទួលផែនការ ប៉ុន្តែមិនមែនហៅទៅចាប់ខ្លួនទេ។ ល្បិចកលទាំងនេះ គឺគេធ្វើឱ្យយើងមានការច្របូកច្របល់ក្នុងចិត្ត"]។

710 ឯកសារ D119/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច ឈានឡុង ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.41-44 KH 01024759-01024760 [សាក្សីជាប្រធានកងភ្ជួររាស់នៅព្រះនេត្រព្រះ៖ "ឆ.41៖ ខ្ញុំធ្លាប់បានចូលរួមប្រជុំម្តងនៅភ្នំលាប នៅចុងឆ្នាំ១៩៧៦ ដែលពេលនោះគណៈស្រុកជាអ្នកដឹកនាំអង្គប្រជុំ"។ សះ តើគណៈស្រុកនោះជាអ្នកណា? ឆ.42៖ គឺយាយថែម។ សះ តើកិច្ចប្រជុំនៅគេបានលើកឡើងអំពីអ្វីខ្លះ? ឆ.43៖ ក្នុងអង្គប្រជុំ យាយថែម និយាយថា នៅរដូវបង្កបង្កើនផល គឺត្រូវចម្រាញ់អ្នកដែលមានឋានន្តរស័ក្តិយកទៅសម្លាប់ចោល គឺធ្វើដូច្នេះដើម្បីសល់អង្ករទុកសម្រាប់ឱ្យអ្នកដែលមិនជាប់និន្នាការជាមួយចាស់។ សះ តើនៅក្នុងអង្គប្រជុំនោះ មានមនុស្សចូលរួមប៉ុន្មាននាក់? ឆ.44៖ នៅពេលនោះ មានមនុស្សចូលរួមប្រហែល ៧០-៨០នាក់ចូលរួម ដែលមានឋានៈចាប់ពីប្រធានកងឡើងទៅនោះ ជាមនុស្សក្នុងភូមិភាគពាយ័ព្យ ឬក៏និរតី"] ឆ. 46-47 KH 01024760 [សាក្សីជាប្រធានកងភ្ជួររាស់នៅព្រះនេត្រព្រះ៖ "សះ នៅពេលដែលអង្គប្រជុំ [នៅក្នុងអង្គប្រជុំគណៈស្រុកនៅភ្នំល្មៀបដែលដឹកនាំដោយ អ៊ឹម ចែម] បានបញ្ចប់ តើលោកមានសម្គាល់ឃើញថា មានការចាប់ខ្លួនកើតឡើងច្រើននៅក្នុងតំបន់របស់លោកដែរឬទេ? ឆ.46៖ បាទ មាន។ សះ តើលោកអាចរៀបរាប់ឱ្យបានលម្អិតអំពីរឿងនេះបន្ថែមទៀតបានទេ? ឆ.47៖ ខ្ញុំដឹងថា សហករណ៍មានតួនាទីបញ្ជាប្រធានកងធំនានាឱ្យចុះចាប់មនុស្សនៅតាមកងរបស់ខ្លួន។ កម្មាភិបាលនិរតីដែលគ្រប់គ្រងសហករណ៍មានឯកសារឈ្មោះមនុស្សដែលត្រូវចាប់ខ្លួន ហើយពួកគេទទួលបានឯកសារនោះមកពីភ្នំពេញ។ ប្រធានកងធំដែលមានគ្នា៣ទៅ៤នាក់ក្នុងមួយក្រុម មានតួនាទីចុះចាប់មនុស្សនៅក្នុងកងរបស់ខ្លួន"] ឆ.54 KH 01024761 ["ខ្ញុំគិតថា ក្នុងតួនាទីគាត់ជាគណៈស្រុក យាយថែម ត្រូវតែដឹងអំពីការចាប់ខ្លួនមនុស្សនៅក្នុងស្រុករបស់គាត់ ហើយខ្ញុំគិតថា គាត់គឺជាអ្នកចេញបញ្ជាឱ្យចាប់មនុស្សទាំងនោះនៅក្នុងស្រុករបស់គាត់"]។

711 ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.29 KH 00976178 [សាក្សីជាប្រធានកងចល័តដែលមានកម្មករ ៣០ នាក់ ត្រូវបានចាត់ឱ្យទៅធ្វើការនៅត្រពាំងថ្ម ក្រោយមកទៅស្ពានស្រែង៖ "សះ នៅទំព័រទី១២ដដែល លោកបាននិយាយអំពីអ្នកនៅក្នុងកងរបស់លោកដែលស្គមស្គាំង ហើយបានរត់ ហើយត្រូវបានកូនចៅ យាយថែម ចាប់ដាក់នៅមន្ទីរសន្តិសុខ។ តើលោកអាចពន្យល់បញ្ជាក់បន្ថែមបានដែរឬទេ? ឆ.29៖ ពេលនោះដោយសារកូនក្រុមរបស់ខ្ញុំស្គមស្គាំង ពួកគេក៏បានរត់ចេញពីការដ្ឋាន។ ពេលនោះពួកឈ្លបដែលជាកូនចៅរបស់ យាយថែម បានចាប់ពួក

គេ។ ក្រោយពីពួកគេទាំងនោះត្រូវបានគេសួរថា តើលួចរត់មកពីកងណា ហើយពួកគេបានប្រាប់ថា ពួកគេបានលួចរត់ពីកងរបស់ខ្ញុំ។ ដូច្នេះហើយបានជា យាយថែម បានប្រាប់ទៅ តាពាល់ ហើយ តាពាល់ បានប្រាប់មកខ្ញុំឱ្យទៅទទួលយកកូនក្រុមរបស់ខ្ញុំមកការដ្ឋានវិញ”]។ ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045324 [សាក្សី OCIJ-068 (ទុំ សឿន - ប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង)៖ “ធ៖ ខ្ញុំមិនបានបញ្ជូនអ្នកយាមទៅតាមចាប់អ្នកទោសនោះទេ គឺខ្ញុំត្រូវរាយការណ៍ឱ្យទៅ យាយថែម តែប៉ុណ្ណោះ។ [...] នៅពេលយើងរាយការណ៍ទៅថ្នាក់លើ គឺថ្នាក់លើចាត់វិធានការណ៍បន្តទៅទៀត”] KH 01045323 [សាក្សី OCIJ-068៖ “មានមួយដង គឺអ្នកវាយថ្មបានរត់គេចដោយយកដែកវាយអ្នកយាមហើយរត់គេចបាត់ទៅ។ អ្នករត់រួចនោះ មិនត្រូវបានចាប់បានទេ។ ខ្ញុំបានរាយការណ៍ពីការរត់គេចនេះទៅ យាយថែម។ យាយថែម មិនបាននិយាយអ្វីនោះទេ។ ហើយ ខាងលើ ចាត់វិធានការណ៍យ៉ាងម៉េចខ្ញុំមិនដឹងទេ។ ហើយ គាត់ក៏មិនដែលបានជូនដំណឹងមកខ្ញុំទាក់ទងនឹងបញ្ហានេះដែរ”] KH 01045325 [សាក្សីOCIJ-068៖ “ខ្ញុំគ្រាន់តែរាយការណ៍ទៅយាយថែម អំពីបញ្ហានេះ ហើយខ្ញុំមិនដឹងពីការចាត់វិធានការណ៍របស់គាត់នោះទេ”]។

712 ឯកសារ D119/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស្វើយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឆ.15 KH 00894518 [សាក្សីជាប្រធានកងតូចនៅកងចល័តតំបន់៖ “ខ្ញុំមិនដឹងទេ ព្រោះខ្ញុំធ្វើការនៅកងចល័ត ហើយខ្ញុំបានមកលេងឪពុកម្តាយបានតែម្តងគត់។ ពេលនោះ គាត់នៅធ្វើការនៅភ្នំត្រឡោក។ ពេលនោះ ខ្ញុំបានមកពីកងចល័តជាមួយ២នាក់ផ្សេងទៀត។ នៅភ្នំត្រឡោក ដោយខ្ញុំមិនមានលិខិតធ្វើដំណើរ គេបាននាំខ្ញុំមកមន្ទីរឃុំភ្នំលៀប។ ពេលនោះ អ្នកដែលមកជាមួយខ្ញុំដឹងថា គេចាប់ខ្ញុំមកដាក់មន្ទីរឃុំ ពួកគេបានវិលត្រឡប់ទៅកងចល័តវិញ ហើយប្រាប់ប្រធានវីរៈថា ខ្ញុំត្រូវបានគេចាប់ដាក់មន្ទីរឃុំ ព្រោះមិនមានលិខិតធ្វើដំណើរ។ ពេលនោះ ប្រធានវីរៈបានទាក់ទងទៅយាយថែម ហើយនៅព្រឹកថ្ងៃបន្ទាប់ គេបានដោះលែងខ្ញុំឱ្យទៅលេងឪពុកម្តាយខ្ញុំវិញ”]។

713 ឯកសារ D101/1.2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 00743550 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ “អាត្មាមិនដឹងហេតុអ្វីបានជាគេចាប់អាត្មាមកទេ។ កាលនោះ ប្រហែលខ្ទង់ឆ្នាំ ១៩៧៨ អាត្មាត្រូវបានគេឱ្យចល័តទៅធ្វើការនៅស្វាយស៊ីសុផុន។ ពេលនៅបានត្រឹមប្រហែល១ខែ ត្រូវបានគេចាប់យកមកភ្នំត្រយ៉ូងនេះឯង។ អាត្មាជាប់ណៅទីនោះប្រហែលជា ៦ ខែ”]។

714 ឯកសារ D101/1.2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 00743551 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ “អាត្មាបានជួបតែម្តងគត់ពេលដែលគេចាប់អាត្មាទៅភ្នំលាប។ ពេលនោះអាត្មាជិះឡានទៅជាមួយអ្នកដែលចាប់អាត្មាទៅ ហើយគេបានឱ្យចុះអង្គុយនៅតុមួយនៅភ្នំលាប ហើយគេឱ្យចុងភៅលើកបាយមកឱ្យអាត្មា។ ពេលនោះ អាត្មាបានឃើញអ្នកដែលចាប់អាត្មាមកបានចុះទៅនិយាយជាមួយនារីម្នាក់។ អាត្មាមិនដឹងនិយាយអំពីអ្វីទេ ការនិយាយនេះយូរដែរ។ ពេលនោះ ចុងភៅដែលលើកបាយមកបាននិយាយគ្នាថា យាយនោះហើយគឺជាយាយថែម។ អាត្មាជឿថា អ្នកដែលនិយាយជាមួយអ្នកចាប់អាត្មាមកនោះគឺយាយថែមនេះឯង។ ក្រោយពេលនិយាយគ្នាចប់ ទើបគេយកអាត្មាទៅភ្នំត្រយ៉ូង”]។ ឯកសារ D5/1075 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022735 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ “១៩៧៨ ពេលមកដល់ភ្នំទ្រយោងភ្លាម ពេលនោះមិត្តថែមប្រធានយោធា

បញ្ជាឲ្យចុងភៅទៅដាំបាយ ស្ងោរមាន់ឲ្យហូបទៀត រួចមកបញ្ជូនឲ្យឈ្លបពីរ៤នាក់នាំខ្ញុំយកទៅដាក់មន្ទីរសន្តិសុខភ្នំទ្រយោង"]។

715 ឯកសារ D119/49 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.39 KH 00933106 [សាក្សីគឺជាពេទ្យនៅព្រះនេត្រព្រះ និងត្រូវបានឃុំឃាំងនៅភ្នំទ្រយោង៖ "សៈ តើនេះមានន័យថា យាយថែម មានសិទ្ធិអំណាចក្នុងការបញ្ជាឲ្យចាប់ខ្លួនមនុស្សដាក់គុកមែនទេ? ឆ.39៖ បាទ"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.56 KH 00976183-00976184 [សាក្សីជាប្រធានកងចល័តដែលមានកម្មករ ៣០ នាក់ ត្រូវបានចាត់ឲ្យទៅធ្វើការនៅត្រពាំងថ្ម ក្រោយមកទៅស្ពានស្រែង៖ "សៈ លោកនិយាយថា លោកធ្លាប់បានទៅទទួលអ្នកទោសនៅមន្ទីរសន្តិសុខភ្នំលៀប មកកងរបស់លោកវិញ ហើយឃើញយាយថែមបញ្ជូនទៅភ្នំត្រយ៉ូង។ តើយាយថែម ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខទាំងនោះឬ? ឆ.56៖ តាមការអង្កេតរបស់ខ្ញុំ យាយថែម ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខទាំងនោះ"]។ ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.37 KH 01114730 [សាក្សីជានិរសាររបស់ អ៊ឹម ចែម៖ "សៈ បើគុកនៅជប់ លោកថាគុកទើបនឹងបង្កើត ហើយចុះកន្លែងវាយថ្មហ្នឹង ទើបនឹងបង្កើតដែរមែនទេ? ឆ.37៖ បាទ កន្លែងវាយថ្មគឺថ្មីដែរ ហើយ អ៊ឹម ចែម ក៏ជាអ្នកទទួលខុសត្រូវនៅកន្លែងហ្នឹងដែរ"] ឆ.42 KH 01114731 [សាក្សីជានិរសាររបស់ អ៊ឹម ចែម៖ "សៈ តើលោកគិតថា យាយថែម ជាអ្នកទទួលខុសត្រូវរឿងការស្លាប់របស់មនុស្ស នៅស្រុកព្រះនេត្រព្រះដែរឬទេ? ឆ.42៖ បាទ គឺខ្ញុំគិតថា គាត់ជាអ្នកទទួលខុសត្រូវព្រោះរាល់ការងារទាំងអស់ និងអ្នកទោសទាំងអស់នៅស្រុកព្រះនេត្រព្រះ"]។ ឯកសារ D219/255 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ រឿប ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៥ ឆ.21 KH 01085158 [សាក្សីជាអនុប្រធានភូមិនៅព្រះនេត្រព្រះ៖ "សៈ តើលោកដឹងទេថា ការដ្ឋាន កន្លែងឃុំឃាំងទាំងអស់គឺគ្រប់គ្រងដោយយាយថែមឬ? ឆ.21៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D119/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.61 KH 01003887 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "តាមរយៈបទពិសោធរបស់ខ្ញុំក្នុងសម័យនោះ ក្នុងនាមគាត់ជាគណៈស្រុកព្រះនេត្រព្រះ ដូច្នេះគាត់អាចមានតួនាទី និងសិទ្ធិអំណាច គ្រប់គ្រងនៅក្នុងគុកទាំងពីរនោះហើយ ពីព្រោះគុកទាំងពីរនោះ វាស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ"]។ ឯកសារ D119/33 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឆ.22 KH 00923048 [សាក្សីជាប្រធានផ្នែកសេដ្ឋកិច្ចកងចល័តតំបន់៥៖ "តាមខ្ញុំយល់ ពេលយាយថែមឡើងជាគណៈជំនួស តារិន គាត់ក៏មានសិទ្ធិអំណាចគ្រប់គ្រងមន្ទីរសន្តិសុខនេះដែរ ព្រោះមន្ទីរសន្តិសុខនេះស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់តំបន់៥"]។ ឯកសារ D119/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឆ.9 KH 00894513 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "ក្នុងតួនាទីជាគណៈស្រុក យាយថែម មានសិទ្ធិអំណាចគ្រប់គ្រងស្រុក និង មន្ទីរសន្តិសុខហើយមើលទៅ"]។ ឯកសារ D119/144 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឆ.63 KH 01009213 [សាក្សីជាទាហានស្រុកភ្នំស្រុក និងបានធ្វើការក្នុងកងចល័ត៖ "សៈ ដូច្នេះមានន័យថា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈស្រុកដែលជាកម្មាភិបាលនិរតីអាចមានសិទ្ធិគ្រប់គ្រងមន្ទីរសន្តិសុខដែរឬទេ? ឆ.63៖ បាទ ត្រឹមត្រូវហើយ ពីព្រោះក្រោយពីពួកកម្មា

ភិបាលពាយ័ព្យត្រូវចាប់ខ្លួនអស់ ពួកកម្មាភិបាលនិរតីបានឡើងជំនួស ហើយពួកកម្មាភិបាលនិរតីទាំងនេះ ត្រូវរាយការណ៍ផ្ទាល់ទៅគណៈស្រុកតែម្តង"]។

716 ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ាក់ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.37-38 KH 01024749 [សាក្សីជាពលករក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "ឈ្មោះ គិត ដែលជាប្រធានភូមិជញ្ជាំង ហើយជាកម្មាភិបាលនិរតី [...]។ នៅពេលនោះ គិត បានចាប់ខ្លួនពួកយើងប្រហែល៦ឬ៧នាក់ ហើយដឹកតាមគោយន្តឱ្យទៅផ្ទះយាយថែមដែលមានទីតាំងនៅភ្នំលាប ក្នុងគោលបំណងបញ្ជូនយើងទៅភ្នំត្រយោង។ នៅពេលគោយន្តដឹកពួកយើង គឺពួកយើងមិនត្រូវបានគេចងទេ។ ពេលយើងទៅដល់ផ្ទះយាយថែម គាត់មិននៅទីនោះទេ ពីព្រោះគាត់បានគេចខ្លួនបាត់ទៅហើយ ដូច្នេះហើយទើប គិត ដឹងយើងមកភ្នំជញ្ជាំងវិញ ហើយឃុំយើងនៅក្រោមផ្ទះ គិត អស់រយៈពេល៣យប់"]។ ឆ.36 KH 01024748 ["ពីព្រោះនៅពេលនោះ ខ្ញុំឮគេនិយាយថានៅពេលដែលអ្នកណាម្នាក់មានកំហុស ហើយអ្នកនោះត្រូវបានគេបញ្ជូនទៅជួបយាយថែម អ្នកទាំងនោះត្រូវយាយថែមបញ្ជូនទៅដាក់គុក ឬត្រូវយាយថែមសម្លាប់ចោលដែរ។ អ្នកដែលគេបញ្ជូនទៅដាក់គុកនៅភ្នំត្រយោងនោះកម្រមានជីវិតណាស់ ព្រោះនៅទីនោះគេបង្ខំឱ្យធ្វើការធ្ងន់ និងបង្អត់អាហារ"]។ ឯកសារ D5/1075 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022735 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "១៩៧៨ ពេលមកដល់ភ្នំទ្រយោងភ្លាម ពេលនោះមិត្តថែមប្រធានយោធាបញ្ជាឱ្យចុងភៅទៅដាំបាយ ស្ងោរមាន់ឱ្យហូបទៀត រួចមកបញ្ជូនឱ្យឈ្លបពារី៤នាក់នាំខ្ញុំយកទៅដាក់មន្ទីរសន្តិសុខភ្នំទ្រយោង"]។

717 ឯកសារ D219/151 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ជៀង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឆ.3 KH 01058746 [សាក្សីជាអ្នកធ្វើការក្នុងសហករណ៍មួយនៅភ្នំលៀប និង ជាអ្នកបររទេះគោ៖ "នៅទល់មុខផ្ទះយាយយាយថែម គឺជាផ្ទះដែលយោធាធ្វើជាមួយគាត់រស់នៅ ពុំមានមន្ទីរពេទ្យទេ ហើយផ្ទះនោះនៅរហូតដល់សព្វថ្ងៃនេះ។ តាមការសង្កេតរបស់ខ្ញុំមានមន្ទីរសន្តិសុខមួយនៅក្រោយផ្ទះដែលយោធានោះរស់នៅ ពុំមានមន្ទីរពេទ្យទេ។ មូលហេតុដែលខ្ញុំដឹងថា នៅទីនោះមានមន្ទីរសន្តិសុខដែរ ព្រោះប្អូនថ្លៃរបស់ខ្ញុំឈ្មោះ សាំង ដែលមានផ្ទះនៅម្តុំនោះដែរ។ នៅពេលមួយ ខ្ញុំបានទៅលេងគាត់ ហើយខ្ញុំបានឃើញអ្នកទោសត្រូវបានគេធ្វើទារុណកម្មនៅទីនោះ ដោយវាយនឹងកៅអីឈើ។ អ្នកទោសទាំងនោះខ្លះជាមិត្តភក្តិរបស់ខ្ញុំ នៅពេលដែលគេឃើញខ្ញុំដើរនៅទីនោះ គេស្រែកឱ្យខ្ញុំជួយគេផង។ ទីនោះ គឺជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន មុនពេលគេបញ្ជូនទៅឃុំឃាំងនៅភ្នំត្រយោង ឬយកទៅសម្លាប់"] ឆ.4 KH 01058747 ["តាមខ្ញុំដឹង នៅពេលយប់ គេបញ្ចេញអ្នកទោសទាំងនោះទៅវៃចោលនៅភ្នំត្រយោងតែម្តង"] ឆ.5 KH 01058747 ["ស៖ តើលោកដឹងអំពីរឿងនេះពីប្អូនថ្លៃរបស់លោកឈ្មោះ សាំង នោះមែនទេ? ឆ.5៖ បាទ ត្រឹមត្រូវហើយ។ សាំង គឺជាឈ្លបឃុំ តែខ្ញុំមិនដឹងមេវាឈ្មោះអីទេ គ្រាន់តែដឹងថា យាយថែម គឺជាមេស្រុក"]។ ឆ.9-10 KH 01058748-01058749 [សាក្សីមានមូលដ្ឋានក្នុងសហករណ៍មួយនៅភ្នំលៀប៖ "ឆ.9៖ កាលនោះ គេប្រើឱ្យខ្ញុំដឹកស្រូវពីភូមិឡោទេ ទៅឱ្យពួកអ្នកភ្ជួរនៅក្នុងភូមិកំបោរ។ ខ្ញុំបររទេះកាត់ទីនោះ ហើយប្រទះឃើញរណ្តៅសាកសពដូចខ្ញុំរៀបរាប់ខាងលើ ដោយមានឈាម និងចំណងពោះត្នោតនៅជុំវិញរណ្តៅនោះផង។ ក្រោយមកទៀត ខ្ញុំឮពីប្អូនថ្លៃឈ្មោះ សាំង នោះថា ជារណ្តៅសាកសពមិត្តភក្តិរបស់ខ្ញុំ រួមទាំងពូករបស់ខ្ញុំផង ដែលគេបានសម្លាប់ពីយប់។ ខ្ញុំអាចឃើញសាកសពទាំងនោះ ដោយគេកប់រាក់ៗប៉ុណ្ណោះ ព្រោះខ្ញុំអាចមើលឃើញ ទោះបីអង្គុយបរទេះក៏ដោយ ហើយរណ្តោះនោះមានទំហំប្រហែល ៣X៣ម៉ែត្រ និងឆ្ងាយពីផ្លូវប្រហែល១៥ម៉ែត្រប៉ុណ្ណោះ។ ហេតុការណ៍នេះ កើតឡើងនៅម្តុំពាក់

កណ្ដាលឆ្នាំ១៩៧៨ ហើយ។ តាមខ្ញុំសង្កេត សាកសពទាំងនោះ ភាគច្រើនមានតែខោខ្លីទេ ហើយខ្លះក៏មានអាវនៅជាប់នឹងខ្លួនដែរ។ ស៖ តើឈ្មោះ សាំង ដែលជាប្អូនថ្លៃរបស់លោកបានប្រាប់លោកថា អ្នកទាំងនោះ គឺជាមនុស្សដែលគេយកមកពីភ្នំត្រយោង ឬក៏មន្ទីរសន្តិសុខបណ្ដោះអាសន្នដែលមានទីតាំងនៅទល់មុខផ្ទះយាយថែម? ឆ.10៖ បើតាម សាំង អ្នកទាំងនោះ ត្រូវបាននាំយកទៅសម្លាប់នៅទីនោះពីមន្ទីរសន្តិសុខបណ្ដោះអាសន្ន ដែលមានទីតាំងនៅទល់មុខផ្ទះយាយថែម។ ឈ្មោះ ប៉ាវ (ស្លាប់) ដែលជាអ្នកភូមិ ហើយធ្វើការល្អ ពួកឈ្លបតែងតែប្រើគាត់ឲ្យធ្វើការងារផ្សេងៗរួមទាំងជីករណ្ដៅនោះផង ក៏បានបញ្ជាក់អំពីហេតុការណ៍នេះដែរ ព្រោះគេឲ្យគាត់ជីករណ្ដៅជាមុន មុននឹងគេយកអ្នកទាំងនោះទៅសម្លាប់នៅយប់នោះ។ ជាទូទៅ នៅយប់ដែលគេយកអ្នកទោសទៅសម្លាប់ គេតែងប្រកាសអាសន្នប្រាប់ប្រជាជន ដែលរស់នៅតាមបណ្ដោយផ្លូវជាតិមិនឲ្យឆ្លងផ្លូវពីម្ខាងទៅម្ខាងទៀតទេ ព្រោះខ្លាចឃើញសកម្មភាពយកអ្នកទោសទៅសម្លាប់របស់ពួកគេ។ ប្រជាជនដែលរស់នៅតាមបណ្ដោយផ្លូវជាតិ គឺសុទ្ធតែជាសាច់ញាតិ ឬក្រុមគ្រួសាររបស់ពួកឈ្លប ពួកទាហាន និងកម្មាភិបាលខ្មែរក្រហមទាំងអស់។ ចំណែកឯប្រជាជនដែលអ្នកមូលដ្ឋាននៅទីនោះ ត្រូវបានគេជម្លៀសឲ្យទៅនៅកន្លែងផ្សេងៗឆ្ងាយពីនេះអស់ហើយ"]។ ឯកសារ D219/141 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥ ឆ.58 KH 01056107 [សាក្សីជាអ្នកធ្វើការក្នុងកងចល័ត៖ "ស៖ តើសាលាឃុំភ្នំលៀប និងផ្ទះយាយថែមមានចម្ងាយប៉ុន្មានពីគ្នា? ឆ.58 ៖ មានចម្ងាយប្រហែល៥-៦ម៉ែត្រប៉ុណ្ណោះ"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.32-33 KH 00976179 [សាក្សីជាប្រធានកងចល័តដែលមានកម្មករ ៣០ នាក់ ត្រូវបានចាត់ឲ្យទៅធ្វើការនៅត្រពាំងថ្ម ក្រោយមកទៅស្ពានស្រែង៖ "ដំបូង ខ្ញុំទៅជួបយាយថែម នៅផ្ទះរបស់គាត់ ហើយក្រោយមកឈ្លបបាននាំខ្ញុំទៅកាន់មន្ទីរសន្តិសុខនោះដែលមានចម្ងាយ១០០ម៉ែត្រពីផ្ទះរបស់គាត់។ ខ្ញុំបានទៅយកកូនក្រុមរបស់ខ្ញុំ នៅមន្ទីរសន្តិសុខភ្នំលៀប ដែលមានទីតាំងនៅខាងលិចវត្តភ្នំលៀប [...]។ កន្លែងឃុំមនុស្សនោះ គឺជារោងវែងស្រក់ស្បូវដែលមានប្រវែង១៥ម៉ែត្រ ហើយមានអ្នកទោសបួនជួរដែលត្រូវបានគេដាក់ខ្នោះជើង។ អ្នកទោសមានចំនួនច្រើន ប៉ុន្តែខ្ញុំមិនដឹងពីចំនួនពិតប្រាកដទេ"] ឆ.35-36 KH 00976179 ["គាត់មិនបាននិយាយជាមួយខ្ញុំទេ។ គាត់បាននិយាយច្រើនជាមួយនឹងប្រធានវរៈរបស់ខ្ញុំឈ្មោះ ពាល់ ហើយបានឲ្យឈ្លបនាំខ្ញុំទៅទទួលកូនក្រុមរបស់ខ្ញុំត្រឡប់មកវិញ [...]។ បាទ ខ្ញុំបានឃើញយាយថែម ផ្ទាល់ភ្នែក ប៉ុន្តែខ្ញុំមិនបាននិយាយជាមួយគាត់ទេ"]។ ឯកសារ D219/433 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.14 KH 01124144-01124145 [សាក្សីបានជាប់ឃុំឃាំងនៅភ្នំលៀប៖ "ស៖ លោកស្រីនិយាយថា គេដឹកលោកស្រីតាមឡាន ដោយមានមនុស្សជាច្រើននៅក្នុងឡាននោះរួចហើយបន្ទាប់មកគេដឹកលោកស្រីទៅភ្នំលៀប។ ពេលទៅដល់ភ្នំលៀប តើអ្នកណាជាអ្នកមកទទួលលោកស្រី? ឆ.14៖ គេដឹកពួកខ្ញុំយកទៅដាក់គុក តែគុកពេលនោះមិនដែលដូចគុកសម័យឥឡូវទេ។ កន្លែងនោះជាកន្លែងរបស់មេកង។ ពេលដល់គុកដំបូង គេបានហៅឈ្មោះខ្ញុំ និងបងប្អូនខ្ញុំ រួចគេឲ្យអង្គុយម្នាក់ដោយបំបែកពីអ្នកផ្សេងទៀត។ បន្ទាប់មកគេហៅមនុស្សផ្សេងទៀតចូលទៅក្នុង រួចក៏ចាប់ចងទាំងអស់។ បងស្រីបង្កើតរបស់ខ្ញុំដែលគាត់រាងចំណាស់ជាងខ្ញុំ គាត់ដឹងថាអ្នកផ្សេងទៀតត្រូវគេយកទៅសម្លាប់ចោលអស់ហើយ លើកលែងតែពួកខ្ញុំបួននាក់ប៉ុណ្ណោះ។ បងហៀក ដែលជាបងស្រីបង្កើតរបស់ខ្ញុំ គាត់ត្រូវមេកងខ្មែរក្រហមម្នាក់ស្រឡាញ់ ហេតុដូច្នេះហើយទើបគេមិនយកពួកខ្ញុំទៅសម្លាប់ចោល [...]។ សុខ គាត់ជាមេភូមិនៅពេលនោះ ហើយបើកុំតែបាន សុខ នេះ កុំអីពួកខ្ញុំត្រូវគេសម្លាប់ចោលទាំងអស់។ សុខ មានរូបរាងស្គម ខ្ពស់ ខ្មៅ ហើយពេលនោះគេហៅគាត់ "ប្រធានសុខៗ"។ គុកដែលគេបញ្ជូន

ពួកខ្ញុំទៅដាក់នោះ គឺជាផ្ទះមួយស្ថិតនៅតាមផ្លូវជាតិលេខ៦ ខាងលិចមន្ទីរឃុំភ្នំលៀប (សាលាឃុំភ្នំលៀបបច្ចុប្បន្ន) ហើយផ្ទះនេះនៅរហូតដល់សព្វថ្ងៃនេះ។ ក្រោយពេល សុខ ជួយជីវិតខ្ញុំពីភ្នំលៀប គេបានបញ្ជូនខ្ញុំទៅឡោតេ។ នៅឡោតេ នេះគឺគ្មានអ្វីទាំងអស់ សូម្បីតែត្រកួនមួយក៏គ្មានដែរ។ រួចហើយ សុខ បានទឹកឃើញពួកខ្ញុំ ក៏យកពួកខ្ញុំពីឡោតេ ទៅដាក់នៅភ្នំលៀបវិញ”]។ ឆ.15-16 KH 01124145 [“ខ្ញុំឃើញគេនាំមនុស្សទាំងនោះចេញទៅ តែមិនដឹងថាគេយកទៅសម្លាប់ ឬក៏យ៉ាងណាទេ។ ម្យ៉ាងទៀត នៅពេលនោះខ្ញុំនៅក្មេង ហើយមិនចាប់អារម្មណ៍ទេ ចំណែកបងស្រីខ្ញុំ គាត់បានប្រាប់ថា គេយកអ្នកទាំងអស់នោះទៅសម្លាប់ចោល។ ម្តាយរបស់ខ្ញុំបានទៅលបមើលពួកខ្ញុំ ពេលដែលគេបញ្ជូនពួកខ្ញុំទៅដល់ភ្នំលៀប។ គាត់បានពួននៅខាងក្រោយដើមដូង លបមើលខ្ញុំ ហើយខ្ញុំក៏ឃើញគាត់ផងដែរ។ គាត់ចង់ដឹងថា តើខ្ញុំនៅរស់ដែរឬទេ។ ស៖ លោកនិយាយថា លោកស្រីត្រូវគេបញ្ជូនទៅកន្លែងមេកង តើលោកស្រីចាំថា មេកងនោះមានឈ្មោះអ្វីដែរឬទេ? ឆ.16៖ ខ្ញុំមិនចាំទេ។ តែកន្លែងនេះជាម្តុំផ្ទះរបស់ យាយចែម”]។ ឯកសារ D119/48 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដួង វ័ន្តឌី ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.6 KH 00933098 [សាក្សីបានធ្វើការនៅរោងជាងមួយក្បែរផ្ទះ អ៊ឹម ចែម៖ “នៅពេលដែលពួកនិរតីមកដល់ ខ្ញុំបានឃើញប្រជាជនត្រូវគេចងទាំងខ្សែៗបញ្ជូនទៅសម្លាប់នៅកន្លែងមួយដែលស្ថិតនៅខាងជើងភ្នំទ្រយោង។ អ្នកទោសដែលបញ្ជូនទៅសម្លាប់ត្រូវបានគេទុកនៅក្នុងផ្ទះមួយនៅក្បែរកន្លែងខ្ញុំធ្វើការ ដែលមានចម្ងាយប្រហែល៧០០ម៉ែត្រពីផ្ទះយាយចែម។ អ្នកទោសទាំងអស់នោះត្រូវបានគេយកទៅដាក់នៅពេលថ្ងៃ ហើយនៅពេលយប់ទើបគេយកទៅសម្លាប់”] ឆ.7 KH 00933098 [“ព្រឹត្តិការណ៍នេះកើតឡើង១អាទិត្យម្តង គឺចាប់តាំងពីដើមរហូតដល់ចុងរបបខ្មែរក្រហម។ ខ្ញុំសង្កេតថា ក្នុងម្តងៗ គេយយកមនុស្សច្រើនជាង១០០នាក់ទៅសម្លាប់។ ខ្ញុំនៅចាំថា នៅពេលដែលខ្ញុំឃើញមនុស្សចាស់ៗបិតពោះធាងត្នោត គឺនៅយប់នោះហើយដែលគេយកមនុស្សទៅសម្លាប់ទាំងខ្សែៗ។ មនុស្សដែលគេយកទៅសម្លាប់នោះ ត្រូវបានគេចងដៃដោយពោះត្នោត ហើយយកខ្សែនីឡុងស៊កបន្តពីមួយទៅមួយជាជួរ។ ខ្ញុំដឹងរឿងនេះ ដោយសារកាលនោះគេនិយាយគ្រប់គ្នាពីរឿងសម្លាប់នេះ ហើយក្រោយរបបខ្មែរក្រហម ខ្ញុំបានទៅមើលកន្លែងសម្លាប់នោះ ឃើញសុទ្ធតែលលាដ៍ក្បាល និងឆ្អឹងខ្មោចគរលើគ្នា”] ឆ.8 KH 00933098-00933099 [“ពេលពួកពាយ័ព្យគ្រប់គ្រង គឺពួកពាយ័ព្យអ្នកសម្លាប់ តែពួកនិរតីគ្រប់គ្រងជួនកាលគេប្រើពួកពាយ័ព្យឱ្យសម្លាប់ដែរ ប៉ុន្តែភាគច្រើនគេប្រើពួកកូនចៅរបស់គេដែលជាអ្នកនិរតី”]។ ឯកសារ D119/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស្វ៊ីយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឆ.16 KH 00894519 [សាក្សីជាប្រធានកងតូចនៅកងចល័តតំបន់៖ “ខ្ញុំបានឃើញរោងចំនួនពីរនៅខាងជើងផ្លូវជាតិ។ មន្ទីរឃុំនៅខាងត្បូង។ រោងនោះមានបណ្តោយប្រហែល៧ម៉ែត្រ។ គេប្រាប់ខ្ញុំថា រោងនោះគឺសម្រាប់ដាក់អ្នកទោស។ ខ្ញុំឃើញរោងនោះ តែមិនបានឃើញអ្នកទោសទេ”]។

718 ឯកសារ D219/575 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹក ស្នួង ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.15 KH 01166357 [សាក្សីជាឈ្លបឃុំនៅភូមិប្រាសាទ នៅព្រះនេត្រព្រះ៖ “កាលខ្ញុំធ្វើជាមេឈ្លបឃុំភ្នំលៀប នៅក្រោមពាយ័ព្យ មានមន្ទីរសន្តិសុខមួយ នៅអែបសាលាឃុំ។ បន្ទាប់ពីនិរតីមកដល់ គឺមន្ទីរសន្តិសុខពីរត្រូវបានបង្កើតថ្មី គឺមន្ទីរសន្តិសុខខាងជើងថ្នល់ និងមន្ទីរសន្តិសុខភ្នំទ្រយោង ដែលគ្រប់គ្រងដោយ សឿន ជាកម្មាភិបាលនិរតី។ ពេលដែលនិរតីមកដល់ មន្ទីរសន្តិសុខនៅជាប់មន្ទីរឃុំ ត្រូវបានរំលាយចោល”]។

719 ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.28 KH 00801025 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ “គឺយាយចែម ដែលជាអ្នកគ្រប់គ្រងរួម”]។ ឯកសារ D119/65 កំណត់ហេតុនៃ

ការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.198-199 KH 00953046-00953047 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "សៈ តើយាយចែមជាអ្នកអនុវត្តការងារនៅមន្ទីរអប់រំនោះមែនទេ? ឆ.198៖ មែនហើយ គាត់បានបែងចែកការងារដល់ខ្ញុំ។ សៈ តើគាត់ជាអ្នកដែលចាត់តាំងឱ្យលោកគ្រប់គ្រងមន្ទីរអប់រំនោះមែនទេ? ឆ.199៖ បាទមែន"]។ ឯកសារ D119/138 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សរ ឡោម ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.38 KH 01003873 [សាក្សីបានធ្វើការនៅភូមិស្រែះ ហើយប្តីគាត់ត្រូវបានគេសម្លាប់នៅភ្នំទ្រយោង៖ "ខ្ញុំមិនដឹងថា នរណាជាអ្នកគ្រប់គ្រងទេ ប៉ុន្តែខ្ញុំគ្រាន់តែឮគេនិយាយថា យាយចែម ជាអ្នកគ្រប់គ្រងនៅទីនោះតែប៉ុណ្ណោះ"]។ ឯកសារ D119/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈូក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.28 KH 00933133 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "សៈ តើលោកដឹងអ្វីខ្លះអំពីភ្នំទ្រយោង? ឆ.28៖ ប្រធានគុកគឺ យាយចែម ហើយក៏ជាគណៈស្រុកដែរ តែខ្ញុំពុំដឹងអ្វីទៀតទេអំពីគុកនេះ"]។ ឯកសារ D119/144 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឆ.69-70 KH 01009214 [សាក្សីជាទាហានស្រុកភ្នំស្រុក និងបានធ្វើការក្នុងកងចល័ត៖ "ឆ.69៖ ខ្ញុំធ្លាប់ឮឈ្មោះភ្នំត្រយ៉ូង។ ភ្នំត្រយ៉ូងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ យាយចែម។ ឆ.70៖ ខ្ញុំឮគេនិយាយថា ភ្នំត្រយ៉ូង គឺជាកន្លែងឃុំឃាំងមនុស្ស និងកន្លែងសម្លាប់មនុស្សដ៏ធំមួយ ហើយកន្លែងនេះគឺគ្រប់គ្រងផ្ទាល់ដោយ យាយចែម។ ខ្ញុំបានឮគេនិយាយថា នៅពេលនោះ យាយចែម គាត់ជាមនុស្សម្នាក់កាចខ្លាំងណាស់"] ឆ.71 KH 01009214 ["ក្រោយមក មានមនុស្សដែលបានរត់ចេញពីភ្នំត្រយ៉ូង ហើយបានប្រាប់ខ្ញុំថា នៅភ្នំត្រយ៉ូង មានមន្ទីរសន្តិសុខមួយធំ ហើយក៏ជាកន្លែងសម្លាប់មនុស្សធំដែរ ហើយ យាយចែម ជាអ្នកគ្រប់គ្រងនៅទីនោះ"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.56 KH 00976183-00976184 [សាក្សីជាប្រធានកងចល័តដែលមានកម្មករ ៣០ នាក់ ត្រូវបានចាត់ឱ្យទៅធ្វើការនៅត្រពាំងថ្ម ក្រោយមកទៅស្ពានស្រែង៖ "សៈ លោកនិយាយថា លោកធ្លាប់បានទៅទទួលអ្នកទោសនៅមន្ទីរសន្តិសុខភ្នំលៀប មកកងរបស់លោកវិញ ហើយឃើញយាយចែមបញ្ជូនទៅភ្នំត្រយ៉ូង។ តើយាយចែម ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខទាំងនោះឬ? ឆ.56៖ តាមការអង្កេតរបស់ខ្ញុំ យាយចែម ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខទាំងនោះ"]។ ឯកសារ D219/383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អើយ ពឿ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.28 KH 01113226 [សាក្សីជាអ្នកធ្វើការក្នុងកងចល័ត និងជាអ្នកបានទៅមើលអ្នកទោស៖ "សៈ នៅពេលដែលព្រះតេជគុណទៅដល់ភ្នំត្រយ៉ូង តើព្រះតេជគុណមានដឹងទេថា អ្នកណាជាអ្នកគ្រប់គ្រងនៅទីនោះ? ឆ.28៖ អាត្មាមិនដឹងទេ គ្រាន់តែឮគេថា គុកយាយចែមៗ តែប៉ុណ្ណោះ"] ឆ.32 KH 01113227 ["អាត្មាធ្លាប់ឃើញយាយចែម ជិះម៉ូតូជាមួយនិរសាររបស់គាត់ ឌុបគាត់តាមផ្លូវជាតិជាញឹកញាប់ គឺធ្វើដំណើរពីភ្នំត្រយ៉ូង មកព្រះនេត្រព្រះ ហើយពីស្រុកព្រះនេត្រព្រះមកភ្នំត្រយ៉ូងវិញ។ នៅពេលនោះ អ្នកធ្វើការជាមួយអាត្មាក៏ធ្លាប់ប្រាប់អាត្មាផងដែរថានោះគឺជា យាយចែម"] ឆ.36 KH 01113227 ["គាត់មានសិទ្ធិអំណាចគ្រប់គ្រងលើភ្នំត្រយ៉ូងពីព្រោះគាត់ជាអ្នកក្តាប់រួម"]។ ឯកសារ D43 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នៀម ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ KH 00722205 [សាក្សីជាអ្នកធ្វើការក្នុងកងចល័ត៖ "សៈ តើមន្ទីរសន្តិសុខដែលគាត់មកគ្រប់គ្រងនោះឈ្មោះអ្វី? ឆ៖ គឺមន្ទីរសន្តិសុខភ្នំត្រយោង"]។ ឯកសារ D219/256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.25 KH 01085166 [សាក្សីជាពលករនៅភ្នំលៀប៖ "ខ្ញុំដឹងថា យាយចែម ជាអ្នកគ្រប់គ្រងគុកភ្នំត្រយ៉ូងដោយផ្ទាល់ ព្រោះអ្នកបររទេះមួយចំនួនដែលដឹកស្បៀងពីស្រុកទៅគុកភ្នំត្រយ៉ូងជាអ្នកប្រាប់ខ្ញុំអំពីរឿង

នេះ"]។ ឯកសារ D106/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.18 KH 00800990 [សាក្សីបានរស់នៅចម្ងាយ ២ គ.ម ពីភ្នំទ្រយោង៖ "ស៖ តើលោកចាំទេ អ្នកគ្រប់គ្រងទីនោះឈ្មោះអ្វី? ឆ៖ ខ្ញុំចាំថាមានអ្នកគ្រប់គ្រងម្នាក់ជាស្ត្រីដែលមកពីនិរតី គេហៅគាត់ថា ម៉ែចែម"] ឆ.19 ["[...] ខ្ញុំគ្រាន់តែឮគេថា ម៉ែចែម ជាគណៈស្រុកព្រះនេត្រព្រះ តែគាត់ស្នាក់នៅនិងធ្វើការនៅភ្នំលៀបតែម្តង ពីព្រោះមន្ទីរសន្តិសុខនេះ ជាមន្ទីរសន្តិសុខមួយធំនៅទីនេះ។ ខ្ញុំមិនដែលឃើញគាត់ទេនៅភ្នំត្រយោង ហើយខ្ញុំឃើញតែគេបណ្តើរអ្នកទោសនៅទីនោះ"]។

720 ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.89 KH 00980395 [សាក្សីត្រូវបាន អ៊ឹម ចែម ចាត់តាំងជាគណៈឃុំភ្នំលៀប៖ "តាមខ្ញុំដឹងមន្ទីរសន្តិសុខភ្នំត្រយ៉ូងជាមន្ទីរសន្តិសុខថ្នាក់តំបន់។ តាមខ្ញុំដឹង យាយចែម មានអំណាចគ្រប់គ្រងមន្ទីរសន្តិសុខនោះ"]។ ឯកសារ D219/174 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.37-42 KH 01065989 [សាក្សីបានធ្វើការក្នុងកងចល័តភូមិនៅព្រះនេត្រព្រះ៖ "ស៖ នៅរំដួលគេបានសួរចម្លើយលោកស្រី ហើយគេមិនជឿសម្តីលោកស្រី ហើយនៅពេលគេសួរលោកស្រីនៅជប់វារី ក៏គេមិនជឿចម្លើយលោកស្រីដែរ។ តើគេបញ្ជូនលោកស្រីទៅទីណាទៀត? ឆ.37៖ គេបានបញ្ជូនខ្ញុំទៅចំការខ្នុរ។ ស៖ តើគេបញ្ជូនលោកស្រីទៅចំការខ្នុរនៅស្វាយស៊ីសុផុនឬ? ឆ.38៖ ចាស។ ស៖ តើគេបញ្ជូនលោកស្រីទៅចំការខ្នុរតាមរបៀបណាដែរ? ឆ. 39៖ គេបញ្ជូនខ្ញុំតាមឡានទ្រុង។ នៅពេលដែលគេបញ្ជូនខ្ញុំតាមឡាននោះ គឺមានមនុស្សពេញក្នុងឡាន។ ស៖ ពេលគេបញ្ជូនលោកស្រីតាមឡាននោះ តើគេដាក់ខ្នោះលោកស្រីដែរទេ? ឆ.40៖ គេមិនបានដាក់ខ្នោះខ្ញុំទេ ដោយសារខ្ញុំបានសុំការអនុញ្ញាតគេមិនឲ្យដាក់ខ្នោះខ្ញុំ ប៉ុន្តែមនុស្សផ្សេងៗនៅក្នុងឡានជាមួយខ្ញុំនោះ គឺគេដាក់ខ្នោះទាំងអស់។ ស៖ នៅពេលគេសួរចម្លើយលោកស្រីនៅជប់វារី តើគេសួរចម្លើយលោកស្រីអំពីរឿងអ្វីដែរ? ឆ.42៖ គេសួរខ្ញុំថា តើខ្មាំងមកណា ហើយខ្ញុំស្គាល់ខ្មាំងដែរទេ។ គេបានសួរខ្ញុំអំពីភិនភាគរបស់ខ្មាំងនោះ ហើយខ្ញុំបានឆ្លើយពាក្យតែមួយ ថាខ្មាំងនោះមូរដៃអាវម្ខាង ហើយមូរជើងខោម្ខាង។ ដូច្នេះហើយ បានគេជឿលើខ្ញុំ ហើយខ្ញុំមានការធូរស្រាលទោសវិញ"]។ ឆ.51-52 KH 01065990 ["ស៖ តើលោកស្រីជាប់ឃុំឃាំងនៅជាប់ផ្លូវទៅវត្តព្រះពន្លាអស់រយៈពេលប៉ុន្មាន? ឆ.51៖ ខ្ញុំជាប់នៅទីនោះអស់រយៈពេលមួយខែ។ ស៖ តើមានរឿងអ្វីកើតឡើងចំពោះលោកស្រីក្រោយពេលនោះ? ឆ.52៖ ពួកយើងត្រូវបានគេបញ្ជូនទៅឃុំឃាំងនៅចំការស្នួរវិញ ដែលនៅក្បែរកន្លែងឃុំឃាំងអ្នកទោសបុរស"] ឆ.57 KH 01065991 ["បន្ទាប់ពីខ្ញុំចេញពីចំការស្នួរ គេបានបញ្ជូនខ្ញុំទៅចំការគរ ដែលនៅទីនោះមានអ្នកទោសច្រើនត្រូវបានគេសម្លាប់ ហើយមានអ្នកទោសស្រីតែប្រាំបួននាក់ដែលនៅរស់។ ហើយអ្នកដែលនៅរស់ត្រូវបានគេដឹកតាមឡានយកទៅភ្នំត្រយោង"]។ ឯកសារ D219/400 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.57 KH 01115778 [សាក្សីជាអ្នកទោសនៅភ្នំទ្រយោង៖ "ស៖ គុកនៅភ្នំត្រយោងហ្នឹង តើលោកដឹងថាជាគុកសម្រាប់តំបន់ ៥ ឬសម្រាប់ថ្នាក់ណាទេ? ឆ.57៖ សម្រាប់តំបន់៥ហ្នឹង ព្រោះមានមនុស្សមកពីច្រើនស្រុក"] ឆ.59 KH 01115778 ["ប្រធានគុកអត់ចាំទេ ខ្ញុំចាំតែ យាយចែម ដែលជាអ្នកគ្រប់គ្រងនៅទីនោះ"]។

721 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.148 KH 00953039 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "ពេលយាយចែមឲ្យខ្ញុំទៅនៅជិតទីនោះ កងចល័តក៏នៅជិតនោះដែរ។ បើអ្នកដែលនៅសហករណ៍ក្នុងស្រុកព្រះនេត្រព្រះធ្វើខុស គឺត្រូវបញ្ជូនទៅទីនោះ ហើយការបញ្ជូនមិនមែនតែម្នាក់ទេ គឺ

បញ្ជូនទៅទាំងគ្រួសារ។ យាយថែម ក៏បាននិយាយជាមួយខ្ញុំដែរ ថាឲ្យខ្ញុំមើលខុសត្រូវនៅទីនោះ"] ឆ.158 KH 00953041 ["តាមការពិភាក្សាគ្នាដែលយាយថែមនិយាយជាមួយខ្ញុំ គាត់ឲ្យខ្ញុំរៀបចំកន្លែងអប់រំនោះ។ ខ្ញុំមិនដឹងពីការបញ្ជាមកពីថ្នាក់លើទេ។ ខ្ញុំដឹងតែបញ្ជាមកពីយាយថែម។ អ្នកថ្នាក់ក្រោម ទាល់តែមានបញ្ជាមកពីលើទើបធ្វើ"] ឆ.198-199 KH 00953046-00953047 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "សៈ តើយាយថែមជាអ្នកអនុវត្តការងារនៅមន្ទីរអប់រំនោះមែនទេ? ឆ.198៖ មែនហើយ គាត់បានបែងចែកការងារដល់ខ្ញុំ។ សៈ តើគាត់ជាអ្នកដែលចាត់តាំងឲ្យលោកគ្រប់គ្រងមន្ទីរអប់រំនោះមែនទេ? ឆ.199៖ បាទមែន"]។ ឯកសារ D219/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.20 KH 01058765 [សាក្សីជាអ្នកទោសនៅភ្នំទ្រយោង៖ "យាយថែម គឺជាមេធំលើតាសឿន ទៅទៀត។ ខ្ញុំឮពីអ្នកយាម និងអ្នកទោស នៅភ្នំទ្រយោងនិយាយថា យាយថែម ជាមេរបស់តាសឿន"]។ ឯកសារ D219/567 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.131 KH 01165954 [សាក្សីជាអ្នកទោសនៅភ្នំទ្រយោង៖ "យាយថែម ធំជាង"]។ ឯកសារ D219/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.31-32 KH 01043240 [សាក្សីជាអ្នកយាមនៅមន្ទីរសន្តិសុខភ្នំទ្រយោង៖ "ឆ.31៖ គាត់ប្រាប់ខ្ញុំថាមើលអ្នកទោសធ្វើការងារ កុំឲ្យគេរត់។ តាសឿន ប្រាប់ខ្ញុំដោយផ្ទាល់មាត់ ហើយខ្ញុំអនុវត្តបន្តទៅ។ សៈ តើលោកទទួលបញ្ជាពី តាសឿន ដោយផ្ទាល់តែម្តង ឬក៏យ៉ាងណា? ឆ.32៖ បាទ ខ្ញុំទទួលផ្ទាល់"]។ ឯកសារ D219/256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.28 KH 01085166 [សាក្សីជាពលករនៅភ្នំលៀប៖ "ខ្ញុំធ្លាប់ឮគេហៅឈ្មោះគាត់ថា តាសឿន ជាមេគុកភ្នំត្រយ៉ូង។ ខ្ញុំធ្លាប់ឃើញគាត់ មួយដង ឬពីរដងដែរ នៅពេលដែលខ្ញុំបររទេះគោ ហើយគាត់ជិះកង់ក្នុងទិសដៅបញ្ច្រាសទិសគ្នា ដោយពេលនោះអ្នកដែលធ្វើការជាមួយខ្ញុំបានប្រាប់ខ្ញុំថា មនុស្សម្នាក់នោះគឺជា សឿន មេគុកភ្នំត្រយ៉ូង ជាអ្នកមកពីភូមិភាគនិរតី"]។

722 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.215 KH 00953049 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "ខ្ញុំរាយការណ៍ទៅតែយាយថែមម្នាក់"]។

723 ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ EN 01045303 [សាក្សី OCIJ-068 (ទុំ សឿន - ប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង)៖ "ឲ្យតែជាលិខិតដែលយកមកដោយនិរសាយាយថែម ខ្ញុំដឹងថាវាមកពីគាត់ហើយ ពីព្រោះខ្ញុំស្គាល់និរសាគាត់។ សំបុត្រខ្លះមិនមានហត្ថលេខាទេ ហើយពេលខ្លះជាការណែនាំការងារ។ មិនមានហត្ថលេខាទេ តែពេលខ្លះមានដាក់តែឈ្មោះគាត់ប៉ុណ្ណោះ"]។

724 ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ EN 01072612 [សាក្សី OCIJ-068 (ទុំ សឿន - ប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង)៖ "គឺ មានការណែនាំពីខាងលើ គឺថ្នាក់ស្រុកដែលមានយាយថែម។ យើងពិភាក្សាគ្នា ហើយព្រមព្រៀងគ្នាអំពីអ្វីដែលត្រូវធ្វើចំពោះប្រភេទអ្នកទោសនីមួយៗ។ យាយថែម បានប្រាប់ថា ធ្វើម៉េចត្រូវមើលសភាពការណ៍ និងស្ថានការណ៍របស់ម្នាក់ៗ ដើម្បីសម្រេចវិធានការណាមួយ។ ចំណុចខ្លះ ខ្ញុំបានធ្វើលើសតាមអារម្មណ៍ខ្លួនឯង៖ អ្នកខ្លះ ត្រូវបានចោទថាក្បត់អង្គការ ប៉ុន្តែខ្ញុំមើលឃើញមិនមានខុសធ្ងន់ ខ្ញុំក៏ដោះលែងតាមការពិនិត្យរបស់ខ្ញុំ។ បើសិនជាយាយថែមដឹងរឿងនេះ ខ្ញុំមានកំហុស ប៉ុន្តែជាក់ស្តែង អ្នកទាំងអស់នោះនៅធ្វើការ

នាទីនោះ ដោយមិនមានប្រព្រឹត្តកំហុសជាថ្មីទៀត ហើយនៅទីនោះ ដើម្បីជួយគ្រប់គ្រងប៉ុណ្ណោះ ដោយសារយើងមិនមានមនុស្សគ្រប់គ្រាន់"]។

725 ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.44-45 KH 01043199 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "សៈ ចំពោះអ្នកទោសធ្ងន់ ត្រូវបានដាក់ខ្នោះ តើនរណាជាអ្នកសម្រេចឱ្យដាក់ខ្នោះពួកគេ? ឆ.44៖ តាមពិតទៅ នៅកន្លែងខ្ញុំ គឺខ្ញុំគ្រាន់តែនៅចាំទទួលពួកគេតែប៉ុណ្ណោះ ហើយអ្នកបញ្ជាគឺយាយចែម ជាអ្នកបញ្ជាបញ្ជូនពួកគេមក។ សៈ ចំពោះអ្នកទោសធ្ងន់ដែលដាក់ខ្នោះនៅពេលយប់ ពេលថ្ងៃត្រូវបានដោះខ្នោះដើម្បីបញ្ជូនទៅធ្វើការនៅខាងក្រៅ តើករណីនេះនរណាជាអ្នកបញ្ជាឱ្យដោះខ្នោះអ្នកទោសដើម្បីឱ្យធ្វើការ? ឆ.45៖ ចំពោះករណីនេះ ដំបូងយើងត្រូវរាយការណ៍ទៅថ្នាក់លើ គឺយាយចែម ដើម្បីការអនុញ្ញាត ហើយយាយចែម គឺជាអ្នកសម្រេចថាឱ្យដោះខ្នោះ ឬមិនដោះខ្នោះ គឺស្ថិតក្រោមការសម្រេចចិត្តរបស់យាយចែម។ ខ្ញុំសូមបញ្ជាក់បន្ថែមថា នៅពេលខ្ញុំធ្វើការនៅទីនោះ ខ្ញុំបានសួរគាត់ផ្ទាល់ថា បើសិនជាមានអ្នកទោសដែលបានអប់រំកសាងខ្លួនបានហើយ តើខ្ញុំមានសិទ្ធិអ្វីខ្លះ? នៅពេលនោះ យាយចែម បាននិយាយប្រាប់ខ្ញុំថា បើសិនជាមាននរណាម្នាក់អប់រំកសាងបានល្អ ដូច្នេះខ្ញុំមានសិទ្ធិដោះលែងពួកគេឱ្យពួកគេរស់នៅដូចជាប្រជាជនធម្មតា នៅក្នុងកន្លែងដែលខ្ញុំគ្រប់គ្រង នៅភ្នំត្រយោង"]។

726 ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.26 KH 01128311 [សាក្សីជានិរសាររបស់ អ៊ឹម ចែម៖ "សៈ តើលោកទៅគុកនៅជប់ហ្វឹងញឹបញាប់ដែរឬទេ? ឆ.26៖ គឺ យាយចែមឱ្យទៅតែ១ដងទេ"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ .183 KH 00953944 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "មានតែនិរសាររបស់គាត់ទៅមើលក្នុងរវាងពីរបីថ្ងៃម្តង"] ។ ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ KH 00801026 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "ជួនកាល មាននិរសាមកប្រាប់ថា មានសំណើឱ្យបញ្ជូនមនុស្សមកក្នុងកងរបស់ខ្ញុំ ឬស្នើមនុស្សពីកងរបស់ខ្ញុំ"] សម្រាប់ប្រតិចារឹកដែលមានន័យដូចគ្នា សូមមើល ឯកសារ D219/422.9 ប្រតិចារឹកបទសម្ភាសន៍របស់ ទុំ សឿន ដោយ ក.ស.ច.ស ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ KH 01121654 ["ជួនអីអត់ទេ មកគ្រាន់តែនិរសា គេមកថាឥឡូវគាត់សុំកម្លាំង ២០ នាក់ ១០នាក់ ទៅធ្វើនេះធ្វើនោះអីចឹង"] និង EN 01121652-54។ ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.14-15 KH 01043195 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "យាយចែម ចាត់តាំងឱ្យនិរសាររបស់គាត់មកជួបខ្ញុំ"]។ ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045303 [សាក្សី OCIJ-068 (ទុំ សឿន - ប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង)៖ "លិខិតដែលយកមកដោយនិរសាយាយចែម"]។

727 ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045303 [សាក្សី OCIJ-068 (ទុំ សឿន - ប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង)៖ "ខ្ញុំមិនដែលបានទទួលសំបុត្រពីយាយចែមឱ្យដោះលែងអ្នកទោសទេ ប៉ុន្តែធ្លាប់ជជែកពិភាក្សាទល់មុខគ្នា នៅពេលយើងចង់ដោះលែងអ្នកទោសស្រាល។ ពេលដែលយើងជជែកគ្នា បើអ្នកទោសស្រាលគួរត្រូវដោះលែង យើងទាំងអស់គ្នាឯកភាពដោះលែង។ អ្នកខ្លះត្រូវបានចោទថាប្រឆាំងសហករណ៍ ប៉ុន្តែពេលមកដល់ទីនេះ យើងឃើញថាពួកគេមិនបានប្រឆាំងសហករណ៍នោះទេ"]។

728 ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.37-39 KH 01043198 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង៖ "ភាគច្រើន គឺមិនមានអ្នករឹងទទឹងទេ ក្រោយពីបានចេញពីកន្លែងកសាងខ្លួន។ ប៉ុន្តែមានករណីមួយ គឺមានអ្នកទោសរត់ចេញពីការដ្ឋាន។ អ្នកទោសនោះបានវ៉ៃអ្នកយាមម្នាក់នឹងដែកស្បែង ហើយក៏រត់ចេញទៅ។ [...] ខ្ញុំមិនបានបញ្ជូនអ្នកយាមឱ្យតាមចាប់អ្នកទោសនោះទេ គឺខ្ញុំត្រូវរាយការណ៍ឱ្យទៅ យាយចែម តែប៉ុណ្ណោះ។ [...] តាមពិតទៅ នៅពេលដែលយើងរាយការណ៍ទៅថ្នាក់លើ គឺថ្នាក់លើចាត់វិធានការបន្តទៅទៀត"] ឆ.40 KH 01043198 ["សៈ តើលោកបានដឹងថា យាយចែម បានចាត់វិធានការយ៉ាងដូចម្តេចចំពោះអ្នកទោសដែលលួចរត់នោះ? ឆ. 40៖ ខ្ញុំមិនដឹងរឿងនេះ។ ចំពោះខ្ញុំ ខ្ញុំដឹងតែរឿងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំតែប៉ុណ្ណោះ"]។

729 ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045303 [OCIJ-068 (ទុំ សឿន ប្រធានមន្ទីរសន្តិសុខភ្នំត្រយោង)៖ "ខ្ញុំទទួលសំបុត្រដោយនីរសា យាយ ចែម យកមកឱ្យ។ ខ្ញុំមិនចាំខ្លឹមសារលិខិតនោះទេ។"] KH 01045303 [OCIJ-068 (ទុំ សឿន)៖ "ខ្ញុំមិនដែលបានទទួលសំបុត្រពីយាយ ចែមឱ្យដោះលែងអ្នកទោសនោះទេ ប៉ុន្តែធ្លាប់ជជែកពិភាក្សាទល់មុខគ្នា នៅពេលយើងចង់ដោះលែងអ្នកទោសស្រាល។"] KH 01045303 [OCIJ-068 (ទុំ សឿន)៖ "ឲ្យតែជាលិខិតដែលយកមកដោយនីរសាយាយ ចែម ខ្ញុំដឹងថាវាមកពីគាត់ហើយ ពីព្រោះខ្ញុំស្គាល់នីរសាគាត់។ សំបុត្រខ្លះ មិនមានហត្ថលេខាទេ ហើយពេលខ្លះ ជាការណែនាំការងារ។ មិនមានហត្ថលេខាទេ តែពេលខ្លះ មានដាក់តែឈ្មោះគាត់ប៉ុណ្ណោះ។"]។ ឯកសារ D219/567 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.153-154 KH 01165956 [សាក្សីជាអ្នកទោស នៅភ្នំត្រយោង៖ "បាទ ជួប [...] គេជួបនៅកន្លែងអង្គប្រជុំនុំង។"]។ ឯកសារ D5/1075 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022735 [សាក្សីធ្វើការនៅកងចល័ត៖ "១៩៧៨ ពេលមកដល់ភ្នំទ្រយោងភ្លាម ពេលនោះមិត្តចែមប្រធានយោធា បញ្ជូនឱ្យចុងភៅដាំបាយ ស្ងោរមាន់ឱ្យហូបទៀត រួចមក បញ្ជូនឱ្យឈ្លប៣ឬ៤នាក់ នាំខ្ញុំយកទៅដាក់មន្ទីរសន្តិសុខភ្នំទ្រយោង។"]។ ឯកសារ D5/1093 ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ិះ អ៊ិត ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ KH 01024454 [សាក្សីជាអ្នកធ្វើការ ហើយត្រូវបានគេបញ្ជូនទៅភ្នំទ្រយោងដោយសារខ្លួនឈឺ៖ "ត្រូវមិត្តនារីចែម បញ្ជាឱ្យឈ្លបយកខ្ញុំមកដាក់មន្ទីរសន្តិសុខភ្នំទ្រយោង ចំនួនមួយអាទិត្យ ដោយចោទថា ខ្ញុំសតិអារម្មណ៍។"]។ ឯកសារ D5/1252 ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អឿ លឿ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036276 ["ឆ្នាំ ១៩៧៨ មេគុកពួកនិរតី (ភ្លេចឈ្មោះ) បានបញ្ជូនពួកនាងខ្ញុំព្រមទាំងប្តី១ជាច្រើន ដោយជើងជាប់ខ្នោះច្រវ៉ាក់ ឲ្យជិះរថយន្ត បង្ខំឱ្យមកការដ្ឋានភ្នំទ្រយោង។"]។

730 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.183-184 KH 00953044 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "គាត់អត់ដែលទៅម៉លទេ មានតែនីរសាររបស់គាត់ ទៅមើលក្នុងរវាងពីរបីថ្ងៃម្តង [...] ពេលខ្ញុំនៅទីនោះ ខ្ញុំមិនដែលឃើញគាត់មកទេ។ ប៉ុន្តែគាត់អាចមក នោពេលដែលខ្ញុំចេញទៅលេងនៅតាមឃុំនានា។"]។ ឯកសារ D219/567 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.128-129 KH 01165954 [សាក្សីជាអ្នកទោស នៅភ្នំត្រយោង៖ "ខ្ញុំមិនដឹង។ មានគេហៅឈ្មោះ យាយចែម គាត់មកធ្វើការនៅហ្នឹងម្តងម្កាល តែខ្ញុំមិនហ៊ានមើលមុខគាត់ទេ [...] ខ្ញុំមិនដឹងទេ តែគាត់មកទីនោះម្តងម្កាល។"] ឆ.132-

133 KH 01165954 ["ឆ.132៖ ប្រហែល ៣ដង ប៉ុន្តែខ្ញុំមិនដឹងថា គាត់នៅភ្នំត្រយោងត្រង់ណាទេ។"] ឆ.133 KH 01165954 ["ស៖ ហេតុអ្វីបានជាលោកដឹងថា យាយថែម ទៅគុកនោះបីដង? ឆ.133៖ ព្រោះគាត់ជួបជាមួយនឹងអ្នកទោសទាំងអស់។"]។ ឯកសារ D219/433 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឆ. 23 KH 01124146 [សាក្សីជាអ្នករានព្រៃ នៅភ្នំត្រយោង៖ "រោងសម្រាប់អ្នកទោស ឬក៏រោងអ្នកធ្វើការអី ខ្ញុំមិនឃើញមានទេ។ ប៉ុន្តែអ្នកយាមគឺមានជាប្រចាំ ពីព្រោះ យាយថែម នៅកន្លែងនោះ។"]។

731 ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.22 KH 00801024 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "ប្រជាជនដែលគេចាប់បានពីសហករណ៍ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរសន្តិសុខ។"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.148 KH 00953039 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "ពេលយាយថែមឲ្យខ្ញុំទៅនៅជិតទីនោះ កងចល័តក៏នៅជិតនោះដែរ។ បើអ្នកដែលនៅក្នុងសហករណ៍ក្នុងស្រុកព្រះនេត្រព្រះធ្វើខុស គឺត្រូវបញ្ជូនទៅទីនោះ ហើយការបញ្ជូនមិនមែនតែម្នាក់ទេ គឺបញ្ជូនទៅទាំងគ្រួសារ។"]។ ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.87 KH 00980395 [សាក្សីជាកម្មាភិបាលភូមិភាគនិរតី ហើយត្រូវបានអ៊ឹម ចែម ចាត់តាំងឲ្យធ្វើជាគណៈឃុំភ្នំលៀប៖ "ពេលយើងចាប់បាន យើងត្រូវបញ្ជូនមនុស្សនោះទៅមន្ទីរភ្នំត្រយ៉ូង។ ហើយបើប្រធានមន្ទីរភ្នំត្រយ៉ូងគេនឹងចាត់ការទៅតាមសមត្ថកិច្ចរបស់គេផ្ទាល់។"]។

732 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.185 KH 00953044 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "ស៖ តាមការស្តាប់ចម្លើយសាក្សីម្នាក់ឈ្មោះ ឡាយ ខាន់ ឯកសារ D106/4 ជាភាសាខ្មែរ និយាយថា អ្នកដែលគេបញ្ជូនទៅមន្ទីរអប់រំភ្នំត្រយោង ជាពួកនាយទុន ទាហាន ប៉ូលីស គយ ឬអ្នកដែលជម្លៀសមកពីភ្នំពេញ តើលោកយល់ស្របនឹងការលើកឡើងនេះទេ? ឆ.185៖ ខ្ញុំយល់ស្របខ្លះដែរ ព្រោះអ្នកដែលអុកឡុកនៅតាមសហករណ៍នោះ ជាអតីតទាហានលន់ នល់។ ប៉ុន្តែភាគច្រើន ជាអ្នកមូលដ្ឋានព្រះនេត្រព្រះ តាមសម្តីសំដៅរបស់គេ។"]។ ឯកសារ D106/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.8 KH 00800988 [សាក្សីរស់នៅប្រហែលជា ពីរគីឡូម៉ែត ពីមន្ទីរសន្តិសុខភ្នំត្រយោង នៅភូមិត្រឡោក "ខ្ញុំបានឃើញគេដាក់ខ្នោះអ្នកទោស និងបញ្ចេញឲ្យទៅមុជទឹក ដោយមានការភ្ជង់កាំភ្លើងពីក្រោយផងដែរ។ អ្នកដែលគេនាំមកមន្ទីរសន្តិសុខនោះ គឺសុទ្ធតែអ្នកដែលគេចោទថាជានាយទុន ទាហាន ប៉ូលីស ឬគយ ព្រមទាំងប្រជាជនដែលគេជម្លៀសមកពីភ្នំពេញ។ [...] សកម្មភាពនេះបានចាប់ផ្តើមពីឆ្នាំ១៩៧៦ ហើយកាន់តែធ្ងន់ធ្ងរឡើង នៅរវាងឆ្នាំ១៩៧៦-១៩៧៧ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៨ គឺប្រហែលជាពីរខែមុនវៀតណាមចូលមក។"]។

733 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.229 KH 00953051 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "ឈ្មោះពេទ ធ្លាប់ជាគណៈឃុំទឹកជោរ ដោយសារគាត់ខុសសីលធម៌ជាមួយនារីកងចល័ត យាយថែមបានបញ្ជូនគាត់មកនៅជាមួយខ្ញុំ។ តែគាត់មិនមែនជាប្រធាននៅភ្នំត្រយោងទេ។ ខ្ញុំមិនដឹងថា ពេទ ស្លាប់ ឬរស់ទេ។"]។

734 ឯកសារ D119/49 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.35-36 KH 00933106 [សាក្សីជាពេទ្យនៅព្រះនេត្រព្រះ ហើយត្រូវបានឃុំខ្លួននៅភ្នំត្រយោង៖ "សៈ តើគេបញ្ជូនលោកទៅដាក់នៅក្នុងគុកណា? ឆ.35៖ គុកភ្នំត្រយោង។ សៈ លោកត្រូវបានបញ្ជូនទៅគុកភ្នំត្រយោង តើមានមូលហេតុអ្វីបានជាគេបញ្ជូនទៅទីនោះ? ឆ.36៖ មូលហេតុដោយសារខ្ញុំបានទិតៀនរឿងស៊ីចុកនៅក្នុងការប្រជុំស្វ័យទិតៀន អំពីរឿងប្រធានស៊ីចុកស្ងោរមាន់ ហើយយើងស៊ីបាយ ចំណែកកូនចៅយើងស៊ីបបរ អំបិល ឬម្ទេស។" ដល់តែអីចឹងទៅគេក៏រាយការណ៍ឲ្យ យាយចែម យកខ្ញុំទៅដាក់គុក។ ក្នុងមួយអាទិត្យគេប្រជុំស្វ័យទិតៀនម្ដង ហើយខ្ញុំធ្វើការទិតៀនប្រធានរបស់ខ្ញុំនៅក្នុងអង្គប្រជុំនោះ ដូច្នេះហើយបានជាប្រធានរបស់ខ្ញុំ ទៅរាយការណ៍ប្រាប់ យាយចែម អំពីរឿងនេះ ហើយឲ្យគេមកចាប់ខ្ញុំដាក់គុកតែម្ដង។"] ឆ.43-44 KH 00933107 ["នៅពេលដែលខ្ញុំទៅដល់ តាសឿន កំពុងតែរង់ចាំខ្ញុំ។ បន្ទាប់មកគាត់បានសួរខ្ញុំថា "មានដឹងរឿងអ្វីកើតឡើងដែរឬទេ?" ខ្ញុំបានឆ្លើយថា "ខ្ញុំមិនដឹងទេ" ហើយគាត់ក៏ហុចសំបុត្រមួយសន្លឹកមកឲ្យខ្ញុំមើល។ ពេលដែលខ្ញុំមើលសំបុត្រនោះ ទើបខ្ញុំដឹងថាខ្ញុំត្រូវបានគេចោទថា "ក្បត់បដិវត្តន៍ និងចាំចងឈាមបដិវត្តន៍" [...] នៅក្នុងសំបុត្រគឺវាយអង្គុលីលេខ មានឈ្មោះ និងស៊ីញ៉េរបស់ យាយចែម គាត់ជាអ្នកបញ្ជា និងជាអ្នកវ៉ៃត្រាពណ៌ក្រហមលើសំបុត្រនោះតែម្ដង។ សំបុត្រចាប់ខ្លួននេះ គឺមានត្រាពណ៌ក្រហម ហត្ថលេខា និងឈ្មោះរបស់ យាយចែម ដូចគ្នានឹងសំបុត្រធ្វើដំណើរដែរ។"] ឆ.45 KH 00933107 ["សៈ តើនៅក្នុងសំបុត្រចាប់ខ្លួននោះមានមនុស្សប៉ុន្មាននាក់? ឆ.45៖ មានបីនាក់ គឺឈ្មោះ យ៉េត នៅ និងខ្ញុំ។"]។

735 ឯកសារ D219/92 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.16 KH 01040786 [សាក្សីត្រូវបានគេចាប់ខ្លួន នៅព្រះនេត្រព្រះ៖ "សៈ នៅទំព័រ៥ ភាសាអង់គ្លេស ត្រង់ចម្លើយទី១៥ លោកនិយាយថា៖ "ពេលទៅដល់ភ្លាម នៅមន្ទីរភ្នំលៀប ខ្ញុំមិនឃើញយាយចែមទេ។ បន្តិចក្រោយមក គាត់បានមកដល់។ គាត់បានយកសំបុត្រពីខ្ញុំវិញ ហើយប្រាប់ខ្ញុំថា ខ្ញុំត្រូវទៅប្រជុំនៅភ្នំត្រយោង។" តើត្រឹមត្រូវដែរឬទេ? ឆ.16៖ បាទ ត្រឹមត្រូវហើយ។"] ឆ.19 KH 01040787 ["សៈ ទំព័រ៥ ភាសាអង់គ្លេស ដដែល ត្រង់ចម្លើយទី១៨ លោកនិយាយថា៖ "ពេលទៅដល់ ខ្ញុំបានឃើញយោធាប្រដាប់អាវុធប្រហែល១០នាក់ ស្លៀកពាក់ខ្មៅ។ ពួកគេខ្លះជាអ្នកពាយ័ព្យ ហើយខ្លះទៀតជាអ្នកនិរតី។ ខ្ញុំប្រាប់ពួកគេថា យាយចែម ជាអ្នកឲ្យខ្ញុំមកប្រជុំនៅទីនោះ។ ពេលនោះ យោធាបានឲ្យខ្ញុំទៅបែនស្រូវ ដោយគេនិយាយថា នេះជាកិច្ចការដែលខ្ញុំត្រូវធ្វើ។ គេបានឲ្យខ្ញុំបែនស្រូវ ហើយពេលល្ងាច គេបានឲ្យខ្ញុំហូបបបរមួយវែក។ នៅប្រហែលម៉ោង៦ល្ងាច គេបានដាក់ខ្នោះខ្ញុំ ហើយប្រាប់ខ្ញុំថា ឲ្យចូលកន្លែងកសាងខ្លួន។" តើលោកអាចបញ្ជាក់ថាត្រឹមត្រូវដែរឬទេ? ឆ.19៖ បាទ ត្រឹមត្រូវ។"]។

736 ឯកសារ D219/102 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.63 KH 01043201 [សាក្សីជាប្រធានមន្ទីរសន្តិសុខភ្នំត្រយោង៖ "សៈ តើមានឯកសារភ្ជាប់មកជាមួយអ្នកទោសដែលបានបញ្ជាក់អំពីទោសកំហុសរបស់ពួកគេ មកឲ្យលោកដែរឬទេ? ឆ.63៖ ជាធម្មតា គឺមិនមានឯកសារអ្វីបញ្ជាក់អំពីកំហុសរបស់អ្នកទោសនោះទេ។"]។

737 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929837-00929839 ["តែខ្ញុំជួយគាត់បាន ហើយមួយទៀតតាៗដែរនៅសង្គមកិច្ចដែរគេយកទៅដាក់ ដែរផ្ទះខ្ញុំនៅហ្នឹងណាស់? ដានី៖ ពេលនឹងគាត់ជាប់ទោសអី ដែលគេចាប់គាត់ឃុំ ហើយអ៊ំទៅដោះ? ចែម៖ ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំទៅឃើញគេឃុំគាត់។ ដានី៖ ពេលដែលអ៊ំទៅដល់ ប្រលែងគាត់បណ្ដោយ? ចែម៖ ខ្ញុំទៅដល់ ឃើញគេបញ្ចេញពីផ្ទះនឹង ខ្ញុំសាក់សួរគាត់ ដល់ឃើញគាត់ចាស់ ខ្ញុំឲ្យដោះលែង។"]។

738 ឯកសារ D123/1/5.1c កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ KH 00929887 ["ដានី៖ ចុះមួយទៀត ដែលចំណាំគេ ខ្ញុំនៅនេះព័ត៌មានអី...គុកភ្នំត្រយោង យ៉ាងម៉េច អ៊ំបានដឹង? ចែម៖ អត់ ខ្ញុំអត់ដឹង។ ដានី៖ អត់ស្គាល់? ចែម៖ ចា៎! ខ្ញុំនិយាយនែក អ្នកប្ដឹងប្ដល់នឹង ខ្ញុំមិនដែលស្គាល់មុខ ហើយអ្នកនឹងក៏មិនស្គាល់ខ្ញុំទៀត តាមមើលផង ព្រោះខ្ញុំអត់បានទៅរៀបចំនៅកន្លែងនឹង អត់ទាល់តែសោះ។ ដានី៖ អត់ទាល់តែសោះម៉ង? ចែម៖ អត់នឹង។ ខ្ញុំមនុស្សអ្នកត្រង់ ហើយត្រង់ណាដែលខ្ញុំមិនដែល ខ្ញុំមិនប្រព្រឹត្ត។ ដានី៖ ប៉ុន្តែគុកភ្នំត្រយោង មានមែន ហើយក៏អត់ទេ? ចែម៖ ពីមុនមក ឮតែថា ភ្នំត្រយោងៗ ប៉ុន្តែខ្ញុំមិនដឹងថាគេរៀបចំយ៉ាងម៉េចៗ ខ្ញុំមិនដឹងដែរ ពីព្រោះខ្ញុំទៅនៅរយៈពេលខ្លីដែរ ហើយខ្ញុំទៅៗគិតតែទៅដោះស្រាយប្រជាជនអប់រំអីចឹង មួយឆ្នាំមានដឹងរឿងអីគេមិនទាន់អស់មន្ទីរក្រសួងអីនឹងណា។ ភ្នំត្រយោងនឹង បែបខាងដូចថា ខេត្តអីគេរៀបចំផ្ទាល់។ ដានី៖ ប៉ុន្តែអ៊ំស្គាល់ទីតាំង...គុកភ្នំត្រយោង? ចែម៖ អត់ ។ ដានី៖ ឆ្ងាយពីកន្លែងអ៊ំ? ចែម៖ ប្រហែល២០០ម៉ែត្រ ប៉ុនវាបាំងភ្នំ បាំងស្ពានគេ២-៣មកខាងនេះមក ខ្ញុំនៅចុងកើត។ ដានី៖ ប្រហែល២០០-៣០០ម៉ែត្រទេ? ចែម៖ ចា៎!"]។

739 ឯកសារ D119/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.9 KH 009690145 [សាក្សីធ្វើពេទ្យនៅតំបន់៥៖ "គឺជាពួកនិរតី ដែលស្ថិតនៅក្រោមការដឹកនាំរបស់តាម៉ុក និងយាយចែម។ ក្រោយពីការបាត់ខ្លួនរបស់កម្មាភិបាលពាយព្យ គឺយាយចែម ជាអ្នកឡើងជំនួសគណៈតំបន់៥ ដើមឆ្នាំ១៩៧៨។ ពេលនោះពួកតាម៉ុក និងយាយចែម ជាអ្នកចាប់ តាហ៊ីង (គណៈតំបន់៥) តាញ៉ឹម គណៈភូមិភាគពាយព្យ និងកម្មាភិបាលភូមិភាគពាយព្យមួយចំនួនទៀត។ ក្រោយពីការចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយព្យដទៃៗទៀត កម្មាភិបាលភូមិភាគនិរតីបានទទួលខុសត្រូវទាំងស្រុងនៅភូមិភាគពាយព្យ"]។ ឯកសារ D119/154 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.36 KH 01024748 [សាក្សីត្រូវបានគេចាប់ខ្លួននៅព្រះនេត្រព្រះ៖ "ពីព្រោះនៅពេលនោះ ខ្ញុំឮគេនិយាយថា នៅពេលដែលអ្នកណាម្នាក់មានកំហុស ហើយអ្នកនោះត្រូវបានគេបញ្ជូនទៅជួបយាយចែម អ្នកទាំងនោះត្រូវយាយចែមបញ្ជូនទៅដាក់គុក ឬក៏ត្រូវយាយចែមសម្លាប់ចោលដែរ។ អ្នកដែលគេបញ្ជូនទៅដាក់គុកនៅភ្នំត្រយោងនោះកម្រមានជីវិតណាស់ ព្រោះនៅទីនោះគេបង្ខំឱ្យធ្វើការធ្ងន់ និងបង្អត់អាហារ។"] ឆ.37-38 KH 01024749 ["ឈ្មោះ គិត ដែលជាប្រធានភូមិជញ្ជាំង ហើយជាកម្មាភិបាលនិរតី។ [...] នៅពេលនោះ គិត បានចាប់ពួកយើងប្រហែល៦ឬ៧នាក់ ហើយដឹកតាមគោយន្តឱ្យទៅផ្ទះយាយចែមដែលមានទីតាំងនៅភ្នំលាប ក្នុងគោលបំណងបញ្ជូនយើងទៅភ្នំត្រយោង។ នៅពេលគោយន្តដឹកពួកយើង គឺពួកយើងមិនត្រូវបានគេចងទេ។ ពេលយើងទៅដល់ផ្ទះយាយចែម គាត់មិននៅទីនោះទេ ពីព្រោះគាត់បានគេចខ្លួនបាត់ទៅហើយ ដូច្នេះហើយទើប គិត ដឹកយើងមកភ្នំជញ្ជាំងវិញ ហើយឃុំយើងនៅក្រោមផ្ទះ គិត អស់រយៈពេល៣យប់។"]។ ឯកសារ D1.3.11.52 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ តក់ ប៊ុយ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧ KH 00057745-00057746 ["រឿងកាចនោះ ដែលបងប្អូនថាកាច គឺកាចដោយយកបងប្អូនទៅសម្លាប់ចោល [...] បើនិយាយទៅ គេឃោធាសព្វថ្ងៃគេបែកគ្នាទៅណាទៅណែអស់ហើយ កាលហ្នឹងនៅជុំគ្នា ចេះតែនិយាយប្រាប់ថាពួកយាយចែមកាចកំពូលមនុស្សស្រី កាចក្នុងការដូចថាម៉ឺងម៉ាត់នឹងការងារ អត់មានអនុគ្រោះពេលណាដែលខុសឆ្គងស្អី ដូចថាខុសបន្តិចបន្តួចយើងអធ្យាស្រ័យគ្នា"] KH 00057735 ["កាចនេះគឺគំរាមកំហែងវាយមនុស្សចោល គ្រាន់តែធ្វើខុសបន្តិចន្តួច ដូចថាស្ទីកស្រពន់នឹងការងារ ដូចថាធ្វើការទៅដូចថាធ្វើឡេះឡោះ នឹងបាត់ខ្លួនហើយ"]។

740 ឯកសារ D6.1.1200 សេចក្តីរាយការណ៍ជូនបក្សអំពីចម្លើយអ្នកទោសមកពីស្រុក១០៥ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៧ KH 00082724-00082725-00082726 [សេចក្តីរាយការណ៍អំពីចម្លើយអ្នកទោស ផ្ញើចេញមកពីអាន់ មេគុកក្រាំងតាចាន់ ដែលមានចំណារថា "សំរេចកំទេចចុះ" មកពី ប្រាក់ លេខាតំបន់១៣]។ ឯកសារ D118/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម ហឿន របស់ក.ស.ច.ស ឆ.259-264 [សាក្សីជាមេឃុំជាងទង ស្រុកត្រាំកក់៖ "ស. [...] លិខិតនេះគឺផ្ញើចេញមកពី អាន់ នៅគុកក្រាំងតាចាន់។ នៅបន្ទាត់ទីមួយ តើលោកស្រីអាចពន្យល់អំពីបញ្ហានេះបានដែរឬទេ? តើ ត១៣ ជាអ្វី? ហើយឈ្មោះ ប្រាក់ ជាអ្នកណា? ឆ.259 ត១៣ គឺតំបន់១៣ ចំណែកឈ្មោះ ប្រាក់ ជាគណៈតំបន់១៣។"]។ សូមមើលផងដែរ ឯកសារ D219/119.1.5 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ របស់ក.ស.ច.ស ឆ.55 KH 01043326 [លេខាតំបន់១១ មាន "សិទ្ធិក្នុងការបញ្ជាឲ្យសម្លាប់មនុស្ស"]។ ឯកសារ D6.1.679 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន របស់ក.ស.ច.ស ឆ.44 KH 00402512 [ចម្លើយរបស់គណៈស្រុកសង់ (Sang)៖ "កម្មាភិបាលពីតំបន់ហៅគណៈស្រុកឲ្យចូលរួមប្រជុំ ហើយនៅក្នុងពេលប្រជុំនោះ មានការសម្រេចចំពោះអ្នកដែលត្រូវសម្លាប់ និងអ្នកដែលមិនត្រូវសម្លាប់"]។

741 ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045318 [OCIJ-068 (ទុំ សឿន ប្រធានមន្ទីរសន្តិសុខភ្នំត្រយោង)៖ "ខ្ញុំចាំថា មានអ្នកទោស៤នាក់ ត្រូវបានគេវាយធ្វើបាបមុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំត្រយោង។ ពេលមកដល់ ពួកគេចាប់ខ្នោះដើរមិនរួចហើយធ្វើទុក្ខខ្លាំង មិនអាចព្យាបាលបាន។ យាយ ចែម បានបញ្ជាឲ្យខ្ញុំសម្លាប់អ្នកទាំង៤នោះទៅ។ ខ្ញុំបានបញ្ជាបន្តឲ្យអ្នកការពារសម្លាប់ពួកគេទៅ។ ខ្ញុំមិនចាំឈ្មោះអ្នកទោសទាំង៤នាក់ និងអ្នកដែលសម្លាប់នោះទេ។ [...] ទើបខ្ញុំចាំបានថាពួកគេជាអ្នកទោសធ្ងន់។"]។

742 ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.46 KH 00976182 [សាក្សីជាមេកងចល័ត នៅកងចល័តតំបន់៥៖ "ពេទ្យ មឿន (ស្រី) ជាប្រធានពេទ្យកងចល័ត ហើយអនុរបស់គាត់ឈ្មោះ សង់ អា (ប្រុស)។ សង់ អា ចង់បានតំណែងជាប្រធានពេទ្យចល័ត ក៏បានទៅប្រាប់យាយ ចែម ថា មឿនជាមនុស្សអាក្រក់។ យាយ ចែម បានឲ្យឈ្លបទៅហៅ មឿន ពីមន្ទីរពេទ្យនៅវត្តភ្នំលៀប មកផ្ទះរបស់គាត់។ ពេលនោះឈ្លបបានចាប់ចង មឿន តែគាត់បានរត់ ហើយត្រូវឈ្លបតាមចាប់យកមកផ្ទះយាយ ចែម វិញ។ យាយ ចែម បានឲ្យឈ្លបនាំ មឿន ទៅភ្នំត្រយោង ហើយសម្លាប់នៅទីនោះ។ ខ្ញុំបានឃើញព្រឹត្តិការណ៍នេះនៅពេលដែលខ្ញុំកំពុងធ្វើការនៅកងចល័ត នៅថ្នល់ជាតិលេខ៦ មុខផ្ទះរបស់យាយ ចែម។ ពេលគេបណ្តើរទៅ មឿន បានស្រែកប្រាប់ខ្ញុំថា "បងម៉ៅ អើយ! ប្រាប់ប្អូនស្រីខ្ញុំឲ្យដឹងផង ថាគេចាប់ខ្ញុំហើយ"។ ខ្ញុំមិនស្គាល់ប្អូនស្រីគាត់ទេ តែខ្ញុំដឹងថា ប្តីរបស់ មឿន ធ្វើការនៅស្វាយស៊ីសុផុន។"] ឆ.47 KH 00976182 ["ស៖ នៅទំព័រទី១៧ដដែល លោកបាននិយាយថា៖ "គាត់ថា អើ! បើវាពិបាក វាប្រឆាំងក្បត់ ហើយវៃចោលទៅ។""តើលោកអាចបញ្ជាក់បានទេថា នរណាជាអ្នកនិយាយពាក្យនេះ? ឆ.47៖ ខ្ញុំបានឮ យាយ ចែម និយាយពាក្យនេះ នៅពេលដែលគេចាប់ពេទ្យ មឿន មកផ្ទះរបស់គាត់។"]។

743 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.54 KH 00996499 [សាក្សីធ្វើការនៅកងចល័តកុមារ នៅកងចល័តតំបន់៥៖ " យាយ ចែម បានប្រាប់ប្រធានក្រុមកងចល័តរបស់ខ្ញុំឲ្យយកមនុស្សទៅសម្លាប់ម្តងៗ ប្រហែលជា១០នាក់ ដែលស្ថិតនៅក្នុងចលល័ត។"] ឆ.

56 KH 00996499 [“ប្រធានក្រុមរបស់ខ្ញុំបានប្រាប់ខ្ញុំ។”] ឆ.57 KH 00996499 [“សៈ តើលោកស្រីបានដឹងថា ហេតុអ្វីបានជាមនុស្ស១០នាក់ត្រូវបានគេយកទៅសម្លាប់ទេ? ឆ.57៖ ដោយសារពួកគេត្រូវបានចោទថាខុសសីលធម៌។”] ឆ.59 KH 00996499 [“សៈ តើលោកស្រីដឹងថា នរណាគេជាអ្នកចុះមកចាប់មនុស្ស១០នាក់នោះទេ? ឆ.59៖ បញ្ជានោះ គឺធ្លាក់មកពីថ្នាក់លើ ហើយធ្លាក់មកដល់ប្រធានកង និងប្រធានក្រុម រួចហើយប្រធានកងនិងប្រធានក្រុមប្រាប់ទៅឈ្លបឱ្យទៅចាប់មនុស្សទាំងនោះ។”] ឆ.61 KH 00996499 [“មនុស្សទាំង១០នាក់នោះ គេចាប់នៅក្នុងកងចល័ត”]។ ឯកសារ D219/151 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ដៀង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឆ.11-12 KH 01058749 [សាក្សីធ្វើការនៅសហករណ៍ នៅភ្នំ លៀប ជាអ្នកបរទេះគោ៖ “សៈ តើលោកដឹងទេថា ឈ្មោះ សាំង ដែលជាប្អូនថ្លៃរបស់លោក បានចូលរួមសម្លាប់មនុស្សនៅភ្នំត្រយោងដែរឬទេ? ឆ.11៖ បាទ គាត់ច្បាស់ជាបានចូលរួមហើយ ព្រោះគាត់បានធ្វើការនៅទីនោះ ជាច្រើនឆ្នាំ រហូតដល់របបខ្មែរក្រហមដួលរលំ។ ពួកខ្ញុំចេញចូលគ្នាញឹកញាប់ដែរកាលនោះ។ តាមខ្ញុំដឹង គាត់អាចធ្វើការផ្លាស់ទៅផ្លាស់មករវាងមន្ទីរសន្តិសុខបណ្តោះអាសន្ននៅទល់មុខផ្ទះយាយថែម និងមន្ទីរសន្តិសុខភ្នំត្រយោង។ ក្នុងពេលមួយនោះ ខ្ញុំបានទៅលេងប្អូនស្រីដែលជាប្រពន្ធរបស់ សាំង ហើយនាងប្រាប់ខ្ញុំថា ប្តីបានទៅបោសសម្អាតមនុស្សនៅឃុំរហាលហើយ ដែលធ្វើឱ្យខ្ញុំសន្និដ្ឋានថា គាត់ពិតជាបានចូលរួមការងារទាំងអស់នោះមែន។ សៈ តើឈ្មោះ សាំង ធ្លាប់ប្រាប់លោកថា គាត់ទទួលបញ្ជាពីអ្នកណាក្នុងការចាប់ខ្លួន និង សម្លាប់អ្នកទាំងនោះដែរឬទេ? ឆ.12៖ សាំង និង ប្រពន្ធ មិនដែលធ្លាប់និយាយប្រាប់ខ្ញុំពីរឿងនេះទេ តែតាមការយល់របស់ខ្ញុំ សាំង ច្បាស់ជាទទួលបញ្ជាពីថ្នាក់លើរបស់ខ្លួនហើយ នោះ គឺយាយថែម។”]។

744 ឯកសារ D119/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន ហឹយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.8-9 KH 00969014-00969015 [“ពួកគេយកឪពុកខ្ញុំទៅសម្លាប់នៅភូមិដកពោធិ៍ ក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះនៅចន្លោះចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៧៨។ នៅពេលនោះ គេឱ្យឪពុកខ្ញុំចិញ្ចឹមមាន់ ហើយដោយសារតែមានពេលមួយនោះអ្នកទទួលបន្ទុកចែកអង្ករម្នាក់បានឈឺ ដូច្នេះគេបានចាត់តាំងឪពុកខ្ញុំទៅជំនួសគាត់។ នៅពេលនោះ គឺចំពេលដែលពួកនិរតីចូលមកដល់ភូមិភាគពាយព្យ ហើយពេលនោះអ្នកដែលជាប់ពាក់ព័ន្ធនិន្នាការនឹងកម្មាភិបាលភូមិភាគពាយព្យចាស់ត្រូវបានគេចាប់យកទៅសម្លាប់ផងដែរ។ ក្នុងនោះក៏មានឪពុកខ្ញុំម្នាក់ដែរ ដោយសារគាត់ជាអតីតជាអាចារ្យវត្ត ហើយគាត់បានរក្សាទុកគម្ពីរស្លឹករឹត ដូច្នេះពួកនិរតីបានចាប់គាត់ ហើយយកគាត់ទៅសម្លាប់។ [...] គឺជាពួកនិរតី [ដែលជាអ្នកបញ្ជាឱ្យចាប់ខ្លួននិងសម្លាប់] ដែលស្ថិតនៅក្រោមការដឹកនាំរបស់តាម៉ុក និងយាយថែម។ ហើយក្រោយពីការបាត់ខ្លួនរបស់កម្មាភិបាលពាយព្យ គឺយាយថែម ជាអ្នកឡើងជំនួសគណៈតំបន់៥ ដើមឆ្នាំ១៩៧៨។ ពេលនោះពួកតាម៉ុក និងយាយថែម ជាអ្នកចាប់ តាហ៊ឹង (គណៈតំបន់៥) តាញឹម គណៈភូមិភាគពាយព្យ និងកម្មាភិបាលភូមិភាគពាយព្យមួយចំនួនទៀត។ ក្រោយពីការចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយព្យដទៃៗទៀត កម្មាភិបាលភូមិភាគនិរតីបានទទួលខុសត្រូវទាំងស្រុងនៅភូមិភាគពាយព្យ។”]។ ឯកសារ D219/173 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្តើង ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.32 KH 01065977 [“នៅពេលនោះ គណៈស្រុកផ្នែកស្ថិតិឈ្មោះ គ្រូម៉ា បានហៅឱ្យអ្នកគ្រប់គ្រងស្ថិតិក្នុងថ្នាក់ឃុំនានា ក្នុងស្រុកព្រះនេត្រព្រះមកជួបប្រជុំនៅមន្ទីរពាណិជ្ជស្រុកព្រះនេត្រព្រះ ហើយក្រោយមកក៏មានឡានមកដឹកយកពួកគេចេញទៅអស់។”] ឆ.31 KH 01065977 [“ខ្ញុំសូមបញ្ជាក់បន្ថែមថា កាលពីខ្ញុំរៀននៅស្វាយស៊ីសុផុន ខ្ញុំបានស្គាល់លោកគ្រូម្នាក់ឈ្មោះ ពិត ស៊ីតន ដែលគាត់ជាសមាជិកក្រុមស្នូលរបស់ខ្មែរក្រហម ហើយនៅពេលដែលខ្មែរក្រហមកាន់អំណាច គាត់ធ្វើការទទួលខុសត្រូវផ្នែកស្ថិតិឃុំទានកាំ ហើយ

ក្រោយមក គាត់បានឲ្យខ្ញុំចូលធ្វើការជាជំនួយការគាត់ផ្នែកសេដ្ឋកិច្ចសហករណ៍គិរីវ័ន្ត។ នៅពេលពួកនិរតីមកដល់ ពួកនិរតីបានចាប់ខ្លួនលោកគ្រូ ពិត ស៊ីតន ទៅសម្លាប់ ប៉ុន្តែពួកនិរតីមិនបានចាប់ខ្លួនខ្ញុំទេ។"] ឆ.34 KH 01065977 ["សៈ នៅពេលដែលគេចាប់ខ្លួនគ្រូ ពិត ស៊ីតន តើយាយ ចែម កំពុងគ្រប់គ្រងស្រុកព្រះនេត្រព្រះ មែនទេ? ឆ.34៖ បាទ។"]។

745 ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.35 KH 00978923 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "៖សំ ប៊ុន ត្រូវបានគេយកទៅសម្លាប់នៅកន្លែងមួយ នៅចន្លោះភ្នំលៀប និងភ្នំត្រយ៉ូង។ ភ្នំត្រយ៉ូងជាមន្ទីរឃុំឃាំង។ មុនដំបូង សំ ប៊ុន ត្រូវបានគេចាប់យកទៅឃុំនៅភ្នំលៀប ក្រោយមកទើបគេបញ្ជូនយកទៅសម្លាប់។ សំ ប៊ុន ត្រូវបានគេឲ្យឡើងធ្វើជាអ្នកគ្រប់គ្រងមនុស្សក្នុងឃុំបណ្តោះអាសន្ន ហើយនៅថ្ងៃមួយនោះគាត់បានអនុញ្ញាតឲ្យស្ត្រីពីរនាក់ មកលេងផ្ទះនៅសហករណ៍៥។ ពេលនោះ កម្មាភិបាលនារីនិរតី [...] បាននាំស្ត្រីទាំងពីរនោះទៅផ្ទះយាយ ចែម ហើយក្រោយមក ក៏ត្រូវបានដោះលែងមកវិញ។ គេបានហៅ សំ ប៊ុន ទៅផ្ទះយាយ ចែម ហើយក្រោយមកក៏គេយកគាត់ទៅសម្លាប់។ ក្រោយពេលគេយក សំ ប៊ុន ទៅសម្លាប់ ខ្ញុំបានយកកូនប្រុសរបស់គាត់ដែលមានអាយុប្រហែល៤ទៅ៥ឆ្នាំមកចិញ្ចឹមបួនប្រាំថ្ងៃ មុននឹងនាំកូនប្រុសនោះ ទៅឲ្យម្តាយរបស់វាវិញ នៅភូមិស្រែះកើត។"]។

746 ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ីនទី ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឆ.20 KH 00895170 [សាក្សីជាអ្នកទោស៖ "នៅយប់ទីមួយ គេបានដាក់ខ្នោះខ្ញុំ ពីម៉ោង៦ដល់ម៉ោង៩យប់ ហើយបន្ទាប់មក គេឲ្យខ្ញុំនិងសាមុន ទៅជីកអន្លង់ធំមួយ។ នៅទីនោះ សាមុនហើយនិងខ្ញុំ បានឃើញផ្ទាល់ភ្នែក ការសម្លាប់មនុស្សចំនួន៧នាក់។ ពួកគេត្រូវបានសម្លាប់ដោយមនុស្សដែលមានគ្នាប្រហែល៣ទៅ៤នាក់ ដោយវ៉ៃនឹងពូថៅ។ ក្រោយមក ពួកគេបានបញ្ជាឲ្យខ្ញុំនិង សាមុនលប់ដីកប់សាកសពទាំងនោះឲ្យស្អាត។"]។

747 ឯកសារ D85/4.1.5 ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ ក.ស.ច.ស ជាមួយ ប៉ោ បណ្តែត ដែលបានធ្វើបច្ចុប្បន្នភាព KH 00802517 ["លើកទីមួយ មកនៅពេលដែលគេរ៉ៃមនុស្សនៅនឹងសាលា--នៅមុខវត្តនេះម្តង ក្រោយមកទៀតប្រជុំនៅសាលាឃុំចាស់ ប្រធានក្រុម ប្រធានឃុំទាំងអស់។"]។ ឯកសារ D119/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.35 KH 00985871 [សាក្សីជាប្រធានកងចល័ត នៅទំនប់ត្រពាំងថ្ម និងបានដឹកនាំកងកម្លាំងការងារឃុំចំនួន២០០នាក់ នៅស្ពានស្រែង និងអាងទឹកអូរ លៀប៖ "តាមពិតពេលនោះ ខ្ញុំឈរនៅតាមផ្លូវក្បែរផ្ទះយាយចែម។ នៅពេលនោះ មានការប្រជុំមួយនៅជាប់ផ្ទះយាយចែម ប្រហែលជាប្រាំម៉ែត្រ ដែលពេលនោះមានវត្តមាន តាផាង តាចាម តាក្រក នៅទីនោះដែរ។ ហើយនៅពេលនោះ ខ្ញុំបានឮស្នូរសម្រែកមនុស្សស្រែកចេញពីទីនោះ ប៉ុន្តែខ្ញុំមិនដឹងថាមានការចាប់ខ្លួនពួកគេទេ។"] ឆ.42 KH 00985872 ["នៅពេលដែលខ្ញុំបានជូន ខុន មកចូលរួមប្រជុំនោះ ហើយខ្ញុំបានឈរនៅនឹងថ្នល់ប្រហែលមិនបានពីរម៉ោងផង ខ្ញុំក៏ត្រឡប់ទៅកន្លែងធ្វើការខ្ញុំវិញ។ ពេលក្រោយមកទើប ខុន បានត្រឡប់ទៅកន្លែងធ្វើការនៅការដ្ឋានវិញ តែខ្ញុំមិនដែលឃើញមនុស្សទាំងបួននាក់នោះត្រឡប់មកវិញទៀតទេ។"] ឆ.43 KH 00985872 ["តាំងពីពេលនោះមក ខ្ញុំមិនដែលឃើញពួកគេទាំងបួននោះទៀត ដូច្នេះហើយទើបខ្ញុំសម្មតថាពួកទាំងបួននោះ ត្រូវបានចាប់ខ្លួននៅទីនោះ។"] ឆ.44 KH 00985873 ["តាមខ្ញុំដឹង អ្នកដែលត្រូវបានចាប់ខ្លួនផ្សេងទៀតដោយយាយចែម មានអ្នកនៅរស់ខ្លះ ប៉ុន្តែខ្ញុំប្រាជកថា អ្នកទាំងបួននោះពិតជាត្រូវបានគេសម្លាប់ហើយ។"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.22 KH 00978921 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖

"តាមខ្ញុំយល់ គឺយាយថែម ជាអ្នកបញ្ជាឲ្យគេចាប់ពួកគាត់ [តា ក្រាក់ និង តា មួង] ពីព្រោះ យាយ ថែម គឺជាគណៈស្រុកព្រះនេត្រព្រះថ្មី។ ខ្ញុំធ្លាប់បានឮពីមនុស្សនៅក្នុងកងចល័ត ថាគាត់ក៏ជាកម្មាភិបាលថ្នាក់តំបន់ ហើយគាត់ស្នាក់នៅភ្នំលៀប។ ខ្ញុំមិនចាំឈ្មោះមនុស្សនៅក្នុងកងចល័តដែលបានប្រាប់ខ្ញុំទេ។"] ឆ.26-27 KH 00978922 ["សៈ ក្នុងកិច្ចសម្ភាសរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រទី១១ ERN 00969842 លោកបាននិយាយថា "យាយ ថែម បានចាប់តាក្រក និងអ្នកពាយ័ព្យ ហើយអ្នកទាំងនោះ ត្រូវបានគេយកទៅឃុំ និងធ្វើទារុណកម្មនៅផ្ទះ យាយ ថែម យើងអាចឮសំឡេងពួកគេស្រែក។"តើលោកអាចបញ្ជាក់បន្ថែមបានទេ? ឆ.26៖ ឡិន និងខ្មៅ បានប្រាប់ខ្ញុំអំពីព្រឹត្តិការណ៍នេះ។ សៈ លោកដឹងទេ ថាហេតុអ្វីបានជា ឡិន និងខ្មៅ ដឹងអំពីព្រឹត្តិការណ៍នេះ។ ឆ.27៖ ពីព្រោះឡិន និងខ្មៅ ធ្វើការនៅក្នុងកងចល័តតំបន់ ហើយពួកគាត់បានទៅផ្ទះយាយ ថែម។"]។

748 ឯកសារ D106/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.17-18 KH 00800981-00800982 ["ខ្ញុំត្រូវបានក្មេងស្រីជាពេទ្យពីរនាក់បណ្តើរ ដោយមានអូសចបតាមផង ដែលខ្ញុំដឹងថា ពួកគេប្រាកដជានឹងសម្លាប់ខ្ញុំមិនខាន។ នៅពេលនោះ ម្តាយខ្ញុំនៅរស់នៅឡើយ ហើយគាត់ស្រឡាញ់ខ្ញុំណាស់។ គាត់បានទៅជួបយាយថែម សុំឲ្យទុកជីវិតរបស់ខ្ញុំ [...] គេអាចទៅជួបយាយថែមផ្ទាល់បាន។ នៅពេលនោះ ក្មេងស្រីពេទ្យពីរនាក់នោះរៀបនឹងសម្លាប់ខ្ញុំទៅហើយ តែតាសឿន ដែលជាប្រធានមន្ទីរសន្តិសុខ បានមកសួរខ្ញុំ។"]។ ឯកសារ D219/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.20-21 KH 01043163 [សាក្សីធ្វើការនៅអង្គភាពពេទ្យ នៅភ្នំលៀប ហើយត្រូវបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំត្រយោង៖ "សៈ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយមុន ខ្ញុំសូមអានសំណួរ និងចម្លើយ១៧ សៈ តើមានមនុស្សត្រូវបានគេសម្លាប់មុនលោកទៅដល់ ឬនៅពេលដែលលោកនៅទីនោះដែរឬទេ? ឆ៖ ខ្ញុំត្រូវបានក្មេងស្រីជាពេទ្យពីរនាក់បណ្តើរខ្ញុំ ដោយមានអូសចបតាមផង ដោយខ្ញុំដឹងថា ពួកគេប្រាកដជាសម្លាប់ខ្ញុំជាមិនខាន។ នៅពេលនោះ ម្តាយខ្ញុំនៅរស់នៅឡើយ ហើយគាត់ស្រឡាញ់ខ្ញុំណាស់។ គាត់បានទៅជួបយាយថែម សុំឲ្យទុកជីវិតរបស់ខ្ញុំ។ តើត្រឹមត្រូវទេ? ឆ.20៖ បាទ ត្រឹមត្រូវហើយ។ សៈ តើលោកដឹងថា ម្តាយលោកបានទៅជួបយាយថែម នេះដោយរបៀបណា? ឆ.21៖ បន្ទាប់ពីខ្ញុំដើរចេញជួបតាកាន ខ្ញុំបានជួបម្តាយខ្ញុំ ហើយគាត់ប្រាប់ថា គាត់បានទៅជួបយាយថែម សុំឲ្យទុកជីវិតរបស់ខ្ញុំ។"]។ ឯកសារ D119/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស្វ៊ីយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឆ.15 KH 00894518 [សាក្សីជាប្រធានកងតូចនៅកងចល័តតំបន់៖ "ខ្ញុំមិនដឹងទេ ព្រោះខ្ញុំធ្វើការនៅកងចល័ត ហើយខ្ញុំបានមកលេងឪពុកម្តាយតែម្តងគត់។ ពេលនោះ គាត់នៅធ្វើការនៅភ្នំត្រឡោក។ ពេលនោះ ខ្ញុំបានមកពីកងចល័តជាមួយពីរនាក់ផ្សេងទៀត។ នៅភ្នំត្រឡោក ដោយខ្ញុំមិនមានលិខិតធ្វើដំណើរ គេបាននាំខ្ញុំមកមន្ទីរឃុំភ្នំលៀប។ ពេលនោះ អ្នកដែលមកជាមួយខ្ញុំដឹងថា គេចាប់ខ្ញុំមកដាក់មន្ទីរឃុំ ពួកគេបានវិលត្រឡប់ទៅកងចល័តវិញ ហើយប្រាប់ប្រធានវីរៈថា ខ្ញុំត្រូវបានគេចាប់ដាក់មន្ទីរឃុំព្រោះមិនមានលិខិតធ្វើដំណើរ។ ពេលនោះ ប្រធានវីរៈបានទាក់ទងទៅយាយ ថែម ហើយនៅព្រឹកថ្ងៃបន្ទាប់ គេបានដោះលែងខ្ញុំឲ្យទៅលេងឪពុកម្តាយខ្ញុំវិញ។"]។

749 ឯកសារ D119/125 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.14 KH 00987279 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "ព្រឹត្តិការណ៍នៃការចាប់ខ្លួន និងសម្លាប់មនុស្សនៅក្បែរស្រះក្នុងភូមិចក្រី បានកើតឡើងនៅពេលដែលយាយថែម ធ្វើជាគណៈស្រុកនៅទីនេះ។"]។

750 ឯកសារ D219/181 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.19 KH 01066319 ["ការចាប់ខ្លួន និងសម្លាប់ប្រជាជនធម្មតា និងអតីតរដ្ឋការលន់ ណល់ គឺធ្វើឡើងនៅក្រោយពេលដែលគេចាប់ខ្លួនតាក្រក គឺនៅពេលដែលពួកនិរតីមកដល់។ ក្រោយពេលពួកនិរតីមកដល់ មន្ទីឃុំព្រះនេត្រព្រះថ្មីស្ថិតនៅចម្ងាយប្រហែលជាពីរទៅបីផ្ទះ ខាងជើងផ្ទះតាក្រក។"] ឆ.35 KH 01066322 ["លោកខ្ញុំជម្រាបលោកពីមុនថា ការសម្លាប់អតីតរដ្ឋការ លន់ ណល់ នៅតែបន្ត ក្រោយពេលពួកនិរតីមកដល់ បន្ថែមលើការបោសសម្អាតកម្មាភិបាលពាយ័ព្យផង។"] ឆ.16 KH 01066318 ["ហើយក្រោយមកទៀត អ្នកអតីតកម្មាភិបាលខ្មែរក្រហម ក្នុងជួរយោធា និងរដ្ឋបាលនៅភូមិភាគពាយ័ព្យ និងចុងក្រោយបង្អស់ គេចាប់ក្រុមមនុស្សដែលជាអតីតទាហាន និងមន្ត្រីរបស់ លន់ ណល់។"] ឆ.18 KH 01066319 ["ខ្ញុំមិនដឹងថា គេយកកម្មាភិបាលថ្នាក់ធំៗយកទៅសម្លាប់នៅទីណា និងដោយរបៀបណាទេ។ ខ្ញុំគ្រាន់តែដឹងថា ប្រជាជនធម្មតា ឬអតីតយោធា និងមន្ត្រីរបបលន់ ណល់ ត្រូវបានគេយកទៅសម្លាប់នៅពីរ-បីកន្លែង នៅម្តុំភ្នំព្រះនេត្យព្រះ។ ទីតាំងទី១ គឺស្ថិតនៅចម្ងាយប្រហែល១០០ម៉ែត្រខាងក្រោយផ្ទះតាក្រក និងទីតាំងទី២ គឺនៅខាងជើងភ្នំព្រះនេត្យព្រះ។"]។ ឯកសារ D219/13 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឃុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.49 KH 01025648 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ ទីមួយ មានការសម្រិតសម្រាំងជាតិពន្ធុមែន ដោយសារខ្ញុំធ្លាប់ឮសូរពាក្យយាយថែម។ចំពោះសាសនាវិញ នៅពេលគេសម្លាប់ គឺគេយកទៅសម្លាប់តែម្តង។ ចំពោះស្រុកព្រះនេត្រព្រះ គេប្រើពាក្យ សក់អ្នកណា ក្បាលអ្នកនោះ។ មានន័យថា បើឪពុកធ្វើស័ក្តិប្រាំ គឺគេយកតែឪពុកទៅសម្លាប់ទេ ហើយគេមិនយកប្រពន្ធ និងកូន ទៅសម្លាប់ទេ។"]។ ឯកសារ D119/19 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.10 KH 00894492 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "នៅពេលពួកនិរតីមកគ្រប់គ្រង ខ្ញុំសង្កេតឃើញថាការកាប់សម្លាប់នៅបន្តដដែល ហើយអតីតប៉េអឹម និងទាហាន លន់ ណល់ ត្រូវបានបន្តចាប់ខ្លួន។ នៅពេលនោះ ខ្ញុំត្រូវបានគេផ្លាស់ឲ្យទៅដាំដំឡូងនៅខ្នងភ្នំជញ្ជាំង ដែលមានទីតាំងនៅក្នុងភូមិជប់វ៉ារី ឃុំជប់វ៉ារី ស្រុកព្រះនេត្រព្រះ។"]។ ឯកសារ D119/124 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម អេន ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.29-31 KH 00987270 [សាក្សីជាអ្នកថតរូបនៅស-២១៖ "ស៖ នៅពេលដែលកម្មាភិបាលនិរតីគេបញ្ជូនទៅគ្រប់គ្រងនៅភូមិភាគពាយ័ព្យ តើលោកមានបានកត់សម្គាល់ឃើញទេថា មានកម្មាភិបាលភូមិភាគពាយ័ព្យបញ្ជូនទៅកាន់មន្ទីរស-២១ ត្រូវបានកើនឡើងទេ? ឆ.29៖ បាទ ខ្ញុំបានឃើញកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានគេបញ្ជូនទៅកាន់មន្ទីរស-២១ កាន់តែកើនច្រើនឡើងៗ។ ស៖ តើលោកសម្គាល់ឃើញថា ការកើនឡើងនៃការចាប់បញ្ជូនកម្មាភិបាលភូមិភាគពាយ័ព្យទៅកាន់មន្ទីរស-២១ នៅពេលណា? ឆ.30៖ គឺចាប់ផ្តើមពីឆ្នាំ១៩៧៧។ ស៖ តើមនុស្សដែលត្រូវបញ្ជូនពីភូមិភាគពាយ័ព្យទៅកាន់មន្ទីរស-២១ នោះ ជាមនុស្សប្រភេទណា? ឆ.31៖ គឺជាមនុស្សប្រភេទចម្រុះ មានទាំងកម្មាភិបាល ប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ប៉ុន្តែភាគច្រើនជាប្រជាជន ១៧មេសា (ប្រជាជនថ្មី)។"]។ ឯកសារ D119/73 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នូ ជួង ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.17-18 KH 00971121-00971122 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "កម្មាភិបាលពាយ័ព្យប្រាប់ប្រជាជនថា បន្តិចទៀតពួកនិរតីមកគ្រប់គ្រងហើយ។ ពីរបីថ្ងៃក្រោយមក ខ្ញុំបានឃើញពួកនិរតីទាំងឡានៗមកដល់។ បួនប្រាំថ្ងៃក្រោយមក ពួកគេបានចាប់ផ្តើមសម្លាប់ជនជាតិចិន យួន ទាហានលន់ ណល់ដែលនៅសេសសល់ គ្រូបង្រៀន ហើយនិងកម្មាភិបាលពាយ័ព្យ។ កម្មាភិបាលពាយ័ព្យមួយចំនួនបានរត់ទៅថៃ។ [...] ខ្ញុំបានដឹង ដោយសារខ្ញុំបានឃើញផ្ទាល់ភ្នែក ពេលល្ងាចគេចាប់អ្នកទាំងនោះ ហើយនៅ

ពេលយប់ទើបគេយកទៅសម្លាប់។ គេបានឱ្យពួកខ្ញុំពីរនាក់ទៅកប់សាកសពទាំងនោះ។ ឈ្មោះ ស៊ុន ជាអ្នកដែលទៅកប់សាកសពជាមួយខ្ញុំនៅពេលនោះ ហើយសព្វថ្ងៃ ស៊ុន រស់នៅទីក្រុងភ្នំពេញ។ អ្នកដែលត្រូវគេសម្លាប់នោះ គឺជាអ្នក១៧ មេសា ដែលត្រូវបានគេជម្លៀសមកពីក្រុងភ្នំពេញ។"] ឆ.19-21 KH 00971122 ["នៅត្រពាំងភ្លុង ខាងលិចភូមិស្រែះកើត។ [...] មានរណ្ដៅពីរ មួយរណ្ដៅប្រហែលជា១០នាក់។ [...] ខ្ញុំបានទៅកប់សាកសពពីរដង។"]។ ឯកសារ D119/43 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.17 KH 00915884 [សាក្សី ស្វា នង់ ធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "តាម៉ោងត្រូវបានចាប់ខ្លួនដូចតាវ៉ាលដែរ ហើយកម្មាភិបាលថ្នាក់ឃុំ និងប្រធានសហករណ៍ ក៏ត្រូវបានគេចាប់ខ្លួនទាំងអស់ដែរ ហើយជំនួសដោយពួកនិរតី។"] ឆ.21 KH 00915884 ["វាបានកើតឡើងប្រហែល២ឆ្នាំបន្ទាប់ពីពួកខ្មែរក្រហមគ្រប់គ្រងអំណាច គឺប្រហែលនៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។"]។ ឯកសារ D219/255 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភោគ រឿប ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៥ ឆ.16-17 KH 01085157 [សាក្សីធ្វើជាអនុប្រធានភូមិ នៅព្រះនេត្រព្រះ៖ "កម្មាភិបាលនិរតីមានលក្ខណៈលំបាកជាងកម្មាភិបាលពាយ័ព្យ ឧទាហរណ៍ ដូចជាកម្មាភិបាលនិរតីផ្ដល់ការហូបចុកតិចជាងកម្មាភិបាលពាយ័ព្យ។ ចំពោះការងារគឺមានលក្ខណៈដូចគ្នាទេ។ នៅពេលដែលកម្មាភិបាលនិរតីមកកាន់កាប់ ចំពោះអ្នកណាដែលមានប្រវត្តិទាហាន យុវ័ន គឺត្រូវយកទៅកម្ទេច នៅក្នុងឆ្នាំ១៩៧៨ ទាំងអស់។ កាលជំនាន់កម្មាភិបាលពាយ័ព្យគ្រប់គ្រង អតីតទាហាន ឬនគរបាលន់ នល់ ដែលមានសក្តិ១ ឬសក្តិ២ ក៏ត្រូវបានគេយកទៅសម្លាប់ផងដែរ ប៉ុន្តែអ្នកដែលលាក់ប្រវត្តិបាន ក៏រួចខ្លួន។ [...] ខ្ញុំមិនដឹងទេអំពីរឿងសម្លាប់នេះ។ ខ្ញុំគ្រាន់តែឮគេនិយាយថា អ្នកដែលមានប្រវត្តិជាអ្នកធ្វើការជាទាហាន រដ្ឋការ នៅសម័យ លន់ នល់ គឺដឹងតែគេយកទៅវាយសម្លាប់ចោលហើយ ប៉ុន្តែខ្ញុំមិនដែលឃើញគេសម្លាប់មនុស្សដោយផ្ទាល់នឹងភ្នែកទេ។"]។

751 សូមមើល ឯកសារ D6.1.750 ទង់បដិវត្ត លេខ៤ ខែ មេសា ឆ្នាំ ១៩៧៦ KH 00062763 ["សក្តិភូមិ មិនគ្រាន់តែដើបមិនរួចទេ គឺត្រូវគាស់រលើងអស់រលីង អស់ទាំងស្រុង អស់ជាស្ថាពរថែមទៀត។ អស់រលើងហើយ ពីព្រោះយើងវាយរបប បានសេចក្ដីថា យើងជីកឫសអស់។ បើជីកឫសអស់ហើយ យើងមិនព្រួយទេ ពីរឿងដើម ពីរឿងមែក ពីរឿងផ្លែ ដែលនៅសល់មួយ-ពីរ [É] ដល់ឆ្នាំ៧៦ យើងរលើងថែមទៀតរហូតដល់ទៅផ្លែ នៅសល់មួយ-ពីរនេះ ក៏យើងបញ្ចប់ថែមទៀត។ ដូច្នោះរបបជិះជាន់នៃវណ្ណៈសក្តិភូមិ ត្រូវរលំរលាយ គាស់រលើងអស់ទាំងស្រុង។"]។ ឯកសារ D6.1.1156 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052411 [សមមិត្ត ណាត៖ "ព្រឹត្តិការណ៍ជ័យជំនះរបស់បក្ស បានកំទេចខ្សែក្បត់ សុំរីករាយ។ បក្សបានរកឃើញជីកគាស់ឫសកែវក្បត់ [អានមិនដាច់]។"]។ ឯកសារ D6.1.755 ទង់បដិវត្ត លេខពិសេស ខែ ធ្នូ ឆ្នាំ ១៩៧៦ - ខែ មករា ឆ្នាំ ១៩៧៧ KH 00063003 ["វណ្ណៈជិះជាន់ផ្សេងៗ ដែលត្រូវវាយរំលំហើយវាយវាតទៅទៀត ឆ្នាំ៧៦នេះឱ្យវារលំរលើងទៅទៀត។ វាងើបឡើងវិញមិនបានទេ។ នៅជនបទក្តី នៅទីក្រុងក្តី នៅក្នុងក្រសួងប៉ មន្ទីរក្តី នៅក្នុងជួរបដិវត្តក្តី ក្នុងបក្សក្តី ។ ហើយវាយរំលំរលើងនេះ មិនមែនវាយដោយផ្នែក១មួយ ពីរ ទេ គឺវាយជាខ្សែសង្វាក់ វាយគ្រប់ផ្នែក ជីករលើងទាំងឫសធំ ទាំងឫសតូច។"]។ ឯកសារ D1.3.22.5 ទង់បដិវត្ត លេខពិសេស ខែ ធ្នូ ឆ្នាំ ១៩៧៧ - ខែ មករា ឆ្នាំ ១៩៧៨ KH 00064517 ["យើងផ្ដើមបានជ័យជំនះធំ ហើយជាខ្សែសង្វាក់នៅឆ្នាំ១៩៧៧ ដោយសារយើងបានសំរិតសំរាំង និងបោសសំអាតខ្លាំង បានជាខ្សែសង្វាក់ ជីកឫសគល់របស់វាធំៗបានជាមូលដ្ឋាន។ នៅចុងឆ្នាំ ១៩៧៦ ដែលយើងលើកផែនការនេះ ហើយនៅដើមឆ្នាំ ១៩៧៧ ដែលយើងកំចាត់ក្បាលម៉ាស៊ីន

ដឹកនាំខ្លាំងបានមួយចំនួនហើយ ពួកវានៅមានរវើរវាយ មានផែនការវាយយើង។”]។ ឯកសារ D6.1.1168 ស-២១ សៀវភៅរបស់ ម៉ម ណៃ ថ្ងៃទី ២២-២៨ ខែ មីនា ឆ្នាំ ១៩៧៨ KH 00077854 [(យោងតាមពួកកុមិនតាំង)“បក្សន/បណា១ កើតហើយ មិនងាយរលាយអស់ទេ។ យើងត្រូវជីកឫសជីកគល់ឱ្យអស់។”] KH 00077859 [“កន្លងមក មានចចកល្ង នៅទល់ដែនបូព៌ា + បថ្លឹម (តំ២២ + មុខកំពូល)។ នេះក៏បថ្លឹមមានបញ្ហាដែរ។ ត្រូវជីកឫសជីកគល់ទៀត កុំឱ្យបាត់ចុង បាត់ដើមតទៅទៀត។”]។

752 ឯកសារ D119/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.8-9 KH 00969014-00969015 [“ពួកគេយកឪពុកខ្ញុំទៅសម្លាប់នៅភូមិដកពោធិ៍ ក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះនៅចន្លោះចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៧៨។ នៅពេលនោះ គេឱ្យឪពុកខ្ញុំចិញ្ចឹមមាន់ ហើយដោយសារតែមានពេលមួយនោះអ្នកទទួលបន្ទុកចែកអង្ករម្នាក់បានឈឺ ដូច្នេះគេបានចាត់តាំងឪពុកខ្ញុំទៅជំនួសគាត់។ នៅពេលនោះ គឺចំពេលដែលពួកនិរតីចូលមកដល់ភូមិភាគពាយព្យ ហើយពេលនោះអ្នកដែលជាប់ពាក់ព័ន្ធនិន្នាការនឹងកម្មាភិបាលភូមិភាគពាយព្យចាស់ត្រូវបានគេចាប់យកទៅសម្លាប់ផងដែរ។ ក្នុងនោះក៏មានឪពុកខ្ញុំម្នាក់ដែរ ដោយសារគាត់ជាអតីតជាអាចារ្យវត្ត ហើយគាត់បានរក្សាទុកគម្ពីរស្លឹករឹត ដូច្នេះពួកនិរតីបានចាប់គាត់ ហើយយកគាត់ទៅសម្លាប់។ [...] គឺជាពួកនិរតី [ដែលជាអ្នកបញ្ជាឱ្យចាប់ខ្លួននិងសម្លាប់] ដែលស្ថិតនៅក្រោមការដឹកនាំរបស់តាម៉ុក និងយាយចែម។ ហើយក្រោយពីការបាត់ខ្លួនរបស់កម្មាភិបាលពាយព្យ គឺយាយចែម ជាអ្នកឡើងជំនួសគណៈតំបន់៥ ដើមឆ្នាំ១៩៧៨។ ពេលនោះពួកតាម៉ុក និងយាយចែម ជាអ្នកចាប់ តាហ៊ីង (គណៈតំបន់៥) តាញឹម គណៈភូមិភាគពាយព្យ និងកម្មាភិបាលភូមិភាគពាយព្យមួយចំនួនទៀត។ ក្រោយពីការចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយព្យដទៃៗទៀត កម្មាភិបាលភូមិភាគនិរតីបានទទួលខុសត្រូវទាំងស្រុងនៅភូមិភាគពាយព្យ។”]។

753 ឯកសារ D119/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH 00969015-00969016 [សាក្សីគឺជាពេទ្យនៅតំបន់៥៖ “ថ្ងៃដែលគេចាប់ខ្លួនឪពុកខ្ញុំ ខ្ញុំក៏ត្រូវបានគេចាប់ខ្លួនផងដែរ។ នៅពេលដែលគេចាប់ឪពុកខ្ញុំចងដៃ និងដាក់ខ្នោះជើងទាំងពីររបស់គាត់ ពេលនោះគេបានចងដៃខ្ញុំ ឱ្យអង្គុយទល់មុខជាមួយនឹងឪពុករបស់ខ្ញុំដែរ។ ឪពុករបស់ខ្ញុំត្រូវបានគេយកទៅសម្លាប់នៅក្នុងរណ្ដៅដីមួយ ពេលនោះខ្ញុំបានឮសូរសំឡេងរបស់ឪពុកខ្ញុំស្រែកហៅឱ្យខ្ញុំជួយគាត់នៅពេលដែលគេវាយគាត់មួយដំបងដំបង ហើយបន្ទាប់ពីគេវាយគាត់មួយដំបងទៀត ខ្ញុំលែងបានឮសំឡេងគាត់តទៅទៀត។”]។

754 ឯកសារ D119/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន ហ៊ីយ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.8-9 KH 00969014-00969015 [“ពួកគេយកឪពុកខ្ញុំទៅសម្លាប់នៅភូមិដកពោធិ៍ ក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះនៅចន្លោះចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៧៨។ នៅពេលនោះ គេឱ្យឪពុកខ្ញុំចិញ្ចឹមមាន់ ហើយដោយសារតែមានពេលមួយនោះអ្នកទទួលបន្ទុកចែកអង្ករម្នាក់បានឈឺ ដូច្នេះគេបានចាត់តាំងឪពុកខ្ញុំទៅជំនួសគាត់។ នៅពេលនោះ គឺចំពេលដែលពួកនិរតីចូលមកដល់ភូមិភាគពាយព្យ ហើយពេលនោះអ្នកដែលជាប់ពាក់ព័ន្ធនិន្នាការនឹងកម្មាភិបាលភូមិភាគពាយព្យចាស់ត្រូវបានគេចាប់យកទៅសម្លាប់ផងដែរ។ ក្នុងនោះក៏មានឪពុកខ្ញុំម្នាក់ដែរ ដោយសារគាត់ជាអតីតជាអាចារ្យវត្ត ហើយគាត់បានរក្សាទុកគម្ពីរស្លឹករឹត ដូច្នេះពួកនិរតីបានចាប់គាត់ ហើយយកគាត់ទៅសម្លាប់។”] ឆ.9 KH 00969015 “គឺជាពួកនិរតី ដែលស្ថិតនៅក្រោមការដឹកនាំរបស់តាម៉ុក និងយាយចែម។ ហើយក្រោយពីការបាត់ខ្លួនរបស់កម្មាភិបាលពាយព្យ គឺយាយចែម ជាអ្នកឡើងជំនួសគណៈតំបន់៥

ដើមឆ្នាំ១៩៧៨។ ពេលនោះពួកតាម៉ុក និងយាយថែម ជាអ្នកចាប់ តាហ៊ឹង (គណៈតំបន់៥) តាញឹម គណៈភូមិភាគពាយព្យ និងកម្មាភិបាលភូមិភាគពាយព្យមួយចំនួនទៀត។ ក្រោយពីការចាប់ខ្លួន និងសម្លាប់កម្មាភិបាលភូមិភាគពាយព្យដទៃៗទៀត កម្មាភិបាលភូមិភាគនិរតីបានទទួលខុសត្រូវទាំងស្រុងនៅភូមិភាគពាយព្យ។]។ ឯកសារ D1.3.11.52 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ គក់ ប៊ុយ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧ KH 00057733-00057734 [សាក្សីធ្វើការនៅកងចល័ត ហើយបន្ទាប់មកបានឡើងជាកងធំនៅអង្គភាពមួយនៅឯត្រពាំងថ្មៈ "[...] ដល់ពេលនោះមកគេក៏ចាប់តាវ៉ាល់ទៅ ហើយសេនាដៃស្តាំរបស់គាត់ក៏ទៅបណ្តើរៗ រហូតដល់ខ្ញុំដេកមិនលក់បក់មិនល្ហើយមួយយប់ទាល់ព្រឹក ព្រោះខ្ញុំខ្លាចជាប់ដល់ខ្លួនខ្ញុំទៅទៀតព្រោះក្នុងនាមខ្ញុំជាងអនុ ពេលនោះខ្ញុំឡើងជានេះហើយ ឡើងជាកងតូចទៅកងធំហើយ ខ្ញុំនៅជាអនុប្រធានគេ [...] ដូច្នេះកងធំណាមួយចំនួនដែលជាបក្សពួករបស់គាត់ ជាតាវ៉ាល់ណា ដែលជាប់ជាមួយហើយគ្រាន់តែធ្មេចតែភ្នែកបានការបណ្តោយក៏បាត់ខ្លួនទៅទាំងអស់។"]។

755 ឯកសារ D119/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស្វឹយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឆ.20 KH 00894519 [សាក្សីជាប្រធានកងតូចនៅកងចល័តតំបន់៖ "កាលខ្ញុំធ្វើការនៅអាងត្រពាំងថ្ម នៅដើមឆ្នាំ១៩៧៨ មានប្រជាជនវៀតណាមប្រហែល១០០០គ្រួសារ ត្រូវបានគេនាំខ្លួនពីសហករណ៍ផ្សេងៗមកទីនោះ។ ពួកគេត្រូវបាននាំមកតាំងពីព្រលឹមទល់ព្រលប់។ ដល់ស្អែកឡើង ពួកគេបានបាត់ខ្លួនអស់ ប្រហែលជាត្រូវបានគេយកទៅសម្លាប់ហើយ។"]។ ឯកសារ D219/13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.49 KH 01025648 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ ទីមួយ មានការសម្រិតសម្រាំងជាតិពន្ធុមែន ដោយសារខ្ញុំធ្លាប់ឮសូរពាក្យយាយថែម។ចំពោះសាសនាវិញ នៅពេលគេសម្លាប់ គឺគេយកទៅសម្លាប់តែម្តង។ ចំពោះស្រុកព្រះនេត្រព្រះ គេប្រើពាក្យ សក់អ្នកណា ក្បាលអ្នកនោះ។ មានន័យថា បើឪពុកធ្វើស័ក្តិប្រាំ គឺគេយកតែឪពុកទៅសម្លាប់ទេ ហើយគេមិនយកប្រពន្ធ និងកូន ទៅសម្លាប់ទេ។"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.37 KH 00976180 [សាក្សីជាមេកងចល័តគ្រប់គ្រងមនុស្សចំនួន៣០នាក់ ត្រូវបានចាត់តាំងទៅត្រពាំងថ្ម ហើយក្រោយមក ទៅស្ពានស្រែង៖ "ប្រជាជនថ្មី គឺជាអ្នកដែលគេជម្លៀសពីភ្នំពេញ។ ខ្ញុំបានឃើញគេហៅប្រជាជនថ្មី និងជនជាតិយួន ដែលរស់នៅក្នុងភូមិស្រែះរបស់ខ្ញុំទៅបាត់ ហើយមិនដែលឃើញត្រឡប់មកវិញទេ។ ខ្លះទៅតែឪពុកម្តាយ ខ្លះទៀតទៅទាំងគ្រួសារតែម្តង។ព្រឹត្តិការណ៍នេះ កើតឡើងនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី។ នៅក្នុងកងចល័តស្រី ខ្ញុំបានឃើញកូនស្រីដែលមានខ្សែស្រឡាយយួនត្រូវបានគេចាប់យកទៅបាត់។ ពេលនោះ កងចល័តស្រីនោះ ធ្វើការនៅក្បែរកងចល័តរបស់ខ្ញុំដែរ។ ប្រធានកងចល័តនារី ឈ្មោះ ទាវ (ស្រី) ជាអ្នកនិរតី។ ព្រឹត្តិការណ៍នេះ គឺបានកើតឡើងកាលខ្ញុំធ្វើការនៅក្នុងកងចល័តទំនប់អូរលៀប គឺប្រហែលជា៣ខែមុនវៀតណាមចូលមកដល់។"]។

756 ឯកសារ D119/73 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ជួង ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.17-18 KH 00971121-00971122 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "កម្មាភិបាលពាយព្យប្រាប់ប្រជាជនថា បន្តិចទៀតពួកនិរតីមកគ្រប់គ្រងហើយ។ ពីរបីថ្ងៃក្រោយមក ខ្ញុំបានឃើញពួកនិរតីទាំងឡានៗមកដល់។ បួនប្រាំថ្ងៃក្រោយមក ពួកគេបានចាប់ផ្តើមសម្លាប់ជនជាតិចិន យួន ទាហានលន់ ណល់ដែលនៅសេសសល់ គ្រូបង្រៀន ហើយនិងកម្មាភិបាលពាយ័ព្យ។ កម្មាភិបាលពាយ័ព្យមួយចំនួនបានរត់ទៅថៃ។ [...] ខ្ញុំបានដឹង ដោយសារខ្ញុំបានឃើញផ្ទាល់ភ្នែក ពេលល្ងាចគេចាប់អ្នកទាំងនោះ

ហើយនៅពេលយប់ទើបគេយកទៅសម្លាប់។ គេបានឱ្យពួកខ្ញុំពីរនាក់ទៅកប់សាកសពទាំងនោះ។ ឈ្មោះ ស៊ុន ជាអ្នកដែលទៅកប់សាកសពជាមួយខ្ញុំនៅពេលនោះ ហើយសព្វថ្ងៃ ស៊ុន រស់នៅទីក្រុងភ្នំពេញ។ អ្នកដែលត្រូវគេសម្លាប់នោះ គឺជាអ្នក១៧ មេសា ដែលត្រូវបានគេជម្លៀសមកពីក្រុងភ្នំពេញ។"] ឆ.19-21 KH 00971122 ["នៅត្រពាំងភ្លូង ខាងលិចភូមិស្រែះកើត។ [...] មានរណ្ដៅពីរ មួយរណ្ដៅប្រហែលជា១០នាក់។ [...] ខ្ញុំបានទៅកប់សាកសពពីរដង។"]។ ឯកសារ D219/455 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឆ.49 KH 01129810-01129811 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្តព្រះ៖ "បាទ ពេលពួកនិរតីមក [...] គេចាប់ផ្ដើមសម្លាប់កម្មាភិបាលពាយ័ព្យ។ ក្រោយមក គេស្រាវជ្រាវប្រវត្តិប្រជាពលរដ្ឋណាដែលមានជាប់ខ្សែរយៈកម្មាភិបាលចាស់ កា.ហ្សេ.បេ ឬជាប់ខ្សែស្រឡាយវៀតណាមសម្លាប់ចោលទាំងអស់។ នៅពេលនោះ មហន្តរាយធ្ងន់ធ្ងរណាស់ ស្ថានភាពជ្រួលច្របល់មែនទែន។"]។

757 ឯកសារ D219/13 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យុន សេរិន ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.47 KH 01025648 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "ខ្ញុំសូមបន្ថែមទៀតថា មានមិត្តភក្តិខ្ញុំម្នាក់ ឈ្មោះ វ៉ាត់ ដែលមានប្រពន្ធឈ្មោះ ឡី ត្រូវបានយាយ ចែម បានយកពួកគេទៅសម្លាប់ចោល ដោយសារគេចោទថា ប្ដីជាខ្មែរកម្ពុជាក្រោម។ នៅពេលនោះ ប្រពន្ធគាត់ឈ្មោះ ឡី កំពុងមានផ្ទៃពោះប្រាំខែផងដែរ។"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.150-153 KH 01049241 [សាក្សីធ្វើការនៅកងចល័តយុវជន៖ "ឆ.150៖ បន្ទាប់ពីមកពីស្ពានទី១ ខ្ញុំមកភូមិគោកកៃ ខ្ញុំនៅជីកប្រឡាយ។ ថ្ងៃមួយ គេឱ្យជីករណ្ដៅមួយថាសម្រាប់ធ្វើជី។ បន្ទាប់ពីជីករណ្ដៅនោះរួច ខ្ញុំសុំច្បាប់មកលេងស្រុក ហើយពេលត្រឡប់មកវិញ ខ្ញុំឃើញមនុស្សមួយចំនួនបានបាត់ពីក្នុងក្រុមរបស់ខ្ញុំ។ អ្នកបាត់ទាំងនោះ ភាគច្រើនគឺជនជាតិវៀតណាម។ ស៖ ហេតុអីបានជាលោកដឹងថា ជនជាតិវៀតណាមត្រូវគេកប់នៅក្នុងរណ្ដៅនោះ។ ឆ.151៖ ពេលខ្ញុំមកពីស្រុកវិញ ខ្ញុំសួរអ្នកធ្វើការក្នុងកងជាមួយខ្ញុំហ្នឹងថា ពួកយើងទៅណាអស់ហើយ។ ពួកដែលនៅសល់បានប្រាប់ខ្ញុំថា គេយកពួកនោះទៅកប់នៅក្នុងរណ្ដៅក្បែរគុម្ពឫស្សីក្បែរមាត់អូរអស់ហើយ។ នៅពេលនោះ គេស្វែងរកចាប់ពួកវៀតណាម បើសិនជាគេរកឃើញជនជាតិវៀតណាម គេនឹងចាប់ខ្លួនយកទៅសម្លាប់។ ស៖ តើលោកដឹងថា អ្នកណាជាអ្នកបញ្ជាឱ្យសម្លាប់អ្នកទាំងនោះ? ឆ.152៖ ខ្ញុំមិនដឹងទេ។ ខ្ញុំឮគេថា អង្គការៗ។ តាមពិតទៅ គឺពួកគណៈឃុំ គណៈស្រុកហ្នឹងឯង។ ស៖ ហើយនៅក្នុងស្រុកថ្នាក់ដឹកនាំស្រុកហ្នឹងមានយាយចែម ហ្នឹងមែនឬទេ? ឆ.153៖ បាទ គណៈស្រុក គឺយាយចែម។"]។

758 ឯកសារ D119/121 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.16-19 KH 00985869 [សាក្សីជាប្រធានកងចល័ត នៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងប្រឡាយអូរលៀប៖ "ស៖ នៅពេលដែលនារីសាន់ត្រូវបានគេសម្លាប់ តើព្រឹត្តិការណ៍នោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី ឬពាយ័ព្យ? ឆ.16៖ នៅពេលនោះគឺប្រហែលជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី។ ស៖ លោកអាចប្រាប់យើងបានទេថា នៅពេលដែល ធៀប បានប្រាប់លោកអំពីការសម្លាប់នារីទាំងពីរនាក់នោះ តើកើតឡើងនៅឆ្នាំណា? ឆ.17៖ពេលនោះប្រហែលជានៅចុងខែកក្កដា ឬខែសីហាក្នុងឆ្នាំ១៩៧៧។ ស៖ តើការសម្លាប់ នារីសាន់ គឺស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះឬ? ឆ.18៖ បាទ គឺស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ។ ស៖ លោកដឹងទេថា តើនរណាជាអ្នកគ្រប់គ្រងស្រុកព្រះនេត្រព្រះនាពេលនោះ? ឆ.19៖ យាយ ចែមជាអ្នកគ្រប់គ្រងស្រុកព្រះនេត្រព្រះ។"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ

២០១៤ ឆ.31-33 KH 00978922-0097893 [សាក្សីធ្វើការនៅកងចល័ត នៅព្រះនេត្រព្រះ៖ "ពួកនិរតីដែលជាប្រធានរបស់ឡិន បានបញ្ជាឲ្យយកស្ត្រីជនជាតិវៀតណាមពីរនាក់យកទៅសម្លាប់។ ខ្ញុំបានដឹងរឿងនេះ ដោយសារ ឡិនបានប្រាប់ខ្ញុំ។ ស្ត្រីទាំងពីរនាក់នោះ ត្រូវបានគេយកទៅសម្លាប់នៅការដ្ឋានវាលដង្កៀបក្ដាម ដែលមានទីតាំងខាងកើតភ្នំលៀប ក្បែរស្ទឹងក្រឡាញ់។ [...] ឆ. 32៖ យាយ ចែម ត្រូវតែដឹងអំពីព្រឹត្តិការណ៍នេះ ពីព្រោះព្រឹត្តិការណ៍នេះ ត្រូវបានធ្វើឡើងក្រោមបង្គាប់របស់គាត់។ ការស្រាវជ្រាវប្រវត្តិរូបត្រូវបានឡើងនៅតាមភូមិ និងសហករណ៍ បន្ទាប់មកត្រូវបានបញ្ជូនទៅថ្នាក់លើ គឺយាយ ចែម ហើយទើបមានបញ្ជាពីយាយ ចែម មកវិញ ចំពោះអ្នកដែលមានប្រវត្តិរូបពាក់ព័ន្ធ។ [...] ឆ.33៖ ឡិន បានប្រាប់ខ្ញុំថា ពេលនោះ ក្រុមរបស់គាត់មានគ្នាប្រហែល១៤ ទៅ១៥នាក់ ហើយក៏គាត់មានវត្តមាននៅទីនោះដែរ។ មុននឹងសម្លាប់ស្ត្រីវៀតណាមទាំងពីរនាក់នោះ ពួកគេបានរំលោភស្ត្រីទាំងពីរនាក់នោះ ម្នាក់ម្ដងៗ។ ហើយបានយកដងចបរុកប្រដាប់ភេទ ហើយវះពោះទាំងរស់។ ហើយស្ត្រីទាំងពីរនាក់នោះ ជាបងប្អូនបង្កើតនឹងគ្នា ដែលម្នាក់ឈ្មោះ សាន់ និងម្នាក់ទៀតឈ្មោះ នួន។"]។

759 ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.32 KH 00978922-00978923 [សាក្សី បានធ្វើការនៅក្នុងកងចល័តមួយ នៅព្រះនេត្រព្រះ៖ "យាយ ចែម ត្រូវតែដឹងអំពីព្រឹត្តិការណ៍នេះ ពីព្រោះព្រឹត្តិការណ៍នេះ ត្រូវបានធ្វើឡើងក្រោមបង្គាប់របស់គាត់។ ការស្រាវជ្រាវប្រវត្តិរូបត្រូវបានឡើងនៅតាមភូមិ និងសហករណ៍ បន្ទាប់ត្រូវបានបញ្ជូនទៅថ្នាក់លើ គឺទៅយាយ ចែម ហើយទើបមានបញ្ជាពីយាយ ចែម មកវិញចំពោះអ្នកដែលមានប្រវត្តិរូបពាក់ព័ន្ធ។"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.207 KH 01049247 [សាក្សី គឺជាអ្នកធ្វើការនៅក្នុងកងយុវជនចល័ត៖ "ស៖ លោកបាននិយាយថា ពួកវៀតណាមនៅក្នុងកងរបស់លោក ត្រូវបានគេយកទៅសម្លាប់។ តើពេលនោះនៅពេលមុន ឬក៏ក្រោយពួកនិរតីមកដល់? ឆ.207៖ ក្រោយពេលពួកនិរតីមកដល់។ ពេលនោះ គេចាប់ស្រាវជ្រាវរកប្រវត្តិរូបវៀតណាម ដល់ពេលគេរកឃើញអ្នកណាជាវៀតណាម គេនឹងយកទៅសម្លាប់។"]។ ឯកសារ D119/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.55 KH 00985875 [សាក្សី គឺជាប្រធានកងចល័តមួយដែលបានធ្វើការនៅអាងត្រពាំងថ្ម អាងស្ពានស្រែង និងប្រឡាយអូរលាប៖ "ពិតជាមានគោលនយោបាយកំណត់គោលដៅសម្លាប់ជនជាតិវៀតណាមមែន ប៉ុន្តែ ខ្ញុំបានដឹងរឿងនេះពី តា ម៉ោង ដែលជាគណៈស្រុកព្រះនេត្រព្រះ បាននិយាយនៅក្នុងអង្គប្រជុំរួមនៅក្នុងវត្តជប់វារី ក្នុងឆ្នាំ ១៩៧៦។ សូមមើលផងដែរ ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107047-01107048 ["ស៖ អ៊ីចឹងមុនអ៊ំមកព្រះនេត្រព្រះ អ្នកគ្រប់គ្រងឈ្មោះ តា ម៉ោង អ៊ីចឹង? អ៊ឹម ចែម៖ តា ម៉ោង នេះប្រធានស្រុកមុន។ ស៖ តា ម៉ោង មុនអ៊ំមកជាចៅហ្វាយស្រុក? អ៊ឹម ចែម៖ ចាស គាត់ចៅហ្វាយស្រុក។ ដល់តែខ្ញុំទៅដល់ហ្នឹង គាត់ក៏បាត់ខ្លួនរហូតទៅ។ ស៖ គេផ្លាស់គាត់ទៅណាទេ? អ៊ឹម ចែម៖ គេផ្លាស់ អត់ដឹងទៅណាទេ។ ប៉ុន្តែខ្ញុំបានប្រជុំជាមួយគាត់ៗប្រគល់បញ្ជីប្រគល់អីឲ្យដែរ ខ្ញុំអត់មានទំនាស់អីដែរណា ខ្ញុំហើយនិងគាត់ អត់មានប៉ះពាល់អីទេ។ អូ! មកជួបគាត់ដែរអ៊ីចឹង? អ៊ឹម ចែម៖ ជួបៗ។ ជួបមានអីរាក់ទាក់ ញញឹមញញែម ប្រគល់បញ្ជីឲ្យខ្ញុំ បានខ្ញុំធ្វើការងារសព្វ។ ស៖ ប្រគល់កិច្ចការងារឲ្យទៅ។ អ៊ឹម ចែម៖ ប្រគល់ការងារឲ្យខ្ញុំដែរ។ ស៖ បញ្ជីអីគេមីង បញ្ជីអីគេ? អ៊ឹម ចែម៖ បញ្ជីប្រជាជន។ ស៖ បញ្ជីចំនួនប្រជាជន ឬក៏បញ្ជីឯកសារអី? អ៊ឹម ចែម៖ បញ្ជីចំនួនប្រជាជន។ ចាស ធ្វើសាថ្មី ហើយយកបញ្ជីចាស់ហ្នឹងយកទៅមកធ្វើសាថ្មី អ៊ីចឹងវាត្រូវបាត់ ១០.០០០"]។

760 ឯកសារ D118/230 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួន ប៊ុន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.141 KH 00985479 [សាក្សីបានធ្វើការនៅក្បែរវត្តចំការខ្នុរ៖ "មានខ្មែរក្រោមពីរគ្រួសាររបស់នៅក្នុងភូមិរបស់ខ្ញុំ។ ពេលដែលខ្មែរក្រហមចូលមកតំបន់របស់ខ្ញុំ ហើយនៅឆ្នាំ ១៩៧៦ គ្រួសារខ្មែរក្រោមទាំងពីរគ្រួសារនោះត្រូវគេយកទៅវៃចោលទាំងអស់។ ខ្ញុំចាំបុរសដែលជាខ្មែរក្រោម ដែលបានរៀបការជាមួយនឹងប្រពន្ធខ្មែរ ក៏ត្រូវគេយកទាំងគ្រួសារទៅសម្លាប់ចោលផងដែរ។"] ឆ. 31 KH 00985467 ["អត់ត្រូវទេ នៅឆ្នាំ ១៩៧៧ ទើបពួកនិរតីចូលមកដល់ តែខ្ញុំមិនចាំថានៅដើមឆ្នាំ ឬក៏ពាក់កណ្ដាលឆ្នាំ ១៩៧៧ នោះទេ"]។

761 ឯកសារ D219/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.58-59 KH 01032108 [សាក្សីត្រូវបានគេបញ្ជូនពីភូមិភាគនិរតី ទៅកាន់ស្រុកស៊ីសុផុន នៅក្នុងពេលបោសសម្អាត ហើយត្រូវបានតែងតាំងជាប្រធានភូមិម្នាក់ នៅក្នុងស្រុកស៊ីសុផុន៖ "តាមការពិតទៅ គ្រួសារដែលបញ្ជូនមកពីភូមិភាគនិរតី គឺក្នុងគោលបំណងឲ្យមកពង្រឹងសេដ្ឋកិច្ចនៅក្នុងភូមិភាគពាយ័ព្យ។ ចំពោះរឿងចាប់មនុស្សដែលចោទថាជាខ្មាំង គឺគេមានបញ្ជីឈ្មោះអ្នកដែលជាប់និន្នាការនឹងរបប លន់ នល់ រួចហើយ។ បញ្ជីនោះត្រូវបានបញ្ជូនមកឲ្យយើងពិនិត្យ ថាតើមានឈ្មោះទាំងនោះនៅក្នុងភូមិឃុំដែរឬទេ ហើយគេនឹងបញ្ជូនមនុស្សរបស់ពួកគេឲ្យមកចាប់មនុស្សនោះផ្ទាល់តែម្តង។ "គេ" នោះ សំដៅទៅលើអ្នកដែលទទួលខុសត្រូវខាងសន្តិសុខ និងគុក"]។

762 ឯកសារ D219/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.58-59 KH 01032108 [សាក្សីត្រូវបានគេបញ្ជូនពីភូមិភាគនិរតី ទៅកាន់ស្រុកស៊ីសុផុន នៅក្នុងពេលបោសសម្អាត ហើយត្រូវបានតែងតាំងជាប្រធានភូមិម្នាក់ នៅក្នុងស្រុកស៊ីសុផុន៖ "តាមការពិតទៅ គ្រួសារដែលបញ្ជូនមកពីភូមិភាគនិរតី គឺក្នុងគោលបំណងឲ្យមកពង្រឹងសេដ្ឋកិច្ចនៅក្នុងភូមិភាគពាយ័ព្យ។ ចំពោះរឿងចាប់មនុស្សដែលចោទថាជាខ្មាំង គឺគេមានបញ្ជីឈ្មោះអ្នកដែលជាប់និន្នាការនឹងរបប លន់ នល់ រួចហើយ។ បញ្ជីនោះត្រូវបានបញ្ជូនមកឲ្យយើងពិនិត្យ ថាតើមានឈ្មោះទាំងនោះនៅក្នុងភូមិឃុំដែរឬទេ ហើយគេនឹងបញ្ជូនមនុស្សរបស់ពួកគេឲ្យមកចាប់មនុស្សនោះផ្ទាល់តែម្តង។ "គេ" នោះ សំដៅទៅលើអ្នកដែលទទួលខុសត្រូវខាងសន្តិសុខ និងគុក"]។ ឆ.61 KH 01032108 ["បាទ ខ្ញុំធ្លាប់ទទួលបានបញ្ជីនោះ។ នៅក្នុងបញ្ជីនោះ មានសរសេរឈ្មោះមនុស្សដែលធ្លាប់ធ្វើការនៅក្នុងរបបចាស់។ គេបញ្ជាឲ្យនាំយកអ្នកទាំងនោះទៅអប់រំ កសាងខ្លួន។ ប៉ុន្តែខ្ញុំមិនដឹងថា ពួកគេត្រូវបានបញ្ជូនទៅណានោះទេ។"] ឆ.57 KH 01032107 ["ខ្ញុំគ្រាន់តែដឹងថា ពួកគេចេះតែបាត់ខ្លួនជាបន្តបន្ទាប់ ប៉ុន្តែខ្ញុំមិនដឹងថា ពួកគេត្រូវបានបញ្ជូនទៅទីកន្លែងណានោះទេ"។]

763 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929780 ["ចែម៖ មើលហើយអស់ សំបុត្រពីលើ ពីភ្នំពេញ ថានែឲ្យគណៈស្រុកចាស់ហ្នឹងប្រជុំឲ្យខ្ញុំចូលរួមហើយប្រគល់បញ្ជីឲ្យខ្ញុំ ដានី៖ អ? ពីខាងណាទៅ? ចែម៖ ពីខាងមជ្ឈិមទៅ ពីខាងភ្នំពេញទៅ។ KH 00929780 ["ដានី៖ ពីណាគេដែរអ្នកសសេរ? ចែម៖ តាប៉ុលពតនោះ។ ដានី៖ ប៉ុលពតគាត់សសេរខ្លួនដៃ ហើយផ្ទាល់គាត់ហ្អេ? ចែម៖ ចាស ដល់ហើយក៏ប្រជុំ គេអញ្ជើញខ្ញុំចូលរួម ក៏ខ្ញុំទៅចូលរួម ទៅចូលរួមក៏គេប្រាប់ចំនួនប្រជាជនអី ហើយប្រាប់អី ប្រគល់បញ្ជីអី ក៏ឃើញម៉ាសែនណា"]។

764 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929732 ["ដល់ខ្ញុំទៅដល់ តាម៉ោង នៅ អាត នៅ។ ប៉ុនគ្រាន់តែខ្ញុំទៅដល់ គេរៀបចំឱ្យទទួលបញ្ជីអីហើយ គេហៅទៅបាត់។ ដាវ៉ា៖ អ្នកណាអ្នកហៅអ៊ំទៅទទួលបញ្ជី? អ៊ំទទួលបញ្ជីហ្នឹងពីអ្នកណា? ចែម៖ ទទួលពីអ្នកនៅមុន។ ដាវ៉ា៖ ពីអាត ឬពីម៉ោង? ចែម៖ ហ្នឹងហើយ។"]។ ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929781 ["ហើយដល់ទាល់ខ្ញុំទទួលបញ្ជីហើយអស់ បានខ្ញុំដឹងថានែ ការពារហ្នឹង ខ្ញុំមានសិទ្ធចាត់ចែង ហើយការពារហ្នឹង"]។

765 ឯកសារ D119/131 សាក្សីបានធ្វើការនៅក្នុងកងកុមារ នៅកងចល័តតំបន់ ៥៖ កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.54-56 KH 00996499 ["យាយចែម បានប្រាប់ប្រធានក្រុមកងចល័តរបស់ខ្ញុំឱ្យយកមនុស្សទៅសម្លាប់ម្ដងៗ ប្រហែលជា ១០ នាក់ ដែលស្ថិតនៅក្នុងកងចល័ត។ ប្រធានក្រុមរបស់ខ្ញុំបានប្រាប់ខ្ញុំ។"] ឆ.57 KH 00996499 ["ស៖ តើលោកស្រីបានដឹងថា ហេតុអ្វីបានជាមនុស្ស ១០ នាក់ត្រូវបានគេយកទៅសម្លាប់ទេ? ឆ.57៖ ដោយសារពួកគេត្រូវបានចោទថាខុសសីលធម៌។"]។ ឯកសារ D219/347 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.4 KH 01103341 [សាក្សី គឺស្ថិតនៅក្នុងគណៈឃុំព្រះនេត្រព្រះ៖ "សង្សារមួយគូ ត្រូវបានគេចាប់ខ្លួន ព្រោះបានប្រព្រឹត្តខុសសីលធម៌ ហើយគណៈឃុំព្រះនេត្រព្រះឈ្មោះ តាក្រុក បានប្រាប់ តាអាត ដែលជាគណៈស្រុកព្រះនេត្រព្រះថា គូសង្សារនោះ បានប្រព្រឹត្តខុសសីលធម៌។ តាអាតបានណែនាំថា អ្នកដែលបានប្រព្រឹត្តខុសសីលធម៌បែបនេះ មិនត្រូវទុកទេ។ ជាលទ្ធផល គូសង្សារនោះ ត្រូវតែធ្វើការប្ដេជ្ញា នៅចំពោះមុខអ្នកដទៃទៀត ដើម្បីកុំឱ្យអ្នកដទៃធ្វើតាមពួកគេ នៅពេលខាងមុខ។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាខ្ញុំត្រូវបានជ្រើសរើសឱ្យសម្លាប់គូសង្សារមួយគូនេះឡើយ។"] ឆ.52 KH 01103351 ["ស៖ នៅពេលដែលមានការចាប់ខ្លួនអ្នកទាំងនោះ តើ អ៊ឹម ចែម ជាគណៈស្រុកព្រះនេត្រព្រះហើយឬនៅ? ឆ.52៖ ពួកគេទាំងនោះ ត្រូវបានចាប់ខ្លួននៅមុនពេល អ៊ឹម ចែម មកដល់។ ឯកសារ D5/984 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៉ាក់ ស៊ី លឿត ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00990159 [សាក្សី គឺជាអ្នកធ្វើការនៅកងចល័តមួយ៖ "ប្រជាជនទាំងសហករក្នុងឃុំព្រះនេត្រព្រះមកចូលរួម ដោយមិនមានអ្នកណាម្នាក់នៅក្នុងភូមិបានឡើយ ក្នុងអង្គជុំនុំនោះមានប្រធានស្រុកឈ្មោះ ចែម តាផន តាតាន់ នារីម៉ន នារីរ៉េម នឹងប្រធានៗជាច្រើនចូលរួម។ គេចងនារីនៅបង្គោលម្ខាង ប្រុសគេចងបង្គោលម្ខាង ហើយគេប្រាប់ប្រជាជនថា បើនាក់ណាធ្វើដូចគាត់ពីរនាក់នេះ គឺស្លាប់ ចាប៉ុណ្ណឹង។ គេក៏ឱ្យនារីពៅនោះឱនកចុះ ដំបងនៅនឹងដៃ គេក៏លើកសំពោងក្បាលនារីនោះចំនួនប្រាំពីរដំបង ទើបនារីនោះស្លាប់ ចំណែកប្រុសតែបីដំបងប៉ុណ្ណោះក៏ស្លាប់ទៅ។"]។

766 ឯកសារ D119/131 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.120-124 KH 00996506- 00996507 [សាក្សី បានធ្វើការនៅក្នុងកងកុមារ នៅកងចល័តតំបន់ ៥៖ "ស៖ នៅពេលលោកស្រីធ្វើការនៅការដ្ឋានទំនប់អាងត្រពាំងថ្ម តើលោកស្រីដឹងថា មានគេចាប់អ្នកធ្វើការនៅទំនប់អាងត្រពាំងថ្មទេ?ឆ.120៖ ចាស មានអ្នកធ្វើការខ្លះបានដួលដោយសារអស់កម្លាំង ហើយត្រូវបានឈ្លបវ៉ៃដំ ហើយក្រោយមកត្រូវបានឈ្លបទាំងនោះ ចាប់យកទៅបាត់។ ស៖ តើលោកស្រីដឹងថា នរណាជាអ្នកបញ្ជាឱ្យពួកឈ្លបចាប់មនុស្សទាំងនោះទេ? ឆ.121៖ ពួកឈ្លបបានទទួលបញ្ជាពីថ្នាក់លើ ហើយតាមខ្ញុំយល់ បញ្ជាថ្នាក់នោះ គឺចេញមកពីយាយ ចែម។ ស៖ តើលោកស្រី

ដឹងថា អ្នកដែលត្រូវចាប់ខ្លួនទាំងនោះ តើគេយកទៅកន្លែងណាដែរ? ឆ.122៖ អ្នកទាំងនោះ ត្រូវបានគេចាប់យកទៅសម្លាប់។ សៈ លោកស្រីដឹងទេថា តើអ្នកទាំងនោះ ត្រូវបានគេសម្លាប់នៅកន្លែងណា? ឆ.123៖ អ្នកទាំងនោះត្រូវបានគេសម្លាប់ដាក់នៅជើងអាងត្រពាំងថ្មនោះតែម្តង។ សៈ លោកស្រីនិយាយថា អ្នកដែលមានតួនាទីចាប់មនុស្ស ដែលធ្វើការនៅអាងត្រពាំងថ្ម គឺឈ្លបតំបន់ ៥។ តើឈ្លបទាំងនោះ គឺជាមនុស្សដែលទទួលបញ្ជាពីយាយ ចែម ក្នុងការសម្លាប់មនុស្សនៅការដ្ឋានអាងត្រពាំងថ្មនោះ មែនទេ? ឆ.124៖ ចាស ត្រឹមត្រូវហើយ។”]។ សូមមើលផងដែរ ឯកសារ D123/1/2.51 សម្ភាសជាមួយឈ្មោះ នូ ជួង និង កោ វ៉ាន់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00733915-00733916 [“តែយើងយាំប់ខ្លាំងយកទៅវៃចោលហើយ សូម្បីតែអ្នកខ្វាក់មាន់ក៏រែកដែរ។ ទៅទាំងខ្វាក់ ជូនកាលចាក់ដីរអិលអាកន្លែងច្រាំងហ្នឹងទៅ។ ធ្លាក់ទៅថ្ពោះដៃថ្ពោះជើង បើអ្នកស្លាប់មានតែអ្នកពត់ធ្វើជាឈើអីចឹងគេវៃឱ្យឃើញនៅនឹងមុខ។ ពត់អី ឈឺមែនហ្នឹងណាស។”]។ ឯកសារ D1.3.11.52 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ តក់ ប៊ុយ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧ KH 00057733 [“ប៊ុយ៖ បាទ! កាច សូម្បីតែតាវ៉ាល់ជាប្រធានភូមិភាគពាយ័ព្យនេះក៏គាត់កាចណាស់ដែរ។”] KH 00057735 [“ដាវ៉ា៖ ពូនិយាយអម្បាញ់មិញថា យាយ ចែម ជាមនុស្សកាច កាលនោះ ពូដឹងដោយសារអីដែរ? ប៊ុយ៖ កាលហ្នឹងយើងឮគេនិយាយតគ្នាថាកាចណាស់យាយ ចែម។ ឃាង៖ កាចយ៉ាងម៉េចខ្លះ? ប៊ុយ៖ កាចនេះ គឺគំរាមកំហែងវាយមនុស្សចោល គ្រាន់តែធ្វើអីខុសតែបន្តិចបន្តួច ដូចថាស្ពឹកស្រពន់នឹងការងារ ដូចថាធ្វើការទៅដូចថាធ្វើឡេះឡោះ នឹងបាត់ខ្លួនហើយ។”]។

767 ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.46 KH 00976182 [សាក្សី គឺជាប្រធានកងចល័តមានគ្នា ៣០ នាក់ ដែលត្រូវបានគេចាត់តាំងឱ្យធ្វើការនៅអាងត្រពាំងថ្ម ហើយក្រោយមក នៅស្ពានស្រែង៖ “ពេទ្យ មឿន (ស្រី) គឺជាប្រធានពេទ្យកងចល័ត ហើយអនុរបស់គាត់ឈ្មោះ សង់ អា (ប្រុស)។ សង់ អា ចង់បានតំណែងធ្វើជាប្រធានពេទ្យចល័ត ក៏បានទៅប្រាប់យាយ ចែម ថា មឿនជាមនុស្សអាក្រក់។ យាយ ចែម បានឱ្យឈ្លបទៅហៅ មឿន ពីមន្ទីរពេទ្យនៅវត្តភ្នំលៀប មកផ្ទះគាត់។ ពេលនោះ ឈ្លបបានចាប់ចង មឿន តែគាត់បានរត់ ហើយត្រូវឈ្លបតាមចាប់យកមកផ្ទះយាយ ចែម វិញ។ យាយ ចែម បានឱ្យឈ្លបនាំ មឿន ទៅភ្នំត្រយោង ហើយសម្លាប់នៅទីនោះ។ ខ្ញុំបានឃើញព្រឹត្តិការណ៍នេះ នៅពេលដែលខ្ញុំកំពុងធ្វើការនៅកងចល័ត នៅថ្នល់ជាតិលេខ ៦ មុខផ្ទះរបស់យាយ ចែម។ ពេលគេបណ្តើរទៅ មឿន បានស្រែកប្រាប់ខ្ញុំថា “បងម៉ៅ” អើយ! ប្រាប់ប្អូនស្រីខ្ញុំឱ្យដឹងផង ថាគេចាប់ខ្ញុំហើយ”។ ខ្ញុំមិនស្គាល់ប្អូនស្រីគាត់ទេ តែខ្ញុំដឹងថា ប្តីរបស់ មឿន ធ្វើការនៅស្វាយស៊ីសុផុន។”] ឆ.47 KH 00976182 [“សៈ នៅទំព័រទី ១៧ ដដែល លោកបាននិយាយថា “គាត់ថា អើ! បើវាពិបាក វាប្រឆាំងក្បត់ ហើយ វ៉ៃចោលទៅ”។ តើលោកអាចបញ្ជាក់បានទេថា នរណាជាអ្នកនិយាយពាក្យនេះ? ឆ.47៖ ខ្ញុំបានឮយាយ ចែម និយាយពាក្យនេះ នៅពេលដែលគេចាប់ពេទ្យ មឿន មកផ្ទះរបស់គាត់។”]។

768 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929747 [“ចែម៖ ថា មានរហូតដល់សំបុត្រចេញពីភូមិភាគឱ្យខ្ញុំចាប់ទៀត ឥឡូវនៅរស់រាល់ថ្ងៃ បីដងខ្ញុំប្រាប់ហើយ ស្រុកហ្នឹងនៅសមាជិកនៅតាមខ្ញុំរហូត ខ្ញុំទុកគាត់។ ឃាង៖ គេណែនាំសមាសភាពមិនល្អហ្នឹង គេសំដៅទៅលើស្អីខ្លះអ៊ំ? ចែម៖ គេចោទដូចថា យើងទទួលខាងជំនាញអី។”] KH 00929748 [“ឃាង៖ ចុះក្រៅពីចោទប្រកាន់ថាដឹកនាំយុវជនឱ្យធ្វើស្អីចឹង តើមានគេចោទពីបទផ្សេងៗទៀតទេ ដែលត្រូវចាប់ខ្លួន ដូចជាមានចោទពីបទមានសមាសភាពមិនល្អ ដូចជាមានជាប់ប្រវត្តិ

គ្រួសារជាអ្នកមន្ត្រីរាជការពីសម័យមុន ឬក៏សេ.អ៊ី.អា ឬកា.ហ្សេ.បេ ឬភ្នាក់ងារយួនអីមានទេ នៅក្នុងអង្គភាពហ្នឹង? ចែម៖ មានដែរ មានគេសួររកដែរ ប៉ុន្តែខ្ញុំទៅគេចាប់អស់ហើយ"]។

769 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929747 ["ចែម៖ ថា មានរហូតដល់សំបុត្រចេញពីភូមិភាគឲ្យខ្ញុំចាប់ទៀត ឥឡូវនៅរស់រាល់ថ្ងៃ បើដងខ្ញុំប្រាប់ហើយ ស្រុកហ្នឹងនៅសមាជិកនៅតាមខ្ញុំរហូត ខ្ញុំទុកគាត់។ ឃាង៖ គេណែនាំសមាសភាពមិនល្អហ្នឹង គេសំដៅទៅលើស្អីខ្លះអ៊ំ? ចែម៖ គេចោទដូចថា យើងទទួលខាងជំនាញអី។"] KH 00929748 ["ឃាង៖ ចុះក្រៅពីចោទប្រកាន់ថាដឹកនាំយុវជនឲ្យធ្វើស្អីចឹង តើមានគេចោទពីបទផ្សេងៗទៀតទេ ដែលត្រូវចាប់ខ្លួន ដូចជាមានចោទពីបទមានសមាសភាពមិនល្អ ដូចជាមានជាប់ប្រវត្តិគ្រួសារជាអ្នកមន្ត្រីរាជការពីសម័យមុន ឬក៏សេ.អ៊ី.អា ឬកា.ហ្សេ.បេ ឬភ្នាក់ងារយួនអីមានទេ នៅក្នុងអង្គភាពហ្នឹង? ចែម៖ មានដែរ មានគេសួររកដែរ ប៉ុន្តែខ្ញុំទៅគេចាប់អស់ហើយ"]។

770 ឯកសារ D119/49 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.74-75 KH 00933111 [សាក្សីបានធ្វើការនៅក្នុងមន្ទីរពេទ្យឃុំភ្នំល្មៀប៖ "សៈ ក្នុងបទសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយថា យាយ ចែម បានទៅមើលគុកយ៉ាងហោចណាស់ម្តង។ តើត្រឹមត្រូវដែរឬទេ? ឆ.74៖ បាទ ត្រឹមត្រូវ។ សៈ ក្នុងបទសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយថា មានពេលមួយ យាយ ចែម បានមកជួប តា សឿន នៅគុកទ្រយោង។ លោក និងអ្នកផ្សេងទៀតមិនត្រូវបានឲ្យទៅជិតកន្លែងជួបគ្នានេះទេ។ ក្រោយការជួបគ្នានេះ ក៏មានការសម្លាប់មនុស្សទ្រង់ទ្រាយធំតែម្តង។ តើត្រឹមត្រូវដែរឬទេ? ឆ.75៖ បាទ ត្រឹមត្រូវ។ ខ្ញុំឃើញ យាយ ចែម បានជិះម៉ូតូសេអិល ពណ៌សទៅជួប តា សឿន ដោយមាននីរសាជាអ្នកឌុបគាត់។ ពេលទៅដល់ យាយ ចែម បានដើរទៅអង្គុយនិយាយជាមួយ តា សឿន ហើយខ្ញុំក៏បានដើរចេញពីទីនោះ តែខ្ញុំមិនដឹងថាពួកគាត់និយាយអ្វីខ្លះទេ។ ក្រោយ ១ ថ្ងៃនៃការជួបគ្នា រវាង យាយ ចែម និងតា សឿន ក៏មានការសម្លាប់ទ្រង់ទ្រាយ ព្រោះវៀតណាមជិតចូលមក។ យាយ ចែម ក៏ជាមេគុកដែរ ព្រោះគាត់ជាអ្នកបញ្ជា តា សឿន។"]។ ឯកសារ D219/93 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01040810 [សាក្សី គឺជាពេទ្យនៅព្រះនេត្រព្រះ និងជាប់ឃុំនៅទ្រយោង៖ "ចំពោះសំណួរចម្លើយទី ១៥ ឯកសារ D119/49 សាក្សីឆ្លើយថា គាត់មិនចាំទេ។ សាក្សីក៏ឆ្លើយទៀតថា គាត់មិនចាំសំណួរចម្លើយទី ៧៥ ផងដែរ។ ត្រង់សំណួរសួរថា "មានពេលមួយ យាយ ចែម បានជួបតា សឿន នៅគុកត្រយោង។ លោក និងអ្នកផ្សេងទៀតមិនត្រូវបានឲ្យទៅជិតកន្លែងជួបគ្នានោះទេ។ ក្រោយពីការជួបគ្នានេះ ក៏មានការសម្លាប់មនុស្សទ្រង់ទ្រាយធំ តែម្តង។ តើត្រឹមត្រូវដែរឬទេ?" ថ្ងៃនេះ សាក្សីបានឆ្លើយថា គាត់មិនចាំអ្វីដែលគាត់បាននិយាយប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ ដូចជា៖ "បាទ ត្រឹមត្រូវហើយ។ ខ្ញុំបានឃើញយាយ ចែម ជិះម៉ូតូសេអិល ពណ៌សទៅជួប តា សឿន ដោយមាននីរសាជាអ្នកឌុបគាត់។ ពេលទៅដល់ យាយ ចែម បានដើរទៅអង្គុយនិយាយជាមួយ តា សឿន ហើយខ្ញុំក៏បានដើរចេញពីទីនោះ តែខ្ញុំមិនដឹងថា គាត់និយាយអ្វីខ្លះទេ។ ក្រោយមួយថ្ងៃការជួប រវាងយាយ ចែម និងតា សឿន ក៏មានការសម្លាប់ទ្រង់ទ្រាយ ព្រោះវៀតណាមជិតចូលមក។ យាយ ចែម ក៏ជាមេគុកដែរ ព្រោះគាត់ជាអ្នកបញ្ជា តា សឿន។"]។ ឯកសារ D219/567 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.156-157 KH 01165956 [សាក្សី គឺជាអ្នកទោសម្នាក់៖ "សៈ បើសិនជាលោកនឹកឃើញ លោកព្យាយាមនឹកបន្តិចមើល។ ពេលដែល យាយ ចែម ទៅគុកហ្នឹង ចុងក្រោយគេ ប្រហែលជាប៉ុន្មានថ្ងៃ

មុនវៀតណាមវ៉ៃចូល? ឆ.156៖ ប្រហែលជា ៥ ថ្ងៃ។ សៈ ពេលដែល យាយ ចែម ទៅគុកចុងក្រោយគេ តើមុនពេល ឬក្រោយពេលដែលគេចាប់មនុស្សដាក់ខ្នោះជើងនៅពេលយប់ ហើយស្អែកឡើងលែងឃើញមនុស្ស? ឆ.157៖ ក្រោយពេល។"] ឆ.165 KH 01165957 ["មានទាំងប្រុស ទាំងស្រី។"]។ សូមមើលផងដែរ ឯកសារ D5/1246 [redacted] KH 01036169 ["ឆ្នាំ ១៩៧៨ មិត្ត ណុប ជាមេកបញ្ជូនខ្ញុំឱ្យមកការដ្ឋានភ្នំទ្រយោង ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ។ ពេលនោះ មិត្ត ចែម បញ្ជារឱ្យពួកខ្ញុំជីករណ្ដៅ របៀបដូចលេនដ្ឋានកងទ័ព។ ជីករួច វាបញ្ជារឱ្យពួកខ្ញុំកាប់ឬស្សី បិតឬស្សីធ្វើចំរូមស្រួចៗ ដាក់ក្នុងលេនដ្ឋាន។"]។ ឯកសារ D5/903 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នូ ខាំ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ KH 00974438 [មេក្រុមកងចល័ត ដែលត្រូវបានបញ្ជូនឱ្យទៅធ្វើស្រែនៅភ្នំត្រយ៉ូង។ "ឆ្នាំ ១៩៧៨ មិត្ត ភន់ បានជម្លៀសខ្ញុំឱ្យទៅនៅភ្នំត្រយ៉ូង ឃុំភ្នំលៀប។ ឱ្យតែពេលយាយ ចែម ទៅត្រួតម្តងៗ ពួកយោធាហាមកងចល័ត មិនឱ្យដើររហេតរហូត ទៅណាមកណាទេ នៅតាមខ្ទមនីមួយៗនោះ។ ឱ្យតែមុនពេល យាយ ចែម ទៅម្តងៗ អ្នកជាប់គុកក្នុងសន្តិសុខ ត្រូវឈ្លប រឺមេកងយកទៅសម្លាប់ មុនយាយ ចែម មក។ ការធ្វើនេះដើម្បីបោសសំអាតខ្មាំង ជ្រើសរើសវណ្ណៈកសិករ កម្មករ។"]។

771 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.83-89 KH 00996502-00996503 [សាក្សីបានធ្វើការនៅក្នុងកងចល័តតំបន់ ៥ នៅអាងត្រពាំងថ្ម៖ "សៈ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D5/853) លោកស្រីបាននិយាយថា "យាយ ចែម បានបញ្ជាឱ្យគេយកមនុស្សទៅសម្លាប់នៅស្ពានទីមួយ នៅទំនប់អាងត្រពាំងថ្ម"។ តើត្រឹមត្រូវដែរទេ? ឆ.83៖ ចាស ត្រឹមត្រូវហើយ។ មនុស្សដែលត្រូវបានគេយកទៅសម្លាប់នៅត្រង់ស្ពានទីមួយនោះ គឺស្ត្រីមានផ្ទៃពោះចំនួន ៥ នាក់។ សៈ ហេតុអ្វីបានជាលោកស្រីដឹងថា យាយ ចែម ជាអ្នកបញ្ជាឱ្យយកស្ត្រីដែលមានផ្ទៃពោះចំនួន ៥ នាក់ យកទៅសម្លាប់នៅទំនប់អាងត្រពាំងថ្ម? ឆ.84៖ ខ្ញុំបានដឹងរឿងនេះ តាមរយៈអ្នកធ្វើការនៅក្នុងកងចល័ត ជាមួយខ្ញុំប្រាប់។ សៈ តើព្រឹត្តិការណ៍នេះ កើតឡើងនៅឆ្នាំណា? ឆ.85៖ កើតឡើងនៅក្នុងឆ្នាំ ១៩៧៧។ សៈ ហេតុអ្វីបានជាស្ត្រីមានផ្ទៃពោះត្រូវបានគេចាប់យកទៅសម្លាប់? ឆ.86៖ ដោយសារនេះគឺជាជំនឿមួយ ដែលពួកខ្មែរក្រហមគិតថា ការសម្លាប់ស្ត្រីដែលមានផ្ទៃពោះដាក់នៅក្បាលស្ពាន គឺវាអាចជួយការពារស្ពាននោះបាន។ សៈ តើលោកស្រីចាំទេថា ស្ត្រីដែលមានផ្ទៃពោះចំនួន ៥ នោះ គេចាប់មកពីណា? ឆ.87៖ ស្ត្រីមានផ្ទៃពោះ គេចាប់មកពីភូមិនានា ក្នុងស្រុកភ្នំស្រុក។ សៈ តើនរណាជាអ្នកចុះចាប់ស្ត្រីដែលមានផ្ទៃពោះទាំងនោះ? ឆ.88 ៖ អ្នកចុះចាប់ គឺជាពួកយោធា មិនមែនឈ្លបទេ។ សៈ បើតាមលោកស្រីយល់ តើយាយ ចែម ជាមនុស្សដែលបញ្ជាឱ្យពួកយោធាជាអ្នកចុះចាប់ស្ត្រីមានផ្ទៃពោះនោះ មែនទេ? ឆ.89៖ ចាស ត្រឹមត្រូវហើយ។"] ឆ.90 KH 00996503 ["ចាស ស្ពានទីមួយនោះ គឺជាផ្នែកមួយនៃទំនប់អាងត្រពាំងថ្ម។"]។

772 ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234207 ["បើយោធាគេ ដូចថាគេមាន ផែនការខាងយោធាតែហ្នឹង-ហ្នឹងគេសម្លាប់គេអីញ្ចឹង...។ យើងនៅជាមួយប្រជាជន ប៉ានទៅវ៉ៃគេស្រស់ៗដែទទេហ្នឹងគេវ៉ៃវិញងាប់បាត់ទៅហើយ។ ...ប៉ុន្តែអារឿងដោះស្រាយវាមានអារឿងស្លាប់ដោយជម្ងឺអត់បាយអត់ទឹក ដូចសព្វថ្ងៃអីអញ្ចឹង បច្ចុប្បន្ន អាហ្នឹងគឺមាន បើថាឱ្យទៅសម្លាប់គេបញ្ជាឱ្យទៅសម្លាប់ អ្នកនេះអ្នកនោះ អាហ្នឹងគឺគ្មានទេ។ អាហ្នឹងបើយោធា គឺមាន គេមែន។ សង្គ្រាមៗច្បាំងគ្នាអាហ្នឹងវាមានអញ្ចឹងហើយ។"]។ ឯកសារ D6.1.75

កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00978490 ["អត់មានបទបញ្ជាថា ឥឡូវស្អែងទៅសម្លាប់អ្នកនេះអ្នកនោះអី ព្រោះយើងនៅជាប់នឹងប្រជាជន មិនអាចធ្វើអ៊ីចឹងបានទេ។ បើយោធាហ្នឹងគេ ដូចថា ផែនការគេខាងយោធាតែម្តង អាហ្នឹងគេ សម្លាប់គេអីអ៊ីចឹង។"] KH 00978495 ["អ្នកបកប្រែ៖ អ៊ីចឹងពេលពួកខ្ញុំទៅត្រពាំងថ្មហ្នឹង ខ្ញុំជួបម្នាក់ប្រជាជននៅអីណោះ គេថាបងប្អូនជីដូនគេមួយត្រូវបានសម្លាប់ ហើយគេចោទថា អ្នកមីងដែលអ្នកបញ្ជាឲ្យគេទៅសម្លាប់បងប្អូនគេ។ អ៊ឹម ចែម៖ ខ្ញុំរកការពិត ព្រោះខ្ញុំនៅក្នុងមែន នៅក្នុងសង្គមហ្នឹងមែន តែបើថាខ្ញុំបញ្ជាឲ្យសម្លាប់ យកការពិតមក ហើយអ្នកឯងដឹងថា ខ្ញុំសម្លាប់ហ្នឹងនៅពេលណា"]។ សូមមើលផងដែរ ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107033 ["អត់ដែលបានឃើញគុក ឃើញអីទេ។ អត់ទេ អត់ដែលឃើញនៅកន្លែងខ្ញុំ។"]។

773 ឯកសារ D123/1/5.1b កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929794-00929796 ["តែខ្ញុំជួយគាត់បាន ហើយមួយទៀតតាៗដែរនៅសង្គមកិច្ចដែរគេយកទៅដាក់ ដែរផ្ទះខ្ញុំនៅហ្នឹងណាស? ដានី៖ ពេលនឹងគាត់ជាប់ទោសអី ដែលគេចាប់ឃុំគាត់ ហើយអ៊ំទៅដោះ? ចែម៖ ខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំទៅឃើញគេឃុំគាត់។ ដានី៖ ពេលដែលអ៊ំទៅដល់ប្រលែងគាត់បណ្តោយ? ចែម៖ ខ្ញុំទៅដល់ឃើញគេបញ្ចេញពីផ្ទះនឹង ខ្ញុំសាក់សួរគាត់ ដល់ឃើញគាត់ចាស់ ខ្ញុំឲ្យដោះលែង ឲ្យមកធ្វើថ្នាំសង្គមកិច្ចនឹង។"]។ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234194 ["ខ្ញុំនាំកម្លាំងពីនិរតីទៅ ពីតាកែវទៅចល័តប្រាំរយ ដាក់តាមការដ្ឋានគេចាស់ហ្នឹង ទាហានប្រាំរយ ប្រជាជនបីខេត្តហ្នឹងក៏យកប្រាំរយគ្រួសារដែរ យករាយតាមភូមិនៅក្នុងស្រុកទាំងអស់ ហើយខ្ញុំដាក់នេះ គឺដើម្បីស្រណុក (ស្រួល) ហៅធ្វើការ ព្រោះខ្ញុំអត់ដែលស្គាល់សោះស្រុកព្រះនេត្រព្រះហ្នឹង"]។ ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107028 ["ស៖ យកឈ្លបទៅដែរ? អ៊ឹម ចែម៖ ចាស។ ស្រេចតែយើងរៀបចំទេ។ ស៖ ប៉ុន្តែយកទៅធ្វើអីឈ្លបហ្នឹង? អ៊ឹម ចែម៖ បានជាមានឈ្មោះថាឈ្លបភូមិ ការពារនៅភូមិក្រែងលោមានចោរ មានឈ្មួញមានអី។ បើថាគេត្រូវការកម្លាំងទៅស្រែប្រាំង ឬក៏ធ្វើអី"]។ ឯកសារ D119/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ សេង ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.37 KH 00976132 [សាក្សីគឺជាប្រធានកងចល័ត នៅត្រពាំងថ្ម៖ "ខ្ញុំមិនដែលបានជួប យាយ ចែម ទេ។ នៅពេលនោះ ខ្ញុំបានសួរយោធានៅលើឡានហើយយោធានោះ បានប្រាប់ខ្ញុំថា ពួកគេទៅដឹក យាយ ចែម។"]។ ឯកសារ D219/357 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.124 KH 01104654 ["ឆ.124 ៖ ខ្ញុំធ្លាប់ឮគេហៅឈ្មោះ យាយ ចែម ដែលជាប្រធានគ្រប់គ្រងយោធា។"] ឆ.125 KH 01104655 ["ខ្ញុំគ្រាន់តែឮគេនិយាយថា គាត់គ្រប់គ្រងផ្នែកយោធាតែប៉ុណ្ណោះ។"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.65 KH 01049233 [សាក្សីបានធ្វើការនៅក្នុងកងយុវជនចល័តមួយ៖ "ខ្ញុំមិនដឹងពីតួនាទី យាយ ចែម ច្បាស់លាស់ទេ។ ខ្ញុំគ្រាន់តែដឹងថា គាត់មានអំណាចខ្លាំង ដោយគាត់បញ្ជាទាំងយោធាទៀតផង។ ហើយគាត់រស់នៅភ្នំលាប។"] ឆ.66-68 KH 01049233 ["ស៖ លោកនិយាយថា យាយ ចែម បញ្ជាទាំងយោធា តើយោធាយ៉ាងម៉េចដែរ? ឆ.66៖ យោធាមានកាំភ្លើង ដែលអាចចាប់ប្រជាជនបាន។ ស៖ អ៊ីចឹងពេលហ្នឹង យាយ ចែម អាចបញ្ជាឲ្យយោធាទាំងនោះ ចាប់ប្រជាជនបានឬ? ឆ.67៖ ចាស។ ឆ.68៖ ខ្ញុំដឹងពីក្រុមចល័ត ដែលអាចរត់រួចពីភ្នំត្រ

960 ឯកសារ D106/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឆ.12 KH 00801001 [សាក្សីជាអ្នកយាមគុក៖ "មន្ទីរសន្តិសុខនោះធំ កន្លែងដាំដំឡូង និងពោតនៅជុំវិញបរិវេណនោះតែម្តង។ ហើយកន្លែងវាយថ្ម ក៏ស្ថិតនៅក្បែរនោះដែរ។"]។ ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951767 [សាក្សីជាប្រធានគុក៖ "បាទ! ធ្វើវែង ដូចថាធ្វើម៉ាខ្នង១០ម៉ែត្រ ៣-៤-៥ ខ្នង ម៉ាខ្នង៣ម៉ែត្រក៏មាន ៤ម៉ែត្រក៏មាន តាមតូចតាមធំ។ ហើយអាផ្ទះកងចល័តគេម៉ាខ្នងវែងនៅនឹងទៅ។"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.151 KH 00953040 [សាក្សីជាប្រធានគុក៖ "ពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឲ្យកងចល័តរបស់ខ្ញុំប្រមូលឈើពីស្វាយ ពីខេត្តបាត់ដំបង យកទៅធ្វើផ្ទះ។ ខ្ញុំនៅទីនោះធ្វើផ្ទះជិតដប់ខ្នង ដោយលើកជាជួរអមតាមផ្លូវចន្លោះពីភ្នំត្រយោង និងភ្នំលាប។ ផ្ទះនីមួយៗមានទំហំប្រាំគុណប្រាំមួយម៉ែត្រ។"]។ ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.51-52 KH 01043200 [សាក្សីជាប្រធានគុក៖ "រោងសម្រាប់ដាក់អ្នកទោស គឺសង់អំពីឈើ ដំបូលប្រក់ស័ង្កសី ឯជញ្ជាំងក៏ធ្វើពីស័ង្កសី។ សៈ តើផ្ទះសម្រាប់ដាក់មនុស្សថ្មី ធ្វើអំពីអ្វី? ឆ.52៖ ផ្ទះនោះសង់អំពីឈើ ដំបូលប្រក់ក្បឿង ដែលមានបណ្តោយ៦ម៉ែត្រ និងទទឹង៤ម៉ែត្រ។ នៅពេលខ្ញុំទៅដល់មិនមានផ្ទះទេ ប៉ុន្តែក្រោយមក ខ្ញុំបានសង់បានផ្ទះចំនួន៥ និងរោងបាយ១។"]។ ឯកសារ D106/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.9 KH 00800988 [សាក្សីជាប្រជាជនរស់នៅភ្នំទ្រលោក៖ "មន្ទីរនោះមានរោងឈើ និងមានផ្ទះដែលជាកន្លែងពួកគេធ្វើការ។ មានចំនួនសរុបប្រហែល ១០០ខ្នង។"]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.33 KH 00895172 [សាក្សីជាអ្នកទោស៖ "មានរោងធំ២ បណ្តោយប្រវែង៦ម៉ែត្រ ទទឹង៤ម៉ែត្រ ហើយរោងតូចៗនៅខាងក្រោយមានប្រហែល៣-៤ ដែលមានទំហំ៣ម៉ែត្របួនជ្រុង។"]។ ឯកសារ D119/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.29 KH 00894495 [សាក្សីជាអ្នកទោស៖ "ខ្ញុំមិនចាំទេ តែមានរោងប្រហែលជា១០ ដោយមានប្រជាជនជាប់ច្រើនដែរ។"]។ ឯកសារ D119/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច ឈានឡុង ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.59-60 KH 01024762 [សាក្សីជាមេក្រុម គាត់បានដឹកអ្នកទោសទៅគុកនោះ៖ "នៅយប់នោះ ខ្ញុំបានឃើញរោងវែងប្រហែល៦០ម៉ែត្រ ហើយអ្នកទោសគេឲ្យដេកតម្រៀបទល់ជើងគ្នា។"]។ ឯកសារ D219/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.30 KH 01040788 [សាក្សីជាអ្នកទោស៖ "តាមខ្ញុំស្មាន មនុស្សដែលធ្វើការនៅតាមវាលនោះ គឺមានចំនួនប្រហែលពី ២០០ ទៅ៣០០នាក់។"]។ ឯកសារ D219/127 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.28 KH 01049194 [សាក្សីអ្នកយាម៖ "ក្រុមរបស់ខ្ញុំមានតួនាទីនាំក្រុមម៉ែៗទៅធ្វើការនៅតាមស្រែ និងមើលក្រុមកុមារា កុមារីនៅទីនោះផងដែរ។"]។ ឯកសារ D219/583 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ

២០១៥ ឆ.56-57 KH 01166962 ["មានរោងចំនួន៣ ហើយពួកគេដាក់អ្នកទោសប្រុសផ្សេងពីអ្នកទោសស្រ្តី មានអ្នកទោសដេកនៅលើដីទៀតផង [...] អត់ទេ គឺនៅវាលខាងក្រៅរោង។"]។ ឯកសារD219/475 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.15 KH 01134130 [សាក្សីជាអ្នកទោស៖ "ពេលដែលយើងទៅដល់ គេឱ្យយើងតម្រង់ជួរ ហើយដើរចូលក្នុងមន្ទីរគេម្តងម្នាក់!។ ពួកយើងត្រូវបានបញ្ជូនទៅរោងផ្សេងៗគ្នា មានប្រហែល ៦ ទៅ៧រោង]។

961 ឯកសារ D106/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.36 KH 00801017 [សាក្សីជាអ្នកទោស៖ "ដោយសារមានអ្នកទោសច្រើន ទើបគេពង្រីកបន្ថែមមកខាងកើតភ្នំទៀត។"]។ ឯកសារ D119/49 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.53 KH 00933108 [សាក្សីជាអ្នកទោស៖ "ដំបូងមានអ្នកទោសមិនដល់១០០នាក់នោះទេ ប៉ុន្តែ២ខែក្រោយមកគឺមានច្រើនជាង១០០០នាក់មែន ជាពិសេសគឺមុនវៀតណាមចូលមកដល់។"]។ ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.52 KH 01043200 [សាក្សីជាប្រធានគុក៖ "នៅពេលខ្ញុំទៅដល់ មិនទាន់មានផ្ទះទេ ប៉ុន្តែក្រោយមក ខ្ញុំបានសង់បានផ្ទះចំនួន៥ និងរោងបាយ១ ដែលមានទំហំបណ្តោយ៦០ម៉ែត្រ និងទទឹង៣០ម៉ែត្រសម្រាប់រោងបាយរួម។"]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.33 KH 00895172 [សាក្សីជាអ្នកទោស៖ "ក្រោយមក គេអាចសាងសង់រោងបន្ថែមទៀតព្រោះគេបានដឹកឈើពីខេត្តឧត្តរមានជ័យមក។"]។ ឯកសារ D219/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.25 KH 01058767 [សាក្សីជាអ្នកទោស៖ "ខ្ញុំឃើញរោងតែមួយទេ ក្រោយមកទៀត ទើបគេសង់រោងបន្ថែម។ ក្រោយមកមានរោងប្រហែលជាបួន ដប់រោង ដែលរោងនីមួយៗមានទំហំប្រហែល៤x៧ម៉ែត្រ គ្មានជញ្ជាំង។"] ឆ.21 KH 01058765 ["អ្នកទោសត្រូវបានគេដឹកចូលជារៀងរាល់ថ្ងៃ ក្រោយពីខ្ញុំបានទៅដល់ទីនោះបានមួយថ្ងៃ ឬពីរថ្ងៃ។ ក្រោយមកទៀត មានអ្នកទោសរាប់ពាន់នាក់ត្រូវបានគេយកទៅដាក់នៅទីនោះ។"]។ ឯកសារ D119/88 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.20 KH 00976121 [សាក្សីដឹកថ្មពីភ្នំត្រយោងទៅត្រពាំងថ្ម៖ "ពេលខ្ញុំស្នាក់នៅទីនោះ មានអ្នកទោសមិនដល់១០០នាក់ទេ។ ក្រោយពីខ្ញុំចេញ មានឡានដឹកអ្នកទោសចូលច្រើន ហើយគេសង់ផ្ទះឱ្យអ្នកទោសស្នាក់នៅ។ តាមខ្ញុំស្មានអ្នកទោសពេលនោះមានចំនួនពីជាង១០០ ទៅ២០០នាក់។"]។ ឯកសារ D219/150 កំណត់ហេតុនៃការស្តាប់ចម្លើយសក្សី ភួន ស៊ុនទី ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឆ.7 KH 01058743 [សាក្សីជាអ្នកទោស៖ "ស៖ ពេលគេចាត់តាំងលោកឱ្យទៅរកត្រី តើលោក ដែលមានចាប់អារម្មណ៍ ឬសង្កេតឃើញថា មានរោង ឬអគារថ្មីក្នុងបរិវេណមន្ទីរសន្តិសុខនោះ ដែរ ឬទេ? អត់ទេ គឺមានតែអគារពីរបី នៅជិតកន្លែងធ្វើការគេប៉ុណ្ណោះ ហើយប្រហែលមួយខែក្រោយមក ឃើញមានអគារមួយទៀតដែលគេសាងសង់ថ្មី តែមានក្រាលក្តារត្រឹមត្រូវ ដូចផ្ទះដែរ។"]។ ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.21-24 KH 00801024-00801025 [សាក្សីជាប្រធានគុក៖ "នៅទិសនិរតីនៃភ្នំត្រយោង មានផ្លូវទៅកាន់ភ្នំមួយទៀតដែលខ្ញុំមិនចាំឈ្មោះ គឺជាកន្លែងដែលគេគ្រោងសាងសង់មន្ទីរសន្តិសុខធំមួយថ្មីទៀត ប៉ុន្តែមិនទាន់ត្រូវបានសាងសង់ទេ ពីព្រោះវៀតណាមបានចូលមកដល់។...មានគេដឹកឈើចំនួនបីរថយន្តពីភ្នំពេញមក ដើម្បីសាងសង់មន្ទីរសន្តិសុខថ្មី តែគេមិនដែលបានសាងសង់ទេ។"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់

ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.208 KH 00953048 [សាក្សីជាប្រធានគុក៖ "ឃើញម្តងខាងភូមិភាគបានដឹកឈើមកទុកនៅភ្នំត្រយោង ដើម្បីធ្វើមន្ទីរសន្តិសុខថ្មីនៅភ្នំស្រមោច ប៉ុន្តែមិនទាន់បានសាងសង់ទេ ហើយឈើនៅសល់ខ្ញុំក៏យកទៅធ្វើផ្ទះ។ ភ្នំស្រមោចនៅចម្ងាយប្រហែល៥០០ម៉ែត្រពីភ្នំត្រយោង"]។

962 ឯកសារ D106/18 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919483 ["ភ្នំទ្រលោក ស្ថិតនៅឆ្ងាយពីទីនោះបន្តិចនៅទិសខាងត្បូង។ យើងអាចធ្វើដំណើរទៅភ្នំទ្រលោក តាមផ្លូវរទេះគោ ដោយឆ្លងកាត់មន្ទីរសន្តិសុខពីជើងទៅត្បូងចេញពីផ្លូវជាតិលេខ៦។ ភ្នំទ្រលោកស្ថិតនៅទិសខាងជើងភាគខាងលិចនៃមន្ទីរសន្តិសុខនោះ។"]។ ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.21 KH 00801024 [សាក្សីជាប្រធានគុក៖ "សាក្សីពន្យល់ថា មានផ្លូវចូលទៅភ្នំត្រយោងពីផ្លូវជាតិលេខ៦"]។

963 ឯកសារ D106/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.36 KH 00801017 [សាក្សីជាអ្នកទោស៖ "កន្លែងដែលអ្នកទោសដាក់ខ្នោះគឺនៅខាងជើងភ្នំត្រយោង។"]។ ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ធិប សំផាត់ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927406 [សាក្សីជាអ្នកទោស៖ "ប៉ុនដល់ក្រោយមក គេបង្កើតកន្លែងដាក់ខ្នោះមួយនៅខាងជើង។ "]។ ឯកសារ D119/49 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.56 KH 00933109 [សាក្សីជាអ្នកទោស៖ "អ្នកទោសធ្ងន់គេដាក់ខ្នោះ នៅកន្លែងរោងមួយដែលគេសង់ទុកនៅខាងជើងភ្នំ ហើយរោងនោះអាចដាក់អ្នកទោសបានប្រហែល១០០នាក់។"]។ ឯកសារ D219/127 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.47 KH 01049200 [សាក្សីជាអ្នកយាមគុក៖ "អ្នកទោសធ្ងន់គេឱ្យដេកនៅតាមរោង នៅខាងជើងកន្លែងតាសឿនស្នាក់នៅ ហើយនៅចម្ងាយប្រហែល១០ ទៅ១៥ម៉ែត្រពីកន្លែងតាសឿន។"] ឆ50 KH 01049200 ["អ្នកទោសស្រាលស្នាក់នៅតាមខ្ទមតូចៗនៅម្ខាងផ្លូវពីកន្លែងដែលតាសឿនស្នាក់នៅ។"]។ ឯកសារ D119/129 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH 01001322 ["នៅទីតាំងមន្ទីរជំរំឃុំឃាំងភ្នំត្រយោង យើងកត់សម្គាល់ថាទីតាំងឃុំឃាំងអ្នកធ្ងន់ និងអ្នកទោសស្រាលជាទីតាំងដាច់ដោយឡែកពីគ្នា និងមិនអាចមើលគ្នាឃើញឡើយ។ "] រូបទី៩ KH 01001331 ["ទិដ្ឋភាពនេះត្រូវបានថតពីភ្នំត្រយោងឆ្ពោះទៅភ្នំល្ងៀប (ខាងជើងភាគខាងកើត)។ នៅទីតាំងផ្ទះឈើនោះជាទីតាំងឃុំឃាំង "អ្នកទោសធ្ងន់"ជាទីកន្លែងស្នាក់នៅរបស់ប្រធានមន្ទីរសន្តិសុខភ្នំត្រយោង ឈ្មោះ ទុំ សឿន។"]។ ឯកសារ D219/400 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្អួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.95 KH 01115782 [សាក្សីជាអ្នកទោសធ្ងន់៖ "ខ្ញុំស្មានមិនបានទេ អ្នកទោសស្រាលនៅឆ្ងាយពីអ្នកទោសធ្ងន់។ គេខ្លាចច្រឡំ"]។

964 ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.19 KH 00801024 [សាក្សីគឺជាប្រធានគុក៖ "កងរបស់ខ្ញុំនៅខាងជើងភ្នំត្រយោង"]។ ឯកសារ D219/127 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.46 KH 01049199 [សាក្សីគឺជាអ្នកយាមគុក៖ "ខ្ញុំដេកនៅក្នុងខ្ទមតូចមួយ ប្រហែលជា៥០ម៉ែត្រពីកន្លែងដែលតាសឿន ស្នាក់នៅ"] ឆ.49 KH 01049200 ["យោធាមួយចំនួនដេកនៅក្បែរតាសឿន គឺនៅខាងជើងកន្លែងគាត់ស្នាក់នៅ"]។ ឯកសារ D106/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ

មីនា ឆ្នាំ ២០១២ ឆ.25 KH 00801002 [សាក្សីគឺជាអ្នកយាមគុក៖ "ខ្ញុំស្នាក់នៅប៉ែកឥសាននៃមន្ទីរសន្តិសុខត្រយោង។ [...] ទីតាំងនោះនៅចម្ងាយប្រហែល១៥០ម៉ែត្រទៅ២០០ម៉ែត្រពីកន្លែងដែល តា សឿន ស្នាក់នៅ"]។

965 ឯកសារ D219/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.31 KH 01040789 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំ និងសាមុន ត្រូវបានយោធាទាំង៣នាក់នោះ ប្រើទៅជីកអន្លង់ធំដើម្បីកប់សាកសពមនុស្ស៧នាក់"] ឆ.34-35 KH 01040789 ["គឺមានចម្ងាយពី៣០០ ទៅ៥០០ ម៉ែត្រ ពីកន្លែងដែលគេបានដាក់ខ្នោះខ្ញុំ គឺស្ថិតនៅទិសពាយ័ព្យ ឆ្ពោះទៅកាន់ផ្លូវជាតិលេខ៦ [...] វាស្ថិតនៅក្នុងព្រៃរបោះ នៅក្បែរជើងភ្នំត្រយោង។"]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.20-21 KH 00895170 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំដឹងថា កន្លែងសម្លាប់មនុស្សនិងកប់សាកសពស្ថិតនៅខាងជើងឈាងខាងលិចភ្នំត្រយោង ហើយនេះជាកន្លែងដែលខ្ញុំបានជីកនិងកប់សាកសព ដែលខ្ញុំបានឃើញគេសម្លាប់។"]។ ឯកសារ D119/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ឈ្មោះហៅក្រៅ/បដិវត្តន៍ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.34-35 KH 00894496 [សាក្សីគឺជាអ្នកទោស៖ "នៅយប់មួយនោះ ខ្ញុំនិង ទី [ភួន ស៊ុនទី] ត្រូវបានគេហៅឱ្យទៅកប់សាកសព [...]។ [...] គេបញ្ជាឲ្យខ្ញុំអូសទម្លាក់សាកសពទាំងនោះចូលក្នុងរណ្តៅ។ [...] មិននៅឆ្ងាយទេ គឺនៅប្រហែល១០០ទៅ២០០ម៉ែត្រ ពីកន្លែងខ្ញុំស្នាក់នៅ។ ទីតាំងនោះនៅខាងជើងភ្នំក្នុងទិសដៅទៅច្រកចូលពីផ្លូវជាតិលេខ៦ ហើយនៅខាងលិចផ្លូវលំ គឺជាព្រៃរបោះ។"]។ ឯកសារ D219/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.64-65 KH 01043168 [សាក្សីគឺជាអ្នកទោស៖ "ស៖ តើលោកកប់សាកសពអ្នកទោសនោះនៅឯណាដែរ? ឆ.64៖ នៅភ្នំត្រយ៉ូងដែរ ប្រហែលជា២០ម៉ែត្រពីកន្លែងខ្ញុំដេក គឺនៅក្នុងព្រៃ។ ស៖ ចុះកន្លែងលោកដេកនៅឯណា? ឆ.65៖ កន្លែងខ្ញុំដេកនៅជិតកន្លែងតាសឿន ស្នាក់នៅ។"]។ ឯកសារ D219/127 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.55 KH 01049201 [សាក្សីគឺជាអ្នកយាមគុក៖ "បាទ ខ្ញុំដឹង។ ភាគច្រើនគេកប់នៅពីរកន្លែង កន្លែងទី១ គឺនៅប៉ែកពាយព្យ នៅចន្លោះភ្នំត្រយោង និងភ្នំលាប គឺនៅហួសកន្លែងដែលអ្នកទោសស្រាលស្នាក់នៅបន្តិច ហើយកន្លែងទី២ គឺនៅខាងជើងភ្នំត្រយោង ឆ្ងាយពីកន្លែងដែលតាសឿន និងពួកយើងស្នាក់នៅបន្តិច។"]។ ឯកសារ D219/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.48-49 KH 01043242 [សាក្សីគឺជាអ្នកយាមគុក៖ "[ផ្ទះ] ខ្លះនៅខាងជើងភ្នំត្រយ៉ុង។ ស៖ តើមានចម្ងាយប៉ុន្មានពីផ្ទះដែលលោកបានឃើញទៅខ្ទមរបស់ តាសឿន? ឆ.49៖ មានចម្ងាយប្រហែលជា១០០ទៅ២០០ម៉ែត្រ។"]។ ឯកសារ D219/400 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.162 KH 01115788 [សាក្សីគឺជាអ្នកទោស៖ "នៅភ្នំត្រយោង នៅព្លាសាន្តភ្នំ។ គេមានរណ្តៅគេ។"] ឆ.164 KH 01115788 ["ពេលចប់ហើយ ខ្ញុំចុះទៅ មានរណ្តៅពីរ តែឆ្អឹងអីហ្នឹង គេរើរុសអស់ហើយ"]។ ឯកសារ D119/51 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.37 KH 00933125 [សាក្សីគឺជាអ្នកទោស៖ "នៅពេលដែលខ្ញុំដើរទៅជីកដំឡូង ទើបខ្ញុំបានឃើញរណ្តៅសាកសពនៅខាងជើងភ្នំ ហើយខ្ញុំបានឡើងទៅថ្មអើតមើលរណ្តៅនោះ។"]។ ឯកសារ D1.3.11.43 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ រិន ខេង ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ EN 00210494 [សាក្សីគឺជាអ្នកទោស៖ "កន្លែងឃុំឃាំងស្ថិតនៅខាងកើតភ្នំ ហើយកន្លែងសម្លាប់មនុស្សស្ថិតនៅខាងជើងភ្នំ ហេតុនេះខ្ញុំមិនអាចមើលឃើញគេធ្វើអ្វីបានទេ។"]។ ឯកសារ D219/252 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.29 KH 01085125 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំក៏នាំកូនរត់។ កាលនោះគេជីកស្រះបម្រុងនឹងវាយពួកខ្ញុំចោល។"] ឆ.42 KH 01085127 ["ស៖ លោកស្រីបាននិយាយថា ដោយសារតែ វៀតណាមចូលស្រុកធ្វើឱ្យលោកស្រីរត់រួច ហើយនៅពេលនោះឈ្មោះ សឿន បានបញ្ជាឱ្យគេជីកស្រះរួចហើយ បម្រុងនឹងសម្លាប់អ្នកទោសនៅទីនោះ។ តើលោកស្រីបានឃើញស្រះនោះទេ? តើស្រះនោះនៅទីណាដែរ? ចាសខ្ញុំបានឃើញស្រះនោះ។ ស្រះនោះស្ថិតនៅខាងជើងភ្នំក្បែរកន្លែងខ្ញុំរស់នៅ។ ស្រះនោះមានទំហំ ៥០ ម៉ែត្រ បួនជ្រុង មានជម្រៅ ជ្រៅលិចក្បាលមនុស្ស ប្រហែល ២ ម៉ែត្រ។ ពួកគេបានឱ្យខ្ញុំ និងអ្នកទោសផ្សេងទៀតជីកស្រះ ប៉ុន្តែ ពួកខ្ញុំមិនបានដឹងថាគេឱ្យពួកខ្ញុំជីកស្រះនោះធ្វើអ្វីនោះទេ។ នៅពេលដែលខ្ញុំសួរពួកគេ គេបានប្រាប់ថា ជីកស្រះសម្រាប់ស្តុកទឹកប្រើប្រាស់។"]។ ឯកសារ D219/475 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហាល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.21 KH 01134132 [សាក្សីគឺជាអ្នកទោស៖ "គ្រាមួយពេលដែលគេឱ្យយើងគាស់ថ្ម ខ្ញុំបានឃើញសាកសពជាច្រើនដែលគេកប់បានតែពាក់កណ្តាលខ្លួននៅខាងជើងភ្នំត្រយោង។ ខ្ញុំមិនអាចប្រាប់បានថាមានសាកសពប៉ុន្មានទេ ព្រោះមានច្រើនណាស់។ ខ្ញុំមិនដែលបានទៅទីនោះម្តងទៀតទេ។"]។ ឯកសារ D219/583 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.75 KH 01166966 [សាក្សីគឺជាអ្នកទោស៖ "ចំពោះអ្នកដែលគេសម្លាប់ពី ៨០០ ទៅ ១០០០ នាក់ម្តងក្នុងពេលតែមួយគេបោះចូលទៅក្នុងស្រះមួយដោយអត់កប់ទេ ក្លិនស្អុយពាសពេញទីនោះ។] ឆ.78-80 KH 01166966-01166967 ["ស្រះនោះស្ថិតនៅខាងជើងភ្នំត្រយ៉ូងជិតផ្លូវជាតិ ពីព្រោះដូចខ្ញុំនិយាយហើយថា គុកនោះនៅមិនឆ្ងាយពីផ្លូវជាតិទេ ហើយស្រះនោះគឺនៅក្បែរគុកនោះឯងប្រហែល៥០ ទៅ១០០ម៉ែត្រពីគុក។ ស៖ រណ្តៅដែលលោកយកសពទៅកប់នោះ តើនៅកន្លែងណាដែរ? [...] នៅខាងលិចស្រះប្រហែល ១០០ ទៅ ២០០ ម៉ែត្រ"]។ ឯកសារ D119/159 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វ៉ឹង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.53 KH 01025132 [សាក្សីគឺជាអ្នកទោសធ្ងន់៖ "នៅកន្លែងដែលគេឱ្យខ្ញុំកាប់ព្រៃឬស្សី ខ្ញុំមិនឃើញមានរណ្តៅសាកសព ឬធុំក្លិនស្អុយនោះទេ។ ខ្ញុំដឹងថាអ្នកទោសដែលស្លាប់ត្រូវបានគេសែងចេញឆ្ពោះទៅទិសខាងជើងមន្ទីរសន្តិសុខភ្នំត្រយោង។"]។ ឯកសារ D119/137 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិត អៀក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.44-45 KH 01003861 [សាក្សីគឺជាអ្នកភូមិជិតខាង៖ "នៅពេលនោះ [ក្រោយរបស់ខ្មែរក្រហមដួលរលំ] ខ្ញុំបានទៅរកឈើនៅទីនោះ [...] ខ្ញុំក៏បានឃើញមានកន្លែងកប់សាកសពជាច្រើននៅទីនោះផងដែរ ប៉ុន្តែកន្លែងកប់សាកសពនោះ មិនមែនសុទ្ធតែជាកន្លែងកប់សាកសពដែលគេបានសម្លាប់នៅភ្នំត្រយ៉ូងនោះទេ ប៉ុន្តែជាកន្លែងកប់សាកសពមនុស្សដែលស្លាប់ដោយសារការអត់អាហារ និងជំងឺផងដែរ។ [...] កន្លែងកប់សាកសពនោះមានទំហំប្រហែលជាបួន ទៅប្រាំហិកតា ដែលនៅខាងជើងជាប់នឹងភ្នំត្រយ៉ូង។"]។ ឯកសារ D219/433 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.20 KH 01124146 [សាក្សីកាប់ព្រៃនៅភ្នំត្រយ៉ូង៖ "ខ្ញុំឃើញតែសាកសពប៉ុណ្ណោះ។ ថ្ងៃខ្លះនៅតាមជើងភ្នំ ខ្ញុំឃើញមានសាកសពថ្មីៗ ផ្នូរខ្មោច និងឈើជ្រុងដែលប្រឡាក់ឈាម។ សាកសព និងផ្នូរខ្មោចត្រូវគេធ្វើដាក់ជាជួរដូចជួរដំឡូងអ៊ីចឹង ហើយកន្លែងនេះស្ថិតនោះខាងលិចភ្នំលៀប ខាងជើងភ្នំទ្រយោង។ ជួនកាលពីល្ងាចមិនឃើញមានអីទេ តែពេលព្រឹកឡើងទៅធ្វើការខ្ញុំឃើញសាកសពថ្មីៗនៅទីនោះ។ អ្នកអត់បាយស្លាប់ អ្នកដែលត្រូវគេវ៉ៃសម្លាប់អី គឺគេយកទៅដាក់នៅទីនោះទាំងអស់។"]។ ឯកសារ D106/18 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919482 ["រោងដាក់អ្នកទោសធ្ងន់ រោងអ្នកយាមសន្តិសុខ និងទីតាំងរណ្តៅសពរួម៖ ពីចំណុច N13 35.396' - E103

21. 065' ដល់ចំណុច N 13.35.688' - E 103.21.1 07' ទីតាំងរណ្តៅសពរួមផងទៀត៖ ពីចំណុច N 13.35.363' - E 103.21.058' ដល់ចំណុច N 13.35.483' - E 103.21.1 00'"]។

966 ឯកសារ D106/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.36 KH 00801017 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំស្នាក់នៅខាងកើតភ្នំត្រយោង។"]។ ឯកសារ D1.3.11.43 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ រិន ខេង ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ EN 00210494 [សាក្សីគឺជាអ្នកទោស៖ "កន្លែងឃុំឃាំងស្ថិតនៅខាងកើតភ្នំ ហើយកន្លែងសម្លាប់មនុស្សស្ថិតនៅខាងជើងភ្នំ ហេតុនេះខ្ញុំមិនអាចមើលឃើញគេធ្វើអ្វីបានទេ។"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.48 KH 00989344 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំមិនដែលបានឃើញមនុស្សជាប់ខ្នោះនៅភ្នំត្រយោងទេ ព្រោះខ្ញុំរស់នៅភាគខាងត្បូងនៃភ្នំត្រយោង។"]។ ឯកសារ D106/18 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919481 ["រោងដាក់អ្នកទោសស្រាលពីចំណុច N13. 34.922' - E103. 20.980' ដល់ចំណុច N 13. 35.843' - E 103.21.130'"]។ ឯកសារ D106/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ KH 00801002 [សាក្សីជាអ្នកយាមគុក៖ "ខ្ញុំស្នាក់នៅប៉ែកឥសាននៃមន្ទីរសន្តិសុខត្រយោង។ កន្លែងដែលខ្ញុំនៅនេះ គឺជាកន្លែងដែលអ្នកទោសស្រាលនៅ។"]។

967 ឯកសារ D219/127 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.51 KH 01049200 [សាក្សីជាអ្នកយាមគុក៖ "រោងបាយនៅចន្លោះកន្លែងតាសឿន ស្នាក់នៅ និងអ្នកទោសស្រាលស្នាក់នៅ។"]។ ឯកសារ D219/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.30 KH 01058768 [សាក្សីគឺជាអ្នកទោស៖ "មានទីធ្លាធំនៅខាងលិចរោងបាយ ពួកគេយកចានម្នាក់មួយៗ ហើយក៏ហូបបាយនៅទីនោះទៅ។"]។

968 ឯកសារ D119/159 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.52 KH 01025132 [សាក្សីគឺជាអ្នកទោសធ្ងន់៖ "កន្លែងខ្ញុំវ៉ៃថ្ម គឺនៅខាងត្បូងកន្លែងដែលខ្ញុំជាប់ឃុំ"]។ ឯកសារ D106/18 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង KH 00919482 ["កន្លែងយកថ្ម "N13. 34.965' – E103 21.027"]។

969 ឯកសារ D219/127 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.53 KH 01049200 [សាក្សីគឺជាអ្នកយាមគុក៖ "នៅពេលព្រឹក ខ្ញុំឃើញអ្នកទោសធ្ងន់ប្រហែល ៣០ នាក់ ធ្វើការនៅកន្លែងវាយថ្ម ដែលនៅខាងក្រោយកន្លែងដែលតាសឿន ស្នាក់នៅ ហើយមានយោធាប្រដាប់អាវុធចំនួន៤ទៅ៥នាក់ យាមពួកគេ។"]។ ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951771 [សាក្សីគឺជាប្រធានគុក៖ "នាំជូនទៅធ្វើការ ឃើញនាំដើរកាត់ទៅ ទៅវ៉ៃថ្មវ៉ៃអី កម្លាំងគេដូចថាទៅប៉ុន្មាននាក់ ១០នាក់ចឹង គេទៅគ្នា ៣-៤នាក់ចឹង ទៅតាមទៅធ្វើការកន្លែងនឹង។"]។ ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045323 [OCIJ-068 (ទុំ សឿន - ប្រធានគុក)៖ "អ្នកទោស ខ្ញុំមិនដែលបានឃើញរត់ចេញទេ។ មានមួយដង គឺអ្នកវាយថ្មបានរត់គេចដោយយកដែកវាយអ្នកយាមហើយរត់គេចបាត់ទៅ។"]។ ឯកសារ D5/1179 ទំរង់បែបបទព័ត៍មានអំពីជនរងគ្រោះ ប៊ូ ទូក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ

01342491



២០០៩ KH 01030733 [សាក្សីគឺជាអ្នកទោស៖ "នៅពេលថ្ងៃ ពួកឈ្លបសន្តិសុខបណ្ដើរខ្ញុំអោយបង្ខំអោយវាយថ្ម ដោយកំណត់១ថ្ងៃ១មពា ជារៀងរាល់ថ្ងៃ។"]។ ឯកសារ D219/475 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.19 KH 01134131 [សាក្សីគឺជាអ្នកទោស៖ "ព្រឹកឡើងថ្ងៃបន្ទាប់ [ក្រោយពីយើងទៅដល់ទីនោះ] [កម្មាភិបាលខ្មែរក្រហម] គេឱ្យយើងឡើងភ្នំគាស់ថ្ម ហើយទម្លាក់មកក្រោមឱ្យអ្នកខាងក្រោមវៃបំបែក។[...] [ខ្មែរក្រហម] យាមនៅតែជើងភ្នំទេ"]។

970 ឯកសារ D106/5 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.19 KH 00801024 [សាក្សីគឺជាប្រធានគុក៖ "ស្រែខាងកើតភ្នំ"]។ ឯកសារ D49 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ីន ណាន់ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១១ KH 00722216 [សាក្សីគឺជាអ្នកទោស៖ "រោងនោះគឺស្ថិតនៅចង្កេះភ្នំ។ នៅទីនោះមានរោងប្រហែលជាបួន ប្រាំ ហើយមានអ្នកយាមជាប់ជានិច្ច។ ខ្ញុំត្រូវបានគេឱ្យទៅកាប់កន្ទ្រៀនខែតដើម្បីធ្វើជី និងច្រូតស្រូវនៅទីនោះ"]។ ឯកសារ D219/127 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.52 KH 01049200 [សាក្សីគឺជាអ្នកយាមគុក៖ "ម្ដងម្កាលខ្ញុំនាំអ្នកទោសស្រាលទៅធ្វើចម្ការនៅជើងភ្នំ នៅចន្លោះភ្នំលាប និងភ្នំត្រយោង។ តែជាញឹកញាប់ ខ្ញុំនាំក្រុមរបស់ខ្ញុំទៅធ្វើការនៅប៉ែកនិរតីនៃភ្នំ គឺនៅតាមវាលស្រែដែលធំល្វឹងល្វើយ។ នៅវាលស្រែនោះ ខ្ញុំឃើញមានអ្នកទោសស្រាលធ្វើការតាមក្រុមផ្សេងៗ ហើយមានចំនួនរាប់រយនាក់"]។ ឯកសារ D106/18 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919483 ["ភ្នំត្រយោងជាភ្នំដ៏ធំមួយ ព័ទ្ធជុំវិញដោយវាលស្រែ និងអាងស្តុកទឹកព្រៃនាម នៅខាងត្បូងភាគខាងកើតនៃភ្នំនេះ ហើយមានភ្នំលៀប នៅក្បែរនោះនៅទិសខាងជើង"]។

971 ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ធិប សំផាត់ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927406 [សាក្សីគឺជាអ្នកទោស៖ "ប៉ុនដូចថាក្នុងគុកវាអត់មានជញ្ជាំង វាពិបាកជាងអាគុកមានជញ្ជាំង។ ដូចថារាល់ថ្ងៃធ្វើការដីប៉ុននេះចេះ អត់មានឱ្យដើរចេញទេ។"]។ ឯកសារ D119/49 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.53 KH 00933108 [សាក្សីគឺជាអ្នកទោស៖ "គុកឥតជញ្ជាំងគឺមានន័យថា អ្នកទោសទាំងនោះរស់នៅក្នុងកន្លែងមួយដែលគ្មានជញ្ជាំង និងគ្មានរបងនោះទេ តែពុំអាចរត់ចេញទៅណាបានដែរ។"]។ ឯកសារ D119/51 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.17 KH 00933122 [សាក្សីគឺជាអ្នកទោស៖ "ក្រោយមកគេបានចាប់ម្ដាយខ្ញុំ និងខ្ញុំយកទៅកសាងនៅគុកភ្នំត្រយោង ដែលជាគុកឥតជញ្ជាំង ប៉ុន្តែមានអ្នកយាម។"]។ ឯកសារ D219/567 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.79 KH 01165949 [សាក្សីគឺជាអ្នកទោស៖ "[មានអ្នកទោស] រាប់រយ រាប់ពាន់នាក់ គ្មានរបងព័ទ្ធជុំវិញ។"]។ ឯកសារ D106/4 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.9 KH 00800988 [សាក្សីគឺជាអ្នកភូមិភ្នំត្រឡោក៖ "ប៉ុន្តែមន្ទីរសន្តិសុខនោះមិនមានរបងព័ទ្ធជុំវិញទេ។"]។ ឯកសារ D5/1246 [redacted] KH 01036169 [សាក្សីត្រូវបានបញ្ជូនទៅការដ្ឋានភ្នំត្រយោង៖ "ពេលនោះមិត្ត ចែម បញ្ជារឱ្យពួកខ្ញុំជីករណ្ដៅរបៀបដូចលេនដ្ឋានកងទ័ព ជីករួច វាបញ្ជារឱ្យពួកខ្ញុំ កាប់ឬស្សីធ្វើចំរូងស្រួចៗ ដាក់ក្នុងលេនដ្ឋាន នៅពេលនោះ មេកងប្រាប់ខ្ញុំថា លេនដ្ឋានទាំងនេះ ទុកការពារកុំឱ្យកងចល័តណារត់គេចពេលយប់"]។

972 ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.21-24 KH 00801024-00801025 [សាក្សីគឺជាប្រធានគុក៖ "មានផ្លូវទៅកាន់ភ្នំមួយទៀត ដែលខ្ញុំមិនចាំឈ្មោះ គឺជាកន្លែងដែលគេគ្រោងសាងសង់មន្ទីរសន្តិសុខធំមួយថ្មីទៀត ប៉ុន្តែមិនទាន់ត្រូវបានសាងសង់ទេ ពីព្រោះវៀតណាមបានចូលមកដល់។...មានគេដឹកឈើចំនួនបីរថយន្តពីភ្នំពេញមក ដើម្បីសាងសង់មន្ទីរសន្តិសុខថ្មី តែគេមិនដែលបានសាងសង់ទេ"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.208 KH 00953048 [សាក្សីគឺជាប្រធានគុក៖ "ឃើញម្តងខាងភូមិភាគបានដឹកឈើមកទុកនៅភ្នំត្រយោង ដើម្បីធ្វើមន្ទីរសន្តិសុខថ្មីនៅភ្នំស្រមោច ប៉ុន្តែមិនទាន់បានសាងសង់ទេ ហើយឈើនៅសល់ខ្ញុំយកទៅធ្វើផ្ទះ។ ភ្នំស្រមោចនៅចម្ងាយប្រហែល៥០០ម៉ែត្រពីភ្នំត្រយោង"]។

973 ឯកសារ D106/18 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919484 ["យោងតាមសាក្សី ចាប់តាំងពីរបបខ្មែរក្រហម បានដួលរលំក្នុងខែមករា ឆ្នាំ ១៩៧៩ មានការប្រែប្រួលខ្លះនៅក្នុងទីកន្លែងនោះ ដូចជាផ្ទះឈើទាំងអស់ត្រូវបានបំផ្លាញ ហើយសព្វថ្ងៃនេះ បើប្រៀបធៀបក្នុងជំនាន់នោះ ភ្នំមានទំហំតូចជាងឆ្ងាយណាស់ ដោយសារការវាយថ្មយ៉ាងច្រើនពីភ្នំនេះ"]។ ឯកសារ D106/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.40 KH 00800985 [សាក្សីគឺជាអ្នកទោស៖ "ប្រហែលជាខ្ញុំអាច តែវាពិបាក ដោយសារស្ថានភាពទីតាំងបានផ្លាស់ប្តូរអស់ហើយ"]។

974 អ្នកទោសមកពី ឬត្រូវបានចាប់ខ្លួននៅស្រុកព្រះនេត្រព្រះ៖ ឯកសារ D119/28 របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ KH 00907612 [ចាម បួរ មកពីភូមិកណ្តាល ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ។]។ ឯកសារ D106/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.1-7 KH 00801014 [សាក្សី ធិប សំផាត់ គឹម នៅ និង គិម យ៉េត គឺជាក្រុមពេទ្យដែលត្រូវគេចាប់ខ្លួននៅឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ហើយបញ្ជូនទៅទៅភ្នំត្រយោង]។ ឯកសារ D106/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.2-12 KH 00800979-00800981 [សាក្សីត្រូវបានចាប់ខ្លួនពេលគាត់ធ្វើការក្នុងពេទ្យនៅភ្នំលៀបជាមួយ "នៅ និង ផាត់"]។ ឯកសារ D1.3.11.20 បទសម្ភាសន៍របស់ SOAS ជាមួយ គឹម នៅ (Keum Nov) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំត្រូវបានចាប់ខ្លួនប្រហែលជាពីរខែមុនពេលវៀតណាមចូលមកដល់។ ខ្ញុំធ្វើការនៅពេទ្យក្នុងឃុំភ្នំលៀប"]។ ឯកសារ D119/51 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.13-17 KH 00933122 [សាក្សី និងម្តាយរបស់គាត់ [ប៊ឹន ណាន់] ត្រូវបានចាប់ខ្លួននៅស្រុកព្រះនេត្រព្រះ រួចត្រូវគេបញ្ជូនទៅភ្នំទ្រយោង]។ ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.37-38 KH 01024749 [សាក្សីត្រូវបានចាប់ខ្លួននៅភ្នំជញ្ជាំង ស្រុកព្រះនេត្រព្រះ ដើម្បីបញ្ជូនទៅភ្នំត្រយោង]។ ឯកសារ D119/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ឈ្មោះហៅក្រៅ/បដិវត្តន៍ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.10 KH 00894492 [សាក្សីគឺជាអ្នកទោស៖ "នៅពេលនោះ ខ្ញុំត្រូវបានគេផ្លាស់ឱ្យទៅដាំដំឡូងនៅខ្នងភ្នំជញ្ជាំង ដែលមានទីតាំងនៅក្នុងភូមិជប់វ៉ារី ឃុំជប់វ៉ារី ស្រុកព្រះនេត្រព្រះ។"] ឆ.16 KH 00894493 ["ខ្ញុំមិនដឹងពីមូលហេតុទេ តែគេបានមកចាប់ខ្ញុំនិង ទី នៅកងចល័តដាំដំឡូង។"]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.3 KH 00895167 [សាក្សីគឺជាអ្នកទោស៖ "ពេលខ្ញុំនៅជប់បានប្រហែល៣ទៅ៤ខែ ខ្ញុំត្រូវ

បានគេចាប់ខ្លួន ដោយមិនដឹងមូលហេតុ ហើយត្រូវបានគេបញ្ជូនទៅភ្នំត្រយោង ជាមួយអនុប្រធានរបស់ខ្ញុំឈ្មោះ សាមុន។"]។ ឯកសារ D219/230 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង រ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.2 KH 01076373 [សាក្សីគឺជាអ្នកទោស៖ "គេបានចាប់ខ្លួនខ្ញុំនៅចម្ការកប្បាស់នៅក្នុងស្រុកព្រះនេត្រព្រះបន្ទាប់ពីខ្ញុំបានលួចបូតស្រូវគេ"]។ ឯកសារ D101/1.2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 00743550 [សាក្សីគឺជាអ្នកទោស៖ "កាលនោះ ប្រហែលជានៅខ្ទង់ឆ្នាំ ១៩៧៨ អាត្មាត្រូវបានគេឲ្យចល័តទៅធ្វើការនៅស្វាយ ស៊ីសុផុន។ ពេលទៅបានត្រឹមប្រហែល ១ ខែ ត្រូវបានគេចាប់យកមកភ្នំត្រយ៉ូងនេះឯង។ អាត្មាជាប់នៅទីនោះប្រហែលជា ៦ ខែ។ [É] អ្នកទោសភាគច្រើនជាប្រជាជនថ្មី។ អ្នកស្រុកព្រះនេត្រព្រះ ដែលជាប់ខ្នោះនាពេលនោះមានតែអាត្មាទេដែលជាប្រជាជនចាស់ ចំណែកឯអ្នកផ្សេងទៀតគឺជាប្រជាជនដែលមកពីកន្លែងផ្សេងៗ អាត្មាមិនដឹងមកពីណាទេ។"]។ ឯកសារ D219/211 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អឿន ចាន់រី ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.8 KH 01074052-01074053 [ប្តី និងបងប្រុសរបស់សាក្សីបានរត់ពីភូមិតាប៉ុន ក្នុងស្រុកព្រះនេត្រព្រះ ទៅភូមិគំរូ នៅក្នុងស្រុកក្រឡាញ់ ហើយត្រូវគេចាប់ខ្លួនបានរួចបញ្ជូនទៅភ្នំត្រយោង។]។ ឯកសារ D219/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.14-16 KH 01058764 ["សាក្សីគឺជាអ្នកទោស៖ "មានពួកយោធាប្រដាប់អាវុធ៤-៥នាក់ បានបណ្តើរយើងពីការដ្ឋានព្រៃមាន់ទៅកាន់ភ្នំទ្រយោង"]។ ឯកសារ D219/174 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.25 ឆ.37 ឆ.57 KH 01065987 KH 01065989 KH 01065991 [សាក្សីគឺជាអ្នកទោស៖ គាត់ត្រូវបានគេចាប់ខ្លួនពេលធ្វើការជាពេទ្យនៅស្រុកព្រះនេត្រព្រះ ហើយបញ្ជូនទៅគុកចំការខ្នុរ រួចហើយទៅចំការគរជាទីកន្លែងសម្លាប់មនុស្ស បន្ទាប់មកគេបញ្ជូនគាត់ទៅភ្នំត្រយោង។"]។ ឯកសារ D119/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច ឈានឡុង ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.71 KH 01024764 ["សាក្សីគឺជាប្រធានកងក្នុងមូលដ្ឋានដែលដឹកជញ្ជូនអ្នកទោសទៅភ្នំត្រយោង៖ "ពួកគេជាប្រជាជនដែលគេជម្លៀសមកពីទីក្រុងភ្នំពេញ ហើយមករស់នៅក្នុងភូមិទេពកោសា [ស្រុកព្រះនេត្រព្រះ]"]។ អ្នកទោសមកពីស្រុកផ្សេងទៀត៖ ឯកសារ D219/567 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.1 KH 01165943 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំរស់នៅ [É] ស្រុកថ្មពួក"] ឆ. 37-38 KH 01165946 ["ខ្ញុំរត់ទៅភូមិបេង ពេលដែលគេវ៉ៃចោលមនុស្សច្រើន។ [É] ភូមិបេង នៅក្នុងឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ"] ឆ.48 KH 01165947 ["ខ្ញុំទៅជាប់នៅភ្នំត្រយោង១ខែ"] ឆ.51 KH 01165947 ["គេធ្វើសំបុត្រពីតំបន់៥ទៅ។ ខ្ញុំដើរពីភូមិបេងទៅសំរោង ហើយឡើងឡានទៅគុកភ្នំត្រយោង។"] ឆ.67-68 KH 01165948 ["ស៖ ពេលដែលដើរពីភូមិបេងទៅសំរោងមានកម្មាភិបាល គេឃាមយើងតាមផ្លូវទេ? ឆ.67៖ មានប្រហែលជា៤ទៅ៥នាក់។ ស៖ ពេលដល់សំរោងគេឲ្យឡើងឡាន ហើយគេយកទៅគុកភ្នំត្រយោង? ឆ.68៖ បាទ"] ឆ.170 KH 01165957 ["អ្នក[ទោស] ខ្លះមកពីតំបន់៥ ខ្លះតំបន់៣។"]។ ឯកសារ D219/400 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.7 KH 0115773 [សាក្សីគឺជាអ្នកទោស៖ ខ្ញុំនៅភូមិកណ្តាលខាងលិច ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង"] ឆ.45-46 KH 0115777 ["ខ្ញុំរត់ចូលព្រៃ តែទាហានច្រើន ពេក ខ្ញុំចុះមកសារភាពវិញ ហើយនៅផ្ទះបានមួយខែកន្លះ [É] ស៖ ពេលគេចាប់លោក តើលោកនៅក្នុងស្រុកភ្នំស្រុក ឬ? ឆ.46៖ បាទ"] ឆ. 56-57 KH 0115778 ["មកពីស្ពានស្រែង ភ្នំស្រុក អ្នកពីណាមកក៏គេបញ្ចូល [ភ្នំត្រយោង] ដែរ។ គេបញ្ជូនមកហ្នឹងតែទាំង

អស់ ទាំងអ្នកផ្លុង។ [É] សម្រាប់តំបន់៥ហ្នឹងហើយ ព្រោះមានមនុស្សមកពីច្រើនស្រុក។"]។ ឯកសារ D219/252 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.29 KH 01085125 ["សាក្សីគឺជាអ្នកទោស៖ "ខ្ញុំចេញពីទីនោះទៅសហករណ៍ស្ពានស្រែង។ ខ្ញុំនៅសហករណ៍ស្ពានស្រែងបានតែ ២ ខែ គេក៏ចាប់ខ្ញុំមកវិញទៀត។ គេបានយកខ្ញុំទៅដាក់គុកនៅភ្នំខ្លាកូន នៅឯស្វាយ ប្រហែលប៉ុន្មានខែ។ បន្ទាប់មកគេបញ្ជូនទៅភ្នំត្រយ៉ូង ដែលនៅជិតភ្នំលាភ នៅស្រុកព្រះនេត្រព្រះ"]។ ឯកសារ D219/583 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.1-2 ឆ.11-14 KH 01166954-01166956 [សាក្សីមកពីភូមិគោស្រេះ ស្រុកភ្នំស្រុក គេចាត់ឱ្យគាត់ធ្វើការក្នុងកងចល័តតំបន់ រួចហើយគាត់ត្រូវបានគេចាប់ខ្លួននៅភូមិកំណើតរបស់ គាត់។] ឆ.101 KH 01166970 ["វាជាគុកថ្នាក់តំបន់ ព្រោះមានថ្នាក់តំបន់ចូលរួមនៅទីនោះ។"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.2 KH 00989338 [សាក្សីធ្វើការនៅកងចល័តកុមារ៖ "ខ្ញុំរស់នៅភូមិស្រះជីក ឃុំស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។"] ឆ.20 KH 00989340 ["[ពេលកម្មាភិបាលនិរតីចូលមក] មានការចាប់ខ្លួន និងការបាត់ខ្លួនខ្លះដែរ។ មនុស្សដែលត្រូវបានចាប់ខ្លួនទាំងនោះត្រូវបានបញ្ជូនទៅភ្នំត្រយោង។ ក្រោយមកគេបានបញ្ជូនពួកខ្ញុំឱ្យទៅនៅភ្នំត្រយោងដែរ។"]។ ឯកសារ D219/318 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជន តំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ឆ.13-14 ឆ.25 ឆ.48 KH 01097887 KH 01097889 KH 01097893 [សាក្សីគឺជាអនុប្រធានអង្គភាពតម្បាញស្រុកភ្នំស្រុក ដែលត្រូវបានចាប់ខ្លួននៅភូមិគោកធំ រួចហើយបញ្ជូនទៅគុកចំការខ្នុរ ស្ថិតនៅក្នុងស្វាយស៊ីសុផុន បន្ទាប់មកគេបញ្ជូនគាត់ទៅភ្នំត្រយ៉ុង។]។ ឯកសារ D219/174 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.57 KH 01065991 [សាក្សីធ្វើការនៅក្នុងចល័តភូមិក្នុងស្រុកព្រះនេត្រព្រះ រួចហើយត្រូវគេដាក់គុកនៅចំការខ្នុរ៖ "បន្ទាប់ពីខ្ញុំចេញពីចំការខ្នុរ គេបានបញ្ជូនខ្ញុំទៅចំការគរ ដែលនៅទីនោះមានអ្នកទោសច្រើនត្រូវបានគេសម្លាប់ ហើយមានអ្នកទោសស្រីតែប្រាំបួននាក់ដែលនៅរស់។ ហើយអ្នកដែលនៅរស់ ត្រូវបានគេដឹកតាមឡានយកទៅភ្នំត្រយោង។ ក្នុងចំណោមអ្នកទោសស្រីប្រាំបួននាក់ដែលនៅរស់នោះ ខ្ញុំចាំឈ្មោះប្រាំនាក់ គឺឈ្មោះ ធី មកពីភូមិក្របីរៀល ខេត្តសៀមរាប [É] ឈ្មោះ នី មកពីតានីទូកមាស និងឈ្មោះ ឆាន ខ្ញុំមិនច្បាស់ថាគាត់មានភូមិកំណើតទីណាទេ ប៉ុន្តែតាមខ្ញុំស្មានគាត់នៅភូមិស្ពានស្រែង ឬភូមិថា ឬក៏ភូមិរោគ។"] ឆ.4 EN 01112008 ["គុកចំការខ្នុរមានទីតាំងនៅជើងភ្នំ ក្នុងស្រុកស្វាយស៊ីសុផុន"]។ ឯកសារ D219/129 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន យ៉េង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.12-15 KH 01049220-01049221 [សាក្សីគឺជាអ្នកទោស៖ មិនស្គាល់ច្បាស់ពីទីកន្លែងដែលគេចាប់ខ្លួនគាត់ទេ ប៉ុន្តែគេបានបញ្ជូនគាត់ពីចម្ការគ ដែលគាត់បញ្ជាក់ថាស្ថិតនៅខាងជើងស្វាយស៊ីសុផុន ទៅកាន់ភ្នំត្រយោង]។ ឯកសារ D219/357 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.54 KH 01104644 [សាក្សីគឺជាអ្នកទោស៖ [កងចល័តរបស់ខ្ញុំ] ជាកងចល័តរបស់ស្រុកភ្នំស្រុក។"] ឆ.79 KH 01104648 ["គេចាប់ខ្លួនខ្ញុំហើយបញ្ជូនទៅភ្នំត្រយ៉ូងនៅពេលដែលខ្ញុំកំពុងធ្វើការនៅស្ពានស្រែង។"] ឆ.84 KH 01104649 ["ខ្ញុំគ្រាន់តែដឹងថា មនុស្សដែលគេចាប់បញ្ជូនទៅភ្នំត្រយ៉ូង គឺមកពីស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះ។"]។ ឯកសារ D219/475 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.4 KH 01134128 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំធ្វើការនេះ [ស៊ីសុផុន]

រហូតដល់ចុងឆ្នាំ ១៩៧៦។ [É] ដោយសារតែយើងខ្លាច គ្នាយើងប្រហែល ១២០នាក់ បានរត់ទៅរស់នៅក្នុងព្រៃ ហើយយើងនៅទីនោះប្រហែល ៦ខែ។ មានការឃោសនាជាបន្តបន្ទាប់ថា ពួកគេមិនធ្វើបានពួកយើងទេ បើសិនជាពួកយើងចុះចូលហើយត្រលប់មកភូមិវិញ។ [É] អ្នកចុះចូលចូលដំបូងគេ ត្រូវបានបញ្ជូនទៅគុកត្រយោង”]។ ឯកសារ D219/149 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.18 KH 01058728 [សាក្សីគឺជាអ្នកទោស៖ “ក្នុងឆ្នាំ១៩៧៨ ខ្ញុំបានរត់គេចម្តងទៀតពីភូមិពង្រ [ស្រុកភ្នំស្រុក] ទៅភូមិកំណើត គឺភូមិសំរោង ក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប ហើយក្រោយបានស្នាក់នៅទីនោះកន្លះខែ គេចាប់ខ្ញុំ [É] គេបញ្ជូនផ្ទាល់ទៅភ្នំត្រយោងតែម្តង ហើយយើងទៅដល់ទីនោះនៅពេលយប់។”]។ ឯកសារ D119/49 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.49 KH 00933108 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំដឹងថាវាជាគុករបស់តំបន់ ព្រោះមេគុកគាត់ធ្លាប់និយាយថាជាគុកតំបន់”]។ ឯកសារ D101/1.2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 00743550 [សាក្សីគឺជាអ្នកទោស និងជាកងចល័តតំបន់៖ “កាលនោះ ប្រហែលជានៅខ្ទង់ឆ្នាំ ១៩៧៨ អាត្មាត្រូវបានគេឲ្យចល័តទៅធ្វើការនៅស្វាយ ស៊ីសុផុន។ ពេលទៅបានត្រឹមប្រហែល ១ ខែ ត្រូវបានគេចាប់យកមកភ្នំត្រយ៉ូងនេះឯង។ អាត្មាជាប់នៅទីនោះប្រហែលជា ៦ ខែ។ [É] អ្នកទោសភាគច្រើនជាប្រជាជនថ្មី។ អ្នកស្រុកព្រះនេត្រព្រះដែលជាប់ខ្នោះនាពេលនោះមានតែអាត្មាទេដែលជាប្រចាជនចាស់ ចំណែកឯអ្នកផ្សេងទៀតគឺជាប្រជាជនដែលមកពីកន្លែងផ្សេងៗ អាត្មាមិនដឹងមកពីណាទេ។”]។ ឯកសារ D119/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឆ.11-12 KH 00894502 [សាក្សីគឺជាអ្នកធ្វើការក្នុងកងចល័តនៅព្រះនេត្រព្រះ៖ “ខ្ញុំដឹងថាមានគុកនៅភ្នំត្រយោង ដែលជាគុកតំបន់ ៥។ [É] ពីព្រោះអ្នកដែលត្រូវបានចាប់ខ្លួនពីគ្រប់កន្លែងក្នុងតំបន់ ៥ ត្រូវបានគេបញ្ជូនទៅទីនោះ។”]។ ឯកសារ D119/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.14 KH 00978910 [សាក្សីគឺជាប្រធានកងចល័តដែលធ្វើការនៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងទំនប់ភ្នំលៀប៖ “ខ្ញុំបានដឹងត្រឹមតែថា មានមនុស្សបាត់ខ្លួននៅតាមកងចល័តនានា នៅក្នុងតំបន់៥។ ក្រោយមក ទើបខ្ញុំបានដឹងថា គេចាប់មនុស្សយកទៅសម្លាប់នៅភ្នំត្រយ៉ូង ដែលជាកន្លែងវ៉ៃថ្ម។”]។ ឯកសារ D219/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.42 KH 01040790 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំបានដឹងថា គុកភ្នំត្រយោង គឺជាគុករបស់តំបន់៥ ដោយសារតែមានអ្នកទោសនៅស្វាយ ត្រូវបានគេបញ្ជូនមកទីនេះ។ ខ្ញុំបានស្គាល់ស្ត្រីម្នាក់ឈ្មោះ ពេញ [É] ក្រោយមកគាត់ជាអ្នកទោសនៅស្វាយ តំបន់៥ ហើយបន្ទាប់មកគេបានបញ្ជូនគាត់មកដាក់គុកភ្នំត្រយោងជាមួយខ្ញុំ។ ខ្ញុំធ្លាប់បានសួរអ្នកទោសផ្សេងទៀត ដែលត្រូវបានគេបញ្ជូនមកភ្នំត្រយោងដែរ។ ដូច្នេះហើយ បានជាខ្ញុំដឹងថា គុកភ្នំត្រយោង គឺជាគុករបស់តំបន់៥ ពីព្រោះ ស្វាយ គឺស្ថិតនៅក្នុងតំបន់៥។”]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.30 KH 00895171 [សាក្សីគឺជាអ្នកទោស៖ “ស៖ ម្តេចលោកដឹងថា គុកនេះជាគុកតំបន់៥? ព្រោះខ្ញុំដឹងថា អ្នកទោសនៅស្វាយ [ស៊ីសុផុន] ត្រូវបានគេនាំមកដាក់ទៅទីនោះដែរ។ មានអ្នកទោសផ្សេងៗទៀតត្រូវបានគេនាំមកដាក់នៅទីនោះដូចជាមកពី សៀមរាប និងតំបន់៣។”]។ ឯកសារ D106/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.26-28 KH 00800983 [សាក្សីគឺជាអ្នកទោស៖ “នៅរសៀលមួយនោះ នៅម៉ោងប្រហែល ៤ឬ៥ ក្រុមពេទ្យរបស់ខ្ញុំត្រូវបានគេឲ្យដាក់អ្នកទោសជាក្រុមផ្សេងៗគ្នាជាពីរក្រុម ដែលគេបានដឹកតាមឡានមកមន្ទីរសន្តិសុខនោះ។ អ្នក

ទោសនោះត្រូវបានគេដឹកមកពីសៀមរាប ហើយក្នុងមួយឡាននោះមានចំនួនអ្នកទោសពី៣០ ទៅ ៤០ នាក់។...ពួកគេមកពីសៀមរាប ពីតំបន់៤។"]។ ឯកសារ D219/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.48 KH 01043166 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំដឹង [ថាអ្នកទោសទាំងនោះមកពីតំបន់៤ ខេត្តសៀមរាប] ដោយសារអ្នកទោសទាំនោះ ប្រាប់ខ្ញុំនៅពេលដែលពួកគេចុះពីលើឡានមក។"]។ ផ្ទុយនឹង ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951764 [សាក្សីគឺជាប្រធានគុក៖ "អានឹងតាមឮគឺអប់រំក្នុងស្រុកនឹង [É] ស៖ ពីណាគេអ្នករៀបចំ? ឆ៖ យាយ ចែម គាត់រៀបចំយកចល័តយកអីទៅដាក់នឹង។ គាត់រៀបចំដូចថា មាននេះអី គាត់យកទៅអប់រំកន្លែងនឹង គណៈស្រុកគេរៀបចំ។"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.200 KH 00953047 [សាក្សីគឺជាប្រធានគុក៖ "បាទ ពួកគេមកពីសហករណ៍នានានៅក្នុងស្រុកព្រះនេត្រព្រះតែប៉ុណ្ណោះ។"] ឆ.149-150 KH 00953039-00953040 ["សហករណ៍នានាជាអ្នកប្រមូលមក [É] មានតែសហករណ៍នានាក្នុងស្រុកព្រះនេត្រព្រះទេ។"]។ ឯកសារ D1.3.11.20 បទសម្ភាសន៍របស់ SOAS ជាមួយ គឹម នៅ (Keum Nov) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ EN 00211886 [សាក្សីគឺជាអ្នកទោស "គុកនេះគឺជាផ្នែកមួយរបស់យោធាស្រុក"]។

975 ឯកសារ D106/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ឆ.28 KH 00801025 [សាក្សីគឺជាប្រធានគុក៖ "គឺយាយចែម ដែលជាអ្នកគ្រប់គ្រងរួម [នៅភ្នំត្រយោង]"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.148 KH 00953039 [សាក្សីគឺជាប្រធានគុក៖ "យាយចែម ក៏បាននិយាយជាមួយខ្ញុំដែរ ថាឲ្យខ្ញុំមើលខុសត្រូវនៅទីនោះ"] ឆ.158 KH 00953041 ["តាមការពិភាក្សាគ្នាដែលយាយចែមនិយាយជាមួយខ្ញុំ គាត់ឲ្យខ្ញុំរៀបចំកន្លែងអប់រំនោះ។"] ឆ.175 KH 00953043 ["យាយចែម ជាអ្នកចាត់តាំងខ្ញុំឲ្យទទួលខុសត្រូវកន្លែងនោះ។ ពេលកម្លាំងមកច្រើន គាត់ឲ្យខ្ញុំជួយរៀបចំកន្លែងនោះ។"] ឆ.171 KH 00953042 ["បទបញ្ជា ឬគោលនយោបាយ គឺយាយចែមជាអ្នកបង្កើតឡើង។ យាយចែម បញ្ជាថាអ្នកទោសស្រាលឲ្យខ្ញុំបង្កើតជាសហករណ៍"] ឆ. 173 KH 00953043 ["តាមការសន្និដ្ឋានរបស់ខ្ញុំ បើយាយចែមតែម្នាក់ឯងក៏មិនអាចបង្កើតកន្លែងនោះដែរ ព្រោះឈើដែលខ្ញុំយកទៅធ្វើផ្ទះនោះ គឺយកមកពីស្វាយ ពីបាត់ដំបង ដូច្នេះវាមកពីតំបន់៥។ ទាល់តែយាយចែមទទួលបញ្ជាពីលើទើបអាចធ្វើបាន។"] ឆ.178 KH 00953043 [សាក្សីគឺជាប្រធានគុក៖ "ស៖ តើនីរសាររបស់យាយចែមដែលលោកជំនួសនោះមានឈ្មោះអ្វី? ឈ្មោះសាន់។"] ឆ.183 KH 00953044 ["នីរសាររបស់គាត់ ទៅមើលក្នុងរវាងពីរបីថ្ងៃម្តង។"]។ ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.6-7 KH 01043194 [សាក្សីគឺជាប្រធានគុក៖ យាយចែម បញ្ជាសឿន ឲ្យធ្វើការនៅទីនោះ និងទទួលបញ្ជាពីថ្នាក់លើ គឺពីថ្នាក់តំបន់។] ឆ.45 KH 01043199 [សាក្សីគឺជាប្រធានគុក៖ "យាយចែម គឺជាអ្នកសម្រេចថាឲ្យដោះខ្នោះ ឬមិនដោះខ្នោះ គឺស្ថិតលើការសម្រេចចិត្តរបស់យាយចែម។"]។ ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951764-00951765 [សាក្សីគឺជាប្រធានគុក៖ "ស៖ ពីណាគេអ្នករៀបចំ? ឆ៖ យាយ ចែម គាត់រៀបចំយកចល័តយកអីទៅដាក់នឹង។ គាត់រៀបចំដូចថា មាននេះអី គាត់យកទៅអប់រំកន្លែងនឹង គណៈស្រុកគេរៀបចំ។ [...] បាទ! កន្លែងភ្នំទ្រយោងនឹង។ នឹងកន្លែងសន្តិសុខគេ នគរបាលគេអ្នករៀបចំនឹង។ [...] វាធម្មតា តែអ្នកចាត់តាំងវាច្បាស់លាស់នៅ

លើ យាយ ចែម។"]។ ឯកសារ D106/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.35 KH 00801017 [សាក្សីគឺជាអ្នកទោសៈ "តែតាមរយៈសំបុត្រដែលខ្ញុំបានអាន ខ្ញុំអាចដឹងបានថា យាយ ចែម ជាមេរបស់គាត់ [តា សឿន]"]។ ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.89 KH 00980395 [សាក្សីគឺជាមេឃុំភ្នំលៀបៈ "តាមខ្ញុំដឹងមន្ទីរសន្តិសុខភ្នំត្រយ៉ូងជាមន្ទីរសន្តិសុខថ្នាក់តំបន់។ តាមខ្ញុំដឹង យាយចែម មានអំណាចគ្រប់គ្រងមន្ទីរសន្តិសុខនោះ។"]។ ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045323 [OCIJ-068 (ទុំ សឿន - ប្រធានគុក)ៈ "អ្នកទោស ខ្ញុំមិនដែលបានឃើញរត់ចេញទេ។ មានម្តងដង គឺអ្នកវាយថ្មបានរត់គេចដោយយកដែកវាយអ្នកយាមហើយរត់គេចបាត់ទៅ។ អ្នករត់រួចនោះ មិនត្រូវបានចាប់បានទេ។ ខ្ញុំបានរាយការណ៍ពីការរត់គេចនេះទៅយាយ ចែម។ យាយ ចែម មិនបាននិយាយអ្វីនោះទេ។ ហើយ ខាងលើ ចាត់វិធានការណ៍យ៉ាងម៉េច ខ្ញុំមិនដឹងទេ។ ហើយ គាត់ក៏មិនដែលបានជូនដំណឹងមកខ្ញុំទាក់ទងនឹងបញ្ហានេះដែរ។"]។ ឯកសារ D219/567 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.131 KH 01165954 [សាក្សីគឺជាអ្នកទោសៈ "យាយចែម ធំជាង។"]។ ឯកសារ D219/383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អើយ ពឿ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.34 KH 01113227 [សាក្សីជាអ្នកធ្វើការនៅកងចល័ត និងធ្លាប់ទៅឃើញគុកៈ "គាត់មានសិទ្ធិអំណាចគ្រប់គ្រងលើភ្នំត្រយ៉ូងពីព្រោះគាត់ជាអ្នកក្តាប់រួម"]។ ឯកសារ A165.1.14 "អយុត្តិធម៌វិសាមញ្ញ" Douglas Gillison មូលនិធិស៊ើបអង្កេត ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ EN 01021924 [អត្ថបទសារព័ត៌មានដែលអ្នកយកព័ត៌មានបានជួបសម្ភាសអតីតអ្នកទោសម្នាក់ឈ្មោះ នៅ (Neou)ៈ "ខ្ញុំអាចនិយាយបានថាគាត់មិនអនុវត្តផ្ទាល់ដៃដោយខ្លួនឯងទេ ប៉ុន្តែគាត់ជាអ្នកដាក់បញ្ជា។" "នៅបានបញ្ជាក់ថាមន្ទីរសន្តិសុខនៅជំរុំត្រូវបានបង្កើតឡើងក្នុងពេលដែលចែមកាន់កាប់។ គាត់បានបញ្ជាក់ថា នៅក្រោមការមើលខុសត្រូវរបស់ចែម មានមនុស្សច្រើនជាងមុនត្រូវគេសម្លាប់ ការងារធ្ងន់ធ្ងរខ្លាំង ហើយរបបអាហារមានការកំណត់យ៉ាងតឹងរ៉ឹង"]។ ឯកសារ D1.3.11.66 បទសម្ភាសន៍របស់ SOAS ជាមួយ យ៉ែម កោង ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ [សាក្សីគឺជាប្រធានកុមារនៅស្រុកព្រះនេត្រព្រះៈ "ចែមមើលការខុសត្រូវគុកនៅទ្រយោង"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.56 KH 00976184 [សាក្សីជាអ្នកធ្វើការនៅកងចល័តដែលរាយការណ៍ទៅឱ្យ អ៊ឹម ចែម "តាមការអង្កេតរបស់ខ្ញុំ យាយចែម ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខទាំងនោះ។]។ ឯកសារ D219/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.20 KH 01058765 ["សាក្សីគឺជាអ្នកទោសៈ "ខ្ញុំឮពីអ្នកយាម និងអ្នកទោស នៅភ្នំទ្រយោងនិយាយថា យាមចែម ជាមេរបស់តាសឿន"]។ ឯកសារ D219/174 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.71 KH 01065993 [សាក្សីធ្វើការនៅក្នុងចល័តភូមិក្នុងស្រុកព្រះនេត្រព្រះ រួចហើយត្រូវគេដាក់គុកនៅចំការខ្នុរៈ "ខ្ញុំធ្លាប់ឮ ពីព្រោះឈ្មោះនេះ ជាមេខ្លោងធំបំផុត ហើយគាត់ជាអ្នកដើរបើកអង្គប្រជុំនៅតាមកងចល័តនានា។"]។ ឯកសារ D219/400 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.59-62 KH 0115778 [សាក្សីគឺជាអ្នកទោសៈ "ប្រធានគុកអត់ចាំទេ ខ្ញុំចាំតែ យាយចែម ដែលជាអ្នក គ្រប់គ្រងនៅទីនោះ [...] ពេលចេញមក (វៀតណាមចូល) គេប្រាប់ថា វា (យាយចែម) នៅទីនោះ។ គ្នាខ្ញុំធ្លាប់ធ្វើល្អបប្រាប់។ [...] គេប្រជុំប្រាប់។"]។ ឯក

សារ D119/144 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡូត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឆ.69-70 KH 01009214 [សាក្សីគឺជាទាហាននៅស្រុកភ្នំស្រុក និងជាអ្នកធ្វើការក្នុងកងចល័តនៅទំនប់ត្រពាំងថ្ម "ខ្ញុំធ្លាប់ឮឈ្មោះភ្នំត្រយ៉ូង។ ភ្នំត្រយ៉ូងស្ថិតនៅក្រោមការគ្រប់គ្រងរបស់យាយ ថែម។ [...] ខ្ញុំឮគេនិយាយថា ភ្នំត្រយ៉ូង គឺជាកន្លែងឃុំឃាំងមនុស្ស និងកន្លែងសម្លាប់មនុស្សដ៏ធំមួយ ហើយកន្លែងនេះគឺគ្រប់គ្រងផ្ទាល់ដោយ យាយ ថែម។"]។ ឯកសារ D219/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.112-114 KH 01029680 [សាក្សីជាសមាជិកគណៈស្រុកព្រះនេត្រព្រះ៖ "កន្លែងវាយថ្មនោះ ស្ថិតនៅភ្នំត្រយោង... ខ្ញុំមិនស្គាល់ [នរណាជាអ្នកគ្រប់គ្រងកន្លែងវាយថ្មនៅភ្នំត្រយោង] ទេ ប៉ុន្តែ ខ្ញុំគ្រាន់តែដឹងថា គឺជាកម្លាំងរបស់យាយ ថែម ទាំងអស់។"]។ ឯកសារ D43 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យក់ នៀម ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ KH 00722205 [សាក្សីធ្វើការនៅកងចល័ត៖ "ខ្ញុំគ្រាន់តែដឹងថា ក្នុងនាមជាគណៈស្រុក គាត់បានមកត្រួតពិនិត្យនៅតំបន់នេះ ហើយគណៈតំបន់នេះគ្រប់គ្រងមន្ទីរសន្តិសុខនៅក្នុងតំបន់របស់ខ្លួន ចំណែកឯរបៀបគ្រប់គ្រងលំអិតយ៉ាងណានោះ ខ្ញុំមិនបានដឹងទេ។ ស៖ តើមន្ទីរសន្តិសុខដែលគាត់មកគ្រប់គ្រងនោះឈ្មោះអ្វី? គឺមន្ទីរសន្តិសុខភ្នំត្រយោង។"]។ ឯកសារ D219/256 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី តាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.25 KH 01085166 [សាក្សីធ្វើជាអ្នកបររទេះគោនៅភ្នំលៀប៖ "ខ្ញុំដឹងថាយាយថែមជាអ្នកគ្រប់គ្រងគុកភ្នំត្រយ៉ូងដោយផ្ទាល់ ព្រោះអ្នកបររទេះមួយចំនួនដែលដឹកស្បៀងពីស្រុកទៅគុកភ្នំត្រយ៉ូងជាអ្នកប្រាប់ខ្ញុំអំពីរឿងនេះ។"]។ ឯកសារ D5/1246 [redacted] រដ [redacted] ២០១៣ KH 01036169 [សាក្សីត្រូវបានបញ្ជូនទៅការដ្ឋានភ្នំទ្រយោង៖ "ពេលនោះមិត្ត ថែម បញ្ជារឲ្យពួកខ្ញុំជីករណ្តៅរបៀបដូចលេនដ្ឋានកងទ័ព ជីករួច វាបញ្ជារឲ្យពួកខ្ញុំ កាប់ឫស្សីធ្វើចំរូមស្រួចៗ ដាក់ក្នុងលេនដ្ឋាន នៅពេលនោះ មេកងប្រាប់ខ្ញុំថា លេនដ្ឋានទាំងនេះ ទុកការពារកុំឲ្យកងចល័តណារត់គេចពេលយប់"]។ ផ្ទុយនឹង ឯកសារ D61 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ KH 00727222-00727223 [សាក្សីជាអនុកងចល័តតំបន់ ៥៖ "ខ្ញុំ មិនដឹងពីមន្ទីរសន្តិសុខនេះច្បាស់ទេ [...] សឿន រាយការណ៍ទៅគណៈតំបន់ គឺឈ្មោះ តារីន ដេលមកពីនិរតីដែរ។"]។

976 ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.171 KH 00953042 [សាក្សីគឺជាប្រធានគុក៖ "បទបញ្ជា ឬគោលនយោបាយ គឺយាយាថែមជាអ្នកបង្កើតឡើង"]។

977 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.222 KH 00953050 [សាក្សីគឺជាប្រធានគុក៖ "សហករណ៍ពិភាក្សាផ្ទាល់ជាមួយយាយថែមថាតើត្រូវចាប់ឬមិនចាប់។ យាយថែមជាអ្នកសម្រេចថា បើមិនអាចអប់រំនៅក្នុងសហករណ៍បាន ត្រូវបញ្ជូនទៅមន្ទីរអប់រំ។"]។ ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951764 [សាក្សីគឺជាប្រធានគុក៖ "យាយ ថែម គាត់រៀបចំ [...] ដូចថា មាននេះអី គាត់យកទៅអប់រំកន្លែងនឹង"]។ ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.42 KH 01114731 [សាក្សីជានីរសាររបស់ អ៊ឹម ថែម៖ "តើលោកគិតថា យាយ ថែម ជាអ្នកទទួលខុសត្រូវរឿងការស្លាប់របស់មនុស្ស នៅស្រុកព្រះនេត្រព្រះដែរ ឬទេ? បាទ គឺខ្ញុំគិតថា គាត់ជាអ្នកទទួលខុសត្រូវ [...] មិនមែនគ្រប់ករណីសុទ្ធតែគាត់ជាអ្នកចាប់ចងនោះទេ ប៉ុន្តែខ្ញុំ អាចប្រាប់ថា ប្រធានសហករណ៍ទាំងអស់ មកពិភាក្សាជាមួយគាត់អំពីការចាប់ចងទាំងនោះ បានន័យថា រាល់ចង្កោមអ្នកទោសទាំងអស់ គឺត្រូវឆ្លងកាត់

យាយ ចែម ជាមុន។"]។ ឯកសារ D106/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.7-16 KH 00801014-00801015 [សាក្សីគឺជាអ្នកទោសដែលបានលើកឡើងអំពីការចាប់ខ្លួនលោក៖ "សំបុត្រនេះគឺជាការចេញបញ្ជាឲ្យទៅមេគុក ធ្វើការចាប់មនុស្ស។ […] បញ្ជានោះចេញពីយាយ ចែម"]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.12 KH 00895169 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំបានទទួលសំបុត្រមួយពីយាយ ចែម ដែលជាសំបុត្រសរសេរដោយដៃ […] ក្នុងសំបុត្រនេះ គេសរសេរថា ស្នើសមមិត្ត ទី និងសមមិត្ត សាមុន ឡើងមករៀនសូត្រ នៅមន្ទីរឃុំភ្នំលៀប។"]។ ឯកសារ D101/1.2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 00743551 [សាក្សីគឺជាអ្នកទោស៖ "អាត្មាជួបតែម្តងគត់ពេលដែលគេចាប់អាត្មាទៅភ្នំលាប។ ពេលនោះគឺអាត្មាជិះឡានទៅជាមួយអ្នកដែលចាប់អាត្មាទៅ ហើយគេបានឲ្យអាត្មាអង្គុយនៅគុមួយនៅភ្នំលាប ហើយគេឲ្យចុងភៅលើកបាយមកឲ្យអាត្មា។ ពេលនោះ អាត្មាបានឃើញអ្នកដែលចាប់អាត្មាមកបានចុះទៅនិយាយជាមួយនារីម្នាក់។ […] នោះហើយគឺជាយាយ ចែម។"]។ ឯកសារ D5/1075 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022735 [សាក្សីគឺជាអ្នកទោស៖ "១៩៧៨ ពេលមកដល់ភ្នំត្រយោងភ្លាម ពេលនោះមិត្ត ចែម ប្រធានយោធា បញ្ជូនឲ្យចុងភៅដាំបាយ ស្ងោរមាន់ឲ្យហូបទៀត រួចមកបញ្ជូនឲ្យឈ្លប ៣ រឺ ៤ នាក់ នាំខ្ញុំយកទៅដាក់មន្ទីរសន្តិសុខភ្នំទ្រយោង"]។ ឯកសារ D219/174 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.25-26 KH 01065987 [សាក្សីធ្វើការនៅក្នុងចល័តភូមិក្នុងស្រុកព្រះនេត្រព្រះ រួចហើយត្រូវគេដាក់គុកនៅចំការខ្នុរ៖ "ពួកខ្មែរក្រហមបានធ្វើរបាយការណ៍វាយការណ៍ទៅគណៈស្រុក ដោយចោទថាខ្ញុំទាក់ទងជាមួយនឹងខ្មាំង […] សៈ តើហេតុអ្វីបានជាលោកស្រីដឹងថា គេរាយការណ៍រឿងនេះ ទៅថ្នាក់ស្រុក? ឆ.26៖ ខ្ញុំដឹងរឿងនេះក្រោយពេលដែលគេចាប់ខ្លួនខ្ញុំ ហើយក្រោយមកគេសួរសម្លើយ។]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.32 KH 00978922-00978923 [សាក្សីធ្វើការនៅក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "ការស្រាវជ្រាវប្រវត្តិរូបត្រូវបានធ្វើឡើងនៅតាមភូមិ និងសហករណ៍ បន្ទាប់មកត្រូវបានបញ្ជូនទៅថ្នាក់លើ គឺទៅយាយ ចែម ហើយទើបមានបញ្ជាពីយាយ ចែម មកវិញ ចំពោះអ្នកដែលមានប្រវត្តិរូបពាក់ព័ន្ធ"]។ ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.31 KH 01024747 [សាក្សីត្រូវបានចាប់ខ្លួននៅភ្នំជញ្ជាំង ស្រុកព្រះនេត្រព្រះ ដើម្បីបញ្ជូនទៅភ្នំត្រយោង៖ "យាយចែម ជាអ្នកមានសិទ្ធិសម្រេចចាប់មនុស្សទៅដាក់គុកនៅភ្នំត្រយោង"]។ ឯកសារ D106/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.23 KH 00800990 [សាក្សីគឺជាអ្នកភូមិនៅព្រះនេត្រព្រះ៖ "បាទ គាត់គឺជាអ្នកចេញបញ្ជាឲ្យចាប់អ្នកដែលធ្វើខុស"]។

978 ឯកសារ D219/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.45 KH 01043199 [សាក្សីគឺជាប្រធានគុក៖ "យាយចែម គឺជាអ្នកសម្រេចថាឲ្យដោះខ្នោះ ឬមិនដោះខ្នោះ គឺស្ថិតលើការសម្រេចចិត្តរបស់យាយចែម។ […] យាយចែម បាននិយាយប្រាប់ខ្ញុំថា បើសិនជាមាននរណាម្នាក់អប់រំកសាងបានល្អ ដូច្នេះខ្ញុំមានសិទ្ធិដោះលែងពួកគេឲ្យពួកគេរស់នៅដូចប្រជាជនធម្មតា នៅកន្លែងដែលខ្ញុំគ្រប់គ្រង នៅភ្នំត្រយោង។"]។ ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045316 [OCIJ-068 (ទុំ សឿន - ប្រធានមន្ទីរសន្តិសុខភ្នំត្រយោង)៖ "គឺ មានការណែនាំពីខាងលើ គឺថ្នាក់ស្រុកដែលមានយាយ ចែម។ យាយ

ចែម បានប្រាប់ថា ធ្វើម៉េចត្រូវមើលសភាពការណ៍និងស្ថានការណ៍របស់ម្នាក់ៗដើម្បីសម្រេចវិធានការណ៍ណាមួយ។”]។ ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951769 [សាក្សីគឺជាប្រធានគុក៖ “ដារ៉ា៖ ចឹងអ្នកណាដាក់កិច្ចការ [ឱ្យអ្នកទៅភ្នំទ្រយោង] ជាការងារឲ្យធ្វើចេញពីណាមកវិញ? សឿន៖ យាយ ចែម គណៈស្រុកនៅនឹង ចេញពីគណៈស្រុកមកនឹង ចេញពីគណៈស្រុក”]។ ឯកសារ D119/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស្វ៊ីយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឆ.15 KH 00894518 [សាក្សីជាអ្នកត្រូវគេចាប់ខ្លួន៖ “នៅភ្នំត្រឡោក ដោយខ្ញុំមិនមានលិខិតធ្វើដំណើរ គេបាននាំខ្ញុំមកមន្ទីរឃុំភ្នំលៀប។ ពេលនោះ អ្នកដែលមកជាមួយខ្ញុំដឹងថា គេចាប់ខ្ញុំមកដាក់មន្ទីរឃុំ ពួកគេបានវិលត្រលប់ទៅកងចល័តវិញ ហើយប្រាប់ប្រធានវីរៈថា ខ្ញុំត្រូវបានគេចាប់ដាក់មន្ទីរឃុំ ព្រោះមិនមានលិខិតធ្វើដំណើរ។ ពេលនោះ ប្រធានវីរៈបានទាក់ទងទៅយាយ ចែម ហើយនៅព្រឹកថ្ងៃបន្ទាប់ គេបានដោះលែងខ្ញុំឲ្យទៅលេងឪពុកម្តាយខ្ញុំវិញ។”]។

979 ឯកសារ D230 កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045318 [OCIJ-068 (ទុំ សឿន - ប្រធានគុក)៖ “ខ្ញុំចាំថាមានអ្នកទោសធ្ងន់៤នាក់ ត្រូវបានគេវាយធ្វើបាបមុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំត្រយោង។ [...] ពួកគេ [...] ធ្វើទុក្ខខ្លាំង មិនអាចព្យាបាលបាន។ យាយ ចែម បានបញ្ជាឲ្យខ្ញុំសម្លាប់អ្នកទាំង៤នោះទៅ។ ខ្ញុំ បានបញ្ជាបន្តឱ្យអ្នកការពារសម្លាប់ពួកគេទៅ។”]។ ឯកសារ D123/1/2.53 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ូ ម៉ៅ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00730233 [សាក្សីធ្វើការនៅកងចល័តតំបន់៥ ដែលរាយការណ៍ឲ្យ អ៊ឹម ចែម “ដល់ពេលនិយាយគាត់និយាយងាយស្រួលដែរ គាត់ថា អើ! បើវាពិបាក វាប្រឆាំងក្បត់ហើយវៃចោលទៅ។ វណ្ណៈ៖ គាត់ថាអញ្ចឹងដែរ? ម៉ៅ៖ បាទ! គាត់ថាវៃចោលទៅ។”]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.47 KH 00976182 [សាក្សីជាអ្នកធ្វើការនៅកងចល័តតំបន់៥ ដែលរាយការណ៍ទៅឲ្យ អ៊ឹម ចែម “ស៖ នៅលើទំព័រទី១៧ដដែល [ក្នុងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា] លោកបាននិយាយថា “គាត់ថា អើ! បើវាពិបាក វាប្រឆាំងក្បត់ ហើយវៃចោលទៅ”។ តើលោកអាចបញ្ជាក់បានទេថា នរណាជាអ្នកនិយាយពាក្យនេះ? ខ្ញុំបានឮ យាយ ចែម និយាយពាក្យនេះ នៅពេលដែលគេចាប់ពេទ្យ មឿន មកផ្ទះរបស់គាត់ [អ៊ឹម ចែម]។”]។ ឯកសារ D5/1252 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អឿ លឿ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036277 [សាក្សីគឺជាអ្នកទោស៖ “ពេលនោះមេកងមិត្ត ចែម ជាអ្នកបញ្ជា”]។

980 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.222 KH 00953050 [សាក្សីគឺជាប្រធានគុក៖ “សហករណ៍ពិភាក្សាផ្ទាល់ជាមួយយាយចែមថាតើត្រូវចាប់ឬមិនចាប់។ យាយចែមជាអ្នកសម្រេចថា បើមិនអាចអប់រំនៅក្នុងសហករណ៍បាន ត្រូវបញ្ជូនទៅមន្ទីរអប់រំ។”]។ ឯកសារ D119/64.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951764 [សាក្សីគឺជាប្រធានគុក៖ “យាយ ចែម [...] ដូចថា មាននេះអី គាត់យកទៅអប់រំកន្លែងនឹង”]។ ឯកសារ D219/397 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.42 KH 01114731 [សាក្សីជានីរសាររបស់ អ៊ឹម ចែម៖ “តើលោកគិតថា យាយ ចែម ជាអ្នកទទួលខុសត្រូវរឿងការស្លាប់របស់មនុស្ស នៅស្រុកព្រះនេត្រព្រះដែរ ឬទេ? បាទ គឺខ្ញុំគិតថា គាត់ជាអ្នកទទួលខុសត្រូវ [...] មិនមែនគ្រប់ករណីសុទ្ធតែគាត់ជាអ្នកចាប់ចងនោះទេ ប៉ុន្តែខ្ញុំ អាចប្រាប់ថា ប្រធានសហករណ៍ទាំងអស់

មកពិភាក្សាជាមួយគាត់អំពីការចាប់ចងទាំងនោះ បានន័យថា រាល់ចង្កោមអ្នកទោសទាំងអស់ គឺត្រូវឆ្លងកាត់ យាយ ចែម ជាមុន។"]។ ឯកសារ D106/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.7-16KH 00801014-00801015 [សាក្សីគឺជាអ្នកទោសដែលបានលើកឡើងអំពីការចាប់ខ្លួនលោក៖ "សំបុត្រនេះគឺជាការចេញបញ្ជាឱ្យទៅមេគុក ធ្វើការចាប់មនុស្ស។ [...] បញ្ជានោះចេញពីយាយ ចែម"]។ ឯកសារ D119/30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.12 KH 00895169 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំបានទទួលសំបុត្រមួយពីយាយ ចែម ដែលជាសំបុត្រសរសេរដោយដៃ [...] ក្នុងសំបុត្រនេះ គេសរសេរថា ស្នើសមមិត្ត ទី និងសមមិត្ត សាមុន ឡើងមករៀនសូត្រ នៅមន្ទីរឃុំភ្នំលៀប។"]។ ឯកសារ D101/1.2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 00743551 [សាក្សីគឺជាអ្នកទោស៖ "អាត្មាជួបតែម្តងគត់ពេលដែលគេចាប់អាត្មាទៅភ្នំលាប។ ពេលនោះគឺអាត្មាជិះឡានទៅជាមួយអ្នកដែលចាប់អាត្មាទៅ ហើយគេបានឱ្យអាត្មាអង្គុយនៅតុមួយនៅភ្នំលាប ហើយគេឱ្យចុងភៅលើកបាយមកឱ្យអាត្មា។ ពេលនោះ អាត្មាបានឃើញអ្នកដែលចាប់អាត្មាមកបានចុះទៅនិយាយជាមួយនារីម្នាក់។ [...] នោះហើយគឺជាយាយ ចែម។"]។ ឯកសារ D5/1075 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022735 [សាក្សីគឺជាអ្នកទោស៖ "១៩៧៨ ពេលមកដល់ភ្នំត្រយោងភ្លាម ពេលនោះមិត្ត ចែម ប្រធានយោធា បញ្ជូនឱ្យចុងភៅដាំបាយ ស្ងោរមាន់ឱ្យហូបទៀត រួចមកបញ្ជូនឱ្យឈ្លប ៣ រឺ ៤ នាក់ នាំខ្ញុំយកទៅដាក់មន្ទីរសន្តិសុខភ្នំទ្រយោង"]។ ឯកសារ D219/174 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.25-26 KH 01065987 [សាក្សីធ្វើការនៅក្នុងចល័តភូមិក្នុងស្រុកព្រះនេត្រព្រះ រួចហើយត្រូវគេដាក់គុកនៅចំការខ្នុរ៖ "ពួកខ្មែរក្រហមបានធ្វើរបាយការណ៍រាយការណ៍ទៅគណៈស្រុក ដោយចោទថាខ្ញុំទាក់ទងជាមួយនឹងខ្មាំង [...] សៈ តើហេតុអ្វីបានជាលោកស្រីដឹងថា គេរាយការណ៍រឿងនេះ ទៅថ្នាក់ស្រុក? ឆ.26៖ ខ្ញុំដឹងរឿងនេះ ក្រោយពេលដែលគេចាប់ខ្លួនខ្ញុំ ហើយក្រោយមកគេសួរសម្លើយ។]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.32 KH 00978922-00978923 [សាក្សីធ្វើការនៅក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "ការស្រាវជ្រាវប្រវត្តិរូបត្រូវបានធ្វើឡើងនៅតាមភូមិ និងសហករណ៍ បន្ទាប់មកត្រូវបានបញ្ជូនទៅថ្នាក់លើ គឺទៅយាយ ចែម ហើយទើបមានបញ្ជាពីយាយ ចែម មកវិញ ចំពោះអ្នកដែលមានប្រវត្តិរូបពាក់ព័ន្ធ"]។ ឯកសារ D119/154 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ាវ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.31 KH 01024747 [សាក្សីត្រូវបានចាប់ខ្លួននៅភ្នំជញ្ជាំង ស្រុកព្រះនេត្រព្រះ ដើម្បីបញ្ជូនទៅភ្នំត្រយោង៖ "យាយចែម ជាអ្នកមានសិទ្ធិសម្រេចចាប់មនុស្សទៅដាក់គុកនៅភ្នំត្រយោង"]។ ឯកសារ D106/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.23 KH 00800990 [សាក្សីគឺជាអ្នកភូមិនៅព្រះនេត្រព្រះ៖ "បាទ គាត់គឺជាអ្នកចេញបញ្ជាឱ្យចាប់អ្នកដែលធ្វើខុស"]។

1032 ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.85 KH 00989349 [សាក្សីគឺជាអ្នកទោស៖ "តាមពិត ខ្ញុំមិនបានធ្វើអ្វីខុសទេនៅពេលនោះ តែដោយសារនៅពេលនោះ គេចោទខ្ញុំថា មើលងាយអង្គការ ហើយខ្ជិលធ្វើការងារ ដូច្នេះហើយបានជាគេចាប់ខ្លួនខ្ញុំ"]។ ឆ.113 KH 01104652 ["នៅពេលយប់ គេដាក់ខ្នោះខ្ញុំនៅរោងដដែល"]។

1033 ឯកសារ **D119/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង រ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.28 KH 01025129 [សាក្សីគឺជាអ្នកទោស៖ "នៅពេលនោះ ខ្ញុំបានលួចបូតស្រូវ ក្រោយមក គេចាប់ខ្ញុំបញ្ជូនទៅដាក់នៅមន្ទីរសន្តិសុខភ្នំធំ។ គេឃុំខ្លួនខ្ញុំនៅទីនោះ បានមួយអាទិត្យ ហើយក្រោយមក គេបានបញ្ជូនខ្ញុំទៅនៅភ្នំត្រយោង"]។ ឆ.35-38 KH 01025130 [សាក្សីគឺជាអ្នកទោស៖ "នៅពេលនោះ ខ្ញុំនៅជាប់ខ្នោះដៃ និងខ្នោះជើងនៅឡើយ។ [...] ខ្ញុំត្រូវបានគេចោទថាក្បត់សមូហភាព"]។

1034 ឯកសារ **D219/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.45 KH 01043199 [សាក្សីគឺជាប្រធានគុក៖ "យាយ ចែម គឺជាអ្នកសម្រេចថាឱ្យដោះខ្នោះ ឬមិនដោះខ្នោះ គឺស្ថិតលើការសម្រេចចិត្តរបស់ យាយ ចែម"]។ ឆ.45 KH 01043199 ["យាយ ចែម បាននិយាយប្រាប់ខ្ញុំថា បើសិនជាមាននរណាម្នាក់អប់រំកសាងបានល្អ ដូច្នេះខ្ញុំមានសិទ្ធិដោះលែងពួកគេឱ្យពួកគេរស់នៅដូចជាប្រជាជនធម្មតា នៅក្នុងកន្លែងដែលខ្ញុំគ្រប់គ្រង នៅភ្នំត្រយោង"]។ ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045317 [OCIJ-068 (ទុំ សឿន គឺជាប្រធានគុក)៖ "អ្នកទោសធ្ងន់ អាចត្រូវបានចាត់ថ្នាក់ទៅជាអ្នកទោសស្រាល ទៅតាមពេលវេលា។ អ្នកខ្លះត្រូវបាននាំមកដោយចងចំណង បានន័យថាជាអ្នកទោសធ្ងន់ ប៉ុន្តែក្រោយការពិនិត្យតាមដានបាន ៥ឬ៦ថ្ងៃ ខ្ញុំអាចចាត់ថ្នាក់ពួកគាត់ទៅជាអ្នកទោសស្រាលវិញ បើពួកគេមិនបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរនោះទេ"] KH

01045317 [“ប៉ុន្តែ ២ឬ៣ថ្ងៃមុនការចូលមកដល់របស់វៀតណាម មិនមានអ្នកទោសធ្ងន់ទៀតទេ។ នាពេលនោះ អ្នកទោសធ្ងន់ទាំងអស់ ត្រូវបានប្តូរទៅជាអ្នកទោសស្រាល ហើយបញ្ជូនទៅភូមិស្រុករបស់ពួកគេវិញ”]។ ឯកសារ **D59/1/1.67** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ុម សល់ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927468 [សាក្សីគឺជាអ្នកយាមគុក៖ “ដារ៉ា៖ [បន្ទាប់ពីការសួរចម្លើយ] ដោះក៏នៅក្នុងហ្នុងដដែលទេ? សល់៖ ដោះលែងទៅក៏នៅក្នុងនោះ ធ្វើការងារនោះ”]។ សូមមើលផងដែរ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.24-25 KH 01058729 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំជាប់ខ្នោះជើងចំនួនពីរខែ មុននឹងគេបញ្ចេញទៅឲ្យដេកនៅក្នុងរោងវែងមួយទៀត ជាមួយអ្នកទោសផ្សេងៗទៀត។ គេបញ្ចេញពួកខ្ញុំឲ្យទៅភ្ជួររាស់ព្រៃនៅពេលថ្ងៃ ហើយពេលយប់គេពុំដាក់ខ្នោះទៀតទេ តែពុំមានសិទ្ធិដើរទៅណាអ្វីទាំងអស់។ ចំពោះរោងចាស់ដែលគេធ្លាប់ដាក់ខ្នោះខ្ញុំ គឺគេសម្រាប់ដាក់អ្នកទោសដែលទើបនឹងមកដល់ថ្មីៗ”]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.25 KH 00895171 [សាក្សីគឺជាអ្នកទោស៖ “ពេលនោះ គេលែងដាក់ខ្នោះខ្ញុំទៀតហើយ ហើយខ្ញុំបានទៅរស់នៅក្នុងរោងជាមួយអ្នកទោសស្រាល”]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.27 KH 00894495 [សាក្សីគឺជាអ្នកទោស៖ “ក្រោយមក ខ្ញុំមិនដឹងមូលហេតុអ្វីទេ យោធាបានមកប្រាប់ខ្ញុំថា តា សឿន ដែលជាមេគុក បានបញ្ជាឲ្យដោះលែងខ្ញុំ និង ទី ប៉ុន្តែគេឲ្យធ្វើការជាជាងឈើនៅក្នុងគុកនោះ ដើម្បីធ្វើរោងបន្ថែមសម្រាប់អ្នកទោស។ របបហូបចុកពេលនោះ មានភាពប្រសើរជាងមុន”]។ ឯកសារ **D219/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.46 KH 01043182 [សាក្សីគឺជាអ្នកទោស៖ “ស៖ ទាក់ទងទៅនឹងការសុំលុបចោលនេះដែរ នៅចំណុចមួយ គឺលោកឆ្លើយថា គេបានឲ្យលោក និង ទី ទៅធ្វើជាជាងឈើ ចាប់ពីពេលនោះមក ស្ថានភាពរបស់លោកប្រសើរជាងមុន។ តើលោកនៅរក្សាចម្លើយនេះទេ? ឆ.46៖ បាទ ខ្ញុំនៅរក្សាចម្លើយនេះ”]។

1035 ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.181 KH 00953044 [សាក្សីគឺជាប្រធានគុក៖ “ខ្ញុំមិនដែលទទួលអង្ករដោយផ្ទាល់ពីតំបន់៥មកទេ ពេលខ្ញុំត្រូវការអង្ករ ខ្ញុំទៅដឹកមកពីឃ្លាំងក្បែរផ្ទះយាយថែម។ គេថា គេផ្គត់ផ្គង់អង្ករតែមួយឆ្នាំទេ ក្រោយមួយឆ្នាំនេះទៅ ត្រូវដោះស្រាយអង្ករដោយខ្លួនឯង។ ព្រោះកម្លាំងដែលទើបតែមកដល់នោះ មិនទាន់ធ្វើស្រែនៅឡើយទេ។ ដល់ពេលកម្លាំងនោះធ្វើស្រែបានផល អាហ្នឹងត្រូវដោះស្រាយខ្លួនឯង”]។ ឯកសារ **D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ. 33 KH 01114730 [សាក្សីគឺជានីរសាររបស់ អ៊ឹម ចែម៖ “ភ្នំត្រយ៉ូង គឺមានអ្នកផ្សេងជាអ្នកដឹក ខ្ញុំគ្រាន់តែដឹកបន្លែដាក់តាមប្រឡាយទេ ព្រោះខ្ញុំជាប្រជាជនសាមញ្ញ គេខ្លាចខ្ញុំអាចដឹងរឿងក្នុងហ្នឹង”]។ ឯកសារ **D119/33** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឆ.22 KH 00907528 [សាក្សីគឺជាប្រធានកិច្ចការសេដ្ឋកិច្ចកងចល័តតំបន់៥៖ “ចំពោះរបបហូបចុកវិញ មុនដំបូងឲ្យអង្កររមួយកំប៉ុងកន្លះសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ក្រោយមកមួយកំប៉ុងក្នុងមួយថ្ងៃ ហើយជួនកាល ក៏ដាច់អាហារខ្លះដែរ។ ខ្ញុំទទួលបញ្ជាពី តា យ៉ាន់ ក្នុងការបើកអង្ករឲ្យទៅមន្ទីរសន្តិសុខភ្នំត្រយោង។ តាមចំនួនអង្ករដែលខ្ញុំត្រូវបើកឲ្យទៅភ្នំត្រយោងដែលត្រូវបើក ជួនកាល១០ថ្ងៃម្តង ឬមួយអាទិត្យម្តង ចំនួនមនុស្សនៅទីនោះ មិនលើសពី៦០០នាក់ទេ។ ការបើកអង្ករនេះចាប់ផ្តើមឡើងប្រហែលជានៅដើមឆ្នាំ ឬពាក់កណ្តាលឆ្នាំ១៩៧៨ រហូតដល់

បែកខ្មែរក្រហម"]។ ឆ.14 KH 00907526 ["ក្រោយពីចាប់ខ្លួន តា វ៉ាល់ តា រិន គណៈតំបន់ បានចាត់តាំងខ្ញុំឱ្យទៅគ្រប់គ្រងសេដ្ឋកិច្ចចល័តតំបន់៥។ នៅពេលនោះ យ៉ាន់ (អ្នកនិរតី) បានឡើងជំនួស តា វ៉ាល់ ហើយជាប្រធានរបស់ខ្ញុំ"]។ ឯកសារ **D219/494.1.7** ឈិត យឿក ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ពីម៉ោង 16.00.10 ដល់ម៉ោង 16.03.56 KH 01130938-01130939 [សាក្សីគឺជាប្រធានកិច្ចការសេដ្ឋកិច្ចកងចល័តតំបន់៥៖ "បាទ មន្ទីរសន្តិសុខនោះ បើអង្គាល់ដែលខ្ញុំនៅចែកនោះ ចែកទៅអ្នកដែលវាយថ្មនៅភ្នំទ្រយោង នៅភ្នំលៀបយើងនេះបាទ ចែកទៅដែរ [...] កន្លែងនោះវាមានកន្លែងសន្តិសុខគេមួយ ហើយវាលាយឡំជាមួយនឹងយុវចល័តដែលនៅវាយថ្មនោះផងបាទ [...] ចាប់ពីដែលខ្ញុំបើកឱ្យរបហូតទល់នឹងវៀតណាមចូល តែមនុស្សដែលតាមទូទាត់ក្នុងអង្ករនោះ ក៏មិនលើសពី ៦០០"]។

1036 ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.218 KH 00953049 [សាក្សីគឺជាប្រធានគុក៖ "ពេលខ្ញុំនៅកន្លែងនោះ របបអាហារមិនគ្រប់គ្រាន់ទេ គឺគេទទួលបានបបរ ពីរពេលក្នុងមួយថ្ងៃ គឺថ្ងៃត្រង់ និងល្ងាច"]។ ឯកសារ **D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.26 KH 01058767 [សាក្សីគឺជាអ្នកទោស និងអ្នកដាំស្ល៖ "គ្នាខ្ញុំប្អូនប្រាំនាក់ ដាំបាយឱ្យពួកអ្នកយាមផង និងអ្នកទោសផង។ មួយថ្ងៃៗពួកយើងរវល់រហូត ដាំបាយផង ធ្វើម្ហូបផង ចិតបន្លែផង។ ពេលពួកខ្ញុំដាំបាយឱ្យអ្នកយាមគុកហូប ពួកខ្ញុំដាំបបរខាប់ឱ្យអ្នកទោសហូប តែនៅពេលពួកខ្ញុំដាំបបរខាប់ឱ្យអ្នកយាមគុកហូប គឺពួកខ្ញុំត្រូវដាំបបររាវឱ្យអ្នកទោសហូប។ ខ្ញុំសូមបញ្ជាក់ថា ពេលគេរើសពួកខ្ញុំឱ្យទៅដាំបាយនៅទីនោះ គឺដល់ពេលដែលគេផ្តល់បបរខាប់ឱ្យអ្នកទោសហើយ"]។ ឆ .21 KH 01058766 ["គេឱ្យហូបតែបបររាវ និងតិចតួចបំផុត ព្រោះបបរមួយខ្ទះ មានតែអង្ករមួយ ឬពីរកំប៉ុងតែប៉ុណ្ណោះ"]។ ឆ.29 KH 01058768 ["ទោះបីជាពួកខ្ញុំទៅបើកអង្ករ និងសម្ភារៈមកធ្វើម្ហូបជារៀងរាល់ថ្ងៃពី តា សឿន ក៏ដោយ ក៏ពួកអ្នកទោសទាំងនោះ មិនបានហូបគ្រប់គ្រាន់ដែរ"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.79 KH 01115780 [សាក្សីគឺជាអ្នកទោស៖ "គេឱ្យបបរ និងអំបិលពីរបីគ្រាប់មួយថ្ងៃពីរដង ថ្ងៃត្រង់ និងល្ងាច។ មួយពេល មួយកូនចានចង្កឹះ"]។ ឯកសារ **D5/1179** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៊ូ ទូក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ KH 01030733 [សាក្សីគឺជាអ្នកទោស៖ "ហូបតែបបរទឹករាវខ្លុកតែម្តង"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.29 KH 01058730 [សាក្សីគឺជាអ្នកទោស៖ "អ្នកទោសគេឱ្យបបររាវៗ មួយវែក ជាមួយនឹងទឹកមួយផ្តិល មួយថ្ងៃពីរដង"] ។ ឯកសារ **D123/1/2.66** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ធិប សំផាត់ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927405 [សាក្សីគឺជាអ្នកទោស ៖ "ហូបបបររាវទៀត"]។ ឯកសារ **D123/1/2.65** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ណាន់ និង រិន ខេង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927369 [សាក្សីគឺជាអ្នកទោស៖ "គេឱ្យតែបបរ"]។ ឯកសារ **D1.3.11.43** កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ រិន ខេង ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ EN 00210493 [សាក្សីគឺជាអ្នកទោស៖ "ម៉ោងធ្វើការគឺពីម៉ោង៧ ដល់ម៉ោង១១ បន្ទាប់មកយើងទទួលបានបបរ (បបររាវៗមួយវែកសម្រាប់អាហារថ្ងៃត្រង់) បន្ទាប់មកពីម៉ោង ១៣ ដល់ម៉ោង ១៦ រសៀល រួចហើយគេឱ្យបបរមួយវែកទៀត។ នៅពេលខ្ញុំមកដល់ បបរនោះរាវយ៉ាងខ្លាំង ហើយពីរសប្តាហ៍ក្រោយមក បបររៀងខាប់ជាងមុន (មានគ្រាប់អង្ករច្រើនជាងមុន) ប៉ុន្តែគេចែកឱ្យក្នុងបរិមាណដដែល។ នៅពេលយប់ គ្មានធ្វើ

អ្វីទេ គឺដេក"]។ ឯកសារ **D219/230** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.23 KH 01076376 [សាក្សីគឺជាអ្នកទោស៖ "យើងត្រូវបានគេផ្តល់អាហារឲ្យយើងមួយថ្ងៃ២ដង គឺគេឲ្យបបរមួយវែកសម្រាប់អាហារពេលថ្ងៃត្រង់ និង១វែកទៀតសម្រាប់អាហារពេលល្ងាចជាមួយអំបិលម្នាក់១គ្រាប់ ឬ២គ្រាប់តែប៉ុណ្ណោះ"]។ ឯកសារ **D119/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.43 KH 00989343 [សាក្សីគឺជាអ្នកទោស៖ "គេឲ្យហូប១ថ្ងៃបីពេល។ គេបានបើកអង្ករឲ្យយើង១កំប៉ុងសម្រាប់១គ្រួសារ។ ពេលនោះ យើងហូបមិនគ្រប់គ្រាន់ទេ គឺយើងត្រូវដើររកបេះត្រកួន ទំពាំង ហើយនិងដើមចេកមកលាយជាមួយនឹងបាយសម្រាប់ធ្វើជាអាហារ"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោស៖ "គេឲ្យបបរមួយវែក១ម្នាក់"]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.122 KH 01165953 [សាក្សីគឺជាអ្នកទោស៖ "គេឲ្យបបរពោតក្រហមមួយកូនចានតូច។ (កំណត់សម្គាល់៖ សាក្សីបង្ហាញទំហំកូនចាននោះប្រហែលចានចង្កឹះតូចមួយ)"]។ ឯកសារ **D5/998** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ភួង ផៃ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ KH 00989610 [សាក្សីគឺជាអ្នកទោស៖ "គុកភ្នំត្រយោង ខ្ញុំបានឃើញរស់នៅជាក់ស្តែង លំបាកវេទនាជាខ្លាំង ហូបបបរមួយវែកក្នុងមួយគ្រួសារ"]។ ឯកសារ **D5/1616** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈិន សង់ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៣ KH 01092573 [សាក្សីគឺជាអ្នកទោស៖ "ហូបតែបបររាវ១"]។ ឯកសារ **D59/1/1.67** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ុម សល់ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927468 [សាក្សីគឺជាអ្នកយាមគុក៖ "គេឲ្យតែបបរតិច១ដូចតែយើងនៅតាមភូមិយើងអីចឹងឯង នៅកន្លែងនេះ ក៏ដូចតែនៅកន្លែងនោះ វាអត់ខុសគ្នាទេ"]។

1037 ឯកសារ **D219/211** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អឿន ចាន់រី ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.18 KH 01074054 [សាក្សីគឺជាប្អូនស្រីរបស់អ្នកទោស៖ "ការហូបចុកនៅទីនោះមិនគ្រប់គ្រាន់ បងប្រុសរបស់ខ្ញុំមានការអត់ឃ្លានយ៉ាងខ្លាំង"]។ ឯកសារ **D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ. 21 KH 01058765-01058766 [សាក្សីគឺជាអ្នកទោស និងអ្នកដាំស្ល៖ "ក្រោយមកទៀត មានអ្នកទោសរាប់ពាន់នាក់ ត្រូវបានគេយកទៅដាក់នៅទីនោះ។ អ្នកទោសនៅភ្នំទ្រយោងរាប់ពាន់នាក់ បានស្លាប់ដោយដាច់ពោះ និងត្រូវបានគេយកទៅសម្លាប់។ អ្នកដែលមានសុខភាពល្អ ក្រោយពីយកទៅដាក់នៅទីនោះបានប្រហែល១០ថ្ងៃ គឺច្បាស់ជាធ្លាក់ខ្លួនឈឺ និងដាច់ពោះស្លាប់ហើយ ព្រោះតែគេឲ្យហូបតែបបររាវ និងតិចតួចបំផុត"]។ ឯកសារ **D219/318** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជន គំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ឆ.55 KH 01097895 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំឃើញមានមនុស្សនៅទីនោះរាប់ពាន់នាក់ ណែនតាន់តាប់ គ្មានអ្វីហូបទេ ហូបតែស្លឹកឈើ ហើយការរស់នៅគឺលំបាកវេទនាណាស់"]។ ឆ.63 01097896 ["ហើយការហូបចុកក៏មិនសូវលំបាក ហើយក៏មិនសូវមានទុក្ខវេទនាដូចនៅគុកភ្នំត្រយ៉ូងដែរ"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.29 KH 01058730 [សាក្សីគឺជាអ្នកទោស៖ "កាលនោះ អាចម៍ និងនោម គឺសុទ្ធតែទឹក គ្មានកាកទេ"]។

1038 ឯកសារ **D219/475** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.15 KH 01134130 [សាក្សីគឺជាអ្នកទោស៖ "ពេលចង់បត់ជើងធំ យើងត្រូវសុំច្បាប់គេ ហើយពេលដែលយើងមកវិញ យើងក៏ត្រូវតែជូនដំណឹងគេដែរ។ ពេលបត់ជើងតូច គឺយើងបត់ជើងនៅក្បែរៗរោងនោះតែម្ដង ពុំមានបង្គន់ទេ។ ពេលចង់បត់ជើងធំ គេនាំយើងទៅចូលព្រៃខាងក្រោយរោងនោះ គឺពុំមានបង្គន់ទេ"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.26 KH 01058729 [សាក្សីគឺជាអ្នកទោស៖ "ចំណែកអ្នកយាម គេអង្គុយនៅចម្ងាយ១០ ឬ២០ម៉ែត្រពីអ្នកទោស ដូច្នេះពេលយើងត្រូវការបត់ជើងធំ យើងត្រូវស្រែកប្រាប់គេ"]។ ឯកសារ **D5/998** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ភួង ផៃ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ KH 00989610 [សាក្សីគឺជាអ្នកទោស៖ "កន្លែងរោងដេកគឺសុទ្ធអាចម៍ តែសុំច្បាប់ទៅបត់ជើងឆ្ងាយពីកន្លែងដេកបន្តិច វាអត់ឲ្យទៅឆ្ងាយទេ វាអោយបត់ជើងជិតកន្លែងដេកនោះឯង"]។

1039 ឯកសារ **D106/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.8 KH 00800988 [សាក្សីគឺជាអ្នកភូមិ និងអ្នកទៅមើលគុក៖ [សាក្សីគឺជាអ្នកភូមិភ្នំត្រឡោក៖ "ខ្ញុំបានឃើញគេដាក់ខ្នោះអ្នកទោស និងបញ្ចេញឲ្យទៅមុជទឹក ដោយមានការភ្ជង់កាំភ្លើងពីក្រោយផងដែរ"]។ ឯកសារ **D1.3.11.27** ប្រតិចារឹកបទសម្ភាសន៍របស់ ក.ស.ច.ស ជាមួយ ឡាយ ខាន់ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៥ EN 00210515 [សាក្សីគឺជាអ្នកភូមិភ្នំត្រឡោក៖ "ពេលមួយនៅពេលដែលខ្ញុំបានឆ្លងកាត់ទីនោះ ដើម្បីចូលទៅសួរសុខទុក្ខម្ដាយរបស់ខ្ញុំ ខ្ញុំបានឃើញគេបណ្ដើរមនុស្សទៅងូតទឹក ហើយពួកគេបានបណ្ដើរមនុស្សមួយខ្សែ ហើយគេបានភ្ជង់កាំភ្លើងដាក់អ្នកទោសរហូតដល់ពួកគេបានងូតទឹករួច"]។ ឯកសារ **D5/998** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ភួង ផៃ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ KH 00989610 [សាក្សីគឺជាអ្នកទោស៖ "៧ថ្ងៃងូតទឹកម្ដង វាឲ្យឈរតំរៀបជួរ១០នាក់ទៅ២០នាក់ ឬ៣០នាក់ ពួកវាឲ្យឈ្លបចំនួន៨-៩ នាក់ ដើរឆ្មកនាំទៅងូតទឹកម្ដង"]។

1040 ឯកសារ **D219/152** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ែត ដួង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឆ.15 KH 01058757 [សាក្សីធ្វើការនៅក្នុងមន្ទីរពេទ្យ និងបានទៅបើកថ្នាំពីភ្នំត្រយោង៖ "គេបានចាត់តាំងឲ្យខ្ញុំទៅជួយនៅទីនោះពីរបីលើកដែរ [នៅភ្នំត្រយោង] ពិសេសករណីដែលអ្នកជំងឺទាំងនោះ ពុំជាសះស្បើយ ក្រោយពេលគេចាក់ថ្នាំ"]។ ឯកសារ **D119/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.46 KH 00989343 [សាក្សីគឺជាអ្នកទោស៖ "នៅក្បែរនោះមានពេទ្យសង្គមកិច្ច។ ពេលខ្លះក៏ព្យាបាលជា ហើយពេលខ្លះទៀតក៏មិនជា ហើយអ្នកជំងឺខ្លះក៏ត្រូវស្លាប់"]។

1041 ឯកសារ **D219/103** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.44 KH 01043242 [សាក្សីគឺជាអ្នកយាមគុក៖ "ខ្ញុំឃើញផ្នូររបស់អ្នកទោស ដែលស្លាប់ដោយសារជំងឺព្រោះសម័យនោះ គ្មានថ្នាំសង្កូវអ្វីនោះទេ"]។

1042 ឯកសារ **D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.52 KH 00933108 [សាក្សីគឺជាអ្នកទោស និងជាពេទ្យ៖ "អត់មានថ្នាំពេទ្យគ្រប់គ្រាន់នោះទេ មានតែបបរស្ករ និងកន្ទក់សម្រាប់អ្នកហើម"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ជិម

ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.29 KH 01058730 [សាក្សីគឺជាអ្នកទោស៖ "ពេលមានអ្នកទោសឈឺ គេឲ្យអ្នកទោសចាស់ៗ ដែលគេមិនដាក់ខ្នោះ គេឲ្យជួយមើលអ្នកទោសទាំងនោះ ក្រោមការឃ្លាំមើលរបស់ពួកអ្នកយាម"]។

1043 **ទាំងអស់៖** ឯកសារ **D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.50 KH 01040791 [សាក្សីគឺជាអ្នកទោស៖ "តាមការកត់សម្គាល់របស់ខ្ញុំ មនុស្សទាំងអស់នោះ ខ្លះស្លាប់ដោយសារជំងឺ អត់អាហារ ការធ្វើការងារធ្ងន់ធ្ងរ និងការកាប់សម្លាប់។ ខ្ញុំនៅចាំថា នៅពេលគេនៅទីនោះ ខ្ញុំបានកប់មនុស្ស២នាក់ស្លាប់ដោយជំងឺ"]។ ឯកសារ **D106/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឆ.26 KH 00801002 [សាក្សីគឺជាអ្នកយាមគុក៖ "អ្វីដែលខ្ញុំចាំបាន គឺមានតែអ្នកទោសស្លាប់ ដោយសារបាក់កម្លាំង និងអត់អាហារ"]។ **ការបង្អត់អាហារ និងជំងឺ៖** ឯកសារ **D219/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ. 44-46 KH 01043242 [សាក្សីគឺជាអ្នកយាមគុក៖ "ខ្ញុំឃើញផ្នូររបស់អ្នកទោស ដែលស្លាប់ដោយសារជំងឺព្រោះសម័យនោះ គ្មានថ្នាំសង្កូវអ្វីនោះទេ។ មិនត្រឹមតែអ្នកទោសទេដែលស្លាប់ ប្រជាជននៅតាមសហករណ៍ក៏ស្លាប់ដូចគ្នាដែរ។...អ្នកខ្លះស្លាប់ដោយសារអត់មានអ្វីហូប។ ... អ្នកស្លាប់គឺស្លាប់ដូចខ្មោចឆ្កែ មិនមានអ្នកកប់អ្វីនោះទេ គ្មានវត្ត គ្មានលោកសង្ឃ"]។ ឯកសារ **D59/1/1.67** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ុម សល់ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927468 [សាក្សីគឺជាអ្នកយាមគុក៖ "ដារ៉ា៖ ពូមានដែលជួបប្រទះឃើញមនុស្សស្លាប់អីនៅកន្លែងភ្នំត្រយោងហ្នឹងទេ? សល់៖ វាស្លាប់ ខ្លះវាឈឺ ផ្សំនឹងអត់ឃ្លានទៅក៏មានងាប់ដែរអីចឹងណា"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.54 KH 01049200 [សាក្សីគឺជាអ្នកយាមគុក៖ "បើតាមខ្ញុំស្មានអ្នកដែលស្លាប់គឺមានចំនួនប្រហែលពី៥ពាន់ទៅ១ម៉ឺននាក់ប៉ុណ្ណោះ ដែលពួកគេភាគច្រើនស្លាប់ដោយសារជំងឺ អត់អាហារ ហើយប្រហែលជាស្លាប់ដោយសារយោធាសម្លាប់ ប៉ុន្តែខ្ញុំមិនដឹងចំនួនអ្នកទោសប៉ុន្មាននាក់ដែលយោធាបានសម្លាប់ទេ។ បើសិនជាអ្នកទោសត្រូវបានគេសម្លាប់ ចំនួនពី៣០ទៅ៥០នាក់ក្នុងមួយយប់ៗ ហើយមន្ទីរសន្តិសុខភ្នំត្រយោងនេះ ត្រូវបានបង្កើតឡើងជាងមួយឆ្នាំ ខ្ញុំគិតថា ចំនួន៥ពាន់ទៅ១ម៉ឺននាក់នេះ គឺជាចំនួនសមរម្យហើយ"]។ ឯកសារ **D219/318** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដន តំ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៥ ឆ.64 KH 01097896 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំបានឃើញមានអ្នកទោសជាច្រើននាក់ បានស្លាប់ដោយសារការអត់ឃ្លាន និងជំងឺ"]។ ឯកសារ **D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.21 KH 01058765-01058766 [សាក្សីគឺជាអ្នកទោស និងអ្នកដាំស្ល៖ "ក្រោយមកទៀត មានអ្នកទោសរាប់ពាន់នាក់ ត្រូវបានគេយកទៅដាក់នៅទីនោះ។ អ្នកទោសនៅភ្នំទ្រយោងរាប់ពាន់នាក់ បានស្លាប់ដោយដាច់ពោះ និងត្រូវបានគេយកទៅសម្លាប់។ អ្នកដែលមានសុខភាពល្អ ក្រោយពីយកទៅដាក់នៅទីនោះបានប្រហែល១០ថ្ងៃ គឺច្បាស់ជាធ្លាក់ខ្លួនឈឺ និងដាច់ពោះស្លាប់ហើយ ព្រោះតែគេឲ្យហូបតែបបរាវ និងតិចតួចបំផុត"]។ **ការបង្អត់អាហារ និងការធ្វើការបាក់កម្លាំង៖** ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ. 81 KH 01115780 [សាក្សីគឺជាអ្នកទោស៖ "យ៉ាងតិចប្រហែល១០០នាក់ [ស្លាប់ដោយសារការបង្អត់អាហារ និងការងារបាក់កម្លាំង]"]។ ឆ.107 KH 01115783 ["ញ៉ាក់ញាប់ ព្រោះងាប់បន្តគ្នា ដោយដាច់ពោះស្លាប់។ ជួនណាទៅ ស្លាប់ច្រើនគ្នា គេសែងអ្នកនេះទៅ នៅអ្នកនោះអ៊ីចឹងទៅ"]។ **ការធ្វើការបាក់កម្លាំង៖** ឯកសារ **D1.3.11.3** កំណត់ហេតុនៃកិច្ចសម្ភាសន៍

របស់ ក.ស.ព ជាមួយ អែ សេ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨ EN 00210405 [សាក្សីគឺជាអ្នកភូមិ៖ "ចំពោះអ្នកមានកំហុសគេដាក់នៅទីនោះ គេប្រើអ្នកទោសទាំងនោះឲ្យវាយថ្ម។ នៅពេលអ្នកមានកំហុសអ្វីមួយ គេចោទប្រកាន់ថាជាបទល្មើស ហើយបញ្ជូនអ្នកនៅទីនោះដើម្បីវាយបំបែកថ្ម។ ឡើងទៅទីនោះ។ មិនចាំបាច់សម្លាប់នោះទេ គេប្រើឲ្យវាយថ្មរហូតដល់អ្នកទោសស្លាប់ដោយខ្លួនឯង"]។ **ការបង្អត់អាហារ៖** ឯកសារ **D219/230** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង រ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.21-22 KH 01076376 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំបានឃើញគេយកអ្នកទោសដែលស្លាប់នៅក្នុងរោងនោះចេញទៅក្រៅ។ អ្នកទោសនៅក្នុងរោងនោះ គឺស្លាប់ជារៀងរាល់ថ្ងៃ គឺអ្នកទោសស្លាប់ពី២ទៅ៣នាក់ក្នុង១ថ្ងៃ។ [É] អ្នកទោសភាគច្រើនគឺស្លាប់ដោយសារការអត់អាហារ"]។ ឯកសារ **D119/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.47 KH 00989343 [សាក្សីគឺជាអ្នកទោស៖ "ការស្លាប់ភាគច្រើន [នៅភ្នំត្រយោង] គឺស្លាប់ដោយសារអត់អាហារ"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.57 KH 00933109 [សាក្សីគឺជាអ្នកទោស៖ "បើយើងគិតជាមធ្យម អ្នកទោសដែលស្លាប់ដោយអត់បាយ យ៉ាងហោចណាស់២នាក់ក្នុង១ថ្ងៃ១យប់ ហើយចំពោះអ្នកយកទៅសម្លាប់ខ្ញុំមិនដឹងនោះទេ"]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.125 KH 01165953 [សាក្សីគឺជាអ្នកទោស៖ "បាទ មាន។ ខ្ញុំបានឃើញអ្នកទោសពីរនាក់ឈរតម្រង់ជួរដើម្បីយកអាហារហើយពួកគេដួលស្លាប់នៅនឹងកន្លែង"]។ ឯកសារ **D5/998** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ភួង ផៃ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ KH 00989610 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំមើលទៅកូនតូចធំក៏ដោយ គឺសែនលំបាកណាស់ អត់ពីម្តាយថែ គ្មានអ្វីហូបត្រូវស្លាប់ មួយថ្ងៃ៣ទៅ៥នាក់ក៏ឃើញ មិនថាក្មេងៗ ឬចាស់ៗទេ ដែលស្លាប់នោះ ពួកវាបានចាត់តាំងឲ្យយកកប់ចោលដូចសត្វឆ្កែ ឆ្មា គឺវេទនាណាស់"]។ ឯកសារ **D5/1202** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ម៉ក់ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ KH 01031228 [សាក្សីគឺជាអ្នកទោសកុមារ៖ "នៅក្បែរជើងភ្នំត្រយោង ខ្ញុំឃើញមានខ្មោចមនុស្សស្លាប់ជាច្រើន ដោយខ្មោចខ្លះត្រូវអារកសម្លាប់ ខ្លះទៀតឃើញហើមខ្លួនប្រាណ ខ្លះស្គមសល់តែឆ្អឹង"]។

1044 ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.45-47 KH 01115777 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំរត់ចូលព្រៃ។ [...] ខ្ញុំចុះមកសារភាពវិញ ហើយនៅផ្ទះបានមួយខែកន្លះ ហើយវាខ្លាចថាខ្ញុំមានខ្សែរយៈ ដែលអាចនាំអ្នកផ្សេងទៀតរត់ គេក៏មកចាប់ខ្ញុំ។ [...] គេចាប់ដាក់គុកភ្នំត្រយោង"]។ ឆ.69 KH 01115779 [សាក្សីគឺជាអ្នកទោស៖ "ពេលខ្លះ យើងត្រូវដេកជាមួយខ្មោច ព្រោះគេមិនទាន់យកចេញ គេសម្លាប់ឡើងស្រឡះអស់។ ពេលស្រឡះហើយ គេដាក់មនុស្សថ្មីមកពេញទៀត"]។

1045 **អ្នកទោសធ្វើការនៅការដ្ឋានវាយថ្ម៖** ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.159 KH 00953041 [សាក្សីគឺជាប្រធានគុក៖ "ការងារនៅកន្លែងនោះគឺ ទី១ គាស់ថ្ម រែថ្ម ដើម្បីយកទៅធ្វើទ្វារទឹក"]។ ឯកសារ **D219/475** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.4 KH 01134128 [សាក្សីគឺជាអ្នកទោស៖ "ប្រហែលបួន ឬប្រាំថ្ងៃ ដែលយើងត្រូវបានគេបញ្ជូនទៅគុកត្រយោង គេដាក់ឲ្យយើងធ្វើការរែថ្ម"]។ ឯកសារ **D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.24 KH 01058767 [សាក្សីគឺជាអ្នកទោស៖ "ប៉ុន្តែច្រើនថ្ងៃក្រោយមក មានអ្នកទោសច្រើន ទើបបានគេចាត់តាំង

អ្នកទោសឱ្យវាយថ្ម"]។ ឯកសារ **D119/88** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.18 KH 00976121 [សាក្សីបានដឹកជញ្ជូនថ្មពីភ្នំត្រយោងទៅត្រពាំងថ្មៈ "ខ្ញុំធ្លាប់ឃើញគេឱ្យអ្នកទោសរែថ្ម"]។ ឯកសារ **D106/4** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.9 KH 00800988 [សាក្សីគឺជាអ្នកភូមិក្បែរនោះ៖ "អ្នកមានកំហុសត្រូវបានគេបញ្ជាឱ្យវាយថ្ម"]។ ឯកសារ **D289.6** ប៉ាន ឈ្យូង ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ពីម៉ោង 14.17.14 ដល់ម៉ោង 14.19.43 KH 011755950 [សាក្សីគឺជាអនុប្រធានកងចល័តតំបន់៥៖ "បាទ នៅមន្ទីរសន្តិសុខនោះ នៅក្បែរផ្លូវដែលខ្ញុំទៅអង្គភាពខ្ញុំនៃសាទ ម្ល៉ោះហើយ ខ្ញុំក៏ឈាងចូលទៅមើលប្អូនខ្ញុំ ទុំ សឺន [...] ឃើញអង្គុយរែថ្ម មិនដឹងគេរែធ្វើអីទេ"]។

<u>**អ្នកទោសធ្ងន់**</u>៖ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.50 KH 01115777 [សាក្សីគឺជាអ្នកទោស៖ "ពួកខ្ញុំធ្វើការរែថ្ម"]។ ឆ.54 KH 01115778 ["ខ្ញុំគិតថាអ្នកទោសធ្ងន់សម្រាប់ប្រជាជន"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.39 KH 01049198 [សាក្សីគឺជាអ្នកយាមគុក៖ "ខ្ញុំគ្រាន់តែដឹងថានៅគុកភ្នំត្រយោង មានអ្នកទោសធ្ងន់ និងអ្នកទោសស្រាល។ អ្នកទោសធ្ងន់ ត្រូវគេបញ្ជាឱ្យទៅវាយថ្ម"]។ ឆ.53 KH 01049200 ["នៅពេលព្រឹក ខ្ញុំឃើញអ្នកទោសធ្ងន់ប្រហែល៣០នាក់ ធ្វើការនៅកន្លែងវាយថ្ម ដែលនៅខាងក្រោយកន្លែង តា សឿន ស្នាក់នៅ ហើយមានយោធាប្រដាប់អាវុធចំនួន៤ទៅ៥នាក់យាមពួកគេ"]។ ឆ.29 KH 01049195 ["ខ្ញុំសូមបញ្ជាក់ថានៅគុកភ្នំត្រយោង ចំពោះអ្នកទោសធ្ងន់ត្រូវបានគេចាត់តាំងឱ្យវាយថ្ម ចំណែកឯអ្នកទោសស្រាល ត្រូវបានគេឱ្យទៅច្រូតស្រូវ ឬបង្កបង្កើនផលនៅតាមវាលស្រែ"]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.25 KH 00895171 [សាក្សីគឺជាអ្នកទោសដែលចាត់ឱ្យធ្វើការងារផ្សេងៗនៅក្នុងគុក៖ "ខ្ញុំបានរៀបចំអ្នកទោសជា៤ទៅ៥កង ដោយមាន [...] កងរែថ្ម (អ្នកទោសធ្ងន់)"]។ ឯកសារ **D219/383** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អើយ ពឿ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.22 KH 01113225 [សាក្សីគឺជាកម្មករកងចល័ត និងអ្នកទៅមើលគុក ៖ "អាត្មាបានឃើញអ្នកទោសជាច្រើនជាប់ខ្នោះជើង និងមានរបួសពេញខ្លួន កំពុងវាយថ្ម។ អាត្មានៅទីនោះរយៈពេលខ្លីទេ ប្រហែលជា១ម៉ោង"]។ សូមមើលផងដែរ ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.82-83 KH 01104648 [សាក្សីគឺជាអ្នកទោស៖ "អ្នកទោសធ្ងន់ខ្លះត្រូវបានគេសម្លាប់ ហើយអ្នកទោសស្រាលខ្លះ ត្រូវបានគេដាក់ខ្នោះ ដាក់ច្រវ៉ាក់។ នេះជាអ្វីដែលខ្ញុំបានឮនៅឆ្នាំ ១៩៧៥។ [...] អ្នកទោសស្រាល ត្រូវបានគេឱ្យវាយថ្មនៅទីនោះ។ ការពិត ខ្ញុំក៏ត្រូវបានគេបញ្ជូនទៅធ្វើការនៅការដ្ឋានវាយថ្មនោះដែរ"]។ ឆ.109 KH 01104652 ["គេដាក់តែខ្នោះជើង យើងម្ខាងម្នាក់ ហើយគេឱ្យយើងអង្គុយទល់មុខគ្នា"] (ដែលគូសបញ្ជាក់ថាគាត់គឺជាអ្នកទោសធ្ងន់)]។ ឯកសារ **D119/22** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឆ.9 KH 00894513 [សាក្សីគឺជាកម្មករកងចល័តនៅព្រះនេត្រព្រះ៖ "ខ្ញុំបានលឺពីការបង្កើតមន្ទីរសន្តិសុខភ្នំត្រយោង។ មនុស្សដែលគេចាប់ខ្លួនពីកងចល័ត អាចត្រូវបានគេបញ្ជូនទៅទីនោះ។ អ្នកខ្លះនិយាយថា មន្ទីរសន្តិសុខនោះ គឺជាមន្ទីរកែប្រែ ព្រោះអ្នកប្រព្រឹត្តកំហុសតិចតួច ត្រូវបានគេបញ្ជូនទៅទីនោះ ឱ្យរែថ្ម។ តែអ្នកខ្លះទៀត និយាយថា អ្នកទោសធ្ងន់ត្រូវបានបញ្ជូនទៅទីនោះ ហើយត្រូវគេសម្លាប់"]។

1046 ឯកសារ **D219/475** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.19 KH 01134131 [សាក្សីគឺជាអ្នកទោស៖ "គេឱ្យយើងឡើងភ្នំ [នៅជិតគុកត្រយោង] គាស់ថ្ម ហើយទម្លាក់មកក្រោមឱ្យអ្នកខាងក្រោមវ៉ៃបំបែក។ [...] ពួកខ្មែរក្រហមមិនឡើងលើកំពូលភ្នំនោះទេ ព្រោះភ្នំខ្ពស់ ហើយបន្លាស្រួច។ [...] ពេលនោះ ទោះបីពួកខ្ញុំពាក់ខោអាវម្នាក់ពីរបីជាន់ក៏ដោយ ក៏ខោអាវយើងនៅតែរហែកដោយសារបន្លាស្រួចនោះ"]។

1047 ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.78 KH 01115780 [សាក្សីគឺជាអ្នកទោស៖ "មួយថ្ងៃវាឱ្យវ៉ៃឱ្យរាបថ្មមួយគីបបួនជ្រុង។ ញញួរវាមួយប្រាំគីឡូ មានកម្លាំងឯណាលើក"]។ ឆ.84 KH 01115780 ["ពេលខ្លះ ខ្ញុំគ្មានកម្លាំងវ៉ៃថ្មធំ ខ្ញុំក៏វ៉ៃថ្មតូចៗម្តង"]។ ឯកសារ **D5/1179** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៊ូ ទូក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ KH [សាក្សីគឺជាអ្នកទោស៖ "នៅពេលថ្ងៃ ពួកឈ្លបសន្តិសុខបណ្តើរខ្ញុំ បង្ខំឱ្យវាយថ្ម ដោយកំណត់១ថ្ងៃ ១ម³ ជារៀងរាល់ថ្ងៃ"]។

1048 ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.39 KH 01049198 [សាក្សីគឺជាអ្នកយាមគុក៖ "អ្នកទោសធ្ងន់ត្រូវគេបញ្ជាឱ្យទៅវាយថ្ម ហើយពេលខ្លះក៏មានថ្មរមៀលសង្កត់ពីលើ"]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.76 KH 01166966 [សាក្សីគឺជាអ្នកទោស៖ "បាទ [ខ្ញុំកប់សាកសព] ជារៀងរាល់ថ្ងៃ ទាំងអ្នកដែលដេកស្លាប់ដោយខ្លួនឯង និងអ្នកដែលត្រូវគេសម្លាប់ក្នុងពេលវ៉ៃថ្ម"]។ ឯកសារ **D1.3.11.3** កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ អែ សេ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨ EN 00210405 [សាក្សីគឺជាអ្នកភូមិក្បែរនោះ ៖ "ចំពោះអ្នកមានកំហុសគេដាក់នៅទីនោះ គេប្រើអ្នកទោសទាំងនោះឱ្យវាយថ្ម។ នៅពេលអ្នកមានកំហុសអ្វីមួយ គេចោទប្រកាន់ថាជាបទល្មើស ហើយបញ្ជូនអ្នកនៅទីនោះដើម្បីវាយបំបែកថ្ម។ ឡើងទៅទីនោះ។ មិនចាំបាច់សម្លាប់នោះទេ គេប្រើឱ្យវាយថ្មរហូតដល់អ្នកទោសស្លាប់ដោយខ្លួនឯង"]។

1049 ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោស៖ "ប្រុសៗគេឱ្យវាយថ្ម ស្រីៗគេឱ្យធ្វើជី"]។ ឯកសារ **D106/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឆ.14 KH 00801001 [សាក្សីគឺជាអ្នកយាមគុក៖ "អ្នកទោសប្រុសត្រូវទៅធ្វើការបំបែកថ្ម ហើយស្ត្រីត្រូវទៅធ្វើស្រែ និងចំការ"]។

1050 ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045329 [សាក្សី គិម យ៉េត គឺជាអតីតអ្នកទោស៖ "OCIJ-068 [ទុំ សឿន] បានឱ្យខ្ញុំប្រមូលគាស់គល់ឫស្សី ១២ គល់។ ខ្ញុំ និងអ្នកទោស២ទៅ៣ នាក់ បានគាស់គល់រួច។ ពេលគាស់រួចហើយ [ទុំ សឿន] បានដើរមកមើល ហើយបាននិយាយថា អ្ហូ គាស់រួចហើយ ចាំឱ្យ យាយ សឿន (អ្នកដាំស្ល) បបរឱ្យស៊ីខាប់ៗ"]។ [សាក្សី ទុំ សឿន ជាប្រធានគុក៖ "មិនមែនជាការបញ្ជាបែបនេះទេ។ ការងារត្រូវបានបែងចែកជាក្រុម។ ជាការងារផ្សេងៗគ្នា។ បើមានការគាស់គុម្ពមែន គឺមិនមែនក្រុម ៣ ឬ ៤ នាក់នោះទេ គឺពី ៩ ទៅ ដប់នាក់"]។ ឯកសារ **D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.22-23 KH 00800982 [សាក្សីគឺជាអ្នកទោស៖ "គាត់បញ្ជាឱ្យក្រុមរបស់ខ្ញុំគាស់គល់ឫស្សីចំនួន ១២ គុម្ពក្នុង ១ ថ្ងៃឱ្យហើយ ដែលជាការងារសឹងតែមិនអាចធ្វើទៅបាន [...] បើធ្វើមិនហើយ ពួកយើងប្រហែលជាត្រូវបានគេសម្លាប់បាត់ទៅហើយ"]។ ឯកសារ **D1.3.11.20** បទសម្ភាសន៍របស់ SOAS ជាមួយ គឹម នៅ (Keum Nov) ថ្ងៃទី ២១

ខែ តុលា ឆ្នាំ ២០០៥ EN 00211886 [សាក្សីគឺជាអ្នកទោស៖ “បន្ទាប់ពីមកដល់មន្ទីរឃុំឃាំង យើងត្រូវបានគេឃុំឃាំងដោយមានការយាមពីរ ឬបីយប់នៅអគារខាងក្រៅមួយ។ ក្រោយមក យើងត្រូវបានគេយកទៅឲ្យគាស់ឫស្សីនៅក្បែរមន្ទីរនោះ”]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.51 KH 00933108 [សាក្សីគឺជាអ្នកទោស៖ “ដំបូង តា សឿន បានឲ្យខ្ញុំដាំចេក និងគាស់ដំបូកដែលមានគល់ឫស្សី ដើមស្វាយ ដើម្បីរំលាយដំបូកនោះសម្រាប់ធ្វើស្រែ”]។ ឯកសារ **D5/1075** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022736 [សាក្សីគឺជាអ្នកទោស៖ “ពួកគេ [ពួកឈ្លប] បង្ខំឲ្យខ្ញុំធ្វើការកាប់ដើមឫស្សី គាស់គល់ឫស្សីនានាជុំវិញភ្នំត្រយ៉ូង ពេលនោះពួកឈ្លបស្ពាយកាំភ្លើងតាមមើលខ្ញុំ”]។

1051 ឯកសារ **D219/174** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡែម ពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.60 KH 01065991 [សាក្សីធ្វើការនៅក្នុងកងចល័តភូមិនៅក្នុងស្រុកព្រះនេត្រព្រះ និងត្រូវបានឃុំឃាំងនៅចម្ការខ្នុរ៖ “ក្រោយមក គេបានបញ្ជូនពួកខ្ញុំឲ្យទៅធ្វើស្រែប្រាំង”]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.18 KH 00895169 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំប្រាប់ពួកគេថា យាយ ចែម ជាអ្នកឲ្យខ្ញុំមកប្រជុំនៅទីនោះ។ ពេលនោះ យោធាបានឲ្យខ្ញុំទៅបែនស្រូវ ដោយគេនិយាយថា នេះជាកិច្ចការដែលខ្ញុំត្រូវធ្វើ។ គេបានឲ្យខ្ញុំបែនស្រូវ ហើយពេលល្ងាច គេបានឲ្យខ្ញុំហូបបបរមួយវែក។ នៅប្រហែលម៉ោង ៦ ល្ងាច គេបានដាក់ខ្នោះខ្ញុំ ហើយប្រាប់ខ្ញុំថា ឲ្យចូលកន្លែងកសាងខ្លួន”]។ ឯកសារ **D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ. 30 KH 01040788 [សាក្សីគឺជាអ្នកទោស៖ “តាមខ្ញុំស្មាន មនុស្សដែលធ្វើការនៅតាមវាលនោះ គឺមានចំនួនប្រហែលពី ២០០ ទៅ ៣០០ នាក់”]។ ឯកសារ **D219/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.38 KH 01043181 [សាក្សីគឺជាអ្នកទោស៖ “ពេលខ្ញុំទៅដល់ភ្នំត្រយ៉ូង មានឈ្លបម្នាក់ ឬពីរនាក់បានប្រាប់ខ្ញុំឲ្យទៅបានបែនស្រូវ ថានេះជាភារកិច្ចរបស់អ្នកឯង”]។ ឯកសារ **D49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ីន ណាន់ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១១ KH 00722216 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំត្រូវបានគេឲ្យទៅកាប់ទន្រ្ទាំងខែត្រ ដើម្បីធ្វើជី និងច្រូតស្រូវនៅទីនោះ”]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.28 KH 01049194 [សាក្សីគឺជាអ្នកយាមគុក៖ “ក្រុមរបស់ខ្ញុំមានតួនាទីនាំក្រុមម៉ែៗទៅធ្វើការនៅតាមស្រែ និងមើលក្រុមកុមារាកុមារីនៅទីនោះផងដែរ”]។ ឯកសារ **D219/129** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន យ៉ែង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.18 KH 01049221 [សាក្សីគឺជាអ្នកទោស៖ “ចំណែកអ្នកទោសស្រាលដទៃទៀត ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅតាមវាលស្រែ”]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.75 KH 01165949 [សាក្សីគឺជាអ្នកទោស៖ “គេចាប់មនុស្សជាប់ខ្នោះម្នាក់នោះយកទៅ ហើយអ្នកផ្សេងទៀតគេឲ្យធ្វើការច្រូតស្រូវ”]។

1052 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.51 KH 00933108 [សាក្សីគឺជាអ្នកទោស៖ “ដំបូង តា សឿន បានឲ្យខ្ញុំដាំចេក និងគាស់ដំបូកដែលមានគល់ឫស្សី ដើមស្វាយ ដើម្បីរំលាយដំបូកនោះសម្រាប់ធ្វើស្រែ”]។ ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.159 KH 00953041 [សាក្សីគឺជាប្រធានគុក៖ “កម្លាំងមួយផ្នែកសម្រាប់បង្កបង្កើនផល ព្រោះពេល

នោះត្រូវដាំបន្លែ ហើយមួយផ្នែកទៀតសម្រាប់រកម្ហូប ដូចជាឱ្យទៅទន្លេសាប ដើម្បីរកម្ហូបមកឱ្យសហករណ៍"]។ ឯកសារ **D106/7** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឆ.10 KH 00801000 [សាក្សីគឺជាអ្នកយាមគុកៈ "តា សឿន បានចាត់តាំងឱ្យខ្ញុំយាមអ្នកទោស ដែលដាំដំឡូង និងពោត ហើយត្រូវកុំឱ្យអ្នកទោសរត់គេចខ្លួន"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោសៈ "ពួកខ្ញុំគេឱ្យដាំស្ពៃ និងឪឡឹក"]។ ឯកសារ **D219/129** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អ៊ិន យ៉េង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.15 KH 01049221 [សាក្សីគឺជាអ្នកទោសៈ "នៅភ្នំត្រយ៉ូង គេឱ្យខ្ញុំរែកដី គាស់គល់ឈើ កាប់ទន្រ្ទានខែត្រ និងរែកដី [...]។ នៅពេលនោះ ខ្ញុំមានផ្ទៃពោះហើយជិតគ្រប់ខែ"]។ ឯកសារ **D123/1/2.65** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ណាន់ និង រិន ខេង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927369 [សាក្សីគឺជាអ្នកទោសៈ "គេឱ្យខ្ញុំកាប់ទន្រ្ទានខែត្រ ធ្វើជី ច្រូតនោះឯង"]។

1053 ឯកសារ **D119/30** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.24 KH 00895170 [សាក្សីគឺជាអ្នកទោសៈ "តា សឿន បានកោះហៅអ្នកទោសទាំងអស់ប្រហែល ៣០០ នាក់ឱ្យមកប្រជុំ។ [...] ខ្ញុំបានឆ្លើយថា ខ្ញុំឈ្មោះ ភួន ទី ជាអ្នកមកពីប្រាសាទ។ ពេលនោះគាត់បាននិយាយប្រាប់ខ្ញុំថា មិត្តឯងត្រូវធ្វើជាប្រធានអ្នកទោសទាំងអស់ បើបាត់តែម្នាក់ គេនឹងវ៉ៃមិត្តឯងចោល"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.51 KH 00933108 [សាក្សីគឺជាអ្នកទោសៈ "ខ្ញុំធ្វើការនៅទីនោះ [ភ្នំត្រយ៉ូង] បាន ១ ខែ តា សឿន បានយកខ្ញុំមកធ្វើការនៅជិតគាត់វិញ។ គាត់បានឱ្យខ្ញុំធ្វើជាអ្នកបែងចែកកន្ទក់ឱ្យអ្នកទោសដែលមានជំងឺហើមជាដើម"]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.88 KH 01165950 ["គេឱ្យខ្ញុំធ្វើផ្ទះ ទ្វារ គេមិនចាត់ទុកខ្ញុំជាអ្នកទោសធ្ងន់ទេ"]។ ឆ. 124 KH 01165953 ["ជាងឈើ គេឱ្យធ្វើការចាប់ពីម៉ោង ៧ រហូតដល់ម៉ោង ៥ ល្ងាច"]។ ឯកសារ **D219/153** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.26 KH 01058767 [សាក្សីគឺជាអ្នកទោស និងអ្នកដាំស្ល: "គ្នាខ្ញុំប្អូនប្រាំនាក់ ដាំបាយឱ្យពួកអ្នកយាមផង និងអ្នកទោសផង។ មួយថ្ងៃៗពួកយើងរវល់រហូត ដាំបាយផង ធ្វើម្ហូបផង ចិតបន្លែផង"]។ ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045330 [OCIJ-068 (ទុំ សឿន ដែលជាប្រធានគុក)ៈ "អ្នកដាំស្ល គឺយកចេញពីក្នុងចំណោមអ្នកទោសស្រាល"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.50 KH 01115777 [សាក្សីគឺជាអ្នកទោសៈ "[អ្នកទោស] ចាស់ៗគេចាប់ឱ្យធ្វើរទេះ"]។ ឯកសារ **D5/998** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ភួង ផៃ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ KH 00989610 [សាក្សីគឺជាអ្នកទោសៈ "ពួកវាបានចាត់តាំងប្រុសចាស់ឱ្យធ្វើបង្គី សម្រាប់សែងដី"] KH 00989610 ["តែស្រ្តីមានកូនតូចក៏ដោយ កូនធំក៏ដោយ គេឱ្យទុកកូនចោល ឱ្យទៅកាប់ដើមទន្រ្ទានខែត្រយកមកធ្វើជី"]។

1054 ឯកសារ **D219/567** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.88 KH 01165950 [សាក្សីគឺជាអ្នកទោសៈ "គេឱ្យខ្ញុំធ្វើផ្ទះ ទ្វារ គេមិនចាត់ទុកខ្ញុំជាអ្នកទោសធ្ងន់ទេ"]។ ឆ. 91 KH 01165950 [សាក្សីគឺជាអ្នកទោសៈ "ធ្វើ [ខ្នោះ] ពីឈើគេដាក់អ៊ីចេះ"]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន

មុ៊ន ហៅ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.27 KH 00894495 [សាក្សីគឺជាអ្នកទោស៖ "ប្រធានគុក បានបញ្ជាឱ្យដោះលែងខ្ញុំ និង ទី ប៉ុន្តែគេឱ្យធ្វើការជាជាងឈើនៅក្នុងគុកនោះ ដើម្បីធ្វើរោងបន្ថែមសម្រាប់អ្នកទោស"]។ ឯកសារ **D219/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន មុ៊ន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.46 KH 01043182 [សាក្សីគឺជាអ្នកទោស៖ "ស៖ ទាក់ទងទៅនឹងការសុំលុបចោលនេះដែរ នៅចំណុចមួយ គឺលោកឆ្លើយថា គេបានឱ្យលោក និង ទី ទៅធ្វើជាជាងឈើ ចាប់ពីពេលនោះមក ស្ថានភាពរបស់លោកប្រសើរជាងមុន។ តើលោកនៅរក្សាចម្លើយនេះទេ? ឆ.46៖ បាទ ខ្ញុំនៅរក្សាចម្លើយនេះ"]។

1055 ឯកសារ **D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អុឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.26 KH 01058767 [សាក្សីគឺជាអ្នកទោស និងអ្នកដាំស្ល៖ "គ្នាខ្ញុំបួនប្រាំនាក់ ដាំបាយឱ្យពួកអ្នកយាមផង និងអ្នកទោស ផង។ មួយថ្ងៃៗពួកយើងរវល់រហូត ដាំបាយផង ធ្វើម្ហូបផង ចិតបន្លែផង"]។ ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នា ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045330 [OCIJ-068 (ទុំ សឿន គឺជាប្រធានគុក)៖ "អ្នកដាំស្លរ គឺយកចេញពីក្នុងចំណោមអ្នកទោសស្រាល"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.51 KH 00933108 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំធ្វើការនៅទីនោះបាន ១ ខែ តា សឿន បានយកខ្ញុំមកធ្វើការនៅជិតគាត់វិញ។ គាត់បានឱ្យខ្ញុំធ្វើជាអ្នកបែងចែកកន្ទក់ឱ្យអ្នកទោសដែលមានជំងឺហើមជាដើម"]។

1056 ឯកសារ **D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.27 KH 00801016 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំនៅចាំថា នៅពេលមួយនោះ គឺមុនពេលវៀតណាមចូលមកដល់ ក្រុមរបស់ខ្ញុំត្រូវបានគេបញ្ជាឱ្យជីកអន្លង់ធំមួយ ហើយឱ្យកប់សាកសពចំនួនប្រហែល ៩០ នាក់"]។ ឆ.29៖ KH 00801017 ["ដំបូង គេឱ្យពួកយើងជីកអន្លង់ បន្ទាប់មកគេនាំអ្នកទោសមក ហើយសម្លាប់។ យើងនៅក្បែរនោះ ហើយយើងអាចមើលឃើញពួកគេសម្លាប់មនុស្ស។ ក្រោយមក គេឱ្យពួកយើងកប់សាកសពទាំងនោះ"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.58-59 KH 00933109 [សាក្សីគឺជាអ្នកទោស៖ "មានពេលខ្លះ គេបានឱ្យខ្ញុំទៅជួយជីករណ្តៅដើម្បីដាក់ខ្មោចថែមទៀតផង [...] ខ្ញុំជីករណ្តៅប្រហែលបួនប្រាំដង ក្នុងម្តងប្រហែលជាមួយរណ្តៅប៉ុណ្ណោះ"]។ ឯកសារ **D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.31-32 KH 00800984 [សាក្សីគឺជាអ្នកទោស៖ "នៅពេលយប់ អ្នកទោសដែលជាប់ខ្នោះ ត្រូវបានគេបញ្ជូនយកទៅសម្លាប់។ ជួនកាល អ្នកយាមមិនមានពេលកប់សាកសពទាំងអស់នោះទេ ហើយពួកគេបានបញ្ជាឱ្យក្រុមពេទ្យរបស់ខ្ញុំទៅជួយកប់សាកសពទាំងនោះ [...] មានចំនួនពី ២០ ទៅ ៣០ នាក់ម្តងៗ"]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ ឆ. 20 KH 00895170 ["នៅយប់ដំបូង គេបានដាក់ខ្នោះខ្ញុំ ពីម៉ោង ៦ ដល់ម៉ោង ៩ យប់ ហើយបន្ទាប់មក គេឱ្យខ្ញុំ និង សាមុន ទៅជីកអន្លង់ធំមួយ។ នៅទីនោះ សាមុន ហើយនិងខ្ញុំ បានឃើញផ្ទាល់ភ្នែក ការសម្លាប់មនុស្សចំនួន ៧ នាក់។ ពួកគេត្រូវបានសម្លាប់ដោយមនុស្សដែលមានគ្នាប្រហែល ៣ ទៅ ៤ នាក់ ដោយវាយនឹងពូថៅ។ ក្រោយមក ពួកគេបានបញ្ជាឱ្យខ្ញុំ និង សាមុន លុបដីកប់សាកសពទាំងនោះឱ្យស្អាត"]។ ឯកសារ D219/583 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.80-81 KH 01166967 [សាក្សីគឺជាអ្នកទោស៖ "ពេលខ្ញុំបើករបបហូប គេមិនឱ្យទៅជិតគេទេ គេឱ្យមនុស្សយកបាយទៅឱ្យពួកខ្ញុំ ព្រោះមានក្លិនស្អុយជាប់ខ្លួនពួកខ្ញុំ [...] ពេល

ខ្ញុំដើរយកសពទៅកប់ ពេលខ្លះយើងចាំមិនបានថាកប់កន្លែងណាខ្លះ ព្រោះកប់មានមុនមានក្រោយ ហេតុនេះពេលខ្លះ ដើរធ្លាក់រណ្តៅសពចាស់ផុងត្រឹមក្បាលជង្គង់"]។

1057 ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.80-81 KH 01166967 [សាក្សីគឺជាអ្នកទោស៖ "ពេលខ្ញុំបើករបបហូប គេមិនឱ្យទៅជិតគេទេ គេឱ្យមនុស្សយកបាយទៅឱ្យពួកខ្ញុំ ព្រោះមានក្លិនស្អុយជាប់ខ្លួនពួកខ្ញុំ [...] ពេលខ្ញុំដើរយកសពទៅកប់ ពេលខ្លះយើងចាំមិនបានថាកប់កន្លែងណាខ្លះ ព្រោះកប់មានមុនមានក្រោយ ហេតុនេះពេលខ្លះ ដើរធ្លាក់រណ្តៅសពចាស់ផុងត្រឹមក្បាលជង្គង់"]។

1058 ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.138-141 KH 01165954-01165955 [សាក្សីគឺជាអ្នកទោស៖ "គាត់និយាយថា ឱ្យខំបង្កបង្កើនផល ខំកសាងខ្លួន។ គាត់ថា បើអ្នកណាធ្វើខុស ខំកសាងខ្លួន ខ្លាចស្លាប់។ [...] ខ្ញុំឮគាត់និយាយ ពេលដែលខ្ញុំធ្វើការនៅជិតនោះ។ គេមិនហៅខ្ញុំមកចូលរួមទេ។ ស៖ ពេលដែលលោកឮ យាយ ថែម តើលោកឮដោយផ្ទាល់នឹងត្រចៀកតែម្តង? ឆ.141៖ បាទ"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លូក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ. 68-69 KH 01115779 [សាក្សីគឺជាអ្នកទោស៖ "គាត់ថា ឱ្យខំធ្វើការ អ្នកណាកសាងខ្លួនបានក៏រស់ ហើយអ្នកណាកសាងខ្លួនមិនបានក៏ស្លាប់ [...]។ មានន័យថា យោធាយកទៅសម្លាប់"]។

1059 ឯកសារ **D5/1075** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022735-01022736 [សាក្សីគឺជាអ្នកទោស៖ "នៅក្នុងគុក ពួកយោធាសួរចម្លើយខ្ញុំ ម្តងៗវាយកកូនសោមកវាយក្បាល ពេលវាយម្តងៗ ឈឺស្ទើរលេចអាចម៍លេចនោម ស្ទើរសន្លប់ ឬសន្លប់ម្តងៗ ឱ្យខ្ញុំសារភាព ដោយចោទថាខ្ញុំជាទាហាន លន់ នល់ តាមពិតខ្ញុំជាសេនាជនយាមតាមភូមិ កងស្វ័យត្រាណតែប៉ុណ្ណោះ"]។ ឯកសារ **D5/988** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រិន ខេង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 00990222 [សាក្សីគឺជាអ្នកទោស៖ "មិនតែប៉ុណ្ណោះ ពេលយប់ វាបានសួរចម្លើយ ដោយវាយនឹងខ្សែតី វាយវាត់យ៉ាងដំណំ"]។ សូមមើលផងដែរឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លូក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.50 KH 01115777 [សាក្សីគឺជាអ្នកទោស៖ "យប់ឡើងគេយកទៅសួរចម្លើយ បើអ្នកណាឆ្លើយថាចេះជាង គេយកអ្នកនោះទៅវៃចោល"]។ ឆ. 123-129 KH 01115784-01115785 ["បាទ។ [ពួកគេសួរចម្លើយខ្ញុំ] ប្រាំ ទៅប្រាំមួយដង [...] ពួកយោធា [...] គេសួរថា ម៉េចបានគេបញ្ជូនមិត្តឯងមក? ខ្ញុំថា ខ្ញុំដើរមិនបានសុំមេភូមិ [...]។ ស៖ តើនឹងមានរឿងអ្វីកើតឡើង បើលោកផ្តល់ចម្លើយមិនត្រូវ។ ឆ.128៖ មានតែយកទៅវៃចោលហ្នឹង [...]។ គេគ្រាន់តែនាំទៅសួរធម្មតា។ សួររាងស្លូតដែរ ហើយយើងឆ្លើយតាមលំនាំ"]។ ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.112 KH 01104653 [សាក្សីគឺជាអ្នកទោស៖ "តាមពិត គេសួរចម្លើយខ្ញុំធម្មតាទេ នៅពេលនោះ គឺមានអ្នកសួរចម្លើយពីរនាក់ពាក់មួយកន្តិប និងឯកសណ្ឋានខ្មៅ ដែលប្រដាប់ដោយអាវុធ AK ហើយគេបានសួរចម្លើយខ្ញុំធម្មតា ដោយមិនមានធ្វើទារុណកម្មមកលើខ្ញុំទេ"]។ ឯកសារ **D5/1179** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៊ូ ទូក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ KH 01030733 [សាក្សីគឺជាអ្នកទោស៖ "មួយថ្ងៃសួរចម្លើយ ២ ទៅ ៣ ដង ហើយឈ្លបខ្មែរក្រហមវាសួរខ្ញុំថា "ហេតុអ្វីមិត្តឯងរត់ចូលព្រៃ..."]។ ឯកសារ **D230** [D219/102] កំណត់ហេតុនៃការស្តាប់ចម្លើយ

សាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045317 [សាក្សីគឺជាប្រធានគុក៖ "អ្នកខ្លះត្រូវបាននាំមកដោយចង ចំណង បានមានន័យថាជាអ្នកទោសធ្ងន់ ប៉ុន្តែក្រោយការពិនិត្យតាមដានបាន ៥ ឬ ៦ ថ្ងៃ ខ្ញុំអាចចាត់ថ្នាក់ពួកគាត់ទៅជាអ្នក ទោសស្រាលវិញ បើពួកគេមិនបានប្រព្រឹត្តកំហុសធ្ងន់នោះទេ"]។ ឯកសារ **D59/1/1.67** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯក សារកម្ពុជាជាមួយ ស៊ុម សល់ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927467 [សាក្សីគឺជាអ្នកយាមគុក៖ "អារឿងសួរ ចម្លើយ តែមានខ្មោះហើយគេសួរហើយ ព្រោះគេដាក់ខ្មោះហើយ ឧទាហរណ៍ថាទោសធ្ងន់កម្រិតធ្ងន់ទៅគេសួរទៅណា សួរ ចម្លើយអី អានោះវាច្រើនតែផ្នែកគេអ្នកចេះអ្នកដឹង អ្នកនេះទេ ដែលគេសួរចម្លើយទៅសួរអី"]។

1060 ឯកសារ **D119/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.43 KH 01025131 [សាក្សីគឺជាអ្នកទោស៖ "តាមខ្ញុំដឹង ពួកគេទាំងអស់នោះ ប្រហែលជាមិនអាចរស់បានទេ។ ពួកគេប្រហែលជា អាចស្លាប់រយៈពេលបីថ្ងៃក្រោយមក"]។ ឯកសារ **D219/230** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.7 KH 01076374 ["ពួកគេទាំង ២ នោះ [ដែលត្រូវបានផ្ទេរពីរទេះគោរបស់គាត់] បានស្លាប់នៅភ្នំត្រយ៉ូ ងបាត់ហើយ ដោយសារការធ្វើទារុណកម្ម"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃ ទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោស៖ "អ្នកខ្លះខ្សោយពេក អស់កម្លាំង មិនអាចធ្វើការ បាន ត្រូវបានពួកឈ្លបសម្លាប់ ដោយវាយនឹងដំបង ឬស្វាយកាំភ្លើង ខ្ញុំបានឃើញផ្ទាល់ភ្នែករាប់មិនអស់។ ខ្ញុំមិនបានឃើញ ហេតុការណ៍នេះកើតឡើងរាល់ថ្ងៃទេ ប៉ុន្តែជាធម្មតា ខ្ញុំឃើញវាកើតឡើងនៅពេលល្ងាច"]។

1061 ឯកសារ **D119/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.40-43 KH 01025130-01025131 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំធ្លាប់បានឃើញគេធ្វើទារុណកម្មអ្នកទោសនៅទីនោះ។ ខ្ញុំបានឃើញគេ ឲ្យអ្នកទោសប្រហែល ១០ នាក់ដេកផ្ងារមុខឡើង ហើយដៃនិងជើងរបស់ពួកគេនៅជាប់ខ្នោះ ហើយក្រោយមក អ្នកយាមរត់ ជាន់លើពួកគេចុះឡើងៗ។ ក្រោយមក គេឲ្យអ្នកទោសទាំងនោះ ដេកផ្កាប់មុខ ហើយអ្នកយាមបានយកដំបងវាយដំទៅលើពួក គេ [...] ការធ្វើទារុណកម្មនោះ មិនមែនជាការសួរចម្លើយទេ ព្រោះខ្ញុំឃើញអ្នកទាំងនោះ ត្រូវបានគេនាំយកទៅអគាររបស់ អ្នកយាម។ ខ្ញុំបានលួចសួរអ្នកទោសដូចគ្នា ហើយគេប្រាប់ថា ពួកគេត្រូវបានចោទថាក្បត់ជាតិ។ តាមខ្ញុំដឹង ពួកគេទាំងអស់ នោះ ប្រហែលជាមិនអាចរស់បានទេ។ ពួកគេប្រហែលជាអាចស្លាប់រយៈពេលបីថ្ងៃក្រោយមក"]។ ឯកសារ **D219/230** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡេង វ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.7 KH 01076374 [សាក្សីគឺជាអ្នកទោស ៖ "[មនុស្សពីរនាក់ផ្សេងទៀតដែលត្រូវបានគេចាប់មកជាមួយគាត់] បានស្លាប់នៅភ្នំត្រយ៉ូងហើយ ដោយសារការធ្វើទារុណ កម្ម"]។ ឆ.14 KH 01076375 ["ខ្ញុំខ្លួនឯងក៏ត្រូវបានគេធ្វើទារុណកម្មផងដែរ ពួកយើងទាំងអស់គ្នាត្រូវបានគេធ្វើទារុណកម្ម យើងនៅពេលយើងទៅដល់ដំបូង នៅពេលនោះគឺមានឈ្លប ៦-៧ នាក់ឈរព័ទ្ធជុំវិញយើង ដោយទាត់ ធាក់ និងវាយដោយ ដំបងឬស្សី។ ហើយបន្ទាប់ពីវាយដំរួចហើយ យើងត្រូវបានគេបញ្ជូនយើងទៅដាក់ខ្នោះនៅក្នុងរោងអ្នកទោស"]។ ឆ.18 KH 01076376 ["ខ្ញុំបានឃើញគេធ្វើទារុណកម្មនៅរៀងរាល់រសៀល ហើយអ្នកទោសគឺត្រូវបានគេធ្វើពី ១០ ទៅ ១៥ នាក់ក្នុង ពេលនៃការធ្វើទារុណកម្មម្តងៗ"]។ ឯកសារ **D219/129** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមប ណ្តឹងរដ្ឋប្បវេណី អ៊ុន យ៉េង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.24 KH 01165954 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំមិនដែលធ្លាប់ឮ ធ្លាប់ឃើញគេសម្លាប់មនុស្សទេ ប៉ុន្តែខ្ញុំឮសូរសំឡេងគេវាយដំមនុស្ស"]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់

ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.167 KH 01165957 [សាក្សីគឺជាអ្នកទោស៖ "វ៉ៃអ្នកទោសគ្នាខ្ញុំ ដែលវារត់គេចនោះ បងខ្ញុំបានឃើញ ហើយគេវ៉ៃនឹងកំណាត់ឈើ"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោស៖ "អ្នកខ្លះខ្សោយពេក អស់កម្លាំង មិនអាចធ្វើការបាន ត្រូវបានពួកឈ្លបសម្លាប់ ដោយវាយនឹងដំបង ឬស្វាយកាំភ្លើង ខ្ញុំបានឃើញផ្ទាល់ភ្នែករាប់មិនអស់។ ខ្ញុំមិនបានឃើញហេតុការណ៍នេះកើតឡើងរាល់ថ្ងៃទេ ប៉ុន្តែជាធម្មតា ខ្ញុំឃើញវាកើតឡើងនៅពេលល្ងាច"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.132 KH 01115785 [សាក្សីគឺជាអ្នកទោស៖ "ពេលយើងមកពីហូបបាយវិញ ខ្ញុំចង់បេះស្លឹកឈើហូប ហើយចូលវិញយឺត គេដាក់ខ្ញុំពីរបីដំបងធ្ងន់ដែរ តែខ្ញុំរាងស្គម គេមិនវ៉ៃដល់ស្លាប់ទេ"]។ ឯកសារ **D123/1/2.65** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ណាន់ និង រិន ខេង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927369 [សាក្សីគឺជាអ្នកទោស៖ "[ប៊ិន ណាន់៖] បើយើងទៅលួចគេ បានគេវ៉ៃ"]។ សូមមើល *ការជំទាស់៖* ឯកសារ **D219/102** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.36 KH 01043198 [សាក្សីគឺជាប្រធានគុក៖ "[បដិសេធចំពោះការវាយដុំអ្នកទោស] ដោយសារពួកគេមកជាមួយគ្រួសារ បើយើងប្រើអំពើហិង្សាទៅលើពួកគេ នោះគ្រួសារគេនឹងភ័យខ្លាច។ ដូច្នេះ យើងជៀសវាង មិនបំភ័យគ្រួសាររបស់គេទេ"]។

1062 ឯកសារ **D119/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.40-41 KH 01025130 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំធ្លាប់បានឃើញគេធ្វើទារុណកម្មអ្នកទោសនៅទីនោះ។ ខ្ញុំបានឃើញគេឲ្យអ្នកទោសប្រហែល ១០ នាក់ដេកផ្ងារមុខឡើង ហើយដៃនិងជើងរបស់ពួកគេនៅជាប់ខ្នោះ ហើយក្រោយមក អ្នកយាមរត់ជាន់លើពួកគេចុះឡើងៗ។ ក្រោយមក គេឲ្យអ្នកទោសទាំងនោះ ដេកផ្កាប់មុខ ហើយអ្នកយាមបានយកដំបងវាយដំទៅលើពួកគេ"]។

1063 ឯកសារ **D219/475** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.19 KH 01134131 [សាក្សីគឺជាអ្នកទោស៖ "ពេលហូបបាយម្តងៗ ពួកខ្មែរក្រហមយកឈើមកដាក់ជិតក្បាលពួកយើង ហើយគេតែតែងនិយាយថា ៤ នាក់យើងមិនយូរមិនឆាប់នឹងទៅជាស្នូលដីហើយ។ យើងដឹងថា ពួកគេនឹងសម្លាប់យើងមិនយូរ ឬឆាប់ទេ"]។ ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.120 KH 01104654 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំមានការភ័យខ្លាចខ្លាំងណាស់"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោស៖ "ជួនកាលយប់ឡើងគេចងអ្នកទោសទាំងនោះជាខ្សែយកទៅសម្លាប់ ប៉ុន្តែមិនដឹងប៉ុន្មាននាក់នោះទេ ហើយក៏មិនដឹងគេយកទៅសម្លាប់នៅកន្លែងដែរ ព្រោះខ្ញុំភ័យពេក ដូច្នេះខ្ញុំបានរត់ពួន"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.128 KH 01115785 [សាក្សីគឺជាអ្នកទោស៖ "ស៖ តើនឹងមានរឿងអ្វីកើតឡើង បើលោកផ្តល់ចម្លើយមិនត្រូវ? ឆ.128៖ មានតែយកទៅវ៉ៃចោលហ្នឹង"]។ ឯកសារ **D123/1/2.65** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ិន ណាន់ និង រិន ខេង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927368 [សាក្សីគឺជាអ្នកទោស៖ "បើយើងអត់មិនបាន យើងទៅរកលួចអីគេ គេវ៉ៃចោលនោះឯង ខ្ញុំមិនដែលប៉ានទៅរកអីទេ"]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅ សា

មុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.22 KH 00894494 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំមានការភ័យកាន់តែខ្លាំងឡើងៗ ហើយគិតថា ខ្ញុំ និង ទី នឹងត្រូវគេយកទៅសម្លាប់នៅពេលបន្ទាប់”]។

1064 ឯកសារ **D101/1.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 0074550 [សាក្សីគឺជាអ្នកទោស៖ “ដល់ពេលយប់ បានគេយកទៅវាយចោល អាត្មាហ៊ានមានសង្ឃដីកាដូចនេះព្រោះអាត្មាដឹងថាឲ្យតែគេយកទៅ គឺបាត់តែម្តង”]។ ឯកសារ **D123/1/2.65** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌល ឯកសារកម្ពុជាជាមួយប៊ិន ណាន់ និង រិន ខេង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927374 [សាក្សី ណាន់ គឺជាអ្នកទោស៖ “វាច្រើនណាស់ឯង ច្រើន ប៉ុន្តែថាដូចគេថាបាត់ ចេះតែបាត់ៗ ស្ងាត់មនុស្ស មិនដឹងគេយកទៅណាមិនដឹងទេ”]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោស៖ “ជួនកាលយប់ឡើងគេចងអ្នកទោសទាំងនោះជាខ្សែយកទៅសម្លាប់ ប៉ុន្តែមិនដឹងប៉ុន្មាននាក់នោះទេ ហើយក៏មិនដឹងគេយកទៅសម្លាប់នៅកន្លែងណាដែរ ព្រោះខ្ញុំភ័យពេក ដូច្នេះខ្ញុំបានរត់ពួន”]។ ឯកសារ **D219/256** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មី គាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.27 KH 01085166 [សាក្សី គឺជាអ្នកបររទេះគោនៅភ្នំលៀប៖ “ប៉ុន្តែអ្នកជិតខាងរបស់ខ្ញុំមួយចំនួន ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅភ្នំទ្រយោង ហើយក៏បានបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ”]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ. 96 KH 01115782 [សាក្សីគឺជាអ្នកទោស៖ “ចុះបើគេយកចេញពីកន្លែងខ្ញុំ។ គេយកទៅសួរចម្លើយ ហើយមិនដែលយកមកវិញទេ”]។ ឯកសារ **D219/475** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.21 KH 01134132 [សាក្សីគឺជាអ្នកទោស៖ “ក្នុងអំឡុងពេលជាប់ឃុំនៅភ្នំទ្រយោង ខ្ញុំធ្លាប់ឃើញគេបណ្តើរអ្នកទោសចេញទៅទាំងយប់ ហើយអ្នកទោសទាំងនោះ មិនដែលត្រឡប់មកវិញទេ។ ខ្ញុំច្បាស់ថា អ្នកទោសទាំងនោះ គឺត្រូវគេយកទៅសម្លាប់”]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.22 KH 0894494 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំសូមបន្ថែមថានៅថ្ងៃដែលគេដាក់ខ្នោះខ្ញុំនោះ មានមនុស្សចំនួន៨នាក់ទៀត ត្រូវបានគេចាប់ដាក់ខ្នោះជាមួយខ្ញុំ និងទី ដែរ។ នៅពេលយប់ ពួកគេទាំង៨នាក់ ត្រូវបានគេបញ្ជូនចេញ តែខ្ញុំមិនដឹងថាគេបញ្ជូនទៅទីណាទេ ប្រហែលជាគេយកទៅសម្លាប់ចោលហើយ។ ខ្ញុំមានការភ័យកាន់តែខ្លាំងឡើងៗ ហើយគិតថា ខ្ញុំ និងទី នឹងត្រូវគេយកទៅសម្លាប់នៅពេល បន្ទាប់។”]។ ឯកសារ **D219/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.48 KH 01043183 [“មិនឃើញត្រឡប់មកវិញទេ។”]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.74 KH 01165949 [សាក្សីគឺជាអ្នកទោស៖ “មានឈ្មោះឌឿន ដែលគាត់រត់ពីតំបន់ទៅ ហើយនៅពេលដែលគាត់ដឹងថា គេនឹងបញ្ជូនគាត់ទៅទៀត គាត់បានរត់ ហើយមានម្នាក់ទៀត ឈ្មោះ ឌឿន ដែរ ត្រូវបានគេចាប់ខ្លួន ហើយដាក់ខ្នោះជើង ហើយយប់ឡើងក៏បាត់ខ្លួនតែម្តង។”] ឆ.106-109 KH 01165951-01165952 [“ខ្ញុំឃើញតែមួយយប់ទេ។ យប់ក្រោយៗទៀត ខ្ញុំមិនបានឃើញទេ ព្រោះគេមិនឲ្យទៅជិតខ្លាចយើងឃើញ។ [É] ព្រឹកថ្ងៃបន្ទាប់ ខ្ញុំទៅយកអីវ៉ាន់របស់ខ្ញុំ ដូចជា ដែករណា ជាដើម ដែលខ្ញុំទុកនៅទៅនោះ [É] តាមខ្ញុំសន្និដ្ឋាន គេយកទៅសម្លាប់ចោលអស់ហើយ [É] ពីព្រោះពួកគេបាត់ខ្លួន មានម្នាក់មកពីភូមិខ្ញុំដែរ គាត់នៅគុកនោះ ហើយបានព្យាយាមរត់ចេញពីកន្លែងគុកនោះ ដល់ពេលគេចាប់បានមកវិញ គេយកទៅដាកខ្នោះ ហើយក៏បាត់ខ្លួនរហូតដល់សព្វថ្ងៃ។”]

1065 ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.98-101 KH 01115782 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំនៅកន្លែងដេកហ្នឹងមិនឆ្ងាយពីកន្លែងដែលគេយកអ្នកទោសទៅសម្លាប់ទេ ទើបខ្ញុំឮ [É] ឮតែគេវ៉ៃ។ មិនដែលឮសំឡេងគ្រាប់កាំភ្លើងទេ គេទុកសម្រាប់តែពេលយើងរត់។"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.33 KH 01058730 [សាក្សីគឺជាអ្នកទោស៖ "បាទ មិនមែនតែខ្ញុំទេដែលឮសំឡេងស្រែក គឺមានអ្នកទោសផ្សេងទៀតដូចខ្ញុំដែរ ព្រោះវាមានចម្ងាយប្រហែល៥០ម៉ែត្រពីគ្នាប៉ុណ្ណោះ។ ពួកគេស្រែក "អូយៗ" ដែលជាសំឡេងដង្ហើយហៅឲ្យគេជួយ មុននឹងមនុស្សដាច់ខ្យល់។ ខ្ញុំសន្និដ្ឋានថា អ្នកទោសទាំងនោះ ត្រូវបានគេវាយនឹងដំបងរហូតដល់ស្លាប់ ព្រោះខ្ញុំមិនដែលឮស្នូរគ្រាប់កាំភ្លើងទេ។"] ឆ.34-35 KH 01058730 - 01058731 ["ស្រីៗទាំងនោះ គេឲ្យនៅជាមួយឪពុកម្តាយនៅពេលថ្ងៃ ហើយដល់ពេលគេយក គឺគេទៅចាប់មកនៅពេលយប់ មកដាក់នៅរោងពួកអ្នកយាម ដែលមានចម្ងាយប្រហែល៦០ម៉ែត្រពីរោងខ្ញុំដេក។ ខ្ញុំដឹងថាគេធ្វើបាបនារីទាំងនោះ ដោយសារខ្ញុំឮនាងៗទាំងនោះ ជេរប្រទិចអ្នកយាមថា "បើឯងគង់នឹងសម្លាប់អញ! ចាំបាច់ធ្វើបែបនេះធ្វើអី!"។ ខ្ញុំឮសំឡេងហ៊ោកញ្ជៀវ សើចសប្បាយរបស់ពួកអ្នកយាមទាំងនោះ។ តាមខ្ញុំដឹង នារីទាំងនោះ ត្រូវបានគេបញ្ជូនទករស់នៅជាមួយឪពុកម្តាយពួកគេវិញ ក្រោយពីលេងសើចហើយ។ ហើយគេនាំយកមកពួកនាងមកទៀត នៅពេលដែលពួកគេចង់ធ្វើបែបនេះ។ [...] ច្បាស់ជាគេយកនារីទាំងនោះ ក្នុងគោលបំណងសប្បាយហើយ។"]។ ឯកសារ **D5/1015** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជុំ ជិម ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ KH 00990956 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំបានឮសំឡេងមនុស្សស្រែកពេលដែលគេវាយសំលាប់នៅជិតកន្លែងអ្នកទោស។ [...] កងការពារ គេបានចាប់មនុស្សស្រីក្រមុំយកទៅរំលោភរៀងរាល់យប់ និងឮសំឡេងស្រែកដោយធ្វើបានផ្លូវកាយ និងផ្លូវចិត្តគួរឲ្យរន្ធត់ពេកក្រៃ។"]

1066 ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.138-141 KH 01165954-01165955 [សាក្សីគឺជាអ្នកទោស៖ "គាត់ [យាយ ចែម] និយាយថាឲ្យខំបង្កបង្កើនផល ខំកសាងខ្លួន។ គាត់និយាយថា បើអ្នកណាធ្វើខុសខំកសាងខ្លួន ខ្លាចស្លាប់។ [...] ខ្ញុំឮគាត់និយាយ ពេលដែលខ្ញុំធ្វើការនៅជិតនោះ។ គេមិនហៅខ្ញុំមកចូលរួមទេ។ សៈ ពេលដែលលោកឮយាយចែម និយាយ តើលោកឮដោយផ្ទាល់នឹងត្រចៀកតែម្តង? ឆ.141៖ បាទ។"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.68-69 KH 01115779 [សាក្សីគឺជាអ្នកទោស៖ "គាត់ [យាយ ចែម] ឲ្យខំ ធ្វើការ អ្នកណាកសាងខ្លួនបានក៏រស់ ហើយអ្នកណាកសាងខ្លួនមិនបានក៏ស្លាប់។ [...] មានន័យថា យោធាយកទៅសម្លាប់"]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.59 KH 01166963 [សាក្សីគឺជាអ្នកទោស៖ "មេគុកដើរជុំវិញ ហើយនិយាយថា "អ្នកឯងទាំងអស់គ្នាសុទ្ធតែក្បត់ជាតិ"។ ហេតុនេះ យប់នេះ គេនឹងយកទៅលក់ឲ្យចាម"។] ឆ.45 KH 01166961 ["គេថា "យកគោទៅលក់ឲ្យចាម"។]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.24 KH 00895170 [សាក្សីគឺជាអ្នកទោស៖ "តាសឿន បានកោះហៅអ្នកទោសទាំងអស់ប្រហែល៣០០នាក់ឲ្យមកប្រជុំ [...] គាត់បាននិយាយប្រាប់ខ្ញុំថា មិត្តឯងត្រូវធ្វើជាប្រធានអ្នកទោសទាំងអស់ បើបាត់តែម្នាក់ គេនឹងវ៉ៃមិត្តឯងចោល។"]។ ឯកសារ **D219/475** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិ

ត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.19 KH 01134132 [សាក្សីគឺជាអ្នកទោស៖ "ពេលហូបបាយម្តងៗ ពួកខ្មែរក្រហមយកឈើមកដាក់ជិតក្បាលពួកយើង ហើយគេតែងតែនិយាយថា ៤នាក់យើងមិនយូរមិនឆាប់ នឹងទៅជាស្ទួលដីហើយ។ យើងដឹងថា ពួកគេនឹងសម្លាប់យើងមិនយូរឬមិនឆាប់ទេ។"]។ ឯកសារ **D219/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.37 KH 01043241 [សាក្សីគឺជាអ្នកយាមគុក៖ "ស៖ លោកប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរថា អ្នកយាមនៅគុកភ្នំទ្រយោងត្រូវគេអនុញ្ញាតឱ្យបាញ់អ្នកទោសណាដែលព្យាយាមរត់? តើត្រឹមត្រូវដែរឬទេ? ឆ.37៖ បាទ គេប្រាប់ដូច្នេះមែន តែគ្រាន់តែជាការគំរាមទៅលើអ្នកទោសប៉ុណ្ណោះ។"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.36 KH 01049196 [សាក្សីគឺជាអ្នកយាមគុក៖ "ខ្ញុំតែងតែបានប្រាប់ទៅក្រុមម៉ែ១ដែលខ្ញុំបានមើលខុសត្រូវនោះឱ្យពួកគាត់ខំប្រឹងប្រែងធ្វើការ ហើយកុំធ្វើឱ្យមានកំហុសគេចាប់យកទៅសម្លាប់។"]

1067 ឯកសារ **D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.27 KH 00801017 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំនៅចាំថា នៅពេលមួយនោះ គឺមុនពេលវៀតណាមចូលមកដល់ ក្រុមរបស់ខ្ញុំត្រូវបានគេបញ្ជាឱ្យជីកអន្លង់ធំមួយ ហើយកប់សាកសពចំនួនប្រហែលជា៩០នាក់។"] ឆ.29 KH 00801017 ["ដំបូង គេឱ្យពួកយើងជីកងន្លង់ បន្ទាប់មកគេនាំអ្នកទោសមក ហើយសម្លាប់។"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.58-59 KH 00933110 [សាក្សីគឺជាអ្នកទោស៖ "ពេលខ្លះ ខ្ញុំត្រូវបានបញ្ជាឱ្យជីកអន្លង់សម្រាប់សាកសព [É] ខ្ញុំជីកអន្លង់បួនឬប្រាំ ម្តងមួយៗ។"]។ ឯកសារ **D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.31-32 KH 00800984 [សាក្សីគឺជាអ្នកទោស៖ "នៅពេលយប់ អ្នកទោសដែលជាប់ខ្នោះ ត្រូវបានគេបញ្ជូនយកទៅសម្លាប់។ ការសម្លាប់មនុស្សត្រូវបានគេធ្វើឡើងជារៀងរាល់សប្តាហ៍ [É] ជួនកាល អ្នកយាម មិនមានពេលកប់សាកសពទាំងអស់នោះទេ ហើយពួកគេបានបញ្ជាឱ្យក្រុមគ្រពេទ្យរបស់ខ្ញុំទៅជួយកប់សាកសពទាំងនោះ។ មានអ្នកទោសចំនួន២០ ទៅ៣០នាក់ មួយលើកៗ។"]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.20-21 KH 00895170 [សាក្សីគឺជាអ្នកទោស៖ "នៅទីនោះ សាមុន ហើយនិងខ្ញុំ បានឃើញផ្ទាល់ភ្នែកការសម្លាប់មនុស្សចំនួន៧នាក់។ ពួកគេត្រូវបានសម្លាប់ដោយមនុស្សដែលមានគ្នាប្រហែល៣ទៅ៤នាក់ [ខ្មែរក្រហម]។ ក្រោយមក ពួកគេបានបញ្ជាឱ្យខ្ញុំ និងសាមុន លប់ដីកប់សាកសពទាំងនោះឱ្យស្អាត។ គេប្រាប់ខ្ញុំ ឱ្យធ្វើឱ្យស្អាត ទើបអង្គការទុកចិត្ត។ ពេលនោះយោធា បានឈរមើលយើង រហូតដល់ពេលយើងធ្វើរួចរាល់។"]។ ឯកសារ **D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.31 KH 01040789 [សាក្សីគឺជាអ្នកទោស៖ "យោធា៣នាក់ បានមកដោះខ្នោះឱ្យពួកយើង។ ខ្ញុំ និងសាមុន ត្រូវបានយោធាទាំង៣នាក់ប្រើទៅជីកអន្លង់ធំ ដើម្បីកប់សាកសពមនុស្ស៧នាក់។"]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅសាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.34 KH 00894496 [សាក្សីគឺជាអ្នកទោស៖ "ក្រោយពេលគេដោះលែងខ្ញុំឱ្យធ្វើការនៅក្នុងគុក នៅយប់មួយនោះ ខ្ញុំនិងទី ត្រូវបានគេហៅឱ្យទៅកប់សាកសព [É]។ រណ្តៅនោះ ត្រូវបានគេជីករួចហើយ។ សាកសពខ្លះមិនទាន់ស្លាប់មែនទែនទេ ដោយនៅមានកំរើក ហើយចេញខ្យល់ឃ៉ះៗ។ គេបញ្ជាឱ្យខ្ញុំអូសទម្លាក់សាកសពទាំងនោះចូលក្នុងរណ្តៅ។ សាកសពទាំងនោះមិនមានសម្លៀកបំពាក់ទេ គឺសុទ្ធតែស្រាតទាំងអស់ ហើយមានក្មេង ចាស់ មានស្រី

មានប្រុស។ ខ្ញុំត្រូវបានគេប្រើឱ្យកប់សាកសពតែម្តងហ្នឹងទេ ហើយខ្ញុំក៏មិនដឹងពីកន្លែងផ្សេងៗទៀតដែរ។ ក្រោយពេលនោះ ខ្ញុំឈឺគ្រុន ហើយគេក៏លែងឱ្យខ្ញុំទៅកប់សាកសពទៀតដែរ។ ចាប់តាំងពីបានឃើញព្រឹត្តិការណ៍នោះមក ខ្ញុំមានអារម្មណ៍ភ័យតក់ស្លុតរហូតមកដល់សព្វថ្ងៃនេះ។"]។ឯកសារ **D219/95** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.43 KH 01043183 [សាក្សីគឺជាអ្នកទោសដែលកប់សាកសព៖ "ឈ្មោះទី ហើយនិងខ្ញុំ ត្រូវបានគេហៅឱ្យកប់សាកសពអ្នកទោស៧នាក់។"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.102-103 KH 01115782-01147831[សាក្សីគឺជាអ្នកទោស៖ "មានប្អូននាក់ទទួលខុសត្រូវខាងហ្នឹង [កប់សាកសព] [...] ខ្ញុំនៅចាំតែម្នាក់ទេ ឈ្មោះខាំ"]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.74 KH 01166966 [សាក្សីគឺជាអ្នកទោស៖ "គេទុកឱ្យខ្ញុំសែងខ្មោច ខ្ញុំសែងខ្មោច ជីកកប់ខ្មោច និងធ្វើការបានល្អ។ អ្នកដែលសម្លាប់មនុស្សគែអត់កប់ខ្លួនឯងទេ"] ឆ.76 KH 01166966 ["បាទ [ខ្ញុំកប់សាកសព] ជារៀងរាល់ថ្ងៃ ទាំងអ្នកដែលដេកស្លាប់ដោយខ្លួនឯង និងអ្នកដែលត្រូវគេសម្លាប់ក្នុងពេលវ៉ៃថ្ម។ យើងបានយកដែកស័ង្កសីដាក់ខ្សែសែងដោយឈើ។ យើងត្រូវជីករណ្តៅអីផង។ ពួកយើងមិនអាចឈប់បានទេ បើឈប់គេនឹងបាញ់ចោល។ ឆ.80-81 KH 01166967 ["ចំពោះសាកសពដែលខ្ញុំសែងទៅកប់នោះវិញ បើសិនសម្លាប់ម្នាក់ខ្ញុំជីករណ្តៅកប់តែម្នាក់ ប់ស្លាប់ពីរនាក់គឺជីករណ្តៅកប់ជាមួយគ្នា។ ពេលខ្ញុំបើករបបហូបគេមិនឱ្យនៅជិតគេទេ គេឱ្យមនុស្សយកបាយទៅឱ្យពួកខ្ញុំ ព្រោះមានក្លិនស្អុយជាប់ខ្លួនពួកខ្ញុំ។ [...] ពេលខ្ញុំដើរយកសពទៅកប់ ពេលខ្លះយើងចាំមិនបានថាកប់កន្លែងណាខ្លះព្រោះកប់មានមុនមានក្រោយ ហេតុនេះពេលខ្លះដើរធ្លាក់រណ្តៅសពចាស់ផុងត្រឹមក្បាលជង្គង់។"]។ ឯកសារ **D5/998** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ភួង ផៃ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៣ KH 0098610 [សាក្សីគឺជាអ្នកទោស៖ "មួយថ្ងៃ ៣ ទៅ៥នាក់ ក៏ឃើញមិនថាក្មេងៗ ឬចាស់ៗទេដែលស្លាប់នោះ ពួកវាបានចាត់តាំងឱ្យយកកប់ដូចសត្វឆ្កែ ឆ្មា គឺវេទនាណាស់។"]

1068 ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ. 34-35 KH 01058730 -01064154[សាក្សីគឺជាអ្នកទោស៖ "ស្រីៗទាំងនោះ គេឱ្យនៅជាមួយឪពុកម្តាយនៅពេលថ្ងៃ ហើយដល់ពេលគេយក គឺគេទៅចាប់មកនៅពេលយប់ មកដាក់នៅរោងពួកអ្នកយាម ដែលមានចម្ងាយប្រហែល៦០ម៉ែត្រពីរោងខ្ញុំដេក។ ខ្ញុំដឹងថាគេធ្វើបាបនារីទាំងនោះ ដោយសារខ្ញុំឮនាងៗទាំងនោះ ជេរប្រទិចអ្នកយាមថា "បើឯងគង់នឹងសម្លាប់អញ! ចាំបាច់ធ្វើបែបនេះធ្វើអី!"។ ខ្ញុំឮសំឡេងហ៊ោកញ្ជ្រៀវ សើចសប្បាយរបស់ពួកអ្នកយាមទាំងនោះ។ តាមខ្ញុំដឹង នារីទាំងនោះ ត្រូវបានគេបញ្ជូនទទភរស់នៅជាមួយឪពុកម្តាយពួកគេវិញ ក្រោយពីលេងសើចហើយ។ ហើយគេនាំយកមកពួកនាងមកទៀត នៅពេលដែលពួកគេចង់ធ្វើបែបនេះ។ [...] ច្បាស់ជាគេយកនារីទាំងនោះ ក្នុងគោលបំណងសប្បាយហើយ។"]។ ឯកសារ **D5/1015** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជុំ ជិម ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ KH 00990956 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំបានឮសំឡេងមនុស្សស្រែកពេលដែលគេវាយសំលាប់នៅជិតកន្លែងអ្នកទោស។ [...] កងការពារ គេបានចាប់មនុស្សស្រីក្រមុំយកទៅរំលោភរៀងរាល់យប់ និងឮសំឡេងស្រែកដោយធ្វើបានផ្លូវកាយ និងផ្លូវចិត្តគួរឱ្យរន្ធត់ពេកក្រៃ។"]

1069 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.64 KH 00933111 [សាក្សីគឺជាអ្នកទោស៖ "អ្នកទោសមានប្រុសមានស្រី ហើយអ្នកទោសមានសម្លៀកបំពាក់ជាប់ខ្លួន ចំណែកអ្នកទោសស្រីគ្មានសម្លៀកបំពាក់ទេ។"] សូមមើលផងដែរ ឯកសារ **D5/1252** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អឿ លឿ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036277 [សាក្សីគឺជាអ្នកទោស៖ "នៅការដ្ឋានភ្នំទ្រយោងនេះ មុននឹងឈ្លបសម្លាប់អ្នកទោស វាឲ្យអ្នកទោសយកបង្វិចខោអាវទុកមួយកន្លែង ប្រុសឲ្យដោះអាវ ទុកតែខោខ្លី ឬវែង ឯស្ត្រីដោះអាវវែងឬខ្លី ទុកតែអាវទ្រនាប់"]។ ឯកសារ **D119/137** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិត អៀក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.44-48 KH 01003861-01003862 [សាក្សីធ្វើការនៅក្នុងកសេដ្ឋកិច្ចនៅភ្នំលៀប៖ "នៅពេលនោះ [បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ] ខ្ញុំបានទៅរកឈើនៅទីនោះ ពីព្រោះនៅទីនោះ គេមានធ្វើរោងឈើ ដូច្នេះហើយ យើងមានគោលបំណងទៅ រុះយកឈើ... [...] នៅពេលនោះ លលាដ៏ក្បាលបាននៅរាយប៉ាយនៅបរិវេណនោះ។ [...] ជួនកាលខ្ញុំឃើញមានឆ្អឹងនៅរាយប៉ាយមិនមានសម្លៀកបំពាក់នៅជាមួយទេ។"]

1070 ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភូន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.31 KH 00895172 [សាក្សីគឺជាអ្នកទោស៖ "យោធាម្នាក់ឈ្មោះ សល់ [...]ដែលជាអ្នកយាម បានលួចប្រាប់ខ្ញុំថា ក្នុងមួយយប់យ៉ាងហោចណាស់ក៏មានអ្នកទោសពី៣០ទៅ៥០នាក់ ត្រូវបានគេសម្លាប់។ អាចមានមនុស្សរាប់ម៉ឺននាក់ស្លាប់នៅទីនោះ"]។ ឯកសារ **D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភូន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.48 KH 01040791 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំនិយាយដូច្នេះ ពីព្រោះខ្ញុំសន្និដ្ឋានតាមសំដីដែលសល់ បានប្រាប់ខ្ញុំថាមានមនុស្សស្លាប់ពី៣០ទៅ៥០នាក់ ហើយក្នុងរយៈពេលដែលខ្ញុំជាប់នៅទីនោះ គឺមនុស្សប្រហែលរាប់ម៉ឺននាក់បានស្លាប់នៅទីនោះ។"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.54 KH 01049200 [សាក្សីគឺជាអ្នកយាមគុក៖ "បើតាមខ្ញុំស្មាន អ្នកដែលស្លាប់ មានចំនួនប្រហែល៥ពាន់ និង១ម៉ឺននាក់ប៉ុណ្ណោះ ដែលពួកគេភាគច្រើនស្លាប់ដោយសារជំងឺ អត់អាហារ ហើយប្រហែលជាស្លាប់ដោយសារយោធាសម្លាប់ ប៉ុន្តែខ្ញុំមិនដឹងចំនួនអ្នកទិសប៉ុន្មាននាក់ទេដែលយោធាបានសម្លាប់ទេ។ បើសិនជាអ្នកទោសត្រូវបានគេសម្លាប់ ចំនួនពី៣០ទៅ៥០នាក់ក្នុងមួយយប់ៗ ហើយមន្ទីរសន្តិសុខភ្នំ ទ្រយោងនេះត្រូវបានបង្កើតឡើងជាងមួយឆ្នាំ ខ្ញុំគិតថា ចំនួន៥ពាន់នាក់ និង១ម៉ឺននាក់ គឺជាចំនួនសមរម្យ ហើយ។"]។ ឯកសារ **D119/50.2** របាយការណ៍របស់ការិយាល័យឃោសនាការស្រុកព្រះនេត្រព្រះស្តីពីបញ្ជីប្រាសាទបុរាណ អដ្ឋិធាតុ និងសិល្បៈមហាជន ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH 00933219 ["ភ្នំ ទ្រយោង - វាយចោល - ២០.០០០ នាក់"]។ ***សូមមើលផងដែរ*** ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.69 KH 01115779 [សាក្សីគឺជាអ្នកទោស៖ "គេសម្លាប់ឲ្យស្រឡះអស់។ ពេលស្រឡះហើយ គេដាក់មនុស្សថ្មីមកពេញទៀត។"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.58-59 KH 00933110 [សាក្សីគឺជាអ្នកទោស៖ "មាន អ្នកទោសដែលគេយកទៅសម្លាប់រៀងរាល់យប់ ប៉ុន្តែខ្ញុំមិនដឹងថាមានប៉ុន្មាននាក់នោះទេ។ មានពេលខ្លះគេបានឲ្យខ្ញុំទៅជយយជីករណ្តៅដើម្បីដាក់ខ្មោចថែមទៀតផង [É] ខ្ញុំជីករណ្តៅប្រហែលបួនប្រាំដង ក្នុងម្តងប្រហែលជាមួយរណ្តៅប៉ុណ្ណោះ"]។ ឯកសារ **D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.16 KH 00800981[សាក្សីគឺជាអ្នក

ទោសៈ "តែនៅពេលខ្ញុំទៅដល់ទីនោះ ខ្ញុំឃើញមនុស្សជាច្រើនត្រូវបានគេយកទៅសម្លាប់។"]។ ឯកសារ **D219/94** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.60 KH 01043167 [សាក្សីគឺជាអ្នកទោស ៖ "ខ្ញុំមិនដែលឃើញគេសម្លាប់ផ្ទាល់ភ្នែកទេ ពេលគេដាស់ខ្ញុំឱ្យទៅកប់ អ្នកទោសទាំងនោះ គឺគេសម្លាប់រួចរាល់ហើយ ហើយខ្ញុំទៅគ្រាន់តែកប់សាកសពទាំងនោះទេ។"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោសៈ "ជួនកាលយប់ឡើងគេចងអ្នកទោសទាំងនោះជាខ្សែយកទៅសម្លាប់ ប៉ុន្តែមិនដឹងប៉ុន្មាននាក់នោះទេ ហើយក៏មិនដឹងគេយកទៅសម្លាប់នៅកន្លែងដែរ ព្រោះភ័យពេក ដូច្នេះខ្ញុំបានរត់ពួន។"]។

1071 ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045326 [OCIJ-068 (ទុំ សឿន - មេគុក)៖ "មិនអាចទៅរួចទេ។ ការសម្លាប់ណាមួយ ត្រូវមានការជូនដំណឹងពីខ្ញុំ។"] KH 01045318 ["ខ្ញុំចាំថាមានអ្នកទោសធ្ងន់៤នាក់ ត្រូវបានគេវាយធ្វើបាបមុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំទ្រយោង។ [...] ហើយធ្វើទុក្ខខ្លាំង មិនអាចព្យាបាលបាន។ យាយថែម បានបញ្ជាឱ្យខ្ញុំសម្លាប់អ្នកទាំង៤នោះទៅ។"]។ ឯកសារ **D106/6** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.35-36 KH 00800984 [សាក្សីគឺជាអ្នកទោសៈ "បាទ គឺតាសឿន ជាអ្នកបញ្ជាឱ្យយកមនុស្សទៅសម្លាប់នៅពេលយប់ [...] គាត់ទទួលបញ្ជាពីថ្នាក់លើ"] ឆ.39 KH 00800985 ["តាសឿន បានភ្ញាក់ ដោយសារតែផ្ទះរបស់គាត់នៅក្បែរកន្លែងខ្ញុំស្នាក់នៅដែរ ហើយគាត់បានស្ដីបន្ទោសអ្នកយាមថា ហេតុអ្វីមកដាស់ពួកពេទ្យឱ្យជួយកប់សាកសព ព្រោះមិនមែនជាការងាររបស់គេទេ"]។ ឯកសារ **D219/94** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤, ឆ.64-65 KH 01043168 [សាក្សីគឺជាអ្នកទោសៈ "សៈ តើលោកកប់សាកសពអ្នកទោសនោះនៅឯណាដែរ? ឆ.64៖ នៅភ្នំ ទ្រយោងដែរ ប្រហែលជា ២០ម៉ែត្រពីកន្លែងខ្ញុំដេក គឺនៅក្នុងព្រៃ។ សៈ ចុះកន្លែងលោកដេកនៅឯណា? ឆ.65៖ កន្លែងខ្ញុំដេកនៅជិតកន្លែងតាសឿនស្នាក់នៅ"], ឆ.73-74 KH 01043170 [សាក្សីគឺជាអ្នកទោសៈ "សៈ តើលោកឮតាសឿន បញ្ជាឱ្យសម្លាប់អ្នកទោសចំនួនប៉ុន្មានដងដែរ? ឆ.73៖ ខ្ញុំឮតែម្ដងទេ នៅពេលដែល [...] ឮគាត់និយាយជាមួយឈ្លប នៅពេលគេដាស់ខ្ញុំឱ្យទៅជួយកប់សាកសព។"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.62 KH 00933110 [សាក្សីគឺជាអ្នកទោសៈ "តាសឿនជាអ្នកបញ្ជាឱ្យសម្លាប់ ហើយមានយោធា៣០នាក់ជាអ្នករើសម្លាប់អ្នកទោសទាំងនោះ"] សូមមើលផងដែរ ឯកសារ **D219/103** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.48-49 KH 01043242 [សាក្សី គឺជាអ្នកយាមគុកៈ "ខ្លះនៅខាងជើងភ្នំត្រយ៉ង។ សៈ តើមានចម្ងាយប៉ុន្មានពីផ្ទះដែលលោកបានឃើញទៅខ្ទមរបស់តាសឿន? ឆ.49៖ មានចម្ងាយប្រហែលជា១០០ទៅ២០០ម៉ែត្រ។"]។ ឯកសារ **D219/95** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.9 KH 01043178 [សាក្សីគឺជាអ្នកទោសៈ "[ទៅកន្លែងកប់សព] មានចម្ងាយប្រហែលជា១០០ ទៅ២០០ម៉ែត្រដែរ [ពីផ្ទះរបស់តាសឿន]"។ ឯកសារ **D219/127** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.55 KH 01049200 [សាក្សី គឺជាអ្នកយាមគុកៈ "បាទ ខ្ញុំដឹង។ ភាគច្រើនគេកប់នៅពីរកន្លែង កន្លែងទី១ គឺនៅប៉ែកពាយព្យ នៅចន្លោះភ្នំទ្រយោង និងភ្នំលាប គឺនៅ

ហួសកន្លែងដែលអ្នកទោសស្រាលស្នាក់នៅបន្តិច ហើយកន្លែងទី២ គឺនៅខាងជើងភ្នំទ្រយោង ឆ្ងាយពីកន្លែងដែលតាសឿន និងពួកយើងស្នាក់នៅបន្តិច។”]

1072 ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045318 [OCIJ-068 (ទុំ សឿន - មេគុក)៖ [“ខ្ញុំចាំថាមានអ្នកទោសធ្ងន់៤នាក់ ត្រូវបានគេវាយធ្វើបាបមុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំទ្រយោង។ [...] ហើយធ្វើទុក្ខខ្លាំង មិនអាចព្យាបាលបាន។ យាយចែម បានបញ្ជាឱ្យខ្ញុំសម្លាប់អ្នកទាំង៤នោះទៅ។ ខ្ញុំបញ្ជាអ្នកយាមឱ្យសម្លាប់ពួកគេ។”] KH 01045304 [សាក្សីគឺជាមេគុក៖ “ខ្ញុំពុំធ្លាប់ទទួលសំបុត្រមួយពីថ្នាក់ណាខ្ពស់ជាងយាយចែមនោះទេ។”]។ *សូមមើលផងដែរ* ឯកសារ **D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.17-18 KH 00800981 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំត្រូវបានក្មេងស្រីជាពេទ្យពីរនាក់បណ្តើរ ដោយមានអូសចបតាមផង ដែលខ្ញុំដឹងថា ពួកគេប្រាកដជានឹងសម្លាប់ខ្ញុំមិនខាន។ នៅពេលនោះ ម្តាយខ្ញុំនៅរស់នៅឡើយ ហើយគាត់ស្រឡាញ់ខ្ញុំណាស់។ គាត់បានទៅជួបចែម សុំទុកជីវិតរបស់ខ្ញុំ។ [...] គេអាចទៅជួបចែមផ្ទាល់បាន។ នៅពេលនោះ ក្មេងស្រីពេទ្យពីរនាក់នោះរៀបនឹងសម្លាប់ខ្ញុំទៅហើយ តែតាសឿន ដែលជាប្រធានមន្ទីរសន្តិសុខ បានមកសួរខ្ញុំ”] ឆ.35-36 KH 00800984 [“តាសឿន ជាអ្នកបញ្ជាឱ្យសម្លាប់មនុស្សនៅពេលយប់ [...] គាត់បានទទួលបញ្ជាពីថ្នាក់លើ”]។ ឯកសារ **D85/4.1.5** ប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់ ក.ស.ច.ស ជាមួយ ប៉ោ បណ្តែត ពុំមានចុះកាលបរិច្ឆេទ KH 00802522 [សាក្សីត្រូវបានចាត់ឱ្យធ្វើជាប្រធានក្រុមនៅព្រះនេត្រព្រះ ក្នុងឆ្នាំ ១៩៧៧៖ “ឆ.៖ ខ្ញុំបានឮ [ឮដោយផ្ទាល់ អ៊ឹម ចែម បញ្ជាឱ្យយកមនុស្សទៅសម្លាប់”]។ ឯកសារ **D5/1252** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អឿ សឿ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036277 [សាក្សីគឺជាអ្នកទោស៖ “នៅពេលនោះ ប្រធានកង ដែលបានបញ្ជាឱ្យសម្លាប់ គឺមិត្តចែម។”]

1073 ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នា ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 0105325 [OCIJ-068 (ទុំ សឿន - មេគុក)៖ “មិនអាចទៅរួចទេ។ ការសម្លាប់អ្នកណាមួយ ត្រូវមានការជូនដំណឹងពីខ្ញុំ។”] KH 01045318 [“ខ្ញុំចាំថាមានអ្នកទោសធ្ងន់៤នាក់ ត្រូវបានគេវាយធ្វើបាបមុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំទ្រយោង។ [...] ហើយធ្វើទុក្ខខ្លាំង មិនអាចព្យាបាលបាន។ យាយចែម បានបញ្ជាឱ្យខ្ញុំសម្លាប់អ្នកទាំង៤នោះទៅ។ ខ្ញុំបញ្ជាអ្នកយាមឱ្យសម្លាប់ពួកគេ។”]

1074 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.58-59 KH 00933110 [សាក្សីគឺជាអ្នកទោស៖ “មានអ្នកទោសដែលគេយកទៅសម្លាប់រៀងរាល់យប់ [...] ខ្ញុំជីក រណ្តៅប្រហែលបួនប្រាំដង ក្នុងម្តងប្រហែលជាមួយរណ្តៅប៉ុណ្ណោះ”]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.75 KH 01115779 [សាក្សីគឺជាអ្នកទោស៖ “គេវ៉ៃចោល ហើយស្លាប់រាល់ថ្ងៃដែរ។”] ឆ.99-101 KH 01115782 [“រៀងរាល់យប់. [...] បួនទៅប្រាំនាក់ ថ្ងៃខ្លះ១០នាក់។ ខ្ញុំនៅកន្លែងដេកហ្នឹងមិនឆ្ងាយពីកន្លែងដែលគេយកអ្នកទោសទៅសម្លាប់ ទើបខ្ញុំឮ។”]។ ឯកសារ **D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.32 KH 01058768 [សាក្សីគឺជាអ្នកទោស៖ “ខ្ញុំអាចសន្និដ្ឋានបានថា អ្នកទោសនៅទៅនោះត្រូវបានគេយកទៅសម្លាប់រាល់យប់ ព្រោះក្រោយពេលអ្នកយាមនៅទីនោះមកសម្លាប់វិញ ចបរបស់គេតែងតែប្រឡាក់សុទ្ធតែឈាម។ [...] ខ្ញុំបានឮពួកអ្នកយាមដែលមានគ្នាបួនប្រាំនាក់ អួតគ្នាថា យប់មិ

ញអញបានសម្លាប់ពីរ ឬបីនាក់។ ចំពោះអ្នកយាមថ្មីៗ ពេលត្រឡប់មកវិញ ខ្ញុំឃើញពួកគេមានការភ័យខ្លាច និងរន្ធត់យ៉ាងខ្លាំង។"]។ ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.119 KH 01104654 [សាក្សីគឺជាអ្នកទោស៖ "កើតឡើងរាល់ថ្ងៃ ពីព្រោះសាកសពត្រូវបានដុតជារៀងរាល់ថ្ងៃ។"]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.75 KH 01166966 [សាក្សីគឺជា អ្នកទោស៖ "ពេលខ្ញុំសែងខ្មោចទៅកប់ គឺជាខ្មោចដែលគេសម្លាប់នៅកន្លែងធ្វើការដោយគេចោទថាខ្ជិល ធ្វើការមួយថ្ងៃ មាន៧ ទៅ៨នាក់។" [...] បាទ គឺជារៀងរាល់ថ្ងៃ [ខ្ញុំកប់សាកសព] ទាំងអ្នកដែលដេកស្លាប់ដោយខ្លួនឯង និងអ្នកដែលត្រូវគេសម្លាប់ក្នុងពេលវេលថ្ងៃ។"]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.31 KH 00895172 [សាក្សីគឺជាអ្នកទោស៖ "យោធាម្នាក់ឈ្មោះសល់ [É] ដែលជាអ្នកយាម បានលួចប្រាប់ខ្ញុំថា ក្នុងមួយយប់ យ៉ាងហោចណាស់អ្នកទោសពី៣០ទៅ៥០នាក់ ត្រូវបានសម្លាប់។"]។ ឯកសារ **D101/1.2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តោ ពិនថង ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១១ KH 0074550 [សាក្សីគឺជាអ្នកទោស៖ "ដល់ពេលយប់ [អ្នកទោស] គេយកទៅវាយចោល អាត្មាប៉ានមានសង្ឃដីកាដូចនេះព្រោះអាត្មាដឹងថាឲ្យតែគេយកទៅគឺបាត់តែម្តង។"]។ ឯកសារ **D5/1075** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តោ ពិនថង ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 0022736 [សាក្សីគឺជាអ្នកទោស៖ "ពេលយប់ពួកទាហានតែងតែយកអ្នកទោសទៅសម្លាប់។"]។ ឯកសារ **D219/211** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀន ចាន់រី ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.18 KH 01074054 [សាក្សីគឺជាប្អូនស្រីរបស់អ្នកទោស៖ "គាត់បាននិយាយប្រាប់ថា គាត់បានឃើញគេយកមនុស្សទៅសម្លាប់ជារៀងរាល់ថ្ងៃ ទោះបីជាមនុស្សទាំងនោះ មានកំហុសបន្តិចបន្តួចក៏ដោយ។"]។ ឯកសារ **D5/1100** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពេជ្រ រស់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ KH 01025793 [សាក្សីបានឃើញអ្នកភូមិក្បែរនោះឃ្វាលគោនៅជិតភ្នំត្រយ៉ង៖ "ខ្ញុំបានទៅនៅត្នូរនៅអូរលៀបខាងកើតភ្នំលៀប ឃើញយោធាចងបណ្តើរយកមកវាយចោលតាមជើងភ្នំទ្រយង ដែលមាន១៥នាក់ទៅ២០នាក់ជារៀងរាល់យប់។"]។ ឯកសារ **D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.35-36 KH 00978923-00978924 [សាក្សីធ្វើការនៅកងចល័ត និងឃ្វាលគោនៅភ្នំលៀប៖ នៅកន្លែងគ្រប់គ្រងរបស់យាយចែមនៅភ្នំលៀប ការចាប់ និងការសម្លាប់មានការកើនឡើង ពីព្រោះមានមនុស្សជាច្រើនត្រូវបានចាប់បណ្តើរមកទាំងខ្សែៗ យកមកដាក់នៅកន្លែងយាយចែមនៅភ្នំលៀប។"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ. 31 KH 01058730 [សាក្សីគឺជាអ្នកទោស៖ "តាមពិត គេពុំយកអ្នកទោសទៅសម្លាប់រាល់យប់នោះទេ គឺអាចពីរបីយប់ម្តង ហើយម្តងៗប្រហែល២០នាក់។ គេយកអ្នកទោសចាស់ៗទៅសម្លាប់ នៅពេលដែលគេយកអ្នកទោសថ្មីៗមកដាក់ក្នុងរោងដែលខ្ញុំបានជាប់ខ្នោះនៅទៅនោះរយៈពេល២ខែ។ អ្នកទោសដែលគេត្រូវយកទៅសម្លាប់ នៅពេលដែលគេយកអ្នកទោសថ្មីៗមកដាក់ក្នុងរោងដែលខ្ញុំធ្លាប់ជាប់ខ្នោះនោះ ទៅដាក់ក្នុងរោងហាប់ដែលមានទីតាំងក្បែររោងខ្ញុំដេកនៅដែរ។ គេដាក់អ្នកទោសទាំងនោះក្នុងរោងហាប់ទាំងជាប់ចំណង នៅពេលដែលចេញមកនោមនៅក្បែរៗនោះ នៅពេលថ្ងៃ ហើយឃើញពួកគេ។ ខ្ញុំដឹងថាគេយកអ្នកទោសនោះទៅសម្លាប់ ដោយសារក្រោយពីគេយកអ្នកទោសនោះទៅបាត់ អ្នកយាមតែងតែនាំយកមកវិញនូវខ្សែដែលគេចងអ្នកទោសដាក់ក្នុងបាវហើយទុកនៅក្បែររោងខ្ញុំដេកដែរនៅព្រឹក បន្ទាប់។"] ឆ.38 KH 01058731 ["ខ្ញុំមិនអាចប៉ាន់

ស្ថានចំនួនទេ ប៉ុន្តែក្នុងរយៈពេលដែលខ្ញុំជាប់គុក និងធ្វើការនៅទីនោះ គេយកមនុស្ស១៥ទៅ២០នាក់ ទៅសម្លាប់ជារៀងរាល់ពីរបីថ្ងៃម្តង។"]។ ឯកសារ **D119/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដួង វ័ន្តឌី ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.6-7 KH 00933098 [សាក្សីគឺជាអ្នករស់នៅភ្នំលៀប៖ "នៅពេលដែលពួកនិរតីបានមកដល់ ខ្ញុំបានឃើញប្រជាជនត្រូវបានគេចងទាំងខ្សែ១បញ្ជូនទៅសម្លាប់នៅកន្លែងមួយដែលស្ថិតនៅខាងជើងភ្នំទ្រយោង។ អ្នកទោសដែលបញ្ជូនទៅសម្លាប់ត្រូវបានគេទុកនៅក្នុងផ្ទះមួយនៅក្បែរកន្លែងខ្ញុំធ្វើការ ដែលមានចម្ងាយប្រហែល៧០០ម៉ែត្រពីផ្ទះយាយថែម។ អ្នកទោសទាំងនោះ ត្រូវបានគេយកទៅដាក់នៅពេលថ្ងៃ ទើបគេយកសម្លាប់ពេលយប់ [...]ព្រឹត្តិការណ៍នេះកើតឡើង១អាទិត្យម្តង គឺចាប់តាំងពីដើមរហូតដល់ចុងរបបខ្មែរក្រហម។ ខ្ញុំសង្កេតឃើញថាក្នុងម្តង១ គេយលមនុស្ស ច្រើនជាង១០នាក់ទៅសម្លាប់។ [É] ក្រោយរបបខ្មែរក្រហម ខ្ញុំបានទៅមើលកន្លែងសម្លាប់នោះ ឃើញសុទ្ធតែលលាដ៍ និងឆ្អឹងខ្មោចគរលើគ្នា។"] *ផ្ទុយទឹង* ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.36 KH 01049196 [សាក្សីគឺជាអ្នកយាមគុក៖ "ស៖ តើលោកនៅចាំថាលោកមានធ្លាប់បាននិយាយប្រាប់អ្នកទោសណាម្នាក់អំពីចំនួនអ្នកទោសដែលត្រូវបានគេបញ្ចេញយកទៅសម្លាប់រៀងរាល់យប់នោះដែរឬទេ? ឆ.36៖ ទេ ខ្ញុំមិនចាំទេ។"] ឆ.43 KH 01049198 [ស៖ សាក្សី ភួន ស៊ុនទី បានស្បថនៅចំពោះមុខចៅក្រម ហើយគាត់បាននិយាយថា លោកបានប្រាប់គាត់ថា គេយកមនុស្សពី៣០ទៅ៥០នាក់ទៅសម្លាប់ជារៀងរាល់ថ្ងៃ។ តើលោកគិតថាសាក្សី ភួន ស៊ុនទី និយាយកុហកចៅក្រមដែរទេ? ឆ.43៖ ខ្ញុំមិនមានយោបល់អ្វីទេ។"]។

1075 ឯកសារ **D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.31 KH 01040789 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំ និងសាមុន ត្រូវបានយោធាទាំង៣នាក់នោះ ប្រើទៅជីកអន្លង់ធំដើម្បីកប់សាកសពមនុស្ស៧នាក់។"] ឆ.34-35 KH 01040789 ["គឺមានចម្ងាយ៣០០ ទៅ៥០០ម៉ែត្រ ពីកន្លែងដែលគេបានដាក់ខ្នោះខ្ញុំ គឺស្ថិតនៅទិសពាយ័ព្យ ឆ្ពោះទៅកាន់ផ្លូវជាតិលេខ៦ [...] ស្ថិតនៅក្នុងព្រៃរបោះនៅក្បែរជើងភ្នំទ្រយោង"]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.20-21 KH 00895170 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំដឹងថា កន្លែងសម្លាប់មនុស្សនិងកប់សាកសពស្ថិតនៅខាងជើងឈាងខាងលិចភ្នំទ្រយោង ហើយនេះជាកន្លែងដែលខ្ញុំបានជីកនិងកប់សាកសព ដែលខ្ញុំបានឃើញគេ សម្លាប់។"]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅសាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.34-35 KH 00894496 [សាក្សីគឺជាអ្នកទោស៖ "យប់មួយនោះ ខ្ញុំ និង ទី [ភួន ស៊ុនទី] ត្រូវបានគេហៅឲ្យទៅកប់សាកសព [...]។ គេបញ្ជាឲ្យខ្ញុំអូសទម្លាក់សាកសពទាំងនោះចូលក្នុងរណ្តៅ [É] មិននៅឆ្ងាយទេ គឺនៅប្រហែល១០០ទៅ២០០ម៉ែត្រ ពីកន្លែងខ្ញុំស្នាក់នៅ។ ទីតាំងនោះនៅខាងជើងភ្នំ ក្នុងទិសដៅទៅច្រកចូលពីផ្លូវជាតិលេខ៦ ហើយនៅខាងលិចផ្លូវរលំ គឺជាព្រៃរបោះ។"]។ ឯកសារ **D219/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.64-65 KH 01043168 [សាក្សីគឺជាអ្នកទោស៖ "ស៖ តើលោកកប់សាកសពអ្នកទោសនោះនៅឯណាដែរ? ឆ.64៖ នៅភ្នំទ្រយោងដែរ ប្រហែលជា២០ម៉ែត្រពីកន្លែងខ្ញុំដេក គនៅក្នុងព្រៃ។ ឆ.៖ ចុះកន្លែងលោកដេកនៅឯណា? ឆ.65៖ កន្លែងខ្ញុំដេកនៅជិតកន្លែងតាសឿន ស្នាក់នៅ។"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.55 KH 01049200 ឆ.55 KH 01049200 [សាក្សី គឺជាអ្នកយាមគុក៖ "បាទ ខ្ញុំដឹង។ ភាគច្រើនគេកប់នៅពីរកន្លែង កន្លែងទី១ គឺនៅប៉ែកពាយព្យ នៅចន្លោះភ្នំទ្រយោង និងភ្នំលាប គឺនៅហួសកន្លែង

ដែលអ្នកទោសស្រាលស្នាក់នៅបន្ទិច ហើយកន្លែងទី២ គឺនៅខាងជើងភ្នំទ្រយោង ឆ្ងាយពីកន្លែងដែលតាសឿន និងពួកយើងស្នាក់នៅបន្តិច។"]។ ឯកសារ D219/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ. 48-49 KH 01043243 [សាក្សី គឺជាអ្នកយាមគុក៖ "ខ្លះនៅខាងជើងភ្នំត្រយ៉ង។ ស. តើមានចម្ងាយប៉ុន្មានពីផ្ទះដែលលោកបានឃើញទៅខ្មូមរបស់តាសឿន? ឆ. 49. មានចម្ងាយប្រហែលជា១០០ទៅ២០០ម៉ែត្រ។"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ. 162 KH 0115788 [សាក្សីគឺជាអ្នកទោស៖ "នៅភ្នំទ្រយោង នៅឥសាន្តភ្នំ។ គេមានរណ្តៅគេ។"] ឆ.164 KH 0115788 ["នៅពេលចប់ហើយ ខ្ញុំចុះទៅ មានរណ្តៅពីរ តែឆ្អឹងអីហ្នឹង គេរើយសអស់ហើយ។"]។ ឯកសារ **D119/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.37 KH 00933125 [សាក្សីគឺជាអ្នកទោស៖ "នៅពេលដែលខ្ញុំដើរទៅជីកដំឡូង ទើបខ្ញុំបានឃើញរណ្តៅសាកសពនៅខាងជើងភ្នំ ហើយខ្ញុំបានឡើងទៅថ្មអើតមើលរណ្តៅនោះ។"]។ ឯកសារ **D1.3.11.43** កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ រិន ខេង ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ EN 00210494 [សាក្សីគឺជាអ្នកទោស៖ "កន្លែងឃុំឃាំងនៅខាងកើតភ្នំ ហើយកន្លែងសម្លាប់នៅខាងជើងភ្នំ ដូច្នេះខ្ញុំពុំបានឃើញពួកគេធ្វើអ្វីទេ។"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.29 KH 01085126 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំក៏នាំកូនរត់។ កាលនោះគេជីកស្រះបម្រុងនឹងវាយពួកខ្ញុំចោល។"] ឆ.42 KH 01085127 ["ស៖ លោកស្រីបាននិយាយថា ដោយសារតែវៀតណាមចូលស្រុកធ្វើឱ្យលោកស្រីរត់រួច ហើយពេលនោះឈ្មោះសឿន បានបញ្ជាឱ្យគេជីកស្រះរួចហើយ បម្រុងនឹងសម្លាប់អ្នកទោសនៅទីនោះ។ តើលោកស្រីបានឃើញស្រះនោះទេ? ហើយស្រះនោះនៅទីណា? ចាស ខ្ញុំបានឃើញស្រះនោះ។ ស្រះនោះស្ថិតនៅខាងជើងភ្នំក្បែរកន្លែងខ្ញុំរស់នៅ។ ស្រះនោះ មានទំហំ៥០ម៉ែត្រ បួនជ្រុង មានជម្រៅ ជ្រៅលិចក្បាលមនុស្ស ប្រហែល២ម៉ែត្រ។ ពួកគេបានឱ្យខ្ញុំ និងអ្នកទោសផ្សេងទៀត ជីកស្រះ ប៉ុន្តែពួកខ្ញុំមិនដឹងថាគេឱ្យពួកខ្ញុំជីកស្រះនោះធ្វើអ្វីនោះទេ នៅពេលដែលខ្ញុំសួរពួកគេ គេបានប្រាប់ថា ជីកស្រះសម្រាប់ស្តុកទឹកប្រើប្រាស់។"]។ ឯកសារ **D219/475** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អិត ហល់ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ឆ.21 KH 01134132 [សាក្សីគឺជាអ្នកទោស៖ គ្រាមួយពេលដែលគេឱ្យយើងគាស់ថ្ម ខ្ញុំបានឃើញសាកសពជាច្រើនដែលគេកប់បានតែពាក់កណ្តាលខ្លួននៅខាងជើងភ្នំ ទ្រយោង។ ខ្ញុំមិនអាចប្រាប់បានថាមានសាកសពប៉ុន្មានទេ ព្រោះមានច្រើនណាស់។ ខ្ញុំមិនដែលបានទៅទីនោះម្តងទៀតទេ។"]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.75 KH 01166966 [សាក្សីគឺជាអ្នកទោស៖ "ចំពោះអ្នកដែលគេសម្លាប់៨០០ ទៅ ១០០០នាក់ក្នុងពេលតែមួយ គេបោះចូលទៅក្នុងស្រះមួយដោយអត់កប់ទេ ក្លិនស្អុយពាសពេញទៅទីនោះ។"] ឆ.78-80 KH 01166966-01179864 ["ស្រះនោះស្ថិតនៅខាងជើងទ្រយោងជិតថ្នល់ជាតិ ពីព្រោះដូចខ្ញុំនិយាយហើយថា គុកនោះនៅមិនឆ្ងាយពីថ្នល់ជាតិទេ ហើយស្រះនោះគឺនៅក្បែរគុកនោះឯងប្រហែល៥០ម៉ែត្រ ទៅ១០០ម៉ែត្រពីគុក។ ស៖ រណ្តៅដែលលោកយកសពទៅកប់នោះ តើនៅកន្លែណាដែរ? [É] នៅខាងលិចស្រះ ប្រហែល១០០ ទៅ២០០ម៉ែត្រ។"]។ ឯកសារ **D119/159** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង រ៉ុង ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.53 KH 01025132 [សាក្សី គឺជាអ្នកទោសធ្ងន់៖ "នៅកន្លែងដែលគេឱ្យខ្ញុំកាប់ឫស្សី ខ្ញុំមិនឃើញមានរណ្តៅសាកសព ឬក៏ធុំក្លិនស្អុយនោះទេ។ ខ្ញុំដឹងថាអ្នកទោសដែលស្លាប់ត្រូវបានគេសែងចេញឆ្ពោះទៅទិសខាងជើងមន្ទីរសន្តិសុខទ្រយោង។"]។ ឯកសារ **D119/137** កំណត់ហេតុនៃការ

ស្តាប់ចម្លើយសាក្សី អ៊ិត អៀក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.44-45 KH 01003861 [សាក្សីគឺជាអ្នកភូមិនៅក្បែរនោះ៖ "នៅពេលនោះ [ក្រោយរបបខ្មែរក្រហម] ខ្ញុំបានទៅរកឈើរនៅទីនោះ។ [...] ខ្ញុំក៏បានឃើញកន្លែងកប់សាកសពជាច្រើននៅកន្លែងនោះផងដែរ ប៉ុន្តែកន្លែងកប់សាកសពនោះ មិនមែនសុទ្ធជាកន្លែងកប់សាកសពដែលគេបានសម្លាប់នៅភ្នំ ទ្រយោងនោះទេ ប៉ុន្តែជាកន្លែងកប់សាកសពមនុស្សដែលស្លាប់ដោយសារការអត់អាហារ និងជំងឺផងដែរ។ [É] កន្លែងកប់សាកសពនោះ មានទំហំប្រហែលជាបួនទៅប្រាំហិកតា ដែលនៅខាងជើងជាប់នឹងភ្នំទ្រយោង។"]។ ឯកសារ D219/433 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.23 KH 01124146 [សាក្សី បានកាប់ព្រៃនៅភ្នំត្រយ៉ង៖ "ខ្ញុំឃើញតែសាកសពប៉ុណ្ណោះ។ ថ្ងៃខ្លះនៅតាមជើងភ្នំ ខ្ញុំឃើញមានសាកសពថ្មី ផ្នូរខ្មោច និងឈើរជ្រុងដែលប្រឡាក់ឈាម។ សាកសព និងផ្នូរត្រូវគេធ្វើដាក់ជាជួរជុំឡុងអ៊ីចឹង ហើយកន្លែងនេះស្ថិតនៅខាងលិចភ្នំលៀប ខាងជើងភ្នំទ្រយោង។ ជួនកាលពីល្ងាចមិនឃើញមានអីទេ តែពេលព្រឹកឡើងទៅធ្វើការ ខ្ញុំឃើញសាកសពថ្មីៗនៅទីនោះ។ អ្នកអត់បាយស្លាប់ អ្នកដែលត្រូវគេវ៉ៃសម្លាប់អី គឺ គេយកទៅដាក់នៅទីនោះទាំងអស់។"]។ ឯកសារ **D106/18** របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919482 ["រោងដាក់អ្នកទោសធ្ងន់ និងអ្នកយាមសន្តិសុខ និងទីតាំងរណ្តៅរួម៖ ចាប់ផ្តើម N13 35.396' - E103 21. 065' បញ្ចប់ N 13.35.688' - E 103.21.1 07' / ទីតាំងរណ្តៅផ្សេងទៀតនៃសពរួម៖ ចាប់ផ្តើម N 13.35.363' - E 103.21.058' បញ្ចប់ N 13.35.483' - E 103.21.1 00'"]។

1076 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.58-59 KH 00933110 [សាក្សីគឺជាអ្នកទោស៖ "មានអ្នកទោសដែលគេយកទៅសម្លាប់រៀងរាល់យប់ ប៉ុន្តែខ្ញុំមិនដឹងថាមានប៉ុន្មាននាក់នោះទេ។ [É] ខ្ញុំជីករណ្តៅប្រហែលបួនប្រាំដង ក្នុងម្តងប្រហែលជាមួយរណ្តៅប៉ុណ្ណោះ។"]។ ឯកសារ **D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.31-32 KH 00800984 [សាក្សីគឺជាអ្នកទោស៖ "នៅពេលយប់ អ្នកទោសដែលជាប់ខ្នោះ ត្រូវបានគេបញ្ជូនយកទៅ សម្លាប់។ ជួនកាល អ្នកយាម មិនមានពេលកប់សាកសពទាំងអស់នោះទេ ហើយពួកគេបានបញ្ជាឱ្យក្រុមគ្រូពេទ្យរបស់ខ្ញុំទៅជួយកប់សាកសពទាំងនោះ។ មានអ្នកទោសចំនួន២០ ទៅ ៣០នាក់ មួយ លើកៗ។"] ឆ.33 KH 00800984 ["ខ្ញុំក៏បានឃើញអ្នកយាមកប់សាកសពអ្នកទោសដែលត្រូវបានសម្លាប់។"]។ ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.20-21 KH 00895170 [សាក្សីគឺជាអ្នកទោស៖ "គេឱ្យខ្ញុំនឹង សាមុន ទៅជីកអន្លង់ធំមួយ។ នៅទីនោះសាមុន ហើយនឹងខ្ញុំ បានឃើញផ្ទាល់ភ្នែក ការសម្លាប់មនុស្សចំនួន៧នាក់។ ពួកគេត្រូវបានសម្លាប់ដោយមនុស្សដែលមានគ្នាប្រហែល៣ទៅ៤នាក់ដោយវ៉ៃនឹងពូថៅ។ ក្រោយមក ពួកគេបានបញ្ជាឱ្យខ្ញុំ និងសាមុន លប់ដីកប់សាកសពទាំងនោះឱ្យស្អាត។ គេប្រាប់ខ្ញុំថា ឱ្យធ្វើឱ្យស្អាត ទើបអង្គការទុកចិត្ត។ ពេលនោះយោធាបានឈរមើលយើង ហើយពេលយើងធ្វើរួចរាល់ ពួកគេបាននាំយើងមកដាក់ខ្នោះវិញ។ សាកសពទាំងអស់នោះ មានស្លៀកពាក់ខោអាវ។"]។ ឯកសារ **D219/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.31 KH 01040789 [សាក្សីគឺជាអ្នកទោស៖ "យោធា៣នាក់ បានមកដោះខ្នោះពួកយើង។ ខ្ញុំ និងសាមុន ត្រូវបានយោធាទាំងបីនាក់ប្រើទៅជីកអន្លង់ធំដើម្បីកប់សាកសពមនុស្ស៧នាក់។"]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅសាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.34 KH 00894496 [សាក្សីគឺជាអ្នកទោស៖ "ក្រោយពេលគេដោះលែងខ្ញុំឱ្យធ្វើការនៅក្នុងគុក នៅយប់មួយនោះ ខ្ញុំនិងទី ត្រូវបានគេ

ហៅឱ្យទៅកបើសាកសព [...]។ រណ្ដៅនោះ ត្រូវបានគេជីករួចហើយ។ សាកសពខ្លះមិនទាន់ស្លាប់មែនទែនទេ ដោយនៅមានកំរើក ហើយចេញខ្យល់យឺះៗ។ គេបញ្ជាឱ្យខ្ញុំអូសទម្លាក់សាកសពទាំងនោះចូលក្នុងរណ្ដៅ។ សាកសពទាំងនោះមិនមាន សម្លៀកបំពាក់ទេ គឺសុទ្ធតែស្រាតទាំងអស់ ហើយមានក្មេង ចាស់ មានស្រី មានប្រុស។ ខ្ញុំត្រូវបានគេប្រើឱ្យកប់សាកសពតែម្ដងហ្នឹងទេ ហើយខ្ញុំក៏មិនដឹងពីកន្លែងផ្សេងៗទៀតដែរ។ ក្រោយពេលនោះ ខ្ញុំឈឺគ្រុន ហើយគេក៏លែងឱ្យខ្ញុំទៅកប់សាកសពទៀតដែរ។ ចាប់តាំងពីបានឃើញព្រឹត្តិការណ៍នោះមក ខ្ញុំមានអារម្មណ៍ភ័យតក់ស្លុតរហូតមកដល់សព្វថ្ងៃនេះ។"]។ ឯកសារ **D219/95** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.43 KH 01043183 [សាក្សីគឺជាអ្នកទោសដែលកប់សាកសព៖ "ឈ្មោះទី ហើយនិងខ្ញុំ ត្រូវបានគេហៅឱ្យកប់សាកសពអ្នកទោស៧នាក់។"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.102-103 KH 01115782-01147831[សាក្សីគឺជាអ្នកទោស៖ "មានប្អូននាក់ទទួលខុសត្រូវខាងហ្នឹង [កប់សាកសព] [...] ខ្ញុំនៅចាំតែម្នាក់ទេ ឈ្មោះខាំ។"]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.74 KH 01166966 [សាក្សីគឺជាអ្នកទោស៖ "គេទុកឱ្យខ្ញុំសែងខ្មោច ខ្ញុំសែងខ្មោច ជីកកប់ខ្មោច និងធ្វើការបានល្អ។ អ្នកដែលសម្លាប់មនុស្សគែអត់កប់ខ្លួនឯងទេ"] ឆ.76 KH 01166966 ["បាទ [ខ្ញុំកប់សាកសព] ជារៀងរាល់ថ្ងៃ ទាំងអ្នកដែលដេកស្លាប់ដោយខ្លួនឯង និងអ្នកដែលត្រូវគេសម្លាប់ក្នុងពេលវេថ្ង។ យើងបានយកដែកស័ង្កសីដាក់ខ្សែសែងដោយឈើ។ យើងត្រូវជីករណ្ដៅអីផង។ ពួកយើងមិនអាចឈប់បានទេ បើឈប់គេនឹងបាញ់ចោល។ ឆ. 80-81 KH 01166967 ["ចំពោះសាកសពដែលខ្ញុំសែងទៅកប់នោះវិញ បើសិនសម្លាប់ម្នាក់ខ្ញុំជីករណ្ដៅកប់តែម្នាក់ ប់ស្លាប់ពីរនាក់គឺជីករណ្ដៅកប់ជាមួយគ្នា។ ពេលខ្ញុំបើករបបហូបគេមិនឱ្យនៅជិតគេទេ គេឱ្យមនុស្សយកបាយទៅឱ្យពួកខ្ញុំ ព្រោះមានក្លិនស្អុយជាប់ខ្លួនពួកខ្ញុំ។ [...] ពេលខ្ញុំដើរយកសពទៅកប់ ពេលខ្លះយើងចាំមិនបានថាកប់កន្លែងណាខ្លះព្រោះកប់មានមុនមានក្រោយ ហេតុនេះពេលខ្លះដើរធ្លាក់ រណ្ដៅសពចាស់ផុងត្រឹមក្បាលជង្គង់។"]។

1077 ឯកសារ **D219/103** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.48-49 KH 01043243 [សាក្សី គឺជាអ្នកយាមគុក៖ "ខ្លះនៅខាងជើងភ្នំត្រយ៉ង។ ស. តើមានចម្ងាយប៉ុន្មានពីផ្ទះដែលលោកបានឃើញទៅខ្ទមរបស់តាសឿន? ឆ.49៖ មានចម្ងាយប្រហែលជា១០០ទៅ២០០ម៉ែត្រ។"]។ ឯកសារ **D219/92** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.31 KH 01040789 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំ និងសាមុន ត្រូវបានយោធាទាំង៣នាក់នោះ ប្រើទៅជីកអន្លង់ធំដើម្បីកប់សាកសពមនុស្ស៧នាក់។"] ឆ.34-35 KH 01040789 ["គឺមានចម្ងាយ៣០០ ទៅ៥០០ម៉ែត្រ ពីកន្លែងដែលគេបានដាក់ខ្នោះខ្ញុំ គឺស្ថិតនៅទិសពាយ័ព្យ ឆ្ពោះទៅកាន់ផ្លូវជាតិលេខ៦ [...] ស្ថិតនៅក្នុងព្រៃរបោះនៅក្បែរជើងភ្នំទ្រយោង"]។ ឯកសារ **D219/94** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.64-65 KH 0103168 [សាក្សីគឺជាអ្នកទោស៖ "ស៖ តើលោកកប់សាកសពអ្នកទោសនោះនៅឯណាដែរ? ឆ.64៖ នៅភ្នំ ទ្រយោងដែរ ប្រហែលជា២០ម៉ែត្រពីកន្លែងខ្ញុំដេក គឺនៅក្នុងព្រៃ។ ស៖ ចុះកន្លែងលោកដេកនៅឯណា? ឆ. 65៖ កន្លែងខ្ញុំដេកនៅជិតកន្លែងតាសឿនស្នាក់នៅ។"]។

1078 ឯកសារ **D119/48** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដួង វ័ន្តឌី ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.6-7 KH 00933098 [សាក្សីគឺជាអ្នករស់នៅភ្នំល្មៀប៖ "ខ្ញុំនៅចាំថា នៅពេលដែលខ្ញុំឃើញមនុស្សចាស់ៗបិតពោះធាងត្នោត គឺនៅយប់

នោះហើយ ដែលគេយកមនុស្សទៅសម្លាប់ទាំងខ្សែៗ។ មនុស្សដែលគេយកទៅសម្លាប់នោះ ត្រូវបានគេចងដៃដោយពោះត្នោត ហើយយកខ្សែនីឡុងស៊កបន្តពីមួយទៅមួយជាជួរ។ ខ្ញុំដឹងរឿងនេះដោយសារកាលនោះគេនិយាយគ្រប់គ្នាពីរឿងសម្លាប់នេះ។"]។

1079 ឯកសារ **D119/30** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៣ ឆ.20 KH 00895170 [សាក្សីគឺជាអ្នកទោស៖ "នៅទីនោះ សាមុន ហើយនិងខ្ញុំ បានឃើញផ្ទាល់ភ្នែកការសម្លាប់មនុស្សចំនួន៧នាក់។ ពួកគេត្រូវបានសម្លាប់ដោយពូថៅ ដោយមនុស្សដែលមានគ្នាប្រហែល៣ទៅ៤នាក់ [ខ្មែរក្រហម]។ ក្រោយមក ពួកគេបានបញ្ជាឱ្យខ្ញុំ និងសាមុន លប់ដីកប់សាកសពទាំងនោះឱ្យស្អាត។"]។ ឯកសារ **D5/1252** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អឿ លឿ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036277 [សាក្សីគឺជាអ្នកទោស៖ "រួចវាសម្លាប់ចោលអ្នកទោសដោយប្រើកាំបិត ឬផ្គាក់ ពេលវាមកវិញ វាលៀងកាំបិតឱ្យស្អាតកុំឱ្យប្រឡាក់ឈាម ពេលនោះ។"]។ ឯកសារ **D5/1202** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អោម ម៉ក់ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៩ KH 01031228 [សាក្សីគឺជាអ្នកទោសកុមារ៖ "នៅក្បែរជើងភ្នំទ្រយោងខ្ញុំឃើញមានខ្មោចមនុស្សស្លាប់ជាច្រើន ដោយខ្មោចខ្លះត្រូវអាករសម្លាប់ ខ្លះទៀតឃើញហើមខ្លួនប្រាណ ខ្លះស្គមសល់តែឆ្អឹង។"]

1080 ឯកសារ **D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.30 KH 00801017 [សាក្សីគឺជាអ្នកទោស៖ "អ្វីដែលខ្ញុំបានឃើញ អ្នកទោសត្រូវបានគេសម្លាប់ដោយដំបង និង ត្បូងចប។"]។ ឯកសារ **D219/153** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុម សឿន ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឆ.32 KH 01058768 [សាក្សីគឺជាអ្នកទោស៖ "ក្រោយពេលអ្នកយាមនៅទីនោះមកសម្លាប់វិញ ចបរបស់គេតែងតែប្រឡាក់សុទ្ធតែឈាម"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.98-101 KH 01115782 [សាក្សីគឺជាអ្នកទោស៖ "គេវ៉ៃស្លាប់។ គេមានកាំភ្លើងតែគេមិនប្រើទេ គេប្រើដំបងវ៉ៃ។ [...] ខ្ញុំនៅកន្លែងដេកហ្នឹងមិនឆ្ងាយពីកន្លែងដែលគេយកអ្នកទោសទៅសម្លាប់ទេ ទើបខ្ញុំឮ [É] ឮតែគេវ៉ៃ។ មិនដែលឮសំឡេងគ្រាប់កាំភ្លើងទេ គេទុកសម្រាប់តែពេលយើងរត់។"]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.59 KH 01166963 [សាក្សីគឺជាអ្នកទោស៖ "គេប្រើដំបងប៉ុនភ្លៅដើម្បីវាយមនុស្សសម្លាប់។"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.33 KH 01058730 [សាក្សីគឺជាអ្នកទោស៖ "បាទ មិនមែនតែខ្ញុំទេដែលឮសំឡេងស្រែក គឺមានអ្នកទោសផ្សេងទៀតដូចខ្ញុំដែរ ព្រោះវាមានចម្ងាយប្រហែល៥០ម៉ែត្រពីគ្នាប៉ុណ្ណោះ។ ពួកគេស្រែក "អូយៗ" ដែលជាសំឡេងដង្ហើយហៅឱ្យគេជួយ មុននឹងមនុស្សដាច់ខ្យល់។ ខ្ញុំសន្និដ្ឋានថា អ្នកទោសទាំងនោះត្រូវបានគេវាយនឹងដំបងរហូតដល់ស្លាប់ ព្រោះខ្ញុំមិនដែលឮស្នូរគ្រាប់កាំភ្លើងទេ។"]ឯកសារ **D106/6** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១២ ឆ.17-18 KH 00800981 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំត្រូវបានក្មេងស្រីជាពេទ្យពីរនាក់បណ្តើរ ដោយមានអូសចបតាមផង ដែលខ្ញុំដឹងថា ពួកគេប្រាកដជានឹងសម្លាប់ខ្ញុំមិនខាន។ [...]នៅពេលនោះ ក្មេងស្រីពេទ្យពីរនាក់នោះរៀបនឹងសម្លាប់ខ្ញុំទៅហើយ តែតាសឿន ដែលជាប្រធានមន្ទីរសន្តិសុខ បានមកសួរខ្ញុំ។"]។

1081 ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.92 KH 01166969 [សាក្សីគឺជាអ្នកទោស៖ "ទី១ មៀម ទី២ ស្រួល ទី៣ ឃាង ទី៤ លី ទី៥ ចូន ទី៦ ឌុល និងទី៧ ជាក្មេងតូចអាយុប្រហែល១៥ឆ្នាំ តែខ្ញុំភ្លេចឈ្មោះ។ ក្នុងចំណោមនោះ មានតែមៀម ម្នាក់ដែលអាយុជាង៣០ឆ្នាំ ក្រៅពីនោះសុទ្ធតែជាក្មេងអាយុ១៧ ១៨ឆ្នាំ។"]។ ឯកសារ **D106/7** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ KH 00800999 [សាក្សីប្រាប់ថាគាត់មានអាយុ៥២ឆ្នាំ ក្នុងឆ្នាំ ២០១២ ដែលដូច្នេះគាត់មានអាយុ១៧-១៨ ក្នុងឆ្នាំ ១៩៧៧-៧៨។ ក៏ប៉ុន្តែ បន្ទាប់មក គាត់បានអះអាងថាគាត់ត្រូវបានបញ្ជូនឱ្យធ្វើជាអ្នកយាមនៅភ្នំទ្រយោងនៅឆ្នាំជូត ហើយគាត់មានអាយុ១២-១៣ ឆ្នាំ នៅពេលនោះ។ ឆ្នាំជូតគឺត្រូវជាឆ្នាំ១៩៧២ ដែលពេលនោះគាត់មានអាយុ១២ឆ្នាំ។ ឯកសារ **D219/103** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម សល់ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.3 KH 01043237]។

1082 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.56 KH 00933110 [សាក្សីគឺជាអ្នកទោស៖ "អ្នកទោសធ្ងន់គេដាក់ខ្នោះ នៅកន្លែងរោងមួយដែលគេសង់ទុកនៅខាងជើងភ្នំ ហើយរោងនោះអាចដាក់អ្នកទោសបានប្រហែល១០០នាក់ ហើយរហូតដល់ថ្ងៃគេសម្លាប់នោះ គេនឹងយកទៅវ៉ៃចោល។"]។ ឯកសារ **D219/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.50-51 KH 01043166 [សាក្សីគឺជាអ្នកទោស៖ "អ្នកទោសដែលគេដាក់ខ្នោះដៃ ត្រូវបានបាត់ពីមន្ទីរ ឃុំឃាំង។ ស៖ ហេតុអ្វីបានលោកដឹងថា អ្នកទោសដែលគេដាក់ខ្នោះដៃត្រូវបានគេសម្លាប់? ឆ.51៖ ពីព្រោះ អ្នកទោស ដែលគេដាក់ខ្នោះដៃ ត្រូវបានបាត់ខ្លួនពីមន្ទីរឃុំឃាំង។"]។ ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045318 [OCIJ-068 (ទុំ សឿន - មេគុក)៖ "ខ្ញុំចាំថាមានអ្នកទោសធ្ងន់៤នាក់ ត្រូវបានគេវាយធ្វើបាបមុនបញ្ជូនមកមន្ទីរសន្តិសុខភ្នំទ្រយោង។ ពេលមកដល់ពួកគេជាប់ខ្នោះដើរមិន ហើយធ្វើទុក្ខខ្លាំង មិនអាចព្យាបាលបាន។ យាយថែម បានបញ្ជាឱ្យខ្ញុំសម្លាប់អ្នកទាំង៤នោះទៅ។ ខ្ញុំបាបបញ្ជាបន្តឱ្យអ្នកការពារសម្លាប់ពួកគេទៅ។ ខ្ញុំមិនចាំឈ្មោះអ្នកទោសទាំង៤នាក់ និងអ្នកដែលសម្លាប់នោះទេ ករណីសាក្សីទាំង៤នៅទៅនេះ ក្រោយបានស្តាប់ចម្លើយពួកគេនៅទីនេះ ទើបខ្ញុំចាំបានថាពួកគេជាអ្នកទោសធ្ងន់។"]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.161 KH 01165956 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំមិនដែលបានទៅកន្លែងគុក កន្លែងដែលគេដាក់អ្នកទោសធ្ងន់នោះទេ។ ខ្ញុំឃើញតែអ្នកភូមិជាមួយខ្ញុំវារត់គេចខ្លួនពីរនាក់ ត្រូវបានបាញ់សម្លាប់ និងម្នាក់ទៀតជាប់ខ្នោះត្រូវបានគេសម្លាប់ដែរ។ ហើយម្នាក់ទៀតចុះពីឡានមកដែលជាប់ខ្នោះនោះ គេយកទៅបាត់។ ប្រពន្ធគាត់ឈ្មោះ ឡាយ សព្វថ្ងៃនៅរស់"]។ ឯកសារ **D119/51** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រិន ខេង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.31-32 KH 00933125 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំដឹងខ្លួនដោយខ្លួនឯង ព្រោះថ្ងៃឡើងខ្ញុំឃើញពួកគេជាប់ដាក់ខ្នោះ ដល់យប់ឡើងបាត់អស់ ហើយស្អែកឡើងក៏មានអ្នកទោសផ្សេងចូលមកទៀត ក្រោយមកទៀតគេបានរើកន្លែងនោះចេញ ដើម្បីកុំឱ្យអ្នកទោសផ្សេងទៀតឃើញ។ [É] ខ្ញុំបានឃើញពីរដង ព្រោះក្រោយមកគេរើកន្លែងនោះទៅកន្លែងផ្សេង។"] ឆ.29-30 KH 00933125 ["ខ្ញុំដេកនៅជិតកន្លែងដែលគេដាក់អ្នកទោសធ្ងន់ដែលមានជាប់ខ្នោះជើង។"]។ ឯកសារ **D1.3.11.20** បទសម្ភាសន៍របស់ SOAS ជាមួយ គឹម នៅ (Keum Nov) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ [សាក្សីគឺជាអ្នកទោស៖ "ប្រសិនបើអ្នកជាអ្នកទោសស្រាល ហើយត្រូវគេចាប់បាននៅពេលលួចអ្វីមួយ អ្នកត្រូវគេសម្លាប់នៅបរិវេណត្រយឹងហើយ។ មានពីរបីនាក់ត្រូវបានសម្លាប់ដោយសារ

បញ្ហានេះ។ អ្នកផ្សេងទៀតត្រូវបានវាយដំ។ ខ្ញុំមិនច្បាស់មានអ្នកទោសធ្ងន់ប៉ុន្មាននាក់ទេនៅទីនោះ ពីព្រោះយើងត្រូវបានដាក់ដាច់ចេញពីពួកគេ [...] យើងបានឮថាអ្នកទោសធ្ងន់ត្រូវបានសម្លាប់ ប៉ុន្តែខ្ញុំមិនបានឃើញវាទេ។ ទោះបីយ៉ាងណា ខ្ញុំបានឃើញរណ្ដៅថ្មីៗ។ [...] មុនពេលវៀតណាម ចូលមកដល់ មួយយប់ ទាហាននៅគុក បានសម្លាប់អ្នកទោសធ្ងន់ទាំងអស់ ប៉ុន្តែអ្នកទោសស្រាល ពុំត្រូវបានសម្លាប់ទេ។ អ្នកទោសដែលជាប់ខ្នោះជើងទាំងអស់ ត្រូវបានសម្លាប់ ប៉ុន្តែទាហាន មានការភិតភ័យ ហើយយើងបានរត់គេចខ្លួន។"]។

1083 ឯកសារ **D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.64 KH 00933111 [សាក្សីគឺជាអ្នកទោស៖ "អ្នកទោសមានប្រុសមានស្រី ហើយអ្នកទោសមានសម្លៀកបំពាក់ជាប់ខ្លួន ចំណែកអ្នកទោសស្រីគ្មានសម្លៀកបំពាក់ទេ។"]។ ឯកសារ **D119/19** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ហៅ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.34 KH 00894496 [សាក្សីគឺជាអ្នកទោស៖ "យប់មួយនោះ ខ្ញុំ និង ទី ត្រូវបានគេហៅឱ្យទៅកប់សាកសពដែលមានចំនួនពី៣០ទៅ៤០នាក់។ [...] មានក្មេងចាស់ មានស្រី មានប្រុស។ [...] ចាប់តាំងពីឃើញព្រឹត្តិការណ៍នោះមក ខ្ញុំមានអារម្មណ៍ភ័យតក់ស្លុតរហូតមកដល់សព្វថ្ងៃនេះ"]។ ឯកសារ **D219/95** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផុន ម៉ុន ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.43 KH 01043183 [សាក្សីគឺជាអ្នកទោសដែលកប់សាកសព៖ "ចម្លើយ៣៤ "ឈ្មោះទី ហើយនឹងខ្ញុំ ត្រូវបានគេហៅឱ្យទៅកប់សាកសពអ្នកទោស៧នាក់ មិនមែនកប់សកសពចំនួន៣០ទៅ៤០នោះទេ"។ *ផ្ទុយនឹង* ឯកសារ **D219/92** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ. 33 KH 01040789 [សាក្សីគឺជាអ្នកទោស៖ "សាកសពទាំងពីរនោះ សុទ្ធតែជាបុរស"]។

1084 ឯកសារ **D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.50 KH 01115777 [សាក្សីគឺជាអ្នកទោស៖ "យប់ឡើងគេយកទៅសួរចម្លើយ បើអ្នកឆ្លើយថាចេះជាងគេយកអ្នកនោះទៅវ៉ៃចោល។"]។

1085 ឯកសារ **D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.97-98 KH 01115782 [សាក្សីគឺជាអ្នកទោស៖ "គេសម្លាប់នៅមុខពួកខ្ញុំហ្នឹង ព្រោះបើមានអ្នកណាតដៃ គេនឹងសម្លាប់។ [É] ខ្ញុំឃើញតែពីរនាក់ទេ ម្នាក់គេថាជាងកង់ ដល់ពេលគាត់ធ្វើកង់មិនកើត គេក៏បង្ខំឱ្យស៊ីខ្សាច់ ហើយគេធ្វើលដូចកូនក្មេងទាល់តែគាត់ស្លាប់ទៅ។ ម្នាក់ទៀត គាត់លួចរត់ទៅកន្លែងផ្សេងដូចខ្ញុំដែរ តែគាត់ក្រាញហើយគេយកដំបងវ៉ៃ។ គេមានកាំភ្លើងតែគេមិនប្រើទេ គេប្រើដំបងវ៉ៃ។ មានប្រជាជនច្រើនគេស្រាវជ្រាវប្រវត្តិរូប ដែលគេចាប់យកទៅ។ ហើយនៅភ្នំទ្រយោងនោះ គេមិនឱ្យយើងឃើញការសម្លាប់ទេ ព្រោះគេយកទៅសម្លាប់តែពេលយប់។"]។

1086 ឯកសារ **D219/252** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.31 KH 01085126 [សាក្សីគឺជាអ្នកទោស៖ "ពេលដែលអ្នកទោសខ្សោយពេកមិនអាចធ្វើការទៅរួចទៀត ត្រូវបានពួកឈ្លបសម្លាប់។ [É] ខ្ញុំឃើញវាកើតឡើងនៅពេលល្ងាច។ ខ្ញុំឃើញគេសម្លាប់១ឬ២នាក់ នៅនឹងកន្លែង ពេលដែលអ្នកទោសខ្សោយពេកមិនអាចធ្វើការទៅរួចទៀត។"។ ឯកសារ **D219/583** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នួ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.75 KH 01166966 [សាក្សីគឺជាអ្នកទោស៖ "ពេលខ្ញុំសែងខ្មោចទៅកប់គឺជាខ្មោចដែលគេសម្លាប់នៅកន្លែងធ្វើការដោយគេចោទថា ខ្ជិលធ្វើការមួយថ្ងៃមាន៧ទៅ៨នាក់។"]។

---

1087 ឯកសារ **D219/94** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គិម យ៉េត ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.85-90 KH 01043170-01043171[សាក្សីគឺជាអ្នកទោស៖ “គេចាប់អ្នកទោសទាំងនោះ នៅពេលដែលគេចាប់បាន [ព្យាយាមគេចខ្លួច] ។ នៅពេលដែលគេចាប់បាន គេវាយធ្វើបាប ឬសម្លាប់អ្នកទោសទាំងនោះនៅក្រោមដើមពោធិ៍។ [...] គេចាប់អ្នកទោសនោះចងស្លាបសេក ហើយគេវាយដំទៅលើអ្នកទោសទាំងអស់នោះ។ [...] ជាមួយនឹងដែកថ្នាំងអំពោះ ឬបាញ់សម្លាប់តែម្ដង [...] ខ្ញុំឃើញផ្ទាល់ភ្នែក ព្រោះកន្លែងដែលវាយនោះ នៅជិតកន្លែងខ្ញុំធ្វើការ។ [...] ប៉ុន្តែភ្លាមនោះ សល់ មិនដឹងរត់មកពីណាក៏កញ្ឆក់កាន់កាំភ្លើង រួចបាញ់រះទៅលើអ្នកទោស ហើយមានអ្នកទោសខ្លះរងរបួសបាក់ជើង។”]។ ឯកសារ **D219/230** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡេង រ៉ុង ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ ឆ.27 KH 01076377 [សាក្សីគឺជាអ្នកទោស៖ “ពីព្រោះមានពេលមួយនោះ មានអ្នកទោស២នាក់ឪពុក និងកូន បានបបួលខ្ញុំលួចរត់ចេញពីទីនោះនៅពេលយប់ ប៉ុន្តែខ្ញុំបានប្រាប់ពួកគេថាកុំឱ្យរត់អី ប្រយ័ត្នគេសម្លាប់ចោល នៅពេលនោះពួកគេមិនស្ដាប់ខ្ញុំ គេក៏បានលួចរត់ដោយពួកគេនិយាយថា រត់ក៏ងាប់ នៅទីនេះក៏ងាប់ ដូច្នេះពួកគេត្រូវតែរត់។ ពួកគេទាំង២រត់មិនបានឆ្ងាយពីរោងអ្នកទោសប៉ុន្មានទេប្រហែលជា ១០០ម៉ែត្រ ក៏ត្រូវបានអ្នកយាមបាញ់សម្លាប់នៅទីនោះតែម្ដង ជាមួយពេលនោះដែរ ខ្ញុំបានឮសំឡេងកាំភ្លើង៣គ្រាប់បានផ្ទុះឡើង។”]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.36 KH 01049196 [សាក្សីគឺជាអ្នកយាមគុក៖“ខ្ញុំសូមបញ្ជាក់ថា ខ្ញុំនៅចាំហេតុការណ៍មួយដែលពេលនោះ មានអ្នកទោសម្នាក់បានវាយប្រតាយប្រតប់ជាមួយនឹងយោធា ដើម្បីដណ្ដើមយកកាំភ្លើង ហើយបន្ទាប់មកអ្នកទោសនោះបានរត់គេចខ្លួន ប៉ុន្តែអ្នកទោសនោះ រត់មិនបានឆ្ងាយប៉ុន្មានទេ គឺប្រហែល២០ម៉ែត្រតែប៉ុណ្ណោះ ក៏ត្រូវបានពួកយោធាបាញ់គាត់ត្រូវជើងតែម្ដង។”]។ ឯកសារ **D219/567** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.119-120 KH 01165953 [សាក្សីគឺជាអ្នកទោស៖ “ស៖ មុននេះលោកថា អ្នកទោសខ្លះព្យាយាមរត់ចេញពីគុក តើមានរឿងអ្វីកើតឡើងចំពោះពួកគេ? ឆ I19៖ គេបាញ់ចោល [É] អ្នកទោសដែលគេបាញ់ស្លាប់នោះ នៅពេលដែលគេបណ្ដើរអ្នកទោសទៅមុជទឹក។”]។ ឯកសារ **D219/92** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ភួន ស៊ុនទី ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.57 KH 01040793 [សាក្សីគឺជាអ្នកទោស៖ “បាទ ខ្ញុំបានឮអ្នកយាមគុកនៅទៅទីនោះនិយាយថា មានអ្នកទោសម្នាក់បានរត់គេចខ្លួន ហើយនៅពេលនោះពួកអ្នកយាមបានតាមបាញ់អ្នកទោសនោះនៅតាមផ្លូវដែលគេរត់គេច។”]។ ឯកសារ **D219/211** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អឿន ចាន់រី ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឆ.13-14 KH 01074054 [សាក្សីគឺជាប្អូនស្រីរបស់អ្នកទោស៖ “បងប្រុសរបស់ខ្ញុំ និងប្ដីរបស់ខ្ញុំ ត្រូវបានឃុំឃ្លាំងនៅទៅនោះរយៈពេលប្រហែលជាកន្លះខែ។ គាត់បាននិយាយប្រាប់ខ្ញុំថា មុខដំបុងគាត់ឃើញគេចងប្ដីរបស់ខ្ញុំ ហើយគាត់បានគិតថាគាត់ប្រាកដជាស្លាប់ហើយ ដូច្នេះគាត់ត្រូវតែសម្រេចចិត្តរត់គេចខ្លួននៅពេលនោះ។ នៅពេលដែលគាត់កំពុងរត់គេចខ្លួន ពួកអ្នកយាមគុកភ្នំទ្រយោងបានរត់ដេញតាម និងបាញ់សំដៅបងប្រុសរបស់ខ្ញុំ ប៉ុន្តែបាញ់មិនត្រូវ។”]។ ឯកសារ **D219/357** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.117 KH 01104654 [សាក្សីគឺជាអ្នកទោស ៖ “ខ្ញុំមិនដែលឃើញមានអ្នកណាម្នាក់លួចរត់ទេ ប៉ុន្តែប្រសិនបើមានអ្នកណាម្នាក់ហ៊ានលួចរត់ អ្នកយាម នឹងបាញ់សម្លាប់ហើយ។”]។ ឯកសារ **D1.3.11.43** កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ រិន ខេង ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ EN 00210494 [សាក្សីគឺជាអ្នកទោស៖ “ពេលមួយ នៅពេលយប់ អ្នកទោសម្នាក់ បានព្យាយាមគេចខ្លួន។ អ្នកយាម

---

បានបាញ់គាត់ ហើយគាត់បានស្លាប់។"] *ប្រៀបធៀប* ឯកសារ **D123/1/2.65** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៊ិន ណាន់ និង រិន ខេង ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១ KH 00927372 [សាក្សីគឺជាអ្នកទោស៖ "ខេង៖ ខ្ញុំលួចមកផ្ទះម្ដង [...] មានតែយោធាគេនៅតាមស្ពានមួយៗ តែខ្ញុំកូនក្មេងវាមិនសូវចាប់អារម្មណ៍ទេកុហកវាអីចឹង [...] ណាន់៖ បើមនុស្សចាស់វាតាមជាប់ៗ បើចាប់បាន"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.90 KH 0115782 [សាក្សីគឺជាអ្នកទោស៖ "មានគ្នាខ្ញុំ ៦ នាក់រត់ដែរ។ ពេលដែលយើងទៅដល់ព្រៃ គេប្រាប់ថាគេនឹងរត់ តែខ្ញុំថា ខ្ញុំគ្មានកម្លាំងរត់នឹងគេទេ។ អ្នកយាមមិនសូវជាយាមតឹងរឹងទេ ព្រោះគេគិតថាយើងគ្មានកម្លាំងរត់ទេ"]។ *ផ្ទុយទឹង* ឯកសារ **D219/422.9** ប្រតិចារឹក ក.ស.ច.ស នៃកិច្ចសម្ភាសន៍ជាមួយ ទុំ សឿន ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ KH 01121645 [សាក្សីគឺជាមេគុក៖ "កន្លែងហ្នឹង គេធ្វើមន្ទីរសន្តិសុខមែន ប៉ុន្តែមូចមិនកន្លែងធ្ងន់ធ្ងរប៉ុន្មានទេ មនុស្សអាចចេញចូលបាន។ "]។ ឯកសារ **D49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ិន ណាន់ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១១ KH 00722217 [សាក្សីគឺជាអ្នកទោស៖ "ខ្ញុំមិនដឹងច្បាស់ថា កន្លែងនោះគឺជាគុក ឬអត់នោះទេ ប៉ុន្តែគ្រាន់តែដឹងថា មានឆ្មាំយាម ហើយបើយើងទៅណាមកណា ត្រូវសុំការអនុញ្ញាតពីគេ។"]។

1088 ឯកសារ **D119/99** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.35 KH 00978923 [សាក្សីធ្វើការនៅកងចល័ត ដែលនៅមើលកូនប្រុសរបស់សំ ប៊ុន នៅពេលគេយល់ឪពុកវាទៅ៖ "សំ ប៊ុន ត្រូវបានគេយកទៅសម្លាប់នៅកន្លែងមួយ នៅចន្លោះភ្នំលៀប និងភ្នំទ្រយោង។ ភ្នំទ្រយោង ជាមន្ទីរ ឃុំឃាំង។"]។ ឯកសារ **D5/1100** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ពេជ្រ រស់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ KH 01025793 [សាក្សីបានឃើញអ្នកភូមិក្បែរនោះឃ្វាលគោនៅជិតភ្នំត្រយ៉ង៖ "ខ្ញុំបានទៅនៅក្បែរនៅអូរលៀបខាងកើតភ្នំលៀប ឃើញយោធាចងបណ្ដើរយកមកវាយចោលតាមជើងភ្នំទ្រយង ដែលមាន១៥នាក់ទៅ២០នាក់ជារៀងរាល់យប់ ពេលថ្ងៃចង ដឹកនឹងកង់ក្របកន្សែងយកមកភ្នំលៀប"។ ឯកសារ **D119/48** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដួង វ័ន្តឌី ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.6-7 KH 00933098 [សាក្សីគឺជាអ្នករស់នៅភ្នំលៀប៖ "នៅពេលដែលពួកនិរតីបានមកដល់ ខ្ញុំបានឃើញប្រជាជនត្រូវបានគេចងទាំងខ្សែៗបញ្ជូនទៅសម្លាប់នៅកន្លែងមួយដែលស្ថិតនៅខាងជើងភ្នំទ្រយោង។ អ្នកទោសដែលបញ្ជូនទៅសម្លាប់ត្រូវបានគេទុកនៅក្នុងផ្ទះមួយនៅក្បែរកន្លែងខ្ញុំធ្វើការ ដែលមានចម្ងាយប្រហែល៧០០ម៉ែត្រពីផ្ទះយាយថែម។ អ្នកទោសទាំងនោះ ត្រូវបានគេយកទៅដាក់នៅពេលថ្ងៃ ទើបគេយកសម្លាប់ពេលយប់ [...]ព្រឹត្តិការណ៍នេះកើតឡើង១អាទិត្យម្ដង គឺចាប់តាំងពីដើមរហូតដល់ចុងរបបខ្មែរក្រហម។ ខ្ញុំសង្កេតឃើញថាក្នុងម្ដងៗ គេយលមនុស្សច្រើនជាង១០នាក់ទៅសម្លាប់។ [...] ក្រោយរបបខ្មែរក្រហម ខ្ញុំបានទៅមើលកន្លែងសម្លាប់នោះ ឃើញសុទ្ធតែលលាដ៍ និងឆ្អឹងខ្មោចគរលើគ្នា។"]។ ឯកសារ **D119/21** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុក ដៀង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.3 KH 00894507 [សាក្សីជាអ្នកបររទេះគើនៅក្បែរនោះ និងជាសាច់ញាតិរបស់អ្នកទោស៖ "ថ្ងៃមួយនោះ គេឲ្យខ្ញុំបររទេះគោទៅដឹកអង្ករ។ ខ្ញុំបានបររទេះចូលតាមផ្លូវជាតិលេខ៦ ទៅកាន់ច្រកចូលភ្នំទ្រយោង។ ដំបូង ខ្ញុំបានធ្វើដំណើរកាត់តាមមុខមន្ទីរពេទ្យមួយដែលមានទីតាំងនៅខាងស្ដាំដៃ ហើយអមតាមផ្លូវចូលទៅភ្នំទ្រយោង ខ្ញុំឃើញមានរណ្ដៅសាកសពជាច្រើន និងឃើញមានគំនរខោអាវនៅក្បែររណ្ដៅទាំងនោះ និងឃើញមានស្នាមឈាម។ អ្នកដែលធ្លាប់បានទៅជីករណ្ដៅ បានប្រាប់ខ្ញុំថា រណ្ដៅនីមួយៗ មានសាកសពប្រហែលជា១០ទៅ១២នាក់។ រណ្ដៅសាកសពទាំងនោះ នៅចម្ងាយប្រហែលជា៥០០ម៉ែត្រពីភ្នំទ្រយោង។"] ឆ.14-15 KH

00894508-00894509 "[ក្នុងឆ្នាំ ១៩៧៨] ខ្ញុំបានឃើញមានការចាប់មនុស្សនៅពេលយប់។ ប្រជាជនត្រូវបានគេចាប់ ហើយយកទៅឃុំឃាំងនៅមន្ទីរឃុំភ្នំល្មៀប ប្រហែលជា១០ថ្ងៃ មុននឹងគេបញ្ជូនយកទៅសម្លាប់នៅក្នុងព្រៃក្បែរភ្នំទ្រយោង"]។ ឯកសារ **D219/151** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ងៀង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឆ.3-5 KH 01058746-01058747 [សាក្សីជាអ្នកបររទេះគោនៅក្បែរនោះ និងជាសាច់ញាតិរបស់អ្នកទោស៖ "នៅទល់មុខផ្ទះយាយថែម គឺជាផ្ទះដែលយោធាធ្វើការជាមួយគាត់ រស់នៅ [...] មានមន្ទីរសន្តិសុខមួយនៅក្រោយផ្ទះ [...] តាមខ្ញុំដឹង នៅពេលយប់ គេបញ្ជូនអ្នកទោសទាំងនោះ ទៅវ៉ៃចោលនៅភ្នំទ្រយោងតែម្តង។ ស៖ តើលោកបានដឹងរឿងនេះពីប្អូនថ្លៃរបស់លោក ឈ្មោះ សាំង នោះមែនទេ? KH 01058747 ឆ.5៖ បាទ ត្រឹមត្រូវហើយ។ សាំង គឺជាឈ្លបឃុំ។"] ឆ.9-10 01058748-01058749 ["ខ្ញុំបររទេះកាត់ទីនោះ ហើយប្រទះឃើញរណ្តៅសាកសពដូចខ្ញុំរៀបរាប់ខាងលើ ដោយមានឈាម និងចំណងពោះវៀនឆ្នោតនៅជុំវិញ រណ្តៅនោះផង។ ក្រោយមកទៀត ខ្ញុំឮពីប្អូនថ្លៃឈ្មោះ សាំង នោះថា ជារណ្តៅសាកសពមិត្តភក្តិរបស់ខ្ញុំ រួមទាំងពូរបស់ខ្ញុំផង ដែលគេបានសម្លាប់ពីយប់។ ខ្ញុំអាចឃើញសាកសពទាំងនោះ ដោយគេកប់រាក់ៗប៉ុណ្ណោះ ព្រោះខ្ញុំអាចមើលឃើញ ទោះបីខ្ញុំអង្គុយបររទេះក៏ដោយ ហើយរណ្តៅនោះមានទំហំប្រហែល៣ គុណ៣ម៉ែត្រ និងឆ្ងាយពីផ្លូវប្រហែល១៥ម៉ែត្រប៉ុណ្ណោះ។ ហេតុការណ៍នេះ កើតឡើងនៅម្តុំពាក់កណ្តាលឆ្នាំ ១៩៧៨ ហើយ។ តាមខ្ញុំសង្កេត សាកសពទាំងនេះ ភាគច្រើនមានខោខ្លីទេ ហើយខ្លះក៏មានអាវនៅជាប់នឹងខ្លួនដែរ។[...] បើឮតាមសាំង អ្នកទាំងនោះ ត្រូវបាននាំយកទៅសម្លាប់នៅទីនោះពីមន្ទីរសន្តិសុខ បណ្តោះអាសន្ន ដែលមានទីតាំងនៅទល់មុខផ្ទះយាយថែម។ [...] ឈ្មោះ ប៉ាវ (ស្លាប់) [...] គាត់និយាយថាគេឲ្យគាត់ទៅជីករណ្តៅជាមុន មុននឹងគេយកអ្នកទាំងនោះទៅសម្លាប់នៅយប់នោះ។"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.108-121 KH 01115783-01115784 [សាក្សីគឺជាអ្នកទោសដែលពិពណ៌នាថាបានឃើញអ្នកទោស៨០ទៅ១០០នាក់ដែលត្រូវបានគេចងដឹកតាមតាមត្រាក់ទ័រទៅទិសខាងជើងនៃភ្នំទ្រយោង។ អ្នកទោស និងទាហាននៅយាមពួកគេ ពុំមែនមកពីមន្ទីរសន្តិសុខភ្នំទ្រយោងទេ។ គាត់មិនដែលឃើញអ្នកទោសត្រឡប់មកវិញទេ ប៉ុន្តែគាត់បានពិពណ៌នាថាទាហានបានត្រឡប់មកវិញ]។ ឯកសារ **D5/1179** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៊ូ ទូក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ KH 01030733 [សាក្សីគឺជាអ្នកទោស៖ "នៅពេលដែលខ្ញុំជាប់ក្នុងគុកនោះមួយថ្ងៃៗ ឃើញតែរថយន្តដឹកអ្នកទោសប្រហែល៨០ ទៅ១០០នាក់ ដៃជើងជាប់ខ្នោះច្រវ៉ាក់ មិនដឹងមកពីស្រុកភូមិណា [...] យកបណ្តើរទាំងហ្វូងហ្វូងៗសំដៅទៅត្រង់ម្តុំភ្នំទ្រយោង ក្បែរគម្ពោធព្រៃ [É] មិនឃើញត្រឡប់មកវិញសោះទៅបាត់តែម្តង។"]។

1089 ឯកសារ **D119/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដួង វ័ន្តឌី ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.6-7 KH 00933098 [សាក្សីគឺជាអ្នករស់នៅភ្នំល្មៀប៖ "នៅពេលដែលពួកនិរតីបានមកដល់ ខ្ញុំបានឃើញប្រជាជនត្រូវបានគេចងទាំងខ្សែៗបញ្ជូនទៅសម្លាប់នៅកន្លែងមួយដែលស្ថិតនៅខាងជើងភ្នំទ្រយោង។ អ្នកទោសដែលបញ្ជូនទៅសម្លាប់ត្រូវបានគេទុកនៅក្នុងផ្ទះមួយនៅក្បែរកន្លែងខ្ញុំធ្វើការ ដែលមានចម្ងាយប្រហែល៧០០ម៉ែត្រពីផ្ទះយាយថែម។ អ្នកទោសទាំងនោះ ត្រូវបានគេយកទៅដាក់នៅពេលថ្ងៃ ទើបគេយកសម្លាប់ពេលយប់ [...]ព្រឹត្តិការណ៍នេះកើតឡើង១អាទិត្យម្តង គឺចាប់តាំងពីដើមរហូតដល់ចុងរបបខ្មែរក្រហម។ ខ្ញុំសង្កេតឃើញថាក្នុងម្តងៗ គេយលមនុស្សច្រើនជាង១០នាក់ទៅសម្លាប់។ [...] ក្រោយរបបខ្មែរក្រហម ខ្ញុំបានទៅមើលកន្លែងសម្លាប់នោះ ឃើញសុទ្ធតែលលាដ៍ និងឆ្អឹងខ្មោចគរលើគ្នា។"]។ ឯកសារ **D119/21**

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ងៀង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.3 KH 00894507 [សាក្សីជាអ្នកបររទេះគោនៅក្បែរនោះ និងជាសាច់ញាតិរបស់អ្នកទោស៖ "ថ្ងៃមួយនោះ គេឱ្យខ្ញុំបររទេះគោទៅដឹកអង្ករ។ ខ្ញុំបានបររទេះចូលតាមផ្លូវជាតិលេខ៦ ទៅកាន់ច្រកចូលភ្នំទ្រយោង។ ដំបូង ខ្ញុំបានធ្វើដំណើរកាត់តាមមុខមន្ទីរពេទ្យមួយដែលមានទីតាំងនៅខាងស្តាំដៃ ហើយអមតាមផ្លូវចូលទៅភ្នំទ្រយោង ខ្ញុំឃើញមានរណ្តៅសាកសពជាច្រើន និងឃើញមានគំនរខោអាវនៅក្បែររណ្តៅទាំងនោះ និងឃើញមានស្នាមឈាម។ អ្នកដែលធ្លាប់បានទៅជីករណ្តៅ បានប្រាប់ខ្ញុំថា រណ្តៅនីមួយៗ មានសាកសពប្រហែលជា១០ទៅ១២នាក់។ រណ្តៅសាកសពទាំងនោះ នៅចម្ងាយប្រហែលជា៥០០ម៉ែត្រពីភ្នំទ្រយោង។"] ឆ.14-15 KH 00894508-00894509 "[ក្នុងឆ្នាំ ១៩៧៨] ខ្ញុំបានឃើញមានការចាប់មនុស្សនៅពេលយប់។ ប្រជាជនត្រូវបានគេចាប់ហើយយកទៅឃុំឃាំងនៅមន្ទីរឃុំភ្នំលៀប ប្រហែលជា១០ថ្ងៃ មុននឹងគេបញ្ជូនយកទៅសម្លាប់នៅក្នុងព្រៃក្បែរភ្នំទ្រយោង"]។ ឯកសារ **D219/151** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ងៀង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឆ.3-5 KH 01058746-01058747 [សាក្សីជាអ្នកបររទេះគោនៅក្បែរនោះ និងជាសាច់ញាតិរបស់អ្នកទោស៖ "នៅទល់មុខផ្ទះយាយថែម គឺជាផ្ទះដែលយោធាធ្វើការជាមួយគាត់ រស់នៅ [...] មានមន្ទីរសន្តិសុខមួយនៅក្រោយផ្ទះ [...] តាមខ្ញុំដឹង នៅពេលយប់គេបញ្ជូនអ្នកទោសទាំងនោះ ទៅវ៉ៃចោលនៅភ្នំទ្រយោងតែម្តង។ ស៖ តើលោកបានដឹងរឿងនេះពីប្អូនថ្លៃរបស់លោក ឈ្មោះ សាំង នោះមែនទេ? ឆ.5៖ បាទ ត្រឹមត្រូវហើយ។ សាំង គឺជាឈ្លបឃុំ។"] ឆ.9-10 KH 01058748-01058749 ["ខ្ញុំបររទេះកាត់ទីនោះ ហើយប្រទះឃើញរណ្តៅសាកសពដូចខ្ញុំរៀបរាប់ខាងលើ ដោយមានឈាម និងចំណងពោះត្នោតនៅជុំវិញ រណ្តៅនោះផង។ ក្រោយមកទៀត ខ្ញុំឮពីប្អូនថ្លៃឈ្មោះ សាំង នោះថា ជារណ្តៅសាកសពមិត្តភក្តិរបស់ខ្ញុំ រួមទាំងពូរបស់ខ្ញុំផងដែលគេបានសម្លាប់ពីយប់។ ខ្ញុំអាចឃើញសាកសពទាំងនោះ ដោយគេកប់រាក់ៗប៉ុណ្ណោះ ព្រោះខ្ញុំអាចមើលឃើញ ទោះបីខ្ញុំអង្គុយបររទេះក៏ដោយ ហើយរណ្តៅនោះមានទំហំប្រហែល៣ គុណ៣ម៉ែត្រ និងឆ្ងាយពីផ្លូវប្រហែល១៥ម៉ែត្រប៉ុណ្ណោះ។ ហេតុការណ៍នេះ កើតឡើងនៅម្តុំពាក់កណ្តាលឆ្នាំ ១៩៧៨ ហើយ។ តាមខ្ញុំសង្កេត សាកសពទាំងនេះ ភាគច្រើនមានខោខ្លីទេ ហើយខ្លះក៏មានអាវនៅជាប់នឹងខ្លួនដែរ។[...] បើឮតាមសាំង អ្នកទាំងនោះ ត្រូវបាននាំយកទៅសម្លាប់នៅទីនោះពីមន្ទីរសន្តិសុខ បណ្តោះអាសន្ន ដែលមានទីតាំងនៅទល់មុខផ្ទះយាយថែម។ [...] ឈ្មោះ ប៉ាវ (ស្លាប់) [...] គាត់និយាយថាគេឱ្យគាត់ទៅជីករណ្តៅជាមុន មុននឹងគេយកអ្នកទាំងនោះទៅសម្លាប់នៅយប់នោះ។"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.108-121 KH 0115783-0115784 [សាក្សីគឺជាអ្នកទោសដែលពិពណ៌នាថាបានឃើញអ្នកទោស៨០ទៅ១០០នាក់ដែលត្រូវបានគេចង ដឹកតាមតាមត្រាក់ទ័រទៅទិសខាងជើងនៃភ្នំទ្រយោង។ អ្នកទោស និងទាហាននៅយាមពួកគេ ពុំមែនមកពីមន្ទីរសន្តិសុខភ្នំទ្រយោងទេ។ គាត់មិនដែលឃើញអ្នកទោសត្រឡប់មកវិញទេ ប៉ុន្តែគាត់បានពិពណ៌នាថាទាហានបានត្រឡប់មកវិញ]។ ឯកសារ **D5/1179** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៊ូ ទូក ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ KH 01030733 [សាក្សីគឺជាអ្នកទោស៖ "នៅពេលដែលខ្ញុំជាប់ក្នុងគុកនោះមួយថ្ងៃៗ ឃើញតែរថយន្តដឹកអ្នកទោសប្រហែល៨0 ទៅ១០០នាក់ ដៃជើងជាប់ខ្នោះច្រវ៉ាក់ មិនដឹងមកពីស្រុកភូមិណា [...] យកបណ្តើរទាំងហ្វូងហ្វូងៗសំដៅទៅត្រង់ម្តុំភ្នំទ្រយោង ក្បែរគម្លោធព្រៃ [...] មិនឃើញត្រឡប់មកវិញសោះទៅបាត់តែម្តង។"]។ ឯកសារ **D5/1100** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ពេជ្រ រស់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ KH 01025793 [សាក្សីបានឃើញអ្នកភូមិក្បែរនោះឃ្វាលគោនៅជិតភ្នំត្រយ៉ង៖

"ខ្ញុំបានទៅនៅក្ដួរនៅអូរលៀបខាងកើតភ្នំលៀប ឃើញយោធាចងបណ្ដើរយកមកវាយចោលតាមជើងភ្នំទ្រយង ដែលមាន១៥នាក់ទៅ២០នាក់ជារៀងរាល់យប់ ពេលថ្ងៃចង ដឹកនឹងកង់ក្របកន្សែងយកមកភ្នំលៀប"។]។

1090 ឯកសារ **D219/256** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មី គាល់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ឆ.27 KH 01085166 [សាក្សី គឺជាអ្នកបររទេះគោនៅភ្នំលៀប៖ "ប៉ុន្តែអ្នកជិតខាងរបស់ខ្ញុំមួយចំនួន ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅភ្នំទ្រយោង ហើយក៏បានបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ"]។ ឯកសារ **D119/139** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហៅ មុន សារឿន ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.16 KH 01003879 [សាក្សីគឺជាមេកងចល័តនៅក្នុងតំបន់៥៖ "ក្នុងភូមិរបស់ខ្ញុំមានមនុស្សបាត់ខ្លួនចំនួន៣នាក់ ឈ្មោះ ចន នងចៀន (ចន ជាកូនរបស់ចៀន ហើយពីរនាក់ត្រូវបានគេបញ្ជូនទៅភ្នំទ្រយោង និងម្នាក់ទៀតឈ្មោះខួន ដឹកអង្គរទៅអររក្សបាក់ក ហើយក៏បានបាត់ខ្លួន។)"]។

1091 ឯកសារ **D119/99** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.35-36 KH 00978923-00985206 [សាក្សីធ្វើការនៅកងចល័ត ដែលនៅមើលកូនប្រុសរបស់សំ ប៊ុន នៅពេលគេយល់ឪពុកវាទៅ៖ "សំ ប៊ុន ត្រូវបានគេឲ្យឡើងជាអ្នកគ្រប់គ្រងមនុស្សក្នុងឃុំបណ្ដោះអាសន្ន ហើយនៅថ្ងៃមួយនោះ គាត់បានអនុញ្ញាតឲ្យស្ត្រីពីរនាក់ មកលេងផ្ទះនៅសហករណ៍៥។ ពេលនោះ កម្មាភិបាលនីរតី ដែលក្ដាប់លើ សំ ប៊ុន ឃើញស្ត្រីពីរនាក់នោះ ក៏ហៅសួរ ហើយពួកគាត់បានប្រាប់ទៅកម្មាភិបាលនារីនិរតីនោះថា សំ ប៊ុន បានអនុញ្ញាតឲ្យកាត់លេងសហករណ៍៥។ កម្មាភិបាលនារីនិរតីនោះ បាននាំស្ត្រីទាំងពីរនោះ ទៅផ្ទះយាយ ថែម ហើយក្រោយមក ក៏ត្រូវបានដោះលែងមកវិញ។ គេបានហៅ សំ ប៊ុន ទៅផ្ទះយាយថែម ហើយក្រោយមកក៏គេយកគាត់ទៅសម្លាប់។ [...] ក្រោយពេលគេយក សំ ប៊ុន ទៅសម្លាប់ ខ្ញុំបានយកកូនប្រុសរបស់គាត់ដែលមានអាយុប្រហែល៤ទៅ៥ឆ្នាំ មកចិញ្ចឹមប្អូនប្រាំថ្ងៃ មុននឹងនាំកូនប្រុសនោះ ទៅឲ្យម្ដាយវាវិញ នៅភូមិ ស្រះកើត។ ប្រពន្ធរបស់ សំ ប៊ុន ឈ្មោះ ស ឡោម។"]។ ឯកសារ **D119/39** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ ឌៀ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.28-37 EN 01040536-01040537 [សាក្សី ធ្វើការនៅភូមិស្រះ ហើយប្ដីរបស់គាត់ គឺសំ ប៊ុន ៖ "ខ្ញុំមិនដឹងរឿងអ្វីដែលគេចាប់ប្ដីរបស់ខ្ញុំទៅសម្លាប់ទេ។ ខ្ញុំដឹងរឿងនេះ តាមមនុស្សម្នាក់ដែលបានយកកូនប្រុសមកឲ្យខ្ញុំ។ [...] មូលហេតុដែលខ្ញុំដឹងថាប្ដីរបស់ខ្ញុំគេចាប់យកទៅសម្លាប់ ពីព្រោះកូនប្រុសទីពាររបស់ខ្ញុំ [...] ឪពុករបស់គេ ត្រូវបានគេចាប់តកទៅសម្លាប់ ប៉ុន្តែកូនខ្ញុំនៅតូចនៅឡើយ ហើយវាប្រាប់ខ្ញុំមិនសូវច្បាស់អំពីរឿងនេះដែរ ប៉ុន្តែក្រោយមក មានមនុស្សម្នាក់ដែលធ្វើការនៅកន្លែងគុកភ្នំលៀប បានប្រាប់ខ្ញុំថា គាត់បានឃើញប្ដីរបស់ខ្ញុំគេដាក់ខ្នោះជើង ខ្នោះដៃ ហើយក្រោយមកទើបគេបញ្ជូនយកទៅវាយចោលនៅភ្នំទ្រយោង។ [...] វាគឺជាក្មេងប្រុសម្នាក់ដែលគេចាត់តាំងឲ្យធ្វើជាអ្នកយាមគុកនៅ ភ្នំលៀប។ [...] ប៉ុន្តែខ្ញុំបានឮពីបុរសម្នាក់ដែលយកកូនខ្ញុំមកឲ្យខ្ញុំទាំងកណ្ដាលយប់នោះថា ខ្មែរក្រហមបានសួរកូនខ្ញុំថា តើឯងទៅជាមួយឪពុករបស់ឯង ឬក៏ឯងត្រឡប់ទៅម្ដាយឯងវិញ ហើយកូនប្រុសខ្ញុំបានឆ្លើយថាខ្ញុំមិនទៅជាមួយឪពុកខ្ញុំទេ ខ្ញុំចង់ទៅនៅជាមួយម្ដាយខ្ញុំវិញ។ ដោយសារបុរសនោះគិតថា បើទុកក្មេងនោះនៅទីនោះ ខ្មែរក្រហមប្រាកដជាយកវាទៅសម្លាប់ជាមួយឪពុក ដូច្នេះហើយទើបបុរសនោះ លួចយកកូនប្រុសខ្ញុំមកឲ្យខ្ញុំទាំងយប់។"]។

1092 ឯកសារ **D119/94** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.46 KH 00976182 [សាក្សី គឺជាកម្មករនៅក្នុងកងចល័ត តំបន់៥ ដែលរាយការណ៍ឲ្យយាយថែម៖"ឈ្លប បានចាប់ចងមឿន តែគាត់បានរត់ ហើយត្រូវបានឈ្លបតាមចាប់យកមកផ្ទះយាយថែមវិញ។ យាយថែម បានឲ្យឈ្លបនាំមឿន ទៅភ្នំទ្រយោង ហើយសម្លាប់នៅ

ទីនោះ។ ខ្ញុំឃើញព្រឹត្តិការណ៍នេះ នៅពេលដែលខ្ញុំកំពុងធ្វើការនៅកងចល័ត នៅថ្នល់ជាតិលេខ៦ មុខផ្ទះរបស់យាយថែម។ ពេលគេបណ្ដើរទៅ មឿន បានស្រែកប្រាប់ខ្ញុំថា "បងម៉ៅ អើយ! ប្រាប់ប្អូនស្រីខ្ញុំមឱ្យដឹងផង ថាគេចាប់ខ្ញុំហើយ។"] KH 00976182 ["សៈ នៅទំព័រ១៧ដដែល លោកបាននិយាយថា "គាត់ថា អើ! បើវាពិបាក វាប្រឆាំងក្បត់ ហើយវ៉ៃចោលទៅ"។ តើលោកអាចបញ្ជាក់បានទេថា នរណាជាអ្នកនិយាយពាក្យនេះ? ឆ.47៖ ខ្ញុំបានឮ យាយថែម និយាយពាក្យនេះ នៅពេលដែលគេចាប់ពេទ្យ មឿន មកផ្ទះរបស់គាត់"]។ ឯកសារ **D123/1/2.53** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ូ ម៉ៅ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ17 KH 00730233 [សាក្សី គឺជាកម្មករនៅក្នុងកងចល័ត តំបន់៥ ដែលរាយការណ៍ឱ្យយាយថែម៖ "វានិយាយថា អានេះចេះ១មួយចុះមួយ...គាត់ថា អើ! បើវាពិបាក វាប្រឆាំងក្បត់ហើយវ៉ៃចោលទៅ។ វណ្ណៈ៖ គាត់ថាអញ្ចឹងដែរ? ម៉ៅ៖ បាទ! គាត់ថាវ៉ៃចោលទៅ។"]

1093 ឯកសារ **D119/94** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.46 KH 00976182 [សាក្សី គឺជាកម្មករនៅក្នុងកងចល័ត តំបន់៥ ដែលរាយការណ៍ឱ្យយាយថែម៖ "យាយថែម បានឱ្យឈ្លបនាំមឿន ទៅភ្នំទ្រយោង ហើយសម្លាប់នៅទីនោះ។"]។ ឯកសារ **D119/99** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.35 KH 00978923 [សាក្សីធ្វើការនៅកងចល័ត ដែលនៅមើលកូនប្រុសរបស់សំ ប៊ុន នៅពេលគេយល់ឪពុកវាទៅ៖ សំ ប៊ុន ត្រូវបានគេយកទៅសម្លាប់នៅកន្លែងមួយ នៅចន្លោះភ្នំលៀប និងភ្នំទ្រយោង។ ភ្នំទ្រយោងជាមន្ទីរឃុំឃាំង។]។ ឯកសារ **D119/39** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ ខៀ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.28-37 EN 01040536-0104037 [សាក្សី ធ្វើការនៅភូមិស្រះ ហើយប្តីរបស់គាត់ គឺ សំ ប៊ុន៖ "ខ្ញុំមិនដឹងរឿងអ្វីដែលគេចាប់ប្តីរបស់ខ្ញុំទៅសម្លាប់ទេ។ ខ្ញុំដឹងរឿងនេះ តាមមនុស្សម្នាក់ដែលបានយកកូនប្រុសមកឱ្យខ្ញុំ [ពេជ្រ រស់]។ [É] មូលហេតុដែលខ្ញុំដឹងថាប្តីរបស់ខ្ញុំគេចាប់យកទៅសម្លាប់ ពីព្រោះកូនប្រុសទីពីររបស់ខ្ញុំ [...] ឪពុករបស់គេ ត្រូវបានគេចាប់តកទៅសម្លាប់ ប៉ុន្តែកូនខ្ញុំនៅតូចនៅឡើយ ហើយវាប្រាប់ខ្ញុំមិនសូវច្បាស់អំពីរឿងនេះដែរ ប៉ុន្តែក្រោយមក មានមនុស្សម្នាក់ដែលធ្វើការនៅកន្លែងគុកភ្នំលៀប បានប្រាប់ខ្ញុំថា គាត់បានឃើញប្តីរបស់ខ្ញុំគេដាក់ខ្នោះជើង ខ្នោះដៃ ហើយក្រោយមកទើបគេបញ្ជូនយកទៅវាយចោលនៅភ្នំទ្រយោង។ [...] វាគឺជាក្មេងប្រុសម្នាក់ដែលគេចាត់តាំងឱ្យធ្វើជាអ្នកយាមគុកនៅភ្នំលៀប"។]។

1094 ឯកសារ **D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.75 KH 00933111 [សាក្សីជាអ្នកទោសដែលបានកប់សាកសព៖ "ឃើញ យាយថែម បានជិះម៉ូតូ ពណ៌សទៅជួប តាសឿន ដោយមាននិរសាជាអ្នកឌុបគាត់។ ពេលទៅដល់ យាយថែម បានដើរអង្គុយនិយាយជាមួយ តាសឿន ហើយខ្ញុំក៏បានដើរចេញពីទីនោះ តែខ្ញុំមិនដឹងថាពួកគាត់និយាយអ្វីខ្លះទេ។ ក្រោយ១ថ្ងៃនៃការជួបគ្នារវាង យាយថែម និងតាសឿន ក៏មានការសម្លាប់ទ្រង់ទ្រាយព្រោះវៀតណាមជិតចូលមក"] ឆ.82 KH 00933112 ["តាញ៉ែន និង យាយថែម បានទៅគុកភ្នំទ្រយោងមុនព្រឹត្តិការណ៍នោះ"]។ ឯកសារ **D230** កំណត់ហេតុនៃការតទល់មុខគ្នារបស់សាក្សី OCIJ-068, 294, 293, 295, 297, 296 ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ KH 01045304-01045306 KH 01045317 [សាក្សី OCIJ-295 (ធិប សំផាត់) ត្រូវបានដាក់ឱ្យតទល់ពាក់ព័ន្ធនឹងការលើកឡើងរបស់គាត់ និងការលើកឡើងរបស់ ទុំ សឿន អំពីការស្លាប់ និងបញ្ជាក់ចម្លើយរបស់គាត់សាជាថ្មី]។ ឯកសារ **D219/583** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នួ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.46 KH 01166961 [សាក្សីជាអ្នកទោសដែលបានកប់សាកសព៖ "គេបញ្ចេញសម្លាប់បណ្ដើរ១ហើយ គេថាបើកមិទ្ទីញដែលមានរ

យៈពេលពីរថ្ងៃ ពេលប្រជុំចប់គេសម្លាប់ចោលអស់ហើយ។ នៅពេលនោះនៅសល់មនុស្សតែពីរនាក់គត់ដែលគេមិនសម្លាប់ ដែលយកពីសហករណ៍ខ្ញុំមក។ គេទុកពីរនាក់សម្រាប់ជួយសែងខ្មោច ក្រៅពីហ្នឹងគេសម្លាប់ចោលអស់ហើយ"] ឆ.66-67 KH 01166964-01166965 ["មួយអាទិត្យមុននឹងគេធ្វើមិទ្ទីញអត់មានសម្លាប់ទេ។ គេសម្លាប់នៅពេលមានមិទ្ទីញប៉ុណ្ណោះ។ អ្នកដែលត្រូវរស់ គឺគេឲ្យទៅប្រជុំ គឺគេមិនឲ្យឃើញការសម្លាប់នោះទេ ឯអ្នកដែលត្រូវគេសម្លាប់គឺគេសម្លាប់នៅពេលនោះតែម្តង។ [...] នៅពេលនោះ ខ្ញុំបានឃើញកម្មាភិបាលថ្នាក់ខ្ពស់មានដូចជាចៅហ្វាយស្រុក តំបន់ ភូមិភាគ និងមជ្ឈិមបក្សជាដើមមកចូលរួម"] ឆ.70 KH 01166965 ["ចាប់ពីមិទ្ទីញមួយដែលខ្ញុំបានចូលរួម ប្រហែលកន្លះខែ គេធ្វើមិទ្ទីញមួយទៀតនិងសម្លាប់មនុស្ស ហើយកន្លះខែទៀតធ្វើមិទ្ទីញម្តងទៀត។ រួចទើបទ័ពរណសិរ្សគេវាយមក"] ឆ.114 KH 01166972 ["ក្នុងពេល យាយថែម នៅហ្នឹងគឺការសម្លាប់មនុស្សមនុស្សត្រូវបានគេធ្វើឡើង។ ខ្ញុំជាអ្នកយកបាយឲ្យអ្នកទោសហូប តែគេបានប្រាប់មកខ្ញុំវិញថា ថ្ងៃនេះមិនចាំបាច់យកស្ងោទៅឲ្យគោស៊ីទេ"]។ សូមមើលផងដែរ ឯកសារ **D219/567** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សឿន ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៥ ឆ.156 KH 01165956 [សាក្សីជាអ្នកទោស៖ "ស៖ បើសិនជាលោកនឹកឃើញ លោកព្យាយាមនឹកបន្តិចមើល ពេលដែលយាយថែម ទៅគុកហ្នឹងចុងក្រោយគេប្រហែលជាប៉ុន្មានថ្ងៃមុនវៀតណាមវៃចូល? ឆ.156៖ ប្រហែលជា៥ថ្ងៃ"]។

1095 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.60 KH 00933109 [សាក្សីជាអ្នកទោសដែលបានកប់សាកសព៖ "នៅពេលនោះគឺវៀតណាមជិតចូលមកដល់ ដូច្នេះហើយត្រូវបញ្ចេញអ្នកទោសទាំងអស់ចេញ"] ឆ.62 KH 00933110 ["តាសឿន ជាអ្នកបញ្ជាឲ្យសម្លាប់"]។ ឯកសារ **D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.27 KH 00801016 [សាក្សីជាអ្នកទោសដែលបានកប់សាកសព៖ "ខ្ញុំនៅចាំថា នៅពេលមួយនោះគឺមុនពេលវៀតណាមចូលមកដល់ ក្រុមរបស់ខ្ញុំត្រូវបានគេបញ្ជាឲ្យជីកអន្លង់ធំមួយ ហើយឲ្យកប់សាកសពចំនួនប្រហែលជា៩០នាក់"]។ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.29 KH 01085125 [សាក្សីជាអ្នកទោស៖ "ប៉ុន្មានខែក្រោយវៀតណាមចូលស្រុក ខ្ញុំក៏នាំកូនរត់។ កាលនោះគេជីកស្រះបម្រុងនឹងវាយពួកខ្ញុំចោល"] ឆ.42 KH 01085127 [ស៖ "[É] តើលោកស្រីបានឃើញស្រះនោះទេ? តើស្រះនោះនៅទីណាដែរ? ឆ.42៖ ចាស ខ្ញុំបានឃើញស្រះនោះ។ ស្រះនោះស្ថិតនៅខាងជើងភ្នំក្បែរកន្លែងខ្ញុំរស់នៅ។ ស្រះនោះមានទំហំ ៥០ ម៉ែត្រ បួនជ្រុង មានជម្រៅ ជ្រៅលិចក្បាលមនុស្ស ប្រហែល ២ ម៉ែត្រ។ ពួកគេបានឲ្យ ខ្ញុំ និងអ្នកទោសផ្សេងទៀតជីកស្រះ ប៉ុន្តែ ពួកខ្ញុំមិនដឹងថាគេឲ្យពួកខ្ញុំជីកស្រះនោះធ្វើអ្វីនោះទេ។ នៅពេលដែលខ្ញុំសួរពួកគេ គេបានប្រាប់ថា ជីកស្រះសម្រាប់ស្តុកទឹកប្រើប្រាស់"]។ ឯកសារ **D1.3.11.20** បទសម្ភាសន៍របស់ SOAS ជាមួយ គឹម នៅ (Keum Nov) ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ EN 00211886 [សាក្សីជាអ្នកទោស៖ "មួយយប់មុនពេលវៀតណាមចូលមកដល់ យោធានៅគុកបានសម្លាប់អ្នកទោសធ្ងន់ទាំងអស់ តែអ្នកទោសស្រាលមិនបានសម្លាប់ទេ។ អ្នកទោសដែលជាប់ខ្មោះត្រូវបានសម្លាប់ទាំងអស់ ប៉ុន្តែពួកយោធាភ័យតក់ស្លុត ហើយពួកយើងក៏នាំគ្នារត់ចេញ"]។ ឯកសារ **D5/1204** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សោម ធឿម ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៣ KH 01031276 [សាក្សីជាប្រពន្ធអ្នកទោស៖ "នៅឆ្នាំ ១៩៧៨ គេបានយកប្តីឈឺ យកទៅដាក់ក្នុងគុកភ្នំត្រយោង ដោយគាត់ជីកកណ្តាប់ ហើយស្រូវជ្រុះក្នុងបាតរទេះ [...] ខ្ញុំដឹងថា ពេលនោះវៀតណាមចូលមកហើយគេចាប់បណ្តើរ ហើយបាញ់សម្លាប់ទាំងងស់សរុបប្រហែល

៦០០នាក់-៧០០នាក់ ហើយមានអ្នកខ្លះរត់រួច បានប្រហែល៥០នាក់ ពេលគេចេញមកគេប្រាប់ខ្ញុំ តែអកុសលតែប្តីរបស់ខ្ញុំរត់មិនបាន"]។ សូមមើលផងដែរ ឯកសារ **D119/19** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផុន ម៉ុន ហៅ សាមុន ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ ឆ.37 KH 00894496 [សាក្សីជាអ្នកទោសៈ "នៅដើមឆ្នាំ ១៩៧៩ ពេលកងទ័ពវៀតណាមចូលមកដល់ យោធាបានមកប្រាប់ខ្ញុំឱ្យបរទេះគោដឹកក្រណាត់និងក្បាលម៉ាស៊ីនដេរ ទៅផ្ទះយាយចែមដើម្បីរត់ទៅជាមួយពួកគេ ទៅព្រៃកូនខ្លែង ខាងជើងស្រុកភ្នំស្រុក។ នៅពេលនោះ មានជាងឈើពីរនាក់ដែលរត់ទៅជាមួយដែរនោះ បានបាត់ខ្លួន ហើយឮថាគេយកទៅសម្លាប់បាត់ហើយ។ ពេលនៅក្នុងព្រៃ គេឱ្យខ្ញុំបើកអង្ករ ហើយខ្ញុំក៏មានឱកាសរត់គេចខ្លួនទៅចូលក្នុងព្រៃក្នុងស្រុកសំរោង ខេត្តសៀមរាប ហើយរស់រហូតដល់សព្វថ្ងៃ"]។

1096 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.60 KH 00933109 [សាក្សីជាអ្នកទោសៈ "នៅពេលនោះគឺវៀតណាមជិតចូលមកដល់ ដូច្នេះហើយត្រូវបញ្ចេញអ្នកទោសទាំងអស់ចេញ។ គេបានបញ្ជាឱ្យមនុស្សប្រាំនាក់ ក្នុងនោះមានខ្ញុំដែរ ទៅជីករណ្តៅនៅម៉ោង១២យប់។ រណ្តៅនោះប្រហែលជា៤ម៉ែត្របួនជ្រុង ហើយមានជម្រៅជាង១ម៉ែត្រ"]។ សូមមើលផងដែរ ឯកសារ **D219/252** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែង លៀប ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ឆ.29 KH 01085125 [សាក្សីជាអ្នកទោសៈ "ប៉ុន្មានខែក្រោយវៀតណាមចូលស្រុក ខ្ញុំក៏នាំកូនរត់។ កាលនោះគេជីកស្រះបម្រុងនឹងវាយពួកខ្ញុំចោល"] ឆ.42 KH 01085127 [សៈ "[...] តើលោកស្រីបានឃើញស្រះនោះទេ? តើស្រះនោះនៅទីណាដែរ? ឆ.42ៈ ចាស ខ្ញុំបានឃើញស្រះនោះ។ ស្រះនោះស្ថិតនៅខាងជើងភ្នំក្បែរកន្លែងខ្ញុំរស់នៅ។ ស្រះនោះមានទំហំ ៥០ ម៉ែត្រ បួនជ្រុង មានជម្រៅ ជ្រៅលិចក្បាលមនុស្ស ប្រហែល ២ ម៉ែត្រ។ ពួកគេបានឱ្យ ខ្ញុំ និងអ្នកទោសផ្សេងទៀតជីកស្រះ ប៉ុន្តែ ពួកខ្ញុំមិនដឹងថាគេឱ្យពួកខ្ញុំជីកស្រះនោះធ្វើអ្វីនោះទេ។ នៅពេលដែលខ្ញុំសួរពួកគេ គេបានប្រាប់ថា ជីកស្រះសម្រាប់ស្តុកទឹកប្រើប្រាស់"]។

1097 ឯកសារ **D119/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.64 KH 00933110 [សាក្សីជាអ្នកទោសៈ "នៅពេលដែលគេរើសម្លាប់អ្នកទោស១០នាក់អស់ហើយ គេទៅបណ្តើរអ្នកទោសពីរោងអ្នកទោស១០នាក់ "] ឆ.56 KH 00933109 ["អ្នកទោសធ្ងន់គេដាក់ខ្នោះ នៅកន្លែងរោងមួយដែលគេសង់ទុកនៅខាងជើងភ្នំ ហើយរោងនោះដាក់អ្នកទោសបានប្រហែល១០០នាក់ ហើយរហូតដល់ថ្ងៃគេសម្លាប់"]។ សូមមើលផងដែរ ឯកសារ **D219/583** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.85 KH 01166968 ["គេដឹកយកមកម្តងពីរ ម្តងមួយ ហើយដៃមានជាប់ចំណង"] ឆ.86 KH 01166968 [សាក្សីជាអ្នកទោសៈ "សៈ តើកន្លែងចាំមុនយកទៅសម្លាប់មានចម្ងាយប៉ុន្មានពីកន្លែងរើសម្លាប់មនុស្សដែរ? ឆ.86ៈ វាមានឆ្ងាយប្រហែល ៤, ៥ ទៅ ៦ ម៉ែត្រ"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ឆ.31 KH 01058730 [សាក្សីជាអ្នកទោសៈ "អ្នកទោសដែលគេត្រូវយកទៅសម្លាប់ គឺគេបញ្ចេញមកពីរោងដែលខ្ញុំធ្លាប់ជាប់ខ្នោះនោះ ទៅដាក់ក្នុងរោងហាប់ដែលមានទីតាំងក្បែររោងខ្ញុំដេកនៅដែរ។ គេដាក់អ្នកទោសទាំងនោះក្នុងរោងហាប់ទាំងជាប់ចំណង ហើយបញ្ចេញយកទៅសម្លាប់នៅម្តុំម៉ោងប្រាំពីរប្រាំបីយប់"]។

1098 ឯកសារ **D106/8** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ឆ.31 KH 00801017 [សាក្សីជាអ្នកទោសៈ "អ្វីដែលខ្ញុំបានឃើញ មិនមានអ្នកសម្លាប់មនុស្សច្រើនទេ។ អ្នកទោសត្រូវគេបានគេចង

ហើយបញ្ជាឲ្យអង្គុយនៅមាត់រណ្ដៅ ហើយបន្ទាប់មក ត្រូវបានគេវាយនឹងដំបងត្រង់កញ្ចឹងកង។ នៅពេលអ្នកសម្លាប់នោះអស់កម្លាំង គេសំរាក ហើយមានអ្នកសម្លាប់ម្នាក់ទៀត បន្តការសម្លាប់ជំនួស"]។ ឯកសារ **D119/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ធិប សំផាត់ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.62 KH 00933110 [សាក្សីជាអ្នកទោស៖ "តាសឿន ជាអ្នកបញ្ជាឲ្យសម្លាប់ ហើយមានយោធា៣០នាក់ជាអ្នកវៃសម្លាប់អ្នកទោសទាំងនោះ"]។ *សូមមើលផងដែរ* ឯកសារ **D219/583** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នូ ខាំ ហៅ ខាន់ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឆ.84 KH 01166967 [សាក្សីជាអ្នកទោស៖ "គ្នាវាទាំងអស់មាន ៧នាក់។ ពួកគេបានបែងចែកការងារគ្នា គឺមានអ្នកវៃម្នាក់ចាំតែវៃ ម្នាក់ទៀតអ្នកអូសអ្នកទោសយកមក អ្នកចាំផ្លូវ រួចពួកគេផ្លាស់វេនគ្នាធ្វើការ។ ឈាមអ្នកទោសដែលត្រូវគេវៃបាញ់ដូចពេលយើងប្រើធុងទឹកស្រោចដំណាំដូច្នោះដែរ"]។

1099 ឯកសារ **D219/141** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥ ឆ.11-23 KH 01056101-01056102 [សាក្សីជាអ្នកធ្វើការក្នុងកងចល័ត៖ "ខ្ញុំឃើញនៅមន្ទីរសន្តិសុខ។ [É] នៅរោងមន្ទីរសន្តិសុខដែលធ្វើពីឈើ ប្រក់ស័ង្កសី តែមិនមានជញ្ជាំងទេ។ ខ្នោះឈើនោះមានកម្រាសប្រហែល៧ហ៊ុន បន្ទារមានកម្រាសមួយតឹកកន្លះ និងបណ្ដោយប្រវែងប្រហែល១០០ម៉ែត្រ។ [É] សាកសពនោះមិនស្លាប់ដោយសារគេសម្លាប់ទេ តែសាកសពនោះស្លាប់នៅជាប់ខ្នោះ។ [É] ពួកគេស្លាប់ដោយសារអត់អាហារ។ [É] សាកសពនោះហើម។ [É] ខ្ញុំឃើញតែ២សាកសព"]។ ឯកសារ **D219/422.14** ប្រតិចារិកបទសម្ភាសន៍របស់ យក់ នៀម ចម្លងចេះពីឯកសារសំឡេង D43R ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ KH 01121241 [សាក្សីជាអ្នកធ្វើការក្នុងកងចល័ត៖ "ឆ្នាំកាលដែលយួនចូលមក"]។ ឯកសារ **D106/4** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាយ ខាន់ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ឆ.24 KH 00800990-00800991 [សាក្សីជាអ្នកភូមិជិតខាង៖ "ប្រហែលពីរសប្ដាហ៍ក្រោយមក ខ្ញុំបាននៅនោះ ដើម្បីប្រមូលក្ដារ ខ្ញុំបានឃើញអ្នកទោសខ្លះស្លាប់នៅទៅនោះ។ ខ្ញុំឃើញមានអ្នកទោសប្រហែលជាដប់នាក់ ស្លាប់នៅទីនោះ ហើយសាកសពរបស់ពួកគេនៅរឹងនៅឡើយ។ ខ្ញុំគិតថា អ្នកដែលស្លាប់នោះគឺជាអ្នកទោសដែលឈឺ ពួកគេមិនមានជាប់ចំណង ឬខ្នោះទេ។ ខ្ញុំមិនឃើញមានអ្នកទោសដែលស្លាប់មានជាប់ចំណងទេ។ អ្នកយាមបានរត់គេចអស់ នៅពេលវៀតណាមចូលមកដល់ ពីព្រោះពួកគេភ័យខ្លាច ហើយមិនមានពេលគ្រប់គ្រាន់ដើម្បីសម្លាប់អ្នកទោសទាំងនោះទេ"]។ ឯកសារ **D219/400** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប៊ូ តួក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.141-142 KH 01115786 [សាក្សីជាអ្នកទោស៖ "ពួកអ្នកយាមនៅទីនោះប្រាប់ថា អ្នកណាមកពីសហករណ៍ណាទៅសហករណ៍ហ្នឹងវិញទៅ។ [É] ពួកហ្នឹងរត់ទៅភ្នំកូនខ្លែងអស់ហើយ [É] មានប្រហែលជា ៤នាក់ជាប់ខ្នោះ តែប្រហែលមានគ្នាខ្ញុំដែលមានកម្លាំងគាស់បាន ព្រោះស្គមៗដូចខ្ញុំអត់កម្លាំង ក៏រត់ទៅ ព្រោះខ្លាចយោធាមកវិញ"]។ ឯកសារ **D119/137** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ិត អៀក ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.44 KH 01003861 [សាក្សីជាអ្នកធ្វើការនៅផ្នែកសេដ្ឋកិច្ចនៅភ្នំល្មៀប៖ "នៅពេលនោះខ្ញុំបានទៅរកឈើនៅទីនោះ ពីព្រោះនៅទីនោះ គេមានធ្វើរោងឈើ ដូច្នេះហើយ យើងមានគោលបំណងទៅរុះយកឈើទាំងនោះ មកធ្វើជាជម្រកស្នាក់របស់យើង។ [É] នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឃើញខ្នោះឈើសម្រាប់ដាក់ជើង នៅសេសសល់នៅទីនោះជាច្រើនគ្រឿង ព្រមទាំងឃើញមាន ចប និងបង្គីទៀតផង។ ខ្ញុំក៏បានឃើញមានកន្លែងកប់សាកសពជាច្រើននៅទីនោះផងដែរ ប៉ុន្តែកន្លែងកប់សាកសពនោះ មិនមែនសុទ្ធតែជាកន្លែងកប់សាកសពដែលគេបានសម្លាប់នៅភ្នំត្រយ៉ូងនោះទេ

ប៉ុន្តែជាកន្លែងកប់សាកសពមនុស្សដែលស្លាប់ដោយសារការអត់អាហារ និងជំងឺផងដែរ"] ឆ.46-48 KH 01003860-01003861 ["ខ្ញុំមិនអាចកត់សម្គាល់បានទេ ហើយនៅពេលនោះ លលាដ៏ក្បាលបាននៅរាយប៉ាយនៅបរិវេណនោះ [É] ជួនកាលខ្ញុំមានឆ្អឹងនៅរាយប៉ាយមិនមានសម្លៀកបំពាក់នៅជាមួយទេ ប៉ុន្តែជួនកាលខ្ញុំឃើញមានឆ្អឹង ហើយនិងសម្លៀកបំពាក់នៅច្របូកច្របល់ជាមួយគ្នា។ [É] ខ្ញុំមិនអាចដឹងទេ ពីព្រោះខ្ញុំឃើញតែកំណាត់សម្លៀកបំពាក់ផ្ទាំងៗ តែប៉ុណ្ណោះ ប៉ុន្តែខ្ញុំតាមសម្គាល់គឺសុទ្ធតែជាសម្លៀកបំពាក់ធម្មតា មិនមែនជាសម្លៀកបំពាក់យោធាទេ"]។ ឯកសារ **D119/22** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឆ.14 KH 00894514 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "ប្រហែលជា២០ថ្ងៃ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ខ្ញុំបានវិលត្រឡប់មកភូមិកំណើតរបស់ខ្ញុំវិញជាមួយឪពុកម្តាយរបស់ខ្ញុំ។ នៅពេលនោះ ខ្ញុំបានទៅមើលមន្ទីរសន្តិសុខភ្នំត្រយោង។ អ្នកភូមិបានទៅរុះរើរោងនៅមន្ទីរសន្តិសុខអស់ហើយ ដើម្បីយកឈើមកធ្វើផ្ទះ"]។

1100 ឯកសារ **D119/22** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឆ.14 KH 00894514 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តនៅព្រះនេត្រព្រះ៖ "នៅពាក់កណ្តាលឆ្នាំ១៩៧៩ អាជ្ញាធរមូលដ្ឋានបានឲ្យប្រជាជនប្រមូលឆ្អឹងទាំងនោះ ទៅតម្កល់នៅក្នុងស្តូបមួយក្នុងវត្តភ្នំលៀប តែដោយដាក់មិនអស់ ឆ្អឹងមួយចំនួនត្រូវបានគេប្រមូលដុតចោល"]។ **សូមមើលផងដែរ** ឯកសារ **D219/400** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ូ ត្លុក ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.164 KH 01115788 [សាក្សីជាអ្នកទោស៖ "ពេលចប់ហើយ ខ្ញុំចុះទៅ មានរណ្តៅពីរ តែឆ្អឹងអីហ្នឹង គេរើរុះអស់ហើយ"]។

1101 ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792065 ["មន្ទីរឃុំឃាំងភូមិចក្រី និងទីកន្លែងសម្លាប់មនុស្សនៅជិតភូមិនេះ មានទីតាំងនៅចម្ងាយប្រហែល ៣០ នាទី ប្រសិនបើធ្វើដំណើរតាមឡានទៅខាងកើតក្រុងស៊ីសុផុន ឆ្ពោះទៅខេត្តសៀមរាប នៅខាងស្តាំដៃផ្លូវជាតិលេខ ៦ បន្ទាប់មកនៅចម្ងាយប្រហែល ៤០០ម៉ែត្រតាមផ្លូវលំដី ដោយមានកន្លែងឃុំឃាំងមួយកន្លែងនៅទល់មុខច្រកចូលមន្ទីរស្រុក"], KH 00792065 ["ទីតាំងសម្លាប់មនុស្សព្រៃតារ៉ូត នៅភូមិក្រសាំងថ្មី ឃុំជប់ សព្វថ្ងៃនេះគឺវាលចម្ការធំមួយ (កាលពីសម័យខ្មែរក្រហម គឺជាព្រៃក្រាស) ដែលមានផ្ទៃដីច្រើន ឬតិចជាង ១០ហិចតា។ ទីតាំងនេះស្ថិតនៅភាគឦសាន ពីភូមិចក្រី និងមន្ទីរស្រុក"]។ ឯកសារ **D219/205** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ.5 KH 01072290 [សាក្សីបានប្រមូលភ័ស្តុតាងដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរៀបចំរបាយការណ៍ ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ] "នៅកន្លែងនោះត្រូវបានគេហៅថា ភូមិចក្រី ដែលស្ថិតនៅខាងលិចសាលាស្រុកព្រះនេត្រព្រះ"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.18 KH 01049193 [សាក្សីជាឈ្លបនៅឃុំជប់វារី និងបានរស់នៅទីតាំម្ខាងផ្លូវជាតិលេខ៦ ពីភូមិចក្រី៖ "ពេលនោះខ្ញុំរស់នៅភូមិរោលជ្រូកដែលមានទីតាំងនៅម្ខាងផ្លូវជាតិលេខ៦ ហើយភូមិចក្រីនៅម្ខាងទៀតនៃផ្លូវជាតិលេខ៦"]។ ឯកសារ **D5/965/3** ទំរង់បែបបត័មានបន្ថែមរបស់ យូ មុត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ KH 01115123 [សាក្សីជាអ្នកទោសនៅចក្រី៖ "ក្នុងឆ្នាំនោះ គាត់ត្រូវបានពួកយោធាខ្មែរក្រហមមិនស្គាល់ឈ្មោះបានចាប់បញ្ជូនគាត់មកដាក់នៅមន្ទីរសន្តិសុខភូមិចក្រី ឃុំជប់វារី

ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ"]។ ឯកសារ **D119/102** កំណត់ហេតុនៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH 01224749 ["នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់យើង យើងបានរកឃើញថា ទីតាំងសម្លាប់មនុស្សឈ្មោះ "ព្រៃតារុត" ស្ថិតនៅចម្ងាយប្រហែល ៣ គីឡូម៉ែត្រនៅភាគឦសាននៃទីតាំងដែលបានលើកឡើងនៅក្នុងភូមិចក្រី"]។

1102 ឯកសារ **D119/125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.14 KH 00987279 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តដែលត្រូវគេបញ្ជូនទៅឃុំជប់វារី និងបានរស់នៅជិតផ្លូវទៅព្រៃតារុត៖ "ព្រឹត្តិការណ៍នៃការចាប់ខ្លួន និងសម្លាប់មនុស្សនៅក្បែរស្រះក្នុងភូមិចក្រី បានកើតឡើងនៅពេលដែលយាយថែម ធ្វើជាគណៈស្រុកនៅទីនេះ"]។ ឯកសារ **D106/3** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហៀម សាខន ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឆ.14 KH 00780975 [សាក្សីបានឃាមចម្ការដំឡូងនៅព្រៃតារុត និងបានរស់នៅក្នុងខ្ទមតូចមួយនៅទីនោះ៖ "សៈ តើនរណាគេជាអ្នកគ្រប់គ្រងរួមនៅក្នុងតំបន់នេះក្នុងឆ្នាំ១៩៧៨? ឆៈ នៅពេលនោះ ពួកនិរតីចូលមក រួមមាន យាយថែម ដែលជាប្រធានស្រុក និងតារស់ ជាប្រធានឃុំ។ ខ្ញុំខ្លាចគេឡើងរួញខ្លួនអស់ហើយ នៅពេលនោះ"] ឆ.23 KH 00780976 ["សៈ តាមលោកដឹង តើព្រៃតារដ្ឋត្រូវគេយកធ្វើជាកន្លែងសម្លាប់មនុស្សនៅពេលណា? ឆៈ មានចាប់ពីចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ រហូតមក។ ពេលនោះជាពេលដែលពួកនិរតីបានមកដល់ ហើយនៅពេលនោះ ពួកគណៈស្រុកចាស់ និងប្រធានកងចាស់ ត្រូវបានគេសម្លាប់ចោលអស់"]។ ឯកសារ **D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាច់ គិត ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឆ.19 KH 00780968 [សាក្សីជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះ៖ "ទីតាំងនោះ កើតមាននៅពេលដែល យាយថែម មកគ្រប់គ្រង ហើយបន្ទាប់មកតី ហ៊ឹង បានបាត់ខ្លួន"]។ សូមមើលផងដែរ ឯកសារ **D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.28 KH 00976157 [សាក្សី ស៊ុម តៅ ជាអ្នកធ្វើការក្នុងកងចល័ត ហើយផ្ទះគាត់មានចម្ងាយ ៣០០ម៉ែត្រ ពីព្រៃតារុត៖ "ព្រឹត្តិការណ៍នេះ កើតឡើងប្រហែលជានៅក្នុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៨ រហូតដល់ចប់របបខ្មែរក្រហម"]។

1103 ឯកសារ **D119/125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.23 EN 00780976 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តដែលត្រូវគេបញ្ជូនទៅឃុំជប់វារី និងបានរស់នៅជិតផ្លូវទៅព្រៃតារុត៖ "សៈ តាមលោកដឹង តើព្រៃតារដ្ឋត្រូវគេយកធ្វើជាកន្លែងសម្លាប់មនុស្សនៅពេលណា? ឆៈ មានចាប់ពីចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ រហូតមក។ ពេលនោះជាពេលដែលពួកនិរតីបានមកដល់ ហើយនៅពេលនោះ ពួកគណៈស្រុកចាស់ និងប្រធានកងចាស់ ត្រូវបានគេសម្លាប់ចោលអស់"]។

1104 ឯកសារ **D119/125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.23 EN 00784864 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តដែលត្រូវគេបញ្ជូនទៅឃុំជប់វារី និងបានរស់នៅជិតផ្លូវទៅព្រៃតារុត៖ ["សៈ តាមលោកដឹង តើព្រៃតារុតត្រូវគេយកធ្វើជាកន្លែងសម្លាប់មនុស្សនៅពេលណា? ឆៈ មានចាប់ពីចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ រហូតមក។ ពេលនោះជាពេលដែលពួកនិរតីបានមកដល់"] ឆ.14 KH 00987279 ["ព្រឹត្តិការណ៍នៃការចាប់ខ្លួន និងសម្លាប់មនុស្សនៅក្បែរស្រះក្នុងភូមិចក្រី បានកើតឡើងនៅពេលដែលយាយថែម ធ្វើជាគណៈស្រុកនៅទីនេះ"]។ ឯកសារ **D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.28 KH 00976157 [សាក្សី ស៊ុម តៅ

ជាអ្នកធ្វើការក្នុងកងចល័ត ហើយផ្ទះគាត់មានចម្ងាយ ៣០០ម៉ែត្រ ពីព្រៃតារុតៈ "សៈ សូមលោកពន្យល់ឱ្យបានក្បោះក្បាយ អំពីព្រៃតារដ្ឋ បន្ថែមទៀតបានទេ? ឆៈ ផ្ទះរបស់ខ្ញុំមានចម្ងាយប្រហែល៣០០ម៉ែត្រពីព្រៃតារដ្ឋ។ នៅម៉ោងប្រហែល៦ ទៅ៧ យប់ ខ្ញុំបានឮសទ្ទឹកឡានមកព្រៃតារដ្ឋ ពីទិសខាងត្បូងគឺពីផ្លូវជាតិលេខ៦។ មួយសន្ទុះក្រោយមក ខ្ញុំបានឮសំឡេងក្មេងក្អាង ស្រែក [É] ព្រឹត្តិការណ៍នេះ កើតឡើងប្រហែលជានៅក្នុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៨ រហូតដល់ចប់របបខ្មែរក្រហម"]។ ឯកសារ **D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាច់ គិត ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឆ.18 KH 00780968 [សាក្សីជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះៈ "យាយថែម មកគ្រប់គ្រងនៅឆ្នាំ ១៩៧៨ តែមិនចាំខែទេ"]។ ឯកសារ **D219/385** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួន ហឿក ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.31 KH 01113242 [សាក្សីនៅផ្ទះគាត់នៅកងពីរ នៅពេលគាត់ឃើញគេដឹកអ្នកទោសតាមយានយន្តពីផ្លូវជាតិលេខ៦ ឆ្ពោះទៅផ្លូវលំមួយទៅភាគ ប្លិសានៈ "សៈ ពេលលោកឃើញឡានដឹកមនុស្សនោះ តើវាកើតឡើងមុនវៀតណាមចូលយូរទេ? ឆៈ ខ្ញុំឃើញព្រឹត្តិការណ៍នេះ រយៈពេលយូរដែរមុនវៀតណាមចូល ប៉ុន្តែព្រឹត្តិការណ៍នោះ កើតឡើងក្នុងអំឡុងពេលនិរតីគ្រប់គ្រង"]។ ឯកសារ **D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាច់ គិត ឆ.20 KH 00780968 [សាក្សីជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះៈ "ខ្ញុំ ឃើញមនុស្សនៅក្នុងផ្ទះនោះ តែពួកគេមិនត្រូវបានគេចងទេ។ ពួកគេបាននិយាយប្រាប់អ្នកដែលខ្ញុំស្គាល់ថា ពួកគេត្រូវបានអង្គ ការប្រាប់ថាឱ្យធ្វើការនៅកន្លែងផ្សេង។ ស្ថានភាពដូចគ្នានេះ មានបន្តពេញឆ្នាំ ១៩៧៨ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩"] ។ ឯកសារ **D106/3** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហៀម សាខន ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ឆ.23 KH 00780976 ["សៈ តាមលោកដឹង តើព្រៃតារដ្ឋត្រូវគេយកធ្វើជាកន្លែងសម្លាប់មនុស្សនៅពេលណា? ឆៈ មានចាប់ពីចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ១៩៧៨ រហូតមក។ ពេលនោះជាពេលដែលពួកនិរតីបានមកដល់ ហើយនៅពេលនោះ ពួកគណៈស្រុកចាស់ និងប្រធានកងចាស់ ត្រូវបានគេសម្លាប់ចោលអស់"]។ *ផ្ទុយនឹង* ឯកសារ **D219/175** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.29 KH 01066001 [សាក្សីជាអ្នកធ្វើការក្នុងកងចល័តនៅតំបន់៥ៈ "សៈ យោងតាមកំណត់ហេតុស្តាប់ចម្លើយសាក្សី យូ មុត (D219/1) ត្រង់ទំព័រទី ៩ ជាភាសាខ្មែរ សាក្សី យូ មុត បាននិយាយថា លោកបានដឹងរឿងគេចាប់ដឹកមនុស្សចេញពីភូមិចក្រីយកទៅសម្លាប់។ តើលោកអាចពន្យល់ប្រាប់យើងអំពីរឿងនេះបានដែរ ឬទេ? ឆៈ ទាក់ទងអំពីរឿងនេះ គឺខ្ញុំគ្រាន់តែដឹងអំពីការចាប់ខ្លួននៅក្នុងក្រុមរបស់ខ្ញុំទេ។ ក្រុមរបស់ខ្ញុំត្រូវបានគេចាត់ឱ្យទៅ លើកទំនប់អមផ្លូវជាតិចាប់ពីភូមិចក្រី មកដល់ភូមិព្រៃមាន់។ នៅពេលនោះ ប្រសិនបើអ្នកណាឈឺ គឺគេចោទថា អ្នកនោះមាន ជំងឺសតិអារម្មណ៍ ហើយគេចាប់ដាក់ឡានយកចេញទៅ។ ព្រឹត្តិការណ៍នេះ គឺខ្ញុំឃើញនៅក្នុងការគ្រប់គ្រងរបស់កម្មាភិបាលពា យ័ព្យ"] ឆ.19 KH 01065999 ["សៈតាមលោកយល់ តើតាវ៉ាល់ និងតាមោង ត្រូវបានគេដកចេញដែរឬទេ? ឆៈ ខ្ញុំមិនអាច ដឹងរឿងនេះបានទេ ពីព្រោះនៅពេលដែលពួកនិរតីមកដល់ កម្មាភិបាលពាយ័ព្យធំៗទាំងអស់តែងតែមានការព្រួយបារម្ភចំពោះ រឿងផ្ទាល់ខ្លួនរបស់ពួកគេ"] ឆ.30 KH 01066001 ["សៈ តើលោកដឹងថាមានគុក ឬកន្លែងសម្លាប់មនុស្សនៅក្នុងភូមិចក្រី នោះដែរទេ? ឆៈ ខ្ញុំមិនដឹងទេ"] ឆ.22 KH 01066000 ["សៈ នៅពេលដែលលោកមកធ្វើការនៅឃុំប្រាសាទ តើលោកដឹងថា នរណាជាអ្នកគ្រប់គ្រងនៅកងរបស់លោកនៅពេលនោះ? ឆៈ តាមខ្ញុំដឹង គឺនៅពេលនោះ តាវ៉ាល់ និងតាមោង បានបាត់ខ្លួន ហើយកងចល័តរបស់ខ្ញុំត្រូវបានគ្រប់គ្រងដោយកម្មាភិបាលនិរតី"] ឆ.23 KH 01066000 ["ខ្ញុំធ្វើការនៅទីនោះបានពីរខែ មុន ពេលដែលកងទ័ពវៀតណាមចូលដល់"]។

1105 ឯកសារ **D219/212** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខុប សុក ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឆ.24 KH 01074064 [សាក្សីនៅក្នុងកងចល័ត ត្រូវបានបញ្ជូនទៅស្រុកភ្នំស្រុក និងបានឃើញគេចាប់ខ្លួន យូ មុត៖ "នៅពេលនោះហើយដែល យូ មុត ត្រូវបានគេចាប់ដាក់គុកនៅជប់វារី"]។ ឯកសារ **D219/437** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ គិន ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.15 KH 01124197 [សាក្សីបានធ្វើការជាមួយ យូ មុត ក្នុងកងចល័តនៅជប់វារី និងបានរស់នៅជិត (នៅម្ខាងផ្លូវ) គុកជប់វារី៖ "ជប់វារីនៅក្នុងស្រុកព្រះនេត្រព្រះ"]។ ឯកសារ **D5/965/3** ទំរង់បែបព័ត៌មានបន្ថែមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ មុត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ KH 01115123 [សាក្សី យូ មុត ជាអ្នកទោសនៅចក្រី៖ "ក្នុងឆ្នាំនោះ គាត់ត្រូវបានពួកយោធាខ្មែរក្រហមមិនស្គាល់ឈ្មោះបានចាប់បញ្ជូនគាត់មកដាក់នៅមន្ទីរសន្តិសុខភូមិចក្រី ឃុំជប់វ៉ារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ"]។

1106 ឯកសារ **D106/14** របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ ក.ស.ច.ស KH 00787423 ["អ្នកទោសខ្លះត្រូវបានយកទៅសម្លាប់នៅភូមិផាល ឬគេហៅថាភូមិចក្រី" (ភូមិចក្រីមានឈ្មោះម្យ៉ាងទៀតគឺភូមិផាល)]។

1107 ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792065 ["មន្ទីរឃុំឃាំងភូមិចក្រី និងទីកន្លែងសម្លាប់មនុស្សនៅជិតភូមិនេះ មានទីតាំងនៅចម្ងាយប្រហែល ៣០ នាទី ប្រសិនបើធ្វើដំណើរតាមឡានទៅខាងកើតក្រុងស៊ីសុផុន ឆ្ពោះទៅខេត្តសៀមរាប នៅខាងស្តាំដៃផ្លូវជាតិលេខ ៦ បន្ទាប់មកនៅចម្ងាយប្រហែល ៤០០ម៉ែត្រតាមផ្លូវលំដី ដោយមានកន្លែងឃុំឃាំងមួយកន្លែងនៅទល់មុខច្រកចូលមន្ទីរស្រុក"]។

1108 ឯកសារ **D219/173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្តើង ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.37 KH 01065978 [សាក្សីបានរស់នៅចម្ងាយពីរគីឡូម៉ែត្រពីព្រៃតារុត៖ "ព្រៃតារុតនេះ មានមនុស្សខ្លះហៅថា បុស្សចេក តែតាមពិតគឺជាទីតាំងតែមួយទេ"]។ ឯកសារ **D219/385** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួន ហឿក ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.27 KH 01113242 [សាក្សីនៅផ្ទះគាត់នៅកងពីរ នៅពេលគាត់ឃើញគេដឹកអ្នកទោសតាមយានយន្តពីផ្លូវជាតិលេខ៦ ឆ្ពោះទៅផ្លូវលំមួយទៅភាគព្លសាន៖ "ជួនកាលព្រៃតារុត នេះ ត្រូវបានគេហៅថា ព្រៃបុសចេក តែតាមពិត ឈ្មោះទាំងពីរនេះ ជាទីតាំងតែមួយទេ"]។

1109 ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792065 ["ទីតាំងសម្លាប់មនុស្សព្រៃតារ៉ូត នៅភូមិក្រសាំងថ្មី ឃុំជប់ សព្វថ្ងៃនេះគឺវាលចម្ការធំមួយ (កាលពីសម័យខ្មែរក្រហម គឺជាព្រៃក្រាស) ដែលមានផ្ទៃដីច្រើន ឬតិចជាង ១០ហិចតា។ ទីតាំងនេះស្ថិតនៅភាគព្លសាន ពីភូមិចក្រី និងមន្ទីរស្រុក។ ទីតាំងនេះអាចទៅដល់ តាមផ្លូវកែងបត់ចូលទៅត្រពាំងថ្ម និងស្រុកភ្នំស្រុក តាមផ្លូវជាតិលេខ ៦ នៅភូមិព្រះនេត្រព្រះ"]។ ឯកសារ **D119/102** កំណត់ហេតុនៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ KH 01224749 ["នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់យើង យើងបានរកឃើញថា ទីតាំងសម្លាប់មនុស្សឈ្មោះ "ព្រៃតារុត" ស្ថិតនៅចម្ងាយប្រហែល ៣ គីឡូម៉ែត្រនៅភាគព្លសាននៃទីតាំងដែលបានលើកឡើងនៅក្នុងភូមិចក្រី"]។ ឯកសារ **D219/173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្តើង ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.42 KH 01065978 [សាក្សីបានរស់នៅចម្ងាយពីរគីឡូម៉ែត្រពីព្រៃតារុត៖ "កន្លែងដែលគេសម្លាប់មនុស្សឈ្មោះព្រៃតារុត ស្ថិតនៅភូមិក្រសាំងថ្មី"]។

1110 ឯកសារ **D219/384** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌឹក គុយ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.21 KH 01113233 [សាក្សីបានរស់នៅ និងធ្វើការនៅភូមិជ្រាប់ ស្រុកព្រះនេត្រព្រះ៖ "ទីតាំង ព្រៃតារ័ត្ននេះ (ព្រៃតារុត) ស្ថិតនៅខាងលិចភូមិប្រាសាទ ដែលមានចម្ងាយប្រហែលជា ១,៥ គីឡូម៉ែត្រ ពីភូមិជប់នេះ។ ផ្លូវចូលទៅកាន់ទីតាំងព្រៃតារុត គឺស្ថិតនៅតាមបណ្តោយផ្លូវមួយ ទៅកាន់ឃុំទានកាំ ចុះពីផ្លូវជាតិលេខ៦ ទៅកាន់ទិសខាងជើង"]។ ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792066 ["ច្រកចូលទីកន្លែងសម្លាប់នេះមានចម្ងាយ ២ គីឡូម៉ែត្រពីផ្លូវកែងផ្លូវជាតិលេខ ៦ តាមផ្លូវលំបត់ចូលទៅត្រពាំងថ្ម និងស្រុកភ្នំស្រុក យោង GPS៖ N= 1338.'555 - E= 103 11. 479"]។

1111 ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792065 ["មន្ទីរឃុំឃាំងភូមិចក្រី មានផ្ទះឈើមួយ និងបន្ទប់ទឹកមួយនៅខាងក្រៅ ដែលសព្វថ្ងៃនេះនៅ ឃើញមានចំណែកងផ្ទះឈើវិញត្រូវបានបំផ្លាញចោលនៅចុងឆ្នាំ ១៩៧៨"]។

1112 ឯកសារ **D219/437** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ គិន ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.25 KH 01124199 [សាក្សីបានធ្វើការជាមួយ យូ មុត ក្នុងកងចល័តនៅជប់វារី និងបានរស់នៅជិត (នៅម្ខាងផ្លូវ) មន្ទីរសន្តិសុខចក្រី៖ "វានៅខាងក្រៅរបង និងខាងត្បូងវត្តជប់វារី។ គុកនេះមានបណ្តោយប្រហែល៦ម៉ែត្រ និងទទឹង៥ម៉ែត្រ ហើយមានជញ្ជាំងក្តារ និងដំបូលស័ង្កសី"]។

1113 ឯកសារ **D219/1** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ មុត ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.38 KH 01044857-01044859 [សាក្សីជាអ្នកទោសនៅចក្រី៖ "គេចងដៃខ្ញុំទាំងពីរទៅក្រោយ ហើយរុញខ្ញុំចូលទៅក្នុងគុកនោះ ដែលនៅទីនោះ ខ្ញុំបានឃើញអ្នកទោសប្រហែលជា២០ទៅ៣០នាក់ទៀត ត្រូវបានគេចងដៃទៅក្រោយដូចខ្ញុំដែរ ហើយដែលចំណងចងដៃទាំងនោះស្ទើរតែកប់ទៅក្នុងដៃ ពីព្រោះដៃរបស់ពួកគេបានហើមធំ"]។ សូមមើលផងដែរ ឯកសារ **D5/965** ទំរង់បែបបត័មានបន្ថែមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យូ មុត ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ KH 00989853 [សាក្សី យូ មុត ជាអ្នកទោសនៅចក្រី៖ "បន្ទាប់មក ខ្ញុំត្រូវពួកយោធាបញ្ជូនមកដាក់មន្ទីរសន្តិសុខភូមិចក្រី ឃុំជប់ ស្រុកព្រះនេត្រព្រះ ដោយចោទថា ខ្ញុំធ្វើទាហាន លន់ ណុល [É] ខ្ញុំជាប់ក្នុងគុកកន្លះខែ ដោយដៃជាប់ចំណងជើងជាប់ខ្នោះឈើ មិនអាចអង្គុយបានទេ គឺឈរជារហូត រហូតដល់ដៃជើងជាប់ចំណង ហើយស្វា ហើយមកដៃ។ បន្ទាប់មក ខ្ញុំបានស្រាយពីរួច ពេលយប់ ខ្ញុំយកដៃទាំង២ កកាយដី ទើបចេញបាន"]។ ឯកសារ **D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.25 KH 01114729 [សាក្សីជានិរសាររបស់ អ៊ឹម ចែម៖ "គឺបើតាមឈរពីលើថ្នល់ មើលទៅឃើញថា វាអាចដាក់មនុស្សបានប្រហែលជា២០នាក់"]។

1114 ឯកសារ **D119/125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.12 KH 00987279 [សាក្សីគឺជាកម្មករកងចល័តដែលត្រូវបានបញ្ជូនទៅឃុំជប់វារី និងបានរស់នៅជាប់នឹងផ្លូវទៅកាន់ព្រៃតារុត៖ "ពួកគេត្រូវបានឃុំខ្លួននៅពេលថ្ងៃ ឬ រសៀលហើយនៅពេលយប់ ទើបត្រូវបានគេបញ្ជូនចេញយកទៅសម្លាប់នៅក្បែរស្រះក្នុងភូមិចក្រី។ ស្រះនោះបច្ចុប្បន្នមានទីតាំងនៅទល់មុខសាលាស្រុកព្រះនេត្រព្រះ នៅខាងត្បូងផ្លូវជាតិលេខ៦ និងចម្ងាយប្រហែល១០០ម៉ែត្រពីផ្លូវជាតិ។"]។

1115 ឯកសារ **D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ច្រាច់ គិត ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឆ.22 KH 00780969 [សាក្សីគឺជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះ៖ "ខ្ញុំបានដឹងតាមរយៈ និរសា ដែលបាននិយាយគ្នាពីចំនួនមនុស្សដែលត្រូវបានគេសម្លាប់កាលពីយប់មុិញ។ជួនកាល ពួកគេនិយាយគ្នាពីការចាប់បោកកូនក្មេងទៅនឹងគល់ឈើ។ អ្នកដែលនៅក្បែរនោះ ក៏បានលឺសម្រែកមនុស្សដែរនៅពេលយប់។"]។ ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792065 ["សាក្សី ក្រាច គិត ដែលជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះ (KH 00792064-00792066) បាននាំក្រុមការងារទៅទីតាំងភូមិចក្រី។ គាត់បានបង្ហាញយើងពីទីតាំងដែលប្រជាជនត្រូវបានសម្លាប់ និងកប់ចោល ព្រមទាំងទីតាំងផ្ទះឈើនោះដែលត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំង។ គាត់បានចង្អុលបង្ហាញដើមដូង ៣ ដើម ដែលគេបានចាប់កូនក្មេងបោក។ ទីតាំងនេះស្ថិតនៅចន្លោះទីតាំងរណ្តៅសាកសព និងផ្ទះឃុំឃាំង។"]។ ឯកសារ **D106/15.5** រូបថតនៃរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឧបសម្ព័ន្ធ ៥ KH 00804673 [រូបថតលេខ ៤ ទីតាំងដើមដូងដែលគេបានកម្ទេចកូនក្មេង។]។

1116 ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ EN 00787087 ["ចេញពីផ្លូវជាតិលេខ៦ មានផ្លូវចូលទៅកន្លែងសម្លាប់មនុស្ស និងមន្ទីរឃុំឃាំងភ្នំចក្រី។ សងខាងផ្លូវ មានរណ្តៅកប់សាកសពមនុស្ស"]។

1117 ឯកសារ **D119/125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.12 KH 00987279 [សាក្សីគឺជាកម្មករកងចល័តដែលត្រូវបានបញ្ជូនទៅឃុំជប់វារី និងបានរស់នៅជាប់នឹងផ្លូវទៅកាន់ព្រៃតារុត៖ "ពួកគេត្រូវបានឃុំខ្លួននៅពេលថ្ងៃ ឬ រសៀលហើយនៅពេលយប់ ទើបត្រូវបានគេបញ្ជូនចេញយកទៅសម្លាប់នៅក្បែរស្រះក្នុងភូមិចក្រី។ ស្រះនោះបច្ចុប្បន្នមានទីតាំងនៅទល់មុខសាលាស្រុកព្រះនេត្រព្រះ នៅខាងត្បូងផ្លូវជាតិលេខ៦ និងចម្ងាយប្រហែល១០០ម៉ែត្រពីផ្លូវជាតិ។"]។

1118 ឯកសារ **D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ច្រាច់ គិត ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឆ.22 KH 00780969 [សាក្សីគឺជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះ៖ "ខ្ញុំបានដឹងតាមរយៈ និរសា ដែលបាននិយាយគ្នាពីចំនួនមនុស្សដែលត្រូវបានគេសម្លាប់កាលពីយប់មុិញ។ ជួនកាល ពួកគេនិយាយគ្នាពីការចាប់បោកកូនក្មេងទៅនឹងគល់ឈើ។ អ្នកដែលនៅក្បែរនោះ ក៏បានលឺសម្រែកមនុស្សដែរនៅពេលយប់។"]។ ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792065 ["សាក្សី ក្រាច គិត ដែលជាជាងឈើនៅមន្ទីរស្រុកព្រះនេត្រព្រះ (KH 00792064-00792066) បាននាំក្រុមការងារទៅទីតាំងភូមិចក្រី។ គាត់បានបង្ហាញយើងពីទីតាំងដែលប្រជាជនត្រូវបានសម្លាប់ និងកប់ចោល ព្រមទាំងទីតាំងផ្ទះឈើនោះដែលត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំង។ គាត់បានចង្អុលបង្ហាញដើមដូង ៣ ដើម ដែលគេបានចាប់កូនក្មេងបោក។ ទីតាំងនេះស្ថិតនៅចន្លោះទីតាំងរណ្តៅសាកសព និងផ្ទះឃុំឃាំង។"]។ ឯកសារ **D106/15.5** រូបថតនៃរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឧបសម្ព័ន្ធ ៥ KH 00804673 [រូបថតលេខ ៤ ទីតាំងដើមដូងដែលគេបានកម្ទេចកូនក្មេង។]។ សូមមើលផងដែរ ឯកសារ **D219/205** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ.4 KH 01072289-90 [សាក្សីបានប្រមូលភស្តុតាងឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីរៀបចំរបាយការណ៍ [ឯកសារ **D1.3.10.10** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទី

តាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ៖ "ស៖ ឥឡូវយើងចាប់ផ្តើមនិយាយអំពីភូមិចក្រី នៅក្នុងរបាយការណ៍នៅភូមិចក្រី ព័ត៌មានចុះក្នុងបញ្ជីថា មានជនរងគ្រោះចំនួន ៣៥៧០នាក់។ តើលោកសម្រេចលើចំនួននេះតាមរបៀបណា? ឆ៖ ប៉ុន្តែនៅក្នុងរបាយការណ៍របស់ខ្ញុំគឺមាន ៣៥៨០ នាក់ នេះគឺការសន្និដ្ឋានរបស់សាក្សីៗប្រាប់យើង។ [...] សាក្សីដែលនាំយើងទៅ កន្លែងនោះមិនមានគុកសន្តិសុខទេ គឺជាកន្លែងសម្លាប់តែម្តង គឺគេសម្លាប់មនុស្សដោយចាក់នឹងចំពុះទង់កាំភ្លើង និងវាយខ្ទប់នឹងដើមដូង។"]។

1119 ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792066 ["រណ្តៅសាកសពចំនួន ៤ កន្លែងដំបូងមានទីតាំងនៅវាលចម្ការដ៏ធំមួយដែលចែកជាពីរផ្នែក ដោយមានរបងខណ្ឌគ្នា។ រណ្តៅសាកសពមួយកន្លែងនោះ មានចម្ងាយ ១០០ ម៉ែត្រនៅខាងឆ្វេងដៃច្រកចូលចម្ការ ហើយមានទំហំ ៣ x ៣ ម៉ែត្រការ៉េ ជម្រៅប្រហែល ១,៨ ម៉ែត្រ យោង GPS ៖ <u>N=13 38.555" é E= 103 11.516"</u>។ រណ្តៅបីផ្សេងទៀតមានទីតាំងនៅចម្ការផ្នែកទីពីរ ចម្ងាយ ២០០ ម៉ែត្រពីរណ្តៅទីមួយ។ រណ្តៅទាំងបីនេះនៅជិតគ្នា ដោយមានទំហំដូចរណ្តៅទីមួយដែរ យោង GPS ៖ <u>N=13 38.541" é E= 103 11.524"</u>។ "] KH 00792064 ["ព្រៃតារ៉ូត៖ រណ្តៅសាកសព ៣កន្លែងនៅព្រៃតារ៉ូត៖ N13 38.541'- E103 11.524' រណ្តៅសាកសព ១កន្លែងនៅព្រៃតារ៉ូត៖ N13 38.555' - E103 11.524' រណ្តៅសាកសព ១កន្លែងនៅព្រៃតារ៉ូត៖ N13 38.834' - E103 11.651'"]។ សូមមើលផងដែរ ឯកសារ **D219/173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្តើង ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.44 KH 01065979 [សាក្សីរស់នៅចម្ងាយពីរគីឡូម៉ែត្រពីព្រៃតារុត "ក្រោយពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានទៅកន្លែងសម្លាប់មនុស្សនៅព្រៃតារុតម្តង។ នៅពេលនោះ ខ្ញុំបានឃើញមានរណ្តៅសាកសពបីកន្លែង។"]។ ឆ.45 KH 01065979 ["ឆ៖ រណ្តៅសាកសពទាំងនោះ មានបណ្តោយប្រហែល៦ម៉ែត្រ និងទទឹងប្រហែល៣ម៉ែត្រ ប៉ុន្តែខ្ញុំមិនអាចប៉ាន់ស្មានអំពីជម្រៅរណ្តៅទាំងនោះទេ ហើយខ្ញុំក៏មិនអាចប៉ាន់ស្មានបានថា មានសាកសពប៉ុន្មានដែរនៅក្នុងរណ្តៅនោះ។"]

1120 ឯកសារ **D106/15** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00792066 ["រណ្តៅសាកសពចំនួន ៤ កន្លែងដំបូងមានទីតាំងនៅវាលចម្ការដ៏ធំមួយដែលចែកជាពីរផ្នែក ដោយមានរបងខណ្ឌគ្នា។ រណ្តៅសាកសពមួយកន្លែងនោះ មានចម្ងាយ ១០០ ម៉ែត្រនៅខាងឆ្វេងដៃច្រកចូលចម្ការ ហើយមានទំហំ ៣ x ៣ ម៉ែត្រការ៉េ ជម្រៅប្រហែល ១,៨ ម៉ែត្រ យោង GPS៖ <u>N=13 38.555" é E= 103 11.516"</u>។ រណ្តៅបីផ្សេងទៀតមានទីតាំងនៅចម្ការផ្នែកទីពីរ ចម្ងាយ ២០០ ម៉ែត្រពីរណ្តៅទីមួយ។ រណ្តៅទាំងបីនេះនៅជិតគ្នា ដោយមានទំហំដូចរណ្តៅទីមួយដែរ យោង GPS៖ <u>N=13 38.541" é E= 103 11.524"</u>។ (*សូមមើលរូបថតលេខ ១១-១២ នៅឧបសម្ព័ន្ធ ៥*)។ រណ្តៅសាកសពទី៥ មានទីតាំងនៅកន្លែងផ្សេងគ្នាតាមផ្លូវលំដូចគ្នានេះចូលទៅត្រពាំងថ្ម និងភ្នំស្រុកចម្ងាយ ១ពាន់ម៉ែត្រពីទីតាំងរណ្តៅទាំងបួន។ រណ្តៅសាកសពទី ៥ នេះនៅចិញ្ចើមផ្លូវចាប់ចម្ការមួយ ហើយមានទំហំ ៤ X ៤ ម៉ែត្រការ៉េ ជម្រៅ ២ ម៉ែត្រ។ រណ្តៅសាកសពទី៥ មានទីតាំងនៅកន្លែងផ្សេងគ្នាតាមផ្លូវលំដូចគ្នានេះចូលទៅត្រពាំងថ្ម និងភ្នំស្រុកចម្ងាយ ១ពាន់ម៉ែត្រពីទីតាំងរណ្តៅទាំងបួន។ រណ្តៅសាកសពទី ៥ នេះនៅចិញ្ចើមផ្លូវជាប់ចម្ការមួយ ហើយមានទំហំ ៤ x ៤ ម៉ែត្រការ៉េ ជម្រៅ ២ ម៉ែត្រ។"] KH 00792064 ["ព្រៃតារ៉ូត៖ រណ្តៅសាកសព ៣កន្លែងនៅព្រៃតារ៉ូត៖ N13 38.541'- E103 11.524' រណ្តៅសាកសព ១កន្លែងនៅព្រៃតារ៉ូត៖ N13 38.555' - E103 11.524' រណ្តៅសាកសព ១កន្លែងនៅព្រៃតារ៉ូត៖ N13 38.834'

- E103 11.651'"]។ សូមមើលផងដែរ ឯកសារ **D219/173** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស ស្តើង ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.44 KH 01065979 [សាក្សីរស់នៅចម្ងាយពីរគីឡូម៉ែត្រពីព្រៃតារុត "ក្រោយពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានទៅកន្លែងសម្លាប់មនុស្សនៅព្រៃតារុតម្តង។ នៅពេលនោះ ខ្ញុំបានឃើញមានរណ្តៅសាកសពបីកន្លែង។"]។ ឆ. 45 KH 01065979 ["ឆ៖ រណ្តៅសាកសពទាំងនោះ មានបណ្តោយប្រហែល៦ម៉ែត្រ និងទទឹងប្រហែល៣ម៉ែត្រ ប៉ុន្តែខ្ញុំមិនអាចប៉ាន់ស្មានអំពីជម្រៅរណ្តៅទាំងនោះទេ ហើយខ្ញុំក៏មិនអាចប៉ាន់ស្មានបានថា មានសាកសពប៉ុន្មានដែរនៅក្នុងរណ្តៅនោះ។"]។

1121 ឯកសារ **D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.27 KH 01114729 [សាក្សីគឺជានារសាររបស់ អ៊ឹម ចែម ហើយ អ៊ឹម ចែម បានប្រាប់គាត់ឲ្យទៅជួប រាម នៅគុកជប់៖ "ឈ្មោះ រាម ដែលជាអ្នកទទួលខុសត្រូវនៅគុកនៅជប់ ហើយហៅលោកឲ្យទៅយកអ្នកគុកទៅផ្ទះ យាយ ចែម ហ្នឹង តើគាត់មកខាងណាដែរ? ឆ៖ រាម គឺជាមេគុក ហើយជាអ្នកចំណូលថ្មី គាត់មកជំនាន់ជាមួយ យាយ ចែម។"]

1122 ឯកសារ **D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.20 KH 01114728 [សាក្សីគឺជានារសាររបស់ អ៊ឹម ចែម ហើយ អ៊ឹម ចែម បានប្រាប់គាត់ឲ្យទៅជួប រាម នៅគុកជប់៖ "ខ្ញុំបាននឹកឃើញឡើងវិញហើយ។ យាយ ចែម បានសួរខ្ញុំថា ហ៊ានទៅជួបឈ្មោះ រាម ដែរឬទេ? ដែលឈ្មោះ រាម ឈរជើងនៅជប់ ហើយជាអ្នកទទួលខុសត្រូវមនុស្សដែលគេចាប់យកទៅ ខ្ញុំបានឆ្លើយប្រាប់គាត់ថា ខ្ញុំហ៊ានទៅ។ ដល់ខ្ញុំទៅ ឃើញនីរសារនៅទីនោះ នីរសារមិនទាល់ឲ្យខ្ញុំចូល ពេលនោះ រាម កំពុងតែដេក។ ពេលខ្ញុំឈប់បានកន្លះម៉ោង រាម ចេញមក ហើយគាត់និយាយថា មិនមានអីទេហើយថា ពេលខ្ញុំត្រឡប់ទៅវិញ ត្រូវយកមនុស្សប្រាំពីរនាក់ ទៅឲ្យ យាយ ចែម ផង។"]។ ឯកសារ **D119/75** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤ ឆ.19 KH 00971135-36 [សាក្សីគឺជានារសាររបស់ អ៊ឹម ចែម ហើយ អ៊ឹម ចែម បានប្រាប់គាត់ឲ្យទៅជួប រាម នៅគុកជប់៖ "តាមពិត ខ្ញុំបានជួបអ៊ឹម ចែម ម្តង [É] គាត់ប្រាប់ខ្ញុំថា ឲ្យទៅជួបឈ្មោះរាម នៅគុកជប់ [É] គាត់បានឲ្យគេនាំអ្នកទោសចំនួនប្រហែល៧នាក់ មកផ្ទះគាត់។ គាត់បានប្រាប់ខ្ញុំឲ្យនាំអ្នកទោសនោះយកទៅឲ្យយាយ ចែម នៅឯភ្នំលៀប។ [É] ខ្ញុំបានទៅជួបរាម នៅផ្ទះរបស់គាត់ ដែលមានទីតាំងនៅក្បែរស្រះធំមួយ នៅតាមផ្លូវទៅភូមិចក្រី ហើយនៅខាងកើតមន្ទីរស្រុកព្រះនេត្រព្រះបច្ចុប្បន្ន [É]គាត់បានឲ្យគេនាំអ្នកទោសចំនួនប្រហែល៧នាក់ មកផ្ទះគាត់។"]។

1123 ឯកសារ **D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.27 KH 01114729 [សាក្សីគឺជានារសាររបស់ អ៊ឹម ចែម ហើយ អ៊ឹម ចែម បានប្រាប់គាត់ឲ្យទៅជួប រាម នៅគុកជប់៖ "ឈ្មោះ រាម ដែលជាអ្នកទទួលខុសត្រូវនៅគុកនៅជប់ ហើយហៅលោកឲ្យទៅយកអ្នកគុកទៅផ្ទះ យាយ ចែម ហ្នឹង តើគាត់មកខាងណាដែរ? ឆ៖ រាម គឺជាមេគុក ហើយជាអ្នកចំណូលថ្មី គាត់មកជំនាន់ជាមួយ យាយ ចែម។"]។ ឯកសារ **D67.4** គម្រោងជម្រុញការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១១ EN 00728606 ["រាម គឺជាកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតី ហើយគាត់ត្រូវបានបញ្ជូនទៅស្រុកព្រះនេត្រព្រះជាមួយនឹង អ៊ឹម ចែម។"]។

1124 ឯកសារ **D123/1/5.1b** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929776 ["ពេលមកដល់ យើងរៀបចំមានប៉ុន្មានឃុំ ដូចជា ៥ ឃុំហ្នឹង យើងដាក់ម៉ាសហករណ៍

ប្រមាណចូលតាមជំនាញមួយៗហ្នឹង"]។ ឯកសារ **D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.41 KH 00980387 [សាក្សីជាកម្មាភិបាលភូមិភាគនិរតីដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ៖ "ដំបូងឈ្មោះ ផុន (ស្លាប់) ជាគណៈស្រុកព្រះនេត្រព្រះ ប៉ុន្តែក្រោយមកគឺ យាយចែម ជាគណៈស្រុកព្រនេត្រព្រះ ពីព្រោះនៅពេលនោះ យាយចែម បានចាត់តាំងខ្ញុំជាគណៈឃុំ"] ឆ.42 KH 00980388 ["នៅពេលនោះ ខ្ញុំមិនដឹងពីមូលហេតុច្បាស់ទេ គឺគាត់បានបញ្ឈប់ខ្ញុំពីអង្គភាពយោធា ហើយឱ្យខ្ញុំធ្វើជាមេឃុំភ្នំលៀប។ ខ្ញុំគិតថា មូលហេតុដែលគាត់ស្គាល់ខ្ញុំ ដោយសារតែគាត់ដឹងថា ខ្ញុំធ្លាប់ធ្វើជាយោធានៅការពារនៅស្រុកព្រះនេត្រព្រះ។ ក្នុងចំណោមសមាជិកយោធា ៣០ នាក់នោះគឺមានតែខ្ញុំម្នាក់គត់ដែលជ្រើសរើសជាគណៈឃុំភ្នំលៀប។ យោធាទាំង ៣០ នាក់នោះត្រូវបានគេបំបែកជាក្រុមតូចៗដែលមានគ្នាពីពីរទៅបួននាក់ ហើយត្រូវបានបញ្ជូនឱ្យទៅការពារតាមឃុំផ្សេងៗ"]។ ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.148 KH 00953039 [សាក្សីជាកម្មាភិបាលភូមិភាគនិរតីដែលត្រូវបានបញ្ជូនទៅ ភូមិភាគពាយ័ព្យ៖ "ពេលយាយចែមឱ្យខ្ញុំទៅនៅជិតទីនោះ កងចល័តក៏នៅជិតនោះដែរ។ បើអ្នកដែលនៅក្នុងសហករណ៍ក្នុងស្រុកព្រះនេត្រព្រះ គឺត្រូវបញ្ជូនទៅទីនោះ ហើយការបញ្ជូនមិនមែនតែម្នាក់ទេ គឺបញ្ជូនទៅទាំងគ្រួសារ។ យាយចែម ក៏បាននិយាយជាមួយខ្ញុំដែរ ថាឱ្យខ្ញុំមើលខុសត្រូវនៅទីនោះ"] ឆ.96 KH 00953033 [ "ខ្ញុំនៅទានកាំប្រហែលមួយខែកន្លះ យាយចែម បានចាត់តាំងខ្ញុំឱ្យទៅដឹកនាំកងចល័តដឹកប្រឡាយប្រចាំស្រុកព្រះនេត្រព្រះ"]។

1125 ឯកសារ **D1.3.12.1** កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234194 ["ខ្ញុំនាំកម្លាំងប្រាំរយ (ទាហាន) ពីនិរតី (ភូមិភាគ) ពីតាកែវទៅចូលរួមកងចល័ត(ក្នុងស្រុកខ្ញុំ)។ កម្លាំងប្រាំរយ (ទាហាន) ដាក់តាមការដ្ឋានគេចាស់ហ្នឹង ទាហានប្រាំរយ ប្រជាជនបីខេត្តហ្នឹងក៏យកប្រាំរយគ្រួសារដែរយករាយតាមភូមិនៅក្នុងស្រុកទាំងអស់ ខ្ញុំដាក់នេះគឺដើម្បីស្រណុកហៅធ្វើការ ព្រោះខ្ញុំអត់ដែលស្គាល់សោះស្រុកព្រះនេត្រព្រះហ្នឹង"]។ ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ិាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.124 KH 01104654 សាក្សីធ្វើការនៅកន្លែងជាច្រើននៅតំបន់ ៥ រួមទាំងស្រុកព្រះនេត្រព្រះ៖ "ឆ៖ ខ្ញុំធ្លាប់ឮគេហៅ ឈ្មោះយាយចែម ថាជាប្រធានគ្រប់គ្រងយោធា"] ឆ.125 KH 01104655 ["ខ្ញុំគ្រាន់តែឮគេនិយាយថាគាត់គ្រប់គ្រងផ្នែកយោធាតែប៉ុណ្ណោះ"]។ ឯកសារ **D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.65 KH 01049233 [សាក្សី ធ្វើការក្នុងកងចល័តយុវជន៖ "ខ្ញុំមិនដឹងពីតួនាទី យាយ ចែម ច្បាស់លាស់ទេ។ ខ្ញុំគ្រាន់តែដឹងថា គាត់មានអំណាចខ្លាំងដោយគាត់បញ្ជាទាំងយោធាទៀតផង។ ហើយគាត់រស់នៅភ្នំលាប"], ឆ.66-68 KH 01049233 [សាក្សីធ្វើការក្នុងកងចល័តយុវជន៖ "ស៖ លោកនិយាយថាយាយចែមបញ្ជាទាំងយោធា តើយោធាយ៉ាងដូចម្តេចដែរ? ឆ.66៖ យោធាមានកាំភ្លើង ដែលអាចចាប់ប្រជាជនបាន។ ស៖ ចឹងពេលហ្នឹង យាយចែមអាចបញ្ជាឱ្យយោធាទាំងនោះចាប់ប្រជាជនបានឬ? ឆ.67៖ បាទ។ ឆ.68៖ ខ្ញុំដឹងពីក្រុមចល័តដែលអាចរត់រួចពីភ្នំត្រយោង"] ឆ.267 KH 01049253 ["ខ្ញុំឮគេថា [អ៊ឹម ចែម] កាច ហើយបើគេបញ្ជាទាហានឱ្យធ្វើអ្វីមួយ គេត្រូវតែធ្វើតាម"]។ ឯកសារ **D119/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.87 KH 00989348 [សាក្សីធ្វើការនៅកងកុមារនៅត្រពាំងថ្ម៖ "ខ្ញុំធ្លាប់ឮឈ្មោះយាយចែម ណៅត្រពាំងថ្ម។ យាយចែម ក៏ជាអ្នកគ្រប់គ្រងកងទ័ពដែរ"]។ ឯកសារ **D219/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

ពុំ ខូ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.57-59 KH 01029673 [សាក្សីជាសមាជិកនៃគណៈកម្មាធិការស្រុកព្រះនេត្រព្រះ៖ "ខ្ញុំប្រគល់កាំភ្លើងអាកាទៅឱ្យគេ នៅពេលដែលពួកនិរតីមកដល់ [...] ខ្ញុំប្រគល់កាំភ្លើងឱ្យយាយថែម នៅផ្ទះរបស់គាត់ នៅភ្នំលៀប [...] ខ្ញុំប្រគល់ឱ្យគេមុនឆ្នាំ ១៩៧៧ [...] ខ្ញុំប្រគល់កាំភ្លើងឱ្យយាយថែម"]។ ឯកសារ **D119/144** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឆ.53 KH 010092121 [សាក្សីជាយោធាស្រុករបស់ខ្មែរក្រហម និងធ្វើការក្នុងកងចល័តនៅអាងនៅត្រពាំងថ្ម៖ "នេះជារចនាសម្ព័ន្ធគ្រប់គ្រងតាមស្រុកសរបស់ខ្មែរក្រហម គឺប្រធានយោធាត្រូវរាយការណ៍ទៅគណៈស្រុក។ ខ្ញុំឮតាមប្រជាជនដែលរស់នៅស្រុកព្រះនេត្រព្រះថា យាយថែម មានអំណាចគ្រប់គ្រងមនុស្សទាំងអស់ ហើយប្រធានយោធាស្រុកក៏ត្រូវរាយការណ៍ជូនគាត់ដែរ"]។ ឯកសារ ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.82 KH 00953031 សាក្សីជាកម្មាភិបាលភូមិភាគនិរតីដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ៖ "ពេលខ្ញុំទៅដល់នោះ កម្លាំងក្របខ័ណ្ឌស្រុកគឺនៅដដែល ប៉ុន្តែពេលដែលយាយថែមទៅដល់ គឺចូលរួមជាមួយកម្លាំងចាស់។ ពេលទៅដល់ព្រះនេត្រព្រះប្រហែលដប់ថ្ងៃ យាយថែម និងគណៈស្រុកចាស់ ប្រជុំរួមគ្នា ដើម្បីរៀបចំកម្លាំង"]។ ឯកសារ **D119/88** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.30 KH 00976122 [សាក្សីដឹកជញ្ជូនថ្មពីភ្នំត្រយោងទៅអាងត្រពាំងថ្ម៖ "នៅពេលនោះ ខ្ញុំបានឃើញគាត់ជិះឡានសេអ៊ីមសេ នៅផ្លូវជាតិលេខ ៦ មកពីទិសខាងលិចឆ្ពោះទៅភ្នំលៀប ប្រហែលជាគាត់មកពីស្វាយស៊ីសុផុនហើយ។ ខ្ញុំបានឃើញគាត់ ប្រហែលជាពីរបីថ្ងៃមុនវៀតណាមមកដល់។ នៅលើឡាននោះ មានយោធាប្រហែល១០នាក់ តែពួកគេមិនមានកាន់កាំភ្លើងទេ"]។

1126 ឯកសារ **D219/385** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួន ហឿក ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.22 KH 01113241 [សាក្សីនៅផ្ទះនៅកងពីរចំពេលដែលគាត់ឃើញគេដឹកអ្នកទោសតាមឡានលើផ្លូវជាតិលេខ ៦ ឆ្ពោះទៅទិសខាងជើង៖ "សៈ តើលោកឃើញមនុស្សដែលនៅក្នុងឡានទាំងពីរ ត្រូវបានគេចងដៃដែរទេ? ឆ៖ ខ្ញុំមិនដែលមើលទេ គ្រាន់តែឃើញមនុស្សទាំងនោះ ដឹកតាមឡាន។ ពួកឈ្លបដែលយកមនុស្សទាំងនោះទៅសម្លាប់គឺជាកូនឈ្លបតូចៗ"]។ ឯកសារ **D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.29 KH 00976158 [សាក្សីជាកងចល័តដែលមានផ្ទះចម្ងាយ ៣០០ម៉ែត្រពីព្រៃតារត់៖ "សៈ តើលោកដឹងថាបញ្ជាឱ្យចាប់ និងសម្លាប់មនុស្សចេញមកពីថ្នាក់ណា? ឆ៖ ខ្ញុំមិនដឹងថា បញ្ជាឱ្យចាប់ និងសម្លាប់មនុស្សចេញមកពីថ្នាក់ណានោះទេ តែគឺមកពីថ្នាក់លើ។ ចំណែកយោធាដែលចុះមកចាប់គឺអាចមកពីថ្នាក់ស្រុក ឬឈ្លបមកពីសហករណ៍"]។

1127 ឯកសារ **D119/75** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤ ឆ.19 KH 00971135 - 00971136 [សាក្សីជានីរសាររអ៊ឹម ចែម ហើយអ៊ឹម ចែមបានប្រាប់ឱ្យទៅជួបរាមនៅ គុកជប់៖ "តាមពិត ខ្ញុំបានជួបអ៊ឹម ចែមម្តង [É] គាត់ប្រាប់ខ្ញុំថា ឱ្យទៅជួបឈ្មោះរាម នៅគុកជប់។ [É] គាត់បានប្រាប់ខ្ញុំឱ្យនាំអ្នកទោសប្រហែល ៧ នាក់មកផ្ទះគាត់។ គាត់បានប្រាប់ខ្ញុំឱ្យនាំអ្នកទោសនោះយកទៅឱ្យយាយថែម នៅឯភ្នំលៀប"]។

1128 ឯកសារ **D119/125** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ វន្នី ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.12 KH 00987279 [សាក្សីជាកងចល័តដែលត្រូវបានបញ្ជូនទៅឃុំជប់វារី និងរស់នៅជិតផ្លូវចូលទៅព្រៃតារត់៖ "សៈ តើលោកដឹងអ្វីខ្លះពីមនុស្សដែលត្រូវបានគេចាប់យកទៅសម្លាប់នៅក្បែរស្រះក្នុងភូមិចក្រីនោះ? ឆ៖ នៅពេលនោះ ខ្មែរក្រហមមិនចាប់មនុស្សយកទៅ

សម្លាប់ផ្ទាល់ទេ ក៏ប៉ុន្តែគេបានប្រាប់អ្នកដែលត្រូវគេចាប់ខ្លួនថា ឱ្យទៅដឹកស្រូវ ឬអង្គរនៅស្វាយស៊ីសុផុន ឬឱ្យទៅរៀនសូត្រ។ ប្រធានឃុំឈ្មោះ រស់ និងប្រធានពាណិជ្ជកម្មឃុំឈ្មោះ ពត ជាអ្នកចាត់តាំងមនុស្សទាំងនោះ។ នៅពេលដែលអ្នកទាំងនោះធ្វើដំណើរតាមផ្លូវលំពីភូមិពោលជ្រូកទៅផ្លូវជាតិ ពួកគេត្រូវបានឈ្លបខ្មែរក្រហមចាប់ខ្លួន ហើយយកទៅឃុំនៅកន្លែងមួយដែលបច្ចុប្បន្នជាអធិការដ្ឋាននគរបាលស្រុកព្រះនេត្រព្រះ"]។

1129 ឯកសារ **D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ច្រាច់ គិត ឆ.20 KH 00780969 [សាក្សីធ្វើជាជាងឈើនៅការិយាល័យស្រុកព្រះនេត្រព្រះ៖ "ខ្ញុំឃើញមនុស្សក្នុង [មន្ទីរសន្តិសុខចក្រី] [É] ពួកគេប្រាប់អ្នកដែលខ្ញុំស្គាល់ថា ពួកគេត្រូវបានអង្គការប្រាប់ថាឱ្យទៅធ្វើការនៅកន្លែងផ្សេង ស្ថានភាពដូចគ្នានេះ មានបន្តពេញឆ្នាំ១៩៧៨ រហូតដល់ថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩"]។

1130 ឯកសារ **D119/145** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិប គឹមលន់ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឆ.69 KH 01022034 [សាក្សីជាកងចល័តនៅស្រុកព្រះនេត្រព្រះ៖ "ស៖ តើលោកធ្លាប់ឮថា មានការសម្លាប់មនុស្សនៅភូមិចក្រីដែរឬទេ? ឆ៖ នៅពេលដែលខ្ញុំនៅធ្វើការវត្តជប់ គឺមានការហៅប្រជាជនឱ្យចូលរៀនសូត្រ ហើយក្រោយមកនៅម៉ោង ៥ ល្ងាច គេចាប់មនុស្សទាំងនោះ ហើយបញ្ជូនចេញតាមឡានយោធា។ ខ្ញុំមិនដឹងថា គេបញ្ជូនពួកនោះយកទៅណាទេ"]។

1131 ឯកសារ **D106/2** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ច្រាច់ គិត ឆ.20 KH 00780968 [សាក្សីធ្វើជាជាងឈើនៅការិយាល័យស្រុកព្រះនេត្រព្រះ៖ "ស៖ តើលោកបានដឹងពីទីតាំងសម្លាប់មនុស្សនៅភូមិចក្រីតាមរបៀបណា? ឆ៖ ខ្ញុំបានដឹងដោយសារខ្ញុំបានទៅរែកទឹកស្រះនៅក្បែរនោះ ហើយខ្ញុំបានឃើញមនុស្សដែលគេបាននាំមកទីនោះ នៅពេលល្ងាច ហើយពួកគេទាំងនោះ បានបាត់ខ្លួននៅពេលព្រឹក។ ខ្ញុំឃើញមនុស្សក្នុងផ្ទះនោះ តែពួកគេមិនត្រូវបានគេចងទេ"]។ ឯកសារ **D219/212** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុប សុក ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៥ ឆ.24 KH 01074063-01074064 [សាក្សីជាធ្វើការនៅកងចល័ត ហើយត្រូវបានបញ្ជូនទៅស្រុកភ្នំស្រុក និង បាឃើញគេចាប់ខ្លួន យូ មុត៖ "ខ្ញុំបានជួប យូ មុត នៅពេលដែលកងចល័តរបស់ខ្ញុំត្រូវបញ្ជូនឱ្យទៅធ្វើការនៅភ្នំស្រុក។ បន្ទាប់មកគេបានបញ្ជូនពីភ្នំស្រុកទៅគោករំចេកដែលទីនោះ ខ្ញុំបានឃើញគេចាប់មនុស្សដែលធ្វើនៅក្នុងកងចល័តជាមួយខ្ញុំត្រូវបានគេចាប់យកទៅសម្លាប់នៅពេលយប់ ដោយចោទថាបានប្រព្រឹត្តខុសសីលធម៌។ បន្ទាប់មកទៀតគេបានបញ្ជូនពួកខ្ញុំពីគោករំចេកទៅជប់ [ដែលបច្ចុប្បន្នគេហៅថាជប់វារី]។ ពេលនោះខ្ញុំបានឃើញការចាប់មនុស្សជាច្រើនដឹកតាមឡានយកទៅសម្លាប់ឆ្ពោះទៅទិសដៅខាងភ្នំជញ្ជាំង។ នៅពេលនោះដែល យូ មុត ត្រូវបានគេចាប់ដាក់គុកនៅជប់វារី"] ឆ.25 KH 01074064 ["ថ្ងៃចាប់ខ្លួនរបស់ យូ មុត គឺនៅចន្លោះពាក់កណ្តាលនៃរបបខ្មែរក្រហម ខ្ញុំពិបាកក្នុងការប៉ាន់ស្មានថាតើក្នុងអំឡុងពេលនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលពាយ័ព្យ ឬ នីរតីទេ។ ខ្ញុំបានឃើញព្រឹត្តិការណ៍នេះនៅពេលដែលខ្ញុំកំពុងអង្គុយកាត់សក់នៅតាមបណ្តោយផ្លូវជាតិលេខ៦ ខាងឆ្វេងដៃប្រសិនបើធ្វើដំណើរពីសៀមរាបទៅបន្ទាយមានជ័យ។ [សូមបមើលរូបផែនទីភ្ជាប់ជាឧបសម្ព័ន្ធជាមួយនឹងការស្តាប់ចម្លើយនេះ]។ នៅពេលនោះខ្ញុំបានឃើញ យូ មុត និង ពៀង ដែលត្រូវបានបណ្តើរដោយឈ្លប ៣ នាក់តាមទិសដៅផ្លូវលំមួយដែលចេញពីផ្លូវជាតិលេខ ៦ ទៅកាន់អាងត្រពាំងថ្ម ហើយអ្នកទាំងពីរនោះត្រូវបានបណ្តើរពីជើងទៅត្បូងឆ្ពោះទៅកាន់ផ្លូវជាតិលេខ ៦ និងផ្លូវលំនោះ។ យូ មុត និង ពៀង ជាសមាជិកនៅក្នុងក្រុមកងចល័តរបស់ខ្ញុំ ២-៣នាទីក្រោយមក ខ្ញុំឃើញពៀងព្យាយាមរត់គេចចេញ

1230 ឯកសារ D119/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល ហេវ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤ ឆ.26 KH 00982262 [សាក្សីត្រូវបានតែងតាំងជាប្រធានភូមិកំពង់រាប ស្រុកស៊ីសុផុន ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧៖ "ខ្ញុំមិនដឹងថាមនុស្សទាំងនោះ [កម្មាភិបាលភូមិភាគពាយ័ព្យ មន្ត្រីស៊ីវិល និងទាហាន] បញ្ជូនទៅកន្លែងណាទេ។ ប៉ុន្តែនៅពេលដែលខ្ញុំបានសួរអ្នកបររទេះសេះត្រឡប់មកវិញ ខ្ញុំបានសួរគេ គេបានប្រាប់ខ្ញុំថា មនុស្សទាំងនោះ ត្រូវដឹកទៅចម្ការខ្មុរ"]។ ឯកសារ D6.1.634 កិច្ចសម្ភាសន៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សជាមួយ ទិល ហេវ ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០០៥ KH 00831512 [សាក្សីត្រូវបានតែងតាំងជាប្រធានភូមិកំពង់រាប ស្រុកស៊ីសុផុនពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៧៖ "ពួកកម្មាភិបាលភូមិភាគនិរតីបានប្រមូលកម្មាភិបាលភូមិភាគពាយ័ព្យទាំងអស់ [...] ខ្ញុំគិតថា ពួកគេទាំងនោះត្រូវបញ្ជូនទៅដាក់នៅចម្ការខ្មុរ។ អ្នកបររទេះសេះដឹកពួកនោះ និយាយថា ពួកគេនឹងយកទៅដាក់នៅចម្ការខ្មុរ"]។

1231 ឯកសារ D5/983/1 របាយការណ៍របស់អង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ម៉ុក ធូ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ EN 00990127 [សាក្សីធ្វើការនៅតាមជើងភ្នំជុំវិញចម្ការខ្នុរ៖ "ជនរងគ្រោះទាំងនោះ គឺជាអតីតនិស្សិត ដែលត្រូវបានបោកប្រាស់ដោយកម្មាភិបាលខ្មែរក្រហមឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បី ជួយកសាងជាតិ"]។

1232 ឯកសារ D5/1460 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ទិន ស៊ីម៉ាច ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៣ KH 01043713 [សាក្សីត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៨៖ "ពេលនោះ [ឆ្នាំ ១៩៧៨] នាងខ្ញុំត្រូវបាត់បង់បងប្អូនចំនួនបីនាក់ [...] ឪពុកមាឈ្មោះ លឿយ ឡាយ ជាគ្រូបង្រៀន ព្រមទាំងប្រពន្ធកូនចំនួនបីនាក់ ស្លាប់នៅវត្តចម្ការខ្នុរ"]។ ឯកសារ D5/1460/1 របាយការណ៍ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទិន ស៊ីម៉ាច ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ KH 01215511 ["ពូរបស់គាត់ ឈ្មោះ លឿយ ឡាយដែលជាគ្រូបង្រៀនម្នាក់ ព្រមទាំងប្រពន្ធ និងកូនចំនួន៤នាក់របស់គាត់។ ពួកគាត់ត្រូវបានគេបញ្ជូនយកទៅសម្លាប់នៅឯវត្តចំការខ្នុរ"]។

1233 ឯកសារ D1.3.27.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមចំណងជើង "គម្រោងរៀបចំផែនទី ឆ្នាំ ១៩៩៨" បន្ទាយមានជ័យ ថ្ងៃទី២០ ខែ សីហា ឆ្នាំ ១៩៩៨ KH 00184621 ["ព្រះអង្គបានគូសបញ្ជាក់ប្រាប់យើងថា នៅចំការខ្នុរនេះមានការសម្លាប់ទាំងខ្សែៗ ហើយប្រភេទជនរងគ្រោះមានលាយចំរុះគ្នា ប៉ុន្តែភាគច្រើនគឺជាអនិកជនវៀតណាមដែលបានមករស់នៅតាំងពីយូរយារណាស់មកហើយ។"]។ ឯកសារ D119/111.1 ឧបសម្ព័ន្ធ ១៖ ទស្សនាវដ្តីស្វែងរកការពិត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឥណ្ឌូចិន ក្នុងសៀវភៅខ្មៅ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០០ KH 00982218 [ព្រះតេជគុណ សៀន ញាណ បានឃើញការកាប់សម្លាប់នៅចំការខ្នុរពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨៖ "នៅចំការខ្នុរនេះមានការសម្លាប់ទាំងខ្សែៗ ហើយប្រភេទជនរងគ្រោះមានលាយចំរុះគ្នា ប៉ុន្តែភាគច្រើនគឺជាអនិកជនវៀតណាមដែលបានមករស់នៅតាំងពីយូរយារណាស់មកហើយ។"]។ សូមមើលផងដែរឯកសារ D5/1252 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អឿ លឿ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036276 [សាក្សីជាអ្នកទោសនៅចំការខ្នុរនៅឆ្នាំ១៩៧៧ ហើយគាត់ត្រូវគេបញ្ជូនទៅភ្នំត្រយោងនៅឆ្នាំ១៩៧៨៖ "នៅក្នុងគុកវាចោទខ្ញុំថាជាជនជាតិយួន សដូចយួន"]។

1234 ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107083 [បើតាមសាក្សី ឃួន សាយ បានជាប់ឃុំនៅចំការខ្នុរពីដើមឆ្នាំ១៩៧៥ ដល់១៩៧៧៖ "ចិនក៏មក លោកធ្វើការណាក៏មក បាទ។"]។ ឯកសារ D119/111.1 ឧបសម្ព័ន្ធ ១៖ ទស្សនាវដ្តីស្វែងរកការពិត របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឥណ្ឌូចិន ក្នុងសៀវភៅខ្មៅ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០០ [បើតាមព្រះតេជគុណ សៀន ញាណ KH 00982218 [ព្រះតេជគុណ សៀន ញាណ បានឃើញការកាប់សម្លាប់នៅចំការខ្នុរពីឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨៖ "ជនជាតិចិន ចាម និងឡាវក៏មានស្លាប់នៅទីនេះដែរ។"]។ ឯកសារ D1.3.27.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមចំណងជើង "គម្រោងរៀបចំផែនទី ឆ្នាំ ១៩៩៨" បន្ទាយមានជ័យ "ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៨ KH 00184621 [ព្រះតេជគុណ សៀន ញាណជាគ្រូសូត្រ៖ "ហើយអនិកជនចិន ឡាវ និងចាមក៏មានស្លាប់នៅទីនោះដែរ។ "]។

1235 ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107061 [បើតាមសាក្សី សៀន មាន បានឃើញកន្លែងសម្លាប់នៅចម្ការខ្នុរក្នុងឆ្នាំ១៩៧៩៖ "មនុស្សមួយចំនួនស្លាប់ដោយសារមានគេឆ្លើយដាក់។ ស៊ិន ឃិន៖ អ្ហ៎! ឆ្កឹះឆ្កៀលគ្នា រាយការណ៍ភូតកុហក់ បោកប្រាស់ អានេះធ្វើនេះ អានោះធ្វើនោះ អីចឹង? សៀន មាន៖ បាទ។"]។

1236 ឯកសារ D219/433 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឆ.10 KH 01124143 [សាក្សីធ្វើការនៅភ្នំលៀប៖ "ប៉ុន្តែនៅដំណាក់កាលទី២ មានប្រជាជនច្រើនត្រូវបានគេសម្លាប់។ គ្រួសារបងស្រីខ្ញុំមា និងសាច់ញាតិផ្សេងទៀតចំនួន២៤នាក់ ត្រូវគេយកទៅសម្លាប់ចោលនៅចម្ការខ្នុរ។ ពួកគាត់បានរត់ទៅថៃ ហើយថៃចាប់បានក៏បញ្ជូនត្រឡប់មកវិញ រួចគេយកទៅសម្លាប់ចោលនៅចម្ការខ្នុរ"]។

1237 ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ឆ.166 KH 01049243 [សាក្សីជាចល័តហើយកងរបស់គាត់ត្រូវគេបញ្ជូនទៅធ្វើការនៅម្តុំខេត្តបន្ទាយមានជ័យជាញឹកញាប់។ បងស្រីគាត់ម្នាក់ទៀតបានប្រាប់គាត់ពីការចាប់ខ្លួន៖ ["គាត់នៅចល័តដែលគេហៅថា ដងទង់ នៅភូមិប៉ោយឈ្លូល ឃុំប៉ោយចារ [...] បន្ទាប់ពីលួចរួច គាត់ក៏បាត់ខ្លួនទៅ។"] ឆ.167 KH 01049243 ["ស៖ នៅក្នុងពាក្យបណ្តឹងរបស់លោក លោកបានប្រាប់ថាបងស្រីរបស់លោកបានប្រាប់ថា គេចាប់បងស្រីរបស់លោកនៅចំការខ្នុរ។ តើមែនទេ? ឆ.167៖ បាទ មែន។"]។ ឯកសារ D5/876/1 របាយការណ៍របស់អង្គភាពការពារជនរងគ្រោះ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នៅ ចាត់ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៣ EN 00957255 [សាក្សីជាចល័តហើយកងរបស់គាត់ត្រូវគេបញ្ជូនទៅធ្វើការនៅម្តុំខេត្តបន្ទាយមានជ័យជាញឹកញាប់។ បងស្រីគាត់ម្នាក់ទៀតបានប្រាប់គាត់ពីការចាប់ខ្លួន៖ "ប្អូនស្រីគាត់ឈ្មោះ នៅ អត (CHHAO Ort) ត្រូវគេចាប់យកទៅសម្លាប់នៅចម្ការ [...] ដោយសារគាត់លួចដំឡូងហូប"]។

1238 ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107080 [បើតាមសាក្សី ឃួន សាយ បានជាប់ឃុំនៅចំការខ្នុររហូតដល់កងទ័ពវៀតណាមចូលមកដល់៖ "អាលើកប្រឡាយធ្វើយោធាហ្នឹង វាឲ្យអ្នកទោសធ្វើ។ ធ្វើហើយវៃចោលៗទៅ"]។

1239 ឯកសារ D219/433 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.10 KH 01124143 [សាក្សីធ្វើការនៅភ្នំលៀប៖ "ប៉ុន្តែនៅដំណាក់កាលទី២ មានប្រជាជនច្រើនត្រូវបានគេសម្លាប់។ គ្រួសារបងស្រីខ្ញុំមា និងសាច់ញាតិផ្សេងទៀតចំនួន២៤នាក់ ត្រូវគេយកទៅសម្លាប់ចោលនៅចម្ការខ្នុរ។"]។ ឯកសារ D5/1617/1 របាយការណ៍របស់អង្គភាពការពារជនរងគ្រោះ ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទិន សាលឿង ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ KH 01216128-01216129 ["ក្នុងឆ្នាំ១៩៧៨ [...] ពូរបស់គាត់ឈ្មោះ សើយ ឡាយ អតីតគ្រូបង្រៀន ត្រូវបានទាហានខ្មែរក្រហមសម្លាប់ ជាមួយប្រពន្ធគាត់ [...] និងកូន៤នាក់នៅចម្ការខ្នុរក្នុងក្រុងសិរីសោភ័ណ្ឌ"]។

1240 ឯកសារ D119/113 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម រតនៈ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ឆ.24 KH 00982247 [សាក្សីឈប់សម្រាកនៅចម្ការខ្នុរនៅពេលដែលគាត់រត់ទៅព្រំដែនថៃ នៅថ្ងៃទី២៨ ឬ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨៖ "សាកសពខ្លះត្រូវបានកប់ និងសាកសពខ្លះទៀតមិនបានកប់ទេ គឺនៅរាយប៉ាយពេញដី។"]។ ឯកសារ D219/206 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ឆ.2-3 KH 01072257 [សាក្សីបានសម្ភាសជាមួយសាក្សីចម្ការខ្នុរដទៃទៀតក្នុងឆ្នាំ១៩៩៧ ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានឃើញរណ្តៅក្នុងពេលស៊ើបអង្កេតនោះ៖"ខ្ញុំបានឃើញរណ្តៅខ្លះ ហើយរណ្តៅទាំងនោះគឺដីលុបជិតពេញអស់ហើយនៅមានស្នាមដីក្រហូងតិចៗ។"]។ ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107056 [បើតាមសាក្សី សៀន មាន បានឃើញកន្លែងសម្លាប់នៅចម្ការខ្នុរក្នុងឆ្នាំ១៩៧៩៖ "មិនមែនតែកប់ទាំងអស់ទេទានណា។ [...] សល់ក្រៅរណ្តៅ"]។ ឯក

សារ D1.3.10.10 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា "របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ" ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 00750669 [បើតាមសាក្សីម្នាក់ឈ្មោះ ចិន សារ៉ង ដែលធ្លាប់គាស់រណ្តៅនៅចម្ការខ្នុរក្នុងឆ្នាំ១៩៨៣ និង១៩៨៤ "រណ្តៅសាកសពជាច្រើនត្រូវបានកាយលុបយ៉ាងត្រឹមត្រូវ ប៉ុន្តែរណ្តៅសាកសពមួយចំនួនទៀតមិនបាលលុបទេ"]។

1241 ឯកសារ D119/113 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម រតនៈ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ឆ.19 KH 00982247 [សាក្សីឈប់សម្រាកនៅចម្ការខ្នុរនៅពេលដែលគាត់រត់ទៅព្រំដែនថៃ នៅថ្ងៃទី២៨ ឬ២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨៖ "សាកសពខ្លះមានដៃជាប់ចំណងខាងមុខ សាកសពខ្លះមានដៃជាប់ចំណងទៅខាងក្រោយ"] ឆ.18 KH 00982246 ["នៅក្នុងបរិវេណវត្ត គឺមានបន្ទប់ធ្វើអំពីឈើដែលប្រឡាក់ដោយឈាម និងមានសាកសពនៅក្នុងនោះព្រមទាំងមានខ្នោះដៃខ្នោះជើងផងដែរ"]។ ឆ.24 KH 00982247 ["សាកសពខ្លះត្រូវបានកប់ និងសាកសពខ្លះទៀតមិនបានកប់ទេ គឺនៅរាយប៉ាយពេញដី។"]។ ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107056 [បើតាមសាក្សី សៀន មាន បានឃើញកន្លែងសម្លាប់នៅចម្ការខ្នុរក្នុងឆ្នាំ១៩៧៩៖ "មានជាប់ចំណងដោយខ្សែការ"]។

1242 ឯកសារ D6.1.345 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុត ផល ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH 00279117 [សាក្សីបានលាក់ខ្លួនក្នុងចម្ការខ្នុរចំនួន២ខែមុនកងទ័ពវៀតណាមចូលមកដល់៖ "ពេលឡានមកដល់ គេថយគូទឡាន រួចផ្អឹងចាក់មនុស្សទាំងរស់ទៅក្នុងរណ្តៅ [...]។ រួចបង ង៉ៀម បើកត្រាក់ទ័ររុញដីកប់ទាំងរស់។ [...] ហើយមនុស្សដែលគេចាក់ក្នុងរណ្តៅនោះមិនអាចរត់រួចទេព្រោះដៃជាប់ចំណង។"]។

1243 ឯកសារ D119/113 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម រតនៈ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ឆ.15 KH 00982246 [សាក្សីឈប់សម្រាកនៅចម្ការខ្នុរនៅពេលដែលគាត់រត់ទៅព្រំដែនថៃ នៅថ្ងៃទី២៨ ឬ២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨៖ "យើងបានឃើញសាកសពមនុស្ស ឃើញស្នាមឈាម និងឃើញខ្នោះដៃ ខ្នោះជើង នៅរាយប៉ាយពេញនៅទីនោះ។"]។ ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107056 [បើតាមសាក្សី សៀន មាន បានឃើញកន្លែងសម្លាប់នៅចម្ការខ្នុរក្នុងឆ្នាំ១៩៧៩៖ "ហើយនិងគល់ពឹងពង់ ហើយនិងត្បូងចបនេះឯងទាន។"] KH 01107088 [បើតាមលោក សិត ថ្លា បានមកដល់វត្តចម្ការខ្នុរក្នុងឆ្នាំ១៩៧៩ "ឃើញតែខ្នោះ និងឈាម"]។

1244 ឯកសារ D119/112 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ឆ.27 KH 00982233 [សាក្សីធ្វើការនៅក្បែរចម្ការខ្នុរពីខែមីនា ឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩៖ "តែក្រោយពីបែករបបខ្មែរក្រហមទើបខ្ញុំបានទៅទីនោះ ហើយនៅក្នុងចម្ការខ្នុរ មានវិហារចាស់មួយដែលប្រឡាក់សុទ្ធតែឈាម។"]។ ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107083-01107084 [បើតាមសាក្សី ឃួន សាយ បានជាប់ឃុំនៅវត្តចំការខ្នុរពីដើមឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧៖ "បាទ ឈាមនៅទាំងអស់។ [...] ឈាមវារីទៅ វាខ្ទាតទៅលើជញ្ជាំង។"] KH 01107088 [បើតាមលោក សិត ថ្លា បានមកដល់វត្តចម្ការខ្នុរក្នុងឆ្នាំ១៩៧៩៖ "ឃើញតែខ្នោះ និងឈាម"]។ សូមមើលផងដែរឯកសារ D5/944 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ កិញ អាយ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ KH

00981368 [សាក្សីត្រូវគេបញ្ជូនទៅចម្ការខ្នុរឱ្យដាំកប្បាសពីឆ្នាំ១៩៧៧-១៩៧៨៖ "ធុំតែក្លិនឈាម ស្អុយតែក្លិនខ្មោច ស្អុយអសោចពាសពេញ។"]។

1245 ឯកសារ D119/112 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល សេងលី ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ ឆ.28 KH 00982233 [សាក្សីធ្វើការនៅក្បែរចម្ការខ្នុរពីខែមីនា ឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩៖ "ខ្ញុំដឹងថាមានរណ្តៅធំបួន ហើយនិងរណ្តៅតូចជាច្រើន"]។ ឯកសារ D119/111 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ឡាង ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ឆ.5 KH 00982222 [សាក្សីបានឃើញរណ្តៅសាកសពបន្ទាប់ពីថ្ងៃរំដោះក្នុងឆ្នាំ១៩៧៩។ គាត់ផ្តល់ព័ត៌មានឱ្យក.ស.ច.ស សម្រាប់ធ្វើរបាយការណ៍បឋមស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឯកសារ D118/38៖ "រណ្តៅនេះមានប្រវែងទទឹង៥ម៉ែត្រ បណ្តោយប្រហែលជា២០០ម៉ែត្រ និងជម្រៅ១ម៉ែត្រ។ [...] រណ្តៅមួយទៀត គឺនៅក្បែររណ្តៅវែងនោះ [មើល "រូបភាពទីពីរ" នៅទំព័រដែលមានលេខ KH 01223519]។ រណ្តៅនេះមានទំហំបណ្តោយ៥ម៉ែត្រ ទទឹង៥ម៉ែត្រ និជម្រៅ១ម៉ែត្រ។"]។ ឯកសារ D119/114 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុង ស្រី ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ឆ.6 KH 00982254 [សាក្សីជាអ្នកជីកកកាយសាកសពដើម្បីរកមាស បានទៅគាស់កកាយនៅចម្ការខ្នុរក្នុងឆ្នាំ១៩៨៣៖ "ក្រៅពីរណ្តៅទាំង៥នេះ ដែលខ្ញុំបានឃើញ គឺមានរណ្តៅមួយវែងដែលមានប្រវែង៦០ម៉ែត្រ ជម្រៅប្រហែលជាង១ម៉ែត្រ និងទទឹងប្រហែលជា៥ម៉ែត្រសម្រាប់កប់មនុស្សនៅទីនោះ។ នៅក្នុងរណ្តៅវែងនេះមានសាកសពនៅរាយប៉ាយ ប៉ុន្តែវាមិនណែនណាន់តាន់តាប់ទេ។"]។

1246 ឯកសារ D219/204.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយ លោកស៊ិន ឃិន ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ KH 01107081 [បើតាមសាក្សី ឃួន សាយ បានជាប់ឃុំនៅវត្តចំការខ្នុរពីដើមឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧៖ "ប្រហែលជា៣ម៉ែត្របួនជ្រុងមួយកន្លែងទៅ។ នេះ១កន្លែងដែលមានដាំដើមរាំងនេះ អន្លង់មួយ។"]។ ឯកសារ D1.3.10.10 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា "របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ" ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 00750669 [សាក្សីរស់នៅភូមិអូរអំបិលក្រោយឆ្នាំ១៩៧៩ ហើយគាត់បានគាស់កកាយរណ្តៅនៅចម្ការខ្នុរក្នុងឆ្នាំ១៩៨៣-១៩៨៤៖ "[គាត់បានប្រាប់ពួកយើងថានៅពេលដែលគាត់ជីគាស់កកាយរណ្តៅសាកសពទាំងនោះ និងនៅពេលដែលគាត់ឃើញមនុស្សជីកគាស់កកាយរណ្តៅសាកសព រណ្តៅសាកសពនីមួយៗមានមុខប្រមាណប្រវែង៥ម៉ែត្រ និងបណ្តោយពី៦ម៉ែត្រ ទៅ១០ម៉ែត្រ មានជម្រៅ១,៥ម៉ែត្រទៅ២ម៉ែត្រ។"]។

1247 ឯកសារ D118/38 របាយការណ៍បឋមស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស នៅវាលពិឃាតវត្តចម្ការខ្នុរ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ KH 01223513 ["ទីតាំងទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណនៅថ្ងៃនេះ មានរូបរាងមូល ឬចតុកោណ ឬជាលេនដ្ឋាន/ស្នាមភ្លោះ ដែលត្រូវបានគេជីក ឬកើតឡើងដោយធម្មជាតិ"]។

1248 ឯកសារ D1.3.10.10 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា "របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ" ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ KH 00750665 [របាយការណ៍នេះរៀបចំដោយ លោក ស៊ិន ឃិន ក្នុងឆ្នាំ១៩៩៧ ដោយផ្អែកលើសាក្សីដដែលដែលគាត់សម្ភាសជាមួយនៅពេលក្រោយ៖ "ចម្ការខ្នុរ/ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ ចំនួនរណ្តៅ

សាកសព ១០០រណ្តៅ"]។ ឯកសារ D219/204.2. កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដោយ លោកស៊ិន ឃិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107080 [បើតាមសាក្សី ឃួន សាយ បានជាប់ឃុំនៅវត្តចំការខ្នុរពីដើមឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧៖ "មិនដឹងបានប៉ុន្មាន ប្អូនដប់ម្ភៃហើយទេដឹង!"] KH 01107082 ["ដូចជារាប់រយ។"]។ ឯកសារ D219/206 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឆ.3 KH 01072257 [សាក្សីបានសម្ភាសជាមួយសាក្សីចម្ការខ្នុរដទៃទៀតក្នុងឆ្នាំ១៩៩៧ ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ៖ "យើងមិនអាចរាប់បានទេ [...] ខ្ញុំមិនបានរាប់រណ្តៅទាំង១០០នោះទេ ចំនួននេះគឺបានមកពីសាក្សីឈ្មោះ ចិន សារ៉ង។"] ឆ.4 [ការពន្យល់ពីអ្វីដែលឈ្មោះ ចិន សារ៉ង ដឹង៖ "តែកាលពេលនោះគាត់ជាអ្នកនាំយើងទៅចង្អុលបង្ហាញដល់ទីតាំងនោះ ហើយកាលនោះគាត់អាយុ៦៥ឆ្នាំ។ គាត់រស់នៅភូមិអូរអំបិល ឃុំអូរអំបិល ស្រុកសេរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ បានន័យថាគាត់រស់នៅជិតទីតាំងជិតចម្ការខ្នុរតែម្តង"]។

1249 ឯកសារ D119/111 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ឡាង ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ឆ.7 KH 00982222 [សាក្សីបានឃើញរណ្តៅសាកសពបន្ទាប់ពីថ្ងៃរំដោះក្នុងឆ្នាំ១៩៧៩។ គាត់ផ្តល់ព័ត៌មានឲ្យ ក.ស.ច.ស សម្រាប់ធ្វើរបាយការណ៍បឋមស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឯកសារ D118/38៖ "តាមខ្ញុំស្មាន រណ្តៅទីមួយមានប្រហែល ១០០០នាក់។"]។ ឯកសារ D119/114 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុង ស្រី ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤ ឆ. 1 KH 00982253 [សាក្សីជាអ្នកជីកកកាយសាកសពដើម្បីរកមាស បានទៅគាស់កកាយនៅចម្ការខ្នុរក្នុងឆ្នាំ១៩៨៣ គាត់ជួយគាស់កកាយរណ្តៅសាកសព៖ "រណ្តៅមួយមានសាកសពប្រហែល៤៣នាក់។ រណ្តៅមួយធំមានសាកសពរាប់រយ [...] រណ្តៅមួយទៀតមានសាកសព២០នាក់។ [...] មានសាកសពចំនួន១៦នាក់"]។ ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ដោយ លោក ស៊ិន ឃិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 01107082 [បើតាមសាក្សី ឃួន សាយ បានជាប់ឃុំនៅវត្តចំការខ្នុរពីដើមឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧៖ "មួយអន្លង់មាន២០-៣០ណាទាន។"]។ ឯកសារ D1.3.27.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមចំណងជើង "គម្រោងរៀបចំផែនទី ឆ្នាំ ១៩៩៨" បន្ទាយមានជ័យ ថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩៨ KH 00184622 ["គាត់ [សោម ឡាង បានឃើញរណ្តៅសាកសពបន្ទាប់ពីថ្ងៃរំដោះក្នុងឆ្នាំ១៩៧៩] បានប៉ាន់ស្មានថាសាកសពដែលបានស្លាប់ក្នុងចម្ការខ្នុរនេះមានប្រហែលរាប់ពាន់នាក់ ព្រោះនៅក្នុងរណ្តៅដ៏ធំមួយនេះអាចមានមនុស្សស្លាប់លើសពី៥០០នាក់"]។

1250 ឯកសារ D119/111 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ឡាង ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤ ឆ.5 KH 00982222 [[សាក្សីបានឃើញរណ្តៅសាកសពបន្ទាប់ពីថ្ងៃរំដោះក្នុងឆ្នាំ១៩៧៩។ គាត់ផ្តល់ព័ត៌មានឲ្យ ក.ស.ច.ស សម្រាប់ធ្វើរបាយការណ៍បឋមស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឯកសារ D118/38៖ "ខ្ញុំឃើញសាកសពស្អុយរលួយ ឃើញឆ្អឹងនិងខោអាវនៅក្នុងរណ្តៅនោះ។"]។ ឯកសារ D119/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល ហេវ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៤ ឆ.34 KH 00982264 [នៅក្នុងខែធ្នូ ឆ្នាំ១៩៧៩៖ "នៅក្នុងព្រៃប៉ែកខាងត្បូងវត្តចម្ការខ្នុរ ខ្ញុំឃើញមានឆ្អឹងនិងលលាដ៍ក្បាលនៅរាយប៉ាយនៅលើដីនៅឡើយ [...] ហើយនៅខាងលិចវត្ត ខ្ញុំឃើញរណ្តៅសាកសពមួយដែលមានសាកសពខ្លះនៅក្នុងនោះ [...] សាកសពទាំងនោះរលួយសាច់អស់ហើយ ហើយមិនមានក្លិនស្អុយទេ។"]។ ឯកសារ D118/230 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួន ប៊ុន ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ឆ.115-116 KH 00985476

[សាក្សីធ្វើការនៅក្បែរចម្ការខ្នុរ៖ "អត់ទេ ខ្ញុំគ្រាន់តែបានឃើញរណ្តៅសាកសព និងឆ្អឹងមនុស្សតែប៉ុណ្ណោះ។ [...] នៅឆ្នាំ១៩៧៩ គឺក្រោយរបបខ្មែរក្រហម។"]។ ឯកសារ D119/113 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម រតនៈ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ឆ.1 KH 00982244 [សាក្សីឈប់សម្រាកនៅចម្ការខ្នុរនៅពេលដែលគាត់រត់ទៅព្រំដែនថៃ នៅថ្ងៃទី២៨ ឬ២៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨៖ "នៅពេលធ្វើដំណើរពួកខ្ញុំបានឈប់សម្រាកនៅតាមផ្លូវជាតិលេខ៥ ផ្លូវឡើងទៅចម្ការខ្នុរ។ ពេលខ្ញុំឡើងទៅខាងលើ ខ្ញុំបានឃើញអដ្ឋិធាតុនៅចម្ការខ្នុរ។"]។ ឯកសារ D119/114 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុង ស្រី ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ឆ.26 KH 00982256 [សាក្សីជាអ្នកជីកកកាយសាកសពដើម្បីរកមាស បានទៅគាស់កកាយនៅចម្ការខ្នុរក្នុងឆ្នាំ១៩៨៣ គាត់ជួយគាស់កកាយរណ្តៅសាកសព៖ "សាកសពទាំងនោះនៅសល់តែឆ្អឹង និងខោអាវតែប៉ុណ្ណោះ មិនមានសល់សាច់ទេ"]។

1251 ឯកសារ D118/230 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួន ប៊ុន ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ឆ.119 KH 00985476 [សាក្សីធ្វើការនៅក្បែរចម្ការខ្នុរ៖ "[ក្រោយឆ្នាំ១៩៧៩] ហើយអ្នករកមាសនៅអណ្តូងនោះបានទៅស្រង់យកឆ្អឹងមកដាក់ចោលនៅពេញដី"]។ សូមមើលផងដែរឯកសារ D5/944 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ កិញ អាយ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ KH 00981367 [សាក្សីត្រូវគេបញ្ជូនទៅចម្ការខ្នុរឲ្យដាំកប្បាស ឆ្នាំ១៩៧៧៖ "នៅការដ្ឋានភ្នំកងវ៉ាចម្ការខ្នុរ ឲ្យតែពេលរសៀល ឃើញឈ្លប ឬពួកយោធាតែងបណ្តើរមនុស្សយកទៅសម្លាប់ [...]។ ខ្លះយកទៅសម្លាប់ក្នុងអណ្តូង វាយទម្លាក់ក្នុងអណ្តូង"]។

1252 ឯកសារ D119/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទិល ហេរ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ឆ.31 KH 00982263 [សាក្សីត្រូវគេចាត់តាំងធ្វើជាប្រធានភូមិកំពង់រាប ស្រុកស៊ីសូផុន ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧៖ "ក៏ប៉ុន្តែនៅពេលគេប្រមូលអដ្ឋិធាតុមកតម្កល់ទុកនៅក្នុងវត្តសុភមង្គល ខ្ញុំក៏បានទៅចូលរួមក្នុងពិធីបុណ្យនោះដែរ ហើយពេលនោះខ្ញុំបានឃើញអដ្ឋិធាតុជាច្រើននៅទីនោះ។"]។ ឯកសារ D118/38 របាយការណ៍បឋមស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស នៅវាលពិឃាតវត្តចម្ការខ្នុរ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ KH 01223526 [បង្ហាញរូបភាពនៃគំនរឆ្អឹងមនុស្សនៅក្នុងចេតីយ៍។]។ ឯកសារ D219/206 [ដែលកែតម្រូវ 1] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឆ.9 KH 01072258 [សាក្សីបានសម្ភាសជាមួយសាក្សីចម្ការខ្នុរដទៃទៀតក្នុងឆ្នាំ១៩៩៧ ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា៖ "តែឆ្អឹងបានយកទៅតម្កល់នៅវត្តសុភមង្គល។"] ឆ.11 ["ផ្អែកលើព័ត៌មានដែលសាក្សីទាំងបីផ្តល់ឲ្យ គឺឆ្អឹងទាំងអស់យកមកពីចម្ការខ្នុរ។"]។

1253 ឯកសារ D219/204.2.1 ប្រតិចារឹកបទសម្ភាសន៍ដោយ លោក ស៊ិន ឃិន KH 01107056-01107057 [សាក្សី សៀន មាន បានទៅមើលកន្លែងពិឃាតនៅចម្ការខ្នុរ ក្នុងឆ្នាំ១៩៧៩៖ "រណ្តៅហ្នឹងដូចជាមានជីក ឬឈូស [...] មានខ្លះជីកដោយដៃមនុស្ស ដោយសារកម្លាំងមនុស្ស។"]។ ឯកសារ D1.3.10.10 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា "របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ" ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ KH 00750669 [គាត់ [ចិន សារ៉ង ជាអ្នកបានគាស់កកាយរណ្តៅនៅចម្ការខ្នុរក្នុងឆ្នាំ១៩៨៣-១៩៨៤] បានប្រាប់យើង [មជ្ឈមណ្ឌលឯកសារកម្ពុជា] ថា នៅពេលគាត់ជីកគាស់កកាយរណ្តៅសាកសពទាំងនោះ និងនៅពេលដែលគាត់ឃើញមនុស្សជីកគាស់កកាយរណ្តៅសាកសព [...] មាន

ជម្រៅពី១,៥០ម៉ែត្រ ទៅ២ម៉ែត្រ។"]។ ឯកសារ D118/250 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុត វើក ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.170 KH 00992432 [សាក្សីត្រូវគេឃុំខ្លួននៅវត្តបន្ទាយនាង ហើយគាត់ក៏ស្គាល់វត្តចម្ការខ្នុរផងដែរៈ "ចម្ការខ្នុរនេះក៏ជាកន្លែងសម្លាប់មនុស្សដែរ ព្រោះក្រោយពីរបបខ្មែរក្រហមគេបានទៅជីករកមាសនៅម្ដុំចម្ការខ្នុរនេះ ហើយឃើញមានឆ្អឹងមនុស្សនៅទីនោះផងដែរ"]។

1254 ឯកសារ **D118/38** របាយការណ៍បឋមស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស នៅវាលពិឃាតវត្តចម្ការខ្នុរ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ KH 01223513 ["សូមកត់សម្គាល់ថា រណ្ដៅសាកសពទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណរហូតមកដល់ពេលនេះសុទ្ធតែមានទីតាំងស្ថិតនៅក្នុងតំបន់ធ្វើស្រែចម្ការរបស់ប្រជាជន។ តំបន់ហួសពីចំណុច១៣៨ គឺជាតំបន់ដែលមានរុក្ខជាតិដុះគ្របដណ្ដប់ក្រាស់ តំបន់នោះមិនមែនជាតំបន់ធ្វើស្រែចម្ការនោះឡើយ"]។

1255 ឯកសារ **D118/38** របាយការណ៍បឋមស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស នៅវាលពិឃាតវត្តចម្ការខ្នុរ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ KH 01223513 [ហុង ស្រី បានធ្វើការឱ្យ សោម ឡាងក្នុងការគាស់កកាយរណ្ដៅសាកសពក្នុងទសវត្សរ៍១៩៨០ៈ "យោងតាមលោក ហុង ស្រី នៅមានរណ្ដៅសាកសពជាច្រើនទៀតដែលមិនទាន់ត្រូវបានគេជីកគាស់រហូតមកដល់ពេលនេះ [...] តំបន់ហួសពីចំណុច [...] គឺជាតំបន់ដែលមានរុក្ខជាតិដុះគ្របដណ្ដប់ក្រាស់ តំបន់នោះមិនមែនជាតំបន់ធ្វើស្រែចម្ការនោះឡើយ"]។

1256 ឯកសារ D1.3.10.10 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចំណងជើងថា "របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្ដីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧ៈ ខេត្តបន្ទាយមានជ័យ" ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៧ KH 00750665 ["ចម្ការខ្នុរ/ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ ចំនួនជនរងគ្រោះតាមការប៉ាន់ស្មាន ២០០០០ នាក់។"] និង KH 00750671 ["ដូច្នេះទីតាំងពិឃាតមនុស្សនៅចម្ការខ្នុរ វត្តចម្ការខ្នុរត្រូវបានគេធ្វើការប៉ាន់ស្មានថាមានជនរងគ្រោះ [...] (ប្រមាណជា២៥០០០នាក់)។"]។ ឯកសារ D219/204.1 ឧបសម្ព័ន្ធ ១ៈ របាយការណ៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧ KH 01074005 ["ដូច្នេះទីតាំងសម្លាប់គុកសន្តិសុខ ចម្ការខ្នុរ វត្តចម្ការខ្នុរអាចសន្និដ្ឋានបានថា ជាង ២០០០០ (ជាងពីរម៉ឺននាក់) ទៅ ២៥០០០នាក់"]។

1257 ឯកសារ D106/12 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788226-00788227 ["មានទីតាំងនៅក្នុងខេត្តៈ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ [...] កំណត់បង្ហាញពីភូមិភាគ និងតំបន់របស់ខ្មែរក្រហមៈ តំបន់៥ភូមិភាគពាយ័ព្យ"]។

1258 ឯកសារ D106/12 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788227 ["មន្ទីរឃុំឃាំងវត្តព្រះនេត្រព្រះ ព័ទ្ធជុំវិញដោយវាលស្រែ បឹងបួរ និងភូមិតូចៗចំនួន១១ (ព្រះនេត្រព្រះ តាប៉ែន ប៉ោយព្រីង Kandak ប៉ោយសំរោង ប៉ុស្តិ៍ចាស់ ជើងវត្ត ផ្សារ ប៉ោយក្លឿង ចក្រី គោកតាយូ)។ ភូមិទាំងនោះគឺជាភូមិទាំងអស់នៃឃុំព្រះនេត្រព្រះ។"]។ ឯកសារ D106/11 របាយការណ៍អនុវត្តដីការចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១២ KH 00787417 ["នៅសម័យប៉ុលពត ភូមិចំនួន១១ គឺជាផ្នែកមួយនៃតំបន់ជុំវិញវត្តព្រះនេត្រព្រះ (គឺភូមិតាប៉ែន ភូមិប៉ោយព្រីង ភូមិកណ្ដាក ភូមិប៉ោយសំរោង ភូមិប៉ុសចាស់ ភូមិជើងវត្ត ភូមិផ្សារ ភូមិប៉ោយក្លឿង ភូមិចក្រី និងភូមិគោកតាយូ)"]
។

1259 ឯកសារ D119/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈុក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.24 KH 00933133 [សាក្សីជាចល័តនៅស្រុកព្រះនេត្រព្រះ៖ "គេបានយកវត្តព្រះនេត្រព្រះធ្វើជាមន្ទីរពេទ្យនៅក្នុងឆ្នាំ១៩៧៦"]។ ឯកសារ D119/38 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ឆ.3 KH 00915847 [សាក្សីជាជាងដំដែកនៅស្រុកព្រះនេត្រព្រះ ហើយបានរស់នៅជាច្រើនភូមិនៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំដឹងថា វត្តព្រះនេត្រព្រះ គឺគេយកធ្វើជាមន្ទីរពេទ្យ។"]។ ឯកសារ D106/14 របាយការណ៍អនុវត្តដីការចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១២ KH 00787422 ["គាត់បានបញ្ជាក់ថា បរិវេណវត្តព្រះនេត្រព្រះត្រូវបានគេប្រើប្រាស់ជាមន្ទីរពេទ្យ ហើយខ្លួនគាត់ផ្ទាល់បានចំណាយពេលបីថ្ងៃនៅទីនោះ។"]។ ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228 ["អគារមន្ទីរពេទ្យមានពីរជាន់"]។ ឯកសារ D106/11 របាយការណ៍អនុវត្តដីការចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ KH 00787417 [សាក្សីរស់នៅក្នុងឃុំព្រះនេត្រព្រះ៖ "អ្នកស្រី ចៃ លឿន [...] បញ្ជាក់ថាមានមន្ទីរពេទ្យមួយនៅក្នុងបរិវេណវត្តព្រះនេត្រព្រះ។]"]។ ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ៖ ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៧ KH 00750677 ["នៅក្នុងវត្ត មានមន្ទីរពេទ្យ ប៉ុល ពត មួយ"]។ ឯកសារ D1.3.11.40 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ក្រុមវត្តព្រះនេត្រព្រះ ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៨ KH 01084703 ["វត្តនេះត្រូវបានគេប្រើជាមន្ទីរពេទ្យឃុំព្រះនេត្រព្រះ"]។

1260 ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228 ["អគារមន្ទីរពេទ្យ មានពីរជាន់ និងមានច្រកចូលមួយទល់មុខវត្តព្រះនេត្រព្រះ។ ចំណែកឯវត្តវិញមានច្រកចូលសំខាន់ចំនួនពីរ មួយបែរទៅទិសខាងលិច ហើយមួយទៀតបែរទៅទិសខាងកើត"]។ ឯកសារ D106/12.4 ឧបសម្ព័ន្ធ ៤ នៃរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ហ.ស ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ KH 00804663-00804665 [រូបថត ១-៤]។

1261 ឯកសារ D106/12.4 ឧបសម្ព័ន្ធ ៤ នៃរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ហ.ស ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០១២ KH 00804663-00804665 [រូបថត ១-៤]។

1262 ឯកសារ D119/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.35 KH 00985871 [សាក្សីជាប្រធានកងចល័តនៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងទំនប់ភ្នំលៀប តំបន់៥៖ "តាមពិតពេលនោះខ្ញុំឈរនៅតាមផ្លូវក្បែរផ្ទះយាយថែម។ នៅពេលនោះមានការប្រជុំមួយនៅជាប់ផ្ទះយាយថែម ប្រហែលជាប្រាំម៉ែត្រ ដែលពេលនោះមានវត្តមាន តាផាង តាចាម តាក្រុក នៅទីនោះដែរ។ ហើយនៅពេលនោះ ខ្ញុំឮសូរសម្រែកមនុស្សស្រែកចេញពីទីនោះ ប៉ុន្តែខ្ញុំមិនដឹងថាមានការចាប់ខ្លួនពួកគេទេ។"] ឆ.42 KH 00985872 ["នៅពេលដែលខ្ញុំបានជូន ខុន មកចូលរួមប្រជុំនោះ ហើយខ្ញុំបានឈរនៅនឹងថ្នល់ប្រហែលមិនបានពីរម៉ោងផង ខ្ញុំក៏ត្រឡប់ទៅកន្លែងធ្វើការខ្ញុំវិញ។ ពេលក្រោយមកទើប ខុន បានត្រឡប់ទៅកន្លែងធ្វើការនៅការដ្ឋានវិញ តែខ្ញុំមិនដែលឃើញមនុស្សទាំងបួននាក់នោះត្រឡប់មកវិញទៀតទេ។"] ឆ.43 KH 00985872 ["តាំងពីពេលនោះមក ខ្ញុំមិនដែលឃើញពួកគេទាំងបួននោះទៀត ដូច្នេះហើយទើបខ្ញុំសន្មតថាពួកទាំងបួននោះត្រូវបានចាប់ខ្លួននៅទីនោះ។"] ឆ.44 KH 00985873 ["តាមខ្ញុំដឹងអ្នកដែលត្រូវបានចាប់ខ្លួនផ្សេងទៀតដោយយាយថែម

មានអ្នកនៅរស់ខ្លះ ប៉ុន្តែខ្ញុំប្រកដថាអ្នកទាំងបួនពិតជាត្រូវគេសម្លាប់ហើយ។"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ ឆ.22 KH 00978921 [សាក្សីជាសមាជិកកងចល័តសហករណ៍៥ ឃុំព្រះនេត្រព្រះ៖ "តាមខ្ញុំយល់ គឺយាយ ចែម ជាអ្នកបញ្ជាឲ្យគេចាប់ពួកគាត់ ពីព្រោះ យាយចែម ជាគណៈស្រុកព្រះនេត្រព្រះថ្មី។ ខ្ញុំធ្លាប់ឮពីមនុស្សនៅក្នុងកងចល័ត ថាគាត់ជាកម្មាភិបាលថ្នាក់តំបន់ ហើយគាត់ស្នាក់នៅភ្នំលៀប។ ខ្ញុំមិនចាំឈ្មោះមនុស្សនៅក្នុងកងចល័តដែលបានប្រាប់ខ្ញុំទេ។"] ឆ.26-27 KH 00978922 ["ស៖ ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ១១ ERN 00969842 លោកបាននិយាយថា "យាយ ចែម បានចាប់ តាក្រេក និងអ្នកពាយ័ព្យ ហើយអ្នកទាំងនោះត្រូវបានគេយកទៅឃុំ និងធ្វើទារុណកម្មនៅផ្ទះ យាយ ចែម យើងអាចឮសំឡេងស្រែក"។ តើលោកអាចបញ្ជាក់បន្ថែមបានទេ? ឆ.26៖ ឡឹន និងខ្មៅ បានប្រាប់ខ្ញុំអំពីព្រឹត្តិការណ៍នេះ។ ស៖ លោកដឹងទេថាហេតុអ្វីបានជា ឡឹន និងខ្មៅដឹងអំពីព្រឹត្តិការណ៍នេះ? ឆ.27៖ ពីព្រោះ ឡឹន និងខ្មៅ ធ្វើការនៅក្នុងកងចល័តតំបន់ ហើយពួកគេបានទៅផ្ទះយាយ ចែម។"]។

1263 ឯកសារ D219/347 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.23 KH 01103344 [សាក្សីជាសមាជិកនៅក្នុងគណៈឃុំព្រះនេត្រព្រះ៖ "ទាល់តែមេឃុំនិរតីមកដល់ ទើបផ្ទះគាត់ [ផ្ទះតាក្រេក] ត្រូវបានគេយកធ្វើជាមន្ទីរឃុំឃាំង។"]។ ឯកសារ D119/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.25-30 KH 00907515-00907516 [សាក្សីជាសមាជិកនៅក្នុងគណៈឃុំព្រះនេត្រព្រះ៖ "ដំបូងផ្ទះនោះគឺជាផ្ទះធម្មតាទេ។ តែក្រោយមក ពេលគេចោទតាក្រេកថាក្បត់ ហើយគេក៏ដកគាត់ចេញ ហើយប្រើផ្ទះនោះធ្វើជាមន្ទីរឃុំឃាំង។ ខ្ញុំមិនចាំថាគេដកគាត់នៅពេលណាទេ តែគាត់ត្រូវបានគេដកនៅពេលពួកនិរតីមកដល់។ [...] ខ្ញុំប្រាកដណាស់ [ថាផ្ទះតាក្រេកត្រូវបានប្រើធ្វើជាមន្ទីរឃុំឃាំងបន្ទាប់ពីការដកគាត់ចេញ] ព្រោះពេលនោះ ប្រពន្ធនិងកូនរបស់តាក្រេក ក៏គេដកចេញពីផ្ទះនោះដែរ ហើយអ្នកមានកំហុសតាមភូមិត្រូវបានគេចាប់យកមកដាក់ក្នុងផ្ទះនោះ [ផ្ទះតាក្រេក] ក្រោមការគ្រប់គ្រងរបស់នារីថា និង តាណុញ ។"]។ ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.18 KH 01066319 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះ៖ "ប្រជាជនធម្មតា [...] ត្រូវបានគេយកទៅសម្លាប់ [...] នៅចម្ងាយប្រហែល ១០០ម៉ែត្រ ខាងក្រោយផ្ទះតាក្រេក។"] ឆ.21 KH 01066319 ["ប្រជាជនរស់នៅជិតៗនោះដឹងតៗគ្នាថា មុនគេយកមនុស្សទៅសម្លាប់ ពួកនិរតីយកមនុស្សទៅឃុំខ្លួននៅទីនោះសិន។"] ឆ.22 KH 01066319 ["មនុស្សដែលមានផ្ទះនៅក្បែរផ្ទះតាក្រេក ចម្ងាយប្រហែល៥០ម៉ែត្រ ធ្លាប់បានឃើញគេបណ្ដើរមនុស្សដើរកាត់តាមខ្លោងទ្វារវត្តទៅទីកន្លែងនោះ ហើយក៏ឮសូរសំឡេងមនុស្សទាំងនោះដែលគេយកទៅសម្លាប់ផងដែរ។"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6 KH 00915872 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំបានឃើញគេបណ្ដើរមនុស្សទាំងខ្សែៗ ដែលគេចាប់ខ្លួនមកពីភូមិផ្សេងៗ ហើយបានបញ្ជូនទៅសម្លាប់នៅក្រោយផ្ទះតាក្រេកក្នុងភូមិប៉ោយគៀង។"]។ ឆ.10-11 KH 00915872-00915873 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ "ពេលដែលតាក្រេកបាត់ខ្លួន ពួកនិរតីបានមកនៅផ្ទះតាក្រេក ហើយកន្លែងនោះក៏នៅតែជាកន្លែងសម្រាប់ទុកមនុស្សដដែល [...] តាក្រេក ត្រូវបានចាប់ខ្លួនកន្លះឆ្នាំ ក្រោយពេលពួកនិរតីមកដល់។"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.9 KH 00978919

[សាក្សីគឺជាសមាជិកម្នាក់នៅក្នុងកងចល័តក្នុងសហករណ៍៥ ក្នុងឃុំព្រះនេត្រព្រះ៖ “ខ្ញុំធ្លាប់បានឮគេថាមានយកមនុស្សទៅឃុំឃាំងនៅទីនោះមែន [ផ្ទះតាក្រក] ប៉ុន្តែខ្ញុំមិនដឹងថាគេយកមនុស្សទាំងនោះ ទៅសម្លាប់ទីណាទេ។”]។ ឯកសារ D119/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945877 [“ផ្ទះតាក្រក [ត្រូវ] បានប្រើជាមន្ទីរឃុំឃាំង ក្រោយពេលតាក្រកបានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៨។”]។ សុំមើលចំណុចមិនស៊ីសង្វាក់គ្នា៖ ឯកសារ D119/38 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.15 KH 00915849 [សាក្សីជាជាងដែកម្នាក់នៅក្នុងស្រុកព្រះនេត្រព្រះ ហើយបានរស់នៅក្នុងភូមិផ្សេងៗនៅក្នុងឃុំព្រះនេត្រព្រះ ៖ “មួយរយៈដំបូងពួកពាយ័ព្យ និងពួកនិរតីធ្វើការជាមួយគ្នានៅផ្ទះតាក្រក ដែលបានប្រើជាកន្លែងឃុំឃាំងមនុស្ស។ តែបន្ទាប់ពីមានព្រឹត្តិការណ៍ចាប់ខ្លួនពួកពាយ័ព្យដោយពួកនិរតី ផ្ទះតាក្រកត្រូវបានគេរុះរើអស់ទាំងស្រុង។”]។ សូមមើលផងដែរ ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.18 KH 01066319 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះ៖ “ការចាប់ខ្លួននិងសម្លាប់ប្រជាជនធម្មតា និងអតីតរដ្ឋការ លន់ នល់ គឺធ្វើឡើងនៅក្រោយពេលដែលគេចាប់ខ្លួនតាក្រក គឺនៅពេលដែលពួកនិរតីមកដល់។ ក្រោយពេលពួកនិរតីមកដល់ មន្ទីរឃុំព្រះនេត្រព្រះថ្មី ស្ថិតនៅចម្ងាយប្រហែលជាពីរទៅបីផ្ទះ ខាងជើងផ្ទះតាក្រក។”]។ ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788227 [“សាក្សីម្នាក់បាននិយាយថា ‘គណៈឃុំរបស់ ប៉ុល ពត’ បានប្រើផ្ទះនៅជិតវត្តព្រះនេត្រព្រះ […]។ [00788228] នៅក្នុងរបបនោះ ផ្ទះរបស់អនុគណៈឃុំឈ្មោះតាក្រក មានចម្ងាយប្រហែល៨០០ម៉ែត្រ ខាងជើងវត្ត នៅខាងឆ្វេងដៃផ្លូវតូចមួយឆ្ពោះទៅផ្លូវជាតិលេខ៦។”]។

1264 ឯកសារ D119/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945878 [“ផ្ទះតាក្រក ព័ទ្ធជុំវិញដោយព្រៃក្រាស់ និងនៅពីមុខ មានផ្លូវដីឆ្ពោះទៅវត្តព្រះនេត្រព្រះនៅម្ខាង និងម្ខាងទៀតនៅជាប់ផ្លូវជាតិ៦។ […] ផ្ទះនោះជាផ្ទះឈើមួយជាន់ដែលច្រកចូលបែរមុខទៅផ្លូវ។”]។

1265 ឯកសារ D119/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945878 [“ក្នុងរបបខ្មែរក្រហម មានអណ្តូងនៅខាងក្រោយផ្ទះជាប់និងផ្ទះបច្ចុប្បន្នរបស់សាក្សី សោះ ណារិន។ បច្ចុប្បន្ននេះ មិនមានអណ្តូងទឹកនោះទេ។”]។ ឯកសារ D119/46.2 ឧបសម្ព័ន ២ នៃរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ EN 00920242, EN 00920243 [រូបថតទី៣-៤]។

1266 ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.18 KH 01066319 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះ៖ “(ប្រជាជនត្រូវបានគេយកទៅសម្លាប់) ១០០ម៉ែត្រ ខាងក្រោយផ្ទះតាក្រក។”]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6 KH 00915872 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ “ខ្ញុំបានឃើញគេបណ្តើរមនុស្សទាំងខ្សែៗ ដែលគេចាប់ខ្លួនមកពីភូមិផ្សេងៗ ហើយបានបញ្ជូនទៅសម្លាប់នៅក្រោយផ្ទះតាក្រកក្នុងភូមិប៉ោយក្តឿង។”]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.4 KH 00915839 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តកុមារនៅ ទំនប់កំបោរ ស្រះ និង ការដ្ឋានអូរលៀប៖ “មានមនុស្សមួយចំនួនក្នុងចំណោមដែលគេយកទៅសម្លាប់ហ្នឹង បានរត់គេចខ្លួន ប៉ុន្តែប្រពន្ធ និងកូនរបស់ពួកគេត្រូវបានគេប្រមូលយកទៅ

សម្លាប់នៅក្បែរជើងភ្នំព្រះនេត្រព្រះ ដែលមានទីតាំងនៅខាងក្រោយផ្ទះតាក្រក ដែលនៅទីនោះមានរណ្តៅសាកសពដ៏ធំមួយ។”]។

1267 ឯកសារ D119/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945878 [“ផ្ទះរបស់អនុគណៈឃុំ ឈ្មោះតាក្រក មានចម្ងាយប្រហែល៨០០ម៉ែត្រ ខាងជើងវត្ត នៅឆ្វេងដៃផ្លូវតូចមួយ ឆ្ពោះទៅផ្លូវជាតិលេខ៦។”]។ ឯកសារ D119/46.1 ឧបសម្ព័ន ១ នៃរបាយការណ៍កំណត់បង្ហាញទីតាំងរបស់ ក.ស.ច.ស. ផែនទីផ្ទះតាក្រក និងចំការដូង និងចំការយាយណឹង ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945878។ ឯកសារ D119/143 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យាង យុន ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឆ.45-47 KH 00019190-00019191 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ “ផ្ទះតាក្រក គឺនៅតាមផ្លូវលំធំមួយទៅកាន់វត្តព្រះនេត្រព្រះ។ [...] ទីតាំងផ្លូវលំធំមួយនោះគឺស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ឆ្ពោះទៅកាន់ផ្លូវជាតិលេខ៦ ក្នុងស្រុកជប់។”]។

1268 ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228 [“យោងតាម GPS ចំការតាឡឹង មានទីតាំងនៅខាងក្រោយវត្ត និងស្ថិតនៅទិសអគ្នេយ៍នៃវត្ត”]។ ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ KH 00750678 [ប៉ាន់ស្មានថាទីតាំងសម្រាប់ពិឃាតមនុស្សនៅចម្ការតាលឹង នោះស្ថិតនៅប្រមាណ ៥០ម៉ែត្រ ពីក្រោយវត្តព្រះនេត្រព្រះ។]។ ឯកសារ D219/205 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ.32 KH 01072294 [សាក្សីបានប្រមូលភ័ស្តុតាងសំរាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីធ្វើរបាយការណ៍ ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ៖ “ចម្ការតាឡឹង [...] នៅចម្ងាយ៥០ម៉ែត្រពីក្រោយវត្ត”]

1269 ឯកសារ **D1.3.10.10** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ KH 00750665 [“ចម្ការតាឡឹង៖ ចំនួនរណ្តៅសាកសព=៦រណ្តៅ”] KH 00750678 [“សាក្សី តុំ សឿម [...] បានចូលរួមនៅក្នុងការជីកគាស់កកាយរណ្តៅសាកសពនានាដែលមានមុខកាត់ទំហំ ៤ ម៉ែត្រការេ និងជំរៅ២ម៉ែត្រ។”]។ ឯកសារ **D219/205** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ.28 KH 01072293 [សាក្សីបានប្រមូលភ័ស្តុតាងសំរាប់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីធ្វើរបាយការណ៍។ ឯកសារ **D1.3.10.10** នៅក្នុងខេត្តបន្ទាយមានជ័យ៖ “ខ្ញុំមិនដឹងទេ ខ្ញុំដឹងតែចំនួន៦៦០ ទៅ៧២០នាក់ ដែលជាចំនួនសាក្សីប្រាប់ថា គេយកចេញពីរណ្តៅចំនួន៦ រណ្តៅធំៗ គឺទំហំ៤ម៉ែត្របួនជ្រុងជម្រៅពីរម៉ែត្រហ្នឹង។”]។

1270 ឯកសារ **D106/12** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228 [“ចំការតាឡឹង មានទីតាំងនៅខាងក្រោយវត្ត និងស្ថិតនៅទិសអគ្នេយ៍នៃវត្ត ហើយបច្ចុប្បន្ននេះមាននៅសល់ចេតីយ៍ ស្រះ និងដីទំនេរ [ស្រះ]”]។ ឯកសារ **D106/12.4** ឧបសម្ព័ន ៤ នៃរបាយការណ៍កំណត់បង្ហាញទីតាំងរបស់ ក.ស.ច.ស. ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00804663 រូបថត៥ និងរួមទាំងចំណងជើងដែលភ្ជាប់ជាមួយ។

1271 ឯកសារ **D106/12** របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228-00788229 ["អ្នកទោសត្រូវបាននាំយកទៅផ្ទះនោះនៅពេលថ្ងៃ ហើយត្រូវបានសម្លាប់នៅពេលយប់នៅក្នុងទីកន្លែងចំនួនពីរនៅក្បែរគ្នា និងមានចម្ងាយត្រង់មិនលើសពី១០០០ម៉ែត្រ ខាងជើងភាគលិចពីផ្ទះតាក្រក [...]។ ទីតាំងទាំងពីរនោះមានឈ្មោះ *ចម្ការដូង* និង *ចម្ការយាយណឹង* ស្ថិតនៅក្នុងភូមិប៉ោយក្បៀង"]។ ឯកសារ **D119/46** របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945877 ["ផ្ទះតាក្រកដែលត្រូវបានប្រើជាមន្ទីរឃុំឃាំងក្រោយពេលតាក្រកបាត់ខ្លួនក្នុងឆ្នាំ១៩៧៨ រួមទាំង កន្លែងសម្លាប់មនុស្សផ្សេងទៀតដែលនៅក្បែរនោះ គឺចម្ការដូង និង ចម្ការយាយណឹង គឺស្ថិតនៅក្នុងភូមិប៉ោយក្បៀង។"]។ ឯកសារ **D119/46.1** ឧបសម្ព័ន ១ នៃរបាយការណ៍កំណត់បង្ហាញទីតាំងរបស់ ក.ស.ច.ស. ផែនទីផ្ទះតាក្រក និងចំការដូង និងចំការយាយណឹង ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ EN 00920239។

1272 ឯកសារ D119/46 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945878 ["ដើម្បីទៅដល់កន្លែងសម្លាប់មនុស្សទាំងពីរកន្លែង ចំការដូង និងចំការយាយណឹង យើងត្រូវដើរតាមផ្លូវដីក្រហមមួយ នៅខាងឆ្វេងផ្ទះ បន្ទាប់មកដើរឆ្លងកាត់ខ្លោងទ្វាររបងមួយទើបសាងសង់រួច។ កន្លែងសម្លាប់មនុស្សទាំងពីរនោះនៅទល់មុខគ្នា មានចម្ងាយប្រហែល១.៥គីឡូម៉ែត្រពីគ្នា។ ទីកន្លែងទាំងពីរ បែកចេញពីគ្នាដោយផ្លូវដើរតូចមួយ និងគ្របដណ្ដប់ដោយព្រៃគុម្ពោត។"]។ ឯកសារ D119/46.2 ឧបសម្ព័ន ២ នៃរបាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ EN 00920241, EN 00920248 [រូបថត២ ៥-៩]។

1273 ឯកសារ **D119/152** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.18 KH 01024727 [សាក្សីធ្វើការក្នុងកងចល័តដែលលើកភ្លឺនៅព្រះនេត្រព្រះ ស្រេះ កំបោរ ព្រៃមាន់ អូរលាប និងធ្វើពលកម្មនៅទំនប់ត្រពាំងថ្ម៖ "ក្រោយពេលខ្មែរក្រហមចូលគ្រប់គ្រងអំណាច តាក្រកត្រូវបានគេតែងតាំងឲ្យធ្វើជាមេឃុំព្រះនេត្រព្រះ។"]។ ឯកសារ **D219/181** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.12 KH 01066316 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះ៖ "តាក្រក មេឃុំព្រះនេត្រព្រះ"]។ ឯកសារ **D119/143** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឃាង ឃុន ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឆ.43 KH 01009190 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ "តាក្រកជាគណៈឃុំព្រះនេត្រព្រះ"]។ ឯកសារ **D119/37** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុង ផាវ៉ាត់ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.3 KH 00915839 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តកុមារនៅ ទំនប់កំបោរ ស្រេះ និងការដ្ឋានអូរលាប៖ "តាក្រក គឺជាគណៈឃុំព្រះនេត្រព្រះ"]។ ឯកសារ **D119/38** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.5 KH 00915848 [សាក្សីជាជាងដែកម្នាក់នៅក្នុងស្រុកព្រះនេត្រព្រះ ហើយបានរស់នៅក្នុងភូមិផ្សេងៗក្នុងឃុំព្រះនេត្រព្រះ៖ "វាកើតឡើងនៅក្នុងជំនាន់តាក្រក (មេឃុំព្រះនេត្រព្រះ)"]។

1274 ឯកសារ **D219/181** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.12 KH 01066316 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះ៖ "ផន អនុឃុំព្រះនេត្រព្រះ"]។ ឯកសារ **D119/143** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឃាង ឃុន ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឆ.43 KH 01009190 [សាក្សីគឺជាអ្នកធ្វើ

ការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ "តាក្រក ជាគណៈឃុំព្រះនេត្រព្រះ។ តាផន ជាអនុរបស់គាត់។"]។ ឯកសារ **D119/38** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.5 KH 00915848 [សាក្សីជាជាងដែកម្នាក់នៅក្នុងស្រុកព្រះនេត្រព្រះ ហើយបានរស់នៅក្នុងភូមិ ផ្សេងៗក្នុងឃុំព្រះនេត្រព្រះ៖ "វាកើតឡើងនៅក្នុងជំនាន់តាក្រក (មេឃុំព្រះនេត្រព្រះ) និងតាផន (អនុឃុំព្រះនេត្រព្រះ)"]។

1275 ឯកសារ D119/121 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.35 KH 00985871 [សាក្សីជាប្រធានកងចល័តម្នាក់នៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងទំនប់ភ្នំលាប] ក្នុងតំបន់៥ "តាមពិតពេលនោះ ខ្ញុំឈរនៅតាមផ្លូវក្បែរផ្ទះ យាយចែម។ នៅពេលនោះមានការប្រជុំមួយនៅជាប់ផ្ទះយាយ ចែម ប្រហែលជា៥ម៉ែត្រ ដែលពេលនោះមានវត្តមាន តាផាង តាចាម តាក្រក នៅទីនោះដែរ។ ហើយពេលនោះខ្ញុំបានឮសូរសម្រែកមនុស្សស្រែកចេញពីទីនោះ ប៉ុន្តែខ្ញុំមិនដឹងថាមានការចាប់ខ្លួនពួកគេទេ។"] ឆ.42 KH 00985872 ["នៅពេលដែលខ្ញុំបានជូន ខុន មកចូលរួមប្រជុំនោះហើយ ខ្ញុំបានឈរនៅនឹងថ្នល់ប្រហែលមិនបានពីរម៉ោងផង ខ្ញុំក៏ត្រឡប់ទៅកន្លែងធ្វើការខ្ញុំវិញ។ ពេលក្រោយមកទើប ខុន បានត្រឡប់ទៅកន្លែងធ្វើការនៅការដ្ឋានវិញ តែខ្ញុំមិនដែលឃើញមនុស្សទាំងបួននាក់នោះត្រឡប់មកវិញទៀតទេ។"] ឆ.43 KH 00985872 ["តាំងពីពេលនោះមក ខ្ញុំមិនដែលឃើញពួកគេទាំងបួននោះទៀតទេ ដូច្នេះហើយទើបខ្ញុំសន្មតថាពួកទាំងបួននោះត្រូវបានចាប់ខ្លួននៅទីនោះ។"] ឆ.44 KH 00985873 ["តាមខ្ញុំដឹង អ្នកដែលត្រូវបានចាប់ខ្លួនផ្សេងទៀតដោយយាយចែម មានអ្នកនៅរស់ខ្លះ ប៉ុន្តែខ្ញុំប្រាកដថាអ្នកទាំងបួននោះពិតជាត្រូវបានគេសម្លាប់ហើយ។"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.22 KH 00978921 [សាក្សីជាសមាជិកម្នាក់នៅក្នុងកងចល័តក្នុងសហករណ៍៥ ក្នុងឃុំព្រះនេត្រព្រះ៖ "តាមខ្ញុំយល់ គឺយាយចែម ជាអ្នកបញ្ជាឱ្យគេចាប់ពួកគាត់ [តាក្រក និង តាម៉ោង] ពីព្រោះ យាយចែម គឺជាគណៈស្រុកព្រះនេត្រព្រះថ្មី។ ខ្ញុំធ្លាប់បានឮពីមនុស្សនៅក្នុងកងចល័ត ថាគាត់ក៏ជាកម្មាភិបាលថ្នាក់តំបន់ ហើយគាត់ស្នាក់នៅភ្នំលៀប។ ខ្ញុំមិនចាំឈ្មោះមនុស្សនៅក្នុងកងចល័តដែលបានប្រាប់ខ្ញុំទេ។"] ឆ.26-27 KH 00978922 ["ស៖ ក្នុងកិច្ចសម្ភាសរបស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រទី១១ ERN 00969842 លោកបាននិយាយថា "យាយចែម បានចាប់តាក្រក និងអ្នកពាយ័ព្យ ហើយអ្នកទាំងនោះត្រូវបានគេយកទៅឃុំ និងធ្វើទារុណកម្មនៅផ្ទះយាយចែម យើងអាចឮសម្រែកពួកគេស្រែក"។ តើលោកអាចបញ្ជាក់បន្ថែមបានទេ? ឆ.26៖ ឡិន និង ខ្មៅបានប្រាប់ខ្ញុំអំពីព្រឹត្តិការណ៍នេះ។ ស៖ លោកដឹងទេ ថាហេតុអ្វីបានជា ឡិន និង ខ្មៅ ដឹងអំពីព្រឹត្តិការណ៍នេះ? ឆ.27៖ ពីព្រោះឡិន និង ខ្មៅ ធ្វើការនៅក្នុងកងចល័តតំបន់ ហើយពួកគេបានទៅផ្ទះ យាយ ចែម។"]។ ឯកសារ D119/38 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.12 KH 00915849 [សាក្សីជាជាងដែកម្នាក់នៅក្នុងស្រុកព្រះនេត្រព្រះ ហើយបានរស់នៅក្នុងភូមិផ្សេងៗក្នុងឃុំព្រះនេត្រព្រះ៖ "តាក្រកបានចាប់ខ្លួនដោយពួកនិរតី។ តាក្រក គេចាប់នៅមុខផ្ទះរបស់គាត់។ [...] ខ្ញុំបានឃើញគេចាប់តាក្រក បោះចូលក្នុងឡានដូចជ្រូក។"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.11 KH 00915873 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ "តាក្រក ត្រូវបានចាប់ខ្លួនកន្លះឆ្នាំ ក្រោយពេលពួកនិរតីមកដល់ ពីព្រោះពេលនោះពួកគេ (និរតី និងពាយ័ព្យ បានធ្វើការជាមួយគ្នានៅតាមការដ្ឋាននៅឡើយ)"]។ ឯកសារ D119/32 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.25 KH 00907515 [សាក្សីជា

សមាជិកនៅក្នុងគណៈឃុំព្រះនេត្រព្រះ៖ "តែក្រោយមកពេលគេចោទតាក្រក ថាក្បត់ ហើយគេក៏ដកគាត់ចេញ [...] គាត់ត្រូវបានគេដកនៅពេលពួកនិរតីមកដល់។"]។

1276 ឯកសារ D119/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.25 KH 00907515 [សាក្សីជាសមាជិកនៅក្នុងគណៈឃុំព្រះនេត្រព្រះ៖ "[តាក្រក] គាត់ត្រូវបានគេដកនៅពេលពួកនិរតីមកដល់ ហើយអ្នកដែលឡើងជំនួសគាត់មានឈ្មោះ ថា (ស្រី) និងក្រោយមកមានឈ្មោះ តាណុញ។"] ឆ.30 KH 00907516 ["ខ្ញុំប្រាកដណាស់ [ដែលថាផ្ទះតាក្រកត្រូវបានប្រើធ្វើជាមន្ទីរឃុំឃាំងបន្ទាប់ពីការដកគាត់ចេញ] ព្រោះពេលនោះ ប្រពន្ធនិងកូនរបស់តាក្រក ក៏គេដកចេញពីផ្ទះនោះដែរ។ ហើយអ្នកមានកំហុសតាមភូមិត្រូវបានគេចាប់មកដាក់នៅផ្ទះនោះ [ផ្ទះតាក្រក] ក្រោមការគ្រប់គ្រងរបស់នារី ថា និងតាណុញ។"]។ ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.26 KH 01066320 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះ៖ "ឈ្មោះ ឡុញ ភេទប្រុស (កម្មាភិបាលនិរតី) និង ឈ្មោះ ថា ភេទស្រី (កម្មាភិបាលនិរតី) [បានឡើងជំនួសតាក្រកជាគណៈឃុំព្រះនេត្រព្រះ]"]។

1277 ឯកសារ D215/1.1.1 កិច្ចសម្ភាសជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ EN 01030496 ["ខ្ញុំបានធ្វើជាប្រធានស្រុករហូតដល់ចុងបញ្ចប់របប។"] ["ខ្ញុំបានធ្វើជាប្រធានស្រុករហូតដល់ចុងបញ្ចប់របប"]។

1278 ឯកសារ **D119/32** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.41 KH 00907517 [សាក្សីជាសមាជិកនៅក្នុងគណៈឃុំព្រះនេត្រព្រះ៖ "តាមធម្មតាការរាយការណ៍គឺចេញពីប្រជាជន ទៅប្រធានក្រុម ទៅប្រធានភូមិ ទៅប្រធានឃុំ និងឡើងទៅស្រុក។"]។

1279 ឯកសារ **D219/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.36 KH 01066322 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំសូមគូសបញ្ជាក់ថា ឈ្មោះរុន និងឈ្មោះសាត ដែលជាគណៈសហករណ៍ពីរ រាយការណ៍ទៅឲ្យតាឡុញ និងនារី ថា ហើយអ្នកទាំងពីរនេះនិងត្រូវរាយការណ៍ផ្ទាល់ទៅឲ្យយាយចែម។"]។ ឯកសារ **D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.32 KH 00978922 [សាក្សីជាសមាជិកម្នាក់នៅក្នុងកងចល័តក្នុងសហករណ៍៥ ក្នុងឃុំព្រះនេត្រព្រះ៖ "ការស្រាវជ្រាវប្រវត្តិរូបត្រូវបានធ្វើឡើងនៅតាមភូមិ និងសហករណ៍ បន្ទាប់មកត្រូវបានបញ្ជូនទៅថ្នាក់លើ គឺទៅយាយចែម"]។ ឯកសារ **D219/347** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.12 KH 01103342 [សាក្សីជាសមាជិកនៅក្នុងគណៈឃុំព្រះនេត្រព្រះ៖ "ទេ ខ្ញុំមិនដឹងថា ឃុំត្រូវរាយការណ៍ទៅថ្នាក់ស្រុកញឹកញាប់ដល់កំរិតណានោះទេ ប៉ុន្តែជាធម្មតា ក្នុងនាមខ្ញុំជាសមាជិកគណៈឃុំ ខ្ញុំត្រូវរាយការណ៍ទៅអនុឃុំ ហើយអនុឃុំជាអ្នករាយការណ៍បន្តទៅលើទៀត។"]។

1280 ឯកសារ **D119/37** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.20 KH 00915842 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តកុមារនៅ ទំនប់ កំបោរ ស្រែះ និងការដ្ឋានអូរលាប ហើយធ្លាប់បានចូលរួមប្រជុំដែលដឹកនាំដោយ អ៊ឹម ចែម៖ "[អ៊ឹម ចែម] គាត់បានមកដឹកនាំប្រជុំធំៗជាច្រើនដងនៅមុខវត្តព្រះនេត្រព្រះ"]។ ឯកសារ **D119/34** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម ឡៃហៀង ហៅ ហឿន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឆ.17 KH 00907537 [សាក្សីជាអ្នកបើកអង្ករនៅសហករណ៍២ ក្នុងស្រុកព្រះនេត្រព្រះនិងធ្លាប់បានចូលរួមប្រជុំនៅវត្តព្រះនេត្រព្រះ៖ "ខ្ញុំ

ស្គាល់គាត់ [អ៊ឹម ចែម] ដោយខ្ញុំឮគេហៅឈ្មោះគាត់ពេលគេហៅប្រជាជនទៅប្រជុំនៅវត្តព្រះនេត្រព្រះ"]។ *សូមមើលផងដែរ* ឯកសារ **D119/143** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យាង យុន ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឆ.65 KH 01009194 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះ៖ "រស់នៅក្នុងឃុំព្រះនេត្រព្រះ ខ្ញុំបានជួបយាយចែមតែម្តងនៅពេលដែលខ្ញុំបានចូលរួមប្រជុំធំមួយ។"]។ ឯកសារ **D219/181** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.36 KH 01066322 [សាក្សីជាប្រធានពួកម្នាក់ នៅក្នុងឃុំព្រះនេត្រព្រះធ្លាប់បានចូលរួមប្រជុំដែលដឹកនាំដោយ អ៊ឹម ចែម៖ "ខ្ញុំធ្លាប់តែឃើញយាយចែមក្នុងអង្គប្រជុំធំៗ"]។ ឯកសារ **D119/122** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាប ថា ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៥ ឆ.37-38 KH 00987253 [សាក្សីជាកម្មាភិបាលនិរតីដែលមកនៅភូមិភាគពាយ័ព្យ៖ "ចាស ខ្ញុំធ្លាប់បានជួបគាត់ [អ៊ឹម ចែម] នៅពេលដែលមានការប្រជុំ ដែលខ្ញុំត្រូវទទួលផែនការធ្វើការងារពីគាត់ក្នុងការងារស្រែប្រាំង។ [...] ជួនកាលយើងប្រជុំជាមួយប្រជាជនទូទៅ ជួនកាលជាមួយអ្នកដឹកនាំសហករណ៍នៅតាមភូមិ ។ល។"]។ ឯកសារ **D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ិត ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.40 KH 00998140 [សាក្សីរស់នៅក្នុងភូមិភ្នំជញ្ជាំង ស្រុកព្រះនេត្រព្រះ និងជាអ្នកធ្វើការនៅទំនប់អូរលៀប ក្នុងឃុំប្រាសាទ ហើយធ្លាប់បានចូលរួមប្រជុំដែលដឹកនាំដោយ អ៊ឹម ចែម ក្នុងឆ្នាំ ១៩៧៨៖ "នៅពេលប្រជុំម្តងៗគឺមានប្រជាជនចូលរួមចន្លោះពី ៣០០ ទៅ ៦០០ នាក់។ ប្រជាជនដែលទៅចូលរួមប្រជុំនោះ គឺត្រូវធ្វើដំណើរផ្លូវឆ្ងាយ ដោយសារពួកគេរស់នៅក្នុងឃុំផ្សេងៗ ដូចជា ឃុំរហាល ឃុំព្រះនេត្រព្រះ និង ឃុំទានកាំ។"]។

1281 ឯកសារ **D119/37** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.19 KH 00915842 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តកុមារនៅ ទំនប់ កំបោរ ស្រេះ និងការដ្ឋានអូរលាប ហើយធ្លាប់បានចូលរួមប្រជុំដែលដឹកនាំដោយ អ៊ឹម ចែម៖ "ខ្ញុំធ្លាប់បានចូលរួមប្រជុំច្រើនដង ដែលនៅពេលនោះមានវត្តមាន យាយចែម តាផន និងតាក្រក ជាអ្នកដឹកនាំអង្គប្រជុំ ហើយក៏មានអ្នកចូលរួមរាប់ពាន់នាក់ផងដែរនៅទីធ្លាមុខវត្តព្រះនេត្រព្រះ។"]។

1282 ឯកសារ D119/34 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម ឡៃហៀង ហៅ ហឿន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឆ.17 KH 00907537 [សាក្សីជាអ្នកបើកអង្ករនៅសហករណ៍២ ក្នុងស្រុកព្រះនេត្រព្រះនិងធ្លាប់បានចូលរួមប្រជុំដែលដឹកនាំដោយ អ៊ឹម ចែម៖ "សៈ តើហេតុអ្វីបានជាលោកស្រីស្គាល់យាយចែម? ឆៈ ខ្ញុំស្គាល់គាត់ដោយខ្ញុំឮគេហៅឈ្មោះគាត់ពេលគេហៅប្រជាជនទៅប្រជុំនៅវត្តព្រះនេត្រព្រះ ប៉ុន្តែខ្ញុំមិនដឹងថា គាត់មានតួនាទីអ្វីទេ។ គេប្រាប់ថាគាត់មកពីគណៈលើ។ ខ្ញុំបានចូលរួមកិច្ចប្រជុំនោះ ហើយខ្លឹមសារនៃកិច្ចប្រជុំ គឺត្រូវរួបរួមសាមគ្គីគ្នា ហើយត្រូវរស់នៅជាមួយគ្នា។ ឆ.20 KH 00907537 [តែពេលប្រជុំគឺគេធ្វើឡើងនៅកន្លែងវាលធំនៅក្នុងវត្ត។"] សូមមើលផងដែរ ឯកសារ D119/133 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ិត ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.43 KH 00998140 [សាក្សីរស់នៅក្នុងភូមិភ្នំជញ្ជាំង ស្រុកព្រះនេត្រព្រះ និងជាអ្នកធ្វើការនៅទំនប់អូរលៀប ក្នុងឃុំប្រាសាទ ហើយធ្លាប់បានចូលរួមប្រជុំដែលដឹកនាំដោយ អ៊ឹម ចែម ក្នុងឆ្នាំ ១៩៧៨៖ "សៈ នៅក្នុងកិច្ចប្រជុំ តើយាយចែម បាននិយាយអំពីអ្វីខ្លះ? ឆ.43៖ គាត់ប្រាប់ឱ្យយើងស្មោះត្រង់ជាមួយអង្គការ ខិតខំធ្វើការ ពង្រឹងគោលជំហរកុំឱ្យទ្រេតទ្រោត កុំឱ្យចាញ់ល្បិចកលខ្មាំង ហើយខិតខំសាមគ្គីគ្នា ដើម្បីសម្រេចផែនការដែលអង្គការបានដាក់ទិស។"]។ ឯកសារ D119/143 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យាង យុន ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឆ.65 KH 01009194 [សាក្សីគឺជាអ្នកធ្វើការនៅក្នុងកងចល័តក្នុងឃុំព្រះនេត្រព្រះហើយធ្លាប់បានចូលរួមប្រជុំដែល

ដឹកនាំដោយ អ៊ឹម ចែម៖ "រស់នៅក្នុងឃុំព្រះនេត្រព្រះ ខ្ញុំបានជួបយាយចែមតែម្តងនៅពេលដែលខ្ញុំបានចូលរួមប្រជុំធំមួយ។ ខ្លឹមសារនៃការប្រជុំគឺតែងតែលើកដូចៗគ្នានឹងប្រជុំមុនៗដែរ ពិសេសលើកឡើងអំពីការកម្ទេចខ្មាំងស៊ីរូងផ្ទៃក្នុង និងការខិតខំបង្កបង្កើនផលតែប៉ុណ្ណោះ។"]។

1283 ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.20 KH 00915842 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប៖ "ស៖ តើវត្តព្រះនេត្រព្រះត្រូវបានគេប្រើប្រាស់ធ្វើអ្វីនៅក្នុងសម័យខ្មែរក្រហម? ឆ.20៖ វត្តព្រះនេត្រព្រះ នៅពេលនោះ គេយកធ្វើជាមន្ទីរពេទ្យ ពីព្រោះគេយកអ្នកជំងឺទៅព្យាបាលនៅទីនោះ។ ខ្ញុំមិនបានដឹងថា យាយ ចែម បានទៅពិនិត្យមើលមន្ទីរពេទ្យព្រះនេត្រព្រះនោះទេនៅពេលនោះ ប៉ុន្តែខ្ញុំគិតថា គាត់បានដឹងអំពីមន្ទីរពេទ្យនោះហើយ ពីព្រោះគាត់បានមកដឹកនាំប្រជុំធំៗជាច្រើនដង នៅមុខវត្តព្រះនេត្រព្រះ (មន្ទីរពេទ្យ)"]។ ឆ.22 KH 00915842 ["ស៖ លោកស្រីដឹងទេថា នៅមន្ទីរពេទ្យនោះ តើមានមនុស្សស្លាប់ដោយសារជំងឺ និងស្លាប់ដោយសារគេយកទៅសម្លាប់ដែរទេ? ឆ៖ មិនមានមនុស្សគេសម្លាប់នៅទីនោះទេ ប៉ុន្តែភាគច្រើនស្លាប់ដោយអត់អាហារ ជំងឺ (ជំងឺហើម និងជំងឺគ្រុនញាក់) និងខ្វះថ្នាំព្យាបាល។ តាមខ្ញុំចាំ គឺមានមនុស្សបានស្លាប់ជាច្រើនរៀងរាល់ថ្ងៃ"]។ ឯកសារ D119/24 របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00897497 [លោក ហុង ហ៊ុយ ដែលជាអតីតមេឃុំព្រះនេត្រព្រះ បានប្រាប់អ្នកស៊ើបអង្កេតថា៖ "ការផ្លាស់ប្តូរជំនួសកម្មាភិបាលខ្មែរក្រហមនៅភូមិភាគពាយ័ព្យបានកើតឡើងនៅអំឡុងចុងឆ្នាំ ១៩៧៦ ឬនៅក្នុងឆ្នាំ ១៩៧៧ ហើយស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងស្រុកព្រះនេត្រព្រះ មានសភាពលំបាកលំបិនណាស់ មិនថានៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ ឬកម្មាភិបាលភូមិភាគនិរតីឡើយ។ [...] ព្រះនេត្រព្រះនៅពេលនោះត្រូវបានប្រើប្រាស់ជាមន្ទីរពេទ្យ។ [...] ប្រជាជនជាច្រើននាក់បានស្លាប់នៅមន្ទីរពេទ្យនោះ ហើយអ្នកដែលបានស្លាប់ត្រូវបានគេកប់នៅក្នុងបរិវេណវត្តនោះ។ [...] ប្រជាជនរាប់ពាន់នាក់បានស្លាប់ និងត្រូវបានគេកប់នៅមន្ទីរពេទ្យនោះ។ គ្រួសាររបស់គាត់ [ហុង ហ៊ុយ] បានស្លាប់នៅកន្លែងនោះផងដែរ"]។

1284 ឯកសារ D119/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈូក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.24 KH 00933133 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅស្រុកព្រះនេត្រព្រះ៖ "គេបានយកវត្តព្រះនេត្រព្រះធ្វើជាមន្ទីរពេទ្យនៅឆ្នាំ ១៩៧៦"]។ ឆ.26 KH 00933133 ["មន្ទីរពេទ្យនេះពុំមែនត្រូវបានប្រើប្រាស់ជាគុកនោះទេ"។ឯកសារ D106/11 របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787416-00787417 ["យើងបានជួបស្ត្រីម្នាក់ឈ្មោះ សុង ផារ៉ាត់ នៅទីតាំងវត្តនេះ ហើយគាត់បានប្រាប់យើងថា នៅសម័យខ្មែរក្រហម គាត់បាននៅកំដរម្តាយមីងគាត់ឈ្មោះ ប៊ិន គឹមយ៉ា ដែលឈឺ ហើយគាត់បានស្នាក់នៅមន្ទីរពេទ្យដែលមានទីតាំងនៅក្នុងបរិវេណវត្តនេះឯង។ ដោយសារមូលហេតុនេះ ទើបស្ត្រីម្នាក់នេះអាចពន្យល់ប្រាប់ក្រុមការងារថា វត្តនេះត្រូវបានគេប្រើជាមន្ទីរពេទ្យ មិនមែនជាគុកទេ ហើយគេប្រើតែផ្ទះមួយខ្នងនៅជិតច្រកចូល និងព្រះវិហារប៉ុណ្ណោះ។ មនុស្សនៅទីតាំងនេះមិនត្រូវបានគេសម្លាប់ទេ ប៉ុន្តែបានស្លាប់ដោយសារជំងឺ ហើយគេយកទៅកប់នៅទីធ្លាជុំវិញព្រះវិហារ"]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.20 KH 00915842 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប៖ "ស៖ តើវត្តព្រះនេត្រព្រះ ត្រូវបានគេប្រើប្រាស់ធ្វើអ្វីនៅក្នុងសម័យខ្មែរក្រហម? ឆ.20៖

វត្តព្រះនេត្រព្រះ នៅពេលនោះ គេយកធ្វើជាមន្ទីរពេទ្យ ពីព្រោះគេយកអ្នកជំងឺទៅព្យាបាលនៅទីនោះ។ ខ្ញុំមិនបានដឹងថា យាយ ចែម បានទៅពិនិត្យមើលមន្ទីរពេទ្យព្រះនេត្រព្រះនោះទេនៅពេលនោះ ប៉ុន្តែខ្ញុំគិតថា គាត់បានដឹងអំពីមន្ទីរពេទ្យនោះហើយ ពីព្រោះគាត់បានមកដឹកនាំប្រជុំធំៗជាច្រើនដង នៅមុខវត្តព្រះនេត្រព្រះ (មន្ទីរពេទ្យ)"]។ ឆ.22 KH 00915842 ["សៈ លោកស្រីដឹងទេថា នៅមន្ទីរពេទ្យនោះ តើមានមនុស្សស្លាប់ដោយសារជំងឺ និងស្លាប់ដោយសារគេយកទៅសម្លាប់ដែរទេ? ឆៈ មិនមានមនុស្សគេសម្លាប់នៅទីនោះទេ ប៉ុន្តែភាគច្រើនស្លាប់ដោយអត់អាហារ ជំងឺ (ជំងឺហើម និងជំងឺគ្រុនញាក់) និងខ្វះថ្នាំព្យាបាល។ តាមខ្ញុំចាំ គឺមានមនុស្សបានស្លាប់ជាច្រើនរៀងរាល់ថ្ងៃ"]។ ឯកសារ D123/1/2.51 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នូ ដួង និង កោ វ៉ាន់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00733909 [នូ ដួង គឺជាកម្មករកងចល័តនៅព្រះនេត្រព្រះ។ ប្រពន្ធរបស់គាត់ឈ្មោះ កោ វ៉ាន់ ធ្វើការនៅមន្ទីរពេទ្យព្រះនេត្រព្រះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានចងចាំថាៈ "យើងមានតែដបទឹកក្រូចប៉ុណ្ណោះមក គេថាបេខូ បេអង។"។ ឈុនលី ៖ បេដីបេអង? វ៉ាន់ ៖ គេថាបេខូបេអង ទឹកក្រហម ទឹកស ចាក់ឲ្យអ្នកជំងឺ។ ឈុនលីៈ ឈឺអីបានចាក់អាហ្នឹង? វ៉ាន់ៈ តំរៀបជួរគ្នាចាក់។ […] ចេះតែធ្វើ បើគេដាក់ទិសហើយ ធ្វើតាមគេទៅ។ […] ចាក់ទឹកដូងឲ្យគេ។ […] យូរៗទៅក៏បានថ្នាំល្អមកម្តង"]។ ឯកសារ D119/24 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00897497 [លោក ហុង ហ៊ុយ ដែលជាអតីតមេឃុំព្រះនេត្រព្រះ បានប្រាប់អ្នកស៊ើបអង្កេតថាៈ "គ្មានថ្នាំពេទ្យនៅទីនោះទេ [នៅមន្ទីរពេទ្យព្រះនេត្រព្រះ] ហើយទឹកដូងត្រូវបានគេប្រើប្រាស់ធ្វើជាសេរ៉ូម ដើម្បីព្យាបាលជំងឺគ្រប់មុខ រួមទាំងថ្នាំអាចម៍ទន្សាយផងដែរ"]។

1285 ឯកសារ D119/24 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00897497 [លោក ហុង ហ៊ុយ ដែលជាអតីតមេឃុំព្រះនេត្រព្រះ បានប្រាប់អ្នកស៊ើបអង្កេតថាៈ "គ្មានថ្នាំពេទ្យនៅទីនោះទេ [នៅមន្ទីរពេទ្យព្រះនេត្រព្រះ] ហើយទឹកដូងត្រូវបានគេប្រើប្រាស់ធ្វើជាសេរ៉ូម ដើម្បីព្យាបាលជំងឺគ្រប់មុខ រួមទាំងថ្នាំអាចម៍ទន្សាយផងដែរ"]។ ឯកសារ D123/1/2.51 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នូ ដួង និង កោ វ៉ាន់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00733909 [នូ ដួង គឺជាកម្មករកងចល័តនៅព្រះនេត្រព្រះ។ ប្រពន្ធរបស់គាត់ឈ្មោះ កោ វ៉ាន់ ធ្វើការនៅមន្ទីរពេទ្យព្រះនេត្រព្រះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានចងចាំថាៈ "យើងមានតែដបទឹកក្រូចប៉ុណ្ណោះមក គេថាបេខូ បេអង។"។ ឈុនលីៈ បេដីបេអង? វ៉ាន់ៈ គេថាបេខូបេអង ទឹកក្រហម ទឹកស ចាក់ឲ្យអ្នកជំងឺ។ ឈុនលីៈ ឈឺអីបានចាក់អាហ្នឹង? វ៉ាន់ៈ តំរៀបជួរគ្នាចាក់។ […] ចេះតែធ្វើ បើគេដាក់ទិសហើយ ធ្វើតាមគេទៅ។ […] ចាក់ទឹកដូងឲ្យគេ។ […] យូរៗទៅក៏បានថ្នាំល្អមកម្តង"] KH 00733906 ["គេឲ្យទៅបុកថ្នាំរែងថ្នាំអាចម៍ទន្សាយចឹងឯង"]។

1286 ឯកសារ D106/11 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787416-00787417 ["យើងបានជួបស្ត្រីម្នាក់ឈ្មោះ សុង ផាវ៉ាត់ នៅទីតាំងវត្តនេះ ហើយគាត់បានប្រាប់យើងថា នៅសម័យខ្មែរក្រហម គាត់បាននៅកំដរម្តាយមីងគាត់ឈ្មោះ ប៊ិន គីមយ៉ា ដែលឈឺ ហើយគាត់បានស្នាក់នៅមន្ទីរពេទ្យដែលមានទីតាំងនៅក្នុងបរិវេណវត្តនេះឯង។ ដោយសារមូលហេតុនេះ ទើបស្ត្រីម្នាក់នេះអាចពន្យល់ប្រាប់ក្រុមការងារថា វត្តនេះត្រូវបានគេប្រើជាមន្ទីរពេទ្យ មិនមែនជាគុកទេ ហើយគេប្រើតែផ្ទះមួយខ្នងនៅជិតច្រកចូល និងព្រះវិហារប៉ុណ្ណោះ។ មនុស្សនៅទីតាំងនេះមិនត្រូវបានគេសម្លាប់ទេ ប៉ុន្តែបានស្លាប់ដោយសារជំងឺ ហើយគេយកទៅកប់នៅទីធ្លាជុំវិញព្រះវិហារ"]។ ឯកសារ D119/24 របាយ

ការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00897497 [លោក ហុង ហ៊ុយ ដែលជាអតីតមេឃុំព្រះនេត្រព្រះ បានប្រាប់អ្នកស៊ើបអង្កេតថា៖ "ការផ្លាស់ប្តូរជំនួសកម្មាភិបាលខ្មែរក្រហមនៅភូមិភាគពាយ័ព្យបានកើតឡើងនៅអំឡុងចុងឆ្នាំ ១៩៧៦ ឬនៅក្នុងឆ្នាំ ១៩៧៧ ហើយ [...] ព្រះនេត្រព្រះនៅពេលនោះត្រូវបានប្រើប្រាស់ជាមន្ទីរពេទ្យ។ ប្រជាជនជាច្រើននាក់បានស្លាប់នៅមន្ទីរពេទ្យនោះ [...] ហើយអ្នកដែលបានស្លាប់ត្រូវបានគេកប់នៅក្នុងបរិវេណវត្តនោះ។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.23 KH 00915842 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប៖ "អ្នកដែលសម្លាប់នៅក្នុងមន្ទីរពេទ្យវត្តព្រះនេត្រព្រះ អ្នកខ្លះគេយកទៅកប់ និងអ្នកខ្លះយកទៅដុត។ ដល់ពេលសម្លាប់ច្រើនពេក បុគ្គលិកពេទ្យយកខ្មោចទៅកប់ក្នុងបរិវេណពេទ្យ"]។ ឯកសារ D123/1/2.51 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នូ ដួង និង កោ វ៉ាន់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00733906 [នូ ដួង គឺជាកម្មករកងចល័តនៅព្រះនេត្រព្រះ។ ប្រពន្ធរបស់គាត់ឈ្មោះ កោ វ៉ាន់ ធ្វើការនៅមន្ទីរពេទ្យព្រះនេត្រព្រះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានចងចាំថា ៖ "សែងតែខ្មោចគ្មានធ្វើការអីទេ សែងម្តងបី ក្តាប៉ុណ្ណេះមួយ ដាក់កង់ទៅអូស។ ទៅដល់ជីកអន្លង់ប៉ុណ្ណេះទៅឱ្យតែជ្រៅទៅ យុវជនយើងអីក៏ចាប់បោះទៅ"]។ ឯកសារ D119/38 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.8 KH 00915848 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ "ប្រជាជន ឬអ្នកភូមិបាននិយាយថា អ្នកជំងឺដែលបានស្លាប់នៅមន្ទីរពេទ្យព្រះនេត្រព្រះ ត្រូវបានគេយកទៅកប់នៅទីនោះ [នៅចម្ការដូង និងចម្ការយាយនឹង]"]។

1287 ឯកសារ **D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ3.2 KH 00978922-00978923 [សាក្សីគឺជាសមាជិកកងចល័តនៅក្នុងសហករណ៍៥ នៅក្នុងឃុំព្រះនេត្រព្រះ៖ "ការស្រាវជ្រាវប្រវត្តិរូប ត្រូវបានធ្វើឡើងនៅតាមភូមិ និងសហករណ៍ បន្ទាប់មកត្រូវបានបញ្ជូនទៅថ្នាក់លើ គឺទៅយាយ ថែម"]។

1288 ឯកសារ D119/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.42 KH 00907517 [សាក្សីគឺជាគណៈឃុំព្រះនេត្រព្រះ៖ "ការពិនិត្យកើតឡើងគ្រប់ដំណាក់កាលឱ្យបានត្រឹមត្រូវជាមុនសិន នឹងរាយការណ៍ទៅថ្នាក់លើបន្ត"]។

1289 ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.32 KH 00978922-00978923 [សាក្សីគឺជាសមាជិកកងចល័តនៅក្នុងសហករណ៍៥ នៅក្នុងឃុំព្រះនេត្រព្រះ៖ "យាយថែម ត្រូវតែដឹងអំពីព្រឹត្តិការណ៍នេះ [ការសម្លាប់ស្ត្រីជនជាតិវៀតណាមនៅការដ្ឋានវាលដង្កៀបក្តាម] ពីព្រោះព្រឹត្តិការណ៍នេះ ត្រូវបានធ្វើឡើងក្រោមបង្គាប់របស់គាត់។ ការស្រាវជ្រាវប្រវត្តិរូបត្រូវបានធ្វើឡើងនៅតាមភូមិ និងសហករណ៍ បន្ទាប់មកត្រូវបានបញ្ជូនទៅថ្នាក់លើ គឺទៅយាយ ថែម ហើយទើបមានបញ្ជាពីយាយ ថែម មកវិញ ចំពោះអ្នកដែលមានប្រវត្តិរូបពាក់ព័ន្ធ"]។ ឯកសារ D119/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.41 KH 00907517 [សាក្សីគឺជាគណៈឃុំព្រះនេត្រព្រះ៖ "តាមធម្មតា ការរាយការណ៍ គឺចេញពីប្រជាជនទៅប្រធានក្រុម ទៅប្រធានភូមិ ទៅប្រធានឃុំ និងឡើងទៅស្រុក"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត វិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.9 KH 00915872 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "សៈ លោកដឹងទេថា តើ

នរណាជាប្រធាននារីមកពីនិរតី? ឆ.9៖ ខ្ញុំមិនច្បាស់ដែរ ប៉ុន្តែពួកគេហាក់បីដូចជាមានអំណាចក្នុងការចាប់មនុស្សទាំងអស់នោះ"]។

1290 ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6-7 KH 00907517 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំបានឃើញគេបណ្តើរមនុស្សទាំងខ្សែៗ ដែលគេចាប់ខ្លួនមកពីភូមិផ្សេងៗ ហើយបានបញ្ជូនទៅសម្លាប់នៅក្រោយផ្ទះតាក្រក ក្នុងភូមិប៉ោយក្តឿង។ [...] វាមិនទៀងទាត់ទេ ជួនកាលគេបណ្តើរមនុស្សនៅពេលយប់ ជួនកាលនៅពេលថ្ងៃ វាអាស្រ័យទៅលើស្ថានភាពដែលគេបានចាប់មនុស្សទាំងអស់នោះ"]។ ឯកសារ D119/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ឈួក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.23 KH 00933132 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅស្រុកព្រះនេត្រព្រះ ៖ "ខ្ញុំបានឃើញពួកយោធាបណ្តើរអ្នកទោសទាំងខ្សែៗទាំងថ្ងៃ តាមផ្លូវធំនៅមុខវត្តព្រះនេត្រព្រះ"]។ ឯកសារ D106/11 របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787417 ["លោក សុះ ណារិន អនុប្រធានភូមិប៉ោយក្តឿង បានប្រាប់យើងថា ប្រជាជន [...] ត្រូវបានចាប់ខ្លួននៅពេលថ្ងៃ យកទៅផ្ទះតាក្រក ហើយយកទៅកន្លែងសម្លាប់នៅពេលយប់"]។ ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228-00788229 ["មេភូមិប៉ោយសំរោងឈ្មោះ លោក គង់ លិប បានប្រាប់ក្រុមអ្នកស៊ើបអង្កេតថា [...] អ្នកទោសត្រូវបាននាំយកទៅផ្ទះ [របស់តាក្រក] នៅពេលថ្ងៃ ហើយត្រូវបានសម្លាប់នៅពេលយប់នៅក្នុងទីកន្លែងចំនួនពីរនៅក្បែរគ្នា"]។

1291 ឯកសារ D119/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.30 KH 00907517 [សាក្សីគឺជាគណៈឃុំព្រះនេត្រព្រះ៖ "ខ្ញុំប្រាកដណាស់ [ថាផ្ទះរបស់តាក្រក ត្រូវបានប្រើធ្វើជាមន្ទីរឃុំឃាំង បន្ទាប់ពីគេដកគាត់ចេញ] ពីព្រោះពេលនោះ ប្រពន្ធ និងកូនរបស់តាក្រក ក៏គេដកចេញពីផ្ទះនោះដែរ ហើយអ្នកមានកំហុសតាមភូមិ ត្រូវបានគេចាប់មកដាក់នៅផ្ទះនោះ ក្រោមការគ្រប់គ្រងរបស់នារី ថា និងតាណុញ"]។ ឯកសារ D219/347 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.23 KH 01103344 [សាក្សីគឺជាសមាជិកគណៈឃុំព្រះនេត្រព្រះ៖ "ទាល់តែមេឃុំនិរតីមកដល់ ទើបផ្ទះគាត់ [តាក្រក] ត្រូវបានគេយកធ្វើជាមន្ទីរឃុំឃាំង"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.9 KH 00978919 [សាក្សីគឺជាសមាជិកកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំធ្លាប់បានឮគេថា មានយកមនុស្សទៅឃុំនៅទីនោះមែន [នៅផ្ទះរបស់តាក្រក] ប៉ុន្តែខ្ញុំមិនដឹងថាគេយកមនុស្សនោះទៅសម្លាប់ទីណាទេ"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.10-11 KH 00915872-00915873 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "ពេលដែលតាក្រកបាត់ខ្លួន ពួកនិរតីបានមកនៅផ្ទះតាក្រក ហើយកន្លែងនោះ ក៏នៅតែជាកន្លែងសម្រាប់ទុកមនុស្សដដែល។ [...] តាក្រក ត្រូវបានចាប់ខ្លួនកន្លះឆ្នាំ ក្រោយពេលពួកនិរតីមកដល់"]។ ឯកសារ D119/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945877 ["ផ្ទះតាក្រក ត្រូវបានប្រើជាមន្ទីរឃុំឃាំង ក្រោយពេលតាក្រក បានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៨"]។ ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH

00788227 [“សាក្សីម្នាក់បាននិយាយថា “គណៈឃុំរបស់ ប៉ុល ពត” បានប្រើប្រាស់ផ្ទះនៅជិតវត្តព្រះនេត្រព្រះជាកន្លែងឃុំឃាំងអ្នកទោស”]។

1292 ឯកសារ **D5/1547** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឈិត រ័ត្ន ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៣ KH 01093384-01093385 [សាក្សីធ្វើការនៅកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ៖ “ឆ្នាំ ១៩៧៨ […] ការដ្ឋានរបស់នាងខ្ញុំនៅមិនឆ្ងាយប៉ុន្មានម៉ែត្រទេពីមន្ទីរឃុំឃាំងវត្តព្រះនេត្រព្រះ។ ពេលល្ងាច ឬពេលព្រលប់ ខ្ញុំឃើញពួកយោធាបណ្ដើរមនុស្សទាំងកងៗយកមកធ្វើទារុណកម្ម នៅពេលសួរចម្លើយ ហើយគឺវាយសម្លាប់ចោលក្នុងរណ្ដៅស្រះទឹកតែម្ដង។ […] ពេលថ្ងៃ ពេលព្រឹក ពេលយប់ លឺតែស្នូរសំឡេងស្រែកអូយៗនោះតែម្ដង”]។

1293 ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.18 KH 01066319 [សាក្សីគឺជាមេក្រុមនៅក្នុងឃុំព្រះនេត្រព្រះ៖ “ប្រជាជន […] ត្រូវបានគេយកទៅសម្លាប់ […] ១០០ ម៉ែត្រខាងក្រោយផ្ទះតាក្រក”]។ ឆ.21 KH 01066319 [“ប្រជាជនរស់នៅជិតៗនោះដឹងតៗគ្នាថា មុនគេយកមនុស្សទៅសម្លាប់ ពួកនិរតីយកមនុស្សទៅឃុំខ្លួននៅទីនោះសិន”]។ ឆ.22 KH 01066319 [“មនុស្សដែលមានផ្ទះនៅក្បែរតាក្រក ចម្ងាយប្រហែល ៥០ម៉ែត្រ ធ្លាប់បានឃើញគេបណ្ដើរមនុស្សដើរកាត់តាមខ្លោងទ្វារវត្តទៅទីកន្លែងនោះ ហើយក៏ឮស្នូរសំឡេងមនុស្សទាំងនោះដែលគេយកទៅសម្លាប់ផងដែរ”]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6-7 KH 00907517 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ “ខ្ញុំបានឃើញគេបណ្ដើរមនុស្សទាំងខ្សែៗ ដែលគេចាប់ខ្លួនមកពីភូមិផ្សេងៗ ហើយបានបញ្ជូនទៅសម្លាប់នៅក្រោយផ្ទះតាក្រក ក្នុងភូមិប៉ោយក្តឿង។ […] អ្នកដែលបាត់ខ្លួន និងចាប់ខ្លួន ខ្ញុំមិនដែលឃើញពួកគេត្រឡប់មកវិញទេ”]។ ឯកសារ D119/38 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6 KH 00915848 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ សៈ […] លោកបានពន្យល់ថា គេធ្លាប់ប្រើផ្ទះតាក្រក ធ្វើជាកន្លែងឃុំឃាំងមនុស្ស ហើយអាចមានមនុស្សប្រហែលជា២០០នាក់ ត្រូវបានសម្លាប់នៅទីនោះ។ តើលោកអាចបញ្ជាក់បន្ថែមដល់យើងបានទេ? ឆៈ “ខ្ញុំមើលឃើញពីចម្ងាយ និងឮអ្នកជិតខាងគេនិយាយថា គេដឹកមនុស្សពី៥ទៅ១០នាក់ជួនកាលតាមរទេះសេះ និងជួនកាលតាមឡាន យកទៅសម្លាប់នៅជិតស្រះទឹកមួយ នៅខាងលិចទីធ្លា (បច្ចុប្បន្នជាផ្សារជប់វ៉ារី)”]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.4 KH 00915839 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប៖ “មានមនុស្សមួយចំនួនក្នុងចំណោមដែលគេយកទៅសម្លាប់ហ្នឹង បានរត់គេចខ្លួន ប៉ុន្តែប្រពន្ធ និងកូនរបស់ពួកគេ ត្រូវបានគេប្រមូលយកទៅសម្លាប់នៅក្បែរជើងភ្នំព្រះនេត្រព្រះ ដែលមានទីតាំងនៅខាងក្រោយផ្ទះ តាក្រក ដែលនៅទីនោះ មានរណ្ដៅសាកសពដ៏ធំមួយ”]។ ឯកសារ D106/11 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787417 [“លោក សុះ ណារិន អនុប្រធានភូមិប៉ោយក្តឿង បានប្រាប់យើងថា ប្រជាជន […] ត្រូវបានចាប់ខ្លួននៅពេលថ្ងៃ យកទៅផ្ទះ តាក្រក ហើយយកទៅកន្លែងសម្លាប់នៅពេលយប់”]។ ឯកសារ D119/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945879 [“ថ្មីៗនេះ ក្នុងអំឡុងពេលសម្ភាសន៍ជាមួយសាក្សី ឈឹម ផន […] គាត់ប្រាប់យើងថា ផ្ទះតាក្រក ត្រូវបានប្រើជាគុកបណ្ដោះអាសន្នសម្រាប់ឃុំឃាំងមនុស្សដែលត្រូវបានចាប់ខ្លួនក្នុងឃុំ

និងស្រុកព្រះនេត្រព្រះតែប៉ុណ្ណោះ ក្រោយពេលតាក្រកត្រូវបានកម្មាភិបាលខ្មែរក្រហមមកពីនិរតីចាប់ខ្លួន និងបានបាត់ខ្លួនតាំងពីពេលនោះមក។ អ្នកដែលត្រូវបានចាប់ខ្លួន ត្រូវបានសម្លាប់នៅពេលយប់នៅ [កន្លែងសម្លាប់មនុស្សចម្ការដូង និងចម្ការយាយណឹង]"]។ សូមមើលផងដែរ ឯកសារ D119/46.2 ឧបសម្ព័ន ២ នៃរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ EN 00920242, EN 0092024243 [រូបថត 3-4]។

1294 ឯកសារ D119/38 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.3 KH 00915847 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំដឹងថា វត្តព្រះនេត្រព្រះគឺគេធ្វើជាមន្ទីរពេទ្យ។ នៅទីនោះ ខ្ញុំបានឃើញអ្នកដែលលួចច្រូតស្រូវ និងអ្នកដែលឡើងលួចយកទឹកត្នោតផឹក ត្រូវបានចាប់យកទៅសម្លាប់ចោលនៅក្នុងបរិវេណវត្តព្រះនេត្រព្រះ"]។ ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788227 ["សាក្សីម្នាក់បាននិយាយថា [...] បានប្រើប្រាស់ផ្ទះនៅជិតវត្តព្រះនេត្រព្រះជាកន្លែងឃុំឃាំងអ្នកទោសមុនពេលយកទៅសម្លាប់នៅក្នុងចម្ការតាលឹង"]។ ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទីឆ្នាំ ១៩៩៧ KH 007506780-0750679 [អ្នកស៊ើបអង្កេតបញ្ជាក់ថា ទុំ សឿន ដែលបានរស់នៅក្នុងឃុំព្រះនេត្រព្រះចាប់តាំងពីរបបប៉ុល ពត មកដល់បច្ចុប្បន្ន៖ "បានឃើញប្រជាជនត្រូវគេសម្លាប់ចោលនៅតាមបណ្តាកន្លែងជាច្រើន ប៉ុន្តែនៅត្រង់ទីតាំងសម្រាប់ពិឃាតមនុស្សនៃកន្លែងដែលកើតមានឧក្រិដ្ឋកម្មស្ថិតក្នុងវត្តព្រះនេត្រព្រះនេះ គាត់បានចូលរួមនៅក្នុងការជីកគាស់កកាយរណ្តៅសាកសពនានា ដែលមានមុខកាត់ទំហំ៤ម៉ែត្រការេ និងជម្រៅ២ម៉ែត្រ។ រណ្តៅសាកសពនីមួយៗ មានផ្ទុកសាកសពចំនួនពី១០០ ទៅ១២០ សាកសព។ យោងតាមសម្តីរបស់សាក្សីរូបនេះ ចំនួនមនុស្សដែលត្រូវបានសម្លាប់សរុបមានចំនួនប្រហែល ៦៦០ ទៅ ៧២០ នាក់។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ឯកសារនានាបានចង្អុលបង្ហាញថាមានសាកសពចំនួន៤០៧ប៉ុណ្ណោះ ហើយទីតាំងសម្រាប់ពិឃាតមនុស្សនៅចម្ការតាលឹងនោះ ស្ថិតនៅប្រមាណ៥០ម៉ែត្រពីក្រោយវត្តព្រះនេត្រព្រះ។ នៅចម្ការតាលឹង ផ្ទះប្រក់ក្បឿងមួយខ្នងរបស់គណៈឃុំនៃរបប ប៉ុល ពត [ផ្ទះរបស់តាក្រក] ត្រូវបានប្រើប្រាស់ដើម្បីឃុំអ្នកទោស។ នៅពេលដែលអ្នកជាប់ឃុំឃាំងចាស់ៗត្រូវគេសម្លាប់ចោលអស់ អ្នកជាប់ឃុំថ្មីៗ ត្រូវគេបញ្ជូនមកឃុំខ្លួននៅផ្ទះនោះ។ ផ្អែកតាមការមើលឃើញដោយផ្ទាល់នូវឆ្អឹងក្បាលខ្មោចរបស់ជនរងគ្រោះ [...] ភាគច្រើនជនរងគ្រោះគឺជាមនុស្សពេញវ័យ មានអាយុក្រោម៤៥ឆ្នាំ។ ពួកគេគឺជាមន្រ្តីរាជការ ដែលត្រូវគេជម្លៀសមកពីទីក្រុង ហើយជនរងគ្រោះទាំងអស់គឺជាបុរស"]។ សូមមើលផងដែរ ឯកសារ D219/204.1 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះសិក្សាស្រាវជ្រាវពីទីតាំងសម្លាប់ មន្ទីរសន្តិសុខ និងបូជនីយដ្ឋានដែលបន្សល់ទុកក្រោយរបបខ្មែរក្រហមនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៧ KH 01074009 [អ្នកស៊ើបអង្កេតបញ្ជាក់ថា សាក្សី ទុំ សឿន ដែលបានស្នាក់នៅឃុំព្រះនេត្រព្រះតាំងពីរបបប៉ុល ពត រហូតមកដល់បច្ចុប្បន្ន៖ "បានដឹង និងឃើញគេសម្លាប់ផ្ទាល់កន្លែងផ្សេង ឯកន្លែងនោះ [ចម្ការតាលឹង] គ្រាន់តែដឹងថា ពេលគាត់មកជីករកមាស គាត់ដឹងថា មួយរណ្តៅឃើញពី ១០០-១២០ នាក់ មានរណ្តៅ៦ធំៗ [...] ដូច្នេះអាចមាន៦៦០នាក់ទៅ៧២០នាក់ ដែលត្រូវបានសម្លាប់នៅទីនោះ [...] ចម្ការតាលឹង នៅខាងក្រោយសន្តិសុខគុក ៥០ម៉ែត្រទេ។ នៅទីនោះ គណៈឃុំ ប៉ុល ពត នៅមានផ្ទះក្បឿងមួយខ្នង [ផ្ទះរបស់តាក្រក] សម្រាប់ដាក់អ្នកទោស វាយសម្លាប់អស់ដាក់បន្ថែមថ្មី យកមកក្រោយៗទៀត។ [...] ជនរងគ្រោះភាគច្រើនជាមនុស្សចាស់ អាយុ៤៥ចុះ ហើយជាមន្ត្រីរដ្ឋ

ការ ស៊ីវិល ជម្លៀសពីទីក្រុង"]។ ឯកសារ D219/205 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ.24-25 KH 01072292-01072293 [សាក្សីបានប្រមូលភស្តុតាងសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំរបាយការណ៍ ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ៖ "សៈ នៅក្នុង ឯកសារ D1.3.10.10 បាននិយាយថា នៅចម្ការតាលឹង មានរណ្តៅសាកសពចំនួន៦។ តើលោកមានទៅឃើញរណ្តៅទាំងហ្នឹងដែរឬទេ? ឆ.24៖ ខ្ញុំភ្លេចហើយ តែនៅក្នុងរបាយការណ៍ ខ្ញុំមានសរសេរ តែបើតាមជាក់ស្តែង គឺសាក្សីចង្អុលបង្ហាញប្រាប់ទីកន្លែងតែប៉ុណ្ណោះ។ សៈ នៅក្នុងរបាយការណ៍ ចំនួនជនរងគ្រោះមាន៧២០នាក់។ តើចំនួនហ្នឹងផ្អែកទៅលើអ្វី? ឆ.25៖ គឺផ្អែកទៅលើសាក្សីឈ្មោះ ទុំ សឿន នៅចម្ការតាលឹង ព្រោះសាក្សីនេះគាត់ជាអ្នកទៅជីកគាស់រកមាស"]។ ឆ.29-30 KH 01072293 ["សៈ នៅក្នុងរបាយការណ៍ [ឯកសារ D1.3.10.10] គេនិយាយថា [ចម្ការតាលឹង] ជាកន្លែងសម្លាប់? តើលោកដឹងតាមរបៀបណាថាកន្លែងហ្នឹងជាកន្លែងសម្លាប់? ឆ.29៖ ខ្ញុំដឹងតាមរយៈសាក្សីឈ្មោះ ទុំ សឿន ពេលគាត់ជីករកមាស គាត់ឃើញចំនួនរណ្តៅ និងចំនួនសាកសពទាំងនោះ ដែលមានចំនួន១១០ ទៅ ១២០នាក់ក្នុងមួយរណ្តៅ។ សៈ ម៉េចបាន ទុំ សឿន ដឹងថាអ្នកដែលកប់នៅក្នុងរណ្តៅនោះ ត្រូវគេសម្លាប់? ឆ.30៖ គាត់ដឹងដោយសារនៅកន្លែងនោះ មានផ្ទះក្បឿងជាកន្លែងឃុំឃាំង ដែលយកធ្វើជាគណៈឃុំ ប៉ុល ពតមួយសម្រាប់ដាក់អ្នកទោសដែលគេមក ហើយយកទៅសម្លាប់នៅក្បែរនោះ"]។ ឆ.32-34 KH 01072293-01072294 ["សៈ តើគេយកអ្នកទោសមកពីណាមក? ឆ.32៖ ចម្ការតាលឹងនៅចម្ងាយ៥០ម៉ែត្រពីក្រោយវត្ត ហើយនៅទីនោះមានគណៈឃុំដែលជាផ្ទះក្បឿងជាគណៈឃុំ ប៉ុល ពត ហើយពេលគេសម្លាប់អស់ គេយកអ្នកទោសមកសម្លាប់បន្តទៀត។ សៈ ផ្ទះក្បឿងដែលគណៈឃុំនៅ តើផ្ទះនោះនៅដល់សព្វថ្ងៃដែរឬទេ? ឆ.33៖ ពេលដែលខ្ញុំទៅដល់ពេលនោះ ផ្ទះនោះនៅៗឡើយ តែបច្ចុប្បន្ន ខ្ញុំមិនដឹងទេ។ សៈ ពីកន្លែងផ្ទះគណៈឃុំ ទៅចម្ការតាលឹង មានចម្ងាយប៉ុន្មានម៉ែត្រ? ឆ.34៖ ចម្ការតាលឹងនៅខាងក្រោយផ្ទះក្បឿងចម្ងាយ៥០ម៉ែត្រ"]។

1295 ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផាវ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.12 KH 00915840-00915841 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប៖ "ខ្ញុំបានដឹងអំពីចម្ការដូង ពីព្រោះនៅក្នុងសម័យខ្មែរក្រហម គឺមានមនុស្សជាច្រើនដែលស្លាប់ដោយសារជំងឺ ត្រូវបានគេយកទៅកប់នៅទីនោះ ហើយបើតាមខ្ញុំស្មាន គឺប្រហែលជាមានមនុស្សមួយចំនួន ដែលត្រូវបានឃុំឃាំងនៅទីនោះ ក៏បានគេយកទៅសម្លាប់នៅទីនោះ នៅពេលយប់"]។ ឯកសារ D119/38 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.8 KH 00915848 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ "សៈ [...] លោកបានរៀបរាប់អំពីទីតាំងសម្លាប់មនុស្សពីរកន្លែង គឺចម្ការដូង និងចម្ការយាយនឹង។ តើលោកអាចបញ្ជាក់បន្ថែមដល់យើងបានទេអំពីទីតាំងទាំងពីរនេះ? ឆ.8៖ ប្រជាជន ឬអ្នកភូមិបាននិយាយថា អ្នកជំងឺដែលបានស្លាប់នៅមន្ទីរពេទ្យព្រះនេត្រព្រះ ត្រូវបានគេយកទៅកប់នៅទីនោះ។ ខ្ញុំបានទៅទីតាំងទាំងនោះផ្ទាល់ ហើយបានឃើញផ្នូរខ្មោចជាច្រើនដូចអ្វីដែលគេបាននិយាយមែន"]។ ឯកសារ D106/11 របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787417 ["មនុស្សទាំងអស់បានបញ្ជាក់ថា មុន និងក្រោយពេលដែលយាយ ចែម លេខាស្រុកបានមកដល់ ទីតាំងសម្លាប់មនុស្សគឺនៅចម្ការដូង និងចំការយាយនឹង នៅភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ។

[...] គេប្រាប់យើងថា ប្រជាជនដែលត្រូវបានសម្លាប់នៅទីតាំងទាំងនេះ គឺជាប្រជាជនថ្មី ឬកម្មាភិបាលភូមិភាគពាយ័ព្យ ហើយពួកគេត្រូវបានចាប់ខ្លួននៅពេលថ្ងៃយកទៅផ្ទះ តាក្រុក ហើយយកទៅកន្លែងសម្លាប់នៅពេលយប់"]។ ឯកសារ D106/12 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228-00788229 ["អ្នកទោសត្រូវបាននាំយកទៅផ្ទះនោះ [ផ្ទះរបស់តាក្រុកដែលមានចម្ងាយ៨០០ម៉ែត្រ ខាងជើងវត្ត] នៅពេលថ្ងៃ ហើយត្រូវបានសម្លាប់នៅពេលយប់នៅក្នុងទីកន្លែងពីរនៅក្បែរគ្នា និងមានចម្ងាយត្រង់មិនលើសពី១០០០ម៉ែត្រ ខាងជើងភាគលិចពីផ្ទះតាក្រុក។ [...] ទីតាំងទាំងពីរនោះមានឈ្មោះ ចម្ការដូង និងចម្ការយាយណឹង ស្ថិតនៅក្នុងភូមិប៉ោយគ្បឿង"]។ ឯកសារ D119/46 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945877 ["ផ្ទះតាក្រុក ត្រូវបានប្រើជាមន្ទីរឃុំឃាំង ក្រោយពេលតាក្រុកបានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៨ និងមានកន្លែងសម្លាប់មនុស្សនៅក្បែរនោះ ស្ថិតនៅចម្ការដូង និងចម្ការយាយណឹង"] KH 00945879 [លោក ឈឹម ផន អតីតអនុគណៈឃុំព្រះនេត្រព្រះក្នុងអំឡុងរបបខ្មែរក្រហម បានប្រាប់អ្នកស៊ើបអង្កេតថា "ផ្ទះតាក្រុកត្រូវបានប្រើជាគុកបណ្ដោះអាសន្ន សម្រាប់ឃុំឃាំងមនុស្សដែលត្រូវបានចាប់ខ្លួនក្នុងឃុំ និងស្រុកព្រះនេត្រព្រះតែប៉ុណ្ណោះ ក្រោយពេលតាក្រុកត្រូវបានកម្មាភិបាលខ្មែរក្រហមមកពីនិរតីចាប់ខ្លួន និងបានបាត់ខ្លួនតាំងពីពេលនោះមក" ។ គាត់ក៏បាននិយាយផងដែរថា អ្នកដែលត្រូវបានឃុំខ្លួននៅក្នុងផ្ទះតាក្រុក "ត្រូវបានសម្លាប់នៅពេលយប់នៅ [កន្លែងសម្លាប់មនុស្សចម្ការដូង និងចម្ការយាយណឹង]"។

1296 ឯកសារ D119/42 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6 KH 00907517 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំបានឃើញគេបណ្ដើរមនុស្សទាំងខ្សែៗ ដែលគេចាប់ខ្លួនមកពីភូមិផ្សេងៗ ហើយបានបញ្ជូនទៅសម្លាប់នៅក្រោយផ្ទះតាក្រុក ក្នុងភូមិប៉ោយគ្បឿង"] ។ ឆ.7 KH 00907517 ["ពេលខ្លះ កម្មាភិបាលនារីមកពីនិរតីបានកាន់កាំភ្លើងកាប៊ិន និងបង់កក្រម៉ាឆ្នូតពណ៌ខ្មៅ និងស បានបណ្ដើរមនុស្សទាំងនោះយកទៅសម្លាប់ ប៉ុន្តែខ្ញុំមិនបានឃើញគេសម្លាប់មនុស្សទាំងនោះទេ។ អ្នកដែលបាត់ខ្លួន និងចាប់ខ្លួន ខ្ញុំមិនដែលឃើញពួកគេត្រឡប់មកវិញទេ"]។ ឯកសារ D119/52 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុំ ឈុក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឆ. 23 KH 00933132 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅស្រុកព្រះនេត្រព្រះ ៖ "នៅពេលធ្វើការនៅតាមភូមិ ខ្ញុំបានឃើញពួកយោធាបណ្ដើរអ្នកទោសទាំងខ្សែៗទាំងថ្ងៃ តាមផ្លូវធំនៅមុខវត្តព្រះនេត្រព្រះ"]។

1297 ឯកសារ D119/38 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6 KH 00915848 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ "ស៖ ក្រោយពីបានអានឯកសារដែលមានលេខ ERN 00780978-00780979 លោកបានពន្យល់ថា គេធ្លាប់ប្រើផ្ទះ តាក្រុក ធ្វើជាកន្លែងឃុំឃាំងមនុស្ស ហើយអាចមានមនុស្សប្រហែលជា២០០នាក់ ត្រូវបានសម្លាប់នៅទីនោះ។ តើលោកអាចបញ្ជាក់បន្ថែមដល់យើងបានទេ? ឆ៖ "ខ្ញុំមើលឃើញពីចម្ងាយ និងឮអ្នកជិតខាងគេនិយាយថា គេដឹកមនុស្សពី៥ទៅ១០នាក់ ជួនកាលតាមរទេះសេះ និងជួនកាលតាមឡាន យកទៅសម្លាប់នៅជិតស្រះទឹកមួយ នៅខាងលិចទីផ្លា (បច្ចុប្បន្នជាផ្សារដប់រ៉ាវី)។ ខ្ញុំមិនច្បាស់ទេ ប៉ុន្តែខ្ញុំគិតថា ពួកគេទាំងនោះ នឹងត្រូវបានសម្លាប់នៅទីនោះ។ បងថ្លៃប្រុសរបស់ខ្ញុំម្នាក់ ក៏បានគេចាប់យកទៅសម្លាប់ដែរ"]។ ស៖ អ្នកដែលត្រូវបានគេចាប់យកទៅសម្លាប់នៅទីនោះ តើជាប្រជាជនថ្មី ឬក៏ប្រជាជនមូលដ្ឋាន? ឆ.7៖ មនុស្សដែលត្រូវបានគេចាប់យកទៅសម្លាប់នៅទីនោះ គឺចម្រុះគ្នា មានទាំងប្រជាជនថ្មី និងប្រជាជនចាស់"]។ ឯកសារ D106/11 របាយ

ការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787417 ["មុន និងក្រោយពេលដែលយាយ ចែម លេខាស្រុកបានមកដល់ ទីតាំងសម្លាប់មនុស្សគឺនៅចម្ការដូង និងចម្ការយាយនឹង នៅភូមិប៉ោយគ្លៀង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ។ លោក សុះ ណារិន (អាយុ ៧៤ ឆ្នាំ) អនុប្រធានភូមិប៉ោយគ្លៀង បាននាំក្រុមការងារទៅកាន់ទីតាំងទាំង ពីរកន្លែង។ គ្មានទីតាំងណាមួយក្នុងចំណោមទីតាំងទាំងនេះ មានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី ឡើយ ហើយគេបានប្រាប់យើងថា ប្រជាជនដែលត្រូវបានសម្លាប់នៅទីតាំងទាំងនេះ គឺជាប្រជាជនថ្មី ឬកម្មាភិបាលភូមិភាគពាយ័ព្យ ហើយពួកគេត្រូវបានចាប់ខ្លួននៅពេលថ្ងៃយកទៅផ្ទះតាក្រក ហើយយកទៅកន្លែងសម្រាប់នៅពេលយប់។ ប្រជាជន ប្រហែលជា២០០នាក់ ត្រូវបានសម្លាប់នៅទីនោះ ទាំងក្នុងពេលដែលតាក្រក ធ្វើជាគណៈស្រុក និងក្នុងពេលដែល អ៊ឹម ចែម បានកាន់កាប់តំណែងដូចគ្នានេះ ពីពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់វៀតណាមចូលមករំដោះ។ អ្នកភូមិបានជីកកកាយរណ្តៅសាកសពដើម្បីរកមាស បន្ទាប់ពីការដួលរលំរបបប៉ុល ពត នៅឆ្នាំ ១៩៧៩។ សាកសពត្រូវបានគេដុតចោលនៅនឹងកន្លែង"]។ ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ៖ KH 00750678 ["នៅទីកន្លែងដែលកើតមានឧក្រិដ្ឋកម្មនាវត្តព្រះនេត្រព្រះ (ចម្ការតាលឹង) ក្នុងភូមិសំរោង ឃុំព្រះនេត្រព្រះ យើងបានជួបជាមួយសាក្សីមួយរូប មានឈ្មោះ ទុំ សឿន ភេទប្រុស អាយុ៤៥ឆ្នាំ កម្ពស់១ម៉ែត្រ៦០សង់ទីម៉ែត្រសក់ខ្មៅ មានសម្បុរស។ នៅក្នុងរបបប៉ុលពត គាត់រស់នៅក្នុងភូមិពយសំរោង ឃុំព្រះនេត្រព្រះ ដែលជាទីកន្លែងគាត់កំពុងរស់នៅនាពេលសព្វថ្ងៃ។ គាត់បានឃើញប្រជាជនត្រូវគេសម្លាប់ចោលនៅតាមបណ្តាកន្លែងជាច្រើន ប៉ុន្តែនៅត្រង់ទីតាំងសម្រាប់ពិឃាតមនុស្សនៃកន្លែងដែលកើតមានឧក្រិដ្ឋកម្មស្ថិតក្នុងវត្តព្រះនេត្រព្រះនេះ គាត់បានចូលរួមនៅក្នុងការជីកគាស់កកាយរណ្តៅសាកសពនានា ដែលមានមុខកាត់ទំហំ៤ម៉ែត្រការេ និងជម្រៅ២ម៉ែត្រ។ រណ្តៅសាកសពនីមួយៗ មានផ្ទុកសាកសពចំនួនពី១០០ ទៅ១២០សាកសព។ យោងតាមសម្តីរបស់សាក្សីរូបនេះ ចំនួនមនុស្សដែលត្រូវបានសម្លាប់សរុបមានចំនួនប្រហែល៦៦០ ទៅ៧២០នាក់។ [...] ផ្អែកតាមការមើលឃើញដោយផ្ទាល់នូវឆ្អឹងក្បាលខ្មោចរបស់ជនរងគ្រោះ យើងសន្មតថា ភាគច្រើនជនរងគ្រោះគឺជាមនុស្សពេញវ័យ មានអាយុក្រោម៤៥ឆ្នាំ។ ពួកគេគឺជាមន្ត្រីរាជការ ដែលត្រូវគេជម្លៀសមកពីទីក្រុង ហើយជនរងគ្រោះទាំងអស់គឺជាបុរស"]។ ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788227 ["របាយការណ៍មួយបង្ហាញថា អដ្ឋិធាតុភាគច្រើននៅទីនោះជាអដ្ឋិធាតុរបស់មនុស្សប្រុសអាយុក្រោម៤៥ឆ្នាំ។ អ្នកទាំងនោះទំនងជាប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ"]។ សូមមើលផងដែរ ឯកសារ D219/204.1 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះសិក្សាស្រាវជ្រាវពីទីតាំងសម្លាប់ មន្ទីរសន្តិសុខ និងបូជនីយដ្ឋានដែលបន្សល់ទុកក្រោយរបបខ្មែរក្រហមនៅខេត្តបន្ទាយមានជ័យ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៧ KH 01074009 [អ្នកស៊ើបអង្កេតបញ្ជាក់ថា សាក្សី ទុំ សឿន ដែលបានស្នាក់នៅឃុំព្រះនេត្រព្រះតាំងពីរបប ប៉ុល ពត រហូតមកដល់បច្ចុប្បន្ន៖ "បានដឹង និងឃើញគេសម្លាប់ផ្ទាល់កន្លែងផ្សេង ឯកន្លែងនោះ [ចម្ការតាលឹង] គ្រាន់តែដឹងថា ពេលគាត់មកជីករកមាស គាត់ដឹងថា មួយរណ្តៅឃើញពី១០០-១២០ នាក់ មានរណ្តៅ៦ធំៗ [...] ដូច្នេះអាចមាន៦៦០នាក់ទៅ៧២០នាក់ ដែលត្រូវបានសម្លាប់នៅទីនោះ [...] ចម្ការតាលឹង នៅខាងក្រោយសន្តិសុខគុក៥០ម៉ែត្រទេ។ នៅទីនោះ គណៈឃុំ ប៉ុល ពត នៅមានផ្ទះក្បឿងមួយខ្នង [ផ្ទះរបស់តាក្រក] សម្រាប់ដាក់អ្នកទោស វាយសម្លាប់អស់ ដាក់បន្ថែមថ្មី យកមកក្រោយៗទៀត។ [...] ជនរងគ្រោះភាគច្រើនជាមនុស្សចាស់ អាយុ៤៥ចុះ

ហើយជាមន្ត្រីរដ្ឋការ ស៊ីវិល ជម្លៀសពីទីក្រុង"]។ ឯកសារ D219/205 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ.42 KH 01072294 [សាក្សីបានប្រមូលភ័ស្តុតាងសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំរបាយការណ៍ [ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ៖] នៅក្នុងខេត្តបន្ទាយមានជ័យ៖ "នៅចម្ការតាលឹង អ្នកដែលគេសម្លាប់គឺអ្នកជម្លៀសចេញពីទីក្រុងនៅឆ្នាំ ១៩៧៥ ហើយគឺជាមន្ត្រីរាជការស៊ីវិលដែលសុទ្ធតែប្រុសត្រូវបានគេសម្លាប់នៅទីនោះ"]។

1298 ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្ឌិត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.18 KH 01066319 [សាក្សីគឺជាមេក្រុមនៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំគ្រាន់តែដឹងថា ប្រជាជនធម្មតា ឬអតីតយោធា និងមន្ត្រីរបបលន់ នល់ ត្រូវបានគេយកទៅសម្លាប់នៅពីរបីកន្លែង នៅម្តុំភ្នំព្រះនេត្រព្រះ"។ ឆ.19 KH 01066319 ["ការចាប់ខ្លួន និងសម្លាប់ប្រជាជនធម្មតា និងអតីតរដ្ឋការ លន់ នល់ គឺធ្វើឡើងនៅក្រោយពេលដែលគេចាប់ខ្លួនតាក្រក គឺនៅពេលដែលពួកនិរតីមកដល់"]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.4 KH 00915839 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប ៖ "ស៖ លោកស្រីបានមានប្រសាសន៍ថា មុនវៀតណាមចូល ប្រហែលជាក្នុងខែ សីហា មានមនុស្សជាច្រើនត្រូវគេយកទៅសម្លាប់ តើពួកគេទាំងនោះជាមនុស្សប្រភេទណា? ឆ.4៖ ភាគច្រើនជាអតីតគ្រូបង្រៀន និងទាហានក្នុងរបប លន់ នល់"]។ ឯកសារ D119/39 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ឌៀ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.5-8 KH 00915853-00915854 [សាក្សីធ្វើការនៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ រួមបញ្ចូលទាំងទំនប់ត្រពាំងថ្ម៖ "ខ្ញុំបានទៅមើលដីចម្ការរបស់ខ្ញុំដែលស្ថិតនៅខាងជើងក្បែរផ្ទះតាក្រក។ ទីកន្លែងនោះហើយ ដែលខ្ញុំបានឃើញលលាដ៍ក្បាលមនុស្សតូចធំ និងឆ្អឹងសក្បុះនៅពាសពេញទីនោះ។ ស៖ តើទីតាំងនោះមានឈ្មោះអ្វី? ឆ៖ ទីនោះគេហៅថាកន្លែងតាក្រក។ បន្ទាប់ពីដួលរលំរបបខ្មែរក្រហម មានអ្នកភូមិជាច្រើនបានទៅជីករណ្តៅសាកសពទាំងនោះ ដើម្បីរកមាស។ ស៖ តើលោកស្រីដឹងទេថា ហេតុអ្វីបានជាមនុស្សដែលគេសម្លាប់នោះ ត្រូវបានកប់នៅទីនោះ? ឆ៖ ខ្ញុំបានឮគេនិយាយថា អ្នកដែលបានជាប់ពាក់ព័ន្ធនឹងយួន ហើយជាអតីតមន្ត្រីរាជការក្នុងរបបចាស់ និងទាហាន ត្រូវបានគេសម្លាប់ចោលទាំងគ្រួសារ សូម្បីតែកូនង៉ែតមួយក៏មិនទុកដែរ។ [...] អ្វីដែលខ្ញុំបានឃើញ ខ្ញុំអាចប៉ាន់ស្មានថា មានរាប់រយនាក់ដែលបានកប់នៅទីនោះ"]។ ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.15 KH 01024726 [សាក្សីរស់នៅក្នុងភូមិឯកពោធិ៍ និងធ្វើការនៅក្នុងកងចល័តលើកភ្លឺស្រែនៅព្រះនេត្រព្រះ ស្រះ កំបោរ ព្រៃមាន់ អូរលៀប និងធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ពូរបស់ខ្ញុំជាអតីតទាហាន លន់ នល់។ នៅពេលនោះពូរបស់ខ្ញុំរស់នៅភូមិប៉ោយសំរោង [ស្រុកព្រះនេត្រព្រះ]។ ពួកខ្មែរក្រហមបានបណ្តើរយកគាត់ទៅវ៉ៃចោល"]។

1299 ឯកសារ D123/1/2.57 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឃ ម៉ុត ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ KH 00737593 [សាក្សីធ្វើការនៅក្នុងកងចល័ត និងជាប្រធានកងនារី៖ "ឈុនលី៖ ដល់ពេលមីងទៅធ្វើការនៅត្រពាំងថ្មឃើញមានមនុស្សស្លាប់ទេ? ម៉ុត៖ ដែលអត់ហ្មាស។ ឈុនលី៖ ស្លាប់ដោយសារអី? ម៉ុត៖ ដូចយើងខុសសីលធម៌ ខុសអីចឹងដូចថាយើងមានប្រវត្តិថាយួនថាអី គេយកទៅវ៉ៃចោល"]។ ឯកសារ D119/39 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់

ឌៀ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.5-8 KH 00915853-00915854 [សាក្សីធ្វើការនៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ រួមបញ្ចូលទាំងទំនប់ត្រពាំងថ្ម៖ "ខ្ញុំបានទៅមើលដីចម្ការរបស់ខ្ញុំដែលស្ថិតនៅខាងជើងក្បែរផ្ទះតាក្រក។ ទីកន្លែងនោះហើយ ដែលខ្ញុំបានឃើញលលាដ៍ក្បាលមនុស្សតូចធំ និងឆ្អឹងសក្បុះនៅពាសពេញទីនោះ។ ស៖ តើទីតាំងនោះមានឈ្មោះអ្វី? ឆ៖ ទីនោះគេហៅថាកន្លែងតាក្រក។ បន្ទាប់ពីដួលរលំរបបខ្មែរក្រហម មានអ្នកភូមិជាច្រើនបានទៅជីករណ្ដៅសាកសពទាំងនោះ ដើម្បីរកមាស។ ស៖ តើលោកស្រីដឹងទេថា ហេតុអ្វីបានជាមនុស្សដែលគេសម្លាប់នោះ ត្រូវបានកប់នៅទីនោះ? ឆ៖ ខ្ញុំបានឮគេនិយាយថា អ្នកដែលបានជាប់ពាក់ព័ន្ធនឹងយួន ហើយជាអតីតមន្ត្រីរាជការក្នុងរបបចាស់ និងទាហាន ត្រូវបានគេសម្លាប់ចោលទាំងគ្រួសារ សូម្បីតែកូនង៉ែតមួយក៏មិនទុកដែរ។ [...] អ្វីដែលខ្ញុំបានឃើញ ខ្ញុំអាចប៉ាន់ស្មានថា មានរាប់រយនាក់ដែលបានកប់នៅទីនោះ"]។

1300 ឯកសារ D119/38 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.12 KH 00915849 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ "ប្រធានភូមិជំនាន់តាក្រក ដែលជាអ្នកពាយ័ព្យមួយចំនួន ក្នុងនោះរួមមាន ភូមិប៉ោយតាប៉ែន ភូមិប៉ោយព្រីង ភូមិប៉ោយក្បៀង និងភូមិជើងវត្តក៏ត្រូវបានគេចាប់ខ្លួនដូចតាក្រកដែរ"]។ ឯកសារ D219/181 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.35 KH 01066322 [សាក្សីគឺជាមេក្រុមនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ការសម្លាប់អតីតរាជការលន់ នល់ នៅតែបន្ត ក្រោយពេលពួកនិរតីមកដល់ បន្ថែមលើការបោសសម្អាតកម្មាភិបាលពាយ័ព្យផង"]។ ឯកសារ D106/11 របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787417 [មនុស្សទាំងអស់ដែល ក.ស.ច.ស បានសាកសួរ "បានបញ្ជាក់ថា មុន និងក្រោយពេលដែលយាយ ចែម លេខាស្រុកបានមកដល់ ទីតាំងសម្លាប់មនុស្សគឺនៅចម្ការដូង និងចំការយាយនឹង [...] គេប្រាប់យើងថា ប្រជាជនដែលត្រូវបានសម្លាប់នៅទីតាំងទាំងនេះ គឺជាប្រជាជនថ្មី ឬកម្មាភិបាលភូមិភាគពាយ័ព្យ"]។ ឯកសារ D119/76 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឆ.13 KH 00971143 [សាក្សីធ្វើការនៅក្នុងកងចល័តនារី រួមទាំងកូនខ្លែង ព្រៃមាន់ និងត្រពាំងថ្ម៖ "ស៖ តើលោកស្រីដឹងថា ពួកនិរតីមកដល់ស្រុកព្រះនេត្រព្រះនៅពេលណា? ឆ.13៖ "ខ្ញុំមិនចាំថា ពួកគេមកដល់នៅពេលណាទេ។ ខ្ញុំដឹងថា ពេលដែលពួកគេមកដល់ភ្លាម ពួកគេបានចាប់ទាហាន និងអ្នកគ្រប់គ្រងដែលជាអ្នកពាយ័ព្យយកទៅវាយចោលអស់"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.13 KH 00915873 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "ដំបូងពួកពាយ័ព្យ និងនិរតីបានធ្វើការជាមួយគ្នាបានមួយរយៈ តែក្រោយមក ពួកនិរតីបានចាប់ខ្លួនពួកពាយ័ព្យ"]។

1301 ឯកសារ D119/37 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.4 KH 00915839 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប៖ "ស៖ លោកស្រីបានមានប្រសាសន៍ថា មុនវៀតណាមចូល ប្រហែលជាក្នុងខែ សីហា មានមនុស្សជាច្រើនត្រូវគេយកទៅសម្លាប់ តើពួកគេទាំងនោះជាមនុស្សប្រភេទណា? ឆ.4៖ ភាគច្រើនជាអតីតគ្រូបង្រៀន និងទាហានក្នុងរបប លន់ នល់។ នៅពេលនោះ មានមនុស្សមួយចំនួនក្នុងចំណោមដែលគេយកទៅសម្លាប់ហ្នឹង បានរត់គេចខ្លួន ប៉ុន្តែប្រពន្ធ និងកូនរបស់ពួកគេ ត្រូវបានគេប្រមូលយកទៅ

សម្លាប់នៅក្បែរជើងភ្នំព្រះនេត្រព្រះ ដែលមានទីតាំងនៅខាងក្រោយផ្ទះ តាក្រក ដែលនៅទីនោះ មានរណ្ដៅសាកសពដ៏ធំមួយ"]។

1302 ឯកសារ D119/37 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុង ផាក់ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.4 KH 00915839 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប៖ "មានមនុស្សមួយចំនួនក្នុងចំណោមដែលគេយកទៅសម្លាប់ហ្នឹង បានរត់គេចខ្លួន ប៉ុន្តែប្រពន្ធ និងកូនរបស់ពួកគេ ត្រូវបានគេប្រមូលយកទៅសម្លាប់នៅក្បែរជើងភ្នំព្រះនេត្រព្រះ ដែលមានទីតាំងនៅខាងក្រោយផ្ទះ តាក្រក ដែលនៅទីនោះ មានរណ្ដៅសាកសពដ៏ធំមួយ"]។ ឯកសារ D219/181 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.23 KH 01066320 [សាក្សីគឺជាមេក្រុមនៅក្នុងស្រុកព្រះនេត្រព្រះ៖ "តាមខ្ញុំដឹងពីអ្នកដែលរស់នៅជិតផ្ទះតាក្រក បាននិយាយថា គេយកមនុស្សទៅសម្លាប់រៀងរាល់យប់ នៅប្រហែលជាចុងឆ្នាំ ១៩៧៧ ដែលនេះគឺជាការបោសសម្អាតចុងក្រោយ។ ក្នុងអំឡុងពេលនោះ ប្រជាជនជាច្រើននៅព្រះនេត្រព្រះបានរត់គៀសខ្លួនទៅស្រុកថៃដោយសារការភ័យខ្លាចរឿងចាប់ខ្លួន និងសម្លាប់ចោលនោះ"]។ ឆ.25 KH 01066320 ["ប៉ុន្តែគេនៅតែបន្តចាប់ខ្លួនអ្នកដែលលួចរបស់របរ និងគ្រួសារអ្នកដែលបានរត់ទៅព្រំដែនថៃដដែល"]។

1303 ឯកសារ D119/38 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.3 KH 00915847 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំដឹងថា វត្តព្រះនេត្រព្រះគឺគេធ្វើជាមន្ទីរពេទ្យ។ នៅទីនោះ ខ្ញុំបានឃើញអ្នកដែលលួចច្រូតស្រូវ និងអ្នកដែលឡើងលួចយកទឹកត្នោតផឹក ត្រូវបានចាប់យកទៅសម្លាប់ចោលនៅក្នុងបរិវេណវត្តព្រះនេត្រព្រះ"]។ ឯកសារ D219/181 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ោ បណ្ដែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.25 KH 01066320 [សាក្សីគឺជាមេក្រុមនៅក្នុងស្រុកព្រះនេត្រព្រះ៖ ["ប៉ុន្តែគេនៅតែបន្តចាប់ខ្លួនអ្នកដែលលួចរបស់របរ និងគ្រួសារអ្នកដែលបានរត់ទៅព្រំដែនថៃដដែល"]។

1304 ឯកសារ **D5/1547** ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឈិត រ័ត្ន ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៣ KH 01093384-01093385 [សាក្សីធ្វើការនៅកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ឆ្នាំ ១៩៧៨ [...] ការដ្ឋានរបស់នាងខ្ញុំនៅមិនឆ្ងាយប៉ុន្មានម៉ែត្រទេពីមន្ទីរឃុំឃាំងវត្តព្រះនេត្រព្រះ។ [...] ពេលថ្ងៃ ពេលព្រឹក ពេលយប់ លឺតែស្នូរសំឡេងស្រែកអូយៗនោះតែម្ដង គិតៗទៅអញ្ចប្រហែលជាត្រូវស្លាប់នៅពេលនោះ ឲ្យតែធ្វើខុស ឬអង្គការចោទថាខ្មាំង ឬក្បត់អង្គការ ច្បាស់ជាត្រូវស្លាប់តែម្ដង"]។

1305 ឯកសារ D119/145 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ធិប គឹមលន់ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤ ឆ.108-109 KH 01022038 [សាក្សីរស់នៅ និងធ្វើការនៅក្នុងភូមិ និងការដ្ឋានមួយចំនួនក្នុងស្រុកព្រះនេត្រព្រះ រួមទាំងទំនប់គោករំចេក និងអូរស្មាច់៖ "ខ្ញុំធ្លាប់បានឮគេនិយាយថា មានគេយកប្រុស១នាក់ ស្រី១នាក់ មកសម្លាប់នៅខាងលិចជាប់របងវត្តព្រះនេត្រព្រះ ដោយចោទថា ពួកគេប្រព្រឹត្តខុសសីលធម៌។ [...] គឺកើតឡើងប្រហែលជាចុងរបបខ្មែរក្រហម ដែលពេលនោះខ្ញុំបានរៀបការរួច ហើយមានផ្ទៃពោះ"]។ ឯកសារ D119/52 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុំ ឈួក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.21 KH 00933132 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅស្រុកព្រះនេត្រព្រះ៖ "ខ្ញុំបានឃើញហេតុការណ៍សម្លាប់ស្រីប្រុសមួយគូ នៅខាងលិចមុខវត្តព្រះនេត្រព្រះដោយសារតែបានប្រព្រឹត្តខុសសីលធម៌។ ពីរនាក់នុងត្រូវបានគេចងភ្ជាប់នឹងបង្គោលឈើទល់មុខគ្នា ហើយត្រូវបានវៃរហូតដល់ស្លាប់នៅចំពោះ

មុខប្រជាជន ដែលអង្គុយជុំវិញនោះ តាមបញ្ជារបស់ តាក្រក និងសម្លាប់ផ្ទាល់ដោយអនុប្រធានរបស់គាត់ គឺ អា ផន"]។ ឯកសារ D219/60 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិម សុវណ្ណី ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឆ.53-55 KH 01037119 [សាក្សីរស់នៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ និងធ្វើការនៅតាមការដ្ឋានមួយចំនួន រួមទាំងទំនប់ត្រពាំងថ្ម៖ "ស៖ លោកស្រីបាននិយាយថា "មានមនុស្សស្រីម្នាក់ និងប្រុសម្នាក់បានខុសសីលធម៌ ហើយស្ត្រីនោះមានផ្ទៃពោះ ត្រូវបានគេយកទៅសម្លាប់ទាំងពីរនាក់"។ [...] ឆ.53៖ [...] ខ្ញុំបានឃើញគេវ៉ៃមនុស្សនោះស្លាប់។ ស៖ តើលោកស្រីមានចាំពីទីកន្លែងដែលគេសម្លាប់អ្នកទាំងពីរនោះទេ? ឆ.54-55៖ ខ្ញុំនៅចាំ គឺវានៅខាងលិចវត្តព្រះនេត្រព្រះ។ [...] គឺនៅក្រៅវត្ត"]។ ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.15 KH 01024726 [សាក្សីរស់នៅក្នុងភូមិដកពោធិ៍ និងធ្វើការនៅក្នុងកងចល័តលើកភ្លឺស្រែនៅព្រះនេត្រព្រះ ស្រះ កំបោរ ព្រៃមាន់ អូរលៀប និងធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ខ្ញុំធ្លាប់បានឃើញគេសម្លាប់ប្រុសស្រី២នាក់ដែលត្រូវបានគេចោទប្រកាន់ថាធ្វើខុសសីលធម៌ ហើយមនុស្សទាំងពីរនាក់នោះ ត្រូវបានគេយកមកសម្លាប់នៅមុខអង្គប្រជុំមួយ ដែលធ្វើនៅមុខវត្តព្រះនេត្រព្រះ"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.9 KH 00915872 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "ស៖ លោកដឹងទេថា តើនរណាជាប្រធាននារីមកពីនិរតី? ឆ.9៖ ខ្ញុំមិនច្បាស់ដែរ ប៉ុន្តែពួកគេហាក់បីដូចជាមានអំណាចក្នុងការចាប់មនុស្សទាំងអស់នោះ [ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន។ ខ្ញុំបានឃើញគេសម្លាប់មនុស្សប្រុសស្រីមួយគូ នៅមុខកាច់ជ្រុងវត្តព្រះនេត្រព្រះ"]។ ឯកសារ D123/1/2.57 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ យ ម៉ុត ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ KH 00737593 [សាក្សីធ្វើការនៅក្នុងកងចល័ត និងជាប្រធានកងនារី៖ "ឈុនលី៖ ដល់ពេលមីងទៅធ្វើការនៅត្រពាំងថ្ម ឃើញមានមនុស្សស្លាប់ទេ? ម៉ុត៖ ដែលអត់ហ្អាស។ ឈុនលី៖ ស្លាប់ដោយសារអី? ម៉ុត៖ ដូចយើងខុសសីលធម៌ ខុសអីចឹង ដូចថាយើងមានប្រវត្តិថាយួនថាអី គេយកទៅវ៉ៃចោល។ ឈុនលី៖ និយាយថា អាពេលទៅធ្វើត្រពាំងថ្មហ្នឹង មានឃើញអ្នកណាធ្វើការៗស្លាប់ទេ? ម៉ុត៖ ទេ មិនដែលសូវមានទេ មានតែខុសសីលធម៌ ខុសអីហ្នឹង។ ឈុនលី៖ ខុសសីលធម៌ដែលយកទៅសម្លាប់នៅមុខវត្តព្រះនេត្រព្រះហ្នឹង? ម៉ុត៖ ហ្នឹងឯង។ ឈុនលី៖ មីងមកមើលដែរ? ម៉ុត៖ មកមើល។ ឈុនលី៖ ហើយយ៉ាងម៉េចខ្លះទៅ? ម៉ុត៖ មានម៉េច គេវ៉ៃខ្លាក១"]។ D5/969 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិម សុវណ្ណី ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ KH 00989914-00989915 [សាក្សីរស់នៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ និងធ្វើការនៅតាមការដ្ឋានមួយចំនួន រួមទាំងទំនប់ត្រពាំងថ្ម៖ "ភាពជាក់ស្តែងដែលនាងខ្ញុំបានឃើញច្បាស់នឹងភ្នែក នៅដើមឆ្នាំ ១៩៧៩ ពួកគេបានសម្លាប់ប្រជាជនដែលប្រព្រឹត្តខុសសីលធម៌ ប្រុសឈ្មោះ សឿន ស្រីឈ្មោះ ពៅ ជាប្រជាជនថ្មី សកម្មភាពសម្លាប់នោះ អស្ចារ្យណាស់ គឺពួកគេប្រមូលប្រជាជនយ៉ាងច្រើន ឲ្យចូលរួមទស្សនា ដូចទៅមើលសិល្បៈ ពួកគេបណ្តើរគាត់ទាំងពីរមកចង និងបង្គោលទាំងពីរ ហើយពួកគេបានស្រែកប្រកាសប្រាប់ពីទោសអ្នកប្រព្រឹត្តខុសសីលធម៌ និងស្រែកប្រាប់ប្រជាជនទាំងអស់កុំយកតម្រាប់តាម លុះប្រកាសរួចហើយ ពួកគេយកដងចបវាយពីក្រោយកញ្ចឹងកបីដំបងស្លាប់ ហើយទៅសម្លាប់ស្រីទៀត គឺវាយច្រើនដំបង មិនងាយស្លាប់ព្រោះនាងមានផ្ទៃពោះផង"]។ ឯកសារ D5/853 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00956904-00956905 [សាក្សីធ្វើការនៅក្នុងកងកុមារក្នុងកងចល័តតំបន់៥៖ "យាយថែម កាន់កាប់តំបន់៥ទាំងមូល ខ្ញុំធ្លាប់ឃើញគាត់បញ្ជាឲ្យសម្លាប់មនុស្សដែលខុសសីលធម៌ គ្រាន់តែប្រុសស្រីនិយាយ

រកគ្នាក៏មិនបាន។ មនុស្សពីរនាក់នោះត្រូវគេចងស្លាបសេក យកទៅសម្លាប់ដោយវាយនឹងត្បូងចប"]។ D5/989 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឡាំ បូផ្កា ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៣ KH 00990238 [សាក្សីរស់នៅ និងធ្វើការនៅក្នុងភូមិចក្រី ស្រុកព្រះនេត្រព្រះ៖ "ឆ្នាំ ១៩៧៨ មិត្ត យ៉ន ប្រធានសហករណ៍ បានចាត់តាំងនាងខ្ញុំឱ្យទៅនៅដកស្ទូង លើកភ្លឺស្រែក្បែរភូមិ [...] នៅពេលល្ងាចនោះ ពួកមេកង ឬឈ្លបកោះហៅប្រជាជនមកប្រជុំនៅវត្តព្រះនេត្រព្រះ ស្រាប់តែឃើញមនុស្សជាប់ចំណង២នាក់ ស្រីប្រុសចងផ្ដោបគល់ឈើ មួយសន្ទុះក្រោយមក ឈ្លបម្នាក់បានកាប់សម្លាប់ដោយប្រើដាវ ឬកាំបិតភ្លាមដោយចោទថាខុសសីលធម៌ កុំឱ្យប្រជាជនយកគំរូតាម"]។ ឯកសារ D5/1254 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី កេតុ សាវ៉ន ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៣ KH 01036312 [សាក្សីរស់នៅ និងធ្វើការនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ឆ្នាំ ១៩៧៧ [...] ខ្ញុំមានផ្ទៃពោះ៨ខែ។ [...] ក្រោយមក នាងខ្ញុំបានសម្រាលកូនប្រុសមួយឈ្មោះ អាចក់ ទើបអង្គការបញ្ជូនឱ្យមករស់នៅក្នុងភូមិប៉ុស្ដិរាជ ឃុំព្រះនេត្រព្រះ ទល់មុខវត្តព្រះនេត្រព្រះ ខេត្តបាត់ដំបង។ នៅពេលនោះ ហេតុការណ៍មួយបានកើតឡើង គឺពួកកងចល័តស្រឡាញ់គ្នា ពួកឈ្លបចាប់មកចងផ្អឹបគល់ដូង (ក្នុងបរិវេណវត្តព្រះនេត្រព្រះ) រួចវាបាញ់សម្លាប់កុំឱ្យបងប្អូនយកគំរូតាម"]។ ឯកសារ D119/76 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លៀម សារ៉េម ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤ ឆ.22 KH 00971144 [សាក្សីធ្វើការនៅក្នុងកងចល័តនារី រួមទាំងកូនខ្លែង ព្រៃមាន់ និងត្រពាំងថ្ម៖ "ខ្ញុំធ្លាប់ឮថា មានអ្នកខុសសីលធម៌ ហើយទាំងប្រុសទាំងស្រីនោះ ត្រូវបានគេចាប់យកទៅវត្តព្រះនេត្រព្រះ នៅពេលមានកិច្ចប្រជុំធំមួយ តែខ្ញុំមិនបានចូលរួមប្រជុំនោះទេ"]។ ផ្ទុយនឹង ឯកសារ D119/38 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុស ណារិន ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.3-5 KH 00915847-00915848 [សាក្សីគឺជាជាងដំដែកនៅក្នុងស្រុកព្រះនេត្រព្រះ និងបានរស់នៅក្នុងភូមិមួយចំនួននៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំដឹងថា វត្តព្រះនេត្រព្រះគឺគេធ្វើជាមន្ទីរពេទ្យ។ [...] ក្រោយមកទៀត ខ្ញុំបានឃើញគេសម្លាប់មនុស្សប្រុសស្រីមួយគូដែលបានចោទថាខុសសីលធម៌ ក៏ត្រូវបានសម្លាប់ចោលនៅទីធ្លាមួយនៅមុខវត្តព្រះនេត្រព្រះ ដែលគេតែងតែយកធ្វើជាទីតាំងប្រជុំ។ ស៖ តាមការស្មានរបស់លោក តើមានមនុស្សប៉ុន្មានដែលត្រូវបានគេយកទៅសម្លាប់ក្នុងវត្តព្រះនេត្រព្រះ? ឆ.4៖ ខ្ញុំឃើញតែ៣ដងប៉ុណ្ណោះ (គេសម្លាប់មនុស្ស៤នាក់)។ [...] វាកើតឡើងនៅក្នុងជំនាន់តាក្រក (មេឃុំព្រះនេត្រព្រះ)"]។

1306 ឯកសារ D219/347 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.2 KH 01103340-01103341 [សាក្សីគឺជាសមាជិកគណៈឃុំព្រះនេត្រព្រះ៖ "ស៖ លោកបាននិយាយថា លោកបានសម្លាប់គូសង្សារមួយគូ តើលោកជួយបញ្ជាក់បន្ថែមបានទេ ថាមានអ្វីកើតឡើងនៅក្នុងឆ្នាំ ១៩៧៧? ឆ.2៖ វាគឺពេលខែពង្រោះ គឺជាពេលមុនខែរងារ"]។ ឆ.6 KH 01103341-01103342 ["ប៉ុន្តែពេលនោះ កម្មាភិបាលនិរតីបានមកដល់ តាអាត និងតាម៉ោង នៅតែដដែល"]។ ឆ.18 KH 01103343 ["ស៖ នៅក្នុងចម្លើយដែលលោកបានផ្ដល់ឱ្យពីមុនហ្នឹង លោកបាននិយាយថា ពេលដែលគូសង្សារត្រូវបានគេសម្លាប់នោះ នៅពេលនោះ កម្មាភិបាលនិរតីបានមកដល់ហើយ ប៉ុន្តែតាម៉ោង និងតាអាត នៅកាន់កាប់ដដែលទេ។ តើ យាយ ចែម មានវត្តមាននៅកន្លែងដែលគូសង្សារត្រូវបានសម្លាប់នោះដែរឬទេ? តើយាយ ចែម មក ឬនៅ នៅពេលសម្លាប់នោះ? ឆ.18៖ ពេលនោះ និរតីបានមកដល់ហើយ ហើយយាយ ចែម ក៏មកដល់ហើយ ប៉ុន្តែមិនដឹងគាត់នៅឯណាទេ"]។ ឯកសារ D5/984 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ប៉ាក់ ស៊ី លឿត ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៣ KH 00990159 [សាក្សីធ្វើការនៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ៖ ["នៅក្នុងឆ្នាំ ១៩៧៨ មាននារីម្នាក់ឈ្មោះ ពៅ

និងប្រុសឈ្មោះ សឿន បានធ្វើខុសសីលធម៌ស្រឡាញ់គ្នាលួចលាក់ក្បត់អង្គការ ពេលនោះអង្គការចាប់យកមកកាត់ទោសប្រហារជីវិត ដោយអញ្ជើញប្រជាជនទាំងសហករណ៍ក្នុងឃុំព្រះនេត្រព្រះមកចូលរួម ដោយមិនមានអ្នកណាម្នាក់នៅក្នុងភូមិបានឡើយ ក្នុងអង្គជំនុំនោះ មានប្រធានស្រុកឈ្មោះ ថែម តា ផន តា តាន់ នារី ម៉ន នារី វ៉េម និងប្រធាន១ជាច្រើនចូលរួម។ ពេលនោះ គេចងនារីនៅបង្គោលម្ខាង ប្រុសគេចងបង្គោលម្ខាង ហើយគេប្រាប់ប្រជាជនថា បើអ្នកណាធ្វើដូចអ្នកពីរនាក់នេះគឺស្លាប់ ថាប៉ុណ្ណឹង គេក៏ឱ្យនារីពៅនោះខិនកចុះ ដំបងនៅនឹងដៃ គេក៏លើកសំពងក្បាលនារីនោះចំនួនប្រាំពីរដំបងទើបនារីនោះស្លាប់ ចំណែកប្រុសតែបីដំបងប៉ុណ្ណោះក៏ស្លាប់ទៅ។ រឿងនេះបញ្ចប់ត្រឹមនឹង"]។ សូមមើលផងដែរ ឯកសារ D5/969 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធិម សុវណ្ណី ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ KH 00989914-00989915 [សាក្សីរស់នៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ និងធ្វើការនៅតាមការដ្ឋានមួយចំនួន រួមទាំងទំនប់ត្រពាំងថ្ម៖ "ភាពជាក់ស្តែងដែលនាងខ្ញុំបានឃើញច្បាស់នឹងភ្នែក នៅដើមឆ្នាំ ១៩៧៩ ពួកគេបានសម្លាប់ប្រជាជនដែលប្រព្រឹត្តខុសសីលធម៌ ប្រុសឈ្មោះ សឿន ស្រីឈ្មោះ ពៅ ជាប្រជាជនថ្មី សកម្មភាពសម្លាប់នោះ អស្ចារ្យណាស់ គឺពួកគេប្រមូលប្រជាជនយ៉ាងច្រើន ឱ្យចូលរួមទស្សនាដូចទៅមើលសិល្បៈ ពួកគេបណ្តើរគាត់ទាំងពីរមកចង និងបង្គោលទាំងពីរ ហើយពួកគេបានស្រែកប្រកាសប្រាប់ពីទោសអ្នកប្រព្រឹត្តខុសសីលធម៌ និងស្រែកប្រាប់ប្រជាជនទាំងអស់កុំយកគតម្រាប់តាម លុះប្រកាសរួចហើយ ពួកគេយកដងចបវាយពីក្រោយកញ្ចឹងកបីដំបងស្លាប់ ហើយទៅសម្លាប់ស្រីទៀត គឺវាយច្រើនដំបង មិនងាយស្លាប់ព្រោះនាងមានផ្ទៃពោះផង"]។ ឯកសារ D5/986 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាំ ប៊ុនសួយ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ KH 00990189-00990190 [សាក្សីគឺជាកម្មករនៅតាមការដ្ឋាននានា រួមទាំងទំនប់តាវ៉ាល់ និងទំនប់ស្ពានស្រែង៖ "ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ គេបញ្ជូនខ្ញុំទៅលើកទំនប់តាវ៉ាល់ និងទំនប់ស្ពានស្រែង។ [...] ទំនប់ខាងកើតវត្តព្រះនេត្រព្រះទល់ស្ពានដែក ពេលនោះខ្ញុំក៏ជួបជនរងគ្រោះពីរនាក់ទៀត ខុសសីលធម៌ស្រឡាញ់គ្នាគ្មានច្បាប់ ពេលនោះប្រធានសហករណ៍ បានចាប់ទាំងពីរនាក់មកចងទុកនឹងមុខវត្ត ជាប់នឹងបង្គោល កណ្តាលអង្គប្រជុំ ដែលមានប្រជាជនប្រហែលជា៥00 នាក់ មួយឃុំ ក៏បានសម្លាប់ក្នុងអង្គប្រជុំ រួចថាជាខ្មាំង"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.20-21 KH 00978921 [សាក្សីគឺជាសមាជិកកងចល័តនៅក្នុងសហករណ៍៥ នៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំធ្លាប់បានចូលរួមកិច្ចប្រជុំមួយនៅវត្តព្រះនេត្រព្រះ ដែលនៅពេលនោះ បុរស និងស្ត្រីម្នាក់ ត្រូវបានខ្មែរក្រហមចោទថាខុសសីលធម៌ ហើយត្រូវបានគេសម្លាប់នៅ កណ្តាលអង្គមិទិញ [...] អង្គមិទិញ ប្រហែលធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៧ តាក្រក ជាអ្នកដឹកនាំអង្គមិទិញនោះ"]។ ផ្ទុយនឹង ឯកសារ D119/143 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃាង ឃុន ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឆ.51-52 និង ឆ.54 KH 01009191-01009192 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "មនុស្សដែលត្រូវបានគេចោទថាខុសសីលធម៌នោះ បុរសឈ្មោះ ជឿម ចំណែកនារីឈ្មោះ ពៅ [...] ស៖ តើព្រឹត្តិការណ៍នេះកើតឡើងនៅឆ្នាំណា? ឆ.52៖ ខ្ញុំមិនចាំឆ្នាំច្បាស់លាស់ទេ ខ្ញុំគ្រាន់តែដឹងនៅពេលនោះ គឺនៅរដូវភ្លៀង។ [...] តា សំអាត គឺជាគណៈស្រុកព្រះនេត្រព្រះ មុនពេលដែលយាយថែម បានមកដល់ស្រុកព្រះនេត្រព្រះ បានបញ្ជាឱ្យគេយកមនុស្សទាំងពីរនាក់នោះចេញមកក្រៅ ហើយក្រោយមក គាត់បានបញ្ជាឱ្យ តាផន ដែលជាអនុឃុំព្រះនេត្រព្រះ យកចបជីក វាយសម្លាប់មនុស្សទាំងពីរនាក់នោះចោល"។ [...] KH 01009199 ["ត្រង់ចម្លើយ៥៤ សាក្សីបន្ថែមឃ្លា បន្ទាប់ពាក្យថា "ខ្ញុំសូមបញ្ជាក់ថា" នូវខ្លឹមសារ "នៅពេលនោះគេមានដាំបង្គោលឈើពីរដើមចំកណ្តាលអង្គប្រជុំនៅក្នុងទីធ្លាខាងលិចវត្តព្រះនេត្រព្រះ" ហើយដាក់ឃ្លាថា

"មុនពេលដែល យាយ ចែម មកដល់ស្រុកព្រះនេត្រព្រះ" ជំនួសដោយឃ្លាថា "ដែលជាប្រធានអង្គប្រជុំ" សាក្សីបន្ថែមនៅខាងចុងចម្លើយ៥៤ថា៖ "យាយ ចែម បានឡើងធ្វើជាគណៈស្រុកព្រះនេត្រព្រះ ក្រោយពេលដែល តា សំអាត បានបាត់ខ្លួន។ ខ្ញុំមិនបានដឹងថា គាត់បាត់ខ្លួននៅពេលណាទេ"]។

1307 ឯកសារ D123/1/2.54 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សូ ឡាយ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ KH 00927226 [សាក្សីគឺជាសមាជិកកងចល័តដែលធ្វើការនៅទំនប់ត្រពាំងថ្ម៖ "វណ្ណៈ៖ អីចឹងជំនាន់តាក្រក តាវ៉ាល់ អីហ្នឹងក៏មានសម្លាប់មនុស្សដែរ? ឡាយ៖ អូ! ម៉ាជំនាន់ហ្នឹងមិនសូវសម្លាប់ទេ សម្លាប់តែសម័យខាងនិរតីចូលម៉ោ"]។ ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.19 KH 01066319 [សាក្សីគឺជាមេក្រុមនៅក្នុងឃុំព្រះនេត្រព្រះ៖ "ការចាប់ខ្លួន និងសម្លាប់ប្រជាជនធម្មតា និងអតីតរដ្ឋការលន់ នល់ គឺធ្វើឡើងនៅក្រោយពេលដែលគេចាប់ខ្លួនតាក្រក គឺនៅពេលដែលពួកនិរតីមកដល់"]។

1308 ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.19 KH 01024727 [សាក្សីរស់នៅក្នុងភូមិដកពោធិ៍ និងធ្វើការនៅក្នុងកងចល័តលើកភ្លឺស្រែនៅព្រះនេត្រព្រះ ស្រះ កំបោរ ព្រៃមាន់ អូរលៀប និងធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ពីដំបូងខ្ញុំឮមនុស្សស្រែកនៅពេលយប់ តែមិនញឹកញាប់ទេ។ ប្រហែល១ខែជិតបែករបបខ្មែរក្រហម ខ្ញុំបានឮមនុស្សស្រែកដោយសារគេយកទៅសម្លាប់ស្ទើររៀងរាល់យប់។ ជាទូទៅ គេមិនសម្លាប់មនុស្សនៅពេលថ្ងៃទេ គឺគេសម្លាប់នៅពេលយប់"]។ ឆ.21 KH 01024727 ["ខ្ញុំឮសំឡេងស្រែកនោះនៅខាងជើងភ្នំព្រះនេត្រព្រះ និងខាងលិចផ្ទះតាក្រកងណោះទេ"]។ ឆ.25 KH 01024728 ["ខ្ញុំឃើញគេចងបណ្តើរមនុស្សយកទៅសម្លាប់ប្រហែលជា១២នាក់នៅពេលយប់។ ខ្ញុំបានឃើញព្រឹត្តិការណ៍នេះនៅប្រហែល១ខែមុនរបបខ្មែរក្រហមដួលរលំ"]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផាវ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.3-4 KH 00915839 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រះ និងការដ្ឋានអូរលៀប ៖ "នៅខែ សីហា មុនពេលដែលកងទ័ពវៀតណាមចូលមកដល់ក្នុងឆ្នាំ ១៩៧៩ គឺមានការសម្លាប់មនុស្សយ៉ាងខ្លាំង។ [...] ភាគច្រើនជាអតីតគ្រូបង្រៀន និងទាហានក្នុងរបបលន់ នល់។ នៅពេលនោះ មានមនុស្សមួយចំនួនក្នុងចំណោមដែលគេយកទៅសម្លាប់ហ្នឹង បានរត់គេចខ្លួន ប៉ុន្តែប្រពន្ធ និងកូនរបស់ពួកគេ ត្រូវបានគេប្រមូលយកទៅសម្លាប់នៅក្បែរជើងភ្នំព្រះនេត្រព្រះ ដែលមានទីតាំងនៅខាងក្រោយផ្ទះ តាក្រក ដែលនៅទីនោះ មានរណ្តៅសាកសពដ៏ធំមួយ"]។ ឯកសារ D5/1547 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឈិត រ័ត្ន ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៣ KH 01093384-01093385 [សាក្សីធ្វើការនៅកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ឆ្នាំ ១៩៧៨ [...] ការដ្ឋានរបស់នាងខ្ញុំនៅមិនឆ្ងាយប៉ុន្មានម៉ែត្រទេពីមន្ទីរឃុំឃាំងវត្តព្រះនេត្រព្រះ។ [...] ពេលថ្ងៃ ពេលព្រឹក ពេលយប់ លឺតែស្នូរសំឡេងស្រែកអូយៗនោះតែម្តង"]។

1309 ឯកសារ **D1.3.10.10** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ KH 00750679 ["គ្មានឆ្អឹងសាកសពនៅសេសសល់ទេដោយសារតែអ្នកភូមិដែលមានវ័យចំណាស់ៗ បញ្ជាឲ្យគេដុតឆ្អឹងដែលនៅសេសសល់ទាំងអស់នោះចោល"]។ ឯកសារ **D106/12** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788227 ["តាមការប៉ាន់ស្មាន

ដំបូង មានមនុស្សប្រហែល៧០០នាក់ ត្រូវបានសម្លាប់នៅទីនោះ [នៅចម្ការតាឡឹង] ប៉ុន្តែសាកសពខ្លះអាចត្រូវបានដុតចោលនៅទីតាំងរណ្តៅសពទាំងនោះ [វត្តព្រះនេត្រព្រះ និងចម្ការតាឡឹង"]។

1310 ឯកសារ **D119/50.2** របាយការណ៍ពីការិយាល័យឃោសនាការស្រុកព្រះនេត្រព្រះ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH 00933220 ["សាកសពប្រហែល២៥៣នាក់ នៅ 'ចម្ការ តាលឹង' (វាយ បាញ់ និងទំលាក់រណ្តៅ)"]។ ឯកសារ **D219/205** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ2.6 KH 01072293 [សាក្សីបានប្រមូលភ័ស្តុតាងសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំរបាយការណ៍ [ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ] នៅក្នុងខេត្តបន្ទាយមានជ័យ ៖ "ចំនួន២៥៣នាក់ មិនរាប់បញ្ចូលក្នុងចំនួន៧២០នាក់ទេ។ ចំនួន៧២០នាក់នេះ គឺផ្អែកទៅលើចំនួនសាកសព ដែលគាស់ចេញពីរណ្តៅ"]។ ឯកសារ **D1.3.10.10** របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ KH 00750678 ["នៅទីកន្លែងដែលកើតមានឧក្រិដ្ឋកម្ម នាវត្តព្រះនេត្រព្រះ (ចម្ការតាលឹង) ក្នុងភូមិសំរោង ឃុំព្រះនេត្រព្រះ យើងបានជួបជាមួយសាក្សីមួយរូប មានឈ្មោះ ទុំ សឿន ភេទប្រុស អាយុ៤៥ឆ្នាំ កម្ពស់១ម៉ែត្រ៦០សង់ទីម៉ែត្រសក់ខ្មៅ មានសម្បុរស។ នៅក្នុងរបប ប៉ុល ពត គាត់រស់នៅក្នុងភូមិពយ សំរោង ឃុំព្រះនេត្រព្រះ ដែលជាទីកន្លែងគាត់កំពុងរស់នៅនាពេលសព្វថ្ងៃ។ គាត់បានឃើញប្រជាជនត្រូវគេសម្លាប់ចោលនៅតាមបណ្តាកន្លែងជាច្រើន ប៉ុន្តែនៅត្រង់ទីតាំងសម្រាប់ពិឃាតមនុស្សនៃកន្លែងដែលកើតមានឧក្រិដ្ឋកម្មស្ថិតក្នុងវត្តព្រះនេត្រព្រះនេះ គាត់បានចូលរួមនៅក្នុងការជីកគាស់កកាយរណ្តៅសាកសពនានា ដែលមានមុខកាត់ទំហំ៤ម៉ែត្រការេ និងជម្រៅ២ម៉ែត្រ។ រណ្តៅសាកសពនីមួយៗ មានផ្ទុកសាកសពចំនួនពី១០០ ទៅ១២០សាកសព។ យោងតាមសម្តីរបស់សាក្សីរូបនេះ ចំនួនមនុស្សដែលត្រូវបានសម្លាប់សរុបមានចំនួនប្រហែល ៦៦០ ទៅ ៧២០នាក់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ឯកសារនានាបានចង្អុលបង្ហាញថា មានសាកសពចំនួន ៤៦៧ប៉ុណ្ណោះ ហើយទីតាំងសម្រាប់ពិឃាតមនុស្សនៅចម្ការតាលឹងនោះ ស្ថិតនៅប្រមាណ៥០ ម៉ែត្រពីក្រោយវត្តព្រះនេត្រព្រះ"]។ ឯកសារ **D106/12** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788227 ["តាមការប៉ាន់ស្មានដំបូង មានមនុស្សប្រហែល៧០០នាក់ ត្រូវបានសម្លាប់នៅទីនោះ [នៅចម្ការតាឡឹង] ប៉ុន្តែសាកសពខ្លះអាចត្រូវបានដុតចោលនៅទីតាំងរណ្តៅសពទាំងនោះ [វត្តព្រះនេត្រព្រះ និងចម្ការតាឡឹង"]។

1311 ឯកសារ **D119/50.2** របាយការណ៍ពីការិយាល័យឃោសនាការស្រុកព្រះនេត្រព្រះ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៨៤ KH 00933220 ["សាកសព ២៥៣នាក់ នៅ 'ចម្ការ តាលឹង' (វាយ បាញ់ និងទំលាក់រណ្តៅ)"]។ ឯកសារ **D219/205** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៥ ឆ2.6 KH 01072293 [សាក្សីបានប្រមូលភ័ស្តុតាងសម្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំរបាយការណ៍ [ឯកសារ D1.3.10.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការចុះកំណត់ទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ ១៩៩៧៖ ខេត្តបន្ទាយមានជ័យ] នៅក្នុងខេត្តបន្ទាយមានជ័យ៖ "ចំនួន២៥៣នាក់ មិនរាប់បញ្ចូលក្នុងចំនួន៧២០នាក់ទេ។ ចំនួន៧២០នាក់នេះ គឺផ្អែកទៅលើចំនួនសាកសព ដែលគាស់ចេញពីរណ្តៅ"]។

1312 ឯកសារ D219/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ោ បណ្តែត ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.18 KH 01066319 [សាក្សីគឺជាមេក្រុមនៅក្នុងឃុំព្រះនេត្រព្រះ៖ "(មនុស្សត្រូវបានគេយកទៅសម្លាប់នៅ) ចម្ងាយប្រហែល១០០ ម៉ែត្រខាងក្រោយផ្ទះតាក្រក"]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.4 KH 00915839 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប ៖ "មានមនុស្សមួយចំនួនក្នុងចំណោមដែលគេយកទៅសម្លាប់ហ្នឹង បានរត់គេចខ្លួន ប៉ុន្តែប្រពន្ធ និងកូនរបស់ពួកគេ ត្រូវបានគេប្រមូលយកទៅសម្លាប់នៅក្បែរជើងភ្នំព្រះនេត្រព្រះ ដែលមានទីតាំងនៅខាងក្រោយផ្ទះ តា ក្រក ដែលនៅទីនោះ មានរណ្តៅសាកសពដ៏ធំមួយ"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.6 KH 00907517 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តនៅក្នុងឃុំព្រះនេត្រព្រះ៖ "ខ្ញុំបានឃើញគេបណ្តើរមនុស្សទាំងខ្សែៗដែលគេចាប់ខ្លួនមកពីភូមិផ្សេងៗ ហើយបានបញ្ជូនទៅសម្លាប់នៅក្រោយផ្ទះតាក្រកក្នុងភូមិប៉ោយក្មៀង"]។

1313 ឯកសារ **D119/46.2** ឧបសម្ព័ន្ធ ២ នៃរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ EN 00920242-00920243 [សំដៅទៅលើរូបថត 3 និង 4]។

1314 ឯកសារ D119/39 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ឌៀ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.5-8 KH 00915853-00915854 [សាក្សីធ្វើការនៅក្នុងកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ រួមបញ្ចូលទាំងទំនប់ត្រពាំងថ្ម៖ "ខ្ញុំបានទៅមើលដីចម្ការរបស់ខ្ញុំដែលស្ថិតនៅខាងជើងក្បែរផ្ទះតាក្រក។ […] ខ្ញុំបានឮគេនិយាយថា អ្នកដែលបានជាប់ពាក់ព័ន្ធនឹងយួន ហើយជាអតីតមន្ត្រីរាជការក្នុងរបបចាស់ និងទាហាន ត្រូវបានគេសម្លាប់ចោលទាំងគ្រួសារ។ […] អ្វីដែលខ្ញុំបានឃើញ ខ្ញុំអាចប៉ាន់ស្មានថា មានរាប់រយនាក់ដែលបានកប់នៅទីនោះ"]។ ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.24-25 KH 01024727-01024728 [សាក្សីរស់នៅក្នុងភូមិដកពោធិ៍ និងធ្វើការនៅក្នុងកងចល័តលើកភ្លឺស្រែនៅព្រះនេត្រព្រះ ស្រេះកំបោរ ព្រៃមាន់ អូរលៀប និងធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ស៖ នៅពេលដែលលោកស្រីរស់នៅភូមិដកពោធិ៍ តើលោកស្រីមានឃើញគេបណ្តើរមនុស្សយកទៅសម្លាប់នៅពេលយប់ដែរឬទេ? ឆ.24៖ ខ្ញុំបានឃើញគេចងមនុស្សបណ្តើរយកទៅទីនោះនៅពេលយប់។ ស៖ តើលោកស្រីឃើញមនុស្សត្រូវបានគេបណ្តើរយកទៅសម្លាប់ប៉ុន្មាននាក់នៅពេលនោះ? ឆ.25៖ ខ្ញុំឃើញគេចងបណ្តើរមនុស្សយកទៅសម្លាប់ប្រហែលជា១២នាក់នៅពេលយប់។ ខ្ញុំបានឃើញព្រឹត្តិការណ៍នេះនៅប្រហែល១ខែមុនរបបខ្មែរក្រហមដួលរលំ"]។ ឯកសារ D106/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00788228-00788229 ["ផ្ទះរបស់អនុគណៈឃុំឈ្មោះ តាក្រក […] អ្នកទោសត្រូវបាននាំយកទៅផ្ទះនោះនៅពេលថ្ងៃ ហើយត្រូវបានសម្លាប់នៅពេលយប់នៅក្នុងទីកន្លែងចំនួនពីរនៅក្បែរគ្នា និងមានចម្ងាយត្រង់មិនលើសពី ១០០០ ម៉ែត្រ ខាងជើងភាគខាងលិចពីផ្ទះតាក្រក"]។ ឯកសារ D106/11 របាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787417 ["ប្រជាជនប្រហែលជា២០០នាក់ ត្រូវបានសម្លាប់នៅទីនោះ ទាំងក្នុងពេលដែលតាក្រក ធ្វើជាគណៈស្រុក និងក្នុងពេលដែល អ៊ឹម ចែម បានកាន់កាប់តំណែងដូចគ្នានេះ ពីពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់វៀតណាមចូលមករំដោះ"]។ ឯកសារ D119/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុង ផារ៉ាត់ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.12 KH 00915840-00915841 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តកុមារនៅទំនប់កំបោរស្រេះ និងការដ្ឋានអូរលៀប ៖ "បើតាមខ្ញុំស្មាន គឺប្រហែលជាមាន

មនុស្សមួយចំនួនដែលត្រូវបានឃុំឃាំងនៅទីនោះ ក៏បានគេយកទៅសម្លាប់នៅទីនោះ នៅពេលយប់"]។ ឯកសារ D119/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៣ KH 00945878 ["ផ្ទះនោះជាផ្ទះរបស់អនុគណៈឃុំ ឈ្មោះ តាក្រក [...] ទីនោះជាកន្លែងដាក់អ្នកទោសនៅពេលថ្ងៃ ហើយអ្នកទោសទាំងនោះត្រូវបានសម្លាប់នៅពេលយប់នៅក្នុងទីតាំងចំនួនពីរនៅជិតគ្នា"]។

1315 ឯកសារ D5/1547 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឈិត វ័ន្ត ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៣ KH 01093384-01093385 [សាក្សីធ្វើការនៅកងចល័តនៅក្នុងស្រុកព្រះនេត្រព្រះ៖ "ឆ្នាំ ១៩៧៨ [...] ការដ្ឋានរបស់នាងខ្ញុំនៅមិនឆ្ងាយប៉ុន្មានម៉ែត្រទេពីមន្ទីរឃុំឃាំងវត្តព្រះនេត្រព្រះ។ [...] ពេលថ្ងៃ ពេលព្រឹក ពេលយប់ លឺតែស្នូរសំឡេងស្រែកអូយៗនោះតែម្តង"]។ ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.19 KH 01024727 [សាក្សីរស់នៅក្នុងភូមិដកពោធិ៍ និងធ្វើការនៅក្នុងកងចល័តលើកភ្លឺស្រែនៅព្រះនេត្រព្រះ ស្រះ កំបោរ ព្រៃមាន់ អូរលៀប និងធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ប្រហែល១ខែជិតបែករបបខ្មែរក្រហម ខ្ញុំបានឮមនុស្សស្រែកដោយសារគេយកទៅសម្លាប់ស្ទើររៀងរាល់យប់"]។

1316 ឯកសារ **D106/11** របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១២ KH 00787417 ["ទីតាំងសម្លាប់មនុស្សគឺនៅចម្ការដូង និងចំការឃាយនឹង នៅភូមិប៉ោយគ្រៀង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ។ [...] គេបានប្រាប់យើងថា ប្រជាជនដែលត្រូវបានសម្លាប់នៅទីតាំងទាំងនេះគឺជាប្រជាជនថ្មី ឬកម្មាភិបាលភូមិភាគពាយ័ព្យ ហើយពួកគេត្រូវបានចាប់ខ្លួននៅពេលថ្ងៃយកទៅផ្ទះតាក្រក ហើយយកទៅកន្លែងសម្រាប់នៅពេលយប់។ [...] អ្នកភូមិបានជីកកកាយរណ្តៅសាកសពដើម្បីរកមាស បន្ទាប់ពីការដួលរលំរបបប៉ុល ពត នៅឆ្នាំ ១៩៧៩។ សាកសពត្រូវបានគេដុតចោលនៅនឹងកន្លែង"]។

1317 ឯកសារ **D106/19** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919500 ["ព្រែកជីកស្ពានស្រែងចេញពីទិសខាងជើងស្ទឹងស្ពានស្រែង ស្ថិតក្នុងភូមិចារ ឃុំស្ពានស្រែង ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ"]។

1318 ឯកសារ **D1.3.28.4** ឯកសារ **D123/1/5.1a** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែមថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929735-00929736 ["ខ្ញុំរៀបចំធ្វើទំនប់ពីរ និងប្រឡាយមួយកាលខ្ញុំនៅហ្នឹង ហ្នឹងបន្តពីទំនប់ខាងក្រោមត្រពាំងថ្មមួយ។ សៈ ឈ្មោះទំនប់អីគេដែរអ៊ំ? ឆៈ ឈ្មោះទំនប់ស្ពានស្រែង [...]នៅខាងក្រោមត្រពាំងថ្មហ្នឹង"]។

1319 ឯកសារ **D119/129** កំណត់ហេតុនៃកិច្ចស៊ើបសួរ (របស់អ្នកស៊ើបអង្កេត Bernard Brun) ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ KH 01001321 ["យោងតាមសាក្សី កោ ឡិន "ស្ពានមេម៉ាយ" [...] [ទីតាំងលើ GPS N13'40.877 – E103'25.126] [...] ជាព្រំប្រទល់ស្រុកភ្នំស្រុកនៅខាងជើងស្ពាន និងស្រុកព្រះនេត្រព្រះនៅខាងត្បូងស្ពាន"]។

1320 ឯកសារ **D119/129** កំណត់ហេតុនៃកិច្ចស៊ើបសួរ (របស់អ្នកស៊ើបអង្កេត Bernard Brun) ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ KH 01001321 ["ផ្នែកខាងជើងនៃប្រឡាយនោះ បានសាងសង់រួច មុនពេល អ៊ឹម ចែម និងកម្មាភិបាលនិរតីបានមកដល់"]។

1321 ឯកសារ **D119/129** កំណត់ហេតុនៃកិច្ចស៊ើបសួរ (របស់អ្នកស៊ើបអង្កេត Bernard Brun) ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ KH 01001321 ["យោងតាមសាក្សី កោ ឡិន "ស្ពានមេម៉ាយ" [...] [ទីតាំងលើ GPS N13'40.877 – E103'25.126] [...] ជាព្រំប្រទល់ស្រុកភ្នំស្រុក [...] និងស្រុកព្រះនេត្រព្រះ"]។ ឯកសារ **D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ

កាន់ ហៅ ញ៉ុន ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.70 KH 00980392 [សាក្សីគឺជាមេឃុំភ្នំលៀប៖ គេហៅប្រឡាយនោះថា "ការដ្ឋានប្រឡាយស្ពានស្រែង"]។ ឆ.72 KH 00980392 ["ប្រឡាយស្ពានស្រែងគឺចាប់ពីស្ពានស្រែងចុះពីជើងទៅត្បូងកាត់តាមផ្លូវជាតិលេខប្រាំមួយទៅកាន់ឃុំប្រាសាទ។ ប្រឡាយនោះមានចម្ងាប្រហែល មួយគីឡូម៉ែត្រខាងកើតភ្នំលៀប"]។ ឯកសារ **D119/64.1** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទុំ សឿន ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១ KH 00951761 [សាក្សីគឺជាប្រធានកងចល័តដែលមានសមាជិក៣០០នាក់ និងបានក្លាយជាប្រធានមន្ទីរសន្តិសុខភ្នំត្រយ៉ូង៖ "ដារ៉ា៖ ហើយអំពីភ្នំលៀបទៅកន្លែងប្រឡាយនឹង [ប្រឡាយស្ពានស្រែង]ឆ្ងាយទេ? សឿន ៖ វាល មើលឃើញ ប៉ុនពីចម្ងាយដីនឹង ភ្លេច ហើយប៉ាន់ស្មាន។ ពីភ្នំលៀបនឹងទៅដីខ្ពង់៥គីឡូដល់មើលពីភ្នំលៀបទៅឃើញ នៅវែតាមផ្លូវ១ចុះវាលដី"]។ ឯកសារ **D251/4** សេចក្ដីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្ដីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ឬបុគ្គលម្នាក់ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៥ KH 01173007 ["ទំនប់ស្ពានស្រែង និងទំនប់ព្រៃរនាម" ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានពិពណ៌នា ស្របគ្នាទៅនឹងអ្វីដែលអ្នកស៊ើបអង្កេតបានហៅថា "ប្រឡាយស្ពានស្រែង" និង "អាងស្ដុកទឹកព្រៃរនាម" នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ"]។ ឯកសារ **D106/19** របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919499 [បញ្ជាក់ថា ការដ្ឋានស្ពានស្រែងរួមបញ្ចូលទាំងឃុំភ្នំលៀប និងឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ព្រមទាំងឃុំស្ពានស្រែង ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ]។ ឯកសារ **D106/19.4** ផែនទីនៃការដ្ឋានទំនប់ស្ពានស្រែង និងទំនប់ព្រៃរនាម។ ឯកសារ **D219/357** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ5.9 KH 01104645 [សាក្សីគឺជាកម្មករក្នុងកងចល័តនៅព្រះនេត្រព្រះ រួមទាំងនៅទំនប់ស្ពានស្រែង (ឆ្នាំ ១៩៧៨) និងនៅព្រៃរនាម៖ "ស៖ នៅពេលដែលពួកនិរតីមកដល់អំឡុងឆ្នាំ ១៩៧៧ ឬ១៩៧៨ តើលោកធ្វើការនៅទីកន្លែងណា? ឆ៖ នៅពេលនោះ [...] គេបានបញ្ជូនខ្ញុំឱ្យទៅលើកទំនប់ ជីកប្រឡាយនៅការដ្ឋានស្ពានស្រែង ដែលមានទីតាំងនៅស្រុកភ្នំស្រុក "]។ ឯកសារ **D219/141** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យក់ នាម ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៥ ឆ8.7 KH 01056110 [សាក្សីគឺជាកម្មករកងចល័ត៖ "គេជីក [ប្រឡាយស្ពានស្រែង] នៅក្រោយពេលពួកនិរតីមកដល់ ។

1322 ឯកសារ **D106/19** របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919501 ["ស្ពានស្រែងត្រូវបានសាងសង់ដើម្បីបង្ហូរទឹកពីអាងស្ដុកទឹកព្រៃរនាមយកទៅស្រោចស្រពស្រែស្រូវប្រាំង"]។ ឯកសារ **D219/264.1** ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107030 ["អ៊ឹម ចែម៖ ផ្លូវជាតិលេខ ៦ ទឹកកម្រាស់នេះ កាលខែទឹកជំនន់ ត្រឹមឡានបរអត់រួចក៏មានដែរ កាលពីជំនាន់មុនណា។ ដល់តែខ្ញុំជីកប្រឡាយហ្នឹង ទៅដល់ខាងកើតភ្នំលៀបហ្នឹងណា ចុះពីស្ពានតាប៉ុនទៅ ឃើញប្រឡាយមួយធំហើយវែង ហ្នឹងប្រឡាយខ្ញុំ"]។ ឯកសារ **D119/97** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លន់ រួប ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.15 KH 00978905 [សាក្សីគឺជាកម្មករនៅកងចល័តនៅទំនប់ស្ពានស្រែងក្នុងអំឡុងឆ្នាំ ១៩៧៧-១៩៧៨៖ "ពួកខ្មែរក្រហមសាងសង់ទំនប់ និងប្រឡាយស្ពានស្រែងនេះដើម្បីយកទឹកធ្វើស្រែប្រាំង។ ប្រឡាយស្ពានស្រែងនេះត្រូវយកទឹកពីស្ទឹងស្ពានស្រែងដែលយកទឹកមកពីភ្នំដងរែក"]។ ឯកសារ **D119/32** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ.37 KH 00907517 [សាក្សីគឺជាគណៈឃុំព្រះនេត្រព្រះ៖ "[ស្ពានស្រែង] ជាទំនប់ទប់ទឹកសម្រាប់ធ្វើស្រែប្រាំង"]។ ឯកសារ **D119/65** កំណត់ហេតុនៃការ

ស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.135-136 KH 00953038 [សាក្សីគឺជាប្រធានកងចល័តដែលមានសមាជិក ៣០០នាក់ និងបានក្លាយជាមេមន្ទីរសន្តិសុខភ្នំត្រយ៉ូង៖ ឆ.135៖ "ក្រោយពេលវៀតណាមចូលមក ខ្ញុំបានរត់ទៅស្វាយចេក ឧត្តរមានជ័យ ខ្ញុំឃើញក្បាលទឹកហូរមកពីភ្នំដងរែក។ ស៖ តាមគម្រោងនោះ គឺត្រូវជីកទម្លុះផ្ទល់ ហើយដាក់លូដើម្បីបង្ហូរទៅត្បូងតើមែនទេ? ឆ.136៖ បាទ ដើម្បីបង្ហូរទឹកទៅក្រោមហៅព្រៃរនាម"]។ ឯកសារ **D215/1.1.1** កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ EN 01030495 ["បន្ទាប់ពីប្រឡាយនេះត្រូវបានបញ្ចប់ យើងធ្វើស្រែនៅរដូវប្រាំង"] EN 01030495 [" ប្រឡាយនេះ [...] ការពារឃុំទឹកជោរ និងឃុំភ្នំលៀបពីទឹកជំនន់ពីបឹងទន្លេសាប"] EN 01030495 ["បន្ទាប់ពីប្រឡាយនេះត្រូវបានបញ្ចប់ យើងធ្វើស្រែនៅរដូវប្រាំង"] EN 01030495 [" ប្រឡាយនេះ [...] ការពារឃុំទឹកជោរ និងឃុំភ្នំលៀបពីទឹកជំនន់ពីបឹងទន្លេសាប"] EN 0997077 ["ប្រឡាយនេះមានទំហំធំ។ ពីម្ខាងទៅម្ខាងមានទំហំ ៣០ម៉ែត្រ និងជម្រៅ ១៥ម៉ែត្រ។ វាជួយការពារឃុំទឹកជោរ និងឃុំភ្នំលៀបពីទឹកជំនន់មកពីបឹងទន្លេសាប។ បន្ទាប់ពីប្រឡាយនេះត្រូវបានបញ្ចប់ យើងធ្វើស្រែនៅរដូវប្រាំង"]។ ឯកសារ **D123/1/5.1a** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929737 ["ខ្ញុំដឹងថា ស្រុកព្រះនេត្រព្រះហ្នឹងប្រជាជនថា ខែវស្សាឡើងទឹកឡើងលិចផ្លូវជាតិលេខ៦ ត្រឹមជង្គង់ ហើយចាស់ៗគាត់ស្រឡាញ់ខ្ញុំ គាត់មានយោបល់ថា បើក្មួយឯងធ្វើប្រឡាយ ជីកផ្តាច់អាផ្លូវជាតិលេខ៦ គឺប្រជាជននៅសងខាងហ្នេះ ឃុំទឹកជោរ ឃុំប្រាសាទ និងឃុំភ្នំលៀប អាហ្នឹងច្បាស់ជារស់បានស្រួល មិនមានទឹកលិច។ ចឹងសួរគាត់ថា បើជីកប្រឡាយជីកប៉ុន្មាន? គាត់ថា ដាក់មាត់ ៣០ (ម៉ែត្រ) ដាក់មាត់ ៣០ ចឹងតួប្រឡាយមាត់ ៣០ អាបាតក្រោមវា ១៥ កណ្តាល ២០ ចឹងមក មាត់លើ ៣០។ ចឹងយកអាចម៍ដាក់មកលើ ខែវស្សាឡើង គាត់ជញ្ជូនអ្នកដែលនៅជាប់ហ្នឹងមាត់ស្ទឹងហ្នេះ គាត់ជញ្ជូនគោ ជ្រូក មាន់ទា យកមកដាក់លើប្រឡាយហ្នឹង ដាក់លើប្រឡាយហ្នឹង។ ដល់ខែវស្សាឡើង ទឹកវាចេញរាជពីទំនប់ ដែលខ្ញុំទប់ពីត្រង់នោះមកហើយទឹកវាមកតាមចិត្ត ដល់មកចឹងវាចូលពេញប្រឡាយ ១០ គីឡូម៉ែត្រ ខ្ញុំធ្វើអាតួប្រឡាយហ្នឹង ១០ គីឡូម៉ែត្រ បានហូរចូលទៅអាមួយទៀត"]។ ឯកសារ **D123/1/5.1b** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929789 ["ចែម៖ អាប្រឡាយមួយដែលធ្វើហ្នឹង ហើយខ្ញុំហ្នឹងខ្ញុំធ្វើហ្នឹងតែ ៣ ខែទេ។ ដានី៖ គេហៅអីគេប្រឡាយហ្នឹង? ចែម៖ ប្រឡាយភ្នំលៀប ភ្នំលៀបមើលទៅឃើញត្រង់ជើងត្បូងហ្នឹងណា"]។

1323 ឯកសារ **D219/397** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ិន សុខ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.6 KH 01114726 [អតីតនីរសាររបស់ អ៊ឹម ចែម៖ "ប្រឡាយដែល អ៊ឹម ចែម បានធ្វើគឺបែកជា ២ គឺ មួយដែលធ្វើចេញពីប្រឡាយអូរលៀប កាត់តាមផ្លូវថ្នល់ពីប៉ោយចារលើទៅប៉ោយចារក្រោម បត់ទៅរកអូររំចេក ហើយនិងទៅភ្នំស្រុក គឺជាប្រឡាយចាស់ ហើយប្រឡាយមួយទៀតដែលធ្វើចេញពីប្រឡាយអូរលៀប កាត់តាមផ្លូវថ្នល់ពីប៉ោយចារលើទៅប៉ោយចារក្រោម ហើយឆ្ពោះទៅស្ទឹងស្ពែនស្រែងគឺជាប្រឡាយថ្មី"]។ ឯកសារ **D123/1/2.53** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៊ូ ម៉ៅ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00730239 [ប្រធានកងចល័តដែលមានកម្មករ ៣០ នាក់ ដែលត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅស្ពានស្រែង៖ "ម៉ៅ៖ ដូចគ្នា ដកមនុស្សពីនោះមក ពីភូមិរោងមក ពីភ្នំស្រុកមកទល់ព្រៃមាន់ ធ្វើប្រឡាយហ្នឹងធ្វើមួយអាទិត្យប្រឡាយហ្នឹងគេធ្វើមួយអាទិត្យហើយ ហើយបានគេលើកអាង [អូរលៀប] ហ្នឹង [...] រយៈពេលឆ្នាំដែលវៀតណាមចូលហ្នឹងឯង [...] ៧៨-៧៩ ហ្នឹងឯង"]។ ឯកសារ **D1.3.28.4** ឯកសារ **D123/1/5.1a** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុ

ជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929736 ["ចែម៖ ហើយអូរជីកហ្នឹងវាជាប់ហ្នឹងស្ពានស្រែង អាស្ទឹងតាប៉ុនណា ស្ទឹងជាប់ប្រឡាយ។ ចឹងស្ទឹងហ្នឹងវាទៅទល់ហ្នឹងស្ទឹងអូរជីកនេះ។ អាពីតាប៉ុនមក វាមកជាប់ហ្នឹងស្ទឹងស្ពានស្រែងហ្នឹង ដល់ស្ទឹងស្ពានស្រែងហ្នឹង វាហូរមកអូរជីក ចឹងខ្ញុំទប់អាក្បាល ទប់អាក្បាលហ្នឹងហើយ ប្រឡាយមួយជីកចេញពីទំនប់ត្របាំងថ្មដល់ខ្ញុំទប់អា ១០ គីឡូខាងជាប់ព្រៃរនាម ព្រោះដីហ្នឹងដីទំនេរ ចឹងទប់អាហ្នឹង កាត់ចឹងហើយ ជីកប្រឡាយក្បាល ៣០ ម៉ែត្រមកសំដៅមកទំនប់មួយនេះត្រង់អាហ្នឹង ចឹងមកទាំងកំភ្លាញ ត្រីកេះ ត្រីរ៉ស់អី ប្រជាជនសម្បូរណាស់កាលហ្នឹង។ ឥឡូវប្រឡាយហ្នឹងរក្សាមកជាប់រាល់ថ្ងៃ ត្រង់មើលទៅដល់ខាងកើតភ្នំលៀប មើលទៅដាច់កន្ទុយភ្នែកហ្នង អាហ្នឹងអាហ្នឹង ហើយខ្ញុំនៅហ្នឹង"]។

1324 ឯកសារ **D106/19** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ KH 00919500 ["ព្រែកជីកស្ពានស្រែង [...] មានប្រហែលប្រហែលពី ៨-១០ គីឡូម៉ែត្រ [...] ចុងព្រែកជីកនេះ ត្រូវបានភ្ជាប់អាងស្តុកទឹកព្រៃរនាម ដោយមានស្ពានមួយកាត់ផ្លូវជាតិលេខ ៦ ត្រង់ចំណុចទីតាំង GPS N13.35.681–E103.22.970"]។ ឯកសារ **D219/264.1** ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107030-01107031 ["អ៊ឹម ចែម៖ [ប្រឡាយនេះ] ទៅដល់ខាងកើតភ្នំលៀបហ្នឹងណា ចុះពីស្ពានតាប៉ុនទៅ ឃើញប្រឡាញមួយធំហើយវែង ហ្នឹងប្រឡាយខ្ញុំ។ មានប្រឡាយមួយនៅរាល់ថ្ងៃហ្នឹង ខ្ញុំទៅធ្វើបានប្រឡាយមួយហ្នឹងចាស" [...] "អ៊ឹម ចែម៖ ប្រឡាយ ៨គីឡូ ប្រឡាយហ្នឹងទម្លុះផ្លូវជាតិលេខ ៦ ដាក់ធ្វើទ្វារទឹក"]។ ឯកសារ **D215/1.1.1** កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ EN 00997077 ["ប្រឡាយនេះមានទីតាំងស្ថិតនៅខាងកើតឃុំភ្នំលៀប [...] ប្រឡាយដែលមានប្រវែង ៩ គីឡូម៉ែត្រនេះ ត្រូវចំណាយពេលប្រហែលបីខែដើម្បីបញ្ចប់ការសាងសង់"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឆ.10-11 KH 01058726 [សាក្សីគឺជាកម្មករនៅកងចល័តនៅប្រឡាយស្ពានស្រែង៖ "ការដ្ឋាននេះគឺជាកន្លែងជីកប្រឡាយ ដែលលាតសន្ធឹងពីខាងលិចស្ពានតាប៉ុន ត្រង់ផ្លូវជាតិលេខ ៦ រហូតដល់ស្ពានស្រែង ខាងកើតភូមិគោកធំ នៅក្នុងឃុំភ្នំដី ស្រុកភ្នំស្រុក។ ស៖ ប្រឡាយស្ពានស្រែងវាវែង តើក្រុមរបស់លោកគេឲ្យធ្វើការនៅកន្លែងណា? ឆ.11៖ គឺមិនទៀង ដោយសារពេលកងយើងធ្វើចប់ចំណុចណាមួយ គេផ្លាស់ទៅចំណុចថ្មីមួយផ្សេងទៀត នៅតាមបណ្តោយប្រឡាយនោះ។ ស៖ តើលោកចាំទេថា ចូលរួមជីកប្រឡាយស្ពានស្រែងនោះប្រហែលប៉ុន្មានខែដែរ? ឆ.12៖ [...] គឺប្រហែលពេញមួយរដូវប្រាំង"]។ ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.98 KH 00953033 [សាក្សីគឺជាប្រធានកងចល័តដែលមានសមាជិក ៣០០នាក់ និងបានក្លាយជាប្រធានមន្ទីរសន្តិសុខភ្នំត្រយ៉ូង៖ ឆ.98៖ "ប្រឡាយនោះបែកចេញពីផ្លូវភ្នំស្រុក ទៅភូមិចារ ក្នុងឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ហើយចេញពីមុខភូមិចារទៅផ្លូវជាតិលេខ៦ ហើយចេញពីផ្លូវជាតិលេខ៦ ធ្លាក់ទៅរនាមក្រោម។ ប្រឡាយនោះនៅតាមដងស្ទឹងខាងលិចវត្តតាប៉ុន ប្រហែលបួនប្រាំគីឡូម៉ែត្រ។ ស៖ តើប្រឡាយនោះឈ្មោះអ្វី? ឆ.99៖ អត់មានឈ្មោះទេ [...] ឆ.103៖ ចាប់ជីកពីខែមួយ [ឆ្នាំ ១៩៧៨] ដល់ខែប្រាំ គេដកខ្ញុំចេញ [ទៅភ្នំលៀប]"]។

1325 ឯកសារ **D119/95** កំណត់ហេតុនៃកិច្ចស៊ើបសួរ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ EN 00976186 [អះអាងថា អតីតផ្ទះដែលត្រូវបានកាន់កាប់ដោយ អ៊ឹម ចែម ក្នុងអំឡុងសម័យខ្មែរក្រហមមានចំណាយ ២,៨ គីឡូម៉ែត្រពីការដ្ឋានប្រឡាយស្ពានស្រែងជាទីដែលប្រឡាយស្ពានស្រែងជួបប្រសព្វជាមួយអាងព្រៃរនាម]។ ឯកសារ **D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.36 KH 00978913 [សាក្សីបានដឹកនាំកងចល័តដែលមានសមាជិក ២០០ នាក់នៅស្ពានស្រែង និងអាងអូរលៀប៖ "យាយ ចែម រស់នៅ និងធ្វើការនៅមន្ទីរភ្នំលៀប"]។ ឯកសារ **D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.21 KH 00976167 [សាក្សីបានធ្វើការនៅអូរលៀប៖ "យាយ ចែម រស់នៅភ្នំលៀប"]។ ឯកសារ **D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.72 ឆ.76 KH 00998145 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តក្នុងស្រុកព្រះនេត្រព្រះ រួមទាំងនៅអូរលៀប និងឃុំភ្នំលៀប និងឃុំប្រាសាទ៖ ឆ.72៖ "[កេង ដែលជាគ្រូថ្នាំបុរាណ និងជាអតីតព្រះសង្ឃ] ប្រាប់ខ្ញុំថា គេចាប់ខ្លួនគាត់ដាក់នៅផ្ទះមួយនៅភ្នំលៀប ដែលស្ថិតនៅខាងជើងផ្លូវជាតិលេខ ៦"]។ ឆ.76៖ ["[...] គាត់មិនបានប្រាប់ខ្ញុំថាមានមនុស្សប៉ុន្មាននាក់ត្រូវបានឃុំនៅទីនោះទេ [ប៉ុន្តែគេបានឲ្យគាត់] ទៅព្យាបាល [សាច់ញាតិរបស់ អ៊ឹម ចែម]។ ទើបក្រោយមក គាត់ត្រូវបានគេដោះលែងវិញ"]។ ឯកសារ **D119/154** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីវ ម៉ារ៉ា ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.38-39 KH 01024749 [សាក្សីគឺជាកម្មករនៅកងចល័តនៅព្រះនេត្រព្រះ៖ "ឆ.38៖ នៅពេលនោះ គិត [ជាប្រធានភូមិជញ្ជាំង និងជាកម្មាភិបាលនិរតី]" បានចាប់ពួកយើងប្រហែល ៦ ឬ ៧ នាក់ ហើយដឹកតាមគោយន្តឲ្យទៅផ្ទះយាយចែម ដែលមានទីតាំងនៅភ្នំលៀបក្នុងគោលបំណងបញ្ជូនយើងទៅភ្នំត្រយ៉ូង [...]។ ស៖ តើលោកស្រីត្រូវបានគេបញ្ជូនទៅគុកភ្នំត្រយ៉ូងដែរឬទេ? ឆ.39៖ អត់ទេ គិត បញ្ជូនយើងត្រឹមតែផ្ទះយាយ ចែម តែប៉ុណ្ណោះ"]។

1326 ឯកសារ **D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ KH 00998152 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តក្នុងស្រុកព្រះនេត្រព្រះ រួមទាំងនៅអូរលៀប និងឃុំភ្នំលៀប និងឃុំប្រាសាទ៖ "ស៖ តើលោកស្គាល់ប្រឡាយស្ពានស្រែង ឬក៏ប្រឡាយអូរលៀបដែរឬទេ? ឆ.121៖ បច្ចុប្បន្នគេហៅថាប្រឡាយអូរលៀប ហើយមានប្រភពទឹកចេញពីស្ពានស្រែង"], ឯកសារ KH 00998135 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តក្នុងស្រុកព្រះនេត្រព្រះ រួមទាំងនៅអូរលៀប និងឃុំភ្នំលៀប និងឃុំប្រាសាទ៖ "ស៖ តើទំនប់អូរលៀបដែលលោកធ្វើការនោះ ស្ថិតនៅខាងត្បូង ឬខាងជើងផ្លូវជាតិលេខ ៦? ឆ.13៖ កន្លែងខ្ញុំធ្វើការស្ថិតនៅខាងជើងផ្លូវជាតិលេខ ៦"], KH 00998135 ["ស៖ តើការដ្ឋានទំនប់អូរលៀប ដែលលោកធ្វើការ គេហៅថាទំនប់ស្ពានស្រែងឬ? ឆ.11៖ មិនមែនទេ កន្លែងខ្ញុំធ្វើការគឺនៅក្នុងឃុំភ្នំលៀប ហើយទំនប់ស្ពានស្រែងមានទីតាំងនៅក្នុងឃុំទឹកជោរ"]។ ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.70 KH 01104646 [សាក្សីគឺជាកម្មករក្នុងកងចល័តនៅព្រះនេត្រព្រះ រួមទាំងនៅទំនប់ស្ពានស្រែង (ឆ្នាំ ១៩៧៨) និងនៅព្រៃរនាម៖ "ប្រឡាយអូរលៀបក៏ជាផ្នែកមួយនៃប្រឡាយស្ពានស្រែងដែរ ប៉ុន្តែប្រឡាយអូរលៀបនេះបានសាងសង់ចេញពីស្ពានធំ ដែលស្ថិតក្នុងភូមិរោគឆ្ពោះទៅកាន់អូរលៀបដែលនៅក្នុងឃុំភ្នំលៀប"]។ ឯកសារ **D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ហៅ ញ៉ុន ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.70 KH 00980392 [សាក្សីគឺជាមេឃុំភ្នំលៀប៖ "ស៖ លោកដឹងទេថា តើការដ្ឋានជីកប្រឡាយនោះឈ្មោះអ្វី? ឆ.70៖ ខ្ញុំដឹងមិនច្បាស់ទេ ប៉ុន្តែគេហៅប្រឡាយនោះថា "ការដ្ឋានប្រឡាយស្ពានស្រែង"] KH 00980389 ឆ.46៖["នៅពេលដែលខ្ញុំធ្វើជាគណៈឃុំភ្នំលៀប ខ្ញុំធ្លាប់បាននាំមនុស្សទៅធ្វើការនៅការដ្ឋានប្រឡាយមួយដែលស្ថិតនៅខាងកើតផ្ទះរបស់ខ្ញុំ ចាប់ពីស្ពានស្រែង ដែលស្ថិតនៅខាងជើងឆ្ពោះទៅខាងត្បូងឆ្លងកាត់ផ្លូវជាតិលេខប្រាំមួយទៅកាន់ឃុំប្រាសាទ"] KH 00980389 ឆ.48៖ ["[...] យើងត្រូវចំណាយពេលជិតពីរខែ ដើម្បីបញ្ចប់ការដ្ឋានជីកប្រឡាយនោះ ដែលមានប្រវែងប្រហែលជាប្រាំទៅប្រាំ

មួយគីឡូម៉ែត្រ"]។ ឯកសារ **D119/99** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ KH 00978921 [សាក្សីគឺជាកម្មករនៅកងចល័តនៅអូរលៀប៖ "ឆ.25៖ ការដ្ឋានប្រឡាយអូរលៀបដែលខ្ញុំធ្លាប់បានធ្វើការ មានចម្ងាយប្រហែលជាពីរគីឡូម៉ែត្រ ខាងកើតភ្នំលៀបដែលស្ថិតនៅចន្លោះភ្នំលៀប និងស្ពានតាប៉ុន។ ស្ពានតាប៉ុន គឺជាស្ពានដែលឆ្លងកាត់ស្ទឹងក្រឡាញ់ ឬស្ទឹងស្ពានស្រែង ដែលជាព្រំប្រទល់រវាងស្រុកព្រះនេត្រព្រះ និងស្រុកក្រឡាញ់។ ឆ.24៖ ខ្ញុំមិនធ្លាប់ធ្វើការនៅទំនប់ត្រពាំងថ្ម និងទំនប់ស្ពានស្រែងទេ តែខ្ញុំធ្លាប់បានធ្វើការនៅប្រឡាយអូរលៀប"]។ ឯកសារ **D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ឆ.29 KH 00978912 [សាក្សីបានដឹកនាំកងចល័តដែលមានសមាជិក ២០០ នាក់នៅស្ពានស្រែង និងអាងអូរលៀប៖ "កងចល័តឃុំរបស់ខ្ញុំបានបញ្ចប់ការលើកទំនប់ស្ពានស្រែង ហើយត្រូវបានផ្លាស់ទៅការដ្ឋានធ្វើអាងអូរលៀប"]។ ឯកសារ **D219/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.98 KH 01029678 [សាក្សីគឺជាសមាជិកគណៈស្រុកព្រះនេត្រព្រះ៖ "វា [ប្រឡាយស្ពានស្រែង] មានចម្ងាយប្រហែលជា ៣ គីឡូម៉ែត្រ ដែលស្ថិតនៅខាងជើងភ្នំលៀប"]។ ឯកសារ **D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ KH 00976167 [សាក្សីបានធ្វើការនៅអូរលៀប៖ "សៈ តើលោកដឹងថា ទីតាំងការដ្ឋានទំនប់អូរលៀបនៅទីកន្លែងណា? ឆ.24៖ ទីតាំងទំនប់អូរលៀបដែលខ្ញុំធ្វើការនោះ គឺនៅខាងត្បូងថ្នល់ជាតិលេខ ៦ ហើយមានចម្ងាយប្រហែល ៣ គីឡូម៉ែត្រខាងកើតភ្នំលៀប។ សៈ លោកធ្វើការនៅខាងត្បូងថ្នល់នៃការដ្ឋានទំនប់អូរលៀប ហើយទំនប់អូរលៀបនេះ ក៏មាននៅខាងជើងថ្នល់ដែរ។ តើលោកអាចដឹងពីចំនួនអ្នកធ្វើការនៅការដ្ឋាននេះបានឬទេ? ឆ25.៖ ខ្ញុំមិនដឹងចំនួនពិតប្រាកដទេ តែមានអ្នកធ្វើការរាប់ពាន់នាក់នៅការដ្ឋាននេះ។ ប្រជាជនត្រូវបានគេយកមកគ្រប់ឃុំទាំងអស់ ក្នុងតំបន់ ៥ មកធ្វើការនៅការដ្ឋាននេះ"] KH 00976168 ["សៈ តើលោកដឹងថា ការដ្ឋានទំនប់អូរលៀបមានឈ្មោះអ្វីផ្សេងទៀតទេ? ឆ.31៖ ទេ ខ្ញុំដឹងថា ជាទំនប់អូរលៀបប៉ុណ្ណោះ"]។ ឯកសារ **D119/152** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ឆ.37 KH 01024730 [សាក្សីគឺជាកម្មករនៅកងចល័តនៅទំនប់អូរលៀប៖ "សៈ លោកស្រីនិយាយថា លោកស្រីធ្វើការនៅទំនប់អូរលៀប តើលោកស្រីធ្វើការនៅកន្លែងណា? ឆ.37៖ ខ្ញុំធ្វើការនៅខាងជើងតាមបណ្តោយផ្លូវជាតិលេខ ៦ ដែលមានទីតាំងនៅខាងលិចភ្នំលៀប"]។ ឯកសារ **D123/1/2.44** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម គឹមរស់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00927076 [សាក្សីគឺជាកម្មករនៅកងចល័តនៅទំនប់ស្ពានស្រែងក្នុងឆ្នាំ ១៩៧៨៖ "៧៨ បានលើកនៅឯណោះទៀត ឆ្នាំ ៧៨ លើកទំនប់ដង្កៀបក្តាម អាផ្លូវអូរលៀស [លៀប] នោះបានឆ្លងទៅណោះខាងកើតភ្នំស្រុក បាននៅឯណុះ ទៅឯស្ពានស្រែងណុះ"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ19. KH 01049193 [សមាជិកគណៈឃុំ និងជាអ្នកយាមគុកនៅតំបន់ ៥ រួមទាំងនៅប្រឡាយអូរលៀប៖ "សៈ នៅពេលដែលលោកយាមមនុស្សធ្វើការនៅប្រឡាយអូរលៀប តើប្រឡាយនោះមានទីតាំងនៅខាងណាផ្លូវជាតិលេខ៦? ឆ.19៖ ប្រឡាយនោះមានទីតាំងស្ថិតនៅខាងត្បូងផ្លូវជាតិលេខ ៦ ហើយដែលប្រឡាយអូរលៀបនោះបានធ្វើ បានបន្តរហូតដល់ដង្កៀបក្តាម"]។ ឯកសារ **D123/1/5.1a** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929737 ["ខ្ញុំដឹងថា ស្រុកព្រះនេត្រព្រះហ្នឹងប្រជាជនថា ខែវស្សាឡើងទឹកឡើងលិចផ្លូវជាតិលេខ៦ ត្រឹមជង្គង់ ហើយចាស់ៗគាត់ស្រឡាញ់ខ្ញុំ គាត់មានយោបល់ថា បើក្មួយឯងធ្វើប្រឡាយ ជីកផ្តាច់អាផ្លូវជាតិលេខ៦ គឺប្រជាជននៅសងខាងហ្នេះ ឃុំទឹកជោរ ឃុំប្រាសាទ និងឃុំភ្នំលៀប អាហ្នឹងច្បាស់ជារស់បានស្រួល មិនមានទឹកលិច។ ចឹងសួរគាត់ថា បើជីក

ប្រឡាយជីកប៉ុន្មាន? គាត់ថា ដាក់មាត់ ៣០ (ម៉ែត្រ) ដាក់មាត់ ៣០ ចឹងតួប្រឡាយមាត់ ៣០ អាបាតក្រោមវា ១៥ កណ្តាល ២០ ចឹងមក មាត់លើ ៣០។ ចឹងយកអាចម៍ដាក់មកលើ ខែវស្សាឡើង គាត់ជញ្ជូនអ្នកដែលនៅជាប់ហ្នឹងមាត់ស្ទឹងហ្នេះ គាត់ជញ្ជូនគោ ជ្រូក មាន់ទា យកមកដាក់លើប្រឡាយហ្នឹង ដាក់លើប្រឡាយហ្នឹង។ ដល់ខែវស្សាឡើង ទឹកវាចេញរាជពីទំនប់ ដែលខ្ញុំទប់ពីត្រង់នោះមកហើយទឹកវាមកតាមចិត្ត ដល់មកចឹងវាចូលពេញប្រឡាយ ១០ គីឡូម៉ែត្រ ខ្ញុំធ្វើអាតួប្រឡាយហ្នឹង ១០ គីឡូម៉ែត្រ បានហូរចូលទៅអាមួយទៀត"]។ ឯកសារ **D123/1/5.1b** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨ KH 00929789 ["ចែម៖ អាប្រឡាយមួយដែលធ្វើហ្នឹង ហើយខ្ញុំហ្នឹងខ្ញុំធ្វើហ្នឹងតែ ៣ ខែទេ។ ដានី៖ គេហៅអីគេប្រឡាយហ្នឹង? ចែម៖ ប្រឡាយភ្នំលៀប ភ្នំលៀបមើលទៅឃើញត្រង់ជើងត្បូងហ្នឹងណា"]។ ឯកសារ **D123/1/2.41** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ក្រឹង រិត ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ KH 00927024 [សាក្សីគឺជាកម្មករនៅកងចល័តនៅទំនប់ស្ពានស្រែងក្នុងឆ្នាំ ១៩៧៨៖ "[...] ចប់ដាច់ស្រេចបិទវគ្គឆ្លងទៅអូរលៀប។ អាទំនប់អូរលៀបធំទទឹងចេះនេះ។ អូរលៀបនៅខាងនោះភ្នំលៀបនោះខាងកើតបៀតអូរលៀប។ ធានី៖ ព្រោះនៅកន្លែងភ្នំលៀបមានតែអូរមួយទេ ហៅអូរលៀប កន្លែងស្ពាន? រិត៖ នេះឯងស្ពាន [...]"]។ ឯកសារ **D219/212** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុប សុក ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥ ឆ.33-34 KH 01074066 [ជាកម្មករនៅកងចល័តក្នុងស្រុកព្រះនេត្រព្រះ៖ "ស៖ តើលោកធ្លាប់ឮឈ្មោះប្រឡាយអូរលៀប និងប្រឡាយស្ពានស្រែងដែរទេ? ឆ.33៖ ខ្ញុំមិនធ្លាប់ឮឈ្មោះប្រឡាយស្ពានស្រែងទេ ប៉ុន្តែខ្ញុំធ្លាប់ឮប្រឡាយអូរលៀបក្រោយពីខ្ញុំផ្លាស់ពីចល័តមកភូមិរបស់ខ្ញុំវិញ។ ស៖ តើលោកដឹងថានរណាជាអ្នកគ្រប់គ្រងប្រឡាយអូរលៀបដែរទេ? ឆ.34៖ ខ្ញុំមិនដឹងទេ"]។ *ផ្ទុយនឹង* ឯកសារ **D119/92** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.21 KH 00976156 [សាក្សីគឺជាកម្មករនៅកងចល័តដែលបានរស់នៅជិត តារុត (ដែលបានដឹងឮអំពីរឿងរ៉ាវរបស់ស្រុកព្រះនេត្រព្រះ)៖ "ប្រឡាយអូរលៀបមានចម្ងាយប្រហែល១គីឡូម៉ែត្រនៅខាងកើតភ្នំលៀប"]។

1327 សាក្សីមួយចំនួនក៏សំដៅទំនប់នេះថាជាទំនប់អូរលៀបផងដែរ។ *សូមមើល* ឯកសារ **D119/152** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ឆ.37 KH 01024730 [សាក្សីគឺជាកម្មករនៅកងចល័តនៅទំនប់អូរលៀប៖ "ស៖ លោកស្រីនិយាយថា លោកស្រីធ្វើការនៅទំនប់អូរលៀប តើលោកស្រីធ្វើការនៅកន្លែងណា? ឆ.37៖ ខ្ញុំធ្វើការនៅខាងជើងតាមបណ្តោយផ្លូវជាតិលេខ៦ ដែលមានទីតាំងនៅខាងលិចភ្នំលៀប"]។ ឯកសារ **D219/127** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាង សល់ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.19 KH 01049193 [សមាជិកគណៈឃុំ និងជាអ្នកយាមគុកនៅតំបន់ ៥ រួមទាំងនៅប្រឡាយអូរលៀប៖ "ស៖ នៅពេលដែលលោកយាមមនុស្សធ្វើការនៅប្រឡាយអូរលៀប តើប្រឡាយនោះមានទីតាំងនៅខាងណាផ្លូវជាតិលេខ ៦? ឆ.19៖ ប្រឡាយនោះមានទីតាំងស្ថិតនៅខាងត្បូងផ្លូវជាតិលេខ ៦ ហើយដែលប្រឡាយអូរលៀបនោះបានធ្វើ បានបន្តរហូតដល់ដង្កៀបក្តាម"]។ ឯកសារ **D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.16 KH 00976166 [សាក្សីគឺជាកម្មករនៅព្រះនេត្រព្រះ៖ "ខ្ញុំបានទៅធ្វើការនៅការដ្ឋានទំនប់អូរលៀប បានប្រហែល ១ ឆ្នាំ ក្នុងឆ្នាំ ១៩៧៨ រហូតដល់វៀតណាមចូលមកដល់"]។

1328 ឯកសារ **D219/23** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.116 KH 01029680 [សាក្សីគឺជាសមាជិកគណៈស្រុកព្រះនេត្រព្រះ៖ "ស៖ តើលោកធ្លាប់ឮឈ្មោះព្រៃនាម នៅក្បែរភ្នំលៀបដែរទេ?

ឆ.116៖ ព្រៃរនាមនៅឆ្ងាយពីភ្នំលៀបប្រហែលជា ៩ ទៅ ១០ គីឡូម៉ែត្រ។ សៈ តើព្រៃរនាមជាកន្លែងអ្វីដែរ? ឆ.117៖ ព្រៃរនាមជាព្រៃទឹកលិច ដែលនៅពេលទឹកឡើង គឺទឹកហូរមកពីទន្លេសាប។ សៈ តើព្រៃរនាមមានចម្ងាយប៉ុន្មានពីទន្លេសាប? ឆ.118៖ វាមានចម្ងាយប្រហែលជា ៣០ គីឡូម៉ែត្រ ហើយនៅពេលដែលទឹកទន្លេសាបឡើង នៅតំបន់នោះមានជម្រៅទឹកប្រហែល ២ ទៅ ៣ ម៉ែត្រ"]។ ឯកសារ **D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រឹម សឺត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ឆ.10 KH 00800994 [សាក្សីគឺជាកម្មករនៅកងចល័តនៅព្រៃរនាម៖ "គេប្រាប់យើងថា គេសាងសង់ការដ្ឋាននេះ [ព្រៃរនាម] ជាអាងទឹកសម្រាប់ធ្វើស្រែប្រាំង"]។

1329 ឯកសារ **D219/264.1** ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107021 ["អ៊ឹម ចែម៖ ខែ--ពេលទៅអត់ទាន់មានទេ ដល់ទាល់តែជីក៣ខែបានហើយប្រឡាយហ្នឹង [ស្ថិតនៅខាងកើតភ្នំលៀប]"] KH 01107030-01107031 [អ៊ឹម ចែម៖ "ទៅដល់ខាងកើតភ្នំលៀបហ្នឹងណា ចុះពីស្ពានតាប៉ុនទៅ ឃើញប្រឡាញមួយធំហើយវែង ហ្នឹងប្រឡាយខ្ញុំ។ មានប្រឡាយមួយនៅរាល់ថ្ងៃហ្នឹង ខ្ញុំទៅ ធ្វើបានប្រឡាញមួយហ្នឹងចាស។ ប្រឡាយនេះធ្វើទាំងប្រាំឃុំ" [...] "៣ ខែ។ ប្រឡាយ ៨ គីឡូ ប្រឡាយហ្នឹងទម្លុះផ្លូវជាតិលេខ៦ ដាក់ធ្វើទ្វារទឹក ធ្វើដោយកម្លាំងប្រជាពលរដ្ឋទាំងអស់" [...] "ប្រឡាយហ្នឹងយកទឹកចេញពីឃុំស្ពានស្រែង ហើយខែវស្សាទឹកហូរពីទន្លេសាប"]។ ឯកសារ **D215/1.1.1** កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ EN 00997077 ["ប្រឡាយដែលមានប្រវែង ៩ គីឡូម៉ែត្រនេះ ត្រូវចំណាយពេលប្រហែលបីខែដើម្បីបញ្ចប់ការសាងសង់"]។ ឯកសារ **D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.219 KH 01049248 [សាក្សីគឺជាកម្មករនៅកងចល័តនៅស្ពានស្រែង៖ "សៈ តើលោកចាំបានថាឆ្នាំណាដែលលោកត្រូវបានគេឱ្យជីកប្រឡាយ [ស្ពានស្រែង] នោះ? ឆៈ ឆ្នាំ ១៩៧៧"]។ ឆ.230 KH 01049249 ["សៈ តើលោកដែលធ្វើការនៅប្រឡាយស្ពានស្រែងទេ បន្ទាប់ពីពួកនិរតីមកដល់? សៈ បាទ ព្រោះ តាពាល់ ជាអ្នកគ្រប់គ្រង ហើយពេលនោះ គេឱ្យខ្ញុំបោះបង្គោលធ្វើស្ពានឆ្លងប្រឡាយ"]។ ឯកសារ **D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.38 KH 00985871 [សាក្សីគឺជាប្រធានកងចល័តដែលបានធ្វើការនៅទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង និងប្រឡាយអូរលៀប៖ "ទំនប់ស្ពានស្រែងបានធ្វើចប់រួចរាល់នៅអំឡុងខែ មីនា ឬមេសា ឆ្នាំ ១៩៧៨"]។ ឯកសារ **D219/149** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឆ.11-12 KH 01058726 [សាក្សីគឺជាកម្មករនៅកងចល័តនៅប្រឡាយស្ពានស្រែង៖ "សៈ ប្រឡាយស្ពានស្រែងវាវែង តើក្រុមរបស់លោកគេឱ្យធ្វើការនៅកន្លែងណា? ឆ.11៖ គឺមិនទៀង ដោយសារពេលកងយើងធ្វើចប់ចំណុចណាមួយ គេផ្លាស់ទៅចំណុចថ្មីមួយផ្សេងទៀត នៅតាមបណ្តោយប្រឡាយនោះ។ សៈ តើលោកចាំទេថា ចូលរួមជីកប្រឡាយស្ពានស្រែងនោះប្រហែលប៉ុន្មានខែដែរ? ឆ.12៖ ខ្ញុំពុំចាំទេ គឺប្រហែលពេញមួយរដូវប្រាំង"]។

1330 ឯកសារ **D1.3.28.4** ឯកសារ **D123/1/5.1a** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929735-00929736 ["ខ្ញុំរៀបចំធ្វើទំនប់ពីរ និងប្រឡាយមួយកាលខ្ញុំនៅហ្នឹង ហ្នឹងបន្តពីទំនប់ខាងក្រោមត្រពាំងថ្មមួយ។ សៈ ឈ្មោះទំនប់អីគេដែរអ៎ី? ឆៈ ឈ្មោះទំនប់ស្ពានស្រែង [...] នៅខាងក្រោមត្រពាំងថ្មហ្នឹង [...] ខ្ញុំទប់ពី [...] ព្រៃរនាមក្នុងឃុំ (ប្រាសាទ)។ [...] សៈ ចុះអាទំនប់ពីរ និងប្រឡាយមួយហ្នឹងអំពើក សង់នៅឆ្នាំណាដែរ? ឆៈ [...] អាហ៎ ១៩៧៨ ពេញមួយឆ្នាំ។ សៈ ពេញមួយឆ្នាំហ្នឹងហ្មង? ចាស"]។ ឯកសារ **D219/175** កំណត់ហេតុនៃការស្តាប់

ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.6 KH 01065998 [សាក្សីគឺជាកម្មករក្នុងកងចល័តនៅការដ្ឋានស្ពានស្រែង៖ “មុនដំបូងក្រុមរបស់ខ្ញុំនៅលើកទំនប់កាត់ស្ពានស្រែងហើយខ្ញុំជាអ្នកដាំបាយឲ្យកងចល័តនោះ។ [...] ខ្ញុំមិនចាំឆ្នាំច្បាស់ទេ ប៉ុន្តែបើតាមខ្ញុំស្មានគឺប្រហែលជាពីរឆ្នាំក្រោយថ្ងៃដែលខ្មែរក្រហមបានគ្រប់គ្រងប្រទេស”]។ ឯកសារ **D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.26 KH 00978911 [សាក្សីបានដឹកនាំកងចល័តដែលមានសមាជិក ២០០ នាក់នៅស្ពានស្រែង និងអាងអូរលៀប៖ “នៅពេលនោះ កម្លាំងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំក្នុងកងចល័តខ្ញុំ គឺមានប្រហែល ២០០ នាក់ ហើយយើងបានទៅលើកទំនប់ស្ពានស្រែងនៅដើមឆ្នាំ១៩៧៨”]។ ឯកសារ **D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ហៅ ញ៉ុន ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤, ឆ.48 KH 00980389 [សាក្សីគឺជាមេឃុំភ្នំលៀប៖ “យើងត្រូវចំណាយពេលជិតពីរខែ ដើម្បីបញ្ចប់ការដ្ឋានជីកប្រឡាយនោះ ដែលមានប្រវែងប្រហែលជាប្រាំទៅប្រាំមួយគីឡូម៉ែត្រ”], ឆ.65 KH 00980392 [សាក្សីគឺជាមេឃុំភ្នំលៀប៖ “ស៖ តើនៅពេលណាលោកជ្រើសរើសមនុស្សពីឃុំរបស់លោកឲ្យទៅធ្វើការនៅប្រឡាយស្ពានស្រែង? ឆ.65៖ ខ្ញុំចាំឆ្នាំមិនច្បាស់ទេ ប៉ុន្តែបើតាមខ្ញុំគិតគឺប្រហែលជាមួយឆ្នាំមុនពេលកងទ័ពវៀតណាមចូលមកដល់ គឺអាចចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨”]។ ឯកសារ **D1.3.30.19** សេចក្តីរាយការណ៍ពី ញឹម លេខាភូមិភាគពាយ័ព្យជូនអង្គការ ៨៧០ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ KH 00021044 [“អាងទឹកតំបន់ ៥៖ [...] បន្តធ្វើអាងពីស្ពានស្រែងមកទល់ជាប់ទួលភ្នំស្រុកជិតរួចហើយ នៅតែទ្វារទេ”]។ ឯកសារ **D119/93** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ1.6 KH 00976166 [សាក្សីបានធ្វើការនៅការដ្ឋានផ្សេងៗនៅព្រះនេត្រព្រះ៖ “ខ្ញុំបានទៅធ្វើការនៅការដ្ឋានទំនប់អូរលៀប បានប្រហែល ១ ឆ្នាំ ក្នុងឆ្នាំ ១៩៧៨ រហូតដល់វៀតណាមចូលមកដល់”]។ ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.67 KH 01104646 [សាក្សីគឺជាកម្មការក្នុងកងចល័តនៅព្រះនេត្រព្រះ រួមទាំងនៅទំនប់ស្ពានស្រែង (ឆ្នាំ ១៩៧៨) និងនៅព្រៃរនាម៖ “យើងត្រូវចំណាយពេលប្រហែល១ឆ្នាំ ដើម្បីលើកទំនប់ [ស្ពានស្រែង] និងជីកប្រឡាយឲ្យរួចចប់សព្វគ្រប់”]។ ឯកសារ **D123/1/2.56** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទូច ភាន ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00736763 [ជាពេទ្យនៅទំនប់ត្រពាំងថ្មដែលក្រោយមកបានធ្វើការនៅស្ពានស្រែង៖ “[ខ្ញុំបានធ្វើការនៅ] ស្ពានស្រែងនោះប្រហែលមួយឆ្នាំ [...] [យើង] នៅលើកទំនប់ប្រឡាយតូចៗ”]។ ឯកសារ **D119/78** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត បណ្តែត ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ ឆ.16 KH 00971158-00971159 [សាក្សីបានធ្វើការនៅត្រពាំងថ្មក្នុងពេលដែលកម្មាភិបាលភូមិភាគនិរតីបានមកដល់ ហើយក្រោយមកបានធ្វើការនៅស្ពានស្រែង៖ “គេត្រូវការកម្លាំងទៅជួយនៅស្ពានស្រែង ដូច្នេះគេក៏បញ្ជូនយើងទៅធ្វើការនៅទីនោះ។ [...] ស្ពានស្រែងស្ថិតនៅក្នុងស្រុកភ្នំស្រុក ហើយខ្ញុំធ្វើការនៅទីនោះរយៈពេល ២ ខែ។ ខ្ញុំធ្វើនៅកន្លែងស្ពានចាស់បុរាណ ហើយធ្វើរហូតដល់ស្ពានស្រែង ពេលនោះមានមនុស្សរាប់រយនាក់]។ ឯកសារ **D106/9** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក់ ប៉ិយ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ឆ.24 KH 00801010 [បានធ្វើការនៅក្នុងកងចល័តតំបន់ ៥ នៅប្រឡាយស្ពានស្រែងចន្លោះពីឆ្នាំ ១៩៧៧ ដល់ ១៩៧៩៖ “ស៖ តើលោកដឹងទេថា ការជីកប្រឡាយស្ពានស្រែង ត្រូវចំណាយពេលវេលាប៉ុន្មាន? ឆ.24៖ ខ្ញុំដឹងមិនច្បាស់ដែរ តែតាមការប៉ាន់ស្មានរបស់ខ្ញុំ គឺប្រហែលជាពីរខែ ឬតិចជាងនេះ”]។ ឆ.29៖ [“អ្វីដែលខ្ញុំចាំបាន នៅពេលដែលពួក [កម្មាភិបាល] និរតីមកដល់ ការជីកប្រឡាយបានចប់ហើយ។ តែប្រហែលជាពួកនិរតី

អាចធ្វើបន្ត តែខ្ញុំមិនច្បាស់ដែរ ព្រោះខ្ញុំត្រូវបានគេបញ្ជូនទៅកន្លែងធ្វើការ [មួយ] ផ្សេងទៀត"]។ ឯកសារ **D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឹត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ឆ.13-14 KH 00800995 [សាក្សីគឺជាកម្មករនៅកងចល័តនៅព្រៃរនាម៖ "ឆ.13៖ ខ្ញុំក៏ដឹងដែរថា ប្រឡាយដែលពួកគេបានជីក នាំទឹកពីស្ទឹងស្ពានស្រែងទៅទំនប់ព្រៃរនាម។ [...] ឆ.14៖ ការដ្ឋានដែលកងចល័តធ្វើនៅប្រឡាយស្ពានស្រែង ត្រូវបានសាងសង់រួច មុនពេលយើងចាប់ផ្តើមធ្វើការនៅការដ្ឋានព្រៃរនាម"]។ ឯកសារ **D215/1.1.1** កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ EN 0997077 ["ខ្ញុំមានផែនការសាងសង់ប្រឡាយទីពីរមួយខ្សែទៀតនៅក្នុងស្រុកនេះ ប៉ុន្តែយើងមិនទាន់បានចាប់ផ្តើមផង របបនេះក៏ត្រូវបានផ្តួលរំលំ"]។ ឯកសារ **D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.29 KH 00978912 [សាក្សីបានដឹកនាំកងចល័តដែលមានសមាជិក ២០០ នាក់នៅស្ពានស្រែង និងអាងអូរលៀប៖ "កងចល័តឃុំរបស់ខ្ញុំបានបញ្ចប់ការលើកទំនប់ស្ពានស្រែង ហើយត្រូវបានផ្លាស់ទៅការដ្ឋានធ្វើអាងអូរលៀប។ យើងធ្វើការនៅអាងអូរលៀបជិតចប់សព្វគ្រប់ហើយ នៅតែផ្លូវទឹកប៉ុណ្ណោះ មុនពេលវៀតណាមចូលមកដល់"]។

1331 ឯកសារ **D119/120** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឆ.79 KH 00984313 [សាក្សីគឺជាកម្មករក្នុងកងកុមារនៅស្ពានស្រែង និងភ្នំស្រុក [ត្រពាំងថ្ម ដែលស្ថិតនៅខាងជើងស្ពានស្រែង]៖ "ស៖ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (D5/76) លោកបាននិយាយថា "ពួកខ្មែរក្រហមបានបញ្ជូនរូបលោកតាមរថយន្តធុនធំនៅពេលយប់ឱ្យទៅធ្វើការទប់ស្ទឹង ដែលគេហៅថា ស្ទឹងស្រែង មានព្រំប្រទល់ជាប់នឹងខេត្តសៀមរាបអស់រយៈពេលពីរខែ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៧។ តើត្រឹមត្រូវដែរទេ? ឆ.79៖ បាទ ត្រឹមត្រូវហើយ [...]"។ ឆ.82 KH 00984314 ["ទំនប់នោះត្រូវបានសាងសង់រួចរាល់ហើយ ប៉ុន្តែនៅពេលមានទឹកជំនន់ ទំនប់នោះបានដាច់ហើយគេបានបញ្ជូនពួកយើងឱ្យមកជួសជុលទំនប់នោះឡើងវិញ។ ស៖ តើគេបញ្ជូនលោកឱ្យទៅជួសជុលទំនប់ស្ពានស្រែងនៅពេលណា? ឆ.83៖ ខ្ញុំមិនចាំនៅពេលណាទេ។ ខ្ញុំគ្រាន់តែចាំថា គេបញ្ជូនខ្ញុំក្រោយពេលដែលទំនប់នោះបាក់តែប៉ុណ្ណោះ។ ស៖ តើលោកចាំទេថា នៅពេលដែលគេដកលោកទៅទំនប់ត្រពាំងថ្មវិញ ហើយក្រោយមក គេដកលោកឱ្យមកជួសជុលទំនប់ស្ពានស្រែង។ តើវាមានរយៈពេលប៉ុន្មាន? ឆ.84៖ ខ្ញុំចាំមិនច្បាស់ទេ"]។ ឯកសារ **D219/347** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.48 KH 01103350 [សាក្សីគឺជាសមាជិកគណៈឃុំព្រះនេត្រព្រះ៖ "ស្ពាននេះ [ទំនប់ស្ពានស្រែង] ស្ថិតនៅភាគខាងជើង ឆ្ងាយពីផ្លូវជាតិលេខ ៦ ក្បែរស្ពានបុរាណ។ នៅពេលនោះ វាមានទឹកជំនន់ខ្លាំង ហើយអ្នកដែលគេបញ្ជូនឱ្យទៅធ្វើការនៅទីនុង ដើរមើលតាមទំនប់ ខ្លាចទំនប់បាក់។ ហើយទំនប់ហ្នឹងគឺបានតភ្ជាប់រហូតដល់ផ្លូវជាតិលេខ ៦"]។ ឯកសារ **D119/133** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ិត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.32 KH 00998139 [សាក្សីគឺជាកម្មករនៅក្នុងកងចល័តក្នុងស្រុកព្រះនេត្រព្រះ រួមទាំងនៅអូរលៀប និងឃុំភ្នំលៀប និងឃុំប្រាសាទ៖ "ឆ.32៖ ដូចខ្ញុំបាននិយាយពីខាងដើមអ៊ីចឹង ស្ថានភាពរស់នៅ នៅក្រោមការគ្រប់គ្រងរបស់ពួកកម្មាភិបាលនិរតីគឺកាន់តែលំបាកឡើងៗ ហើយស្ថានភាពធ្វើការកាន់តែធ្ងន់ធ្ងរជាងមុន ដោយសារនៅឆ្នាំ ១៩៧៨ មានទឹកជំនន់ធំនៅក្នុងតំបន់នេះ"]។ ឯកសារ **D119/42** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.19 KH 00915874 [សាក្សីគឺជាកម្មករនៅកងចល័ត៖ "ពេលដែលខ្ញុំកំពុងធ្វើការនៅទំនប់ស្ពានស្រែង

ដោយដឹងថានឹងមានទឹកជំនន់ និងខ្យល់ខ្លាំង នៅពេលនោះ ពួកប្រធាន (និរតី) បានបញ្ជាឱ្យយើង (មនុស្សពីរក្រុម មានប្រហែលជា២០នាក់) ជិះតាមត្រាក់ទ័រទៅកាប់ធាងដូងនៅភ្នំលៀបក្បែរផ្ទះ យាយ ចែម ដើម្បីយកមកទប់ការពារទំនប់ទឹក"]។

1332 ឯកសារ **D215/1.1.1** កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ EN 0997077 ["ខ្ញុំមានផែនការសាងសង់ប្រឡាយទីពីរមួយខ្សែទៀតនៅក្នុងស្រុកនេះ ប៉ុន្តែយើងមិនទាន់បានចាប់ផ្តើមផង របបនេះក៏ត្រូវបានផ្តួលរំលំ"]។ ឯកសារ **D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.29 KH 00978912 [សាក្សីបានដឹកនាំកងចល័តដែលមានសមាជិក ២០០ នាក់នៅស្ពានស្រែង និងអាងអូរលៀប៖ "កងចល័តឃុំរបស់ខ្ញុំបានបញ្ចប់ការលើកទំនប់ស្ពានស្រែង ហើយត្រូវបានផ្លាស់ទៅការដ្ឋានធ្វើអាងអូរលៀប។ យើងធ្វើការនៅអាងអូរលៀបជិតចប់សព្វគ្រប់ហើយ នៅតែផ្លូវទឹកប៉ុណ្ណោះ មុនពេលវៀតណាមចូលមកដល់"]។

1333 ឯកសារ D119/43 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.10 KH 00915882 [សាក្សីធ្វើការនៅក្នុងកងចល័តភូមិភាគ៥៖ តាវ៉ាល់គឺជាប្រធានកងតំបន់៥ ដែលមានមនុស្ស៨០០០នាក់ ដែលមកពីកន្លែងផ្សេងៗគ្នា រួមមានទាំងប្រជាជនចាស់ និងប្រជាជនថ្មី។"] ឆ.12 KH 00915882 ["នៅពេលនោះ គេបានបំបែកកងចល័តតំបន់៥ជាបីក្រុម៖ ក្រុមទីមួយ ធ្វើការនៅទំនប់ស្នាច់ ក្រុមទីពីរ ធ្វើការនៅទំនប់ស្ពាន់ស្រែងដែលលាតសន្ធឹងពីចូកគ្រោះដល់ស្ពានស្រែង និងក្រុមទី៣ ធ្វើការនៅអាងត្រពាំងថ្ម។"]។ ប្រតិចារឹកសំណុំរឿង០០២/០២ ឯកសារ D219/494.1.7 ឈិត យឿក ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ KH 01130899 [សាក្សីគឺជាប្រធានកងចល័តយុវជនស្រុកព្រះនេត្រព្រះ ដែល ប្រជាជនចំនួនពី៦០០ ទៅដល់១០០០នាក់ "ស៖ នៅពេលដែលលោកធ្វើជាជំនួយការឱ្យតាវ៉ាល់ លោកដឹងទេ តើមានមនុស្សប៉ុន្មាននាក់ស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់គាត់។ ឆ៖ ខ្ញុំកាលនុង គិតទាំងចល័តទាំងអស់ អង្កាល់ តាវ៉ាល់ នៅប្រហែល៨០០០។"]។ ប្រតិចារឹកសំណុំរឿង០០២/០២ ឯកសារ D219/494.1.6 ឡុត សួយ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ពីម៉ោង 11.21.43 ដល់ម៉ោង 11.23.23 KH 01130087-01130088 [សាក្សីគឺជាទាហានស្រុកដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយតាវ៉ាល់ នៅក្នុងកងចល័តនៅទំនប់ត្រពាំងថ្ម៖ "[តាវ៉ាល់] គាត់ក្តាប់រួមទាំងអស់ក្នុងមួយតំបន់៥នេះ គឺកន្លែងទំនប់ត្រង់ណាក៏គាត់ក្តាប់រួមដែរ។ ព្រោះចល័តច្រើន បែងចែកគ្នាល់តាមទំនប់ ដូចជាទំនប់រន្ទះបាញ់ក្តី ទំនប់ស្ពានស្រែង ទំនប់អាងត្រពាំងថ្ម គឺជាចល័តៗតំបន់ ហើយចល័តតាមភូមិលើក នៅក្នុងការគ្រប់គ្រងរបស់តាវ៉ាល់ ទាំងអស់។"]។ ឯកសារ D219/357 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.54 KH 01118000 [សាក្សីធ្វើការនៅក្នុងកងចល័តនៅស្រុកព្រះនេត្រព្រះ រួមទាំងទំនប់ស្ពានស្រែង (១៩៧៨) និងព្រៃរនាម "កងចល័តរបស់ខ្ញុំ ជាកងចល័តស្រុកភ្នំស្រុក។ ឆ.56៖ តាវ៉ាល់ ជាប្រធានកងចល័ត។"]។ ឯកសារ D119/100 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម គិន ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.8 KH 00978931 [ប្រពន្ធតាវ៉ាល់៖ "ខ្ញុំស្នាក់នៅស្វាយ តែចំណែកប្តីរបស់ខ្ញុំ [តាវ៉ាល់] គាត់មកភ្នំលៀប ក្នុងស្រុកព្រះនេត្រព្រះ ពីព្រោះគាត់ជាប្រធានចល័តកងតំបន់៥។"] ឆ.16 KH 00978932 ["ខ្ញុំដឹងតែពីតួនាទីរបស់គាត់ ដឹកនាំកម្លាំងទៅលើកទំនប់ និងជីកប្រឡាយតែប៉ុណ្ណោះ។ ស៖ តើលោកស្រីអាចរៀបរាប់បានទេ តើគាត់ដឹកនាំកម្លាំងទៅលើកទំនប់ និងជីកប្រឡាយណាខ្លះ? ឆ.17៖ មានទំនប់ស្ពានស្រែង ទំនប់អាងត្រពាំងថ្ម និងនៅតាមការដ្ឋានទំនប់ផ្សេងៗទៀត ប៉ុន្តែខ្ញុំមិនបានចាំឈ្មោះ។"]។ ឯកសារ D119/120 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេ

សា ឆ្នាំ ២០១៤ ឆ.70 KH 00984313 [សាក្សីធ្វើការនៅកងចល័តកុមារនៅស្ពានស្រែង និងភ្នំស្រុក [ត្រពាំងថ្ម ជាប់ព្រំប្រទល់ផ្នែកខាងជើងនៃស្ពានស្រែង]៖ "សៈ តើនរណាជាអ្នកគ្រប់គ្រងនៅការដ្ឋានស្ពានស្រែង? ឆ៖ ខ្ញុំមិនដឹងទេ ប៉ុន្តែបញ្ជាចេញពី តាវ៉ាល់។"]។ ឯកសារ D119/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាយ ផាន ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.5 KH 00915860 [សាក្សីធ្វើការនៅកងចល័ត ហើយក្រោយមក ក្លាយជាប្រធានក្រុមចល័តនៅស្ពានស្រែង៖ "អ្នកគ្រប់គ្រងនៅក្នុងកងចល័តតំបន់៥របស់ខ្ញុំ ឈ្មោះតាវ៉ាល (អ្នកពាយ័ព្យ)។] ឆ.12 KH00950736 ["សៈ នៅការដ្ឋានស្ពានស្រែងនរណាជាអ្នកគ្រប់គ្រងរួមនៅទីនោះ? ឆ៖ តាវ៉ាល ជាអ្នកគ្រប់គ្រងនៅទីនោះ។"]។ ឯកសារ D219/149 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឆ.9 KH 01064148 [សាក្សីធ្វើការនៅប្រឡាយស្ពានស្រែង៖ "ឆ៖ នៅក្នុងឆ្នាំ១៩៧៧ លោកថា គេឲ្យលោកទៅជីកទំនប់ស្ពានស្រែងក្រោមការគ្រប់គ្រងរបស់តាវ៉ាល់។ តើតាវ៉ាល់ជានរណា?" ឆ៖ ខ្ញុំមិនដែលឃើញមុខគាត់ទេ ខ្ញុំដឹងថា គាត់ជាអ្នកគ្រប់គ្រងពួកខ្ញុំនៅការដ្ឋានទំនប់ស្ពានស្រែ តែមិនដឹងថាគាត់មានមុខតំណែង និងតួនាទីច្បាស់លាស់ជាអ្វីនោះទេ។"]។ ឯកសារ D123/1/2.46 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុត បណ្តែត ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ KH 00927092 [សាក្សីធ្វើការនៅត្រពាំងថ្មនៅពេលដែលកម្មាភិបាលភូមិភាគនីរតី បានមកដល់ ហើយក្រោយមកធ្វើការនៅស្ពានស្រែង៖ "[តាវ៉ាល់] ឋានៈធំ [...] ក្តាប់កងចល័ត៤ស្រុក [...] ដារ៉ា៖ ស្រុកអីខ្លះ? បណ្តែត៖ ស្រុកព្រះនេត្រព្រះ ស្រុកសិរីសោភណ ស្រុកថ្មពួក ស្រុកភ្នំស្រុក ៤ស្រុក ទទួល៤ស្រុក។"] KH 00927093 ["[តាវ៉ាល់] ជាប្រធានទទួលខុសត្រូវលើកទំនប់។"]។ ឯកសារ D119/78 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត បណ្តែត ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ ឆ.15-16 KH 00971158 [សាក្សីធ្វើការនៅត្រពាំងថ្មនៅពេលដែលកម្មាភិបាលភូមិភាគនីរតី បានមកដល់ ហើយក្រោយមកនៅស្ពានស្រែង៖ "ខ្ញុំគ្រាន់តែដឹងថា តាវ៉ាល់ជាអ្នកគ្រប់គ្រងចល័តតំបន់សម្រាប់ស្រុកទាំងបួននោះ។ ឆ.16៖ [...] គេត្រូវការកម្លាំងទៅជួយនៅស្ពានស្រែង ដូច្នេះគេក៏បញ្ជូនយើងទៅធ្វើការនៅទីនោះ។"]។ ឯកសារ D119/148.1 គម្រោងលើកកម្ពស់គណនេយ្យភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កិច្ចសម្ភាសន៍ជាមួយ ក្រឹក រិត ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១ EN 00729887 [សាក្សីធ្វើការនៅកងចល័ត៖ "រេត វែកដីជីកប្រឡាយ ដូចជាស្រះកើត កំបៅ អូរលៀប ស្ពានស្រែង និងការដ្ឋានទំនប់ត្រពាំងថ្ម [...] [តា] វ៉ាល់ គឺជប្រធានកងចល័តតំបន់ [៥]។"]។ ឯកសារ D67.10 គម្រោងលើកកម្ពស់គណនេយ្យភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កិច្ចសម្ភាសន៍ជាមួយ មុន មុត ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00728845 [ប្រធានកងចល័តតំបន់៥៖ "[តា]វ៉ាល់ ត្រូវជាប្រធានកងចល័តតំបន់៥"]។ ឯកសារ D119/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.60 KH 01003887 [សាក្សីគឺជាប្រធានកងចល័តក្នុងតំបន់៥ ៖"នៅពេលដែលខ្ញុំធ្វើការនៅការដ្ឋានប្រឡាយស្ពានស្រែង តាសន និងតាវ៉ាល់ គឺជាអ្នកគ្រប់គ្រងផ្ទាល់នៅការដ្ឋានប្រឡាយស្ពានស្រែងនោះ ប៉ុន្តែពេលមួយនោះ ខ្ញុំធ្លាប់បានឃើញ យាយថែម និងកម្មាភិបាលពីរបីនាក់ផ្សេងទៀត បានចុះទៅមើលការដ្ឋាននោះដែរ។"]

1334 ឯកសារ D6.1.883 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលត្រូវបានកែសម្រួល [បង្ហាញថាលេខរៀង៥៧ អន ម៉ោង លេខាព្រះនេត្រព្រះ តំបន់៥ ចូល ស-២១ ថ្ងៃទី២៨ ខែ មិថុនា ឆ្នាំ ១៩៧៧ និងត្រូវបានសម្លាប់ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧។ ឯកសារ D1.3.28.4 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយអ៊ឹម ថែម ថ្ងៃទី ០៤ ខែ

មីនា ឆ្នាំ ២០០៧ KH 00929732 ["ដល់ខ្ញុំទៅដល់ តាម៉ោង នៅ អាត នៅ។ ប៉ុនគ្រាន់តែខ្ញុំទៅដល់ គេរៀបចំឲ្យទទួលបញ្ជីអី ហើយ គេហៅទៅបាត់"]។ ឯកសារ D106/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម ស៊ីត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ឆ.34 KH 00800997 [សាក្សីធ្វើការនៅកងចល័តនៅព្រៃរនាម៖ "សៈ តើនរណាគេជាចៅហ្វាយស្រុកព្រះនេត្រព្រះ មុនយាយចែម មកដល់ក្នុងឆ្នាំ១៩៧៧? សៈ តាម៉ោងគឺជាចៅហ្វាយស្រុក។ ខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះគាត់ទេ។ ក្រុមគាត់ត្រូវបានគេចាប់ដាក់លើឡាន ហើយដឹកទៅបាត់។ ខ្ញុំមិនដឹងថាគេដឹកទៅទីណាទេ។"]។ ឯកសារ D119/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.8-9 KH 00978909 [សាក្សីដឹកនាំកងចល័តឃុំដែលមានគ្នា២០០គាត់ នៅស្ពានស្រែង និងអាងស្តុកទឹកអូរលៀប៖ "ខ្ញុំគ្រាន់តែដឹងថា នៅពេលពួក នីរតីមកដល់ ពួកគាត់ត្រូវបានគេចាប់ និងសម្លាប់ចោលអស់ ប៉ុន្តែខ្ញុំមិនដឹងថានរណាគេជាអ្នកបញ្ជាឲ្យយកទៅសម្លាប់ទេ។ ខ្ញុំបានដឹងរឿងនេះ តាមរយៈការនិយាយតៗគ្នា។ ឆ.9៖ តាម៉ោង និងតាហ៊ីង ត្រូវបានសម្លាប់ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៧។"]។ ឯកសារ D219/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.14 KH 01065999 [សាក្សីធ្វើការនៅកងចល័តការដ្ឋានស្ពានស្រែង៖ "ចំណែក តាមោង និងតាវ៉ាល់ ខ្ញុំមិនដឹងថា ពួកគាត់នៅរស់ ឬក៏ត្រូវបានគេសម្លាប់ទេ ខ្ញុំគ្រាន់តែដឹងថា ពួកគាត់បាត់ខ្លួននៅពេលនោះ។"] ឆ.22 KH 01066000 ["តាមខ្ញុំដឹង គឺនៅពេលនោះ តាវ៉ាល់ និងតាមោង បានបាត់ខ្លួន ហើយកងចល័តរបស់ខ្ញុំត្រូវបានគ្រប់គ្រងដោយកម្មាភិបាលនិរតី។"]។ ឯកសារ D219/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.69 KH 01029674 [សាក្សីគឺជាសមាជិកគណៈស្រុកព្រះនេត្រព្រះ៖ "សៈ តើលោកអាចបញ្ជាក់បានទេថា នៅពេលដែលតាម៉ោងបាត់ខ្លួន គឺយាយ ចែម បានមកដល់ស្រុកព្រះនេត្រព្រះរួចហើយឬ? ឆៈ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D6.1.1128 បញ្ជីអ្នកទោសដែលត្រូវបានសម្លាប់នៅ ស-២១៖ ឈ្មោះអ្នកទោសដែលត្រូវបានសម្លាប់នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ១៩៧៨ EN 00193556 [បង្ហាញនៅលេខរៀង១២ ឈ្មោះ អោក ហន ហៅវ៉ាល់ ចូល ស-២១ នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៧]។ ឯកសារ D119/100 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម គិន ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.21 KH 00978933 [ប្រពន្ធតាវ៉ាល់ "មួយអាទិត្យក្រោយពីពួកនិរតីចូលមក គេបានចាប់ប្តីរបស់ខ្ញុំ នៅឯការដ្ឋានស្ពានស្រែង។ ខ្ញុំដឹងថាដោយសារតែខ្ញុំសួរអ្នកភូមិនៅជប់ ហើយក៏គេបានប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំត្រូវបានចាប់ខ្លួននៅទីនោះ"]។ ឯកសារ D119/43 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.14 KH 00915883 [កម្មករនៅកងចល័តតំបន់៥៖ "គេបានចាប់ខ្លួនតាវ៉ាល់នៅទំនប់ស្ពានស្រែង កាលខ្ញុំធ្វើការក្នុងកងពិសេសនៅកំបោរ។ តាវ៉ាលចាប់ខ្លួនដោយពួកនីរតី។"] ឆ.17 KH 00915884 ["តាម៉ោងត្រូវបានចាប់ខ្លួនដូចតាវ៉ាល់ដែរ ហើយកម្មាភិបាលថ្នាក់ឃុំ និងប្រធានសហករណ៍ក៏ត្រូវបានគេចាប់ខ្លួនទាំងអស់ដែរ ហើយជំនួសដោយពួកនីរតី។"]។ ឯកសារ D123/1/2.46 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុត បណ្តែត ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ KH 00927102 [សាក្សីធ្វើការនៅត្រពាំងថ្មនៅពេល កម្មាភិបាលនីរតីមកដល់ ហើយក្រោយនៅស្ពានស្រែង៖ "ចាប់តាវ៉ាល់មុន ចាឯងក្បត់ ចាប់ទៅ គាត់ក៏រត់មិនរួចទេ ចាប់យកទៅបាត់រហូត។"]។ ឯកសារ D119/78 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត បណ្តែត ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ ឆ.21 KH 00971159 [សាក្សីធ្វើការនៅត្រពាំងថ្មនៅពេលកម្មាភិបាលនីរតីមកដល់ ហើយក្រោយនៅស្ពានស្រែង៖ "ពេលខ្ញុំធ្វើការនៅទំនប់ត្រពាំងថ្ម ខ្ញុំបានសួរមេរបស់ខ្ញុំឈ្មោះរឿន ថាហេតុអ្វីបានជាមិនដែលឃើញតាវ៉ាល់។ គាត់ប្រាប់ខ្ញុំថា តាវ៉ាល់ត្រូវបាន

គេចាប់ខ្លួនទៅជប់"]។ ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.36 KH 01148731 [សាក្សីធ្វើការនៅកងចល័តៈ "ខ្ញុំឮគេនិយាយថា ពេលយាយចែមមកដល់ គេចាប់តាវ៉ាល់ និងទម្លាក់តំណែងគាត់។ ក្រោយមកយាយចែម ឡើងជំនួសតាវ៉ាល់"]។ ឯកសារ D219/357 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.58 KH 0114645 [សាក្សីធ្វើការនៅក្នុងកងចល័តនៅស្រុកព្រះនេត្រព្រះ រួមទាំងទំនប់ស្ពានស្រែង (១៩៧៨) និងព្រៃរនាម "[តាវ៉ាល់ និងតាញឹម] បានបាត់ខ្លួននៅពេលដែលពួកនីរតីបានមកដល់។"]

1335 ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.31 KH 00953023 [សាក្សីជាអនុប្រធានកងចល័តក្នុងតំបន់១៣ ហើយត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ៖ "បន្ទាប់មកក្នុងខែមីនា ឆ្នាំ ១៩៧៧ ខ្ញុំត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ។ "] ឆ.39 KH 00953024 ["ការចេញទៅនោះ មិនមែនតែគ្រួសារខ្ញុំមួយទេ គឺប្រជាជនទូទាំងខេត្តតាកែវ។ គេបញ្ជូនយើងតាមឡានទៅជួបជុំនៅខេត្តតាកែវ។ សម្រាកនៅខេត្តតាកែវមួយយប់។ ពេលប្រមូលបានគ្នាច្រើន យើងចេញទៅពាយ័ព្យតាមរទេះភ្លើង។ ឆ.40៖ សរុបទាំងអស់ គឺមានមនុស្សរាប់ពាន់នាក់។"] ឆ.44 KH 00953025 ["ចំណែកអ្នកគ្រប់គ្រង ប្រជាជន គឺយាយចែម។ ឯអ្នកគ្រប់គ្រងរួមក្នុងការបញ្ជូនមនុស្សទាំងអស់ទៅភូមិភាគពាយ័ព្យក៏យាយចែមហ្នឹងដែរ។"] ឆ.62 KH 00953027 ["ពេលរថភ្លើងទៅដល់ថ្មគោល យើងត្រូវបានបញ្ជូនតាមឡានទៅស្វាយ (បច្ចុប្បន្នទីរួមខេត្តបន្ទាយមានជ័យ) នៅទីនោះ មានការប្រជុំចែកការងារឲ្យគ្នាទៅកាន់ស្រុកនីមួយៗ ហើយយាយចែមត្រូវទទួលបន្ទុកជាគណៈស្រុកព្រះនេត្រព្រះ។"]។ ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ KH 00980380 [សាក្សីជាមេឃុំភ្នំលៀប៖ "នៅពេលនោះ [១៩៧៥-១៩៧៧] ខ្ញុំជាប្រធានក្រុមក្នុងកងវរសេនាតូច ក្នុងកងពលលេខ២ [...] នៅក្នុងខេត្តតាកែវ [...] គេបានបញ្ជូនខ្ញុំទៅទីនោះនៅចុងឆ្នាំ១៩៧៦ ដើមឆ្នាំ១៩៧៧ [ទៅប៉ោយប៉ែត ដើម្បីការពារព្រំដែនថៃ" [...] "មានមនុស្សរាប់ពាន់នាក់ [ភាគច្រើនជាទាហាន ប៉ុន្តែមានស្ត្រីរាប់រយនាក់មកពីស្រែអំបិល]។ រទេះភ្លើងវែង គឺមានប្រហែលជា៣០ទៅ៤០ទូររទេះភ្លើង។"] KH 00980382 ["គេបានបញ្ជូនពួកខ្ញុំឱ្យមកធ្វើការនៅស្រុកព្រះនេត្រព្រះ [កងវរសេនាតូចដែលមានយោធាប្រហែល៣០នាក់] ដើម្បីការពារសន្តិសុខក្នុងស្រុក" [...] "នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨"]។ ផ្ទុយនឹង ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107008 ["អ៊ឹម ចែម៖ [ទៅព្រះនេត្រព្រះ] ឆ្នាំ៧៨ [...] ៧៨ ខែ១០ហើយ បានខ្ញុំមកស្រុកព្រះនេត្រព្រះ"] KH 01107009 ["ខ្ញុំស្ម័គ្រចិត្តមក ព្រោះឮដំណឹងថា ស្រុកព្រះនេត្រព្រះហ្នឹងដីទូលាយ [...] កាលហ្នឹងចេះតែនេះទៅ។ ហ្នឹងហើយ បើយើងមិនមកក៏បានដែរ ប៉ុន្តែគេថា អ្នកណាស្ម័គ្រចិត្តទៅខេត្តបាត់ដំបងអីអ៊ីចឹងទៅ ហើយយើងឆ្លើយថា ស្ម័គ្រចិត្តទៅយើងមក។"]។

1336 ឯកសារ **D67.10** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មុន មុត ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00728891 [មេកងចល័តភូមិភាគ៥៖ "[យាយ] ចែមមកដល់ដើរមើលគ្រប់កន្លែងរបស់តាវ៉ាល់កាន់កាប់ទាំងអស់ [តា] វ៉ាល់។"]។ ឯកសារ **D219/494.1.1** កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ លោក សែន សុផុន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ KH 01122556 [សាក្សីធ្វើការនៅកងចល័ត៖ "លើកក្រោយនេះមក [នៅពលចាត់តាំងទៅភ្នំលៀប] គេហៅពួកនីរតីចូល។ នីរតីចូលហ្នឹងបាត់ឈ្មោះតាវ៉ាល់ អត់ឮតាវ៉ាល់ទេ ឮឈ្មោះយាយចែ

មៗវិញ មេៗធំ។”]។ ឯកសារ **D219/264.1** ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 1107032 [“អ្នកបកប្រែ៖ ទៅនៅព្រះនេត្រព្រះហ្នឹងមីងធ្វើអ្វីវិញ ?លស្រុក ឬមិនមែននៅព្រះនេត្រព្រះហ្នឹងជាប្រធានអភិបា ?អ៊ឹម ចែម៖ នៅអភិបាល ប៉ុន្តែអភិបាលគេម្តងចាត់តាំង ម្តងមិនចាត់តាំង […] ដូចថាខាងខេត្តថាយកទៅហ្នឹង យកទៅធ្វើប្រធាន។ ដល់ទៅដល់ គេអត់ប្រកាសថាប្រធានទេ ឱ្យធ្វើបណ្តោះអាសន្ន ហ្នឹង។”]។ ឯកសារ **D119/65** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ6.5 KH 00953028-00953029 [សាក្សីជាអនុប្រធានកងចល័តក្នុងតំបន់៣ ហើយក្រោយមកត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ៖ “ស៖ លោកនិយាយថា យាយចែមត្រូវតែងតាំងជាគណៈស្រុកព្រះនេត្រព្រះ។ ហេតុអ្វីបានជាលោកដឹងថា យាយចែម ត្រូវបានតែងតាំងជាគណៈស្រុកព្រះនេត្រព្រះ ?ឆ.65៖ ពេលទៅដល់ស្វាយបីថ្ងៃ [មកពីភូមិភាគនិរតី] មានការបែងចែកកម្លាំងទៅកាន់ស្រុកនានា។ ការប្រជុំនោះ ខ្ញុំក៏ចូលរយមប្រជុំជាមួយតាជៀលដែរដោយក្នុងនោះមានតំណាងតាមស្រុកចម្រុះទាំងអស់ចូលរួមប្រជុំ។ ឆ.67៖ នៅអង្គប្រជុំនោះ មានតាជៀល និងយាយចែម ជា អ្នកដឹកនាំការប្រជុំ។”] ឆ.73 KH 00953030 [“នៅពេលនោះសម្រេច [តែងតាំងនៅព្រះនេត្រព្រះ] នៅក្នុងអង្គប្រជុំដោយតាជៀល និងយាយចែមតែម្តង។”]។

1337 ឯកសារ D219/264.1 ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107021 [“អ្នកបកប្រែ៖ ចុះបើដល់ប្រះនេត្រព្រះហ្នឹង អ្នកមីងធ្វើ គេឲ្យធ្វើអីដែរមីង? អ៊ឹម ចែម៖ មានធ្វើអី ខ្ញុំដឹកនាំបងប្អូនជីក ប្រឡាយ។ […] អ៊ឹម ចែម៖ នៅទៅដល់អត់មានទេ ដល់ទាល់តែជីក៣ខែបានហើយប្រឡាយហ្នឹង [ខាងកើតភ្នំលៀប]។”] KH 01107030 [“អ៊ឹម ចែម៖ ទៅដល់ខាងកើតភ្នំលៀបហ្នឹងណា ចុះពីស្ពានតាប៉ុនទៅ ឃើញប្រឡាយមួយធំហើយវែង ហ្នឹងប្រឡាយខ្ញុំ។ មានប្រឡាយមួយនៅរាល់ថ្ងៃហ្នឹង ខ្ញុំទៅធ្វើបានប្រឡាយមួយហ្នឹង ចាស។ ប្រឡាយនេះធ្វើទាំងប្រាំឃុំ។”] KH 011070041 [“អ៊ឹម ចែម៖ ឃុំមួយៗកម្លាំងរបស់គាត់ចែកម្នាក់ៗត្រូវទទួលបានប៉ុន្មានម៉ែត្រអីចឹងទៅ។ […] អាហ្នឹងជាក់ស្តែងគាត់ដូចថា គាត់ទទួល១គីឡូ។ ១គីឡូអីចឹង កម្លាំងគាត់មានប៉ុន្មាននាក់ ហើយគាត់ត្រូវចែកម្នាក់១០ម៉ែត្រក្នុងមួយខែ ឬក៏ម្នាក់ត្រូវចែក៥ម៉ែត្រតាមកម្លាំងតិចកម្លាំងច្រើនរបស់គាត់។ អីចឹងធ្វើមិនមែនធ្វើដាក់កំណត់ឲ្យហើយ មិនហើយមិនបាន អត់ទេ អ្នកណាចង់រែកយប់រែកទៅ អ្នកណាចង់រែកថ្ងៃរែកទៅ ឲ្យគ្រប់ផែនការរបស់គេហ្នឹង ហ្នឹងហើយ។”]។ ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.69 KH 00900392 [សាក្សីជាមេឃុំភ្នំលៀប៖ “ស៖ ក្នុងតួនាទីយាយចែម ជាគណៈស្រុកព្រះនេត្រព្រះ ដូច្នេះមានន័យថា គាត់មានតួនាទីជាអ្នកស្នើកម្លាំងពីឃុំនានា ដើម្បីយកទៅធ្វើការងារនៅតាមការដ្ឋានជីកប្រឡាយនោះឬ? ឆ.69៖ បាទ ត្រឹមត្រូវហើយ។”]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.112 KH 00953035 [សាក្សីជាប្រធានកងចល័ត ដែលក្រោយមកបានក្លាយជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានវៃថ្ម៖ “ស៖ តើគាត់បានទៅមើលការងារលោកនៅការដ្ឋាននោះទេ? ឆ.112៖ […] គាត់ឧស្សាហ៍ទៅមើលដែរ ពីរបីថ្ងៃម្តង។ គណៈតំបន់ក៏ទៅដែរ។”] KH 00953035 [“ស៖ តើកងចល័តផ្សេងទៀតរាយការណ៍មកលោក ឬរាយការណ៍ទៅយាយចែម? ឆ.124៖ ទៅយាយចែម។”]។ ឯកសារ D67.10 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មុន មុត ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00728891 [មេកងចល័តតំបន់៥៖ “[យាយ] ចែម មកដល់ដើរមើលគ្រប់កន្លែងរបស់តាវ៉ាល់កាន់កាប់ទាំង អស់។ ខ្ញុំមិនបានចងចាំអារឿងឆ្នាំប៉ុននេះ ប៉ុននោះ បើនៅភ្លេចៗ អារឿងឆ្នាំនោះលោកគ្រូរឿងឆ្នាំចេះចុះ ដូចថាវាឯកោដូចជាគ្មានតាមសណ្តាប់ទេ បើនិយាយកកញ្ចប់ៗ វៀតណា

មចូលយកឲ្យចប់"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.77 KH 01049234 [សាក្សីធ្វើការនៅកងចល័តនៅស្ពានស្រែង៖ "ស៖ អីចឹង តើយាយចែមមានអំណាចគ្រប់គ្រងស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះផងឬ? ឆ៖ បាទ"]។ ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.36 KH 01148731 [សាក្សីធ្វើការនៅក្នុងកងចល័ត៖ "ខ្ញុំឮគេនិយាយថា ពេលយាយ ចែម មកដល់ គេចាប់តាវ៉ាល់ និងទម្លាក់តំណែងគាត់។ ក្រោយមក យាយចែមឡើងជំនួស តាវ៉ាល់។ យាយ ចែមគឺជាអ្នកមកពីភូមិភាគនីរតី។"]។ ឯកសារ D219/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុំ ខូ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.102 KH 01029679 [សាក្សីគឺជាសមាជិកគណៈស្រុកព្រះនេត្រព្រះ៖ "យាយចែម មិនបានបើកការដ្ឋានថ្មីទេ គឺគាត់បានធ្វើបន្តការដ្ឋានចាស់ពីតាម៉ោង។"]។ ឯកសារ D106/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឹត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ឆ.27 KH 0080996 [សាក្សីធ្វើការនៅកងចល័តនៅព្រៃរនាម៖ "ស៖ តាមអ្វីដែលលោកចាំបាន តើលោកគិតថាយាយចែម ជាអ្នកគ្រប់គ្រងរួមនៅការដ្ឋានព្រៃរនាមឬ? ស៖ បាទ។"]។ ឯកសារ D119/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.31 KH 00976159 [សាក្សីធ្វើការនៅក្នុងកងចល័តនៅក្បែរតារុត [គាត់ដឹងអំពីស្រុកព្រះនេត្រព្រះ]៖ សាក្សីបានបង្ហាញអ្នកស៊ើបអង្កេត ក.ស.ច.ស អំពីទីតាំងប្រឡាយអូរលៀប និងបញ្ជាក់ថាការដ្ឋានប្រឡាយអូរលៀប ក្រោមការគ្រប់គ្រងរបស់យាយចែម ក្នុងអំឡុងរបបខ្មែរក្រហម។]។ ឯកសារ D119/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ រិន ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.19 KH 01024736 [សាក្សីធ្វើការនៅក្នុងកុមារនៅក្នុងទំនប់ស្ពានស្រែង៖ "ខ្ញុំធ្លាប់ឮគេនិយាយថា យាយចែមគឺជាអ្នកចុះមកត្រួតមើលមនុស្សធ្វើការនៅការដ្ឋានទំនប់ [...] ខ្ញុំឮអំពីយាយចែម នៅពេលដែលខ្ញុំធ្វើការនៅស្ពានស្រែង នៅពេលដែលគាត់ចុះមកការដ្ឋាននេះ តែខ្ញុំមិនដែលឃើញគាត់ទេ។"]។ ឯកសារ D119/93 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ ផុន ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.18 KH 00976166 [សាក្សីធ្វើការនៅការដ្ឋាននានានៅព្រះនេត្រព្រះ៖ "យាយចែម ជាអ្នកមកពី នីរតី។ បើតាមខ្ញុំដឹង យាយចែម ក្តាប់តំបន់៥ទាំងមូល ពីព្រោះគាត់បានចុះធ្វើការនៅតាមការដ្ឋាននានា នៅក្នុងតំបន់៥នេះ។ ស.19៖ [...] ខ្ញុំធ្លាប់ឃើញ យាយចែមនៅតំបន់អូរលៀប។ នៅពេលនោះ គាត់បានទៅកោះប្រជុំដោយហៅគ្រប់តំណាងស្រុកទាំងអស់នៅក្នុងតំបន់៥ឲ្យមកចូលរួម។ ឆ.22៖ ពេលយាយ ចែម មកប្រជុំ គឺមានយោធាប្រដាប់អាវុធ ប្រហែល៥ទៅ១០នាក់ អមដំណើរមកជាមួយ។"] ផ្ទុយនឹង ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.129 KH 00953037 [សាក្សីគឺជាប្រធានកងចល័ត ដែលក្រោយមកក្លាយជាប្រធានមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានវៃថ្ម៖ "ស៖ តើលោកដែលឮឈ្មោះប្រឡាយស្ពានស្រែងទេ? ឆ.129៖ មានឈ្មោះស្ពានស្រែង ប៉ុន្តែប្រឡាយទៅមិនដល់នោះតេ។ ស៖ តើទីតាំងស្ពានស្រែងនោះនៅកន្លែងណា? ស.130៖ ស្ពានស្រែងខ្ញុំមិនច្បាស់ដែរ។ ប៉ុន្តែវានៅលើស្ទឹងជាប់ព្រំប្រទល់រវាងស្រុកព្រះនេត្រព្រះ និងស្រុកក្រឡាញ់។ ស្ទឹងនោះមានឈ្មោះថាស្ទឹងតាប៉ុន ព្រោះវានៅជិតភូមិតាប៉ុន។"]

1338 ឯកសារ **D215/1.1.1** កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ EN 01030495 ["ប្រជាជនមកពី៥ឃុំ ចូលរួមក្នុងការលើកទំនប់ [ស្ពានស្រែង និងព្រៃរនាម]។ ប្រជាជនប្រហែល២០០ ទៅ៣០០នាក់ ត្រូវបាន បញ្ជូនពីឃុំនីមួយៗ យោងតាមចំនួន

ប្រជាជន"]។ ឯកសារ **D219/264.1** ប្រតិចារឹកបទសម្ភាសន៍ជាមួយ អ៊ឹម ចែម ឆ្នាំ ២០១១ KH 01107041 ["អាហ្នឹងចែក គាត់ហ្នឹង ចែកគ្នា។ ឃុំមួយៗកម្លាំងរបស់គាត់ចែកម្នាក់ៗត្រូវទទួលប៉ុន្មានម៉ែត្រអីចឹងទៅ។"]។

1339 ឯកសារ **D219/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.103 KH 01049236 [សាក្សីធ្វើការជាកងចល័តនៅស្នាយស្រែង៖ "តាពាល់ដែលជាអ្នកកមកពីនីរតី។"] ឆ.228 KH 01049249 ["ប្រឡាយនេះ គឺតាពាល់ជាអ្នកគ្រប់គ្រងបន្ត [ស្ពានស្រែង] ពេលពួកនីរតីមកដល់។"] ឆ.79-80 KH 01049234 [...តាពាល់ [...] គាត់ជាប្រធានកងចល័ត។"]។ ឯកសារ **D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.26 KH 0978912 [សាក្សីដឹកនាំកងចល័តឃុំ ដែលមានប្រហែល២០០នាក់ នៅស្ពានស្រែង និងអូរលៀប៖ "នៅពេលនោះ កម្លាំងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំក្នុងកងចល័តឃុំ គឺមានប្រហែល២០០ នាក់ ហើយយើងបានទៅលើកទំនប់ស្ពានស្រែងនៅដើមឆ្នាំ១៩៧៨។"] ឆ.31 KH 0978912 ["ខុន ជាប្រធានគ្រប់គ្រងកងចល័តស្រុកព្រះនេត្រព្រះទាំងមូល។ ខ្ញុំទទួលបញ្ជាដោយផ្ទាល់ពីខុន ជួនកាល តារន និងតាពាល់ អ្នកនីរតី) បានពិនិត្យមើល) ការដ្ឋានផ្ទាល់។"]។ ឯកសារ **D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ.29 KH 00976178 [ជាប្រធានកងចល័ត៣០នាក់ ដែលត្រូវបានចាត់ឱ្យទៅធ្វើការនៅស្ពានស្រែង៖ "ស៖ នៅទំព័រ១២ ដដែល [នៃកិច្ចសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (ERN 00730228)] លោកបាននិយាយអំពីអ្នកនៅក្នុងកងរបស់លោក ដែលស្គមស្គាំង ហើយបានរត់ ហើយត្រូវបានកូនចៅយាយចែម ចាប់ដាក់នៅមន្ទីរសន្តិសុខ។ តើលោកអាចពន្យល់បញ្ជាក់បន្ថែមបានដែរទេ ?ឆ.29៖ ពេលនោះដោយសារ កូនក្រុមរបស់ខ្ញុំស្គមស្គាំង ពួកគេក៏បានរត់ចេញពីការដ្ឋាន។ ពេលនោះ ពួកឈ្លបដែលជាកូនចៅរបស់យាយ ចែម បានចាបពួកគេ។ ក្រោយពីពួកគេទាំងនោះ ត្រូវបានគេសួរថា តើលួចរត់មកពីកងណា ហើយពួកគេបានប្រាប់ថា ពួកគេបានលួចរត់មកពីកងរបស់ខ្ញុំ។ ដូច្នេះហើយ បានជាយាយចែម បានប្រាប់ទៅ តាពាល់ ហើយ តាពាល់ បានប្រាប់មកខ្ញុំឱ្យទៅទទួលយកកូនក្រុមរបស់ខ្ញុំមកការដ្ឋានវិញ។"]។ ឯកសារ **D119/121** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ ឆ.26 KH 00985870-00985871 [ដឹកនាំកងចល័តឃុំដែលមានប្រហែល២០០នាក់ នៅស្ពានស្រែង និងអាងស្តុកទឹកអូរលៀប៖ "ស៖ នៅក្នុងកិច្ចសម្ភាសន៍របស់ ប៊ូ ម៉ៅ (Dl19/94) នៅទំព័រទី៧ ជាភាសាខ្មែរ ប៊ូ ម៉ៅ បាននិយាយថា អ្នកធ្វើការនៅការដ្ឋានដែលស្គមស្គាំង ហើយបានលួចរត់ ពេលនោះ ត្រូវបានកូនចៅយាយចែមចាប់ដាក់នៅមន្ទីរសន្តិសុខ ហើយក្រោយមក គាត់ត្រូវបានតាពាល់ ប្រាប់ឱ្យទៅយកមកការដ្ឋានវិញ។ តើលោកដឹងពីព្រឹត្តិការណ៍នោះដែរឬទេ?"]ឆ.32 KH 00985871 ["ខ្ញុំត្រូវរាយការណ៍ទៅតាពាល់ ហើយតាពាល់ត្រូវរាយការណ៍ទៅយាយចែម។ នៅពេលនោះ យាយចែម បានឱ្យឈ្លបចុះទៅតាមសហករណ៍ដើម្បីឱ្យប្រធានសហករណ៍ ឬគណៈឃុំស្វែងរកមនុស្សទាំងនោះត្រឡប់មកការដ្ឋានវិញ។"] KH 00985872 ["ស៖ តើលោកអាចពន្យល់បញ្ជាក់ដល់យើងបានទេថា លោកបានធ្វើការនៅទំនប់ភ្នំលៀប ថាតើហេតុអ្វីបានជាលោកមកឈរនៅមុខផ្ទះយាយចែមទៅវិញ ?ឆ.40៖ មូលហេតុដែលខ្ញុំមកឈរនៅផ្ទះយាយ ចែមដោយសារពេលនោះខ្ញុំបានជូន ខុន ដែលជាអនុរបស់តាពាល់មកប្រជុំនៅមន្ទីរភ្នំលៀប។ កិច្ចប្រជុំនោះគឺធ្វើសម្រាប់តែគណៈឃុំតែប៉ុណ្ណោះ គេមិនឱ្យខ្ញុំចូលរួមក្នុងកិច្ចប្រជុំនោះទេ។"]។ ឯកសារ **D219/455** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួរ ចាន់សារ៉េត ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ ឆ.68 KH 01129816 [សាក្សីធ្វើការនៅកងចល័តតំបន់៥៖ "ពេលដែលខ្ញុំទៅទីនោះ [មន្ទីរអ៊ឹម ចែម នៅ ភ្នំលៀប] ខ្ញុំឃើញមានយោធា៤ ឬ៥នាក់ និងយាយចែមតែ ប៉ុណ្ណឹង។ មុនចូលទៅ

ជួប យាយថែម តាពាល់បានចេញលិខិតឧទ្ទេសនាមឱ្យខ្ញុំកាន់ដើម្បីចូលជួបយាយថែម។ ពេលទៅដល់កន្លែងយាយថែម ខ្ញុំហុចលិខិតឧទ្ទេសនាមទៅសន្តិសុខ ថាខ្ញុំចង់ជួបយាយថែម។ ពេលនោះ សន្តិសុខឱ្យខ្ញុំចូលជួបយាយ ថែម។"] ឆ.91 KH 0119820 ["បើគិតតាមឋានានុក្រម តាពាល់ជាប្រធានចល័តតំបន់ ចំណែកយាយថែមជាគណៈស្រុក ដូច្នេះឋានៈតាពាល់គួរណាតែខ្ពស់ជាងយាយថែម តែតាមការសង្កេតឃើញថា តាពាល់ដូចជាគោរពកោតខ្លាចយាយថែមខ្លាំងណាស់។ [...] បានន័យថាយាយថែម ប្រាកដជាមានឋានៈអ្វីមួយខ្ពស់ជាងតាពាល់។ ខ្ញុំសង្កេតឃើញផងដែរថា ក្នុងចំណោមគណៈស្រុកទាំងអស់ យាយថែមមានអំណាចលើសគេ។ [...] ខ្ញុំឃើញ តាពាល់ ដូចជាគោរពគាត់ណាស់។"]។ **ឯ**កសារ **D119/98** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.39 KH 00978914 [សាក្សីដឹកនាំកងចល័តឃុំដែលមានប្រហែល ២០០នាក់ នៅស្ពានស្រែង និងអាងស្តុកទឹកអូរលៀប៖ "ខ្ញុំបានទៅជួបយាយ ថែម នៅមន្ទីរភ្នំលៀប នៅពេលដែលខ្ញុំជូនមេរបស់ខ្ញុំ ឈ្មោះ ខុន ឬពាល់ទៅចូលរួមប្រជុំជាមួយ យាយ ថែម នៅទៅនោះ តាំងពីឆ្នាំ១៩៧៨ រហូតដល់វៀតណាមចូល។ ការប្រជុំជាមួយ យាយ ថែម គឺមិនទៀង ជួនកាលមួយអាទិត្យម្តង ជួនកាលពីរអាទិត្យម្តង ឬមួយខែ នៅពេលដែលការងារ រវាល់ឬជួនកាលគាត់ទៅប្រជុំនៅការដ្ឋានតែម្តង។"]។ **ឯ**កសារ **D123/1/2.44** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម គឹមរស់ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ KH 00927071-00927072 [សាក្សីធ្វើការនៅកងចល័តនៅទំនប់ស្ពានស្រែងក្នុងឆ្នាំ១៩៧៨៖ ["វណ្ណៈ៖ តើនរណាជំនួសតាវាល់? គឹម រស់៖ តាពាល់ ជំនួសតាវ៉ាល់។ វណ្ណៈ៖ តើតាពាល់ជាគណៈតំបន់ ឬគណៈស្រុក? គឹម រស់៖ [...] គាត់មានឋានៈស្មើតាវ៉ាល់។ គាត់ជំនួសតាវ៉ាល់។"] KH 00927072 ["តាពាល់ [...] ជាអ្នកដែលចុះមកមើល រដ្ឋាន)។កា)"]។ **ឯ**កសារ **D67.9** កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឈិត យឿក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១ KH 00728820 [ប្រធានផ្នែកសេដ្ឋកិច្ចភ័ស្តុភាក្នុងស្រុកព្រះនេត្រព្រះ៖ "ស៖ ចុះកាលនោះពេលដែលចាប់ តាវ៉ាល់ ខែ៦ហ្នឹង គេតែងតាំងអ្នកណាជំនួយស។ [...] យ៉ាន់ ហើយតាពាល់។"] *ផ្ទុយទឹង* ឯកសារ **D119/110** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ហៅ ញ៉ុន ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.95 KH 00980398 [សាក្សីជាមេឃុំភ្នំលៀប៖ "ខ្ញុំធ្លាប់ឮតាម៉ោង គាត់អាចមានតួនាទីជាថ្នាក់តំបន់ ប៉ុន្តែពេលខ្ញុំទៅដល់គាត់បានបាត់ខ្លួនទៅហើយ។ ខ្ញុំធ្លាប់ឮឈ្មោះតាវាល់ គាត់អាចមានតួនាទីជាគណៈតំបន់ ប៉ុន្តែពេលខ្ញុំទៅដល់ គាត់បាត់ខ្លួនដែរ។ [សូមមើល KH 00980383៖ "សាក្សីប៉ាន់ស្មានថាគាត់មកដល់ព្រះនេត្រព្រះនៅចុង ឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។"]។

1368 ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ធិប សំផាត់ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927407 [សាក្សីជាពេទ្យនៅភ្នំលៀប ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅភ្នំត្រយោងក្នុងឆ្នាំ ១៩៧៨៖ "ដារ៉ា៖ ចុះពេលដែលមក ដែលពូក្រោយមកដែលមានជាប់គុកហ្នឹង រាប់ពាន់គ្រួសារមកនឹង មកមានទាំងក្មេង មានទាំងចាស់ ទាំងប្រុសទាំងស្រី? សំផាត់៖ បាទ! ជួនកាលមកទាំងគ្រួសារ ដូចថាម៉ាគ្រួសារដែលខុសទៅ គេបញ្ជូនគ្រួសារចូលមក [មន្ទីរភ្នំត្រយោង]"] KH 00927406 ["មានអ្នកទោសច្រើន ប្រហែលមួយពាន់គ្រួសារ"]។ ឯកសារ D119/133 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និត ស៊ត់ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.48 KH 00994181 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅស្រុកព្រះនេត្រព្រះ រួមទាំងនៅអូរលៀប និងឃុំភ្នំលៀប និងឃុំប្រាសាទ៖ "តាមបទពិសោធន៍របស់ខ្ញុំនៅជំនាន់នោះ បើមាននរណាម្នាក់ត្រូវបានចាត់ទុកថាជាខ្មាំងរបស់អង្គការហើយ ភាគច្រើនគឺត្រូវបានគេហៅឱ្យទៅរៀនសូត្រ ហើយអ្នកនោះមិនដែលឃើញត្រឡប់មកវិញទេ។ នៅក្នុងរបបនោះ គេមិនដែលនិយាយថាយកទៅសម្លាប់ទេ គេនិយាយថាយកទៅរៀនសូត្រ ហើយអ្នកដែលគេយកទៅរៀនសូត្រនោះមិនដែលឃើញវិលត្រឡប់មកវិញឡើយ"]។ ឯកសារ D219/149 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជុំ ជិម ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៥ ឆ.16 KH 01058727 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅប្រឡាយស្ពានស្រែង៖ "ខ្ញុំគ្រាន់តែឮពីក្រុមគ្នាឯងនិយាយគ្នាអំពីរឿងបាត់ខ្លួនមនុស្ស ដូច្នេះហើយខ្ញុំខ្លួនឯងក៏ខ្លាច ហើយសម្រេចរត់តែម្តង"]។ ឯកសារ D119/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.14 KH 00978910 [សាក្សីដឹកនាំកងចល័តឃុំដែលមានសមាជិកចំនួន ២០០ នាក់នៅអាងស្ពានស្រែង និងអូរលៀប៖ "ជាការពិត គឺបានកើតឡើងដូចនេះមែន ប៉ុន្តែខ្ញុំមិនដឹងថាគេយកទៅសម្លាប់ទីកន្លែងណាទេ ខ្ញុំបានដឹងត្រឹមតែថាមានមនុស្សបាត់ខ្លួននៅតាមកងចល័តនានានៅក្នុងតំបន់៥។ ក្រោយមក ទើបខ្ញុំបានដឹងថាគេចាប់មនុស្សយកទៅសម្លាប់នៅភ្នំត្រយោងដែលជាកន្លែងវ៉ៃថ្ម"]។ ឯកសារ D119/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឆ.71 KH 00969035 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅទំនប់ស្ពានស្រែង៖ "ខ្ញុំមិនបានឃើញទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាមានការបាត់ខ្លួន។ ខ្ញុំមិនដឹងថាអ្នកនោះត្រូវបានបញ្ជូនទៅការដ្ឋានកន្លែង ឬយ៉ាងណាទេ"]។ ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.42 KH 01148732 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "ខ្ញុំមិនបានឃើញមនុស្សត្រូវបានគេចាប់ខ្លួនទេ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាមានមនុស្សបាត់ខ្លួនដោយមិនដឹងមូលហេតុ ដូចជាអ្នកធ្វើការនៅក្នុងក្រុមរបស់ខ្ញុំជាដើម។ ខ្ញុំមិនដឹងថាមានមនុស្សប៉ុន្មាននាក់បាត់

ខ្លួនទេ ប៉ុន្តែនៅក្នុងក្រុមរបស់ខ្ញុំ មានមនុស្សបាត់ខ្លួន ដូច្នេះនៅក្នុងក្រុមផ្សេង ក៏អាចមានមនុស្សបាត់ខ្លួនដែរ។ នៅពេលនោះ គឺមានមនុស្សរាប់ពាន់នាក់ធ្វើការនៅក្នុងកងចល័ត"] ឆ.43 KH 01148733 ["ក្រោយពេលយាយ ថែម ចូលមកគឺមានមនុស្សបាត់ខ្លួនច្រើន និងត្រូវបានចាប់ខ្លួន។ ខ្ញុំបានឮថានៅជិតចុងបញ្ចប់នៃរបបខ្មែរក្រហម គេបានជីករណ្តៅធំ និងត្រៀមរៀបចំធ្វើនំបញ្ចុកឲ្យប្រជាជនក្នុងកងចល័តហូប ហើយសម្លាប់ពួកគេទាំងអស់។ ប៉ុន្តែគម្រោងការនេះមិនបានសម្រេចឡើយដោយសារតែប្រទេសត្រូវបានរំដោះមុន"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.147-148 KH 01049241 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅស្ពានស្រែង៖ "ស៖អ្នកដែលខុសសីលធម៌ជាអ្នកកម្មាភិបាល ឬក៏ជាអ្នកធ្វើការធម្មតា? ឆ.147៖ ភាគច្រើនអ្នកធ្វើការនៅកងចល័ត។ នៅពេលនោះមានយុវជនក្នុងកងចល័តស្គាល់គ្នាជាមួយនឹងនារី ហើយចែកម្ហូបអាហារគ្នាហូប គេនឹងចោទថាខុសសីលធម៌ ហើយនឹងចាប់ទាំងពីរនាក់យកទៅសម្លាប់។ [...] ឆ.148៖ ខ្ញុំគ្រាន់តែដឹងថាព្រឹកឡើងបាត់ខ្លួនគាត់តែម្តង"]។

1369 ឯកសារ **D106/10** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រីម សឺត ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ឆ.21 KH 00800995 [សាក្សីជាអ្នកធ្វើនៅកងចល័តនៅព្រៃរនាម៖ទាក់ទងការចាប់មនុស្សនៅការដ្ឋានព្រៃរនាម៖ "នៅពេលយប់។ ពួកយោធាបានទៅចាប់មនុស្សពីរោងដោយបានដឹងជាមុនពីអ្នកដែលត្រូវចាប់ខ្លួន។ ខ្ញុំគិតថាពួកយោធាមានឈ្មោះមនុស្សដែលត្រូវចាប់ខ្លួនហើយ"] ឆ.22 KH 00800996 ["មិនមានការចាប់ខ្លួននៅពេលថ្ងៃទេ ហើយប្រហែលជាប្រធានសហករណ៍ជាអ្នកឲ្យឈ្មោះអ្នកដែលត្រូវគេចាប់ខ្លួននោះទៅឲ្យពួកយោធាហើយ។ ខ្ញុំនិយាយដូច្នេះព្រោះប្រធានសហករណ៍ជាអ្នកត្រួតពិនិត្យការងាររបស់យើងនៅពេលថ្ងៃ"]។

1370 ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.252 KH 01049251 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅស្ពានស្រែង៖ "ប្រហែលជាបីថ្ងៃទៅមួយអាទិត្យ មានមនុស្សបាត់ប្រហែលពីរទៅបីនាក់"]។ ឯកសារ D219/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.28 KH 01066001 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅការដ្ឋានស្ពានស្រែង៖ "មុនពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មិនសូវខ្លាំងប៉ុន្មានទេ ប៉ុន្តែក្រោយពេលកម្មាភិបាលនិរតីមកដល់ ការចាប់ខ្លួន និងសម្លាប់មនុស្សរឹតតែខ្លាំងៗឡើង"]។ ឯកសារ D219/357 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.73 KH 01104647 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅព្រះនេត្រព្រះ រួមទាំងទំនប់ស្ពានស្រែង (១៩៧៨) និងព្រៃរនាម៖ "ស៖នៅពេលដែលលោកធ្វើការនៅការដ្ឋានស្ពានស្រែងដែលមានមនុស្ស១៥០នាក់ តើមានសមាជិកណាម្នាក់ក្នុងកងរបស់លោកត្រូវបានចាប់ខ្លួន ឬស្លាប់ដោយការសម្លាប់ដែរឬទេ"? ឆ៖ មានអ្នកដែលត្រូវគេចាប់ខ្លួន ប៉ុន្តែនៅពេលនោះ យើងមិនប៊ាននិយាយអំពីអ្នកណាម្នាក់ត្រូវបានចាប់ខ្លួនទេ"]។ ឆ.75 KH 01104647 ["នៅពេលដែលយើងនៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យគឺត្រូវបានចាប់ខ្លួនដោយពួកពាយ័ព្យ ហើយនៅពេលដែលធ្វើការនៅក្រោមពួកនិរតីត្រូវបានចាប់ខ្លួនដោយពួកនិរតី"]។ ឯកសារ D119/97 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លន់ រួប ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.10 KH 00978904 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅទំនប់ស្ពានស្រែងក្នុងអំឡុងចុងឆ្នាំ១៩៧៧-១៩៧៨៖ "ខ្ញុំមិនដែលឃើញគេសម្លាប់មនុស្សនៅការដ្ឋាននោះទេ [...] តែខ្ញុំបានឃើញផ្ទាល់ភ្នែកគឺមនុស្សពីរនាក់ក្នុងក្រុមរបស់ខ្ញុំ ដែលកំពុងរែកដី ត្រូវយោធាចាប់ដឹកឆ្ពោះទៅទិសខាងត្បូង តែមិនដឹងយកទៅទីណាទេ។

ចំណែកអ្នកឈឺនៅការដ្ឋានត្រូវបានគេបញ្ជូនមកមន្ទីរពេទ្យក្រឡាញ់ ហើយមិនឃើញត្រឡប់ទៅវិញទេ”] KH 00978905 “មានការចាប់មនុស្សច្រើនពីចុងឆ្នាំ១៩៧៧ និងក្នុងឆ្នាំ១៩៧៨ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកនិរតី”]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.20 KH 00915874 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ “ខ្ញុំបានឃើញគេចាប់មនុស្សជាច្រើននៅតាមការដ្ឋាន ប៉ុន្តែខ្ញុំមិនបានឃើញគេសម្លាប់ផ្ទាល់ភ្នែកទេ។ មនុស្សដែលគេចាប់នោះគឺត្រូវបានគេយកចេញទៅក្រៅ។ ការចាប់ខ្លួនមនុស្សភាគច្រើនគឺនៅព្រះនេត្រព្រះមានច្រើនជាងនៅទំនប់ស្ពានស្រែង។ ខ្ញុំនិយាយនេះគឺនិយាយតែនៅក្នុងកងចល័តកុមារ ប៉ុន្តែខ្ញុំដឹងថានៅក្នុងកងចល័តយុវជននិងវ័យកណ្តាល គឺមានការចាប់ខ្លួនច្រើនជាងនេះ”]។

1371 ឯកសារ D119/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ហៅ ញ៉ុន ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ឆ.87 KH 00980395 [សាក្សីជាប្រធានឃុំភ្នំលៀប៖ “នៅពេលយើងចាប់បាន យើងត្រូវបញ្ជូនមនុស្សនោះទៅមន្ទីរភ្នំត្រយ៉ូង ហើយបើប្រធានមន្ទីរភ្នំត្រយោងគេនឹងចាត់ការទៅតាមសមត្ថកិច្ចរបស់គេផ្ទាល់”]។ ឯកសារ D219/381 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ រត្តនា ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.13 KH 01113201 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅការដ្ឋានស្ពានស្រែង (ចំនួន៩ខែ)៖ “អ្នកដែលមិនអាចរែកដីបានត្រូវធ្វើជីអាចម៍យកមកហាលឱ្យស្ងួត។ គេឱ្យយើងដកសំណាប ត្រូវលាងទឹកឱ្យស្អាត ដោយដកម្តងមួយដើម ប្រសិនបើយើងធ្វើឱ្យដាច់ដើមសំណាប យើងនឹងត្រូវយកទៅសម្លាប់។ នៅពេលស្ទូង យើងត្រូវដោតម្តងពីរដើម បើស្ទូងលើសពីពីរដើម គេថាក្បត់”]។ ឯកសារ D119/120 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឆ.92 KH 00984315 [សាក្សីជាអ្នកធ្វើការនៅកងកុមារនៅស្ពានស្រែង និងភ្នំស្រុក ត្រពាំងថ្ម-ព្រំប្រទល់ខាងជើងស្ពានស្រែង៖ “ស៖ ប្រសិនបើមានមនុស្សរត់ចេញពីការដ្ឋាននោះ តើមានរឿងអ្វីកើតឡើងចំពោះពួកគេ? ឆ៖ ប្រធានក្រុមនឹងដឹង”]។

1372 ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ KH 00976178 [ប្រធានកងចល័តដែលមានមនុស្សចំនួន ៣០ នាក់ដែលត្រូវបានចាត់តាំងទៅស្ពានស្រែង៖ “ឆ.29៖ នៅពេលនោះដោយសារកូនប្រុសរបស់ខ្ញុំស្គមស្គាំង ពួកគេក៏បានរត់ចេញពីការដ្ឋាន។ ពេលនោះ ពួកឈ្លបដែលជាកូនចៅរបស់យាយ ចែម បានចាប់ពួកគេ។ ក្រោយពីពួកគេទាំងនោះត្រូវបានគេសួរថាតើលួចរត់មកពីកងណា ហើយពួកគេបានប្រាប់ថាពួកគេបានលួចរត់មកពីកងរបស់ខ្ញុំ។ ដូច្នេះហើយបានជាយាយ ចែម បានប្រាប់ទៅ តា ពាល់ ហើយតា ពាល់ បានប្រាប់មកខ្ញុំឱ្យទៅទទួលយកកូនក្រុមរបស់ខ្ញុំមកការដ្ឋានវិញ”]។ ឯកសារ D119/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡុន ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៤ KH 00985870 [បានដឹកនាំកងចល័តឃុំដែលមានមនុស្សចំនួន ២០០ នាក់នៅស្ពានស្រែង និងអាងអូរលៀប៖ “ស៖ នៅក្នុងកិច្ចសម្ភាសន៍របស់ ប៊ូ ម៉ៅ (ឯកសារ D119/94)...គាត់និយាយថាអ្នកធ្វើការនៅការដ្ឋានដែលស្គមស្គាំង ហើយបានលួចរត់ ពេលនោះត្រូវបានកូនចៅយាយ ចែម ចាប់ដាក់នៅមន្ទីរសន្តិសុខ ហើយក្រោយមកគាត់ត្រូវបាន តា ពាល់ ប្រាប់ឱ្យទៅយកមកការដ្ឋានវិញ។ តើលោកដឹងពីព្រឹត្តិការណ៍នោះដែរឬទេ? ឆ.26៖ បាទ អ្វីដែល ប៊ូ ម៉ៅ និយាយគឺត្រឹមត្រូវហើយ។ KH 00985870 [“ស៖តើលោកផ្ទាល់ធ្លាប់បានទៅយកកូនក្រុមរបស់លោកមកការដ្ឋានវិញដែរឬទេ? ឆ.27៖ ទេ ខ្ញុំមិនដែលទៅទេ។ តាមខ្ញុំដឹងនៅពេលនោះ អ្នកដែលធ្វើការនៅការដ្ឋាន ហើយដែលបានលួចរត់ត្រឡប់ទៅសហករណ៍វិញ ហើយក្រោយមកត្រូវបានកូនចៅយាយចែមចាប់ ប្រសិនជាពួកគេនៅមានកម្លាំងអាចនៅធ្វើការបានមិនត្រូវបានគេបញ្ជូនមកការដ្ឋានទេ ហើយប្រហែលគេបញ្ជូនទៅ

សហករណ៍វិញ ឬទៅតាមមន្ទីរពេទ្យ។ [...] សៈ តើនរណាគេជាអ្នកមកប្រាប់លោកថាមានកូនក្រុមរបស់លោកបានលួចរត់ពីការដ្ឋាន ត្រូវបានកូនចៅយាយ ចែម ចាប់ហើយឲ្យលោកទៅយកពួកគេត្រឡប់មកការដ្ឋានវិញនោះ? ឆ.28ៈ នីរសាររបស់យាយ ចែម ជាអ្នកមកប្រាប់ខ្ញុំ"]។ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234222 ["(ប្រជាជន) "សប្បាយ" ធ្វើការ ប្រឹងទាំងយប់ថ្ងៃ (នៅការដ្ឋាន) ដោយគ្មានការត្រួតត្រា"]។

1373 ឯកសារ D219/357 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហ៊ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.77 KH 01104647 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅព្រះនេត្រព្រះ រួមទាំងទំនប់ស្ពានស្រែង (១៩៧៨) និងព្រៃរនាមៈ "លោកនិយាយថាគេចាប់បញ្ជូនទៅភ្នំត្រយោងនិងយកទៅសម្លាប់។ តើការសម្លាប់នេះសម្លាប់នៅកន្លែងណាដែរ? ឆៈ គេសម្លាប់នៅភ្នំត្រយោងផងដែរ"] ឆ.76 KH 01104647 ["សៈ នៅពេលដែលមនុស្សមួយចំនួនត្រូវបានចាប់ខ្លួនដោយពួកពាយ័ព្យ ឬដោយពួកនិរតី តើពួកគេទាំងនោះត្រូវបានបញ្ជូនទៅកន្លែងណា? ឆៈ ពួកគេទាំងនោះត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខភ្នំត្រយោង ឬយកទៅសម្លាប់"] ឆ.79-80 KH 01104648 ["គេចាប់ខ្លួនខ្ញុំហើយបញ្ជូនទៅភ្នំត្រយោងនៅពេលដែលខ្ញុំកំពុងធ្វើការនៅស្ពានស្រែង។ សៈ តើលោកត្រូវបានគេចាប់ខ្លួនលោកនៅពេលដែលពួកនិរតីគ្រប់គ្រងការដ្ឋានស្ពានស្រែងនោះឬ? ឆៈ បានត្រឹមត្រូវហើយ"] ឆ.85 KH 01104649 ["ខ្ញុំមិនដឹងពីមូលហេតុទេ មុនដំបូងឈ្លបមកចាប់ខ្ញុំចងស្លាបសេក ហើយគេបណ្តើរខ្ញុំទៅកាន់ភ្នំត្រយោងតែម្តង។ នៅពេលដែលខ្ញុំទៅដល់ភ្នំត្រយោងភ្លាម គេក៏ដាក់ខ្នោះខ្ញុំតែម្តង។ គេចាប់ខ្លួនខ្ញុំនៅម៉ោងប្រហែល៨ព្រឹក។ ខ្ញុំមិនដឹងថានរណាជាអ្នកបញ្ជាឲ្យចាប់ខ្លួនខ្ញុំទេ ប៉ុន្តែគឺមានអ្នកដែលធ្វើការជាមួយគ្នានិយាយបង្ខូចគ្នា ហើយបានរាយការណ៍ទៅឲ្យពួកឈ្លប ហើយពួកឈ្លបក៏ចាប់ខ្ញុំទៅ។ តាមពិត ខ្ញុំមិនបានធ្វើអ្វីខុសទេនៅពេលនោះ តែដោយសារនៅពេលនោះ គេចោទខ្ញុំថាមើលងាយអង្គការហើយខ្ជិលធ្វើការ ដូច្នេះហើយបានជាគេចាប់ខ្លួនខ្ញុំ"] ឆ.86 KH 01104649 ["មានតែខ្ញុំម្នាក់ទេ គេចាប់ខ្ញុំម្នាក់ឯង ហើយបណ្តើរខ្ញុំទៅភ្នំត្រយោង"]។ ឯកសារ D119/97 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លន់ រួប ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.12 KH 00978904 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅស្ពានស្រែងក្នុងអំឡុងចុងឆ្នាំ ១៩៧៧-១៩៧៨ៈ "ខ្ញុំឮថាមានមន្ទីរសន្តិសុខមួយនៅភ្នំត្រយោង។ ចំណែកអ្នកដែលគេចាប់យកមកដាក់នៅមន្ទីរសន្តិសុខដូវតន្ត្រី គឺសុទ្ធតែអ្នកស្រុកក្រឡាញ់ និងអ្នកស្រុកស្រីស្នំ"] ឆ.5 KH 00978903 ["ពួកនិរតីចូលដល់ស្រុកក្រឡាញ់ប្រហែលជានៅក្នុងខែ មិថុនា ឬ ខែ កក្កដា ១៩៧៧។ ពេលពួកនិរតីមកដល់ គេបានស្រាវជ្រាវរកកម្មាភិបាលពាយ័ព្យចាប់ពីសហករណ៍ ថ្នាក់ឃុំ និងស្រុកឡើងទៅ ហើយបានចាប់យកមកដាក់នៅមន្ទីរសន្តិសុខនៅខាងលិចភ្នំទ្រង់បាតក្នុងភូមិដូវតន្ត្រី ឃុំកំពង់ថ្កូវ ហើយក្រោយមកទើបគេបញ្ជូនយកទៅសម្លាប់នៅភ្នំទ្រង់បាត"] ឆ.5 KH 00978903 ["មនុស្សដែលគេចាប់យកមកដាក់មន្ទីរសន្តិសុខក្នុងភូមិដូវតន្ត្រីនោះ ត្រូវបានគេទុកពីរបីថ្ងៃដើម្បីសួរចម្លើយ រួចហើយគេបញ្ជូនយកទៅសម្លាប់នៅភ្នំទ្រង់បាត។ មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សនោះត្រូវបានបង្កើតឡើងដោយពួកពាយ័ព្យ"] ឆ.11 KH 00978904 ["នៅពេលដែលខ្ញុំធ្វើការដ្ឋានទំនប់ស្ពានស្រែង ខ្ញុំធ្លាប់បានឮគេនិយាយថាមានមនុស្សនៅធ្វើការទីនោះត្រូវបានគេបញ្ជូនមកឃុំឃាំងក្នុងភូមិដូវតន្ត្រី ហើយក្រោយមកយកទៅសម្លាប់នៅភ្នំទ្រង់បាត"] ឆ.12 KH 00978904 ["ខ្ញុំឮថាមានមន្ទីរសន្តិសុខមួយនៅភ្នំត្រយោង។ ចំណែកអ្នកដែលគេចាប់យកមកដាក់នៅមន្ទីរសន្តិសុខភូមិដូវតន្ត្រី គឺសុទ្ធតែអ្នកស្រុកក្រឡាញ់ និងអ្នកស្រុកស្រីស្នំ"]។

1374 ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.38 KH 01148731 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "ស្ថានភាពរស់នៅរបស់ប្រជាជនមានស្ថានភាពអាក្រក់ជាងមុនពីព្រោះគ្រួសាររបស់ខ្ញុំ រួមមានឪពុកម្តាយ និងបងប្អូនត្រូវបានគេចាប់យកទៅសម្លាប់ដោយមិនដឹងមូលហេតុ"]។ ឯកសារ D219/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.13 KH 01065999 ["អ្នកធ្វើការនៅកងចល័តនៅការដ្ឋានស្ពានស្រែង ប្រសិនបើអ្នកណាម្នាក់បាត់ខ្លួននោះ គឺមានន័យថាអ្នកនោះត្រូវគេយកទៅសម្លាប់ហើយ។ មិនមែនមានន័យថាគេយកអ្នកនោះទៅកន្លែងផ្សេងទេ"]។ ឯកសារ D119/97 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លន់ រូប ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.11 KH 00984921 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅទំនប់ស្ពានស្រែងក្នុងចុងឆ្នាំ១៩៧៧-១៩៧៨៖ "នៅពេលធ្វើការនៅទំនប់ស្ពានស្រែង ខ្ញុំបានឮថាអ្នកខ្លះត្រូវបានគេបញ្ជូនយកទៅឃុំនៅភូមិដូរតន្ត្រីមុនពេលគេយកទៅសម្លាប់ទៅភ្នំទ្រង់បាត"]។ ឯកសារ D123/1/2.66 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ធិប សំផាត់ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១១ KH 00927406 [ពេទ្យនៅភ្នំលៀប ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅភ្នំត្រយោងក្នុងឆ្នាំ១៩៧៨៖ "មានខ្លះដែររត់ ហើយខ្លះក៏រត់រួចទៅ [ពីភ្នំត្រយោង] ហើយខ្លះក៏រត់ហើយចាប់វិញបានទៅ។ ដារ៉ា៖ អាចាប់បានវិញគេធ្វើម៉េច? សំផាត់៖ អាចាប់បានវិញដឹងតែងាប់ហើយ។ [...] បើសិនជាគេតាមទាន់កំពុងរត់ក៏គេបាញ់ បើសិនជាគេចាប់បានមកនៅរស់គេយកមកវ៉ៃចោល"] KH 00927407 ["ដូចថាអ្នកដែលគេបញ្ជូនទៅថាវាទោសធ្ងន់ទៅគេយកទៅដាក់ខ្នោះ។ ដល់ថ្ងៃគេយកទៅវ៉ៃចោល"]។

1375 ឯកសារ **D219/357** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាន ស ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.74 KH 01104647 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅព្រះនេត្រព្រះ រួមទាំងទំនប់ស្ពានស្រែង និងព្រៃរនាម៖ (១៩៧៨)"មនុស្សជាច្រើនត្រូវបានចាប់ខ្លួន ហើយប្រជាជនថ្មីមកជំនួស"]។

1376 ឯកសារ D6.1.710 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464718 ["ការតភ្ជាប់គ្នារវាងទំនប់ខាងឧត្តរ/ទក្សិណ និងទំនប់ខាងមជ្ឈិម/បូព៌ា និងទីកន្លែងគំនរថ្ម/សញ្ញា៖ N13 47.054' E103 18.284"] KH 00464719 ["ត្រពាំងថ្មមានទីតាំងក្នុងទឹកដីនៃតំបន់ពាយ័ព្យនៃភូមិប៉ោយចារ ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ"]។ ឯកសារ D6.1.822 សេវាផ្សព្វផ្សាយក្នុងស្រុកប្រចាំទីក្រុងភ្នំពេញ ពីខែ ឧសភា ឆ្នាំ ១៩៧៨ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៧៨ EN 00170047 [របាយការណ៍សហកាលស្តីពីការវិវត្តន៍នៃការកសាងអាង៖ "ជាឧទាហរណ៍ អាងត្រពាំងថ្មនៅភ្នំស្រុក ខេត្តបាត់ដំបង អាងដ៏ធំដោយមានលទ្ធភាពផ្ទុកទឹក២រយលានម៉ែត្រគុប កសាងហើយតែក្នុងពេល១ឆ្នាំ"]។ ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សាក្សីជាអ្នកធ្វើការ និងក្រោយមកជាប្រធានកងនៅត្រពាំងថ្ម៖ "ទំនប់ត្រពាំងថ្មស្ថិតនៅភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ"]។ ឯកសារ D6.1.448 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ ហុច ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៩ KH 00279127 [សាក្សីធ្វើការនៅកងចល័តកុមារនៅត្រពាំងថ្ម៖ "ទំនប់នោះស្ថិតនៅខាងលិចភូមិត្រពាំងថ្ម និងភូមិមួយចំនួនទៀតនៅក្នុងស្រុកភ្នំស្រុក"]។ ឯកសារ D119/132 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉េង ឆាន ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.76 KH 00997306 [សាក្សីជាអ្នកធ្វើការនៅត្រពាំងថ្ម៖ "មានទីតាំងក្នុងស្រុកភ្នំស្រុក"]។ ឯកសារ D119/120 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឆ.104 KH 00984317 [សាក្សីជាអ្នកធ្វើការនៅត្រពាំងថ្មនៅពេលកម្មាភិបាលនិរតីចូលកាន់កាប់៖ "ទំនប់ត្រពាំងថ្មមានទីតាំងនៅភូមិត្រពាំងថ្ម ឃុំតាណាវ ស្រុកភ្នំស្រុក"]។ ឯកសារ D6.1.450 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH 00279105 [សាក្សីជាប្រធានកងចល័ត ដែលស្ថិតនៅទីតាំងនោះរហូតដល់ដំណាច់ឆ្នាំ១៩៧៧៖ "ទំនប់នេះស្ថិតនៅក្នុងភូមិត្រពាំងថ្ម ខាងលិចទល់នឹងភូមិពន្លៃ ឃុំពន្លៃ ស្រុកភ្នំស្រុក"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ចុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្ម៖ "ទីតាំងរបស់ទំនប់នេះស្ថិតនៅភូមិត្រពាំងថ្ម ទៅលិចទល់នឹងឃុំពន្លៃ ស្រុកភ្នំស្រុក ហើយខាងជើងទៅទល់នឹងពពួល ឃុំប៉ោយចារ ស្រុកភ្នំស្រុក"]។ ឯកសារ D6.1.429 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដាន់ ថេវ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267749 [សាក្សីជាអ្នកធ្វើការនៅត្រពាំងថ្ម៖ "ទំនប់ត្រពាំងថ្មស្ថិតនៅក្នុងឃុំប៉ោយចារ ឃុំពន្លៃ ស្រុកភ្នំស្រុក"]។ ឯកសារ D6.1.425 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267782 [សមាជិកនៃកងឆ្លាំរបស់ តា វ៉ាល់ រហូតពាក់កណ្តាលឆ្នាំ ១៩៧៧៖ "ទីតាំងរបស់ទំនប់ត្រពាំងថ្មនេះស្ថិតនៅក្នុងភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង បច្ចុប្បន្នខេត្តបន្ទាយមានជ័យ"]។

1377 ឯកសារ D6.1.710 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464719 ["នៅក្នុងរបបខ្មែរក្រហម ស្រុកភ្នំស្រុកចំណុះឲ្យខេត្តបាត់ដំបង ប៉ុន្តែក្រោយមកបន្ទាប់ពីមានការផ្លាស់ប្តូរព្រំដែនស្រុកនេះត្រូវបានដាក់ចូលទៅក្នុងខេត្តបន្ទាយមានជ័យ"]។

1378 ឯកសារ D6.1.426 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267765 [សាក្សីធ្វើការនៅក្នុងកងចល័តរបស់តា វ៉ាល់ នៅពេលលើកទំនប់ត្រពាំងថ្ម៖ "ទំនប់ត្រពាំងថ្មនោះស្ថិតនៅក្នុងតំបន់៥"]។ ឯកសារ D106/9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តក់ ប៊ុយ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ឆ.2 KH 00801006 [សាក្សីធ្វើការនៅកងចល័តតំបន់៥៖ "ខ្ញុំធ្វើការនៅក្នុងកងចល័តតំបន់៥ [...] កងរបស់ខ្ញុំត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅប្រឡាយស្ពានស្រែង បន្ទាប់ពីខ្ញុំបានបញ្ចប់ការងារនៅទំនប់ត្រពាំងថ្ម"]។ ឯកសារ D119/43 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.12 KH 00915882 [សាក្សីធ្វើការនៅកងចល័តតំបន់៥៖ "នៅពេលនោះ គេបានបំបែកកងចល័តតំបន់៥ជាបីក្រុម៖ ក្រុមទីមួយធ្វើការនៅទំនប់ស្វាច់ ក្រុមទីពីរធ្វើការនៅទំនប់ស្ពានស្រែងដែលលាតសន្ធឹងពីថ្ងកគ្រោះដល់ស្ពានស្រែង និងក្រុមទីបីធ្វើការនៅអាងត្រពាំងថ្ម"]។

1379 ឯកសារ D6.1.425 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267782 [សមាជិកនៃកងឆ្លាំរបស់ តា វ៉ាល់ រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៧៖ "ទំនប់ត្រពាំងថ្មចាប់ផ្តើមលើកពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧"]។ ឯកសារ D6.1.428 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត អ៊ិន ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267738 [ប្រធានកងនៅត្រពាំងថ្ម៖ "ទំនប់នេះចាប់ផ្តើមលើកនៅក្នុងឆ្នាំ១៩៧៦"]។ ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267743 [សាក្សីជាអ្នកធ្វើការ និងក្រោយមកជាប្រធានកងនៅត្រពាំងថ្ម៖ "ទំនប់នោះលើកចាប់ពីខែ កុម្ភៈ ឆ្នាំ ១៩៧៦"]។ ឯកសារ D118/61 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.10 KH 00920155 [សាក្សីជាអ្នកធ្វើការ និងក្រោយមកជាប្រធានកងនៅត្រពាំងថ្ម៖ "ស៖ក្នុងកំណត់ហេតុលោកឆ្នាំ២០០៨ លោកនិយាយថាលោកធ្វើទំនប់ចាប់ពីខែ ២ ឆ្នាំ ១៩៧៦

របហូតដល់ខែ ៧ ឆ្នាំ ១៩៧៧ តើត្រឹមត្រូវដែរឬទេ? ឆ.10៖ បាទ ត្រឹមត្រូវ"]។ ឯកសារ D219/35 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សិលា ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ឆ.30 KH 01032082 [ប្រធានកងនៅត្រពាំងថ្ម៖ "ទំនប់អាងទឹកត្រពាំងថ្មចាប់សាងសង់នៅឆ្នាំ១៩៧៦"] ឆ.31 KH 01032082 ["ខ្ញុំមិនបានចាំខែច្បាស់ទេ ខ្ញុំគ្រាន់តែដឹងថាវាសាងសង់នៅក្នុងឆ្នាំ១៩៧៦ប៉ុណ្ណោះ"]។ ឯកសារ D6.1.453 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង សាមួត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH 00279088 [សាក្សីជាអ្នកធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ទំនប់ត្រពាំងថ្ម គេចាប់ផ្តើមលើកនៅចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.28 KH 01049230 [សាក្សីជាអ្នកធ្វើការនៅកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨៖ "ស៖ "តើលោកនៅចាំថាពេលណាដែលគេបញ្ជូនលោកទៅទីនោះ? ឆ.28៖ ១៩៧៦"]។ ឯកសារ D6.1.449 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដាន់ ស ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ KH 00279083 [សាក្សីជាអ្នកធ្វើការនៅកងចល័តក្នុងតំបន់ត្រពាំងថ្ម៖ "ទំនប់នោះគេចាប់ផ្តើមលើកប្រហែលជាក្នុងឆ្នាំ១៩៧៦"]។ ឯកសារ D119/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.6 KH 00969023 [ធ្វើការនៅក្រសួងការបរទេស និងបាននាំគណៈប្រតិភូទៅកាន់ត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "ទំនប់អាងត្រពាំងថ្មត្រូវបានចាប់ផ្តើមកសាងនៅឆ្នាំ១៩៧៦"]។ ឯកសារ D6.1.342 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ រួម ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH 00279078 [កសិករនៅក្បែរត្រពាំងថ្ម៖ "ក្នុងឆ្នាំ ១៩៧៦-១៩៧៧ ដំណើរការលើកទំនប់អាងត្រពាំងថ្ម គឺជាពេលសម្រុកស្រួចស្រាល់"]។

1380 ឯកសារ D6.1.766 យុវជន យុវនារី បដិវត្ត លេខ៧-៨ ខែ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH 00376343 [បញ្ជាក់ក្នុងពេលជាមួយអំពីការប្រើប្រាស់ការងារពលកម្មដោយបង្ខំនៅការដ្ឋាន៖ "ការដ្ឋាននេះ បងប្អូនចាប់បើកនៅថ្ងៃ ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៧"]។ សំណុំរឿង ០០២/០១ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្ម៖ "គេចាប់ផ្តើមលើកទំនប់ត្រពាំងថ្មពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៧"]។ ឯកសារ E1/327.1 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ លោក កាន ថុល ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ ពីម៉ោង 13.51.36 ដល់ម៉ោង 13.53.42 KH 01130011 [អនុប្រធានកងតូចនៅត្រពាំងថ្ម៖ "ស៖ [...] នៅពេលណាដែលការកសាងចាប់ផ្តើម? ឆ៖ វាចាប់ផ្តើមនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៧"]។ ឯកសារ D6.1.364 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន សែម ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩ KH 00316511 [សាក្សីជាប្រពន្ធរបស់លេខាស្រុកភ្នំស្រុក ហាត់៖ "គេបានរៀបចំគម្រោងនៅក្នុងឆ្នាំ១៩៧៦ ហើយបានចាប់ផ្តើមលើកទំនប់ក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D119/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.2 KH 00898157 [សាក្សីជាអនុប្រធានកងចល័តតំបន់៥របស់ តា ហ៊ីង នៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៧៖ "នៅខែកុម្ភៈ ឆ្នាំ ១៩៧៧ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមកម្មាភិបាល៦នាក់ ដែលត្រូវទៅរៀបចំការដ្ឋានអាងត្រពាំងថ្មជាមុន ហើយក្រោយមកកម្លាំងចល័តតំបន់ទាំងមូល ត្រូវបានបញ្ជូនទៅធ្វើការនៅទីនោះ"]។ ឯកសារ D6.1.453 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង សាមួត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH 00279088 [សាក្សីជាអ្នកធ្វើការនៅត្រពាំងថ្ម៖ "ទំនប់ត្រពាំងថ្ម គេចាប់ផ្តើមលើកនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧"]។

1381 ឯកសារ D6.1.766 យុវជន និងយុវនារីបដិវត្ត លេខ ៧-៨ ខែ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH 00376344 [ បញ្ជាក់លម្អិតអំពីការប្រើប្រាស់ការងារពលកម្មដោយបង្ខំនៅការដ្ឋាន៖ "នៅរដូវប្រាំងឆ្នាំក្រោយ [១៩៧៨] បងប្អូននឹងបន្តពង្រឹងពង្រីកឲ្យកាន់តែធំ អាង [ត្រពាំងថ្ម] [...] ដោយលើកឲ្យបានបាតក្រោម ១២០ ម៉ែត្រខ្នងលើ ២៥ ម៉ែត្រ"]។ ឯកសារ D6.1.742 ទង់បដិវត្ត លេខ ៤ ខែ មេសា ឆ្នាំ ១៩៧៨ KH 00519843 ["អ្នកកាសែតយូហ្គោស្លាវីបានមកមើលអាងរបស់យើងនៅបាត់ដំបងឈ្មោះត្រពាំងថ្មនៅភ្នំស្រុក។ ដោយក្រឡេកមើលវា ពួកគេមិនអាចមើលឃើញច្រាំងឡើយ ហើយពួកគេបាននិយាយថាពួកគេទើបមកពីកំពង់សោម និងបានឃើញសមុទ្រនៅកំពង់សោម មុនពេលមកមើលអាងនៅភ្នំស្រុកបាត់ដំបង។ ពួកគេនិយាយថាមានសមុទ្រមួយទៀតនៅទីនោះ។ ពួកគេកោតស្ញប់ស្ញែងនឹងសមុទ្រមួយនេះ ដែលមានន័យថាអាងនេះធំអនេកជិត ២០០ម៉ែត្រគុប។ យើងសង់ហើយតែក្នុងពេល១ឆ្នាំ"]។ ឯកសារ D1.3.30.19 សារទូរលេខ ២៤២ ពី ញ៉ឹម លេខាភូមិភាពពាយ័ព្យជូនចំពោះអង្គការ ៨៧០ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ KH 00021044 [របាយការណ៍ពី ញ៉ឹម ស្តីពីការបន្តកសាងត្រពាំងថ្ម៖ "អាងទឹកតំបន់៥៖ ត្រពាំងថ្មបានពង្រឹងថែមរួចហើយ"]។ ឯកសារ D119/14 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឆ.26-27 KH 00893271 [សាក្សីជាអ្នកធ្វើការនៅទំនប់ត្រពាំងថ្ម៖ "សាក្សីជាអ្នកធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ខ្ញុំបានទៅធ្វើការនៅទីនោះប្រហែលជានៅចន្លោះខែ កុម្ភៈ និ ងខែ មេសា ឆ្នាំ ១៩៧៨។ ស៖ តើលោកជួយនឹកឡើងវិញមើលពីព្រោះអាងត្រពាំងថ្មគេបានធ្វើហើយនៅពាក់កណ្តាលឆ្នាំ១៩៧៧ ហេតុអ្វីបានជាលោកនិយាយថាលោកបានទៅធ្វើការនៅទីនោះចន្លោះខែកុម្ភៈ និងមេសា ១៩៧៧ ទៅវិញ? ឆ.27៖ ទោះបីជាទំនប់ត្រពាំងថ្មនោះបានធ្វើហើយនៅពាក់កណ្តាលឆ្នាំ១៩៧៧ក៏ដោយ ប៉ុន្តែតាមពិតតាមខ្ញុំបានឃើញគឺវាមិនទាន់ធ្វើហើយចប់ពេញលេញនៅឡើយទេ"]។ ឯកសារ D6.1.357 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េង ប៊ុនថារ៉ា ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ KH 00295965 [សាក្សីជាប្រធានក្រុមកងចល័ត ដែលបានជួយ ក.ស.ច.ស ក្នុងការរៀបចំរបាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ឯកសារ D6.1.710៖ "តែក្នុងឆ្នាំ១៩៧៧ ឬ ឆ្នាំ ១៩៧៨ នៅពេលដែលទំនប់បានបញ្ចប់"]។ ឯកសារ D119/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.25 KH 01024774 [សាក្សីជាប្រធានកងចល័តនៃសហករណ៍សំរោង៖ "ប្រហែលជាក្នុងខែ មករា ឬខែ កុម្ភៈ ឆ្នាំ ១៩៧៨ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានកងចល័តសហករណ៍សំរោង និងទៅធ្វើការដើម្បីពង្រឹងអាងត្រពាំងថ្ម ដូចជាត្រូវបិតរុនខ្លះដែលមានទឹកហូរបាក់ទំនប់"]។ ឯកសារ D119/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន ឈ្លួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.4 KH 00895158 [សាក្សីជាអនុប្រធានកងចល័តតំបន់៥របស់ តា ហ៊ីង នៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៧៖ " នៅប្រហែលក្នុងខែ កក្កដា ឬខែសីហា ឆ្នាំ ១៩៧៧ ពួកបស្ចិមបានមកដល់តំបន់នេះ។ បីខែក្រោយមក ទើបពួកនិរតីមកដល់។ នៅពេលនោះ ការងារនៅការដ្ឋានទំនប់ត្រពាំងថ្មមិនទាន់ចប់ទៅឡើយទេ"] ឆ.14 KH 00895161 ["តាមពិត ទំនប់នេះសឹងតែចប់សព្វគ្រប់ហើយ តែមិនទាន់ត្រូវបានសម្ពោធជាផ្លូវការនៅឡើយទេ ព្រោះនៅពេលវៀតណាមចូលមកក្នុងឆ្នាំ១៩៧៩ យើងត្រូវរត់គេចខ្លួន"]។ ឯកសារ D119/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស្វ៊ីយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ ឆ.20 KH 00894519 [សាក្សីជាប្រធានកងនៃកងចល័តតំបន់៖ "កាលខ្ញុំនៅធ្វើការនៅអាងត្រពាំងថ្មដើមឆ្នាំ១៩៧៨"]។ ឯកសារ D119/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឆ.3 KH 00894512 [សាក្សីជាអ្នកធ្វើការនៅទំនប់ត្រពាំងថ្ម៖ "ទំនប់នេះមិនទាន់ត្រូវបានចប់ជាស្ថាពរនៅឡើយទេ ពេលវៀតណាមចូលមក"]។ ឯកសារ D119/47

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ហុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.7 KH 00933093 [សាក្សីជាអ្នកធ្វើការនៅកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្ម៖ "ខ្ញុំទៅធ្វើការនៅកងចល័តត្រពាំងថ្មរហូតដល់ទំនប់ត្រពាំងថ្មត្រូវបានបញ្ចប់ដែលនៅជិតចុងនៃខ្មែរក្រហម"]។ ឯកសារ D118/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឹម ចាន់ធឿន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.28 KH 00920186 [សាក្សីជាអ្នកធ្វើការនៅត្រពាំងថ្ម៖ "ខ្ញុំលើកទំនប់ត្រពាំងថ្មក្នុងឆ្នាំ ១៩៧៨"]។ ឯកសារ D6.1.426 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00277831 [សាក្សីធ្វើការនៅកងចល័តរបស់តា វ៉ាល់ នៅពេលកំពុងលើកទំនប់ត្រពាំងថ្ម៖ "ការលើកទំនប់ត្រពាំងថ្មប្រហែលជានៅក្នុងឆ្នាំ១៩៧៨"]។ ឯកសារ D119/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.6 KH 00969022 [បុគ្គលិកនៃក្រសួងការបរទេសដែលបាននាំគណៈប្រតិភូទៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៧៖ "នៅពេលដែលខ្ញុំដឹកនាំគណៈប្រតិភូទៅទស្សនកិច្ចនៅទីនោះក្នុងឆ្នាំ១៩៧៨គឺនៅពុំទាន់រួចរាល់ពេញលេញនៅឡើយទេ។ តាមពិតខ្ញុំកត់សម្គាល់ឃើញថាទំនប់អាងត្រពាំងថ្មនេះគឺមិនទាន់ធ្វើចប់សព្វគ្រប់នៅឡើយទេ ដោយសារតែមានទ្វារទឹកតែមួយប៉ុណ្ណោះនៅខាងត្បូង ហើយគ្មានទ្វារទឹកទេនៅប៉ែកខាងកើត"]។ ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.38 KH 01105586 [សាក្សីជាអ្នកធ្វើការនៅការដ្ឋានទំនប់អាងត្រពាំងថ្ម៖ "ខ្ញុំត្រូវបានបញ្ជូនទៅទំនប់ត្រពាំងថ្មរហូតដល់ចប់របបខ្មែរក្រហម"]។ ឯកសារ D219/35 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សិលា ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ឆ.32 KH 01032082 [ប្រធានក្រុមដែលមានសមាជិកចំនួន ៣០ នាក់នៅត្រពាំង៖ "គេបានបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅទំនប់អាងទឹកត្រពាំងថ្មនៅក្នុងឆ្នាំ ១៩៧៧។ នៅពេលនោះ ទំនប់អាងទឹកត្រពាំងថ្មបានសាងសង់រួចហើយ ពួកខ្ញុំគ្រាន់តែរែកដីចាក់បំពេញត្រចៀកអាងនោះតែប៉ុណ្ណោះ"] ឆ.36 KH 0132083 ["ខ្ញុំធ្វើការនៅទីនោះរហូតឆ្នាំ១៩៧៨"]។ ឯកសារ D6.1.425 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267781 [ទាហាននៅក្នុងកងឆ្មាំរបស់ តា វ៉ាល់ រហូតពាក់កណ្តាលឆ្នាំ ១៩៧៧៖ "ទំនប់នោះមិនទាន់ពេញជារូបរាងនៅឡើយទេ នៅពេល តា វ៉ាល់ ត្រូវគេចាប់ [ក្នុងពាក់កណ្តាលឆ្នាំ ១៩៧៧]"]។ ឯកសារ D5/1065 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឱប ផល្លា ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ KH 010993275 [សាក្សីធ្វើការនៅកងចល័តកុមារនៅត្រពាំងថ្ម៖ "១៩៧៨ នាងខ្ញុំត្រូវមិត្ត ភន់ មេកងចល័តបញ្ជូនឱ្យមកលើកទំនប់ត្រពាំងថ្មបន្តទៀតចាប់ពីស្ពានទី២ (ស្ពានរាប) រហូតដល់ស្ពានទី៣អាងត្រពាំងថ្មត្រង់ម្តុំភ្នំមិពន្លៃ"]។ ឯកសារ D119/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.19 KH 00978910 [សាក្សីជាប្រធានកងចល័តតំបន់៥៖ "ខ្ញុំធ្វើការនៅទំនប់ត្រពាំងថ្មបានបីខែ ហើយពេលហ្នឹងទំនប់ត្រពាំងថ្ម គឺគេបានធ្វើរួចរាល់គឺមុនចូលឆ្នាំខ្មែរក្នុងឆ្នាំ១៩៧៧ [...] តាមពិត ទំនប់ត្រពាំងថ្មធ្វើហើយចប់សព្វគ្រប់ ប៉ុន្តែលើកលែងតែស្ពានមួយចំនួននៅមិនទាន់ធ្វើចប់ពេញលេញនៅឡើយ"] សូមមើលផងដែរ ឯកសារ D1.3.10.1 របាយការណ៍ពីគណៈតំបន់ ៥ ទៅ ម-៥៦០ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ KH 00275598 [ឯកសារសហកាលដែលបង្ហាញផែនការសម្រាប់ការកសាងត្រពាំងថ្ម៖ "អាងទឹកយុទ្ធសាស្ត្រនៅត្រពាំងថ្មកំពុងបន្តសំណង់ទ្វារទឹកទាំង៣ ទិសធំគឺសំដៅបញ្ចប់សំណង់ខាងក្រោមក្នុងខែ៥នេះ ទុកសំណង់ខាងលើបញ្ចប់ជាបណ្តើរតទៅទៀត"]។ ផ្ទុយនឹង ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267743 [សាក្សីជាអ្នកធ្វើការ និងក្រោយមកជាប្រធានកងនៅត្រពាំងថ្មដែលបានធ្វើការនៅទី

01342695



តាំងនោះនៅពេលកម្មាភិបាលភូមិភាគនិរតីចូលកាន់កាប់៖ "ទំនប់នោះលើកចាប់ពីខែកុម្ភៈ ឆ្នាំ ១៩៧៦ ដល់ខែ កក្កដា ឆ្នាំ ១៩៧៧ ទើបចប់"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ចុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្ម៖ "គេចាប់ផ្តើមលើកទំនប់ត្រពាំងថ្មពីថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ១៩៧៧ ហើយបញ្ចប់នៅឆ្នាំដដែល]។ ឯកសារ D119/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.8 KH 00894502 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "នៅខែ មិថុនា ឬខែកក្កដា ឆ្នាំ១៩៧៧ នៅពេលដែលក្រុមយាយ ចែម មកដល់ ខ្ញុំនៅការដ្ឋានទំនប់ត្រពាំងថ្ម ហើយពេលនោះទំនប់នេះត្រូវបានបញ្ចប់ជាស្ថាពរហើយ"]។

1382 ឯកសារ D6.1.710 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464720 ["សញ្ញានៅលើថ្មត្រង់ចំណុចប្រសព្វនៃខ្នងទំនប់អាងទឹកត្រពាំងថ្មបង្ហាញថាទីអាងទឹកត្រពាំងថ្មត្រូវបានស្តារឡើងវិញនៅឆ្នាំ ២០០៤ ដែលធ្វើឱ្យអាងទឹកនេះមានចំណុចខ្លះខុសប្លែកពីទ្រង់ទ្រាយកាលពីទសវត្សរ៍ឆ្នាំ១៩៧០"]។ ឯកសារ D6.1.357 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េង ប៊ុនថារ៉ា ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ KH 00295965 [សាក្សីជាប្រធានក្រុមកងចល័ត ដែលបានជួយ ក.ស.ច.ស ក្នុងការរៀបចំរបាយការណ៍ ឯកសារ D6.1.710៖ "សៈតើអាចលោកប្រៀបធៀបទំហំរបស់អាងពីមុន និងអាងបច្ចុប្បន្ននេះខុសគ្នាយ៉ាងណាដែរ? ឆ៖ មិនមានភាពខុសគ្នានោះទេគឺមានលក្ខណៈដដែល"]។

1383 ឯកសារ D6.1.710 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464723 ["ទំនប់មានប្រវែងប្រហែល៩គីឡូម៉ែត្រ។ ចេញពីស្ពានទីមួយទៅជើងមានប្រវែងប្រហែលជា១៣គីឡូម៉ែត្រ"]។ ឯកសារ D6.1.357 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េង ប៊ុនថារ៉ា ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ KH 00295965 [សាក្សីជាប្រធានក្រុមកងចល័ត ដែលបានជួយ ក.ស.ច.ស ក្នុងការរៀបចំរបាយការណ៍ D6.1.710៖ "ពីស្ពានទីមួយដល់ចុងទំនប់ (ភូមិពន្លៃ) មានប្រវែងប្រហែលជា៩គីឡូម៉ែត្រ។ ចេញពីស្ពានទី១ទៅជើងមានប្រវែងប្រហែលជា១៣គីឡូម៉ែត្រ"]។

1384 ឯកសារ D61 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ KH 00727221 [សាក្សីជាអនុប្រធានកងចល័តតំបន់៥របស់តា ហ៊ីង ក្នុងឆ្នំ១៩៧៧៖ "គំរោងដែលរៀបចំទំនប់នេះ មាន [...] កម្ពស់ ៨ ម៉ែត្រ"]។ ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សាក្សីជាអ្នកធ្វើការ និងក្រោយមកជាប្រធានកងនៅត្រពាំងថ្ម៖ "កន្លែងខ្ញុំលើកមានកម្ពស់ប្រហែល៨ម៉ែត្រ"]។

1385 ឯកសារ D61 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ KH 00727221 [សាក្សីជាអនុប្រធានកងចល័តតំបន់៥របស់ តា ហ៊ីង នៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "គំរោងដែលរៀបចំទំនប់នេះ មាន [...]ខ្នងលើ ២០ម៉ែត្រ"]។ ឯកសារ D6.1.766 ទង់បដិវត្ត លេខ៧-៨ ខែ កក្កដា-សីហា ១៩៧៧ KH 00376344 [លម្អិតអំពីការប្រើប្រាស់ការងារពលកម្មដោយបង្ខំនៅឯការដ្ឋាននេះ៖ "នៅរដូវប្រាំងឆ្នាំក្រោយ [១៩៧៨] បងប្អូននឹងបន្តពង្រឹងពង្រីកឱ្យកាន់តែធំអាង [ត្រពាំងថ្ម] [...] ដោយលើកឱ្យបានបាតក្រោម ១២០ ម៉ែត្រខ្នងលើ ២៥ ម៉ែត្រ"]។

1386 ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សាក្សីជាអ្នកធ្វើការ និងក្រោយមកជាប្រធានកងនៅត្រពាំងថ្មដែលធ្វើការនៅទីតាំងនោះនៅពេលដែលកម្មាភិ បាលភូមិភាគនិរតីចូលកាន់កាប់៖ "តាមគម្រោង ខ្នងទំនប់ប្រហែល៥០ម៉ែត្រ"]។

1387 ឯកសារ **D61** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន ឈួង ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១១ KH 00727221 [សាក្សីជាអនុប្រធានកងចល័តតំបន់៥របស់ តា ហ៊ីង នៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "គំរោងដែលរៀបចំទំនប់នេះ គឺបាតក្រោម ៦០ ម៉ែត្រ"]។

1388 ឯកសារ **D6.1.766** យុវជន យុវនារី បដិវត្ត លេខ៧-៨ ខែ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH 00509686 [បញ្ជាក់លម្អិតក្នុងពេលដំណាលគ្នាអំពីការប្រើប្រាស់ការងារពលកម្មដោយបង្ខំនៅការដ្ឋាន៖ "ជាសរុប អាងទំនប់ត្រពាំងថ្ម [...] មានទទឹងបាត ៤០ ទៅ ៧០ ម៉ែត្រ [...]នៅរដូវប្រាំងឆ្នាំក្រោយ [១៩៧៨] បងប្អូននឹងបន្តពង្រឹងពង្រីកឲ្យកាន់តែធំ អាង [ត្រពាំងថ្ម] [...] ដោយលើកឲ្យបានបាតក្រោម ១២០ ម៉ែត្រខ្នងលើ ២៥ ម៉ែត្រ"]។ ឯកសារ **D6.1.431** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00277816 [សាក្សីជាអ្នកធ្វើការ និងក្រោយមកជាប្រធានកងនៅត្រពាំងថ្ម ដែលធ្វើការនៅទីតាំងនោះនៅពេលដែលកម្មាភិបាលភូមិភាគនិរតីចូលកាន់កាប់ "តាមគម្រោង [...] បាតវាប្រហែល ១០០ ម៉ែត្រ"]។

1389 ឯកសារ D6.1.822 សេវាផ្សព្វផ្សាយព័ត៌មានក្នុងស្រុកពីខែ ឧសភា ឆ្នាំ ១៩៧៨ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៧៨ KH 00701800 [របាយការណ៍អំពីការកសាងអាង៖ "ឧទាហរណ៍អាងត្រពាំងថ្មនៅភ្នំស្រុក ខេត្តបាត់ដំបង អាងធំមានលទ្ធភាពស្តុកទឹក២០០លានម៉ែត្រគុបសង់ហើយស៊ីពេល១ឆ្នាំប៉ុណ្ណោះ"]។ ឯកសារ D6.1.826 សេវាផ្សព្វផ្សាយព័ត៌មានក្នុងស្រុកពីខែ តុលា ឆ្នាំ ១៩៧៨ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៧៨ KH 00702826 [របាយការណ៍អំពីការកសាងអាង៖ "យើងបានបញ្ចប់ការកសាងអាងដែលស្តុកទឹបាន២០០លានម៉ែត្រគុបដូចជាជាអាងត្រពាំងថ្ម"]។

1390 ឯកសារ D6.1.710 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464721 [ផែនទីអាងត្រពាំងថ្ម៖ "រចនាសម្ព័ន្ធរូបវន្តចំនួន៣ដូចដែលត្រូវបានបង្ហាញនៅលើផែនទីដែលស្ថិតនៅតាមបណ្តោយទំនប់ពីកើតទៅលិចគឺជាស្ពានដែលមាននាបច្ចុប្បន្ននេះ"]។ ឯកសារ D119/88 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កៅ ផាន ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.11 KH 00976119 [សាក្សីដឹកជញ្ជូនថ្មពីភ្នំត្រយោងទៅត្រពាំងថ្ម៖ ខ្ញុំដឹកថ្មមកសម្រាប់ធ្វើស្ពានពីរ គឺស្ពានទី១ និងស្ពានទី២។ នៅអាងត្រពាំងថ្មមានស្ពានចំនួន៣"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ. 27 KH 01049230 [សាក្សីធ្វើការនៅកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៦ និង១៩៧៨៖ "ខ្ញុំទៅធ្វើការនៅទំនប់អាងត្រពាំងថ្ម កន្លែងស្ពានទី១"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.12 KH 00976176 [ប្រធានកងចល័តដែលមានសមាជិកចំនួន ៣០ នាក់ដែលត្រូវបានចាត់តាំងទៅត្រពាំងថ្ម៖ "ខ្ញុំធ្វើការនៅស្ពានទី២នៃទំនប់អាងត្រពាំងថ្ម"]។ ឯកសារ D119/152 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ទាវ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.31 KH 01024729 [សាក្សីជាអ្នកធ្វើការនៅត្រពាំងថ្ម៖"ព្រឹត្តិការណ៍នេះកើតឡើងនៅត្រង់ស្ពានទី៣ ឬទី៤នៃទំនប់អាងត្រពាំងថ្មដែលពេលនោះទំនប់ត្រពាំងថ្មនេះសាងសង់ជិតរួចហើយ"]។

1391 ឯកសារ **D6.1.710** របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង កស.ច.ស. ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464719 ["ស្ពានលេខ១ N13 47.079’ E103 18.196’"] KH 00464721 ["ស្ពានលេខ១ គឺជារចនាសម្ព័ន្ធរូបវន្តស្ថិតនៅ

ចុងទំនប់ខាងកើត ជិតភូមិប៉ោយចារ ជាងគេបង្អស់"] KH 00464724 ["ស្ពានលេខ១ ស្ថិតនៅប៉ែកខាងលិចនៃចំណុចប្រសព្វនៃទំនប់ទាំងពីរ"]។

1392 ឯកសារ D6.1.710 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464719 ["ស្ពានលេខ២ N13 47.552' E103 16.521'"] KH 00464721 [ផែនទីអាងត្រពាំងថ្ម៖ "ស្ពានលេខ២ គឺជារចនាសម្ព័ន្ធរូបវន្តស្ថិតកណ្ដាលដូចដែលបានបង្ហាញលើផែនទី"] KH 00464724 ["'ស្ពានលេខ២ មានចម្ងាយ ៣.២ គម ខាងលិចស្ពានទី១"]។

1393 ឯកសារ D6.1.710 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464719 ["ស្ពានលេខ៣ N13 48.069' E103 14.663'"] KH 00464721 ["'ស្ពានលេខ៣' គឺជារចនាសម្ព័ន្ធរូបវន្តស្ថិតនៅចុងទំនប់អាងទឹកផ្នែកខាងលិច"] KH 00464724 ["ស្ពានលេខ៣ មានចម្ងាយ ៣.៥ គម ខាងលិចស្ពានទី២"]។

1394 ឯកសារ D6.1.710 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ក.ស.ច.ស ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១០ KH 00464720 ["នៅលើខ្នងទំនប់នៃអាងទឹកត្រពាំងថ្មមានផ្លូវលំតូចៗពីរ"]។

1395 ឯកសារ D6.1.766 យុវជន យុវនារីបដិវត្ត លេខ៧-៨ កក្កដា សីហា ១៩៧៧ KH 00376344 [លម្អិតអំពីការប្រើប្រាស់ការងារពលកម្មដោយបង្ខំនៅការដ្ឋាន៖ "នៅរដូវប្រាំងឆ្នាំក្រោយៗ បងប្អូននឹងបន្តពង្រឹងពង្រីកឲ្យកាន់តែធំ និងកាន់តែរឹងមាំថែមទៀតដោយលើកកំពស់អាងឲ្យបាន [...] ហើយតម្កល់ទឹកទុកឲ្យបានច្រើនរយលានម៉ែត្រគ្រីគុណ"]។ ឯកសារ D1.3.30.19 សារទូរលេខ ២៤២ ពី ញឹម លេខាភូមិភាគពាយព្យទៅអង្គការ ៨៧០ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ KH 00021044 [របាយការណ៍ពី ញឹម អំពីការបន្តកសាងត្រពាំងថ្ម៖ "អាងទឹកតំបន់៥៖ ត្រពាំងថ្មបានពង្រឹងថែមរួចហើយ"]។ ឯកសារ D6.1.992 របាយការណ៍ទស្សនកិច្ចនៅកម្ពុជារបស់Chen Yung-Kuei ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 00659260 [របាយការណ៍ព័ត៌មានអំពីទស្សនកិច្ចទៅការដ្ឋានត្រពាំងថ្មរបស់ឧបនាយករដ្ឋមន្ត្រីចិន៖ "សមមិត្ត រស់ ញឹម អនុប្រធានទី២នៃប្រធានគណៈរដ្ឋកម្ពុជាប្រជាធិបតេយ្យ និងជាលេខានៃគណៈកម្មាធិការភូមិភាគពាយ័ព្យនៃបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្នុងភូមិភាគពាយ័ព្យ បានមានប្រសាសន៍ថាអាងស្តុកទឹកត្រូវកសាងក្នុងឆ្នាំនេះ ដោយប្រជាជនក្នុងតំបន់៥នៃភូមិភាគពាយ័ព្យដោយប្រើរយៈពេលតិចជាង២ខែ ជាការឆ្លើយតបសេចក្តីអំពាវនាវរបស់គណៈកម្មាធិការមជ្ឈិមបក្សដើម្បីកសាងអាងស្តុកទឹកដ៏ធំមួយ។ ឆ្នាំនេះអាងស្តុកនេះអាចស្តុកទឹកបាន១៥០លានម៉ែត្រគុប។ ក្រោយមកប្រឡាយចំនួន៣ត្រូវបានជីកក្នុងរយៈពេលមួយសប្តាហ៍ដើម្បីភ្ជាប់អាងស្តុកដែលអាចស្រោចស្រពស្រែបានជាង៧០០០ហិកតា។ ពេលនេះ អាងស្តុកទឹកកំពុងត្រូវបានពង្រីកបន្ថែម។ បួនឆ្នាំក្រោយ អាងនេះអាចស្តុកទឹកបានចំនួន៣០០លានម៉ែត្រគុប"]។ ឯកសារ D6.1.742 ទង់បដិវត្ត លេខ៤ ខែ មេសា ឆ្នាំ ១៩៧៨ KH 00519843 ["អ្នកកាសែតយូហ្គោស្លាវីបានមកមើលអាងរបស់យើងនៅបាត់ដំបងឈ្មោះត្រពាំងថ្មនៅភ្នំស្រុក។ ដោយក្រឡេកមើលវា ពួកគេមិនអាចមើលឃើញច្រាំងឡើយ ហើយពួកគេបាននិយាយថាពួកគេទើបមកពីកំពង់សោម និងបានឃើញសមុទ្រនៅកំពង់សោម មុនពេលមកមើលអាងនៅភ្នំស្រុកបាត់ដំបង។ ពួកគេនិយាយថាមានសមុទ្រមួយទៀតនៅទីនោះ។ ពួកគេកោតស្ងប់ស្ងែងនឹងសមុទ្រមួយនេះ ដែលមានន័យថាអាងនេះធំអនេកជិត២០០ម៉ែត្រគុប។ យើងសង់ហើយតែក្នុងពេល១ឆ្នាំ"]។ ឯកសារ D5/1065 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឌិប ផល្លា ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ KH 01210527 [សាក្សីធ្វើការនៅកងចល័តកុមារ

នៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៨៖ "១៩៧៨ នាងខ្ញុំត្រូវមិត្ត ភន់ មេកងចល័តបញ្ជាឲ្យមកលើទំនប់អាងត្រពាំងថ្មបន្តទៀតចាប់ពីស្ពានទី២ (ស្ពានរាប) រហូតដល់ស្ពានទី៣អាងត្រពាំងថ្ម ត្រង់ម្តុំភូមិពន្លៃ"]។ ឯកសារ D5/962 ទំរង់បែបបទព័ត៍មានអំពីជនរងគ្រោះ អៀម វុយ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00989802 [សាក្សីធ្វើការនៅត្រពាំងថ្មពីឆ្នាំ ១៩៧៦ ដល់១៩៧៨៖ "១៩៧៨ អង្គការប៉ុល ពត បានបង្ខំឱ្យនាងខ្ញុំធ្វើការលើកទំនប់អាងត្រពាំងថ្មបន្ថែមទៀត"]។ ឯកសារ D5/1623 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប្លែក សារ៉ាប ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៣ KH 01092708 [សាក្សីធ្វើការនៅកងចល័តនារីនៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៨៖ "ខ្ញុំលើកទំនប់ចាប់ពីស្ពានទី១ដល់ស្ពានទី២នៃទំនប់ត្រពាំងថ្ម"]។

1396 ឯកសារ **D5/1029** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លឿង សាលឿម ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៣ KH 00991182 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "១៩៧៨ មិត្តឈន់ មេកងបានបញ្ជាឱ្យខ្ញុំព្រមទាំងកងចល័តផ្សេងទៀតទៅលើកទំនប់អាងត្រពាំងថ្ម"]។

1397 ឯកសារ D5/1314 ទំរង់បែបបទព័ត៍មានអំពីជនរងគ្រោះ ដន ប៉ោច ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៣ KH 01037948 [សមាជិកនៃកងចល័តកុមារ "១៩៧៨ មិត្ត ដន មេកងបានបញ្ជាឲ្យរូបខ្ញុំមកលើកទំនប់ប្រឡាយព្រែកជីកខាងត្បូងនៃទំនប់អាងត្រពាំងថ្ម"]។ ឯកសារ D5/1206 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មាន លឿយ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ KH 01031309 [សាក្សីជាអ្នកធ្វើការនៅកងចល័ត៖ "គេបញ្ជូនឱ្យទៅជីកប្រឡាយពីស្ពានទីបីខាងលិចអាងត្រពាំងថ្ម និងជីកប្រឡាយនៅស្ពានទីមួយ"] KH 01031304 ["ពេលរៀបការរួចបាន៧ថ្ងៃ យោធា (មិនចាំឈ្មោះ) ក៏បានបញ្ជូនខ្ញុំនិងមិត្តជាប្តីទាំង៦៣គូ (មិនចាំឈ្មោះ)ដែលបានរៀបការទៅលើកប្រឡាយនៅស្ពានទីបីខាងលើខាងអាងត្រពាំងថ្ម [...] នៅពេលលើកទំនប់ជីកប្រឡាយស្ពានទី៣រួច មិត្ត វ៉ាល់ បានដកខ្ញុំឱ្យទៅលើកទំនប់បន្ថែមទាំងយប់ទាំងថ្ងៃចាប់ពីស្ពានទីមួយ"]។ ឯកសារ D5/1033 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រឹក ធួង ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ KH 00991263 [សាក្សីជាអ្នកធ្វើការនៅត្រពាំងថ្ម៖ "នៅខែ ឧសភា ១៩៧៨ នាងខ្ញុំត្រូវមិត្ត ចែម មេកងបញ្ជូនឱ្យទៅលើកទំនប់ប្រឡាយនៅអាងត្រពាំងថ្ម"]។ ឯកសារ D1.3.10.1 របាយការណ៍ពីគណៈតំបន់ ៥ ទៅ ម-៥៦០ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៧៧ KH 00275598 ["ព្រែកជីកប្រវែង២៣ គ.ម តភ្ជាប់ពីទ្វារទឹកទី១ត្រពាំងថ្ម មកស្ទឹងអន្លង់សារ ដែលមានមាត់លើ១២ ម បាតក្រោម ៦ ម ជម្រៅ ១ ម បានបញ្ចប់ហើយ"]។

1398 ឯកសារ **D5/1143** ទំរង់បែបបទព័ត៍មានអំពីជនរងគ្រោះ កែវ ណារិទ្ធ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01145271-72 [សាក្សីជាអ្នកធ្វើការនៅកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្ម៖ "១៩៧៨ បន្ទាប់ពីលើកទំនប់ប្រឡាយខេត្តបាត់ដំបងរួចមក គឺឱ្យលើកភ្លឺស្រែម្នាក់១០០ម ទទឹងភ្លឺ ០,៥ម កម្ពស់ ០,៥ម នៅការដ្ឋានទំនប់អាងត្រពាំងថ្ម"]។

1399 ឯកសារ **D5/1177** ទំរង់បែបបទព័ត៍មានអំពីជនរងគ្រោះ ឡូម រឿម ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៣ KH 01030699 [ភ្ជួរស្រែនៅអាងត្រពាំងថ្ម៖ "១៩៧៧ ខ្ញុំភ្ជួរស្រែនៅខាងក្រោមអាងត្រពាំងថ្មដើម្បីឧបត្ថម្ភស្រូវដល់អ្នកលើកអាងត្រពាំងថ្មធ្វើរហូតដល់៧៨"]។ ឯកសារ **D5/922** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រស់ បុន ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣ KH 00979784 [សាក្សីជាសមាជិកនៃកងនារីពិសេសដែលត្រូវបានចាត់តាំងឲ្យជីកប្រឡាយនៅត្រពាំងថ្មពីឆ្នាំ ១៩៧៦ ដល់១៩៧៧ ៖ "ពាក់កណ្តាលឆ្នាំ១៩៧៧ ទៅស្ទូងស្រូវនៅវាលអាងត្រពាំងថ្ម"]។ ឯកសារ **D5/1013** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

ប្បវេណីរបស់ សូ សាខៃ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00990928 [សាក្សីធ្វើការនៅតំបន់ត្រពាំងថ្ម៖ "១៩៧៨ [...] ដកស្ទូងនៅវាលគោកត្រាច តែស្ទូងនៅត្រពាំងថ្ម"]។

1400 ឯកសារ D5/1250 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តាំង ហ៊ីវ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036240 [សាក្សីជាអ្នកធ្វើការនៅកងចល័តនៅត្រពាំងថ្ម៖ "១៩៧៨ ឆ្នាំនោះជាឆ្នាំរោង ទឹកជំនន់ធំខ្លាំងក្លាណាស់បណ្ដាលឲ្យទឹកហូរដាច់ជាច្រើនកន្លែងលើខ្នងទំនប់អាងត្រពាំងថ្ម [...] ពេលនោះ កងចល័តជាច្រើនពាន់នាក់រត់កាប់ដើមឈើឬស្សីធំៗជញ្ជូនពីទីជិតឆ្ងាយយកមកដាក់ទប់ទល់ការពារផ្ទៃទឹកកុំឱ្យហូរបាក់ទៀត។ ឯកងចល័តខ្លះទៀតត្រូវរែកសែងកាប់ដីវាល់ៗល្វាចយ៉ាងសស្រាក់សស្រាំយកមកចាក់លើខ្នងទំនប់"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.96 KH 01049236 [សាក្សីធ្វើការនៅកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨៖ "ស៖ ហើយបន្ទាប់ពីនោះទៀត? ឆ.96៖ បន្ទាប់ពីនោះមក ខ្ញុំដើរកាប់មែកឈើដើម្បីសង់ទប់រលកកុំឱ្យបាក់ទំនប់"] ឆ.97 ["ស៖ តើទីនោះជាផ្នែកមួយនៃទំនប់ត្រពាំងថ្មឬយ៉ាងណា? ឆ.97៖ បាទ"]។ សូមមើលផងដែរ ឯកសារ D5/1463 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ធុង ឈាត ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ KH 01043764 [សាក្សីជាអ្នកធ្វើនៅកងចល័ត៖ "១៩៧៧ មិត្ត មួក ជាមេកងចល័ត ឲ្យខ្ញុំ [...] លើកទំនប់អាងទឹកត្រពាំងថ្ម [...]។ នៅរដូវវស្សាឆ្នាំនោះ ទឹកជំនន់មួយយ៉ាងធំអស្ចារ្យ វាបានបោកបក់រលកផ្ទៃទឹកធ្វើឱ្យទំនប់នានាមួយចំនួនត្រូវទឹកហូរពីលើ ធ្វើឱ្យកងចល័តធ្វើការយ៉ាងពិបាក ធ្វើទាំងយប់ទាំងថ្ងៃ បើមិនទប់ទឹកនោះពុំជាប់ទេ អង្គការ ប៉ុល ពត ដោយចោទថាខ្មាំង វាយកទៅសម្លាប់ចោលជាមិនខាន"]។ ឯកសារ D119/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.25 KH 01024774 [សាក្សីជាប្រធានកងចល័ត៖ "ប្រហែលជាក្នុងខែ មករា ឬខែ កុម្ភៈ ឆ្នាំ ១៩៧៨ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានកងចល័តសហករណ៍សំរោង និងទៅធ្វើការដើម្បីពង្រឹងអាងត្រពាំងថ្មដូចជាត្រូវបិតរុនខ្លះដែលមានទឹកហូរបាក់ទំនប់"]។

1401 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929729 ["ដារ៉ា៖ចេញពីតាកែវទៅវិញ? ចែម៖ ចា! ដារ៉ា៖ចេញពីតាកែវទៅកន្លែងត្រពាំងថ្មហ្នឹងហ្មង? ចែម៖ហ្នឹងហើយ ទៅរៀបចំកន្លែងហ្នឹង នៅក្រោមទំនប់ហ្នឹងមួយចំនួន"] KH 00929729 ["ដារ៉ា៖ហីពេលទៅដល់ទំនប់ហ្នឹងមានសភាពយ៉ាងម៉េច គេធ្វើបានប៉ុណ្ណា? ចែម៖ មាន គេទប់ហើយហើយ។ គេដាក់កម្លាំងធ្វើស្រែប្រាំង"] KH 00929732 ["ចែម៖ [...] ដូចកម្លាំងខាងស្រុកព្រះនេត្រព្រះអីក៏ខ្ញុំទៅមើលដែរ"] KH 00929741 ["ដារ៉ា៖ ចុះអ៊ំមានបានទៅលើកនៅកន្លែងហ្នឹង ទៅគ្រប់គ្រងនៅកន្លែងហ្នឹងអត់នៅត្រពាំងថ្មហ្នឹង? ចែម៖ ខ្ញុំអត់បានគ្រប់គ្រងទេ គ្រាន់តែទៅមើលកម្លាំងដែលខ្ញុំទៅជួយគេធ្វើហ្នឹង"]។ ឯកសារ D1.3.12.1 កំណត់ហេតុចម្លងចេញពីខ្សែអាត់សម្លេងរបស់ អ៊ឹម ចែម ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៧ KH 00234198 ["ទំនប់ត្រពាំងថ្ម ពេលខ្ញុំទៅដល់គេទប់ហើយ ប៉ុន្តែគ្រាន់តែយកកម្លាំងទៅដាក់សម្រាប់ធ្វើស្រែប្រាំងនៅខាងក្រោម"]។ ឯកសារ D215/1.1.1 ខាងក្រោយភាពខ្មៅងងឹត៖ ការទទួលខុសត្រូវ ឬការអនុវត្តតាមបញ្ជា? KH 01030495 [កិច្ចសម្ភាសន៍ជាមួយ អ៊ឹម ចែម៖ "នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំអាចឃើញទំនប់នេះដែលមានទឹកពេញ។ នៅជិតនោះ មនុស្សម្នាកំពុងដាំស្រូវប្រាំង។"]។ ឯកសារ D119/124 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.19 KH 010987268 [សាក្សីជាអ្នកថតរូបនៅមន្ទីរ ស-២១ និងបានធ្វើដំណើរទៅត្រពាំង

ថ្មៈ "លោកនិយាយថាលោកបានទៅការដ្ឋានអាងត្រពាំងថ្មពីរដង នៅដើមឆ្នាំ ១៩៧៧ និងពាក់កណ្តាលឆ្នាំ ១៩៧៧។ តើលោកចាំលោកបានទៅនៅខែណាទេ? តើលោកជួបយាយថែមទាំងពីរលើកឬ? ឆ.19ៈ ខ្ញុំទៅការដ្ឋានអាងត្រពាំងថ្មលើកដំបូងនៅខែមករា ឆ្នាំ១៩៧៧ ហើយនៅពេលនោះខ្ញុំមិនបានជួបគាត់ទេ។ ខ្ញុំបានជួបគាត់នៅពេលដែលខ្ញុំធ្វើដំណើរលើកទី២នៅពាក់កណ្តាលឆ្នាំ១៩៧៧គឺប្រហែលជានៅក្នុងខែមិថុនា ឬកក្កដា។"]។

1402 ឯកសារ D118/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.57 KH 00968038 [សាក្សីជាកម្មាភិបាលខ្មែរក្រហម "ក្រៅពីតួនាទីជាគណៈស្រុក គេឲ្យគាត់ចូលជាសមាជិកតំបន់៣ ជាមួយនឹងតាចាត"] ឆ.59 KH 00968039 ["ព្រោះពេលដែលខ្ញុំឡើងមកប្រជុំ គឺខ្ញុំជួបគាត់ ហើយពេលនោះគេប្រាប់អំពីតួនាទីរបស់គាត់។"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.75 KH 01049234 [សាក្សីធ្វើការនៅកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៨ៈ "ខ្ញុំមិនដឹងពីមុខតំណែងគាត់ច្បាស់ទេ តែគាត់ជាអ្នកគ្រប់គ្រងធំនៅភ្នំស្រុក ភ្នំលៀប និងភ្នំទ្រយោង។"] ឆ.77 KH 01049234 ["ឆៈ អ៊ីចឹង តើយាយថែមមានអំណាចគ្រប់គ្រងស្រុកភ្នំស្រុក និងស្រុកព្រះនេត្រព្រះផងឬ? ឆ. 77ៈ បាទ។"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.117-118 KH 00989352-00989353[សាក្សីធ្វើការនៅក្នុងកងកុមារៈ "យាមថែម ជាអ្នកបញ្ជាផ្ទាល់ទាំងអស់ [...] គ្រប់កម្រិតទាំងអស់ ទាំងថ្នាក់តំបន់ផងដែរ។"] ឆ.119 KH 00989353 ["សៈ ហេតុអ្វីបានជាលោកស្រីដឹងថាគាត់មានសិទ្ធិអំណាចខ្លាំងដល់កម្រិតនេះ? ឆ.119ៈ ព្រោះគាត់ជាអ្នកបញ្ជាពីថ្នាក់លើ ហើយអ្នកខាងក្រោមជាអ្នកបញ្ជាបន្តដើម្បីអនុវត្ត។"]។ ឯកសារ D219/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.42 KH 01032106 [សាក្សីត្រូវបានបញ្ជូនពីភូមិភាគនីរតីទៅកាន់ស្រុកស៊ីសុផុន ក្នុងអំឡុងពេលបោសសម្អាត និងត្រូវបានតែងតាំងជាមេភូមិមួយក្នុងស្រុកស៊ីសុផុនៈ "ខ្ញុំមិនដឹងថាគាត់មានតួនាទីអ្វីទេ ប៉ុន្តែខ្ញុំធ្លាប់បានឃើញយាយថែម ចេញចូល និងប្រជុំនៅមន្ទីរស្វាយស៊ីសុផុន នៅពេលដែលខ្ញុំចូលរួមប្រជុំនៅទីនោះ។ មន្ទីរនៅស្វាយស៊ីសុផុន គឺជាមន្ទីរតំបន់៥។"]។ ឯកសារ D119/144 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត សួយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ឆ.94 KH 01009218 [សាក្សីធ្វើការនៅកងចល័តនៅត្រពាំងថ្មៈ ក្រោយពេលដែលពួកកម្មាភិបាលពាយ័ព្យទាំងអស់ ត្រូវបានចាប់ខ្លួន ពុំទាន់មានគណៈស្រុកថ្មីណាមកជំនួសទេ ហើយនៅពេលនោះ ពួកយើងឮតែឈ្មោះមនុស្សពីរនាក់ប៉ុណ្ណោះ គឺឈ្មោះតាម៉ុក និងយាយថែម ហើយពួកគាត់ទាំងពីរនេះ មានឈ្មោះល្បីល្បាញណាស់នៅពេលនោះ ហេតុដូច្នេះហើយ បានខ្ញុំនិយាយថា គណៈតំបន់៥ អាចជាយាយថែម ក៏បាន តាម៉ុកក៏បាន។"]។ ឯកសារ D219/433 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ស៊ីន ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥ ឆ.8 KH 011242412-011242413 [សាក្សីធ្វើការនៅភ្នំលៀបៈ "ខ្ញុំគ្រាន់តែដឹងថាពួកគេជាអ្នកមកពីនីរតី មកពីតាកែវ តែខ្ញុំមិនដឹងថានីរតីនេះនៅឯណាទេ។ ខ្ញុំចាំតែឈ្មោះយាយ ថែម ម្នាក់ទេដែលមកពីនីរតី ហើយយាយ ថែមជាអ្នកក្តាប់រួមនៅតំបន់របស់ខ្ញុំ។"] ឆ.9 KH 011242413 ["ខ្ញុំឃើញយាយថែម នៅភ្នំលៀប និងភ្នំទ្រយោង តែខ្ញុំមិនចាំក្នុងតំបន់ប៉ុន្មានទេ។"]។ ឯកសារ D119/99 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ រស់ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៤ ឆ.22 KH 00978921 [សាក្សីធ្វើការនៅកងចល័តក្នុងស្រុកព្រះនេត្រព្រះៈ "តាមខ្ញុំយល់គេយាយថែមជាអ្នកបញ្ញជាឲ្យគេចាប់ពួកគាត់ ពីព្រោះយាយថែម គឺជាគណៈស្រុកព្រះនេត្រព្រះថ្មី។ ខ្ញុំធ្លាប់បានឮពីមនុស្ស

នៅក្នុងកងចល័ត ថាគាត់ក៏ជាកម្មាភិបាលថ្នាក់តំបន់ ហើយគាត់ស្នាក់នៅភ្នំលៀប។ ខ្ញុំមិនចាំឈ្មោះមនុស្សនៅក្នុងកងចល័តដែលបានប្រាប់ខ្ញុំទេ។"]។ ឯកសារ D5/853 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ថង ធឿយ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00956904 [សាក្សីធ្វើការនៅក្នុងកងចល័តក្នុងកងចល័តតំបន់៖ "យាយថែមកាន់កាប់តំបន់៥ទាំងមូល"]។ ឯកសារ D5/865 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ រឿង សារួន ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00957090 [សមាជិកកងចល័តក្នុង "កម្លាំងទី១"៖ "នៅឆ្នាំ៧៧ ចុងឆ្នាំ ខ្ញុំត្រូវគេបង្ខំឲ្យរៀបការ១០០គូនៅស្វាយស៊ីសុផុន ដែលមានតាលាស់ [...] អ្នកដឹកនាំសម័យនោះ មានឈ្មោះតាវ៉ល់ តាហាក់ តាហាត់ តាឆាំ តាញ៉ឹម តាជាល ឯយាយថែមជាអ្នកដឹកនាំតំបន់។"]។

1403 ឯកសារ D118/93 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ស៊ឹម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៣ ឆ.19-21 KH 00947263 [សាក្សីគឺជាកម្មាភិបាលភូមិភាគនីរតី ដែលត្រូវបានចាត់តាំងឲ្យទៅនៅភូមិភាគពាយ័ព្យ៖ "ឆ.19៖ ក្នុងគណៈតំបន់មានតាចាយ ជាប្រធាន យាយថែម ជាអនុប្រធាន តាញៀន ជាប្តីយាយថែម គឺជាសមាជិក និងតាប៊ូក៏ជាសមាជិកដែរ។ តាចាយ គាត់ទទួលរួម ហើយគាត់នៅមង្គលបុរី យាយថែម គាត់កាន់ខាងស្រុកព្រះនេត្រព្រះ តាប៊ូ គាត់កាន់ខាងស្រុកភ្នំតូច ភ្នំធំ ហើយចំពោះតាញៀន ខ្ញុំភ្លេចថា គាត់កាន់ខាងអ្វីហើយ។ យាយថែម តាញៀន និងតាប៊ូ គាត់មកភូមិភាគពាយ័ព្យនេះមុន តាចាយ និងខ្ញុំយូរណាស់។ សៈ តើលោកដែលបានជួបផ្ទាល់ជាមួយយាយថែមដែរឬទេ? ឆ.20៖ ពេលដែលខ្ញុំនៅមង្គលបុរី តាចាយ គាត់ហៅខ្ញុំទៅប្រជុំ ហើយនៅទីនោះ ទើបខ្ញុំបានជួបយាយថែម។នៅពេលប្រជុំនោះ តាចាយ គាត់និយាយណែនាំថា ថ្នាក់ភូមិភាគ ថ្នាក់តំបន់ ថ្នាក់ស្រុក មិនមានសិទ្ធិសម្លាប់មនុស្សទេ មានតែថ្នាក់មជ្ឈិមទេ ទើបអាចមានសិទ្ធិសម្លាប់មនុស្សបាន ហើយបើប្រជាជនធ្វើខុសគឺត្រូវយកមកអប់រំជាមូលដ្ឋាន។ ខ្ញុំគិតថា តាចាយគាត់ជាមនុស្សល្អណាស់ ឧទាហរណ៍ថា នៅពេលដែលគេមករាយការណ៍ ថាមានប្រជាជនលួចម្ហូប តាចាយ គាត់ថាមកពីប្រជាជនមិនមានអាហារហូបទើបបានគេមកលួច ហើយគាត់មិនបានធ្វើទោសលើប្រជាជននោះទេ។ សៈ តើនៅក្នុងពេលប្រជុំនោះ មានអ្នកណាមកពីតំបន់ផ្សេងចូលរួមប្រជុំដែរឬទេ? ឆ.21៖ មិនមានទេ គឺមានតែគណៈតំបន់តែប៉ុណ្ណោះ។ ឯកសារ D118/153 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង វុន ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.57-59 KH 00968038-00968039 [សាក្សីបានចូលរួមក្នុងកិច្ចប្រជុំដែលយាយថែម ត្រូវបានតែងតាំងជា គណៈតំបន់៖ "ឆ.57៖ ក្រៅពីតួនាទីជាគណៈស្រុក គេឲ្យគាត់ចូលជាសមាជិកតំបន់៣ ជាមួយនឹងតាចាយ។ យាយថែម ធ្វើជាសមាជិកតំបន់៣ គឺនៅពេលដែលមានការដាក់បញ្ចូលគ្នានូវតំបន់៥ និងតំបន់៣។ សៈ នៅពេលដែលគេដាក់បញ្ចូលតំបន់៥ទៅក្នុងតំបន់៣ តើលោកដឹងថាមានអ្នកណាខ្លះទៀតនៅក្នុងគណៈតំបន់៣? ឆ.58៖ តាមខ្ញុំដឹងគឺមានតែ តាចាយ និងយាយថែមប៉ុណ្ណោះនៅក្នុងគណៈតំបន់។ ចំណែកប្រធានរបស់ខ្ញុំឈ្មោះ នយ លាវ គាត់ក៏នៅក្នុងនោះដែរ គឺជាជំនួយការគណៈតំបន់តំបន់។"]។ ឯកសារ D219/4.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សួន ម៉ុត ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១៤ KH 01025156 [សាក្សីត្រូវបានបញ្ជូនពីភូមិភាគនីរតីទៅស្រុកស៊ីសុផុន ក្នុងអំឡុងពេលបោសសម្អាត និងត្រូវបានតែតាំងជាមេភូមិមួយនៅក្នុងស្រុកស៊ីសុផុន៖ "សៈ ដល់ពេលតាជាល គេចាប់ទៅ តារិន ក្រោយមកគេចាប់ទៀតទៅ នៅតែយាយថែម? ឆៈ នៅសល់តែយាយថែម បានតាចាយមក"។ ឯកសារ D119/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឆ.16 KH 00894503 [សាក្សីបានរៀប

ការជាមួយអតីតប្រធានកងនៅព្រះនេត្រព្រះ៖ "ខ្ញុំឮតាមប្រធានកងចល័តថា នៅចុងឆ្នាំ ១៩៧៨ យាយថែម ត្រូវបានតែងតាំងជាគណៈតំបន់៥។"]

1404 សូមមើល ឯកសារ D6.1.960 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ KH 00442269 [មាត្រា៧(៣) អង្គការគឺមានសិទ្ធិអំណាចធំជាងគេបំផុត សំរាប់តំបន់ឬក្រុងនីមួយៗ គឺសន្និបាតតំណាងតំបន់ ឬក្រុងនីមួយៗ។ ក្នុងរយៈពេលពីសន្និបាតតំបន់ ឬក្រុងមួយទៅមួយទៀតមានអង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតសំរាប់តំបន់ ឬក្រុងនីមួយៗនោះ គឺគណៈកម្មាធិការតំបន់ ឬក្រុង។"] KH 00442269 [មាត្រា៧(៤) អង្គករមានសិទ្ធិអំណាចធំជាងគេបំផុតសំរាប់ស្រុកនីមួយៗ គឺសន្និបាតតំណាងស្រុក។ ក្នុងរយៈពេលពីសន្និបាតស្រុកមួយទៅមួយទៀត មានអង្គការប្រតិបត្តិការសំរាប់ស្រុកនីមួយៗនោះ គឺគណៈកម្មាធិការស្រុក។"] KH 00442268 [មាត្រា៦(១)-(២)៖ "គ្រប់អង្គការដឹកនាំរបស់បក្ស ត្រូវអនុវត្តរបបដឹកនាំសមូហភាព ហើយមានបុគ្គលទទួលខុសត្រូវដោយឡែក [...] គ្រប់ការសំរេចផ្សេងៗរបស់បក្ស ត្រូវធ្វើឡើងដោយ សមូហភាព។"]។

1405 ឯកសារ D6.1.342 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ រួម ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH 00279079 [សាក្សីគឺជាកសិករដែលបោះទីតាំងនៅជិតត្រពាងថ្ម៖ "អ្នកកាន់ការលើទំនប់ត្រពាំងថ្មនោះ ឈ្មោះតាវ៉ាល់"]។ ឯកសារ D55 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ាន់ ចាន់រុំ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727210 [សាក្សីគឺជា កម្មករនៅត្រពាំងថ្មពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩៖ "សៈ តើនរណាជាអ្នកគ្រប់គ្រងការងារនៅទំនប់នេះ? ឆៈ គឺឈ្មោះតាវ៉ាល់""]។ ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.104 KH 00996504 [សាក្សីធ្វើការនៅក្នុងកងកុមារក្នុងកងចល័តតំបន់៥៖ "តាវ៉ាល់ ធ្លាប់គ្រប់គ្រងរួមនៅកន្លែងធ្វើការនៅទំនប់អាងត្រពាំងថ្ម""]។ ឯកសារ D57 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យ៉ែម គិមរស់ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 007272213 [សាក្សី ជាកម្មកក្នុងកងចល័តដែលត្រូវបញ្ជូនទៅត្រពាំងថ្ម៖ "សៈ តើនរណាជាអ្នកគ្រប់គ្រងការងារទាំងអស់នៅលើការងារទំនប់ទីនោះ? សៈ [...] អ្នកគ្រប់គ្រងទូទៅនៅឆ្នាំ ១៩៧៧ គឺតាវ៉ាល់។"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១ ឆ.37 KH 01049231 [សាក្សីធ្វើការនៅក្នុងកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៦ និងឆ្នាំ ១៩៧៨៖ "ប្រធានធំ ឈ្មោះតាវ៉ាល់។"]។ ឯកសារ D119/33 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឆ.14 KH 00907526 [សាក្សីគឺជាប្រធានសេដ្ឋកិច្ចនៃកងចល័តតំបន់ និងជាអ្នកគ្រប់គ្រងម្នាក់នៅត្រពាំងថ្ម៖ "តាវ៉ាល់គឺជាប្រធានចល័តតំបន់ និងជាអ្នកគ្រប់គ្រងទំនប់ត្រពាំងថ្ម។"]។ ឯកសារ D119/90 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.12 KH 00976141 [សាក្សីគឺជាកម្មករកងចល័តថ្នាក់ស្រុក ដែលដឹកប្រឡាយនៅត្រពាំងថ្មរហូតដល់ពួកភូមិភាគនិរតី បានមកដល់៖ "ពេលដែលខ្ញុំធ្វើការនៅអាងត្រពាំងថ្ម ដំបូង តាវ៉ាល់ ជាអ្នកគ្រប់គ្រង។"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ចុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267756 [អនុប្រធានកងអនុសេនាតូចនៅត្រពាំងថ្ម "មានអ្នកនៅប្រចាំការក្នុងការដ្ឋានទំនប់ត្រពាំងថ្មទាំងព្រឹកល្ងាច ឈ្មោះតាវ៉ាល់ (បានបាត់ខ្លួន)។"]។ ឯកសារ D119/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.30 KH 01024775 [សាក្សីគឺជាប្រធានកងចល័ត៖

"ខ្ញុំមិនដែលឃើញតាវ៉ាល់ទេ តែខ្ញុំឮប្រជាជនៅក្នុងកងចល័តនិយាយថាតាវ៉ាល់ ធ្លាប់ជាអ្នកគ្រប់គ្រងការដ្ឋានអាងត្រពាំងថ្ម ពីព្រោះនៅពេលដែលខ្ញុំទៅដល់ទំនប់ត្រពាំងថ្ម គាត់មិននៅទីនោះទេ។"]។

1406 ឯកសារ D119/43 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.10 KH 00915882 [សាក្សីធ្វើការនៅក្នុងកងចល័តភូមិភាគ៥៖ "តាវ៉ាល់គឺជាប្រធានកងចល័តតំបន់៥។"]។ ឯកសារ D119/98 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កោ ឡិន ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៤ ឆ.18 KH 00978910 [សាក្សីគឺជាប្រធានកងចល័តមួយនៃតំបន់៥ នៅត្រពាំងថ្ម និងការដ្ឋានផ្សេងទៀត៖ "តាវ៉ាល់ជាអ្នកគ្រប់គ្រងកងចល័តតំបន់៥ ដែលធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។"]។ ឯកសារ D119/33 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឆ.14 KH 00907526 [សាក្សីគឺជាប្រធានសេដ្ឋកិច្ចនៃ កងចល័តតំបន់ និងជាអ្នកគ្រប់គ្រងម្នាក់នៅត្រពាំងថ្ម៖ "តាវ៉ាល់គឺជាប្រធានចល័តតំបន់ និងជាអ្នកគ្រប់គ្រងទំនប់ត្រពាំងថ្ម។"]។ ឯកសារ D119/139 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.33 KH 01003881 [សាក្សីជាប្រធានកងចល័តមួយក្នុងតំបន់៥៖ "តាវ៉ាល់គឺជាអ្នកគ្រប់គ្រងកងចល័តតំបន់៥"។

1407 ឯកសារ D6.1.425 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តន់ ថាន ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267782 [សមាជិកកងអ្នកយាមរបស់តាវ៉ាល់ រហូតដល់ពាក់កណ្ដាលឆ្នាំ១៩៧៧៖ "តាវ៉ាល់ត្រូវគេចាប់យកទៅសម្លាប់នៅពាក់កណ្ដាលឆ្នាំ១៩៧៧ ដោយគេចោទថាក្បត់។"]។ ឯកសារ D119/43 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វា នង់ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.14 KH 0091883 [សាក្សីធ្វើការនៅក្នុងកងចល័តភូមិភាគ៥៖ "គេបានចាប់តាវ៉ាល់នៅទំនប់ស្ពានស្រែង កាលខ្ញុំធ្វើការក្នុងកងពិសេសនៅកំបោរ។ តាវ៉ាល់ចាប់ខ្លួនដោយពួក នីរតី"។]។ ឯកសារ D55 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យ៉ាន់ ចាន់រ៉ុ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727210 [សាក្សីធ្វើការនៅត្រពាំងថ្មពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩៖ "សៈ តើនរណាជាអ្នកគ្រប់គ្រងការងារនៅទំនប់នោះ? ឆៈ គឺឈ្មោះតាវ៉ាល់។ គាត់បានស្លាប់ពេលពួកនីរតីមកដល់។"]។ ឯកសារ D119/156 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ឹង ជឿន ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.25 KH 01024774 [សាក្សីគឺជាប្រធានកងចល័តមួយ៖ "ប្រហែលជាក្នុងខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានកងចល័តសហករណ៍សំរោង និងទៅធ្វើការដើម្បីពង្រឹងអាងត្រពាំងថ្ម ដូចជាត្រូវបិទរន្ធខ្លះដែលមានទឹកហូរបាក់ទំនប់។"] ឆ.30 KH 01024775 [សាក្សីគឺជាប្រធានកងចល័តមួយដែលត្រូវបានបញ្ជូនទៅត្រពាំងថ្មនៅដើមឆ្នាំ១៩៧៨ ជាផ្នែកមួយនៃការបោសសម្អាត៖ "ខ្ញុំមិនដែលឃើញតាវ៉ាល់ទេ តែខ្ញុំឮប្រជាជនក្នុងកងចល័តនិយាយថាតាវ៉ាល់ ធ្លាប់ជាអ្នកគ្រប់គ្រងការដ្ឋានអាងត្រពាំងថ្ម ពីព្រោះនៅពេលដែលខ្ញុំទៅដល់ទំនប់ត្រពាំងថ្ម គាត់មិននៅទីនោះទេ។"]។ ឯកសារ D57 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យ៉ែម គិមរស់ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727214 [សាក្សីជាកម្មករនៅក្នុងកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្ម៖ "តាវ៉ាល់ ត្រូវបានគេសម្លាប់នៅចុងឆ្នាំ១៩៧៧ ហើយប្រហែលជានៅឆ្នាំ១៩៧៧ មានអ្នកថ្មីមកជំនួសគាត់ ហើយពួក នីរតីនេះ បានបន្តនៅគ្រប់គ្រងរហូតឆ្នាំ១៩៧៩។ [...] ខ្ញុំឮគេនិយាយថាគេវាយតាវ៉ាល់ចោលហើយ គឺនៅចុងខែវស្សា ឆ្នាំ១៩៧៧។" ឯកសារ D219/130 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.46 KH 01049231 [សាក្សីជាកម្មករនៅក្នុងកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្ម ក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨៖ "សៈ តាវ៉ាល [...] តើមានអ្នកណានៅរស់ទេ? ឆៈ ទេ គេវាយចោល

អស់ហើយ"] ឆ.51 KH 01049232 ["គាត់ត្រូវបានគេសម្លាប់នៅឆ្នាំ១៩៧៧។"] ឆ.57 KH 01049232 ["នៅចុងឆ្នាំ ១៩៧៧។ បន្ទាប់ពីគេចាប់ពួកនោះអស់ គេបញ្ជូនពួកពីនិរតីទៅគ្រប់គ្រង។ ពួកគេកាចណាស់។"]។ ឯកសារ D119/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.4 KH 00895159 [សាក្សីគឺជាអនុប្រធានកងចល័តតំបន់៥របស់តាហ៊ីងនៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៧ "ពេលពួកនិរតីមកដល់ តាវ៉ាល់ ត្រូវបានគេចាប់ខ្លួន។"]។ ឯកសារ D119/33 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឆ.14 KH 00907526 សាក្សីគឺជាប្រធានសេដ្ឋកិច្ចនៃកងចល័តតំបន់ និងជាអ្នកគ្រប់គ្រងម្នាក់នៅត្រពាំងថ្ម៖ "ក្រុមដែលចាប់មនុស្សនោះ គឺជាមនុស្សមកពីភូមិភាគនិរតី" [...] គាត់ [តាវាល់] ក៏ត្រូវបានចាប់ខ្លួនផងដែរ។"]។ ឯកសារ D118/61 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.42 KH 00920158 [សាក្សី គឺជាកម្មករ ហើយក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម។គាត់បានធ្វើការនៅការដ្ឋាននោះនៅពេលដែលកម្មាភិបាលភូមិភាគនិរតីមកគ្រប់គ្រង៖ "គេមិនបាននិយាយអ្វីទេ ស្រាប់តែឃើញគេចូលមកតែម្តង។ ពេលដែលគេចូលមកបាន២ទៅ២ថ្ងៃស្រាប់តែតាវ៉ាល់តែម្តង តែខ្ញុំមិនដឹងថា គាត់បាត់ទៅណាទេ"]។ ឯកសារ D119/78 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុត បណ្ដែត ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤ ឆ.21 KH 00971160 [សាក្សីធ្វើការនៅត្រពាំងថ្មនៅពេលពួកនិរតីបានមកដល់៖ "ពេលខ្ញុំធ្វើការនៅត្រពាំងថ្ម ខ្ញុំបានសួរមេរបស់ខ្ញុំឈ្មោះ វឿន ថាហេតុអ្វីបានជាមិនដែលឃើញតាវ៉ាល់។ គាត់បានប្រាប់ខ្ញុំថាតាវ៉ាល់ត្រូវបានគេចាប់ខ្លួនទៅជប់។"]។ ឯកសារ D119/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ ឆ.36 KH 01003882[សាក្សីគឺជាប្រធានកងចល័តមួយក្នុងតំបន់៥៖ "ស៖ តើលោកនៅចាំទេថា នៅពេលណាកម្មាភិបាលនីរតីឈ្មោះ តាញ៉ែវ បានមកជំនួសតាវ៉ាល់? ឆ.36៖ គឺនៅក្នុងឆ្នាំ១៩៧៧ប្រហែលនៅខែច្រូតកាត់ គឺពាក់កណ្តាលខែវិច្ឆិកា។"]។ ឯកសារ D219/506 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែន សុផុន ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៥ ឆ.36 KH 01148732 [សាក្សីធ្វើការនៅកងចល័តនៅត្រពាំងថ្ម។ គាត់បានធ្វើការនៅការដ្ឋាននោះ ពេលដែលកម្មាភិបាលនីរតីមកគ្រប់គ្រង៖ ឆ.36៖ "ខ្ញុំមិនដឹងរឿងច្រើនពីគាត់ទេ។ ខ្ញុំឮគេនិយាយថា ពេលយាយចែម មកដល់ គេចាប់តាវ៉ាល់ និងទម្លាក់តំណែងគាត់។ ក្រោយមក យាយចែម ឡើងជំនួសតាវ៉ាល់។ យាយចែម គឺជាអ្នកមកពីភូមិភាគនិរតី។"]។

1408 ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267746 [សាក្សី គឺជាកម្មករ ហើយក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម។គាត់បានធ្វើការនៅការដ្ឋាននោះនៅពេលដែលកម្មាភិបាលភូមិភាគនិរតីមកគ្រប់គ្រង៖ "តាយន់ មកពីនិរតីគ្រប់គ្រងការលើកទំនប់ត្រពាំងថ្ម គាត់បានចាប់យកមនុស្សជាច្រើនយកទៅសម្លាប់។"]។ ឯកសារ D119/33 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត យឿក ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឆ.14 KH 00907526 [សាក្សីគឺជាប្រធានសេដ្ឋកិច្ចនៃកងចល័តតំបន់ និងជាអ្នកគ្រប់គ្រងម្នាក់នៅត្រពាំងថ្ម៖ "នៅពេលនោះ យាន់ អ្នកនិរតី បានឡើងជំនួសតាវ៉ាល់ ហើយជាប្រធានរបស់ខ្ញុំ។"។ ឯកសារ D119/47 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីម ហុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.9 KH 00933093 [ធ្វើការនៅក្នុងកងចល័តត្រពាំងថ្មរហូតដល់ទំនប់ធំបានសាងសង់ហើយ៖ "តាយន់ អ្នកនិរតី គឺជាអ្នកគ្រប់គ្រងកងចល័តត្រពាំងថ្មទាំងមូល។"]។ ឯកសារ D118/61 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.48 KH 00920159 [សាក្សី គឺជា

កម្មករ ហើយក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម។គាត់បានធ្វើការនៅការដ្ឋាននោះនៅពេលដែលកម្មាភិបាលភូមិភាគនីរតីមកគ្រប់គ្រង៖ "ពេលកំពុងធ្វើអាងនេះ តាវ៉ាល់ គាត់ជាអ្នកដឹកនាំប្រជុំ ហើយក្រោយមក ទើបតាយ៉ុន។"

1409 ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥, ឆ.44 KH 01105586 [សាក្សីជាកម្មករនៅការដ្ឋានទំនប់ត្រពាំងថ្ម៖ "នៅទំនប់ត្រពាំថ្ម ដំបូងគេឱ្យលើកមួយម៉ែត្រគីប បន្ទាប់មកគេឱ្យលើកបីម៉ែត្រគីប"], ឆ.87 KH 01105590 "តែពេលដែលយាយ ចែម មកដាក់ការងារឱ្យធ្វើការ៣ម៉ែត្រក្នុងមួយនាក់។"] ឆ.88 KH 01105590 ["យាយចែម ប្រជុំឱ្យធ្វើការឱ្យគ្រប់៣ម៉ែត្រគីប ហើយធ្វើឱ្យគ្រប់តាមផែនការ។"] ឆ.89 KH 01105591 ["យាយចែម មកបញ្ជាបានតែ១ដងគត់ ហើយគាត់ដាក់ឱ្យធ្វើ៣ម៉ែត្រ ក្នុងមួយនាក់តែម្តង។"] សូមមើលផងដែរ ឯកសារ D5/962 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ អៀម វុយ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ KH 00989803 [សាក្សីធ្វើការនៅត្រពាំងថ្មឆ្នាំ១៩៧៦រហូតដលឆ្នាំ១៩៧៨៖ "១៩៧៦ កាលនោះ អង្គការប៉ុល ពត មិត្តវ៉ាល់ យាយចែម បានចាត់តាំងឱ្យធ្វើការលើកទំនប់អាងត្រពាំងថ្មដោយកំណត់៣ម៉ែត្រគីបក្នុងមួយថ្ងៃ។"]។ ឯកសារ D5/1074 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ម៉ុក ថូវ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ KH 01022717 [សាក្សីជាកម្មករកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្មពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨៖ "មិត្តវ៉ាល់ ជាមេកង មិត្តចែម ជាប្រធានយោធាគណៈតំបន់៥ បានបញ្ជាដាក់លាក់៣ម៉ែត្រគីបក្នុងម្នាក់ៗ។"]។ ឯកសារ D219/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឆ.27 KH 01066001 [សាក្សីធ្វើការនៅក្នុងកងចល័តតំបន់៥នៅត្រពាំងថ្ម៖ "មុនកម្មាភិបាលនីរតីមកដល់ ស្ថានភាពការងារ គឺគេឱ្យយើងជីកដីពីពីរ ឬបីម៉ែត្រគូបក្នុងមួយថ្ងៃ។ ហើយពេលដែលកម្មាភិបាលនីរតីមកដល់ គឺគេឱ្យយើងរែលដីបីម៉ែត្រគូបក្នុងមួយថ្ងៃ។"]។ ឯកសារ D6.1.427 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267760 [សាក្សីគឺជាមេកងចល័តនៅទំនប់ត្រពាំងថ្ម៖ "មុនដំបូងគេឱ្យជីក និងរែកដី ក្នុងម្នាក់ៗមួយម៉ែត្រ គូបក្នុងមួយថ្ងៃ ក្រោយមកគេតំឡើងពីរម៉ែត្រគូប និងក្រោយមកទៀតគេតំឡើងដល់បីម៉ែត្រគូប។"]។ ឯកសារ D5/1348 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡេវ សំភុយ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៣ KH 0104917 [សាក្សីធ្វើការនៅត្រពាំងថ្មនៅដើមឆ្នាំ ១៩៧៧៖ "នៅការដ្ឋាននោះ [ត្រពាំងថ្ម] មិត្តវ៉ាល់ មេចល័ត បញ្ជាកំណត់កងចល័តម្នាក់ៗលើកទំនប់ជីកប្រឡាយ ឱ្យបាន២ម៉ែត្រគីបក្នុងមួយថ្ងៃ។"]។ ឯកសារ D5/1507 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ស៊ុន ចេស ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៣ KH 01080194 [សាក្សីបានទៅត្រពាំងថ្មនៅដើមឆ្នាំ១៩៧៧៖ "[ក្រោមការដឹកនាំ] របស់មិត្តវ៉ាល់ [...] ម្នាក់ៗត្រូវជីក និងរែកដីឱ្យបានពីរម៉ែត្រគីបក្នុងមួយថ្ងៃ។"]។

1410 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.95 KH 00996504 [សាក្សីធ្វើការក្នុងកងកុមារក្នុងចល័តតំបន់៥៖ "ចាស ខ្ញុំធ្លាប់ឃើញគាត់ [អ៊ឹម ចែម] មកត្រួត ពិនិត្យនៅទំនប់អាងត្រពាំងថ្មនោះ។"] ឆ.96 KH 00996504 ["គាត់មកពិនិត្យអាងត្រពាំងថ្មរៀងរាល់មួយអាទិត្យម្តង។"]។ ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.44 KH 01105587 [សាក្សីធ្វើការនៅត្រពាំងថ្ម៖ "ខ្ញុំធ្លាប់ឃើញចែមដែរ។ គាត់ជិះសេះមកមើលនៅកន្លែងធ្វើការ ប្រាប់ឱ្យអ្នកធ្វើការនៅទីនោះខំប្រឹងធ្វើការ។"] ឆ.73 KH 01105589

["គាត់មិនស្នាក់នៅអាងត្រពាំងថ្មទេ គាត់គ្រាន់តែមកមើលនៅអាងហ្នឹងហើយ ហើយក៏ទៅ។"] ឆ.74 KH 01105589 ["គឺមក១ដងក្នុង មួយសប្តាហ៍។"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.90 KH 00989349 [សាក្សីធ្វើការនៅកងចល័តកុមារនៅត្ពាំងថ្ម៖ "គឺមានតែតាវ៉ាល់ និងយាយចែមប៉ុណ្ណោះដែលចុះមកមើលការដ្ឋានទំនប់ត្រពាំងថ្ម។"] ឆ.92 KH 00989349 ["ខ្ញុំឮគេនិយាយថា យាយ ចែម យូរៗចុះមកអាងត្រពាំងថ្មម្តង។"]។ ឯកសារ D119/90 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.12 KH 00976141 [សាក្សីជាកម្មករនៅក្នុងកងចល័តថ្នាក់ស្រុក ដែលជីកប្រឡាយនៅត្រពាំងថ្ម រហូតដល់ក្រោយពេលពួកភូមិភាគនិរតីបានមកដល់៖ "ខ្ញុំបានឃើញយាមចែមម្តងម្កាល ពេលគាត់មកពិនិត្យការងារនៅការដ្ឋាននេះ។"]។ ឯកសារ D119/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុម តៅ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.21 KH 00976156 ["យាយចែម ចុះមកពិនិត្យមើលការដ្ឋានធំៗ ដូចជាទំនប់ត្រពាំងថ្មនិងប្រឡាយអូរលៀប។ [...] ខ្ញុំមិនបានទៅធ្វើការនៅការដ្ឋានទាំងពីរនេះទេ ក៏ប៉ុន្តែគេប្រាប់ខ្ញុំថា គាត់ចុះទៅពិនិត្យការដ្ឋានទាំងនេះ។"]។ ឯកសារ D119/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.8 KH 00895159 [សាក្សីគឺជាអនុប្រធានកងចល័តតំបន់៥របស់តាហ៊ីង នៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៧៖ "យាយចែម មានតួនាទីជាគណៈស្រុកព្រះនេត្រព្រះ ដូច្នេះគាត់មិនមានតួនាទីណាមកគ្រប់គ្រងការដ្ឋានពាំងថ្មទេ។ ប៉ុន្តែមានកងចល័តស្រុកព្រះនេត្រព្រះធ្វើការនៅការដ្ឋាននោះ ដូច្នេះប្រហែលជាគាត់មកគ្រប់គ្រងកម្លាំងនេះ ហើយអ្នកខ្លះបានឃើញយាយចែម មកការដ្ឋាន មានការយល់ច្រឡំថាគាត់ជាអ្នកគ្រប់គ្រងការដ្ឋានទាំងមូល។"]។ ឯកសារ D5/979 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស៊ុន សប ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ KH 00990077 [សាក្សីធ្វើការក្នុងកងចល័ត៖ "នៅការដ្ឋានត្រពាំងថ្មនេះ ពិបាកខ្លាំងណាស់ មិត្តវ៉ាល់ដើរត្រួតពិនិត្យគ្រប់ទីកន្លែង បន្ទាប់មក យាយចែម ទៅជាមួយគ្នាដែរ។"] ផ្ទុយនឹង ឯកសារ D119/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លី សិញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៣ ឆ.8 KH 00894502 [សាក្សីធ្វើការនៅក្នុងកងចល័ត៖ "យាយចែម មិនដែលចុះទៅពិនិត្យការដ្ឋានទំនប់ត្រពាំងថ្មទេ។"]។

1411 ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.43 KH 01105586 [សាក្សីធ្វើការនៅត្រពាំងថ្ម៖ "ខ្ញុំមិនដែលបានឃើញយាយចែម និងញ៉ុនទេ ព្រោះគេបញ្ជូនតែ កូនចៅឱ្យមើលយើងតែប៉ុណ្ណោះ។"] ឆ.47 KH 01105586 ["ទេ គាត់ [អ៊ឹម ចែម] គ្រាន់តែបញ្ជូនកូនចៅឱ្យមកណែនាំប៉ុណ្ណោះ។"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.109 KH 01049237 [សាក្សីធ្វើការនៅក្នុងកងចល័តដែលត្រូវបានបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨៖ "មានអ្នកមកពីក្រុមរបស់យាយចែមមកត្រួតពិនិត្យការងារនៅកន្លែងការដ្ឋានសង់ទំនប់ដែរ។"]។ ឯកសារ D119/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹម ផន ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៣ ឆ. 52 KH 00907519[សាក្សីមើលការខុសត្រូវកងចល័តឃុំ ដែលត្រូវបានបញ្ជូនទៅធ្វើការនៅត្រពាំងថ្ម៖ "ស៖ ក្រោមការគ្រប់គ្រងស្រុកព្រះនេត្រព្រះ យាយចែមបានបញ្ជូនកងចល័តទៅធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។តើលោកមានបានទៅធ្វើការនៅកន្លែងនោះទេ? ឆ.52៖ បាទ ខ្ញុំមានទៅ។ ខ្ញុំទៅមើលការខុសត្រូវកងចល័តរបស់ឃុំ ដែលទៅលើកទំនប់ត្រពាំងថ្មនោះ។"]។

1412 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929740 ["ដារ៉ា៖ កាលម៉ាពេលជំនាន់ ដែលអ៊ំធ្វើការនៅត្រពាំងថ្មគ្រប់គ្រងអីនៅហ្នឹង ឧស្សាហ៍មានប្រតិភូ ឬ ថ្នាក់លើមជ្ឈិមអីចុះមកមើលដែរ? ចែម៖ ចុះមកមើលដែរ មកមើលខ្ញុំជូនទៅ។ ដារ៉ា៖ ចឹងអ៊ំធ្លាប់ជូនថ្នាក់លើពីណាខ្លះ? ចែម៖ ចិនហើយនឹង អ៊ំ ខៀវ សំផន ក៏ធ្លាប់មកដែរ។ ដារ៉ា៖ ដូច នួន ជា ប៉ុល ពត អីធ្លាប់មកដែរ? ចែម៖ តា ប៉ុល ពត មិនសូវទៅទេ ប៉ុនបើអ៊ំ ខៀវ សំផន អាហ្នឹងគាត់ទៅ។ ដារ៉ា៖ (ខៀវ សំផន) ទៅមើលដល់ទំនប់ហ្នឹងផ្ទាល់? ចែម៖ ចាស! ទៅមើលដល់ទំនប់ហ្នឹងផ្ទាល់"]។ ឯកសារ D6.1.1103 សៀវភៅនិពន្ធដោយ ខៀវ សំផន មានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៤ KH 00103875 ["ម្យ៉ាងទៀត ខ្ញុំមិនសូវមានឱកាសចេញដើរក៏ពិតមែននៅឆ្នាំ ១៩៧៥ ដល់ ១៩៧៨ ប៉ុន្តែ ខ្ញុំក៏បានឃើញផ្ទាល់នឹងភ្នែកនូវសមិទ្ធិខ្លះដែលខ្ញុំចង់បានយូរហើយ គឺការដោះស្រាយទឹកជាចាំបាច់សម្រាប់ស្រោចស្រពជនបទយើង ដូចជាអាងត្រពាំងថ្ម (នៅក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ) និងអាងកំពីងពួយ (ខាងលិចបាត់ដំបង) ព្រមទាំងវាលស្រែរាបស្មើជាក្រឡាឈើត្រង់ដាច់កន្ទុយភ្នែក"]។

1413 ឯកសារ D119/131 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ. 102 KH 00996504 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "ចាស! យាយ ចែម ធ្លាប់កោះហៅប្រធានក្រុម និង ប្រធានកងឱ្យចូលរួមប្រជុំ"]។ ឯកសារ D5/314 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ខូយ សារុន ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ KH 00790635 [សាក្សីធ្វើការក្នុងកងនារីនៅត្រពាំងថ្ម៖ "លុះក្រោយមក នាងខ្ញុំបានឃើញអង្គការថ្មី មកពីនិរតី ដែលជាមេធំនៅទំនប់ត្រពាំងថ្ម ធ្លាប់ដើរមើលពួកកងចល័តលើកទំនប់ ហើយនាងខ្ញុំបានឃើញច្បាស់ឈ្មោះយាយ ចែម នេះ នៅពេលធ្វើមិទ្ទីងកងចល័ត"]។

1414 ឯកសារ **D219/361** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.75 KH 01105589 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "គាត់បញ្ជាឱ្យកូនចៅរៀបចំ ហើយគាត់ក៏ធ្លាប់នៅក្នុងកិច្ចប្រជុំនេះដែរ"]។

1415 ឯកសារ D59 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាច គា ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727218 [សាក្សីធ្វើការនៅផ្ទះបាយ នៅត្រពាំងថ្ម៖ "អ៊ឹម ចែម គឺជាអ្នកគ្រប់គ្រងការងារទូទៅនៅទីនោះ [...]។ ខ្ញុំបានចូលរួមប្រជុំពីរដងមែនជាមួយគាត់ មួយដងនៅទំនប់ត្រពាំងថ្ម និង មួយដងទៀតនៅទំនប់កូនខ្លែង ប៉ុន្តែ ខ្ញុំមិនបានឃើញគាត់ទេ ពីព្រោះមានមនុស្សចូលរួមច្រើនណាស់ ប្រហែលរាប់ពាន់នាក់ ហើយខ្ញុំនៅឆ្ងាយណាស់ មិនអាចមើលឃើញគាត់ទេ។ ខ្ញុំដឹងថាគាត់ អ៊ឹម ចែម ពីព្រោះពេលនិយាយពេលសន្និបាត គាត់និយាយថាគាត់ឈ្មោះយាយ ចែម"។ ឯកសារ D219/361 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.75 KH 01105589 [សាក្សីធ្វើជាកម្មករនៅត្រពាំងថ្ម៖ "គឺមានការប្រជុំនៅម៉ោង ៥ ល្ងាច បន្ទាប់ពីធ្វើការហើយ គឺពីរបីថ្ងៃប្រជុំម្ដង"] ឆ.77 KH 01105589 ["ស៖ តើយាយ ចែម ធ្លាប់បាននិយាយក្នុងការប្រជុំទេ? ឆ៖ ចាស! ធ្លាប់ គាត់និយាយពីរឿងប្ដេជ្ញា"]។

1416 ឯកសារ D59 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាច គា ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727218 [សាក្សីធ្វើជាអ្នកដាំបាយនៅត្រពាំងថ្ម៖ "ស៖ តើលោកស្រី មានបានឮគេនិយាយអ្វីផ្សេងទៀតទេអំពីយាយ ចែម? ឆ៖ ខ្ញុំគ្រាន់តែឮគាត់

និយាយថា យើងត្រូវពង្រឹងគោលជំហរ និង ខំប្រឹងធ្វើការឱ្យបានល្អ"]។ ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.76 KH 01105589 [សាក្សីធ្វើជាកម្មករនៅការដ្ឋានទំនប់ត្រពាំងថ្មៈ "សៈ លោកស្រីធ្លាប់ចូលរួមប្រជុំ ដែលដឹកនាំដោយយាយ ចែម ទេ? ឆៈ ចាស! ខ្ញុំធ្លាប់។ ការប្រជុំ គឺនិយាយពីការលើកទំនប់ ធ្វើយ៉ាងម៉េចប្តេជ្ញាឱ្យរួចបីម៉ែត្រគីបក្នុងមួយថ្ងៃ"] ឆ.77 KH 01105589 ["ចាស! ធ្លាប់ គាត់និយាយពីរឿងប្តេជ្ញា"]។

1417 ឯកសារ D59 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច គា ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ KH 00727218 [សាក្សីធ្វើជាកម្មករនៅត្រពាំងថ្មបានបីខែៈ "សំណួរៈ លោកស្រីនិយាយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា អ៊ឹម ចែម បាននិយាយថា "អ្នកទាំងអស់គ្នាត្រូវខិតខំធ្វើការ និង លុបបំបាត់ឱ្យអស់នូវវណ្ណៈមូលធននិយម"។ តើលោកស្រីអាចបញ្ជាក់បានទេ? ឆ្លើយៈ ចាស! មែន គេឱ្យយើងស្រែកអញ្ចឹង ខ្ញុំចេះតែស្រែកតាមគេទៅ"]។

1418 ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.121 KH 00996506 [សាក្សីធ្វើជាកម្មករនៅត្រពាំងថ្មៈ "ពួកឈ្លបបានទទួលបញ្ជាពីថ្នាក់លើ ហើយតាមខ្ញុំយល់ បញ្ជាថ្នាក់លើនោះ គឺចេញមកពីយាយ ចែម"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.131 KH 01049239 [សាក្សីធ្វើការក្នុងកងចល័ត ដែលគេបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨ៈ "សៈ បើយាយ ចែម ជាអ្នកគ្រប់គ្រងស្រុក អ៊ីចឹងគាត់ជាមេរបស់ពួកយោធាទាំងអស់នោះឬ? ឆ.131ៈ ចាស! គាត់ជាមេ"]។ ឯកសារ D119/90 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជួន ភាព ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.12-13 KH 00976141 [សាក្សីជាអ្នកធ្វើការនៅកងចល័តថ្នាក់ស្រុក ត្រូវគេបញ្ជូនទៅត្រពាំងថ្ម ក្នុងពេលកំពុងមានការបោសសម្អាតៈ "ឆ.១២ៈ ពេលដែលខ្ញុំធ្វើការនៅអាងត្រពាំងថ្មដំបូង តាវ៉ាល់ ជាអ្នកគ្រប់គ្រង [...] ឆ.13ៈ ខ្ញុំគិតថា យាយ ចែម គាត់មកពីតំបន់ ហើយគាត់ជាអ្នកគ្រប់គ្រងយោធា។ ខ្ញុំនិយាយដូច្នេះ ពីព្រោះរាល់ពេលដែលយាយ ចែម មកពិនិត្យការដ្ឋាន មានយោធាប្រហែល ៤ឬ៥នាក់ប្រដាប់ដោយអាវុធអមដំណើរ"]។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.29 KH 00976178 [សាក្សីជាប្រធានកងចល័តមានគ្នា ៣០ នាក់ដែលបញ្ជូនទៅធ្វើការនៅត្រពាំងថ្មៈ "ពេលនោះដោយសារកូនក្រុមខ្ញុំស្គមស្គាំង ពួកគេក៏បានរត់ចេញពីការដ្ឋាន។ ពេលនោះពួកឈ្លបដែលជាកូនចៅរបស់យាយ ចែម បានចាប់ពួកគេ"] ឆ.31 KH 00976179 ["ដូច្នេះហើយបានយាយ ចែម បានហៅឱ្យខ្ញុំយកមនុស្សត្រឡប់ទៅអាងត្រពាំងថ្មវិញ"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.87 KH 01049235 [សាក្សីធ្វើការក្នុងកងកុមារនៅត្រពាំងថ្មៈ "ខ្ញុំធ្លាប់ឮគេនិយាយថា យាយ ចែម ជាអ្នកនាំកងទ័ព និង ប្រជាជនឱ្យទៅធ្វើការនៅអាងត្រពាំងថ្ម។ យាយ ចែម ក៏គ្រប់គ្រងទ័ពដែរ"]។

1419 <u>មេកង</u>ៈ ឯកសារ D6.1.450 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH 00279106 [សាក្សីជាប្រធានកងចល័ត បន្តនៅកន្លែងនោះរហូតដល់ដាច់ឆ្នាំ ១៩៧៧ៈ "គេឱ្យមេកងតូច ដូចជាខ្ញុំជាអ្នកមូលដ្ឋានដើរមើល ត្រួតពិនិត្យដោយខ្លួនឯង"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជា

ដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.126 KH 01049239 [សាក្សីធ្វើការក្នុងកងចល័ត ដែលគេបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៦ និង ឆ្នាំ ១៩៧៨៖ "កន្លែងធ្វើការគឺគ្មានអ្នកយាមទេ។ មានតែប្រធានកងប៉ុណ្ណោះដែលចាំមើលយើង ហើយរាយការណ៍ទៅឱ្យយោធា បើសិនមានអ្នកធ្វើខុស គេនឹងបញ្ជាឱ្យទាហ៊ានចាប់"]។ ឯកសារ D6.1.429 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដាន់ ថេវ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267749 [សាក្សីធ្វើការក្នុងកងចល័តនៅត្រពាំងថ្ម៖ "មានអ្នកតាមដាននៅពេលធ្វើការ គឺប្រធានកង"]។

កងឈ្លប៖ ឯកសារ D119/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.116 KH 00996506 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "មានកងឈ្លបប្រហែល ១០ នាក់នៅឈរយាមអ្នកធ្វើការនៅទីនោះ"] ឆ.117 KH 00996506 ["ចាស! អ្នកយាមទាំងនោះ ពួកគេកាន់កាំភ្លើងកាប៊ីន"] ឆ.118 KH 00996506 ["ចាស! កងឈ្លបទាំងនោះ ជាកងឈ្លបថ្នាក់តំបន់ ៥"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.104 KH 00989350 [សាក្សីធ្វើការក្នុងកងចល័តកុមារនៅត្រពាំងថ្ម៖ "តើកងឈ្លបមានយាមអ្នកធ្វើការនៅការដ្ឋានត្រពាំងថ្មឬទេ? ឆ. 104៖ ចាស! យាម"] ឆ.105 KH 00989350 ["ស៖ តើកងឈ្លបមានកាំភ្លើងឬទេ? ឆ.105៖ ចាស! មាន"]។ ឯកសារ D5/1264 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ ឈឹម សំពៀត ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ KH 01037456 [សាក្សីធ្វើការក្នុងកងចល័ត៖ "ពេលធ្វើការ ពួកមេកង ឬឈ្លបវាតែងតែឃ្លាំមើល"]។

យោធា៖ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.127 KH 01049239 [សាក្សីធ្វើការក្នុងកងចល័ត ដែលត្រូវបញ្ជូនទៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៦ និង ឆ្នាំ ១៩៧៨៖ "ស៖ តើមានយោធានៅទីនោះដែរឬទេ? ឆ.127៖ បាទ! មាន។ មានសេនាជនទៀតផង"]។ ឆ.128 KH 01049239 ["ស៖ តើពួកគេមានកាន់កាំភ្លើងទេ? ឆ.128៖ បាទ! មាន"]។ ឯកសារ D6.1.452 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ កៀត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH 00279099 [សាក្សីធ្វើការនៅក្នុងកងចល័តកុមារ ដែលត្រូវបានបញ្ជូនទៅអាងត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "អ្នកបណ្តើរមនុស្សយកទៅនោះជាពួកយោធា [...] មានគ្នាប្រហែល ៤-៥ នាក់ ហើយពួកគេមានកាន់កាំភ្លើងគ្រប់ដៃ"]។

1420 ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.29 KH 00976178 [សាក្សីជាប្រធានកងចល័ត ដែលមានសមាជិក ៣០ នាក់ ត្រូវបានចាត់ឱ្យទៅត្រពាំងថ្ម៖ "ពេលនោះដោយសារកូនក្រុមខ្ញុំស្គមស្គាំង ពួកគេក៏បានរត់ចេញពីការដ្ឋាន។ ពេលនោះពួកឈ្លបដែលជាកូនចៅរបស់យាយ ចែម បានចាប់ពួកគេ។ ក្រោយពីពួកគេទាំងនោះ ត្រូវបានគេសាកសួរថា តើលួចរត់មកពីកងណា ហើយពួកគេបានប្រាប់ថា ពួកគេបានលួចរត់មកពីកងរបស់ខ្ញុំ។ ដូច្នេះហើយបានជាយាយ ចែម បានប្រាប់ទៅតា ពាល់ ហើយតា ពាល់ បានប្រាប់មកខ្ញុំឱ្យទៅទទួលយកកូនក្រុមរបស់ខ្ញុំមកការដ្ឋានវិញ"] ឆ.31 KH 00976179 ["កូនក្រុមរបស់ខ្ញុំជាអ្នកមកពីស្រុកព្រះនេត្រព្រះ ហើយបានលួចរត់ទៅស្រុកព្រះនេត្រព្រះ"]។

1421 ឯកសារ **D119/94** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឆ.31 KH 00976179 [សាក្សីជាប្រធានកងចល័ត មានសមាជិក ៣០ នាក់ ដែលត្រូវបានចាត់តាំងឱ្យទៅត្រពាំងថ្ម៖ "ដូច្នេះ យាយ ចែម បានហៅឱ្យ

ខ្ញុំមកយកមនុស្សត្រឡប់ទៅអាងត្រពាំងថ្មវិញ"] ឆ.32 KH 00976179 ["ដំបូង ខ្ញុំទៅជួបយាយ ចែម នៅផ្ទះរបស់គាត់ ហើយក្រោយមកឈ្លបបាននាំខ្ញុំទៅកាន់មន្ទីរសន្តិសុខនោះ ដែលមានចម្ងាយប្រហែល ១០០ ម៉ែត្រ ពីផ្ទះរបស់គាត់។ ខ្ញុំបានទៅយកកូនក្រុមរបស់ខ្ញុំ នៅមន្ទីរសន្តិសុខភ្នំលៀប"។ ឯកសារ **D5/1057** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ យូ សារី ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣ KH 00993138-00993139 [សាក្សីធ្វើការក្នុងកងចល័ត៖ "ក្នុងឆ្នាំ ១៩៧៨ នាងខ្ញុំត្រូវអង្គការ ប៉ុល ពត បង្ខំឲ្យទៅលើកទំនប់នៅអាងត្រពាំងថ្ម [...] នៅពេលនោះមិត្ត ចែម គណៈតំបន់គាត់ដើរត្រួតមានឈ្លបយោធាផង មានពួកមេសហករណ៍ មកងចល័តផង"]។

1422 ឯកសារ **D119/132** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យ៉េង ឆាន ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.80 KH 00997307 [សាក្សីជាកម្មករនៅត្រពាំងថ្ម នៅពេលកម្មាភិបាលភូមិភាគនិរតីមកដល់៖ "មានមនុស្សច្រើនណាស់នៅធ្វើការនៅទំនប់ត្រពាំងថ្មនោះ គឺប្រហែលរាប់ពាន់នាក់"]។ ឯកសារ **D119/131** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចង ធឿយ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៤ ឆ.98 KH 00996503-00996504 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "ខ្ញុំគ្រាន់តែសម្គាល់ឃើញថានៅទីនោះ នៅពេលថ្ងៃ អ្នកធ្វើការមានគ្នាប្រហែល ៥០០ ទៅ ៦០០ នាក់ ហើយជួនកាលរហូតដល់រាប់ពាន់នាក់ ហើយពេលយប់ អ្នកធ្វើការមានគ្នាប្រហែលរាប់រយនាក់"]។ ឯកសារ **D119/47** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លីម ហុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.9 KH 00933093 [សាក្សីជាកម្មករក្នុងកងចល័ត ដែលត្រូវគេបញ្ជូនទៅកាន់ត្រពាំងថ្ម៖ "កងចល័តស្រុកថ្មពួកមានប្រហែលជិត ១០០០ នាក់ ក្នុងនោះមានកងបុរស កងនារី និង កងកុមារ"]។ ឯកសារ **D219/361** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី លើយ គើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.50 KH 01105587 [សាក្សីជាកម្មករនៅការដ្ឋានត្រពាំងថ្ម៖ "មានមនុស្សរាប់ពាន់នាក់"]។

1423 ឯកសារ **D6.1.992** សេចក្ដីរាយការណ៍អំពីដំណើរទស្សនៈកិច្ចរបស់លោក Chen Yung-Kuei មកកាន់ប្រទេសកម្ពុជា ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 00659260 [សេចក្ដីរាយការណ៍ព័ត៌មានពិស្ដារអំពីដំណើរទស្សនកិច្ចរបស់ឧបនាយករដ្ឋមន្ត្រីចិនទៅកាន់ការដ្ឋានត្រពាំងថ្ម៖ "[លេខាតំបន់ពាយ័ព្យឈ្មោះ រស់ ញឹម] និយាយថា 'គ្រោះរាំងស្ងួតបានកើតឡើង នៅពេលយើងចាប់ផ្ដើមសាងសង់អាងស្ដុកទឹក ដោយមានប្រជាជនចំនួន ២០,០០០ នាក់បានចូលរួមសាងសង់។ ពួកគេមិនមានទឹកហូបគ្រប់គ្រាន់ឡើយ' នរណាក៏កោតសរសើរដែរ អំពីជំហរបដិវត្តដ៏ក្លៀវក្លារបស់ប្រជាជនក្នុងការកសាងប្រទេស និង សមិទ្ធិផលដ៏អស្ចារ្យ ដែលបានសម្រេចបានក្នុងរយៈពេលតែពីរឆ្នាំប៉ុណ្ណោះក្រោយសង្គ្រាម"]។ ឯកសារ D6.1.448 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តាន់ ហុច ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ KH 00279127 [សាក្សីបានធ្វើការក្នុងកងចល័តកុមារនៅត្រពាំងថ្ម៖ "សៈ តើមានមនុស្សប៉ុន្មាននាក់បានចូលរួមក្នុងការលើកទំនប់ត្រពាំងថ្ម? ឆ៖ ខ្ញុំឃើញមនុស្សរាប់ម៉ឺននាក់ចូលរួមលើកទំនប់ត្រពាំងថ្ម មើលទៅឃើញតែក្បាលមនុស្ស"]។ ឯកសារ D6.1.449 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដាន់ ស ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ KH 00279083 [សាក្សីធ្វើការនៅក្នុងកងចល័តនៅកន្លែងត្រពាំងថ្ម៖ "មានមនុស្សច្រើនណាស់បានចូលរួមលើកទំនប់ គឺមានរាប់ម៉ឺននាក់"]។ ឯកសារ D6.1.343 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យី ឡៃស្រូវ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៨ KH 00279133 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "មានមនុស្សច្រើនណាស់ រាប់សែននាក់ ដូចស្រមោច"]។ ឯកសារ D6.1.427 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH

00267760 [សាក្សីជាមេកងចល័តនៅទំនប់ត្រពាំងថ្ម៖ "មានមនុស្សរាប់ម៉ឺននាក់ចូលរួម ច្រើនដូចស្រមោច"]។ ឯកសារ D6.1.766 យុវជន និង យុវនារីបដិវត្ត លេខ ៧-៨ ខែ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH 00376344-00376345 [រៀបរាប់លម្អិតអំពីការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ នៅការដ្ឋាន៖ "កម្លាំងក៏មានច្រើនរាប់ម៉ឺននាក់យ៉ាងនេះ នៅការដ្ឋានត្រពាំងថ្ម"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.156 KH 01049242 [សាក្សីធ្វើការនៅក្នុងកងចល័ត ដែលត្រូវបញ្ជូនទៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៦ និង ១៩៧៨៖ "មនុស្សមនុស្សរាប់ម៉ឺននាក់"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៧៖ "មនុស្សចូលរួមលើទំនប់មានចំនួនមួយម៉ឺនប្រាំពាន់នាក់ ព្រោះមានការប្រជុំសន្និបាត ដោយប្រកាសប្រាប់ថា កម្លាំងសរុបលើកទំនប់ មានចំនួន ១៥,000 នាក់។ តាញ៉ឹមជាអ្នកប្រកាសនៅពេលសន្និបាតបើកការដ្ឋាននោះ"]។

1424 ឯកសារ **D119/130** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.79 KH 00989347 [សាក្សីធ្វើការក្នុងកងចល័តកុមារនៅត្រពាំងថ្ម៖ "ខ្ញុំមិនអាចស្មានបានទេ ដោយសារមានមនុស្សច្រើនណាស់"]។ ឯកសារ **D119/120** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឆ.121 KH 00984319 [សាក្សីជាកម្មករនៅត្រពាំងថ្ម នៅពេលកម្មាភិបាលភូមិភាគនិរតី៖ "ខ្ញុំមិនដឹងថាមានប៉ុន្មានទេ ពីប្រជាជននៅក្នុងស្រុកភ្នំស្រុកទាំងមូលមកធ្វើការនៅក្នុងកងនោះទាំងអស់"]។ ឯកសារ **D219/474** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ចាន់រីន ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឆ. 24 KH 01134122 [សាក្សីធ្វើការនៅកងចល័តស្រុកនៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៨៖ "ចំពោះអ្នកស្លាប់នៅអាងត្រពាំងថ្ម ខ្ញុំមិនអាចប៉ាន់ស្មានបានទេ ដោយសារថាពេលនោះ មនុស្សច្រើនណាស់បានទៅធ្វើការនៅទីនោះ ហើយខ្ញុំមិនដឹងថាគេមកពីណាខ្លះទេ"]។

1425 ឯកសារ D6.1.452 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ កឿត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH 00279099 [សាក្សីធ្វើការក្នុងកងចល័តកុមារ គេបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "ខ្ញុំឃើញគេចងបណ្តើរ មានទាំងនារី យុវជននៅក្នុងកងចល័ត តែខ្ញុំមិនដឹងនៅក្នុងកងចល័តណាទេ។ ការចាប់មនុស្សបណ្តើរនេះ ខ្ញុំឃើញរាល់ថ្ងៃ រាល់ល្ងាច"]។ ឯកសារ D6.1.347 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីវ ម៉ៅ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH 00279094 [សាក្សីធ្វើការនៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៨៖ "មនុស្សចូលរួមលើកទំនប់ត្រពាំងថ្មមានចំនួនច្រើនណាស់ មានទាំងចាស់ទាំងក្មេង"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.96 KH 00989349 [សាក្សីធ្វើការនៅក្នុងកងចល័តកុមារនៅត្រពាំងថ្ម៖ "នារីៗគេបង្ខំឱ្យធ្វើការឱ្យរួចតាមផែនការកំណត់ ប្រសិនបើធ្វើមិនហើយតាមផែនការ គេមិនឱ្យបានហូបទេ"]។ D119/47 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ហុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.9 KH 00933093 [សាក្សីជាអ្នកធ្វើការក្នុងកងចល័ត ដែលគេបញ្ជូនទៅត្រពាំងថ្ម៖ "មានកងបុរស កងនារី និង កងកុមារ"]។ ឯកសារ D6.1.450 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH 00279106 [សាក្សីធ្វើជាប្រធានកងចល័តនៅតំបន់ ៥៖ "ភាគច្រើនជាមនុស្សវ័យកណ្តាល"] KH 00279106 ["គេឱ្យកងចល័តដាំបាយរួម តែបុរស និងស្ត្រីរស់នៅដាច់ពីគ្នា"]។ សូមមើលផងដែរ

ឯកសារ D6.1.429 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដាន់ ថេវ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267749 [សាក្សីធ្វើការក្នុងកងចល័តនៅត្រពាំងថ្ម៖ "អ្នកចូលរួមលើកទំនប់ មានវ័យកណ្ដាល យុវជន យុវនារី"]។ ឯកសារ D6.1.427 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267761 [សាក្សីជាមេកងចល័តនៅទំនប់ត្រពាំងថ្ម៖ "នៅក្នុងកងខ្ញុំមានទាំងប្រុស មានទាំងស្រី"]។

1426 ឯកសារ D6.1.766 យុវជន និង យុវនារីបដិវត្ត លេខ ៧-៨ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH 00376344 [រៀបរាប់លម្អិតអំពីការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ នៅការដ្ឋាន៖ "ក្នុងរយៈពេលវាយសម្រុកធ្វើប្រព័ន្ធសំណង់ចាត់ចែងទឹកត្រពាំងថ្មកន្លងមកនេះ យុវជន យុវនារីសហករណ៍យើងនៅតំបន់បាត់ដំបងខាងជើង បានយកអស់កម្លាំងចិត្ត កម្លាំងកាយរបស់ខ្លួន នឹងបានលះបង់នូវអ្វីៗទាំងអស់ ដើម្បីបម្រើផលប្រយោជន៍រួមរបស់សមូហភាព និង សម្រេចផែនការរបស់បក្ស ឲ្យបានជោគជ័យទាំងស្រុង"]។ ឯកសារ D6.1.347 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គីវ ម៉ៅ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH 00279094 [ធ្វើការនៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៨៖ "ខ្ញុំចូលរួមសង់ទំនប់ត្រពាំងថ្ម ពេលនោះខ្ញុំអាយុប្រហែល ១៤ ឬ ១៥ ឆ្នាំ"]។ ឯកសារ D6.1.450 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ KH 00279106 [សាក្សីធ្វើជាប្រធានកងចល័ត គាត់នៅកន្លែងនោះរហូតដល់ដាច់ឆ្នាំ ១៩៧៧៖ "ភាគច្រើនជាមនុស្សវ័យកណ្ដាល"] សូមមើលផងដែរ ឯកសារ D219/37 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួន មុត ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.71 KH 01032109 [សាសាក្សីគេបញ្ជូនពីភូមិភាគនិរតីទៅស្រុកស៊ីសុផុន ក្នុងពេលបោសសម្អាត៖ "ខ្ញុំគ្រាន់តែដឹងថាប្រជាជនក្មេងៗជាច្រើនត្រូវបានគេកេណ្ឌឲ្យទៅធ្វើអាងទឹកត្រពាំងថ្ម"]។ ឯកសារ D6.1.427 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267761 [សាក្សីជាមេកងចល័តនៅទំនប់ត្រពាំងថ្ម៖ "ក្រៅពីកងមនុស្សវ័យកណ្ដាល មានកងយុវជន និង យុវនារី ក៏បានចូលរួមសង់ទំនប់ត្រពាំងថ្មដែរ"]។ ឯកសារ D6.1.431 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សាក្សីជាកម្មករ និងក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម គាត់ធ្វើការនៅកន្លែងនោះ ពេលពួកកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រង៖ "ភាគច្រើនជាយុវជន និង យុវនារី"]។ ឯកសារ D6.1.425 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គន់ ថាន ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267782 [ទាហានក្នុងកងការពាររបស់ តាវ៉ាល់ រហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៧៖ "អ្នកចូលរួមលើកទំនប់ភាគច្រើនមកពីកងចល័ត មានយុវជន និង យុវនារីអាយុចាប់ពី ១៨ ឆ្នាំ"]។

1427 ឯកសារ **D6.1.452** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ៃ កឿត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH 00279100 [សាក្សីធ្វើការនៅក្នុងកងចល័តកុមារ ដែលត្រូវបានបញ្ជូនទៅអាងត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "កុមារជាច្រើនស្លាប់ក្នុងកងកុមារ [នៅទំនប់ត្រពាំងថ្ម] [...] ក្នុងក្រុមខ្ញុំមានកុមារអ្នកមូលដ្ឋានប្រាំនាក់ និង កុមារមកពីភ្នំពេញប្រាំនាក់"]។ ឯកសារ **D119/47** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លីម ហុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.9 KH 00933093 [សាក្សីជាអ្នកធ្វើការក្នុងកងចល័ត ដែលគេបញ្ជូនទៅត្រពាំងថ្ម៖ "មានកងបុរស កងនារី និង កងកុមារ"]។ ឯកសារ **D119/130** កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.75 KH 00989347 [សាក្សីធ្វើការក្នុងកងកុមារនៅត្រពាំងថ្ម៖ "ស៖ តើអ្នកធ្វើការនៅកងកុមាមែនឬទេ ?ឆ.75៖ បាទនៅកងធ្វើខ្ញុំ ! កុមារ"]។ ឯកសារ **D119/42** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គ្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.2 KH

00915871 [សាក្សីចូលក្នុងកម្លាំងកងចល័តកុមារ៖ "ហើយពេលនោះ គេបានឲ្យខ្ញុំចូលកងកុមារ ដែលមានគ្នា ១០ នាក់"]។ សូមមើលផងដែរ ឯកសារ **D6.1.448** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ ហុច ថ្ងៃទី ២៩ ខែ មករា២០០៩ឆ្នាំ KH 00279128 [សាក្សីធ្វើការក្នុងកងចល័តកុមារនៅត្រពាំងថ្ម៖ "កងខ្ញុំជាកងកុមារ ដូច្នេះមិនមានអ្នកឈឺធ្ងន់ ឬ ឈឺដល់ស្លាប់ទេ"]។ ឯកសារ **D6.1.449** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដាន់ ស ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ KH 00279085 [សាក្សីធ្វើការក្នុងកងចល័តនៅត្រពាំងថ្ម៖ "នៅការដ្ឋានលើកទំនប់គ្មានសាលារៀនទេ ហើយក្មេងតូចៗគេឲ្យរែកដី"]។ *ផ្ទុយនឹង* ឯកសារ **D6.1.450** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH 00279106 [ប្រធានកងចល័ត បន្តនៅកន្លែងនោះរហូតដល់ដាច់ឆ្នាំ ១៩៧៧៖ "ភាគច្រើនជាមនុស្សវ័យកណ្តាល យុវជន និងនារី តែមិនមានកុមារទេ"]។

1428 ឯកសារ D123/1/5.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹម ចែម ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៧ KH 00929729-00929730 ["ដារ៉ា៖ ហើយចុះអ្នកណា ដូចថាមនុស្សម្នាអីយកពីខាងណាមកកសាងទំនប់ហ្នឹង អ៊ំដឹងទេ? ចែម៖ មនុស្សយកពីស្រុកស្វាយស៊ីផុន ស្រុកថ្មពួក (ស្រុក)ភ្នំស្រុក (ស្រុក) ព្រះនេត្រព្រះ"]។ ឯកសារ D6.1.450 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH 00279105 [សាក្សីជាប្រធានកងចល័ត បន្តនៅកន្លែងនោះរហូតដល់ដាច់ឆ្នាំ ១៩៧៧៖ "អ្នកទាំងនោះមកពីប្រាំស្រុកគឺ ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ស្រុកសេរីសោភ័ណ្ឌ ស្រុកស្វាយចេក និងស្រុកថ្មពួក។ ស្រុកទាំងប្រាំនេះស្ថិតនៅក្នុងនៅតំបន់ប្រាំ ភូមិភាគពាយ័ព្យ"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ឆ.85 KH 00953031 [សាក្សីដឹកនាំកម្លាំងកងចល័តនៅត្រពាំងថ្ម៖ "គាត់ [តាជៀល] បានចាត់តាំងឲ្យខ្ញុំរៀបចំកម្លាំង ដើម្បីធ្វើការនៅក្នុងកងចល័តតំបន់ [...] ក្នុងកងចល័តតំបន់នេះ មានកម្លាំងចេញពីស្រុកព្រះនេត្រព្រះ ស្រុកស្វាយស៊ីសុផុន ស្រុកថ្មពួក និង ស្រុកភ្នំស្រុក"]។ ឯកសារ D119/120 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ ឆ.122 KH 00984319 [ធ្វើការនៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៧ ក្នុងពេលបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ៖ "បាទ មាន។ គេបែងចែកឲ្យប្រជាជនរស់នៅផ្សេងៗពីគ្នា ដូចជាប្រជាជននៅក្នុងស្រុកព្រះនេត្រព្រះ ប្រជាជននៅស្រុកថ្មពួកស្នាក់នៅកន្លែងមួយផ្សេង ហើយប្រជាជនមកពីស្រុកភ្នំស្រុក ស្នាក់នៅកន្លែងមួយផ្សេងទៀត"]។ សូមមើលផងដែរ ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សារសាក្សីធ្វើជាកម្មករ និង ក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម គាត់ធ្វើការនៅកន្លែងនោះនៅពេលកម្មាភិបាលនិរតីគ្រប់គ្រង៖ "គឺតំបន់ ៥ ទាំងមូល បូកជាមួយនឹងប្រជាជនតាមសហករណ៍ [...] តំបន់ ៥ មានស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក ស្រុកស្វាយចេក ស្រុកថ្មពួក"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "ប្រជាជនមកពីតំបន់ ៥ មាន ៤ ស្រុក គឺ ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ស្រុកសេរីសោភ័ណ្ឌ និង ស្រុកថ្មពួក"]។ ឯកសារ D6.1.427 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិវ ពៅ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267760 [សាក្សីជាមេកងចល័តនៅទំនប់ត្រពាំងថ្ម៖ "មានមនុស្សរាប់ម៉ឺននាក់ចូលរួម ច្រើនដូចស្រមោច។ ប្រជាជនទាំងនោះមកពីតំបន់ ៥ ភូមិភាគពាយ័ព្យ"]។ ឯកសារ D1.3.27.10 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមចំណងជើង "ខេត្តបន្ទាយមានជ័យ" ដោយមានឯកសារភ្ជាប់

ក្រោមចំណងជើង "ទម្រង់ទីតាំង" ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៨ EN 00769752 [កិច្ចសម្ភាសន៍ជាមួយ ឈុំ រួម កសិករនៅក្បែរត្រពាំងថ្ម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ "រួម៖ គេឲ្យការដ្ឋានធំធ្វើអាង បិទអាង អាងទឹកហ្នឹងណា។ អីចឹងពលករម៉ោមិនមែនទីនេះទេ ម៉ោពីស្រុកសេរីសោភ័ណ្ឌ ស្រុកព្រះនេត្រព្រះ និយាយរួមនៅក្នុងតំបន់ ៥។ ពាក្យថា"តំបន់ ៥"យកមកបញ្ចូលទាំងអស់"]។

1429 ឯកសារ D6.1.450 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ផាន់ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ KH 00279104 [សាក្សីជាប្រធានកងចល័ត បន្តនៅកន្លែងនោះរហូតដល់ដាច់ឆ្នាំ ១៩៧៧៖ "អ្នកកងខ្ញុំខ្លះជាអ្នកមូលដ្ឋាន ក្រៅពីនេះ ភាគច្រើនសុទ្ធតែប្រជាជនថ្មីមកពីភ្នំពេញ"]។ ឯកសារ D6.1.452 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ គឿត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH 00279100 [សាក្សីធ្វើការនៅក្នុងកងចល័តកុមារ ដែលត្រូវបានបញ្ជូនទៅអាងត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "កុមារជាច្រើនស្លាប់ក្នុងកងកុមារ ប៉ុន្តែអត់ចាំឈ្មោះទេ ដោយសារពួកគេមកពីភ្នំពេញ។ ក្នុងក្រុមខ្ញុំមានកុមារអ្នកមូលដ្ឋានប្រាំនាក់ និង កុមារមកពីភ្នំពេញប្រាំនាក់"]។ ឯកសារ D6.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម លាង ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០៩ KH 00279110 [សាក្សីជាកម្មករនៅក្នុងកងកុមារនៅត្រពាំងថ្ម៖ "[សមាជិកក្នុងកងចល័តរបស់សាក្សី] ជាប្រជាជនថ្មីមកពីភ្នំពេញ"]។

1430 ឯកសារ D6.1.452 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ៃ គឿត ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៩ KH 00279099 [សាក្សីធ្វើការនៅក្នុងកងចល័តកុមារ ដែលត្រូវបានបញ្ជូនទៅអាងត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "សង់ទំនប់ មនុស្សគេចែកជាពីរក្រុម ក្នុងក្រុមខ្ញុំមានគ្នាដប់នាក់"]។ ឯកសារ D119/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ហួន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៤ ឆ.77 KH 00989347 [សាក្សីធ្វើការក្នុងកងចល័តកុមារនៅត្រពាំងថ្ម៖ "ស៖ តើកងកុមាររបស់លោកស្រី ដែលត្រូវបញ្ជូនទៅធ្វើការនៅទំនប់ត្រពាំងថ្ម មានចំនួនប៉ុន្មាននាក់? ឆ.77៖ មានគ្នា ១០ នាក់"]។ ឯកសារ D119/42 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រិត រិត ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.2 KH 00915871 [សាក្សីធ្វើការក្នុងកងកុមារ ត្រូវគេបញ្ជូនទៅត្រពាំងថ្ម ក្រោយពី តាវ៉ាល់ បាត់ខ្លួន៖ "ហើយនៅពេលនោះ គេឲ្យខ្ញុំចូលក្នុងកងកុមារដែលមានគ្នា ១០ នាក់"]។ សូមមើលផងដែរ ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សាក្សីជាកម្មករ និងក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម គាត់ធ្វើការនៅកន្លែងនោះ ពេលពួកកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រង៖ "កម្មករគេចែកចេញជាក្រុម និង កង ក្នុងមួយកងមានគ្នា ១០ នាក់"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ផុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៧៖ "ការលើកទំនប់នោះ គឺគេចែកជាក្រុម ជាកង ដោយមួយក្រុមមានគ្នា១០នាក់"]។ ឯកសារ D6.1.448 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តាន់ ហុច ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៩ KH 00279127 [សាក្សីធ្វើការក្នុងកងចល័តកុមារនៅត្រពាំងថ្ម៖ "ក្រុមខ្ញុំមានគ្នា ១០ នាក់"]។ ឯកសារ D6.1.426 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267765 [សាក្សីធ្វើការក្នុងកងចល័ត តាវ៉ាល់ កាលនៅសង់ទំនប់ត្រពាំងថ្ម៖ "ការងារលើកទំនប់ គឺប្រើកម្លាំងមនុស្សសុទ្ធ ដោយបែងចែកជាក្រុមមានគ្នា ១០ នាក់"]។ ឯកសារ D6.1.359 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង អ៊ួ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៩ KH 00295936 [សាក្សីធ្វើជាកម្មករនៅត្រពាំងថ្មរហូតដល់ឆ្នាំ ១៩៧៩៖ "នៅក្នុងមួយក្រុមមានគ្នា ១០ នាក់"]។ ឯកសារ

D219/39 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថូយ ថៀម ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឆ.13 KH 01032123 [សាក្សីធ្វើការក្នុងកងចល័ត៖ "ក្នុងក្រុមរបស់ខ្ញុំមានគ្នា ១០ នាក់ ហើយនៅក្រោមការគ្រប់គ្រងរបស់ ជីន"]។

1431 ឯកសារ D119/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាយ ផាន ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.8 KH 00915860 [ប្រធានក្រុមដែលមានសមាជិក ៣០ នាក់ នៅត្រពាំងថ្ម៖ "ប៉ុន្តែ ក្រោយមក ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានក្រុម ដែលមានសមាជិក ៣០ នាក់នៅការដ្ឋានទំនប់ត្រពាំងថ្ម"] ឆ.20 KH 00915862 ["មួយកងតូចមាន ៣០ នាក់"]។ សូមមើលផងដែរ ឯកសារ D6.1.426 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267765 [សាក្សីធ្វើការក្នុងកងចល័ត តាវ៉ាល់ កាលនៅសង់ទំនប់ត្រពាំងថ្ម៖ "ការងារលើកទំនប់ គឺប្រើកម្លាំងមនុស្សសុទ្ធ ដោយបែងចែកជាក្រុម [...] កងតូចមានគ្នា ៣០ នាក់"]។ ឯកសារ D6.1.359 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង អ៊ួ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៩ KH 00295936 [សាក្សីធ្វើជាកម្មករនៅត្រពាំងថ្មរហូតដល់ឆ្នាំ ១៩៧៩៖ "មួយកងតូចមានគ្នាសាបសិបនាក់"]។ ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សាក្សីជាកម្មករ និងក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម គាត់ធ្វើការនៅកន្លែងនោះ ពេលពួកកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រង៖ "មួយកងតូចមានគ្នា ៣០ នាក់"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "ការលើកទំនប់នេះ គឺគេចែកជា [...] មួយកងតូចមានគ្នា ៣០ នាក់"]។

1432 ឯកសារ D119/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាយ ផាន ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.20 KH 00915862 [ប្រធានក្រុម ៣០ នាក់ នៅត្រពាំងថ្ម៖ "កងធំមួយៗមានគ្នា ១០០ នាក់"]។ ឯកសារ D6.1.431 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៀប ឈាន ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267744 [សាក្សីជាកម្មករ និងក្រោយមកក្លាយជាប្រធានកងនៅត្រពាំងថ្ម គាត់ធ្វើការនៅកន្លែងនោះ ពេលពួកកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រង៖ "ការធំមួយៗមានកងតូចបី"]។ ឯកសារ D6.1.430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាន ថុល ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267754 [អនុប្រធានកងតូចនៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៧៖ "កងធំមានបីកងតូច"]។ ឯកសារ D6.1.359 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង អ៊ួ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៩ KH 00295936 [សាក្សីធ្វើជាកម្មករនៅត្រពាំងថ្មរហូតដល់ឆ្នាំ ១៩៧៩៖ "កងធំមានប្រាំមួយកងតូច"]។ ឯកសារ D6.1.428 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈិត អ៊ិន ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267738 [ប្រធានកងនៅត្រពាំងថ្ម៖ "នៅពេលនោះ ខ្ញុំបានឡើងជាប្រធានកង ទទួលខុសត្រូវសមាជិក ១២០ នាក់ ភាគច្រើនជាអ្នក ១៧ មេសា មកពីភ្នំពេញ"]។ ឯកសារ D6.1.426 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267765 [សាក្សីធ្វើការក្នុងកងចល័ត តាវ៉ាល់ កាលនៅសង់ទំនប់ត្រពាំងថ្ម៖ "ការងារលើកទំនប់ គឺប្រើកម្លាំងមនុស្សសុទ្ធ ដោយបែងចែកជា [...] កងធំមានគ្នា ១៥០ នាក់"]។

1433 ឯកសារ D6.1.766 យុវជន និង យុវនារីបដិវត្ត លេខ ៧-៨ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH 00376344 [រៀបរាប់លម្អិតអំពីការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ នៅការដ្ឋាន៖ "សរុបទាំងអស់ ទំនប់អាងត្រពាំងថ្មនេះ [...] បាតក្រោមពី ៤០ ទៅ ៧០ ម៉ែត្រ [...] នៅរដូវប្រាំងឆ្នាំក្រោយៗ បងប្អូននឹងបន្តពង្រីង ពង្រីកវាឲ្យកាន់តែធំ និង កាន់តែរឹងមាំថែមទៀត [...] ដោយ

លើកទំនប់បាតក្រោម ១២០ ម៉ែត្រ និង ខ្នងលើ ២៥ ម៉ែត្រ"]។ ឯកសារ D6.1.992 សេចក្តីរាយការណ៍អំពីដំណើរទស្សនៈកិច្ចរបស់លោក Chen Yung-Kuei មកកាន់ប្រទេសកម្ពុជា ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 00659260 [សេចក្តីរាយការណ៍ព័ត៌មានពិស្តារអំពីដំណើរទស្សនកិច្ចរបស់ឧបនាយករដ្ឋមន្ត្រីចិន ទៅកាន់ការដ្ឋានត្រពាំងថ្ម៖ "សមមិត្ត វស់ ញឹម អនុប្រធានទី ២ នៃគណប្រធានរដ្ឋនៃរដ្ឋកម្ពុជាប្រជាធិបតេយ្យ និង ជាលេខាគណៈកម្មាធិការភូមិភាគពាយ័ព្យនៃបក្សកុម្មុនីស្តកម្ពុជា និង ជាប្រធានគណៈកម្មាធិការបម្រើប្រជាជនដែលមានសមាជិក ៧ រូបនៃភូមិភាគពាយ័ព្យ មានប្រសាសន៍ថា អាងស្តុកទឹក [ត្រពាំងថ្ម] ត្រូវកសាងក្នុងឆ្នាំនេះ ដោយប្រជាជនក្នុងតំបន់ ៥ នៃ ភូមិភាគពាយ័ព្យ ដោយប្រើរយៈពេល តិចជាង ២ ខែ ជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់គណៈកម្មាធិការមជ្ឈិមបក្ស ដើម្បីកសាងស្តុកទឹកដ៏ធំមួយ។ ឆ្នាំនេះអាងស្តុកទឹកនេះ អាចស្តុកទប់ទឹកបាន ១៥០ លានម៉ែត្រគីប។ ក្រោយមកប្រឡាយចំនួន ៣ បានជីកក្នុងពេលមួយសប្តាហ៍ ដើម្បីតភ្ជាប់អាងស្តុកដែលអាចស្រោចស្រពស្រែបានជាង ៧,០០០ ហិចតា។ ពេលនេះ អាងស្តុកទឹកកំពុងត្រូវបានពង្រីកបន្ថែម។ បួនឆ្នាំក្រោយ អាងនេះអាចស្តុកទឹកបាន ៣០០ លានម៉ែត្រ គីប"]។ ឯកសារ D6.1.742 ទង់បដិវត្តលេខ ៤ មេសា ខែ មេសា ឆ្នាំ ១៩៧៨ KH 00064727 ["ពួកក្រុមកាសែតយូហ្គោស្លាវី មកមើលអាងទឹកនៅខាងបាត់ដំបង ហៅថាត្រពាំងថ្ម នៅភ្នំស្រុក មើលទៅ វាមិនឃើញត្រើយ គាត់ថា គាត់ទើបមកពីកំពង់សោម ឃើញសមុទ្រនៅកំពង់សោម ដល់មកមើលអាងទឹកនៅភ្នំស្រុក ខាងបាត់ដំបង គាត់ថា មានសមុទ្រមួយទៀតនៅកន្លែងនេះ។ ការចាប់អារម្មណ៍សមុទ្រមួយទៀត បានសេចក្តីថា អាងទឹកហ្នឹងវាធំ។ ធំល្វឹងល្វើយ មើលដាច់កន្ទុយភ្នែកសុទ្ធតែទឹក គឺជិត ២០០ លានម៉ែត្រគ្រីគុណ។ យើងធ្វើតែមួយឆ្នាំ"]។ ឯកសារ D119/14 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ កាន់ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឆ.26-27 KH 00893271 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "ខ្ញុំបានទៅធ្វើការនៅទីនោះ ប្រហែលជានៅចន្លោះខែ កុម្ភៈ និង ខែ សីហា ឆ្នាំ ១៩៧៨។ ស៖ តើលោកជួយនឹកឡើងវិញមើល៍ [...] ពីព្រោះអាងត្រពាំងថ្ម គេបានធ្វើហើយនៅពាក់កណ្តាលឆ្នាំ ១៩៧៧ ហេតុអ្វីបានជាលោកនិយាយថា លោកបានទៅធ្វើការនៅទីនោះ ចន្លោះខែ កុម្ភៈ និង ខែ មេសា ឆ្នាំ ១៩៧៨ ទៅវិញ? ឆ.27៖ ទោះបីជាទំនប់ត្រពាំងថ្មនោះ បានធ្វើហើយនៅពាក់កណ្តាលឆ្នាំ ១៩៧៧ ក៏ដោយ ប៉ុន្តែតាមពិតតាមខ្ញុំបានឃើញ គឺវាមិនទាន់ធ្វើហើយចប់ពេញលេញនៅឡើយ"]។ ឯកសារ D6.1.357 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េង ប៊ុនថារ៉ា ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ KH 00295965 [សាក្សីជាប្រធានក្រុមកងចល័តនៅត្រពាំងថ្ម៖ "ប្រហែលជានៅឆ្នាំ ១៩៧៧ ឬក៏ឆ្នាំ ១៩៧៨ គឺនៅពេលដែលទំនប់បានបញ្ចប់"]។ ឯកសារ D119/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធឹង ជឿន ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ឆ.25 KH 01024774 [សាក្សីជាប្រធានកងចល័ត៖ "ប្រហែលក្នុងខែ មករា ឬ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានកងចល័តសហករណ៍សំរោង និង ទៅធ្វើការដើម្បីពង្រឹងអាងត្រពាំងថ្ម ដូចជាត្រូវបិទរន្ធខ្លះដែលមានទឹកហូរបាក់ទំនប់"]។ ឯកសារ D219/361 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.38 KH 01105585 [សាក្សីធ្វើការនៅទីតាំងអាងត្រពាំងថ្ម៖ "គេបញ្ជូនខ្ញុំឱ្យទៅលើកទំនប់ត្រពាំងថ្ម រហូតដល់ដាច់របបខ្មែរក្រហម"]។ ឯកសារ D119/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន ឈួង ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ឆ.4 KH 00895158 [សាក្សីជាអនុប្រធានកងចល័ត តាហ៊ីង តំបន់ ៥ នៅអាងត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៧៖ "ប្រហែលក្នុងខែ កក្កដា ឬ ខែ សីហា ឆ្នាំ ១៩៧៧ ពួកបស្ចិមបានមកដល់តំបន់នេះ។ បីខែក្រោយមក ទើបពួកនិរតីមកដល់។ នៅពេលនោះការងារនៅការដ្ឋានទំនប់ត្រពាំងថ្មមិនទាន់ចប់ឡើយ"]។ ឆ.14 KH

00895161 ["តាមពិតទំនប់សឹងតែចប់សព្វគ្រប់ហើយ តែមិនទាន់ត្រូវបានសម្ភោធជាផ្លូវការនៅឡើយទេ ព្រោះនៅពេលវៀតណាមចូលមកក្នុងឆ្នាំ ១៩៧៩ យើងត្រូវរត់គេចខ្លួន"]។ ឯកសារ D119/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុត ស៊ើយ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ KH 00894519 [សាក្សីជាប្រធានកងតូចកងចល័តតំបន់៖ "កាលខ្ញុំធ្វើការនៅអាងត្រពាំងថ្ម នៅដើមឆ្នាំ ១៩៧៨"]។ ឯកសារ D119/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភោគ គុយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៣ ឆ.3 KH 00894512 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "ពេលវៀតណាមចូលមក ទំនប់នោះមិនទាន់ហើយនៅឡើយទេ"]។ ឯកសារ D119/47 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ហុង ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ឆ.7 KH 00933093 [សាក្សីជាកម្មករនៅកងចល័ត ដែលគេបញ្ជូនទៅត្រពាំងថ្ម៖ "ខ្ញុំធ្វើការនៅកងចល័តត្រពាំងថ្មរហូតដល់ទំនប់ត្រូវបានបញ្ចប់ ដែលជិតចុងនៃរបបខ្មែរក្រហម"]។ ឯកសារ D118/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជឹម ចាន់ធឿន ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឆ.28 KH 00920186 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "ខ្ញុំសង់ទំនប់ត្រពាំងថ្មក្នុងឆ្នាំ ១៩៧៨"]។ ឯកសារ D6.1.426 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីវ សាលាង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ KH 00267764 [សាក្សីធ្វើការក្នុងកងចល័ត តាវ៉ាល់ សង់ទំនប់ត្រពាំងថ្ម៖ "ទំនប់ត្រពាំងថ្មប្រហែលសង់ក្នុងឆ្នាំ ១៩៧៨"]។ ឯកសារ D119/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ភី ភួន ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឆ.6 KH 00969022-00969023 [សមាជិកនៅក្រសួងកិច្ចការបរទេស នាំគណៈប្រតិភូទៅត្រពាំងថ្ម ក្នុងឆ្នាំ ១៩៧៧៖ "ពេលខ្ញុំដឹកគណៈប្រតិភូទៅទស្សនកិច្ចនៅទីនោះក្នុងឆ្នាំ ១៩៧៨ គឺនៅពុំទាន់រួចរាល់ពេញលេញនៅឡើយទេ។ តាមពិតខ្ញុំកត់សម្គាល់ឃើញថា ទំនប់អាងត្រពាំងថ្មនេះ គឺមិនទាន់ធ្វើចប់សព្វគ្រប់នៅឡើយទេ ដោយសារតែមានទ្វារទឹកតែមួយប៉ុណ្ណោះនៅខាងត្បូង ហើយគ្មានទ្វារទឹកទេនៅប៉ែកខាងកើត"]។

1434 ឯកសារ D5/1250 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តាំង ហ៊ីវ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036240 [សាក្សីជាកម្មករនៅត្រពាំងថ្ម៖ "ឆ្នាំ ១៩៧៨ ឆ្នាំនោះជាឆ្នាំរោង ទឹកជំនន់ធំខ្លាំងណាស់ បណ្តាលឲ្យទឹកហូរដាច់ជាច្រើនកន្លែងលើខ្នងទំនប់អាងត្រពាំងថ្ម ធ្វើឲ្យកងចល័តភាគច្រើនបានស្លាប់ ដោយ សារដើរមិនរួច អស់កម្លាំង ហេវហត់ ហើមដៃជើង ហើមខ្លួន [...] ពេលនោះកងចល័តជាច្រើននាក់រត់កាប់ដើមឈើ ឬស្សីធំៗជញ្ជូនពីទីជិតឆ្ងាយ មកដល់ទប់ទល់ការពារផ្ទៃទឹកកុំឲ្យហូរបាក់ទៀត។ ឯកងចល័តខ្លះទៀត ត្រូវរែកសែង កាប់ដីវាល់ៗល្ងាច យ៉ាងសស្រាក់សស្រាំយកមកចាក់លើខ្នងទំនប់"]។ ឯកសារ D5/1463 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចុង ឈាត ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ KH 01043763 [សាក្សីជាកម្មករក្នុងកងចល័ត៖ "ក្នុងឆ្នាំ ១៩៧៧ មិត្តមួត ជាមេកងចល័តបានបង្ខំរូបខ្ញុំ ព្រមទាំងកងចល័តដទៃទៀត ឲ្យទៅជួយលើកទំនប់អាងទឹកត្រពាំងថ្ម [...] ឆ្នាំនោះទឹកជំនន់មួយយ៉ាងធំអស្ចារ្យ វាបានបោកបក់ រលកផ្ទៃទឹកធ្វើឲ្យទំនប់នានាមួយចំនួន ត្រូវទឹកហូរពីលើ ធ្វើឲ្យកងចល័ត ធ្វើការយ៉ាងពិបាក ធ្វើទាំងយប់ធ្វើទាំងថ្ងៃ បើទប់ទឹកនោះមិនជាប់ទេ អង្គការ ប៉ុល ពត ចោទជាខ្មាំង វាយកទៅសម្លាប់ចោលជាមិនខាន"]។

1435 ឯកសារ D5/1250 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តាំង ហ៊ីវ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036240 [សាក្សីធ្វើការនៅកងចល័តនៅត្រពាំងថ្ម៖ "ឆ្នាំ ១៩៧៨ ឆ្នាំនោះជាឆ្នាំរោង ទឹកជំនន់ធំខ្លាំងណាស់ បណ្តាលឲ្យទឹកហូរដាច់ជាច្រើនកន្លែងលើខ្នងទំនប់អាងត្រពាំងថ្ម ធ្វើឲ្យកងចល័តភាគច្រើនបានស្លាប់ [...] ពេលនោះកងចល័តជាច្រើននាក់រត់កាប់ដើមឈើ ឬស្សីធំៗជញ្ជូនពីទីជិតឆ្ងាយ មកដល់ទប់ទល់ការពារផ្ទៃទឹកកុំឲ្យហូរបាក់ទៀត។ ឯកងចល័តខ្លះទៀត ត្រូវរែកសែង កាប់

ដីវាល់ៗល្វាច យ៉ាងសស្រាក់សស្រាំយកមកចាក់លើខ្នងទំនប់"]។ ឯកសារ D5/1463 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផុង ឈាត ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ KH 01043763 [សាក្សីជាកម្មករក្នុងកងចល័ត៖ "ក្នុងឆ្នាំ ១៩៧៧ មិត្តម្ងួត ជាមេកងចល័តបានបង្គំរូបខ្ញុំ [...]ឱ្យទៅជួយលើកទំនប់អាងទឹកត្រពាំងថ្ម [...]ឆ្នាំនោះទឹកជំនន់មួយយ៉ាងធំអស្ចារ្យ វាបានបោកបក់ រលកផ្ទៃទឹកធ្វើឱ្យទំនប់នានាមួយចំនួន ត្រូវទឹកហូរពីលើ ធ្វើឱ្យកងចល័ត ធ្វើការយ៉ាងពិបាក ធ្វើទាំងយប់ធ្វើទាំងថ្ងៃ បើទប់ទឹកនោះមិនជាប់ទេអង្គការ ប៉ុល ពត ចោទជាខ្មាំង វាយកទៅសម្លាប់ចោលជាមិនខាន"]។ ឯកសារ D5/1029 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លឿង សាលឿម ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១៣ KH 00991182 [សាក្សីធ្វើជាកម្មករនៅកងចល័ត៖ "នៅឆ្នាំ ១៩៧៨ មិត្តឈន់ មេកងបានបញ្ជាឱ្យខ្ញុំព្រមទាំងកងចល័តផ្សេងទៀត ទៅសង់ទ្វារទឹកទី ១ នៃទំនប់អាងត្រពាំងថ្ម។ កាលណោះ ឆ្នាំនោះទឹកជំនន់ខ្លាំង ទឹកធំបានហូរដាច់ទំនប់ជាច្រើនកន្លែង ធ្វើឱ្យកងចល័តជាច្រើនពិបាកណាស់ រត់កាប់ដើមឈើ មែកឈើ ជញ្ជូនដីពីក្នុងទឹក"]។ ឯកសារ D5/1078 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ុក ណារី ចុះ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣ KH 01022787 [សាក្សីធ្វើជាកម្មករក្នុងកងចល័ត និង ត្រូវគេបញ្ជូនទៅត្រពាំងថ្ម៖ "ឆ្នាំនោះឆ្នាំរោង [១៩៧៨] ទឹកជំនន់ខ្លាំងណាស់ ហូរពេញប្រៀបលើទំនប់តែម្តង [...] គឺបង្ខំឱ្យរែករត់ បើមិនរត់"]។ ឯកសារ D219/130 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅ ចាត់ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ឆ.96 KH 01049236 [សាក្សីធ្វើការនៅកងចល័ត ហើយត្រូវគេបញ្ជូនទៅត្រពាំងថ្មក្នុងឆ្នាំ ១៩៧៦ និង ឆ្នាំ ១៩៧៨៖ "សៈ ហើយបន្ទាប់ពីនោះទៀត? ឆៈ បន្ទាប់ពីនោះមក ខ្ញុំដើរកាប់មែកឈើ ដើម្បីសង់ទប់រលកកុំឱ្យបាក់ទំនប់"] ឆ.97 ["សៈ តើនេះជាផ្នែកមួយនៃទំនប់ត្រពាំងថ្មឬយ៉ាងណា? ឆៈ បាទ"]។ ឯកសារ D5/1250 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ តាំង ហ៊ីវ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ KH 01036240 [សាក្សីធ្វើការនៅកងចល័តនៅត្រពាំងថ្ម៖ "ឆ្នាំ ១៩៧៨ ឆ្នាំនោះជាឆ្នាំរោង ទឹកជំនន់ធំខ្លាំងណាស់ បណ្តាលឱ្យទឹកហូរដាច់ជាច្រើនកន្លែងលើខ្នងទំនប់អាងត្រពាំងថ្ម ធ្វើឱ្យកងចល័តភាគច្រើនបានស្លាប់ ដោយ សារដើរមិនរួច អស់កម្លាំង ហេវហត់ ហើមដៃជើង ហើមខ្លួន [...] ពេលនោះកងចល័តជាច្រើននាក់រត់កាប់ដើមឈើ ឫស្សីធំៗជញ្ជូនពីទីជិតឆ្ងាយ មកដល់ទប់ទល់ការពារផ្ទៃទឹកកុំឱ្យហូរបាក់ទៀត។ ឯកងចល័តខ្លះទៀត ត្រូវរែកសែង កាប់ដីវាល់ៗល្វាច យ៉ាងសស្រាក់សស្រាំយកមកចាក់លើខ្នងទំនប់"]។ ឯកសារ D5/1463 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ផុង ឈាត ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ KH 01043763 [សាក្សីជាកម្មករក្នុងកងចល័ត៖ "ក្នុងឆ្នាំ ១៩៧៧ មិត្តម្ងួត ជាមេកងចល័តបានបង្គំរូបខ្ញុំ [...]ឱ្យទៅជួយលើកទំនប់អាងទឹកត្រពាំងថ្ម [...]នោះទឹកជំនន់មួយយ៉ាងធំអស្ចារ្យ វាបានបោកបក់ រលកផ្ទៃទឹកធ្វើឱ្យទំនប់នានាមួយចំនួន ត្រូវទឹកហូរពីលើ ធ្វើឱ្យកងចល័ត ធ្វើការយ៉ាងពិបាក ធ្វើទាំងយប់ធ្វើទាំងថ្ងៃ បើទប់ទឹកនោះមិនជាប់ទេ អង្គការ ប៉ុល ពត ចោទជាខ្មាំង វាយកទៅសម្លាប់ចោលជាមិនខាន"]។

1436 ឯកសារ **D219/35** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម សិលា ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤ ឆ.43 KH 01032084 [សាក្សីជាមេក្រុមដែលមានសមាជិក ៣០ នាក់ នៅត្រពាំងថ្ម៖ "ស្ថានភាពការងារ និងរស់នៅ នៅក្រោមពួកពាយ័ព្យមានលក្ខណៈធូរស្រាលជាងពួកនិរតី។ ក្រោយពីពួកនិរតីចូលមកគ្រប់គ្រង ស្ថានភាពការងារ និង រស់នៅមាការលំបាកខ្លាំង ហើយព្រមទាំងមានការកាប់សម្លាប់កាន់តែច្រើនទៀតផង"]។ ឯកសារ **D219/361** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើយ តើស ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៥ ឆ.90 KH 01105591 [សាក្សីធ្វើជា

